# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ១៦

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

# បបញ្ចសូទនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# មជ្ឈិមនិកាយ

# មជ្ឈិមបណ្ណាសក ចតុត្ថភាគ

# បញ្ចមភាគ ភិក្ខុវគ្គ

# ១៦

## បាលីប្រែ ២៣-២៤

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ១៦

## ភិក្ខុវគ្គ

## ចូឡរាហុលោវាទសូត្រទី ១

[ ១២៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័នជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ព្រះរាហុលមានអាយុ គង់នៅក្នុងអម្ពលដ្ឋិកាវ័ន ។ គ្រានោះឯង ព្រះ-មានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិ ក្នុងវេលាសាយណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅឯអម្ពលដ្ឋិកាវ័ន សំដៅទៅត្រង់កន្លែងដែលព្រះរាហុលមានអាយុនៅ ។ ព្រះរាហុលមានអាយុ ក៏បានឃើញព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបចំអាសនៈនិងទឹក សម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគទ្រង់គង់លើអាសនៈដែលព្រះរាហុល ក្រាលបម្រុងទុក លុះគង់ហើយ ទើបលាងព្រះបាទា ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយដាក់អង្គគង់ក្នុងទីសមគួរ ។

[ ១២៦ ] លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ទុកទឹកឲ្យនៅសល់បន្តិច ក្នុងផ្តិលទឹក ហើយទ្រង់ត្រាស់សួរព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិច ដែលតថាគតដាក់ក្នុងផ្តិលទឹកនេះឬទេ ។ ព្រះរាហុលក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ( ឃើញ ) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចជាទឹកដែលមានប្រមាណតិច យ៉ាង

នេះឯង ។ បន្ទាប់អំពីនោះ ព្រះមានព្រះភាគទ្រង់ចាក់ទឹកដែលសល់បន្តិចនោះ ចោល ហើយសួរបញ្ហាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញទឹកសល់បន្តិចដែលតថាគតចាក់ចោលហើយនេះឬទេ ។ ព្រះករុណាព្រះអង្គ ( ឃើញ ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចទឹកដែលតថាគតចាក់ចោលហើយ យ៉ាងនេះឯង ។ ទើបព្រះមានព្រះភាគទ្រង់ផ្កាប់ផ្តិលទឹកនោះ ហើយត្រាស់សួរបញ្ហាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹក ដែលតថាគតផ្កាប់ហើយនេះឬទេ ។ ព្រះករុណាព្រះអង្គ ( ឃើញ ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចផ្តិលទឹកដែលតថាគតផ្កាប់ យ៉ាងនេះឯង ។ តអំពីនោះមកទៀត ព្រះមានព្រះភាគទ្រង់ផ្ងារផ្តិលទឹកនោះ ត្រាស់សួរបញ្ហាក់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកបានឃើញផ្តិលទឹក ដែលទទេរលីងធេងនេះឬទេ ។ ព្រះករុណាព្រះអង្គ ( ឃើញ ) ។ ម្នាលរាហុល សមណធម៌របស់ពួកភិក្ខុដែលមិនមានសេចក្តីអៀនខ្មាស ក្នុងសម្បជានមុសាវាទ ដូចជាផ្តិលទឹកដែលទទេរលីងធេង យ៉ាងនេះឯង ។

[ ១២៧ ] ម្នាលរាហុល ដូចជាដំរីរបស់ស្តេច ដែលមានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ដំរីនោះកាលបើចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយ

ក្បាលខ្លះ ធ្វើការដោយត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ។ ឯហ្មដំរីមានសេចក្តីត្រិះរិះ ក្នុងដំណើរដែលដំរីរក្សាប្រមោយទុកនោះ យ៉ាងនេះថា ដំរីរបស់ស្តេចនេះឯង មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ( ទោះបី ) ចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយស្លឹកត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ រក្សាទុកតែប្រមោយប៉ុណ្ណោះ ដំរីរបស់ស្តេច ( នេះ ) ឈ្មោះថា មិនទាន់ប្រថុយជីវិតឡើយ ។ ម្នាលរាហុល កាលដែលដំរីរបស់ស្តេច មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ( ទោះបី ) ចូលទៅកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ។បេ។ ធ្វើការដោយកន្ទុយខ្លះ ធ្វើការដោយប្រមោយខ្លះ ។ ហ្មដំរីមានសេចក្តីត្រិះរិះក្នុងដំណើរនោះយ៉ាងនេះថា ដំរីរបស់ស្តេចនេះឯង មានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម ( ទោះបី ) ចូលកាន់សង្គ្រាម តែងធ្វើការដោយជើងមុខខ្លះ ធ្វើការដោយជើងក្រោយខ្លះ ធ្វើការដោយកាយខាងមុខខ្លះ ធ្វើការដោយកាយខាងក្រោយខ្លះ ធ្វើការដោយក្បាលខ្លះ ធ្វើការដោយស្លឹកត្រចៀកខ្លះ ធ្វើការដោយភ្លុកខ្លះ ធ្វើការដោយកន្ទុយខ្លះ ធ្វើការដោយប្រមោយខ្លះ ដំរីរបស់ស្តេចនេះ ទើបឈ្មោះថា ប្រថុយលះបង់ជីវិតហើយ ឥឡូវនេះ អំពើណាមួយ ដែលដំរីរបស់ស្តេចឈ្មោះថា មិន

ទាន់ធ្វើមិនមានឡើយ សេចក្ដីនេះ មានឧបមាយ៉ាងណា ។ ម្នាលរាហុល មានឧបមេយ្យដូចភិក្ខុណាមួយ ដែលមិនមានសេចក្ដីអៀនខ្មាស ក្នុងសម្បជានមុសាវាទ តថាគតមិនពោលថា ភិក្ខុនោះមិនធ្វើបាបកម្មតិចតួច ដូច្នេះទេ ។ ម្នាលរាហុល ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកគួរសិក្សាថា អាត្មាអញនឹងមិនពោលពាក្យកុហក សូម្បីដើម្បីសើចលេង ម្នាលរាហុល អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ១២៨ ] ម្នាលរាហុល អ្នកសម្គាល់សេចក្ដីនោះថាដូចម្ដេច កញ្ចក់មានប្រយោជន៍ដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន កញ្ចក់មានប្រយោជន៍ខាងការឆ្លុះមើលមុខ ។ ម្នាលរាហុល យ៉ាងនោះមែនហើយ អ្នកគប្បីពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយកាយ ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយវាចា ពិចារណាត្រិះរិះមើលរួចហើយ សឹមធ្វើកម្មដោយចិត្ត ។

[ ១២៩ ] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយកាយ អ្នកត្រូវពិចារណាមើលនូវកាយកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះឯង ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួនឯងនិងអ្នកដទៃផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញចង់ធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្ត

ទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀន បុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយកាយដែលមានទំនងយ៉ាងនេះដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញចង់ធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀន បុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាកុសល ចម្រើនតែខាងសេចក្ដីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដោយកាយយ៉ាងនេះចុះ ។ ម្នាលរាហុល បើទុកជាអ្នកកំពុងធ្វើអំពើដោយកាយ អ្នកត្រូវតែពិចារណាមើល នូវកាយកម្មនោះឯងថា អាត្មាអញកំពុងធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅដឹងយ៉ាងនេះថា អាត្មាអញកំពុងធ្វើអំពើណា ដោយកាយ កាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្ដីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់កាយកម្ម ដែលមាន

ទំនងយ៉ាងនេះចេញ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញកំពុងធ្វើអំពើណាដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើឲ្យរឿយៗ នូវកាយកម្មដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើដោយកាយរួចហើយ អ្នកត្រូវពិចារណាមើលកាយកម្មនោះថា អាត្មាអញបានធ្វើអំពើណាដោយកាយ តើកាយកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯងផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញបានធ្វើកាយកម្មណា កាយកម្មរបស់អាត្មាអញនេះប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវសម្តែង បើក បង្ហើប ប្រាប់នូវកាយកម្ម ដែលមានទំនងយ៉ាងនេះចំពោះគ្រូ ឬចំពោះសព្រហ្មចារីបុគ្គលទាំងឡាយជាអ្នកប្រាជ្ញ លុះអ្នកសម្តែង បើក បង្ហើប ប្រាប់រួចហើយ អ្នកគប្បីដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកបានពិចារណា

មើលទៅដឹងយ៉ាងនេះវិញថា អាត្មាអញបានធ្វើអំពើណា ដោយកាយ កាយកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង កាយកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវខំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ទាំងឡាយជាកុសលហើយនៅដោយបីតិ និងបាមុជ្ជៈនោះឯង ។

[ ១៣០ ] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាមួយ ដោយវាចាអ្នកត្រូវពិចារណានូវវចីកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណាដោយវាចា តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែក គឺខ្លួននិងបុគ្គលដទៃផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ ចង់ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយវាចា ដែលមានទំនងយ៉ាងនេះ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើជាអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញចង់ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បី

បៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដោយវាចាដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកកំពុងធ្វើអំពើដោយវាចា អ្នកត្រូវពិចារណាមើលវចីកម្មនោះថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់នូវវចីកម្ម មានទំនងយ៉ាងនេះចេញ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ កំពុងធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើវចីកម្មដែលមានទំនងយ៉ាងនេះឲ្យរឿយៗ ទៅចុះ ។

ម្នាលរាហុល បើអ្នកបានធ្វើអំពើដោយវាចារួចហើយ អ្នកត្រូវពិចារណាមើលវចីកម្មនោះថា អាត្មាអញ បានធ្វើអំពើណាដោយវាចាហើយ តើវចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកគប្បីសម្តែង បើក បង្ហើប ប្រាប់នូវវចីកម្មដែលមានទំនងយ៉ាងនេះចំពោះគ្រូ ឬចំពោះសព្រហ្មចារីបុគ្គលទាំងឡាយដែលមានប្រាជ្ញា លុះអ្នកសម្តែង បើក បង្ហើប ប្រាប់ហើយ គប្បីដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ ធ្វើអំពើណាដោយវាចា វចីកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង វចីកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវខំសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ជាកុសលទាំងឡាយ ហើយនៅដោយបីតិនិងបាមោជ្ជៈ នោះចុះ ។

[ ១៣១ ] ម្នាលរាហុល បើអ្នកចង់ធ្វើអំពើណាដោយចិត្ត អ្នកត្រូវពិចារណាមើលនូវមនោកម្មនោះសិនថា អាត្មាអញ ចង់ធ្វើអំពើណាដោយចិត្ត តើមនោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកគឺខ្លួននិងអ្នកដទៃផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញចង់ធ្វើអំពើណាដោយចិត្ត មនោកម្មរបស់អាត្មាអញនេះប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកមិនត្រូវធ្វើអំពើដោយចិត្ត ដែលមានទំនងយ៉ាងនេះ ដោយដាច់ខាត ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញចង់ ធ្វើអំពើណាដោយចិត្ត មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផងមិន ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើអំពើដែលមានទំនងយ៉ាងនេះចុះ ។ ម្នាលរាហុល បើអ្នកកំពុងធ្វើអំពើណាដោយចិត្ត អ្នកត្រូវពិចារណាមើល នូវមនោកម្មនោះថា អាត្មាអញកំពុងធ្វើអំពើណាដោយចិត្ត តើមនោកម្មរបស់អាត្មាអញនេះប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃ

ផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មានោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញកំពុងធ្វើអំពើណាដោយចិត្ត មានោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មានោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវលះបង់មានោកម្ម ដែលមានទំនងយ៉ាងនេះចេញ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ កំពុងធ្វើអំពើណាដោយចិត្ត មានោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនអ្នកដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មានោកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវធ្វើនូវមានោកម្ម ដែលមានទំនងយ៉ាងនេះឲ្យរឿយ ៗ ទៅចុះ ។ ម្នាលរាហុល បើអ្នកបានធ្វើអំពើដោយចិត្តរួចហើយ អ្នកត្រូវពិចារណានូវមានោកម្មនោះឯងថា អាត្មាអញបានធ្វើនូវអំពើណាដោយចិត្តហើយ តើមានោកម្មរបស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មានោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខឬហ្ន៎ ។ ម្នាលរាហុល បើអ្នកបានពិចារណាមើលទៅ ដឹងយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើណាដោយចិត្តហើយ មានោកម្ម

របស់អាត្មាអញនេះ ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាអកុសល ចម្រើនតែខាងសេចក្តីទុក្ខ មានផលជាទុក្ខ ម្នាលរាហុល អ្នកត្រូវធុញទ្រាន់ នឿយណាយ ខ្ពើមរអើម ចំពោះមនោកម្ម ដែលមានទំនងយ៉ាងនេះ លុះអ្នកធុញទ្រាន់ នឿយណាយ ខ្ពើមរអើមហើយ ត្រូវដល់នូវការសង្រួមតទៅ ។ ម្នាលរាហុល ប្រសិនបើអ្នកពិចារណាមើលទៅ ដឹងយ៉ាងនេះវិញថា អាត្មាអញ បានធ្វើនូវអំពើណាដោយចិត្តហើយ មនោកម្មរបស់អាត្មាអញនេះ មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំងពីរចំណែកផង មនោកម្មនេះជាកុសល ចម្រើនតែខាងសេចក្តីសុខ មានផលជាសុខ ម្នាលរាហុល អ្នកត្រូវសិក្សាទាំងយប់ទាំងថ្ងៃ ក្នុងធម៌ជាកុសលទាំងឡាយ ហើយនៅដោយ បីតិ និងបាមោជ្ជនោះចុះ ។

[ ១៣២ ] ម្នាលរាហុល ព្រោះថាសមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលកន្លងទៅហើយ បានជម្រះកាយកម្ម ជម្រះវចីកម្ម ជម្រះមនោកម្ម ពួកសមណព្រាហ្មណ៍ទាំងអស់នោះ សុទ្ធតែបានពិចារណា ត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះកាយកម្ម ពិចារណាត្រិះរិះមើលសព្វ យ៉ាងនេះហើយ ទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វយ៉ាងនេះហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលដែលមិនទាន់មានមក នឹងជម្រះកាយកម្ម នឹងជម្រះវចីកម្ម នឹងជម្រះមនោកម្ម ក៏ពួក

សមណៈឬព្រាហ្មណ៍ទាំងអស់នោះ នឹងពិចារណាត្រិះរិះមើលសព្វ យ៉ាងនេះហើយ ទើបជម្រះកាយកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល សមណៈឬព្រាហ្មណ៍ណាមួយ ក្នុងកាលឥឡូវនេះ ជម្រះកាយកម្ម ជម្រះវចីកម្ម ជម្រះមនោកម្ម ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តែងពិចារណាត្រិះរិះមើលសព្វ យ៉ាងនេះហើយ ទើបជម្រះកាយកម្ម ពិចារណាត្រិះរិះមើលសព្វ ហើយទើបជម្រះវចីកម្ម ពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្មដែរ ។ ម្នាលរាហុល ព្រោះហេតុដូច្នោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាថា អាត្មាអញនឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះកាយកម្ម អាត្មាអញនឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះវចីកម្ម អាត្មាអញនឹងពិចារណាត្រិះរិះមើលសព្វហើយ ទើបជម្រះមនោកម្ម ដូច្នេះ ម្នាលរាហុល អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ចូឡរាហុលោវាទសូត្រ ទី ១

# អដ្ឋកថា
# ចូឡរាហុលោវាទសូត្រ

[ ១២៥ ] ចូឡរាហុលោវាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **អម្ពលដ្ឋិកាយំ វិហរតិ** គឺព្រះរាហុលនៅក្នុងប្រាសាទឈ្មោះអម្ពលដ្ឋិកា គឺកាលគេសាងចំណែកសង្ខេបរបស់ផ្ទះនេះ តាំងនៅខាងចុងវេឡុវនវិហារ ដើម្បីជាទីនៅនៃបុគ្គលត្រូវការវិវេក ព្រះរាហុលចម្រើនវិវេកក្នុងប្រាសាទដែលមានឈ្មោះយ៉ាងនេះថា អម្ពលដ្ឋិកា ។ ឈ្មោះថា បទ្ធា រមែងស្រួចតាំងអំពីកំណើត ។ សូម្បីព្រះរាហុលនេះក៏យ៉ាងនោះ ចម្រើនវិវេកក្នុងទីនោះ កាលនៅជាសាមណេរ មានអាយុ ៧ ឆ្នាំ ។ បទថា **បដិសល្លានា វុដ្ឋិតោ** ព្រះមានព្រះភាគ យាងចេញអំពីទីពួនសម្ងំ គឺទ្រង់ចេញអំពីផលសមាបត្តិ ។ បទថា **អាសនំ** គឺក្នុងទីនេះ ក៏មានអាសនៈដែលក្រាលទុកជាប្រក្រតី ហើយព្រះរាហុល ក៏គង់បោសអាសនៈនោះតាំងទុក ។

[ ១២៦ ] បទថា **ឧទកាធានេ** គឺភាជនៈដាក់ទឹក ។ បាឋៈថា **ឧទកាធានេ** ក៏មាន ។ បទថា **អាយស្មន្តំ រាហុលំ អាមន្តេសិ** ព្រះមានព្រះភាគត្រាស់ហៅព្រះរាហុល គឺត្រាស់ដើម្បីប្រទានឱវាទ ។ ពិតហើយព្រះមានព្រះភាគទ្រង់សម្ដែងធម្មទេសនាទុកច្រើន ដល់ព្រះរាហុល ។ ព្រះអង្គត្រាស់សាមណេរបញ្ហាដល់ ព្រះថេរៈទុកដូចគ្នា ។ម្យ៉ាងទៀត ព្រះអង្គត្រាស់រាហុលសំយុត្ត មហារាហុលោវាទសូត្រ ចូឡរាហុលោវាទសូត្រ រួម

ទាំងអម្ពលដ្ឋិកាភាហុលោវាទសូត្រនេះចូលផងដែរ ។

ពិតហើយ ព្រះរាហុលនេះ កាលព្រះជន្ម ៧ ឆ្នាំ ទ្រង់ចាប់ជាយចីវរ ទូលសូមមត៌កនឹងព្រះមានព្រះភាគថា បពិត្រសមណៈ សូមទ្រង់ប្រទានមត៌កដល់ខ្ញុំចុះ ។ ព្រះមានព្រះភាគ ទ្រង់ប្រគល់ឲ្យដល់ព្រះធម្មសេនាបតីសារីបុត្របំបួស ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ឈ្មោះថាក្មេងតែងពោលពាក្យដែលគួរនិងមិនគួរ តថាគតនឹងឲ្យឱវាទដល់រាហុល ដូច្នេះហើយ ត្រាស់ហៅព្រះរាហុលដោយព្រះតម្រាស់ថា ម្នាលរាហុល ឈ្មោះថាសាមណេរ មិនគួរពោលតិរច្ឆានកថា ។ អ្នកកាលនឹងពោល គួរពោលកថាបែបនេះ គឺពាក្យសួរ ១០ ប្រការ ការឆ្លើយ ៥៥ ប្រការ បញ្ហា ១ ឧទ្ទេស ១ វេយ្យាករណ៍ ១ បញ្ហា ២ ។បេ។ បញ្ហា ១០ ឧទ្ទេស ១០ វេយ្យាករណ៍ ១០ ដែលព្រះពុទ្ធទាំងពួងទ្រង់មិនលះ ហើយព្រះមានព្រះភាគត្រាស់សាមណេរបញ្ហានេះថា **ឯកន្នាម កឹ** អ្វីឈ្មោះថា ១ **សព្វេ សត្តា អាហារដ្ឋិតិកា** សត្វទាំងឡាយទាំងពួង តាំងនៅបានដោយអាហារ ។បេ។ **ទស នាម កឹ** អ្វីឈ្មោះថា ១០ **ទសហង្គេហិ សមន្នាគតោ អរហាតិ វុច្ចតិ** បុគ្គលប្រកបដោយអង្គ ១០ តថាគតពោលថា ជាអរហន្ត ។ ព្រះពុទ្ធអង្គទ្រង់ត្រិះរិះតទៅថា ឈ្មោះថា ក្មេង រមែងពោលកុហក ដោយពាក្យគួរជាទីស្រឡាញ់ រមែងពោលវត្ថុដែលមិនឃើញថា ខ្ញុំបានឃើញ ពោលវត្ថុដែលឃើញថា ខ្ញុំមិនឃើញ តថាគតនឹងឲ្យឱវាទដល់រាហុលនោះ សម្លឹងមើលដោយភ្នែក ក៏ដើម្បីឲ្យយល់បានងាយ ទើបទ្រង់សម្តែងឧបមា ដោយភាជនៈដាក់ទឹក ៤ ជាដំបូង

បន្ទាប់អំពីនោះ ទ្រង់សម្តែងឧបមាដោយដំរី ២ បន្ទាប់អំពីនោះ ទ្រង់សម្តែងឧបមាដោយកញ្ចក់ ១ ហើយទើបត្រាស់ ព្រះសូត្រនេះ ។ ទ្រង់សម្តែងការវៀរតណ្ហាក្នុងបច្ច័យ ៤ ការលះឆន្ទរាគៈ ក្នុងកាមគុណ ៥ និងភាពដែលឧបនិស្ស័យនៃកល្យាណមិត្រ ជាគុណជំក្រៃលែង ទើបត្រាស់រាហុលសូត្រ ។ ដើម្បីទ្រង់សម្តែងថា មិនគួរធ្វើឆន្ទរាគៈក្នុងភពទាំងឡាយក្នុងទីដែលមកហើយ ទើបត្រាស់រាហុលសំយុត្ត ។ ដើម្បីទ្រង់សម្តែងថា មិនគួរធ្វើឆន្ទរាគៈដែលអាស្រ័យផ្ទះ អាស្រ័យអត្តភាពថា អញស្អាត ពណ៌សម្បុររបស់អញផូរផង់ ទើបត្រាស់មហារាហុលោវាទសូត្រ ។ ក្នុងមហារាហុលោវាទសូត្រនោះ មិនគួរពោលថារាហុលសូត្រ លោកពោលទុកហើយក្នុងកាលនេះ ។ ព្រោះរាហុលសូត្រនោះលោកពោលដោយឱវាទរឿយៗ ។ ទ្រង់ត្រាស់រាហុលសំយុត្ត តាំងអំពីរាហុលមានព្រះជន្មបាន ៧ ឆ្នាំ រហូតដល់ជាភិក្ខុដែលមិនទាន់មានវស្សា ។ ទ្រង់ត្រាស់មហារាហុលោវាទសូត្រ ក្នុងកាលព្រះរាហុលជាសាមណេរ មានព្រះជន្ម ១៨ វស្សា ទ្រង់ត្រាស់ចូឡរាហុលោវាទសូត្រក្នុងកាល ព្រះរាហុលជាភិក្ខុបានកន្លះវស្សា ។ ទ្រង់ត្រាស់កុមារកបញ្ហា និងអម្ពលដ្ឋិករាហុលោវាទសូត្រ[១] ក្នុងកាលព្រះរាហុល ជាសាមណេរមានអាយុ ៧ ឆ្នាំ ។

ក្នុងព្រះសូត្រទាំងនោះ ទ្រង់ត្រាស់រាហុលោវាទសូត្រ ដើម្បីទូន្មានរឿយៗត្រាស់រាហុលសំយុត្ត ដើម្បីកាន់យកបន្ទប់វិបស្សនារបស់ព្រះថេរៈ ត្រាស់

---

១- អម្ពលដ្ឋិករាហុលោវាទសូត្រ និងចូឡរាហុលោវាទសូត្រ ជាសូត្រតែមួយនោះឯង តែក្នុងទីនេះ ស្តាប់ទៅហាក់បីដូចជាសូត្រទីទៃពីគ្នា ។ សេចក្តីនេះ បណ្ឌិតគប្បីពិចារណា ។

មហារាហុលោវាទសូត្រ ដើម្បីកម្ចាត់ឆន្ទរាគៈដែលអាស្រ័យផ្ទះ ត្រាស់ចូឡរាហុលោវាទសូត្រ ដើម្បីទាញយកព្រះអរហត្ត ក្នុងវេលាដែលធម៌ចម្រើនដោយវិមុត្តិ ១៥ របស់ព្រះថេរៈចាស់ក្លាហើយ ។ ព្រះរាហុលត្ថេរ សំដៅព្រះសូត្រនេះ កាលនឹងសរសើរព្រះគុណរបស់ព្រះតថាគត ក្នុងកណ្ដាលភិក្ខុសង្ឃ ទើបពោលគាថានេះថា

**កិកីវ ពីជំ រក្ខេយ្យ ចាមរី វាលមុត្តមំ**
**និបកោ សីលសម្បន្នោ មមំ រក្ខិ តថាគតោ ។**

ព្រះតថាគត មានព្រះបញ្ញាដ៏ឈ្លាស ទ្រង់បរិបូណ៌ដោយសីល ទ្រង់រក្សាខ្ញុំ ដូចត្រដេវរិចរក្សាពូជ គឺ ស៊ុត ដូចចាមរីរក្សាកន្ទុយដ៏ឧត្តមដូច្នោះ ។

ទ្រង់ត្រាស់សាមណេរបញ្ហា ដើម្បីលះវាទៈដែលមិនគួរត្រាស់ ក្នុងអម្ពលដ្ឋិករាហុលោវាទសូត្រនេះ ដើម្បីកុំឲ្យធ្វើសម្បជានមុសាវាទ គឺកុហក ទាំងដឹងខ្លួន ។

ក្នុងបទទាំងនោះ បទថា **បស្សសិ នោ** កែជា **បស្សសិ នុ** គឺអ្នកឃើញឬហ្ន៎ ។ បទថា **បរិត្តំ** គឺតិចតួច ។ បទថា **សាមញ្ញំ** គឺសមណធម៌ ។ បទថា **និក្កុជ្ជិត្វា** គឺផ្កាប់ ។ បទថា **ឧក្កុជ្ជិត្វា** គឺផ្ងារ ។

[ ១២៧ ] បទថា **សេយ្យថាបិ រាហុល រញ្ញោ នាគោ** សេចក្ដីថា ម្នាលរាហុល ដូចដំរីរបស់ព្រះរាជា ទ្រង់ពោលឧបមានេះ ដើម្បីសម្ដែងការប្រៀបប្រៀបនៃបុគ្គលមិនមានសំវរៈក្នុងការពោល កុហកទាំងដឹងខ្លួន ។ ក្នុងបទទាំងនោះ បទថា **ឦសាទន្តោ** មានភ្លុកដ៏ងស្អាត គឺមានភ្លុកដូចគ្នានឹង

យាមនង្គ័ល ។ បទថា **ឧរុឡ្ហវា** ជាពាហនៈដែលចម្រើនក្រៃលែង គឺគួរជិះ ។ បទថា **អភិជាតោ** គឺមានកំណើតល្អ បរិបូណ៌ដោយជាតិ ។ បទថា **សង្គាមាវចរោ** គឺធ្លាប់ចូលសង្គ្រាម ។ បទថា **កម្មំ ករោតិ** សេចក្តីថា រមែងធ្វើកម្ម គឺប្រហារសត្រូវ ដែលចូលមកហើយឲ្យដួលចុះ ។ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទជាដើមថា ដោយកាយខាងមុខ ដូច្នេះ គឺញុំាងខ្លោងទ្វារ និងកំពែងត្រងោលឲ្យដួលចុះ ដោយកាយខាងមុខមុន ។ ដោយកាយខាងក្រោយក៏ដូចគ្នា កំណាត់កម្មដោយក្បាល ហើយត្រឡប់ ក្រឡេកមើលដោយគិតថា អញនឹងញុំាញីប្រទេសនេះ ។ ដោយហេតុមានប្រមាណប៉ុណ្ណោះ ក៏ទម្លាយវត្ថុរាប់រយរាប់ពាន់ឲ្យបែកជាពីរចំណែក ឈ្មោះថា ធ្វើកម្មដោយក្បាល ការប្រហារកូនសរដែលមកហើយ ឲ្យធ្លាក់ទៅដោយត្រចៀក ឈ្មោះថា ធ្វើកម្មដោយត្រចៀក ។ ការចាក់ទម្លុះជើងដំរីសត្រូវ សេះសត្រូវ កងដំរី កងសេះ និងពលថ្មើរជើងជាដើម ឈ្មោះថា ធ្វើកម្មដោយភ្លុក ការកាត់ទម្លាយដោយឈើវែង ឬដោយអង្រែដែកដែលចងទុកត្រង់កន្ទុយ ឈ្មោះថា ធ្វើកម្មដោយ កន្ទុយ ។ បទថា **រក្ខតេវ សោណ្ឌំ** រមែងរក្សាទុកតែប្រមោយប៉ុណ្ណោះ គឺដាក់ប្រមោយទុកក្នុងមាត់រក្សាទុក ។ បទថា **តត្ថ** ក្នុងការដែលដំរីរក្សាប្រមោយនោះ ។ បទថា **អបរិច្ចត្តំ** គឺមិនព្រមលះបង់ សូម្បីឃើញអ្នកជទៃឈ្នះ និងខ្លួនចាញ់ ។

បទថា **សោណ្ឌាយតិ កម្មំ ករោតិ** រមែងធ្វើកម្មដោយប្រមោយ គឺចាប់ដំបងដែក ឬអង្រែគគីរ ញុំាញីទីប្រមាណ ១៨ ហត្ថ ដោយជុំវិញ ។

បទថា **បរិច្ចត្តំ** សេចក្តីថា រមែងលះបង់ គឺឥឡូវនេះមិនខ្លាចអ្វីមួយឡើយ សូម្បីក្នុងទ័ពដ៏វីជាដើម រមែងឃើញជ័យជម្នះរបស់ខ្លួន ។

បទថា **នាហន្តស្ស កិញ្ចិ ចាបំ** បុគ្គលមិនមានការខ្មាសក្នុងការពោលកុហកទាំងដឹងខ្លួន ដែលមិនធ្វើបាបកម្ម សូម្បីតិចតួចមិនមាន សេចក្តីថា បុគ្គលនោះ នឹងមិនគប្បីធ្វើកម្មតិចតួច ក្នុងការកន្លងអាបត្តិទុក្កដជាដើម ឬក្នុងកម្ម មានមាតុឃាតជាដើមមិនមាន ។ បទថា **តស្មា តិហ តេ** សេចក្តីថា ព្រោះបុគ្គលពោលកុហកទាំងដឹងខ្លួន នឹងមិនធ្វើបាបមិនមាន ដូច្នោះ អ្នកគប្បីសិក្សាថា អញនឹងមិនពោលកុហក សូម្បីដើម្បីសើច និងព្រោះប្រាថ្នានឹងលេង ។

[ ១២៨ ] បទថា **បច្ចវេក្ខណត្ថោ** គឺមានប្រយោជន៍សម្រាប់ ពិចារណាមើល អធិប្បាយថា មានប្រយោជន៍ឆ្លុះមើលទោសត្រង់មុខ ។ បទថា **បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា** គឺពិចារណាមើលហើយមើលទៀត ។

[ ១៣០ ] បទថា **សសក្កំ ន ករណីយំ** គឺមិនគប្បីធ្វើដោយចំណែកមួយប៉ុណ្ណោះ ។ បទថា **បដិសំហរេយ្យាសិ** សេចក្តីថា គប្បីលើក គឺគប្បីត្រឡប់ កុំគប្បីធ្វើ ។ បទថា **អនុបទជ្ជេយ្យាសិ** សេចក្តីថា គប្បីបន្ថែម គឺគប្បីឲ្យកើតឡើង គប្បីឧបការៈទុក គប្បីធ្វើរឿយៗ ។ បទថា **អហោរត្តានុសិក្ខិតា** គឺសិក្សាទាំងយប់ទាំងថ្ងៃ ។

[ ១៣១ ] បទថា **អដ្ដិយិតព្វំ** សេចក្តីថា គប្បីធុញទ្រាន់ គឺគប្បីខ្លាចគប្បីគ្រប់សង្កត់ ។ បទថា **ហរាយិតព្វំ** សេចក្តីថា គប្បីនឿយណាយ គឺ

គប្បីខ្ពាស ។ បទថា **ជិគុច្ឆិតព្វំ** សេចក្តីថា គប្បីខ្ពើម គឺគប្បីឲ្យកើតការខ្ពើម ដូចឃើញលាមក ។ ម្យ៉ាងទៀត ព្រោះមនោកម្មមិនមែនវត្ថុនៃទេសនា ដែលគួរសម្តែងទុកក្នុងទីនេះ ព្រោះហេតុនោះ ទើបលោកមិនពោលទុក ។ ក្នុងឋានៈដូចម្តេច ទើបគួរជម្រះកាយកម្ម និងវចីកម្ម ។ ក្នុងឋានៈដូចម្តេច ទើបគួរជម្រះមនោកម្ម ។ គួរជម្រះកាយកម្ម និងវចីកម្ម ក្នុងវេលាមុនអាហារម្តងមុន កាលឆាន់អាហារហើយ គួរអង្គុយក្នុងទីសម្រាកពេលថ្ងៃ ពិចារណាថា តាំងអំពីអរុណរះមកទល់គ្នានឹងអង្គុយក្នុងទីនេះ កាយកម្ម ឬវចីកម្មដែលមិនសមគួរដល់អ្នកដទៃ ក្នុងចន្លោះនេះ មានដល់អាត្មាអញឬទេហ្ន៎ ។ បើដឹងថាមាន គួរសម្តែងប្រការដែលគួរសម្តែង គួរធ្វើឲ្យជាក់ច្បាស់ក្នុងប្រការដែលគួរធ្វើឲ្យជាក់ច្បាស់ ។ បើមិនមាន គួរមានបីតិ បាមោជ្ជៈ ។ ម្យ៉ាងទៀត គួរជម្រះមនោកម្មក្នុងទីស្វែងរកបិណ្ឌបាតម្តង ជម្រះដូចម្តេច គួរជម្រះថា ថ្ងៃនេះ ការពេញចិត្តក្តី តម្រេកក្តី ទោមនស្សក្តី ក្នុងរូបជាដើម ក្នុងទីស្វែងរកបិណ្ឌបាតមានឬហ្ន៎ ។ បើមានគួរតាំងចិត្តថា អញនឹងមិនធ្វើយ៉ាងនេះទៀតឡើយ ។ បើមិនមាន គួរមានបីតី បាមោជ្ជៈ ។

[ ១៣២ ] បទថា **សមណា វា ព្រាហ្មណា វា** បានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬសាវករបស់ព្រះតថាគត ។ បទថា **តស្មា តិហ** សេចក្តីថា ព្រោះសមណព្រាហ្មណ៍ទាំងឡាយ ក្នុងអតីតក៏ជម្រះហើយយ៉ាងនេះ ក្នុងអនាគត ក៏នឹងជម្រះយ៉ាងនេះ ក្នុងបច្ចុប្បន្ន ក៏រមែងជម្រះយ៉ាងនេះ ដូច្នោះ សូម្បីពួកអ្នក កាលសិក្សាតាមសមណព្រាហ្មណ៍ទាំងនោះ ក៏គប្បីសិក្សាយ៉ាង

នេះ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់អស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះធម្មទេសនានេះ ឲ្យចប់ដោយអំណាចនៃបុគ្គលដែលគួរទូន្មាន ដូចទេវតាដ៏វិសេសកាន់យកកំពូលនៃគំនររតនៈ ដែលតាំងឡើងរហូតកវគ្គព្រហ្ម ដោយគំនរនៃកែវមណីដែលប្រកបគ្នា ។

## អដ្ឋកថាចូឡរាហុលោវាទសូត្រ ចប់

## សូត្រទី ១ ចប់

# សុត្តន្តបិដក

## មហារាហុលោវាទសូត្រទី ២

[ ១៣៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយទ្រង់ពុទ្ធដំណើរចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ ចំណែកខាងព្រះរាហុលមានអាយុ ក៏ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយដើរតាមក្រោយៗ ព្រះមានព្រះភាគ ។ ក្នុងសម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ផ្ទៀងព្រះកក្រ្តត្រាស់ទៅនឹងព្រះរាហុលមានអាយុថា ម្នាលរាហុល រូបណាមួយ ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ឬរូបណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដែលជាអតីត អនាគត បច្ចុប្បន្ន រូបទាំងអស់នោះ ក៏គ្រាន់តែជារូប ( ប៉ុណ្ណោះឯង ) អ្នកគួរយល់ឃើញនូវរូបនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ ព្រះរាហុលក្រាបបង្គំសួរថា បពិត្រព្រះមានព្រះភាគ ( សេចក្តីនេះ ) មានតែរូបម្យ៉ាងទេឬ បពិត្រព្រះសុគត ( សេចក្តីនេះ ) មានតែរូបម្យ៉ាងទេឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលរាហុល រូបក៏មាន ម្នាលរាហុល វេទនាក៏មាន ម្នាលរាហុល សញ្ញាក៏មាន ម្នាលរាហុល សង្ខារទាំងឡាយក៏មាន ម្នាលរាហុល វិញ្ញាណក៏មាន ។

[ ១៣៤ ] គ្រានោះឯង ព្រះរាហុលមានអាយុគិតថា បាននរណាហ្ន៎ ( ជាវិញ្ញូបណ្ឌិត ) ដែលព្រះមានព្រះភាគទូន្មានហើយ ដោយដំបូន្មានផ្ទាល់ព្រះឱស្ឋ នឹងចូលមកកាន់ស្រុក ដើម្បីបិណ្ឌបាតក្នុងថ្ងៃនេះទៅអេះ ដូច្នេះហើយ លោកក៏ត្រឡប់ថយចេញ អំពីសម្នាក់ព្រះមានព្រះភាគនោះ ហើយទៅអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន ទៀបគល់ឈើ ១ ដើម ។ គាប់ចួនជាព្រះសារីបុត្តមានអាយុបានឃើញព្រះរាហុលមានអាយុ ដែលកំពុងអង្គុយផ្គត់ភ្នែន តម្រង់កាយឲ្យត្រង់ តាំងស្មារតីឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន ទៀបគល់ឈើ ១ ដើម លុះឃើញហើយ ក៏ប្រាប់ព្រះរាហុលមានអាយុថា ម្នាលរាហុល អ្នកចូរចម្រើនអានាបានស្សតិភាវនាចុះ ម្នាលរាហុល ( ដ្បិត ) អានាបានស្សតិភាវនាដែលគេបានអប់រំ បន្ទុំ ធ្វើឲ្យរឿយៗហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ លុះដល់ពេលថ្ងៃរសៀល ព្រះរាហុលមានអាយុ ក្រោកអំពីសំណិង ហើយចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគទ្រង់គង់ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចហើយដាក់អង្គគង់ក្នុងទីសមគួរ ។ លុះព្រះរាហុលមានអាយុ គង់ក្នុងទីសមគួរហើយ ក៏បានទូលស្នើសេចក្ដីនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចុះអានាបានស្សតិ ត្រូវចម្រើនដោយប្រការដូចម្ដេច ត្រូវបន្ទុំ ធ្វើឲ្យរឿយៗ ដោយប្រការដូចម្ដេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើនបាន ។

[ ១៣៥ ] ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលរាហុល រូបណា

មួយ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ជារូបដែលវិញ្ញាណកាន់កាប់ គឺ សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ជារូបដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះហៅថា បឋវីធាតុខាងក្នុង ។ មួយទៀត បឋវីធាតុណាខាងក្នុងក្តី បឋវីធាតុណាខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា បឋវីធាតុ ដូចគ្នា ។ បុគ្គលគួរឃើញបឋវីធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គល លុះឃើញបឋវីធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយចាកបឋវីធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកបឋវីធាតុ ។

[ ១៣៦ ] ម្នាលរាហុល ចុះអាបោធាតុ តើដូចម្តេចខ្លះ អាបោធាតុ (នោះ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល ចុះអាបោធាតុខាងក្នុងដូចម្តេច រូបណា ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណចូលទៅកាន់យក គឺ ប្រមាត់ ស្លេស្មខុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ពុំនោះសោត រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណ

ចូលទៅកាន់យក ម្នាលរាហុល នេះហៅថា អាបោធាតុខាងក្នុង ។ មួយវិញទៀត អាបោធាតុណា ជាខាងក្នុងក្តី អាបោធាតុណា ជាខាងក្រៅក្តី ធាតុទាំងនុ៎ះហៅថា អាបោធាតុដូចគ្នា ។ បុគ្គលគួរឃើញអាបោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គល លុះឃើញអាបោ-ធាតុ នុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយចាកអាបោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកអាបោធាតុ ។

[ ១៣៧ ] ម្នាលរាហុល ចុះតេជោធាតុ តើដូចម្តេចខ្លះ តេជោធាតុ ( នោះ ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល ចុះតេជោធាតុខាងក្នុងដូចម្តេច រូបណា ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវភាពជារបស់ក្តៅ ដែលវិញ្ញាណចូលទៅកាន់យក គឺភ្លើងដែលធ្វើកាយឲ្យផ្សព្វផ្សាយ ១ ភ្លើងដែលធ្វើកាយឲ្យទ្រុឌទ្រោម ១ ភ្លើងដែលធ្វើកាយឲ្យក្តៅរោលរាល ១ ភ្លើងធ្វើអាហារដែលស៊ីផឹកទំពាលិទ្ធភ្លក្ស ហើយឲ្យទ្រុឌទ្រោមរលួយទៅដោយស្រួល ១ ពុំនោះសោត រូបណាមួយ ក្រៅអំពីនេះដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវភាពជារបស់ក្តៅ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា តេជោធាតុខាងក្នុង ។ មួយវិញទៀត តេជោធាតុណាខាងក្នុងក្តី តេជោធាតុណា ខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា តេជោធាតុដូចគ្នា ។ បុគ្គលគួរឃើញនូវតេជោ-ធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ

នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គល លុះឃើញតេជោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយចាកតេជោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកតេជោធាតុ ។

[ ១៣៨ ] ម្នាលរាហុល ចុះវាយោធាតុ តើដូចម្តេចខ្លះ វាយោធាតុ ( នោះ ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល រូបណាដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក គឺ ខ្យល់បក់ឡើងទៅខាងលើ ១ ខ្យល់បក់ចុះមកខាងក្រោម ១ ខ្យល់បក់ក្នុងពោះក្រៅពោះវៀន ១ ខ្យល់បក់ក្នុងពោះវៀន ១ ខ្យល់បក់សព្វអវយវៈតូចធំ ១ ខ្យល់ដង្ហើមចេញចូល ១ ពុំនោះ រូបណាមួយក្រៅអំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានសភាពជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា វាយោធាតុខាងក្នុង ។ មួយទៀត វាយោធាតុណាជាខាងក្នុងក្តី វាយោធាតុណាជាខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា វាយោធាតុដូចគ្នា ។ បុគ្គលគួរឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គលលុះឃើញវាយោធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយចាកវាយោធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកវាយោធាតុ ។

[ ១៣៩ ] ម្នាលរាហុល អាកាសធាតុ តើដូចម្តេចខ្លះ អាកាសធាតុ

( នោះ ) ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលរាហុល អាកាសធាតុខាងក្នុង តើដូចម្តេច រូបណា ជារូបខាងក្នុង ដែលជារូបអាស្រ័យនូវខ្លួន មានសភាពជាទីវាល ដល់នូវភាពជាទីទំនេរ ដែលវិញ្ញាណចូលទៅកាន់យក គឺ រន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ បុគ្គលលេបចូលនូវអាហារដែលស៊ីផឹកទំពាលិទ្ធភ្លក្ស ហើយ តាមទ្វារណាក្តី ភោជនដែលបុគ្គលស៊ីផឹកទំពាលិទ្ធភ្លក្សហើយ ឋិតនៅក្នុងទ្វារណាក្តី ភោជនដែលបុគ្គលស៊ីផឹកទំពាលិទ្ធភ្លក្សហើយ តែងចេញមកតាម ចំណែកខាងក្រោម ដោយទ្វារណាក្តី ពុំនោះសោត រូបណាមួយក្រៅ អំពីនេះ ដែលជារូបខាងក្នុង ជារូបអាស្រ័យនូវខ្លួន មានភាពជាទីវាល ដល់នូវភាពជាទីទំនេរ ជាទីទទេ ដល់នូវភាពទទេ ជាចន្លោះ ដល់នូវទីជាចន្លោះ ដែលសាច់និងឈាមមិនប៉ះពាល់គ្នា ដែលវិញ្ញាណចូលទៅកាន់យក ម្នាលរាហុល នេះហៅថា អាកាសធាតុខាងក្នុង ។ មួយទៀត អាកាសធាតុ ណាជាខាងក្នុងក្តី អាកាសធាតុណាជាខាងក្រៅក្តី ធាតុទាំងនុ៎ះ ហៅថា អាកាសធាតុដូចគ្នា ។ បុគ្គលគួរឃើញអាកាសធាតុនុ៎ះ ដោយប្រាជ្ញាល្អ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។ បុគ្គល លុះឃើញអាកាសធាតុនុ៎ះដោយ ប្រាជ្ញាល្អ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយចាកអាកាសធាតុ ធ្វើចិត្តឲ្យប្រាសចេញចាកអាកាសធាតុ ។

[ ១៤០ ] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដី ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាផែនដីហើយ ផស្សៈ

ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់នូវចិត្តអ្នក ។ ម្នាលរាហុល ជនទាំងឡាយ ដាក់វត្ថុស្អាតក្តី ដាក់វត្ថុមិនស្អាតក្តី ដាក់ចុះនូវគូថក្តី ដាក់ចុះនូវទឹកមូត្រក្តី ដាក់ចុះនូវទឹកមាត់ក្តី ដាក់ចុះនូវខ្ទុះក្តី សម្រក់ឈាមដាក់ក្តី លើផែនដី ផែនដី ក៏មិនទៀយណាយ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាផែនដី យ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាផែនដីហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[ ១៤១ ] ម្នាលរាហុល អ្នកចូរចម្រើនភាវនា ឲ្យដូចជាទឹក ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាទឹកហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ជនទាំងឡាយ លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងគូថក្តី លាងទឹកមូត្រក្តី លាងទឹកមាត់ក្តី លាងខ្ទុះក្តី លាងឈាមក្តី ក្នុងទឹក ទឹកក៏មិនបានទៀយណាយ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាទឹក យ៉ាងនោះឯង ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាទឹកហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[ ១៤២ ] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាភ្លើង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈជាទីគាប់ចិត្ត ឬ

មិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ភ្លើង ឆេះវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះគូថក្តី ឆេះទឹកមូត្រក្តី ឆេះទឹក-មាត់ក្តី ឆេះខ្ទុះក្តី ឆេះឈាមក្តី ភ្លើងក៏មិនទៀយណាយ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ដោយវត្ថុទាំងនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាភ្លើង យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[ ១៤៣ ] ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាខ្យល់ ព្រោះថា កាល បើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។ ម្នាលរាហុល ខ្យល់បក់វត្ថុស្អាតក្តី បក់វត្ថុមិនស្អាតក្តី បក់គូថក្តី បក់ទឹកមូត្រក្តី បក់ទឹកមាត់ក្តី បក់ខ្ទុះក្តី បក់ឈាមក្តី ខ្យល់ក៏មិនទៀយណាយ ឬធុញទ្រាន់ ឬក៏ខ្ពើមរអើម ដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនាឲ្យដូចជាខ្យល់ យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[ ១៤៤ ] ម្នាលរាហុល អ្នកចូរចម្រើនភាវនា ឲ្យដូចជាអាកាស ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាអាកាសហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតហើយ រមែងមិនគ្របសង្កត់ចិត្ត ។

ម្នាលរាហុល អាកាស មិនប្រតិស្ឋាននៅតែក្នុងទីណាមួយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចម្រើនភាវនា ឲ្យដូចជាអាកាសយ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនភាវនា ឲ្យដូចជាអាកាសហើយ ផស្សៈ ជាទីគាប់ចិត្ត ឬមិនជាទីគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

[ ១៤៥ ] ម្នាលរាហុល អ្នកចូរចម្រើននូវមេត្តាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនមេត្តាភាវនាហើយ ព្យាបាទ នឹងវិនាសសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនករុណាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនករុណាភាវនាហើយ វិហេសាគឺសេចក្តីបៀតបៀន នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនមុទិតាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនមុទិតាភាវនាហើយ អរតិគឺសេចក្តីមិនត្រេកអរ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនឧបេក្ខាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនឧបេក្ខាភាវនាហើយ បដិឃៈគឺសេចក្តីថ្នាំងថ្នាក់ចិត្ត នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអសុភភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនអសុភភាវនាហើយ រាគៈគឺតម្រេកក្នុងកាមគុណ នឹងសាបសូន្យទៅ ។ ម្នាលរាហុល អ្នកចូរចម្រើនអនិច្ចសញ្ញា-ភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចម្រើនអនិច្ចសញ្ញាភាវនាហើយ អស្មិមានះគឺសេចក្តីប្រកាន់ខ្លួន នឹងសាបសូន្យទៅ ។

[ ១៤៦ ] ម្នាលរាហុល អ្នកចូរចម្រើននូវអានាបានស្សតិភាវនា ម្នាល

រាហុល អានាបានស្សតិភាវនា ដែលអ្នកបានចម្រើនហើយ បានធ្វើឲ្យរឿយៗ ហើយ ជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ចុះ អានាបានស្សតិភាវនា ដែលចម្រើនហើយ តើដូចម្តេច ដែលធ្វើឲ្យរឿយ ៗ ហើយ តើដូចម្តេច ទើបជាគុណជាតិមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឲ្យត្រង់ តម្កល់ស្មារតី ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ហើយភិក្ខុនោះ មានស្មារតីចាំជាក់ ដកដង្ហើមចេញ មានស្មារតីចាំជាក់ ដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលបើដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយគឺការដកដង្ហើមទាំងពួងហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយគឺការដកដង្ហើមទាំងពួង ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវកាយសង្ខារគឺដង្ហើមចេញនិងដង្ហើមចូល ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសេចក្តីសុខ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសេចក្តីសុខ ហើយដក

ដង្ហើមចូល ។ សិក្សាថា អាត្មាអញ ដឹងច្បាស់ នូវចិត្តសង្ខារ គឺវេទនាក្ខន្ធ និងសញ្ញាខន្ធ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារគឺ វេទនាក្ខន្ធនិងសញ្ញាខន្ធ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្តសង្ខារ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្តសង្ខារហើយ ដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្ត ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងរម្ងាប់នូវចិត្ត ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹង ច្បាស់នូវចិត្ត ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរីករាយ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរីករាយ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងតម្កល់ចិត្តឲ្យស្មើ ហើយដកដង្ហើមចេញ សិក្សាថាអាត្មាអញ នឹងតម្កល់ចិត្តឲ្យស្មើ ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងដោះចិត្តឲ្យផុតស្រឡះ ( ចាកនីវរណៈជាដើម ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងដោះចិត្តឲ្យផុតស្រឡះ ( ចាកនីវរណធម៌ជាដើម ) ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណា ( នូវបញ្ចក្ខន្ធថា ) មិនទៀង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណា ( នូវបញ្ចក្ខន្ធថា ) មិនទៀង ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក គឺវិបស្សនានិងមគ្គ ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណា ធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក ហើយដក

ដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណានូវសេចក្តីរលត់ ( នៃកងទុក្ខ ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណានូវសេចក្តីរលត់ ( នៃកងទុក្ខ ) ហើយដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿងធ្វើចិត្តឲ្យលះបោល ( នូវកិលេសព្រមទាំងខន្ធនិងអភិ-សង្ខារ ) ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងពិចារណាធម៌ជាគ្រឿង ធ្វើចិត្តឲ្យលះបោល ( នូវកិលេសព្រមទាំងខន្ធនិងអភិសង្ខារ ) ហើយដកដង្ហើមចូល ។ ម្នាលរាហុល អានាបានស្សតិ ដែលបុគ្គលបានចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយៗហើយ យ៉ាងនេះឯង ទើបជាគុណជាតិ មានផលច្រើន មានអានិសង្សច្រើន ម្នាលរាហុល កាលបើអានាបានស្សតិ ដែលបុគ្គល ចម្រើនហើយយ៉ាងនេះ ធ្វើឲ្យរឿយៗហើយ យ៉ាងនេះ ដង្ហើមចេញ និងដង្ហើមចូលទាំងឡាយណា ដែលមានក្នុងកាលជាខាងក្រោយ ដង្ហើមចេញនិងដង្ហើមចូលទាំងនោះ នឹងរលត់ទៅវិញជាប្រាកដ មិនមែនមិនរលត់ទៅវិញទេ ។ លុះព្រះ-មានព្រះភាគ សម្តែងព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុក៏មានចិត្តរីករាយត្រេកអរ ចំពោះភាសិត នៃព្រះមានព្រះភាគ ។

មហារាហុលោវាទសូត្រទី ២ ចប់

# អដ្ឋកថា

## មហារាហុលោវាទសូត្រ

[ ១៣៣ ] មហារាហុលោវាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ** សេចក្ដីថា ព្រះរាហុលបានតាមព្រះមានព្រះភាគទៅ អំពីខាងក្រោយខ្នង សេចក្ដីថា ព្រះរាហុល មិនលះខ្សែភ្នែក តាមទៅពីក្រោយមិនដាច់រយៈ ដោយការតាមទៅគ្រប់ឥរិយាបថ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ឈានព្រះបាទទៅខាងមុខ ដោយភាពស្រស់ស្អាត ។ ព្រះរាហុលដើរតាមព្រះទសពលទៅក្នុងទីនោះ ព្រះមានព្រះភាគទ្រង់ទៅត្រង់ កណ្ដាលព្រៃសាលព្រឹក្ស មានផ្ការីកស្គុសស្គាយ ទ្រង់រុងរឿងដូចដំរីដ៏ប្រសើរ ចុះប្រេង ចេញទៅដើម្បីកាន់សមរភូមិ ។ ព្រះរាហុល រុងរឿងដូចកូនដំរី តាមទៅពីខាងក្រោយដំរី ដ៏ប្រសើរនោះ ។ ព្រះមានព្រះភាគ ទ្រង់រុងរឿងដូចកេសរសីហរាជ ចេញអំពីគុហាកែវ ទៅស្វែងរកអាហារក្នុងពេលល្ងាច ។ ព្រះរាហុលក៏រុងរឿងដូចកូនសីហៈ ចេញដំណើរ តាមសីហមិគរាជ ។ ព្រះមានព្រះភាគ ដូចស្ដេចខ្លាធំមានចង្កូមជាកម្លាំង កំពុងចេញអំពីព្រៃសណ្ឋមណីបព៌ត ដ៏មានឫក្ស ព្រះរាហុលក៏ ដូចកូនស្ដេចខ្លាធំ ជាប់តាមស្ដេចខ្លាធំទៅ ។ ព្រះមានព្រះភាគដូចស្ដេចគ្រុឌ ចេញអំពីស្រះសិម្ពលី ព្រះរាហុលក៏ ដូចកូនស្ដេចគ្រុឌ តាមទៅអំពីក្រោយស្ដេចគ្រុឌ ។ ព្រះមានព្រះភាគ ដូចស្ដេចហង្សប៉ោណ្ឌតខ្ពួនទៅលើវេហាស៍អំពីភ្នំចិត្តកូដ ព្រះរាហុលក៏ដូចកូនហង្សប៉ោណ្ឌត

ខ្ជួនលយលឿនតាមស្ដេចហង្សទៅកាន់ស្រះធំ ព្រះរាហុលកុមារដូចកូនទូកមាស ជាប់តាមពីក្រោយមហានាវាមាសនោះ ។ ព្រះមានព្រះភាគ ដូចស្ដេចចក្រពត្តិទៅកាន់លម្ហមេឃដោយអានុភាពចក្រកែវ ព្រះរាហុលកុមារដូចបរិនាយកកែវជាប់តាមស្ដេចចក្រពត្តិទៅ ។ ព្រះមានព្រះភាគ ដូចមហាតារា អណ្ដែតលើផ្ទៃមេឃដែលប្រាសចាកភ្លៀង ព្រះរាហុលកុមារដូចផ្កាយព្រឹកស្រស់ស្អាតអណ្ដែតទៅតាមផ្កាយអធិបតី ។ សូម្បីព្រះមានព្រះភាគ សូម្បីព្រះរាហុលកុមារ ក៏ទ្រង់កើតក្នុងវង្សឱក្កាករាជ បន្តសន្តិវង្សព្រះបាទមហាសម្មតិរាជ ។ សូម្បីព្រះមានព្រះភាគ សូម្បីព្រះរាហុលកុមារ ក៏ទ្រង់កើតក្នុងត្រកូលក្សត្រ មានព្រះជាតិបរិសុទ្ធ ដូចគ្នានឹងទឹកដោះ ដែលដាក់ក្នុងស័ង្ខ ។ ព្រះមានព្រះភាគក្ដី ព្រះរាហុលកុមារក្ដី ក៏ទ្រង់លះរាជសម្បត្តិ ទ្រង់ចេញព្រះផ្នួស ។ ព្រះសរីរៈនៃព្រះមានព្រះភាគ លម្អដោយបុរិសលក្ខណៈ ៣២ ប្រការ សូម្បីព្រះរាហុលកុមារ ក៏ជាទីស្រឡាញ់យ៉ាងក្រៃលែង ដូចខ្លោងទ្វារកែវ ដែលតាំងឡើងក្នុងទេវនគរ និងដូចផ្កាសួគ៌រីកផ្សាយទៅក្នុងទីទាំងពួង ។

ដោយប្រការដូច្នេះ ទាំង ២ ព្រះអង្គ បរិបូណ៌ដោយអភិនីហារ ជារាជបព្វជិត ជាស្ដេចសុខមាលជាតិ មានព្រះឆវីដូចមាស បរិបូណ៌ដោយលក្ខណៈ ទ្រង់យាងទៅក្នុងផ្លូវតែមួយ រុងរឿងដូចគ្របសង្កត់នូវសិរីនៃសិរីរបស់ចន្ទមណ្ឌលទាំង ២ សុរិយមណ្ឌលទាំង ២ សក្កទេវរាជ ស្ដេចសុយាម ស្ដេចសន្ដុសិត ស្ដេចបរនិម្មិតវសវត្តី និងស្ដេចមហាព្រហ្មជាដើមទាំង ២ ទៅតាមលំដាប់ ។ ក្នុងខណៈនោះ ព្រះរាហុលយាងទៅខាងក្រោយខ្នង

ព្រះមានព្រះភាគ សម្លឹងមើលព្រះតថាគត តាំងអំពីចុងព្រះបាទរហូតដល់ចុងព្រះកេសា ។ ព្រះរាហុលនោះ ទតឃើញលម្អរបស់ព្រះសម្ពុទ្ធ ទើបត្រិះរិះថា ព្រះមានព្រះភាគ ទ្រង់មានព្រះសិរី វិចិត្រដោយមហាបុរិសលក្ខណៈ ៣២ ប្រការដ៏ស្រស់ស្អាត ប្រៀបដូចយានទៅត្រង់កណ្ដាលលម្អិតមាស ដ៏ព្រោងព្រាយ ព្រោះហែហមដោយព្រះរស្មីប្រមាណមួយព្យាម ដូចកនកបពិត ដែលចោមរោមដោយផ្លេមេឃ ដូចមាសមានតម្លៃវិចិត្រដោយរតនៈ ដែលអូសដោយយន្ត សូម្បីទ្រង់ដណ្ដប់ដោយសំពត់បង្សុកូលពណ៌ក្រហម ក៏ទ្រង់ល្អដូចភ្នំមាសដែលគ្របដោយសំពត់កម្ពលក្រហម ដូចមាសដែលមានតម្លៃ ប្រដាប់ដោយខ្សែកែវប្រពាល ដូចចេតិយមាស ដែលគេក្រាលដោយលម្អិតមាស ដូចសសរមាសលាបដោយទឹកល័ក្ត ដូចព្រះចន្ទពេញវង់ ផុសឡើងក្នុងខណៈនោះ ក្នុងចន្លោះភ្លៀងពណ៌ក្រហម ។ សិរីសម្បត្តិរបស់អត្តភាព ដែលបានត្រៀមទុកដោយអានុភាពនៃសមតឹសបារមី ។ ក្រោយអំពីនោះ ព្រះរាហុលត្ថេរក៏ពិនិត្យមើលខ្លួនខ្លះ ត្រិះរិះថា សូម្បីអញក៏ស្អាត បើព្រះមានព្រះភាគ ទ្រង់បានគ្រងរាជ្យជាស្ដេចចក្រពត្តិ ក្នុងមហាទ្វីបទាំង ៤ ទ្រង់បានប្រទាន តំណែងបរិនាយកកែវដល់អញ កាលបើដូច្នោះ ជម្ពូទ្វីបនឹងមានសោភណភាព ក្រៃពេក ទើបកើតឆន្ទរាគៈដែលអាស្រ័យផ្ទះ ព្រោះអត្តភាព ។

ព្រះមានព្រះភាគ ទ្រង់យាងទៅអំពីខាងមុខ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ រាហុលមានរាងកាយបរិបូណ៌ដោយស្បែក សាច់ និងឈាមហើយ ។ ជាវេលាដែលចិត្តរាយមាយទៅក្នុងរូបារម្មណ៍ជាដើម ដែលគួរត្រេកត្រអាល ។ រាហុល

ញ៉ាំងកាលឲ្យកន្លងទៅ ព្រោះជាអ្នកល្មោភឬហ៊ឺ ។ ព្រមគ្នានឹងការពិចារណា ទ្រង់បានឃើញចិត្តប្បាទរបស់រាហុលនោះដូចឃើញត្រីក្នុងទឹកថ្លា និងដូចឃើញស្រមោលក្នុងកញ្ចក់ដ៏បរិសុទ្ធ ។ កាលទ្រង់ឃើញហើយ ទ្រង់ធ្វើព្រះអធ្យាស្រ័យថា រាហុលនេះ ជាឱរសរបស់តថាគត ដើរតាមក្រោយតថាគត បែរជាកើតឆន្ទរាគៈដែលអាស្រ័យផ្ទះ ព្រោះអាស្រ័យអត្តភាពថា អញស្អាត ពណ៌សម្បុររបស់អញផូរផង់ ។ រាហុលរសាត់ទៅក្នុងទីដែលមិនគួរគោចរ ត្រាច់ទៅក្រៅផ្លូវ ត្រាច់ទៅក្នុងអគោចរ ទៅកាន់ទិសដែលមិនគួរទៅ ដូចមនុស្សធ្វើដំណើរវង្វេងទិស ។ម្យ៉ាងទៀត កិលេសរបស់រាហុលនេះ ចម្រើនធំធាត់ឡើងក្នុងខាងក្នុង រមែងមិនឃើញសូម្បីប្រយោជន៍ខ្លួន ឬប្រយោជន៍អ្នកដទៃ ឬប្រយោជន៍ទាំង ២ តាមសេចក្ដីពិត ។ បន្ទាប់អំពីនោះ នឹងបដិសន្ធិក្នុងនរកខ្លះ ក្នុងកំណើតតិរច្ឆានខ្លះ ក្នុងបេតវិស័យខ្លះ ក្នុងគភ៌មាតាដ៏ចង្អៀតខ្លះ ព្រោះហេតុនោះ នឹងធ្លាក់ទៅក្នុងសង្សារវដ្ដ ដែលមិនដឹងទីបំផុតខាងដើម និងខាងចុង ព្រោះថា លោភៈ ជាធម៌ញ៉ាំងសេចក្ដីវិនាសឲ្យកើត លោភៈ ជាធម៌ញ៉ាំងចិត្តឲ្យកម្រើក ភ័យកើតហើយក្នុងចិត្ត ជនមិនដឹងនូវភ័យនោះឡើយ បុគ្គលអ្នកលោភ រមែងមិនស្គាល់ប្រយោជន៍ បុគ្គលអ្នកលោភ រមែងមិនឃើញធម៌ សេចក្ដីលោភ គ្របសង្កត់នរជន ក្នុងកាលណា សេចក្ដីងងឹតដ៏មានកម្លាំងក៏កើតឡើងក្នុងកាលនោះ ។ តថាគត មិនគួរព្រងើយកន្តើយក្នុងរាហុលនេះ ដូចទូកពំពេញទៅដោយរតនៈច្រើន ដែលជ្រាបទឹកទៅក្នុងរវាងក្ដារបែក ម្ចាស់ទូកមិនគួរព្រងើយកន្តើយ សូម្បីត្រឹមតែមួយសន្ទុះ ដូច្នោះ ។ តថាគតនឹងសង្កត់-

សន្តិនរាហុលនោះ ទាន់កិលេសនេះមិនទាន់ធ្វើឲ្យសីលរតនៈជាដើម ក្នុងខាងក្នុងរបស់រាហុលនោះ វិនាសទៅជាមុន ។ ក្នុងឋានៈបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងបែរមើល ដូចស្តេចដំរី ។ ព្រោះដូច្នោះ ទើបព្រះ-មានព្រះភាគទ្រង់ប្រថាប់ឈរបង្វិលព្រះវរកាយទាំងមូល ដូចបដិមាមាសរំលិតត្រឡប់ ត្រាស់ហៅព្រះរាហុលភទ្ទ ។ ព្រះអានន្ទត្ថេរ សំដៅដល់ ព្រះរាហុលភទ្ទនោះ ទើបពោលពាក្យ ថា **អថ ខោ ភគវា អវលោកេត្វា** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **យំ កិញ្ចិ រូបំ** ជាដើម ពិស្តារហើយ ក្នុងខន្ធនិទ្ទេស ក្នុងវិសុទ្ធិមគ្គ ដោយប្រការទាំងពួង ។ បទថា **នេតំ មម** ប្រែថា នុ៎ះមិនមែនរបស់អញ លោកពោលទុកហើយ ក្នុងមហាហត្ថិបទោបមសូត្រ ។ ព្រោះហេតុអ្វី ទើបព្រះរាហុលទូលសួរថា **រូបមេវ នុ ខោ ភគវា** បពិត្រព្រះមានព្រះភាគ រូបប៉ុណ្ណោះឬ ព្រះអង្គ ។ បានឮថា ព្រះរាហុលនោះកើតន័យឡើង ព្រោះឮថា រូបទាំងពួងនុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនអញ នុ៎ះមិនមែនខ្លួនរបស់អញ ព្រះមានព្រះភាគត្រាស់ថា អ្នកគប្បីឃើញ រូបទាំងពួងយ៉ាងនេះដោយវិបស្សនាបញ្ញា ក្នុងវេទនាជាដើម និងគប្បីបដិបត្តិ ដូចម្តេចហ្ន៎ ។ ព្រោះដូច្នោះ រាហុលតាំងនៅក្នុងន័យនោះ ទើបទូលសួរ ។ ពិតហើយ ព្រះរាហុលនេះជាអ្នកឈ្លាសក្នុងន័យ កាលព្រះមានព្រះភាគត្រាស់ថា វត្ថុនេះមិនគួរធ្វើ រមែងចាក់ដុះរាប់រយរាប់ពាន់ន័យថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ ។ សូម្បីកាលព្រះមានព្រះភាគត្រាស់ថា វត្ថុនេះគួរធ្វើ ក៏មានន័យដូចគ្នា ។

ពិតហើយ ព្រះរាហុលនេះ ជាអ្នកប្រាថ្នាចំពោះការសិក្សា កៀរខ្សាច់ប្រមាណមួយបាត្រក្នុងបរិវេណព្រះគន្ធកុដិអំពីព្រលឹម ដោយគិតថា ថ្ងៃនេះអញនឹងបានឱវាទប្រមាណប៉ុណ្ណេះ បានការដាស់តឿនប្រមាណប៉ុណ្ណេះ អំពីសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ អំពីសម្នាក់របស់ព្រះឧបជ្ឈាយ៍ ។ សូម្បីព្រះសម្មាសម្ពុទ្ធកាលទ្រង់តាំងព្រះរាហុលទុកក្នុងឯតទគ្គៈ ក៏ទ្រង់តាំងឲ្យជាអ្នកកំពូល ក្នុងការសិក្សាថា ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុសាវករបស់តថាគតអ្នកប្រាថ្នាចំពោះការសិក្សា រាហុលជាកំពូលនៃភិក្ខុទាំងនោះ ។

សូម្បីព្រះរាហុលនោះ ក៏បន្លឺសីហនាទក្នុងកណ្តាលភិក្ខុសង្ឃយ៉ាងនោះ ដូចគ្នាថា ព្រះធម្មរាជា ជាបិតារបស់ខ្ញុំ ទ្រង់តាំងខ្ញុំទុកក្នុងតំណែងឯតទគ្គ ក្នុងទីចំពោះមុខភិក្ខុសង្ឃ ដើម្បីការដឹងដ៏ក្រៃលែង ក្នុងវត្ថុទាំងពួងនេះ ព្រះធម្មរាជាទ្រង់លើកតម្កើងខ្ញុំថា ជាកំពូលជាងភិក្ខុទាំងឡាយ ដែលប្រាថ្នាចំពោះការសិក្សា និងកំពូលជាងភិក្ខុទាំងឡាយ ដែលបួសដោយសទ្ធា ព្រះធម្មរាជាដ៏ប្រសើរ ដ៏ជាសម្លាញ់ ជាព្រះជនករបស់ខ្ញុំ ខ្ញុំមានព្រះសារីបុត្រ ដែលជាអ្នករក្សាធម៌ មានការឆ្អែតដោយបីតិជាឧបជ្ឈាយ៍ ខ្ញុំដឹងទាំងអស់ នូវពាក្យប្រៀនប្រដៅរបស់ព្រះជិនស្រី ។

លំដាប់នោះ ព្រោះមិនគប្បីឃើញរូបតែម្យ៉ាងប៉ុណ្ណោះ សូម្បីវេទនាជាដើម ក៏គប្បីឃើញយ៉ាងនេះ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់នឹងព្រះរាហុលថា **រូបំបិ រាហុល** ជាដើម ។

[ ១៣៤ ] បទថា **កោន្នុដ្ឋ** កាត់បទជា **កោ នុ អដ្ឋ** ប្រែថា នរណា

ហ្ន៎ ។ បានឮថា ព្រះថេរៈមានបរិវិតក្កថា ព្រះសម្មាសម្ពុទ្ធ នៃយើងមិនបានត្រាស់កថា ដោយបរិយាយថា ឈ្មោះថា សមណៈ គប្បីដឹងធុរកៈ អាស្រ័យអត្តភាព ហើយមិនគប្បីត្រិះរិះដល់វិតក្កបែបនេះ ។ ទ្រង់មិនបាន បញ្ជូនទូតទៅថា ម្នាលភិក្ខុ អ្នកចូរទៅ ចូរប្រាប់រាហុលថា អ្នកកុំត្រិះរិះដល់ វិតក្កបែបនេះឡើយ តាំងអញទុកចំពោះមុខ ហើយទ្រង់ប្រទាន សុគតោវាទ ចំពោះមុខដូចចាប់ចោរ ព្រមដោយកណ្ឋៈត្រង់ផុក ។ ឈ្មោះថា សុគតោវាទ រកបានដោយលំបាក ដោយអសង្ខេយ្យកប្ប ។ បុគ្គលណាហ្ន៎ ជាអ្នកមានជាតិ នៃបណ្ឌិត វិញ្ញូជនបានទទួលឱវាទចំពោះព្រះភក្ត្រព្រះពុទ្ធបែបនេះហើយ ថ្ងៃនេះនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ។

លំដាប់នោះ ព្រះរាហុលលះអាហារកិច្ច បានទទួលឱវាទហើយ ត្រឡប់អំពីទីនោះ ទៅអង្គុយត្រង់គល់ឈើមួយដើម ។ ព្រះមានព្រះភាគ ទ្រង់ឃើញព្រះរាហុលត្រឡប់ ក៏មិនបានត្រាស់យ៉ាងនេះថា ម្នាលរាហុល នេះជាវេលាភិក្ខាចាររបស់តថាគត អ្នកកុំត្រឡប់ឡើយ ព្រោះហេតុអ្វី បានឮថាព្រះមានព្រះភាគអង្គនោះ មានព្រះតម្រិះថា ថ្ងៃនេះរាហុលចូរបរិភោគអមតភោជន គឺកាយគតាសតិមុន ។

បទថា **អទ្ទសា ខោ អាយស្មា សារីបុត្តោ** ព្រះសារីបុត្របានឃើញហើយ គឺកាលព្រះមានព្រះភាគយាងទៅហើយ ព្រះសារីបុត្រទៅខាងក្រោយបានឃើញហើយ ។ បានឮថា កាលព្រះសារីបុត្រនៅមួយអង្គឯង ក៏មានវត្តម្យ៉ាង កាលនៅជាមួយព្រះមានព្រះភាគ ក៏មានវត្តម្យ៉ាង ។ ក្នុងកាលណា

ព្រះអគ្គសាវកទាំង ២ នៅតាមទំនើង ក្នុងកាលនោះ លោកទាំង ២ បោស សេនាសនៈអំពីព្រលឹម ជម្រះរាងកាយ អង្គុយចូលសមាបត្តិ ហើយទៅ បិណ្ឌបាតតាមពេញចិត្តរៀងៗ ខ្លួន ។ ម្យ៉ាងទៀត ព្រះថេរៈទាំង ២ កាលនៅ ជាមួយព្រះមានព្រះភាគ មិនបានធ្វើយ៉ាងនោះ ។ ក្នុងកាលនោះ ព្រះមានព្រះភាគ ហែហមដោយភិក្ខុសង្ឃ យាងទៅភិក្ខាចារមុន ។ កាលព្រះមានព្រះភាគ យាង ទៅហើយ ព្រះថេរៈចេញចាកសេនាសនៈរបស់ខ្លួន ត្រិះរិះថា ក្នុងទីដែលភិក្ខុនៅ ជាមួយគ្នាច្រើនៗ ភិក្ខុទាំងអស់អាចធ្វើឲ្យជ្រះថ្លា ឬមិនអាចទើប ទៅក្នុងទីនោះៗ ហើយបោសទីដែលមិនទាន់បោស បើសំរាមមិនទាន់បានកើបចោល ក៏យកទៅ ចោល កាលមិនទាន់មានក្អមទឹកផឹក ក្នុងទីដែលតាំងទឹកទុក ក៏តាំងក្អមទឹកទុក ។ ទៅសួរសុខទុក្ខភិក្ខុឈឺ ហើយសួរថា អាវុសោ ខ្ញុំនឹងនាំអ្វីមកប្រគេន លោក ត្រូវការអ្វី ។ ទៅរកភិក្ខុកំលោះដែលមិនទាន់មានវស្សា ហើយប្រៀនប្រដៅ ថា អាវុសោទាំងឡាយ ចូរលោកត្រេកអរចុះ កុំទៀយណាយក្នុងព្រះពុទ្ធសា-សនា ដែលមានសារៈក្នុងបដិបទាឡើយ កាលធ្វើយ៉ាងនេះហើយ ក៏ទៅ ភិក្ខាចារខាងក្រោយគេបង្អស់ ។ ប្រៀបដូច ស្តេចចក្រពត្តិ មានបំណងយាងទៅ ក្នុងទីណាមួយ ទ្រង់ចោមរោមដោយសេនា យាងទៅមុន ។ បរិនាយកកែវ រៀបចំកងទ័ពចេញទៅខាងក្រោយយ៉ាងណា ព្រះមានព្រះភាគជាធម្មចក្រពត្តិរាជ ក៏ដូច្នោះ ទ្រង់ហែហមដោយភិក្ខុសង្ឃ យាងចេញទៅមុន ព្រះធម្មសេនាបតីដ៏ជា បរិនាយកកែវនៃព្រះមានព្រះភាគអង្គនោះ ធ្វើកិច្ចនេះស្រេចហើយ ទើបចេញ ទៅ ឯក្រោយភិក្ខុទាំងអស់ ។ ព្រះថេរៈនោះ ចេញទៅយ៉ាងនេះហើយ ក្នុង

ថ្ងៃនោះ បានឃើញព្រះរាហុលកំពុងអង្គុយត្រង់គល់ឈើមួយដើម ។ ដោយហេតុនោះ ទើបលោកពោលថា **បច្ចា គច្ឆន្តោ អទ្ទស** ដូច្នេះ ។

កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះសារីបុត្រដឹកនាំក្នុងអានាបានស្សតិទៅវិញ ។ ព្រោះសមគួរដល់ការអង្គុយ បានឮថា ព្រះថេរៈមិនបានគិតដល់ថា ព្រះមានព្រះភាគត្រាស់រូបកម្មដ្ឋានដល់រាហុលនោះ ហើយគិតថា កម្មដ្ឋាននេះ សមគួរដល់ការអង្គុយរបស់ព្រះរាហុលនោះ ដោយអាការដែលព្រះរាហុលនេះអង្គុយនៅជាប់ជាមួយអាសនៈដែលមិនកម្រើក ទើបពោលយ៉ាងនេះ ។

ក្នុងបទទាំងនោះ បទថា **អានាបានស្សតឹ** ព្រះសារីបុត្រសម្ដែងថា ចូរលោកកំណត់ខ្យល់ដង្ហើមចូល-ចេញ ហើយញុំាងឈានពួក ៤ ពួក ៥ ឲ្យកើតក្នុងអានាបានស្សតិនោះ ហើយចម្រើនវិបស្សនា កាន់យកព្រះអរហត្ត ។ បទថា **មហប្ផលា ហោតិ** សេចក្ដីថា មានផលច្រើន ។ មានផលច្រើនដូចម្ដេច ភិក្ខុក្នុងសាសនានេះ ខ្វល់ខ្វាយក្នុងអានាបានស្សតិ អង្គុយលើអាសនៈមួយ ញុំាងអាសវៈទាំងឡាយឲ្យអស់ទៅ ហើយសម្រេចអរហត្ត ។ កាលមិនអាចយ៉ាងនោះ ក៏ជាសមសីសី គឺអស់ជីវិតព្រមគ្នានឹងអស់កិលេស ក្នុងពេលស្លាប់ ។ កាលមិនអាចយ៉ាងនោះ ក៏កើតក្នុងទេវលោក កាលស្ដាប់ធម៌របស់ទេវបុត្រដែលជាធម្មកថិកហើយ បានសម្រេចអរហត្ត ។ ក្លាត់ទៅអំពីនោះ បើកើតមិនទាន់ពុទ្ធុប្បាទកាល រមែងធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បើមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណនោះ រមែងជាខិប្បាភិញ្ញា គឺត្រាស់ដឹងរហ័ស ចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយ ដូចព្រះពាហិយៈជាដើម

ដូច្នោះ រមែងមានផលច្រើន ដោយប្រការដូច្នេះ ។ បទថា **មហានិសំសា** ជាវេវចនៈនៃបទថា **មហប្ផលា** នោះឯង ។ សេចក្ដីនេះ សូម្បីព្រះមានព្រះភាគ ក៏ត្រាស់ទុកថា

**អានាបានស្សតី យស្ស    បរិបុណ្ណា សុភាវិតា**
**អនុបុព្វំបរិចិតា    យថា ពុទ្ធេន ទេសិតា**
**សោមំ លោកំ បភាសេតិ    អព្ភា មុត្តោវ ចន្ទិមា ។**

អាណាបានស្សតិ ដែលព្រះយោគាវចរណា បានចម្រើន ល្អគ្រប់គ្រាន់ ហើយបានសន្សំហើយតាមលំដាប់ ដូចព្រះពុទ្ធ ទ្រង់សម្ដែងមកព្រះយោគាវចរនោះ រមែងញុំាងលោកនេះឲ្យ ភ្លឺច្បាស់ ដូចព្រះចន្ទ ផុតចាកពពក ។

ព្រះថេរៈកាលឃើញអានាបានស្សតិ មានផលច្រើននេះ ទើបដឹកនាំសទ្ធិវិហារិកក្នុងអានាបានស្សតិនោះ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់ប្រាប់រូបកម្មដ្ឋាន ព្រះថេរៈប្រាប់អានាបានស្សតិ ព្រោះហេតុនោះ សូម្បីទាំង ២ អង្គ ក៏ប្រាប់កម្មដ្ឋានហើយទៅ ។ ព្រះរាហុលភទ្ទ ជាអ្នកត្រូវទុកចោលក្នុងវិហារនោះឯង ព្រះមានព្រះភាគ សូម្បីទ្រង់ដឹងថា ព្រះរាហុលភទ្ទត្រូវទុកចោល ទ្រង់មិនទទួលខាទនីយដោយព្រះអង្គ ហើយក៏មិនបានយាងទៅ ។ ទ្រង់មិនបានបញ្ជូនក្នុងដៃរបស់ព្រះអានន្ទត្ថេរ មិនបានឲ្យសញ្ញាដល់ព្រះបាទបសេទិកោសលមហារាជ និងអនាថបិណ្ឌិកសេដ្ឋីជាដើមឡើយ ព្រោះជនទាំងនោះ បានត្រឹមតែសញ្ញា ក៏នឹងនាំទេយ្យធម៌ទាំងអម្រែកមក ។ ព្រះសារីបុត្តត្ថេរ ក៏មិនបានធ្វើអាការណាមួយ ដូចព្រះមានព្រះភាគដែរ ។

ព្រះរាហុលអត់អាហារ ដាច់កត្ត តែព្រះរាហុលនោះ សូម្បីតែចិត្តក៏មិនកើតឡើងថា ព្រះមានព្រះភាគជីងថា អញនៅក្នុងវិហារ ទ្រង់ទទួលបិណ្ឌបាតដែលព្រះអង្គបានហើយ ដោយព្រះអង្គឯង ក៏មិនបានយាងមក ។ ទ្រង់មិនបានបញ្ជូនទៅក្នុងដៃរបស់អ្នកដទៃ ។ ទ្រង់មិនបានឲ្យសញ្ញាដល់មនុស្សទាំងឡាយ សូម្បីឧបជ្ឈាយ៍របស់អញក៏ដឹងថា អញត្រូវទុកចោល ក៏មិនបានធ្វើ អ្វីមួយយ៉ាងនេះឡើយ ។ ការប្រមាថ ឬការមើលងាយព្រោះការធ្វើនោះជាបច្ច័យនឹងមានមកអំពីណា ។ ម្យ៉ាងទៀត ព្រះរាហុលមនសិការជាលំដាប់ ដល់កម្មដ្ឋានដែលព្រះមានព្រះភាគទ្រង់ប្រាប់មុនកត្ត ក្រោយកត្តថា រូបមិនទៀងយ៉ាងនេះ ជាទុក្ខយ៉ាងនេះ មិនស្អាតយ៉ាងនេះ ជាអនត្តាយ៉ាងនេះ ដូចបុគ្គលប្រាថ្នាចង់បានភ្លើង ក្នុងវេលាត្រជាក់ ទើបគិតថា ព្រះឧបជ្ឈាយ៍ប្រាប់អញថា អ្នកចូរចម្រើនអានាបានស្សតិ អញនឹងជឿលោក ព្រោះបុគ្គលមិនជឿអាចារ្យ និងឧបជ្ឈាយ៍ ឈ្មោះថា ជាអ្នកប្រដៅក្រ ។ ព្រោះហេតុនោះ ឈ្មោះថា ការបៀតបៀនដ៏គ្រោតគ្រាតជាង ព្រោះការកើតឡើងនៃការតិះដៀលថា ព្រះរាហុល ជាអ្នកប្រដៅក្រ មិនធ្វើតាមពាក្យរបស់ឧបជ្ឈាយ៍ដូច្នេះ រមែងមិនមាន ។

ព្រះរាហុលបំណងនឹងទូលសួរវិធីនៃភាវនា ទើបបានចូលគាល់ព្រះមានព្រះភាគ ។ ដើម្បីសម្តែងសេចក្តីនោះ ទើបព្រះអានន្ទត្ថេរពោលថា **អថ ខោ អាយស្មា រាហុលោ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បដិសល្លានា** សេចក្តីថា ចាកទីពួនសម្ងំ គឺចាកភាពជាបុគ្គលម្នាក់ឯង ។

[ ១៣៥ ] បទថា **យំកិញ្ចិ រាហុល** សេចក្តីថា ព្រោះហេតុអ្វី ព្រះរាហុល

ទូលសួរដល់អានាបានស្សតិ ព្រះមានព្រះភាគត្រាស់ រូបកម្មដ្ឋានទៅវិញ ឆ្លើយថា ដើម្បីលះ ឆន្ទរាគៈក្នុងរូប ។ បានឮថា ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះថា ឆន្ទរាគៈ កើតឡើងដល់រាហុល ព្រោះអាស្រ័យអត្តភាព ។ ក្នុងខាងដើម ព្រះអង្គត្រាស់រូបកម្មដ្ឋានទុកដោយសង្ខេបដល់ព្រះរាហុលនោះ ។ ឥឡូវនេះ តថាគត នឹងបែកការមិនតាក់តែងអត្តភាព ដោយអាការ ៤០ ហើយញ៉ាំងឆន្ទរាគៈ អាស្រ័យអត្តភាពនោះ ដែលមិនទាន់កើតជាធម្មតា ឲ្យកើតដល់រាហុលនោះ ។ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបធ្វើអាកាសធាតុឲ្យពិស្តារទៅវិញ ។ ដើម្បីសម្តែងឧបាយទារូប ។ ព្រោះទ្រង់ត្រាស់ ដល់មហាភូតរូប ៤ ទុកហើយខាងដើម ។ មិនបានពោលដល់ឧបាទាយរូប ។ ដូច្នោះ ដើម្បី សម្តែងឧបាទាយរូបនោះដោយមុខនេះ ទើបញ៉ាំងអាកាសធាតុឲ្យពិស្តារ ម្យ៉ាងទៀតសូម្បីបរិច្ឆិន្នរូប ក៏មកប្រាកដដោយអាកាសខាងក្នុង ។ ដើម្បីការប្រាកដ ជាក់ច្បាស់នៃរូប ដែលកំណត់ទុកដោយអាកាស តាមដែលប្រដាប់ទុក ទើបព្រះមានព្រះភាគដ៏ជានាយក ទ្រង់ប្រកាសរូបនោះ ។ បទដែលគួរពោល ក្នុងធាតុ ៤ ក្នុងសូត្រនេះ និងសូត្រមុន បានពោលទុកហើយក្នុងមហាហត្ថិបទោបមសូត្រ ។

[ ១៣៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអាកាសធាតុដូចតទៅនេះថា បទថា **អាសគតំ** សេចក្តីថា ជាសភាវៈ ដែលមានលក្ខណៈទទេ ។ បទថា **ឧបាទិន្នំ** សេចក្តីថា ដែលកម្មនិងកិលេស ចូលទៅប្រកាន់មាំ គឺ រូបរឹតតាំងនៅក្នុងសរីរៈ ។ បទថា **កណ្ណាជិទ្ទំ** គឺរន្ធត្រចៀកមិនប៉ះដោយសាច់ និង ឈាម ។

សូម្បីក្នុងបទថា **ឆាសច្ចិទ្ធំ** ទន្ទេប្រមុះជាដើមក៏មានន័យនេះដូចគ្នា ។ បទថា **យេន** ច គឺដោយប្រហោងណា ។ បទថា **អជ្ឈោហរតិ** វមែងលេប ឲ្យចូលទៅខាងក្នុង ។ បទនេះលោកពោលសំដៅដល់ទីដែលជាប្រហោង ១ ចំអាម ៤ ធ្នាប់របស់មនុស្សទាំងឡាយ តាំងអំពីគល់អណ្តាតដល់ផ្ទៃពោះ ។ បទថា **យត្ថ** ច គឺ ក្នុងឱកាសណា ។ បទថា **សំតិដ្ឋតិ** គឺតាំងនៅ ។ បទនេះលោកពោល សំដៅដល់ផ្ទៃពោះធំ ដែលដូចជាសំពត់តម្រងទឹកធំ របស់មនុស្សទាំងឡាយ ។ បទថា **អធោភាគំ និក្ខមតិ** គឺបន្ទោបង់ចេញខាងក្រោម ។ បទនេះលោកពោលសំដៅដល់ពោះវៀនធំ ដែលមានប្រវែងប្រមាណ ៣២ ហត្ថ ក្នុងទី ២១ កន្លែង ។ ដោយបទនេះថា **យំ វា បន អញ្ញំបិ** ឬវត្ថុណាទីមួយដទៃ លោកសម្តែងដល់អាកាសដែលទៅក្នុងរវាងហទយៈនិងសាច់ជាដើម និងដែលតាំងនៅដោយភាពជារណ្តៅ ។ ពាក្យដ៏សេសក្នុងបទនេះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងបឋវីធាតុជាដើម ។

[ ១៤០ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់លក្ខណៈនៃភាពជាបុគ្គលមាំទាំដល់ព្រះរាហុលនោះ ទើបត្រាស់បទថា **បឋវីសមំ** ជាដើម ។ បុគ្គលមិនត្រេកអរ មិនប្រទូស្ត ក្នុងអារម្មណ៍ ដែលគួរប្រាថ្នា ឈ្មោះថា តាទិបុគ្គល គឺបុគ្គលមិនញាប់ញ័រ ។ ក្នុងបទថា **មនាបាមនាបា** នេះគប្បីជ្រាបដូចតទៅនេះ ។ ផស្សៈសម្បយុត្តដោយចិត្ត សហគតៈដោយលោភៈ ៨ ឈ្មោះថា **មនាបា** ជាទីពេញចិត្ត ។ ផស្សៈ សម្បយុត្តដោយទោមនស្សចិត្ត ២ ឈ្មោះថា **អមនាបា** មិនជាទីពេញចិត្ត ។ បទថា **ចិត្តំ**

**ន បរិយាទាយ ឋស្សន្តិ** ផស្សៈនឹងមិនគ្របសង្កត់ចិត្តតាំងនៅបាន សេចក្ដីថា ផស្សៈទាំងនោះកើតឡើងហើយ នឹងមិនអាចគ្របសង្កត់ចិត្តរបស់លោក ដូចធ្វើឲ្យនៅក្នុងកណ្ដាប់ដៃបាន ។ ធនូរាគៈនឹងមិនកើតព្រោះអាស្រ័យអត្តភាពទៀតថា អញស្អាត ពណ៌សម្បុររបស់អញផូរផង់ ដូច្នេះ ។ លាមកនោះឯង ឈ្មោះថា **គូថគតំ** ក្នុងបទថា **គូថគតំ**ជាដើម ។ ក្នុងបទទាំងពួងក៏យ៉ាងនេះ ។

បទថា **ន កត្ថចិ បតិដ្ឋិតោ** ដូចអាកាសមិនតាំងនៅក្នុងទីណាមួយ គឺមិនតាំងនៅសូម្បីក្នុងទីមួយ មានក្នុងផែនដី ភ្នំ និងដើមឈើជាដើម ។ ឧបមាថា អាកាសគប្បីតាំងនៅលើផែនដី កាលផែនដីបែកធ្លាយ ក៏គប្បីបែកធ្លាយទៅដូចគ្នា ។ កាលភ្នំបាក់ ក៏នឹងបាក់ទៅដូចគ្នា ។ កាលដើមឈើបាក់ ក៏បាក់ទៅជាមួយគ្នាប៉ុណ្ណោះ ។

[ ១៤៥ ] ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ប្រារព្ធថា **មេត្តំ រាហុល** ឆ្លើយថា ដើម្បីសម្ដែងហេតុនៃភាពជាបុគ្គលមិនញាប់ញ័រ ។ ព្រោះទ្រង់សម្ដែងហេតុនៃតាទិបុគ្គលទុកហើយក្នុងខាងដើម ។ បុគ្គលណាមួយ មិនអាចចម្រើន ព្រោះមិនមែនហេតុថា អញជាបុគ្គលមិនញាប់ញ័រ ។ បុគ្គលណាមួយមិនមែនឈ្មោះថា ជាតាទិបុគ្គលដោយហេតុប៉ុណ្ណោះថា អញជាអ្នកខ្វល់-ខ្វាយក្នុងត្រកូលខ្ពស់ ជាពហូសូត ជាអ្នកមានលាភ ។ ព្រះរាជា មហាមាត្យរបស់ព្រះរាជាជាដើម រមែងគប់រកអញ ។ អញជាអ្នកមិនញាប់ញ័រក៏ទេ ។ តែជាអ្នកមិនញាប់ញ័រ ដោយការចម្រើនមេត្តាជាដើម ព្រោះហេតុនោះ ទើប

ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដើម្បីសម្តែងហេតុនៃភាពជាតាទិបុគ្គល ។

ក្នុងបទទាំងនោះ បទថា **ភាវយតោ** សេចក្តីថា ញ៉ាំងឧបចារភាវនា ឬអប្បនាភាវនាឲ្យដល់ ។ បទថា **យោ ព្យាបាទោ** សេចក្តីថា នឹងលះសេចក្តីក្រោធក្នុងសត្វបាន ។ បទថា **វិហេសា** សេចក្តីថា បៀតបៀនសត្វទាំងឡាយដោយបាតដៃជាដើម ។ បទថា **អរតិ** សេចក្តីថា ភាពជាបុគ្គលនឿយណាយក្នុងសេនាសនៈស្ងាត់ និងក្នុងអធិកុសលធម៌ ។ បទថា **បដិឃោ** សេចក្តីថា កិលេសជាគ្រឿងឲ្យក្តៅក្រហាយគ្រប់ៗ យ៉ាង ។ បទថា **អសុភំ** សេចក្តីថា ចម្រើនឧបចារៈ និងអប្បនាក្នុងសាកសព ដែលហើមប៉ោងជាដើម ។ បទថា **ឧទ្ធុមាតកា** ប្រែថា សាកសពដែលហើមប៉ោង អសុភភាវនានេះ លោកពោលទុកដោយពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។ បទថា **រាគោ** បានដល់ រាគៈប្រកបដោយកាមគុណ ៥ ។ បទថា **អនិច្ចសញ្ញំ** សេចក្តីថា សញ្ញាដែលកើតព្រមនឹងអនិច្ចានុបស្សនា ឬវិបស្សនានោះឯង ។ សូម្បីការមិនមានសញ្ញា ក៏លោកពោលថាសញ្ញា ដោយមាតិកានៃសញ្ញា ។ បទថា **អស្មិមានោ** សេចក្តីថា ប្រកាន់ថា អញមាននៅក្នុងរូបជាដើម ។

[ ១៤៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលញ៉ាំងបញ្ហាដែលព្រះថេរៈសួរឲ្យពិស្តារ ទើបពោលថា **អានាបានស្សតឹ** ដូច្នេះជាដើម ។ កម្មដ្ឋាននេះ កម្មដ្ឋានភាវនា និងអត្ថនៃបាលី ព្រមដោយអានិសង្សក្រថា លោកពោលទុកពិស្តារហើយ ក្នុងអនុស្សតិនិទ្ទេស ក្នុងវិសុទ្ធិមគ្គ ដោយគ្រប់គ្រាន់សព្វប្រការ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ធម្មទេសនានេះ ដោយអំណាចនៃបុគ្គល ដែលគប្បីទូន្មាននោះឯង ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថាមហារាហុលោវាទសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## ចូឡមាលុង្ក្យោវាទសូត្រទី ៣

[ ១៤៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ឯង ព្រះមាលុង្ក្យបុត្រមានអាយុ ចូលទៅសម្ងំនៅក្នុងទីរហោស្ថាន ក៏មានចិត្ត ត្រិះរិះកើតឡើងយ៉ាងនេះថា ទិដ្ឋិទាំងឡាយណាថា លោកទៀង ដូច្នេះក្តី លោក មិនទៀង ដូច្នេះក្តី លោកមានទីបំផុត ដូច្នេះក្តី លោកមិនមានទីបំផុត ដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ ហើយកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះក្តី សត្វស្លាប់ ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយ កើត ទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ព្រះមានព្រះភាគ មិនបាន សម្តែងគ្រាន់តែតម្កល់ទុក តែទ្រង់ហាមឃាត់ ព្រះមានព្រះភាគមិនបានសម្តែង ទិដ្ឋិទាំងនោះ ដល់អញទេ ព្រះមានព្រះភាគមិនបានសម្តែងទិដ្ឋិទាំងឡាយណា ដល់អញ ដំណើរដែលមិនបានសម្តែងទិដ្ឋិនោះ មិនគាប់ចិត្តអញទេ ដំណើរ ដែលមិនបានសម្តែងទិដ្ឋិនោះ មិនបានពេញចិត្តអញឡើយ អញឯងនឹងចូល ទៅគាល់ព្រះមានព្រះភាគ ហើយសួរដំណើរនុ៎ះ ប្រសិនបើព្រះមានព្រះភាគ នឹងសម្តែងប្រាប់អញថា លោកទៀង ដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយ កើត ទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគ តែប្រសិនបើព្រះមាន

ព្រះភាគ មិនបានសម្តែងថា លោកទៀង ដូច្នេះក្តី លោកមិនទៀង ដូច្នេះក្តី លោកមានទីបំផុត ដូច្នេះក្តី លោកមិនមានទីបំផុត ដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ក៏មិនមែន មិនកើតទៀត ក៏មិនមែន ដូច្នេះក្តី កាលបើយ៉ាងនេះ អាត្មាអញនឹងលះបង់សិក្ខា ហើយត្រឡប់មកកាន់ហីនភេទវិញ ។

[ ១៤៨ ] គ្រានោះឯង ព្រះមាលុង្ក្យបុត្រមានអាយុ ក្រោកចេញអំពីសំណិង ក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ ព្រះមាលុង្ក្យបុត្រមានអាយុ លុះអង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលនូវដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះអង្គចូលទៅសម្ងំនៅក្នុងទីរហោស្ថាន ក៏មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា ទិដ្ឋិទាំងឡាយណាថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ព្រះមានព្រះភាគមិនបានសម្តែង គ្រាន់តែតម្កល់ទុក តែ

ទ្រង់ឃាត់ហាម ព្រះមានព្រះភាគមិនទាន់សំដែងទិដ្ឋិទាំងនោះប្រាប់អាត្មាអញនៅឡើយ ព្រះមានព្រះភាគមិនបានសំដែងនូវទិដ្ឋិទាំងឡាយណា ដល់អាត្មាអញ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនគាប់ចិត្តដល់អាត្មាអញទេ ដំណើរដែលមិនបានសំដែងទិដ្ឋិនោះ មិនពេញចិត្តដល់អាត្មាអញឡើយ អាត្មាអញនឹងចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលសួរនូវដំណើរនុ៎ះ បើព្រះមានព្រះភាគសំដែងប្រាប់ដល់អាត្មាអញថា លោកទៀងក្តី ថាលោកមិនទៀងក្តី ថាលោកមានទីបំផុតក្តី ថាលោកមិនមានទីបំផុតក្តី ថាជីវិតនោះក៏គឺសរីរៈនោះក្តី ថាជីវិតដទៃសរីរៈក៏ដទៃក្តី ថាសត្វស្លាប់ហើយកើតទៀតក្តី ថាសត្វស្លាប់ហើយមិនកើតទៀតក្តី ថាសត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានក្តី ថាសត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ ទើបអាត្មាអញ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់នៃព្រះមានព្រះភាគ បើព្រះមានព្រះភាគមិនសំដែងថា លោកទៀងក្តី ថាលោកមិនទៀងក្តី ។បេ។ ថាសត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើយ៉ាងនេះ អាត្មាអញនឹងលាសិក្ខា ហើយត្រឡប់មកកាន់ហីនភេទវិញ ។ បើព្រះមានព្រះភាគទ្រង់ជ្រាបថា លោកទៀង ដូច្នេះហើយ សូមព្រះមានព្រះភាគសំដែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀង ដូច្នេះឲ្យទាន បើព្រះមានព្រះភាគទ្រង់ជ្រាបថា លោកមិនទៀង សូមព្រះមានព្រះភាគសំដែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនទៀង ដូច្នេះឲ្យទាន បើព្រះមានព្រះភាគមិនជ្រាបថា លោកទៀងក្តី ថាលោកមិនទៀងក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប

មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹងមិនឃើញដែរ ។ បើព្រះមានព្រះភាគជ្រាបថា លោកមានទីបំផុត សូមព្រះមានព្រះភាគសម្តែងប្រាប់ខ្ញុំព្រះអង្គថា លោកមានទីបំផុត ដូច្នេះឲ្យទាន បើព្រះមានព្រះភាគជ្រាប ថា លោកមិនមានទីបំផុត សូមព្រះមានព្រះភាគសម្តែងប្រាប់ខ្ញុំព្រះអង្គថា លោកមិនមានទីបំផុត ដូច្នេះឲ្យទាន បើព្រះមានព្រះភាគមិនជ្រាបថា លោកមានទីបំផុតក្តី ថាលោកមិនមានទីបំផុតក្តី កាលបើព្រះមានព្រះភាគមិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគជ្រាបថា ជីវិតនោះក៏គឺសរីរៈនោះ សូមព្រះមានព្រះភាគ សម្តែងប្រាប់ខ្ញុំព្រះអង្គថា ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះឲ្យទាន បើព្រះមានព្រះភាគជ្រាបថា ជីវិតដទៃសរីរៈក៏ដទៃ សូមព្រះមានព្រះភាគសម្តែងប្រាប់ខ្ញុំ ព្រះអង្គថា ជីវិតដទៃសរីរៈក៏ដទៃ ដូច្នេះឲ្យទាន បើព្រះមានព្រះភាគមិនជ្រាប ថា ជីវិតនោះក៏គឺសរីរៈនោះក្តី ថាជីវិតដទៃសរីរៈក៏ដទៃក្តី កាលបើព្រះមានព្រះភាគមិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគជ្រាបថា សត្វស្លាប់ហើយកើតទៀត សូមព្រះមានព្រះភាគ សម្តែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយកើតទៀត ដូច្នេះឲ្យទាន បើព្រះមានព្រះភាគជ្រាបថា សត្វស្លាប់ហើយមិនកើតទៀត សូមព្រះមានព្រះភាគសម្តែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះឲ្យទាន បើព្រះមានព្រះភាគមិនជ្រាបថា សត្វស្លាប់ហើយកើតទៀតក្តី ថាសត្វស្លាប់ហើយមិនកើតទៀតក្តី កាលបើព្រះមានព្រះភាគមិនជ្រាប មិនឃើញ ហើយក៏

ត្រូវគ្នានឹងខ្ញុំព្រះអង្គដែលមិនដឹង មិនឃើញដែរ ។ បើព្រះមានព្រះភាគជ្រាបថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន សូមព្រះមានព្រះភាគសម្តែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះឲ្យទាន បើព្រះមានព្រះភាគជ្រាបថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សូមព្រះមានព្រះភាគ សម្តែងប្រាប់ខ្ញុំព្រះអង្គថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែន ដូច្នេះឲ្យទាន បើព្រះមានព្រះភាគមិនជ្រាបថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មានក្តី ថាសត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្តី កាលបើព្រះមានព្រះភាគ មិនជ្រាប មិនឃើញហើយ ក៏ត្រូវគ្នានឹងខ្ញុំព្រះអង្គ ដែលមិនដឹង មិនឃើញ ។

[ ១៤៩ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលមាលុង្ក្យបុត្រ ចុះតថាគត បាននិយាយនឹងអ្នកយ៉ាងនេះថា ម្នាលមាលុង្ក្យបុត្រ អ្នកចូរមកអាយអ្នកចូរប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់តថាគតចុះ តថាគតនឹងសម្តែងប្រាប់អ្នកថា លោកទៀង ដូច្នេះក្តី លោកមិនទៀង ដូច្នេះក្តី លោកមានទីបំផុត ដូច្នេះក្តី លោកមិនមានទីបំផុត ដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែនដូច្នោះទេ ។ ចុះអ្នកបាន

និយាយនឹងតថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងប្រព្រឹត្ត ព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ឲ្យតែព្រះមានព្រះភាគនឹង សម្តែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀង ដូច្នេះក្តី លោកមិនទៀង ដូច្នេះក្តី លោកមានទីបំផុត ដូច្នេះក្តី លោកមិនមានទីបំផុត ដូច្នេះក្តី ជីវិតនោះក៏គឺ សរីរៈនោះ ដូច្នេះក្តី ជីវិតដទៃសរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏ មានមិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិន កើតទៀតក៏មិនមែន ដូច្នេះក្តី ឬអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន មិនមែន ដូច្នោះទេ ។ ម្នាលមាលុង្ក្យបុត្រ បានឮថា តថាគតមិនបាននិយាយនឹងអ្នកថា ម្នាលមាលុង្ក្យបុត្រ អ្នកចូរមកអាយ ចូរអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសម្នាក់ តថាគតចុះ តថាគតនឹងសម្តែងប្រាប់អ្នកថា លោកទៀង ដូច្នេះក្តី លោកមិន ទៀង ដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយ កើតទៀត ក៏មិនមែន មិនកើតទៀតក៏ មិនមែន ដូច្នេះក្តី ទាំងបានឮថា អ្នកក៏មិនបាននិយាយថា បពិត្រព្រះអង្គដ៏ ចម្រើន ខ្ញុំព្រះអង្គ នឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ឲ្យតែព្រះមានព្រះភាគ សម្តែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀងដូច្នេះក្តី លោក មិនទៀងដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀត ក៏មិនមែន ដូច្នេះក្តី ម្នាលមោឃបុរស កាលបើហេតុយ៉ាងនេះទេ ចុះអ្នក ជាអ្នក ជាទុក្ខប្រាប់អ្នកណា ។

[ ១៥០ ] ម្នាលមាលុង្ក្យបុត្រ បុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំមិន

ទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគមិនទាន់សម្តែងប្រាប់ខ្ញុំព្រះអង្គថា លោកទៀង ដូច្នេះក្តី លោកមិនទៀង ដូច្នេះក្តី ។បេ។ សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ម្នាលមាលុង្ក្យបុត្រ តថាគតនឹងសម្តែងនូវដំណើរនោះឲ្យស្តាប់មិនទាន់ទេ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅ ( មុនសម្តែង ) ដោយពិត ។ ម្នាលមាលុង្ក្យបុត្រ ដូចជាបុរសមុតព្រួញ ( របស់សេនានៃស្តេចដទៃ ) ដែលលាបប្រឡាក់ដោយថ្នាំពិសដ៏ក្រាស់ មិត្តអាមាត្យញាតិនិងសាលោហិតរបស់បុរសនោះ ក៏ចូលទៅរកពេទ្យជាអ្នកវះ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ថាជាក្សត្រ ឬព្រាហ្មណ៍ ឬវេស្សៈ ឬសុទ្ទៈនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះថា មាននាមយ៉ាងនេះ ឬមានគោត្រយ៉ាងនេះ នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ថាជាមនុស្សខ្ពស់ ឬទាប ឬកណ្តាលនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ថាជាមនុស្សសម្បុរខ្មៅ ឬសណ្តែកបាយ ឬប្រផេះនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ថានៅក្នុងស្រុកឬនិគម ឬនគរឯណោះៗ នៅឡើយ ។ បុរស

នោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ធ្នូដែលមុតខ្ញុំនោះ ថាជាកាំភ្លើង ឬស្នានៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ខ្សែប្រន្ទះដែលបាញ់ខ្ញុំនោះ ថាជាសំបកវាក់ ឬពន្លងឫស្សី ជាសរសៃសត្វ ឬសំបកខ្លែងព័រ ឬវល្លិទឹកដោះនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំ ថាជាព្រួញឈើព្រៃ ឬព្រួញឈើដែលគេដាំនៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ថាជាព្រួញ ដែលគេសៀតដោយស្លាបសត្វណា សត្វនោះ ជាត្មាត ឬប្រមង់ ឬខ្លែង ឬក្ងោក ឬទុង នៅឡើយ ។ បុរសនោះនិយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ថាជាព្រួញដែលគេរុំដោយសរសៃគោឬក្របី សរសៃសីហៈខ្មៅឬស្វានៅឡើយ ។ បុរសនោះ និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់ព្រួញដែលមុតខ្ញុំនោះ ថាជាព្រួញមានមុខមូល ឬមានមុខសំប៉ែតដូចមុខកាំបិត ព្រួញមានងៀងឬមានស្រោបដែក ព្រួញមានមុខដូចពន្លាក ឬព្រួញធ្វើអំពីទ្រនុងជាងទ្រាំង នៅឡើយ ម្នាលមាលុង្ក្យ-បុត្រ បុរសនោះចាំដឹងដំណើរនោះមិនទាន់ទេ មុខជាបុរសនោះនឹងធ្វើមរណកាលទៅពុំខាន ។ ម្នាលមាលុង្ក្យបុត្រ បុគ្គលណា និយាយយ៉ាងនេះថា ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគមិនទាន់សម្តែងប្រាប់ខ្ញុំថា លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោក

មានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះក្តី ជីវិតដទៃ សរីរៈក៏ដទៃ ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះក្តី សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក្តី ម្នាលមាលុង្ក្យបុត្រ តថាគតនឹងសម្តែងដំណើរនោះឲ្យស្តាប់មិនទាន់ទេ បុគ្គលនោះ មុខជានឹងធ្វើមរណកាលទៅ ( មុនសម្តែង ) ពុំ-ខាន មានឧបមេយ្យដូចជាបុរស ដែលត្រូវព្រួញមុតនោះឯង ។

[ ១៥១ ] ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀង ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌នឹង មានដូច្នេះ មិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញ ថា លោកមិនទៀង ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកទៀង ឬថាលោកមិនទៀង ដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគតបញ្ញត្ត ថាមានសេចក្តីវិនាស ក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុត ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រកាលបើមានសេចក្តីយល់ឃើញ ថា លោកមិនមានទីបំផុត ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្ម

ចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រកាលបើមានសេចក្តីយល់ឃើញថា លោកមានទីបំផុត ឬថា លោកមិនមានទីបំផុត ដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែល តថាគតបញ្ញត្តថា មានសេចក្តីវិនាស ក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតដទៃ សរីរៈក៏ដទៃ ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាល មាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា ជីវិតនោះក៏គឺសរីរៈនោះ ឬថាជីវិតដទៃ សរីរៈក៏ដទៃ ដូច្នេះហើយ ជាតិក៏មាន ។បេ។ បញ្ញត្តថា មានសេចក្តីវិនាស ។ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយកើតទៀត ឬថា សត្វស្លាប់ហើយមិនកើតទៀត ដូច្នេះហើយ ជាតិក៏មាន ។បេ។ ជាធម៌ដែលតថាគតបញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។ ម្នាលមាលុង្ក្យបុត្រ

កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះហើយ សេចក្តីយល់ឃើញថា ការអប់រំព្រហ្មចរិយធម៌ នឹងមានដូច្នេះមិនមានទេ ម្នាលមាលុង្ក្យបុត្រ កាលបើមានសេចក្តីយល់ឃើញថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន ឬថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះហើយ ជាតិក៏មាន ជរាក៏មាន មរណៈក៏មាន សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតូចចិត្ត សេចក្តីក្រៀមក្រំចិត្តក៏មាន ជាធម៌ដែលតថាគត បញ្ញត្តថា មានសេចក្តីវិនាសក្នុងបច្ចុប្បន្ន ។

[ ១៥២ ] ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តី ដែលតថាគតមិនបានសំដែងហើយ តាមសេចក្តីដែលតថាគតមិនបានសំដែង ទាំងចូរចាំទុកនូវសេចក្តី ដែលតថាគតបានសំដែងហើយតាមសេចក្តីដែលតថាគតបានសំដែងចុះ ។ ម្នាលមាលុង្ក្យបុត្រ ចុះតថាគតមិនបានសំដែងសេចក្តីដូចម្តេចខ្លះ ម្នាលមាលុង្ក្យបុត្រតថាគតមិនបានសំដែងថា លោកទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមិនទៀង ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគតមិនបានសំដែងថា លោកមិនមានទីបំផុត ម្នាលមាលុង្ក្យបុត្រ តថាគត

មិនបានសម្តែងថា ជីវិតនោះក៏គឺសរីរៈនោះ តថាគតមិនបានសម្តែងថា ជីវិតដទៃសរីរៈក៏ដទៃ តថាគតមិនបានសម្តែងថា សត្វស្លាប់ហើយកើតទៀត តថាគតមិនបានសម្តែងថា សត្វស្លាប់ហើយមិនកើតទៀត តថាគតមិនបាន សម្តែងថា សត្វស្លាប់ហើយ កើតទៀតក៏មាន មិនកើតទៀតក៏មាន តថាគតមិនបានសម្តែងថា សត្វស្លាប់ហើយ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុអ្វី បានជាតថាគតមិនសម្តែងទិដ្ឋិនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះទិដ្ឋិនោះ មិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនបានសម្តែងទិដ្ឋិនោះ ។ ម្នាលមាលុង្ក្យបុត្រ ចុះសេចក្តីដូចម្តេចដែលតថាគតតែងសម្តែង ម្នាលមាលុង្ក្យបុត្រ តថាគតតែងសម្តែងថា នេះជាទុក្ខ ម្នាលមាលុង្ក្យបុត្រ តថាគតតែងសម្តែងថា នេះជាហេតុប្រជុំកើតឡើងនៃទុក្ខ តថាគតតែងសម្តែងថា នេះជាគ្រឿងរម្ងត់ទុក្ខ តថាគតតែងសម្តែងថា នេះជាសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ។ ម្នាលមាលុង្ក្យបុត្រ ហេតុដូចម្តេច បានជាតថាគតសម្តែងពាក្យនុ៎ះ ម្នាលមាលុង្ក្យបុត្រ ព្រោះថាពាក្យនុ៎ះ ប្រកបដោយប្រយោជន៍ ពាក្យនុ៎ះ ជាខាងដើមនៃព្រហ្មចរិយធម៌ ពាក្យនុ៎ះ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅដើម្បីប្រាសចាក

ភាគៈ ប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ទុក្ខ ប្រព្រឹត្តទៅដើម្បី សេចក្តីស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីសេចក្តីដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតសម្តែងពាក្យនោះ ។ ម្នាលមាលុង្ក្យបុត្រ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរចាំទុកនូវសេចក្តីដែលតថាគតមិនបានសម្តែងហើយ តាមសេចក្តីដែលតថាគតមិនបានសម្តែងហើយផង ចូរចាំទុកនូវសេចក្តីដែលតថាគតបានសម្តែងហើយ តាមសេចក្តីដែលតថាគតបានសម្តែងហើយផង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះចប់ហើយ ព្រះមាលុង្ក្យបុត្រមានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចូឡមាលុង្ក្យោវាទសូត្រ ទី ៣ ចប់

# អដ្ឋកថា

## ចូឡមាលុង្ក្យោវាទសូត្រ

[ ១៤៧ ] ចូឡមាលុង្ក្យោវាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **មាលុង្ក្យបុត្តស្ស** សេចក្ដីថា ព្រះថេរៈមានឈ្មោះយ៉ាងនេះ ។ បទថា **ឋបិតានិ បដិក្ខិត្តានិ** សេចក្ដីថា ទ្រង់ហាម គឺព្រះមានព្រះភាគ ទ្រង់ឃាត់ ទ្រង់ហាមយ៉ាងនេះថា ទិដ្ឋិទាំងឡាយ មិនគួរព្យាករ ។ បទថា **តថាគតោ** គឺសត្វ ។ បទថា **តម្មេ ន រុច្ចតិ** សេចក្ដីថា ការមិនព្យាករណ៍នោះ មិនពេញចិត្តដល់អញ ។ បទថា **សិក្ខំ បច្ចក្ខាយ** សេចក្ដីថា អញនឹងលាសិក្ខា ។

[ ១៤៩ ] បទថា **កោ សន្តោ កំ បច្ចាចិក្ខសិ** សេចក្ដីថា អ្នកជាអុក ជាទុក្ខ ប្រាប់អ្នកណា គឺអ្នកសូមគប្បីទារអ្នកខ្ចី ឬអ្នកខ្ចីគួរទារអ្នកសូម អ្នកមិនមែនជាអ្នកសូម មិនមែនជាអ្នកខ្ចី ឥឡូវនេះ អ្នកជាអ្វី អ្នកមកទារនឹងបុគ្គលណាវិញ

[ ១៥០ ] បទថា **វិទ្ធោ អស្ស** សេចក្ដីថា បុរសត្រូវចាក់ដោយសរ គឺត្រូវបាញ់ ។ បទថា **គាឡ្ហលេបនេន** គឺដោយសរដែលលាបថ្នាំពិសដ៏ក្រាស់ទុកត្រង់មុខ ។ បទថា **ភិសក្កំ** គឺគ្រូពេទ្យដែលជំនាញ ។ បទថា **សល្លកត្តំ** គឺធ្វើការវះកាត់មុខរបួស ។ បទថា **អក្កស្ស** ប្រែថា សម្បកឆ្មៃ[១]គឺយកសម្បកឆ្មៃធ្វើខ្សែ ។ ដោយហេតុនោះ ទើបលោកពោលថា **អក្កស្ស** ធ្វើដោយសម្បកឆ្មៃ ។

---

១- បិដកខ្មែរថា សម្បករាក់ ។

បទថា **សណ្ហស្ស** គឺពន្ទងឫស្សី ។ ជនទាំងឡាយធ្វើខ្សែដោយសម្បកខ្ទែង ព័រ និងដោយវល្លិទឹកដោះនោះឯង ដោយហេតុនោះ ទើបលោកពោលថា **យទិ វា មរុវាយ យទិ វា ខីរបណ្ណិនោ** ដូច្នេះ ។ បទថា **គច្ឆំ** សេចក្តីថា ឈើដែលកើតឯង គឺកើតត្រង់ជួរភ្នំ ឬត្រង់ទីដែលមានទឹកហូរ ។ បទថា **រោបិមំ** សេចក្តីថា ឈើដាំ គឺឈើដាំដែលដុះល្អ ធ្វើជាព្រួញ ។ បទថា **សិថិលហនុនោ** សេចក្តីថា ជាឈ្មោះរបស់បក្សីដែលមានឈ្មោះថា សិថិលហនុ ( ទុង ) ។ បទថា **ភេរវស្ស** បានដល់ សីហៈខ្មៅ។ បទថា **សេម្ហារស្ស** បានដល់ ស្វា ។

[ ១៥១ ] បទថា **ឯវំ នោ** សេចក្តីថា កាលទិដ្ឋិមានយ៉ាងនោះ ក៏មិនមែន ។ បទថា **អត្ថេវ ជាតិ** សេចក្តីថា កាលនៅមានទិដ្ឋិយ៉ាងនោះ ការប្រព្រឹត្តិព្រហ្មចរិយៈរមែងមិនមាន តែជាតិនៅមាន ។ ម្យ៉ាងទៀត លោកសម្តែងដល់ជរា និងមរណៈជាដើមផងដែរ ។ បទថា **យេសាហំ** កាត់បទជា **យេសំ អហំ ។** បទថា **និឃាតំ** សេចក្តីថា ជក គឺចូលទៅកម្ចាត់ឲ្យវិនាស អធិប្បាយថា ព្រោះសាវកទាំងឡាយរបស់តថាគត នឿយណាយក្នុងជរានិងមរណៈជាដើមនោះ ទើបសម្រេចនិព្វានក្នុងសាសនានេះឯង ។

[ ១៥២ ] បទថា **តស្មាតិហ** សេចក្តីថា ព្រោះដូច្នោះឯង សេចក្តីនោះតថាគតមិនព្យាករឡើយ តថាគតព្យាករអរិយសច្ច ៤ ប៉ុណ្ណោះ ។

បទថា **នហេតំ មាលុង្ក្យបុត្ត អត្ថសញ្ហិតំ** សេចក្តីថា ម្នាលមាលុង្ក្យបុត្រ សេចក្តីនោះ មិនប្រកបដោយប្រយោជន៍ឡើយ គឺទិដ្ឋិនេះក្តី ព្យាករនេះក្តី មិន

បានអាស្រ័យហេតុឡើយ ។ បទថា **ន អាទិព្រហ្មចរិយកំ** សេចក្តីថាមិនជាខាងដើមនៃព្រហ្មចរិយៈ គឺសូម្បីត្រឹមតែខាងដើមនៃព្រហ្មចរិយៈ ក៏មិនមានត្រឹមតែសីលក្នុងចំណែកខាងដើមក៏មិនមាន ។ ក្នុងបទថា **ន និព្វិទាយ** មានសេចក្តីដូចតទៅនេះ គឺមិនប្រព្រឹត្តទៅដើម្បីការនឿយណាយក្នុងវដ្តៈ ដើម្បីប្រាសចាកតម្រេក ដើម្បីរម្ងាប់វដ្តៈ ដើម្បីស្ងប់រាគៈជាដើម ដើម្បីដឹងក្រៃលែងនូវធម៌ដែលគួរដឹងក្រៃលែង ដើម្បីត្រាស់ដឹងមគ្គ ៤ ឬដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាអសង្ខតធម៌ឡើយ ។ បទថា **ឯតញ្ហិ** គឺព្យាករអរិយសច្ច ៤ នេះ ។ បទថា **អាទិព្រហ្មចរិយកំ** សេចក្តីថា ជាខាងដើមនៃព្រហ្មចរិយៈ ។ បទដ៏សេសគប្បីជ្រាបដោយន័យ ផ្ទុយគ្នាតាមដែលពោលហើយ ។ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះធម្មទេសនានេះ ដោយអំណាចនេយ្យបុគ្គល ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថា ចូឡមាលុង្ក្យោវាទសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មហាមាលុង្ក្យោវាទសូត្រទី ៤

[ ១៥៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ បានចាំឱរម្ភាគិយសំយោជនៈទាំង ៥ ដែលតថាគតបានសម្តែងហើយដែរឬ ។ កាលដែលព្រះមានព្រះភាគ ត្រាស់សួរយ៉ាងនេះហើយ ព្រះមាលុង្ក្យបុត្រមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំឱរម្ភាគិយសំយោជនៈទាំង ៥ ដែលព្រះមានព្រះភាគសម្តែងហើយ ។ ព្រះអង្គត្រាស់សួរថា ម្នាលមាលុង្ក្យបុត្រ ចុះអ្នកចាំឱរម្ភាគិយសំយោជនៈ ៥ ដែលតថាគតសម្តែងហើយ ដូចម្តេចខ្លះ ។ មាលុង្ក្យបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា សក្កាយទិដ្ឋិ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា វិចិកិច្ឆា ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា សីលព្វតបរាមាសៈ ជាឱរម្ភាគិយសំយោជនៈដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា កាមច្ឆន្ទៈ ជាឱរម្ភាគិយសំយោជនៈ

ដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំថា ព្យាបាទៈ ជាឱរម្ភាគិយសំយោជនៈ ដែលព្រះមានព្រះភាគសម្តែងហើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចាំបាននូវឱរម្ភាគិយសំយោជនៈទាំង ៥ ដែលព្រះមានព្រះភាគសម្តែងហើយ យ៉ាងនេះឯង ។

[ ១៥៤ ] ព្រះអង្គត្រាស់ថា ម្នាលមាលុង្ក្យបុត្រ អ្នកចាំបាននូវឱរម្ភាគិយសំយោជនៈទាំង ៥ យ៉ាងនេះ ដែលតថាគតបានសម្តែងហើយ ថាជាសំយោជនៈរបស់អ្នកណា ម្នាលមាលុង្ក្យបុត្រក្រែងពួកបរិព្វាជក ជាអន្យតិរ្ថិយនឹងពោលប្រកួតប្រកាន់ ដោយសេចក្តីប្រកួតប្រកាន់ ដែលប្រៀបដោយកូនក្មេងតូចទេដឹង ម្នាលមាលុង្ក្យបុត្រ ដ្បិតកូនក្មេងតូចកំពុងដេកផ្ងារនៅឡើយ នឹងថាមានសក្កាយៈ មិនទាន់បានទេ តើសក្កាយទិដ្ឋិនឹងកើតឡើងដល់កូនក្មេងនោះ ដូចម្តេចបាន តែត្រង់សក្កាយទិដ្ឋានុស័យរបស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចីកំពុងដេកផ្ងារនៅឡើយ នឹងថាមានធម៌ មិនទាន់បានទេ តើសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្តេចបាន តែត្រង់វិចិកិច្ឆានុស័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ តាមការពិត កូនក្មេងតូចខ្ចី កំពុងដេកផ្ងារនៅឡើយ នឹងថាមានសីល មិនទាន់បានទេ តើសីលព្វតបរាមាសៈក្នុងសីលទាំងឡាយនឹងកើតឡើងដល់កូនក្មេងនោះ ដូចម្តេចបាន តែត្រង់សីលព្វតបរាមាសានុស័យរបស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចីកំពុងដេកផ្ងារនៅឡើយ នឹងថាមានកាម មិនទាន់បានទេ តើកាមច្ឆន្ទៈក្នុងកាម

ទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្តេចបាន តែត្រង់កាមរាគានុស ័យ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ កូនក្មេងតូចខ្ចី កំពុងដេកផ្ងារនៅឡើយ នឹងថាមានសត្វ មិនទាន់បានទេ តើការព្យាបាទទៅរកសត្វទាំងឡាយ នឹងកើតឡើងដល់កូនក្មេងនោះ ដូចម្តេចបាន តែត្រង់ព្យាបាទានុសយ័ របស់កូនក្មេងនោះ គង់ដេកនៅខាងក្នុង ម្នាលមាលុង្ក្យបុត្រ ក្រែងពួកបរិព្វាជកជាអន្យតិ្ថយ នឹងពោលប្រកួតប្រកាន់ ដោយសេចក្តីប្រកួតប្រកាន់ ដែលប្រៀបដោយកូនក្មេងនេះឯង ទេដឹង ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរហើយ បពិត្រព្រះសុគត កាលនេះជាកាលគួរ ដែលព្រះមានព្រះភាគនឹងសម្តែងនូវឱរម្ភាគិយសំយោជនៈទាំង ៥ ហើយ ពួកភិក្ខុបើបានស្តាប់ភាសិតរបស់ព្រះមានព្រះភាគហើយ នឹងចងចាំទុកបាន ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទបើដូច្នោះ ចូរអ្នកប្រុងស្តាប់ ចូរយកចិត្តទុកដាក់ ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១៥៥ ] ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលអានន្ទ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់មិនបានឃើញព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានសិក្សាក្នុងធម៌របស់ព្រះអរិយៈ ទាំងមិនបានជួបប្រទះនូវពួកសប្បុរស មិនឈ្លាសវៃក្នុងធម៌របស់សប្បុរស មិនបាន

សិក្សាក្នុងធម៌របស់សប្បុរស ជាអ្នកមានសក្កាយទិដ្ឋិគ្របសង្កត់ចិត្ត មានសក្កាយទិដ្ឋិរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញនូវសក្កាយទិដ្ឋិដែលកើតឡើង តាមសេចក្តីពិតបានឡើយ សក្កាយទិដ្ឋិនោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះ ក៏មិនអាចនឹងរលាស់ចោលបាន ( នេះ ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានវិចិកិច្ឆាគ្របសង្កត់ចិត្ត មានវិចិកិច្ឆារួបរឹតចិត្ត ទាំងមិនបានដឹងច្បាស់ នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង តាមសេចក្តីពិតបានឡើយ វិចិកិច្ឆានោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះ ក៏មិនអាចនឹងរលាស់ចេញបាន ( នេះ ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានសីលព្វតបរាមាសៈគ្របសង្កត់ចិត្ត មានសីលព្វតបរាមាសៈរួបរឹតចិត្ត ទាំងមិនដឹងច្បាស់ នូវព្រះនិព្វានជាគ្រឿងរលាស់ចេញនូវសីលព្វតបរាមាសៈ ដែលកើតឡើង តាមសេចក្តីពិតបានឡើយ សីលព្វតបរាមាសៈនោះរបស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះក៏មិនអាចនឹងរលាស់ចោលបាន ( នេះ ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានកាមរាគគ្របសង្កត់ចិត្ត មានកាមរាគរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញនូវកាមរាគដែលកើតឡើង តាមសេចក្តីពិតបានឡើយ កាមរាគនោះ របស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះ ក៏មិនអាចនឹងរលាស់ចេញបាន ( នេះ ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ជាអ្នកមានព្យាបាទគ្របសង្កត់ចិត្ត មានព្យាបាទរួបរឹតចិត្ត ទាំងមិនដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវព្យាបាទដែលកើតឡើង តាមពិតបានឡើយ ព្យាបាទនោះ

របស់បុគ្គលនោះ មានកម្លាំង បុគ្គលនោះក៏មិនអាចនឹងរលាស់ចេញបាន ( នេះ ) ជាឱរម្ភាគិយសំយោជនៈ ១ ។ ម្នាលអានន្ទ ចំណែកខាងអរិយសាវក ជាអ្នកបានស្តាប់បានឃើញនូវពួកព្រះអរិយៈ ជាអ្នកឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានសិក្សាក្នុងធម៌របស់ព្រះអរិយៈ ទាំងបានឃើញនូវពួកសប្បុរស ជាអ្នកឈ្លាសវៃក្នុងធម៌របស់សប្បុរស បានសិក្សាក្នុងធម៌របស់សប្បុរស ជាអ្នកមិនមានសក្កាយទិដ្ឋិគ្របសង្កត់ចិត្ត មិនមានសក្កាយទិដ្ឋិរួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញនូវសក្កាយទិដ្ឋិដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវកនោះ តែងលះបង់នូវសក្កាយទិដ្ឋិ ដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានវិចិកិច្ឆាគ្របសង្កត់ចិត្ត មិនមានវិចិកិច្ឆារួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវវិចិកិច្ឆាដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវកនោះតែងលះបង់នូវវិចិកិច្ឆា ដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានសីលព្វតបរាមាសៈគ្របសង្កត់ចិត្ត មិនមានសីលព្វតបរាមាសៈរួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញ នូវសីលព្វតបរាមាសៈ ដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវកនោះ តែងលះបង់នូវសីលព្វតបរាមាសៈដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានកាមរាគគ្របសង្កត់ចិត្ត មិនមានកាមរាគរួបរឹតចិត្ត ទាំងដឹងច្បាស់នូវព្រះនិព្វានជាគ្រឿងរលាស់ចេញ នូវកាមរាគដែលកើតឡើង តាមសេចក្តីពិតបាន អរិយសាវកនោះតែងលះបង់នូវកាមរាគដែលប្រកបដោយអនុស័យនោះ ។ ជាអ្នកមិនមានព្យាបាទគ្របសង្កត់ចិត្ត មិនមានព្យាបាទរួបរឹតចិត្ត

ទាំងបានដឹងច្បាស់នូវព្រះនិព្វាន ជាគ្រឿងរលាស់ចេញនូវព្យាបាទ ដែលកើតឡើងតាមសេចក្តីពិតបាន អរិយសាវកនោះតែងលះបង់នូវព្យាបាទដែលប្រកបដោយអនុស័យនោះ ។

[ ១៥៦ ] ម្នាលអានន្ទ មគ្គណា បដិបទាណា ប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បុគ្គលមិនបាច់អាស្រ័យ នូវមគ្គនោះ នូវបដិបទានោះទេ ក៏គង់ដឹង គង់ឃើញ ឬគង់លះបង់ នូវឱរម្ភាគិយសំយោ-ជនៈទាំង ៥ បាន ពាក្យដូច្នេះ មិនសមហេតុទេ ។ ម្នាលអានន្ទ ដូចដើមឈើធំមានខ្លឹម កំពុងឋិតនៅ បុគ្គលមិនបានប្រាសយកសំបកចេញ មិនបានចាំងយកស្រាយចេញ ក៏គង់តែកាប់យកខ្លឹមបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ មគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បុគ្គលមិនបាច់អាស្រ័យនូវមគ្គនោះ នូវបដិបទានោះទេ ក៏គង់ដឹង គង់ឃើញ ឬគង់លះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលអានន្ទ លុះតែមគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បុគ្គលក៏បានអាស្រ័យនូវមគ្គនោះ នូវបដិបទានោះ នឹងដឹង នឹងឃើញ ឬនឹងលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បាន ពាក្យដូច្នេះនេះ ទើបសមហេតុមែន ។ ម្នាលអានន្ទ ដូចដើមឈើមានខ្លឹម កំពុងឋិតនៅ ហើយគេបានប្រាសសំបកចេញ ចាំងស្រាយចេញ ទើបគេកាប់យកខ្លឹមបាន ពាក្យដូច្នេះនេះ ទើបសម

ហេតុ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ មគ្គណា បដិបទាណា ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បុគ្គលក៏បានអាស្រ័យនូវមគ្គនោះ នូវបដិបទានោះ នឹងដឹង នឹងឃើញ ឬនឹងលះបង់នូវឱរម្ភាគិយ-សំយោជនៈទាំង ៥ បាន ពាក្យដូច្នេះនេះ ទើបសមហេតុ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលអានន្ទ មួយទៀត ដូចទន្លេគង្គាមានទឹកពេញព្រៀបស្មើនឹងច្រាំង ល្មមក្អែកទំលើមាត់ច្រាំងឱនផឹកបាន កាលនោះ មានបុរសមានកម្លាំងខ្សោយដើរមកដោយគិតថា អាត្មាអញនឹងឆ្លងកាត់ខ្សែទឹកត្រង់ទទឹងទន្លេគង្គានេះដោយដៃ ហើយនឹងបានដល់ទៅត្រើយនាយដោយសួស្តី ដូច្នេះ បុរសនោះ មិនអាចនឹងឆ្លងកាត់ខ្សែទឹកត្រង់ទទឹងទន្លេគង្គាដោយដៃ ទៅដល់ត្រើយខាងនាយដោយសួស្តីបានឡើយ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ កាលតថាគតសំដែងធម៌ដើម្បីរម្ងត់នូវសក្កាយៈ ដល់បុគ្គលណាមួយ ចិត្តរបស់បុគ្គលនោះមិនស្ទុះទៅ មិនជ្រះថ្លា មិនឋិតនៅស៊ប់ មិនជឿជាក់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បណ្ឌិតត្រូវឃើញពួកជនទាំងនោះ ដូចបុរសដែលមានកម្លាំងខ្សោយនោះឯង ។ ម្នាលអានន្ទ ទន្លេគង្គាមានទឹកពេញព្រៀបស្មើមាត់ច្រាំង ល្មមក្អែកទំលើមាត់ច្រាំងឱនផឹកទឹកបាន កាលនោះ បុរសមានកម្លាំងដើរមកដោយគិតថា អាត្មាអញនឹងឆ្លងកាត់ខ្សែទឹកត្រង់ទទឹងទន្លេគង្គានេះ ដោយដៃ ហើយនឹងបានដល់ត្រើយខាងនាយដោយសួស្តី ដូច្នេះ បុរសនោះ អាចនឹងឆ្លងកាត់ខ្សែទឹកត្រង់ទទឹងទន្លេគង្គា ដោយដៃ ក៏ដល់ទៅត្រើយខាងនាយដោយសួស្តីបាន មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ កាលតថាគតសំដែងធម៌

ដើម្បី រមួតនូវសក្កាយៈដល់បុគ្គលណាមួយ ចិត្ត ( របស់បុគ្គលនោះ ) ក៏ស្ទុះទៅ ជ្រះថ្លា ឋិតនៅស៊ប់ ជឿជាក់ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ បណ្ឌិតត្រូវឃើញពួកជនទាំងនោះ ដូចបុរសដែលមានកម្លាំងនោះឯង ។

[ ១៥៧ ] ម្នាលអានន្ទ ចុះមគ្គដូចម្តេច បដិបទាដូចម្តេច ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បាន ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានឧបធិវិវេក ព្រោះលះបង់នូវពួកអកុសលធម៌ ព្រោះរម្ងាប់នូវការប្រព្រឹត្តិអាក្រក់ដោយកាយ ដោយសព្វអន្លើ ហើយស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខ ដែលកើតអំពីវិវេក ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវពួកធម៌ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិនោះ ថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិនស្តាប់បង្គាប់ចិត្ត ។ ភិក្ខុនោះ រមែងដោះចិត្តចាកធម៌ទាំងនោះ លុះភិក្ខុនោះ បានដោះចិត្តចាកធម៌ទាំងនោះហើយ ក៏បង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់នូវសង្ខារទាំងពួង ការលះបង់នូវឧបក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជាសេចក្តីល្អិត ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរ ។ ភិក្ខុនោះ បានឋិតនៅក្នុងវិបស្សនា ដែលមានព្រះត្រៃលក្ខណ៍ជា

អារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះសមថធម៌និងវិបស្សនាធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះការអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយ នឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯង ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំ-យោជនៈទាំង ៥ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។បេ។ ចូលកាន់តតិយជ្ឈាន ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវពួកធម៌ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិ ។បេ។ ដើម្បីលះបង់នូវសំយោជនៈទាំងឡាយ ។

[ ១៥៨ ] ម្នាលអានន្ទ មួយទៀត ភិក្ខុព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរម្ងត់នូវបដិឃសញ្ញា ព្រោះមិនយកចិត្តទុកដាក់នូវនានត្តសញ្ញា ដោយប្រការទាំងពួង ក៏ចូលកាន់អាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ ។ ភិក្ខុនោះ រមែងពិចារណាឃើញច្បាស់នូវពួកធម៌ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលកាន់សមាបត្តិនោះ ថាជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិន

ស្តាប់បន្ទាប់ចិត្តឡើយ ។ ភិក្ខុនោះ រមែងដោះចិត្តចាកធម៌ទាំងនោះបាន លុះភិក្ខុនោះ បានដោះចិត្តចាកធម៌ទាំងនោះហើយ ក៏បង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវឧបក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់នៃតណ្ហា គឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជារបស់ល្អិត ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរល្អ ។ ភិក្ខុនោះ បានឋិតនៅ ក្នុងវិបស្សនា ដែលមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍នោះហើយ រមែងដល់នូវការអស់ទៅ នៃអាសវៈទាំងឡាយ បើបែរជាមិនបានដល់នូវការអស់ទៅនៃអាសវៈទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរចំពោះធម៌នោះ ព្រោះសេចក្តីរីករាយចំពោះធម៌នោះ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯង ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុលុះកន្លងបង់នូវអាកាសានញ្ចាយតនៈ ដោយសព្វអន្លើហើយ ក៏ចូលកាន់វិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ ភិក្ខុនោះពិចារណានូវពួកធម៌ គឺវេទនា ។បេ។ ដើម្បីលះបង់នូវសំយោជនៈទាំងឡាយ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុលុះកន្លងបង់នូវវិញ្ញាណញ្ចាយតនៈ ដោយសព្វអន្លើហើយ ទើបចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា អ្វីបន្តិចបន្តួចមិនមាន ។ ភិក្ខុនោះរមែងពិចារណាឃើញច្បាស់ នូវពួកធម៌ គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងខណៈដែលចូលសមាបត្តិនោះថា ជា

របស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាព្រួញ ជាសេចក្តីមិនសប្បាយ ជាអាពាធ ជារបស់ដទៃ ជារបស់វិនាស ជារបស់សាបសូន្យ ជារបស់មិនស្តាប់បង្គាប់ចិត្ត ។ ភិក្ខុនោះ រមែងដោះចិត្តចាកធម៌ទាំងនោះបាន លុះភិក្ខុនោះបានដោះចិត្តចាកធម៌ទាំងនោះហើយ រមែងបង្អោនចិត្តទៅក្នុងអមតធាតុថា ការរម្ងាប់បង់នូវសង្ខារទាំងពួង ការលះបង់នូវឧបធិក្កិលេសទាំងពួង ការអស់ទៅនៃតណ្ហា សេចក្តីនឿយណាយ សេចក្តីរលត់តណ្ហាគឺព្រះនិព្វានណា ព្រះនិព្វាននុ៎ះ ជារបស់ល្អិត ព្រះនិព្វាននុ៎ះ ជារបស់ប្រសើរល្អ ។ ភិក្ខុនោះបានឋិតនៅក្នុងវិបស្សនាដែលមានព្រះត្រៃលក្ខណ៍ជាអារម្មណ៍ រមែងដល់នូវការអស់ទៅនៃអាសវៈទាំងឡាយ បើបែរជាមិនបានដល់នូវការអស់ទៅនៃអាសវៈទាំងនោះទេ ក៏គង់បានទៅកើតជាឱបបាតិកៈកំណើត ព្រោះសេចក្តីត្រេកអរក្នុងធម៌នោះ ព្រោះសេចក្តីរីករាយក្នុងធម៌នោះ ព្រោះការអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះមកវិញឡើយ ។ ម្នាលអានន្ទ មគ្គនេះឯង បដិបទានេះឯងហើយ ដែលប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ ។

[ ១៥៩ ] ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើមគ្គនុ៎ះ បដិបទានុ៎ះ ប្រព្រឹត្តទៅដើម្បីលះបង់នូវឱរម្ភាគិយសំយោជនៈទាំង ៥ បាន កាលបើដូច្នេះ ចុះហេតុដូចម្តេច បានជាក្នុងសាសនានេះ មានពួកភិក្ខុខ្លះ ជាចេតោវិមុត្តិ ពួកភិក្ខុខ្លះ ជាបញ្ញាវិមុត្តិ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ក្នុងសាសនានោះឯង តថាគតពោលថា ពួកភិក្ខុទាំងនោះ មានឥន្ទ្រិយផ្សេងៗ គ្នា ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏រីករាយ ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មហាមាលុង្ក្យោវាទសូត្រជាគម្រប់ ៤

# អដ្ឋកថា

# មហាមាលុង្ក្យោវាទសូត្រ

[ ១៥៣ ] មហាមាលុង្ក្យោវាទសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **ឱរម្ភាគិយានិ** សេចក្តីថា សំយោជនៈដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ញុាំងសត្វឲ្យប្រព្រឹត្តទៅ គឺកើតក្នុងភព ។ បទថា **សំយោជនានិ** គឺ ចំណង ។

[ ១៥៤ ] បទថា **កស្ស ខោ នាម** សេចក្តីថា អ្នកចាំឱរម្ភាគិយសំយោជនៈដែលតថាគតសម្តែងដល់អ្នកណា គឺដល់ទេវតា ឬដល់មនុស្ស ។ អ្នកម្នាក់ឯងប៉ុណ្ណោះបានស្តាប់បុគ្គលណាមួយដទៃ ឬមិនបានស្តាប់ៗ បទថា **អនុសេតិ** សេចក្តីថា រមែងជាប់តាម គឺឈ្មោះថា រមែងដេកត្រាំ ព្រោះមិនទាន់លះបាន ។ ឈ្មោះថា សំយោជនៈ គឺការដេកត្រាំ ។ មុ៉ាងទៀត ក្នុងបទនេះ ព្រះមានព្រះភាគត្រាស់ដល់សំយោជនៈ ។ សូម្បីព្រះថេរៈ ក៏ព្យាករសំយោជនៈប៉ុណ្ណោះ កាលបើដូច្នោះ ព្រះមានព្រះភាគទ្រង់លើកទោសក្នុងវាទៈរបស់អ្នកណា ។ ព្រោះហេតុអ្វីទើបទ្រង់លើកទោសព្រះថេរៈនោះទៅវិញ ។ ព្រោះព្រះថេរៈប្រកាន់លទ្ធិយ៉ាងនោះ ។ ព្រោះនេះជាលទ្ធិនៃព្រះថេរៈនោះ ។ ព្រះថេរៈជាបុគ្គលឈ្មោះថា ប្រកបដោយកិលេសក្នុងខណៈប្រព្រឹត្តនោះឯង មិនប្រកបក្នុងខណៈក្រៅអំពីនេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់លើកទោសដល់ព្រះថេរៈនោះ ។

លំដាប់នោះ ព្រះអានន្ទគិតថា ព្រះមានព្រះភាគ ទ្រង់ផ្តើមធម្មទេសនា ដោយ

ធម្មតារបស់ព្រះអង្គថា តថាគតនឹងសម្តែងធម៌ដល់ភិក្ខុសង្ឃ ។ ភិក្ខុសូម្បីមិនឈ្លាសនេះ នឹងពោលបន្ទាប់ក្នុងព្រះធម្មទេសនានោះ ណ្ហើយចុះ អញនឹងទូលអង្វរព្រះមានព្រះភាគ ហើយឲ្យទ្រង់សម្តែងធម៌ដល់ភិក្ខុទាំងឡាយ ព្រះអានន្ទបានធ្វើយ៉ាងនោះហើយ ។ ដើម្បីសម្តែងសេចក្តីនោះ ទើបលោកពោលថា **ឯវំ វុត្តេ អាយស្មា អានន្ទោ** ដូច្នេះ ។

[ ១៥៥ ] ក្នុងបទទាំងនោះ បទថា **សក្កាយទិដ្ឋិ បរិយុដ្ឋិតេន** សេចក្តីថា មានចិត្តដែលសក្កាយទិដ្ឋិចោមរោមហើយ គឺ ដែលសក្កាយទិដ្ឋិប្រកាន់ទុកគ្របសង្កត់ហើយ ។ បទថា **សក្កាយទិដ្ឋិ បរេតេន** សេចក្តីថា ដែលសក្កាយទិដ្ឋិគ្របសង្កត់ហើយ គឺដែលសក្កាយទិដ្ឋិតាមទៅហើយ ។ បទថា **និស្សរណំ** សេចក្តីថា ឧបាយជាគ្រឿងរលាស់ចេញ បានដល់ និព្វាន និព្វាន ឈ្មោះថា ឧបាយជាគ្រឿងរលាស់ចេញនៃទិដ្ឋិ ។ មិនដឹងឧបាយជាគ្រឿងរលាស់ចេញនោះតាមសេចក្តីពិត ។ បទថា **អប្បដិវិនីតា** គឺដែលបុថុជ្ជនបន្ទោបង់មិនបានហើយ នាំចេញទៅមិនបានហើយ ។ បទថា **ឱរម្ភាគិយសំយោជនំ** បានដល់ សំយោជនៈដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ធម៌ចំណែកសមានអត្ថងាយទាំងអស់ហើយ ។

ម្យ៉ាងទៀត ក្នុងសូត្រនេះ ព្រោះបាលីថា **សានុសយា បហីយតិ** សេចក្តីថា សក្កាយទិដ្ឋិ ព្រមដោយអនុស័យ ដែលព្រះអរិយបុគ្គលលះបានហើយ អាចារ្យពួកខ្លះពោលថា សំយោជនៈម្យ៉ាង អនុស័យម្យ៉ាង ។ ដូច

កាលពោលថា កត្ត ព្រមទាំងសម្ព ។ សម្ពម្យ៉ាងដទៃអំពីកត្តយ៉ាងណា លទ្ធិរបស់អាចារ្យទាំងនោះ អនុស័យគប្បីដទៃអំពីសក្កាយទិដ្ឋិដែលចោមរោម ព្រោះព្រះបាលីថា **សានុសយា** ព្រមដោយអនុស័យក៏យ៉ាងនោះ ។ អាចារ្យទាំងនោះ បដិសេធដោយបទជាដើមថា **សសីសំ ចារុបេត្វា** គ្របរហូតដល់ក្បាល ។ ព្រោះបុគ្គលដទៃទៅអំពីសីសៈរមែងមិនមាន ។

បើដូច្នោះ គប្បីមានពាក្យសួរថា ឧបមាថា សំយោជនៈយ៉ាងនោះ អនុស័យមិនជាយ៉ាងនោះ កាលបើដូច្នោះ ព្រះមានព្រះភាគ ទ្រង់លើកព្រះថេរៈឧបមាដោយកូនក្មេង ក៏ជាការប្រារព្ធមិនល្អទៅហើយឬ ។ មិនមែនលើកឡើងមិនល្អទេ ព្រោះបទនេះថា **ឯវំ លទ្ធិកត្តា** ព្រោះមានលទ្ធិយ៉ាងនេះពោលពិស្តារហើយ ។ ដូច្នោះ កិលេសនោះ ឈ្មោះថា សំយោជនៈ ព្រោះជាគ្រឿងចង ឈ្មោះថា អនុស័យ ព្រោះលះមិនបាន ។ ព្រោះហេតុនោះគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា **សានុសយា បហីយតិ** សក្កាយទិដ្ឋិ ព្រមដោយអនុស័យដែលព្រះអរិយបុគ្គលលះបង់បាន ។ សំដៅសេចក្តីនេះ ។

[ ១៥៦ ] ក្នុងបទថា **តចំ ឆេត្វា** ជាដើម បទនេះសម្តែងការប្រៀបធៀប ។ គប្បីឃើញថា សមាបត្តិ ដូចការស្ទោះសម្បក ។ គប្បីឃើញវិបស្សនា ដូចការប្រាសស្រាយ គប្បីឃើញមគ្គ ដូចការកាប់យកខ្លឹម ។ ម្យ៉ាងទៀត បដិបទាលាយដោយលោកិយ និងលោកុត្តរនោះឯង ទើបគួរ ។ បទថា **ឯវមេតេ ទដ្ឋព្វា** គឺគប្បីឃើញបុគ្គលបែបនោះ ដូច្នោះ ។

[ ១៥៧ ] បទថា **ឧបធិវិវេកា** គឺព្រោះឧបធិវិវេក ។ ដោយបទនេះ លោកពោលដល់ការស្ងាត់ចាកកាមគុណ ៥ ។ បទថា **អកុសលានំ ធម្មានំ បហានា** សេចក្តីថា ព្រោះលះអកុសលធម៌បាន លោកពោលដល់ការលះនីវរណៈ ។ បទថា **កាយទុដ្ឋុល្លានំ បដិបស្សទ្ធិយា** លោកពោលដល់ការរម្ងាប់នូវការប្រូសកាយ ។ បទថា **វិវិច្ចេវ កាមេហិ** គឺជាអ្នកវៀរចាកកាមដោយឧបធិវិវេក ។ បទថា **វិវិច្ចអកុសលេហិ** សេចក្តីថា ជាអ្នកវៀរចាកអកុសល ដោយការលះអកុសលធម៌ និងដោយការរម្ងាប់ការ ខ្ជិលប្រូស ។ បទថា **យទេវ តត្ថ ហោតិ** សេចក្តីថា ធម្មជាតមានរូបជាដើមដែលតាំងនៅក្នុងសមាបត្តិ រមែងមានក្នុងខាងក្នុងសមាបត្តិនោះ និងក្នុងខណៈនៃសមាបត្តិ ។ បទថា **តេ ធម្មេ** បានដល់ ធម៌ទាំងនោះ មានរូបជាដើម ដូចពោលហើយដោយន័យថា **រូបគតំ** ជាដើម ។ បទថា **អនិច្ចតោ** សេចក្តីថា ដោយភាពជារបស់មិនទៀង គឺដោយភាពជារបស់ទៀងក៏ទេ ។ បទថា **ទុក្ខតោ** សេចក្តីថា ដោយភាពជាទុក្ខ គឺដោយភាពជាសុខក៏ទេ ។ គប្បីជ្រាបក្នុងបទថា **រោគតោ** ជាដើមដូចតទៅនេះ ឈ្មោះថា រោគ ព្រោះអត្ថថា ឈឺចាប់ ។ ឈ្មោះថា បូស ព្រោះអត្ថថា មានទោសខាងក្នុង ។ ឈ្មោះថា ជាសរ ព្រោះអត្ថថា ចូលទៅចាក់ទម្លុះ និងព្រោះអត្ថថា ឲ្យកើតទុក្ខ ។ ឈ្មោះថា ជាសេចក្តីមិនសប្បាយ ព្រោះអត្ថថា ជាទុក្ខ ។ ឈ្មោះថា អាពាធ ព្រោះអត្ថថា ជារោគ ។ ឈ្មោះថា ជារបស់ដទៃ ព្រោះអត្ថថា មិនមែនជារបស់ខ្លួន ។ ឈ្មោះថា ជារបស់វិនាស ព្រោះអត្ថថា បែកធ្លាយទៅ ។ ឈ្មោះថា ជារបស់

សាបសូន្យ ព្រោះអត្ថថា មិនមែនសត្វ ។ ឈ្មោះថាជារបស់មិនស្តាប់បង្គាប់ ព្រោះអត្ថថា មិនជាតួខ្លួន ។

ក្នុងបទទាំងនោះ លោកពោលដោយអនិច្ចលក្ខណៈ ដោយបទ ២ គឺ **អនិច្ចតោ** និង **បលោកតោ** ។ លោកពោលដល់ទុក្ខលក្ខណៈដោយបទ ៦ មាន **ទុក្ខតោ** ជាដើម ។ លោកពោលដល់អនត្តលក្ខណៈដោយបទ ៣ គឺ **បរតោ សុញ្ញតោ** និង **អនត្តតោ** ។ បទថា **សោ តេហិ ធម្មេហិ** សេចក្តីថា លោករមែងដកចិត្តអំពីធម៌ គឺខន្ធ ៥ ខាងក្នុងសមាបត្តិ ដែលលើកឡើងកាន់ត្រៃលក្ខណ៍ ដែលខ្លួនឃើញហើយទាំងនោះយ៉ាងនេះ ។ បទថា **ចិត្តំ បដិវាបេតិ** គឺរមែងលែងចិត្ត នាំចិត្តចេញទៅ ។ បទថា **ឧបសំហរតិ** សេចក្តីថា បង្អោនចិត្តទៅក្នុងអមតធាតុ ដែលជាអសង្ខតៈ យ៉ាងនេះថា វិបស្សនាចិត្ត ជាការរម្ងាប់ដ៏ស្ងប់ ដោយការស្តាប់ ការសរសើរ ការរៀន និងការបញ្ញត្តិ ។ រមែងមិនពោលយ៉ាងនេះថា មគ្គចិត្តជា ការស្ងប់ ជាការប្រណីត ដោយការធ្វើនិព្វានឲ្យជាអារម្មណ៍ ។ម្យ៉ាងទៀត មាន អធិប្បាយថា កាលចាក់ធ្លុះនូវធម្មជាតិនោះដោយអាការនេះ រមែងបង្អោន ចិត្តទៅក្នុងអមតធាតុនោះ ។

បទថា **សោ តត្ថ ឋិតោ** សេចក្តីថា លោកតាំងនៅក្នុងវិបស្សនា ដែលមានត្រៃលក្ខណ៍ជាអារម្មណ៍នោះ ។ បទថា **អាសវានំ ខយំ បាបុណាតិ** សេចក្តីថា រមែងសម្រេចធម៌ដែលអស់ទៅនៃអាសវៈទាំងឡាយ គឺចម្រើនមគ្គ ៤ ដោយលំដាប់ ហើយទើបសម្រេច ។ បទថា **តេនេវ**

**ធម្មរាគេន** សេចក្តីថា ព្រោះត្រេកអរ ក្នុងធម៌នោះ គឺព្រោះការពេញចិត្ត ត្រេកអរក្នុងធម៌គឺសមថៈ និងវិបស្សនា ។ ពិតហើយ កាលអាចកាន់យកនូវការពេញចិត្ត និងការត្រេកអរក្នុងសមថៈ និងវិបស្សនា ដោយប្រការទាំងពួង រមែងសម្រេចអរហត្ត កាលមិនអាច រមែងជាព្រះអនាគាមី ។

[ ១៥៨ ] បទថា **យទេវ តត្ថ ហោតិ វេទនាគតំ** គឺវេទនារមែងមានក្នុងសមាបត្តិនោះ ក្នុងបទនេះ លោកមិនកាន់យករូប ។ ព្រោះហេតុអ្វី ព្រោះកន្លងទៅហើយ ។ ពិតហើយ ភិក្ខុនេះចូលដល់រូបាវចរជ្ឈានក្នុងខាងដើម ហើយឈានកន្លងរូប ជាអ្នកចូលដល់អរូបាវចរសមាបត្តិ ព្រោះហេតុនោះ ទើបឈានកន្លងរូប ទៅដោយអំណាចសមថៈ ។ កាលពិចារណារូបខាងដើមហើយ ឈានកន្លងរូបនោះ ឥឡូវនេះរមែងពិចារណាអរូប ព្រោះហេតុនោះ ទើបរូបឈានកន្លងទៅ ដោយអំណាចវិបស្សនា តែក្នុងអរូបរមែងមិនមានរូប ដោយប្រការទាំងពួង ព្រោះហេតុនោះ សូម្បីលោកសំដៅដល់អរូបនោះ ក្នុងទីនេះ ក៏មិនកាន់យករូប ។ មិនកាន់យកដោយប្រពៃ ។

បទថា **អថ កិញ្ចរហិ** កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ។ ព្រះអានន្ទទូលសួរថា ខ្ញុំព្រះអង្គសូមទូលសួរថា ព្រោះហេតុអ្វី ។ ព្រះថេរៈមិនមានសេចក្តីសង្ស័យក្នុងសេចក្តីនេះថាធុរៈ គឺភាពជាបុគ្គលមានឯកគ្គតាចិត្ត តែងមានដល់ភិក្ខុ ដែលទៅដោយអំណាចសមថៈ ភិក្ខុនោះឈ្មោះថា ជាចេតោវិមុត្តិ ធុរៈគឺបញ្ញា រមែងមានដល់ភិក្ខុដែលទៅដោយអំណាចនៃវិបស្សនា ។ ភិក្ខុនោះឈ្មោះថា ជាបញ្ញាវិមុត្តិ ។ ព្រះថេរៈទូលសួរថា ភិក្ខុនេះជាបុរសគួរទូន្មានទាំងអស់ តែកាលភិក្ខុទាំងឡាយទៅដោយអំណាច សមថៈ ១ រូប ជាចេតោវិមុត្តិ ។

កាលទៅដោយអំណាចនៃវិបស្សនា ១ រូបឈ្មោះថាជាបញ្ញាវិមុត្តិ ១ រូបជាចេតោវិមុត្តិ ។ អ្វីជាហេតុក្នុងសេចក្តីនេះ ។ បទថា **ឥន្ទ្រិយវេមត្តំ វទាមិ** សេចក្តីថា តថាគតពោលការផ្សេងគ្នានៃឥន្ទ្រិយ ។ លោកអធិប្បាយថា ម្នាលអានន្ទ អ្នកបំពេញបារមី ១០ ហើយ មិនទាន់សម្រេចសព្វញ្ញុតញ្ញាណ ។ ព្រោះហេតុនោះ ទើបសព្វញ្ញុតញ្ញាណនោះមិនប្រាកដដល់អ្នក ។ តែតថាគតចាក់ធ្លុះហើយ ដោយហេតុនោះ ទើបសព្វញ្ញុតញ្ញាណនោះប្រាកដដល់តថាគត ។ ការផ្សេងគ្នានៃឥន្ទ្រិយជាហេតុក្នុងសេចក្តីនេះឯង ព្រោះកាលភិក្ខុទាំងឡាយទៅដោយអំណាចនៃសមថធុរៈ គឺភាពជាអ្នកមានចិត្តមូលតែមួយ ទើបមានដល់ភិក្ខុមួយរូប ភិក្ខុនោះឈ្មោះថា ជាចេតោវិមុត្តិ ។ ធុរៈ គឺបញ្ញា រមែងមានដល់ភិក្ខុមួយរូប ។ ភិក្ខុនោះឈ្មោះថា ជាបញ្ញាវិមុត្តិ ។ម្យ៉ាងទៀត កាលភិក្ខុទាំងឡាយទៅដោយអំណាចវិបស្សនាធុរៈ គឺបញ្ញារមែងមានដល់ភិក្ខុមួយរូប ភិក្ខុនោះឈ្មោះថា ជាបញ្ញាវិមុត្តិ ។ ធុរៈ គឺភាពជាបុគ្គលមានចិត្តមូលតែមួយ រមែងមានដល់ភិក្ខុមួយរូប ។ ភិក្ខុនោះ ឈ្មោះថា ចេតោវិមុត្តិ ។ ព្រះអគ្គសាវកទាំង ២ សម្រេចព្រះអរហត្តដោយ ធុរៈ គឺសមថៈនិងវិបស្សនា ។ ក្នុងលោកទាំង ២ អង្គនោះ ព្រះធម្មសេនាបតី ជាបញ្ញាវិមុត្តិ ។ ព្រះមហាមោគ្គល្លានជាចេតោវិមុត្តិ ។ គប្បីជ្រាបថា ការផ្សេងគ្នានៃឥន្ទ្រិយជាហេតុក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ដូច្នេះឯង ។ ៚

**អដ្ឋកថាមហាមាលុង្ក្យោវាទសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ភទ្ទាលិសូត្រទី ៩

[ ១៦០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតតែងឆាន់ភោជន ដែលគួរបរិភោគតែមួយពេល ម្នាលភិក្ខុទាំងឡាយ កាលតថាគតឆាន់ភោជន ដែលគួរបរិភោគតែមួយពេល ក៏បានដឹងច្បាស់នូវភាពមិនមានអាពាធ មិនមានទុក្ខ ការងើបក្រោកដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកមកណោះ ចូរបរិភោគភោជនដែលគួរបរិភោគតែមួយពេលចុះ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិភោគភោជនដែលគួរបរិភោគតែមួយពេលហើយ មុខជានឹងបានដឹងច្បាស់នូវភាពមិនមានអាពាធ មិនមានទុក្ខ ការងើបក្រោកដោយរហ័ស កម្លាំងកាយ និងការនៅសប្បាយដោយឥរិយាបថទាំង ៤ ។

[ ១៦១ ] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះភទ្ទាលិមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងបរិភោគភោជន ដែលគួរបរិភោគ តែមួយពេលបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើខ្ញុំព្រះអង្គបរិភោគភោជន

ដែលគួរបរិភោគ តែមួយពេលហើយ សេចក្តីសាប់សល់ក៏មាន សេចក្តីក្តៅក្រហាយក៏មាន ។ ព្រះអង្គត្រាស់ថា ម្នាលភទ្ទាលិ បើដូច្នោះ គេនិមន្តអ្នកឆាន់ក្នុងទីណា អ្នកគប្បីបរិភោគតែបន្តិចបន្តួច ឬរំលែកយកមក បរិភោគតែបន្តិចបន្តួច ក្នុងទីនោះ ម្នាលភទ្ទាលិ កាលបើអ្នកបរិភោគយ៉ាងនេះហើយ ក៏គង់ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ភទ្ទាលិក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាចនឹងបរិភោគយ៉ាងនេះបានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលបើខ្ញុំព្រះអង្គបរិភោគយ៉ាងនេះហើយ សេចក្តីសាប់សល់ក៏មាន សេចក្តីក្តៅក្រហាយក៏មាន ។ គ្រាកាលដែលព្រះមានព្រះភាគ កំពុងបញ្ញត្តនូវសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទាននូវសិក្ខា ព្រះភទ្ទាលិមានអាយុ ក៏ក្រាបទូលនូវសេចក្តីមិនអាចធ្វើតាមបាន ។ លំដាប់នោះឯង ព្រះភទ្ទាលិមានអាយុ លែងឲ្យជួបព្រះភក្ត្រព្រះមានព្រះភាគ ពេញ ៣ ខែគត់ លែងបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដោយដាច់ស្រឡះ ។

[ ១៦២ ] សម័យនោះឯង ភិក្ខុទាំងឡាយមានប្រមាណច្រើនរូប នាំគ្នាធ្វើចីវរកម្ម ថ្វាយព្រះមានព្រះភាគ លុះព្រះមានព្រះភាគ មានចីវរសម្រេចហើយ កន្លង ៣ ខែទៅ ព្រះអង្គបម្រុងនឹងស្តេចចេញទៅកាន់ចារិក ។ គ្រានោះឯង ព្រះភទ្ទាលិមានអាយុ បានចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល មួយអន្លើដោយពួកភិក្ខុទាំងនោះ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទាលិមានអាយុ អង្គុយក្នុងទីសមគួរហើយ

ភិក្ខុទាំងនោះ ក៏នាំគ្នានិយាយយ៉ាងនេះថា ម្នាលអាវុសោភទ្ទាលិ ចីវរកម្មនេះ ឯង ដែលយើងទាំងឡាយធ្វើថ្វាយព្រះមានព្រះភាគ លុះព្រះមានព្រះភាគមាន ចីវរកម្មសម្រេចហើយ កន្លង ៣ ខែទៅ ទ្រង់នឹងស្តេចចេញទៅកាន់ចារិក ។ ម្នាលភទ្ទាលិមានអាយុ យើងសូមដាស់តឿន ចូរលោកយកចិត្តទុកដាក់នឹង កំហុស ( ចំពោះសិក្ខាបទដែលព្រះសាស្តាទ្រង់បញ្ញត្ត ) នុ៎ះ ឲ្យប្រពៃចុះ អ្នក កុំធ្វើឲ្យលំបាក ក្នុងកាលជាខាងក្រោយឡើយ ។ ព្រះភទ្ទាលិមានអាយុ ក៏ ទទួលពាក្យពួកភិក្ខុទាំងនោះថា ករុណាអាវុសោ ដូច្នេះហើយ ក៏ចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចទើប អង្គុយក្នុងទីសមគួរ ។ លុះព្រះភទ្ទាលិមានអាយុអង្គុយក្នុងទីសមគួរហើយ ទើប ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទោស គ្របសង្កត់ខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិន ឈ្លាស ព្រោះកាលព្រះមានព្រះភាគកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃ សមាទានសិក្ខា ខ្ញុំព្រះអង្គក៏បានក្រាបទូលនូវសេចក្តីមិនអាចធ្វើតាមបាន បពិត្រ ព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអត់ទោសចំពោះកំហុស តាមទោស របស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត ។

[ ១៦៣ ] ព្រះអង្គទ្រង់ត្រាស់ថា អើ ភទ្ទាលិ ទោសគ្របសង្កត់អ្នក ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាសពិតមែនហើយ ព្រោះកាលដែលតថាគត កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកបានប្រាប់នូវសេចក្តីមិនអាចធ្វើតាមបាន ។ ម្នាលភទ្ទាលិ អ្នកមិនបានដឹង

ហេតុថា ព្រះមានព្រះភាគ គង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ដឹងអាត្មាអញថា ភិក្ខុឈ្មោះកឡាលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលកឡាលិ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលកឡាលិ អ្នកមិនបានដឹងហេតុថា ភិក្ខុច្រើនរូប នៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បីភិក្ខុទាំងនោះ ក៏គង់ដឹងអាត្មាអញថា កឡាលិភិក្ខុមិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលកឡាលិ នេះឯង ជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលកឡាលិ អ្នកមិនបានដឹងហេតុថា ពួកភិក្ខុនីមានប្រមាណច្រើនរូប នៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បីភិក្ខុនីទាំងនោះ គង់ដឹងអាត្មាអញថា កឡាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ ម្នាលកឡាលិ នេះឯង ជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលកឡាលិ អ្នកមិនបានដឹងហេតុថា ពួកឧបាសកមានប្រមាណច្រើននាក់ដែលនៅអាស្រ័យក្នុងក្រុងសាវត្ថី សូម្បីឧបាសកទាំងនោះ ក៏គង់ដឹងអាត្មាអញថា កឡាលិភិក្ខុ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ នេះឯងជាហេតុដែលអ្នកមិនបានដឹង ម្នាលកឡាលិ អ្នកមិនបានដឹងហេតុថា ពួកឧបាសិកាច្រើនគ្នាដែលអាស្រ័យនៅក្នុងក្រុងសាវត្ថី សូម្បីឧបាសិកាទាំងនោះ ក៏គង់ដឹងអាត្មាអញថា កឡាលិភិក្ខុ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ម្នាលកឡាលិ អ្នកមិនបានដឹងហេតុថា ពួកសមណៈឬព្រាហ្មណ៍ ជាតិរ្ថិយផ្សេងៗ មានប្រមាណច្រើនរូប ដែលនៅចាំវស្សាក្នុងក្រុងសាវត្ថី សូម្បី

ពួកអ្នកទាំងនោះ ក៏គង់ដឹងអាត្មាអញថា ភទ្ទាលិភិក្ខុជាសាវ័ករបស់ព្រះសមណគោតម ជាព្រះថេរៈមួយអង្គ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា ដូច្នេះឡើយ នេះឯងជាហេតុដែលអ្នកមិនបានដឹង ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទោសគ្របសង្កត់នូវខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ព្រោះកាលដែលព្រះមានព្រះភាគ កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា ខ្ញុំព្រះអង្គបាន ក្រាបទូលនូវសេចក្តីមិនអាចធ្វើតាមបាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អត់ទោសចំពោះកំហុស តាមទោស របស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅ ។

[ ១៦៤ ] ព្រះអង្គទ្រង់ត្រាស់ថា អើ ភទ្ទាលិ ទោសគ្របសង្កត់អ្នកដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ពិតមែនហើយ ព្រោះកាលដែលតថាគត កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកក៏បានប្រាប់នូវសេចក្តីមិនអាចនឹងធ្វើតាមបាន ។ ម្នាលភទ្ទាលិ អ្នកសម្គាល់ហេតុនោះថាដូចម្តេច ភិក្ខុក្នុងសាសនានេះ ជាឧភតោភាគវិមុត្តិ តថាគតនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមកចុះ ស្ពានរបស់តថាគតមានក្នុងភក់ ដូច្នេះ តើភិក្ខុនោះគប្បីទៅខ្លួនឯង ឬប្រើអ្នកដទៃឲ្យប្រានកាយរបស់ខ្លួន ឬគប្បីពោលប្រកែកថាទេ ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនគួរទេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភទ្ទាលិ អ្នកសម្គាល់ហេតុនោះថាដូចម្តេច ភិក្ខុក្នុងសាសនានេះ ជាបញ្ញាវិមុត្តបុគ្គល ជា

កាយសក្ខីបុគ្គល ជាទិដ្ឋិប្បត្តបុគ្គល ជាសទ្ធាវិមុត្តបុគ្គល ជាធម្មានុសារីបុគ្គល ជាសទ្ធានុសារីបុគ្គល តថាគតនិយាយនឹងបុគ្គលនោះ យ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមកចុះ ស្ពានរបស់តថាគតមានក្នុងភក់ ដូច្នេះ តើភិក្ខុនោះគប្បីដើរទៅខ្លួនឯង ឬប្រើអ្នកដទៃឲ្យប្រាទកាយរបស់ខ្លួន ឬគប្បីពោលប្រកែកថាទេ ។ ព្រះភទ្ទាលិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនគួរទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ អ្នកសម្គាល់ហេតុនោះដូចម្តេច ម្នាលភទ្ទាលិ ក្នុងសម័យនោះ អ្នកបានឧភតោភាគវិមុត្តបុគ្គល ឬបានជាបញ្ញាវិមុត្តបុគ្គល ជាកាយសក្ខីបុគ្គល ជាទិដ្ឋប្បត្តបុគ្គល ជាសទ្ធាវិមុត្តបុគ្គល ជាធម្មានុសារីបុគ្គល ជាសទ្ធានុសារីបុគ្គល ដែរឬ ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរនុ៎ះ មិនមានទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ចុះមានតែក្នុងសម័យនោះ អ្នកជាបុគ្គលសោះសូន្យ ជាមនុស្សទទេ មានកំហុសទេឬ ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះមែនហើយ បពិត្រព្រះអង្គដ៏ចម្រើន ទោសគ្របសង្កត់នូវខ្ញុំព្រះអង្គ ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ព្រោះកាលដែលព្រះមានព្រះភាគកំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា ខ្ញុំព្រះអង្គក៏ក្រាបទូលនូវសេចក្តីមិនអាចនឹងធ្វើតាមបាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់អត់ទោសចំពោះកំហុស តាមកំហុសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅទៀត ។

[ ១៦៥ ] ព្រះអង្គទ្រង់ត្រាស់ថា អើភទ្ទាលិ ទោសគ្របសង្កត់នូវអ្នក

ដែលជាមនុស្សពាល ជាមនុស្សល្ងង់ ជាមនុស្សមិនឈ្លាស ពិតមែនហើយ ព្រោះកាលដែលតថាគត កំពុងបញ្ញត្តសិក្ខាបទ កំពុងឲ្យភិក្ខុសង្ឃសមាទានសិក្ខា អ្នកបានប្រាប់នូវសេចក្តីមិនអាចនឹងធ្វើតាមបាន ម្នាលភទ្ទាលិ កាលណាអ្នកបានឃើញទោសតាមទោសហើយ ត្រឡប់មកធ្វើតាមធម៌គឺសូមខមាទោស តថាគតនឹងអត់ទោសចំពោះកំហុសនោះដល់អ្នក ម្នាលភទ្ទាលិ ព្រោះថាបុគ្គលដែលបានឃើញទោសតាមទោស ហើយត្រឡប់មកធ្វើតាមធម៌គឺសូមខមាទោសវិញ ទើបដល់នូវការសង្រួមតទៅ នេះឯងជាសេចក្តីចម្រើន ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ១៦៦ ] ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងសាសនានេះ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តាទេ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ គប់រកសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំគុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង ( កាលបើនៅក្នុងទីដូច្នេះ ) មុខជាអាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ។ ភិក្ខុនោះ ក៏គប់រកសេនាសនៈស្ងាត់ គឺ ព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង កាលបើភិក្ខុនោះចេញទៅនៅដូច្នោះហើយ ព្រះសាស្តាក៏តិះដៀលពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងបានគយគន់ហើយក៏តិះដៀល ទេវតាទាំងឡាយក៏តិះដៀល ទាំងខ្លួនឯង ក៏តិះដៀលខ្លួនឯង បុគ្គលនោះ កាលបើព្រះសាស្តាតិះដៀល ពួកសព្រហ្មចារី

បុគ្គលជាអ្នកចេះដឹង បានគយគន់ហើយក៏តិះដៀល ពួកទេវតាក៏តិះដៀលហើយ ទាំងខ្លួនឯងក៏តិះដៀលខ្លួនឯងហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេស ដ៏ក្រៃលែងជាងមនុស្សធម៌មិនបានឡើយ ដំណើរនុ៎ះ តើព្រោះហេតុអ្វី ម្នាលកទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ មិនបានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តានុ៎ះឯង ដោយពិត ។

[ ១៦៧ ] ម្នាលកទ្ទាលិ មួយទៀត ភិក្ខុពួកខ្លះក្នុងសាសនានេះ បានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញគប់រកនូវសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង គួរតែអាត្មាអញ ធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ អាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ ។ ភិក្ខុនោះ ក៏គប់រកសេនាសនៈស្ងាត់ គឺ ព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង កាលបើភិក្ខុនោះ ចេញទៅនៅដូច្នេះហើយ ព្រះសាស្តាក៏មិនតិះដៀល ពួកសព្រហ្មចារីបុគ្គល ជាអ្នកចេះដឹង បានគយគន់ហើយ ក៏មិនតិះដៀល ពួកទេវតាក៏មិនតិះដៀល ទាំងខ្លួនឯងក៏មិនតិះដៀលខ្លួនឯង បុគ្គលនោះ កាលបើព្រះសាស្តាមិនតិះដៀល ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹង បានគយគន់ហើយ ក៏មិនតិះដៀល ពួកទេវតាក៏មិនតិះដៀល ទាំងខ្លួនឯងក៏មិនតិះដៀលខ្លួនឯងហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរអាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌បាន ។

ភិក្ខុនោះ រមែងស្ងប់ស្ងាត់ចាកកាម ស្ងប់ស្ងាត់ចាកអកុសលធម៌ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានតែបីតិនិងសុខដែលកើតអំពីវិវេក ដំណើរនុ៎ះ តើព្រោះហេតុអ្វី ម្នាលភគ្គុលិ ព្រោះហេតុតែភិក្ខុនោះ បានបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ ម្នាលភគ្គុលិ មួយទៀត ភិក្ខុព្រោះបានរម្ងាប់នូវវិតក្កៈនិងវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាទីផូរផង់ក្នុងសន្តាន មានភាពនៃចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិប៉ុណ្ណោះ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភគ្គុលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ ម្នាលភគ្គុលិ មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញនូវសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ ម្នាលភគ្គុលិ មួយទៀត ភិក្ខុព្រោះលះបង់សេចក្តីសុខ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភគ្គុលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។

[ ១៦៨ ] កាលបើចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនៃកម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ភិក្ខុនោះ រមែងបង្អោនចិត្តទៅរកបុព្វេនិវាសានុស្សតិញ្ញាណ ។ ភិក្ខុនោះ រមែងរឭកឃើញនូវជាតិ ដែលធ្លាប់អាស្រ័យនៅក្នុងភពមុនជាច្រើនជាតិ គឺរឭកឃើញមួយ

ជាតិ ។បេ។ រឭកឃើញនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងភពមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តាយ៉ាងនោះឯង ។ កាលបើចិត្តខាប់ខ្ជួន បរិសុទ្ធ ផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារ ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅរកប្រាជ្ញាជាគ្រឿងដឹងនូវចុតិ និងបដិសន្ធិនៃពួកសត្វ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា បានឃើញសត្វទាំងឡាយ ដែលច្យុត ដែលកើត ថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនថា ឱហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ។បេ។ ហើយកើតក្នុងកំណើតអសុរកាយ នរក ។បេ។ ចំណែកខាងសត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ។បេ។ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ភិក្ខុដែលមានចក្ខុ ដូចជាទិព្វដ៏បរិសុទ្ធកន្លងបង់ចក្ខុរបស់មនុស្សធម្មតា ។បេ។ រមែងដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួនដូច្នេះឯង ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះ ជាអ្នកបំពេញសិក្ខាក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ កាលបើចិត្តខាប់ខ្ជួន បរិសុទ្ធ ផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់

គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាង នេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅរកអាសវក្ខយញ្ញាណ ។ ភិក្ខុនោះ រមែងដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខ ។បេ។ ដឹងច្បាស់តាមសេចក្តី ពិតថា នេះជាបដិបទា ជាដំណើរដើម្បីរម្ងត់នូវទុក្ខ ដឹងច្បាស់តាមសេចក្តីពិត ថា នេះជាអាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងច្បាស់តាម សេចក្តីពិតថា នេះជាបដិបទា ជាដំណើរដើម្បីរម្ងត់នៃអាសវៈ ។ កាលភិក្ខុ នោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈ ផង ចិត្តក៏រួចចាកទិដ្ឋាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចស្រឡះចាក អវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះ ប្រាជ្ញាក៏កើតមានឡើងថា ( ចិត្តរបស់ អាត្មាអញ ) រួចស្រឡះហើយ ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើ ហើយ មគ្គការនាកិច្ចដទៃដើម្បីសោឡសកិច្ចនេះ មិនមានឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភទ្ទាលិ ព្រោះហេតុតែភិក្ខុនោះជាអ្នកបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា យ៉ាងនោះឯង ។ កាលព្រះមានព្រះភាគទ្រង់ ត្រាស់យ៉ាងនេះហើយ ព្រះភទ្ទាលិមានអាយុ ក្រាបបង្គំទូលសួរព្រះមាន ព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីជាបច្ច័យ ដែល នាំឲ្យពួកភិក្ខុធ្វើការសង្កត់សង្កិនទូវភិក្ខុពួកខ្លះក្នុងសាសនានេះ បពិត្រព្រះអង្គដ៏ ចម្រើន មួយទៀត អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុមិនធ្វើការ

សង្កត់សង្កិននូវភិក្ខុពួកខ្លះ ក្នុងសាសនានេះ ។

[ ១៦៩ ] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិរឿយៗ ជាអ្នកច្រើនដោយអាបត្តិ កាលពួកភិក្ខុស្តីប្រដៅភិក្ខុនោះ ក៏ពោលបន្ថែបន្ថយពាក្យដទៃដោយពាក្យដទៃ តែងបោះពាក្យទៅខាងក្រៅ ធ្វើឲ្យប្រាកដឡើងនូវសេចក្តីក្រោធ សេចក្តីប្រទូស្តនិងសេចក្តីអាក់អន់ចិត្ត មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ញបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារលាស់ខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើ ដូច្នេះឡើយ ។ ម្នាលភទ្ទាលិ ពួកភិក្ខុមានសេចក្តីត្រិះរិះក្នុងហេតុដែលប្រដៅក្រនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ត្រូវអាបត្តិរឿយៗ ច្រើនដោយអាបត្តិ ភិក្ខុនោះ កាលពួកភិក្ខុផងគ្នាស្តីប្រដៅ ភិក្ខុនោះ ក៏ពោលបន្ថែបន្ថយពាក្យដទៃដោយពាក្យដទៃ តែងបោះពាក្យទៅខាងក្រៅ ធ្វើឲ្យប្រាកដឡើងនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្ញបរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនប្រាប់ហេតុនោះថា ខ្ញុំធ្វើ ដូច្នេះឡើយ បពិត្រលោកមានអាយុទាំងឡាយ សូមលោកទាំងឡាយ ពិចារណាមើលអធិករណ៍របស់ភិក្ខុនេះដោយឆាប់រហ័ស តាមទំនងដែលមិនបានរម្ងាប់ ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុក៏ពិចារណានូវអធិករណ៍របស់ភិក្ខុនោះ តាមទំនងដែលមិនរម្ងាប់ដោយឆាប់រហ័ស យ៉ាងនេះឯង ។ ម្នាលភទ្ទាលិ ចំណែកខាង

ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិរឿយៗ ជាអ្នកច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះក៏មិនពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត រមែងប្រព្រឹត្តវត្តដោយប្រពៃ សមប្បរោម ប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃត្រាប់ចិត្ត ដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះក្នុងហេតុដែលប្រដៅងាយនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះជាអ្នកត្រូវអាបត្តិរឿយៗ ជាអ្នកច្រើនទៅដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះ ក៏មិនបានពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបានបោះពាក្យទៅខាងក្រៅ ទាំងមិនធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត តែងប្រព្រឹត្តវត្តដោយប្រពៃ សមប្បរោម ប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ បពិត្រលោកមានអាយុទាំងឡាយ សូមលោកទាំងឡាយពិចារណាមើលអធិករណ៍របស់ភិក្ខុនេះ តាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័សយ៉ាងនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុក៏ពិចារណានូវអធិករណ៍របស់ភិក្ខុនោះ តាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័ស យ៉ាងនេះឯង ។

[ ១៧០ ] ម្នាលភទ្ទាលិ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្តងៗ ជាអ្នកមិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយ ស្តីប្រដៅ

ភិក្ខុនោះ រមែងពោលបន្ទែបន្ទប់ពាក្យដទៃ ដោយពាក្យដទៃ បោះពាក្យទៅខាងក្រៅ ធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធ សេចក្តីប្រទូស្តនិងសេចក្តីអាក់អន់ចិត្ត មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្របរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើ ដូច្នេះឡើយ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះ ក្នុងហេតុដែលប្រដៅក្រនោះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្តងៗ ជាអ្នកមិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះរមែងពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ បោះពាក្យទៅខាងក្រៅ ធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត មិនប្រព្រឹត្តវត្តដោយប្រពៃ មិនសម្របរោម មិនប្រព្រឹត្តវត្តគួរដល់កិរិយារើខ្លួនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា មិនបានប្រាប់ហេតុនោះថា ខ្ញុំធ្វើ ដូច្នេះឡើយ បពិត្រលោកទាំងឡាយមានអាយុ សូមលោកទាំងឡាយពិចារណាមើលអធិករណ៍របស់ភិក្ខុនេះ តាមទំនងដែលមិនរម្ងាប់ ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុពិចារណាអធិករណ៍ របស់ភិក្ខុនោះ តាមទំនងដែលមិនរម្ងាប់ដោយឆាប់រហ័ស យ៉ាងនេះឯង ។ ម្នាលភទ្ទាលិ ចំណែកខាងភិក្ខុពួកមួយ ក្នុងសាសនានេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្តងៗ មិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះ មិនបានពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធសេចក្តី

ប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត ប្រព្រឹត្តវត្តដោយប្រពៃ សមួបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាវេីខនចេញចាកអាបត្តិ សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា បានប្រាប់ហេតុនោះថា ខ្ញុំធ្វើ ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះក្នុងហេតុដែលប្រដៅនាយនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះ ជាអ្នកត្រូវអាបត្តិក្នុងកាលម្តងៗ មិនច្រើនដោយអាបត្តិ កាលភិក្ខុទាំងឡាយស្តីប្រដៅ ភិក្ខុនោះ មិនបានពោលបន្ទែបន្ទប់ពាក្យដទៃដោយពាក្យដទៃ មិនបោះពាក្យទៅខាងក្រៅ មិនបានធ្វើឲ្យប្រាកដឡើង នូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្ត ប្រព្រឹត្តវត្តដោយប្រពៃ សមួបរោម ប្រព្រឹត្តវត្តគួរដល់កិរិយាវេីខនចេញចាកអាបត្តិបាន សង្ឃមានសេចក្តីពេញចិត្ត ដោយហេតុណា ក៏ប្រាប់ហេតុនោះថា ខ្ញុំធ្វើ បពិត្រលោកមានអាយុទាំងឡាយ សូមលោកពិចារណាអធិករណ៍របស់ភិក្ខុនេះ តាមទំនងដែលគប្បីរម្ងាប់ដោយឆាប់រហ័សនេះចុះ ។ ម្នាលភទ្ទាលិ ពួកភិក្ខុពិចារណាអធិករណ៍របស់ភិក្ខុនោះ តាមទំនងដែលបានរម្ងាប់ដោយឆាប់រហ័ស យ៉ាងនេះឯង ។

[ ១៧១ ] ម្នាលភទ្ទាលិ ភិក្ខុពួកមួយ ក្នុងសាសនានេះ ប្រព្រឹត្តដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង ( ចំពោះអាចារ្យ និងឧបជ្ឈាយ៍ ) ។ ម្នាលភទ្ទាលិ ភិក្ខុទាំងឡាយ តែងមានសេចក្តីត្រិះរិះចំពោះហេតុនោះ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះប្រព្រឹត្តដោយសទ្ធាស្តួចស្តើង ដោយសេចក្តីស្រឡាញ់ស្តួចស្តើង (ចំពោះអាចារ្យនិងឧបជ្ឈាយ៍) ប្រសិនបើយើងទាំងឡាយ ធ្វើនូវការសង្កត់សង្កិនភិក្ខុនេះ សទ្ធាស្តួចស្តើងនិង

សេចក្តីស្រឡាញ់ស្ងួចស្ងើងណា ដែលមាននៅ ភិក្ខុនេះ នឹងមិនសាបសូន្យ ចាកសទ្ធានិងសេចក្តីស្រឡាញ់ស្ងួចស្ងើងនោះឡើយ ។ ម្នាលភទ្ទាលិ បុរស មានចក្ខុតែមួយ ពួកមិត្តអាមាត្យញាតិសាលោហិត គប្បីជួយថែរក្សាចក្ខុម្ខាង របស់បុរសនោះ ដោយគិតថា ចក្ខុណា ដែលមាននៅ សូមកុំឲ្យបុរសនោះ សាបសូន្យចាកចក្ខុម្ខាងនោះឡើយ យ៉ាងណាមិញ ម្នាលភទ្ទាលិ ភិក្ខុពួកមួយ ក្នុងសាសនានេះ ប្រព្រឹត្តដោយសទ្ធាស្ងួចស្ងើង ដោយសេចក្តីស្រឡាញ់ស្ងួច ស្ងើង ( ចំពោះអាចារ្យនិងឧបជ្ឈាយ៍ ) យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ ភិក្ខុ ទាំងឡាយ តែងមានសេចក្តីត្រិះរិះចំពោះហេតុនោះ យ៉ាងនេះថា ម្នាលអាវុសោ ទាំងឡាយ ភិក្ខុនេះប្រព្រឹត្តដោយសទ្ធាស្ងួចស្ងើង ដោយសេចក្តីស្រឡាញ់ ស្ងួចស្ងើង ( ចំពោះអាចារ្យនិងឧបជ្ឈាយ៍ ) ប្រសិនបើយើងទាំងឡាយ នាំ គ្នាធ្វើការសង្កត់សង្កិនភិក្ខុនេះ សទ្ធាស្ងួចស្ងើង និងសេចក្តីស្រឡាញ់ស្ងួចស្ងើង ណា ដែលមាននៅ ភិក្ខុនេះនឹងមិនសាបសូន្យចាកសទ្ធានិងសេចក្តីស្រឡាញ់ ស្ងួចស្ងើង ( ចំពោះអាចារ្យនិងឧបជ្ឈាយ៍ ) នោះឡើយ យ៉ាងនោះឯង ។ ម្នាលភទ្ទាលិ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យភិក្ខុទាំងឡាយ ធ្វើការ សង្កត់សង្កិនភិក្ខុពួកមួយ ក្នុងសាសនានេះ ម្នាលភទ្ទាលិ មួយទៀត នេះជា ហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកភិក្ខុមិនធ្វើការសង្កត់សង្កិនភិក្ខុពួកមួយ ក្នុងសាសនានេះ ។ ព្រះភទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អ្វី ហ្ន៎ ជាហេតុ អ្វីហ្ន៎ ជាបច្ច័យ បានជាក្នុងកាលពីដើមមានសិក្ខាបទតិចល្មម តែ ពួកភិក្ខុច្រើនរូប បានតាំងនៅក្នុងព្រះអរហត្ត បពិត្រព្រះអង្គដ៏ចម្រើន មួយ

ទៀត អ្វីជាហេតុ អ្វីជាបច្ច័យ បានជាក្នុងកាលឥឡូវនេះ មានសិក្ខាបទច្រើនណាស់ តែពួកភិក្ខុតិចពេក ដែលបានតាំងនៅក្នុងព្រះអរហត្ត ។

[ ១៧២ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភទ្ទាលិ ដំណើរនោះយ៉ាងនោះឯង គឺ កាលបើសត្វទាំងឡាយសាបសូន្យ កាលបើព្រះសទ្ធម្មអន្តរធាន សិក្ខាបទទាំងឡាយ រមែងមានច្រើន ឯពួកភិក្ខុដែលបានឋិតនៅក្នុងព្រះអរហត្ត មានតិច ។ ម្នាលភទ្ទាលិ ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ មិនទាន់កើតប្រាកដចំពោះសង្ឃក្នុងសាសនានេះត្រឹមណា ព្រះសាស្តាក៏មិនទាន់បញ្ញត្តសិក្ខាបទ ដល់សាវកទាំងឡាយត្រឹមណោះ ។ ម្នាលភទ្ទាលិ លុះតែធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ កើតប្រាកដចំពោះសង្ឃក្នុងសាសនានេះ ក្នុងកាលណា ទើបព្រះសាស្តា ទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវក ក្នុងកាលនោះ ដើម្បីនឹងការពារនូវធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈនោះ ប៉ុណ្ណោះ ។ ម្នាលភទ្ទាលិ សង្ឃមិនទាន់មានច្រើន ត្រឹមណា ធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃត្រឹមណោះដែរ ។ ម្នាលភទ្ទាលិ លុះតែសង្ឃមានច្រើន ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មានប្រាកដ ចំពោះសង្ឃ ក្នុងកាលណោះ ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទដល់ពួកសាវក ដើម្បីការពារនូវធម៌ទាំងឡាយ ដែលជាទីតាំងឡើងនៃអាសវៈនោះឯង ។ ម្នាលភទ្ទាលិ សង្ឃមិនទាន់ដល់នូវលាភដ៏ប្រសើរ ... មិនទាន់ដល់នូវយសដ៏ប្រសើរ ... មិនទាន់ដល់នូវភាពជាពហុស្សូត ... មិនទាន់ដល់នូវភាពជាអ្នកស្គាល់នូវរាត្រី

( ច្រើន ) ត្រឹមណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មិនទាន់មានប្រាកដចំពោះសង្ឃ ក្នុងសាសនានេះ ត្រឹមណោះដែរ ។ ម្នាលកទ្ទាលិ លុះតែសង្ឃដល់នូវភាពជាអ្នកស្គាល់រាត្រី ( ច្រើន ) ក្នុងកាលណា ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងឡើងនៃអាសវៈ ក៏មានប្រាកដចំពោះសង្ឃ ក្នុងសាសនានេះ ក្នុងកាលនោះ ទើបព្រះសាស្តាបញ្ញត្តសិក្ខាបទ ដល់ពួកសាវក ដើម្បីនឹងការពារនូវធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈនោះឯង ។

[ ១៧៣ ] ព្រះអង្គត្រាស់ថា ម្នាលកទ្ទាលិ តថាគតបានសម្តែងធម្មបរិយាយ ប្រៀបដោយសន្ទុះនៃសេះអាជានេយ្យស្ទាវ ដល់អ្នក ក្នុងកាលណា អ្នកទាំងឡាយ មានប្រមាណតិច បាននាំគ្នាពោលហើយ ក្នុងសម័យនោះ ម្នាលកទ្ទាលិ អ្នករឭកឃើញហេតុនោះដែរឬ ។ ព្រះកទ្ទាលិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនឃើញទេ ។ ម្នាលកទ្ទាលិ អ្នកជឿនូវហេតុក្នុងការរឭកមិនឃើញដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ជាអ្នកមិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តា អស់កាលយូរពិតមែន ។ ម្នាលកទ្ទាលិ នុ៎ះ មិនមែនជាហេតុ មិនមែនជាបច្ច័យទេ ម្នាលកទ្ទាលិ ចំណែកខាងអ្នក តថាគតបានកំណត់ដឹងចិត្តដោយចិត្ត ( របស់តថាគត ) អស់កាលយូរមកហើយថា មោឃបុរសនេះ កាលដែលតថាគតសម្តែងធម៌ ក៏មិនធ្វើឲ្យជាប្រយោជន៍ មិនយកចិត្តទុកដាក់ មិនប្រមូលចិត្តដោយសព្វគ្រប់ មិនផ្ទៀងត្រចៀកស្តាប់ធម៌ឡើយ ម្នាលកទ្ទាលិ ចំណែកខាងតថាគតនឹងសម្តែងនូវធម្មបរិយាយ ដែលប្រៀបដោយសន្ទុះនៃសេះអាជានេយ្យស្ទាវដល់អ្នក ចូរអ្នក

យកចិត្តទុកដាក់ស្តាប់ធម្មបរិយាយនោះ ដោយគោរពចុះ តថាគតនឹងសម្តែង ។ ភទ្ទាលិមានអាយុទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១៧៤ ] ព្រះមានព្រះភាគបានត្រាស់សេចក្តីនុ៎ះថា ម្នាលភទ្ទាលិ បុរសអ្នកបង្ហាត់សេះ ដែលឈ្លាសវៃ បានសេះអាជានេយ្យល្អមកហើយ រមែងធ្វើនូវការបង្ហាត់ដោយបង្ហៀរ ជាដំបូង ។ សេះនោះ កាលបើសារថីធ្វើនូវការបង្ហាត់ដោយបង្ហៀរហើយ ពុតត្បុត ការកិកកុក ការកៀច គង់មាននៅខ្លះៗ មិនខាន ព្រោះថាសេះនោះគេមិនធ្លាប់ធ្វើនូវការបង្ហាត់ ។ សេះនោះ លុះគេបានបង្ហាត់រឿយៗ បានបង្ហាត់ដោយលំដាប់ ក៏បានរាបទាបក្នុងទីនោះ ។ ម្នាលភទ្ទាលិ កាលណា សេះអាជានេយ្យល្អដែលគេបានបង្ហាត់រឿយៗ បានបង្ហាត់ដោយលំដាប់ ក៏បានរាបទាបក្នុងទីនោះ អ្នកបង្ហាត់សេះ រមែងធ្វើនូវការបង្ហាត់សេះនោះតទៅទៀត ដោយការដាក់ទឹម ។ សេះនោះ កាលដែលសារថីធ្វើនូវការបង្ហាត់ដាក់ទឹមហើយ ពុតត្បុត ការកិកកុក ការកៀច គង់មាននៅខ្លះៗ មិនខាន ព្រោះថា សេះនោះ គេមិនធ្លាប់បានធ្វើនូវការបង្ហាត់ ។ សេះនោះ លុះគេបានបង្ហាត់រឿយៗ បានបង្ហាត់ដោយលំដាប់ ក៏បានរាបទាបក្នុងទីនោះ ។ ម្នាលភទ្ទាលិ កាលណា សេះអាជានេយ្យល្អ គេបានបង្ហាត់រឿយៗ បានបង្ហាត់ដោយលំដាប់ រមែងបានរាបទាបក្នុងទីនោះ ទើបអ្នកបង្ហាត់សេះ ធ្វើនូវការបង្ហាត់សេះនោះតទៅទៀត ក្នុងទីដែលលើក ឬដាក់ ( នូវជើង ) ក្នុងមណ្ឌល ក្នុងទីដែលកកាយផែនដីដោយចុងក្រចក ក្នុងសន្ទុះដ៏រហ័ស ក្នុងកាល

ដែលត្រូវការកញ្ច្រៀវ ក្នុងព្រះរាជគុណ ក្នុងព្រះរាជវង្ស ក្នុងសន្ទុះដ៏ប្រសើរ ក្នុងការៈនៃសេះដ៏ប្រសើរ ក្នុងកាលដែលមានវាចាដ៏ពីរោះ ។ សេះនោះ កាលបើសារថីធ្វើនូវការបង្ហាត់ ក្នុងសន្ទុះដ៏ប្រសើរ ក្នុងការៈនៃសេះដ៏ប្រសើរក្នុងកាលដែលមានវាចាពីរោះហើយ ពុតត្បុត ការកិកកុក ការកៀច គង់នៅមានខ្លះៗ មិនខាន ព្រោះថាសេះនោះ គេមិនធ្លាប់ធ្វើនូវការបង្ហាត់ ។ សេះនោះលុះតែគេបានបង្ហាត់រឿយៗ បង្ហាត់ដោយលំដាប់ ក៏រាបទាបក្នុងទីនោះ ។ ម្នាលកទ្ទាលិ កាលណា សេះអាជានេយ្យល្អ ដែលសារថីបង្ហាត់រឿយៗ បង្ហាត់ដោយលំដាប់ ក៏រាបទាបក្នុងទីនោះហើយ ទើបសារថីជាអ្នកបង្ហាត់សេះ បំប៉នសេះនោះឲ្យមានសម្បុរល្អនិងកម្លាំងច្រើន តទៅទៀត ។ ម្នាលកទ្ទាលិ សេះអាជានេយ្យល្អ ប្រកបដោយអង្គ ១០ នេះឯង ជាសេះគួរសមដល់ស្តេច ជាសេះគួរស្តេចប្រើប្រាស់ ដល់នូវការរាប់ថាជាអង្គរបស់ស្តេចបាន សេចក្តីទាំងនេះ មានឧបមាយ៉ាងណា ម្នាលកទ្ទាលិ មានឧបមេយ្យដូចភិក្ខុ ដែលប្រកបដោយធម៌ ១០ ប្រការ ឈ្មោះថាជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ជាអ្នកគួរទទួលអាគន្តុកទាន ជាអ្នកគួរទទួលទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក អង្គ ១០ ប្រការនោះ តើអ្វីខ្លះ ម្នាលកទ្ទាលិ ភិក្ខុក្នុងសាសនានេះ ប្រកបដោយអសេក្ខសម្មាទិដ្ឋិ ១ ប្រកបដោយអសេក្ខសម្មាសង្កប្បៈ ១ ប្រកបដោយអសេក្ខសម្មាវាចា ១ ប្រកបដោយអសេក្ខសម្មាកម្មន្តៈ ១ ប្រកបដោយអសេក្ខសម្មាអាជីវៈ ១ ប្រកបដោយអសេក្ខសម្មាវាយាមៈ ១ ប្រកបដោយ

អសេក្ខសម្មាសតិ ១ ប្រកបដោយអសេក្ខសម្មាសមាធិ ១ ប្រកបដោយអសេក្ខសម្មាញាណៈ ១ ប្រកបដោយអសេក្ខសម្មាវិមុត្តិ ១ ម្នាលកទ្ទលិ ភិក្ខុដែលប្រកបដោយធម៌ ១០ ប្រការនេះឯង ឈ្មោះថា ជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ជាអ្នកគួរទទួលអាគន្តុកទាន ជាអ្នកគួរទទួលទក្ខិណាទាន ជាអ្នកគួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តដ៏ប្រសើរបស់សត្វលោក ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ព្រះកទ្ទលិមានអាយុ ក៏មានចិត្តរីករាយ ត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ កទ្ទលិសូត្រ ទី ៥

# អដ្ឋកថា

## ភទ្ទាលិសូត្រ

[ ១៦០ ] *ភទ្ទាលិសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **ឯកាសនភោជនំ** *បានដល់ ឆាន់អាហារក្នុងវេលាមុនភត្តម្តង សេចក្តីថា អាហារដែលគួរឆាន់ ។ បទថា* **អប្បាពាធតំ** *ជាដើម ភាពជាបុគ្គលមានអាពាធតិច ពោលទុកពិស្តារហើយ ក្នុងកកចូបមសូត្រ ។*

[ ១៦១ ] *បទថា* **ន ឧស្សហាមិ** *គឺមិនអាច ។ បទថា* **សិយា កុក្កុច្ចំ សិយា វិប្បដិសារោ** *សេចក្តីថា គប្បីមានការរំខាន គប្បីមានការក្តៅក្រហាយ គឺ កាលឆាន់យ៉ាងនេះ គប្បីមានការក្តៅក្រហាយ ដល់ខ្លួនថា អញនឹងអាចប្រព្រឹត្តព្រហ្មចរិយៈបានអស់មួយជីវិតឬទេហ្ន៎ ។ បទថា* **ឯកទេសំ ភុញ្ជិត្វា** *សេចក្តីថា បានឮថា ព្រះថេរៈ អំពីមុន ទាយកដាក់អាហារចូលក្នុងបាត្រហើយ ប្រគេនសប្បិធាន់សប្បិក្តៅបន្តិចហើយ លាងដៃ នាំចំណែកដែលសល់ទៅខាងក្រៅ អង្គុយឆាន់ក្នុងទីមានម្លប់ឈើ និងទឹកសប្បាយ ។ ព្រះសាស្តាត្រាស់សំដៅសេចក្តីនោះ ។ តែព្រះភទ្ទាលិគិតថា បើភិក្ខុឆាន់អាហារ ដែលទាយកប្រគេនពេញបាត្រម្តង ហើយលាងបាត្រនាំអាហារដែលបានពេញដោយបាយ ទៅខាងក្រៅហើយ គប្បីឆាន់ក្នុងទីដែលមានម្លប់ឈើ និងទឹកសប្បាយ ។ គប្បីគួរយ៉ាងនេះ ។ ក្រៅអំពីនេះ បុគ្គលណាវិញនឹងអាច ។ ព្រោះដូច្នោះ ទើបព្រះភទ្ទាលិទូលថា សូមទ្រង់ព្រះមេត្តា*

ប្រោស ខ្ញុំព្រះអង្គមិនអាចនឹងបរិភោគយ៉ាងនេះបានឡើយ ។

បានឮថា ក្នុងអតីត ព្រះកឡាលិនេះ កើតក្នុងកំណើតក្អែក ក្នុងជាតិជាលំដាប់មក ។ ធម្មតាក្អែកទាំងឡាយ ជាសត្វឃ្លានជានិច្ច ព្រោះដូច្នោះ ទើបព្រះថេរៈឈ្មោះថា ជាអ្នកឃ្លាន ។ កាលព្រះថេរៈនោះ វង្វេងទៅ ទើបព្រះមានព្រះភាគទ្រង់សង្កត់សង្កិនព្រះថេរៈនោះហើយ ទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាមួយទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយៈ ឬភោជនីយៈ ក្នុងពេលវិកាល ត្រូវអាបត្តិបាចិត្តិយ ។ ដោយហេតុនោះ ទើបលោកពោលថា គ្រានោះឯងព្រះកឡាលិប្រកាសភាពមិនឧស្សាហៈឡើងហើយ ក្នុងកាលព្រះមានព្រះភាគទ្រង់កំពុងបញ្ញត្តសិក្ខាបទ ក្នុងកាលភិក្ខុសង្ឃសមាទាននូវសិក្ខា ។ បទថា **យថាតំ** សេចក្ដីថា ព្រះកឡាលិមិនបានឲ្យដូចភិក្ខុដទៃដែលមិនធ្វើការបរិបូណ៌ក្នុងសិក្ខា សូម្បីក្នុងថ្ងៃជាមួយគ្នា ក៏មិនគប្បីឲ្យខ្លួនជួបព្រះភក្ត្រព្រះសាស្ដា ។ មិនទៅឧបដ្ឋាកព្រះមានព្រះភាគ ។ មិនទៅកាន់ទីសម្ដែងធម៌ ។ មិនទៅកាន់រោងពិចារណា មិនបដិបត្តិត្រឹមតែភិក្ខាចារម្ដង ។ ទៅឈរត្រង់ទ្វារនៃត្រកូល ដែលព្រះមានព្រះភាគប្រថាប់គង់ ។ បើព្រះមានព្រះភាគទ្រង់ចូលទៅកាន់លំនៅរបស់កឡាលិភិក្ខុនោះ ព្រះកឡាលិដឹងមុន ក៏ទៅក្នុងទីដទៃ ។ បានឮថា កឡាលិភិក្ខុនោះ ជាកុលបុត្របួសដោយសទ្ធា មានសីល បរិសុទ្ធ ដោយហេតុនោះ វិតក្កដទៃមិនមានដល់កឡាលិនោះ មានត្រឹមតែវិតក្កប៉ុណ្ណោះថា អញជំទាស់ការបញ្ញត្តិសិក្ខាបទ របស់ព្រះមានព្រះភាគ ព្រោះហេតុនៃផ្ទៃអញធ្វើកម្មមិនសមគួរ ។ ព្រោះដូច្នោះ ព្រះកឡាលិសូម្បីនៅក្នុងវត្តជាមួយ

ព្រះសាស្តា ក៏មិនបានឲ្យខ្ញុំនជួបព្រះភក្ត្រព្រះសាស្តា ។

[ ១៦២ ] បទថា **ចីវរកម្មំ ករោន្តិ** សេចក្តីថា ពួកមនុស្សបាន ថ្វាយសំពត់សាដក ធ្វើចីវរដល់ព្រះមានព្រះភាគ ។ ទើបភិក្ខុទាំងឡាយ កាន់យកសាដកនោះធ្វើចីវរ ។ បទថា **ឯតំ តេសំ** សេចក្តីថា លោកចូរ មនសិការឱកាសនេះ កំហុសនេះ គឺ ហេតុដែលលោកជំទាស់ការបញ្ញត្តិ សិក្ខាបទរបស់ព្រះសាស្តាឲ្យល្អ ។ បទថា **ឧក្ការតាំ** សេចក្តីថា ពួកភិក្ខុសួរ ភិក្ខុទាំងឡាយដែលនៅចាំវស្សា ហើយចៀសចេញទៅតាមទិសថា លោក ទាំងឡាយនៅក្នុងទីណា ។ កាលភិក្ខុទាំងឡាយប្រាប់ថា ក្នុងវត្តជេតពន ។ ភិក្ខុទាំងនោះ ក៏នឹងជាអ្នកសួរថា អាវុសោទាំងឡាយ ខាងក្នុងវស្សានេះ ព្រះមានព្រះភាគត្រាស់ជាតកអ្វី ។ ត្រាស់ព្រះសូត្រអ្វី ។ ទ្រង់បញ្ញត្ត សិក្ខាបទអ្វី ។ ភិក្ខុទាំងឡាយនឹងប្រាប់ថា ព្រះមានព្រះភាគ ទ្រង់បញ្ញត្ត វិកាលភោជនសិក្ខាបទ ។ តែភិក្ខុមួយរូបឈ្មោះថា ភទ្ទាលិបានជំទាស់ ។ ភិក្ខុទាំងឡាយបានស្តាប់ដូច្នោះ ទើបនាំគ្នាពោលថា ធម្មតា ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទ មិនមែនហេតុដែលគួរជំទាស់ ។ ភិក្ខុទាំងឡាយសម្គាល់ ថា កំហុសរបស់លោកនេះ ប្រាកដក្នុងរវាងមហាជនយ៉ាងនេះ នឹងដល់នូវ ភាពជាអ្នកសម្តែងបានលំបាក ទើបពោលយ៉ាងនេះ ។ មយ៉ាងទៀត ភិក្ខុពួក ដទៃ កាលចេញវស្សាហើយ នឹងនាំគ្នាទៅគាល់ព្រះសាស្តា ។ កាលបើ ដូច្នោះ លោកនឹងប្រជុំសង្ឃ ដោយពោលថា អាវុសោទាំងឡាយ កាលខ្ញុំ ញុំាងព្រះសាស្តា ឲ្យទ្រង់អត់ទោសក្នុងកំហុសនេះ សូមពួកលោក ជាសម្មាញ់

ខ្ញុំផងចុះ ។ អាគន្តុកភិក្ខុទាំងឡាយក្នុងទីនោះនឹងសួរថា អាវុសោ ភិក្ខុនេះធ្វើអ្វីវិញ ។ កាលពួកអាគន្តុកៈភិក្ខុដឹងសេចក្ដីនោះហើយ នឹងពោលថា ភិក្ខុធ្វើកម្មធ្ងន់ ។ កម្មនេះមិនសមគួរឡើយ ដែលភិក្ខុនឹងជំទាស់ព្រះទសពល ។ ភិក្ខុទាំងឡាយសូម្បីសម្គាល់ថា ការខុសរបស់លោកនេះប្រាកដក្នុងមហាជនយ៉ាងនេះ នឹងដល់នូវភាពជាបុគ្គលសម្ដែងបានលំបាក ទើបពោលយ៉ាងនេះ ។

លំដាប់នោះឯង ព្រះមានព្រះភាគ កាលចេញវស្សាហើយ ទ្រង់នឹងគេចទៅកាន់ចារិក ។ កាលបើដូច្នោះ លោកនឹងប្រជុំសង្ឃដើម្បីសូមឲ្យព្រះមានព្រះភាគ ទ្រង់អត់ទោសក្នុងទីដែលយាងទៅហើយ ។ ភិក្ខុទាំងឡាយដែលនៅក្នុងទិសក្នុងទីនោះ នឹងសួរថា អាវុសោទាំងឡាយ ភិក្ខុនេះធ្វើកម្មអ្វីទុក ។បេ។ សូម្បីសម្គាល់ថា កំហុសនេះនឹងដល់នូវភាពជាអ្នកសម្ដែងបានលំបាក ទើបពោលយ៉ាងនេះ ។ បទថា **ឯតទវោច** សេចក្ដីថា ព្រះកោកាលិកសូម្បីសម្គាល់ថា ព្រះមានព្រះភាគនឹងអត់ទោសដល់អញ បានពោលពាក្យនេះជាដើមថា **អច្ចយោ មំ ភន្តេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អច្ចយោ** គឺទោស ។ បទថា **មំ អច្ចគមា** គឺទោសបានកន្លងគ្របសង្កត់ខ្ញុំព្រះអង្គប្រព្រឹត្តទៅហើយ ។ បទថា **បដិគ្គ-ណ្ហាតុ** គឺសូមទ្រង់អត់ទោស ។ បទថា **អាយតឹ សំវរាយ** គឺដើម្បីសេចក្ដីសង្រួមក្នុងអនាគត ដើម្បីមិនធ្វើកំហុស គឺការភ្លាំងភ្លាត់បែបនេះទៀត ។

[ ១៦៣ ] បទថា **តគ្ឃ** គឺដោយពិតប្រាកដ ។ បទថា **សមយោបិ ខោ តេ កោកាលិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងថា ម្នាលកោកាលិ

ហេតុមួយដែលគួរ ដែលអ្នកគប្បីចាក់ផ្ទុះមាន ។ អ្នកក៏មិនបានចាក់ផ្ទុះ មិនបានកំណត់ទុក ។

[ ១៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧភតោភាគវិមុត្តោ** ជាដើម ដូចតទៅនេះថា បុគ្គលទាំងឡាយ ដែលមានការដល់ព្រមដោយមគ្គ ក្នុងខណៈចិត្តមួយ ២ ពួក គឺព្រះអរិយបុគ្គលឈ្មោះធម្មានុសារី ១ ព្រះអរិយបុគ្គលឈ្មោះ សទ្ធានុសារី ១ ។ ការដែលព្រះមានព្រះភាគទ្រង់ឲ្យព្រះអរិយបុគ្គលទាំង ៧ ពួកនេះ ធ្វើតាមពាក្យ ប្រៀនប្រដៅក៏មិនគួរ ។ ព្រោះកាលព្រះមានព្រះភាគទ្រង់បញ្ញត្តហើយ ព្រះអរិយបុគ្គលទាំងនោះ ក៏មិនគួរធ្វើយ៉ាងនោះ ។ ម្យ៉ាងទៀត ដើម្បីសម្តែងភាពដែលព្រះអរិយបុគ្គលទាំងឡាយជាអ្នកប្រដៅងាយដោយការកំណត់មិនមែនឋានៈ និងដើម្បីសម្តែងភាពដែលព្រះភទ្ទាលិត្ថេរជាអ្នកប្រដៅក្រ ទើបព្រះមានព្រះភាគត្រាស់បទនេះ ។ ព្រោះហេតុអ្វី ទើបព្រះមាន-ព្រះភាគទ្រង់ប្រារព្ធទេសនាថា **អបិ នុ ត្វំ តស្មឹ សមយេ ឧភតោភាគ - វិមុត្តោ** ឆ្លើយថា ដើម្បីសង្កត់សង្កិនព្រះភទ្ទាលិ ។ ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះថា ម្នាលភទ្ទាលិ ព្រះអរិយបុគ្គលទាំង ៧ ពួកនេះ ជាទក្ខិណេយ្យបុគ្គលក្នុងលោក ជាម្ចាស់ក្នុងសាសនារបស់តថាគត កាលតថាគតបញ្ញត្តសិក្ខាបទកាលមានហេតុដែលគួរ ដែលព្រះអរិយបុគ្គល គប្បីជំទាស់ការជំទាស់នៃព្រះអរិយបុគ្គលទាំងនោះ ទើបគួរ ។ តែអ្នកជាមនុស្សក្រៅចាកសាសនារបស់តថាគត កាលតថាគតបញ្ញត្តសិក្ខាបទ អ្នកមិនគួរជំទាស់ ។ បទថា **រិត្តោ តុច្ឆោ** អ្នកជាមនុស្សទទេ គឺភទ្ទាលិ ជាមនុស្សសោះសូន្យទទេ

ព្រោះមិនមានអរិយគុណខាងក្នុង មិនមានអ្វីមួយក្នុងពាក្យពោលជាឥស្សរៈ ។

[ ១៦៥ ] បទថា **យថាធម្មំ បដិករោសិ** សេចក្តីថា អ្នកសម្តែងដោយប្រពៃតាមធម៌ គឺអ្នកតាំងនៅក្នុងធម៌ យ៉ាងណា ចូរធ្វើយ៉ាងនោះ អធិប្បាយថា អត់ទោសឲ្យ ។ បទថា **តន្តេ មយំ បដិគ្គណ្ហាម** គឺតថាគតអត់ទោសដល់អ្នក ។ បទថា **វុឌ្ឍិ ហេសា ភទ្ទាលិ អរិយស្ស វិនយេ** សេចក្តីថា ម្នាលភទ្ទាលិ នេះឈ្មោះថា ជាការចម្រើនក្នុងវិន័យរបស់ព្រះអរិយៈ គឺក្នុងសាសនារបស់ព្រះមានព្រះភាគ ។ ការឃើញទោសថាជាទោស ហើយសម្តែងតាមសមគួរដល់ធម៌ ហើយដល់នូវការសង្រួមតទៅ ដូចម្តេច ។ ព្រះមានព្រះភាគត្រាស់ថា ភិក្ខុណាធ្វើទេសនាឲ្យជាបុគ្គលាធិដ្ឋាន ឃើញទោសថាជាទោស ហើយសម្តែងតាមសមគួរដល់ធម៌ ភិក្ខុនោះឈ្មោះថារមែងដល់នូវការសង្រួមតទៅ ។

[ ១៦៦ ] បទថា **សត្ថាបិ ឧបវទតិ** សេចក្តីថា ភិក្ខុនៅវត្តនោះ ជាសទ្ធិវិហារិករបស់ព្រះថេរៈឈ្មោះនោះ ភិក្ខុឈ្មោះនេះ ដែលជាអន្តេវាសិករបស់ព្រះថេរៈរូបនោះ ចូលទៅកាន់ព្រៃដើម្បីញ៉ាំងលោកុត្តរធម៌ឲ្យកើត ហើយទ្រង់តិះដៀលយ៉ាងនេះថា ព្រោះហេតុអ្វី ភិក្ខុមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខា ក្នុងសាសនារបស់តថាគត ដោយការនៅព្រៃរបស់ភិក្ខុនោះ ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ដោយពិត ទេវតាមិនតិះដៀលតែម្យ៉ាង គង់សម្តែងអារម្មណ៍គួរខ្លាច ហើយធ្វើឲ្យរត់ទៅទៀតផង ។ បទថា **អត្តាបិ អត្តានំ** សេចក្តីថា សូម្បីខ្លួនក៏តិះដៀលខ្លួន គឺកាលភិក្ខុគិតដល់សីល ឋានៈដ៏សៅហ្មង

រមែងប្រាកដ ។ ចិត្តរមែងស្មុះទៅ កម្មដ្ឋានរមែងមិនជាប់ ។ ភិក្ខុនោះមានការរំខានថា ប្រយោជន៍អ្វីដោយការនៅព្រៃរបស់ភិក្ខុដូចអញ ក្រោកហើយចៀសចេញទៅ ។ បទថា **អត្តាបិ អត្តានំ ឧបវទតោ** គឺខ្លួនឯងតិះដៀលខ្លួនឯង ។ បាឋៈ ក៏យ៉ាងនេះឯង ។ គប្បីជ្រាបធម៌ជាចំណែកស ដោយន័យផ្ទុយគ្នាដែលបានពោលហើយ ។

[ ១៦៧ ] ព្រះមានព្រះភាគត្រាស់បទជាដើមថា **សោ វិវិច្ចេវ កាមេហិ** នេះ ដើម្បីសម្ដែងបទថា **ឃរំ សច្ឆិករោតិ** ឯណោះ ។

[ ១៦៨ ] បទថា **បវយ្ហ បវយ្ហ ការណំ ករោន្តិ** សេចក្ដីថា គ្របសង្កត់ទោស សូម្បីមានប្រមាណតិច ហើយធ្វើរឿយៗ ។

[ ១៦៩ ] បទថា **នោ តថា** សេចក្ដីថា មិនសង្កត់សង្កិនសូម្បីកំហុសធំ ដូចភិក្ខុក្រៅអំពីនេះ រូបធ្វើជាហេតុ ។

បានឮថា ភិក្ខុនោះពោលថា នែភទ្ទាលិដ៏មានអាយុ លោកកុំគិតអ្វីឡើយ ឈ្មោះថា កម្មបែបនេះ រមែងមាន លោកចូរមកឲ្យព្រះសាស្ដាទ្រង់អត់ទោសចុះ ហើយបញ្ជូនភិក្ខុមួយរូបអំពីគណៈភិក្ខុ ឲ្យហៅភទ្ទាលិភិក្ខុមករកខ្លួន បំណងអនុគ្រោះអំពីសម្នាក់របស់ព្រះសាស្ដាយ៉ាងនេះថា នែភទ្ទាលិ កុំគិតឡើយ កម្មបែបនេះរមែងមាន ។ បន្ទាប់អំពីនោះ ព្រះភទ្ទាលិគិតថា ភិក្ខុសង្ឃក្ដី ព្រះសាស្ដាក្ដី ក៏មិនបានបោះបង់អញចោលឡើយ ហើយទើបពោលយ៉ាងនេះ ។

លំដាប់នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងថា ភិក្ខុសង្ឃក្ដី ព្រះសាស្ដាក្ដី ទ្រង់ទូន្មាន និងប្រៀនប្រដៅបុគ្គលដែលគួរទូន្មាន ទ្រង់មិនបាន

ប្រៀនប្រដៅ និងទូន្មានបុគ្គលក្រៅអំពីនេះឡើយ ទើបត្រាស់បទថា **ឥធ ភទ្ទាលិ ឯកច្ចោ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អញ្ញេនញ្ញំ** ជាដើម លោកពោលពិស្តារហើយក្នុងអនុមានសូត្រ ។ បទថា **ន សម្មា វត្តតិ** សេចក្តីថា មិនប្រព្រឹត្តក្នុងវត្តដោយប្រពៃ ។ បទថា **ន លោមំ បាតេតិ** សេចក្តីថា មិនធ្វើរោមឲ្យធ្លាក់ បានដល់ មិនប្រព្រឹត្តក្នុងអនុលោមវត្ត គឺ សម្ជបរោម ។ បទថា **ន និត្ថារំ វត្តតិ** មិនប្រព្រឹត្តដកខ្លួនចេញ គឺ មិនប្រព្រឹត្តក្នុងវត្ត គឺការដកខ្លួនចេញ មិនពេញចិត្ត ប្រញាប់ប្រញាល់ដើម្បី ចេញចាកអាបត្តិ ។ បទថា **តត្រ** គឺក្នុងហេតុនៃការប្រដៅក្រនោះ ។ បទថា **អភិណ្ហាបត្តិកោ** គឺជាអ្នកត្រូវអាបត្តិរឿយៗ ។ បទថា **អាបត្តិពហុលោ** សេចក្តីថា ជាអ្នកច្រើនដោយអាបត្តិ គឺឱកាសត្រូវអាបត្តិមានច្រើន ឱកាស បរិសុទ្ធមិនត្រូវអាបត្តិមានតិច ។ បទថា **ន ខិប្បមេវ វូបសមតិ** គឺអធិករណ៍ មិនរម្ងាប់រហ័ស ជាអ្នកដេកលក់យូរ ។

ព្រះវិនយធរទាំងឡាយ ពោលនឹងភិក្ខុដែលមកក្នុងវេលាលាងជើងថា អាវុសោ ចូរទៅ បានវេលាបដិបត្តិហើយ ពោលនឹងភិក្ខុដែលដឹងវេលា មក ហើយទៀត មានពាក្យថា អាវុសោ ចូរទៅ បានឱកាសបោសវិហារហើយ បានវេលាបង្រៀនសាមណេរជាដើមហើយ បានវេលាផ្លូតទឹករបស់ខ្ញុំហើយ បានវេលាឧបដ្ឋាកព្រះថេរៈហើយ បានវេលាលុបមុខហើយ ហើយបញ្ជូនភិក្ខុ ដែលមកក្នុងពេលថ្ងៃខ្លះ ក្នុងពេលយប់ខ្លះទៅ កាលភិក្ខុពោលថា បពិត្រ លោកម្ចាស់ នឹងមានឱកាសក្នុងវេលាណាទៀត ទើបពោលពាក្យជា

ដើមថា អាវុសោ ចូរទៅចុះ លោករមែងដឹងដល់ឋានៈនេះថា ព្រះថេរៈជាវិនយធររូបនោះ កំពុងឆាន់ប្រេង រូបនោះឲ្យគេធ្វើចម្ការ ព្រោះហេតុអ្វី ទើបលោកប្រញាប់ប្រញាល់ទៅវិញ ហើយដេកលក់យូរតទៅ ។ បទថា **ចិប្បមេវ រូបសមតិ** សេចក្ដីថា រម្ងាប់របស់ មិនដេកលក់យូរ ។

ភិក្ខុទាំងឡាយ មានការខ្វល់ខ្វាយ ពោលថា អាវុសោទាំងឡាយ ភិក្ខុរូបនេះជាអ្នកប្រដៅឆាយ ។ ឈ្មោះថា ភិក្ខុដែលនៅក្នុងជនបទ រមែងមិនមានផាសុក មានការទៅ ការឈរ ការអង្គុយជាដើម ក្នុងសេនាសនៈចុងស្រុក ។ ភិក្ខាចារក៏លំបាក ។ អធិករណ៍នៃភិក្ខុរូបនោះ រម្ងាប់បានរបស់ ហើយប្រជុំគ្នាឲ្យភិក្ខុនោះចេញចាកអាបត្តិ ឲ្យតាំងនៅក្នុងភាពបរិសុទ្ធ ។

[ ១៧០ ] បទថា **អធិច្ចាបត្តិកោ** គឺភិក្ខុជាអ្នកត្រូវអាបត្តិម្ដងម្កាល ។ ភិក្ខុនោះ ជាអ្នកមានការខ្មាសរៀបរយក៏ពិត តែព្រោះភិក្ខុនោះជាអ្នកប្រដៅក្រ ទើបភិក្ខុទាំងឡាយត្រូវបដិបត្តិយ៉ាងនោះ ។

[ ១៧១ ] បទថា **សទ្ធាមត្តកេន វហតិ បេមមត្តកេន** សេចក្ដីថា ភិក្ខុរូបខ្លះនាំជីវិតទៅដោយសទ្ធាល្មមប្រមាណ ដោយការស្រឡាញ់ល្មមប្រមាណ គឺភិក្ខុរូបខ្លះ ញុំាងជីវិតឲ្យប្រព្រឹត្តទៅក្នុងអាចារ្យ និងឧបជ្ឈាយ៍ទាំងឡាយដោយសទ្ធាអាស្រ័យផ្ទះ មានប្រមាណតិច ដោយសេចក្ដីស្រឡាញ់អាស្រ័យផ្ទះមានប្រមាណតិច ។ ឈ្មោះថា បព្វជ្ជានេះ ដូចគ្មានទឹងការកាន់យកបដិសន្ធិ ។ ភិក្ខុបួសថ្មី មិនទាន់ស្គាល់គុណរបស់បព្វជ្ជា ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយការស្រឡាញ់ល្មមប្រមាណ ក្នុងអាចារ្យ និងឧបជ្ឈាយ៍ ។ ព្រោះដូច្នោះ គួរ

សង្គ្រោះ គួរអនុគ្រោះភិក្ខុបែបនេះ ព្រោះភិក្ខុទាំងឡាយ កាលបានសង្គ្រោះ សូម្បីមានប្រមាណតិច ហើយតាំងនៅក្នុងបព្វជ្ជា និងជាមហាសមណៈ សម្រេច អភិញ្ញា ។ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីនេះទុកថា ព្រះសាស្តា ទ្រង់ រមែងទូន្មានបុគ្គលដែលគួរទូន្មាន ដោយយកថាមគ្គ មានប្រមាណប៉ុណ្ណោះ ។ ក្រៅអំពីនេះ ទ្រង់មិនទូន្មាន ។ បទថា **អញ្ញាយ សណ្ឋហឹសុ** គឺភិក្ខុតាំងនៅ ក្នុងអរហត្តផល ។

[ ១៧២ ] បទថា **សត្ថេសុ ហាយមានេសុ** សេចក្តីថា កាលការបដិបត្តិ សាបសូន្យ សត្វឈ្មោះថា សាបសូន្យ ។ បទថា **សទ្ធម្មេ អន្តរធាយមានេ** សេចក្តីថា កាលបដិបត្តិសទ្ធម្មកំពុងអន្តរធាន ពិតហើយកាលមិនមានសត្វ ដែល បំពេញការបដិបត្តិ សូម្បីបដិបត្តិសទ្ធម្ម ក៏ឈ្មោះថា អន្តរធាន ។ បទ ថា **អាសវដ្ឋានីយា** គឺធម៌ជាទីតាំងនៃអាសវៈទាំងឡាយ ។ អធិប្បាយថា អាសវៈទាំងឡាយ មានការតិះដៀលអ្នកដទៃ ការក្តៅក្រហាយ ការសម្លាប់ ការចងជាដើម នឹងជាការពិសេសនៃទុក្ខក្នុងអបាយ រមែងតាំងនៅក្នុងធម៌ពួក ណា ។ ព្រោះដូច្នោះ ហេតុនោះ រមែងមាន ដល់ធម៌ទាំងនោះ ។ ក្នុងបទ នេះ យោជនាកែទុកថា វីតិក្កមធម៌ គឺធម៌ឈានកន្លង ដែលជាទីតាំងនៃ អាសវៈទាំងនោះ គង់មិនប្រាកដក្នុងសង្ឃដរាបណា ។ ព្រះសាស្តាទ្រង់មិន បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយដរាបនោះ ។ បទថា **យតោ ច ខោ ភទ្ទាលិ** ព្រះមានព្រះភាគកាលទ្រង់សម្តែងអកាល យ៉ាងនេះហើយ ទើបទ្រង់ សម្តែងដល់កាលតទៅ ត្រាស់ពាក្យថា **យតោ ច ខោ ភទ្ទាលិ** ជាដើម ។

ក្នុងបទទាំងនោះ បទថា **យតោ** គឺក្នុងកាលណា ។ បទដ៏សេសគប្បីជ្រាបដោយទំនងដូចគ្នា ដូចបានពោលហើយនោះឯង ។ ម្យ៉ាងទៀត សេចក្តីសង្ខេបក្នុងបទនេះ មានដូច្នេះថា ក្នុងកាលណា មានវីតិក្កមទោស ដែលរាប់ថា ធម៌ជាទីតាំងនៃអាសវៈប្រាកដក្នុងសង្ឃ ។ ក្នុងកាលនោះ ទើបព្រះសាស្តាទ្រង់បញ្ញត្តដល់សាវកទាំងឡាយ ។ ព្រោះហេតុអ្វី ព្រោះដើម្បីកម្ចាត់វីតិក្កមទោស ដែលបានដល់ធម៌ជាទីតាំងនៃអាសវៈ ទាំងនោះឯង ។ ព្រះមានព្រះភាគ កាលត្រាស់ដល់អកាល នៃកាលបញ្ញត្តសិក្ខាបទដែលមិនទាន់កើតធម៌ដែលជាទីតាំងនៃអាសវៈយ៉ាងនេះ និងកាលដែលកើតឡើងនៃធម៌ដែលជាទីតាំងនៃអាសវៈហើយ ឥឡូវនេះ ដើម្បីទ្រង់សម្តែង ដល់កាលដែលមិនកើតដល់ធម៌ទាំងនោះ និងកាលដែលកើតធម៌ទាំងនោះ ទើបត្រាស់ពាក្យថា **ន តាវ ភទ្ទាលិ អេកច្ចេ** គឺធម៌ជាទីតាំង នៃអាសវៈ ពួកខ្លះមិនទាន់ប្រាកដក្នុងសង្ឃក្នុងធម្មវិន័យនេះ ។

ក្នុងបទទាំងនោះ បទថា **មហត្តំ** គឺភាពជាធំ ។ ពិតហើយ សង្ឃជាបុគ្គលមិនទាន់ដល់នូវភាពជាធំ ដោយអំណាចនៃព្រះនវកភិក្ខុ មជ្ឈិមភិក្ខុ និងព្រះថេរៈ ទាំងឡាយដរាបណា ។ សេនាសនៈរមែងមានធម៌ដែលជាទីតាំងនៃអាសវៈពួកខ្លះ មិនទាន់កើតឡើងក្នុងសាសនាដរាបនោះ ។ តែកាលសង្ឃដល់នូវភាពជាធំ ទើបធម៌ទាំងនោះកើតឡើង ។ កាលបើដូច្នោះ ព្រះសាស្តាទ្រង់រមែងបញ្ញត្តសិក្ខាបទ ។ កាលសង្ឃដល់នូវភាពជាធំ គប្បីជ្រាបសិក្ខាបទដែលទ្រង់បញ្ញត្តទុក ដោយន័យនេះថា ភិក្ខុណាមួយ សម្រេចនូវការដេកជាមួយ

នឹងអនុបសម្បន្នលើសជាងពីរយប់ ឬបីយប់ឡើងទៅ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីណាមួយ ឲ្យឧបសម្បទារាល់ឆ្នាំ ភិក្ខុនីនោះត្រូវ អាបត្តិបាចិត្តិយ ។ ភិក្ខុនីណាមួយ ឲ្យឧបសម្បទាដល់ស្រីពីររូបក្នុង ១ ឆ្នាំ ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយ ។

បទថា **លាភគ្គំ** គឺជាអ្នកច្រើនដោយលាភ ។ ពិតហើយ សង្ឃមិនទាន់ដល់នូវភាពច្រើនក្រៃលែងដោយលាភដរាបណា ។ ធម៌ជាទីតាំងនៃអាសវៈមិនទាន់កើតឡើង ព្រោះអាស្រ័យលាភដរាបនោះ ។ តែកាលសង្ឃដល់ហើយ ទើបធម៌ទាំងនោះកើតឡើង ។ កាលបើដូច្នោះ ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុណាមួយ ឲ្យវត្ថុដែលបុគ្គលគួរទំពាស៊ី ឬវត្ថុដែលបុគ្គលគួរបរិភោគដល់អចេលកក្តី បរិព្វាជកក្តី បរិព្វាជិកាក្តី ដោយដៃរបស់ខ្លួនត្រូវអាបត្តិបាចិត្តិយ ។ ព្រោះកាលសង្ឃដល់នូវភាពជាអ្នកច្រើនដោយលាភ ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទនេះ ។ បទថា **យសគ្គំ** គឺជាអ្នកធំក្រៃលែងដោយយស ។ ពិតហើយ សង្ឃមិនទាន់ដល់នូវភាពជាអ្នកច្រើនក្រៃលែងដោយយសដរាបណា ។ ធម៌ជាទីតាំងនៃអាសវៈមិនទាន់កើតឡើង ព្រោះអាស្រ័យយសដរាបនោះ ។ តែកាលសង្ឃដល់ហើយនូវធម៌ទាំងនោះ ទើបកើតឡើង កាលបើដូច្នោះ ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទថា ភិក្ខុផឹកសុរានិងមេរ័យ ត្រូវអាបត្តិបាចិត្តិយ ។ ព្រោះកាលសង្ឃដល់នូវភាពជាអ្នកច្រើនដោយយស ទើបព្រះសាស្តា ទ្រង់បញ្ញត្តសិក្ខាបទនេះ ។ បទថា **ពាហុសច្ចំ** គឺជាពហូសូត ។ ពិតហើយ សង្ឃមិនទាន់ដល់

នូវភាពជាពហុស្សុតដរាបណា ធម៌ជាទីតាំងនៃអាសវៈមិនទាន់កើតដរាបនោះ ។ តែកាលសង្ឃដល់នូវភាពជាពហុស្សុត បុគ្គលទាំងឡាយ រៀននិកាយ ១ ក្តី ២ ក្តី ៥ ក្តី ស្ទាត់ដោយមិនមែនឧបាយ ប្រៀបធៀបរសដោយរស ហើយសម្តែងពាក្យព្រះសាស្តា ក្រៅធម៌ ក្រៅវិន័យ ។ កាលបើដូច្នោះ ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទដោយន័យជាដើមថា ភិក្ខុណាមួយ ពោលយ៉ាងនេះថា ធម៌ទាំងឡាយណា តែងធ្វើនូវសេចក្តីអន្តរាយ ដែលព្រះដ៏មានព្រះភាគសម្តែងហើយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏-មានព្រះភាគ សម្តែងហើយ ដោយប្រការយ៉ាងនោះ ... ។ បើសមណុទ្ទេស ពោលយ៉ាងនេះថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគសម្តែងហើយ ... ។

គប្បីជ្រាប បទថា **រត្តញ្ញុតប្បត្តោ** ដូចតទៅនេះថា ឈ្មោះថា រត្តញ្ញូ ព្រោះអត្ថថា ដឹងរាត្រី គឺដឹងរាត្រីច្រើន តាំងអំពីថ្ងៃដែលខ្លួនបួស អធិប្បាយថា បួសយូរ ។ ភាពជាអ្នកដឹងរាត្រី ឈ្មោះថា **រត្តញ្ញុតំ** ក្នុងបទនោះ គប្បីជ្រាបថា កាលសង្ឃដល់នូវភាពជាអ្នកដឹងរាត្រី ទើបព្រះសាស្តាទ្រង់បញ្ញត្តសិក្ខាបទប្រារព្ធព្រះឧបសេនវង្គន្តបុត្រ ព្រោះព្រះឧបសេនវង្គន្តបុត្រនោះ ឃើញភិក្ខុទាំងឡាយមានវស្សាតិចជាង ១០ ឲ្យនូវឧបសម្បទា ខ្លួនលោកមានវស្សា ១ ឲ្យសទ្ធិវិហារិកបួសដែរ ។ កាលបើដូច្នោះ ទើបព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយភិក្ខុមានវស្សាថយអំពី ១០ មិនត្រូវឲ្យឧបសម្បទាដល់កុលបុត្រឡើយ ភិក្ខុណាឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។

កាលព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទយ៉ាងនេះ ភិក្ខុល្ងង់មិនឈ្លាសឲ្យកុលបុត្របួសទៀត ដោយគិតថា អញមានវស្សា ១០ ហើយអញមានវស្សា ១០ ហើយ ។ កាលបើដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុពាលមិនឆ្លាសមិនត្រូវឲ្យឧបសម្បទា ( ដល់កុលបុត្រ ) ឡើយ ភិក្ខុពាលណា ឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលឆ្លាសប្រតិពលមានវស្សា ១០ ឬមានវស្សាច្រើនជាង ១០ ឡើងទៅគួរឲ្យឧបសម្បទា ( ដល់កុលបុត្រ ) បាន ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តសិក្ខាបទ ២ ក្នុងវេលាដែលសង្ឃដល់នូវភាពជាអ្នកដឹងរាត្រី ដោយប្រការដូច្នេះ ។

[ ១៧៣ ] បទថា **អាជានីយសុសូបមំ ធម្មបរិយាយំ ទេសេសឹ** សេចក្តីថា តថាគតសម្តែងធម្មបរិយាយ ប្រៀបដោយជាអាជានេយ្យស្ទាវ ។ បទថា **តត្ថ** គឺក្នុងការរៀកមិនបាននោះ ។ បទថា **ន ខោ ភទ្ទាលិ ឯសេវ ហេតុ** គឺភាពជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខានេះ មិនជាហេតុឡើយ ។

[ ១៧៤ ] បទថា **មុខាធានេ ការណំ ការេតិ** សេចក្តីថា បង្ហឹកឲ្យដឹងហេតុដើម្បីលើកកឲ្យល្អ ក្នុងការដាក់បង្ហៀរជាដើមត្រង់មាត់ ។ បទជាដើមថា **វិសូកាយិកានិ** សេចក្តីថា ប្រព្រឹត្តជាសត្រូវ ព្រះមានព្រះភាគត្រាស់ដល់ការប្រព្រឹត្តិព្យសន៍ ។ បទទាំងអស់នេះ ជាវេវចនៈនៃគ្នានិងគ្នា ។ បទថា **តស្មឹ ឋានេ** សេចក្តីថា ក្នុងការប្រព្រឹត្តិព្យសន៍នោះ ។ បទថា **បរិនិព្វាយតិ** សេចក្តីថា អស់ព្យសន៍ អធិប្បាយថា លះនូវព្យសន៍នោះបាន ។

បទថា **យុគាធានេ** សេចក្ដីថា ក្នុងការដាក់និងដើម្បីផ្គងឲ្យល្អ ។ បទថា **អនុក្កមេ** សេចក្ដីថា ក្នុងការលើក និងការដាក់ជើងទាំង ៤ ក្នុងគ្រាតែមួយ ។ រមែងឈរក្នុងរណ្ដៅ កាន់ដាវកាត់ជើងសេះរបស់សត្រូវដែលកំពុងដើរមក ក្នុងសម័យនោះ សេះនោះនឹងលើកជើងទាំង ៤ ក្នុងពេលតែមួយ ព្រោះហេតុនោះ ទើបអ្នកបង្វឹកសេះទូន្មានឲ្យដឹងហេតុនោះ ដោយវិធីចងខ្សែ ។ បទថា **មណ្ឌលេ** សេចក្ដីថា បង្វឹកឲ្យដឹងហេតុក្នុងការរត់ជារង្វង់ ដើម្បីធ្វើដោយអាការដែលបុគ្គលអង្គុយលើខ្នង អាចរើសយកអាវុធដែលធ្លាក់លើផែនដីបាន ។ បទថា **ខុរកាសេ** សេចក្ដីថា ក្នុងការយកក្រចកទល់ផែនដី ។ ព្រោះក្នុងការរត់ទៅនៅពេលយប់ ដើម្បីមិនឲ្យសត្រូវបានឮសំឡេងជើង ទើបឲ្យសញ្ញាក្នុងទីមួយកន្លែង ហើយឲ្យសិក្សាការដើរដោយចុងក្រចក ។ លោកពោលបទនេះ សំដៅយក មិនឲ្យសត្រូវបានឮសំឡេងជើងនោះ ។ បទថា **ធាវេ** សេចក្ដីថា ក្នុងភាពជាពាហនៈមានសន្ទុះរហ័ស ។ បាលីថា **ធាវេ** ក៏មាន ប្រែថា ទូន្មានឲ្យដឹងហេតុនោះ ដើម្បីគេចខ្លួនក្នុងកាលចាញ់ និងដើម្បីដេញតាមចាប់សត្រូវ ដែលគេចទៅ ។ បទថា **រវត្ថេ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការស្រែក ។ ព្រោះក្នុងការច្បាំង កាលដំរីកន្លួច សេះកញ្ជ្រៀវរត់បុកទម្លាយ ឬទាហានស្រែកជ័យឃោស ដើម្បីមិនឲ្យខ្លាចសំឡេងនោះ ហើយចូលទៅរកសត្រូវ ទើបទូន្មានដោយហេតុនោះ ។ បទថា **រាជគុណេ** ក្នុងភាពជាសេះដែលមានគុណ ព្រះរាជាគប្បីដឹង ។ បានឮថា ព្រះរាជាកូដកណ្ណៈ មានសេះឈ្មោះថា គុឡវណ្ណៈ ព្រះរាជាស្ដេចចេញអំពី

ផ្លូវទិសខាងកើតយាងដល់ច្រាំង កទម្ពនទី ដោយទ្រង់ព្រះតម្រិះថា អញនឹងទៅចេតិយបពិត ។ សេះឈរក្បែរច្រាំង មិនប្រាថ្នានឹងឆ្លងនាំទៅ ។ ព្រះរាជាហៅនាយអស្សាចារ្យមក ហើយត្រាស់ថា ឱសេះដែលអ្នកបង្ហឹកមិនប្រាថ្នានឹងឆ្លងទឹក ។ នាយអស្សាចារ្យក្រាបទូលថា គួរអស្ចារ្យ សេះនេះទូលបង្គំបង្ហឹកល្អហើយ ។ សេះគិតថា អញឆ្លងទឹក កន្ទុយក៏នឹងសើម កាលកន្ទុយសើម នឹងសើមត្រង់ព្រះវរកាយរបស់ព្រះរាជា ព្រោះហេតុនោះ ទើបសេះមិនឆ្លង ព្រោះខ្លាចទឹកសើមវរកាយរបស់ព្រះអង្គ ដោយអាការយ៉ាងនេះ ។ សូមព្រះអង្គចាប់កន្ទុយសេះលើកឡើង ។ ព្រះរាជាទ្រង់ធ្វើយ៉ាងនោះ សេះប្រញាប់ឆ្លងទៅដល់ច្រាំង ។ នាយអស្សាចារ្យទូន្មានសេះឲ្យដឹងយ៉ាងនេះ ដើម្បីត្រូវការយ៉ាងនោះ ។ បទថា **រាជវំសេ** សេចក្តីថា ពិតហើយ វង្សរបស់ស្តេចសេះនោះ មានអធិប្បាយថា សូម្បីរាងកាយត្រូវធ្លុះទៅដោយការប្រហារនោះ ក៏មិនធ្វើអ្នកជិះឲ្យ ធ្លាក់ទៅក្នុងពួកសត្រូវ រមែងនាំចេញទៅខាងក្រៅបាន ។ ទូន្មានឲ្យដឹងនូវហេតុ ដើម្បីប្រយោជន៍នោះ ។

បទថា **ឧត្តមេ ជវេ** សេចក្តីថា ក្នុងការដល់ព្រមដោយកម្លាំង អធិប្បាយថា ទូន្មានឲ្យដឹងហេតុដោយអាការដែលមានកម្លាំងដ៏កំពូល ។ បទថា **ឧត្តមេ ហយេ** សេចក្តីថា ក្នុងភាពជាសេះដ៏ឧត្តម អធិប្បាយថា ទូន្មានឲ្យដឹងហេតុ ដោយអាការដែលជាសេះដ៏កំពូល ។ ក្នុងបទនោះ តាមប្រក្រតីសេះដ៏ឧត្តម រមែងគួរដល់ហេតុនៃភាពជាសេះដ៏កំពូល ។ សេះដទៃមិនគួរ ។ សេះរមែងបដិបត្តិ រមែងមានកម្លាំងដ៏ឧត្តមយ៉ាងនេះ ព្រោះជាសេះដ៏កំពូល ។

សេះ ដទៃរមែងមិនបដិបត្តិនូវភាពដែលមានកម្លាំងដ៏កំពូល ។ ក្នុងសេះដ៏ឧត្តមនោះ មានរឿងដូចតទៅនេះថា

បានឮថា ព្រះរាជាមួយអង្គបានកូនសេះសិន្ធពមួយ តែទ្រង់មិនជ្រាបថាជាសេះសិន្ធព ទើបទ្រង់ឲ្យនាយអស្សាចារ្យយកសេះនេះបង្ហឹក ។ នាយអស្សាចារ្យក៏មិនដឹងថា សេះនោះជាសេះសិន្ធព ទើបនាំយកសណ្តែករាជមាសទៅឲ្យកូនសេះស៊ី ។ កូនសេះក៏មិនស៊ី ព្រោះមិនសមគួរដល់ខ្លួន ។ នាយអស្សាចារ្យមិនអាចបង្ហឹកសេះនោះបាន ទើបទូលព្រះរាជាថា បពិត្រមហារាជ សេះនេះជាសេះកៀច ហើយលែងទៅ ។ ថ្ងៃមួយ ភិក្ខុកំលោះមួយរូបធ្លាប់ជាអស្សាចារ្យ កាន់យកបរិក្ខារបស់ឧបជ្ឈាយ៍ទៅ ឃើញសេះនោះដើរ លើខ្នងប្រឡាយ ទើបប្រាប់ព្រះឧបជ្ឈាយ៍ថា លោកម្ចាស់ នុ៎ះកូនសេះសិន្ធព មានតម្លៃកាត់ថ្លៃមិនបាន បើព្រះរាជាទ្រង់ជ្រាបគប្បីធ្វើកូនសេះនោះឲ្យជាសេះមង្គល ព្រះថេរៈពោលថា នែលោក ព្រះរាជាជាមិច្ឆាទិដ្ឋិ ធ្វើម្តេចហ្ន៎ ទើបទ្រង់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា លោកចូរទៅទូលព្រះរាជាចុះ ។ ភិក្ខុកំលោះទូលព្រះរាជាថា បពិត្រមហារាជ មានកូនសេះសិន្ធព មានតម្លៃកាត់ថ្លៃមិនបានមួយក្បាល ព្រះរាជាត្រាស់សួរថា លោកម្ចាស់ឃើញឬ ភិក្ខុកំលោះថ្វាយព្រះពរថា ឃើញមហាបពិត្រ ។ ព្រះរាជាត្រាស់សួរថា បានអ្វីទើបសមគួរ ភិក្ខុនោះថ្វាយព្រះពរថា គួរឲ្យព្រះក្រយាហារដែលមហាបពិត្រសោយក្នុងភាជនៈមាស ដែលដាក់គ្រឿងសោយរបស់មហាបពិត្រ រស ជាគ្រឿងផឹករបស់មហាបពិត្រ ក្លិនក្រអូប ផ្ការបស់មហាបពិត្រ ។ ព្រះរាជា

ត្រាស់ឲ្យធ្វើគ្រប់យ៉ាង ។ ភិក្ខុកំលោះបានឲ្យមនុស្សនាំទៅ ។ កូនសេះហិតក្លិន គិតថា នាយអស្សាចារ្យ ដឹងគុណរបស់អញ ប្រហែលជាមាន ទើបអើតក្បាលសម្លឹងមើល ។ ភិក្ខុកំលោះដើរទៅ ផ្ទាត់ម្រាមដៃពោលថា ចូរបរិភោគអាហារចុះ ។ សេះមកស៊ីអាហារក្នុងថាសមាស ផឹកទឹកដ៏មានរស ។

លំដាប់នោះ ភិក្ខុកំលោះយកក្លិនក្រអូបលាបសេះហើយ ប្រដាប់នូវគ្រឿងប្រដាប់របស់ព្រះរាជា ផ្ទាត់ម្រាមដៃពោលថា ទៅខាងមុខចុះ សេះដើរទៅខាងមុខភិក្ខុកំលោះ បានឈរក្នុងទីរបស់សេះមង្គល ។ ភិក្ខុកំលោះថ្វាយព្រះពរថា សូមថ្វាយព្រះពរ កូនសេះមានតម្លៃកាត់ថ្លៃមិនបាន សូមមហាបពិត្រឲ្យអស្សាចារ្យទំនុកបម្រុងសេះនោះត្រឹម ២-៣ ថ្ងៃចុះ ។

កាលកន្លងទៅ ២-៣ ថ្ងៃ ភិក្ខុកំលោះទូលសួរថា បពិត្រមហារាជ ទ្រង់ចង់មើលអានុភាពរបស់សេះឬ ព្រះរាជាត្រាស់ថា សាធុ អាចារ្យ ។ ខ្ញុំឈរក្នុងទីណាទើបឃើញ ភិក្ខុកំលោះថ្វាយព្រះពរថា សូមមហាបពិត្រយាងទៅកាន់ឧទ្យានចុះ ។ ព្រះរាជាត្រាស់ប្រើឲ្យចាប់សេះមក ភិក្ខុកំលោះផ្ទាត់ម្រាមដៃឲ្យសញ្ញាដល់សេះថា ឯងចូររត់ទៅជុំវិញដើមឈើមួយដើម សេះក៏រត់ទៅជុំវិញដើមឈើ ហើយក៏មក ។ ព្រះរាជាទ្រង់មិនបានឃើញសេះរត់ទៅរត់មក ភិក្ខុកំលោះទូលសួរថា មហាបពិត្រ ទ្រង់ឃើញឬ ព្រះរាជាត្រាស់ថា មិនឃើញទេ លោកម្ចាស់ ។ ភិក្ខុកំលោះទូលថា សូមមហាបពិត្រ ដាក់គ្រឿងចំណាំផ្អែកត្រង់ដើមឈើមួយដើមទុក ហើយផ្ទាត់ដៃពោលថា ឯងចូរពាំគ្រឿងចំណាំនោះមក ។ សេះរត់ទៅពាំគ្រឿងចំណាំនោះមក ។ ភិក្ខុទូល

សួរថា មហាបពិត្រឃើញហើយឬ ព្រះរាជាត្រាស់ថា មិនឃើញទេលោកម្ចាស់ ។ ភិក្ខុកំលោះផ្ទាត់ម្រាមដៃទៀតពោលថា អ្នកចូររត់ទៅជុំវិញរបូតផុតកំពែងព្រះឧទ្យានហើយមកចុះ សេះបានធ្វើយ៉ាងនោះ ។ ភិក្ខុកំលោះទូលសួរថា មហាបពិត្រ ទ្រង់ឃើញហើយឬ ព្រះរាជាត្រាស់ថាមិនឃើញទេលោកម្ចាស់ ភិក្ខុកំលោះឲ្យនាំសំពត់កម្ពលពណ៌ក្រហមមកចងត្រង់ជើងសេះបានឲ្យសញ្ញាយ៉ាងនោះ ។ សេះលោតរត់ទៅរបូតដល់ផុតកំពែង ។ បានប្រាកដក្នុងទីបំផុតកំពែងព្រះឧទ្យាន ដូចអណ្តាតភ្លើងដែលបុរសកំពុងគ្រវី ។ សេះទៅឈរក្នុងទីជិត ។ ភិក្ខុទូលសួរថា មហាបពិត្រ ទ្រង់ឃើញហើយឬ ព្រះរាជាត្រាស់ថា ឃើញហើយលោកម្ចាស់ ។ ភិក្ខុបានឲ្យសញ្ញាថា អ្នកចូររត់ទៅជុំវិញរបូតផុតកំពែងស្រះមង្គលបោក្ខរណី សេះបានរត់ទៅជុំវិញរបូតផុតកំពែងស្រះបោក្ខរណី ។ ភិក្ខុកំលោះបានឲ្យសញ្ញាទៀតថា អ្នកចូរចុះកាន់ស្រះបោក្ខរណី ហើយរត់លើស្លឹកឈូកទាំងអស់ ។ មិនមានសូម្បីស្លឹកមួយដែលសេះមិនបានជាន់ក្តី បាក់រហែកក្តី ។ ភិក្ខុទូលសួរថា មហាបពិត្រទ្រង់ឃើញឬ ព្រះរាជាត្រាស់ថា ឃើញហើយលោកម្ចាស់ ភិក្ខុកំលោះផ្ទាត់ម្រាមដៃ ហើយលាបាតដៃចេញទៅ សេះរហ័សដូចខ្យល់បានលោតទៅឈរលើបាតដៃ ភិក្ខុទូលសួរថា មហាបពិត្រឃើញឬ ព្រះរាជាត្រាស់ថា ឃើញហើយលោកម្ចាស់ ។ សេះដ៏ឧត្តមយ៉ាងនេះ រមែងបដិបត្តិកម្លាំងដ៏កំពូលដោយហេតុដ៏កំពូលយ៉ាងនេះ ។ បទថា **ឧត្តមេ សាខល្យេ** សេចក្តីថា គួរទូន្មានហេតុនៃភាពជាសេះដ៏កំពូលដោយវាចាដ៏ត្រជាក់ថា នៃសេះដ៏ចម្រើនអ្នក

កុំគិតថ្វីឡើយ អ្នកនឹងជាសេះមង្គលរបស់ព្រះរាជា អ្នកនឹងបានអាហារ មានព្រះក្រយាស្ងោយរបស់ព្រះរាជាជាដើម ដោយហេតុនោះ ទើបលោកពោលថា **ឧត្តមេ សាខល្យេ** ដូច្នេះ ។ បទថា **រាជភោគោ** គឺជាពាហនៈសម្រាប់ប្រើប្រាស់របស់ព្រះរាជា ។ បទថា **រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ** សេចក្តីថា ព្រះរាជាយាងទៅក្នុងទីណាមួយ មិនបានបោះបង់ ដូចដៃ និងជើង ព្រោះដូច្នោះ ទើបរាប់ថាជាអង្គ ឬជាអង្គមួយ ក្នុងអង្គនៃសេនា ៤ ពួក ។ បទថា **អសេក្ខាយ សម្មាទិដ្ឋិយា** សេចក្តីថា សម្មាទិដ្ឋិដែលជាអរហត្តផល សូម្បីសម្មាសង្កប្បៈជាដើម ក៏សម្បយុត្តដោយអរហត្តផលនោះ ។ សម្មាញាណ ជាសម្មាទិដ្ឋិ ដូចពោលហើយខាងដើម ។ម្យ៉ាងទៀត ធម៌ដ៏សេសវៀរអង្គ នៃផល ៨ គប្បីជ្រាបថា ជាវិមុត្តិ ។ បទដ៏សេសក្នុងបទទាំងពួងងាយយល់ទាំងអស់ហើយ ។

ទេសនានេះ ព្រះមានព្រះភាគ ទ្រង់កាន់យកដោយធម៌ជាកំពូលនៃ អរហត្ត ហើយទ្រង់បញ្ចប់ដោយអំណាចនៃឧគ្ឃដិតញ្ញូបុគ្គល ដោយប្រការដូច្នេះ ។

**អដ្ឋកថាកក្ខាលិសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## លដុកិកោបមសូត្រទី ៦

[ ១៧៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាបណនិគមរបស់ពួកជនអង្គុត្តរាបៈ ក្នុងដែនឈ្មោះអង្គុត្តរាបៈ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់អាបណនិគមដើម្បីបិណ្ឌបាត ។ លុះព្រះអង្គស្តេចទៅបិណ្ឌបាត ក្នុងអាបណនិគមហើយ ត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត ក៏ស្តេចចូលទៅត្រង់ជង្គព្រៃមួយ លុះចូលសំដៅទៅដល់ជង្គព្រៃនោះហើយ ទើបគង់សម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយដើម ។ ចំណែកខាងព្រះឧទាយីមានអាយុ ក៏ស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ ចូលទៅកាន់អាបណនិគម ដើម្បីបិណ្ឌបាត ក្នុងវេលាព្រឹកព្រហាមដែរ ។ លុះលោកទៅបិណ្ឌបាតក្នុងអាបណនិគមហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅរកជង្គព្រៃមួយ លុះចូលទៅសំដៅទៅកាន់ជង្គព្រៃនោះហើយ ទើបអង្គុយសម្រាកក្នុងវេលាថ្ងៃ ក្រោមម្លប់ឈើមួយដើម ។ កាលដែលព្រះឧទាយីមានអាយុ នៅក្នុងទីស្ងាត់ កំពុងតែសម្ងំ ក្នុងផលសមាបត្តិ ក៏មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើង យ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវធម៌ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាអកុសលច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់

ប្រកបនូវធម៌ជាកុសលច្រើនយ៉ាង ។ គ្រានោះឯង ព្រះឧទាយីមានអាយុចេញអំពីផលសមាបត្តិ ក្នុងវេលាថ្ងៃរសៀលហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

[ ១៧៦ ] លុះព្រះឧទាយីមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងទីស្ងាត់ កំពុងតែសម្ងំក្នុងផលសមាបត្តិ ក្នុងទីឯណោះ ក៏មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើង យ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវធម៌ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាអកុសលច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគនៃយើង ទ្រង់ប្រកបនូវធម៌ជាកុសលច្រើនយ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថាកាលពីដើម ពួកយើងខ្ញុំព្រះអង្គបរិភោគក្នុងវេលាល្ងាចផង ក្នុងវេលាព្រឹកផង ក្នុងវេលាថ្ងៃជាវេលាវិកាលផង ។ បពិត្រព្រះអង្គដ៏ចម្រើន មានសម័យមួយដែលព្រះមានព្រះភាគបានទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរលះបង់នូវការបរិភោគក្នុងវេលាថ្ងៃ ដែលជាវេលាវិកាលនុ៎ះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីរាយមាយចិត្ត និងទោមនស្ស ដោយគិតថា ពួកគហបតីដែលមានសទ្ធា រមែងឲ្យនូវខាទនីយភោជនីយាហារដ៏ឧត្តមណា ដល់យើងទាំងឡាយ ក្នុងវេលាថ្ងៃដែលជា

វេលាវិកាល ព្រះមានព្រះភាគបានត្រាស់ឲ្យយើងលះបង់នូវខាទនីយភោជនី-
យាហារដ៏ឧត្តមនោះផង ព្រះសុគតបានត្រាស់ឲ្យយើងលះបោលនូវខាទនីយ-
ភោជនីយាហារដ៏ឧត្តមនោះផង បពិត្រព្រះអង្គដ៏ចម្រើន តែឥឡូវនេះ ពួកយើង
ខ្ញុំព្រះអង្គទាំងនោះ បែរជាបាននូវសេចក្តីស្រឡាញ់ សេចក្តីគោរព សេចក្តី
ខ្មាសបាប និងសេចក្តីខ្លាចបាប ចំពោះព្រះមានព្រះភាគវិញ កាលបើយ៉ាងនេះ
ទើបយើងខ្ញុំព្រះអង្គលះបង់នូវការបរិភោគក្នុងវេលាថ្ងៃ ដែលជាវេលាវិកាល
ចេញ បពិត្រព្រះអង្គដ៏ចម្រើន តែពួកយើងខ្ញុំព្រះអង្គនោះ នៅបរិភោគក្នុង
វេលាល្ងាចផង ក្នុងវេលាព្រឹកផង បពិត្រព្រះអង្គដ៏ចម្រើន មានសម័យមួយ
ដែលព្រះមានព្រះភាគបានត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ
អ្នកទាំងឡាយ ចូរលះបង់នូវការបរិភោគក្នុងវេលាយប់ ដែលជាវេលាវិកាល
នុ៎ះចេញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ មានសេចក្តីកាយមាយចិត្ត
និងទោមនស្ស ដោយគិតថា បណ្តាភត្តទាំងពីរនេះ ភត្តណាឧត្តមវិសេស
ដែលគេបានចាត់ចែងបម្រុងយើងទាំងឡាយ ព្រះមានព្រះភាគបានត្រាស់ឲ្យ
យើងលះបង់នូវភត្តនោះផង ព្រះសុគតបានត្រាស់ឲ្យយើងលះបោល នូវភត្ត
នោះផង ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ មានបុរសម្នាក់
បាននូវគ្រឿងសម្ល ក្នុងវេលាថ្ងៃ ហើយនិយាយនឹងប្រពន្ធ យ៉ាងនេះថាហ៏ នាង
ចូរទុកនូវគ្រឿងសម្លនេះសិនចុះ ចាំដល់វេលាល្ងាច យើងនឹងបរិភោគទាំងអស់
គ្នា ជាមួយគ្នាតែម្តង បពិត្រព្រះអង្គដ៏ចម្រើន ខាទនីយភោជនីយាហារណា
មួយ ដែលគួរចាត់ចែងទុក ខាទនីយភោជនីយាហារដែលគួរចាត់ចែងនោះ

មានពោរពាស តែក្នុងវេលាយប់ ដល់វេលាថ្ងៃមានតិច បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះអង្គទាំងឡាយនោះ បែរជាបាននូវសេចក្តីស្រឡាញ់ សេចក្តីគោរព សេចក្តីខ្មាសបាប និងសេចក្តីខ្លាចបាប ចំពោះព្រះមានព្រះភាគវិញ កាលបើយ៉ាងនេះ ទើបយើងខ្ញុំព្រះអង្គ លះបង់នូវការបរិភោគនូវភោជនក្នុងវេលាយប់ ដែលជាវេលាវិកាលនុ៎ះចេញ ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាត ក្នុងវេលារាត្រីងងឹតសូន្យសុង ក៏ចូលទៅប្រទះនឹងអណ្តូងជ្រាំខ្លះ ធ្លាក់ទៅក្នុងទីទំនាបទឹកជ្រាំខ្លះ ឡើងទៅប្រទះគំនរបន្លាខ្លះ ដើរជាន់ទៅលើមេគោកំពុងដេកលក់ខ្លះ ជួបប្រទះនឹងពួកមាណពគឺចោរ ដែលកំពុងធ្វើចោរកម្មខ្លះ មិនទាន់បានធ្វើចោរកម្មខ្លះ មាតុគ្រាមនិមន្តពួកភិក្ខុនោះដោយអសទ្ធម្មខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ ខ្ញុំព្រះអង្គត្រាច់ទៅបិណ្ឌបាតក្នុងវេលារាត្រីងងឹតសូន្យសុង បពិត្រព្រះអង្គដ៏ចម្រើន ស្រីម្នាក់កំពុងលាងភាជនៈ បានឃើញខ្ញុំព្រះអង្គក្នុងពេលមានផ្លេកបន្ទោរ លុះឃើញខ្ញុំព្រះអង្គហើយ ក៏ភិតភ័យស្រែកយ៉ាងខ្លាំងថា អញវិនាសហើយ យីអើ អ្នកនេះ ជាបិសាច ( មកប្រហែងស៊ី ) អញទេដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន កាលស្រីនោះស្រែកយ៉ាងនេះហើយ ខ្ញុំព្រះអង្គបាននិយាយពាក្យនេះនឹងស្រីនោះថា ម្នាលប្អូនស្រី មិនមែនបិសាចទេ ភិក្ខុឈរបិណ្ឌបាតទេតើ ។ ស្រីនោះឆ្លើយតបថា ឪពុករបស់ភិក្ខុស្លាប់ហើយ ម្តាយរបស់ភិក្ខុស្លាប់ហើយ ម្នាលភិក្ខុ លោកវះនូវផ្ទៃរបស់លោក ដោយកាំបិតដ៏មុតសម្រាប់វះគោប្រសើរជាង លោកត្រាច់ទៅក្នុងវេលារាត្រីងងឹតសូន្យសុង

ព្រោះហេតុតែផ្លែ មិនប្រសើរទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គនោះ រឭកឃើញដំណើរនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាទុក្ខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវធម៌ជាសុខច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់កម្ចាត់បង់នូវធម៌ជាអកុសលច្រើនយ៉ាង ឱហ្ន៎ ព្រះមានព្រះភាគរបស់យើង ទ្រង់ប្រកបនូវពួកធម៌ជាកុសលច្រើនយ៉ាង ។

[ ១៧៧ ] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលឧទាយី ដូចយ៉ាងមោឃបុរសពួកខ្លះក្នុងលោកនេះ កាលតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់នូវអំពើនេះចេញ ពួកមោឃបុរសទាំងនោះ ក៏និយាយយ៉ាងនេះថា ចុះសមណៈនេះ សព្វបើហេតុប៉ិចប៉ុ បន្តិចបន្តួច ក៏ប្រិតអ្វីដល់ម៉្លេះ ពួកមោឃបុរសទាំងនោះ ក៏មិនលះបង់នូវអំពើនោះចេញទេ ថែមទាំងធ្វើសេចក្តីអាក់អន់ឲ្យកើតឡើងចំពោះតថាគតផង ម្នាលឧទាយី ចំណែកពួកភិក្ខុ ដែលជាសិក្ខាកាម ( តែងធ្វើសេចក្តីអាក់អន់នឹងពួកមោឃបុរសនោះ ) កិច្ចដែលត្រូវលះបង់បន្តិចបន្តួច របស់ពួកមោឃបុរសនោះ ទុកដូចជាចំណងមានកម្លាំង ចំណងមាំ ចំណងជាប់ ចំណងមិនពុកផុយ ឬដូចកំណាត់ឈើធំ ។ ម្នាលឧទាយី សត្វប្រចៀច ដែលជាប់ដោយចំណងវល្លិផោម តែងដល់នូវការសម្លាប់ ឬនូវការចង ឬក៏នូវសេចក្តីស្លាប់ ក្នុងទីនោះឯង ម្នាលឧទាយី បើបុគ្គលណានិយាយយ៉ាងនេះថា សត្វប្រចៀចនោះ ជាប់ដោយចំណងវល្លិផោមណា តែងដល់នូវការសម្លាប់ ឬនូវការចង ឬក៏នូវសេចក្តីស្លាប់ ក្នុងទីនោះ ចំណងនោះ

របស់សត្វនោះ ជាចំណងឥតកម្លាំង ជាចំណងមិនមាំ ជាចំណងពុកផុយ ជាចំណងមិនមានខ្លឹមទេ ម្នាលឧទាយី បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន សត្វប្រចៀចនោះ ជាប់ដោយចំណងវល្លិផោមណា តែងដល់នូវការសម្លាប់ ឬនូវការចង ឬក៏នូវសេចក្តីស្លាប់ ក្នុងទីនោះ ឯចំណងនោះ របស់សត្វនោះ ជាចំណងមានកម្លាំង ជាចំណងមាំ ជាចំណងជាប់ ជាចំណងមិនពុកផុយ ជាកំណាត់ឈើធំ ។ ម្នាលឧទាយី យ៉ាងនោះឯងហើយ រឿងនេះ ដូចមោឃបុរសពួកខ្លះក្នុងលោកនេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយ ចូរលះបង់នូវអំពើនេះចេញ ពួកមោឃបុរសទាំងនោះ ក៏ត្រឡប់និយាយយ៉ាងនេះថា ចុះសមណៈនេះ សព្វបើហេតុប៉ិចប៉ុ បន្តិចបន្តួច ក៏ប្រិតអ្វីដល់ម្ល៉េះ ពួកមោឃបុរសនោះ ក៏មិនលះបង់នូវអំពើនោះចោលឡើយ ថែមទាំងធ្វើសេចក្តីអាក់អន់ឲ្យកើតឡើងដល់តថាគត ម្នាលឧទាយី ចំណែកពួកភិក្ខុដែលជាសិក្ខាកាម ( ក៏ធ្វើសេចក្តីអាក់អន់ចិត្ត ចំពោះមោឃបុរសទាំងនោះ ) កិច្ចដែលត្រូវលះបង់បន្តិចបន្តួចរបស់ពួកមោឃបុរសទាំងនោះ ទុកដូចជាចំណងមានកម្លាំង ជាចំណងមាំ ជាចំណងជាប់ ជាចំណងមិនពុកផុយ ឬទុកដូចជាកំណាត់ឈើធំ ។

[ ១៧៨ ] ម្នាលឧទាយី មួយទៀត ពួកកុលបុត្រក្នុងសាសនានេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយ ចូរលះបង់អំពើនេះចេញ ពួកកុលបុត្រនោះ បាននិយាយយ៉ាងនេះថា ព្រះមានព្រះភាគ ត្រាស់ឲ្យយើងទាំងឡាយ លះបង់

នូវអំពើណា ព្រះសុគត ត្រាស់ឲ្យយើងលះបង់ចោលនូវអំពើណា ថ្វីបើអំពើនេះ ជាហេតុរប៉ុចរប៉ុបន្តិចបន្តួច យើងទាំងឡាយត្រូវតែលះបង់ចោលចេញ ពួកកុលបុត្រទាំងនោះ ក៏លះបង់នូវអំពើនោះចេញ ទាំងមិនធ្វើឲ្យទាស់អធ្យា-ស្រ័យតថាគតឡើយ មួយវិញទៀត ភិក្ខុណា ដែលជាសិក្ខាកាម ពួកភិក្ខុនោះ ក៏បានលះបង់នូវអំពើនោះចេញ ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ជាអ្នកសម្បុរោម ជាអ្នកចិញ្ចឹមជីវិតដោយចតុប្បច្ច័យ ដែលអ្នកដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ ម្នាលឧទាយិ ភិក្ខុនោះ ឈ្មោះថា មានចំណងមិនមានកម្លាំង មានចំណងខ្សោយ មានចំណងផុយ មានចំណងឥតខ្លឹម ។ ម្នាលឧទាយិ ដូចដំរីរបស់ព្រះរាជា ដែលមានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម គេចងដោយចំណង ព្រ័ត្រយ៉ាងមាំ ក៏ទម្រោមកាយបន្តិចហើយ កាត់ទម្លាយនូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ម្នាលឧទាយិ បុគ្គលណា ពោលយ៉ាងនេះថា ដំរីរបស់ព្រះរាជានោះ ជាដំរីមានភ្លុកងទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះកាន់សង្គ្រាម គេចងដោយចំណងព្រ័ត្រដ៏មាំណា ក៏ទម្រោមកាយបន្តិចហើយ កាត់ទម្លាយនូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ដំរីនោះ ឈ្មោះថា មានចំណងមានកម្លាំង មានចំណងមាំ មានចំណងខ្ជាប់ខ្ជួន មានចំណងមិនផុយ ឬទុកដូចជាកំណាត់ឈើធំ ម្នាលឧទាយិ បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវ ឬដូចម្តេច ។ សូមទ្រង់ព្រះមេត្តាប្រោស គេនិយាយនោះមិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន ដំរីរបស់ព្រះរាជានោះ ជាដំរីមានភ្លុកង

ទន្ទាំ មានរូបសមរម្យគួរជាព្រះទីនាំង ជាសត្វធ្លាប់ចុះសង្គ្រាម គេចងដោយចំណងព្រ័ត្រដ៏មាំណា ក៏ទម្រោមកាយបន្តិច ហើយកាត់ទម្លាយ នូវចំណងទាំងនោះ រួចចៀសចេញទៅតាមប្រាថ្នា ព្រោះថា ដំរីនោះ មានចំណាងមិនមានកម្លាំង ។បេ។ មានចំណាងឥតខ្លឹម ។ ម្នាលឧទាយិ យ៉ាងនោះឯងហើយ រឿងនេះ ដូចពួកកុលបុត្រខ្លះ ក្នុងសាសនានេះ កាលតថាគត ពោលថា អ្នកទាំងឡាយ ចូរលះបង់អំពើនេះចេញ ដូច្នេះ ពួកកុលបុត្រនោះ ពោលយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ឲ្យយើងទាំងឡាយ លះបង់អំពើណា ព្រះសុគតត្រាស់ឲ្យយើងទាំងឡាយលះបោលអំពើណា ថ្វីបើអំពើនេះ ជាហេតុរបុិចរបុិបន្តិចបន្តួច យើងទាំងឡាយត្រូវតែលះបង់ចោលចេញ ពួកកុលបុត្រនោះ ក៏លះបង់នូវអំពើនោះចេញបាន ទាំងមិនធ្វើឲ្យទាស់អធ្យាស្រ័យតថាគត មួយទៀត ពួកភិក្ខុណា ដែលជាសិក្ខាកាម ពួកភិក្ខុនោះ បានលះបង់នូវអំពើនោះ ជាអ្នកខ្វល់ខ្វាយតិច ជាអ្នកសម្ងបរោម ជាអ្នកប្រព្រឹត្តចិញ្ចឹមជីវិត ដោយបច្ច័យដែលបុគ្គលដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ ម្នាលឧទាយិ អំពើរបស់កុលបុត្រនោះ ទុកដូចជាចំណាងឥតកម្លាំង ចំណាងផុយចំណាងឥតខ្លឹម ។

[ ១៧៩ ] ម្នាលឧទាយិ ដូចបុរសកម្សត់ដែលឥតយស មិនមានសម្បត្តិស្តុកស្តម្ភ បុរសនោះ មានខ្ទមតូច ១ រខេករខាក ក្អែកហើរកាត់ចុះឡើងបាន មានរាងរៅមិនល្អ មានគ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត មានរាងមិនចំណាប់ មានស្រូវនិងពូជសម្រាប់សាបព្រោះរាល់ឆ្នាំ ១

ក្អម ជាពូជមិនល្អ មានស្ត្រីម្នាក់ជាប្រពន្ធដែលមានរូបមិនល្អ បុរសនោះ ឃើញភិក្ខុ ១ រូប នៅក្នុងអារាមដែលលាងដៃជើងស្អាតល្អ បរិភោគភោជនជាទីពេញចិត្ត អង្គុយតែក្នុងម្លប់ត្រជាក់ ប្រកបក្នុងអធិចិត្ត ។ បុរសនោះ ក៏គិតយ៉ាងនេះថា អើភាពជាសមណៈ សុខណាស់ហ្ន៎ ភាពជាសមណៈឥតមានរោគអ្វីសោះ គួរតែអាត្មាអញ កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ តែបុរសនោះ មិនអាចនឹងលះបង់នូវផ្ទះតូចដែលរខេករខាក ក្អែកហើរកាត់ចុះឡើងបាន ដែលមានរាងរៅមិនល្អ មិនអាចនឹងលះបង់នូវគ្រែ ១ ដែលវែងដោយបន្ទោះឫស្សីទ្រេតទ្រោត រាងរៅមិនចំណាប់ មិនអាចនឹងលះបង់នូវស្រូវនិងពូជ សម្រាប់ព្រោះរាល់ឆ្នាំ ១ ក្អម ដែលជាពូជមិនល្អ មិនអាចនឹងលះបង់នូវស្ត្រីម្នាក់ជាប្រពន្ធ ដែលមានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសបានឡើយ ។ ម្នាលឧទាយី បុគ្គលណានិយាយយ៉ាងនេះថា បុរសនោះ ជាប់ដោយចំណងណា ទើបមិនអាចនឹងលះបង់នូវផ្ទះតូច ដែលរខេករខាក ក្អែកហើរកាត់ចុះកាត់ឡើងបាន មានរាងរៅមិនល្អ មិនអាចនឹងលះបង់នូវគ្រែ ១ ដែលវែងដោយបន្ទោះឫស្សីទ្រេតទ្រោត រាងរៅមិនចំណាប់ មិនអាចនឹងលះបង់នូវស្រូវនិងពូជ សម្រាប់សាបព្រោះរាល់ឆ្នាំ ១ ក្អម ដែលជាពូជមិនល្អ មិនអាចនឹងលះបង់នូវស្ត្រីម្នាក់ជាប្រពន្ធ ដែលមានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសបានឡើយ

ព្រោះចំណងរបស់បុរសនោះ ជាចំណងធូរ ចំណងខ្សោយ ចំណងផុយ ចំណងឥតខ្លឹម ម្នាលឧទាយិ បុគ្គលដែលនិយាយនោះ ឈ្មោះថា និយាយត្រូវ ឬដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន គេនិយាយនេះ មិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះជាប់ដោយចំណងណា ហើយមិនអាចនឹងលះបង់នូវផ្ទះតូចមួយ ដែលរខេករខាក ក្អែកហើរកាត់ចុះកាត់ឡើងបាន មានរាងរៅមិនល្អ មិនអាចនឹងលះបង់នូវគ្រែ ១ ដែលវែងដោយបន្ទោះឫស្សី ទ្រេតទ្រោត មានរាងរៅមិនចំណាប់ មិនអាចនឹងលះបង់នូវស្រូវនិងពូជសម្រាប់សាបព្រោះរាល់ឆ្នាំ ១ ក្អម ដែលជាពូជមិនល្អ មិនអាចនឹងលះបង់នូវស្ត្រីម្នាក់ជាប្រពន្ធ ដែលមានរូបមិនល្អ ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈរួចចេញចាកផ្ទះចូលទៅកាន់ផ្នួសបានឡើយ ព្រោះថា ចំណងរបស់បុរសនោះ ជាចំណងតឹង ចំណងមាំ ចំណងខ្ជាប់ខ្ជួន ចំណងមិនផុយ ឬទុកដូចជាកំណាត់ឈើធំ ។ ម្នាលឧទាយិ យ៉ាងនោះឯងហើយ រឿងនេះ ដូចមោឃបុរសពួកខ្លះ ក្នុងលោកនេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយ ចូរលះបង់អំពើនោះចេញ ពួកមោឃបុរសទាំងនោះ និយាយយ៉ាងនេះថា ចុះសមណៈនេះ សព្វបើហេតុរបុិចរបុិបន្តិចបន្តួច ក៏ប្រិតអ្វីដល់ម្ល៉េះ ហើយពួកមោឃបុរសទាំងនោះ ក៏មិនលះបង់នូវអំពើនោះចោលឡើយ ថែមទាំងធ្វើឲ្យទាស់អធ្យាស្រ័យតថាគតទៀត ចំណែកពួកភិក្ខុ ដែលជាសិក្ខាកាម ( តែងធ្វើសេចក្តីអាក់អន់ចិត្ត ចំពោះមោឃបុរសទាំងនោះ ) ម្នាលឧទាយិ កិច្ចដែលត្រូវលះបង់បន្តិចបន្តួចរបស់មោឃបុរសទាំងនោះ ទុកជាចំណងតឹង ចំណង

មាំ ចំណងខ្ជាប់ខ្ជួន មិនមែនជាចំណងពុកផុយ ឬទុកដូចកំណាត់ឈើធំ ។

[ ១៨០ ] ម្នាលឧទាយី ដូចគហបតីក្តី គហបតិបុត្រក្តី ជាអ្នកស្តុកស្តម្ភ មានទ្រព្យសម្បត្តិច្រើន មានគ្រឿងប្រើប្រាស់ច្រើន ជាអ្នកសន្សំនូវគំនរមាសធ្លោរទុកច្រើន ជាអ្នកសន្សំនូវគំនរស្រូវទុកច្រើន ជាអ្នកសន្សំនូវចំនួនស្រែទុកច្រើន ជាអ្នកសន្សំនូវចំនួនចម្ការទុកច្រើន ជាអ្នកសន្សំនូវពួកភរិយាទុកច្រើន ជាអ្នកសន្សំនូវពួកខ្ញុំប្រុសទុកច្រើន ជាអ្នកសន្សំនូវពួកខ្ញុំស្រីទុកច្រើន គហបតីនោះ ឃើញភិក្ខុក្នុងអារាមដែលមានដៃជើងលាងស្អាតល្អ ឆាន់ភោជនជាទីគាប់ចិត្ត អង្គុយក្នុងម្លប់ត្រជាក់ប្រកបក្នុងអធិចិត្ត ។ គហបតី ឬគហបតិបុត្រនោះ ក៏គិតថា អើ ភាពជាសមណៈ សុខណាស់ហ្ន៎ ភាពជាសមណៈ ឥតមានរោគសោះហ្ន៎ គួរតែអាត្មាអញ កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ជននោះ ក៏អាចលះបង់នូវគំនរមាសធ្លោរច្រើន លះបង់នូវគំនរស្រូវច្រើន លះបង់នូវចំនួនស្រែច្រើន លះបង់នូវចំនួនចម្ការច្រើន លះបង់នូវពួកភរិយាច្រើន លះបង់នូវពួកខ្ញុំប្រុសច្រើន លះបង់នូវពួកខ្ញុំស្រីច្រើនបាន ហើយកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ម្នាលឧទាយី បុគ្គលណានិយាយយ៉ាងនេះថា គហបតីក្តី គហបតិបុត្រក្តី ជាប់ដោយចំណងណា ហើយអាចលះបង់នូវគំនរមាសធ្លោរជាច្រើន លះបង់នូវគំនរស្រូវជាច្រើន លះបង់នូវចំនួនស្រែជាច្រើន លះបង់នូវចំនួនចម្ការជាច្រើន លះបង់នូវពួកភរិយាជាច្រើន លះបង់នូវពួកខ្ញុំប្រុសជាច្រើន លះ

បង់នូវពួកខ្ញុំស្រីជាច្រើន ហើយកោរសក់និងពុកមាត់ពុកចង្កា រួចស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសបាន ព្រោះចំណងនោះរបស់ជននោះ ជាចំណងតឹង ជាចំណងមាំ ចំណងខ្ជាប់ខ្ជួន មិនមែនជាចំណងផុយ ទុកដូចកំណាត់ឈើធំ ដូច្នេះ ម្នាលឧទាយិ បុគ្គលដែលនិយាយនោះ ឈ្មោះថានិយាយត្រូវ ឬដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន គេនិយាយយ៉ាងនេះ មិនត្រូវទេ បពិត្រព្រះអង្គដ៏ចម្រើន គហបតីក្តី គហបតិបុត្រក្តី ទោះជាប់ដោយចំណងណា ហើយអាចលះបង់នូវគំនរមាសគ្គោរច្រើនបាន លះបង់នូវគំនរស្រូវច្រើនបាន លះបង់នូវចំនួនស្រែច្រើនបាន លះបង់នូវចំនួនចម្ការច្រើនបាន លះបង់នូវពួកភរិយាច្រើនបាន លះបង់នូវពួកខ្ញុំប្រុសច្រើនបាន លះបង់នូវពួកខ្ញុំស្រីជាច្រើន ហើយកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសបាន ព្រោះថា ចំណងនោះ របស់ជននោះ មិនមែនជាចំណងតឹង ជាចំណងខ្សោយ ជាចំណងផុយ ជាចំណងឥតខ្លឹម ។ ម្នាលឧទាយិ យ៉ាងនោះឯងហើយ រឿងនេះ ដូចពួកកុលបុត្រខ្លះក្នុងសាសនានេះ កាលតថាគតប្រាប់ថា អ្នកទាំងឡាយចូរលះបង់នូវអំពើនេះចេញ ពួកកុលបុត្រនោះ ក៏ពោលយ៉ាងនេះថា ព្រះមានព្រះភាគ ត្រាស់ឲ្យយើងទាំងឡាយលះបង់អំពើណា ព្រះសុគតត្រាស់ឲ្យយើងលះបង់អំពើណា ថ្វីបើអំពើនោះ ជាអំពើរបុិចរបុិបន្តិចបន្តួច យើងត្រូវតែលះបង់ចោលចេញ ហើយពួកកុលបុត្រនោះ ក៏បានលះបង់នូវអំពើនោះចេញ ទាំងមិនធ្វើឲ្យទាស់អធ្យាស្រ័យតថាគតឡើយ មួយវិញទៀត ពួកភិក្ខុណា ដែលជាសិក្ខាកាម

ភិក្ខុទាំងនោះ លះបង់នូវអំពើនោះ ហើយជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច ជាអ្នកសម្ងបរោម ជាអ្នកប្រព្រឹត្តចិញ្ចឹមជីវិត ដោយបច្ច័យដែលអ្នកដទៃឲ្យ មានចិត្តប្រព្រឹត្តដូចជាសត្វម្រឹគ ម្នាលឧទាយី អំពើរបស់ភិក្ខុនោះ ទុកដូចជាចំណងធូរ ចំណងទុព្វលភាព ចំណងផុយ ចំណងឥតខ្លឹម ។

[ ១៨១ ] ម្នាលឧទាយី បុគ្គលទាំងឡាយ ៤ ពួកនេះ តែងមានប្រាកដក្នុងលោក បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ម្នាលឧទាយី បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ សេចក្តីរឭកឃើញនិងការត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ បុគ្គលនោះ ក៏ស៊ូអត់ទ្រាំ មិនលះបង់ មិនបន្ទោបង់ មិនធ្វើឲ្យវិនាស មិនធ្វើឲ្យមានកំណើតទៀត នូវឧបធិទាំងនោះឡើយ ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាកកិលេសទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយផ្សេងៗ ( មាន ) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ សេចក្តីរឭកឃើញនិងសេចក្តីត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់នូវបុគ្គលនោះ ដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ បុគ្គលនោះ មិនអត់ទ្រាំ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀត នូវឧបធិទាំងនោះ ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯង

ថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាកកិលេសទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយផ្សេងៗ (មាន) ក្នុងបុគ្គលនោះ ។ ម្នាលឧទាយិ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ ការរឭកឃើញ និងសេចក្តីត្រិះរិះ ដែលប្រកបដោយឧបធិ តែងគ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិ ដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ ព្រោះការភ្លេចស្មារតីក្នុងកាលម្តងៗ ម្នាលឧទាយិ ការកើតឡើងនៃសតិ ជាការយឺតយូរ តែបុគ្គលនោះ លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតទៀត នូវឧបធិនោះដោយឆាប់រហ័ស ។ ម្នាលឧទាយិ បុរសចាក់ដំណក់ទឹកពីរបីតំណក់ ទៅក្នុងខ្ទះដែកដែលគេដុតអស់មួយថ្ងៃ ម្នាលឧទាយិ ការស្រក់ចុះនៃតំណក់នោះ រមែងយឺតយូរ តែតំណក់ទឹកនោះ ក៏ដល់នូវការរីងស្ងួតអស់ទៅ ដោយឆាប់រហ័ស សេចក្តីនេះ មានឧបមាយ៉ាងណា ម្នាលឧទាយិ មានឧបមេយ្យដូចបុគ្គលពួកមួយ ក្នុងលោកនេះ ប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ ការរឭកឃើញនិងសេចក្តីត្រិះរិះ ដែលប្រកបដោយឧបធិ រមែងគ្របសង្កត់បុគ្គលនោះ ដែលប្រតិបត្តិដើម្បីលះបង់ឧបធិ ដើម្បីរលាស់ចោលនូវឧបធិ ព្រោះការភ្លេចស្មារតីក្នុងកាលម្តងៗ ម្នាលឧទាយិ ការកើតឡើងនៃស្មារតីជាការយឺតយូរ តែបុគ្គលនោះ លះបង់ បន្ទោរបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យមានកំណើតទៀត នូវឧបធិនោះ ដោយឆាប់រហ័ស ម្នាលឧទាយិ តថាគតហៅបុគ្គលនេះឯងថា ជាអ្នកប្រកបដោយកិលេស មិនហៅថា ជាអ្នកប្រាសចាក

កិលេសទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយផ្សេងៗ គ្នា ( មាន ) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលពួកមួយ ក្នុងលោកនេះ ដឹងច្បាស់ថា ឧបធិគឺបញ្ចក្ខន្ធ ជាឫសគល់នៃសេចក្តីទុក្ខដូច្នេះ តែជាអ្នកឥតមានឧបក្កិលេស មានចិត្តជឿស៊ប់ក្នុងព្រះនិព្វាន ជាគ្រឿងអស់ទៅនៃឧបធិក្កិលេស ម្នាលឧទាយី តថាគតហៅបុគ្គលនេះឯងថាជាអ្នកប្រាសចាកឧបធិក្កិលេស មិនហៅថា ប្រកបដោយឧបធិក្កិលេសឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលឧទាយី ព្រោះតថាគតដឹងច្បាស់ថា ឥន្ទ្រិយដែលផ្សេងៗ គ្នា ( មាន ) ក្នុងបុគ្គលនេះ ។ ម្នាលឧទាយី បុគ្គលទាំងឡាយ ៤ ពួកនេះឯង ដែលមានប្រាកដក្នុងលោក ។

[ ១៨២ ] ម្នាលឧទាយី កាមគុណនេះ មាន ៥ ប្រការ កាមគុណ ៥ ប្រការ តើអ្វីខ្លះ គឺ រូបទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយចក្ខុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួររីករាយ ១ សំឡេងទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយត្រចៀក ... ១ ក្លិនទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយច្រមុះ ... ១ រសទាំងឡាយ ដែលបុគ្គលគប្បីដឹងបានដោយអណ្តាត ... ១ ផោដ្ឋព្វៈទាំងឡាយ ដែលបុគ្គលគប្បីដឹងបាន ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ១ ។ ម្នាលឧទាយី នេះឯងហៅថា កាមគុណ ៥ ប្រការ ។ ម្នាលឧទាយី សុខនិងសោមនស្សណាកើតឡើងព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ សេចក្តីសុខនិងសោ-

មនស្សនេះ តថាគតហៅថា ជាសុខក្នុងកាម ជាសុខមិនស្អាត ជាសុខរបស់បុថុជ្ជន មិនមែនជាសុខរបស់ព្រះអរិយៈ ដែលគេមិនគួរធ្វើឲ្យច្រើន មិនគួរចម្រើន មិនគួរធ្វើឲ្យរឿយៗ ឡើយ តថាគតពោលថា គួរខ្លាចសេចក្តីសុខនេះ ។

[ ១៨៣ ] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ភិក្ខុព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន ព្រោះលះបង់សេចក្តីសុខ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន នេះទើបតថាគតហៅថា សុខផុតចាកកាម សុខស្ងប់ស្ងាត់ សុខស្ងប់រម្ងាប់ សុខប្រព្រឹត្តទៅដើម្បីសេចក្តីត្រាស់ដឹង ដែលបុគ្គលគួរធ្វើឲ្យច្រើន គួរចម្រើន គួរធ្វើឲ្យរឿយៗ តថាគតហៅថា បុគ្គលមិនគួរខ្លាចសេចក្តីសុខនេះឡើយ ។

[ ១៨៤ ] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា បឋមជ្ឈាននោះឯង ជាធម្មជាតញាប់ញ័រនៅឡើយ អ្វីដែលញាប់ញ័រក្នុងបឋមជ្ឈាននោះ វិតក្កៈនិងវិចារៈណា ក្នុងបឋមជ្ឈាននោះ ដែលមិនទាន់រម្ងត់នៅឡើយ នេះឯងជាធម្មជាតញាប់ញ័រ ក្នុងបឋមជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ចូលកាន់ទុតិយជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា ទុតិយជ្ឈាននេះឯង ជាធម្មជាតញាប់ញ័រនៅឡើយ ចុះអ្វីដែលញាប់ញ័រក្នុងទុតិយជ្ឈាននោះ បីតិនិងសុខណា ក្នុងទុតិយជ្ឈាននោះ ដែលមិនទាន់រម្ងត់នៅឡើយ នេះឯង ជាធម្មជាត

ញាប់ញ័រ ក្នុងទុតិយជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា តតិយជ្ឈាននេះឯង ជាធម្មជាតញាប់ញ័រនៅឡើយ ចុះអ្វីដែលញាប់ញ័រក្នុងតតិយជ្ឈាននោះ ឧបេក្ខានិងសុខណា ក្នុងតតិយជ្ឈាននោះ ដែលមិនទាន់រម្ងត់នៅឡើយ នេះឯង ជាធម្មជាតញាប់ញ័រ ក្នុងតតិយជ្ឈាននោះ ។ ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលឧទាយី តថាគតពោលថា ចតុត្ថជ្ឈាននេះឯង ជាធម្មជាតឥតមានញាប់ញ័រឡើយ ។

[ ១៨៥ ] ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ។បេ។ ចូលកាន់បឋមជ្ឈាន ។ ម្នាលឧទាយី តថាគតពោលនូវបឋមជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថាអ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងចេញនូវបឋមជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈទាំងឡាយ ។បេ។ ចូលកាន់ទុតិយជ្ឈាន នេះហៅថា ការកន្លងនូវបឋមជ្ឈាននោះ ។ ម្នាលឧទាយី តថាគតពោលនូវទុតិយជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងទុតិយជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះប្រាសចាកបីតិ ។បេ។ ចូលកាន់តតិយជ្ឈាន នេះហៅថា ការកន្លងនូវទុតិយជ្ឈាននោះ ។បេ។ ម្នាលឧទាយី

តថាគតពោលនូវតតិយជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវតតិយជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់នូវសុខ ។បេ។ ចូលកាន់ចតុត្ថជ្ឈាននេះឯង ហៅថា ការកន្លងនូវតតិយជ្ឈាននោះ ។ ម្នាលឧទាយី តថាគតពោលនូវចតុត្ថជ្ឈាននេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវចតុត្ថជ្ឈាននោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ ព្រោះកន្លងបង់នូវរូបសញ្ញា ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនមានមនសិការៈចំពោះនានត្តសញ្ញា ដោយប្រការទាំងពួង ចូលកាន់អាកាសានញ្ចាយតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុត នេះហៅថា ការកន្លងនូវចតុត្ថជ្ឈាននោះ ។ ម្នាលឧទាយី តថាគតពោលនូវអាកាសានញ្ចាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវអាកាសានញ្ចាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវអាកាសានញ្ចាយតនៈដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ នេះហៅថាការកន្លងនូវអាកាសានញ្ចាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវវិញ្ញាណញ្ចាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយចូរលះបង់ចេញ ពោលថាអ្នក

ទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវវិញ្ញាណញ្ចាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវវិញ្ញាណញ្ចាយ-តនៈ ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា អ្វីតិចតួចមិនមាន ដូច្នេះ នេះហៅថាការកន្លងនូវវិញ្ញាណញ្ចាយតនៈ នោះ ។ ម្នាលឧទាយី តថាគតពោលនូវអាកិញ្ចញ្ញាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវអាកិញ្ចញ្ញាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះហៅថា ការកន្លងនូវអាកិញ្ចញ្ញាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវនេវស-ញ្ញានាសញ្ញាយតនៈនេះឯងថា មិនទាន់ល្មមទេ តថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ចេញ ពោលថា អ្នកទាំងឡាយ ចូរកន្លងឲ្យផុតចេញ ។ ចុះការកន្លងនូវនេវសញ្ញានាសញ្ញាយតនៈនោះ តើដូចម្តេច ម្នាលឧទាយី ភិក្ខុក្នុងសាសនានេះ កន្លងនូវនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង ហើយចូលកាន់សញ្ញាវេទយិតនិរោធ ( ការរលត់សញ្ញាព្រមទាំងវេទនា ) នេះហៅថា ការកន្លងនូវនេវសញ្ញានាសញ្ញាយតនៈនោះ ។ ម្នាលឧទាយី តថាគតពោលនូវការលះបង់នូវនេវសញ្ញានាសញ្ញាយតនៈ ដូច្នេះឯង ។ ម្នាលឧទាយី តថាគតពោលនូវការលះបង់សំយោជនៈណា អ្នកឃើញនូវសំយោជនៈទាំងតូចទាំងធំនោះឬទេ ។ ឧទាយីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិន

ឃើញទេ ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះឧទាយីមានអាយុ ក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ លដុកិកោបមសូត្រ ជាគម្រប់ ៦

# អដ្ឋកថា

## លដុកិកោបមសូត្រ

[ ១៧៥ ] លដុកិកោបមសូត្រ មានពាក្យផ្ដើមថា **ឯកំ សមយំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **យេន សោ វនសណ្ឌោ** សេចក្ដីថា ព្រះមហាឧទាយិត្ថេរនេះ ចូលទៅបិណ្ឌបាតជាមួយព្រះមានព្រះភាគ ហើយចៀសចេញទៅជាមួយព្រះមានព្រះភាគនោះ ។ ព្រោះដូច្នោះ គប្បីជ្រាបថា ព្រះមហាឧទាយិត្ថេរចូលទៅកាន់ដងព្រៃ ដែលព្រះមានព្រះភាគ គប្បីយាងចូលទៅ ។ បទថា **អបហាត្ថា** គឺនាំចេញទៅ ។ បទថា **ឧបហាត្ថា** គឺនាំចូលទៅ ។ បទថា **បដិសល្លានា វុដ្ឋិតោ** ព្រះមហាឧទាយី ចេញអំពីទីសម្ងំ គឺចេញអំពីផលសមាបត្តិ ។

[ ១៧៦ ] បទថា **យំ ភគវា** សេចក្ដីថា ក្នុងសម័យណាព្រះមានព្រះភាគ ។ បទថា **សុទំ** ជានិបាត ចុះក្នុងការបញ្ហា ។ បទថា **អញ្ញថត្តំ** សេចក្ដីថា ភាពដែលពេញចិត្តដទៃថា អញមិនបានភោជនដ៏ប្រណីតបែបនេះ ព្រោះអាស្រ័យព្រះមានព្រះភាគអង្គនោះ នឹងញុំាងជីវិតឲ្យប្រព្រឹត្តទៅបានដូចម្ដេច ដោយប្រការដូច្នេះ គប្បីជ្រាបថា ព្រោះអាស្រ័យលោក គឺភោជនដ៏ប្រណីត ទើបរស់នៅបាន ។

ដោយបទថា **ភុត្តបុព្វំ** នេះ ព្រះឧទាយិត្ថេរ សម្ដែងនូវភោជនដែលជារបស់ប្រណីតក្នុងវេលារាត្រី ។ បទថា **សូបេយ្យំ** សេចក្ដីថា របស់គួរដល់សម្ល បានដល់ ត្រី សាច់ និងទំពាំងជាដើម គួរនាំទៅស្ល ។ បទថា **សមគ្គា**

**ភុញ្ជិស្សាម** សេចក្តីថា បរិភោគរួមគ្នា ។ បទថា **សន្ទិវិយោ** គឺរបស់ទំពាសម្រាប់ចម្អិនបរិភោគ ។ បទថា **សព្វា តា រត្តឹ** គឺរបស់ទំពាសម្រាប់ចម្អិនបរិភោគទាំងអស់នោះ រមែងមានរសក្នុងពេលយប់ ។ តែពេលថ្ងៃមានរសតិចតួច ។ ព្រោះពេលថ្ងៃមនុស្សទាំងឡាយញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយបបរលាយបាយជាដើម ពេលយប់ រមែងបរិភោគ តាមចំណែកដែលដល់តាមសតិ តាមការប្រណីត ។ ដោយបទថា **ភូតបុព្វំ** នេះទៀត ព្រះឧទាយិត្ថេរសម្តែងដល់ទោសក្នុងការបរិភោគក្នុងពេលយប់ និងវេលាវិកាល ។

ក្នុងបទទាំងនោះ បទថា **អន្ធការតិមិសាយ** បានដល់ ក្នុងវេលាងងឹតខ្លាំង ។ បទថា **មាណវេហិ** បានដល់ ពួកចោរ ។ បទថា **កតកម្មេហិ** គឺធ្វើចោរកម្ម ។ បានឮថា ចោរទាំងនោះធ្វើចោរកម្ម សម្លាប់មនុស្សហើយកាន់យកឈាមក្នុងបំពង់កជាដើម ដើម្បីត្រូវការនាំកម្មដែលសម្រេច ព្រោះបានបន់ស្រន់ទេវតាទុក ហើយចូលទៅលាបំណន់ ។ ពួកចោរទាំងនោះសម្គាល់ថា កាលអញសម្លាប់មនុស្សដទៃ ក៏នឹងកើតកោលាហល ។ ឈ្មោះថា អ្នកស្វែងរកបព្វជិតរមែងមិនមាន ទើបចាប់ភិក្ខុទាំងឡាយសម្លាប់ ។ លោកពោលបទនោះ សំដៅដល់សេចក្តីនេះ ។ បទថា **អកតកម្មេហិ** គឺ បំណងនឹងធ្វើពលីកម្មមុន ដើម្បីឲ្យសម្រេចកិច្ចការក្នុងវេលាមកអំពីព្រៃ ចូលក្នុងស្រុក ។ បទថា **អសទ្ធម្មេន និមន្តេតិ** សេចក្តីថា បបួលដោយមេថុនធម្មថា បពិត្រភិក្ខុ សូមលោកម្ចាស់មកចុះ ថ្ងៃនេះលោកនឹងឆាន់ក្នុងទីនេះឯងនិងនៅក្នុងទីនេះអស់រាត្រីមួយ ហើយសោយសម្បត្តិ ស្អែកនេះសឹមទៅ ។

ដោយបទថា **ភូតបុព្វំ** នេះទៀត ព្រះឧទាយិត្ថេរ ពោលដល់ហេតុដែលឃើញដោយខ្លួនឯង ។ បទថា **វិជ្ជន្តរិកាយ** សេចក្តីថា ខណៈដែលផ្លេកបន្ទោរជះពន្លឺ ។ បទថា **វិស្សរមកាសិ** គឺស្រែកដោយសំឡេងខ្លាំង ។ បទ ថា **អភុម្មេ** សេចក្តីថា ពាក្យថា **ភូ** បានដល់ សេចក្តីចម្រើន ពាក្យថា **អភូ** បានដល់ សេចក្តីវិនាស ។ អធិប្បាយថា ការវិនាសនឹងមានដល់អញ ។ បទថា **បិសាចោ វត មំ** គឺមានបិសាចមកស៊ីអញ ។ គប្បីជ្រាបសេចក្តី ក្នុងបទនេះថា **អាតុមារី មាតុមារី** ដូចតទៅនេះ ។ បទថា **អាតុ** បានដល់ ឪពុក ។ បទថា **មាតុ** បានដល់ ម្តាយ ។ លោកអធិប្បាយថា បិតា ឬ មាតារបស់ភិក្ខុណាមាន មាតាបិតាកើតការអាណិតអាសូរភិក្ខុនោះថា ជាកូនរបស់អញ ហើយឲ្យរបស់ទំពា របស់ទាន់ណាមួយ ឲ្យដេកក្នុងទីមួយ ភិក្ខុនោះមិនត្រាច់បិណ្ឌបាត ក្នុងយប់យ៉ាងនេះឡើយ ។ តែមាតាបិតារបស់លោកប្រហែលជាស្លាប់ហើយ ទើបលោកត្រាច់ទៅយ៉ាងនេះ ។

[ ១៧៧ ] បទថា **ឯវមេវំ បន** គឺមោឃបុរសទាំងឡាយមិនឃើញអានិសង្សណាមួយយ៉ាងនោះ ។ ព្រះមានព្រះភាគ កាលទ្រង់តិះដៀល ទើបត្រាស់ថា **ឯវមាហំសុ** ។ ក្នុងបទទាំងនោះ បទថា **អាហំសុ** គឺរមែងពោល ។ បទថា **កឹ បនិមស្ស** គឺហេតុអ្វី ទើបត្រូវពោលព្រោះហេតុនៃ ទោសត្រឹមតែបន្តិចបន្តួចនេះទៅវិញ ។ គួរធ្វើដូចជាមិនឃើញមិនឮ មិនមែនឬ ។ បទថា **ឱរមត្តកស្ស** គឺល្មមប្រមាណ ។ បទថា **អធិសល្លេខតេវាយំ** ព្រោះស-

មណៈនេះប្រហែលជាដុសខាត់ពន់ពេកទៅ គឺសមណៈនេះរមែងដុសខាត់កិ-លេសជ្រុលពេក គឺធ្វើសេចក្ដីព្យាយាមធ្ងន់ពេក ដូចផឹកនវនីត ដូចកាត់ដើមឈូកដោយរណា ។ បទថា **សិក្ខាកាមា** គឺជាអ្នកប្រាថ្នាក្នុងការសិក្សា ដូចព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ដូច្នោះ ។ មិនចូលទៅតាំងការកោតក្រែងក្នុងលោកទាំងនោះ ។ មោឃបុរសទាំងនោះ មានការគិតយ៉ាងនេះថា បើភិក្ខុទាំងនេះគប្បីពោលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់នាំទោសត្រឹមតែបន្តិចបន្តួចចេញទៅ ។ ហេតុអ្វី ព្រះសាស្ដាទ្រង់មិននាំចេញទៅ ។ ម្យ៉ាងទៀត កាលភិក្ខុទាំងឡាយមិនពោលយ៉ាងនេះ អង្គុយចោមរោមព្រះមានព្រះភាគ រមែងបានទូវឧស្សាហៈយ៉ាងក្រៃលែងថា **ឯវំ ភគវា សាធុ ភគវា សាធុ ភគវា បញ្ញាបេថ** សេចក្ដីថា បពិត្រព្រះមានព្រះភាគយ៉ាងនេះ បពិត្រព្រះមានព្រះភាគ ជាការល្អ បពិត្រព្រះមានព្រះភាគ ជាការល្អ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់បញ្ញត្តចុះ ។ ព្រោះដូច្នោះ មោឃបុរសទាំងឡាយ ឈ្មោះថា មិនចូលទៅតាំងការកោតក្រែង ក្នុងភិក្ខុទាំងនោះ ។

បទថា **តេសំ** គឺនៃមោឃបុរសទាំងនោះ ។ បទថា **តំ** គឺគួរលះទោសត្រឹមតិចតួចនោះ ។ បទថា **ថូលោ កលិង្គរោ** ដូចកំណាត់ឈើធំ គឺដូចឈើធំដែលចងត្រង់ក ។ បទថា **លដុកិកា សកុណិកា** គឺសត្វប្រចៀច ។ បានឮថា សត្វប្រចៀចនោះស្រែកមួយរយដង រំមួយរយដង ចេញរកអា-ហារម្ដង ។ មនុស្សចិញ្ចឹមគោជាដើមឃើញសត្វប្រចៀចនោះ ហើរអំពីអា-

កាស ឈរនៅលើផែនដី ទើបយកវល្លិផោមចងទុកដើម្បីលេង ដូចអ្នកចិញ្ចឹមកូនសត្វ ។ លោកពោលឧបមានេះ សំដៅដល់ការចងនោះ ។ បទថា **អាគមេតិ** គឺរមែងដល់ ។ បទថា **តញ្ហិ តស្សា** គឺការចងដោយវល្លិផោមនោះ ឈ្មោះថាជាគ្រឿងចងដែលមានកម្លាំង ព្រោះសត្វប្រចៀចមានរាងកាយតូច និងមានកម្លាំងតិច សូម្បីខ្សែក្នុងស្រកីដូង ក៏គង់ធំ កាត់ផ្តាច់បានលំបាក ។

បទថា **តេសំ** ឈ្មោះថា គ្រឿងចងមានកម្លាំង ព្រោះមោឃបុរសមានសទ្ធាទន់ខ្សោយ និងព្រោះមានបញ្ញាខ្ចី សូម្បីឃើញវត្ថុនៃអាបត្តិទុក្កដ ក៏ដូចជារបស់ធំ លះបានលំបាក ដូចវត្ថុនៃបារាជិក ដូច្នោះ ។

[ ១៧៨ ] គប្បីជ្រាប សេចក្តីក្នុងសុក្កបក្ខៈ គឺ ធម៌ចំណែកសដូចតទៅនេះ ។ បទថា **បហាតព្វស្ស** សេចក្តីថា មានបដិបទាដែលព្រះមានព្រះភាគ គួរត្រាស់ព្រោះហេតុនៃទោសត្រឹមតែបន្តិចបន្តួច ដែលគួរលះនេះ ដែលព្រះមានព្រះភាគ ត្រាស់ឲ្យយើងលះ ។ អធិប្បាយថា សូម្បីជ្រាបបំណងរបស់ព្រះមានព្រះភាគយ៉ាងនេះហើយ ក៏គួរលះមិនមែនឬ ។ បទថា **អប្បោស្សុក្កា** សេចក្តីថា មិនមានខ្វល់ខ្វាយឡើយ ។ បទថា **បន្នលោមា** សេចក្តីថា មិនមានរោមបះ ព្រោះខ្លាច គប្បីលះទោសត្រឹមបន្តិចបន្តួចនោះ ។ បទថា **បរទវុត្តា** គឺភាពជាអ្នកនៅដោយរបស់អ្នកដទៃឲ្យ អធិប្បាយថា ចិញ្ចឹមជីវិតដោយរបស់ដែលបានអំពីអ្នកដទៃ ។ បទថា **មិគភូតេន ចេតសា វិហរន្តិ** គឺ ជាអ្នកតាំងនៅក្នុងចំណែកនៃការមិនជាប់ជំពាក់ ។ ពិតហើយ ម្រឹគបានទទួលការប្រហារហើយ មិនគិតថា

អញនឹង ទៅកាន់ទីលំនៅរបស់មនុស្ស ហើយនឹងបានថ្នាំឬប្រេងលាបដំបៅ កាលបានទទួលការប្រហារហើយ ទើបចូលទៅកាន់ព្រៃដែលមិនមែនស្រុក ធ្វើអាកប្បកិរិយាត្រូវប្រហារទុកខាងក្រោយ ហើយដេក កាលសប្បាយល្អ ក៏ក្រោកទៅ ។ ម្រឹគទាំងឡាយតាំងនៅក្នុងចំណែកនៃការមិនជាប់ជំពាក់យ៉ាងនេះ ។ លោកពោលថា **មិគភូតេន ចេតសា វិហរន្តិ** សំដៅដល់សេចក្តីនេះ ។ បទថា **តញ្ហិ តស្ស** គឺចងដោយខ្សែនោះ ឈ្មោះថាជាគ្រឿងចងដែលស្រាល ព្រោះស្តេចដំរីនោះ មានកាយធំ មានកម្លាំងច្រើន ទើបជាគ្រឿងចង ដែលដាច់បានងាយ ដូចវល្លិផោម ដូច្នោះ ។ បទថា **តេសំ តំ** គឺទោសត្រឹមតែតិចតួចរបស់ភិក្ខុទាំងនោះ ជាទោសដែលលះបានងាយ ព្រោះកុលបុត្រទាំងឡាយមានសទ្ធាច្រើន មានបញ្ញាច្រើន សូម្បីវត្ថុនៃបារាជិកដែលជារបស់ធំ ក៏លះបានងាយ ហាក់ដូចវត្ថុនៃអាបត្តិទុក្កដ ដូច្នោះ ។

[ ១៧៩ ] បទថា **ទលិទ្ទោ** គឺបុគ្គលក្រីក្រ ជាអ្នកប្រកបដោយការខ្វះខាត ។ បទថា **អស្សកោ** គឺមិនមានអ្វីជារបស់ខ្លួន ។ បទថា **អនាឡ្ហិយោ** គឺមិនមែនជាអ្នកស្តុកស្តម្ភ ។ បទថា **អគារិកំ** មានផ្ទះមួយខ្នងតូច ។ បទថា **ឱលុគ្គវិលុគ្គំ** មានគ្រឿងប្រក់ និងគ្រឿងចងពុកផុយ គឺមានគ្រឿងប្រក់ជ្រុះចាកដំបូលចុះមក ទើរលើជញ្ជាំង ជញ្ជាំងជ្រុះមកគរលើផែនដី ។ បទថា **កាកាតិទាយឹ** គឺក្នុងវេលាអន្ធយខាងក្នុង ដោយគិតថានឹងបរិភោគអ្វី ឈ្មោះថាកិច្ចដោយទ្វារមិនមានដោយឡែក ។ បន្ទាប់អំពីនោះ ហ្វូងក្អែក ក៏នឹងចូលទៅចោមរោម តែក្អែកក្លាហាន ក្នុងវេលាគេច ក៏នឹង

គេចចេញទៅភ្លាមៗ ចំពោះមុខ ។ បទថា **ន បរមរូបំ** គឺមានទ្រង់ទ្រាយមិនល្អ ដូចផ្ទះរបស់អ្នកមានបុណ្យ ។ បទថា **កឡោបិកា** គឺមានក្រែតែមួយ ។ បទថា **ឱលុគ្គវិលុគ្គា** គឺជ្រះរាត់រាយ ។ បទថា **ធញ្ញសមវាបកំ** គឺស្រូវ និងពូជសម្រាប់ព្រោះ ។ ក្នុងបទនោះ ស្រូវឈ្មោះថា **ធញ្ញ** ពូជ មានឃ្លោក ត្រឡាចជាដើម ឈ្មោះថា **សមវាបកំ** ។ បទថា **ន បរមរូបំ** គឺ ពូជមិនល្អ ដូចជាពូជរបស់អ្នកមានបុណ្យ មានស្រូវសាលីក្រអូប ដែលជាពូជបរិសុទ្ធល្អជាដើមឡើយ ។ បទថា **ជាយិកា** គឺកិរិយាក្រិក្រ ។ បទថា **ន បរមរូបា** មានរូបមិនស្អាត គឺគួរស្អប់ មានត្រគាកធ្លាក់ ដូចកំប្រោង ដូចបិសាចពោះធំ ។ បទថា **សាមញ្ញំ** គឺភាពជាសមណៈ ។ បទថា **សោ វតស្សំ យោហំ** គឺ អញគួរកោរសក់ ពុកមាត់ពុកចង្កាចេញបួស ។ បទថា **សោ ន សក្កុណេយ្យ** គឺសូម្បីបុគ្គលគិតហើយយ៉ាងនេះ ក៏ត្រឡប់ទៅផ្ទះ ត្រិះរិះថា ឈ្មោះថាបព្វជ្ជា ជាការៈ លំបាកធ្វើបាន លំបាកចូលដល់បាន សូម្បីត្រាច់ទៅបិណ្ឌបាត ក្នុង ៧ ផ្ទះខ្លះ ៨ ផ្ទះខ្លះ ក៏ត្រូវត្រឡប់មកលាងបាត្រ អញមិនអាចនៅយ៉ាងនេះបាន ទើបត្រឡប់មកទៀត នៅផ្ទះអញល្អជាង ទព្វសម្ភារៈមានស្មៅ និងវល្លិ ក៏ប្រមូលធ្វើជញ្ជាំងទុកបាន ។ បព្វជ្ជាធ្វើអ្វីបាន ។ ពេលនោះ ផ្ទះមួយខ្នងតូចរបស់បុគ្គលនោះ ក៏ប្រាកដដូចវេជយន្តប្រាសាទ ។ បន្ទាប់អំពីនោះ បុគ្គលនោះក្រឡេកមើលគ្រែរបស់ខ្លួនហើយគិតថា កាលអញទៅហើយ ជនទាំងឡាយនឹងមិនជួសជុលគ្រែនេះ នឹងធ្វើជាចង្ក្រាន អញគួរបានបួសឬ ធ្វើគ្រែទៀត ។

អញនឹងធ្វើអ្វីជាមួយការបួស ។ ពេលនោះគ្រែរបស់បុគ្គលនោះ ប្រាកដដូចជាដំណេកដ៏មានសិរី ។ បន្ទាប់ពីនោះ បុគ្គលនោះក្រឡេក មើលភ្លមដាក់ស្រូវហើយ គិតថាកាលអញទៅហើយ ស្រីមេផ្ទះនេះ នឹងបរិភោគស្រូវនេះជាមួយបុរសនោះ ។ អញគួរត្រឡប់មកឲ្យការប្រព្រឹត្តិទៅរបស់ជីវិតថ្មី ។ អញនឹងធ្វើអ្វីជាមួយការបួស ។ ពេលនោះ ភ្លមស្រូវរបស់បុគ្គលនោះ ប្រាកដដូចជង្រុក ១២៥០ ខ្នង បន្ទាប់អំពីនោះ បុគ្គលនោះ ក្រឡេកមើលកិរិយាហើយគិតថា កាលអញទៅហើយ អ្នកចិញ្ចឹមដំរីក្តី អ្នកចិញ្ចឹមសេះក្តី ណាមួយ នឹងបៀតបៀនកិរិយានេះ ។ អញគួរត្រឡប់មកបានស្រីចម្អិនអាហារទៀត ។ អញនឹងធ្វើអ្វីជាមួយការបួស ពេលនោះកិរិយារបស់ បុគ្គលនោះ ប្រាកដដូចព្រះទេវីរូបស្អាត ។ លោកសំដៅយកសេចក្តីនេះ ទើបពោលថា **សោ ឆ សត្តុណោយ្យ** ជាដើម ។

[ ១៨០ ] បទថា **ឆិក្ខគណានំ** គឺមាសមួយរយដុំ ។ បទថា **ចយោ** គឺធ្វើការសន្សំបន្តគ្នាមក ។ បទថា **ធញ្ញគណានំ** គឺស្រូវមួយរយរទេះ ។

[ ១៨១ ] ព្រះមានព្រះភាគ ទ្រង់សម្តែងដល់អ្វីក្នុងបទនេះ គឺបទថា **ចត្តារោ មេ ឧទាយិ បុគ្គលា** ។ បុគ្គលទាំងនោះលះឧបធិនោះខាងក្រោយ ។ ហើយបុគ្គលទាំងនោះ មិនលះឧបធិនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងទាំងអ្នកលះ និងបុគ្គលមិនលះ ដោយអំណាចពួកគណៈ មិនមែនទ្រង់បែកចំពោះខ្លួន ។ ឥឡូវនេះព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងថាបុគ្គលអ្នកលះបង់ឧបធិដែលមិនទាន់លះបាន ហើយធ្វើឲ្យជាអញ្ញោហារិកមាន

៤ ពួក ដូចបុគ្គលទៅដើម្បីត្រូវការទព្វសម្ភារៈ ទើបកាប់ដើមឈើតាមលំដាប់ ហើយត្រឡប់មកទៀត កាប់ដើមដែលវៀចចោល កាន់យកតែឈើដែលសមគួរ នាំទៅប្រកបការងារបានប៉ុណ្ណោះ ដូច្នោះទើបទ្រង់ប្រារព្ធទេសនានេះ ។ បទថា **ឧបធិប្បហានាយ** បានដល់ ដើម្បីលះឧបធិទាំងនេះ គឺ ខន្ធូបធិ កិលេសូបធិ អភិសង្ខារូបធិ កាមគុណូបធិ ។ បទថា **ឧបធិប្បដិសំយុត្តា** គឺស៊ុះទៅក្នុង ឧបធិ ។

ក្នុងបទថា **សរសង្កប្បា** មានសេចក្ដីដូចតទៅនេះ ។ ឈ្មោះថា **សរា** ព្រោះអត្ថថា ស៊ុះទៅ រត់ទៅ ។ ឈ្មោះថា **សង្កប្បា** ព្រោះអត្ថថា ត្រិះរិះ ។ សេចក្ដីថា ការត្រិះរិះដែលស៊ុះទៅ ។ ដោយបទទាំង ២ នេះ លោកពោលដល់វិតក្កនោះឯង ។ បទថា **សមុទាចរន្តិ** គឺគ្របសង្កត់ ប្រព្រឹត្តលិចលង់ ។ បទថា **សំយុត្តោ** គឺប្រកបដោយកិលេសទាំងឡាយ ។ បទថា **ឥន្ទ្រិយវេមត្តតា** គឺការផ្សេងគ្នានៃឥន្ទ្រិយ ។ បទថា **ករធាចិ ករហាចិ** គឺ កន្លងទៅៗ ក្នុងកាលដ៏យូរ ។ បទថា **សតិសម្មោសា** គឺការមិនមានស្មារតី ។ បទថា **និបាតោ** គឺធ្លាក់ចុះទៅក្នុងខ្ទះដែក ។ ដោយហេតុមានប្រមាណប៉ុណ្ណោះ លោកសម្ដែង ៣ ពួក គឺមិនទាន់លះបាន ១ លះបាន ១ លះបានដាច់ ១ ។

ក្នុងជន ៣ ពួកនោះ ជន ៤ ពួក ឈ្មោះថា លះមិនបាន ៤ ពួក ឈ្មោះថា លះបាន ៤ ពួក ឈ្មោះថា លះបានដាច់ ។ ក្នុងបុគ្គលទាំងនោះ ជន ៤ ពួកនេះ គឺបុថុជ្ជន ១ ព្រះសោតាបន្ន ១ ព្រះសកទាគាមី ១ ព្រះអនាគាមី ១ ឈ្មោះថា មិនទាន់លះបាន ។ បុថុជ្ជនជាដើមដែលមិនទាន់

លះបាន ស្មេះទុកសិន ។ ព្រះអនាគាមីមិនទាន់លះបានដូចម្តេច ។ ព្រោះព្រះអនាគាមីនោះ ក៏នៅត្រេកអរថា សុខហ្ន៎ សុខហ្ន៎ ដរាបដែលនៅមានការចង់បានក្នុង ភពរបស់ទេវតា ។ ដូច្នោះទើបឈ្មោះថា មិនទាន់លះបាន ។ ឯជន ៤ ពួកនេះ ឈ្មោះថាលះបាន ។ ព្រះសោតាបន្នជាដើមលះបាន សូមស្មេះទុកសិន ។ ចុះបុថុជ្ជនលះបានដូចម្តេច ។ ព្រោះបុថុជ្ជនអ្នកចម្រើនវិបស្សនាធ្វើសេចក្តីសង្វេគថា កាលកិលេសកើតឡើងភ្លាមៗ ព្រោះការមិនមានស្មារតី កិលេសកើតឡើងហើយដល់ភិក្ខុដូចអាត្មាអញ ដូច្នេះទើបផ្តងសេចក្តីព្យាយាម ចម្រើនវិបស្សនា ដកកិលេសដោយមគ្គ ។ បុថុជ្ជននោះឈ្មោះថាលះបាន ដោយប្រការដូច្នេះ ។ ជនទាំង ៤ ពួកនោះ ឈ្មោះថាលះបានដោយរហ័ស ។ លោកកាន់យកតតិយវារៈ ក្នុងសូត្រទាំងនេះ គឺក្នុងមហាហត្ថិបទោបមសូត្រ ក្នុងឥន្ទ្រិយភាវនាសូត្រដោយពិត ។ សូម្បីបញ្ហាក៏គប្បីជ្រាបថា លោកពោលទុកហើយ ក្នុងទុតិយវារៈនោះឯង ។ បញ្ចកន្ទ ឈ្មោះថា **ឧបធិ** ក្នុងបទនេះថា **ឧបធិ ទុក្ខស្ស មូលំ ។** កាលដឹងថា ឧបធិនោះជាមូលនៃទុក្ខដូច្នេះហើយ ជាអ្នកមិនមានឧបធិ ដោយកិលេសូបធិ អធិប្បាយថា មិនមានព្រៃស្ពុក មិនមានតណ្ហា ។ បទថា **ឧបធិសង្ខយេ វិមុត្តោ** គឺបង្អោនចិត្តទៅក្នុងនិព្វាន ដែលជាទីអស់ទៅនៃតណ្ហាចាកអារម្មណ៍ ។

[ ១៨២ ] ព្រះមានព្រះភាគ កាលញ៉ាំងបុគ្គល ៤ ពួកឲ្យពិស្តារយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់សម្តែងថា បុគ្គលណាលះបាន បុគ្គលនោះឈ្មោះថា លះកិលេសប្រមាណប៉ុណ្ណេះបាន ។ បុគ្គលណាមិនទាន់លះបាន បុគ្គល

នោះក៏ឈ្មោះថា លះកិលេសប្រមាណប៉ុណ្ណោះមិនបាន ទើបត្រាស់ថា **បញ្ចិមេ ឧទាយិ កាមគុណា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **មិឡ្ហសុខំ** គឺសេចក្តីសុខមិនស្អាត ។ បទថា **អនរិយសុខំ** គឺសុខដែលព្រះអរិយៈមិនសេព ។ បទថា **ភាយិតព្វំ** សេចក្តីថា គួរពោលតែការបានទទួលសេចក្តីសុខនេះខ្លះ អំពីវិបាកខ្លះ ។

[ ១៨៣ ] បទថា **នេក្ខម្មសុខំ** គឺសុខដែលកើតអំពីការចេញចាកកាម។ បទថា **បវិវេកសុខំ** គឺសេចក្តីសុខកើតអំពីការស្ងាត់ចាកពួកខ្លះ ចាកកិលេសខ្លះ ។ បទថា **ឧបសមសុខំ** គឺសេចក្តីសុខដើម្បីប្រយោជន៍ ដល់សេចក្តីស្ងប់ចាករាគៈជាដើម ។ បទថា **សម្ពោធិសុខំ** គឺសេចក្តីសុខដើម្បីប្រយោជន៍ដល់ការកើតនៃការត្រាស់ដឹងព្រម ពោល គឺមគ្គ ។ បទថា **ន ភាយិតព្វំ** គឺ មិនគប្បីខ្លាចអំពីការបានសុខនេះក្តី អំពីវិបាកក្តី សេចក្តីសុខនេះ គួរឲ្យកើតមាន ។

[ ១៨៤ ] បទថា **ឥញ្ជិតស្មឹ វទាមិ** គឺតថាគតពោលថា ញាប់ញ័រស្លុតស្លាញ អន្ទះអន្ទែង ។ បទថា **កិញ្ច តត្ថ ឥញ្ជិតស្មឹ** គឺបឋមជ្ឈាននោះនៅមានអ្វីញាប់ញ័រ ។ បទថា **ឥទំ តត្ថ ឥញ្ជិតស្មឹ** នេះជាការញាប់ញ័រក្នុងបឋមជ្ឈាននោះ គឺវិតក្ក វិចារៈមិនទាន់រលត់ នេះជាការញាប់ញ័រក្នុងបឋមជ្ឈាននោះ ។ សូម្បីក្នុងទុតិយជ្ឈាន និងតតិយជ្ឈានក៏មានន័យដូចគ្នា ។ បទថា **អនេញ្ជិតស្មឹ វទាមិ** គឺចតុត្ថជ្ឈាននេះ តថាគតពោលថា មិនញាប់ញ័រមិនស្លុតស្លាញ មិនអន្ទះអន្ទែង ។

[ ១៨៥ ] បទថា **អនលន្តិ វទាមិ** គឺតថាគតពោលថា មិនគួរធ្វើសេចក្តីអាល័យ ព្រះមានព្រះភាគ ទ្រង់សម្តែងថា មិនគួរឲ្យការអាល័យក្នុងតណ្ហាកើតឡើងក្នុងឈានទេះ ។ ម្យ៉ាងទៀត តថាគតពោលថា មិនគួរធ្វើការតក់ស្លុតថា មិនគ្រប់គ្រាន់ មិនមានទីបំផុត ត្រឹមប៉ុណ្ណេះទើបគ្រប់គ្រាន់ ។ បទថា **នេវសញ្ញានាសញ្ញាយតនស្សបិ** គឺតថាគតពោលការលះសមាបត្តិ ដែលស្ងប់ហើយសូម្បីបែបនេះ ។ បទថា **អណុំ វា ថូលំ វា** សេចក្តីថាមានទោសតិចក្តី មានទោសច្រើនក្តី ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយធម៌កំពូល គឺអរហត្តដោយអំណាចនេយ្យបុគ្គល ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថាលដុកិកោបមសូត្រ ចប់**

**សូត្រ ទី ៦ ចប់**

# សុត្តន្តបិដក

## ចាតុមសូត្រទី៧

[ ១៨៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងអាមលកីវ័ន ( ព្រៃកន្ទួតព្រៃ ) ក្នុងស្រុកចាតុមា ។ ក៏សម័យនោះ ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាន និមន្តទៅដល់ស្រុកចាតុមា ដើម្បីគាល់ព្រះមានព្រះភាគ ។ ក៏ឯពួកភិក្ខុអាគន្តុកៈអម្បាលនោះ ក៏និយាយរាក់ទាក់មួយអន្លើដោយពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលសេនាសនៈ ឲ្យរៀបចំទុកដាក់បាត្រ ចីវរ មានសំឡេងគឹកកងមានសំឡេងអ៊ូអា ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកសួរថា ម្នាលអានន្ទ ចុះសំឡេងគឹកកង អ៊ូអាទាំងនុ៎ះ តើជាសំឡេងអ្វី ហាក់ដូចជាពួកព្រានសំណាញ់ដណ្តើមចាប់ត្រី ដូច្នោះ ។ ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាននុ៎ះ មកដល់ស្រុកចាតុមា ដើម្បីគាល់ព្រះមានព្រះភាគ ពួកអាគន្តុកភិក្ខុអម្បាលនោះ ក៏និយាយរាក់ទាក់មួយអន្លើដោយពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលអាសនៈ ឲ្យរៀបចំទុកដាក់បាត្រនិងចីវរ ទើបមានសំឡេងគឹកកង អ៊ូអា ដូច្នេះ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរហៅភិក្ខុទាំងឡាយមក តាមពាក្យរបស់តថាគតថា ព្រះសាស្តា ទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ព្រះ

អានន្ទមានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយនឹងភិក្ខុទាំងនោះយ៉ាងនេះថា ព្រះសាស្តាទ្រង់ត្រាស់ហៅលោកមានអាយុទាំង-ឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ពាក្យព្រះអានន្ទមានអាយុថា ករុណាលោកមានអាយុ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ដូចម្តេចបានជាអ្នកទាំងឡាយ មានសំឡេងគឹកកង អ៊ូអាបីដូចជាពួកព្រានសំណាញ់ ដណ្តើមចាប់ត្រី ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្ត និងព្រះមោគ្គល្លានជាប្រធាននេះ មកដល់ស្រុកចាតុមា ដើម្បីនឹងគាល់ព្រះមានព្រះភាគ អាគន្តុកភិក្ខុអម្បាលនោះ ក៏និយាយរាក់ទាក់ជាមួយនឹងពួកនេវាសិកភិក្ខុ ប្រើគ្នានិងគ្នាឲ្យក្រាលសេនាសនៈ ឲ្យរៀបចំទុកដាក់បាត្រ ចីវរ ទើបមានសំឡេងគឹកកងអ៊ូអា ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរទៅ តថាគត បណ្តេញអ្នកទាំងឡាយ អ្នកទាំងឡាយ មិនគួរនៅក្នុងសម្នាក់តថាគតទេ ។ ភិក្ខុអម្បាលនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ រៀបចំទុកដាក់សេនាសនៈហើយ កាន់យកបាត្រ និងចីវរចៀសចេញទៅ ។

[ ១៨៧ ] ក៏សម័យនោះ សក្យៈទាំងឡាយអ្នកស្រុកចាតុមា ប្រជុំគ្នាក្នុងរោងស្នាក់អាស្រ័យ ដោយកិច្ចដែលគួរធ្វើណាមួយ ។ លុះសក្យៈទាំងឡាយអ្នកស្រុកចាតុមា បានឃើញភិក្ខុទាំងឡាយនោះ កំពុងដើរមកពីចម្ងាយ លុះឃើញច្បាស់ហើយ បានចូលទៅរកភិក្ខុទាំងអម្បាលនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះ នឹងភិក្ខុទាំងអម្បាលនោះថា បពិត្រលោកមានអាយុទាំងឡាយ លោកទាំងឡាយនិមន្តទៅណា ។ ម្នាលអាវុសោ ព្រះមានព្រះភាគបានបណ្តេញភិក្ខុសង្ឃទៅហើយ ។ បពិត្រលោកមានអាយុទាំងឡាយ បើដូច្នោះ សូមលោកទាំងឡាយ និមន្តគង់មួយរំពេចសិន ក្រែងជួនជាយើងទាំងឡាយ សម្រួលព្រះទ័យព្រះមានព្រះភាគបាន ។ ភិក្ខុទាំងនោះទទួលស្តាប់សក្យៈទាំងឡាយ អ្នកស្រុកចាតុមាថា ថ្វាយព្រះពរ សក្យៈមានអាយុ ។ លំដាប់នោះ សក្យៈទាំងឡាយ អ្នកស្រុកចាតុមា បានចូលទៅគាល់ព្រះមានព្រះភាគលុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសក្យៈទាំងឡាយអ្នកស្រុកចាតុមា គង់ក្នុងទីសមគួរហើយ បានក្រាបទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ ( នឹងការចូលមកវិញនៃភិក្ខុសង្ឃ ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ ( ថាចូរមកវិញ ) ចុះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃ ដែលព្រះមានព្រះភាគធ្លាប់ទ្រង់អនុគ្រោះហើយក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះ សូមព្រះមានព្រះភាគទ្រង់អនុគ្រោះភិក្ខុសង្ឃ យ៉ាងនោះទៀត បពិត្រព្រះអង្គដ៏

ចម្រើន ភិក្ខុសង្ឃដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងឡាយនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីរាយមាយ និងសេចក្តីប្រែប្រួលពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ដូចជាពូជទាំងឡាយដ៏ខ្ចី កាលមិនមានទឹកហើយ នឹងស្វិតស្រពោន ឬប្រែប្រួលយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ ធម្មវិន័យនេះ កាលភិក្ខុទាំងនោះមិនបានជួបព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីរាយមាយ និងសេចក្តីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ដូចកូនគោតូច កាលមិនឃើញមេហើយ មុខជានឹងស្គាំងស្គម ឬប្រែប្រួលយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែនឹងមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងឡាយនោះមិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តី រាយមាយនិងសេចក្តីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ ( នឹងការចូលមកវិញនៃភិក្ខុសង្ឃ ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ ( ថាចូរមកវិញ ) ចុះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគ ធ្លាប់អនុគ្រោះ ហើយក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះ សូមព្រះមានព្រះភាគ ទ្រង់អនុគ្រោះភិក្ខុសង្ឃ យ៉ាងនោះទៀត ។

[ ១៨៨ ] គ្រានោះ សហម្បតិព្រហ្ម បានជ្រាបសេចក្តីបរិវិតក្កៈ ក្នុង

ព្រះហឫទ័យនៃព្រះមានព្រះភាគ ដោយចិត្ត ( របស់ខ្លួន ) ហើយ ក៏ស្រាប់តែបាត់អំពីព្រហ្មលោកមួយរំពេច ហើយមកប្រាកដនៅទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ហាក់ដូចបុរសមានកម្លាំងលាដៃដែលខ្លួនបត់ចូល ឬ បត់ដៃដែលខ្លួនលាចេញ ។ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ក្រាបទូលសេចក្តីនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ ( នឹងការចូលមកនៃភិក្ខុសង្ឃ ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ ( ថាចូរមកចុះ ) បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃ ដែលព្រះមានព្រះភាគធ្លាប់អនុគ្រោះហើយ ក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះ សូមព្រះមានព្រះភាគអនុគ្រោះភិក្ខុសង្ឃ ដោយប្រការយ៉ាងនោះទៀត បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មីបួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលបើភិក្ខុទាំងនោះមិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីវាយមាយ និងសេចក្តីប្រែប្រួលជាពុំខាន បពិត្រព្រះអង្គដ៏ចម្រើន ដូចពូជទាំងឡាយដ៏ខ្ចី កាលមិនបានទឹកហើយ នឹងមានការស្វិតស្រពោន ឬនឹងមានដំណើរប្រែប្រួលពុំខានយ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលភិក្ខុទាំងនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្តីវាយមាយ និងសេចក្តីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន ដូចកូនគោតូច កាល

មិនឃើញមេហើយ នឹងមានការស្ដាំងស្ដម ឬប្រែប្រួលពុំខាន យ៉ាងណា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុដែលមានក្នុងទីនេះ ជាភិក្ខុថ្មី បួសហើយមិនយូរប៉ុន្មាន ទើបតែមកកាន់ធម្មវិន័យនេះ កាលបើភិក្ខុទាំងនោះ មិនបានជួបនឹងព្រះមានព្រះភាគហើយ មុខជានឹងមានសេចក្ដីរាយមាយ និងសេចក្ដីប្រែប្រួលពុំខាន យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគត្រេកអរ ( នឹងការចូលមកនៃភិក្ខុសង្ឃ ) បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុសង្ឃ ( ថាចូរមកចុះ ) បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃដែលព្រះមានព្រះភាគធ្លាប់អនុគ្រោះហើយ ក្នុងកាលមុន ដោយប្រការយ៉ាងណា ឥឡូវនេះ សូមព្រះមានព្រះភាគ ទ្រង់អនុគ្រោះភិក្ខុសង្ឃ ដោយប្រការយ៉ាងនោះទៀត ។ សក្យៈទាំងឡាយអ្នកស្រុកចាតុមានិងសហម្បតិព្រហ្ម អាចធ្វើព្រះមានព្រះភាគឲ្យត្រេកអរបាន ដោយពាក្យប្រៀបធៀបនឹងពូជផង ដោយពាក្យប្រៀបធៀបនឹងកូនគោតូចផង ។

[ ១៨៩ ] លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ បានប្រាប់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ អ្នកទាំងឡាយ ចូរក្រោក កាន់បាត្រនិងចីវរឡើង ដ្បិតសក្យៈទាំងឡាយអ្នកស្រុកចាតុមា និងសហម្បតិព្រហ្ម បានសម្រួលព្រះទ័យនៃព្រះមានព្រះភាគ ដោយពាក្យប្រៀបធៀបនឹងពូជផង ដោយពាក្យប្រៀបធៀបនឹងកូនគោតូចផង ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះមោគ្គល្លានមានអាយុថា ករុណាលោកមានអាយុ ហើយក៏ក្រោកអំពីអាសនៈកាន់យកបាត្រនិងចីវរ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់

ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ កាលដែលព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរយ៉ាងនេះថា ម្នាលសារីបុត្ត កាលបើភិក្ខុសង្ឃ ដែលតថាគតបណ្តេញហើយ តើអ្នកមានគំនិតដូចម្តេច ។ ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃ ដែលព្រះមានព្រះភាគទ្រង់បណ្តេញហើយ ខ្ញុំព្រះអង្គមានគំនិតយ៉ាងនេះថា សូមព្រះមានព្រះភាគ មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបរឿយៗ នូវធម៌ ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះចុះ សូម្បីខ្ញុំព្រះអង្គទាំងឡាយ ក៏មានសេចក្តីខ្វល់ខ្វាយតិច ប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះដែរ ។ ម្នាលសារីបុត្ត អ្នកចូរឈប់សិនចុះ ម្នាលសារីបុត្ត អ្នកចូរឈប់សិនចុះ ម្នាលសារីបុត្ត គំនិតរបស់អ្នក មានសភាពយ៉ាងនេះ មិនគួរឲ្យកើតឡើងទៀតទេ ។ លំដាប់នោះព្រះមានព្រះភាគ ទ្រង់ត្រាស់សួរព្រះមហាមោគ្គល្លាន មានអាយុថា ម្នាលមោគ្គល្លាន កាលបើភិក្ខុសង្ឃ ដែលតថាគតបណ្តេញចេញហើយ តើអ្នកមានគំនិតដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃ ដែលព្រះមានព្រះភាគទ្រង់បណ្តេញចេញហើយ ខ្ញុំព្រះអង្គមានគំនិតយ៉ាងនេះថា សូមព្រះមានព្រះភាគមានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបរឿយៗ នូវធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ក្នុងកាលឥឡូវនេះចុះ ឯខ្ញុំព្រះអង្គនិងព្រះសារីបុត្តមានអាយុ នឹងគ្រប់គ្រងភិក្ខុសង្ឃជំនួសព្រះអង្គ ។ ម្នាលមោគ្គល្លាន ប្រពៃហើយ ម្នាលមោគ្គល្លាន ដ្បិតថា តថាគតក្តី សារីបុត្តក្តី មោគ្គល្លានក្តី គួរគ្រប់គ្រងភិក្ខុសង្ឃ

មែនហើយ ។

[ ១៩០ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយនេះ មាន ៤ យ៉ាង តែងមានចំពោះបុគ្គលអ្នកចុះទឹក ភ័យទាំង ៤ យ៉ាងនោះ ដូចម្តេចខ្លះ ភ័យ ៤ យ៉ាង គឺ ភ័យកើតពីរលក ១ ភ័យកើតពីក្រពើ ១ ភ័យកើតពីអន្លង់ទឹក ១ ភ័យកើតពីត្រីសាហាវ ១ ម្នាលភិក្ខុទាំងឡាយ ភ័យទាំង ៤ នេះឯង តែងមានចំពោះបុគ្គលអ្នកចុះទឹក ម្នាលភិក្ខុទាំងឡាយ ភ័យ ៤ យ៉ាង តែងមានចំពោះបុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលចេញចាកផ្ទះ ហើយបួលមកកាន់ផ្នួសក្នុងធម្មវិន័យនេះដែរ ភ័យ ៤ យ៉ាងនោះ តើដូចម្តេចខ្លះ គឺ ភ័យកើតពីរលក ១ ភ័យកើតពីក្រពើ ១ ភ័យកើតពីអន្លង់ទឹក ១ ភ័យកើតពីត្រីសាហាវ ១ ។

[ ១៩១ ] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីរលក តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកខ្លះ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះហើយ បួលទៅកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញ មានជាតិ ជរា មរណៈ និងសេចក្តីសោក ខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងឧបាយាសៈគឺសេចក្តីខ្វាចផ្សាចិត្ត គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងច្បាស់ប្រាកដបាន ។ កាលពួកកុលបុត្រនោះបួសហើយ សព្រហ្មចារីបុគ្គលទាំងឡាយ តែងទូន្មានប្រៀនប្រដៅយ៉ាងនេះថា អ្នកគប្បីឈានទៅខាងមុខយ៉ាងនេះ អ្នកគប្បីឈានថយក្រោយយ៉ាងនេះ អ្នកគប្បីក្រឡេកមើលទៅខាងមុខយ៉ាងនេះ អ្នកគប្បីងាក

ច្រើនណាកស្ដាំយ៉ាងនេះ អ្នកគប្បីអង្គុញយ៉ាងនេះ អ្នកគប្បីសណ្ដូកយ៉ាងនេះ អ្នកគប្បីទ្រទ្រង់នូវសំពត់សង្ឃាដីបាត្រនិងចីវរយ៉ាងនេះ ។ កុលបុត្តនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលពីមុន យើងនៅជាគ្រហស្ថ តែងទូន្មានប្រៀនប្រដៅជនទាំងឡាយដទៃ ឯសព្រហ្មចារិបុគ្គលទាំងឡាយនេះ ប្រហែលនឹងកូនចៅរបស់យើង ស្មានថា យើងជាបុគ្គល គួរគេទូន្មានប្រៀនប្រដៅបាន ។ កុលបុត្តនោះ ក៏លាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីរលក បានជាពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីរលក នុ៎ះ ជាឈ្មោះនៃសេចក្ដីក្រោធនិងឧបាយាសៈ ។

[ ១៩២ ] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីក្រពើ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះហើយចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្ដីសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្ដីខ្វាចផ្សាចិត្ត គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្ដេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងច្បាស់ប្រាកដបាន ។ កាលដែលកុលបុត្តនោះបួសហើយ សព្រហ្មចារិបុគ្គលទាំងឡាយ តែងទូន្មានប្រៀនប្រដៅយ៉ាងនេះថា របស់នេះអ្នកគួរទំពា របស់នេះអ្នកមិនគួរទំពា របស់នេះអ្នកគួរឆាន់ របស់នេះអ្នកមិនគួរឆាន់ របស់នេះអ្នកគួរជញ្ជក់ជញ្ជាប របស់នេះអ្នកមិនគួរជញ្ជក់ជញ្ជាប របស់នេះអ្នកគួរក្រេបផឹក របស់នេះអ្នកមិនគួរក្រេបផឹក (របស់នេះ)

ជាកប្បិយវត្ថុ អ្នកគួរទំពា ជាអកប្បិយវត្ថុ អ្នកមិនគួរទំពា ជាកប្បិយវត្ថុអ្នកគួរឆាន់ ជាអកប្បិយវត្ថុ អ្នកមិនគួរឆាន់ ជាកប្បិយវត្ថុ អ្នកគួរជញ្ជក់ជញ្ជាប ជាអកប្បិយវត្ថុ អ្នកមិនគួរជញ្ជក់ជញ្ជាប ជាកប្បិយវត្ថុ អ្នកគួរក្រេបផឹក ជាអកប្បិយវត្ថុ អ្នកមិនគួរក្រេបផឹក របស់នេះគួរទំពាក្នុងកាល ( តាំងពីព្រឹកដល់ថ្ងៃត្រង់ ) របស់នេះអ្នកមិនគួរទំពាក្នុងវិកាល ( តាំងពីថ្ងៃជ្រេទៅ ) របស់នេះអ្នកគួរឆាន់ក្នុងកាល របស់នេះអ្នកមិនគួរឆាន់ក្នុងវិកាល របស់នេះអ្នកគួរជញ្ជក់ជញ្ជាបក្នុងកាល របស់នេះអ្នកមិនគួរជញ្ជក់ជញ្ជាបក្នុងវិកាល របស់នេះអ្នកគួរក្រេបផឹកក្នុងកាល របស់នេះអ្នកមិនគួរក្រេបផឹកក្នុងវិកាល ។ កុលបុត្តនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុន យើងនៅជាគ្រហស្ថ យើងចង់របស់ណា ក៏ទំពារបស់នោះបាន យើងមិនចង់របស់ណា ក៏មិនទំពារបស់នោះ យើងចង់របស់ណា ក៏បរិភោគរបស់នោះបាន យើងមិនចង់របស់ណា ក៏មិនបរិភោគរបស់នោះ យើងចង់របស់ណា ក៏ជញ្ជក់ជញ្ជាបរបស់នោះ យើងមិនចង់របស់ណា ក៏មិនជញ្ជក់ជញ្ជាបរបស់នោះ យើងចង់របស់ណា ក៏ក្រេបផឹករបស់នោះ យើងមិនចង់របស់ណា ក៏មិនក្រេបផឹករបស់នោះ យើងទំពានូវរបស់ដែលគួរក៏បាន យើងទំពានូវរបស់ដែលមិនគួរក៏បាន យើងបរិភោគនូវរបស់ដែលគួរក៏បាន យើងបរិភោគនូវរបស់ដែលមិនគួរក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ដែលគួរក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ដែលមិនគួរក៏បាន យើងក្រេបផឹកនូវរបស់ដែលគួរក៏បាន យើងក្រេបផឹកនូវរបស់ដែលមិនគួរក៏បាន យើងទំពានូវរបស់ក្នុងកាលក៏បាន យើងទំពានូវរបស់ក្នុងវិកាលក៏បាន

យើងបរិភោគនូវរបស់ក្នុងកាលក៏បាន យើងបរិភោគនូវរបស់ក្នុងវិកាលក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ក្នុងកាលក៏បាន យើងជញ្ជក់ជញ្ជាបនូវរបស់ក្នុងវិកាលក៏បាន យើងក្រេបផឹករបស់ក្នុងកាលក៏បាន យើងក្រេបផឹករបស់ក្នុងវិកាលក៏បាន មួយវិញទៀត គហបតីទាំងឡាយ ដែលមានសទ្ធា តែងឲ្យរបស់ដែលគួរឆាន់គួរបរិភោគដ៏ប្រណីតណា ដល់យើងទាំងឡាយ ក្នុងវេលាព្រឹក ( ឬ ) ក្នុងវេលាថ្ងៃរសៀល លោកអម្បាលនេះ ហាក់ដូចជាធ្វើកិរិយាហាមឃាត់មាត់យើង ក្នុងរបស់ទាំងនោះ ។ កុលបុត្តនោះ ក៏ពោលលាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះតថាគតពោលថា មានភ័យអំពីក្រពើ បានជាពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យអំពីក្រពើនុ៎ះ ជាឈ្មោះរបស់បុគ្គល ដែលឃើញតែត្រង់ការបំពេញផ្ទៃប៉ុណ្ណោះ ។

[ ១៩៣ ] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីអន្លង់ទឹក តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីខ្វាចផ្សាចិត្ត គ្របសង្កត់ឈ្មោះថា មានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កាលដែលកុលបុត្តនោះបួសយ៉ាងនេះហើយ ក្នុងវេលាព្រឹកព្រហាម ក៏ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត តែមិនបានរក្សាកាយ មិនបានរក្សា

វាចា មិនបានតម្កល់ស្មារតីឲ្យខ្ជាប់ខ្ជួន ទាំងមិនបានសង្រួមឥន្ទ្រិយទាំងឡាយឡើយ ។ កុលបុត្តនោះ ឃើញគហបតីក្តី គហបតិបុត្តក្តី ក្នុងស្រុកនោះ ឬនិគមនោះ ដែលកំពុងតែឆ្អែតស្កប់ស្កល់ មូលមិត្ត ផ្គូកផ្គិត ដោយកាមគុណទាំង ៥ ។ កុលបុត្តនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលពីមុន យើងនៅជាគ្រហស្ថ តែងឆ្អែតស្កប់ស្កល់ មូលមិត្រ ផ្គូកផ្គិត ដោយកាមគុណ ៥ ទាំងភោគសម្បត្តិក្នុងត្រកូល របស់យើងក៏មានព្រម យើងអាចនឹងបរិភោគភោគសម្បត្តិ នឹងធ្វើបុណ្យទាំងឡាយបានដែរ ។ កុលបុត្តនោះ ក៏ពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីអន្ទង់ទឹក បានជាពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យកើតអំពីអន្ទង់ទឹកនុ៎ះ ជាឈ្មោះនៃកាមគុណទាំង ៥ ។

[ ១៩៤ ] ម្នាលភិក្ខុទាំងឡាយ ភ័យកើតអំពីត្រីសាហាវ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ កុលបុត្តពួកមួយ ក្នុងធម្មវិន័យនេះ ចេញចាកផ្ទះ ចូលកាន់ផ្នួសដោយសទ្ធា គិតថា អាត្មាអញមានជាតិ ជរា មរណៈ សេចក្តីសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីខ្វល់ខ្វាយចិត្ត គ្របសង្កត់ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើម្តេចហ្ន៎ ការធ្វើនូវទីបំផុតនៃកងទុក្ខទាំងអស់នេះ នឹងប្រាកដបាន ។ កាលដែលកុលបុត្តនោះ បួសយ៉ាងនេះហើយ ក្នុងវេលាព្រឹកព្រហាម ក៏ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ចូលទៅកាន់ស្រុកឬនិគម ដើម្បីបិណ្ឌបាត តែមិនបានរក្សាកាយ មិនបានរក្សា

វាចា មិនបានតម្កល់ស្មារតីឲ្យខ្ជាប់ខ្ជួន ទាំងមិនបានសង្រួមឥន្ទ្រិយទាំងឡាយ ។ កុលបុត្តនោះ បានឃើញមាតុគ្រាម ក្នុងស្រុកឬនិគមនោះ ដែលមានសំពត់ស្លៀកមិនស្រួល មានសំពត់ដណ្តប់មិនស្រួល តម្រេកក៏ញាំញីចិត្តរបស់កុល-បុត្តនោះឲ្យស្វិតស្រពោន ព្រោះឃើញនូវមាតុគ្រាម ដែលមានសំពត់ស្លៀកមិនស្រួល ឬមានសំពត់ដណ្តប់មិនស្រួល ។ កុលបុត្តនោះ ក៏ពោលលាសិក្ខាវិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ព្រោះចិត្តដែលស្វិតស្រពោនដោយរាគៈ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តនេះ តថាគតពោលថា មានភ័យអំពីត្រីសាហាវ បានជាពោលលាសិក្ខា វិលត្រឡប់ទៅកាន់ភេទថោកទាបវិញ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យកើតអំពីត្រីសាហាវ នុ៎ះ ជាឈ្មោះនៃមាតុគ្រាម ។ ម្នាលភិក្ខុទាំងឡាយ ភ័យទាំង ៤ នេះឯង ដែលកើតមានចំពោះបុគ្គលពួកមួយ ក្នុងសាសនានោះ ជាបព្វជិត ដែលចេញចាកផ្ទះចូលកាន់ផ្នួសក្នុងធម្ម-វិន័យនេះ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងអម្បាលនោះ ក៏មានសេចក្តីពេញចិត្តត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចាតុមសូត្រទី ៧

# អដ្ឋកថា

## ចាតុមសូត្រ

[ ១៨៦ ] ចាតុមសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ចាតុមាយំ** គឺជិតស្រុកចាតុមា ។ បទថា **បញ្ចមត្តានិ ភិក្ខុសតានិ** គឺភិក្ខុបួសថ្មីប្រមាណ ៥០០ អង្គ ។ បានឮថា ព្រះថេរៈទាំង ២ គិតថា កុលបុត្រទាំងនេះ បួសហើយ មិនធ្លាប់ឃើញព្រះទសពលឡើយ យើងនឹងឲ្យភិក្ខុទាំងនេះគាល់ព្រះមានព្រះភាគ ។ ភិក្ខុទាំងនេះស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះមានព្រះភាគហើយ នឹងតាំងនៅតាមឧបនិស្ស័យរៀងខ្លួន ។ ព្រោះដូច្នោះ ទើបព្រះថេរៈទាំង ២ នាំភិក្ខុទាំងនោះ មក ។ បទថា **សម្មោទមានា** សេចក្ដីថា ភិក្ខុទាំងឡាយពោលពាក្យ ស្វាគមន៍ជាដើមថា អាវុសោ សប្បាយជាទេ ។ បទថា **សេនាសនានិ បញ្ញាបយមានា** សេចក្ដីថា បោសសម្អាតលំនៅរបស់អាចារ្យ និងឧបជ្ឈាយ៍រៀងៗខ្លួន ហើយបើកទ្វារ បើកបង្អួច សែងគ្រែ តាំង និងកន្ទេល ផែងជាដើមចេញ ជូតតាំងទុកក្នុងទីតាមលំដាប់ ។ បទថា **បត្តចីវរានិ បដិសាមយមានា** សេចក្ដីថា ប្រាប់សមណបរិក្ខារ យ៉ាងនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ដាក់បាត្រនេះ ចីវរនេះ ថាសនេះ កុណ្ឌីទឹកនេះ ឈើប្រត់នេះ ។ បទថា **ឧច្ចាសទ្ទា មហាសទ្ទា** សេចក្ដីថា ធ្វើសំឡេងអ៊ឹអា ព្រោះមានសំឡេងខ្លាំង ព្រោះសំឡេងផូងផាង ។ បទថា **កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តិ** សេចក្ដីថា ពួកជនប្រជុំគ្នាក្នុងទីដែលអ្នកប្រមង់ ដាក់ត្រក

សម្រាប់ដាក់ត្រីទុក ពោលថា សូមលោកឲ្យត្រីដទៃមួយ សូមឲ្យត្រីដែលកាត់ហើយមួយ ហើយក៏បន្លឺសំឡេងអឺងកងថា អ្នកនោះលោកឲ្យត្រីធំ ឯខ្ញុំឲ្យត្រីតូច ដូច្នេះ លោកពោលដូច្នេះ សំដៅដល់ការដែលភិក្ខុជជែកគ្នានោះ ។ កាលដាក់សំណាញ់ដើម្បីចាប់ត្រី អ្នកប្រមង់ និងមនុស្សដទៃៗ ក្នុងទីនោះ បញ្ចូនសំឡេងខ្លាំងថា ត្រីចូលទៅហើយ ត្រីមិនទាន់ចូលទៅ ចាប់បានត្រីហើយ មិនទាន់ចាប់ត្រីបាន ។ លោកពោលដូច្នេះ សំដៅដល់ការដែល អ្នកប្រមង់បន្លឺសំឡេងខ្លាំងនោះ ។ បទថា **បណាមេមិ** សេចក្តីថា បណ្តេញចេញទៅ ។ បទថា **ន វោ មម សន្តិកេ វត្ថព្វំ** សេចក្តីថា ពួកអ្នកមិនគួរនៅក្នុងសម្នាក់របស់តថាគត ព្រះមានព្រះភាគទ្រង់សម្តែងថា ពួកអ្នកមកដល់លំនៅរបស់ព្រះពុទ្ធដូចតថាគតនេះហើយ នៅធ្វើសំឡេងខ្លាំងដល់ម្ល៉េះ កាលពួកអ្នកនៅតាមទំនើងរបស់ខ្លួន នឹងធ្វើការសមគួរបានដូចម្តេច ។ បុគ្គលដូចពួកអ្នកមិនមានកិច្ច ដែលនឹងនៅក្នុងសម្នាក់របស់តថាគត ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុមួយរូប ក៏មិនអាចទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់កុំបណ្តេញពួកខ្ញុំព្រះអង្គ ដោយហេតុត្រឹមតែសំឡេងខ្លាំង ឬពាក្យដទៃៗ ឡើយ ។

ភិក្ខុទាំងឡាយទទួលព្រះពុទ្ធតម្រាស់ របស់ព្រះមានព្រះភាគហើយ ក្រាបទូលថា យ៉ាងនោះហើយព្រះអង្គ ហើយនាំគ្នាចេញទៅ ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះមានបំណងថា អញនឹងគាល់ព្រះសាស្តា នឹងស្តាប់ធម្មកថា នឹងនៅក្នុងសម្នាក់របស់ព្រះសាស្តា ដូច្នេះ ទើបបានមក ។ តែកាលមកគាល់ព្រះ

សាស្តាជាបរមគ្រូបែបនេះហើយ នៅធ្វើសំឡេងខ្លាំង ជាការខុសរបស់ពួកយើង ទើបត្រូវបណាម ។ យើងមិនបាននៅក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ មិនបានឃើញព្រះសរីរៈពណ៌ដូចមាស មិនបានស្តាប់ធម៌ដោយព្រះសូរសៀងដ៏ពីរោះ ដូច្នេះ ភិក្ខុទាំងនោះមានទោមនស្សដ៏ខ្លាំងក្លា ទើបនាំគ្នាចៀសចេញទៅ ។

[ ១៨៧ ] បទថា **តេនុបសង្កមឹសុ** សេចក្តីថា ពួកសក្យៈទាំងនោះ សូម្បីក្នុងវេលាដែលភិក្ខុមក ក៏ប្រថាប់គង់ក្នុងទីនោះ ទ្រង់ឃើញភិក្ខុទាំងឡាយ ។ ស្តេចសក្យៈទាំងឡាយមានព្រះវិតក្ក ទើបទ្រង់ត្រិះរិះថា ព្រោះអ្វីហ្ន៎ ទើបភិក្ខុទាំងនេះចូលទៅហើយ នាំគ្នាត្រឡប់ អញនឹងដឹងហេតុនោះ ទើបចូលទៅរកភិក្ខុទាំងនោះ ។ បទថា **හន្ទ** ជានិបាត ចុះក្នុងអត្ថនៃវាចា ។ បទថា **ករហំ បន តម្ហេ** សេចក្តីថា លោកម្ចាស់ទាំងឡាយមកប្រញាប់ប្រញាល់ តើនាំគ្នាទៅណាទៀត អន្តរាយណាមួយកើតដល់លោកម្ចាស់ឬ ឬកើតដល់ព្រះទសពល ភិក្ខុទាំងនោះ មិនបិទបាំងដោយពាក្យយ៉ាងនេះថា ថ្វាយព្រះពរ អាត្មាទាំងឡាយមកដើម្បីឃើញព្រះមានព្រះភាគ ឥឡូវនេះពួកអាត្មាបានឃើញព្រះមានព្រះភាគហើយនឹងត្រឡប់ទៅកាន់លំនៅក៏ពិត តែមិនបានធ្វើលេស ដោយន័យបែបនេះ បានទូលតាមត្រង់ ហើយពោលថា ថ្វាយព្រះពរ ភិក្ខុសង្ឃត្រូវព្រះមានព្រះភាគ ទ្រង់បណ្តេញ ដូច្នេះ ។ម្យ៉ាងទៀត ព្រះរាជាទាំងនោះទ្រង់ខ្វល់ខ្វាយក្នុងព្រះសាសនា ។ ព្រោះដូច្នោះ ទើបទ្រង់ត្រិះរិះថា កាលភិក្ខុ ៥០០ រូប និងព្រះអគ្គសាវកទាំង ២ ទៅអស់

បាទមូលរបស់ព្រះមានព្រះភាគនឹងទម្លាយ ។ អញនឹងធ្វើឲ្យភិក្ខុទាំងនេះត្រឡប់ឲ្យទាល់តែបាន កាលទ្រង់ត្រិះរិះយ៉ាងនេះហើយ ទើបត្រាស់ពាក្យជាដើមថា **គេឆហាយស្នេត្ត** បើដូច្នេះ ។ បណ្ដាភិក្ខុទាំងនោះ មិនមានភិក្ខុសូម្បីតែមួយរូបដែលក្ដៅក្រហាយចិត្តថា អញត្រូវបណ្ដេញ ដោយហេតុត្រឹមតែធ្វើសំឡេងខ្លាំង ។ អញបួសហើយ មិនអាចតម្រង់ជីវិតបាន ។ តែភិក្ខុទាំងអស់ ទទួលព្រះតម្រាស់ព្រមគ្នា ។ បទថា **អភិនន្ទតុ** គឺសូមព្រះមានព្រះភាគទ្រង់ប្រាថ្នាការមករបស់ភិក្ខុសង្ឃ សូមទ្រង់ត្រេកអរចុះ ។ បទថា **អភិវទតុ** គឺ សូមព្រះមានព្រះភាគទ្រង់អាស្រ័យព្រះករុណាប្រាប់ថាចូរភិក្ខុសង្ឃមកចុះ ។ បទថា **អនុគ្គហិតោ** សេចក្ដីថា សូមទ្រង់អនុគ្រោះដោយអាមិស និង ធម៌ ។ បទថា **អញ្ញថត្តំ** សេចក្ដីថា គប្បីដល់នូវទោមនស្សថា អញមិនបានឃើញ ព្រះទសពល ។ បទថា **វិបរិណាមោ** សេចក្ដីថា កាលភិក្ខុសឹកដោយទោមនស្ស គប្បីដល់ការប្រែប្រួល ។ បទថា **វីជានំ តរុណានំ** គឺសន្ទង់ខ្ចី ។ បទថា **សិយា អញ្ញថត្តំ** សេចក្ដីថា ពូជដែលនៅខ្ចី កាលមិនបានទឹកក្នុងវេលាដែលគួរបញ្ចូលទឹក គប្បីដល់នូវភាពដទៃ ព្រោះការក្រៀមស្វិត ។ គប្បីប្រែប្រួល ព្រោះដល់នូវភាព ក្រៀមស្វិត ។ កូនគោស្គាំងស្គម ព្រោះស្រេកទឹកដោះ ឈ្មោះថា ដល់នូវភាពដទៃ ។ កូនគោស្គាំងស្គមស្លាប់ ឈ្មោះថា ដល់នូវការប្រែប្រួល ។

[ ១៨៩ ] បទថា **ចាសាទិតោ ភគវា** សេចក្ដីថា ព្រះមានព្រះភាគកាលស្ដេចសក្យៈ និងស្ដេចសហម្បតីព្រហ្ម ទ្រង់ឲ្យជ្រះថ្លាហើយ ។ បានឮ

ថា ព្រះថេរៈអង្គុយក្នុងទីនោះ បានឃើញព្រហ្មមកដោយទិព្វចក្ខុ បានឮសំឡេងទូលអង្វរដោយទិព្វសោត ។ បានជ្រាបភាពដែលព្រះមានព្រះភាគ ទ្រង់ជ្រះថ្លាហើយ ដោយចេតោបរិយញ្ញាណ ព្រោះដូច្នោះ ការបញ្ជូនភិក្ខុណាមួយទៅ មិនជាទីសប្បាយដល់ ភិក្ខុដែលត្រូវហៅ ទើបតាំងចិត្តថា អញនឹងទៅ ទម្រាំព្រះសាស្តាទ្រង់មិនទាន់បញ្ជូនទៅ ទើបពោលយ៉ាងនេះ ។ បទថា **អប្បោស្សុក្កោ** ជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច គឺជាអ្នកមិនខ្វល់ខ្វាយក្នុងកិច្ចដទៃ ។ បទថា **ទិដ្ឋធម្មសុខវិហារំ** គឺធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ ។ ព្រះមានព្រះភាគ ទ្រង់គង់ខ្វល់ខ្វាយក្នុងធម៌ជាគ្រឿងនៅ គឺផលសមាបត្តិ មានបំណងនឹងប្រថាប់នៅ ។ ឥឡូវនេះ ព្រះអង្គនឹងប្រថាប់នៅតាមគាប់ចិត្ត ទើបព្រះមហាមោគ្គល្លានពោលថា ចិត្តរបស់ខ្ញុំព្រះអង្គបានកើតយ៉ាងនេះ ។ បទថា **មយម្បិទានិ** គឺព្រះមានព្រះភាគត្រាស់ថា តថាគតទូន្មានអ្នកដទៃ ដោយដេញចេញអំពីវិហារ ។ ប្រយោជន៍អ្វីដោយឱវាទរបស់អ្នកដទៃដល់ តថាគត ។ ឥឡូវនេះ សូម្បីតថាគតក៏នឹងនៅដោយវិហារធម៌ ជាសុខក្នុង ទិដ្ឋធម៌ ។ ព្រះថេរៈខុសក្នុងឋានៈនេះ មិនបានដឹងថា ជាភារៈរបស់ខ្លួន ។ ព្រោះភិក្ខុសង្ឃនេះជាភារៈរបស់ព្រះមហាថេរៈទាំង ២ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ កាលទ្រង់ហាមព្រះសារីបុត្រនោះ ត្រាស់បទថា **អាគមេហិ** ជាដើម ។ ឯព្រះមហាមោគ្គល្លានបានជ្រាបថា ជាភារៈរបស់ខ្លួន ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់បានប្រទានសាធុការដល់ព្រះមហាមោគ្គល្លាននោះ ។

[ ១៩០ ] សួរថា ព្រោះហេតុអ្វីទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា **ចត្តារីមានិ ភិក្ខវេ** ដូច្នេះ ឆ្លើយថា ព្រោះព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះឡើង ដើម្បីសម្តែងថា ក្នុងសាសនានេះ មានភ័យ ៤ យ៉ាង ។ បុគ្គលណាមិនខ្លាចភ័យទាំងនោះ បុគ្គលនោះ អាចស្ថិតនៅក្នុងសាសនានេះបាន ។ ឯពួកដទៃក្រៅអំពីនេះ មិនអាចឡើយ ។

ក្នុងបទទាំងនោះ បទថា **ឧទកោរោហន្តេ** គឺកាលបុគ្គលកំពុងចុះទៅ ។ បទថា **កុម្ភីលភយំ** បានដល់ ភ័យអំពីក្រពើ ។ បទថា **សុសុកាភយំ** បានដល់ ភ័យអំពីត្រីកាច ។ បទថា **ឧម្មិភយំ** នេះជាឈ្មោះរបស់សេចក្តីក្រោធ និងឧបាយាស ។ ឧបមាដូចបុគ្គលចុះកាន់ទឹកខាងក្រៅ លិចក្នុងរលកស្លាប់យ៉ាងណា ភិក្ខុក្នុងសាសនានេះ លិចក្នុងសេចក្តីក្រោធ និងសេចក្តីចង្អៀតចង្អល់ ហើយសឹក ក៏ដូច្នោះ ។ ហេតុនោះ សេចក្តីក្រោធ និងការចង្អៀតចង្អល់ លោកពោលថា **ឧម្មិភយំ** ។ បទថា **កុម្ភិលភយំ** ភ័យអំពីក្រពើនេះ ជាឈ្មោះរបស់ការឃើញតែផ្ទៃ ។ ឧបមាដូចបុគ្គលចុះកាន់ទឹកខាងក្រៅ ត្រូវក្រពើខាំស្លាប់ យ៉ាងណា ភិក្ខុក្នុងសាសនានេះ ក៏ដូច្នោះ បរិភោគព្រោះឃើញដល់ផ្ទៃ រមែងសឹក ។ ព្រោះហេតុនោះ ការឃើញដល់ផ្ទៃ លោកពោលថា **កុម្ភិលភយំ** ។

[ ១៩៣ ] បទថា **អរក្ខិតេនេវ កាយេន** សេចក្តីថា មិនរក្សាកាយដោយការអង្រួនក្បាលជាដើម ។ បទថា **អរក្ខិតាយ វាចាយ** សេចក្តីថា មិនរក្សាវាចាដោយពោលពាក្យគ្រោតគ្រាតជាដើម ។ បទថា **អនុបដ្ឋិតាយ**

**សតិយា** គឺ មិនតាំងស្មារតីប្រព្រឹត្តទៅក្នុងកាយ ។ បទថា **អសំវុតេហិ** គឺមិនបិទ ។ បទថា **បញ្ចន្នេតំ កាមគុណានំ អធិវចនំ** សេចក្តីថា បព្វជិតក្នុងសាសនានេះ លិចចុះក្នុងក្រសែទឹកកួចនៃកាមគុណ ៥ ហើយ សឹកចេញទៅ ដូចបុគ្គលចូលទឹក ដើម្បីទៅកាន់ត្រើយនាយ កាលលិចចុះ ក្នុងក្រសែទឹកកួចហើយ ក៏លិចស្លាប់ដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ ថា ភ័យកើតអំពីទឹកកួច គឺកាមគុណ ៥ ។

[ ១៩៤ ] បទថា **អនុទ្ធំសេតិ** គឺធ្វើឲ្យលំបាក ធ្វើឲ្យរួញរា ។ បទថា **រាគានុទ្ធំសេន** គឺមានចិត្តដែលរាគៈកម្ចាត់ហើយ ។ បទថា **មាតុគាម-ស្សេតំ អធិវចនំ** សេចក្តីថា ភ័យព្រោះត្រីកាច នេះជាឈ្មោះនៃ មាតុ គ្រាម ។ ឧបមាដូចបុគ្គលចុះកាន់ទឹកខាងក្រៅ បានទទួលការប្រហារ ស្លាប់ ព្រោះ អាស្រ័យត្រីកាច យ៉ាងណា ភិក្ខុក្នុងសាសនានេះ ក៏ដូច្នោះ កើត កាមរាគៈ ព្រោះអាស្រ័យមាតុគ្រាម ក៏សឹក ។ ព្រោះដូច្នោះ ទើបមាតុគ្រាម លោកពោលថា **សុសុកាភយំ** ។ បើបុគ្គលខ្លាចភ័យ ៤ យ៉ាង ហើយមិនចុះ កាន់ទឹក ក៏មិនបានទទួលផលអាក្រក់ ព្រោះអាស្រ័យទឹក ជាអ្នកស្រេកព្រោះ ត្រូវការទឹក និងជាអ្នកមានរាងកាយសៅហ្មង ព្រោះលម្អងធូលី យ៉ាងណា កាលភិក្ខុខ្លាចភ័យទាំង ៤ យ៉ាងនេះហើយ សូម្បីមិនបួសក្នុងសាសនា ក៏មិន បានទទួលផលល្អ ព្រោះអាស្រ័យសាសនា ជាអ្នកស្រេក ព្រោះចំណង់ គឺ តណ្ហា និងជាអ្នកមានចិត្តសៅហ្មងដោយធូលី គឺកិលេស ដូច្នោះ ។ម្យ៉ាង ទៀត កាលបុគ្គលមិនខ្លាចភ័យទាំង ៤ យ៉ាងនេះ ហើយចុះកាន់ទឹក រមែង

មានផលដូចពោលហើយ យ៉ាងណា កាលបុគ្គលមិនខ្លាចភ័យ ៤ យ៉ាងនេះហើយ សូមបួសក្នុងសាសនា ក៏រមែងមានអានិសង្សដូចពោលហើយ ។

ម្យ៉ាងទៀត ព្រះថេរៈពោលថា បុគ្គលខ្លាចភ័យ ៤ យ៉ាងហើយ មិនចុះកាន់ទឹកក៏មិនអាចឆ្លងកាត់ក្រសែ ឆ្លងដល់ត្រើយនាយបាន ។ កាលមិនខ្លាច ចុះកាន់ទឹកក៏អាចឆ្លងទៅបាន យ៉ាងណា កាលបុគ្គលនោះខ្លាចហើយ សូមបួសក្នុងសាសនា ក៏មិនអាចកាត់ក្រសែតណ្ហា ហើយឃើញត្រើយ គឺព្រះនិព្វានបាន ។ បើមិនខ្លាច ចេញបួស ទើបអាច ដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ។

ម្យ៉ាងទៀត ទេសនានេះ ចប់ដោយអំណាចនេយ្យបុគ្គល ដោយប្រការដូច្នេះ ។ ៚

## អដ្ឋកថា ចាតុមសូត្រទី ៧ ចប់

# សុត្តន្តបិដក

## នឡកបានសូត្រទី ៨

[ ១៩៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃចារ ទៀបស្រុកនឡកបានៈ ក្នុងដែនកោសល ។ ក៏សម័យនោះ កុលបុត្តទាំងឡាយច្រើនរូប ជាអ្នកមានកេរ្តិ៍ឈ្មោះប្រាកដជាងគេ ចេញចាកផ្ទះចូលមកកាន់ផ្នួស ដោយសទ្ធា ឧទ្ទិសព្រះមានព្រះភាគ គឺ ព្រះអនុរុទ្ធ មានអាយុ ១ ព្រះភទ្ទិយៈមានអាយុ ១ ព្រះកិម្ពិលៈមានអាយុ ១ ព្រះភគ្គុ មានអាយុ ១ ព្រះកោណ្ឌញ្ញៈមានអាយុ ១ ព្រះរេវតៈមានអាយុ ១ ព្រះអានន្ទមានអាយុ ១ និងកុលបុត្តទាំងឡាយ ដែលមានកេរ្តិ៍ឈ្មោះប្រាកដជាងគេដទៃទៀត ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃជាបរិវារ ទ្រង់គង់ក្នុងទីវាល ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ប្រារព្ធនូវកុលបុត្តទាំងឡាយ ហើយត្រាស់ហៅពួកភិក្ខុមកសួរថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ផ្នួសហើយ ដោយសទ្ធា ឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងនោះ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ភិក្ខុទាំងឡាយនោះ ក៏នៅស្ងៀម ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធកុលបុត្តទាំងនោះ ទើបត្រាស់សួរពួកភិក្ខុអស់វារៈពីរដងថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ផ្នួសហើយ ដោយសទ្ធា ឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនោះ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ភិក្ខុ

អម្បាលនោះ ក៏នៅស្សៀមអស់ វារៈពីរដងទៀត ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធកុលបុត្តទាំងនោះ ទើបត្រាស់សួរពួកភិក្ខុ អស់វារៈបីដងថា ម្នាលភិក្ខុទាំងឡាយ កុលបុត្តទាំងឡាយណា ចេញចាកផ្ទះចូលមកកាន់ ផ្នួសហើយដោយសទ្ធា ឧទ្ទិសតថាគត ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនោះ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ភិក្ខុអម្បាលនោះ ក៏នៅស្សៀមអស់វារៈបីដងទៀត ។

[ ១៩៦ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា បើដូច្នោះគួរតែតថាគត សួរកុលបុត្តអម្បាលនោះឯង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រាស់សួរព្រះអនុរុទ្ធមានអាយុថា ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ខ្លះដែរឬទេ ។ ឱព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គត្រេកអរក្នុងព្រហ្មចរិយៈ ។ ម្នាលពួកអនុរុទ្ធ ប្រពៃហើយ ប្រពៃហើយ ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយ ត្រេកអរហើយក្នុងព្រហ្មចរិយៈ ដោយហេតុណា ហេតុនុ៎ះឯង សមគួរដល់អ្នកទាំងឡាយ ដែលជាកុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួសដោយសទ្ធាហើយ ម្នាលពួកអនុរុទ្ធ ព្រោះថា អ្នកទាំងឡាយប្រកបដោយវ័យជាដំបូង ជាកំលោះដ៏ចម្រើន មានសក់ខ្មៅស្រិល គួរនឹងបរិភោគកាមទាំងឡាយ ព្រោះហេតុណា ម្នាលពួកអនុរុទ្ធ ព្រោះហេតុនោះ អ្នកទាំងឡាយ កំពុងប្រកបដោយវ័យជាដំបូង ជាកំលោះដ៏ចម្រើន មានសក់ខ្មៅស្រិល ក៏ឆ្លៀតចេញចាកផ្ទះ ចូលមកកាន់ផ្នួសបាន ម្នាលពួកអនុរុទ្ធ មួយវិញទៀត អ្នកទាំងឡាយនោះ មិនមែនព្រះរាជាទ្រង់គុំកួន ហើយចេញចាកផ្ទះ

ចូលមកកាន់ផ្នួសទេ មិនមែនចោរគុំកួន ហើយចេញចាកផ្ទះចូលមកកាន់ផ្នួសទេ មិនមែនចំពាក់បំណុលគេ ហើយចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ មិនមែនមានវៀរក្តី ហើយភ័យចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ មិនវិបត្តិដោយចិញ្ចឹមជីវិត ហើយចេញចាកផ្ទះ ចូលមកកាន់ផ្នួសទេ គឺពិតជា ( អ្នកទាំងឡាយ គិតឃើញថា ) ឱហ្ន៎ អាត្មាអញជាអ្នកត្រូវជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ គ្របសង្កត់ ឈ្មោះថាមានទុក្ខគ្របសង្កត់ មានទុក្ខរួបរឹតហើយ ឱធ្វើដូចម្តេចហ្ន៎ ការធ្វើនូវទីបំផុតកងទុក្ខទាំងអស់នេះ នឹងប្រាកដបាន ម្នាលពួកអនុរុទ្ធ ក្រែងអ្នកទាំងឡាយ មានសទ្ធាយ៉ាងនេះ ហើយចេញចាកផ្ទះចូលមកកាន់ផ្នួសឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលពួកអនុរុទ្ធ ចុះកុលបុត្តដែលបួសយ៉ាងនេះហើយ ត្រូវធ្វើកិច្ចអ្វីខ្លះ ។ ម្នាលពួកអនុរុទ្ធ ( ប្រសិនបើ ) បុគ្គល ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ តែនៅមិនទាន់បានដល់បីតិនិងសុខ ឬមិនទាន់បានដល់សេចក្តីសុខដទៃ ដែលស្ងាត់លើសជាងបីតិនិងសុខនោះទេ ។ អភិជ្ឈាក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ព្យាបាទក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ថីនមិទ្ធៈក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន វិចិកិច្ឆាក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ឧទ្ធច្ចកុក្កុច្ចៈក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន អរតិក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន សេចក្តីខ្ជិលច្រអូសក្តី តែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ម្នាលពួកអនុរុទ្ធ ( ព្រោះថា ) បុគ្គលនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌

ទាំងឡាយ តែនៅមិនទាន់បានបីតិនិងសុខ ឬមិនទាន់បានសេចក្ដីសុខដទៃ ដែលស្ងាត់លើសជាងបីតិនិងសុខនោះ ។ ម្នាលពួកអនុរុទ្ធ ( បើ ) បុគ្គល ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់បីតិនិង សុខ ឬបានដល់សេចក្ដីសុខដទៃ ដែលស្ងាត់លើសជាងបីតិនិងសុខនោះ ហើយ ។ អភិជ្ឈាក្ដី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ព្យាបាទក្ដី មិន គ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ថីនមិទ្ធៈក្ដីមិនគ្របសង្កត់ចិត្តរបស់បុគ្គល នោះបាន ឧទ្ធច្ចកុក្កុច្ចៈក្ដី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន វិចិកិច្ឆាក្ដី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន អរតិក្ដី មិនគ្របសង្កត់ចិត្តរបស់បុគ្គល នោះបាន សេចក្ដីខ្ជិលច្រអូសក្ដី មិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះបាន ម្នាល ពួកអនុរុទ្ធ ( ព្រោះថា ) បុគ្គលនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាក អកុសលទាំងឡាយ ហើយបានដល់នូវបីតិនិងសុខ ឬបានដល់នូវសេចក្ដី សុខដទៃ ដែលស្ងាត់ជាងបីតិនិងសុខនោះ ។

[ ១៩៧ ] ម្នាលពួកអនុរុទ្ធ អ្នកទាំងឡាយ មានសេចក្ដីត្រិះរិះ ក្នុង តថាគតថា អាសវៈទាំងឡាយណា នាំមកនូវសេចក្ដីសៅហ្មង នាំមកនូវភព ថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរានិងមរណៈ អាសវៈអម្បាលនោះ ព្រះតថាគតពុំទាន់បានលះបង់ទេ ហេតុដូច្នោះ បានជាព្រះតថាគត ដឹងហើយទើបសេពរបស់ខ្លះ ( ដែលគួរ សេព ) ដឹងហើយទើបអត់សង្កត់របស់ខ្លះ ( ដែលគួរអត់សង្កត់ ) ដឹងហើយ ទើបវៀររបស់ខ្លះ ( ដែលគួរវៀរ ) ដឹងហើយទើបបន្ទោបង់របស់ខ្លះ ( ដែល

គួរបន្ទោបង់ ) ដូច្នេះឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនឹងបានត្រិះរិះចំពោះព្រះមានព្រះភាគយ៉ាងនេះថា អាសវៈទាំងឡាយណា នាំមកនូវសេចក្ដីសៅហ្មង នាំមកនូវភពថ្មីប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិជរា មរណៈ អាសវៈអម្បាលនោះ ព្រះតថាគតមិនទាន់បានលះបង់ទេ ហេតុដូច្នោះ បានជាព្រះតថាគត ទ្រង់ជ្រាបហើយទើបសេពរបស់ខ្លះ ទ្រង់ជ្រាបហើយទើបអត់សង្កត់របស់ខ្លះ ទ្រង់ជ្រាបហើយ ទើបវៀររបស់ខ្លះ ទ្រង់ជ្រាបហើយទើបបន្ទោបង់របស់ខ្លះ ដូច្នេះក៏ទេ បពិត្រព្រះអង្គដ៏ចម្រើន តែពួកខ្ញុំព្រះអង្គ មានសេចក្ដីត្រិះរិះចំពោះព្រះមានព្រះភាគយ៉ាងនេះថា អាសវៈទាំងឡាយណា នាំមកនូវសេចក្ដីសៅហ្មង នាំមកនូវភពថ្មីប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិជរា មរណៈ អាសវៈអម្បាលនោះ ព្រះតថាគតទ្រង់លះបង់បានហើយ ហេតុដូច្នោះ បានជាព្រះតថាគតទ្រង់ជ្រាបហើយទើបសេពរបស់ខ្លះ ទ្រង់ជ្រាបហើយទើបអត់សង្កត់របស់ខ្លះ ទ្រង់ជ្រាបហើយទើបវៀររបស់ខ្លះ ទ្រង់ជ្រាបហើយទើបបន្ទោបង់របស់ខ្លះ ដូច្នេះឯង ។ ម្នាលពួកអនុរុទ្ធ ប្រពៃហើយ ប្រពៃហើយ ម្នាលពួកអនុរុទ្ធ អាសវៈទាំងឡាយណា ដែលនាំមកនូវសេចក្ដីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា មរណៈ អាសវៈអម្បាលនោះ តថាគតបានលះបង់ហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្របែល គាស់រម្លើងឲ្យលែងដុះតទៅទៀត

ជាធម៌លែងមានបែបភាពតទៅទៀត ជាធម៌មិនមានកំណើតតទៅខាងមុខទៀត ម្នាលពួកអនុរុទ្ធ ដូចជាដើមត្នោតកំបុតក មិនគួរដុះឡើងវិញបាន យ៉ាងណា ម្នាលពួកអនុរុទ្ធ អាសវៈទាំងឡាយណា ដែលនាំមកនូវសេចក្ដីសៅហ្មង នាំមកនូវភពថ្មី ប្រកបដោយសេចក្ដីក្រវល់ក្រវាយ មានវិបាកជាទុក្ខតទៅ ជាទីតាំងនៃជាតិ ជរា មរណៈ ( អាសវៈទាំងនោះ ) តថាគតលះបង់ហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀតឲ្យអស់រលីង ដូចជាដើមត្នោត ដែលគេក្របែលគាស់រម្លើងឲ្យលែងដុះតទៅទៀត ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌មិនមានកំណើតតទៅខាងមុខទៀតទេ យ៉ាងនោះឯង ព្រោះហេតុនោះ បានជាតថាគតដឹងហើយទើបសេពរបស់ខ្លះ ដឹងហើយទើបអត់សង្កត់របស់ខ្លះ ដឹងហើយទើបវៀររបស់ខ្លះ ដឹងហើយទើបបន្ទោបង់របស់ខ្លះ ។

[ ១៩៨ ] ម្នាលពួកអនុរុទ្ធ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច ព្រះតថាគតឃើញប្រយោជន៍ដូចម្ដេច បានជាព្យាករក្នុងកំណើតរបស់ពួកសាវក ដែលធ្វើមរណកាលកន្លងទៅហើយថា សាវកឯណោះ កើតក្នុងទីឯណោះ សាវកឯណោះ កើតក្នុងទីឯណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយរបស់ខ្ញុំព្រះអង្គទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹងអាស្រ័យ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាប្រោសបំភ្លឺនូវសេចក្ដីនៃភាសិតនុ៎ះ ភិក្ខុទាំងឡាយបានស្ដាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុកបាន ។ ម្នាលពួកអនុរុទ្ធ

តថាគតព្យាករក្នុងកំណើតរបស់ពួកសាវ័ក ដែលធ្វើមរណកាលកន្លងទៅ ហើយថាសាវ័កឯណោះ កើតក្នុងទីឯណោះ សាវ័កឯណោះ កើតក្នុងទីឯណោះ ដើម្បីឲ្យជនស្ញប់ស្ញែងក៏ទេ ដើម្បីប្រលោមជនក៏ទេ ដើម្បីអានិសង្សគឺលាភសក្ការៈនិងសេចក្តីសរសើរក៏ទេ ( ឬ ) គិតថា ឲ្យគេស្គាល់តថាគតក៏ទេ ។ ម្នាលពួកអនុរុទ្ធ កុលបុត្តទាំងឡាយមានសទ្ធា មានសេចក្តីត្រេកអរខ្លាំង មានបាមោជ្ជៈក្លៀវក្លា លុះកុលបុត្តអម្បាលនោះ បានស្តាប់ព្យាករណ៍នោះហើយ តែងបង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ម្នាលពួកអនុរុទ្ធ ការព្យាករណ៍នោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្តីសុខ ដល់បុគ្គលទាំងឡាយនោះ អស់កាលជាយូរអង្វែង ។

[ ១៩៩ ] ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះ រមែងឮថាភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា បានឋិតនៅក្នុងអរហត្តផល ដូច្នេះ ភិក្ខុនោះ យល់ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា លោកមានអាយុនោះ មានសីលយ៉ាងនេះដូច្នេះខ្លះ លោកមានអាយុនោះ មានធម៌យ៉ាងនេះ ដូច្នេះខ្លះ លោកមានអាយុនោះ មានបញ្ញាយ៉ាងនេះ ដូច្នេះខ្លះ លោកមានអាយុនោះ មានវិហារធម៌យ៉ាងនេះ ដូច្នេះខ្លះ លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់លោកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុ ។ ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្មវិន័យនេះ រមែង

ឮថា ភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះ ព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាឧបបាតិកៈកំណើត ( កើតក្នុងសុទ្ធាវាស ) បរិនិព្វាន ក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះ អស់ទៅនៃឱរម្ភាគិយសំយោជនៈទាំងឡាយ ៥ ដូច្នេះ ភិក្ខុនោះ យល់ឃើញ លោកមានអាយុនោះ ដោយខ្លួនឯង ឬបានឮតៗ មកថា លោកមានអាយុ នោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាង នេះ ... មានវិហារធម៌យ៉ាងនេះ ... លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនោះរឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់លោកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអានន្ទ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌របស់ភិក្ខុ ។ ម្នាលពួកអានន្ទ ភិក្ខុក្នុង ធម្មវិន័យនេះ រមែងឮថា ភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះ ព្រះមានព្រះភាគ ទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខបាន ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ មានរាគៈ ទោសៈ មោហៈស្រាលស្តើង ដូច្នេះ ភិក្ខុនោះយល់ឃើញលោក មានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា លោកមានអាយុនោះ មាន សីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... លោកមានអាយុនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់លោក នោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអានន្ទ យ៉ាងនេះ

ឯង ឈ្មោះថាផាសុវិហារធម៌របស់ភិក្ខុ ។ ម្នាលពួកអនុរុទ្ធ ភិក្ខុក្នុងធម្ម-វិន័យនេះ រមែងឮថា ភិក្ខុឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ ដូច្នេះ ភិក្ខុនោះ យល់ឃើញលោកមានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា លោកមានអាយុនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... លោកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់លោកនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌ របស់ភិក្ខុ ។

[ ២០០ ] ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថាភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា បានឋិតនៅក្នុងអរហត្តផល ដូច្នេះ ភិក្ខុនីនោះ យល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះមានសីលយ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានបញ្ញាយ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានវិហារធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនីនោះរឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធយ៉ាងនេះ

ឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអានន្ទ ភិក្ខុនីក្នុងធម្ម-វិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា មានសភាពជាឱបបាតិកៈកំណើត បរិនិព្វាន ក្នុងលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ដូច្នេះ ភិក្ខុនីនោះ យល់ឃើញនាងនោះ ដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះមានសីលយ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានបញ្ញាយ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានវិហារធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនីនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអានន្ទ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអានន្ទ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិនីបុគ្គល មកកាន់លោក នេះតែម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខ ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ មានរាគៈ ទោសៈ មោហៈស្រាលស្តើង ដូច្នេះ ភិក្ខុនីនោះ បានយល់ឃើញ នាងនោះដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះមានសីលយ៉ាងនេះ ដូច្នេះ ខ្លះ មានធម៌យ៉ាងនេះខ្លះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនីនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់

ភិក្ខុនីនោះ ក៏បង្អោនចិត្តទៅដើម្បីភាព ដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌របស់ភិក្ខុនី ។ ម្នាលពួកអនុរុទ្ធ ភិក្ខុនីក្នុងធម្មវិន័យនេះ រមែងឮថា ភិក្ខុនីឈ្មោះនេះ មានមរណកាលធ្វើហើយ ភិក្ខុនីនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិ ជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ ភិក្ខុនីនោះ បានយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ភិក្ខុនីនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ភិក្ខុនីនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ភិក្ខុនី ។

[ ២០១ ] ម្នាលពួកអនុរុទ្ធ ឧបាសកក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាឱបបាតិកៈកំណើត បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈ ៥ ដូច្នេះ ឧបាសកនោះ បានយល់ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា អ្នកមានអាយុនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ អ្នកមានអាយុនោះ មានធម៌យ៉ាងនេះ ដូច្នេះខ្លះ អ្នកមានអាយុនោះ មានបញ្ញាយ៉ាងនេះ

ដូច្នេះខ្លះ អ្នកមានអាយុនោះមានវិហារធម៌យ៉ាងនេះ ដូច្នេះខ្លះ អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសកនោះ រឭកឃើញ នូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ឧបាសកនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ឧបាសក ។ ម្នាលពួកអនុរុទ្ធ ឧបាសកក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ដូច្នេះ ឧបាសកនោះ បានយល់ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា អ្នកមានអាយុនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសកនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញារបស់ ឧបាសកនោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ឧបាសក ។ ម្នាលពួកអនុរុទ្ធ ឧបាសកក្នុងធម្មវិន័យនេះ បានឮថា ឧបាសកឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសកនោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ ឧបាសកនោះ បានយល់

ឃើញអ្នកមានអាយុនោះដោយខ្លួនឯង ឬបានឮតៗ មកថា អ្នកមានអាយុនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... អ្នកមានអាយុនោះ មានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសកនោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និង បញ្ញា របស់ឧបាសកនោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌របស់ឧបាសក ។

[ ២០២ ] ម្នាលពួកអនុរុទ្ធ ឧបាសិកាក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះមានមរណកាលធ្វើហើយ ឧបាសិកានោះ ព្រះមានព្រះភាគទ្រង់ព្យាករថា មានសភាពជាឱបបាតិកៈកំណើត បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃ ឱរម្ភាគិយសំយោជនៈ ៥ ដូច្នេះ ឧបាសិកានោះបានយល់ឃើញនាងនោះ ដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះមានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ មានវិហារធម៌យ៉ាងនេះ ... នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសិកានោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ឧបាសិកានោះហើយ ក៏បង្អោនចិត្តទៅដើម្បីភាពដូច្នោះ ។ ម្នាលពួកអនុរុទ្ធ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌ របស់ឧបាសិកា ។ ម្នាលពួកអនុរុទ្ធ ឧបាសិកាក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសិកានោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសកទាគាមិនីបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើ

នូវទីបំផុតទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ មានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ដូច្នេះ ឧបាសិកានោះ យល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះឯង មានសីលយ៉ាងនេះ ដូច្នេះខ្លះ មានធម៌យ៉ាងនេះ ។បេ។ មានបញ្ញាយ៉ាងនេះ ... មានវិហារធម៌យ៉ាងនេះ ... នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសិកានោះរឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ឧបាសិកានោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថាផាសុវិហារធម៌ របស់ឧបាសិកា ។ ម្នាលអានន្ទ ឧបាសិកាក្នុងធម្មវិន័យនេះ រមែងឮថា ឧបាសិកាឈ្មោះនេះ មានមរណកាលធ្វើហើយ ឧបាសិកានោះ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាសោតាបន្នបុគ្គល មានភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀងមានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ដូច្នេះ ឧបាសិកានោះយល់ឃើញនាងនោះដោយខ្លួនឯង ឬបានឮតៗ មកថា នាងនោះ មានសីលយ៉ាងនេះ ដូច្នេះខ្លះ នាងនោះ មានធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះ មានវិហារធម៌យ៉ាងនេះ ដូច្នេះខ្លះ នាងនោះមានវិមុត្តិយ៉ាងនេះ ដូច្នេះខ្លះ ។ ឧបាសិកានោះ រឭកឃើញនូវសទ្ធា សីលៈ សុតៈ ចាគៈ និងបញ្ញា របស់ឧបាសិកានោះហើយ ក៏បង្អោនចិត្តទៅ ដើម្បីភាពដូច្នោះ ។ ម្នាល ពួកអានន្ទ យ៉ាងនេះឯង ឈ្មោះថា ផាសុវិហារធម៌ របស់ឧបាសិកា ។ ម្នាលពួកអានន្ទ ហេតុដូច្នោះ បានជាតថាគតព្យាករក្នុងកំណើតរបស់ពួកសាវ័កដែលធ្វើមរណកាលកន្លងទៅហើយថា សាវ័កឯណោះ កើតក្នុងទីឯណោះ

សាវ័កឯណោះ កើតក្នុងទីឯណោះ ដើម្បីនឹងឲ្យជនស្ញប់ស្ញែងក៏ទេ ដើម្បីនឹងប្រលោមជនក៏ទេ ដើម្បីអានិសង្ស គឺលាភសក្ការៈនិងសេចក្តីសរសើរក៏ទេ ( ឬ ) គិតថា ឲ្យគេស្គាល់តថាគត ក៏ទេដែរ ។ ម្នាលពួកអនុរុទ្ធ កុលបុត្តទាំងឡាយ អ្នកមានសទ្ធា មានសេចក្តីត្រេកអរខ្លាំង មានបាមោជ្ជៈ ក្សៀវក្លា កុលបុត្តអម្បាលនោះ លុះបានស្តាប់នូវព្យាករណ៍នោះហើយ តែងបង្អោនចិត្តទៅដើម្បីភាពដូច្នោះ ម្នាលពួកអនុរុទ្ធ ការព្យាករណ៍នោះ ( តែងប្រព្រឹត្តទៅ ) ដើម្បីប្រយោជន៍និងសេចក្តីសុខដល់កុលបុត្តទាំងឡាយនោះ អស់កាលជាយូរអង្វែង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ព្រះអនុរុទ្ធមានអាយុ ក៏មានសេចក្តីពេញចិត្តត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ នឡកបានសូត្រទី ៨

# អដ្ឋកថា

## នឡកបានសូត្រ

[ ១៩៥ ] នឡកបានសូត្រ មានពាក្យផ្ដើមថា **ឯវមេ្ម សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **នឡកបានេ** គឺជិតស្រុកមានឈ្មោះយ៉ាងនេះ ។ មានរឿងតំណាលថា ក្នុងអតីត ព្រះពោធិសត្វកើតក្នុងកំណើតពានរ មានរាងកាយធំ ជាស្ដេចស្វា មានស្វាច្រើនពាន់ជាបរិវារ ត្រាច់ទៅឯដើងភ្នំ ។ ស្ដេចពានរមានបុណ្យ និងមានបញ្ញាច្រើន ទូន្មានបរិវារថា នែអ្នកទាំងឡាយ ត្រង់ជើងភ្នំនេះ មានផ្លៃឈើពុល ឈ្មោះថា ស្រះបោក្ខរណីក៏មានអមនុស្សហួងហែង ។ ពួកអ្នកចូរស៊ីផ្លៃឈើចំពោះអ្នកធ្លាប់ស៊ីប៉ុណ្ណោះ ។ ផឹកទឹកចំពោះដែលធ្លាប់ផឹក ។ ក្នុងសេចក្ដីនេះមិនមានកិច្ចដែលពួកអ្នកត្រូវសួរខ្ញុំទេ ម្យ៉ាងទៀត ពួកអ្នកបើមិនទាន់សួរដល់ផ្លៃឈើដែលមិនធ្លាប់ស៊ី ទឹកដែលមិនធ្លាប់ផឹកជាមួយខ្ញុំជាមុនទេ ចូរកុំស៊ី កុំផឹកឡើយ ។ ថ្ងៃមួយ ពានរទាំងនោះស្វែងរកអាហារ ទៅដល់ជើងភ្នំមួយពិនិត្យមើលទឹកផឹក ឃើញស្រះបោក្ខរណីមួយ ដែលមានអមនុស្សហួងហែង ទើបមិនប្រញាប់ប្រញាល់ផឹក អង្គុយព័ទ្ធជុំវិញស្រះ រង់ចាំព្រះមហាសត្វមក ។ ព្រះមហាសត្វមកហើយ សួរថា ហេតុអ្វីពួកអ្នកមិនផឹកទឹក ។ ពួកពានរឆ្លើយថា រង់ចាំលោកម្ចាស់មកសិន ។ ស្ដេចពានរពោលថា ល្អហើយអ្នកទាំងឡាយ ហើយក៏ពិនិត្យ មើលស្នាមជើង បានឃើញតែស្នាមជើងចុះទៅប៉ុណ្ណោះ មិនឃើញស្នាមជើងឡើងមកឡើយទើបបានដឹងថា

មានអន្តរាយ រំពេចនោះឯង អមនុស្សដែល កើតក្នុងស្រះនោះបានញែក ទឹកជា ២ ចំណែកចេញមក ។ អារក្ខទឹកមានមុខក្រហម ពោះខៀវ ដៃ ជើងក្រហម ចង្កូមធំ ជើងកោង រូបរាងគួរខ្លាច ពោលថាព្រោះហេតុអ្វី ទើប ពួកឯងមិនផឹកទឹក ទឹកឆ្ងាញ់ ចូរផឹកចុះ ពួកឯងជឿពាក្យរបស់ស្តេចពានរ នោះឬ ព្រះមហាសត្វសួរថា អ្នកជាអមនុស្សអាស្រ័យនៅក្នុងស្រះនេះឬ យក្ខ ឆ្លើយថា ត្រូវហើយយើងអាស្រ័យនៅក្នុងស្រះនេះ ។ មហាសត្វសួរថា អ្នក ចាប់បុគ្គលដែលចុះទៅក្នុងស្រះនេះឬ យក្ខឆ្លើយថា ត្រូវហើយ យើងនឹង ស៊ីអ្នកទាំងអស់ ។ មហាសត្វពោលថា នែយក្ខ អ្នកមិនអាចស៊ីពួកខ្ញុំបាន ទេ ។ យក្ខសួរថា ពួកឯងនឹងផឹកទឹកឬ មហាសត្វឆ្លើយថា ត្រូវហើយខ្ញុំ នឹងផឹក ។ យក្ខពោលថា កាលបើដូច្នោះ សូម្បីតែម្នាក់ក៏នឹងមិនរួចផុតអំពី យើងទៅបានដែរ ។ ស្តេចពានរពោលថា ខ្ញុំនឹងផឹកទឹក មិនទៅក្នុងអំ-ណាចរបស់អ្នក ដូច្នេះហើយ ទើបឲ្យពានរនាំយក ដើមបបុសមួយមក ចាប់ ត្រង់ចុង ហើយផ្លុំទៅ ។ បបុសបានជាបំពង់មួយ ។ ស្តេចពានរនោះ អង្គុយ ផឹកទឹកត្រង់ច្រាំង ។ ស្តេចពានរបានឲ្យពានរដ៏សេសនាំដើមបបុសចំពោះ ខ្លួន ផ្លុំហើយ ឲ្យទៅ ។ កាលយក្ខកំពុងមើលនោះឯង ពានរគ្រប់គ្នា ក៏បាន ផឹកទឹក ដូចដែលស្តេចពានរពោលទុកថា

យើងឃើញស្នាមជើងដែលមិនឡើង ឃើញតែស្នាមជើងដែលចុះ យើង ផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់យើងមិនបានឡើយ ។ តាំងអំពីនោះ មក បបុសទាំងឡាយដែលដុះក្នុងទីនោះ មិនមានថ្នាំង ជាបំពង់តែមួយ រហូត

ដល់សព្វថ្ងៃនេះ ។ ក្នុងកប្បនេះ ដើមបបុសនេះ និងទីកន្លែង ៣ ទៀត តាំងនៅអស់បាដិហារិយកប្ប មាន ៤ យ៉ាង គឺរូបទន្សាយលើមណ្ឌលព្រះចន្ទ ១ ទីដែលភ្លើងរលត់កាលព្រះពោធិសត្វធ្វើសច្ចកិរិយាក្នុងវដ្តកជាតក ១ កាលដែលភ្លៀងមិនស្រក់ត្រង់ទីលំនៅនៃមាតាបិតារបស់ឃដិការស្មូនឆ្នាំង ១ ភាពដែលដើមបបុសត្រង់ស្រះបោក្ខរណីនោះ ជាបំពង់ឥតថ្នាំង ១ ដោយប្រការនេះ ទើបស្រះបោក្ខរណីនោះ ឈ្មោះថា **នឡកបាន** ព្រោះពានរផឹកទឹកដោយដើមបបុស ។ ក្នុងកាលតមក ស្រុកតាំងឡើងព្រោះអាស្រ័យស្រះបោក្ខរណីនោះ ដូច្នោះទើបស្រុកនោះឈ្មោះថា **នឡកបាន** លោកពោលថា **នឡកបានេ** ព្រោះសំដៅដល់ស្រុកនោះ ។

បទថា **បលាសវនេ** គឺក្នុងព្រៃដើមចារ ។

[ ១៩៦ ] បទថា **តគ្ឃ មយំ ភន្តេ** គឺ បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គតែមួយចំណែកប៉ុណ្ណោះ ។ លោកសម្តែងថា ភិក្ខុពួកដទៃណា សូម្បីត្រេកអរហើយ រមែងត្រេកអរក្នុងពាក្យ ទូន្មានរបស់លោក ភិក្ខុទាំងនោះដូចគ្នានឹងពួកយើង រមែងត្រេកអរក្រៃលែង។

គប្បីជ្រាបបទ **នេវ រាជាភិនីតា** ជាដើមដូចតទៅនេះថា បុគ្គលម្នាក់ធ្វើខុសចំពោះព្រះរាជាហើយ ចៀសចេញទៅ ព្រះរាជាត្រាស់សួរថា បុគ្គលឈ្មោះនោះទៅណា ក្រាបទូលថា គេចទៅហើយ ។ ព្រះរាជាត្រាស់ថា បុគ្គលនោះនឹងមិនរួចផុតអំពីយើង សូម្បីក្នុងទីដែលគេចចេញទៅ ។ តែបើបុគ្គលនោះ គប្បីបួស ក៏គប្បីផុតបាន ។ បុគ្គលចិត្តល្អម្នាក់ ទៅប្រាប់ដំណឹងនោះ

ដល់បុគ្គលនោះថា បើអ្នកប្រាថ្នាជីវិត សូមអ្នកបួសចុះ ។ បុគ្គលនោះបួសហើយ រក្សាជីវិតត្រាច់ទៅ ភិក្ខុនេះឈ្មោះថា ធ្វើនូវកំហុសចំពោះព្រះរាជា ។ ឯបុគ្គលម្នាក់កាត់ជញ្ជាំង លួចរបស់មានតម្លៃ របស់ចោរត្រាច់ទៅ ។ ពួកចោរដឹងហើយ មិនដឹងភាពដែលបុរសមានសេចក្ដីត្រូវការ ទើបពោលថា អញនឹងឲ្យបុគ្គលនេះដឹង បុគ្គលនោះដឹងដំណឹងនោះ ហើយក៏គេចទៅ ។ ពួកចោរបានឮថា បុគ្គលនោះគេចទៅហើយ ទើបពោលថា បុគ្គលនោះនឹងមិនផុតអំពីយើងបានឡើយ សូម្បីក្នុងទីដែលគេទៅ តែបើបុគ្គលនោះបួស គប្បីផុតបាន ។ បុគ្គលនោះឮដំណឹងនោះហើយ ទើបបួស ។ ភិក្ខុនេះឈ្មោះថា ត្រូវចោរឃ្លាំតាមចាប់ ។ ឯបុគ្គលម្នាក់ទៀត មានបំណុលច្រើន ត្រូវម្ចាស់បំណុលបៀតបៀន ទើបគេចចេញអំពីស្រុកនោះ ពួកម្ចាស់បំណុលស្ដាប់ហើយ ទើបពោលថា បុគ្គលនោះនឹងមិនផុតអំពីយើងទៅបាន សូម្បីតែក្នុងទីដែលគេទៅ បើបុគ្គលនោះគប្បីបួស ទើបផុតបំណុលទៅបាន ។ បុគ្គល នោះឮដំណឹងនេះហើយ ទើបបួស ។ ភិក្ខុនេះឈ្មោះថា ត្រូវម្ចាស់បំណុលរឹបជាន់ ។ បុគ្គលខ្លាចភ័យឯណាមួយ មានរាជភ័យជាដើម ជាអ្នកក្ដៅក្រហាយ ចេញបួស ឈ្មោះថា ក្ដៅក្រហាយព្រោះភ័យ ។ បុគ្គលមិនអាចតាំងជីវិតនៅបាន ក្នុងវេលាអត្តរឡើងថ្លៃជាដើម ទើបបួស ឈ្មោះថា ត្រូវអាជីវៈបៀតបៀន ។ អធិប្បាយថា ត្រូវអាជីវៈគ្របសង្កត់ ។ ក្នុងជនទាំងនេះទោះមួយរូប ឈ្មោះថា បួសហើយដោយហេតុទាំងនេះមិនមាន ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **នេវ រាជាភិនីតា** គឺមិន

មែនជាអ្នកធ្វើខុស ចំពោះព្រះរាជាជាដើម ។ បទថា **វិវេកំ** គឺជាអ្នកស្ងាត់ ។ លោកអធិប្បាយថា បុគ្គលដែលស្ងាត់ចាកកាម និងចាកអកុសលធម៌ គប្បីសម្រេចបីតិ និងសុខ ពោលគឺ បឋមជ្ឈាន និងទុតិយជ្ឈាន បើស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ហើយ មិនទាន់សម្រេចបីតិ និងសុខ ឬមិនទាន់សម្រេចសុខដទៃដែលស្ងប់ជាង ដោយអំណាចនៃឈាន ២ និងមគ្គ ៤ ខាងលើ ។ អភិជ្ឈាជាដើមនេះ រមែងគ្របសង្កត់ ចិត្តនៃភិក្ខុនោះ តាំងនៅ ។ ក្នុងបទទាំងនោះ បទថា **អរតិ** បានដល់ ភាពជាអ្នកនឿយណាយក្នុងធម៌ដែលជាអធិកុសល ។ បទថា **តន្ទី** គឺ ភាពជាបុគ្គលខ្ជិលច្រអូស ។ ភិក្ខុណាបួសហើយយ៉ាងនេះ មិនអាចធ្វើកិច្ចរបស់អ្នកបួសបាន ។ ធម៌លាមកទាំង ៧ យ៉ាងនេះ កើតដល់ភិក្ខុហើយ រមែងគ្របសង្កត់ចិត្ត ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងដូច្នេះហើយ ឥឡូវនេះដើម្បីទ្រង់សម្តែងថា ធម៌ទាំងនោះរមែងគ្រប់សង្កត់ចិត្តនៃភិក្ខុណា តាំងនៅ ភិក្ខុនោះមិនអាចធ្វើកិច្ចរបស់សមណៈ ទើបត្រាស់ថា **វិវេកំ អនុរុទ្ធា ។បេ។ អញ្ញំ វា តតោ សន្តតរំ** ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ចំណែកខ្មៅរួចហើយ ឥឡូវនេះ ដើម្បីសម្តែងធម៌ចំណែកស ដោយន័យនោះ ទើបត្រាស់បទថា **វិវេកំ** ជាដើម ដូច្នេះទៀត គប្បីជ្រាបអត្ថនៃបទទាំងនោះ ដោយន័យដូចពោលហើយនោះឯង ។ បទថា **សង្ខាយ** គឺដឹងហើយ ។ បទ ថា **ឯកំ** គឺមួយ ។ បទថា **បដិសេវតិ** គឺរមែងសេពវត្ថុដែលគួរសេព ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។

[ ១៩៨ ] បទថា **ឧបបត្តីសុ ព្យាករោតិ** គឺព្យាករក្នុងភព ព្រម ដោយបដិសន្ធិចូរលើកទុក ។ ទ្រង់ព្យាករក្នុងភពដែលមិនបដិសន្ធិ ដូចម្តេច ។ កាលពោលថា បដិសន្ធិក្នុងភពថ្មី មិនមានដល់បុគ្គលដែលមិនទាន់មាន បដិសន្ធិ ឈ្មោះថា ទ្រង់ព្យាករក្នុងភពដែលកើត ។ បទថា **ជនកុហានត្ថំ** គឺ ដើម្បីឲ្យជនស្រប់ស្រែងក្នុងចិត្ត ។ បទថា **ជនលបនត្ថំ** គឺដើម្បីកៀរគរ មហាជន ។ បទថា **ឧ ឥតិ មំ ជនោ ជានាតុ** គឺមហាជននឹងដឹងយ៉ាងនេះ ។ អធិប្បាយថា ទ្រង់មិនព្យាករដោយហេតុនេះ កិត្តិសព្ទរបស់អញនឹងខ្ចរខ្ចាយ ឡើងក្នុងរវាងមហាជនយ៉ាងនេះ ។ បទថា **ឧឡារវេទា** គឺមានការត្រេកអរច្រើន ។

[ ១៩៩ ] បទថា **សោ ខោ បនស្ស អាយស្មា** គឺលោកនោះបរិនិព្វាន ហើយជាបុគ្គលដែលលោកតាំងនៅនេះបានឃើញហើយឬបានស្តាប់ហើយ ។ ក្នុងបទជាដើមថា **ឯវំ សីលោ** គប្បីជ្រាបសីលជាដើមលាយដោយលោកិយ និងលោកុត្តរ ។ ធម៌ជាចំណែកសមាធិ លោកបំណងយកថា **ធម្មៈ** ក្នុង បទនេះថា **ឯវំធម្មោ** ។ បទថា **ជាសុវិហារោ ហោតិ** គឺកាលបំពេញ ក្នុងបដិបទា ដែលភិក្ខុនោះបំពេញឲ្យបរិបូណ៌ហើយ ភិក្ខុធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល ជាអ្នកមានវិហារធម៌សប្បាយ ដោយវិហារធម៌ គឺផល សមាបត្តិ ។ កាលមិនអាចសម្រេចអរហត្ត និងកាលបំពេញបដិបទា រហូត បរិបូណ៌ ឈ្មោះថា ជាអ្នកមានវិហារធម៌សប្បាយខាងមុខ ។ គប្បីជ្រាបអត្ថ ក្នុងវារៈទាំងពួងដោយន័យនេះ ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថាទឡ្ហបានសូត្រទី ៨ ចប់**

# សុត្តន្តបិដក

## គោលិស្សានិសូត្រទី ៩

[ ២០៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានភិក្ខុមួយរូបឈ្មោះគោលិស្សានិ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមានមារយាទមិនរៀបរយ អង្គុយក្នុងកណ្តាលជំនុំសង្ឃដោយកិច្ចណាមួយ ។

[ ២០៤ ] លំដាប់នោះ ព្រះសារីបុត្តមានអាយុ ប្រារព្ធនូវគោលិស្សានិភិក្ខុ ហើយទើបពោលនឹងភិក្ខុទាំងឡាយថា ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុដែលសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែប្រកបដោយសេចក្តីគោរព សេចក្តីកោតក្រែងចំពោះពួកសព្រហ្មចារីទាំងឡាយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះពួកសព្រហ្មចារីហើយ ពួកជននឹងពោលតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ សមាទានអារញ្ញិកធុតង្គនៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ជាអ្នកមិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែង ចំពោះសព្រហ្មចារីទាំងឡាយ លោកមានអាយុនោះ នឹងមានពួកជនតិះដៀល ដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទី

ប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែប្រកបដោយសេចក្តីគោរព កោត ក្រែង ចំពោះសព្រហ្មចារីទាំងឡាយ ។

[ ២០៥ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវ អារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជា អ្នកឈ្លាស ក្នុងការអង្គុយថា អាត្មាអញនឹងមិនអង្គុយជ្រៀតបៀតភិក្ខុទាំង-ឡាយជាថេរៈផង មិនហាមឃាត់ភិក្ខុថ្មីទាំងឡាយដោយអាសនៈផង ។ ម្នាល លោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹង ទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃមិនឈ្លាសក្នុងការអង្គុយហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ សមាទានអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួន ក្នុងព្រៃម្នាក់ឯង លោកមាន អាយុនេះ មិនដឹងច្បាប់អភិសមាចារិកវត្តសោះ លោកមានអាយុនោះ នឹង មានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិក ធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរតែឈ្លាស ក្នុងការអង្គុយ ។

[ ២០៦ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវ អារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិន គួរចូលទៅកាន់ស្រុកឲ្យហួសវេលា មិនគួរត្រឡប់មកឲ្យទាល់ថ្ងៃ ម្នាលលោក មានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលទៅកាន់ទី ប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ នឹងចូលទៅកាន់ស្រុកឲ្យហួសវេលា

ត្រឡប់មកទាល់ថ្ងៃហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ សមាទានអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្វនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ចូលទៅកាន់ស្រុកឲ្យហួសវេលា ត្រឡប់មកវិញទាល់ថ្ងៃ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរចូលទៅកាន់ស្រុកឲ្យហួសវេលា មិនគួរត្រឡប់មកឲ្យទាល់ថ្ងៃឡើយ ។

[ ២០៧ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរដល់នូវការត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តឡើយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ដល់នូវការត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្វនក្នុងព្រៃម្នាក់ឯង ទាំងការត្រាច់ទៅក្នុងវេលាវិកាល ភិក្ខុនោះក៏បានធ្វើរឿយៗ នាំឲ្យសង្ឃលំបាកហៅរកភិក្ខុនោះមកកាន់ជំនុំសង្ឃ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃហើយ មិនគួរដល់នូវការត្រាច់ទៅក្នុងត្រកូល

ទាំងឡាយ ក្នុងវេលាមុនភត្តនិងក្រោយភត្តឡើយ ។

[ ២០៨ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃនៅក្នុងកណ្តាលជំនុំសង្ឃ មិនគួរមានចិត្តរាយមាយឃ្លេងឃ្លោងឡើយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ មានចិត្តរាយមាយឃ្លេងឃ្លោងហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯងមែន តែមានចិត្តរាយមាយឃ្លេងឃ្លោងធ្វើឲ្យរឿយៗ នាំឲ្យសង្ឃលំបាកហៅរកមកកាន់ជំនុំសង្ឃ លោកមានអាយុនោះ នឹងមានពួក ជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងទីប្រជុំសង្ឃ មិនគួរជាអ្នកមានចិត្តរាយមាយឃ្លេងឃ្លោងឡើយ ។

[ ២០៩ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ កុំជាអ្នកមានមាត់រឹង កុំជាអ្នកមានវាចាឡេះឡោះឡើយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកមានមាត់រឹង ពោលវាចាឡេះឡោះហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង

លោកមានអាយុនេះ ជាអ្នកមានមាត់រឹង ពោលវាចាឡេះឡោះ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ហើយកុំជាអ្នកមានមាត់រឹង កុំជាអ្នកមានវាចាឡេះឡោះឡើយ ។

[ ២១០ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកប្រដៅងាយ មានមនុស្សល្អជាមិត្រ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ ជាអ្នកប្រដៅក្រ មានមនុស្សអាក្រក់ជាមិត្រហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ជាអ្នកប្រដៅក្រ មានមនុស្សអាក្រក់ជាមិត្រ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវ អារញ្ញិកធុតង្គ កាលនឹងទៅកាន់ទីប្រជុំសង្ឃ នៅក្នុងកណ្តាលជំនុំសង្ឃ គួរជាអ្នកប្រដៅងាយ មានមនុស្សល្អជាមិត្រ ។

[ ២១១ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមិនមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយហើយ នឹងមានពួកជនតិះដៀលចំពោះ

ភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិក-ធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ជាអ្នកមានទ្វារមិនបានគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានទ្វារគ្រប់គ្រង ក្នុងឥន្ទ្រិយទាំងឡាយ ។

[ ២១២ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកដឹងប្រមាណក្នុងភោជន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមិនដឹងប្រមាណក្នុងភោជនហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ជាអ្នកមិនដឹងប្រមាណក្នុងភោជន លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកដឹងប្រមាណក្នុងភោជន ។

[ ២១៣ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រឭក ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ មិនប្រកបរឿយៗ នូវការភ្ញាក់រឭកហើយ នឹងមានពួកជនតិះដៀលចំពោះភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង លោកមានអាយុនេះ ជាអ្នកមិនប្រកបរឿយៗ នូវការភ្ញាក់រឭក

លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រកបរឿយៗ នូវការក្រាក់រឭក ។

[ ២១៤ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រារព្ធព្យាយាម ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកខ្ជិលច្រអូសហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកខ្ជិលច្រអូស លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកប្រារព្ធព្យាយាម ។

[ ២១៥ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកតាំងស្មារតីឲ្យមាំ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកភ្លេចស្មារតីហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វីលោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកភ្លេចស្មារតី លោកមានអាយុនោះ នឹងមានពួកជនតិះដៀល ដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកតាំងស្មារតីឲ្យមាំ ។

[ ២១៦ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានចិត្តខ្ជាប់ខ្ជួន ។ ម្នាលលោកមានអាយុទាំងឡាយ

បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកមានចិត្តមិនខ្វាប់ខ្ជួនហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកមានចិត្តមិនខ្វាប់ខ្ជួន លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានចិត្តខ្វាប់ខ្ជួន ។

[ ២១៧ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានប្រាជ្ញា ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ជាអ្នកគ្មានប្រាជ្ញាហើយ នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ជាអ្នកគ្មានប្រាជ្ញា លោកមានអាយុនោះ នឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គួរជាអ្នកមានប្រាជ្ញា ។

[ ២១៨ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្តីព្យាយាម ក្នុងអភិធម្ម និងអភិវិន័យ ។ ម្នាលលោកមានអាយុទាំងឡាយ ពួកជនអ្នកសួរប្រស្នាក្នុងអភិធម្ម និងអភិវិន័យចំពោះភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គង់មាន ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ត្រូវគេសួរប្រស្នាក្នុងអភិធម្ម និងអភិវិន័យ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា

ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ តាមអំពើចិត្តខ្លួន នៅក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះ ត្រូវគេសួរប្រស្នាក្នុងអភិធម្ម និងអភិវិន័យហើយឆ្លើយមិនរួច លោកមានអាយុនោះនឹងមានពួកជនតិះដៀលដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើសេចក្ដីព្យាយាមក្នុងអភិធម្មនិងអភិវិន័យ ។

[ ២១៩ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្ដីព្យាយាម ក្នុងវិមោក្ខជាអារុប្ប: ដែលហួសរូបសមាបត្តិទៅ ។ ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុជាអ្នកសមាទាននូវអារញ្ញិកធុតង្គ តែងមានគេសួរប្រស្នាក្នុងវិមោក្ខជាអារុប្ប: ដែលហួសរូប-សមាបត្តិទៅ ។ ម្នាលលោកមានអាយុទាំងឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ មានគេសួរប្រស្នាក្នុងវិមោក្ខជាអារុប្ប: ដែលហួសរូបសមាបត្តិទៅ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួនក្នុងព្រៃម្នាក់ឯង ព្រោះលោកមានអាយុនេះ មានគេសួរប្រស្នាក្នុងវិមោក្ខជាអារុប្ប: ដែលហួសរូបសមាបត្តិទៅ ហើយឆ្លើយមិនរួច លោកមានអាយុនោះនឹងមានពួកជនតិះដៀល ដូច្នេះឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីធ្វើសេចក្ដីព្យាយាមក្នុងវិមោក្ខជាអារុប្ប: ដែលហួសរូបសមាបត្តិទៅ ។

[ ២២០ ] ម្នាលលោកមានអាយុទាំងឡាយ ភិក្ខុអ្នកសមាទាននូវ

អារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើសេចក្តីព្យាយាម ក្នុងឧត្តរិមនុស្សធម៌ ។ ម្នាល
លោកមានអាយុទាំងឡាយ ពួកជនអ្នកសួរប្រស្នាក្នុងឧត្តរិមនុស្សធម៌ ចំពោះ
ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គង់មាន ។ ម្នាលលោកមានអាយុទាំង
ឡាយ បើភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ ត្រូវគេសួរប្រស្នាក្នុងឧត្តរិមនុស្ស
ធម៌ ហើយឆ្លើយមិនរួច នឹងមានពួកជនតិះដៀលភិក្ខុនោះថា ប្រយោជន៍អ្វី
លោកមានអាយុនេះ ជាអ្នកសមាទាននូវអារញ្ញិកធុតង្គ នៅតាមអំពើចិត្តខ្លួន
ក្នុងព្រៃតែម្នាក់ឯង ព្រោះលោកមានអាយុនេះបួសហើយដើម្បីប្រយោជន៍ណា
ក៏មិនដឹងប្រយោជន៍នោះ លោកមានអាយុនោះនឹងមានពួកជនតិះដៀល ដូច្នេះ
ឯង ព្រោះហេតុនោះ ភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ គប្បីជាអ្នកធ្វើ
សេចក្តីព្យាយាម ក្នុងឧត្តរិមនុស្សធម៌ ។

[ ២២១ ] កាលព្រះសារីបុត្ត ពោលយ៉ាងនេះហើយ ព្រះមហាមោគ្គ-
ល្លានមានអាយុ បានពោលពាក្យនេះ នឹងព្រះសារីបុត្តមានអាយុថា ម្នាល
អាវុសោសារីបុត្ត ចុះធម៌ទាំងនេះ គួរតែភិក្ខុអ្នកសមាទាននូវអារញ្ញិកធុតង្គ
ទើបសមាទានប្រព្រឹត្តបានឬ ឬក៏ភិក្ខុដែលនៅក្នុងស្រុក គួរសមាទានប្រព្រឹត្ត
បានដែរ ។ ម្នាលអាវុសោមោគ្គល្លាន ធម៌ទាំងនេះ សូម្បីភិក្ខុអ្នកសមាទាននូវ
អារញ្ញិកធុតង្គ ក៏គួរតែសមាទានប្រព្រឹត្តទៅហើយ នឹងចាំបាច់ពោលទៅថ្វីដល់
ភិក្ខុដែលនៅក្នុងស្រុក ។

ចប់ គោលិស្សានិសូត្រទី ៩

# អដ្ឋកថា

## គោលិស្សានិសូត្រ

[ ២០៣ ] គោលិស្សានិសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បទរសមាចារោ** គឺ ប្រព្រឹត្ត អាក្រក់ មានអាចារៈគ្រោតគ្រាត សម្ងំក្នុងបច្ច័យទាំងឡាយ ដូចព្រះមហាវក្ខិតត្ថេរ បានឮថា ឧបដ្ឋាកពោលនឹងព្រះថេរៈនោះ ដែលអង្គុយក្នុងត្រកូលឧបដ្ឋាកថា លោកម្ចាស់ ខ្ញុំប្រគេនចីវរដល់ព្រះថេរៈរូបនោះហើយ ។ ព្រះថេរៈពោលថា ញោមធ្វើល្អហើយ ដែលប្រគេនចីវរដល់ព្រះថេរៈអ្នកត្រិះរិះដល់ចីវរនោះ ។ ឧបដ្ឋាកពោលថា លោកម្ចាស់ ខ្ញុំនឹងប្រគេនចីវរដល់ លោកម្ចាស់ ។ ព្រះថេរៈពោលថា ល្អហើយ ញោមប្រគេនដល់ព្រះថេរៈ ដែលត្រិះរិះដល់ចីវរនោះ ។ ភិក្ខុបែបនេះ ឈ្មោះថា មានអាចារៈគ្រោតគ្រាត ។

[ ២០៤ ] បទថា **សប្បតិស្សេន** គឺមានភាពជាធំ ។ មិនគួរធ្វើខ្លួនឲ្យជាធំ ។ បទថា **សេរិវិហារេន** គឺដោយការនៅតាមពេញចិត្ត របស់ខ្លួន ដោយការនៅមិនមានអ្នកចាំជាស់តឿន ។

[ ២០៥ ] បទថា **នានុប្បវិស្សដ្ឋ** គឺមិនចូលទៅជិត ។ ភិក្ខុណាកាលព្រះមហាថេរៈ ២ រូប អង្គុយទាំងសងខាង មិនប្រាប់ព្រះថេរៈទាំងនោះ អង្គុយជ្រៀតបៀតដោយចីវរក្តី ដោយជង្គង់ក្តី ភិក្ខុនេះ ឈ្មោះថា ចូលទៅអង្គុយជ្រៀតបៀត ។ មួយវិញទៀត មិនធ្វើយ៉ាងនោះ កាលនៅជិតអាសនៈដែលគួរដល់ខ្លួន ព្រះថេរៈពោលថា អង្គុយចុះអ្នកមានអាយុ ដូច្នេះ ទើប

អង្គុយ ។ បើព្រះថេរៈមិនពោល គួរពោលសួរថា លោកម្ចាស់ ខ្ញុំអង្គុយបានឬ ដូច្នេះហើយ គួរអង្គុយ ។ តាំងអំពីពេលពោលសួរ បើព្រះថេរៈពោលថា អង្គុយចុះ ឬបើមិនពោល ក៏គួរអង្គុយបាន ។

ក្នុងបទថា **ន បដិពាហិស្សាមិ** មានអធិប្បាយថា ភិក្ខុណារំលងអាសនៈដែលដល់ខ្លួនហើយ អង្គុយប្រជែងត្រង់អាសនៈភិក្ខុថ្មី ភិក្ខុនេះឈ្មោះថា ឃាត់អាសនៈភិក្ខុថ្មី ។ កាលភិក្ខុនោះអង្គុយយ៉ាងនោះ ភិក្ខុថ្មីឈរពោលទោសថា ភិក្ខុនេះមិនឲ្យអញអង្គុយក្តី ឬដើររកអាសនៈក្តី ព្រោះដូច្នោះគប្បីអង្គុយលើអាសនៈដែលដល់ខ្លួននោះឯង យ៉ាងនេះឈ្មោះថា មិនហាមអាសនៈ ។ បទថា **អភិសមាចារិកម្បិ ធម្មំ** គឺធម៌ត្រឹមតែការបដិបត្តិអភិសមាចារិកវត្ត ។

[ ២០៦ ] បទថា **នាតិកាលេន** គឺមិនគួរចូលស្រុកអំពីព្រឹកពេក មិនគួរត្រឡប់ឲ្យយឺតពេក ។ គួរចូល និងចេញជាមួយពួកភិក្ខុ ។ ព្រោះកាលចូលទៅព្រឹកពេក ចេញទៅយឺតពេក ការបដិបត្តិក្នុងលានព្រះចេតិយ និងលានពោធិព្រឹក្សជាដើម រមែងបាត់បង់ ។ ភិក្ខុមិនស្គាល់កាលនោះ លុបមុខអំពីព្រលឹម រួចបោសសម្អុកពីងពាងក្នុងកាលទឹកសន្សើមធ្លាក់ ចូលស្រុកហើយ ស្វែងរកបបរអង្គុយពោលតិរច្ឆានកថាច្រើនប្រការ ខាងក្នុងស្រុកនោះឯង រហូតដល់ពេលបិណ្ឌបាត ហើយឆាន់អាហារ ចេញទៅក្នុងពេលរសៀលទៅដល់វត្តក្នុងវេលាខាងក្រោយការលាងជើងរបស់ភិក្ខុទាំងឡាយ ។

[ ២០៧ ] បទថា **ន បុរេភត្តំ បច្ឆាភត្តំ កុលេសុ ចារិត្តំ អាបជ្ជិតព្វំ**

គឺភិក្ខុទទួលនិមន្តន៍ព្រមដោយភោជន មិនលាភិក្ខុដែលមាននៅ ត្រាច់ទៅក្នុងត្រកូលក្នុងវេលាមុនភត្តក្តី ក្នុងវេលាក្រោយភត្តក្តី វៀរលែងតែមានសម័យត្រូវអាបត្តិបាចិត្តិយ ព្រោះហេតុនោះ ភិក្ខុអ្នករក្សាសិក្ខាបទនេះ មិនគួរត្រាច់ទៅ ក្នុងវេលាមុនភត្ត និងក្នុងវេលាក្រោយភត្ត ដែលលោកពោលទុកហើយ ក្នុងវិភង្គនៃសិក្ខាបទនោះ ។

[ ២០៨ ] បទថា **ឧទ្ធតោ ហោតិ ចបលោ** គឺជាអ្នកមានប្រក្រតីរាយមាយ និងប្រកបដោយភាពជាអ្នករពិស ដូចកូនក្មេង ដូចលោកពោលទុកថា ប្រដាប់ចីវរ ប្រដាប់បាត្រ ប្រដាប់សេនាសនៈ ឬតាក់តែង ប្រដាប់កាយស្អុយនេះ ។

[ ២១៧ ] បទថា **បញ្ញវតា ភវិតព្វំ** គឺកាលគួរធ្វើចីវរកម្មជាដើម គួរជាអ្នកប្រកបដោយឧបាយនៃបញ្ញា ។

[ ២១៨ ] បទថា **អភិធម្មេ អភិវិនយេ** គឺគួរធ្វើសេចក្តីព្យាយាមក្នុងអភិធម្មបិដក និងក្នុងវិនយបិដក ដោយបាលី និងដោយអដ្ឋកថា ។ មិនគួរភ្លាត់ចាកធម្មហទយវិភង្គ ព្រមដោយទុកមាតិកា និងតិកមាតិកាជាដើមក្នុងអភិធម្មដោយបរិច្ឆេទចុងក្រោយ ។ មិនគួរឃ្លាងឃ្លាត បាតិមោក្ខទាំង ២ ដែលលោកវិនិច្ឆ័យទុកល្អហើយ ព្រមគ្នានឹងការវិនិច្ឆ័យក្នុងប្រការគួរធ្វើ និងមិនគួរធ្វើក្នុងវិន័យ ។

[ ២១៩ ] បទថា **អារុប្បា** គឺលោកពោលដល់សមាបត្តិ ៨ ប្រការម្យ៉ាងទៀត កាលមិនអាចបំពេញសមាបត្តិទាំងនោះបានទាំងអស់ ក៏គួរបំពេញ

ក្នុងសមាបត្តិ ៧ ក្តី ៦ ក្តី ៥ ក្តី ដោយកំណត់បទចុងក្រោយ ប្រព្រឹត្តកាន់យកកម្មដ្ឋាន គឺបរិកម្មកសិណណាមួយធ្វើឲ្យស្ទាត់ ។ ប៉ុណ្ណេះក៏មិនគួរឃ្លាងឃ្លាត ។

[ ២២០ ] ដោយបទថា **ឧត្តរិមនុស្សធម្មេ** នេះ ព្រះសារីបុត្រសម្តែងលោកុត្តរធម៌ទាំងអស់ ព្រោះដូច្នោះ បុគ្គលជាព្រះអរហន្តគប្បីលះ ។ បុគ្គលដែលមិនទាន់សម្រេចអរហត្ត គួរតាំងនៅក្នុងអនាគាមិផល សកទាគាមិផល ឬសោតាបត្តិផល ។ ដោយបរិយាយចុងក្រោយ គួរប្រព្រឹត្តកាន់យកវិបស្សនាសុទ្ធតែម្យ៉ាង រហូតដល់ធ្វើឲ្យស្ទាត់ជំនាញនូវព្រះអរហត្ត ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ។

ព្រះសារីបុត្រញ៉ាំងគោលិស្សានិភិក្ខុ ឲ្យសម្រេចព្រះអរហត្តដោយលំដាប់តាំងអំពីអភិសមាចារិកវត្ត ដោយអំណាចវេនេយ្យបុគ្គល ។ ទេសនានេះចប់ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថាគោលិស្សានិសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## កីដាគិរិសូត្រទី ១០

[ ២២២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិកក្នុងកាសីជនបទ មួយអន្លើដោយភិក្ខុសង្ឃច្រើនរូប ។ គ្រា នោះឯង ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគវៀរចាកការបរិភោគភោជន ក្នុងវេលាយប់ ម្នាលភិក្ខុទាំងឡាយ កាលតថាគតបរិភោគវៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹង ច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរ បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ ហើយ គង់ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោក រហ័សរហួន កម្លាំងនិងការនៅសប្បាយ ពុំខាន ។ ពួកភិក្ខុទាំងនោះ ទទួល ស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ២២៣ ] គ្រានោះឯង ព្រះមានព្រះភាគ ស្តេចទៅកាន់ចារិកតាម លំដាប់ក្នុងកាសីជនបទ បានស្តេចទៅដល់និគមឈ្មោះកីដាគិរី របស់កាសី ជនបទ ។ មានសេចក្តីតំណាលថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងកីដាគិរិ និគម របស់កាសីជនបទនោះ ។ ជួនសម័យនោះឯង ភិក្ខុឈ្មោះអស្សជិនិង ឈ្មោះបុនព្វសុកៈ អ្នកនៅក្នុងកីដាគិរិនិគម ។ គ្រានោះឯង មានភិក្ខុច្រើន

រូប ចូលទៅរកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ បាន ពោលពាក្យនេះ នឹងអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុថា ម្នាលលោកមានអាយុ ទាំងឡាយ ព្រះមានព្រះភាគទ្រង់សោយ វៀរចាកការសោយភោជនក្នុងវេលា យប់ ម្នាលលោកមានអាយុទាំងឡាយ ទាំងភិក្ខុសង្ឃ ក៏បរិភោគ វៀរចាក ការបរិភោគភោជនក្នុងវេលាយប់ដែរ កាលពួកភិក្ខុបរិភោគ វៀរចាកការ បរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោក មានអាយុទាំងឡាយ លោកទាំងឡាយ ចូរបរិភោគ វៀរចាកការបរិភោគ ភោជន ក្នុងវេលាយប់ចុះ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោក ទាំងឡាយ បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់ នឹងបានដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោក រហ័សរហួន កម្លាំង និងការនៅសប្បាយពុំខាន ។ កាលបើភិក្ខុទាំងឡាយ ពោលយ៉ាងនេះហើយ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ក៏ឆ្លើយតបទៅនឹងភិក្ខុ ទាំងនោះ យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ពួកយើងតែង បរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាល ពួកយើងទាំងនោះ កាលបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មាន ជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ពួកយើងទាំង នោះ នឹងលះបង់អានិសង្សដែលត្រូវបានក្នុងបច្ចុប្បន្ន ហើយស្ទុះតាមរក

អានិសង្សក្នុងអនាគតដូចម្តេចកើត ពួកយើងនឹងនៅតែបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលដដែល ។

[ ២២៤ ] ពួកភិក្ខុទាំងនោះ មិនអាចធ្វើអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុឲ្យយល់បានក្នុងកាលណាហើយ ទើបភិក្ខុទាំងនោះចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយនៅក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយើងខ្ញុំព្រះអង្គដែលមានក្នុងទីនេះ បានចូលទៅរកអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុថា ម្នាលលោកមានអាយុទាំងឡាយ ព្រះមានព្រះភាគទ្រង់សោយ វៀរចាកការសោយភោជនក្នុងវេលាយប់ ទាំងភិក្ខុសង្ឃ ក៏បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ដែរ ម្នាលអាវុសោទាំងឡាយ កាលពួកភិក្ខុបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោកមានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរមក ចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោកទាំង-ឡាយបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ គង់នឹងបានដឹងច្បាស់ នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ បពិត្រព្រះអង្គដ៏ចម្រើន កាលពួកខ្ញុំព្រះអង្គពោល

យ៉ាងនេះហើយ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ក៏ឆ្លើយតបមកនឹងពួកខ្ញុំព្រះអង្គ យ៉ាងនេះថា ម្នាលលោកមានអាយុទាំងឡាយ ពួកយើងតែងបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាល ពួកយើងនោះ កាលបរិភោគភោជន ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃដែលជាវេលាវិកាល ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ពួកយើងទាំងនោះ នឹងលះបង់អានិសង្សដែលត្រូវបានក្នុងបច្ចុប្បន្ន ហើយស្ទុះតាមរកអានិសង្សដែលត្រូវបានក្នុងអនាគតទៅវិញ ដូចម្ដេចកើត ពួកយើងនឹងនៅតែបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃដែលជាវេលាវិកាលដដែល បពិត្រព្រះអង្គដ៏ចម្រើន កាលណាពួកខ្ញុំព្រះអង្គ មិនអាចធ្វើអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុឲ្យយល់បានហើយ ទើបពួកខ្ញុំព្រះអង្គមកសូមក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគ ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុ ១ រូបមកប្រាប់ថា ម្នាលភិក្ខុ អ្នកចូរមក ចូរទៅហៅអស្សជិភិក្ខុនិងបុនព្វសុកភិក្ខុតាមពាក្យតថាគតថា ព្រះសាស្ដា ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ ភិក្ខុនោះទទួល ព្រះបន្ទូលព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយចូលទៅរកអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ លុះចូលទៅដល់ហើយ ក៏បាននិយាយនឹងអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុយ៉ាងនេះថា ព្រះសាស្ដា ទ្រង់ត្រាស់ហៅលោកមានអាយុទាំងឡាយ ។ អស្សជិភិក្ខុនិងបុនព្វសុកភិក្ខុ ទទួលពាក្យភិក្ខុនោះថា ករុណាលោកមានអាយុ ហើយចូលទៅគាល់ព្រះមានព្រះភាគ

លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកភិក្ខុច្រើនរូប ចូលទៅរកអ្នកទាំងឡាយ ហើយបាននិយាយថា ម្នាលលោកមានអាយុទាំងឡាយ ព្រះមានព្រះភាគទ្រង់សោយ វៀរចាកការសោយភោជនក្នុងវេលាយប់ ទាំងភិក្ខុសង្ឃក៏បរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ដែរ ម្នាលលោកមានអាយុទាំងឡាយ កាលពួកភិក្ខុបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ហើយ ក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលលោកមានអាយុទាំងឡាយ លោកទាំងឡាយចូរមក ចូរបរិភោគ វៀរចាកការបរិភោគភោជនក្នុងវេលាយប់ចេញ ម្នាលលោកមានអាយុទាំងឡាយ កាលបើលោកទាំងឡាយបរិភោគ វៀរចាកការបរិភោគ ភោជនក្នុងវេលាយប់ហើយ គង់នឹងបានដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន កម្លាំង និងការនៅសប្បាយ ម្នាលភិក្ខុទាំងឡាយ បានឮថា កាលដែលពួកភិក្ខុពោលយ៉ាងនេះហើយ អ្នកទាំងឡាយបានឆ្លើយតបទៅនឹងពួកភិក្ខុទាំងនោះយ៉ាងនេះវិញថា ម្នាលលោកមានអាយុទាំងឡាយ ពួកយើងតែងបរិភោគក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃដែលជាវេលាវិកាល យើងទាំងនោះកាលបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាល ហើយក៏ដឹងច្បាស់នូវភាពជាអ្នកមានអាពាធតិច មានជំងឺតិច ការក្រោករហ័សរហួន

កម្លាំង និងការនៅសប្បាយ យើងទាំងនោះនឹងលះបង់អានិសង្សដែលត្រូវបានក្នុង បច្ចុប្បន្ន ហើយស្ទុះតាមរកអានិសង្សដែលត្រូវបានក្នុងអនាគតទៅវិញ ដូចម្តេច កើត ពួកយើងនឹងនៅតែបរិភោគ ក្នុងវេលាល្ងាច វេលាព្រឹក និងវេលាថ្ងៃ ដែលជាវេលាវិកាលដដែល យ៉ាងនេះមែនឬ ។ ព្រះករុណាព្រះអង្គ មែន ។

[ ២២៥ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ យល់ធម៌ ដែល តថាគតសំដែងហើយ យ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលវេទនា ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ អកុសលធម៌ទាំងឡាយរបស់ គេនោះ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ រមែងចម្រើនឡើង ដែរ ឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនយល់ទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ក្រែងយល់ធម៌ដែលតថាគតសំដែងហើយ យ៉ាងនេះថា បុរស បុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលសុខវេទនាបែបនេះហើយ អកុ-សលធម៌ទាំងឡាយ ចម្រើនឡើងកុសលធម៌ទាំងឡាយ សាបសូន្យទៅ មួយ ទៀត បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលសុខវេទនា បែបនេះ ហើយ អកុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ កុសល ធម៌ទាំងឡាយ រមែងចម្រើនឡើង បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលទុក្ខ-វេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំង-ឡាយ តែងសាបសូន្យទៅ មួយទៀត បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ

កាលទទួលអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែង ចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ មួយវិញទៀត បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង ដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំយល់ ។

[ ២២៦ ] ម្នាលភិក្ខុទាំងឡាយ ប្រពៃហើយ ម្នាលភិក្ខុទាំងឡាយមួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយក្នុងសាសនានេះ កាលទទួលសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយ ចូរលះបង់នូវសុខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុបែបនុ៎ះ ដែលមានដល់តថាគតឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនដែលមានទេ ។ ម្នាលភិក្ខុទាំងឡាយតែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរលះបង់នូវសុខវេទនាបែបនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ

មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយ ចូរសម្រេចនៅដោយសុខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះកាលទទួលនូវសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយតែងចម្រើនឡើង ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយសុខវេទនាបែបនេះចុះ ។

[ ២២៧ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌ តែងចម្រើនឡើង កុសលធម៌ តែងសាបសូន្យទៅ កាលបើតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយចូរលះទុក្ខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុ

ទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់ទុក្ខវេទនា បែបនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវ ដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយ ចូរសម្រេចនៅដោយទុក្ខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវ ដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវទុក្ខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ព្រោះហេតុណា ព្រោះហេតុនោះបានជាតថាគតពោលថាអ្នកទាំងឡាយចូរសម្រេចនៅ ដោយទុក្ខវេទនាបែបនេះចុះ ។

[ ២២៨ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង

មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវ ដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយ ចូរលះបង់នូវអទុក្ខមសុខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។ ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវ ដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយ ចូរលះបង់នូវអទុក្ខមសុខវេទនាបែបនេះចេញ ម្នាលភិក្ខុទាំងឡាយមួយទៀត ហេតុនុ៎ះ តថាគតមិនធ្លាប់ដឹង មិនធ្លាប់ឃើញ មិនធ្លាប់យល់ មិនធ្លាប់ធ្វើឲ្យជាក់ច្បាស់ មិនធ្លាប់ពាល់ត្រូវ ដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង កាលតថាគតមិនដឹងយ៉ាងនេះទេ ហើយពោលថា អ្នកទាំងឡាយ ចូរសម្រេចនៅដោយអទុក្ខមសុខវេទនាបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះ សមគួរដល់តថាគតដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនសមគួរទេ ។

ម្នាលភិក្ខុទាំងឡាយ តែហេតុនុ៎ះ តថាគតធ្លាប់ដឹង ធ្លាប់ឃើញ ធ្លាប់យល់ ធ្លាប់ធ្វើឲ្យជាក់ច្បាស់ ធ្លាប់ពាល់ត្រូវដោយប្រាជ្ញាថា បុរសបុគ្គលពួកមួយ ក្នុងសាសនានេះ កាលទទួលនូវអទុក្ខមសុខវេទនាបែបនេះ អកុសលធម៌ទាំង-ឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ព្រោះហេតុណា ព្រោះហេតុនោះ ទើបតថាគតពោលថា អ្នកទាំងឡាយចូរសម្រេចនៅ ដោយអទុក្ខមសុខវេទនាបែបនេះចុះ ។

[ ២២៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោលថា ភិក្ខុទាំងអស់ត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ដូច្នេះក៏ទេ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតនឹងបានពោលថា ភិក្ខុទាំងអស់ មិនត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ដូច្នេះក៏ទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ មានកិច្ចដែលគួរធ្វើបានធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់រលីងហើយ ជាអ្នកផុតស្រឡះដោយប្រពៃហើយ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពួកភិក្ខុមានសភាពដូច្នោះ មិនបាច់ធ្វើកិច្ច ដោយសេចក្តីមិនប្រមាទឡើយ ដំណើរនោះព្រោះហេតុអ្វី ព្រោះថាភិក្ខុទាំងឡាយនោះ បានធ្វើកិច្ចរួចហើយដោយសេចក្តីមិនប្រមាទ ពួកភិក្ខុជាអរហន្តខីណាស្រព នោះមិនគួរប្រមាទទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា ជាសេក្ខបុគ្គល មិនទាន់បានដល់អរហត្តផល កំពុងប្រាថ្នានូវធម៌ដ៏ប្រសើរជាទីក្សេមចាកយោគៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ពួកភិក្ខុមានសភាព

ដូច្នោះ ទើបត្រូវធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុទាំងនេះ សេពសេនាសនៈដ៏សមគួរ សេពគប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវលោកុត្តរធម៌នោះដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុទាំងឡាយនេះហើយ ទើបពោលថា ពួកភិក្ខុទាំងនោះ ត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទ ។

[ ២៣០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៧ ពួកនេះ តែងមានប្រាកដក្នុងលោក បុគ្គល ៧ ពួក ដូចម្តេចខ្លះ គឺ ឧភតោភាគវិមុត្តបុគ្គល ១ បញ្ញាវិមុត្តបុគ្គល ១ កាយសក្ខីបុគ្គល ១ ទិដ្ឋិប្បត្តបុគ្គល ១ សទ្ធាវិមុត្តបុគ្គល ១ ធម្មានុសារីបុគ្គល ១ សទ្ធានុសារីបុគ្គល ១ ។

[ ២៣១ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះឧភតោភាគវិមុត្តៈនោះតើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ ពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយផង បានឃើញច្បាស់ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាផង អាសវៈទាំងឡាយរបស់បុគ្គលនោះ អស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ឧភតោ-ភាគវិមុត្តបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង មិនបាច់

ធ្វើកិច្ចដោយសេចក្ដីមិនប្រមាទឡើយ ដំណើរនោះព្រោះហេតុអ្វី ព្រោះថាភិក្ខុនោះបានធ្វើកិច្ចនោះរួចហើយ ដោយសេចក្ដីមិនប្រមាទ ភិក្ខុនោះ មិនគួរប្រមាទទៀតឡើយ ។

[ ២៣២ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះបញ្ញាវិមុត្តៈនោះ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ តែបានឃើញច្បាស់ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាផង អាសវៈទាំងឡាយរបស់បុគ្គលនោះ ក៏អស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថាបញ្ញាវិមុត្តបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯងមិនបាច់ធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀតឡើយ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ភិក្ខុនោះបានធ្វើកិច្ចនោះ ដោយសេចក្ដីមិនប្រមាទរួចហើយ ភិក្ខុនោះមិនគួរប្រមាទទៀតទេ ។

[ ២៣៣ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះកាយសក្ខីនោះ តើដូចម្ដេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ បានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយផង បានឃើញច្បាស់ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាផង អាសវៈទាំងឡាយពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅផង ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា កាយសក្ខីបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង ទើបត្រូវធ្វើកិច្ច ដោយសេចក្ដីមិនប្រមាទទៀត ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា

ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈ ដ៏សមគួរ សេពគប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ ទើបបានពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀត ។

[ ២៣៤ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះទិដ្ឋិប្បត្តៈ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ គ្រាន់តែបានឃើញ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាប៉ុណ្ណោះហើយ អាសវៈទាំងឡាយពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅ ទាំងពួកធម៌ដែលតថាគតសម្តែងហើយ ក៏បុគ្គលនោះ បានយល់ច្បាស់ដោយប្រាជ្ញា បានប្រព្រឹត្តត្រឹមត្រូវ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ទិដ្ឋិប្បត្តបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង ត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថាត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់

លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ បានជាពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ។

[ ២៣៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលឈ្មោះសទ្ធាវិមុត្តៈ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូប ដោយកាយទេ គ្រាន់តែឃើញ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាប៉ុណ្ណោះហើយ អាសវៈទាំងឡាយពួកខ្លះរបស់បុគ្គលនោះក៏អស់ទៅ ទាំងសទ្ធាក៏បុគ្គលនោះតាំងមាំ មានឫសគល់ប្រតិស្ឋានខ្ជាប់ខ្ជួន ក្នុងព្រះតថាគត ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា សទ្ធាវិមុត្តៈ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង ត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ កុលបុត្តទាំងឡាយដែលចេញចាកផ្ទះចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផល នៃសេចក្តីមិនប្រមាទនេះឯង

របស់ភិក្ខុនេះច្បាស់ហើយ បានជាពោលថាភិក្ខុនោះត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ។

[ ២៣៦ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះថាធម្មានុសារី តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូបដោយកាយទេ គ្រាន់តែឃើញ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាប៉ុណ្ណោះហើយ អាសវៈទាំងឡាយពួកខ្លះ នៃបុគ្គលនោះក៏អស់ទៅ ទាំងពួកធម៌ដែលព្រះតថាគត សម្តែងហើយ ក៏គួរដល់កិរិយាសម្លឹងមើលដោយប្រាជ្ញារបស់បុគ្គលនោះ ព្រមទាំងបុគ្គលនោះមានធម៌នេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា ធម្មានុសារី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង ត្រូវតែធ្វើកិច្ចដោយ សេចក្តីមិនប្រមាទទៀត ដំណើរនោះព្រោះហេតុអ្វី ព្រោះថាត្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់នូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ ពួកកុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញាខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ បានជាតថាគតពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ។

[ ២៣៧ ] ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលឈ្មោះថាសទ្ធានុសារី តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងសាសនានេះ មិនបានពាល់ត្រូវនូវវិមោក្ខទាំងឡាយដ៏ល្អិត មិនមានរូប ព្រោះកន្លងផុតរូប ដោយកាយទេ គ្រាន់តែឃើញ ( នូវអរិយសច្ចធម៌ ) ដោយប្រាជ្ញាប៉ុណ្ណោះ ទាំងអាសវៈទាំងឡាយពួកខ្លះនៃបុគ្គលនោះក៏អស់ទៅ បុគ្គលនោះមានត្រឹមតែសេចក្តីជឿនិងសេចក្តីស្រឡាញ់ ក្នុងព្រះតថាគត ព្រមទាំងមានធម៌ទាំងឡាយនេះ គឺសទ្ធិន្ទ្រិយ វីរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយ ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា សទ្ធានុសារី ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះឯង ត្រូវតែធ្វើកិច្ច ដោយសេចក្តីមិនប្រមាទទៀត ដំណើរនោះព្រោះហេតុអ្វី ព្រោះថា គ្រាតែលោកមានអាយុនេះ សេពនូវសេនាសនៈដ៏សមគួរ គប់រកនូវកល្យាណមិត្ត ទូន្មាននូវឥន្ទ្រិយទាំងឡាយ ពួកកុលបុត្រចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់លោកុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយធម៌ ដោយប្រាជ្ញា ខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាឃើញនូវផលនៃសេចក្តីមិនប្រមាទនេះឯង របស់ភិក្ខុនេះច្បាស់ហើយ បានជាពោលថា ភិក្ខុនោះត្រូវតែធ្វើកិច្ចដោយសេចក្តីមិនប្រមាទទៀត ។

[ ២៣៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតមិនពោលនូវសេចក្តីត្រេកអរចំពោះអរហត្តផល ថាជាធម៌ខាងដើមទេ ម្នាលភិក្ខុទាំងឡាយ ព្រោះថាសេចក្តី

ត្រេកអរចំពោះអរហត្តផល តែងមានការសិក្សាដោយលំដាប់ មានការធ្វើដោយលំដាប់ មានការប្រតិបត្តិដោយលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីត្រេក-អរចំពោះអរហត្តផល មានការសិក្សាដោយលំដាប់ មានការធ្វើដោយលំដាប់ មានការប្រតិបត្តិដោយលំដាប់ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រក្នុងសាសនានេះ មានសទ្ធាទើបចូលទៅរក កាលបើចូលទៅរកហើយ ទើបចូលទៅអង្គុយជិត លុះចូលទៅអង្គុយជិតហើយ ទើបផ្ទៀងនូវសោតប្បសាទ លុះផ្ទៀងនូវសោតប្បសាទហើយ ទើបស្តាប់ធម៌ លុះស្តាប់ធម៌ហើយ ទើបចងចាំធម៌ ( នោះ ) កាលបើចងចាំធម៌ ( នោះ ) ហើយ ទើបពិចារណារកសេចក្តី លុះពិចារណារកសេចក្តីនៃធម៌នោះហើយ ធម៌ទាំងឡាយតែងគួរដល់កិរិយាលៃលកមើល កាលបើមានការលៃលកមើលហើយ ឆន្ទៈក៏កើតឡើងបុគ្គលនោះលុះមានឆន្ទៈកើតហើយ ទើបព្យាយាម លុះព្យាយាមហើយ រមែងស្ទង់មើល លុះស្ទង់មើលហើយ រមែងតម្កល់ទុក មានចិត្តបញ្ជូនទៅ ( កាន់ព្រះនិព្វាន ) ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈ ដោយនាមកាយ ទាំងបានចាក់ធ្លុះឃើញច្បាស់នូវបរមសច្ចៈនោះ ដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ បើសទ្ធានោះមិនមានហើយ ម្នាលភិក្ខុទាំងឡាយ ការចូលទៅរកនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការចូលទៅអង្គុយជិតនោះក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការផ្ទៀងចុះនូវសោតប្បសាទនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការស្តាប់ធម៌នោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការចងចាំធម៌នោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ការពិចារណាសេចក្តីនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ

ការសម្រឹងនូវធម៌នោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ ឆន្ទៈនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីព្យាយាមនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ទង់មើលនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ សេចក្តីតម្កល់ទុកនោះ ក៏មិនមាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមុខតែនឹងដល់នូវវិបត្តិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមុខតែនឹងបដិបត្តិខុសពុំខាន ម្នាលភិក្ខុទាំងឡាយ មោឃបុរសអម្បាលនេះ នឹងឃ្លាតចាកធម្មវិន័យនេះ ឆ្ងាយអម្បាលម៉ានទៅ ។

[ ២៣៩ ] ម្នាលភិក្ខុទាំងឡាយ ការព្យាករណ៍នូវសច្ចៈទាំង ៤ ពួកវិញ្ញូបុរសគួរដឹងច្បាស់នូវសេចក្តីនៃសច្ចៈទាំង ៤ ណា ដែលតថាគតបានសម្តែងហើយ មិនយូរប៉ុន្មានឡើយ តថាគតនឹងសម្តែងប្រាប់ដល់អ្នកទាំង-ឡាយ ៗ នឹងបានដឹងច្បាស់នូវសច្ចៈនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងឡាយណាខ្លះ ពួកជនទាំងឡាយណាខ្លះ ដែលជាអ្នកគួរដឹងនូវធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ សាស្តាណាជាអ្នកជូន់ដោយអាមិស ជាអ្នកមានអាមិសជាមត៌ក ជាអ្នកចំពាក់ដោយអាមិសទាំងឡាយហើយ គុណសម្បត្តិមានសភាពយ៉ាងនេះ ឥតមានចម្រើនដល់សាស្តានោះឡើយ ថាបើហេតុយ៉ាងនេះ មានដល់យើងទាំងឡាយក្នុងកាលណាហើយ យើងទាំងឡាយ ក៏នឹងធ្វើហេតុនោះក្នុងកាលនោះ បើហេតុយ៉ាងនេះ មិនមានដល់យើងទាំងឡាយ យើងទាំងឡាយក៏មិនគប្បីធ្វើនូវហេតុនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនជាប់ចំពាក់ដោយអាមិសទាំងឡាយ ដោយប្រការទាំងពួងមែនឬ ម្នាលភិក្ខុទាំងឡាយ កាលសាវកជាអ្នកមានសទ្ធាកាន់តាមហើយ ប្រព្រឹត្តក្នុងសាសនា

នៃព្រះសាស្តា សភាវៈនេះតែងមានថា ព្រះមានព្រះភាគ ជាសាស្តា អាត្មាអញជាសាវក ព្រះមានព្រះភាគតែងទ្រង់ជ្រាប ( នូវអានិសង្សក្នុងការបរិភោគតែម្តង ) អាត្មាអញមិនបានដឹងឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលសាវកមានសទ្ធា កាន់តាមហើយប្រព្រឹត្តក្នុងសាសនានៃព្រះសាស្តា សាសនារបស់ព្រះសាស្តានឹងដុះដាល មានឱជៈទៅបាន ។ ម្នាលភិក្ខុទាំងឡាយ កាលសាវកជាអ្នកមានសទ្ធា កាន់តាមហើយប្រព្រឹត្តក្នុងសាសនា របស់ព្រះសាស្តា សភាវៈនេះតែងមានថា សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ កិច្ចណាដែលបុគ្គលត្រូវបាន ដោយកម្លាំងរបស់បុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស បើអាត្មាអញមិនទាន់សម្រេចកិច្ចនោះទេ មិនបន្ធូរបន្ថយព្យាយាមឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលសាវកមានសទ្ធា កាន់តាមហើយប្រព្រឹត្តក្នុងសាសនារបស់ព្រះសាស្តា បណ្តាផលទាំងពីរ ផលណាមួយ តែងបានសម្រេចក្នុងបច្ចុប្បន្នពុំខាន គឺនឹងបានសម្រេចអរហត្តផល ឬបើនៅមានឧបាទានក្ខន្ធសេសសល់ ក៏គង់បានជា អនាគាមិបុគ្គលពុំខានឡើយ ។ លុះព្រះមានព្រះភាគបានត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានសេចក្តីពេញចិត្តត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ កីដាគិរិសូត្រ ទី ១០

ចប់ ភិក្ខុវគ្គទី ២

## បញ្ជីរឿងនៃវគ្គនោះគឺ

ចូឡរាហុលោវាទសូត្រ ១ មហារាហុលោវាទសូត្រ ១
ចូឡមាលុង្ក្យោវាទសូត្រ ១ មហាមាលុង្ក្យោវាទសូត្រ ១
ភទ្ទាលិសូត្រ ១ លដុកិកោបមសូត្រ ១ ចាតុមសូត្រ ១
នឡកបានសូត្រ ១ គោលិស្សានិសូត្រ ១ កីដាគិរិសូត្រ ១ ។

( ចប់ ) វរវគ្គទី ២ ដែលមិនមានវគ្គដទៃស្មើ

# អដ្ឋកថា

## កីដាគិរិសូត្រ

[ ២២២ ] កីដាគិរិសូត្រ មានពាក្យផ្ដើមថា **ឯកំ សមយំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **កាសីសុ** គឺក្នុងជនបទមានឈ្មោះយ៉ាងនេះ ។ ក្នុងបទថា **ឯថ តុម្ហេបិ ភិក្ខវេ** នេះ មានសេចក្ដីដូចតទៅនេះ សូម្បីពួកអ្នកឃើញអានិសង្ស ៥ យ៉ាងនេះ ក៏ចូរឆាន់អាហារ វៀរការឆាន់ក្នុងរាត្រីចេញ ។ ដោយហេតុនេះ ព្រះមានព្រះភាគ ទ្រង់មិនបានឲ្យវៀរការឆាន់ទាំង ២ យ៉ាងនេះ គឺការឆាន់ក្នុងវេលាវិកាលពេលយប់ ១ ការឆាន់ក្នុងវេលាវិកាល ពេលថ្ងៃ ១ ក្នុងគ្រាតែមួយ ។ ក្នុងសម័យមួយ ទ្រង់ឲ្យវៀរការឆាន់ក្នុងពេលវិកាលក្នុងពេលថ្ងៃចេញប៉ុណ្ណោះ ។ កាលវេលាកន្លងទៅ ទ្រង់ឲ្យវៀរការឆាន់ក្នុងវេលាវិកាលពេលយប់ចេញ ទើបត្រាស់យ៉ាងនេះ ។ ព្រោះហេតុអ្វី ព្រោះការឆាន់ទាំង ២ ដងនេះ ជាការសន្សំ វដ្ដនក្នុងវដ្ដៈ មិនបានស្មុះចេញទៅបាន ដូចទឹកហូរចុះកាន់ស្ទឹង កុលបុត្រល្អិតល្អន់ ចម្រើនព្រោះបរិភោគអាហារល្អ ក្នុងផ្ទះដែលស្ងៀមស្ងាត់ វៀរការបរិភោគ ២ ដង ក្នុងគ្រាជាមួយគ្នាប៉ុណ្ណោះ រមែងលំបាក ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់មិនបានឲ្យវៀរក្នុងគ្រាជាមួយគ្នា ។ ទ្រង់ឲ្យវៀរការបរិភោគក្នុងវេលាវិកាលនាពេលថ្ងៃក្នុងភទ្ទាលិសូត្រ ក្នុងសូត្រនេះទ្រង់ឲ្យវៀរការបរិភោគក្នុងវេលាវិកាល ក្នុងពេលយប់ ។ កាលឲ្យលះ ទ្រង់គំរាម ឬទ្រង់សង្កត់សង្កិន ។ ព្រះអង្គទ្រង់សម្ដែងអានិសង្សយ៉ាងនេះថា ពួកអ្នកនឹងដឹងគុណ គឺភាពជាអ្នកមាន

អាពាធតិច ព្រោះលះការបរិភោគទាំងនោះជាបច្ច័យ ហើយទើបទ្រង់ឲ្យវៀរចេញ ។

[ ២២៣ ] បទថា **កីដាគិរិ** ជាឈ្មោះរបស់និគមនោះ ។ បទថា **អស្សជិបុនព្វសុកា** គឺអស្សជិភិក្ខុ និងបុនព្វសុកភិក្ខុ ក្នុងបណ្ដាឆព្វគ្គិយភិក្ខុ ៦ រូប លោកទាំង ២ ជាគណាចារ្យ ។ ជនទាំង ៦ គឺបណ្ឌុក ១ លោហិតក ១ មេត្តិយ ១ ភុម្មជក ១ អស្សជិ ១ បុនព្វសុក ១ ឈ្មោះថា ឆព្វគ្គិយ ។ ក្នុងឆព្វគ្គិយទាំងនោះ បណ្ឌុក និងលោហិតកនាំបរិវាររបស់ខ្លួនទៅនៅ នាក្រុងសាវត្ថី មេត្តិយ និងភុម្មជក ទៅនៅនាក្រុងរាជគ្រឹះ ។ ២ អង្គទៀតជាចៅអាវាសក្នុងកីដាគិរីនិគម ។ បទថា **អាវាសិកា** គឺនៅប្រចាំ ។ លោកទាំង ២ នៅប្រចាំ សាងសេនាសនៈដែលមិនទាន់បានសាង ជួសជុលសេនាសនៈដែលទ្រុឌទ្រោម ជាអ្នកមានឥស្សរៈក្នុងការធ្វើ ។ បទថា **កាលិកំ** គឺអានិសង្សដែលគប្បីដល់ក្នុងអនាគតកាល ។

[ ២២៦ ] សួរថា ព្រះមានព្រះភាគទ្រង់សម្ដែងដល់អ្វី ក្នុងបទនេះថា **មយា ចេតំ ភិក្ខវេ** ឆ្លើយថា ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងអត្ថនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុឆាន់ ៣ ដងមួយថ្ងៃ ហើយញ៉ាំងសុខវេទនាឲ្យកើត ឈ្មោះថា ជាអ្នកធ្វើកិច្ចក្នុងសាសនានេះក៏ទេ ដូច្នេះ ទើបប្រារព្ធទេសនានេះ ។ ម្យ៉ាងទៀត បទថា **ឯវរូបំ សុខំ វេទនំ បជហថ** នេះ ព្រះមានព្រះភាគត្រាស់ ដោយអំណាចសោមនស្សដែលអាស្រ័យកាមគុណ ។ បទថា **ឧបសម្បជ្ជ វិហរថ** ពួកអ្នកចូរដល់សុខវេទនាបែបនេះចុះ នេះទ្រង់ត្រាស់ ដោយអំណាច នៃសោមនស្ស ដែលអាស្រ័យនេក្ខម្មៈ ។ គប្បីជ្រាប

ដោយអំណាចនៃ ទោមនស្ស និងឧបេក្ខាអាស្រ័យនេក្ខម្មៈ ក្នុងវារៈ ២ ដទៃអំពីនេះយ៉ាងនេះ ។

[ ២២៩ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់វេទនាដែលគួរសេព និងមិនគួរសេពយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីសម្តែងដល់កិច្ចដែលភិក្ខុ គួរធ្វើ និងមិនគួរធ្វើ ដោយការមិនប្រមាទ ទើបត្រាស់បទថា **នាហំ ភិក្ខវេ សព្វេសំ** ជាដើម ។ បទថា **កតំ តេសំ អប្បមាទេន** ព្រោះភិក្ខុទាំងនោះបានធ្វើកិច្ចសម្រេចហើយ ដោយការមិនប្រមាទ គឺកិច្ចណាដែលភិក្ខុទាំងនោះគប្បីធ្វើ ដោយការមិនប្រមាទ កិច្ចនោះក៏បានធ្វើស្រេចហើយ ។ បទថា **អនុលោមិកានិ** សេចក្តីថា សេនាសនៈដែលសមគួរដល់ការបដិបត្តិ មានកម្មដ្ឋានជាទីសប្បាយ ។ ដែលបុគ្គលនៅក្នុងសេនាសនៈអាចសម្រេច មគ្គផលបាន ។ បទថា **ឥន្ទ្រិយានិ សមន្នានយមានា** គឺធ្វើសទ្ធិន្ទ្រិយជាដើមឲ្យស្មើ ។

[ ២៣០-២៣៧ ] សួរថា ព្រះមានព្រះភាគ ទ្រង់សម្តែងដល់អ្វីក្នុងបទថា **សត្តិមេ ភិក្ខវេ បុគ្គលា** ឆ្លើយថា ទ្រង់សម្តែងសេចក្តីនេះថា បុគ្គលមាន ៧ ពួកនេះ គឺបុគ្គលដែលមិនមានកិច្ចដែលគួរធ្វើ ដោយការមិនប្រមាទ មាន ២ ពួក ។ បុគ្គលដែលមានកិច្ចគួរធ្វើ ដោយការប្រមាទ មាន ៥ ពួក ។ ក្នុងបទទាំងនោះ បទថា **ឧភតោភាគវិមុត្តោ** គឺបុគ្គលរួចផុតដោយចំណែកទាំង ២ ។ ផុតចាករូបកាយ ដោយអរូបសមាបត្តិ ១ ផុតចាកនាមកាយដោយមគ្គ ១ ។ បុគ្គលនោះចេញអំពីសមាបត្តិណាមួយនៃអរូបសមាបត្តិ

៤ ពិចារណាដល់សង្ខារ ហើយចេញអំពីនិរោធនៃបុគ្គល ៤ ពួក ដែលសម្រេចអរហត្តជាបុគ្គល ៥ ពួកដោយអំណាចនៃអនាគាមី ដែលសម្រេចអរហត្ត ។ ម្យ៉ាងទៀត បាលីក្នុងបទនេះ មកហើយដោយអំណាចនៃបុគ្គលដែលបាននូវវិមោក្ខ ៨ ក្នុងអភិធម្ម យ៉ាងនេះថា បុគ្គលជាឧភតោភាគវិមុត្តតើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយទាំងអាសវៈ របស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្តិ ដូច្នេះ ។

បុគ្គលឈ្មោះថា **បញ្ញាវិមុត្តិ** ព្រោះរួចផុតដោយបញ្ញា ។ បញ្ញាវិមុត្តិ-បុគ្គលនោះមាន ៥ ដោយអំណាចនៃបុគ្គលទាំងនេះ គឺសុក្ខវិបស្សក ១ អ្នកចេញចាកឈាន ៤ ហើយសម្រេចអរហត្ត ៤ ទៀត តែបាលីក្នុងបទនេះមកហើយដោយអំណាចការបដិសេធវិមោក្ខ ៨ ដូចព្រះមានព្រះភាគត្រាស់ទុកថា បុគ្គលនោះឯងមិនមែនពាល់ត្រូវវិមោក្ខ ៨ ដោយកាយឡើយ ។ អាសវៈនៃបុគ្គលនោះអស់ទៅហើយ ព្រោះឃើញអរិយសច្ចធម៌នោះ ដោយបញ្ញា ។ បុគ្គលនេះ តថាគតពោលថា ជាបញ្ញាវិមុត្តិបុគ្គល ។

បុគ្គលឈ្មោះ **កាយសក្ខី** ព្រោះធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលពាល់ត្រូវហើយនោះ ។ បុគ្គលណាពាល់ផស្សៈ គឺឈានក្នុងគ្រាដំបូង ក្រោយមកទើបធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ដែលជាការរម្ងត់ឥតមានសេសសល់ គប្បីជ្រាបបុគ្គលនោះថា មាន ៦ ចាប់ពីបុគ្គលដែលតាំងនៅក្នុងសោតាបត្តិផលរហូតដល់បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ។ ដោយហេតុនោះ ទើបព្រះ-

មានព្រះភាគត្រាស់ថា បុគ្គលខ្លះ ក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះ របស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញ( អរិយសច្ចៈ ) ដោយបញ្ញា នេះហៅថា បុគ្គលជាកាយសក្ខី ។

បុគ្គលឈ្មោះថា **ទិដ្ឋិប្បត្ត** ព្រោះសម្រេចធម៌ដែលឃើញហើយនោះ ។ ក្នុងបទនេះ មានលក្ខណៈដោយសង្ខេបដូចតទៅនេះ ។ ឈ្មោះថា ទិដ្ឋិប្បត្តបុគ្គល ព្រោះជាអ្នកដឹងច្បាស់ ឃើញច្បាស់ ធ្វើឲ្យច្បាស់ ពាល់ត្រូវដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ ការរលត់សង្ខារទាំងឡាយជាសុខ ដូច្នេះ ។ តែដោយពិស្តារ បុគ្គលនេះក៏មាន ៦ ដូចកាយសក្ខីបុគ្គលដែរ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលពួកខ្លះក្នុងលោកនេះ រមែងដឹងច្បាស់តាមការពិតថា នេះទុក្ខ ។បេ។ នេះជាបដិបទាឲ្យដល់ការរលត់ទុក្ខ ។ ម្យ៉ាងទៀត ធម៌ទាំងឡាយដែលតថាគតប្រកាសហើយ ជាធម៌ដែលបុគ្គលនោះឃើញ ឃើញច្បាស់ហើយដោយបញ្ញា ប្រព្រឹត្តល្អហើយ ។ បុគ្គលនេះតថាគតពោលថា ទិដ្ឋិប្បត្តបុគ្គល ។

បុគ្គលឈ្មោះថា **សទ្ធាវិមុត្តិ** ព្រោះបង្អោនចិត្តជឿដោយសទ្ធា ។ សូម្បីសទ្ធាវិមុត្តបុគ្គលនោះ ក៏មាន ៦ ដូចពោលហើយនោះឯង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលពួកខ្លះក្នុងលោកនេះ ដឹងច្បាស់តាមការពិតថា នេះទុក្ខ ។បេ។ នេះជាបដិបទាឲ្យដល់នូវការរលត់ទុក្ខ ។ ម្យ៉ាងទៀត ការជឿក្នុងព្រះតថាគតនៃបុគ្គលនោះ តាំងមាំហើយ មានឫសចាក់ចុះមាំហើយ ។ បុគ្គលនេះ តថាគតពោលថា សទ្ធាវិមុត្តបុគ្គល ។

ពិតហើយ ក្នុងបុគ្គលទាំងនេះ ខណៈនៃកិលេស រមែងមានដល់សទ្ធាវិមុត្តបុគ្គល ដូចមានដល់អ្នកជឿ ដូចដល់អ្នកសម្រេច និងដូចដល់អ្នកបង្អោនចិត្តជឿ ក្នុងខណៈមគ្គដែលជាចំណែកខាងដើម ។ ញាណកាត់កិលេសនៃទិដ្ឋិប្បត្តបុគ្គល ជាញាណប្រាកដមុតស្រួច រមែងនាំទៅក្នុងខណៈនៃមគ្គដែលជាចំណែកខាងដើម ។ ព្រោះដូច្នោះ ដូចយកដាវដែលមិនមុតកាប់ដើមចេក ត្រង់ទីដែលដាច់រមែងមិនរលោង ដាវក៏មិនធ្លងទៅដោយរហ័ស ។ ទាំងបានឮសំឡេង ទើបត្រូវការព្យាយាមខ្លាំងក្លា យ៉ាងណា ការចម្រើនមគ្គដែលជាចំណែកខាងដើមនៃសទ្ធាវិមុត្តបុគ្គល ក៏យ៉ាងនោះ ។ មួយវិញទៀត ដូចយកដាវដែលសំលៀងមុតល្អកាត់ដើមចេក ទីដែលកាត់ក៏ស្មើល្អ ដាវដែលធ្លងទៅក៏រហ័ស សំឡេងក៏មិនឮ មិនចាំបាច់ព្យាយាមខ្លាំងក្លា យ៉ាងណា គប្បីជ្រាបការចម្រើនមគ្គដែលជាចំណែកខាងដើមនៃបញ្ញាវិមុត្តបុគ្គល ក៏យ៉ាងនោះ ។

បុគ្គលឈ្មោះថា **ធម្មានុសារី** ព្រោះរឭករឿយៗ ក្នុងធម៌ ។ បទថា **ធម្មោ** គឺបញ្ញា ។ អធិប្បាយថា ចម្រើនមគ្គដែលជាទីទៅខាងមុខ ។ មួយវិញទៀត ក្នុងសទ្ធានុសារីបុគ្គល ក៏មានន័យនេះដូចគ្នា ។ បុគ្គលទាំង ២ នេះជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គដូចគ្នា ។ សេចក្តីនេះ លោកក៏ពោលទុកថា កាលបុគ្គលបដិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឥន្ទ្រិយរមែងមានប្រមាណក្រៃលែង ។ បញ្ញាជាអ្នកនាំ រមែងចម្រើនមគ្គ ដែលមានបញ្ញាជាប្រធាន បុគ្គលនេះតថាគតពោលថា ជាធម្មានុសារីបុគ្គល ។ មួយវិញទៀត កាលបុគ្គលណាបដិបត្តិដើម្បីឲ្យជាក់ច្បាស់នូវសោតាបត្តិផល សទ្ធិន្ទ្រិយរមែង

មានប្រមាណក្រៃលែង សទ្ធាជាអ្នកនាំ រមែងចម្រើនអរិយមគ្គ ដែលមាន សទ្ធាជាប្រធាន បុគ្គលនេះ តថាគតពោលថា ជាសទ្ធានុសារី នេះជាសេចក្តី សង្ខេបក្នុងបទនេះ ។ តែដោយពិស្តារ កថាមានឧភតោភាគវិមុត្តកថាជា ដើម លោកពោលទុកក្នុងអធិការនៃបញ្ញាភាវនា ក្នុងវិសុទ្ធិមគ្គ ។ ព្រោះ ដូច្នោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។ ដើម្បីសម្តែងវិភាគនៃបុគ្គលទាំងនោះ ទើបលើកបាលីមកក្នុងទីនេះ ។ គប្បី ជ្រាបអត្ថក្នុងបាលីនោះ ដូចតទៅនេះ ។ ព្រោះឈ្មោះថា អរូបសមាបត្តិ វៀរ រូបសមាបត្តិចេញហើយ រមែងមិនមាន ។ ដូច្នោះ សូម្បីកាលពោលថា **អារុប្បា** ក៏គប្បីជ្រាបថា លោកពោលដល់វិមោក្ខ ៨ ផងដែរ ។ បទថា **កាយេន ផុសិត្វា** គឺពាល់ត្រូវដោយនាមកាយដែលកើតរួមគ្នា ។ បទថា **បញ្ញាយ ចស្ស ទិស្វា** គឺ អាសវៈពួកខ្លះនៃបុគ្គលនោះអស់ទៅហើយ ព្រោះ ឃើញអរិយសច្ចធម៌នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា គួរលះអាសវៈចំណែកមួយ ដោយបឋមមគ្គជាដើម ។ បទថា **តថាគតប្បវេទិតា** គឺអរិយសច្ច ៤ ដែលព្រះតថាគតទ្រង់ប្រកាសហើយ ។ បទថា **បញ្ញាយ វោទិដ្ឋា ហោន្តិ** គឺធម៌ទាំងឡាយ ឈ្មោះថា បុគ្គលនោះឃើញល្អ ហើយ ដោយមគ្គបញ្ញា ព្រោះសន្សំការប្រព្រឹត្តិទុកក្នុងអត្ថដោយអត្ថ ក្នុងហេតុ ដោយហេតុយ៉ាងនេះថា សីល សមាធិ វិបស្សនា មគ្គ និងផល លោក ពោលទុកក្នុងទីនេះ ។ បទថា **វោចរិតា** គឺប្រព្រឹត្តល្អហើយ ។ បទថា **សទ្ធា និវិដ្ឋា ហោតិ** បានដល់ ឱកប្បនសទ្ធាតាំងមាំហើយ ។ បទថា **មត្តសោ**

**ឆិជ្ឈានំ ខមន្តិ** គឺគួរសម្លឹងពិនិត្យ ដោយប្រមាណ ។ បទថា **សទ្ធាមត្តំ** គឺ សទ្ធានោះឯង ។ បទក្រៅអំពីនោះ ជាវេវចនៈនៃបទថា **សទ្ធាមត្តំ** នោះឯង ។

ព្រោះហេតុនោះ ក្នុងបុគ្គលដែលគួរធ្វើដោយការមិនប្រមាទទាំងនេះ ព្រះ-សេក្ខៈដែលជាអ្នកចាក់ចុះមគ្គផលទាំង ៣ ពួកនោះ សេពសេនាសនៈដែលសមគួរ គប់រកកល្យាណមិត្ត ធ្វើឥន្ទ្រិយឲ្យស្មើ រមែងកាន់យកអរហត្ត តាមលំដាប់ ។ ព្រោះដូច្នោះ អធិប្បាយនៃបាលីនៃបទទាំងនោះ ជាការតាំងទុកតាមសមគួរហើយ ។

ម្យ៉ាងទៀត ក្នុងទីបំផុត លោកអ្នកដល់ព្រមដោយសោតាបត្តិមគ្គទាំង ២ នោះ សេពសេនាសនៈដែលសមគួរដល់មគ្គនោះ គប់រកកល្យាណមិត្ត ធ្វើឥន្ទ្រិយឲ្យស្ងប់ ធ្វើឥន្ទ្រិយឲ្យស្មើ ដើម្បីប្រយោជន៍ដល់មគ្គ ៣ ខាងលើ និងសម្រេចអរហត្តតាមលំដាប់ នេះជាការអធិប្បាយបាលីក្នុងសូត្រនេះដោយប្រការដូច្នេះ ។ ចំណែកអាចារ្យជាវិតណ្ឌវាទី ចាប់យកបាលីនេះឯង ហើយពោលថា លោកុត្តរមគ្គមិនបានប្រព្រឹត្តទៅក្នុងខណៈចិត្ត ១ តែប្រព្រឹត្តទៅក្នុងខណៈចិត្តច្រើនដួង ។ គប្បីពោលនឹងបុគ្គលដែលពោល នោះថា ឧបមាថា សេពសេនាសនៈដោយចិត្ត ១ គប់រកកល្យាណមិត្តដោយចិត្ត ១ ធ្វើឥន្ទ្រិយឲ្យស្មើដោយចិត្ត ១ អ្នកសំដៅថា មគ្គចិត្តជាចិត្តដទៃ រួចពោលថា មគ្គមិនបានប្រព្រឹត្តទៅក្នុងខណៈចិត្ត ១ ប្រព្រឹត្តទៅក្នុងខណៈចិត្តច្រើនដួងឬ ។ បើដូច្នោះ បុគ្គលសេពសេនាសនៈរមែងឃើញភ្នំមានពន្លឺពណ៌ខៀវ ឃើញព្រៃបានឮសំឡេងម្រឹគ និងបក្សី ហិតក្លិនផ្កា ផ្លែឈើ ផឹកទឹក លិទ្ធរស អង្គុយ

ដេក ពាល់ត្រូវផស្សៈ កាលបើដូច្នោះ សូម្បីការដល់ព្រមដោយវិញ្ញាណ ៥ ក៏នឹងជាការដល់ព្រមនៃលោកុត្តរនោះឯង ។ បើអ្នកទទួលសេចក្តីនោះ រមែងជំទាស់នឹងព្រះសាស្តា ។ ព្រះសាស្តាត្រាស់ដល់គំនរនៃវិញ្ញាណ ៥ ថាជាអព្យាកតៈដោយចំណែកមួយ ។ ជាការជំទាស់ កុសល និងអកុសល នៃបុគ្គលដែលដល់ព្រមដោយមគ្គនោះ ។ ម្យ៉ាងទៀត លោកុត្តរមគ្គ ជាកុសល ដោយចំណែកមួយ ព្រោះដូច្នោះ គួរប្រកាសឲ្យដឹងទុកថា អ្នកគួរលះវាទៈ នោះចេញ បើអ្នកពោលនោះមិនព្រមតាមសញ្ញា គួរបញ្ជូនទៅដោយ ពាក្យ ថា លោកចូរទៅកាន់វិហារពីព្រលឹម ហើយឆាន់បបរចុះ ។

[ ២៣៨ ] បទថា **នាហំ ភិក្ខវេ អាទិកេនេវ** សេចក្តីថា ម្នាលភិក្ខុ ទាំងឡាយ តថាគតមិនគួរពោលការតាំងនៅក្នុងអរហត្តផលជាគ្រាដំបូងប៉ុណ្ណោះ ដូចកង្កែបលោតទៅ ដូច្នោះ ។ បទថា **អនុបុព្វសិក្ខា** ជាបឋមាវិភត្តិ ចុះ ក្នុងអត្ថនៃតតិយាវិភត្តិ ប្រែថា ការសិក្សាដោយលំដាប់ ។ ក្នុងបទពីរតទៅ ក៏មានន័យនេះដូចគ្នា ។ បទថា **សទ្ធាជាតោ** គឺមានសទ្ធាកើតហើយ ដោយ សទ្ធាដែលជាទីតាំងនៃការសម្រេច ។ បទថា **ឧបសង្កមិ** គឺរមែងចូលទៅ រកគ្រូ ។ បទថា **បយិរុបាសតិ** គឺរមែងអង្គុយក្នុងសម្នាក់គ្រូ ។ បទថា **ធារេតិ** គឺរមែងទ្រទ្រង់ទុក ធ្វើឲ្យស្ទាត់ហើយ ។ បទថា **ឆន្ទោ ជាយតិ** គឺភាពជាអ្នកប្រាថ្នាដើម្បីធ្វើរមែងកើត ។ បទថា **ឧស្សហតិ** គឺធ្វើសេចក្តី ព្យាយាម ។ បទថា **តុលេតិ** គឺពិចារណាថា មិនទៀង ជាទុក្ខ ជាអនត្តា ។ បទថា **តុលយិត្វា បទហតិ** គឺកាលពិចារណាដោយវិបស្សនា ជាគ្រឿង

ពិចារណាយ៉ាងនេះ រមែងតាំងសេចក្តីព្យាយាមក្នុងមគ្គ ។ បទថា **បហិតត្តោ** គឺមានខ្លួនបញ្ជូនទៅហើយ ។ បទថា **កាយេន ចេវ បរមសច្ចំ** គឺធ្វើឲ្យជាក់ច្បាស់នូវនិព្វានសច្ចៈដោយនាមកាយ ។ បទថា **បញ្ញាយ ច** គឺរមែងចាក់ធ្លុះ រមែងឃើញដោយមគ្គប្បញ្ញា ដែលសម្បយុត្តដោយ នាមកាយ ។

ឥឡូវនេះ ព្រោះភិក្ខុទាំងនោះបានដំណឹងថា ព្រះសាស្តាយាងមក មិនធ្វើសូម្បីត្រឹមតែការទទួល ។ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់តិះដៀលនូវការប្រព្រឹត្តិនៃភិក្ខុទាំងនោះ ទើបត្រាស់ថា **សាបិ នាម ភិក្ខវេ សត្ថា នាហោសិ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កិំ ទូរេ ឥមេ** គឺក្នុងទីឆ្ងាយសែនឆ្ងាយ ។ គួរនឹងពោលថា បានចៀសចេញទៅហើយ ១០០ យោជន៍ ឬ ១០០០ យោជន៍ ។ តែមិនពោលពាក្យណាមួយបានឡើយ ។

[ ២៣៩ ] បទថា **ចតុប្បទំ វេយ្យាករណំ** លោកពោលសំដៅដល់ការព្យាករណ៍ អរិយសច្ច ៤ ។ បទថា **យស្សុទ្ទិដ្ឋស្ស** កាត់បទជា **យស្ស ឧទ្ទិដ្ឋស្ស** ប្រែថា ដែលតថាគតលើកឡើងសម្តែងហើយ ។ បទថា **យោបិ សោ ភិក្ខវេ សត្ថា** ប្រែថា ម្នាលភិក្ខុទាំងឡាយសាស្តាណា គឺលោកសម្តែងដល់សាស្តា ខាងក្រៅ ។ បទថា **ឯវរូបី** គឺមានជាតិយ៉ាងនេះ ។ បទថា **បណោបណវិយា** គឺមានតម្លៃឡើងចុះៗ ។ បទថា **ន ឧបេតិ** គឺមិនមាន ។ អធិប្បាយថា មិនមានតម្លៃឡើងចុះៗ ដូចពេលទិញ និងលក់ ។ កាលពោលថា គោនេះ តម្លៃប៉ុនណា តម្លៃ ២០ ឈ្មោះថា តម្លៃឡើង ។ កាលពោលថា គោនេះ តម្លៃមិនដល់ ២០ តម្លៃ ១០ ប៉ុណ្ណោះ ឈ្មោះថា តម្លៃចុះ ។ កាលពោល

*បដិសេធពាក្យនេះ ឈ្មោះថា តម្លៃមិនឡើង មិនចុះ ។*

*ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការឡើងចុះៗ នោះ ទើបត្រាស់ថា បើហេតុយ៉ាងនេះ មានដល់យើងទាំងឡាយ ក្នុងកាលណាហើយ យើងទាំងឡាយក៏នឹងធ្វើហេតុនោះក្នុងកាលនោះ បើហេតុយ៉ាងនេះ មិនមានដល់យើងទាំងឡាយ យើងទាំងឡាយក៏មិនគប្បីធ្វើនូវហេតុនោះឡើយ ។ បទថា* **កឹ បន ភិក្ខវេ** *សេចក្តីថា ម្នាលភិក្ខុទាំងឡាយ តថាគតជាប់ជំពាក់ ដោយអាមិសទាំងឡាយ ដោយប្រការទាំងពួងឬ ។ ការមានតម្លៃឡើងចុះៗ បែបនេះ នឹងគួរដូចម្តេច ដល់ព្រះសាស្តាដែលជាប់ជំពាក់ហើយយ៉ាងនេះ ។ បទថា* **បរិយោគយ្ហ វត្តតោ** *គឺឈមចុះ លើកឡើង កាន់យក ហើយប្រព្រឹត្ត ។ បទថា* **អយមនុធម្មោ** *គឺសភាវៈនេះ ។ បទថា* **ជានាតិ ភគវា ជាយាំ ជានាមិ** *គឺព្រះមានព្រះភាគទ្រង់ដឹងអានិសង្សក្នុងការឆាន់ អាហារមួយពេល ឯអាត្មាអញមិនដឹង ។ ភិក្ខុវៀរការឆាន់ ៣ ដង ក្នុងមួយថ្ងៃ ដោយជឿក្នុងតថាគត ហើយឆាន់តែអាហារម្តង ។ បទថា* **រុឡ្ហនីយំ** *គឺ ដុះដាល ។ បទថា* **ឱជវន្តំ** *គឺការច្ចាញ់ ។ ព្រះមានព្រះភាគទ្រង់សម្តែង សេចក្តីព្យាយាមមានអង្គ ៤ ដោយបទនេះថា* **កាមំ តចោ** *ច ពិតហើយ ក្នុងបទនេះ ព្រះមានព្រះភាគទ្រង់សម្តែងថា បុគ្គលតាំងនូវសេចក្តីព្យាយាមប្រកបដោយអង្គ ៤ យ៉ាងនេះ គឺស្បែកជាអង្គ ១ សរសៃជាអង្គ ១ ឆ្អឹងជាអង្គ ១ សាច់និងឈាមជាអង្គ ១ ហើយបដិបត្តិយ៉ាងនេះថា អញមិនសម្រេច អរហត្តហើយ នឹងមិនក្រោកឡើង ដូច្នេះ ។ បទដ៏សេសក្នុង*

ទីទាំងពួងវាយយល់ទាំងអស់ហើយ ។

ព្រះមានព្រះភាគ ទ្រង់បញ្ចប់ទេសនា ដោយធម៌ជាកំពូលគឺអរហត្ត ដោយអំណាចនៃយប្បុគ្គល ដោយប្រការដូច្នេះ ។ ៚

អដ្ឋកថាកីជាគិរិសូត្រ ចប់

សូត្រទី ១០ ចប់

វគ្គទី ២ ចប់

# សុត្តន្តបិដក

## បរិព្វាជកវគ្គ

## ចូឡវច្ឆគោត្តសូត្រទី ១

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងគូដារសាលានាមមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះ វច្ឆគោត្តបរិព្វាជក អាស្រ័យនៅក្នុងអារាមរបស់បរិព្វាជក ដែលមានដើមស្វាយស មួយដើម ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យស្តេចចូលទៅកាន់ក្រុងវេសាលីដើម្បីបិណ្ឌបាត ។ លំដាប់នោះ ព្រះមានព្រះភាគ បានទ្រង់ព្រះតម្រិះយ៉ាងនេះថា ការត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលី នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែតថាគតចៀងចូលទៅរកបរិព្វាជកឈ្មោះវច្ឆគោត្តឯអារាមរបស់បរិព្វាជក ដែលមានដើមស្វាយសមួយដើមសិន ។ លុះព្រះមានព្រះភាគ ស្តេចចូលទៅរកវច្ឆគោត្តបរិព្វាជកឯអារាមរបស់បរិព្វាជក ដែលមានដើមស្វាយស មួយដើមហើយ ។ វច្ឆគោត្តបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចមកចុះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគស្តេចមកជាការប្រពៃហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គខានធ្វើដំណើរមកក្នុងទីនេះ អស់កាលយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចគង់ នេះអាសនៈ ខ្ញុំព្រះអង្គក្រាលស្រេចហើយ ។

ព្រះមានព្រះភាគ ក៏គង់លើអាសនៈ ដែលបរិព្វាជកក្រាលថ្វាយ ។ ចំណែកឯវច្ឆគោត្តបរិព្វាជក ក៏កាន់យកអាសនៈដ៏ទាបមួយ អង្គុយក្នុងទីដ៏សមគួរ ។

[ ២ ] លុះវច្ឆគោត្តបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនេះខ្ញុំព្រះអង្គបានស្តាប់មកថា ព្រះសមណៈគោតម ព្រះអង្គជាសព្វញ្ញូ ព្រះអង្គជ្រាបនូវធម៌ទាំងពួង ទ្រង់ប្តេជ្ញានូវញាណទស្សនៈ ឥតមានសេសសល់ថា កាលតថាគតដើរក្តី ឋិតនៅក្តី លក់ក្តី ភ្ញាក់ក្តី ញាណទស្សនៈរមែងតាំងប្រាកដឡើងជារឿយៗ មិនដាច់ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណា ពោលយ៉ាងនេះថា ព្រះសមណគោតម ព្រះអង្គជាសព្វញ្ញូ ព្រះអង្គជ្រាបនូវធម៌ទាំងពួង ទ្រង់ប្តេជ្ញានូវញាណទស្សនៈ ឥតមានសេសសល់ថា កាលតថាគតដើរក្តី ឋិតនៅក្តី លក់ក្តី ភ្ញាក់ក្តី ញាណទស្សនៈរមែងតាំងនៅប្រាកដជារឿយៗ មិនដាច់ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងនោះ តើឈ្មោះថាជាអ្នកពោលតាមពាក្យដែលព្រះមានព្រះភាគត្រាស់ហើយផង មិនឈ្មោះថា ពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលប្តេជ្ញានូវហេតុ ( ព្រះសព្វញ្ញុតញ្ញាណ ) តាមហេតុ ( ពាក្យដែលមហាជននាំគ្នាប្តេជ្ញាយ៉ាងនោះ ) ផង មួយទៀត វាទានុវាទ ( ពាក្យរបស់ព្រះអង្គនឹងពាក្យដែលអនុលោមតាមវាទៈរបស់ព្រះអង្គ ) ណានីមួយ ដែលប្រកបដោយហេតុ ( តាមហេតុដែលគេពោល ) នឹងមិនមកកាន់ឋានៈដែលអ្នកប្រាជ្ញគប្បីតិះដៀល ទេឬ ។ ម្នាលវច្ឆៈ ជនទាំងឡាយណាពោលយ៉ាងនេះថា ព្រះសមណគោតម ព្រះអង្គជាសព្វញ្ញូ

ព្រះអង្គជ្រាបនូវធម៌ទាំងពួង ទ្រង់ប្ដេជ្ញានូវញាណទស្សនៈ ឥតមានសេសសល់ថា កាលតថាគតដើរក្ដី ឋិតនៅក្ដី លក់ក្ដី ភ្ញាក់ក្ដី ញាណទស្សនៈរមែងតាំងប្រាកដឡើងជារឿយៗ មិនដាច់ ជនទាំងឡាយនោះ មិនមែនពោលតាមពាក្យរបស់តថាគតទេ អ្នកទាំងនោះ ឈ្មោះថាពោលបង្កាច់តថាគតដោយពាក្យមិនពិតទេតើ ។

[ ៣ ] បពិត្រព្រះអង្គដ៏ចម្រើន ចុះយើងខ្ញុំ កាលប្ដេជ្ញាដូចម្ដេច ទើបឈ្មោះថាជាអ្នកពោលតាមពាក្យ របស់ព្រះមានព្រះភាគផង ជាអ្នកមិនពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលប្ដេជ្ញានូវហេតុតាមហេតុផង មួយទៀត វាទានុវាទណានីមួយ ដែលប្រកបដោយហេតុ នឹងមិនមកកាន់ឋានៈដែលអ្នកប្រាជ្ញគប្បីតិះដៀលបាន ។ ម្នាលវច្ឆៈ បុគ្គលកាលពោលប្ដេជ្ញាថា ព្រះសមណគោតមទ្រង់បាននូវវិជ្ជា ៣ ដូច្នេះ ឈ្មោះថាជាអ្នកពោលតាមពាក្យរបស់តថាគតផង មិនឈ្មោះថាពោលបង្កាច់តថាគត ដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលប្ដេជ្ញានូវហេតុតាមហេតុផង មួយទៀត វាទានុវាទណានីមួយ ដែលប្រកបដោយហេតុ ក៏មិនមកកាន់ឋានៈ ដែលអ្នកប្រាជ្ញគប្បីតិះដៀលបាន ។ ម្នាលវច្ឆៈ បើតថាគតចង់រឭក ( ទៅរកជាតិ ) ត្រឹមណា តថាគតក៏រឭកបាននូវបុព្វេនិវាសជាច្រើន ត្រឹមណោះ ការរឭកបាននោះដូចម្ដេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ តថាគតរឭកបាននូវបុព្វេនិវាសជាច្រើន ព្រមទាំងអាការៈព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលវច្ឆៈ បើតថាគតចង់ ( ឃើញ

ពួកសត្វ ) ត្រឹមណា ដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងនូវចក្ខុជារបស់មនុស្សធម្មតា តថាគត ឃើញច្បាស់នូវសត្វទាំងឡាយដែលកំពុងច្យុត ដែលកំពុងកើតឡើង ជាសត្វថោកថយនឹងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ត្រឹមណោះ ។បេ។ តថាគតដឹងច្បាស់នូវសត្វទាំងឡាយ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលវច្ឆៈ ព្រោះតថាគតបានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ ( អរហត្តផលសមាធិ ) នូវបញ្ញាវិមុត្តិ ( អរហត្តផលបញ្ញា ) មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ។ ម្នាលវច្ឆៈ បុគ្គលកាល ពោលប្តេជ្ញាថា ព្រះសមណគោតមទ្រង់បាននូវវិជ្ជា ៣ ដូច្នេះ ឈ្មោះថា ជាអ្នកពោលតាមពាក្យរបស់តថាគតផង មិនឈ្មោះថា ពោលបន្តាប់តថាគត ដោយពាក្យមិនពិតផង ឈ្មោះថាជាអ្នកពោលប្តេជ្ញា នូវហេតុតាមហេតុផង មួយទៀត វាទានុវាទណានីមួយ ដែលប្រកបដោយហេតុ ក៏មិនមកកាន់ឋានៈ ដែលអ្នកប្រាជ្ញគប្បីតិះដៀលបាន ។

[ ៤ ] លុះត្រាស់យ៉ាងនេះហើយ វច្ឆៈគោត្តបរិព្វាជកបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើនបុគ្គលនីមួយដែល ជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ ( សេចក្តីត្រេកអរក្នុងសង្ខារ និងបរិក្ខាររបស់គ្រហស្ថ ជាគ្រឿងព័ន្ធព័ទ្ធ ) លុះដល់រំលាងខន្ធទៅហើយ រមែងធ្វើនូវទីបំផុតទុក្ខបាន មានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលនីមួយដែល ជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ លុះរំលាងខន្ធទៅហើយ រមែង

ធ្វើនូវទីបំផុតទុក្ខបាន មិនមានសោះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះបុគ្គលទីមួយដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈ លុះដល់វិលាឝខន្ធទៅ ចូលទៅកាន់ឋានសួគ៌មានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលទាំងឡាយណាដែលជាគ្រហស្ថ មិនបានលះបង់នូវគិហិសញ្ញោជនៈទេ លុះដល់វិលាឝខន្ធទៅហើយ ចូលទៅកាន់ឋានសួគ៌ មិនមែនមានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ នាក់ទេតាមពិតមានច្រើនលើសប្រមាណណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន បុគ្គលទីមួយដែលជាអាជីវក លុះដល់វិលាឝខន្ធទៅ រមែងធ្វើនូវទីបំផុតទុក្ខបានមានខ្លះដែរឬ ។ ម្នាលវច្ឆៈ បុគ្គលទីមួយដែលជាអាជីវក លុះដល់វិលាឝខន្ធទៅហើយ រមែងធ្វើនូវទីបំផុតទុក្ខបាន មិនមានសោះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះបុគ្គលទីមួយដែលជាអាជីវក លុះដល់វិលាឝខន្ធទៅ ចូលទៅកាន់ឋានសួគ៌មានដែរឬ ។ ម្នាលវច្ឆៈ រាប់អំពីកទូកប្បនេះឡើងទៅ ៩១ កប្ប តថាគតនឹករកមិនឃើញ នូវអាជីវកណាមួយ ដែលចូលទៅកាន់ឋានសួគ៌ទេ វៀរលែងតែបុគ្គលមួយពួក ដែលជាកម្មវាទី ( អ្នកដែលពោលថាបុណ្យបាបជារបស់អ្នកធ្វើ ) នឹងកិរិយវាទី ( អ្នកពោលថាបុណ្យបាបដែលអ្នកធ្វើឈ្មោះថាបានធ្វើហើយ ) ។ បពិត្រព្រះគោតមដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ លទ្ធិរបស់តិរ្ថិយឯណោះដោយហោចទៅឈ្មោះថាសូន្យចាកគុណដែលនឹងនាំទៅកាន់ឋានសួគ៌ ។ ម្នាលវច្ឆៈ យ៉ាងហ្នឹងហើយ លទ្ធិរបស់តិរ្ថិយឯណោះ ដោយហោចទៅឈ្មោះថាសូន្យចាកគុណដែលនឹងនាំទៅកាន់ឋានសួគ៌ ។ លុះព្រះមានព្រះភាគ ទ្រង់

ត្រាស់ព្រះសូត្រនេះចប់ហើយ វច្ឆគោត្តបរិព្វាជក ក៏មានចិត្តរីករាយ ត្រេកអរហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចូឡវច្ឆគោត្តសូត្រទី ១

# អដ្ឋកថា

## ចូឡវច្ឆគោត្តសូត្រ

[ ១ ] ចូឡវច្ឆគោត្តសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **ឯកបុណ្ឌរិកេ** ដើមស្វាយស លោកហៅថា **បុណ្ឌរិក** ។ ឈ្មោះថា **ឯកបុណ្ឌរិកោ** ព្រោះដើមស្វាយសនោះ មានមួយដើម ក្នុងអារាមនោះ ។ បទថា **ឯតទហោសិ** គឺព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះ ព្រោះមានបំណងយាងចូលទៅក្នុងបរិព្វាជការាមនោះ ។ បទថា **ចិរស្សំ ខោ ភន្តេ** សំដៅដល់ ធ្លាប់យាងមកតាមប្រក្រតី ។

[ ២ ] ក្នុងបទថា **ធម្មស្ស ច អនុធម្មំ**នេះ សព្វញ្ញុតញ្ញាណ ឈ្មោះថា ធម៌ ។ ការព្យាករណ៍ ដល់មហាជន ឈ្មោះថា អនុធម្ម គឺធម៌សមគួរ ។ បទដ៏សេសមានន័យដូចពោលហើយ ក្នុងជីវកសូត្រនោះឯង ។ បទថា **ន មេ** សេចក្ដីថា មិនជាការពោលតាមពាក្យដែលតថាគតពោលហើយ គឺតាំងនៅក្នុងការមិនឃើញប្រពៃ បដិសេធសូម្បីការឃើញប្រពៃ ។ ព្រោះព្រះសព្វញ្ញូមានប្រក្រតីឃើញវត្ថុទាំងពួង ទ្រង់ប្ដេជ្ញាញាណទស្សនៈមិនមានចំណែកសេសសល់ ដូច្នោះ ញាណទស្សនៈនេះ គួរដឹងតាម ។ បទថា **ចរតោ ច មេ បច្ចុបដ្ឋិតំ** សេចក្ដីថា កាលតថាគតដើរទៅក្ដី ញាណទស្សនៈប្រាកដហើយ នេះមិនសមគួរដឹងតាម ។ ព្រោះព្រះមានព្រះភាគទ្រង់ពិចារណាដោយសព្វញ្ញុតញ្ញាណ ហើយទ្រង់ដឹង ។ ដូច្នោះ ទ្រង់តាំងនៅក្នុងការមិនឃើញប្រពៃ បដិសេធការឃើញប្រពៃ ទើបត្រាស់យ៉ាងនេះ ។

[ ៣ ] ក្នុងបទថា **អាសវានំ ខយា** នេះ ព្រះមានព្រះភាគមិនបាន ត្រាស់ថា ត្រឹមណា ។ ព្រោះអាសវៈទាំងឡាយដែលអស់ទៅហើយម្តង មិនមានអាសវៈដែលគប្បីអស់ទៅទៀត ។ ព្រះមានព្រះភាគទ្រង់ពោល សង្ខេបព្រះគុណទាំងអស់ ដោយវិជ្ជាទាំង ៣ នេះទ្រង់សម្តែងគុណ គឺ ការដឹងក្នុងអតីត ដោយបុព្វេនិវាសញ្ញាណ ១ ទ្រង់សម្តែងគុណ គឺការដឹង ក្នុងបច្ចុប្បន្ន ដោយទិព្វចក្ខុញ្ញាណ ១ ទ្រង់សម្តែងលោកុត្តរញ្ញាណ ដោយ អាសវក្ខញ្ញាណ ១ ។

[ ៤ ] បទថា **គិហិសំយោជនំ** សេចក្តីថា សំយោជនៈរបស់គ្រហស្ថ គឺការចងរបស់គ្រហស្ថ ក្នុងការប្រាថ្នាបរិក្ខាររបស់គ្រហស្ថ ។ បទថា **នត្ថិ ខោ វច្ឆ** សេចក្តីថា ម្នាលវច្ឆៈ មិនមានឡើយ គឺ បុគ្គលមិនទាន់លះគិហិ-សំយោជនៈ ឈ្មោះថា ធ្វើទីបំផុតទុក្ខ រមែងមិនមាន ។ សូម្បីបុគ្គលពួក ណាស្ថិតនៅក្នុងភេទជាគ្រហស្ថ ដូចជាសន្តតិមហាមាត្យ ឧគ្គសេនសេដ្ឋីបុត្រ វីតសោកជារក ក៏សម្រេចអរហត្តបាន ។ បុគ្គលទាំងនោះ ក៏គង់ប្រាថ្នាក្នុង សង្ខារទាំងពួងឲ្យស្ងួតទៅដោយមគ្គ ហើយសម្រេចបាន ។ តែកាលសម្រេច ហើយ ក៏មិនតាំងនៅដោយភេទនោះ ។ ឈ្មោះថា ភេទគ្រហស្ថនេះហើយ មិនអាចទ្រទ្រង់នូវគុណដ៏ឧត្តមទុកបាន ។ ព្រោះដូច្នោះ បុគ្គលតាំងនៅក្នុង ភេទគ្រហស្ថនោះ សម្រេចអរហត្តហើយ រមែងបួស ឬបរិនិព្វានក្នុងថ្ងៃនោះ ឯង តែកុម្មទេវតាស្ថិតនៅបាន ។ ព្រោះហេតុអ្វី ព្រោះឱកាសដែលនឹង កំបាំងខ្លួននៅបាន ។ ក្នុងកាមភពដ៏សេស ព្រះអរិយបុគ្គល ៣ ពួក មាន

ព្រះសោតាបន្នជាដើមស្ថិតនៅបានក្នុងមនុស្សលោក ។ ក្នុងកាមាវចរលោក ព្រះសោតាបន្ន និងព្រះសកទាគាមីស្ថិតនៅបាន តែអនាគាមី និងព្រះខីណាស្រពតាំងនៅក្នុងកាមាវចរទេវលោកនេះមិនបាន ។ ព្រោះហេតុអ្វី ព្រោះទីនោះមិនមែនជាលំនៅរបស់ជនដែលខ្មាសហើយ និងទីនោះមិនមែនជាទី បិទបាំងដែលសមគួរដល់វិវេករបស់ព្រះខីណាស្រពទាំងនោះ ។

ដោយប្រការដូច្នេះ ទើបព្រះខីណាស្រពបរិនិព្វានក្នុងទីនោះ ។ ព្រះអនាគាមីចុតិហើយ ទៅកើតក្នុងសុទ្ធាវាសព្រហ្ម ។ ព្រះអរិយៈ ៤ ពួក តែងតាំងនៅក្នុងភូមិខាងលើ អំពីកាមាវចរទេវលោកបាន ។ បទថា **សោចាបិកម្មវាទី** គឺអាជីវកដែលជាកម្មវាទី ។ បទថា **កិរិយវាទី** ព្រះមានព្រះភាគទ្រង់ជំទាស់អ្នកដទៃ ហើយទ្រង់ពោលដល់ព្រះអង្គឯងប៉ុណ្ណោះ ក្នុងទីបំផុត ៨៩ កប្ប[១] ។ បានឮថា ក្នុងកាលនោះ ព្រះមហាសត្វទ្រង់បួសដើម្បីទ្រង់ពិសោធមើលលទ្ធិបាសណ្ឌៈ គឺជាលទ្ធិដែលទាក់ទងជាមួយតណ្ហា និងទិដ្ឋិ ។ កាលទ្រង់ជ្រាបថា លទ្ធិបាសណ្ឌៈនោះ មិនមានផល ទ្រង់ក៏មិនបានលះបង់សេចក្ដីព្យាយាម បានជាកិរិយវាទី ទៅកើតក្នុងស្ថានសួគ៌ ។ ព្រោះដូច្នោះទើបទ្រង់ត្រាស់យ៉ាងនេះ ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថា ចូឡវច្ឆគោត្តសូត្រ ចប់**

**សូត្រទី១ចប់**

---

១- ក្នុងបាលីថា ៩១ កប្ប ។

# សុត្តន្តបិដក

## អគ្គិវច្ឆគោត្តសូត្រទី ២

[ ៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងអារាមឈ្មោះជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ បរិព្វាជកឈ្មោះវច្ឆគោត្ត ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលនូវពាក្យរាក់ទាក់ សំណេះសំណាលនឹងព្រះមានព្រះ-ភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ៦ ] វច្ឆគោត្តបរិព្វាជក លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមានទីបំផុតនេះ

ឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះ ថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខ

អំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជា មោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមាន សេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅកើតទៀត ក៏មិនមែនមិនកើតទៀត ក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខ អំពីមរណៈទៅ កើតទៀតក៏មិន មែនមិនកើតទៀតក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះទេ ។

[ ៧ ] វច្ឆគោត្តបរិញ្វាជក ក្រាបទូលថា កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនទៀង នេះឯងជា

ពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា លោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេចក្តីឃើញយ៉ាងនេះ ថាលោកមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា លោកមិនមានទីបំផុត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេចក្តីឃើញយ៉ាងនេះថា នោះជីវិត នោះសរីរៈ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា ជីវិតដទៃ សរីរៈដទៃ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើន មានសេចក្តីឃើញ

យ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ។ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគត មិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោ-តមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀត នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខ អំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតដ៏ចម្រើន ព្រះគោតមដ៏ចម្រើនមានសេចក្តីឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ តថាគតមិនឃើញយ៉ាងនេះថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន នេះឯងជាពាក្យពិត ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។

ព្រះគោតមដ៏ចម្រើន ទ្រង់ឃើញច្បាស់នូវទោសដូចម្ដេច បានជាមិនប្រកាន់នូវទិដ្ឋិទាំងនេះ ដោយប្រការ ទាំងពួងយ៉ាងនេះ ។

[ ៨ ] ម្នាលវច្ឆៈ សេចក្ដីឃើញថា លោកទៀងដូច្នេះឯង ជាសេចក្ដីឃើញយ៉ាងព្រៃស្បាត ជាសេចក្ដីឃើញយ៉ាងឆ្ងាយដាច់ស្រយាល ជាសេចក្ដីឃើញយ៉ាងចម្រូងចម្រាស ជាសេចក្ដីឃើញឃ្វេងឃ្វាង ជាសេចក្ដីឃើញដែលប្រកបសត្វទុក ប្រកបដោយទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ មិនដើម្បីប្រាសចាកតម្រេក មិនដើម្បីសេចក្ដីរម្ងត់ មិនដើម្បីសេចក្ដីស្ងប់រម្ងាប់ មិនដើម្បីសេចក្ដីដឹងច្បាស់ មិនដើម្បីសេចក្ដីត្រាស់ដឹង មិនដើម្បីព្រះនិព្វាន ។ ម្នាលវច្ឆៈ សេចក្ដីឃើញថាលោកមិនទៀងដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថាលោកមានទីបំផុតដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថាលោកមិនមានទីបំផុតដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថា នោះជីវិត នោះសរីរៈ ដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថាជីវិតដទៃ សរីរៈដទៃដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថា សត្វខាងមុខអំពីមរណៈទៅ កើតទៀត ដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថា សត្វខាងមុខអំពីមរណៈទៅ មិនកើតទៀតដូច្នេះ ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះឯង ។បេ។ ម្នាលវច្ឆៈ សេចក្ដីឃើញថា សត្វខាងមុខអំពីមរណៈទៅ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះឯង ជាសេចក្ដីឃើញយ៉ាងព្រៃ

ស្បាត ជាសេចក្តីឃើញយ៉ាងឆ្ងាយដាច់ស្រយាល ជាសេចក្តីឃើញយ៉ាង ចម្រូងចម្រាស ជាសេចក្តីឃើញយ៉ាងឃ្វេងឃ្វាង ជាសេចក្តីឃើញដែល ប្រកបសត្វទុក ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយ សេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ មិនប្រព្រឹត្តទៅ ដើម្បី សេចក្តីនឿយណាយ មិនដើម្បីប្រាសចាកតម្រេក មិនដើម្បីសេចក្តីរម្ងត់ មិន ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនដើម្បីសេចក្តីដឹងច្បាស់ មិនដើម្បីសេចក្តីត្រាស់ដឹង មិនដើម្បីព្រះនិព្វាន ។ ម្នាលវច្ឆៈ តថាគតឃើញច្បាស់នូវទោសដូច្នេះឯង ទើបបានជាមិនប្រកាន់នូវទិដ្ឋិទាំងនេះ ដោយប្រការទាំងពួងយ៉ាងនេះ ។ ចុះ សេចក្តី ឃើញបន្តិចបន្តួចរបស់ព្រះគោតមដ៏ចម្រើនមានខ្លះដែរឬ ។ ម្នាលវច្ឆៈ សេចក្តីឃើញដូច្នេះឯង តថាគតបាននាំចេញហើយ ម្នាលវច្ឆៈ ព្រោះសេចក្តី ឃើញនេះ តថាគតឃើញហើយថា រូបដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃរូប ដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាគ្រឿងកើត ឡើងនៃវេទនាដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃសញ្ញាដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាគ្រឿងកើតឡើងនៃសង្ខារទាំងឡាយដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជា គ្រឿងកើតឡើងនៃវិញ្ញាណដូច្នេះ ហេតុជាគ្រឿងរលត់ទៅនៃវិញ្ញាណដូច្នេះ ព្រោះហេតុនោះ បានជាតថាគតពោលថា តថាគតរួចស្រឡះហើយ ព្រោះមិន ប្រកាន់មាំ ព្រោះអស់ទៅ ព្រោះប្រាសចាកតម្រេក ព្រោះរលត់ទៅ ព្រោះ

លះបង់ ព្រោះរលាស់ចោលនូវសេចក្តីមើលងាយទាំងពួង នូវសេចក្តីបន្ទាបបន្ថោកទាំងពួង នឹងអហង្ការមមង្ការមានានុស័យទាំងពួង ។

[ ៩ ] បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ។ ម្នាលវច្ឆៈ ពាក្យថាកើតទៀតដូច្នេះ មិនគួរទេ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែមិនកើតទៀតទេឬ ។ ម្នាលវច្ឆៈ ពាក្យថា មិនកើតទៀតដូច្នេះ ក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀតខ្លះ មិនកើតទៀតខ្លះ ដូច្នេះក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ ។ ម្នាលវច្ឆៈ ពាក្យថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះឬក៏មិនគួរ ។

[ ១០ ] កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុដែលមានចិត្តរួចស្រឡះហើយយ៉ាងនេះ នឹងកើតទៀតក្នុងទីណា ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថាកើតទៀតដូច្នេះមិនគួរទេ ។ កាលខ្ញុំទូលសួរថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែមិនកើតទៀតទេឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា មិនកើតទៀតដូច្នេះ ក៏មិនគួរ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏ចម្រើន បើដូច្នោះមានតែកើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀតខ្លះ មិនកើតទៀតខ្លះដូច្នេះក៏មិនគួរ ។ កាលខ្ញុំទូលសួរព្រះអង្គថា បពិត្រព្រះគោតមដ៏

ចម្រើន បើដូច្នោះមានតែកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនឬ ព្រះអង្គឆ្លើយថា ម្នាលវច្ឆៈ ពាក្យថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ដូច្នេះក៏មិនគួរ ។ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គដល់នូវសេចក្តីមិនដឹងក្នុងដំណើរនេះ ដល់នូវសេចក្តីវង្វេងក្នុងដំណើរនេះ ។ វាចាណា របស់ខ្ញុំដែលជាវាចាអាចញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតមាន ដោយពាក្យចរចាមុនរបស់ព្រះគោតមដ៏ចម្រើន ឥឡូវនេះ វាចានោះរបស់ខ្ញុំក៏បាត់អស់ទៅ ។

[ ១១ ] ម្នាលវច្ឆៈ គួរតែអ្នកមិនដឹង គួរតែអ្នកវង្វេង ម្នាលវច្ឆៈ ព្រោះធម៌នេះជាធម៌ដ៏ជ្រៅ ជាធម៌ដែលបុគ្គលឃើញបានដោយកម្រ ជាធម៌ត្រាស់ដឹងបានដោយកម្រ ជាធម៌ដ៏ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីត្រាច់ចុះនៃវិតក្កៈបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ធម៌នោះខ្លួនអ្នក ដែលមានទិដ្ឋិដទៃ មានសេចក្តីពេញចិត្តដទៃ មានសេចក្តីគាប់ចិត្តដទៃ មានសេចក្តីព្យាយាមក្នុងទីដទៃ មានអាចារ្យក្នុងទីដទៃ រមែងដឹងបានដោយកម្រ ម្នាលវច្ឆៈ បើដូច្នោះ តថាគតនឹងត្រឡប់សួរអ្នក ក្នុងដំណើរនេះវិញ ដំណើរនោះគួរដល់អ្នកយ៉ាងណា អ្នកគប្បីដោះស្រាយនូវដំណើរនោះយ៉ាងនោះចុះ ម្នាលវច្ឆៈ អ្នកសម្គាល់នូវដំណើរនោះដូចម្តេច បើភ្លើងឆេះក្នុងទីចំពោះមុខអ្នក អ្នកគប្បីដឹង ថាភ្លើងនេះឆេះក្នុងទីចំពោះមុខអាត្មាអញដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន បើភ្លើងឆេះក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះឆេះ ក្នុងទីចំពោះអាត្មាអញ ។ ម្នាលវច្ឆៈ បើគេសួរអ្នកយ៉ាងនេះថា ភ្លើងណាឆេះ ក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះ ព្រោះអាស្រ័យអ្វី ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះ អ្នកគប្បី

ដោះស្រាយដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន បើគេសួរខ្ញុំយ៉ាងនេះ ថា ភ្លើងណាឆេះក្នុងទីចំពោះមុខអ្នក ភ្លើងនេះឆេះ ព្រោះអាស្រ័យអ្វី បពិត្រ គោតមដ៏ចម្រើន បើគេសួរយ៉ាងនេះ ខ្ញុំគប្បីដោះស្រាយយ៉ាងនេះថា ភ្លើង ណាឆេះក្នុងទីចំពោះមុខខ្ញុំ ភ្លើងនេះឆេះឡើង ព្រោះអាស្រ័យនូវកំញមគឺស្មៅ នឹងឧស ។ ម្នាលវច្ឆៈ បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខ ( អ្នក ) អ្នក គប្បីដឹងថា ភ្លើងនេះរលត់ហើយក្នុងទីចំពោះមុខ អាត្មាអញដែរឬ ។ បពិត្រ ព្រះគោតមដ៏ចម្រើន បើភ្លើងនោះរលត់ទៅក្នុងទីចំពោះមុខខ្ញុំ ខ្ញុំគប្បីដឹងថា ភ្លើងនេះរលត់ហើយ ក្នុងទីចំពោះមុខអាត្មាអញ ។ ម្នាលវច្ឆៈ ចុះបើគេសួរ យ៉ាងនេះថា ភ្លើងណា ដែលរលត់ហើយក្នុងទីចំពោះមុខអ្នក ភ្លើងនោះទៅ អំពីទីនេះទៅហើយ ទៅកាន់ទិសណា ខាងកើតឬខាងលិច ខាងជើងឬខាង ត្បូង ម្នាលវច្ឆៈ បើគេសួរយ៉ាងនេះ តើអ្នកគប្បីដោះស្រាយដូចម្តេច ។ បពិត្រគោតមដ៏ចម្រើន មិនគួរនឹងដោះស្រាយបានទេ បពិត្រព្រះគោតមដ៏ ចម្រើន ដ្បិតថាភ្លើងនោះឆេះព្រោះអាស្រ័យនូវកំញម គឺ ស្មៅនឹងឧសណា ដល់នូវកិរិយារាប់ថា រលត់ទៅមិនមានអាហារដូច្នេះ ព្រោះអស់ទៅនៃកំញម គឺស្មៅនឹងឧសនោះផង ព្រោះមិនមានកិរិយានាំចូលទៅជិតនូវវត្ថុដទៃផង ។

[ ១២ ] ម្នាលវច្ឆៈ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយរូប ណា រូបនោះតថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឲ្យដូចជា ត្នោតកំបុតកហើយដល់នូវកិរិយាមិនមាន ជារូបមានកិរិយាមិនកើតឡើងតទៅ ទៀតជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយចាកចំណែកនៃរូប ជាអ្នក

ជ្រៅ ( ដោយគុណ ) មានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បាន ដោយកម្រយ៉ាងនេះឯង ។ ដូចមហាសមុទ្រនឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតទេក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះ ក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយវេទនាណា វេទនានោះ តថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឲ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាវេទនាមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃវេទនា ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថា កើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយសញ្ញាណា សញ្ញានោះតថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឲ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាសញ្ញាមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃសញ្ញា ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គល ស្ទាប-ស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថាកើតទៀតក៏មិនគួរថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន ថាមិនកើតទៀតក៏មិនមែនក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយសង្ខារទាំងឡាយណា សង្ខារទាំងឡាយនោះ តថាគត

លះបង់ហើយ កាត់ឫសចោលហើយ ធ្វើឲ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាសង្ខារមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃសង្ខារ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថាកើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន ថាមិនកើតទៀតក៏មិនមែន ក៏មិនគួរ ។ បុគ្គលកាលបញ្ញត្តនូវសត្វ គប្បីបញ្ញត្តដោយវិញ្ញាណណា វិញ្ញាណនោះតថាគតលះបង់ហើយ កាត់ឫសចោលហើយ ធ្វើឲ្យដូចជាត្នោតកំបុតកហើយ ដល់នូវកិរិយាមិនមាន ជាវិញ្ញាណមានកិរិយាមិនកើតទៀតតទៅជាធម្មតា ម្នាលវច្ឆៈ តថាគតរួចស្រឡះហើយ ចាកចំណែកនៃវិញ្ញាណ ជាអ្នកជ្រៅមានប្រមាណមិនបាន ដែលបុគ្គលស្ទាបស្ទង់បានដោយកម្រ ។ ដូចមហាសមុទ្រ នឹងថាកើតទៀតក៏មិនគួរ ថាមិនកើតទៀតក៏មិនគួរ ថាកើតទៀតខ្លះ មិនកើតទៀតខ្លះក៏មិនគួរ ថាកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ក៏មិនគួរ ។

[ ១៣ ] លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ វច្ឆគោត្តបរិញ្វាជក ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ដើមរាំងភ្នំធំ ( ដុះនៅ ) ក្នុងទីជិតនៃស្រុកក្តី និគមក្តី មែកនិងស្លឹកនៃដើមរាំងភ្នំធំនោះ ក៏វិនាសទៅដោយភាវៈមិនទៀង សម្បកនឹងក្រមរទាំងឡាយក៏វិនាសទៅ ស្រាយក៏វិនាសទៅ សម័យខាងក្រោយមក ដើមរាំងភ្នំធំនោះ ក៏ប្រាសចាកមែក និងស្លឹក ប្រាសចាកសម្បក និងក្រមរ ប្រាសចាក

ស្រាយ បិតនៅតែខ្ទឹមដ៏ស្អាតយ៉ាងណាមិញ ឯពាក្យជាប្រធាន ( ធម្មវិន័យ ) របស់ព្រះគោតមដ៏ចម្រើន ក៏ប្រាសចាកមែកនឹងស្លឹក ប្រាសចាកសម្បក នឹងក្រមរ ប្រាសចាកស្រាយ បិតនៅចំពោះខ្ទឹមដ៏ស្អាតយ៉ាងនោះដែរ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសហើយដោយអនេកបរិយាយយ៉ាងនេះ ដូចជាបុគ្គលផ្ងារឡើងនូវវត្ថុ ដែលផ្កាប់ ឬបើកនូវវត្ថុដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា មនុស្សអ្នកមានភ្នែក ( ភ្លឺ ) រមែងបានឃើញរូបទាំងឡាយដូច្នោះដែរ ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមមានព្រះភាគព្រមទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមរៀងទៅ ។

ចប់ អគ្គិវច្ឆគោត្តសូត្រទី ២

# អដ្ឋកថា

## អគ្គិវច្ឆគោត្តសូត្រ

[ ៥-៦ ] អគ្គិវច្ឆគោត្តសូត្រ មានពាក្យផ្តើមថា **ឯវមេ្ម សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ន ខោ អហំ** សេចក្តីថា តថាគត មិនបានឃើញយ៉ាងនោះ គឺ ព្រះមានព្រះភាគត្រាស់ជំបូងថា តថាគតមិន ឃើញថា លោកទៀង ។ ក្នុងគ្រាទី ២ ត្រាស់ថា តថាគតមិនឃើញថា លោកដាច់សូន្យ ។ គប្បីជ្រាបការបដិសេធក្នុងគ្រប់វារៈ ដោយពាក្យជា ដើមថា លោកមានទីបំផុត និងមិនមានទីបំផុត ដោយប្រការដូច្នេះ ។ វាទៈនេះថា **ហោតិ ច ន ច ហោតិ** ថាជាឯកច្ចសស្សតវាទ ក្នុងទីនេះ ។ វាទៈនេះថា សត្វស្លាប់ទៅហើយមាន ក៏មិនមែន មិនមានក៏មិនមែន គប្បីជ្រាប ថា ជាអមរាវិក្ខេប គឺបោះពាក្យបោះសម្តីមិនឲ្យស្លាប់ខ្លួន ។

[ ៨ ] បទថា **សទុក្ខំ** សេចក្តីថា ប្រព្រឹត្តទៅជាមួយទុក្ខ គឺប្រព្រឹត្តទៅ ដោយទុក្ខ ដោយទុក្ខដែលកើតអំពីកិលេស និងដោយទុក្ខដែលកើតអំពីវិបាក ។ បទថា **សវិឃាតំ** សេចក្តីថា ប្រព្រឹត្តទៅដោយសេចក្តីលំបាក គឺប្រកប ដោយសេចក្តីលំបាក ដោយអំណាចនៃទុក្ខទាំង ២ យ៉ាងនោះ ។ បទថា **សឧបាយាសំ** សេចក្តីថា ប្រកបដោយការចង្អៀតចង្អល់ គឺប្រព្រឹត្តទៅជា មួយការចង្អៀតចង្អល់ដោយអំណាចទុក្ខទាំងនោះ ។ បទថា **សបរិឡាហំ** សេចក្តីថា ប្រព្រឹត្តទៅដោយការក្តៅក្រហាយ ដោយអំណាចនៃទុក្ខទាំងនោះ ឯង ។ បទថា **កិញ្ចិ ទិដ្ឋិគតំ** សេចក្តីថា វច្ឆៈទូលសួរថា ការឃើញ

ណាមួយ ដែលព្រះអង្គទ្រង់ពេញចិត្ត ទ្រង់ពេញចិត្តហើយកាន់យក មានឬ ។ បទថា **អបនីតំ** សេចក្តីថា តថាគតកម្ចាត់ហើយ មិនចូលទៅរកហើយ ។ បទថា **ទិដ្ឋំ** គឺឃើញដោយបញ្ញា ។ បទថា **តស្មា** គឺតថាគតបានឃើញការកើត និងការសូន្យទៅនៃខន្ធ ៥ ។ បទថា **សព្វមញ្ញិតានំ** គឺសេចក្តីសម្គាល់ ដោយតណ្ហា ទិដ្ឋិ និងមានះ ទាំង ៣ ។ បទថា **មត្ថិតានំ** ក៏ជាវេវចនៈនៃបទទាំងនោះឯង ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចែកបទទាំងនោះហើយ កាលទ្រង់សម្តែងដល់ ទើបត្រាស់ថា **សព្វអហង្ការមមង្ការមានានុសយានំ** សេចក្តីថា ការប្រកាន់ថាអញ ថារបស់អញ និងការប្រកាន់ខ្លួនដែលដេកត្រាំនៅក្នុងសន្តានទាំងពួង ។ ពិតហើយ ក្នុងបទនេះគប្បីជ្រាបសេចក្តីដូច្នេះ ។ ការប្រកាន់ថាអញ ជាទិដ្ឋិ ការប្រកាន់ថា ជារបស់អញ ជាតណ្ហា ។ ការប្រកាន់ខ្លួនដែលដេកត្រាំនៅក្នុងសន្តាន ជាមានះ ។ បទថា **អនុបាទា វិមុត្តោ** សេចក្តីថា តថាគតផុតវិសេសហើយអំពីការមិនប្រកាន់មាំ គឺផុតព្រោះមិនប្រកាន់ធម៌ណាមួយ ដោយឧបាទាន ៤ ។

[ ៩-១០ ] បទថា **ន ឧបេតិ** គឺមិនគួរ ។ ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងបទនេះដូចតទៅនេះ ។ បទថា **ន ឧប្បជ្ជតិ** គឺគួរដឹងតាម ។ តែព្រោះកាលត្រាស់យ៉ាងនេះ បរិព្វាជក នោះគប្បីកាន់យកការដាច់សូន្យ បទថា **ឧប្បជ្ជតិ** ប្រែថា រមែងកើត ។ គប្បីកាន់យកការទៀងតែម្យ៉ាង ។ បទថា **ឧប្បជ្ជតិ ច ន ឧប្បជ្ជតិ ច** សេចក្តីថា គប្បីកាន់យកការទៀង

ចំណែកខ្លះ ។ បទថា **នេវ ឧប្បជ្ជតិ ន ច ឧប្បជ្ជតិ** សេចក្តីថា ជាអមរាវិក្ខេបទិដ្ឋិ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា វច្ឆបរិព្វាជកនេះមិនមានទីពឹង មិនមានទីពំនាក់ មិនបានចូលទៅកាន់ទីសុខឡើយ ហើយតាំងនៅក្នុងការមិនឃើញប្រពៃ បដិសេធការឃើញប្រពៃ ។

[ ១១ ] បទថា **អលំ** គឺអាចបាត់បែង ។ បទថា **ធម្មោ** បានដល់ធម៌ គឺបច្ចយាការ ។ បទថា **អញ្ញត្រ យោគេន** គឺមានសេចក្តីព្យាយាមក្នុងផ្លូវដទៃ ។ បទថា **អញ្ញត្រ អាចរិយកេន** គឺនៅក្នុងសម្នាក់របស់អាចារ្យដទៃដែលមិនដឹងបច្ចយាការ ។ បទថា **តេនហិ វច្ឆ** សេចក្តីថា ម្នាលវច្ឆៈ អ្នកពោលថា ខ្ញុំដល់នូវការវង្វេងវង្វាង ដូច្នេះ តថាគតនឹងសាកសួរអ្នកក្នុងសេចក្តីនេះ ។ បទថា **អនាហារោ និព្វុតោ** គឺមិនមានបច្ច័យ ហើយរលត់ទៅ ។

[ ១២ ] បទថា **យេន រូបេន** គឺគប្បីបញ្ញត្តសត្វថាមានរូប ដោយរូបណា ។ បទថា **គម្ភីរោ** គឺមានគុណដ៏ជ្រៅ ។ បទថា **អប្បមេយ្យោ** គឺមិនអាចកាន់យកប្រមាណបាន ។ បទថា **ទុប្បរិយោគាឡ្ហោ** គឺដឹងបានលំបាក ។ បទថា **សេយ្យថាបិ មហាសមុទ្ទោ** គឺ ដូចមហាសមុទ្រដ៏ជ្រៅប្រមាណមិនបាន ដឹងបានលំបាក យ៉ាងណា សូម្បីព្រះខីណាស្រព ក៏ដូច្នោះ ។ បទថា **ឧប្បជ្ជតិ** ជាដើម សេចក្តីថា ព្រោះប្រារព្ធព្រះខីណាស្រពនោះ ។ ប្រៀបដូចអ្វី ប្រៀបដូចបទជាដើមថា បុគ្គលទៅកាន់ទិសខាងកើត ព្រោះប្រារព្ធភ្លើង ដែលរលត់ហើយ មិនគួរទាំងអស់ ដូច្នេះ ។

[ ១៣ ] *បទថា* **អនិច្ចតា** *សេចក្តីថា ព្រោះការមិនទៀង ។ បទថា* **សារេ បតិដ្ឋិតំ** *សេចក្តីថា សល់តែខ្លឹម គឺលោកុត្តរធម៌ ។ បទដ៏សេសងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថាអគ្គិវច្ឆគោត្តសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## មហាវច្ឆគោត្តសូត្រទី ៣

[ ១៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ លំដាប់នោះ វច្ឆគោត្តបរិព្វាជក បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ វច្ឆគោត្តបរិព្វាជក លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា ខ្ញុំព្រះអង្គធ្លាប់និយាយជាមួយនឹងព្រះគោតមដ៏ចម្រើន អស់កាលជាយូរអង្វែងមកហើយ សូមទ្រង់មេត្តាប្រោស សូមព្រះគោតមដ៏ចម្រើន សំដែងកុសលធម៌នឹងអកុសលធម៌ដល់ខ្ញុំព្រះអង្គដោយ សេចក្តីសង្ខេបចុះ ។ ម្នាលវច្ឆៈ តថាគតនឹងសំដែងកុសលធម៌នឹងអកុសលធម៌ ដល់អ្នកដោយសេចក្តីសង្ខេបបាន ម្នាលវច្ឆៈ តថាគតនឹងសំដែងកុសលធម៌ និងអកុសលធម៌ ដល់អ្នកដោយសេចក្តីពិស្តារក៏បាន ម្នាលវច្ឆៈ បើដូច្នោះ តថាគតនឹងសំដែងកុសលធម៌និងអកុសលធម៌ដល់អ្នកដោយសេចក្តីសង្ខេប ចូរអ្នកយកចិត្តទុកដាក់ស្តាប់ធម៌នោះដោយប្រពៃចុះ តថាគតនឹងសំដែង ។ វច្ឆគោត្តបរិព្វាជក ក៏បានទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះករុណាព្រះអង្គ ។

[ ១៥ ] ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលវច្ឆៈ លោភៈជា

អកុសល ម្នាលវច្ឆៈ អលោភៈជាកុសល ម្នាលវច្ឆៈ ទោសៈជាអកុសល ម្នាលវច្ឆៈ អទោសៈជាកុសល ម្នាលវច្ឆៈ មោហៈជាអកុសល ម្នាលវច្ឆៈ អមោហៈជាកុសល ម្នាលវច្ឆៈ ធម៌ទាំងអម្បាលនេះ ជាអកុសល ៣ ជាកុសល ៣ ដោយប្រការដូច្នេះ ។ ម្នាលវច្ឆៈ បាណាតិបាត ជាអកុសល ការវៀរចាកបាណាតិបាត ជាកុសល ម្នាលវច្ឆៈ អទិន្នាទាន ជាអកុសល ការវៀរចាកអទិន្នាទានជាកុសល ម្នាលវច្ឆៈ កាមេសុមិច្ឆាចារៈ ជាអកុសល ការវៀរចាកកាមេសុមិច្ឆាចារៈ ជាកុសល ម្នាលវច្ឆៈ មុសាវាទ ជាអកុសល ការវៀរចាកមុសាវាទ ជាកុសល ម្នាលវច្ឆៈ បិសុណវាចា ជាអកុសល ការវៀរចាកបិសុណវាចា ជាកុសល ម្នាលវច្ឆៈ ផរុសវាចា ជាអកុសល ការវៀរចាកផរុសវាចា ជាកុសល ម្នាលវច្ឆៈ សម្ផប្បលាបៈ ជាអកុសល ការវៀរចាកសម្ផប្បលាបៈ ជាកុសល ម្នាលវច្ឆៈ អភិជ្ឈា ជាអកុសល អនភិជ្ឈា ជាកុសល ម្នាលវច្ឆៈ ព្យាបាទជាអកុសល ការមិនព្យាបាទជាកុសល ម្នាលវច្ឆៈ មិច្ឆាទិដ្ឋិ ជាអកុសល សម្មាទិដ្ឋិ ជាកុសល ម្នាលវច្ឆៈ ធម៌ទាំងអម្បាលនេះ ជាអកុសល ១០ ជាកុសល ១០ ដោយប្រការដូច្នេះឯង ។ ម្នាលវច្ឆៈ កាលបើភិក្ខុបានលះបង់តណ្ហា បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើវត្ថុសម្រាប់កើតទៀត ឲ្យអស់រលីង ដូចជាដើមត្នោតដែលគេគាស់ក្របែលរម្លីង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅ ខាងមុខទៀតហើយ ភិក្ខុនោះឈ្មោះថា ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយធម៌បាន

នៅចប់ហើយ មានកិច្ចដែលគួរធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនដល់សព្វគ្រប់ហើយ មានសំយោជនៈ ដែលប្រព្រឹត្តទៅក្នុងភពអស់ហើយ ជាអ្នកដឹងច្បាស់ដោយប្រពៃ ជាអ្នកមានចិត្តផុតស្រឡះចាកកិលេស ។

[ ១៦ ] វច្ឆគោត្តបរិព្វាជក ក្រាបបង្គំទូលថា ព្រះគោតមដ៏ចម្រើន លើកទុកចុះ ចុះភិក្ខុមួយរូបជាសាវ័ករបស់ព្រះគោតមដ៏ចម្រើន បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ ម្នាលវច្ឆៈ តាមពិតមានច្រើនលើសប្រមាណណាស់ ពួកភិក្ខុជាសាវ័ករបស់តថាគត ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រះគោតមដ៏ចម្រើន លើកទុកចុះទាំងពួកភិក្ខុក៏លើកទុកចុះ ចុះភិក្ខុនីមួយរូបដែលជាសាវិការបស់ព្រះគោតមដ៏ចម្រើន បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ តាមពិតមានច្រើន

លើសប្រមាណណាស់ ពួកភិក្ខុនីដែលជាសាវិកាបេស់តថាគត បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[ ១៧ ] ព្រះគោតមដ៏ចម្រើន លើកទុកចុះ ទាំងពួកភិក្ខុភិក្ខុនីក៏លើកទុកដែរ ។ ចុះគ្រហស្ថជាឧបាសកម្នាក់ ដែលជាសាវ័ករបស់ព្រះគោតមដ៏ចម្រើន ស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ជាឱបបាតិកៈកំណើត នឹងបរិនិព្វានក្នុងទីនោះ មិនបានត្រឡប់ចាកលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈ ជាចំណែកខាងក្រោម ៥ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ តាមពិតមានច្រើនលើសប្រមាណណាស់ ពួកគ្រហស្ថដែលជាឧបាសក ជាសាវ័ករបស់តថាគត ស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ជាឱបបាតិកៈកំណើត នឹងបរិនិព្វានក្នុងទីនោះ មិនបានត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ ។ ព្រះគោតមដ៏ចម្រើនសូមលើកទុកចុះ ពួកភិក្ខុ ភិក្ខុនី ក៏លើកទុកចុះ ទាំងពួកគ្រហស្ថ ជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គលក៏លើកទុកដែរ ចុះគ្រហស្ថ ជាឧបាសកម្នាក់ ដែលជាសាវ័ករបស់ព្រះគោតមដ៏ចម្រើន ស្លៀកដណ្តប់ស ជាអ្នកបរិភោគកាម តែជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គល

ដទៃ ក្នុងសាសនារបស់ព្រះសាស្តា មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែន មានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ តាមពិតមានច្រើន លើសប្រមាណណាស់ ពួកគ្រហស្ថដែលជាឧបាសក ជាសាវករបស់តថាគត ស្លៀកដណ្តប់សនៅបរិភោគកាម តែជាអ្នកជឿតាមពាក្យប្រៀនប្រដៅ ធ្វើ តាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់ នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា ។ ព្រះគោតមដ៏ចម្រើន សូមលើកទុកចុះ ពួកភិក្ខុភិក្ខុនី ក៏លើកទុកចុះ ពួក គ្រហស្ថដែលជាឧបាសកស្លៀកដណ្តប់សជា សព្រហ្មចារីបុគ្គលក៏ លើកទុកចុះ ទាំងពួកគ្រហស្ថដែលជាឧបាសកស្លៀកពាក់ស នៅបរិភោគកាមក៏លើកទុក ដែរ ចុះគ្រហស្ថជាឧបាសិកាម្នាក់ ដែលជាសាវិការបស់ព្រះគោតមដ៏ចម្រើន ស្លៀកដណ្តប់ស ជាសព្រហ្មចារិនី ជាឱបបាតិកៈកំណើត នឹងបរិនិព្វានក្នុងទី នោះ មិនត្រឡប់អំពីលោកនោះ ជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈ ដែលជាចំណែកខាងក្រោម ៥ មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមាន ត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ តាមពិត មានច្រើនលើស ប្រមាណណាស់ គ្រហស្ថដែលជាឧបាសិកា ជាសាវិការបស់តថាគត ស្លៀកដណ្តប់ស ជាសព្រហ្មចារិនី ជាឱបបាតិកៈកំណើតនឹងបរិនិព្វានក្នុងទីនោះ មិនត្រឡប់អំពីលោកនោះជាធម្មតា ព្រោះអស់ទៅនៃសំយោជនៈជាចំណែក ខាងក្រោម ៥ ។ ព្រះគោតមដ៏ចម្រើន សូមលើកទុកចុះ ពួកភិក្ខុភិក្ខុនីក៏ លើកទុកចុះ ពួកគ្រហស្ថដែលជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារី

បុគ្គលក៏លើកទុកចុះ ពួកគ្រហស្ថដែលជាឧបាសកស្លៀកដណ្តប់ស ជាអ្នកបរិភោគកាមក៏លើកទុកចុះ ទាំងពួកគ្រហស្ថជាឧបាសិកាស្លៀកពាក់ស ជាសព្រហ្មចារិនីក៏លើកទុកដែរចុះ គ្រហស្ថជាឧបាសិកាម្នាក់ ដែលជាសាវិការបស់ព្រះគោតមដ៏ចម្រើន ស្លៀកដណ្តប់សនៅបរិភោគកាម ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ជាអ្នកធ្វើតាមឱវាទ ឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា មានដែរឬទេ ។ ម្នាលវច្ឆៈ មិនមែនមានត្រឹមតែ ១០០ ២០០ ៣០០ ៤០០ ៥០០ ទេ តាមពិត មានច្រើនលើសប្រមាណណាស់ ពួកគ្រហស្ថដែលជាឧបាសិកា ជាសាវិការបស់តថាគត ស្លៀក-ដណ្តប់សនៅបរិភោគកាម ជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅ ធ្វើតាមឱវាទ ប្រាសចាកសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃក្នុងសាសនារបស់ព្រះសាស្តា ។

[ ១៨ ] វច្ឆគោត្តបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះគោតមដ៏ចម្រើន នឹងបំពេញធម៌នេះតែមួយអង្គឯង ចំណែកខាងពួកភិក្ខុ មិនបានបំពេញ ( ធម៌នេះ ) ផងទេ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះ-គោតមដ៏ច្រើន លុះតែព្រះគោតមដ៏ចម្រើនបានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ ( ធម៌នេះ ) ដែរ កាលបើយ៉ាងនេះ ទើបព្រហ្មចរិយធម៌នេះបរិបូណ៌ ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះ

គោតមដ៏ចម្រើន នឹងបំពេញធម៌នេះ តែមួយព្រះអង្គឯង ចំណែកខាងពួកភិក្ខុក៏បានបំពេញដែរ តែពួកភិក្ខុនីមិនបានបំពេញផងទេ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ក៏នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតម-ដ៏ចម្រើន លុះតែព្រះគោតមដ៏ចម្រើន បានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ ទាំងពួកភិក្ខុនីក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។

[ ១៩ ] បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះគោតមដ៏ចម្រើន នឹងបានបំពេញធម៌នេះ ទាំងពួកភិក្ខុក៏បានបំពេញ ទាំងពួកភិក្ខុនីក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គលមិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចម្រើន លុះតែព្រះគោតមដ៏ចម្រើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះគោតមដ៏ចម្រើន នឹងបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថដែលជាឧបាសក ស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាមមិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូរណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចម្រើន លុះតែ

ព្រះគោតមដ៏ចម្រើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គលក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាអ្នកបរិភោគកាមក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូណ៌ ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះគោតម ដ៏ចម្រើនបានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គលក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាម ក៏បានបំពេញ តែពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស ជាសព្រហ្មចារិនី មិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ នឹងមិនបានបរិបូណ៌ដោយអង្គនោះ បពិត្រព្រះគោតមដ៏ចម្រើន លុះតែព្រះគោតមដ៏ចម្រើន ក៏បានបំពេញធម៌នេះ ពួកភិក្ខុក៏បានបំពេញ ពួកភិក្ខុនីក៏បានបំពេញ ពួកគ្រហស្ថជាឧបាសក ស្លៀក-ដណ្តប់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀក-ដណ្តប់ស នៅបរិភោគកាម ក៏បានបំពេញ ទាំងពួកគ្រហស្ថ ជាឧបាសិកាស្លៀកដណ្តប់ស ជាសព្រហ្មចារិនីក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្ម-ចរិយធម៌នេះ ទើបបរិបូណ៌ដោយអង្គនោះបាន ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើព្រះគោតមដ៏ចម្រើន បានបំពេញធម៌នេះ ពួកភិក្ខុក៏បំពេញ ពួកភិក្ខុនីក៏បំពេញ ពួកគ្រហស្ថជាឧបាសក ស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គលក៏បានបំពេញ ពួកគ្រហស្ថជា ឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាម

ក៏បានបំពេញ ទាំងពួកគ្រហស្ថ ជាឧបាសិកាស្លៀកដណ្តប់ស ជាសព្រហ្មចារិនី ក៏បានបំពេញ តែពួកគ្រហស្ថ ជាឧបាសិកាស្លៀកដណ្តប់ស ជាអ្នកនៅបរិភោគកាម មិនបានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ មិនបានបរិបូរណ៍ ដោយអង្គនោះទេ បពិត្រព្រះគោតមដ៏ចម្រើន លុះតែព្រះគោតមដ៏ចម្រើន ក៏បំពេញធម៌នេះ ពួកភិក្ខុក៏បំពេញ ពួកភិក្ខុនីក៏បំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស ជាសព្រហ្មចារីបុគ្គល ក៏បានបំពេញ ពួកគ្រហស្ថជាឧបាសកស្លៀកដណ្តប់ស នៅបរិភោគកាមក៏បានបំពេញ ពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស ជាសព្រហ្មចារិនីក៏បានបំពេញ ទាំងពួកគ្រហស្ថជាឧបាសិកាស្លៀកដណ្តប់ស នៅបរិភោគកាមក៏បានបំពេញ កាលបើយ៉ាងនេះ ព្រហ្មចរិយធម៌នេះ ទើបបរិបូរណ៍ដោយអង្គនោះបាន ។

[ ២០ ] បពិត្រព្រះគោតមដ៏ចម្រើន ដូចទន្លេគង្គា តែងមានទំនាបទៅរកសមុទ្រ មានទីជ្រាលទៅរកសមុទ្រ មានទីទេរទៅរកសមុទ្រ ទល់នឹងសមុទ្រទើបឈប់នៅ ( យ៉ាងណា ) បរិស័ទរបស់ព្រះគោតមដ៏ចម្រើននេះ ព្រមទាំងគ្រហស្ថនឹងបព្វជិត តែងមានទំនាបទៅរកព្រះនិព្វាន មានទីដ៏ជ្រាលទៅរកព្រះនិព្វាន មានទីទេរទៅរកព្រះនិព្វាន ដរាបទល់នឹងព្រះនិព្វាន ទើបឈប់បង្អង់ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ធម៌ដែលព្រះគោតមដ៏ចម្រើន ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាបុគ្គលផ្ងារឡើងនូវវត្ថុដែលគេផ្កាប់ចុះ ឬបើកនូវវត្ថុដែលគេបិទបាំងទុក ពុំនោះដូចគេប្រាប់ផ្លូវដល់

មនុស្សដែលវង្វេងផ្លូវ ពុំនោះសោតដូចគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សមានភ្នែកក្តី រមែងឃើញរូបទាំងឡាយក៏ដូច្នោះដែរ ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះគោតមមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គគប្បីបាននូវបព្វជ្ជានឹងឧបសម្បទា ក្នុងសំណាក់នៃព្រះ-គោតមដ៏ចម្រើន ។ ម្នាលវច្ឆៈ បុគ្គលណាដែលធ្លាប់ជាអន្យតិរ្ថិយមកអំពីមុនហើយ ប្រាថ្នាបព្វជ្ជា ឧបសម្បទា ក្នុងធម្មវិន័យនេះ បុគ្គលនោះត្រូវនៅបរិ-វាស អស់ ៤ ខែសិន លុះកន្លង ៤ ខែទៅ ទើបពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ក៏ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បីជាភិក្ខុភាព មួយទៀត ភាពផ្សេងគ្នានៃបុគ្គល ( ការដែលនៅបរិវាសឬមិនត្រូវនៅបរិវាស ) ក្នុងដំណើរនេះ តថាគតដឹងច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកជនដែលធ្លាប់ជាអន្យតិរ្ថិយមកអំពីមុនហើយ ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧប-សម្បទាក្នុងធម្មវិន័យនេះ ត្រូវតែនៅបរិវាសអស់ ៤ ខែសិន លុះកន្លង ៤ ខែទៅ ទើបពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីជាភិក្ខុភាពបាន ខ្ញុំព្រះអង្គនឹងនៅបរិវាសអស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំហើយ សូមឲ្យពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឲ្យឧបសម្បទា ដើម្បីជាភិក្ខុភាពចុះ ។ វច្ឆគោត្តបរិព្វាជក ក៏បាននូវបព្វជ្ជា បានឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។

[ ២១ ] គ្រាកាលវច្ឆគោត្តមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មានគឺបានឧបសម្បទាកន្លះខែ ( ប៉ុណ្ណោះ ) ក៏ចូលទៅគាល់ព្រះមានព្រះភាគ

លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ វច្ឆគោត្តមានអាយុ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សាមញ្ញផលមានប្រមាណប៉ុន្មាន ដែលបុគ្គលគប្បីដល់ ដោយញាណជារបស់សេក្ខបុគ្គល ដោយវិជ្ជាជារបស់សេក្ខបុគ្គល គឺអនាគាមិមគ្គ ខ្ញុំព្រះអង្គដល់ហើយដោយលំដាប់ សូមព្រះមានព្រះភាគ ទ្រង់សម្តែងនូវធម៌ឲ្យខ្ពស់ឡើងទៅ ( ដើម្បីអរហត្តផល ) ដល់ខ្ញុំព្រះអង្គ ។ ម្នាលវច្ឆៈ បើដូច្នោះអ្នកចូរចម្រើនធម៌ ២ ប្រការគឺ សមថៈនឹងវិបស្សនាឲ្យខ្ពស់ឡើងទៅចុះ ម្នាលវច្ឆៈ ធម៌ ទាំង ២ ប្រការនេះ គឺសមថៈ និងវិបស្សនា ដែលអ្នកចម្រើនឲ្យខ្ពស់ឡើង ហើយនឹងប្រព្រឹត្តទៅដើម្បីត្រាស់ដឹងនូវធាតុច្រើនប្រការ ។

[ ២២ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីបាននូវឫទ្ធិច្រើនប្រការ គឺជាមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់ក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាលទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏បាន ធ្វើនូវការងើបឡើង ឬមុជចុះក្នុងផែនដី ដូចជាងើបឡើងឬមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយ ហាក់ដូចដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ដូចជាសត្វសកុណជាតិដែលមានស្លាបក៏បាន អាត្មាអញគប្បីស្ទាបអង្អែល ចាប់ពាល់ ( មណ្ឌល ) ព្រះចន្ទ ព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាន ឬ

អាត្មាអញគប្បីប្រព្រឹត្តទៅទាំងកាយ រហូតដល់ព្រហ្មលោកនាយក៏បាន ។ កាលបើមានហេតុ អ្នកនឹងសម្រេចវិធីជាគ្រឿងសម្តែងឫទ្ធិ ជាគុណសម្បត្តិដែលត្រូវសិក្សាក្នុងសមថៈ នឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៣ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីឮសំឡេងទាំងពីរ ដោយសោតធាតុដ៏បរិសុទ្ធិដូចជាទិព្វ កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតា សំឡេងទាំង ២ នោះគឺអ្វីខ្លះ គឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលនៅក្នុងទីឆ្ងាយក្តី ទីជិតក្តី ។ កាលបើមានហេតុ អ្នកនឹងសម្រេចទិព្វស្រោត ជាគុណសម្បត្តិដែលត្រូវសិក្សាក្នុងសមថៈ នឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៤ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីកំណត់ដឹងនូវចិត្តរបស់សត្វដទៃ របស់បុគ្គលដទៃដោយចិត្តរបស់ខ្លួនបាន គឺចិត្ត ( របស់សត្វដទៃ ) ដែលប្រកបដោយរាគៈក្តី ក៏ដឹងថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈ ក៏ដឹងថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ចិត្តដែលមានអារម្មណ៍មូល ក៏ដឹងច្បាស់ថា ចិត្តមានអារម្មណ៍មូល ចិត្តដែលរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ គឺរូបាវចរ និងអរូបា

វិបរចិត្ត ចិត្តដែលមិនមែនជាមហគ្គតៈ ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈគឺលោកិយចិត្ត ក៏ដឹងច្បាស់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈគឺលោកុត្តរចិត្ត ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ចិត្តដែលតាំងនៅស៊ប់ដោយសមាធិ ក៏ដឹងច្បាស់ថា ចិត្តតាំងនៅស៊ប់ដោយសមាធិចិត្ត ដែលមិនតាំងនៅស៊ប់ដោយសមាធិ ក៏ដឹងថាចិត្តមិនតាំងនៅស៊ប់ ដោយសមាធិចិត្តដែលរួចចាកកិលេស ក៏ដឹងច្បាស់ថា ចិត្តរួចចាកកិលេស ចិត្តដែលមិនបានរួចចាកកិលេស ក៏ដឹងច្បាស់ថា ចិត្តមិនបានរួចចាកកិលេស ដូច្នេះ ។ កាលបើមានហេតុ អ្នកនឹងសម្រេចបរចិត្តវិជ្ជា ជាគុណសម្បត្តិ ដែលត្រូវសិក្សា ក្នុងសមថៈនឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៥ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីរលឹកឃើញនូវបុព្វេនិវាស គឺលំដាប់ខន្ធដែលសត្វនៅអាស្រ័យខាងដើមជាច្រើនប្រការ រលឹកខន្ធនោះដូចម្តេចខ្លះ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១០០០ ជាតិ ១០០០០០ ជាតិ រលឹកនូវសំវដ្តកប្បជាច្រើនក៏បាន វិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្បជាច្រើនក៏បាន ថាអាត្មាអញបានទៅកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏ទៅកើតក្នុងទីឯណោះ លុះអាត្មាអញបានកើតក្នុងទីនោះហើយ ក៏មានឈ្មោះយ៉ាងនេះ មានគោត្រ

យ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខ និងទុក្ខ យ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងទីនេះ អាត្មាអញគប្បីរលឹកឃើញ នូវបុព្វេ-និវាស ជាច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ កាលបើមានហេតុ អ្នកនឹងសម្រេចញាណជាគ្រឿងដឹងនូវខន្ធដែលអាស្រ័យនៅហើយក្នុងកាលមុន ជាគុណសម្បត្តិត្រូវសិក្សាក្នុងសមថៈនឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៦ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីមានចក្ខុដូចជាទិព្វ កន្លងហួសចក្ខុជារបស់មនុស្សធម្មតា ឃើញនូវពួកសត្វ ដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ អាត្មាអញគប្បីដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មថា អើហ្ន៎ ពួកសត្វទាំងនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវពួកព្រះអរិយ-បុគ្គល ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងអម្បាលនោះ លុះរំលាងកាយបន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកខាងពួកសត្វទាំងនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនបានតិះដៀលនូវពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ ពួកសត្វទាំងនោះ លុះរំលាងកាយបន្ទាប់អំពីមរណៈទៅ ក៏បានទៅកើត

ក្នុងសុគតិសួគ៌ទេវលោក ។ អាត្មាអញគប្បីមានចក្ខុដូចជាទិព្វដ៏ បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញនូវពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ អាត្មាអញគប្បីដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ដោយប្រការដូច្នេះ ។ កាលបើមានហេតុ អ្នកនឹងសម្រេចទិព្វចក្ខុញាណ ជាគុណសម្បត្តិដែលត្រូវសិក្សា ក្នុងសមថៈនឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៧ ] ម្នាលវច្ឆៈ អ្នកនោះប្រាកដជានឹងប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ នូវបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះក្ស័យអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ កាលបើមានហេតុ អ្នកនឹងសម្រេចនូវញាណ ក្នុងការអស់ទៅនៃអាសវៈ ជាគុណសម្បត្តិ ដែលត្រូវសិក្សា ក្នុងសមថៈនឹងវិបស្សនានោះៗ ជាប្រាកដ ។

[ ២៨ ] គ្រានោះ ព្រះវច្ឆគោត្តមានអាយុ ត្រេកអរីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមាន-ព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រាកាលដែលព្រះវច្ឆគោត្តមានអាយុ ចៀសចេញទៅតែម្នាក់ឯង ក៏ជាអ្នកមិនមានប្រមាទ ព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន មិនយូរប៉ុន្មានក៏បានដឹងច្បាស់នូវគុណវិសេសដ៏ប្រសើរ ជាទីបំផុតនៃព្រហ្មចរិយធម៌ ដែលពួកកុលបុត្រចេញចាកផ្ទះទៅបួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់គុណវិសេសណា ក៏ធ្វើឲ្យ

ជាក់ច្បាស់នូវគុណវិសេសនោះ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ទើបដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាន នៅចប់ហើយ កិច្ចដែលគួរធ្វើក៏បានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះមិន មានឡើយ ។ បណ្តាពួកព្រះអរហន្តទាំងឡាយ ព្រះវច្ឆគោត្តមានអាយុ ក៏ បានជាព្រះអរហន្តមួយអង្គដែរ ។

[ ២៩ ] សម័យនោះ ពួកភិក្ខុច្រើនរូប នាំគ្នាទៅគាល់ព្រះមានព្រះភាគ ។ វច្ឆគោត្តមានអាយុ បានឃើញពួកភិក្ខុទាំងនោះ កំពុងដើរទៅពីចម្ងាយ លុះ ឃើញហើយ ក៏ចូលទៅរកពួកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បាន និយាយនឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា បពិត្រលោកមានអាយុទាំងឡាយ ចុះលោកទាំងឡាយ នាំគ្នានិមន្តទៅក្នុងទីណា ។ ពួកភិក្ខុទាំងនោះក៏ប្រាប់ថា ម្នាលអាវុសោ យើងនឹងនាំគ្នាទៅគាល់ព្រះមានព្រះភាគ ។ វច្ឆគោត្តភិក្ខុក៏ បានផ្តាំថា បពិត្រលោកទាំងឡាយមានអាយុ បើដូច្នោះសូមលោកទាំងឡាយ ក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគ ដោយត្បូង តាមពាក្យរបស់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះវច្ឆគោត្តសូមក្រាបថ្វាយបង្គំព្រះបាទា ព្រះ មានព្រះភាគដោយត្បូង វច្ឆគោត្តភិក្ខុក្រាបទូលយ៉ាងនេះថា ព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានបម្រើហើយ ព្រះសុគតខ្ញុំព្រះអង្គបានបម្រើហើយ ។ ពួកភិក្ខុ ទាំងនោះ ក៏បានទទួលពាក្យវច្ឆគោត្តភិក្ខុមានអាយុថា អើអាវុសោ ។ ទើប ពួកភិក្ខុទាំងនោះ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ពួកភិក្ខុទាំងនោះ

លុះអង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន វច្ឆគោត្តមានអាយុ សូមក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយត្បូង ហើយក្រាបទូលយ៉ាងនេះទៀតថា ព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានបម្រើហើយ ព្រះសុគតខ្ញុំព្រះអង្គបានបម្រើហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលពីមុនមិញ តថាគតបានកំណត់ដឹងចិត្តវច្ឆគោត្តភិក្ខុ ដោយចិត្តរបស់តថាគតថា វច្ឆគោត្តភិក្ខុបានត្រៃវិជ្ជា ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ ទាំងពួកទេវតាក៏បានប្រាប់សេចក្តីនោះដល់តថាគតទៀតថា បពិត្រព្រះអង្គដ៏ចម្រើន វច្ឆគោត្តភិក្ខុបានត្រៃវិជ្ជាជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ។ លុះព្រះមានព្រះភាគបានត្រាស់ព្រះសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគដោយប្រការដូច្នេះ ។

## ចប់ មហាវច្ឆគោត្តសូត្រទី ៣

# អដ្ឋកថា

## មហាវច្ឆគោត្តសូត្រ

[ ១៤ ] មហាវច្ឆគោត្តសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សហាកថី** គឺឲ្យរឭកដល់វត្ថុដែលធ្វើហើយ បានបន្ទូលមេត្រីចំពោះគ្នាមកថា ខ្ញុំធ្លាប់ពោលជាមួយព្រះអង្គមកច្រើនហើយ ។ ព្រះមានព្រះភាគត្រាស់ពីរសូត្រមុន ដល់វច្ឆបរិញ្វជកនោះ ។ ត្រាស់អព្យាវដ្តសំយុត្ត ក្នុងសំយុត្តនិកាយដល់វច្ឆបរិញ្វជកនោះ ។ នៅមានសេចក្ដីដែលបរិញ្វជកនោះ ពោលជាមួយព្រះមានព្រះភាគទុកក្នុងអង្គុត្តរនិកាយយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន លោកទៀងឬហ្ន៎ វត្ថុនេះប៉ុណ្ណោះពិតវត្ថុដទៃមោឃៈ ព្រោះហេតុនោះ ព្រះអង្គមិនបានព្យាករសេចក្ដីនេះទុក ។ ព្រោះដូច្នោះ ទើបវច្ឆបរិញ្វជកពោលយ៉ាងនេះ ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ធ្វើការសង្គ្រោះ ទ្រង់បានឲ្យឱកាសដល់វច្ឆបរិញ្វជកនោះមករឿយៗ ព្រោះហេតុអ្វី ព្រោះវច្ឆបរិញ្វជកនេះ ជាសស្សតទិដ្ឋិ គឺមានការយល់ឃើញថា ទៀង ។ ម្យ៉ាងទៀត សស្សតទិដ្ឋិបុគ្គលទាំងឡាយ រមែងមិនលះលទ្ធិភ្លាមៗ ណា តែងបរិសុទ្ធបានដោយវេលាយូរ ដូចសំពត់សាច់រឹង ប្រឡាក់ខ្លាញ់ ។ ព្រះមានព្រះភាគឃើញថា បរិញ្វជកនេះ ទៅមកៗ នឹងលះលទ្ធិ ហើយបួសក្នុងសម្នាក់របស់តថាគត នឹងធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ នឹងជាអរិយសាវកអ្នកបានអភិញ្ញា ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគធ្វើការសង្គ្រោះ ទ្រង់ឲ្យឱកាសដល់វច្ឆបរិញ្វជកដែលមកហើយមកទៀត នេះជាការទៅចុងក្រោយ

របស់វច្ឆបរិព្វាជកនោះ ។ ព្រោះក្នុងសូត្រនេះ វច្ឆបរិព្វាជកនោះសម្រេចចិត្តថា ទោះរស់ ឬស្លាប់យ៉ាងណាក៏ដោយ អញនឹងទៅគាល់ព្រះគោតម ហើយនឹងបួស ដូចបុគ្គលស្ទូងឈើប្រត់ចូលទៅក្នុងទឹក ដូច្នោះ ។ ព្រោះហេតុនោះ វច្ឆបរិព្វាជក កាលនឹងទូលសូមព្រះធម្មទេសនា ទើបពោលពាក្យថា **សាធុ មេ ភវំ គោតមោ** ជាដើម ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទេសនាដោយសង្ខេប ដោយមូលនៃកុសល អកុសលយ៉ាងពិស្តារ ដោយកម្មបថ ។ ម្យ៉ាងទៀត ក្នុងទីនេះ ទេសនាដោយអំណាចមូល ទ្រង់សង្ខេបទុក ទេសនាដោយអំណាចកម្មបថ ទ្រង់សង្ខេបទុក ក៏ដូចទ្រង់សម្តែងដោយពិស្តារ ។ ម្យ៉ាងទៀតឈ្មោះថាទេសនាយ៉ាងពិស្តារ ដោយការសម្តែងរហូតអស់ មិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ព្រោះសមន្តប្បដ្ឋាន ២៤ និងមូលទាំងពួង ក៏ទ្រង់រមែងសង្ខេបចុះក្នុងអភិធម្មបិដក ៧ គម្ពីរ ដូច្នោះ គប្បីជ្រាបថា ទ្រង់សម្តែងដោយអំណាចមូលខ្លះ កម្មបថខ្លះ ។

[ ១៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **បាណាតិបាតា វេរមណី កុសលំ** ជាដើម ដូចតទៅនេះថា ។ កាមាវចរធម៌ ៧ តាមលំដាប់ធម៌ ៣ មានអនភិជ្ឈាជាដើម ប្រព្រឹត្តទៅក្នុងភូមិ ៤ រមែងគួរ ។ បទថា **យតោ ខោ វច្ឆ ភិក្ខុនោ** សេចក្តីថា ម្នាលវច្ឆៈ ព្រោះតណ្ហាដែលភិក្ខុលះបានហើយ អ្នកមិនបានកំណត់ទុកក៏ពិត តែគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់បទនេះទុក ទ្រង់សំដៅដល់ព្រះអគ្គបុណ្ណោះ ក្នុងជីវកសូត្រ ក្នុងចង្កីសូត្រ និងក្នុងសូត្រនេះ យ៉ាងនេះ ។

[ ១៦ ] បទថា **អត្ថិ បន** សេចក្តីថា វច្ឆៈទូលសួរថា ខ្ញុំព្រះអង្គសូមសួរថា នៅមានឬ ។ បានឮថា វច្ឆៈនោះមានលទ្ធិថា ក្នុងសាសនានោះមានសាស្តាប៉ុណ្ណោះជាអរហន្ត ។ ចំណែកសាវក ដែលអាចសម្រេចអរហត្តមិនមាន ។ ម្យ៉ាងទៀត ព្រះសមណគោតមត្រាស់ដូចការត្រាស់ជាមួយភិក្ខុមួយរូបថា **យតោ ខោ វច្ឆ ភិក្ខុនោ** ដូច្នេះ ។ វច្ឆៈ សួរដោយគិតថា អញនឹងសួរសេចក្តីនេះថា សាវករបស់ព្រះសមណគោតម សម្រេចអរហត្ត មានឬហ្ន៎ ។

ក្នុងបទទាំងនោះ បទថា **តិដ្ឋតុ** គឺព្រះគោតមចូរលើកទុក អធិប្បាយថា ព្រោះព្រះគោតមជាព្រះអរហន្តប្រាកដហើយក្នុងលោក ។ កាលព្រះអង្គព្យាករហើយ វច្ឆៈទូលសួរបញ្ហាជាប់ទាក់ទងនឹងភិក្ខុនីជាដើមតទៅ ។ សូម្បីព្រះមានព្រះភាគក៏ទ្រង់ព្យាករដល់វច្ឆៈ នោះហើយ ។

[ ១៨ ] បទថា **អារាធកោ** សេចក្តីថា អ្នកពេញចិត្ត អ្នកឲ្យសម្រេច អ្នកធ្វើឲ្យបរិបូណ៌ ។

[ ២១ ] បទថា **សេក្ខាយ វិជ្ជាយ បត្តព្វំ** គឺសម្រេចផល ៣ ខាងក្រោម ។ ព្រះមានព្រះភាគត្រាស់ថា ទាំងអស់នោះតថាគតសម្រេចហើយ ឯអាចារ្យដែលមានវាទៈ ក្រៅបវេណីពោលថា ភិក្ខុទាំងនោះសម្រេចអរហត្តប៉ុណ្ណោះ តែមិនសម្រេចផល ព្រោះពាក្យថា សេក្ខធម៌ដូចម្តេច មគ្គ ៤ មិនទាន់ដល់ទីបំផុត និង សាមញ្ញផល ៣ ក៏ជាខាងក្រោម ។ ដោយហេតុនោះ រមែងពោលដល់ សេចក្តីព្យាយាមឲ្យក្រៃលែងឡើងៗទៅ ដើម្បីសម្រេច

ផលនោះ ។ គួរឲ្យ បុគ្គលនោះដឹងយ៉ាងនេះថា បើនរៈណាលះកិលេសទាំង ៥ បានហើយ ជាព្រះសេក្ខៈបរិបូណ៌ មានធម៌មិនវិនាស ដល់នូវការជំនាញ ផូវចិត្តមានឥន្ទ្រិយ តាំងមាំ នរៈនោះឯង លោកពោលថា ជាអ្នកមានខ្លួន មាំទាំហើយ ។

ពិតហើយ ព្រះអនាគាមិបុគ្គល ជាព្រះសេក្ខៈ បរិបូណ៌ដោយចំណែក មួយ វច្ចៈពោលថា គប្បីសម្រេចវិជ្ជារបស់ព្រះសេក្ខៈ សំដៅដល់ព្រះអនាគាមិ បុគ្គលនោះ ។ ឈ្មោះថា ពាក្យសួរ រមែងមិនមានដល់បុគ្គលដែលតាំងនៅ ក្នុងអនាគាមិមគ្គនោះ ព្រោះមគ្គមានខណៈចិត្ត ១ ។ បើសួរថា ដោយសូត្រ នេះ សូម្បីមគ្គក៏មានច្រើនខណៈចិត្តដូច្នោះឬ ឆ្លើយថា ទុំះមិនមែនពុទ្ធវចនៈ ទាំងអត្ថនៃកថាដែលពោលហើយក៏ខុស។ ព្រោះដូច្នោះ គប្បីជ្រាបថា បុគ្គល តាំងនៅក្នុងអនាគាមិផលហើយ រមែងចម្រើនវិបស្សនា ដើម្បីអរហត្តមគ្គផង ដែរ ក៏ព្រោះអរហត្តមគ្គមិនបានជាឧបនិស្ស័យដល់សុទ្ធអរហត្តតែម្យ៉ាង រមែង ជាឧបនិស្ស័យដល់អភិញ្ញា ៦ ។ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា វច្ឆភិក្ខុនេះ ធ្វើកម្មក្នុងសមថៈយ៉ាងនេះហើយនឹងញ៉ាំងអភិញ្ញា ៥ ឲ្យកើត ធ្វើកម្មក្នុងវិបស្សនាហើយ ទើបសម្រេចអរហត្ត នឹងជាសាវកដែលបាន អភិញ្ញា ៦ យ៉ាងនេះ ទើបទ្រង់មិនពោល ត្រឹមវិបស្សនា ទ្រង់ប្រាប់ទាំងសមថៈ និង វិបស្សនា ។

[ ២៤ ] បទថា **សតិ សតិ អាយតនេ** គឺកាលហេតុមាន ហេតុក្នុងទី នេះ គឺអ្វី ។ គប្បីជ្រាបថា ឈាន ដែលជាបាទនៃអភិញ្ញាក្តី ព្រះអរហត្តក្នុងទី

បំផុតក្តី វិបស្សនាដើម្បីអរហត្តក្តី ឈ្មោះថា ជាហេតុ ។

[ ២៩ ] បទថា **បរិចិណ្ណោ មេ ភគវា** សេចក្តីថា ពិតហើយ ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា ជាអ្នកបម្រើព្រះមានព្រះភាគ ។ ព្រះមានព្រះភាគជាបុគ្គលដែលព្រះខីណាស្រពបម្រើហើយ ដោយប្រការដូច្នេះ ។ ព្រះថេរៈកាលព្យាករអរហត្តដោយសង្ខេប ទើបពោលយ៉ាងនេះ ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះមិនដឹងសេចក្តីនោះ ។ កាលមិនដឹង ក៏មិនទទួលពាក្យរបស់ព្រះថេរៈនោះ ទើបនាំគ្នាទៅក្រាបទូលព្រះមានព្រះភាគ ។ បទថា **ទេវតា** បានដល់ ទេវតាដែលបានគុណទាំងនោះ ។ បទដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ។

**អដ្ឋកថាមហាវច្ឆគោត្តសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ទីឃនខសូត្រទី ៤

[ ៣០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងគុហាឈ្មោះសូករខតា នាភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះ មានបរិព្វាជកម្នាក់ឈ្មោះទីឃនខៈ ( ជាអគ្គិវេស្សនគោត្ត ) ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ។ ទីឃនខបរិព្វាជក លុះឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានវាទៈយ៉ាងនេះ មានទិដ្ឋិ យ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញ ( អាត្មាអញមិនពេញចិត្ត ទាំងអស់ ) ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអគ្គិវេស្សនៈ សេចក្តីឃើញណារបស់អ្នក ថារបស់ទាំងអស់មិនគួរដល់អាត្មាអញ សេចក្តីឃើញ នុ៎ះមិនគួរដល់អ្នកទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើសេចក្តីឃើញ នុ៎ះគួរដល់ខ្ញុំសោត ទោះនរណាៗ ក៏ត្រូវឃើញដូច្នោះឯង ទោះនរណាៗ ក៏ត្រូវឃើញដូច្នោះឯង ។ ម្នាលអគ្គិវេស្សនៈ ពួកជនណាដែលនិយាយយ៉ាងនេះថា ទោះនរណាៗ ក៏ត្រូវឃើញដូច្នោះឯង ទោះនរណាៗ ក៏ត្រូវឃើញដូច្នោះឯង ពួកជននោះក្នុងលោក មានច្រើនជាងនេះទៅទៀត តែពួកជននោះមិនលះបង់ទិដ្ឋិនោះចេញ ហើយគេប្រកាន់មាំចំពោះទិដ្ឋិដទៃតទៅទៀត ។ ម្នាលអគ្គិវេស្សនៈ

ពួកជនណានិយាយយ៉ាងនេះថា ទោះនរណាៗ ក៏ត្រូវឃើញ ដូច្នោះឯង ទោះនរណាៗ ក៏ត្រូវឃើញដូច្នោះឯង ពួកជននោះក្នុងលោក មានចិត្តតិចតួចជាងនេះណាស់ តែពួកជននោះគេលះបង់ទិដ្ឋិនោះចេញបាន ទាំងមិនប្រកាន់ទិដ្ឋិដទៃតទៅទៀតផង ។

[ ៣១ ] ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញ ( អាត្មាអញពេញចិត្តទាំងអស់ ) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញ ( អាត្មាអញ មិនពេញចិត្តទាំងអស់ ) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ ( អាត្មាអញពេញចិត្តខ្លះ មិនពេញចិត្តខ្លះ ) ក៏មាន ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញ ទិដ្ឋិនេះរបស់ពួកសមណព្រាហ្មណ៍នោះ តែងប្រព្រឹត្តទៅក្នុងទីជិត នៃហេតុដែលប្រកបដោយរាគៈ ក្នុងជិតនៃសំយោគៈ ក្នុងទីជិតនៃតម្រេក ក្នុងទីជិតនៃសេចក្តីងប់ចិត្ត ក្នុងទីជិតនៃសេចក្តីប្រកាន់មាំ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរ ដល់អាត្មាអញ ទិដ្ឋិនេះរបស់ពួក សមណព្រាហ្មណ៍ទាំងនោះ ប្រព្រឹត្តទៅ

ក្នុងទីជិត នៃហេតុមិនមែនរាគៈ ក្នុងទីជិតនៃហេតុ មិនមែនជាសំយោគៈ ក្នុងទីជិតនៃហេតុមិនមែនជាតម្រេក ក្នុងទីជិតនៃសេចក្តីមិនងប់ចិត្តក្នុងទីជិត នៃសេចក្តីមិនប្រកាន់មាំ ។ កាលដែលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ ទីឃនខបរិញ្ជក បានក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា ព្រះគោតមដ៏ចម្រើន លើកតម្កើងនូវសេចក្តីឃើញរបស់ខ្ញុំព្រះអង្គ ព្រះគោតមដ៏ចម្រើនទ្រង់លើកតម្កើងនូវសេចក្តីឃើញរបស់ខ្ញុំព្រះអង្គ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ ក៏ទិដ្ឋិណាដែលគួរ ដល់សមណព្រាហ្មណ៍នោះ ទិដ្ឋិនោះប្រព្រឹត្តទៅក្នុងទីជិតនៃហេតុដែលប្រកបដោយរាគៈ ក្នុងទីជិតនៃសំយោគៈ ក្នុងទីជិតនៃតម្រេក ក្នុងទីជិតនៃសេចក្តីងប់ចិត្ត ក្នុងទីជិតនៃសេចក្តីប្រកាន់មាំ មួយយ៉ាងទៀត ទិដ្ឋិណាដែលមិនគួរដល់សមណព្រាហ្មណ៍នោះ ទិដ្ឋិនោះរមែងប្រព្រឹត្តទៅ ក្នុងទីជិតនៃហេតុមិនមែនជារាគៈ ក្នុងទីជិតនៃហេតុមិនមែនជាសំយោគៈ ក្នុងទីជិតនៃហេតុមិនមែនជាតម្រេក ក្នុងទីជិតនៃសេចក្តីមិនងប់ចិត្ត ក្នុងទីជិតនៃសេចក្តីមិនប្រកាន់មាំ ។

[ ៣២ ] ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញ វិញ្ញូបុរស តែងពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាងនេះថា សេចក្តីឃើញរបស់អាត្មាអញណាថា របស់ទាំងអស់គួរដល់អាត្មាអញ

ប្រសិនបើអាត្មាអញ ស្ទាបអង្អែលប្រកាន់ខ្ជាប់ទិដ្ឋិនេះ ហើយនិយាយតាមកម្លាំងចិត្តដោយមួនមាំថា នេះជារបស់ពិត របស់ដទៃជាមោឃៈ អាត្មាអញក៏នឹងប្រកាន់ខុសចាក សមណព្រាហ្មណ៍ទាំងពីរពួក គឺសមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញពួក ១ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញពួក ១ អាត្មាអញនឹងប្រកាន់ខុសចាក សមណព្រាហ្មណ៍ទាំងពីរពួកនេះឯង ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលការទាស់ទែងគ្នាមានហើយ សេចក្តីគុំកួនគ្នាក៏មាន កាលសេចក្តីគុំកួនគ្នាមានហើយ សេចក្តីបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរសនោះ ពិចារណាឃើញច្បាស់នូវសេចក្តីប្រកាន់ខុស សេចក្តីទាស់ទែងគ្នា សេចក្តីគុំកួនគ្នា នឹងសេចក្តីបៀតបៀន ( ថាជាទោសមាន ) ក្នុងខ្លួនដោយប្រការដូច្នេះហើយ ក៏លះបង់ទិដ្ឋិនោះចេញផង មិនបានប្រកាន់ ទិដ្ឋិឯទៀតផង ។ ការលះបង់នូវទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំងនោះតែងមានដោយប្រការយ៉ាងនេះ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាលនោះ ពួកសមណព្រាហ្មណ៍ណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញ វិញ្ញូបុរស តែងពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាងនេះថា សេចក្តីយល់របស់អាត្មាអញណាថា របស់ទាំងអស់មិនគួរដល់អាត្មាអញ ប្រសិនបើអាត្មាអញស្ទាប អង្អែលប្រកាន់ខ្ជាប់ទិដ្ឋិនេះ ហើយនិយាយតាមកម្លាំងចិត្តដោយមាំមួន

ថា នេះជារបស់ពិត របស់ដទៃជាមោឃៈ អាត្មាអញក៏នឹងប្រកាន់ខុស ចាក សមណព្រាហ្មណ៍ទាំងពីរពួក គឺ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញពួកមួយ សមណព្រាហ្មណ៍ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ ខ្លះមិនគួរដល់អាត្មាអញពួកមួយ អាត្មាអញក៏នឹងប្រកាន់ខុសចាកសមណ- ព្រាហ្មណ៍ទាំង ២ ពួកនេះឯង ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលការទាស់ទែងគ្នាមានហើយ សេចក្តីគុំកួនគ្នាក៏មាន កាលសេចក្តីគុំកួនគ្នាមានហើយ ការបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរស នោះ ពិចារណាឃើញច្បាស់នូវសេចក្តីប្រកាន់ខុស សេចក្តីទាស់ទែងគ្នា សេចក្តី គុំកួនគ្នា និងសេចក្តីបៀតបៀនគ្នា ( ថាជាទោសមាន ) ក្នុងខ្លួន ដោយប្រការ ដូច្នេះហើយ ក៏លះបង់នូវទិដ្ឋិនោះចេញផង មិនប្រកាន់ទិដ្ឋិឯទៀតផង ។ ការ លះបង់ទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំង នោះតែងមានដោយប្រការយ៉ាងនេះ ។ ម្នាលអគ្គិវេស្សនៈ ក្នុងទិដ្ឋិអម្បាល នោះ ពួកសមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ វិញ្ញូបុរសតែង ពិចារណាឃើញក្នុងទិដ្ឋិនោះយ៉ាងនេះថា សេចក្តីឃើញរបស់អាត្មាអញណាថា របស់ខ្លះគួរដល់អាត្មាអញ របស់ខ្លះមិនគួរដល់អាត្មាអញ ប្រសិនបើអាត្មាអញ ស្ទាបអង្អែលប្រកាន់ខ្ជាប់ទិដ្ឋិនេះ ហើយនិយាយតាមកម្លាំងចិត្តដោយមាំមួនថា នេះជារបស់ពិត របស់ដទៃជាមោឃៈ អាត្មាអញក៏នឹងប្រកាន់ខុស ចាកសមណ

ព្រាហ្មណ៍ទាំង ២ ពួកគឺ សមណព្រាហ្មណ៍ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់គួរដល់អាត្មាអញពួក ១ សមណព្រាហ្មណ៍មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា របស់ទាំងអស់មិនគួរដល់អាត្មាអញពួក ១ អាត្មាអញក៏នឹងប្រកាន់ខុស ចាកសមណព្រាហ្មណ៍ទាំង ២ ពួកនេះ ដោយប្រការដូច្នេះ ។ កាលបើប្រកាន់ខុសយ៉ាងនេះមានហើយ ការទាស់ទែងគ្នាក៏មាន កាលបើការទាស់ទែងគ្នាមានហើយ សេចក្តីគុំកួនក៏មាន កាលបើសេចក្តីគុំកួនមានហើយ សេចក្តីបៀតបៀនគ្នាក៏មាន ។ កាលវិញ្ញូបុរសនោះពិចារណា ឃើញច្បាស់នូវសេចក្តីប្រកាន់ខុស សេចក្តីទាស់ទែងគ្នា សេចក្តីគុំកួនគ្នា និងសេចក្តីបៀតបៀន ( ថាជាទោសមាន ) ក្នុងខ្លួន ដោយប្រការដូច្នេះហើយ ក៏លះបង់នូវទិដ្ឋិនោះចេញផង មិនប្រកាន់ទិដ្ឋិឯទៀតផង ។ ការលះបង់នូវទិដ្ឋិទាំងនុ៎ះ តែងមានដោយប្រការយ៉ាងនេះ ការរលាស់ចោលនូវទិដ្ឋិទាំងនុ៎ះ តែងមានដោយ ប្រការយ៉ាងនេះ ។

[ ៣៣ ] ម្នាលអគ្គិវេស្សនៈ ក៏ឯកាយនេះមានរូបជាទីប្រជុំនៃមហាភូតទាំង ៤ ( ដី ទឹក ភ្លើង ខ្យល់ ) កើតមកអំពីមាតាបិតា ចម្រើនឡើងដោយបាយនឹងនំកុម្មាស មានការមិនទៀង មានការគក់ប្របាច់ ការដុសខាត់មន្ទិលក្លិនស្អុយ ការបែកធ្លាយនឹងការរាត់រាយទៅជាធម្មតា បុគ្គលគួរពិចារណាឃើញច្បាស់ ដោយសភាពជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្តីលំបាក ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ ។ កាលបុគ្គលនោះពិចារណា

ឃើញច្បាស់នូវកាយនេះថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ថាបីដូចជាបូស ថាបីដូចជាកូនសរ ជាសេចក្តីលំបាក ជាជំងឺ ជារបស់អ្នកដទៃ ជារបស់វិនាសសាបសូន្យ មិនមែនខ្លួនប្រាណ សេចក្តីប្រាថ្នាក្នុងកាយ នឹងសេចក្តីអាល័យកាយ ទាំងកិលេសដែលប្រព្រឹត្តទៅតាមកាយណា កិលេសតណ្ហានោះ គេក៏លះបង់បាន ។

[ ៣៤ ] ម្នាលអគ្គិវេស្សនៈ វេទនានេះមាន ៣ ប្រការគឺ សុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលសុខវេទនា សម័យនោះ មិនទទួលទុក្ខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ ក្នុងសម័យនោះ ទទួលចំពោះតែសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលទុក្ខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលអទុក្ខមសុខវេទនាទេ សម័យនោះទទួលចំពោះតែទុក្ខវេទនា ។ ម្នាលអគ្គិវេស្សនៈ សម័យណា បុគ្គលទទួលអទុក្ខមសុខវេទនា សម័យនោះ មិនទទួលសុខវេទនា មិនទទួលទុក្ខវេទនាទេ សម័យនោះ ទទួលចំពោះ តែអទុក្ខមសុខវេទនា ។ ម្នាលអគ្គិវេស្សនៈ សុខវេទនាជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើងហើយ មានកិរិយាអស់ទៅនឹងសូន្យទៅជាធម្មតា មានកិរិយាក្ស័យទៅ ទាំងមានកិរិយារលត់វិញទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ ទុក្ខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែង កើតឡើងហើយ តែងអស់ទៅនឹងសូន្យទៅជាធម្មតា មានកិរិយាក្ស័យទៅ ទាំងមានកិរិយារលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ សូម្បីអទុក្ខម

សុខវេទនា ក៏ជារបស់មិនទៀង ជារបស់ដែលសង្ខារតាក់តែងកើតឡើង ហើយតែងអស់ទៅ និងសូន្យទៅជាធម្មតា មានកិរិយាក្សាយទៅ និងរលត់ទៅជាធម្មតា ។ ម្នាលអគ្គិវេស្សនៈ អរិយសាវកអ្នកបានស្តាប់ហើយ កាលឃើញយ៉ាងនេះ រមែងនឿយណាយចាកសុខវេទនាផង នឿយណាយចាកទុក្ខវេទនាផង នឿយណាយចាកអទុក្ខមសុខវេទនាផង កាលបើនឿយណាយហើយរមែង ប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចចាកកិលេសកាល ចិត្តរួចចាកកិលេសហើយ ញាណក៏កើតឡើងច្បាស់ថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលគួរធ្វើបានធ្វើរួចស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានឡើយ ។ ម្នាលអគ្គិវេស្សនៈ ភិក្ខុដែលមានចិត្តផុតស្រឡះយ៉ាងនេះ រមែងមិននិយាយផ្សំ នឹងអ្នកណាៗ មិននិយាយទទឹងទាស់នឹងអ្នកណាៗ វាចាណាដែលគេនិយាយ ហើយក្នុងលោកក៏ពោលទៅតាមវាចានោះ តែមិនបានស្ទាបអង្អែល ( ដោយទិដ្ឋិ ) ។

[ ៣៥ ] សម័យនោះឯង ព្រះសារីបុត្តមានអាយុ គង់ខាងព្រះប្រឹស្ដាង្គនៃព្រះមានព្រះភាគ បក់ថ្វាយព្រះមានព្រះភាគ ។ ក្នុងលំដាប់នោះ ព្រះសារីបុត្តមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា បានឮថា ព្រះមានព្រះភាគទ្រង់ត្រាស់ការលះបង់នូវពួកធម៌នោះៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ បានឮថាព្រះសុគត ទ្រង់ត្រាស់ការរលាស់ចោលនូវពួកធម៌នោះ ៗ ដោយប្រាជ្ញាដ៏ក្រៃលែង ដល់យើងទាំងឡាយ ។ កាលព្រះសារីបុត្តមានអាយុ កំពុងពិចារណាហេតុនេះ ស្រាប់តែចិត្តលោកក៏ផុតស្រឡះចាកអាសវៈ

ទាំងឡាយ ព្រោះមិនប្រកាន់មាំដោយប្រការដូច្នេះ ។ ធម្មចក្ខុដែលប្រាសចាក ធូលី ប្រាសចាកមន្ទិលបានកើតឡើងហើយ ដល់ទីឃនខបរិញ្វជកថា ធម្មជាត អ្វីមួយ មានសេចក្តីកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅ វិញជាធម្មតា ។

[ ៣៦ ] គ្រានោះ ទីឃនខបរិញ្វជក បានឃើញធម៌ហើយ បានដល់ ធម៌ហើយ បានដឹងច្បាស់នូវធម៌ហើយ មានចិត្តចុះស៊ប់ក្នុងធម៌ហើយ ឆ្លង ផុតសេចក្តីសង្ស័យហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ ជាហេតុពោលថាអ្វីៗ ដល់នូវសេចក្តីក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនារបស់ព្រះសាស្តា បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់ប្រកាសហើយ ដោយអនេកបរិ- យាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញវត្ថុដែលបិទបាំង ទុក ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោតដូចជាមនុស្ស កាន់ប្រទីប ទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក ( ភ្លឺ ) មើល ឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើនជ្រាបនូវខ្ញុំព្រះអង្គ ថា ជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតទៅ ។

**ចប់ ទីឃនខសូត្រទី ៤**

# អដ្ឋកថា

## ទីឃនខសូត្រ

[ ៣០ ] ទីឃនខសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សូករខាតាយំ** គឺក្នុងគុហាមានឈ្មោះយ៉ាងនេះ ថា សូករខាតា ។ មានរឿងពោលទុកថា កាលសាសនាព្រះសម្មាសម្ពុទ្ធកស្សប គុហានោះ កើតក្នុងផ្ទៃដីដែលដុះឡើងក្នុងពុទ្ធន្តរមួយ ។ តមកថ្ងៃមួយ ជ្រូក មួយក្បាលឈ្ងុសធូលីក្នុងទីក្បែរមាត់គុហានោះ ។ កាលភ្លៀងធ្លាក់បានប្រាកដ ខេត្តបិទ ព្រោះត្រូវភ្លៀងប្រោះ ព្រានព្រៃម្នាក់ឃើញ ទើបគាត់គិតថា កាលមុន មិនមានអ្នកមានសីលនៅក្នុងគុហា អញនឹងរៀបចំគុហានោះ ទើបជញ្ជូនធូលីចេញ បោសគុហាឲ្យស្អាត ហើយធ្វើជញ្ជាំងជុំវិញ ប្រកបដោយទ្វារ និងបង្អួច ធ្វើគុហាឲ្យមានបរិវេណ ក្រាលដោយខ្សាច់ដូចផែនប្រាក់ ធ្វើយ៉ាងវិចិត្រ បូកបាយអរហូតសម្រេចរៀបរយយ៉ាងល្អ ហើយដាក់គ្រែ និងតាំងថ្វាយជាទីប្រថាប់របស់ព្រះមានព្រះភាគ គុហាជ្រៅ ឡើងចុះស្រួល ។ បទថា **សូករខាតាយំ** នេះ លោកពោលសំដៅដល់គុហានោះ ។ បទថា **ទីឃនខោ** គឺ ជាឈ្មោះបរិព្វាជកនោះ ។ បទថា **ឧបសង្កមិ** គឺ ចូលទៅគាល់ ព្រោះហេតុអ្វីទើបទីឃនខបរិព្វាជកចូលទៅគាល់ បានឮថា ទីឃនខបរិព្វាជកនោះ កាលព្រះថេរៈបួសបានកន្លះខែ គិតថា លោកអ៊ំរបស់អញចូលទៅកាន់លទ្ធិដទៃដែលខុស ហើយតាំងនៅអស់កាលដ៏យូរ ។ តែឥឡូវនេះ កាលលោកអ៊ំទៅគាល់ព្រះសមណគោតមបានកន្លះខែហើយ បំណងនឹងទៅ ដោយសង្ឃឹមថា អញ

នឹងដឹងដំណើររបស់លោកអំនោះ ។ អញនឹងដឹងពាក្យប្រៀនប្រដៅដ៏វុនរឿន នោះហ្ន៎ ព្រោះដូច្នោះ ទើបទីឃនខៈចូលទៅគាល់ ។ បទថា **ឯកមន្តំ ឋិតោ** គឺ បានឈរនៅក្នុងទីសមគួរ នាចំណែកម្ខាង បានឮថា ក្នុងខណៈនោះ ព្រះថេរៈឈរបក់ផ្លិតថ្វាយព្រះមានព្រះភាគ ។ បរិព្វាជកដោយមានហិរិឱត្តប្បៈក្នុងលោកអំ ទើបឈរសួរបញ្ហា ដោយហេតុនោះ ទើបលោកពោលថា **ឯកមន្តំ ឋិតោ** ដូច្នេះ ។ បទថា **សព្វំ មេ ន ខមតិ** គឺវត្ថុដែលកើតឡើងទាំងអស់មិនគួរដល់ខ្ញុំ ។ បរិព្វាជកពោលដោយបំណងថា បដិសន្ធិទាំងឡាយមិនគួរ ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ ឈ្មោះថា បរិព្វាជកនោះសម្តែងថា ខ្ញុំជាអ្នកមានវាទៈថា ដាច់សូន្យ តែព្រះមានព្រះភាគ កាលទ្រង់ផ្អាកនូវបំណងរបស់បរិព្វាជកនោះហើយ ទ្រង់សម្តែងដល់ទោសក្នុងការមិនគួរ ទើបត្រាស់ព្រះតម្រាស់ថា **យាបិ ខោ តេ** ជាដើម ដូច្នេះ ។ ក្នុងបទនោះមានសេចក្តីថា សូម្បីការឃើញរបស់អ្នក ក៏មិនគួរ គឺការឃើញដែលអ្នក ពេញចិត្ត កាន់យកគ្រាដំបូងក៏មិនគួរ ។ បទថា **ឯសា ចេ មេ ភោ គោតម ទិដ្ឋិ ខមេយ្យ** សេចក្តីថា បើការឃើញថា វត្ថុទាំងពួងមិនគួរដល់ខ្ញុំ នៃខ្ញុំដែលឃើញថា ព្រោះវត្ថុទាំងពួងមិនគួរដល់ខ្ញុំ គប្បីគួរសោត ទើបលោកពោលថា **សព្វំ មេ ន ខមតិ** ។ សូម្បីការឃើញនោះក៏គប្បីដូច្នោះ ។ សូម្បីការឃើញនោះក៏គួរ ដូចការឃើញនេះ សូម្បីកាន់យកដោយការកាន់យកវត្ថុទាំងពួង ដូច្នោះ ។ បរិព្វាជកពោលដោយយល់ថា អញដឹងទោសដែលលើកក្នុងវាទៈរបស់ខ្លួនឡើងយ៉ាងនេះហើយ រក្សាវាទៈនោះ ។ តែដោយ

អត្ថ រមែងទទួលថា ការឃើញរបស់បរិព្វាជកនោះ មិនគួរដល់តថាគត ដូច្នេះ ។ ម្យ៉ាងទៀត វត្ថុទាំងពួងមិនប្រពៃដល់តថាគត ដោយការឃើញនោះរបស់បុគ្គលដែលមានការឃើញមិនគួរ មិនប្រពៃ ព្រោះហេតុនោះ ទើបជាការដែលប្រពៃ ។ សូម្បីបុគ្គលនោះគប្បីជាអ្នកមិនគួរមិនពេញចិត្ត ព្រោះហេតុនោះ ទើបទទួលបានថា វត្ថុទាំងពួងរមែងគួរ រមែងពេញចិត្ត តែបរិព្វាជកនោះមិនទទួលសេចក្តីនោះ ។ រមែងកាន់យកការដាច់សូន្យនៃឧច្ឆេទទិដ្ឋិនោះតែម្យ៉ាងប៉ុណ្ណោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឥតោ ខោ តេ អគ្គិវេស្សន ។បេ។ អញ្ញញ្ច ទិដ្ឋឹ ន ឧបាទិយន្តិ** សេចក្តីថា ម្នាលអគ្គិវេស្សនៈ ជនក្នុងលោកដែលពោលយ៉ាងនេះថា សូម្បីការឃើញនោះ ក៏គប្បីដូច្នោះទាំងអស់ ការឃើញនោះក៏គប្បី ដូច្នោះទាំងអស់ ដូច្នេះ ជនទាំងនោះលះការឃើញនោះមិនបាន និងនៅប្រកាន់ ការឃើញដទៃច្រើនជាង គឺច្រើនជាងបុគ្គលដែលលះបាន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ឥតោ** ជាបញ្ចមីវិភត្តិ ចុះក្នុងអត្ថថា ជាអ្នកលះបាន ។ សេចក្តីថា បុគ្គលពួកណាលះបាន បុគ្គលទាំងនោះនឹងសួរថា បុគ្គលពួកណាហ្ន៎លះមិនបាន ។ ហើយបុគ្គលទាំងនោះឯងមានច្រើនជាង ។ **ហិ** អក្ខរៈក្នុងបទនេះថា **ពហូ ហិ ពហុតរា** ប្រែថា មានច្រើន គឺច្រើនជាងនេះ ត្រឹមតែជានិបាត អធិប្បាយថា ច្រើនជាង ច្រើនជាង ។ សូម្បីក្នុងបទថា **តនូ ហិ តនុត្តរា** មានតិច គឺតិចជាង ដែលជាបទក្រោយក៏មានន័យដូចគ្នា ។ បទថា **យេ ឯវមាហំសុ** គឺជនពួកណាពោលហើយយ៉ាងនេះ ។ បទថា **តំ**

**ចេវ ធិដ្ឋី ។បេ។ ឧចាធិយន្តិ** គឺ ជនទាំងនោះ លះការឃើញនោះមិនបាន និង នៅប្រកាន់ការឃើញដទៃនោះ គឺមិនទាន់លះការឃើញខាងដើមបាន ។ នៅប្រកាន់ការឃើញដទៃទៀត ។ម្យ៉ាងទៀត ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះថា ប្រកាន់ សូម្បីការទៀងហើយ ក៏មិនលះការទៀងនោះ មិនអាចនឹងប្រកាន់ការដាច់សូន្យ ការទៀងណាមួយបាន សូម្បីប្រកាន់ការដាច់សូន្យហើយ ក៏មិនលះការដាច់សូន្យនោះ មិនអាចប្រកាន់ការទៀង ឬការទៀងណាមួយបាន ។ ប្រកាន់ការទៀងណាមួយហើយ មិនលះការទៀងនោះ មិនអាចប្រកាន់ការទៀង ឬការដាច់សូន្យបាន ។ ម្យ៉ាងទៀត មិនលះការទៀងដើម អាចទាញយកការទៀងដទៃបានដូចម្តេច ។ ព្រោះសម័យមួយ ប្រកាន់ថា រូបទៀង ហើយសម័យតមក មិនប្រកាន់រូបសុទ្ធៗ ប៉ុណ្ណោះថា ទៀង សូម្បីវេទនាក៏ទៀង សូម្បីវិញ្ញាណក៏ទៀង ។ ក្នុងការដាច់សូន្យក្តី ក្នុងការទៀងណាមួយក្តី ក៏មានន័យនេះដូចគ្នា ។ គប្បីយល់ថា សូម្បីក្នុងអាយតនៈក៏ដូចក្នុងខន្ធ ។ លោកពោលបទថា **តំ ចេវ ធិដ្ឋី ។បេ។ ឧចាធិយន្តិ** លះនូវការឃើញនោះមិនបាន និងនៅប្រកាន់ការឃើញដទៃ ដូច្នេះ សំដៅដល់សេចក្តីនេះ ។

គប្បីជ្រាបក្នុងវារៈទី ២ ដូចតទៅនេះ ។ បទថា **អគោ** ជាបញ្ចមីវិភត្តិចុះក្នុងអត្ថថា លះមិនទាន់បាន បុគ្គលណាលះមិនទាន់បាន ព្រោះដូច្នោះ បុគ្គលនោះ នឹងសួរថា បុគ្គលណាលះបាន បុគ្គលនោះឯងមានតិចជាង ។ បទថា **តំ ចេវ ធិដ្ឋី ។បេ។ ឆ ឧចាធិយន្តិ** ជនទាំងនោះលះការឃើញនោះបាន

និងមិនប្រកាន់ការឃើញដទៃ សេចក្ដីថា លះទិដ្ឋិដើមនោះបាន និងមិនកាន់យកទិដ្ឋិដទៃ ។ សេចក្ដីនេះដូចម្ដេច ព្រោះក្នុងសម័យមួយ ប្រកាន់ថា រូបទៀង ហើយសម័យតមក ឃើញទោសក្នុងទិដ្ឋិនោះ ហើយលះបាន ដោយគិតថា ទិដ្ឋិរបស់អញនេះគ្រោតគ្រាត គឺរមែងលះបានថា មិនមែនការឃើញថា រូបទៀងតែម្យ៉ាងប៉ុណ្ណោះគ្រោតគ្រាត ឃើញថា សូម្បីវេទនា ក៏ទៀង គ្រោតគ្រាត សូម្បីវិញ្ញាណក៏ទៀងគ្រោតគ្រាតដូចគ្នា ។ ក្នុងការដាច់សូន្យក្ដី ក្នុងការទៀងណាមួយក្ដី ក៏មានន័យនេះដូចគ្នា ។ គប្បីយល់ថា សូម្បីក្នុង អាយតនៈ ក៏ដូចក្នុងខន្ធដូច្នោះ ។ ដោយប្រការដូច្នេះ ឈ្មោះថា លះការឃើញដើមនោះបាន និងមិនប្រកាន់ការឃើញដទៃ ។

[ ៣១ ] បទថា **សន្តិ អគ្គិវេស្សន** គឺព្រះមានព្រះភាគទ្រង់ប្រារព្ធឡើង ព្រោះហេតុអ្វី មេលទ្ធិដែលប្រកាន់ថាដាច់សូន្យនេះ រមែងបិទបាំងលទ្ធិរបស់ខ្លួន តែកាលពោលគុណរបស់លទ្ធិនោះ នឹងធ្វើលទ្ធិរបស់ខ្លួនឲ្យប្រាកដ ព្រោះព្រះមានព្រះភាគ កាលទ្រង់សម្ដែងលទ្ធិដ៏សេសតែមួយដូចគ្នា ហើយដើម្បីទ្រង់សម្ដែង បែកអំពីគ្នា ទើបទ្រង់ប្រារព្ធទេសនានេះ ។

គប្បីជ្រាបអត្ថក្នុងបទថា **សរាគាយ សន្តិកេ** ជាដើមដូចតទៅនេះថា ជិតកិលេសជាគ្រឿងត្រេកអរក្នុងវដ្តៈដោយអំណាចរាគៈ គឺជិតកិលេសជាគ្រឿងចងក្នុងវដ្តៈ ដោយគ្រឿងចង គឺតណ្ហា និងទិដ្ឋិ អធិប្បាយថា លេបដោយការត្រេកអរក្នុងតណ្ហា និងទិដ្ឋិ ដោយអំណាចនៃតណ្ហា និងទិដ្ឋិនោះឯង ហើយជិតការប្រកាន់ និងការប្រកាន់ មាំ ។ គប្បីជ្រាបអត្ថក្នុងបទថា **វិរាគាយ**

**សន្តិកោ** ជាដើមដូចតទៅនេះថា ជិតគ្រឿង ត្រេកអរក្នុងវដ្ដៈ ។ មួយវិញទៀត ក្នុងបទនេះ ការឃើញថាទៀង មានទោសតិច មានការលះបង់លំបាក ។ ការឃើញថាដាច់សូន្យ មានទោសច្រើន មានការលះបង់ងាយ ។ សេចក្ដីនេះដូចម្ដេច ព្រោះបុគ្គលមានវាទៈថាទៀង តែងមិនដឹងលោកនេះ និងលោកខាងមុខថាមាន រមែងដឹងផលនៃកម្មល្អ កម្មអាក្រក់ថាមាន ទើបធ្វើកុសល កាលធ្វើអកុសល រមែងខ្លាច ពេញចិត្តត្រេកអរក្នុងវដ្ដៈ ។ នៅចំពោះព្រះភក្ត្រព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ រមែងមិនអាចលះការឃើញដោយឆាប់បាន ដូច្នោះ ទើបលោកពោលថា ការឃើញថាទៀងនោះ មានទោសតិច លះបង់លំបាក ។

ឯអ្នកមានវាទៈថា ដាច់សូន្យ រមែងដឹងលោកនេះ និងលោកខាងមុខថាមាន តែមិនដឹងផលរបស់កម្មល្អ និងកម្មអាក្រក់ថាមាន មិនធ្វើកុសល កាលធ្វើអកុសល រមែងមិនខ្លាច មិនពេញចិត្ត មិនត្រេកអរក្នុងវដ្ដៈ នៅចំពោះព្រះភក្ត្រព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធ រមែងលះការឃើញបានរហ័ស អាចបំពេញបារមីជាព្រះពុទ្ធបាន ។ កាលមិនអាច ក៏សន្សំបុណ្យបារមីជាសាវក ហើយបរិនិព្វាន ។ ព្រោះដូច្នោះ ទើបលោកពោលថា ការឃើញថា ដាច់សូន្យ មានទោសច្រើន តែលះបង់រហ័ស ។ បរិព្វាជកនោះកំណត់សេចក្ដីនោះមិនបាន ទើបពណ៌នាសរសើរនូវការឃើញនោះ កាលកំណត់បានថា ការឃើញរបស់អញល្អ ពិតប្រាកដ ទើបពោលពាក្យថា **ឧក្កំសេតិ មេ ភវំ** ជាដើម ។ ឥឡូវនេះ ព្រោះបរិព្វាជកនេះបៀមនូវការឃើញថា ដាច់សូន្យប៉ុណ្ណោះ ដូចឃ្លោកល្ពៅពេញដោយទឹកខ្មេះ ។ បរិព្វាជកនោះ គង់ចោលទឹកខ្មេះមិនបាន ទើបមិនអាច

ចាក់ទឹកឃ្មុំជាដើមចូលក្នុងឃ្លោក ។ សូម្បីចាក់ចូលទៅហើយ ក៏កាន់យកមិនបាន យ៉ាងណា បរិព្វាជកនោះ មិនទាន់លះការឃើញនោះបាន ទើបមិនគួរដើម្បីបានមគ្គផល ដូច្នោះ ។ ព្រោះហេតុនោះ ដើម្បីឲ្យបរិព្វាជកលះទិដ្ឋិនោះ ទើបទ្រង់ផ្ដើមបទថា **តត្រ អគ្គិវេស្សន** ជាដើម ។

[ ៣២ ] បទថា **វិគ្គហោ** គឺជម្លោះ ។ បទថា **ឯវមេតាសំ ទិដ្ឋីនំ បហានំ ហោតិ** គឺកាលឃើញទោសនៃជម្លោះហើយ ទើបលះទិដ្ឋិទាំងនោះបាន ។ បរិព្វាជកនោះគិតថា ប្រយោជន៍អ្វីដល់អញ ដោយការឈ្លោះជាដើមនេះ ទើបលះការយល់ថាដាច់សូន្យនោះបាន ។

[ ៣៣ ] លំដាប់នោះ ព្រះមានព្រះភាគ មានព្រះតម្រាស់ថា តថាគតនឹងឲ្យបរិព្វាជកបំពេញនូវអមតឱសថទុកក្នុងហឫទ័យ ដូចបុគ្គលដាក់សប្បិ និងនវនីត ជាដើមចូលក្នុងឃ្លោកដែលចាក់ទឹកខ្មេះចេញហើយ ដូច្នោះ កាលទ្រង់ប្រាប់ វិបស្សនាដល់បរិព្វាជកនោះ ទើបត្រាស់ព្រះតម្រាស់ ថា **អយំ ខោ បន អគ្គិវេស្សន កាយោ** ជាដើម ដូច្នេះ ។ លោកពោលសេចក្ដីនៃបទនោះទុកហើយ ក្នុងវម្មិកសូត្រ ។ សូម្បីបទថា **អនិច្ចតោ** ជាដើមក៏ពោលពិស្ដារហើយខាងដើមដែរ ។ បទថា **យោ កាយស្មឹ ឆន្ទោ** បានដល់ការពេញចិត្តក្នុងកាយ ។ បទថា **ស្នេហោ** គឺការជាប់ជំពាក់ដោយតណ្ហា ។ បទថា **កាយន្វយតា** គឺការ នៅក្នុងអំណាចនៃកាយ ។ អធិប្បាយថា កិលេសដែលចូលទៅកាន់កាយ ។

[ ៣៤ ] ព្រះមានព្រះភាគ កាលទ្រង់សម្ដែងរូបកម្មដ្ឋានយ៉ាងនេះហើយ

ឥឡូវនេះ កាលទ្រង់សម្ដែងអរូបកម្មដ្ឋាន ទើបត្រាស់ថា **តិស្សោ ខោ** ជាដើម ។ កាលទ្រង់សម្ដែងវេទនាទាំង ៣ នោះមិនលាយឡំគ្នា ទើបត្រាស់ថា **យស្មឹ អគ្គិវេស្សន សមយេ** ជាដើម សេចក្ដីសង្ខេបក្នុងបទនោះមានដូច្នេះថា សម័យណាសោយវេទនាតែម្យ៉ាង ក្នុងបណ្ដាសុខវេទនាជាដើម សម័យនោះ វេទនា ឈ្មោះថា អន្ទ្រយចាំមើលភារៈ ឬឱកាសរបស់ខ្លួន រមែងមិនមាន ។ ដោយពិត វេទនាមិនទាន់កើត ឬបាត់ទៅ ដូចពពុះទឹកដែលបែក ។ បទថា **សុខាបិ ខោ** ជាដើម លោកពោល ដើម្បីសម្ដែងភាពដែលវេទនាទាំង ៣ នោះ ដូចជាលម្អិត ។ បទថា **ន កេនចិ វិវទតិ** គឺមិនពោលរួមគ្នាជាមួយបុគ្គលដែលមានវាទៈថាជាច់សូន្យ ជាខ្ញុំជាអ្នកមានវាទៈ ថាទៀង ព្រោះមានទិដ្ឋិថាទៀង ។ រមែងមិនមានវាទៈជំទាស់នឹងវាទៈ ថាទៀង ពួកខ្លះថា ខ្ញុំជាអ្នកមានវាទៈថាទៀង ព្រោះកាន់យកទិដ្ឋិថាទៀងនោះឯង គប្បីប្រកបផ្លាស់ប្ដូរវាទៈទាំង ៣ យ៉ាង ដោយប្រការដូច្នេះ ។ បទថា **យញ្ច លោកេ វុត្តំ** គឺពោលទៅតាមវោហារដែលសត្វ លោកនិយាយគ្នា ។ បទថា **អបរាមសំ** គឺមិនប្រកាន់ធម៌ណាមួយ ដោយការប្រកាន់ សមដូចលោកពោលទុកថា

ភិក្ខុណាជាអរហន្ត មានកិច្ចធ្វើស្រេចហើយ អស់អាសវៈហើយ ទ្រទ្រង់រាងកាយតែក្នុងជាតិជាទីបំផុត ភិក្ខុនោះ នៅតែនិយាយថា អាត្មានិយាយដូច្នេះក្ដី ភិក្ខុនោះនៅតែនិយាយថា ជនទាំងឡាយនិយាយនឹងអាត្មាដូច្នេះក្ដី ភិក្ខុនោះគ្រាន់តែឈ្មោះថា ជាអ្នកឈ្លាស បានយល់ច្បាស់នូវវោហារក្នុងលោក ហើយនិយាយតាមតែវោហារប៉ុណ្ណោះ ។

លោកពោលតទៅទៀតថា ម្នាលចិត្តៈសំដីទាំងនេះឯង ជាឈ្មោះ សម្រាប់លោក ជាភាសាសម្រាប់លោក ជាវោហាររបស់លោក ជាបញ្ញត្តិ ក្នុងលោក តថាគតរមែងពោលដែរ តែមិនប៉ះពាល់ដោយសេចក្តីប្រកាន់ទេ[១] ។

បទថា **អភិញ្ញា បហានមាហ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ដឹងការទៀង នៃធម៌ទាំងនោះ ក្នុងបណ្តាការទៀងជាដើម ដោយបញ្ញាដ៏ក្រៃលែង ទើបត្រាស់ដល់ការលះនូវការទៀង ។ ទ្រង់ដឹងការដាច់សូន្យ ការទៀងណាមួយ ដោយបញ្ញាក្រៃលែង ហើយទើបត្រាស់ដល់ការលះការទៀងណាមួយ ។ ទ្រង់ដឹងរូបដោយបញ្ញាដ៏ក្រៃលែង ហើយទើបត្រាស់ដល់ការលះរូប គប្បីជ្រាប សេចក្តីក្នុងបទនេះ ដោយន័យជាដើមដូច្នេះឯង ។ បទថា **បដិសញ្ចិក្ខតោ** គឺឃើញច្បាស់ ។ បទថា **អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចិ** គឺចិត្តផុតហើយចាកអាសវៈទាំងឡាយ ដែលរលត់ហើយដោយការរលត់ស្និទ្ធ គឺមិនកើតទៀត ព្រោះមិនប្រកាន់មាំ ។

ដោយហេតុប្រមាណប៉ុណ្ណេះ ព្រះសារីបុត្រ ដូចបុគ្គលបរិភោគអាហារដែលគេដួសឲ្យអ្នកដទៃ ហើយបន្ទាបង់នូវការស្រេកឃ្លានបាន កាលបញ្ជូនញាណទៅក្នុងធម្មទេសនាដែលប្រារព្ធដល់អ្នកដទៃ ទើបចម្រើនវិបស្សនាបានសម្រេចអរហត្ត ចាក់ដុះទីបំផុតនៃសាវកបារមីញាណ និងបញ្ញា ១៦ ហើយតាំងនៅ ។ ឯទីឃនខបានសម្រេចសោតាបត្តិផល ហើយតាំងនៅក្នុងសរណៈទាំងឡាយ ។

ចំណែកព្រះមានព្រះភាគ កាលព្រះអាទិត្យនៅប្រាកដ ទ្រង់ចប់ទេសនា

---
១- បិដកខ្មែរ លេខ ១៥ ទំព័រ ១៥៧ ។

នេះហើយ យាងចុះអំពីភ្នំគិជ្ឈកូដ យាងទៅរកវិហារវេឡុវ័ន ទ្រង់បានប្រជុំព្រះសាវ័ក គឺចតុរង្គសន្និបាត ។ ចតុរង្គសន្និបាតនេះ គឺនោះជាថ្ងៃឧបោសថ ១៥ កើត ប្រកបដោយមាឃនក្ខត្តឫក្ស ១ ភិក្ខុ ១២៥០ រូប ប្រជុំគ្នាតាមធម្មតារបស់ខ្លួន មិនមានអ្នកណាត់មក ១ ភិក្ខុទាំងនោះមិនមានសូម្បីត្រឹមតែមួយរូបដែលជាបុថុជ្ជន ឬព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តជាសុក្ខវិបស្សកៈ ភិក្ខុទាំងអស់ជាអ្នកបានអភិញ្ញាប្រាំមួយ ១ មិនបានកោរសក់ដោយកាំបិតកោរឬសសូម្បីតែមួយរូប គឺភិក្ខុទាំងអស់ សុទ្ធតែជាឯហិភិក្ខុ ១ ។ ៚

## អដ្ឋកថាទីឃនខសូត្រ ចប់

## សូត្រទី ៤ ចប់

# សុត្តន្តបិដក

## មាគណ្ឌិយសូត្រទី ៥

[ ៣៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់លើកម្រាលស្មៅ ក្នុងរោងសម្រាប់បូជាភ្លើងរបស់ព្រាហ្មណ៍ ឈ្មោះ ភារទ្វាជគោត្ត ក្នុងកម្មាសធម្មនិគម របស់ពួកជនកុរុ ក្នុងដែនកុរុ ។ លំដាប់ នោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ហើយស្តេចចូលទៅ កាន់កម្មាសធម្មនិគម ដើម្បីបិណ្ឌបាត ក្នុងបុព្វណ្ហសម័យ ។ លុះចូលទៅ បិណ្ឌបាត ក្នុងកម្មាសធម្មនិគមហើយ ត្រឡប់មកពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ ស្តេចតម្រង់ចូលទៅកាន់ដងព្រៃ ១ ទ្រង់អាស្រ័យដងព្រៃនោះ ដើម្បីសម្រាក ក្នុងវេលាថ្ងៃ ហើយគង់ទៀបគល់ឈើ ១ ដើមក្នុងវេលាថ្ងៃ ។

[ ៣៨ ] គ្រានោះ មាគណ្ឌិយបរិព្វាជក កំពុងចង្ក្រមត្រាច់ដើរទៅមក ដើម្បីសម្រាកកម្លាំងស្មុង ក៏ចូលទៅកាន់រោងសម្រាប់បូជាភ្លើង របស់ភារទ្វា ជគោត្តព្រាហ្មណ៍ ។ មាគណ្ឌិយបរិព្វាជក បានឃើញកម្រាលស្មៅក្នុងរោង សម្រាប់បូជាភ្លើង របស់ភារទ្វាជគោត្តព្រាហ្មណ៍ លុះឃើញហើយ ទើបនិយាយ នឹងភារទ្វាជគោត្តព្រាហ្មណ៍យ៉ាងនេះថា នែសម្លាញ់ កម្រាលស្មៅថ្មីនេះដែល ភារទ្វាជគោត្តឯងក្រាលទុកក្នុងរោងសម្រាប់បូជាភ្លើង បម្រុងអ្នកណា ទំនង គួរជាទីសប្បាយរបស់សមណទេដឹង ។ ម្នាលមាគណ្ឌិយដ៏ចម្រើន មានសមណ ជាគោតមគោត្ត ជាសក្យបុត្តចេញចាកសក្យត្រកូលបួស កិត្តិសព្ទដ៏ល្អនៃ ព្រះគោតមដ៏ចម្រើននោះ ឮខ្ទរខ្ទាយសុះសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគ

អង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គដោយប្រពៃ ព្រះអង្គបរិបូណ៌ដោយវិជ្ជានឹងចរណៈ គឺសេចក្តីចេះដឹង និងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានព្រះដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ មិនមានបុគ្គលណាមួយស្មើ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់ មកកាន់ភពថ្មីទៀត ខ្ញុំក្រាលសេយ្យានេះ បម្រុងព្រះគោតមដ៏ចម្រើនអង្គនោះ ។ ម្នាលភារទ្វាជពួកយើងបានឃើញទីសេយ្យារបស់ព្រះគោតមដ៏ចម្រើន ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនចោលចេញនោះ ឈ្មោះថាបានឃើញនូវហេតុ ដែលគេមិនគួរឃើញទេតើ ។ ម្នាលមាគណ្ឌិយ អ្នកឯងត្រូវរក្សាសម្តីនេះ ម្នាលមាគណ្ឌិយអ្នកឯងត្រូវរក្សានូវវាចានេះ ដ្បិតពួកខត្តិយបណ្ឌិត ព្រាហ្មណបណ្ឌិតគហបតិបណ្ឌិត និងពួកសមណបណ្ឌិតជាច្រើន បាននាំគ្នាជ្រះថ្លា ចំពោះព្រះសមណគោតមអង្គនោះ ព្រះអង្គទ្រង់ណែនាំក្នុងធម៌ជាកុសល ជាគ្រឿងចេញទៅដ៏ប្រសើរ ។ ម្នាលភារទ្វាជៈ ប្រសិនបើយើងគប្បីឃើញ ព្រះគោតមដ៏ចម្រើនអង្គនោះ ក្នុងទីចំពោះព្រះភក្ត្រសោត យើងគប្បីនិយាយនឹងលោកក្នុងចំពោះព្រះភក្ត្រថា ព្រះសមណគោតមកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះសេចក្តីនោះព្រោះហេតុអ្វី ព្រោះចុះសម្រុងគ្នានឹងសូត្ររបស់យើងយ៉ាងនេះ ។

ប្រសិនបើសេចក្តីនោះ មិនទទឹងទាស់ដល់មាគណ្ឌិយទេ ខ្ញុំនឹងក្រាបទូលចំពោះព្រះសមណគោតមអង្គនោះ ។ ភារទ្វាជៈដ៏ចម្រើន គប្បីមានសេចក្តីខ្វល់ខ្វាយតិច ខ្ញុំនិយាយផ្តើមរួចហើយ ត្រូវនិយាយនឹងព្រះគោតមនោះទៀតចុះ ។

[ ៣៩ ] ព្រះមានព្រះភាគបានទ្រង់ព្រះសណ្តាប់ភារទ្វាជព្រាហ្មណ៍ ដែលកំពុងនិយាយចរចាជាមួយនឹងមាគណ្ឌិយបរិព្វាជក ដោយព្រះសោតធាតុដ៏ជាទិព្វបរិសុទ្ធ កន្លងហួសសោតធាតុរបស់មនុស្សធម្មតា ។ ទើបព្រះមានព្រះភាគទ្រង់ចេញអំពីទីសម្ងំ ( ផលសមាបត្តិ ) ក្នុងសាយណ្ហសម័យ ស្តេចចូលទៅកាន់រោងសម្រាប់បូជាភ្លើង របស់ភារទ្វាជគោត្តព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏គង់លើកម្រាលស្មៅ ដែលភារទ្វាជគោត្តព្រាហ្មណ៍ ក្រាលថ្វាយ ។ គ្រានោះ ភារទ្វាជគោត្តព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ និយាយពាក្យសំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹក ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភារទ្វាជគោត្តព្រាហ្មណ៍ ដែលអង្គុយក្នុងទីដ៏សមគួរហើយយ៉ាងនេះថា ម្នាលភារទ្វាជៈ ចុះពាក្យចរចា ដែលអ្នកបាននិយាយជាមួយនឹងមាគណ្ឌិយបរិព្វាជក ប្រារព្ធរឿងកម្រាលស្មៅនេះចុះសម្រេងគ្នាដូចម្តេចទៅ ។ កាលព្រះអង្គទ្រង់ត្រាស់ យ៉ាងនេះហើយ ភារទ្វាជគោត្តព្រាហ្មណ៍ ភ្ញាក់ព្រើត កើតសេចក្តីព្រឺរោម ហើយបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា យើងខ្ញុំព្រះអង្គបម្រុង នឹងក្រាបទូលពាក្យនោះចំពោះព្រះមានព្រះភាគជាម្ចាស់ដែរ ស្រាប់តែព្រះគោតមជា

ម្ចាស់ទ្រង់ត្រាស់សួរ នូវពាក្យដែលខ្ញុំព្រះអង្គមិនទាន់ក្រាបទូល ។ ក៏ឯពាក្យជាចន្លោះនេះ ដែលព្រះមានព្រះភាគ កំពុងតែចរចាជាមួយនឹងភារទ្វាជគោត្តព្រាហ្មណ៍ ក៏ដាច់ពាក់កណ្តាលទៅ ។ គ្រានោះ មាគណ្ឌិយបរិព្វាជក កំពុងដើរចង្ក្រមត្រាច់ទៅមក ដើម្បីនឹងសម្រាកស្មង ក៏ចូលទៅគាល់ព្រះមានព្រះភាគឯរោងសម្រាប់បូជាភ្លើងរបស់ភារទ្វាជគោត្តព្រាហ្មណ៍ លុះចូលទៅដល់ហើយទើបក្រាបទូលរាក់ទាក់សំណេះសំណាល នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ៤០ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងមាគណ្ឌិយបរិព្វាជកដែលអង្គុយក្នុងទីដ៏សមគួរហើយយ៉ាងនេះថា ម្នាលមាគណ្ឌិយ ចក្ខុតែងមានរូបជាទីរីករាយ ត្រេកអរក្នុងរូប ត្រេកត្រអាលក្នុងរូប ចក្ខុនោះព្រះតថាគតបានទូន្មានគ្រប់គ្រងរក្សា សង្រួមរួចហើយ មួយយ៉ាងទៀត ព្រះតថាគត បានសម្តែងធម៌ ដើម្បីសង្រួមចក្ខុនោះ ម្នាលមាគណ្ឌិយ ពាក្យដែលអ្នកឯង ពោលថាព្រះសមណគោតមជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ហេតុនោះទេតើ ។ បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំព្រះអង្គបានពោលថា ព្រះសមណគោតមជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ហេតុនោះមែនហើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះចុះសម្រុងគ្នានឹងសូត្ររបស់យើងយ៉ាងនេះ ។ ម្នាលមាគណ្ឌិយ ត្រចៀក មានសំឡេងជាទីរីករាយ ។បេ។ ម្នាលមាគណ្ឌិយ ច្រមុះ មានក្លិនជាទីរីករាយ...ម្នាលមាគណ្ឌិយ អណ្តាតមានរសជាទីរីករាយ ត្រេកអរក្នុងរស មានរសជាទីត្រេកត្រអាល អណ្តាតនោះ

ព្រះតថាគតបានទូន្មានគ្រប់គ្រងរក្សា សង្រួមរួចហើយ មួយយ៉ាងទៀត ព្រះតថាគតបានសំដែងធម៌ ដើម្បីសង្រួមអណ្តាតនោះ ម្នាលមាគណ្ឌិយ ពាក្យដែលអ្នកឯងពោលថា ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ហេតុនោះទេតើ ។ បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំព្រះអង្គពោលថា សមណគោតមជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ហេតុនោះមែនហើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះថាចុះសម្រេងក្នុងទីងសូត្ររបស់យើងយ៉ាងនេះ ។ ម្នាលមាគណ្ឌិយ កាយមានផោដ្ឋព្វៈជាទីរីករាយ ។បេ។ ម្នាលមាគណ្ឌិយ ចិត្តមានធម្មារម្មណ៍ជាទីរីករាយ ត្រេកអរក្នុងធម្មារម្មណ៍ ត្រេកត្រអាលក្នុងធម្មារម្មណ៍ ចិត្តនោះព្រះតថាគត បានទូន្មានគ្រប់គ្រងរក្សា សង្រួមរួចហើយ មួយយ៉ាងទៀត ព្រះតថាគតបានសំដែងធម៌ ដើម្បីសង្រួមចិត្តនោះ ម្នាលមាគណ្ឌិយ ពាក្យដែលអ្នកពោលថា ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ ហេតុនុ៎ះទេតើ ។ បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំព្រះអង្គពោលថា ព្រះសមណគោតម ជាអ្នកកម្ចាត់បង់នូវសេចក្តីចម្រើនដូច្នេះ ត្រូវត្រង់ហេតុនុ៎ះ មែនហើយ សេចក្តីនោះព្រោះហេតុអ្វី ព្រោះថាចុះសម្រេងក្នុងទីងសូត្ររបស់យើងនេះ ។

[ ៤១ ] ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះដូចម្តេច បុគ្គលពួកខ្លះក្នុងលោកនេះ ធ្លាប់ឲ្យគេបម្រើដោយរូបទាំងឡាយ ដែលគួរដឹងច្បាស់ ដោយចក្ខុ ជាទីប្រាថ្នា ជាទីគាប់ចិត្ត ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីត្រេកអរ លុះគ្រាក្រោយមក បុគ្គលនោះដឹងច្បាស់នូវហេតុ

ដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់រូបទាំងឡាយតាមដោយសេចក្តីពិត ហើយក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងរូប បន្ទោបង់នូវសេចក្តីក្តៅក្រហាយក្នុងរូប ជាអ្នកប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់តាំងនៅក្នុងសន្តានសម្រាននៅ ម្នាលមាគណ្ឌិយៈ ចុះអ្នកឯងគប្បីថាឲ្យបុគ្គលនេះដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន ឥតមានថាអ្វីកើតទេ ។ ម្នាលមាគណ្ឌិយ អ្នកសម្គាល់ហេតុនោះថាដូចម្តេច បុគ្គលពួកខ្លះក្នុងលោកនេះ ( ធ្លាប់ឲ្យគេបម្រើ ) ដោយសំឡេងទាំងឡាយ ដែលគប្បីដឹងដោយត្រចៀក ។បេ។ ដោយក្លិនទាំងឡាយ ដែលគប្បីដឹងដោយច្រមុះ...ដោយរសទាំងឡាយ ដែលគប្បីដឹងដោយអណ្តាត...ធ្លាប់ឲ្យគេបម្រើដោយផោដ្ឋព្វៈទាំងឡាយ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ លុះគ្រាក្រោយមក បុគ្គលនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់ផោដ្ឋព្វៈទាំងឡាយ តាមសេចក្តីពិតហើយ ក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងផោដ្ឋព្វៈ បន្ទោបង់នូវសេចក្តីក្តៅក្រហាយក្នុងផោដ្ឋព្វៈ ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់តាំងនៅក្នុងសន្តានសម្រាន្តនៅ ម្នាលមាគណ្ឌិយ ចុះអ្នកឯងគប្បីថាឲ្យបុគ្គលនេះដូចម្តេច បពិត្រព្រះគោតមដ៏ចម្រើន ឥតមានថាអ្វីកើតទេ ។

[ ៤២ ] ម្នាលមាគណ្ឌិយ កាលពីដើម តថាគតនៅជាគ្រហស្ថក៏ធ្លាប់ឆ្អែតឆ្អន់ មូលមិត្ត ឲ្យគេបម្រើដោយកាមគុណទាំង ៥ គឺរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួររីករាយ សំឡេងដែលគប្បីដឹងដោយត្រចៀក ។បេ។ ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ។ ម្នាលមាគណ្ឌិយ តថាគតនោះមានប្រាសាទ ៣ ខ្នង ប្រាសាទ ១ សម្រាប់នៅក្នុងរដូវភ្លៀង ប្រាសាទ ១ សម្រាប់នៅក្នុងរដូវរងា ប្រាសាទ ១ សម្រាប់នៅក្នុងរដូវក្តៅ ។ ម្នាលមាគណ្ឌិយ តថាគតនោះឲ្យគេបម្រើដោយតន្ត្រីដែលឥតបុរស លើប្រាសាទសម្រាប់នៅក្នុងរដូវភ្លៀងអស់ ៤ ខែ មិនដែលចុះមកខាងក្រោមសោះ ។ លុះគ្រាក្រោយមក តថាគតនោះដឹងច្បាស់នូវហេតុ ដែលនាំឲ្យកើតឡើងផងនូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌សម្រាប់រលាស់ចោលផង សុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្តីពិត ហើយក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងកាម បន្ទោបង់នូវសេចក្តីក្តៅក្រហាយក្នុងកាម ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ តាំងនៅក្នុងសន្តានសម្រាន្តនៅ ។ តថាគតនោះឃើញសត្វទាំងឡាយឯទៀត មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្តីប្រាថ្នាក្នុងកាមកំពុងទំពាស៊ី ជាអ្នកក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយព្រោះកាម កំពុងសេពនូវកាមទាំងឡាយ តថាគតនោះមិន

ប្រាថ្នាពួកជននោះ មិនរីករាយក្នុងការសេពកាមនោះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលមាគណ្ឌិយៈ ព្រោះថា កាលបុគ្គល ត្រេកអរដោយសេចក្តីត្រេកអរ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាក អកុសលធម៌ទាំងឡាយ ក៏នៅជាអ្នកថោកថយ ព្រោះហេតុដូច្នោះ តថាគត ទើបមិនប្រាថ្នា មិនរីករាយក្នុងការសេពកាមនោះឡើយ ។

[ ៤៣ ] ម្នាលមាគណ្ឌិយៈ ដូចជាគហបតី ឬគហបតិបុត្ត ដែលមានទ្រព្យច្រើនស្តុកស្តម្ភ មានសម្បត្តិច្រើន ស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើ ដោយកាមគុណទាំង ៥ គឺដោយរូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេក-អរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ដោយសំឡេងដែលគប្បីដឹងដោយសោតៈ ។បេ។ ដោយក្លិនដែល គប្បីដឹងដោយឃានៈ ។បេ។ ដោយរសដែលគប្បីដឹងដោយជិវ្ហា ។បេ។ ដោយផោដ្ឋព្វៈដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរជាទីរីករាយ ។ គហបតីនោះប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏បានទៅកាន់ទេវលោកគឺឋានសួគ៌ជាសុគតិ ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ទេវបុត្តនោះមានពួកស្រីអប្សរហែហមចោមរោម ក្នុងសួននន្ទវ័ន ក្នុងទេវលោក នោះស្កប់ស្កល់មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ។ ទេវបុត្តនោះគប្បីឃើញនូវគហបតី ឬគហបតិបុត្ត ដែលកំពុងស្កប់ស្កល់មូលមិត្ត បម្រើដោយកាម

គុណទាំង ៥ ។ ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះ ដូចម្ដេច ចុះទេវបុត្តនោះ មានពួកស្រីអប្សរហែហមចោមរោមក្នុងសួននន្ទវ័ន ស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ដ៏ជាទិព្វ ហើយមកប្រាថ្នាគហបតី ឬគហបតិបុត្តឯណោះ ហើយវិលត្រឡប់មករកកាមគុណទាំង ៥ ជារបស់មនុស្ស ដោយកាមជារបស់មនុស្សវិញដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនត្រឡប់មកវិញទេ សេចក្ដីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះកាមដ៏ជាទិព្វ កន្លងហួសប្រសើរផុតកាមជារបស់មនុស្ស ។ យ៉ាងនេះមែនហើយ ម្នាលមាគណ្ឌិយ កាលពីដើមតថាគតនៅជាគ្រហស្ថ ធ្លាប់ស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើដោយកាមគុណទាំង ៥ គឺដោយរូបដែលគប្បីដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយដោយសំឡេងដែល គប្បីដឹងដោយសោតៈ ។បេ។ ដោយក្លិនដែលគប្បីដឹងដោយឃានៈ ។បេ។ ដោយរសដែលគប្បីដឹងដោយជិវ្ហា ។បេ។ ដោយផោដ្ឋព្វៈ ដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីគាប់ចិត្ត ជាទីត្រេកអរ មានសភាពគួរ ស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ។ លុះគ្រាក្រោយមក តថាគតនោះដឹងច្បាស់ នូវហេតុដែលនាំឲ្យកើតផង នូវសេចក្ដីវិនាសផង នូវសេចក្ដីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចោលផង សុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្ដីពិត ហើយក៏លះបង់នូវសេចក្ដីប្រាថ្នាក្នុងកាម បន្ទោបង់នូវសេចក្ដីក្ដៅក្រហាយក្នុងកាម ប្រាសចាកសេចក្ដីស្រេកឃ្លាន មាន

ចិត្តស្ងប់រម្ងាប់ តាំងនៅក្នុងសន្តានសម្រាន្តនៅ ។ តថាគតនោះ ឃើញនូវសត្វទាំងឡាយឯទៀត មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ី ក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយ ព្រោះកាមកំពុងសេពកាម តថាគតនោះមិនប្រាថ្នាពួកជននោះ មិនរីករាយក្នុងការសេពកាមនោះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលមាគណ្ឌិយៈ ព្រោះថាកាលបុគ្គលត្រេកអរដោយសេចក្តីត្រេកអរ វៀរលែងចាកកាម វៀរលែងចាកអកុសលធម៌ ទោះបីនៅប្រកាន់សុខជាទិព្វនៅឡើយ ក៏នៅជាអ្នកថោកថយ ( ព្រោះហេតុដូច្នោះ ) តថាគត ទើបមិនប្រាថ្នា មិនរីករាយក្នុងការសេពកាមនោះឡើយ ។

[ ៤៤ ] ម្នាលមាគណ្ឌិយៈ ដូចជាបុរសឃ្លង់មានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ ឆ្អើរកាយដោយរងើកភ្លើង ពួកមិត្តអមាត្យនឹងញាតិសាលោហិតរបស់បុរសឃ្លង់នោះ គប្បីឲ្យពេទ្យអ្នកវះចូលទៅថែរក្សា ពេទ្យវះនោះក៏បានធ្វើថ្នាំដល់បុរសនោះ បុរសនោះក៏បានជាស្បើយរោគឃ្លង់ ព្រោះអាស្រ័យថ្នាំ ( នោះ ) ជាបុគ្គលឥតរោគ សុខសប្បាយ នៅជាសេរីភាព បាននៅតាមទំនើងខ្លួនឯងបាន ទៅណាមកណាបានតាមប្រាថ្នា ។ បុរសឃ្លង់នោះ បានឃើញបុរសឃ្លង់ឯទៀត ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ កំពុងឆ្អើរកាយលើរងើកភ្លើង ។ ម្នាលមាគណ្ឌិយ អ្នកសម្គាល់ហេតុនោះដូចម្តេច ចុះបុរស

នោះ ប្រាថ្នាបុរសឃ្លង់ឯណោះ ដែលកំពុងផ្អើរកាយលើរងើកភ្លើង ឬកំពុងផឹកថ្នាំដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនប្រាថ្នាទេ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន ព្រោះកាលបើរោគមានហើយ កិច្ចដែលត្រូវការដោយថ្នាំក៏ត្រូវមាន កាលបើរោគមិនមានហើយ កិច្ចដែលត្រូវការដោយថ្នាំក៏មិនត្រូវមាន ។ ម្នាលមាគណ្ឌិយៈ យ៉ាងហ្នឹងមែនហើយ កាលពីដើម តថាគតនោះនៅជាគ្រហស្ថនៅឡើយ ធ្លាប់ស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើដោយកាមគុណទាំង ៥ គឺដោយរូបទាំងឡាយដែលគប្បីដឹង ដោយចក្ខុជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ដោយសំឡេងទាំងឡាយ ដែលគប្បីដឹងដោយ សោតៈ ។បេ។ ដោយក្លិនទាំងឡាយដែលគប្បីដឹងដោយឃានៈ។បេ។ ដោយរសទាំងឡាយ ដែលគប្បីដឹងច្បាស់ដោយជិវ្ហា ។បេ។ ដោយផោដ្ឋព្វៈទាំងឡាយដែលគប្បីដឹងច្បាស់ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរីករាយ ។ លុះគ្រាក្រោយមក តថាគតនោះដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់កាមទាំងឡាយ តាមសេចក្តីពិតហើយ ក៏លះបង់នូវសេចក្តីប្រាថ្នាក្នុងកាមចេញ បន្ទោបង់នូវសេចក្តីក្តៅក្រហាយ ក្នុងកាមចេញ ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ក្នុងសន្តានសម្រាន្តនៅ ។ តថាគតនោះ ឃើញនូវសត្វទាំងឡាយឯទៀត មិនទាន់ប្រាស

ចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ កំពុងទំពាស៊ី កំពុងអន្ទះអន្ទែងដោយសេចក្តីក្តៅក្រហាយព្រោះកាម កំពុងសេពកាម តថាគតនោះទើបមិនប្រាថ្នាពួកជននោះ មិនរីករាយក្នុងការសេពកាមនោះឡើយ សេចក្តីនោះព្រោះហេតុអ្វី ម្នាលមាគណ្ឌិយៈ ព្រោះថាកាលបុគ្គលត្រេកអរដោយសេចក្តីត្រេកអរ វៀរលែងចាកកាមទាំងឡាយ វៀរលែងចាកអកុសលធម៌ទាំងឡាយ ទោះបីនៅប្រកាន់សុខជាទិព្វនៅឡើយ ក៏ទៅជាអ្នកថោកថយ ( ព្រោះហេតុដូច្នោះ ) តថាគតទើបមិនប្រាថ្នា មិនត្រេកអរក្នុងការសេពកាមនោះឡើយ ។

[ ៤៥ ] ម្នាលមាគណ្ឌិយៈ ដូចបុរសឃ្លង់មានខ្លួនដំបៅ មានខ្លួនហើមស្អុល ពួកជន្លេនកំពុងជញ្ជក់ស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ ផ្អើរកាយលើរងើកភ្លើង ពួកមិត្តអាមាត្យនឹងញាតិសាលោហិត របស់បុរសឃ្លង់នោះ បានឲ្យពេទ្យអ្នកវះថែរក្សា ពេទ្យវះនោះក៏ធ្វើថ្នាំឲ្យបុរសនោះ បុរសនោះក៏បានជាស្រឡះស្បើយចាករោគឃ្លង់ ព្រោះបានអាស្រ័យថ្នាំ ( នោះ ) ជាមនុស្សឥតរោគ មានសេចក្តីសុខជាសេរីភាព នៅតាមទំនើងខ្លួនឯងបាន ទៅណាមកណាបានតាមប្រាថ្នា ។ បុរស ២ នាក់មានកម្លាំង គប្បីចាប់បុរសនោះ ត្រង់ដើមដៃម្ខាងម្នាក់ៗ អូសយកទៅផ្អើរលើគំនររងើកភ្លើង ។ ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះដូចម្តេច ចុះបុរសឃ្លង់នោះបន្ទន់កាយតាមទៅដូច្នេះផង ដូច្នោះផងដែរឬទេ ។ បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងហ្នឹង មែនហើយ សេចក្តីនោះព្រោះហេតុអ្វី បពិត្រព្រះគោតមដ៏ចម្រើន

ព្រោះថា ភ្លើងមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយខ្លាំងផង ពេលពលខ្លាំងពន់ពេកណាស់ផង ។ ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះដូចម្តេច ចុះភ្លើងនោះមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយខ្លាំងផង ពេលពលខ្លាំងផង តែក្នុងកាលឥឡូវនេះទេឬ ឬក៏កាលពីដើមមក ភ្លើងនោះមានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ទាំងពេលពលខ្លាំងដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងកាលឥឡូវនេះ ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ពេលពលខ្លាំងដែរ ពីដើមសោត ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ទាំងពេលពលខ្លាំងដូចគ្នា បពិត្រគោតមដ៏ចម្រើន ចំណែកខាងបុរសឃ្លង់ឯណោះ ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ មានឥន្ទ្រិយដែលរោគនោះកម្ចាត់បង់ហើយក៏មានសេចក្តីសម្គាល់ ខុសក្នុងភ្លើងដែលមានសម្ផស្សជាទុក្ខ ( នោះ ) ថាជាសុខស្រួលវិញ ។ ម្នាលមាគណ្ឌិយៈ យ៉ាងហ្នឹងមែនហើយ ក្នុងអតីតកាលយូរអង្វែងមកហើយ កាមទាំងឡាយមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយខ្លាំងផង ពេលពលខ្លាំងផង ក្នុងអនាគតទៅមុខ កាមទាំងឡាយមានសម្ផស្សជាទុក្ខផង ក្តៅក្រហាយផង ពេលពលខ្លាំងផង ក្នុងបច្ចុប្បន្នឥឡូវនេះសោត កាមទាំងឡាយក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ទាំងពេលពលខ្លាំងដូច្នោះដែរ ម្នាលមាគណ្ឌិយៈ ចំណែកពួកសត្វទាំងនេះ មិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ីពេលពលដោយសេចក្តីក្តៅក្រហាយព្រោះកាម មានឥន្ទ្រិយត្រូវកាមកម្ចាត់បង់

ហើយ ក៏មានសេចក្ដីសម្គាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សជាទុក្ខ ថាជាសុខវិញ ។

[ ៤៦ ] ម្នាលមាគណ្ឌិយៈ ដូចបុរសឃ្លង់ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ជន្លេវទាំងឡាយកំពុងជញ្ជក់ស៊ី ខ្វារមុខដំបៅដោយក្រចកទាំងឡាយ ឲ្យគេឆ្អើរកាយលើគំនររងើកភ្លើង ម្នាលមាគណ្ឌិយៈ ដូចជាបុរសឃ្លង់ ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ជន្លេវទាំងឡាយកំពុងជញ្ជក់ស៊ី ខ្វាមុខដំបៅដោយក្រចកទាំងឡាយ ឲ្យគេឆ្អើរកាយលើរងើកភ្លើង យ៉ាងណាមិញ មុខដំបៅអម្បាលនោះរបស់បុរសនោះឯង ក៏រឹងរឹតតែមិនស្អាតផង រឹងរឹតតែមានក្លិនអាក្រក់ផង រឹងរឹតតែស្អុយផង តែជាសេចក្ដីត្រេកត្រអាល និងសេចក្ដីរីករាយបន្តិចបន្តួចនៅតែមាន ព្រោះហេតុដំបៅដែលខ្លួនខ្វារត្រូវមុខ ក៏យ៉ាងនោះដែរ ( សេចក្ដីនេះដូចម្ដេចមិញ ) ម្នាលមាគណ្ឌិយៈ ពួកសត្វដែលមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្ដីប្រាថ្នាក្នុងកាមទាំងឡាយកំពុងទំពាស៊ី កំពុងរោលរាលដោយសេចក្ដីក្ដៅក្រហាយព្រោះកាម សេពនូវកាមទាំងឡាយ ម្នាលមាគណ្ឌិយៈ សត្វទាំងឡាយមិនទាន់ប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ដែលសេចក្ដីប្រាថ្នា ក្នុងកាមទាំងឡាយកំពុងទំពាស៊ី កំពុងរោលរាលដោយសេចក្ដីក្ដៅក្រហាយព្រោះកាម សេពនូវកាមទាំងឡាយ យ៉ាងណាមិញ កាមតណ្ហារបស់សត្វទាំងឡាយនោះ ក៏ចម្រើនឡើង សត្វទាំងនោះក៏ក្ដៅក្រហាយដោយសេចក្ដីក្ដៅក្រហាយព្រោះកាម តែជាសេចក្ដីត្រេកអរ និងសេចក្ដីរីករាយបន្តិចបន្តួចក៏នៅមានព្រោះអាស្រ័យ

នូវកាមគុណទាំង ៥ ក៏យ៉ាងនោះឯង ។

[ ៨៧ ] ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឃើញ ធ្លាប់បានឮព្រះរាជា ឬរាជអាមាត្យ ដែលកំពុងស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើដោយកាមគុណទាំង ៥ មិនទាន់លះបង់នូវកាមតណ្ហា មិនទាន់បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ហើយប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តានទៅហើយផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រាន្តនៅផង ខ្លះដែរឬ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនដែលបានឃើញ មិនដែលបានឮទេ ។ ត្រូវហើយមាគណ្ឌិយៈ ម្នាលមាគណ្ឌិយៈ សេចក្តីនុ៎ះសូម្បីតថាគតសោត ក៏មិនធ្លាប់បានឃើញ បានឮថាព្រះរាជាឬរាជមហាមាត្យ ដែលកំពុងស្កប់ស្កល់មូលមិត្ត ឲ្យគេបម្រើដោយកាមគុណទាំង ៥ មិនទាន់លះបង់កាមតណ្ហា មិនទាន់បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ហើយប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅហើយផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផងដែរ ។ ម្នាលមាគណ្ឌិយៈ កាលបើសមណព្រាហ្មណ៍ណា ដែលប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផង លុះតែពួកសមណព្រាហ្មណ៍ទាំងអស់នោះ ជ្រាបច្បាស់នូវហេតុកើតឡើងផង នូវសេចក្តីវិនាសផង នូវសេចក្តីត្រេកអរផង នូវទោសផង នូវធម៌ជាគ្រឿងរលាស់ចេញផង សុទ្ធតែសម្រាប់កាមទាំងឡាយតាមសេចក្តីពិត ទើបលះ

បង់នូវកាមតណ្ហា បន្ទោបង់នូវសេចក្តីក្តៅក្រហាយព្រោះកាម ប្រាសចាកសេចក្តីស្រេកឃ្លាន មានចិត្តស្ងប់រម្ងាប់ខាងក្នុង សម្រេចសម្រាន្តនៅហើយផង កំពុងសម្រេចសម្រាន្តនៅផង នឹងសម្រេចសម្រាន្តនៅផងបាន ។

[ ៤៨ ] ក្នុងលំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បន្លឺនូវឧទាននេះ ក្នុងពេលនោះថា

លាភទាំងឡាយ មានការមិនមានរោគ ប្រសើរបំផុត ព្រះ
និព្វានជាសេចក្តីសុខដ៏ប្រសើរ មគ្គដែលប្រកបដោយអង្គ
៨ ដ៏ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដើរទៅកាន់
ព្រះនិព្វាន ឈ្មោះ អមតៈ ។

កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយបរិព្វាជក បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន មិនធ្លាប់កើតមានទេ ពាក្យដែលព្រះគោតមដ៏ចម្រើន ត្រាស់ហើយដោយប្រពៃថា លាភទាំងឡាយ មានការមិនមានរោគ ប្រសើរបំផុត ព្រះនិព្វានជាសេចក្តីសុខដ៏ឧត្តម បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីនុ៎ះខ្ញុំព្រះអង្គសោត ក៏ធ្លាប់បានស្តាប់មកអំពីពួកបរិព្វាជកជាន់ដើម ដែលជាអាចារ្យជាប្រធានលើអាចារ្យពោលថា លាភទាំងឡាយមានការមិនមានរោគប្រសើរបំផុត ព្រះនិព្វានជាសេចក្តីសុខដ៏ឧត្តមដូច្នេះដែរ បពិត្រព្រះគោតមដ៏ចម្រើន ពាក្យនេះសមគ្នាហើយ ។ ម្នាលមាគណ្ឌិយៈ ក៏ពាក្យណាដែលអ្នកធ្លាប់បានស្តាប់អំពីពួកបរិព្វាជកជាន់ដើម

ដែលជាអាចារ្យជាប្រធានលើអាចារ្យ ពោលថា លោកទាំងឡាយមានការមិនមានរោគប្រសើរបំផុត ព្រះនិព្វានជាសេចក្តីសុខដ៏ឧត្តមដូច្នេះ ពាក្យថាការមិនមានរោគនោះតើដូចម្តេច ពាក្យថាព្រះនិព្វាននោះតើដូចម្តេច ។ បានឮថា កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយបរិព្វាជកក៏ស្ទាបខ្លួនរបស់ខ្លួនដោយដៃឯងហើយទូលថា បពិត្រព្រះគោតមដ៏ចម្រើន នេះឈ្មោះថាការមិនមានរោគ នេះឈ្មោះថាព្រះនិព្វាន បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គជាអ្នកឥតរោគ បានសេចក្តីសុខ ឥតមានអ្វីមកបៀតបៀនខ្ញុំឡើយ ។

[ ៤៩ ] ម្នាលមាគណ្ឌិយៈ ដូចបុរសខ្វាក់ពីកំណើត បុរសនោះមិនធ្លាប់បានឃើញរូបពណ៌ខ្មៅនឹងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌ហង្សបាទ មិនឃើញទីស្មើនឹងមិនស្មើ មិនឃើញរូបកាយ មិនឃើញព្រះចន្ទ និងព្រះអាទិត្យ ។ បុរសខ្វាក់ពីកំណើតនោះ ឮបុរសមានភ្នែកភ្លឺនិយាយថា អ្នកដ៏ចម្រើន យីអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលទេ ។ បុរសខ្វាក់ពីកំណើតនោះក៏ដើរស្វែងរកសំពត់ស បុរសម្នាក់យកសំពត់ក្រាស់ ដែលធ្វើដោយរោមចៀមខ្មៅ ប្រឡាក់ដោយម្រែងលាយប្រេង មកបញ្ឆោតបុរសនោះថា នែបុរសដ៏ចម្រើន នេះឯងសំពត់សល្អស្អាត ឥតមានមន្ទិលរបស់អ្នកឯង ។ បុរសខ្វាក់ពីកំណើតនោះ ក៏ទទួលយកសំពត់នោះ លុះទទួលហើយយកទៅដណ្តប់ លុះដណ្តប់ហើយ ក៏បញ្ចេញវាចាជាគ្រឿងរីករាយរបស់ខ្លួនថា យីអើ សំពត់

សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ។ ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ចុះបុរសខ្វាក់ពីកំណើតនោះ តើដឹងឃើញឬទេ បានជាទទួលសំពត់ក្រាស់ ដែលធ្វើដោយរោមចៀមខ្មៅ ជ្រលក់ប្រេង លាយប្រេងឯណោះ លុះទទួលហើយ យកមកដណ្តប់ ដណ្តប់ហើយ បញ្ចេញវាចាជាគ្រឿងរីករាយរបស់ខ្លួនថា ឃើអើ សំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ឬក៏ដោយជឿតាមបុរសមានភ្នែកភ្លឺទេ ។ បពិត្រព្រះគោតមដ៏ចម្រើន មិនបានដឹង មិនបានឃើញទេ បុរសខ្វាក់ពីកំណើតឯណោះទទួលសំពត់សាច់ក្រាស់ ដែលធ្វើដោយរោមចៀមខ្មៅ ជ្រលក់ដោយប្រេងលាយប្រេងឯណោះ លុះទទួលហើយក៏ស្លៀកដណ្តប់ លុះដណ្តប់ហើយ បញ្ចេញវាចាជាគ្រឿងរីករាយរបស់ខ្លួនថា ឃើអើសំពត់សស្អាត ល្អបរិសុទ្ធ ឥតមានមន្ទិលមែន ដោយជឿតាមបុគ្គលមានភ្នែកភ្លឺ ( សេចក្តីនេះយ៉ាងណា ) ម្នាលមាគណ្ឌិយៈ ពួកបរិព្វាជកជាអន្យតិរ្ថិយ សុទ្ធតែជាមនុស្សខ្វាក់ ឥតមានចក្ខុ មិនដឹងនូវការមិនមានរោគ មិនឃើញនូវព្រះនិព្វាន ប៉ុន្តែនាំគ្នាពោលគាថានេះថា លាភទាំងឡាយ មានការមិនមានរោគ ដ៏ប្រសើរបំផុត ព្រះនិព្វាន ជាសុខដ៏ឧត្តម ។ ម្នាលមាគណ្ឌិយៈ គាថានេះ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយជាន់ដើម បានពោលហើយថា

លាភទាំងឡាយ មានការមិនមានរោគ ដ៏ប្រសើរបំផុត
ព្រះនិព្វាន ជាសុខដ៏ឧត្តម មគ្គប្រកបដោយអង្គ ៨ ដ៏
ក្សេមក្សាន្តជាងមគ្គទាំងឡាយ សម្រាប់ដំណើរទៅកាន់ ព្រះ

និព្វានឈ្មោះអមតៈ ។

ឥឡូវនេះ គាថានេះជាគាថាសម្រាប់បុថុជ្ជនតាមលំដាប់ ។ ម្នាលមាគណ្ឌិយៈ កាយនេះជារោគ ជាបូស ជាកូនសរ ជាទុក្ខ ជាអាពាធ អ្នកពោលនូវកាយដែលជារោគ ជាបូស ជាកូនសរ ជាទុក្ខ ជាអាពាធនេះថា បពិត្រព្រះគោតមដ៏ចម្រើន នេះឈ្មោះថាការមិនមានរោគ នេះឈ្មោះថាព្រះនិព្វានដូច្នេះវិញ ។ ម្នាលមាគណ្ឌិយៈ អ្នកត្រូវដឹងនូវការមិនមានរោគ ត្រូវឃើញនូវព្រះនិព្វានដោយចក្ខុដ៏ប្រសើរណា ចក្ខុដ៏ប្រសើរនោះ របស់អ្នកមិនមានទេ ។

[ ៥០ ] យ៉ាងហ្នឹងមែនហើយ ខ្ញុំព្រះអង្គជ្រះថ្លាព្រះគោតមដ៏ចម្រើនហើយ ខ្ញុំព្រះអង្គគប្បីដឹងនូវការមិនមានរោគ យល់នូវព្រះនិព្វានដោយឧបាយណា សូមព្រះគោតមដ៏ចម្រើនសម្តែងធម៌ដោយឧបាយនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលមាគណ្ឌិយៈ ដូចបុរសខ្វាក់ពីកំណើត បុរសនោះមិនឃើញ រូបពណ៌ខ្មៅនឹងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌ហង្សបាទ មិនឃើញទីស្មើ និងមិនស្មើ មិនឃើញរូបផ្កាយទាំងឡាយ មិនឃើញព្រះចន្ទ និងព្រះអាទិត្យទាំងឡាយទេ ។ មិត្តអាមាត្យញាតិសាលោហិតរបស់បុរសខ្វាក់ពីកំណើតនោះ ឲ្យពេទ្យអ្នកវះថែរក្សា ពេទ្យអ្នកវះក៏បានផ្សំថ្នាំឲ្យបុរសនោះ បុរសខ្វាក់ពីកំណើតនោះ បានអាស្រ័យថ្នាំនោះហើយ ក៏មិនញុំាងចក្ខុទាំង ២ ឲ្យកើតឡើង មិនញុំាងចក្ខុទាំង ២ ឲ្យភ្លឺឡើងវិញបាន ។ ម្នាលមាគណ្ឌិយៈ អ្នកសម្គាល់ហេតុនោះ

ដូចម្តេច ក្រែងពេទ្យនោះ គ្រាន់តែបានចំណែកនៃសេចក្តីលំបាកកាយ និងចង្អៀតចង្អល់ចិត្តទេឬ ។ បពិត្រព្រះគោតមដ៏ចម្រើន យ៉ាងហ្នឹងមែនហើយ ។ ម្នាលមាគណ្ឌិយៈ បើតថាគតនឹងសម្តែងធម៌ដល់អ្នកថា នេះជាការមិនមានរោគ នេះជាព្រះនិព្វានដូច្នេះ អ្នកក៏មិនដឹងនូវការមិនមានរោគ មិនឃើញនូវព្រះនិព្វាន សេចក្តីលំបាកនោះ ក៏នឹងមានដល់តថាគត សេចក្តីចង្អៀតចង្អល់នោះ ក៏នឹងមានដល់តថាគត មានឧបមេយ្យដូចពេទ្យវះដូច្នោះឯង ។

[ ៥១ ] យ៉ាងហ្នឹងមែនហើយ ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីឃើញនូវការមិនមានរោគ និងព្រះនិព្វានដោយឧបាយណា សូមព្រះគោតមដ៏ចម្រើន សម្តែងធម៌ដោយឧបាយនោះ ដល់ខ្ញុំព្រះអង្គចុះ ។ ម្នាលមាគណ្ឌិយៈ ដូចបុរសខ្វាក់ពីកំណើត បុរសខ្វាក់នោះ មិនឃើញរូបពណ៌ខ្មៅ និងស មិនឃើញរូបពណ៌ខៀវ មិនឃើញរូបពណ៌លឿង មិនឃើញរូបពណ៌ក្រហម មិនឃើញរូបពណ៌ហង្សបាទ មិនឃើញទីស្មើ និងមិនស្មើ មិនឃើញរូបផ្កាយទាំងឡាយ មិនឃើញព្រះចន្ទ និងព្រះអាទិត្យទាំងឡាយ ។ បុរសខ្វាក់ពីកំណើតនោះ ឮបុរសមានភ្នែកភ្លឺនិយាយថា យីអើ សំពត់សស្អាតល្អបរិសុទ្ធ ឥតមានមន្ទិលទេ ។ បុរសខ្វាក់ពីកំណើតនោះ ក៏ដើរទៅស្វែងរកសំពត់ស បុរសម្នាក់យកសំពត់សាច់ក្រាស់ ដែលធ្វើដោយរោមចៀមខ្មៅ ជ្រលក់ដោយម្រែងលាយប្រេង មកបញ្ឆោតបុរសនោះថា នែបុរសដ៏ចម្រើន នេះឯងជាសំពត់សល្អបរិសុទ្ធ ឥតមានមន្ទិល របស់អ្នក ។ បុរសខ្វាក់ពីកំណើតនោះ ក៏ទទួលសំពត់នោះ យកមកស្លៀកដណ្តប់ មិត្ត

អាមាត្យញាតិ សាលោហិតរបស់បុរសនោះ ឲ្យពេទ្យអ្នកវះថែរក្សា ពេទ្យអ្នកវះនោះ ក៏ធ្វើថ្នាំឲ្យបុរសនោះ គឺថ្នាំធ្វើឲ្យក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ ថ្នាំលាង និងថ្នាំផឹក ។ បុរសខ្វាក់ពីកំណើតនោះ លុះបានអាស្រ័យថ្នាំនោះហើយ ក៏បាន ញុំាងចក្ខុឲ្យកើតឡើង បានញុំាងចក្ខុឲ្យភ្លឺឡើងវិញ បានសេចក្តីពេញចិត្តណា ក្នុងសំពត់សាច់គ្រាស់ ដែលធ្វើដោយរោមចៀមខ្មៅ ជ្រលក់ដោយប្រេងលាយ ប្រេងឯណោះ បុរសនោះក៏លះបង់ក្នុងពេលដែលបានជាភ្នែកភ្លឺឡើងវិញបុរស ដែលមានភ្នែកភ្លឺនោះ ក៏ទុកបុរសដែលបញ្ឆោតនោះ ដោយភាពមិនមែនជា មិត្តផង ដោយភាពជាសឹកសត្រូវផង ឬក៏គប្បីសម្គាល់ថាត្រូវ សម្លាប់ចោល ក៏សឹងតែបាន ដោយគិតថា ឱហ្ន៎ ខ្លួនអាត្មាអញត្រូវបុរសនេះ យកសំពត់ គ្រាស់ដែលធ្វើដោយរោមចៀមខ្មៅ ជ្រលក់ដោយប្រេងលាយប្រេង មកបោក បញ្ឆោតប្រលោម អស់កាលយូរហើយថា នែបុរសដ៏ចម្រើន នេះសំពត់ស ស្អាត ល្អបរិសុទ្ធឥតមានមន្ទិល របស់អ្នក ( សេចក្តីនេះយ៉ាងណាមិញ ) ម្នាលមាគណ្ឌិយៈ តថាគតបើនឹងសម្តែងធម៌ដល់អ្នកថា នេះជាការមិនមាន រោគ នេះជាព្រះនិព្វាន ក៏យ៉ាងដូច្នោះដែរ ។ អ្នកគប្បីដឹងការមិនមានរោគ ឃើញនូវព្រះនិព្វាន ឆន្ទៈរាគណាក្នុងឧបាទានក្ខន្ធទាំង ៥ ឆន្ទៈរាគៈនោះ អ្នកលះបង់ក្នុងពេលដែលចក្ខុកើតឡើងដល់អ្នក មួយទៀត អ្នកត្រូវមាន សេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ចិត្តនេះបោកបញ្ឆោតប្រលោមអាត្មាអញ អស់ កាលយូរមកហើយ បានជាអាត្មាអញកាលដែលប្រកាន់ ក៏ប្រកាន់ចំពោះ រូបហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះវេទនាហ្នឹងឯង កាលដែល

ប្រកាន់ ក៏ប្រកាន់ចំពោះសញ្ញាហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះសង្ខារហ្នឹងឯង កាលដែលប្រកាន់ ក៏ប្រកាន់ចំពោះវិញ្ញាណហ្នឹងឯង ភពកើតឡើងដល់អាត្មាអញនោះ ព្រោះមានឧបាទានជាបច្ច័យ ជាតិកើតឡើងព្រោះមានភពជាបច្ច័យ ជរាមរណៈ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីខ្វាចផ្សាចិត្ត កើតឡើងព្រោះមានជាតិជាបច្ច័យ ការដែលកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតឡើងដោយប្រការយ៉ាងនេះ ។

[ ៥២ ] ខ្ញុំព្រះអង្គជ្រះថ្លា ចំពោះព្រះគោតមដ៏ចម្រើនយ៉ាងនេះ ខ្ញុំព្រះអង្គលែងខ្វាក់ គប្បីក្រោកអំពីអាសនៈនេះបាន យ៉ាងណា សូមព្រះគោតមដ៏ចម្រើន សម្តែងធម៌យ៉ាងនោះ ដល់ខ្ញុំព្រះអង្គចុះ ។ ម្នាលមាគណ្ឌិយៈ បើដូច្នោះចូរអ្នកសេពគប់នឹងពួកសប្បុរស ម្នាលមាគណ្ឌិយៈ កាលណាអ្នកសេពគប់នឹងពួកសប្បុរសហើយ ម្នាលមាគណ្ឌិយៈ កាលនោះអ្នកនឹងបានស្តាប់នូវព្រះសទ្ធម្ម ម្នាលមាគណ្ឌិយៈ កាលណាអ្នកស្តាប់ព្រះសទ្ធម្មហើយ ម្នាលមាគណ្ឌិយៈ កាលនោះ អ្នកនឹងបានប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ម្នាលមាគណ្ឌិយៈ កាលណាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ហើយ ម្នាលមាគណ្ឌិយៈ កាលនោះអ្នកនឹងដឹងដោយខ្លួនឯង ឃើញច្បាស់ដោយខ្លួនឯងថា នេះជារោគ នេះជាបូស នេះជាកូនសរ រោគបូសនឹងកូនសរ រមែងរលត់ទៅឥតមានសេសសល់ក្នុងទីនេះ ការរលត់ទៅនៃភពរបស់អាត្មាអញនោះ ព្រោះរលត់ឧបាទាន ការរលត់ទៅនៃជាតិ ព្រោះរលត់ភព ជរា មរណៈ សេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីខ្វាចផ្សាចិត្ត

រលត់ទៅព្រោះរលត់ជាតិ ការរលត់ទៅនៃកងទុក្ខទាំងអស់នេះ រមែងមាន ដោយប្រការយ៉ាងនេះ ។

[ ៥៣ ] កាលដែលព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ មាគណ្ឌិយបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ប្រកាសហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាគេផ្ងាររបស់ ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលបិទបាំងទុក ឬប្រាប់ផ្លូវដល់មនុស្សវង្វេងទិស ពុំនោះសោតដូចជាទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកភ្លឺ រមែងមើលឃើញរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ ខ្ញុំព្រះអង្គគួរបានបព្វជ្ជា គួរបានឧបសម្បទា ក្នុងសំណាក់ព្រះគោតមដ៏ចម្រើន ។ ម្នាលមាគណ្ឌិយៈ បុគ្គលណាធ្លាប់ជាអន្យតិរ្ថិយមកពីមុន ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ បុគ្គលនោះត្រូវនៅបរិវាសអស់ ៤ ខែសិន លុះកន្លង ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បីភាពជាភិក្ខុបាន មួយទៀត បែបភាពរបស់បុគ្គលផ្សេងគ្នា ( ការដែលនៅបរិវាសឬមិននៅបរិវាស ) ក្នុងដំណើរនេះ តថាគតដឹងច្បាស់ហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើបុគ្គលធ្លាប់ជាអន្យតិរ្ថិយមកពីមុន ប្រាថ្នាបព្វជ្ជា ប្រាថ្នាឧបសម្បទាក្នុងធម្មវិន័យនេះ ត្រូវនៅបរិវាសឲ្យអស់ ៤

ខែសិន លុះកន្លង ៤ ខែហើយ ពួកភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទាបាន ខ្ញុំព្រះអង្គនឹងនៅបរិវាសឲ្យអស់ ៤ ឆ្នាំ លុះកន្លង ៤ ឆ្នាំ ហើយ សូមឲ្យភិក្ខុដែលមានចិត្តប្រារព្ធហើយ ឲ្យបព្វជ្ជា ឧបសម្បទា ដើម្បី ភាពជាភិក្ខុចុះ ។ មាគណ្ឌិយបរិព្វាជក បានន្ទូវបព្វជ្ជា បានន្ទូវឧបសម្បទា ក្នុង សំណាក់នៃព្រះមានព្រះភាគ ។ លុះមាគណ្ឌិយមានអាយុ ឧបសម្បទាហើយ មិនយូរប៉ុន្មាន ក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ ព្យាយាមដុត កម្តៅកិលេស បញ្ជូនចិត្តទៅកាន់ព្រះនិព្វាន មិនយូរប៉ុន្មាន ក៏បានធ្វើឲ្យជាក់ ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវគុណវិសេសដ៏ ប្រសើរ ដ៏ជាទីបំផុតនៃព្រហ្មចរិយៈ ដែលពួកកុលបុត្តចេញចាកផ្ទះដោយ ប្រពៃ ហើយបួសក្នុងភេទនៃបុគ្គលមិនមានផ្ទះ ដើម្បីសេចក្តីត្រូវការ ហើយ សម្រេចសម្រាន្តនៅ បានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ បាននៅចប់ហើយ កិច្ចដែលគួរធ្វើបានធ្វើស្រេចហើយ កិច្ចដទៃដើម្បីកិច្ចនេះ ទៀតមិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ មាគណ្ឌិយមានអាយុ ក៏បានជាព្រះអរហន្ត ១ អង្គដែរ ។

**ចប់ មាគណ្ឌិយសូត្រទី ៥**

# អដ្ឋកថា

## មាគណ្ឌិយសូត្រ

[ ៣៧ ] មាគណ្ឌិយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អគ្យាគារេ** គឺក្នុងរោងបូជាភ្លើង ។ បទថា **តិណសន្ថរកេ** គឺលើកម្រាលដែលធ្វើដោយស្មៅ ។ មាគណ្ឌិយបរិព្វាជក ២ នាក់ អ៊ំក្មួយ ។ ក្នុង ២ នាក់នោះ អ៊ំបួសបានសម្រេចអរហត្ត ។ សូម្បីក្មួយក៏មានឧបនិស្ស័យបួស មិនយូរប៉ុន្មាននឹងសម្រេចអរហត្ត ។ គ្រានោះ ព្រះមានព្រះភាគ ឃើញឧបនិស្ស័យរបស់មាគណ្ឌិយបរិព្វាជកនោះ ទ្រង់ចេញពីព្រះគន្ធកុដិ ដែលប្រៀបដូចទេវស្ថាន ទ្រង់ឲ្យក្រាលកម្រាលដែលធ្វើដោយស្មៅ ត្រង់រោងបូជាភ្លើងនោះស្មោកគ្រោកទៅដោយ វល្លិ ស្មៅ និងសំរាម ទ្រង់ប្រថាប់នៅ ២-៣ ថ្ងៃ ដើម្បីធ្វើការសង្គ្រោះអ្នកដទៃ ។ លោកពោលបទថា **តេនុបសង្កមិ** ប្រែថា យាងចូលទៅ សំដៅដល់រោងបូជាភ្លើងនោះ ។ តែព្រោះរោងបូជាភ្លើងនោះ មិននៅជិតស្រុកតែម្យ៉ាង ពេលថ្ងៃប៉ុណ្ណោះ ពួកក្មេងប្រុស និងក្មេងស្រីទៅលេងចុះឡើង មិនមានការស្ងប់ ។ ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់ឲ្យពេលថ្ងៃកន្លងទៅក្នុងព្រៃស្រោងអស់កាលជានិច្ច ។ ក្នុងពេលល្ងាច ទើបទ្រង់យាងចូលទៅក្នុងរោងបូជាភ្លើងនោះ ដើម្បីប្រថាប់នៅ ។

[ ៣៧ ] បទថា **អទ្ទសា ខោ តិណសន្ថរកំ បញ្ញត្តំ** គឺព្រះមានព្រះភាគ ទ្រង់តាក់តែងកម្រាលធ្វើដោយស្មៅក្នុងថ្ងៃដទៃ ហើយទ្រង់ធ្វើគ្រឿងសម្គាល់តាំងទុក ទ្រង់យាងត្រឡប់ទៅ ។ ក្នុងថ្ងៃនោះឯង

ទ្រង់បានក្រាលហើយយាងទៅ ។ ព្រោះហេតុអ្វី ព្រោះកាលពេលទៀបភ្លឺ ទ្រង់ប្រមើលមើលនូវលោក បានឃើញថា ថ្ងៃនេះមាគណ្ឌិយនឹងមកក្នុងទីនេះ កាលឃើញកម្រាល ដែលធ្វើដោយស្មៅនេះហើយ នឹងសន្ទនាប្រារព្ធរឿងកម្រាលដែលធ្វើដោយស្មៅជាមួយនឹងការទ្វាជព្រាហ្មណ៍ ។ បន្ទាប់អំពីនោះ តថាគតនឹងមកសម្តែងធម៌ មាគណ្ឌិយព្រាហ្មណ៍ស្តាប់ធម៌ហើយ នឹងបួសក្នុងសម្នាក់របស់តថាគត ហើយសម្រេចអរហត្ត ។ ពិតហើយ តថាគតបំពេញបារមីមកក៏ដើម្បីធ្វើការសង្គ្រោះអ្នកដទៃ ទើបទ្រង់ក្រាលនូវកម្រាលដែលធ្វើដោយស្មៅ ហើយយាងទៅ ។

បទថា **សមណសេយ្យានុរូបំ មញ្ញេ** គឺសម្គាល់នូវកម្រាលនេះថា ជាទីដេកសមគួរដល់សមណៈ ។ ម្យ៉ាងទៀត កម្រាលនេះមិនមែនលំនៅរបស់សមណៈដែលមិនសង្រួមហើយ ។ សេចក្តីពិតយ៉ាងនោះ ដែលកម្រាលនេះមិនបានប្រាកដ ដែលត្រូវក្តិះដោយដៃ ដែលត្រូវប៉ះខ្ទប់ដោយក្បាល ឬដែលត្រូវកៀរដោយជើង ។ កម្រាលនេះមិនរាត់រាយ មិនខ្ចាត់ខ្ចាយ មិនត្រូវទម្លាយ ដូចជាងលាបពណ៌ដ៏ឈ្លាស យកដីសលាប ហើយក្រាលទុក គង់ជាលំនៅរបស់សមណៈ អ្នកសង្រួមហើយ ។ ទើបមាគណ្ឌិយព្រាហ្មណ៍សួរថា លោកដ៏ចម្រើន នេះជាលំនៅរបស់អ្នកណា ។ បទថា **ភូនហានស្ស** គឺអ្នកសាងមារយាទ ។ ព្រោះហេតុអ្វី ទើបមាគណ្ឌិយពោលយ៉ាងនោះ ព្រោះគាត់មានលទ្ធិ គឺធ្វើឲ្យការចម្រើនប្រាកដក្នុងទ្វារ ៦ នេះជាលទ្ធិរបស់បុគ្គលនោះ គឺគួរធ្វើឲ្យចក្ខុដុះដាល ចម្រើន ។ គប្បីឃើញរូបដែលមិនធ្លាប់ឃើញ

រូបដែលឃើញហើយ គួរកន្ទ្រងទៅ ។ គួរឲ្យសោតដុះដាលចម្រើន គួរស្តាប់សំឡេងដែលមិនធ្លាប់ស្តាប់ ។ សំឡេងដែលស្តាប់ហើយ គួរច្រូងទៅ ។ គួរឲ្យឃានៈដុះដាលចម្រើន គួរហិតក្លិនដែលមិនធ្លាប់ហិត ។ ក្លិនដែលធ្លាប់ហិតហើយ គួរច្រូងទៅ ។ គួរឲ្យជិវ្ហាដុះដាលចម្រើន ។ គួរលិទ្ធរសដែលមិនធ្លាប់លិទ្ធ ។ រសដែលលិទ្ធហើយ គួរច្រូងទៅ ។ គួរឲ្យកាយដុះដាលចម្រើន គួរប៉ះផោដ្ឋព្វៈ ដែលមិនធ្លាប់ប៉ះ ។ ផោដ្ឋព្វៈដែលធ្លាប់ប៉ះហើយ គួរច្រូងទៅ ។ គួរឲ្យមនៈ ដុះដាលចម្រើន គួរដឹងធម៌ដែលមិនធ្លាប់ដឹង ធម៌ដែលដឹងហើយ គួរច្រូងទៅ ។ មាគណ្ឌិយបញ្ញត្តការចម្រើនក្នុងទ្វារ ៦ ទុកដោយប្រការដូច្នេះ ។

តែព្រះមានព្រះភាគ ទ្រង់បញ្ញត្តការសង្រួមក្នុងទ្វារ ៦ ទុកថា

ការសង្រួមភ្នែកប្រពៃ ការសង្រួមត្រចៀកប្រពៃ ការសង្រួមច្រមុះប្រពៃ ការសង្រួមអណ្តាតប្រពៃ ការសង្រួមកាយប្រពៃ ការសង្រួមវាចាប្រពៃ ការសង្រួមចិត្តប្រពៃ ការសង្រួមទាំងអស់ប្រពៃ ភិក្ខុសង្រួមហើយក្នុងទ្វារទាំងអស់ តែងរួចស្រឡះចាកទុក្ខទាំងពួងបាន ។

ព្រោះដូច្នោះ មាគណ្ឌិយព្រាហ្មណ៍សម្គាល់ថា ព្រះសមណគោតមនោះជាអ្នកកម្ចាត់សេចក្តីចម្រើន ជាអ្នកសាងមារយាទ ទើបពោលថា **ភូនហានោ** ដូច្នេះ ។ បទថា **អរិយេ ញាយេ ធម្មេ កុសលេ** គឺក្នុងហេតុ ក្នុងធម៌បរិសុទ្ធមិនមានទោស ។ ដោយបទនេះ ទ្រង់សម្តែងទុកដូចម្តេច បុគ្គលទោះពោលវាចាដល់អ្នកមានយស មានភាពខ្ពង់ខ្ពស់ដែលគេស្គាល់ទូទៅបែបនេះ គួរ-

ត្រិះរិះពិចារណា មិនគួរពោលដោយមិនប្រយ័ត្នមាត់ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា អ្នកកុំពោលផ្តេសផ្តាស អ្នកចូរប្រយ័ត្នមាត់ ។ បទថា **ឯវំ ហិ នោ សុត្តេ ឱចរតិ** សេចក្តីថា ព្រោះថា បទនេះមកក្នុងសូត្ររបស់ពួកយើង ។ ពួកយើងមិនពោលត្រឹមប្រាថ្នាឲ្យដុះដាលតាមមាត់ប៉ុណ្ណោះ ។ម្យ៉ាងទៀត ពួកយើងកាលនិយាយពាក្យដែលមកហើយក្នុងសូត្រគប្បីនិយាយដល់នរណា ដូច្នោះយើងនឹងពោលចំពោះមុខព្រះសមណគោតមនោះ ។ បទថា **អប្បោស្សុក្កោ** សេចក្តីថា មិនខ្វល់ខ្វាយ គឺមិនកន្វល់ដើម្បីនឹងរក្សាខ្ញុំ ។ បទថា **វុត្តោ ច នំ វទេយ្យ** សេចក្តីថា ការទ្វាដដ៏ចម្រើន ខ្ញុំបានពោលទុកហើយ សូម្បីមិនសួរ ក៏តាំងវាចាបាន កាន់យកស្វាយនិង ព្រីងជាដើមហើយ នៅតែមិនគ្រប់ ក៏គប្បីពោលនឹងព្រះសមណគោតមដោយទំនង ដែលខ្ញុំពោលហើយចុះ ។

[ ៣៩ ] បទថា **អស្សោសិ ខោ** សេចក្តីថា ព្រះសាស្តា ទ្រង់ចម្រើនអាលោកកសិណ ទ្រង់បានឃើញមាគណ្ឌិយព្រាហ្មណ៍ដែលមកក្នុងទីនោះ ដោយទិព្វចក្ខុ ទ្រង់បានស្តាប់សំឡេងរបស់ជនទាំងពីរសន្ទនាគ្នាដោយទិព្វសោត ។

បទថា **បដិសល្លានា វុដ្ឋិតោ** សេចក្តីថា ព្រះមានព្រះភាគចេញអំពីទីពួនសម្ងំ គឺចេញអំពីផលសមាបត្តិ ។ បទថា **សំវិគ្គោ** គឺការទ្វាជព្រាហ្មណ៍តក់ស្លុត ភ្ញាក់ដោយកម្លាំងនៃបីតិ ។ បានឮថា ការទ្វាជព្រាហ្មណ៍មានការត្រិះរិះថា មាគណ្ឌិយ និងអញក៏មិនបាននិយាយជាមួយព្រះសមណគោតម អ្នកដទៃក្រៅអំពីអញទាំង ២ នាក់ក្នុងទីនេះ មិនមានអ្នកទី ៣ ។ បុរសមាន

សោតវិញ្ញាណទិព្វនឹងបានឮសំឡេងរបស់អញទាំង ២ ដោយពិត ។ លំដាប់នោះ ការទាស់ប្រាហ្មណ៍កើតបីតិខាងក្នុង រណ្តៅ៧ ៩ ម៉ឺនបានបះហើយ ។ ដោយហេតុនោះ ទើបលោកពោលថា **សុវិញ្ញោ លោមហដ្ឋជាតោ** ដូច្នេះ ។

លំដាប់នោះ មាគណ្ឌិយបរិញ្វជក ទាំងដែលមានញាណចាស់ក្លា ដូចគ្រាប់ពូជដែលមានសម្បកបើកហើយ មិនអាចអង្គុយស្ងប់ បានដើរចង្ក្រម ហើយមកគាល់ព្រះសាស្តាទៀត អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ដើម្បីសម្តែងដល់មាគណ្ឌិយនោះ ទើបពោលបទថា **អថ ខោ មាគណ្ឌិយោ** ដូច្នេះ ជាដើម ។

[ ៤០ ] បានឮថា ព្រះសាស្តាមិនបានត្រាស់យ៉ាងនេះថា ម្នាលមាគណ្ឌិយ អ្នកបានពោលជាមួយគថាគតហើយ ដូច្នេះ ទ្រង់ប្រារព្ធធម្មទេសនាដល់បរិញ្វជកថា **ចក្ខុ ខោ មាគណ្ឌិយ** ដូច្នេះ ។ ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះថា ឈ្មោះថា **ចក្ខុ រូបារាមំ** ព្រោះរូបជាទីមកត្រេកអរនៃចក្ខុដោយអត្ថថា ជាទីអាស្រ័យ ។ ឈ្មោះថា **រូបរតំ** ព្រោះចក្ខុត្រេកអរក្នុងរូប ។ ឈ្មោះថា **រូបសម្មុទិតំ** ព្រោះចក្ខុដែលរូបឲ្យត្រេកអរហើយ ។ បទថា **ទន្តំ** ប្រែថា ទូន្មានហើយ គឺឲ្យអស់ពុតត្បុតហើយ ។ បទថា **គុត្តំ** គឺ គ្រប់គ្រងហើយ ។ បទថា **រក្ខិតំ** គឺតាំងការរក្សាទុកហើយ ។ បទថា **សំវុតំ** គឺបិទហើយ ។ បទថា **សំវរាយ** គឺដើម្បីត្រូវការបិទ ។

[ ៤១ ] បទថា **បរិចារិតបុព្វោ** គឺធ្លាប់ចរចាប្រាស្រ័យ ។ បទថា **រូបបរិឡាហំ** គឺក្តៅក្រហាយកើតឡើង ព្រោះប្រារព្ធរូប ។ បទថា **ឥមស្ស បន តេ មាគណ្ឌិយ កិមស្ស វចនីយំ** គឺអ្នកគប្បីពោលពាក្យ

អ្វីដល់ព្រះខីណាស្រពនេះ ដែលកំណត់រូប ហើយសម្រេចអរហត្ត ។ សួរថា គួរនឹងពោលថា ព្រះសមណគោតមជាអ្នកកម្ចាត់នូវការចម្រើនជាសាងមារយាទ ដូច្នេះ ឬមិនគួរពោល ។ បទថា **ឯ កិញ្ចិ ភោ គោតម** គឺ បពិត្រព្រះគោតមដ៏ចម្រើន មិនគួរពោលពាក្យណាមួយឡើយ ។ សូម្បីក្នុងទ្វារដ៏សេស ក៏មានន័យនេះដូចគ្នា ។

[ ៤២ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្តែងថា មិនមានពាក្យណាមួយ ដែលលោកនឹងពោលដល់ព្រះខីណាស្រព ដែលកំណត់ខន្ធ ៥ ហើយសម្រេច ព្រះអរហត្ត ហើយតថាគតក៏កំណត់ខន្ធ ៥ សម្រេចព្រះសព្វញ្ញូ ។ ដូច្នោះ មាគណ្ឌិយនោះនឹងគួរពោលអ្វីជាមួយតថាគត ដូច្នេះទើបត្រាស់ថា **អហំ ខោ បន** ដូច្នេះ ។ បទថា **តស្ស មយ្ហំ មាគណ្ឌិយ** គឺព្រះមានព្រះភាគ កាលទ្រង់សម្តែងសម្បត្តិ របស់ព្រះអង្គកាលនៅជាគ្រហស្ថទើបត្រាស់ ។ គប្បីជ្រាបសេចក្តីក្នុងបទថា **វស្សិកោ** ជាដើមនោះ ដូចតទៅនេះ ។ សេចក្តីសុខរមែងមានក្នុងលំនៅ ក្នុងរដូវភ្លៀងនេះ គឺប្រាសាទក្នុងរដូវភ្លៀង ។ សូម្បីបទក្រៅអំពីនោះ ក៏មានន័យនេះដូចគ្នា ។ តែក្នុងបទនេះមានអធិប្បាយដូចតទៅនេះ ។ ឈ្មោះថា **វស្សិកោ** ព្រោះគួរនៅក្នុងរដូវភ្លៀង ។ ក្នុងបទក្រៅអំពីនេះ ក៏មានន័យនេះ ដូចគ្នា ។ ក្នុងបទនោះ ប្រាសាទសម្រាប់រដូវភ្លៀង មិនខ្ពស់ពេក មិនទាបពេក ។ ទ្វារ និងបង្អួចនៃប្រាសាទនោះ ក៏មិនតិចពេក មិនច្រើនពេក កម្រាលផ្ទៃ របស់ទំពា របស់បរិភោគក្នុងប្រាសាទនេះមានគ្រប់គ្រាន់ ។ ក្នុងប្រាសាទដែលសម្រាប់នៅក្នុងរដូវរងា

សសរក្តី ជញ្ជាំងក្តី ទាប ៗ ទ្វារ និងបង្អួចក៏មានតិច និងមានប្រហោងតូច ៗ យកប្រហោងជញ្ជាំងចេញ ដើម្បីត្រូវការកម្តៅខាងក្នុង ។ ម្យ៉ាងទៀត ក្នុងប្រាសាទនេះ កម្រាលផ្ទៃ កម្រាលខាងលើ គ្រឿងស្លៀកដណ្តប់គួរជាសំពត់កម្ពលជាដើម ដែលជួយឲ្យក្តៅបាន ។ របស់ទំពា របស់បរិភោគ ល្អិតទន់មានរសប្រៃហឹរ ។ ក្នុងប្រាសាទដែលជាលំនៅក្នុងរដូវក្តៅ សសរក្តី ជញ្ជាំងក្តី ខ្ពស់ ។ ទ្វារ និងបង្អួចក្នុងប្រាសាទនេះមានច្រើន មានពន្លឺភ្លឺទូទៅ ។ កម្រាលផ្ទៃជាដើម គួរជាសំពត់សាច់ល្អ របស់ទំពា និងរបស់បរិភោគ មានរសផ្អែម ធ្វើឲ្យបានទទួលនូវភាពត្រជាក់ ។ ម្យ៉ាងទៀត ក្នុងទីជិតបង្អួចក្នុងប្រាសាទនេះ តាំងពាងទឹកទុក ៩ ពាង ពេញដោយទឹក ដាំឈូកខៀវជាដើមទុក ។ ក្នុងទីនោះ ធ្វើទីទឹកធ្លាក់ទុក ខ្សែទឹកធ្លាក់ចុះមក ដូចភ្លៀងធ្លាក់ ។ តែប្រាសាទរបស់ព្រះពោធិសត្វ គេដាំឈូក ខៀវទុកក្នុងថ្នាំងមាស និងថ្នាំងប្រាក់ នីមួយៗ ១០៨ ពេញទៅដោយទឹកក្រអូបព័ទ្ធជុំវិញបន្ទប់ដេក ។ ដាក់កក់ក្រអូបឲ្យពេញភាជនៈលោហៈ ដាំឈូកខៀវ ឈូកសជាដើម តាំងទុកក្នុងទីនោះៗ ដើម្បីកាន់យកឧតុ ។ ផ្កាទាំងឡាយរមែងរីកដោយរស្មីរបស់ព្រះអាទិត្យ ។ ពួកកមរច្រើនប្រភេទ ហើរចូលទៅកាន់ប្រាសាទ ក្រេបរសកេសរក្នុងផ្កាទាំងឡាយ ។ ប្រាសាទមានក្លិនក្រអូបឈ្ងុយឈ្ងប់ពន់ពេក ។ ក្នុងចន្លោះគូជញ្ជាំង បានតាំងនាឡិលោហៈ ហើយអុជប្រទីប មានរស្មីស្រទន់ទុកត្រង់មណ្ឌបកែវ លើហឹង ខាងលើប្រាសាទ ៩ ជាន់ ។ ក្រាលស្បែកក្របីស្ងួតក្នុងទីមួយកន្លែង ។ ក្នុងវេលាព្រះពោធិសត្វលេងទឹក ទ្រង់ទតថ្ង

សំលៀងត្រង់ស្បែកក្របី ។ គ្រឿងយន្តវិលទៅខាងក្រោម ដូចសំឡេងផ្គរគំរាម ។ ទឹកខ្ពុរឡើងហើយធ្លាក់ទៅត្រង់អណ្តាតភ្លើង ។ ដូចទឹកភ្លៀងធ្លាក់ កាលនោះព្រះពោធិសត្វ ទ្រង់សំពត់ខៀវ ដណ្តប់សំពត់ខៀវ ទ្រង់ប្រដាប់អលង្ការពណ៌ខៀវ សូម្បីពួកបរិវាររបស់ព្រះពោធិសត្វ មានអ្នករបាំ ៤ ម៉ឺន ប្រដាប់ដោយពណ៌ខៀវ តែងខ្លួនពណ៌ខៀវ ហែហមព្រះមហាបុរសទៅកាន់មណ្ឌបកែវ ។ ព្រះពោធិសត្វ ទ្រង់លេងកីឡា ក្នុងទឹកអស់មួយថ្ងៃ សោយសុខក្នុងឧតុដ៏ត្រជាក់ ។ ក្នុងទិស ៤ នៃប្រាសាទ មានស្រះ ៤ ក្នុងពេលថ្ងៃ ហ្វូងបក្សីច្រើនប្រភេទ ចេញចាកស្រះទិសខាងកើត បន្លឺសំឡេងរងំ ហើរទៅកាន់ស្រះទិសខាងលិច តាមផ្លូវកំពូលប្រាសាទ ចេញពីស្រះទិសខាងលិច ហើរទៅកាន់ស្រះទិសខាងកើត ចេញពីស្រះទិសខាងជើងទៅកាន់ ស្រះទិសខាងត្បូង ចេញពីស្រះទិសត្បូង ទៅកាន់ស្រះទិសខាងជើង ។ ដូចសម័យក្នុងរវាងរដូវភ្លៀង ។ ប្រាសាទសម្រាប់នៅក្នុងរដូវរងាមាន ៥ ជាន់ ប្រាសាទនៅក្នុងរដូវភ្លៀងមាន ៧ ជាន់ ។

បទថា **និប្បុរិសេហិ** គឺវៀរចាកបុរស ។ ម្យ៉ាងទៀត មិនមែនតែអ្នកតន្ត្រីប៉ុណ្ណោះ ដែលមិនមានបុរសលាយឡំ សូម្បីក្នុងទីគ្រប់ កន្លែងក៏មិនមានបុរសដូចគ្នា សូម្បីអ្នកយាមទ្វារក៏ជាស្ត្រី ។ សូម្បីអ្នកធ្វើការបម្រើ មានងូតទឹកឲ្យជាដើមក៏ជាស្រី ។ បានឮថា ព្រះរាជាទ្រង់តាំងពួកស្ត្រីទុកក្នុងកិច្ចគ្រប់យ៉ាង ដោយទ្រង់ព្រះតម្រិះថា កាលពោធិសត្វសោយឥស្សរិយយសសម្បត្តិ និងសុខសម្បត្តិបែបនោះនឹងកើតការជាប់ជំពាក់ចិត្តក្នុងបុរស ព្រោះ

ឃើញបុរស ការជាប់ជំពាក់ចិត្តនោះកុំបីមានដល់ឱរសរបស់អញឡើយ ។ បទថា **តាយ រតិយា រមមានោ** នេះលោកពោលសំដៅដល់ការត្រេកអរក្នុងផលសមាបត្តិ ដែលប្រកបដោយឈានទី ៤ ។

[ ៤៣ ] គប្បីជ្រាបក្នុងបទនេះថា **គហបតិ វា គហបតិបុត្តោ វា** ដូចតទៅនេះថា ព្រោះក្សត្រិយ៍ទាំងឡាយ រមែងមានសេចក្តីប្រាថ្នាក្នុងស្វេតច្ឆត្រទាំងអស់ ។ ការប្រាថ្នាធំ ជាការយឺតយូររបស់ក្សត្រិយ៍ទាំងនោះ ។ ព្រាហ្មណ៍ទាំងឡាយមិនឆ្អែតដោយមន្ត ទើបស្វែងរកមន្ត ។ ឯគហបតី ទាំងឡាយរមែងសោយសម្បត្តិ តាំងអំពីកាលរៀនត្រឹមតែគណនាជាន់ខ្ពស់ ។ ដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់មិនកាន់យកក្សត្រិយ៍ និងព្រាហ្មណ៍ ត្រាស់ថា **គហបតិ វា គហបតិបុត្តោ វា** ដូច្នេះ ។ បទថា **អាវដ្ដេយ្យ** សេចក្តីថា គប្បីវិលមក ព្រោះហេតុនៃកាមដែលជារបស់មនុស្ស ។ បទថា **អភិក្កន្តតរា** គឺប្រសើរជាង ។ បទថា **បណីតតរា** ប្រណីតជាង គឺមិនតិចជាង ។ សមដូចដែលលោកពោលដល់សេចក្តីនេះទុកថា

បុគ្គលយកទឹកដោយចុងស្មៅ មកប្រៀបផ្ទឹមនឹងទឹកក្នុងសមុទ្រយ៉ាងណា កាមទាំងឡាយជារបស់មនុស្ស ( ប្រៀបផ្ទឹម ) ក្នុងសម្នាក់នៃកាមជាទិព្វក៏យ៉ាងនោះដែរ ។

បទថា **សមធិគ្គយ្ហ តិដ្ឋតិ** គឺកាន់យកសុខដែលជាទិព្វប្រសើរជាងនោះតាំងនៅ ។ ម្យ៉ាងទៀត គប្បីជ្រាបការប្រៀបធៀបក្នុងសេចក្តីនេះ ដូចតទៅនេះ ។ កាលនៃការត្រេកអរក្នុងចំណោមស្រី ៤ ម៉ឺន ក្នុងប្រាសាទ ៣

ខ្លួននៃព្រះពោធិសត្វ ដូចការដល់ព្រមដោយកាមគុណ ៥ របស់គហបតី ដូច្នោះ ។ កាលដែលព្រះពោធិសត្វទ្រង់បួសហើយ ទ្រង់ចាក់ធ្លុះសព្វញ្ញុ-តញ្ញាណនាពោធិបល្ល័ង្ក ដូចគហបតីនោះបំពេញសុចរិត ហើយកើតក្នុងស្ថាន-សួគ៌ដូច្នោះ កាលដែលព្រះតថាគតញ៉ាំងវេលាឲ្យកន្លងទៅដោយការត្រេក-អរក្នុងផលសមាបត្តិដែលប្រព្រឹត្តទៅក្នុងឈានទី ៤ ដូចកាលដែលគហបតីនោះសោយសម្បត្តិក្នុងនន្ទវ័នដូច្នោះ ។ កាលដែលព្រះតថាគត ញ៉ាំងវេលាឲ្យកន្លងទៅដោយការត្រេកអរក្នុងផលសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងឈានទី ៤ ទ្រង់មិនប្រាថ្នាសេចក្តីសុខរបស់ហីនជន ដែលជារបស់មនុស្ស ដូចកាលដែលគហបតីនោះ មិនប្រាថ្នាកាមគុណ ៥ ដែលជារបស់មនុស្ស ដូច្នោះ ។

[ ៤៤ ] បទថា **សុខី** គឺបានទទួលទុក្ខមុន ខាងក្រោយទើបមានសេចក្តីសុខ ។ បទថា **សេរី** ប្រែថា មានសេរីភាព គឺមានពេទ្យជាសម្លាញ់មុន ខាងក្រោយគប្បីមានសេរីភាព គឺគប្បីជាបុគ្គលម្នាក់ឯង ។ បទថា **សយំវសី** គឺនៅក្នុងអំណាចនៃពេទ្យមុន កាលពេទ្យប្រាប់ថា ចូរអង្គុយ ក៏អង្គុយ ប្រាប់ថា ចូរដេក ក៏ដេក ប្រាប់ថា ចូរបរិភោគ ក៏បរិភោគ ប្រាប់ថា ចូរផឹក ក៏ផឹក ខាងក្រោយ ទើបមានអំណាចក្នុងខ្លួនឯង ។ បទថា **យេនកាមង្គមោ** គឺមិនបានទៅកាន់ទីដែលខ្លួនត្រូវការនឹងទៅមុន ខាងក្រោយ កាលរោគជាល្អហើយ ទើបទៅណាបានតាមការពេញចិត្ត សូម្បីការមើលព្រៃ មើលគុហា និងមើលភ្នំជាដើម គប្បីទៅបានក្នុងទីដែលប្រាថ្នានឹងទៅ ។

ក្នុងបទនេះ មានការប្រៀបធៀបដូចតទៅនេះ កាលព្រះពោធិសត្វនៅ

ប្រថាប់ក្នុងកណ្ដាលប្រាសាទ ដូចកាលបុរសកើតរោគឃ្លង់ ដូច្នោះ កាមវត្ថុណាមួយ ដូចអំបែងដាក់រងើកភ្លើង ដូច្នោះ កាមវត្ថុ ២ យ៉ាង ដូចអំបែង ២ បទុះ អ្នករាំ ៣ កោដិកទុះ ដូចអំបែងដាក់រងើកភ្លើង ៣ កោដិកទុះរបស់សក្កទេវរាជ ដូច្នោះ ។ ការសេពវត្ថុកាម ដូចយកក្រចកអេះដំបៅ ហើយទៅផ្ទើរលើអំបែងដាក់រងើកភ្លើង ដូច្នោះ ។ កាលដែលព្រះពោធិសត្វឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងនេក្ខម្មៈ ហើយទ្រង់ចេញបួស បានជាព្រះពុទ្ធ និងកាលដែលព្រះតថាគតញុំាំងវេលាឲ្យកន្លងទៅដោយការត្រេកអរក្នុងផលសមាបត្តិ ដែលប្រព្រឹត្តទៅក្នុងឈាន ៤ ដូចកាលដែលបុរសកើតរោគឃ្លង់ អាស្រ័យថ្នាំ ហើយជារោគ ដូច្នោះ ។ កាលដែលព្រះតថាគតញុំាំងវេលាឲ្យកន្លងទៅ ដោយការត្រេកអរនោះ ទ្រង់មិនប្រាថ្នាដោយការត្រេកអរក្នុងហីនជន ដូចកាលឃើញបុរសកើតរោគឃ្លង់ដទៃហើយ មិនប្រាថ្នានឹងឃើញទៀត ដូច្នោះ ។

[ ៤៥ ] បទថា **ឧបហតិន្ទ្រិយោ** គឺមានកាយបសាទ ដែលរោគឃ្លង់កម្ចាត់គឺរបើតហើយ ។ បទថា **ឧបហតិន្ទ្រិយា** គឺមានឥន្ទ្រិយដែលទោសកម្ចាត់ហើយ ។ សត្វទាំងឡាយនោះ ព្រោះបញ្ចិន្ទ្រិយត្រូវកម្ចាត់ ត្រឡប់បានការសម្គាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សជាទុក្ខថាជាសុខ ដូចបុរសរោគឃ្លង់នោះ មានកាយិន្ទ្រិយត្រូវរោគកម្ចាត់ បែរជាបាននូវការសម្គាល់ខុសក្នុងភ្លើង ដែលមាន សម្ផស្សជាទុក្ខថាជាសុខ ដូច្នោះ ។

[ ៤៦ ] គប្បីជ្រាបក្នុងបទថា **អសុចិតរានិ ចេវ** ដូចតទៅនេះថា តាម

ប្រក្រតី មុខដំបៅទាំងនោះមិនស្អាត មានក្លិនស្អុយ និងរលួយ តែឥឡូវនេះ រឹតតែមិនស្អាត រឹតតែមានក្លិនស្អុយ និងរលួយឡើងទៀត ។ បទថា **ការិ** គឺជង្គូវទាំងឡាយ រមែងចូលទៅខាងក្នុងដំបៅ ដែលពេលភ្លើង និងអេះ ឈាម និងខ្ទុះដែលគួរខ្ពើមក៏ហូរចេញ ដំបៅយ៉ាងនេះនឹងមានការពេញចិត្ត សូម្បី តិចតួចឬ ។

[ ៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាថា **អារោគ្យា បរមាលាភា** ដូចតទៅនេះថា ការបានទ្រព្យក្តី ការបានយសក្តី ការបានកូនក្តី ណាមួយ ការមិនមានរោគជាលាភដ៏ឧត្តមជាងលាភទាំងនោះ លាភក្រៃលែងជាងការមិន មានរោគនោះមិនមាន ព្រោះហេតុនោះ ទើបការមិនមានរោគជាលាភយ៉ាងក្រៃ លែង ។ សុខកើតអំពីឈានក្តី សុខកើតអំពីមគ្គក្តី សុខកើតអំពីផលក្តី ណាមួយមាន ។ បណ្តាសុខទាំងនោះ និព្វានជាសុខយ៉ាងក្រៃលែងសុខ ក្រៃលែងជាងនិព្វាននោះមិនមានឡើយ ព្រោះហេតុនោះ ទើបនិព្វានថាជាសុខ យ៉ាងក្រៃលែង ។

បទថា **អដ្ឋង្គិកោ ច មគ្គានំ** សេចក្តីថា បណ្តាផ្លូវទាំងឡាយ ដែលឲ្យ កាន់យក អមតធម៌ដោយការទៅដែលជាចំណែកខាងដើម កាន់មគ្គដែលជា ចំណែកខាងដើមទាំងឡាយ មគ្គមានអង្គ ៨ ជាផ្លូវដ៏ក្សេម ។ ផ្លូវដទៃ ក្សេមជាងមគ្គមានអង្គ ៨ នោះមិនមាន ។ ម្យ៉ាងទៀត បទថា **ខេមំ** ក្តី បទ ថា **អមតំ** ក្តី ក្នុងបទថា **ខេមំ អមតំ** នេះ ជាឈ្មោះនៃនិព្វាននោះឯង ។

ក្នុងបទនេះមានសេចក្តីថា សមណព្រាហ្មណ៍អ្នកពោលជំទាស់ជាច្រើន

កាន់យកដោយលទ្ធិថា ផ្លូវដែលជាផ្លូវក្សេម និងផ្លូវដែលឲ្យដល់អមតធម៌ មគ្គមានអង្គ ៨ ជាផ្លូវយ៉ាងល្អក្រៃលែង គឺឧត្តមជាងមគ្គទាំងឡាយ ដែលជាផ្លូវក្សេម និងជាផ្លូវអមតៈទាំងអស់នោះ ។ បទថា **អាចរិយប្បាចរិយានំ** គឺនៃអាចារ្យ និងអាចារ្យរបស់អាចារ្យទាំងឡាយ ។ បទថា **សមេតិ** គឺដូចគ្នា មិនផ្សេងគ្នា ដូចវាល់ដោយនាឡិតែមួយ ដូចថ្លឹងដោយជញ្ជីងតែមួយ ។ បទថា **អធោមជ្ជតិ** គឺ មាគណ្ឌិយបរិព្វាជកសម្រូតបាតដៃចុះខាងក្រោមស្ទាបខ្លួន ។ បទថា **ឥទន្តំ ភោ គោតម អារោគ្យំ អទន្តំ និព្វានំ** នេះគឺការមិនមានរោគ នេះគឺសេចក្តីសុខ គឺមាគណ្ឌិយបរិព្វាជកស្ទាបក្បាល តាមកាលស្ទាបពោះតាមកាល ទើបពោលយ៉ាងនេះ ។

[ ៤៩ ] បទថា **ជេគំ** គឺផុយផង់ ។ បទថា **សាហុលចីវរេន** គឺសំពត់សាច់គ្រោតគ្រាត ដែលធ្វើដោយរោមចៀមខ្មៅ ។ អាចារ្យទាំងឡាយពោលថា **សង្ការចោលកេន** ដូច្នេះក៏មាន ប្រែថា សំពត់ដែលគេចោលត្រង់គំនរសំរាម ។ បទថា **វាចំ និច្ឆរេយ្យ** សេចក្តីថា បន្ទឺវាចាស្ទាបអង្អែលត្រង់ជាយ ត្រង់ចុង ត្រង់កណ្តាលតាមវេលា ។ បទថា **បុព្វកេហេសា** កាត់បទជា **បុព្វកេហិ ឯសា** សេចក្តីថា ព្រះមានព្រះភាគព្រះនាមថាវិបស្សី ។បេ។ ព្រះនាមថាកស្សបក្តី ប្រថាប់គង់ត្រង់កណ្តាលបរិស័ទ ៤ បានត្រាស់ព្រះគាថានេះ ។ គាថាដែលអាស្រ័យប្រយោជន៍ ព្រោះហេតុនោះ ទើបមហាជនបានរៀន ។ កាលព្រះសាស្តាទ្រង់បរិនិព្វានហើយ ក្រោយមកទើបគាថាទាំងឡាយ ចូលទៅកាន់វាងពួកបរិព្វាជក បរិព្វាជកទាំងនោះកត់

ទុកក្នុងសរីរៈ ២ បទប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបលោកពោលថា គាថានោះ ឥឡូវនេះជាគាថារបស់បុថុជ្ជន តាមលំដាប់ ។ ឈ្មោះថា **រោគភូតោ** ព្រោះជាសម្បុករោគ ។ សូម្បីបទដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **អរិយំ ចក្ខុំ** គឺវិបស្សនាញាណ និងមគ្គញ្ញាណបរិសុទ្ធ ។

[ ៥០ ] បទថា **បហោតិ** គឺអាច ។ បទថា **ភេសជ្ជំ កាតវេ** គឺគប្បីផ្សំថ្នាំធ្វើឲ្យក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ភ្នែក ថ្នាំស្ងោរជាដើម ។ បទថា **ន ចក្ខូនិ ឧប្បាទេយ្យ** សេចក្តីថា ចក្ខុបសាទនៃបុគ្គលណាត្រូវការរួបរឹត មានប្រមាត់ និងស្លេស្ម ជាដើមកម្ចាត់ហើយក្នុងចន្លោះ បុគ្គលនោះអាស្រ័យពេទ្យដ៏ឈ្លាស ទទួលទានថ្នាំដ៏សប្បាយ ទើបមើលឃើញបាន ។ តែភ្នែកនៃបុគ្គលដែលខ្វាក់អំពីកំណើត ខ្វាក់តាំងអំពីនៅក្នុងគភ៌មាតា បុគ្គលនោះមិនបានឃើញឡើយ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ន ចក្ខូនិ ឧប្បាទេយ្យ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈទី ២ ដូចតទៅនេះ

[ ៥១ ] បទថា **ជច្ចន្ធោ** គឺខ្វាក់ដោយការរួបរឹត ដោយប្រមាត់ជាដើមតាំងអំពីកំណើត ។ កាលមុនលោកពោលថា **អមុស្មឹ** គឺក្នុងគ្រានោះ ។ បទថា **អមិត្តតោបិ ទហេយ្យ** គឺគប្បីតាំងទុកដោយភាពជាសត្រូវយ៉ាងនេះថា បុរសនេះជាសត្រូវរបស់អញ ដូច្នេះ ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **ឥមិនា ចិត្តេន** គឺដោយចិត្តដែលតាមទៅក្នុងវដ្តៈ ។ បទថា **តស្ស មេ ឧប្បាទានបច្ចយា** គឺលោកពោលដល់បច្ចយាការ ដែលមានសន្និ

១ និងសង្ខេប ២ ប្រកាសវត្ថុៈឲ្យជាក់ច្បាស់ ។

[ ៥២ ] បទថា **ធម្មានុធម្មំ** គឺបដិបទាដែលសមគួរដល់ធម៌ ។ បទថា **ឥមេ ភោគា គណ្ឋា សល្លា** សេចក្តីនេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់ខន្ធ ៥ ។ ព្រះមានព្រះភាគកាលទ្រង់សម្តែងដល់វិវដ្ដៈ ទើបត្រាស់ថា **ឧបាទានិរោធា** ដូច្នេះ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ។ ១

**អដ្ឋកថាមាគណ្ឌិយសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## សន្ទកសូត្រទី ៦

[ ៥៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង មានបរិព្វាជកម្នាក់ឈ្មោះសន្ទកៈ អាស្រ័យនៅក្នុងបិលក្ខគុហា ជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើន ចំនួន ៥០០ នាក់ ។ គ្រានោះ ព្រះអានន្ទមានអាយុ ចេញអំពីទីស្ងប់ស្ងាត់ ក្នុងសាយណ្ហសម័យ ហើយបបួលភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ មកយើងនឹងចូលទៅឯត្រពាំងឈ្មោះទេវកដៈ ( ត្រពាំងទឹកដែលភ្លៀងព្រោះ ) ដើម្បីមើលគុហា ។ ពួកភិក្ខុទាំងនោះ ក៏ទទួលថេរៈវាចា របស់ព្រះអានន្ទមានអាយុថា ករុណាអាវុសោ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅឯត្រពាំងទេវកដៈ ជាមួយនឹងពួកភិក្ខុច្រើនរូប។ ជួនជាពេលនោះ សន្ទកបរិព្វាជក អង្គុយជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើន ដែលកំពុងនិយាយតិរច្ឆានកថា ច្រើនបែបច្រើនស្ថាន ដោយសំឡេងហ៊ោ ដោយសំឡេងខ្លាំង ទ្រហឹងអឺងកង គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីមហាមាត្យ និយាយអំពីសេនាទាហាន និយាយអំពីភ័យ ( នឹងសត្វសាហាវជាដើម ) និយាយអំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីទីដេក និយាយអំពីផ្កាកម្រង និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីក្រុង និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីមនុស្សក្លៀវក្លា

និយាយអំពីប្រកបរហាក និយាយអំពីទីកំពង់ទឹក និយាយអំពីកុម្ភទាសី និយាយអំពីញាតិដែលស្លាប់ទៅកាន់បរលោក និយាយអំពីរឿងផ្សេងៗ ដែលឥតប្រយោជន៍ និយាយអំពីលោក ( លទ្ធិកុហកក្នុងលោក ) និយាយអំពីសមុទ្រ និយាយអំពីវកៈនឹងអវកៈ ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះៗ ។ សន្ទុកបរិព្វាជកក៏បានឃើញព្រះអានន្ទមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយក៏បញ្ឈប់បរិសទ្យ របស់ខ្លួនថា អ្នកដ៏ចម្រើនទាំងឡាយ ចូរនិយាយតិចៗ អ្នកដ៏ចម្រើនទាំងឡាយកុំមាត់ឡើយ ( ដ្បិត ) សមណៈឈ្មោះអានន្ទនេះ ជាសាវករបស់ព្រះសមណគោតមមកឥឡូវនេះ ក៏ពួកសាវកណារបស់ព្រះសមណគោតម ដែលអាស្រ័យនៅក្នុងក្រុងកោសម្ពី បណ្តាសាវកទាំងនោះ អានន្ទនេះឯង លោកជាសមណៈមួយអង្គដែរ ឯពួកលោកមានអាយុទាំងនោះ ចូលចិត្តតែសំឡេងតិចៗ និយាយសរសើរតែសំឡេងតិចៗ ដែលព្រះសម្ពុទ្ធព្រះអង្គមានសំឡេងតិចបានទូន្មានហើយ ធ្វើដូចម្តេចឲ្យព្រះអានន្ទជ្រាបច្បាស់ថា បរិសទ្យមានសំឡេងតិច ហើយសម្គាល់ថាគួរនិមន្តចូលមក ។ គ្រានោះ ពួកបរិព្វាជកទាំងនោះក៏នាំគ្នាស្ងៀម ។ ពេលនោះឯងព្រះអានន្ទមានអាយុ និមន្តចូលទៅត្រង់កន្លែងដែលសន្ទុកបរិព្វាជកនៅ ។ គ្រានោះសន្ទុកបរិព្វាជក និយាយពាក្យនេះ នឹងព្រះអានន្ទមានអាយុថា ព្រះអានន្ទដ៏ចម្រើន ចូរនិមន្តមកចុះ ព្រះអានន្ទដ៏ចម្រើន និមន្តមកស្រួលហើយព្រះអានន្ទដ៏ចម្រើន ខានធ្វើដំណើរដើម្បីមកក្នុងទីនេះយូរណាស់ហើយ សូមព្រះអានន្ទដ៏ចម្រើននិមន្តគង់ចុះ នេះអាសនៈដែលយើងក្រាលទុក ។ ព្រះអានន្ទ

មានអាយុ ក៏គង់លើអាសនៈដែលពួកបរិព្វាជកក្រាលទុក ។ ចំណែកសន្ទកបរិព្វាជក កាន់យកអាសនៈទាបមួយអង្គុយក្នុងទីដ៏សមគួរ ។

[ ៥៥ ] លុះសន្ទកបរិព្វាជក អង្គុយក្នុងទីដ៏សមគួរហើយ ព្រះអានន្ទមានអាយុ បានសួរដូច្នេះថា ម្នាលសន្ទកៈ ចុះអម្បាញ់មិញ ពួកអ្នកអង្គុយប្រជុំគ្នា និយាយអំពីរឿងរ៉ាវដូចម្ដេច ចុះពាក្យជាចន្លោះ ( អំពីគុណធម៌ ) ដូចម្ដេច ដែលពួកអ្នកនិយាយមិនទាន់ចប់ ។ សន្ទកបរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ពាក្យដែលពួកយើងអង្គុយប្រជុំគ្នា និយាយក្នុងកាលអម្បាញ់មិញ ចូរលើកទុកសិនចុះ ព្រោះពាក្យនុ៎ះ ព្រះអានន្ទដ៏ចម្រើនមិនបានជាសល់ក្រទេ ចាំស្ដាប់ក្នុងកាលខាងក្រោយក៏បាន សូមឲ្យតែព្រះអានន្ទដ៏ចម្រើន សំដែងធម្មីកថា ក្នុងលទ្ធិអាចារ្យរបស់ខ្លួនឲ្យទាន ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ បើដូច្នោះ អ្នកចូរចាំស្ដាប់ចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ អាត្មានឹងសំដែង ។ សន្ទកបរិព្វាជក ទទួលតបថេរវាចារបស់ព្រះអានន្ទ មានអាយុថា ព្រះករុណាលោកដ៏ចម្រើន ។ ព្រះអានន្ទមានអាយុបានពោលពាក្យនោះថា ម្នាលសន្ទកៈ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងអព្រហ្មចរិយវាសៈ គឺការមិនប្រព្រឹត្តព្រហ្មចរិយធម៌ ៤ ប្រការនេះផង បានសំដែងអនស្សាសិកព្រហ្មចរិយ គឺព្រហ្មចរិយធម៌មិនមានទំនងស្រួល ៤ ប្រការផង ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយជាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ សន្ទក

បរិព្វាជកសួរថា បពិត្រព្រះអានន្ទ ចុះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងអព្រហ្មចរិយវាសៈ ៤ ប្រការ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលដែលខ្លួនគប្បីដឹងនោះ តើដូចម្តេចខ្លះ ។

[ ៥៦ ] ព្រះអានន្ទឆ្លើយតបថា ម្នាលសន្ទកៈ ក្នុងលោកនេះ មានគ្រូខ្លះតែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ការប្រតិបត្តិខុស ឬត្រូវចំពោះមាតាក៏មិនមាន ផល ( នៃបុណ្យបាប ) ការប្រតិបត្តិខុស ឬត្រូវចំពោះបិតាមិនមានផល ( នៃបុណ្យបាប ) សត្វជាឱបបាតិកកំណើតមិនមាន ពួកសមណៈនឹងព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ហើយធ្វើឲ្យជាក់ច្បាស់នូវលោកនេះនឹងលោកខាងមុខ ដោយបញ្ញារបស់ខ្លួន ហើយអាចសម្តែងបាន ក៏មិនមានក្នុងលោកឡើយ បុរសនេះកើតអំពីមហាភូតរូប ៤ លុះធ្វើមរណកាលក្នុងវេលាណា បឋវីធាតុខាងក្នុងក៏ប្រែក្លាយទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុងក៏ប្រែក្លាយទៅជាតេ-ជោធាតុខាងក្រៅ វាយោធាតុខាងក្នុងក៏ប្រែក្លាយទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយទាំងឡាយ ក៏អណ្តែតត្រសែតទៅឯអាកាស ពួកបុរស ( ៤ នាក់ )

មានត្រៃជាគម្រប់ ៥ សែងយកបុរសស្លាប់ ( នោះ ) ទៅ ស្នាមជើង គឺគុណនិងទោសក៏ប្រាកដនៅ កំណត់ត្រឹមទីឈាបនកិច្ចប៉ុណ្ណោះ សល់នៅតែឆ្អឹងដែលមានសម្បុរ ( ប្រផេះ ) ដូចជាស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជាមានផេះជាទីបំផុត ទាននេះពួកមនុស្សពាលកម្លៅបញ្ញត្តទុកមក ទេជនទាំងឡាយណាពោលពាក្យថា អំពើមានទានជាដើម មានផលពាក្យរបស់ជនទាំងនោះជាពាក្យកុហកទទេ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ រមែងដាច់សូន្យ វិនាសបាត់បង់ មិនកើតវិញទៀតឡើយ ។

[ ៥៧ ] ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណាក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះឯង តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន ការប្រតិបត្តិខុស ឬត្រូវ ចំពោះមាតា មិនមានផល ការប្រតិបត្តិខុស ឬត្រូវ ចំពោះបិតាមិនមានផល សត្វជាឱបបាតិកៈកំណើតមិនមាន ពួកសមណ និងព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អហើយធ្វើឲ្យជាក់ច្បាស់នូវលោកនេះ នឹងលោកខាងមុខ ដោយបញ្ញារបស់ខ្លួនហើយអាចសម្តែងបាន ក៏មិនមានក្នុងលោកឡើយ បុរសនេះកើតអំពីមហាភូតរូប ៤ លុះធ្វើមរណកាលទៅវេលាណា បឋវីធាតុខាងក្នុង ក៏ប្រែក្លាយទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាអា

បោធាតុខាងក្រៅ តេជោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាតេជោធាតុខាងក្រៅ វាយោធាតុខាងក្នុង ក៏ប្រែក្លាយទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយទាំងឡាយ ក៏អណ្តែតត្រសែតទៅឯអាកាស ពួកបុរស ( ៤ នាក់ ) មានគ្រែជាគម្រប់ ៥ សែងយកបុរសស្លាប់ ( នោះ ) ទៅ ស្នាមជើងគឺគុណនិងទោស ក៏ប្រាកដនៅកំណត់ត្រឹមទីឈាបនកិច្ចប៉ុណ្ណោះ សល់នៅតែឆ្អឹង ដែលមានសម្បុរ ( ប្រផេះ ) ដូចជាស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជា មានផេះជាទីបំផុត ទាននេះពួកមនុស្សពាលកម្សៀបញ្ញត្តទុកមកទេ ជនទាំងឡាយណាពោលពាក្យ ថា អំពើមានទានជាដើមមានផល ពាក្យរបស់ជនទាំងនោះ ជាពាក្យកុហក ទទេ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ រមែងដាច់សូន្យវិនាសបាត់បង់ មិនកើតវិញឡើយ ។ ថាបើពាក្យរបស់គ្រូដ៏ចម្រើននេះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញបានធ្វើហើយក្នុងសម័យនោះ ក៏ទុកដូចជាអាត្មាអញមិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញបានប្រព្រឹត្តហើយក្នុងសម័យនោះ ក៏ទុកដូចជាអាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំង ២ នាក់ ជាមនុស្សស្មើៗ គ្នា ដល់នូវភាពស្មើគ្នាក្នុង សមណធម៌នោះ ប៉ុន្តែអាត្មាអញ គ្រាន់តែមិននិយាយថា យើងទាំង ២ នាក់ លុះបែកធ្លាយរាងកាយស្លាប់ទៅហើយ នឹងដាច់សូន្យវិនាស មិនកើតវិញឡើយ ។ ក៏គ្រូដ៏ចម្រើននេះ ប្រព្រឹត្តអាក្រាត កោរត្រងោលព្យាយាមអង្គុយច្រហោង ប្រព្រឹត្តដកសក់ និងពុកមាត់ពុកចង្ការយ៉ាងតឹងលើសលុប ចំណែកអាត្មាអញដែលអាស្រ័យនឹងទីដេក ចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានអំពីដែន

កាសី និងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស និងប្រាក់ ក៏គង់ជាអ្នកមានគតិស្មើៗ គ្នានឹងគ្រូដ៏ចម្រើននេះ ក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើបប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តិនោះឯង មិនមែនជាកិរិយាប្រព្រឹត្តិព្រហ្មចរិយធម៌ទេ បុរសនោះ លុះដឹងច្បាស់ដូច្នេះហើយ ក៏នឿយណាយ ចាកព្រហ្មចរិយធម៌នោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈ ទី ១ ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាបច្បាស់ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៥៨ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះមានគ្រូខ្លះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើគេឲ្យធ្វើ កាត់ ( អវយវៈមានដៃជាដើម ) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើគេឲ្យសោយសោក ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេសោយសោក ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យលំបាក បំភ័យ ឬប្រើគេឲ្យបំភ័យ សម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់នូវទីត ( នៃផ្ទះ ) ប្លន់នូវពួកអ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំក្បែរផ្លូវ ( ដើម្បីដណ្តើមយកព្រទ្យ ) លួចប្រពន្ធរបស់អ្នកដទៃ និយាយពាក្យកុហក កាលបើធ្វើ ( យ៉ាងនេះ ) មិនឈ្មោះ

ថាធ្វើបាបឡើយ មួយទៀត បើបុគ្គលណា យកគ្រឿងចក្រមានខ្នងកន់ដ៏មុត ដូចជាកាំបិតកោរ មកធ្វើសត្វទាំងឡាយ លើផែនដីនេះ ឲ្យមានគំនរនៃសាច់តែមួយ ឲ្យមានពំនូកនៃសាច់តែមួយ បាបដែលមានអំពើនោះជាហេតុមិនមានទេ អំពើបាបក៏មិនឲ្យផល ទោះបីបុគ្គលចូលទៅកាន់ត្រើយខាងស្ដាំនៃទន្លេគង្គា ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់ ( នូវអវយវៈមានដៃជាដើម ) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុមិនមានទេ អំពើបាបក៏មិនឲ្យផល ទោះបីបុគ្គលចូលទៅកាន់ត្រើយខាងឆ្វេងនៃទន្លេគង្គាហើយឲ្យទាន ឬប្រើគេឲ្យៗ បូជា ឬប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ បុគ្គលធ្វើកុសលដោយឲ្យទាន ដោយទូន្មាននូវឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ ។

[ ៥៩ ] ម្នាលសន្ទកៈ វិញ្ញូបុរសតែងពិចារណាក្នុងជំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះឯង តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា បុគ្គលធ្វើបាប ឬប្រើគេឲ្យធ្វើ កាត់ ( អវយវៈមានដៃជាដើម ) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន ធ្វើគេឲ្យសោយសោក ឬប្រើអ្នកដទៃឲ្យធ្វើគេឲ្យសោយសោក ធ្វើគេឲ្យលំបាក ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេលំបាក បំភ័យគេ ឬប្រើគេឲ្យបំភ័យ សម្លាប់សត្វ ឬប្រើគេឲ្យសម្លាប់ កាន់យកទ្រព្យដែលគេមិនបានឲ្យ កាត់នូវទីត ( នៃផ្ទះ ) ប្លន់នូវពួកអ្នក

ស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំក្បែរផ្លូវ( ដើម្បីដណ្តើមយកទ្រព្យ ) លួចប្រពន្ធរបស់អ្នកដទៃ និយាយពាក្យកុហក កាលបើធ្វើ ( យ៉ាងនេះ ) មិនឈ្មោះថាធ្វើបាបឡើយ មួយទៀត បើអ្នកណាយកគ្រឿងចក្រ មានខ្នងកង់ ដ៏មុតដូចជាកាំបិតកោរ មកធ្វើសត្វទាំងឡាយលើផែនដីនេះ ឲ្យមានគំនរនៃ សាច់តែមួយ ឲ្យមានពំនូកនៃសាច់តែមួយ បាបដែលមានអំពើនោះជាហេតុ មិនមានទេ អំពើបាបក៏មិនឲ្យផលឡើយ ទោះបីបុគ្គលចូលទៅកាន់ត្រើយ ខាងស្តាំនៃទន្លេគង្គា ហើយសម្លាប់សត្វ ឬប្រើអ្នកដទៃឲ្យសម្លាប់ កាត់ ( នូវ អវយវៈមានដៃជាដើម ) របស់អ្នកដទៃ ឬប្រើគេឲ្យកាត់ បៀតបៀនគេ ឬប្រើគេឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុមិនមានទេ អំពើបាប ក៏ មិនឲ្យផលឡើយ ទោះបីបុគ្គលចូលទៅកាន់ត្រើយខាងឆ្វេងនៃទន្លេគង្គា ហើយ ឲ្យទាន ឬប្រើគេឲ្យៗ បូជា ឬប្រើគេឲ្យបូជា បុណ្យដែលមានអំពើនោះជា ហេតុមិនមានទេ អំពើបុណ្យមិនឲ្យផលឡើយ បុគ្គលធ្វើកុសល ដោយឲ្យ ទាន ដោយទូន្មាននូវឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យ សច្ចៈ បុណ្យដែលមានអំពើនោះជាហេតុមិនមានទេ អំពើបុណ្យមិនមានផល ឡើយ ។ បើពាក្យរបស់គ្រូដ៏ចម្រើននោះជាពាក្យពិតមែន សមណកម្ម ដែលអាត្មាអញ បានធ្វើហើយក្នុងសម័យនោះ ក៏ទុកដូចជាមិនបានធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញបានប្រព្រឹត្តហើយក្នុងសម័យនោះ ក៏ទុកដូច ជាអាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំង ២ នាក់ជាមនុស្សស្មើៗ គ្នា ដល់ នូវភាពស្មើគ្នាក្នុងសមណធម៌នោះ ប៉ុន្តែអាត្មាអញគ្រាន់តែមិនបាននិយាយ

ថា យើងទាំង ២ នាក់ កាលធ្វើបាបក៏ឈ្មោះថាមិនធ្វើ ។ ក៏គ្រូដ៏ចម្រើន នេះ ប្រព្រឹត្តអាក្រាត កោរត្រងោល ព្យាយាមអង្គុយច្រហោង ប្រព្រឹត្តជក សក់ និងពុកមាត់ពុកចង្កា យ៉ាងតឹងលើសលុប ចំណែកអាត្មាអញដែល អាស្រ័យនៅនឹងទីដេកចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមក អំពី ដែនកាសី និងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រង និងគ្រឿងក្រអូបគ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស និងប្រាក់ គង់ជាអ្នកមានគតិស្មើៗ គ្នានឹងគ្រូដ៏ចម្រើន នេះ ក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើប ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តិនោះឯង មិនមែនជា កិរិយាប្រព្រឹត្តិព្រហ្មចរិយធម៌ទេ បុរសនោះលុះដឹងដូច្នេះហើយ ក៏នឿយ ណាយចាកព្រហ្មចរិយធម៌នោះហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯង ឈ្មោះថាអព្រហ្មចរិយវាសៈទី ២ ដែលព្រះមានព្រះភាគ អរហន្តសម្មា- សម្ពុទ្ធអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជា ធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជា កាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៦០ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូខ្លះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំង- ឡាយ សៅហ្មងមិនមានឡើយ សត្វទាំងឡាយ រមែងសៅហ្មង ដោយឥត ហេតុ ឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយ បរិសុទ្ធមិនមានឡើយ សត្វទាំងឡាយ រមែងបរិសុទ្ធ ដោយឥតហេតុឥតបច្ច័យ កម្លាំងក៏មិនមាន

ព្យាយាមក៏មិនមាន កម្លាំងនៃបុរសក៏មិនមាន ការប្រឹងប្រែងនៃបុរសក៏មិនមាន សត្វទាំងអស់ ( មានសត្វឱដ្ឋ គោ លា ជាដើម ) បាណៈទាំងអស់ ភូតទាំងអស់ ( មានសត្វកើតក្នុងស្រោមស៊ុតជាដើម ) ជីវៈគឺធញ្ញជាតិទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម ( ក្នុងការធ្វើឲ្យសៅហ្មង ឬបរិសុទ្ធ ) ទេ មានសេចក្ដីប្រែប្រួលដោយនិយតិ និងសង្គតិ និងសភាវៈ តាំងនៅក្នុងអភិជាតិទាំង ៦ ហើយរមែងរងសុខ និងទុក្ខ ។

[ ៦១ ] ម្នាលសន្ទកៈ វិញ្ញូបុរសតែងពិចារណាក្នុងជំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះឯង តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយសៅហ្មង មិនមានឡើយ សត្វទាំងឡាយរមែងសៅហ្មង ដោយឥតហេតុឥតបច្ច័យ ហេតុបច្ច័យនាំឲ្យសត្វទាំងឡាយបរិសុទ្ធមិនមានឡើយ សត្វទាំងឡាយរមែងបរិសុទ្ធដោយឥតហេតុឥតបច្ច័យ កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងនៃបុរសក៏មិនមាន សេចក្ដីប្រឹង-ប្រែងនៃបុរសក៏មិនមាន សត្វទាំងអស់ ( មានឱដ្ឋគោលាជាដើម ) បាណៈទាំងអស់ ភូតទាំងអស់ ( មានសត្វកើតក្នុងស្រោមស៊ុតជាដើម ) ជីវៈគឺធញ្ញជាតិទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម ( ក្នុងការធ្វើឲ្យសៅហ្មង ឬបរិសុទ្ធ ) ទេ មានសេចក្ដីប្រែប្រួល ដោយនិយតិ និងសង្គតិ និងសភាវៈ តាំងនៅក្នុងអភិជាតិទាំង ៦ ហើយរមែង ទទួលសុខ និងទុក្ខ ។ បើពាក្យរបស់គ្រូដ៏ចម្រើននេះជាពាក្យពិតមែន សមណកម្មដែលអាត្មាអញបានធ្វើហើយក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបាន

ធ្វើ ព្រហ្មចរិយធម៌ដែលអាត្មាអញបានប្រព្រឹត្តហើយក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំង ២ នាក់ជាមនុស្សស្មើៗគ្នាដល់នូវភាពស្មើគ្នាក្នុងសមណធម៌នុ៎ះ ប៉ុន្តែអាត្មាអញគ្រាន់តែមិននិយាយថា យើងទាំង ២ នាក់ និងបរិសុទ្ធដោយឥតហេតុឥតបច្ច័យ ។ ក៏គ្រូដ៏ចម្រើននេះ ប្រព្រឹត្តអាក្រាត គោរពត្រងោល ព្យាយាមអង្គុយប្រហោង ប្រព្រឹត្តដកសក់ និងពុកមាត់ពុកចង្កាយ៉ាងតឹងលើសលុប ចំណែកអាត្មាអញដែលអាស្រ័យនៅ នឹងទីដេកចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមកអំពីដែនកាសី និងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស និងប្រាក់ ក៏គង់ជាអ្នកមានគតិស្មើៗ គ្នានឹងគ្រូដ៏ចម្រើននេះ ក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វីឃើញអ្វី ទើបមកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តិនោះមិនមែនជាកិរិយាប្រព្រឹត្តិព្រហ្មចរិយធម៌ទេ បុរសនោះលុះដឹងដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយធម៌នោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈទី ៣ ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរ និងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៦២ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះមានគ្រូខ្លះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា កាយគឺពួកទាំង ៧ នេះ គ្មាន

នរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិមិត្តដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាពអារ ( គ្មានពូជតទៅទៀត ) តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំដូចជាសរសគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ កាយគឺពួកទាំង ៧ តើដូចម្តេចខ្លះ គឺពួកធាតុដី ១ ពួកធាតុទឹក ១ ពួកធាតុភ្លើង ១ ពួកធាតុខ្យល់ ១ សេចក្តីសុខ ១ សេចក្តីទុក្ខ ១ ជីវិត ១ គ្រប់ជា ៧ កាយគឺពួកទាំង ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិមិត្តដោយឫទ្ធិបាន គ្មាននរណាសាង កើតជាសភាពអារ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំ ដូចជាសរសគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ បុគ្គលសម្លាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី ស្លាប់ខ្លួនឯងក្តី ប្រើគេឲ្យស្លាប់ក្តី ដឹងច្បាស់ខ្លួនឯងក្តី ញុំាងគេឲ្យដឹងច្បាស់ក្តី មិនមានក្នុងកាយទាំងនោះទេ ទុកជាបុគ្គលកាត់សីសៈដោយសស្ត្រាវុធដ៏មុត ក៏ឈ្មោះថា គ្មាននរណា ផ្តាច់ផ្តិលអ្នកណាឲ្យបាកជីវិតបាន ឯសស្ត្រាវុធគ្រាន់តែចូល តាមចន្លោះនៃកាយទាំង ៧ ប៉ុណ្ណោះ ឯង ។ ឯកំណើតដែលជាប្រធាន មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយ ទាំងនេះក្តី កម្មទាំង ៥០០ ក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្ម គឺកាយកម្ម និងវចីកម្មក្តី កម្មពាក់កណ្តាល គឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី អន្តរកប្បទាំង ៦២ ក្តី អភិជាតិទាំង ៦ បុរិសភូមិទាំង ៨ ពួក

អាជីវកទាំង ១៤៩ ពួក បរិព្វាជកទាំង ១៤៩ លំនៅនៃនាគទាំង ១៤៩ ឥន្ទ្រិយទាំង ១២០ នរកទាំង ១៣០ ធាតុដែលប្រកបដោយធូលី ( មានខ្នងដៃខ្នងជើងជាដើម ) ទាំង ៣៦ ពួកគភ៌នៃសត្វដែលមានសញ្ញាទាំង ៧ ពួកគភ៌នៃ ( ធញ្ញជាតិ ) ដែលគ្មានសញ្ញាទាំង ៧ ពួកគភ៌នៃជាតិដែលដុះអំពីថ្នាំង ( មានអំពៅជាដើម ) ទាំង ៧ ពួកទេវតាទាំង ៧ ពួកមនុស្សទាំង ៧ ពួកបិសាចទាំង ៧ ស្រះទាំង ៧ រអាងភ្នំទាំង ៧ ថ្មទាំង ៧ ជ្រោះធំទាំង ៧ ជ្រោះតូចទាំង ៧០០ សុបិនធំទាំង ៧ សុបិនតូចទាំង ៧០០ ជនពាលក្តី ជនជាបណ្ឌិតក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងវដ្តសង្សារ ) អស់ចំនួន ៨ លានចូឡមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។ បុគ្គលកំណត់ទុកថា អាត្មាអញនឹងញុំាងកម្ម ដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយៗ នូវកម្មដែលចាស់ស្រាប់ហើយៗ ធ្វើឲ្យអស់ទៅផង ដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី ក្នុងកប្បទាំងឡាយនោះមិនមានទេ សេចក្តីសុខទុក្ខ ដែលធ្វើឲ្យមានទីបំផុតដូចគេវាល់របស់ ( ឲ្យអស់ទៅ ) ដោយទោណៈ មិនមានក្នុងសង្សារវដ្តដោយប្រការយ៉ាងនេះឡើយ សេចក្តីសាបសូន្យ ( នៃសង្សាររបស់ជនជាបណ្ឌិត ) នឹងសេចក្តីចម្រើន ( នៃសង្សាររបស់ជនពាល ) មិនមានទេ សេចក្តីលូតលាស់ឡើង និងសេចក្តីរេចរិលចុះមិនមានឡើយ ។ ដូចរមូរនៃអំបោះ ដែលគេបោះចោលទៅ តែងរសាយអស់ ( ត្រឹមតែកំណត់អំបោះប៉ុណ្ណោះ ) យ៉ាងណាមិញ ជនពាលក្តី ជនជាបណ្ឌិតក្តី ដែលអន្ទោល

ទៅ ត្រាច់រង្គាត់ទៅ ( ក្នុងសង្សារអស់កំណត់នេះហើយ ) នឹងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នេះឯង ។

[ ៦៣ ] ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណា ក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះ តែងនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា កាយគឺពួកទាំង ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាពអារ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំដូចជាសសរគោល កាយទាំងនោះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ កាយគឺពួកទាំង ៧ តើដូចម្ដេចខ្លះ គឺពួកជាតុដី ១ ពួកជាតុទឹក ១ ពួកជាតុភ្លើង ១ ពួកជាតុខ្យល់ ១ សេចក្ដីសុខ ១ សេចក្ដីទុក្ខ ១ ជីវិត ១ គ្រប់ជា ៧ កាយគឺពួកទាំង ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាពអារ តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំដូចសសរគោល កាយទាំងនេះ មិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀនគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬបានទុក្ខ ឬទាំងសុខទាំងទុក្ខបានឡើយ បុគ្គលសម្លាប់ដោយខ្លួនឯងក្ដី ប្រើគេឲ្យសម្លាប់ក្ដី ស្លាប់ដោយខ្លួនឯងក្ដី ប្រើគេឲ្យស្លាប់ក្ដី ដឹងច្បាស់ខ្លួនឯងក្ដី ញុំាងគេឲ្យដឹងច្បាស់ក្ដី មិនមានក្នុងកាយទាំងនោះទេ ទុកជាបុគ្គលកាត់សីសៈ ដោយសស្ត្រាវុធដ៏មុត ក៏ឈ្មោះថាគ្មានអ្នកណាផ្ដាច់ផ្ដិលអ្នកណាឲ្យបាកជីវិតបានទេ សស្ត្រាវុធគ្រាន់តែចូលទៅតាមចន្លោះនៃកាយទាំង ៧

ប៉ុណ្ណោះឯង ។ កំណើតដែលជាប្រធាន មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយទាំងនេះក្តី កម្មទាំង ៥០០ ក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្មគឺ កាយកម្ម និងវចីកម្មក្តី កម្មពាក់កណ្តាល គឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី អន្តរកប្បទាំង ៦២ ក្តី អភិជាតិទាំង ៦ ក្តី បុរិសភូមិទាំង ៨ ក្តី ពួកអាជីវកទាំង ១៤៩ ពួកបរិព្វាជកទាំង ១៤៩ លំនៅនៃនាគទាំង ១៤៩ ឥន្ទ្រិយទាំង ១២០ នរកទាំង ១៣០ ធាតុដែលប្រកបដោយធូលី ( មានខ្នងដៃខ្នងជើង ជាដើម ) ទាំង ៣៦ ពួកគភ៌នៃសត្វដែលមានសញ្ញាទាំង ៧ ពួកគភ៌នៃ ( ធញ្ញជាតិ ) ដែលគ្មានសញ្ញាទាំង ៧ ពួកគភ៌នៃជាតិដែលដុះអំពីថ្នាំងទាំង ៧ ពួកទេវតាទាំង ៧ ពួកមនុស្សទាំង ៧ ពួកបិសាចទាំង ៧ ស្រះទាំង ៧ រអាងភ្នំទាំង ៧ ថ្មទាំង ៧ ជ្រោះធំទាំង ៧ ជ្រោះតូចទាំង ៧០០ សុបិនធំទាំង ៧ សុបិនតូចទាំង ៧០០ ជនពាលក្តី ជនជាបណ្ឌិតក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងវដ្តសង្សារ ) អស់កាលចំនួន ៨ លានចូឡមហាកប្ប ហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។ បុគ្គលកំណត់ទុកថា អាត្មាអញ នឹងញុំាងកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយៗ នូវកម្មដែលចាស់ស្រាប់ហើយៗ ធ្វើឲ្យអស់ទៅផង ដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី ក្នុងកប្បទាំងឡាយនោះមិនមានទេ សេចក្តីសុខទុក្ខដែលធ្វើឲ្យមានទីបំផុត ដូចគេវាល់របស់ ( ឲ្យអស់ទៅ ) ដោយទោណៈមិនមានក្នុងសង្សារវដ្តដោយប្រការយ៉ាងនេះឡើយ សេចក្តីសាបសូន្យ ( នៃសង្សាររបស់ជនជាបណ្ឌិត )

នឹងសេចក្តីចម្រើន ( នៃសង្សាររបស់ជនពាល ) មិនមានទេ សេចក្តីលូតលាស់ឡើង និងសេចក្តីរេចរិលចុះ មិនមានឡើយ ។ ដូចរមូរនៃអំបោះ ដែលគេបោះចោលទៅ តែងរសាយអស់ ( ត្រឹមតែកំណត់អំបោះប៉ុណ្ណោះ ) យ៉ាងណាមិញ ជនពាលក្តី ជនជាបណ្ឌិតក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងសង្សារអស់កំណត់នេះហើយ ) នឹងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នោះឯង ។ បើពាក្យរបស់គ្រូដ៏ចម្រើននេះ ជាពាក្យពិតមែន សមណកម្មដែលអាត្មាអញ បានធ្វើហើយ ក្នុងសម័យនុ៎ះ ក៏ទុកដូចជាអាត្មាអញ មិនបានធ្វើព្រហ្មចរិយធម៌ ដែលអាត្មាអញបានប្រព្រឹត្តហើយ ក្នុងសម័យនុ៎ះ ក៏ទុកដូចជា អាត្មាអញមិនបានប្រព្រឹត្ត ឯយើងទាំង ២ នាក់ ជាមនុស្សស្មើៗ គ្នាដល់នូវភាពស្មើគ្នាក្នុងសមណធម៌នោះ ប៉ុន្តែអាត្មាអញគ្រាន់តែមិននិយាយថា យើងទាំង ២ នាក់នឹងអន្ទោលទៅ ត្រាច់រង្គាត់ទៅ ( ក្នុងសង្សារវដ្ត ) ហើយនឹងធ្វើនូវទីបំផុតទុក្ខបាន ។ ក៏គ្រូដ៏ចម្រើននេះប្រព្រឹត្តអាក្រាត កោរត្រងោល ព្យាយាមអង្គុយច្រហោង ប្រព្រឹត្តដកសក់ និងពុកមាត់ពុកចង្កា យ៉ាងតឹងលើសលុប ចំណែកអាត្មាអញដែលអាស្រ័យនៅនឹងទីដេក ចង្អៀតដោយកូន ប្រើប្រាស់សំពត់ដែលបានមកអំពីដែនកាសី និងខ្លឹមចន្ទន៍ ទ្រទ្រង់ផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ត្រេកអរចំពោះមាស និងប្រាក់ ក៏គង់ជាអ្នកមានគតិស្មើៗ គ្នានឹងគ្រូដ៏ចម្រើននេះ ក្នុងលោកខាងមុខដែរ អាត្មាអញនោះឯង កាលដឹងអ្វី ឃើញអ្វី ទើបប្រព្រឹត្តព្រហ្មចរិយៈ ក្នុងសំណាក់គ្រូនេះ ការប្រព្រឹត្តិនោះឯង មិនមែនជាកិរិយាប្រព្រឹត្តិព្រហ្មចរិយធម៌ទេ បុរសនោះ

លុះដឹងដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយធម៌ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈទី ៤ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្ទង់គប្បីដឹងឡើយ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អព្រហ្មចរិយវាសៈ ៤ ប្រការ ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយធម៌ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្ទង់គប្បីដឹងឡើយ ។

[ ៦៤ ] សន្ទកបរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះចំឡែកណាស់ ព្រោះថាព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងអព្រហ្មចរិយវាសៈទាំង ៤ ប្រការនេះថា ជាអព្រហ្មចរិយវាសៈដោយពិតប្រាកដមែន ជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយធម៌ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្ទង់គប្បីដឹងឡើយ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងអនស្សាសិកព្រហ្មចរិយៈ ៤ ប្រការ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់

ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែល ខ្ទួនគប្បី ដឹង តើដូចម្តេចខ្លះ ។

[ ៦៥ ] ព្រះអានន្ទតបថា ម្នាលសន្ទកៈ ក្នុងលោកនេះ មានគ្រូខ្លះ ដឹង សព្វ ឃើញសព្វ តែងប្តេជ្ញានូវញាណទស្សនៈមិនមានសេសសល់ថា អាត្មា អញកាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈ រមែង តម្កល់ស៊ប់ជាប់ជានិច្ច ។ គ្រូនោះចូលទៅកាន់ផ្ទះស្ងាត់ក៏មាន មិនបានដុំ បាយក៏មាន ឆ្កែខាំក៏មាន ជួបប្រទះនឹងដំរីកាចក៏មាន ជួបប្រទះនឹងសេះកាច ក៏មាន ជួបប្រទះនឹងគោកាចក៏មាន សួរនាម និងគោត្ររបស់ស្ត្រី ឬបុរសក៏ មាន សួរឈ្មោះ និងផ្លូវនៃស្រុក ឬនិគមក៏មាន ។ គ្រូនោះកាលបើមានគេ សួរថា ហេតុនេះតើដូចម្តេច ក៏ប្រាប់គេថាផ្ទះស្ងាត់ ដែលគួរខ្ញុំចូលទៅបាន ខ្ញុំក៏ចូលទៅកាន់ផ្ទះស្ងាត់នោះហើយ ដុំបាយដែលខ្ញុំមិនគួរបាន ខ្ញុំក៏មិនបានដុំ បាយនោះហើយ ឆ្កែដែលគួរខាំខ្ញុំបាន ឆ្កែនោះក៏ខាំខ្ញុំហើយ ខ្ញុំគួរជួបនឹងដំរី កាច ខ្ញុំក៏ជួបនឹងដំរីកាចនោះហើយ ខ្ញុំគួរជួបនឹងសេះកាច ខ្ញុំក៏ជួបនឹងសេះ កាចនោះហើយ ខ្ញុំគួរជួបនឹងគោកាច ខ្ញុំក៏ជួបនឹងគោកាចនោះហើយ ខ្ញុំគួរសួរ នាម និងគោត្ររបស់ស្រី ឬប្រុស ខ្ញុំក៏សួរនាម និងគោត្ររបស់ស្រី ឬប្រុស នោះហើយ ខ្ញុំគួរសួរឈ្មោះ និងផ្លូវនៃស្រុក ឬនិគម ខ្ញុំក៏សួរឈ្មោះ និងផ្លូវ នៃស្រុក ឬនិគមនោះរួចហើយ ។ ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណា ក្នុងដំណើរនោះថា គ្រូដ៏ចម្រើននេះដឹងសព្វ ឃើញសព្វ តែងប្តេជ្ញានូវញាណ-ទស្សនៈ មិនមានសេសសល់ថា អាត្មាអញកាលដើរក្តី ឈរក្តី ដេកលក់ក្តី

ភ្ញាក់ឡើងក្តី ញាណទស្សនៈ រមែងតម្កល់ស៊ប់ជាប់ជានិច្ច ។ គ្រូនោះចូលទៅកាន់ផ្ទះស្ងាត់ក៏មាន មិនបានដុំបាយក៏មាន ឆ្កែខាំក៏មាន ជួបប្រទះនឹងដំរីកាចក៏មាន ជួបប្រទះនឹងសេះកាចក៏មាន ជួបប្រទះនឹងគោកាចក៏មាន សួរនាមនឹងគោត្របស់ស្រី ឬប្រុសក៏មាន សួរឈ្មោះនឹងផ្លូវនៃស្រុក ឬនិគមក៏មាន ។ គ្រូនោះកាលបើមានគេសួរថា ហេតុនេះតើដូចម្តេច ក៏ប្រាប់គេថា ផ្ទះស្ងាត់ដែលខ្ញុំគួរចូលទៅបាន ខ្ញុំក៏ចូលទៅកាន់ផ្ទះស្ងាត់នោះហើយ ដុំបាយដែលខ្ញុំមិនគួរបាន ខ្ញុំក៏មិនបានដុំបាយនោះហើយ ឆ្កែដែលគួរខាំខ្ញុំបាន ឆ្កែនោះក៏ខាំខ្ញុំហើយ ខ្ញុំគួរជួបនឹងដំរីកាច ខ្ញុំក៏ជួបនឹងដំរីកាចនោះហើយ ខ្ញុំគួរជួបនឹងសេះកាច ខ្ញុំក៏ជួបនឹងសេះកាចនោះហើយ ខ្ញុំគួរជួបនឹងគោកាច ខ្ញុំក៏ជួបនឹងគោកាចនោះហើយ ខ្ញុំគួរសួររកនាម និងគោត្របស់ស្រីឬប្រុស ខ្ញុំក៏សួរនាមនិងគោត្របស់ស្រីឬប្រុសនោះហើយ ខ្ញុំគួរសួរឈ្មោះ និងផ្លូវនៃស្រុក ឬនិគម ខ្ញុំក៏សួរឈ្មោះ និងផ្លូវនៃស្រុក ឬនិគមនោះរួចហើយ ។ បុរសនោះ លុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះ មិនមានទំនងស្រួលដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈទី ១ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៦៦ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូខ្លះ ជា

អ្នកឮតៗគ្នាមក ប្រកាន់យកពាក្យដែលឮតៗថាជាពាក្យពិត ។ គ្រូនោះឯង តែងសំដែងធម៌តាមពាក្យដែលឮតៗ តាមពាក្យបរម្បរាថាដូច្នេះៗ តាមក្បួនតម្រា ។ ម្នាលសន្ទកៈ ឯគ្រូជាអ្នកឮតៗគ្នាមក ប្រកាន់យកពាក្យដែលឮតៗថាជាពាក្យពិត ( នោះ ) រមែងឮពាក្យល្អខ្លះ ឮពាក្យអាក្រក់ខ្លះ ពិតខ្លះ មិនពិតខ្លះ ។ ម្នាលសន្ទកៈ វិញ្ញូបុរស រមែងពិចារណាក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះ ជាអ្នកឮតៗគ្នាមក ប្រកាន់យកពាក្យដែលឮតៗ ថាជាពាក្យពិត ។ គ្រូនោះឯង តែងសំដែងធម៌តាមពាក្យដែលឮតៗ តាមពាក្យបរម្បរាថា ដូច្នេះៗ តាមក្បួនតម្រា ។ ឯគ្រូជាអ្នកឮតៗ គ្នាមក ប្រកាន់យកពាក្យដែលឮតៗថាជាពាក្យពិត ( នោះ ) រមែងឮពាក្យល្អខ្លះ ឮពាក្យអាក្រក់ខ្លះ ពិតខ្លះ មិនពិតខ្លះ ។ បុរសនោះ លុះដឹងច្បាស់ថាព្រហ្មចរិយៈនេះមិនមានទំនងស្រួលដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈទី ២ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្ត ព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៦៧ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះ មានគ្រូខ្លះ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសំដែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការ

ពិចារណា ជាធម៌កើតមានដោយប្រាជ្ញារបស់ខ្លួន ។ ម្នាលសន្ទកៈ ក៏គ្រូអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ ម្នាលសន្ទកៈ វិញ្ញូបុរសរមែងពិចារណា ក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ គ្រូនោះ តែងសម្តែងធម៌ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាធម៌កើតមាន ដោយប្រាជ្ញារបស់ខ្លួន ។ ក៏គ្រូជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី រមែងត្រិះរិះហេតុល្អក៏មាន ត្រិះរិះហេតុអាក្រក់ក៏មាន ពិតក៏មាន មិនពិតក៏មាន ។ បុរសនោះលុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះ មិនមានទំនងស្រួលដូច្នេះហើយ ក៏នឿយណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈទី ៣ ដែលព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរសលែងប្រព្រឹត្តព្រហ្មចរិយៈដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។

[ ៦៨ ] ម្នាលសន្ទកៈ ប្រការមួយទៀត ក្នុងលោកនេះមានគ្រូខ្លះ ជាមនុស្សមានប្រាជ្ញាទន់ ជាមនុស្សល្ងង់ខ្លៅ ។ គ្រូនោះ ហេតុតែខ្លួនមានប្រាជ្ញាទន់ ហេតុតែខ្លួនល្ងង់ខ្លៅ កាលបើមានអ្នកផងសាកសួរប្រស្នាដូច្នោះៗហើយ ក៏ដល់នូវការផ្សាយវាចា ផ្សាយសំដីមិនឲ្យស្ទាប់ខ្លួនថា ខ្ញុំយល់ឃើញថាយ៉ាងនេះក៏មិនមែន ខ្ញុំយល់ឃើញថាយ៉ាងនោះក៏មិនមែន ខ្ញុំយល់ឃើញថា

យ៉ាងដទៃក៏មិនមែន ខ្ញុំយល់ឃើញថា មិនមែនក៏ទេ ខ្ញុំយល់ឃើញថា មិនមែនជាមិនមែនក៏ទេ ។ ម្នាលសន្ទកៈ វិញ្ញូបុរស តែងពិចារណាក្នុងដំណើរនោះដូច្នេះថា គ្រូដ៏ចម្រើននេះ ជាមនុស្សមានប្រាជ្ញាទន់ ជាមនុស្សល្ងង់ខ្លៅ ។ គ្រូនោះ ហេតុតែខ្លួនមានប្រាជ្ញាទន់ ហេតុតែខ្លួនល្ងង់ខ្លៅ កាលបើមានអ្នកផងសាកសួរប្រស្នាដូច្នោះៗ ហើយក៏ដល់នូវការផ្សាយវាចា ផ្សាយសំដីមិនឲ្យស្ទាប់ខ្លួនថា ខ្ញុំយល់ឃើញថា យ៉ាងនេះក៏មិនមែន ខ្ញុំយល់ឃើញថា យ៉ាងនោះក៏មិនមែន ខ្ញុំយល់ឃើញថា យ៉ាងដទៃក៏មិនមែន ខ្ញុំយល់ឃើញថា មិនមែនក៏ទេ ខ្ញុំយល់ឃើញថា មិនមែនជាមិនមែនក៏ទេ ។ បុរសនោះលុះដឹងច្បាស់ថា ព្រហ្មចរិយៈនេះ មិនមានទំនងស្រួលទេ ដូច្នេះហើយ ក៏នឿយ-ណាយចាកព្រហ្មចរិយៈនោះ ហើយចៀសចេញទៅ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយធម៌ទី ៤ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្តក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ ម្នាលសន្ទកៈ នេះឯងឈ្មោះថា អនស្សាសិកព្រហ្មចរិយៈ ៤ ប្រការ ដែលព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដែលជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរនឹងកុសលធម៌ដែលខ្លួន គប្បីដឹងឡើយ ។

[ ៦៩ ] សន្ទកបរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះចំឡែកណាស់ ព្រោះថាព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្ដែងអនស្សាសិកព្រហ្មចរិយៈ ៤ ប្រការនេះ ថាជាអនស្សាសិកព្រហ្មចរិយៈពិតប្រាកដមែន ជាធម៌នាំឲ្យវិញ្ញូបុរស លែងប្រព្រឹត្តព្រហ្មចរិយៈ ដោយដាច់ស្រឡះ ទុកជាកាលប្រព្រឹត្ត ក៏មិនបានត្រេកអរ នឹងកុសលធម៌ដែលខ្លួនគប្បីដឹងឡើយ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះគ្រូនោះនិយាយ ដូចម្ដេចពោលដូចម្ដេច ទើបជាហេតុនាំឲ្យវិញ្ញូបុរស ប្រព្រឹត្តព្រហ្មចរិយៈ បានដោយស៊ប់ចិត្ត កាលបើប្រព្រឹត្តហើយ ក៏រមែងត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

[ ៧០ ] ព្រះអានន្ទមានថេរវាចាថា ម្នាលសន្ទកៈ ព្រះតថាគតកើតឡើងក្នុងលោកនេះ ព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ យាងទៅកាន់សុន្ទរស្ថាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្ដាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នកដទៃឲ្យត្រាស់ដឹងផង ព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ ។បេ។ ព្រះអង្គបានលះបង់នីវរណធម៌ទាំង ៥ នេះ ដែលគ្រឿង

ស្មោហ្មុងចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ព្រះអង្គស្ងប់ស្ងាត់ចាកកាមទាំង-ឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ចូលបឋមជ្ឈាន ប្រកប ដោយវិតក្កៈ និងវិចារៈ មានបីតិ និងសុខៈ ដែលកើតអំពីវិវេក ។ ម្នាល សន្ទកៈ ចំណែកខាងសាវ័ក រមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈ បាន ដោយស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរ នឹងកុសលធម៌ដែលខ្ជួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុ ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈបានហើយ ។បេ។ ក៏ចូលទុតិយជ្ឈាន ។ ម្នាលសន្ទកៈ សាវ័ករមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាព យ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបានដោយ ស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ ដែលខ្ជួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុព្រោះប្រាសចាក បីតិផង ។បេ។ ក៏ចូលតតិយជ្ឈាន ។ ម្នាលសន្ទកៈ សាវ័ករមែងត្រាស់ដឹងនូវ គុណវិសេសដ៏លើសលុបមានសភាពយ៉ាងនេះក្នុងសំណាក់គ្រូណា វិញ្ញូបុរស គប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើ ប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្ជួនគប្បីដឹង ។ ម្នាលសន្ទកៈ ប្រការមួយទៀត ភិក្ខុព្រោះលះបង់សុខផង លះបង់ទុក្ខផង ។បេ។ ចូល ចតុត្ថជ្ឈាន ។ ម្នាលសន្ទកៈ អរិយសាវ័ករមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បី

ប្រព្រឹត្តព្រហ្មចរិយៈ បានដោយស៊ប់ចិត្ត ក្នុងសំណាក់គ្រូនោះ ។ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

[ ៧១ ] ភិក្ខុនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារកម្មជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងបង្អោនចិត្តទៅរកបុព្វេនិវាសានុស្សតិញ្ញាណ គឺប្រាជ្ញារលឹកឃើញ នូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងភពមុន ។ ភិក្ខុនោះរមែងរលឹកនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ រលឹកឃើញនូវជាតិ ដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះឯង ។ ម្នាលសន្ទកៈ សាវករមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុប មានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបាន ដោយស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។ ភិក្ខុនោះកាលបើចិត្តតម្កល់មាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារកម្មជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រ ទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងបង្អោនចិត្តទៅរកចុតូបបាតញ្ញាណ គឺប្រាជ្ញាជាគ្រឿង ដឹងនូវចុតិ និងបដិសន្ធិនៃពួកសត្វ ( ទិព្វចក្ខុញ្ញាណ ) ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា រមែងឃើញនូវពួកសត្វដែល

ច្យុតដែលកើតឡើង ទន់ទាប និងខ្ពង់ខ្ពស់ មានវណ្ណល្អ មានវណ្ណអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ តែងដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ខ្លួន ។ ម្នាលសន្ទកៈ សាវ័ករមែងត្រាស់ដឹងនូវគុណវិសេស ដ៏លើសលុបមានសភាពយ៉ាងនេះ ក្នុងសំណាក់គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈ បានដោយស៊ប់ចិត្តក្នុងសំណាក់គ្រូនោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។ ភិក្ខុនោះ កាលបើចិត្តតម្កល់មាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់ភ្លន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង ដល់នូវសេចក្តីមិនញាប់ញ័រយ៉ាងនេះហើយ រមែងបង្អោនចិត្តទៅរកអាសវក្ខយញ្ញាណ គឺប្រាជ្ញាដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ។ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីប្រជុំកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះផ្លូវប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ។បេ។ ដឹងច្បាស់តាមពិតថា នេះជាផ្លូវប្រតិបត្តិជាដំណើរទៅកាន់ព្រះនិព្វាន ជាគ្រឿងរលត់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតចាកភវាសវៈផង ចិត្តផុតចាកអវិជ្ជាសវៈផង កាលបើចិត្តភិក្ខុនោះផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងដល់ភិក្ខុនោះថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់

ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្ត ទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលសន្ទកៈ សាវក រមែងត្រាស់ដឹងនូវគុណវិសេសដ៏លើសលុបមានសភាពយ៉ាងនេះក្នុងសំណាក់ គ្រូណា វិញ្ញូបុរសគប្បីប្រព្រឹត្តព្រហ្មចរិយៈបាន ដោយស៊ប់ចិត្តក្នុងសំណាក់គ្រូ នោះ កាលបើប្រព្រឹត្តហើយ ក៏ត្រេកអរនឹងកុសលធម៌ដែលខ្លួនគប្បីដឹង ។

[ ៧២ ] សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ភិក្ខុណាជា ព្រះអរហន្តខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បាន ធ្វើសោឡសកិច្ចរួចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍ របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មានចិត្តផុត ( ចាកអាសវៈទាំងឡាយ ) ព្រោះដឹងដោយប្រពៃ តើភិក្ខុនោះនៅ បរិភោគកាមទាំងឡាយដែរឬ ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ ភិក្ខុណា ជាព្រះអរហន្តខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ ហើយបាន ធ្វើសោឡសកិច្ចរួចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មាន ចិត្តផុត ( ចាកអាសវៈទាំងឡាយ ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនដែល ប្រព្រឹត្តល្មើសនូវហេតុ ៥ យ៉ាងឡើយ គឺភិក្ខុជាព្រះខីណាស្រព មិនដែល ក្លែងធ្វើសត្វឲ្យដាច់ចាកជីវិត ១ ភិក្ខុជាព្រះខីណាស្រពមិនដែលកាន់យក ទ្រព្យដែលគេមិនបានឲ្យពោលគឺការលួច ១ ភិក្ខុជាព្រះខីណាស្រពមិនដែល សេពមេថុនធម្ម ១ ភិក្ខុជាព្រះខីណាស្រពមិនដែលពោលពាក្យកុហកទាំង

ដឹងសេចក្តីច្បាស់ ១ ភិក្ខុជាព្រះខីណាស្រព មិនដែលធ្វើនូវការសន្សំទុក ( នូវវត្ថុទាំងឡាយមានល្ងជាដើម ) បរិភោគនូវកាមទាំងឡាយដូចកាលដែលខ្លួននៅជាគ្រហស្ថក្នុងកាលពីដើម ១ ។ ម្នាលសន្ទកៈ ភិក្ខុណាជាព្រះអរហន្តខីណាស្រព បានប្រព្រឹត្តព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចស្រេចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះ ( ចាកអាសវៈទាំងឡាយ ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះមិនដែលប្រព្រឹត្តល្មើសនូវហេតុទាំង ៥ យ៉ាងនេះឯង ។

[ ៧៣ ] សន្ទកបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះភិក្ខុណាជាព្រះអរហន្តខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡសកិច្ចរួចស្រេចហើយ បានដាក់ចុះភារៈហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មានចិត្តផុតស្រឡះ ( ចាកអាសវៈទាំងឡាយ ) ព្រោះដឹងដោយប្រពៃ តើភិក្ខុនោះកាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈតែងតម្កល់នៅជាប់ជានិច្ចថា អាសវៈទាំងឡាយរបស់អញអស់ហើយដូច្នេះឬទេ ។ ព្រះអានន្ទតបថា ម្នាលសន្ទកៈ បើដូច្នោះ អាត្មានឹងធ្វើពាក្យឧបមាឲ្យអ្នក ( ស្តាប់ ) ដ្បិតវិញ្ញូបុរសពួកខ្លះក្នុងលោកនេះរមែងយល់សេចក្តីនៃភាសិតបានដោយពាក្យឧបមា ។ ម្នាលសន្ទកៈ មានបុរសម្នាក់កំបុតដៃ កំបុតជើង បុរសនោះកាលដើរក្តី ឈរក្តី ដេកលក់ក្តី

ភ្ញាក់ឡើងក្តី ដៃទាំងជើងក៏នៅតែកំបុត ជាប់ជានិច្ចដដែល តែកាលបើបុរស នោះពិចារណាទើបដឹងថា អាត្មាអញកំបុតដៃ កំបុតជើង សេចក្តីនេះមាន ឧបមាយ៉ាងណា ម្នាលសន្ទកៈ មានឧបមេយ្យដូចជាភិក្ខុ ដែលជាព្រះអរហន្ត ខីណាស្រព បានប្រព្រឹត្តមគ្គព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ បានធ្វើសោឡ-សកិច្ចរួចហើយ បានដាក់ភារៈចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួន ដោយលំដាប់ហើយ មានធម៌ជាគ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មានចិត្ត ផុតស្រឡះ ( ចាកអាសវៈទាំងឡាយ ) ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ កាលដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី អាសវៈទាំងឡាយ ក៏នៅតែ អស់ជាប់ជានិច្ចដូចដើម តែកាលបើភិក្ខុនោះពិចារណាទើបដឹងថា អាសវៈ ទាំងឡាយរបស់អាត្មាអញអស់ហើយ ។

[ ៧៤ ] សន្ទកៈបរិព្វាជកសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះពួក បុគ្គលស្រោចស្រង់សត្វក្នុងធម្មវិន័យនេះ មានច្រើនប៉ុន្មាននាក់ទៅ ។ ព្រះ អានន្ទតបថា ម្នាលសន្ទកៈ មិនមែនមានត្រឹមតែ ១០០ នាក់ ២០០ នាក់ ៣០០ នាក់ ៤០០ នាក់ ឬ ៥០០ នាក់ទេ តាមដែលពិតនោះ ពួកបុគ្គល ដែលជាអ្នកស្រោចស្រង់សត្វក្នុងធម្មវិន័យនេះ មានច្រើនណាស់ ។ សន្ទកៈ បរិព្វាជកតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រ ព្រះអានន្ទដ៏ចម្រើន ហេតុនេះចំឡែកណាស់ ព្រោះថាការលើកតម្កើងធម៌ របស់ខ្លួនមិនមាន ការបន្តុះបង្អាប់ធម៌របស់អ្នកដទៃ ក៏មិនមាន មានតែការ សម្តែងធម៌សំដៅយកព្រះអរហត្តតែម្យ៉ាង ទាំងបុគ្គលអ្នកស្រោចស្រង់សត្វ

ក៏មានច្រើនប្រាកដពិត ចម្លែកអ្វីតែខាងពួកអាជីវក ជាកូននៃស្រីស្លាប់កូននេះ តែងលើកតម្កើងខ្លួនឯងផង បន្តុះបង្អាប់អ្នកដទៃផង ទាំងបញ្ញត្តបុគ្គល អ្នកស្រោចស្រង់សត្វថាមានតែ ៣ នាក់គត់ គឺគ្រូឈ្មោះនន្ទវច្ឆៈ ១ កិសសង្កិច្ចៈ ១ មក្ខលិគោសាល ១ ។ លំដាប់នោះ សន្ទកបរិព្វាជកហៅបរិសទ្យរបស់ខ្លួនមកហើយប្រាប់ថា អ្នកដ៏ចម្រើនទាំងឡាយចូរប្រព្រឹត្តចុះ ( ព្រោះថា ) ការប្រព្រឹត្តិព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម ( រមែងមានប្រាកដ ) ឯយើងមិនងាយនឹងលះបង់លាភ សក្ការៈ និងសេចក្ដីសរសើរ ក្នុងកាលឥឡូវនេះបានទេ ។ សន្ទកបរិព្វាជក ក៏បញ្ជូនបរិសទ្យ របស់ខ្លួននេះ ទៅក្នុងព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

ចប់ សន្ទកសូត្រទី ៦

# អដ្ឋកថា

## សន្ទកសូត្រ

[ ៥៤ ] សន្ទកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បិលក្ខគុហាយំ** សេចក្ដីថា ត្រង់ទ្វារគុហានោះ មានដើមលៀប ព្រោះដូច្នោះទើបឈ្មោះថា **បិលក្ខគុហា** ។ បទថា **បដិសល្លានា វុដ្ឋិតោ** គឺចេញចាកវិវេក ។ បទថា **ទេវកតសោព្ភោ** គឺ ស្រះធំកើតក្នុងទីដែលត្រូវទឹកភ្លៀងប្រោះ ។ បទថា **គុហា** ក្នុងបទថា **គុហាទស្សនាយ** សេចក្ដីថា ដើម្បីមើលគុហានោះ ជាគុហាពេញដោយធូលី ។ គុហានោះ បានទៅក្នុងទីដែលផុតទឹក ជាទីទួល ។ ជនទាំងឡាយធ្វើឧម្មង្គ ហើយនាំជង្គត់ឈើ និងធូលីចេញ លើកសសរទុកខាងក្នុង ខាងលើប្រក់ ដោយក្ដារ ធ្វើជាផ្ទះម្ដងម្កាល ។ ពួកបរិព្វាជកទាំងនោះនៅក្នុងគុហានោះ ។ គុហានោះ ក្នុងរដូវភ្លៀងមានទឹកដក់ពេញ ។ សូម្បីរដូវប្រាំង បរិព្វាជកនាំគ្នា ទៅនៅក្នុងគុហានោះ ព្រះអានន្ទពោលថា **គុហាទស្សនាយ** សំដៅដល់ គុហានោះ ។ ពិតហើយ ការទៅដើម្បីមើលវិហារ ឬដើម្បីមើលសមុទ្រ និងភ្នំ ព្រោះពិចារណាដល់សង្សារវដ្ដ ដែលមិនមានខាងដើម និងទីបំផុត ដែលបុគ្គលតាមដឹងមិនបានហើយ រមែងគួរ ។ បទថា **ឧន្នាទិនិយា** គឺបន្លឺ សំឡេងអ៊ូអរ ។ តិរច្ឆានកថានោះផ្សាយសំឡេងយ៉ាងនេះ ជាសំឡេងខ្លាំង ផ្សាយទៅកាន់ទិសទាំងឡាយ ។ ព្រោះហេតុនេះ ទើបឈ្មោះថា **ឧច្ចា–សទ្ទមហាសទ្ទោ** ។ បរិព្វាជកទាំងនោះក្រោកឡើងអំពីព្រលឹម ហើយធ្វើ

ចេតិយវត្ត ពោធិវត្ត អាចរិយវត្ត ឧបជ្ឈាយវត្ត ឬយោនិសោមនសិការ មិនមានឡើយ ។ ពួកគេក្រោកឡើងអំពីព្រលឹម លុះដល់ពេលថ្ងៃ ប្រជុំគ្នាពេលល្ងាចប្រជុំសន្ទនាគ្នាដើម្បីរកការសប្បាយ ។ ផ្តើមជជែកដល់រឿងដៃនិងជើងជាដើមនៃគ្នានិងគ្នាយ៉ាងនេះថា ដៃរបស់អ្នកនេះស្អាត ជើងរបស់អ្នកនេះស្អាត ឬជជែកដល់ពណ៌សម្បុររបស់ស្រី ប្រុស ក្មេងស្រី និងក្មេងប្រុស ឬរឿងដទៃៗ ដូចជាការសរសើរក្នុងកាម និងសរសើរក្នុងភពជាដើម ។ ហើយពោលតិរច្ឆានកថាច្រើនយ៉ាង មានពោលដល់រឿងព្រះរាជា ជាដើមដោយលំដាប់ ។ ពិតហើយ ការពោលដែលជាការជំទាស់សួគ៌ និងនិព្វាន ឈ្មោះថា តិរច្ឆានកថា ព្រោះមិននាំចេញទៅអំពីភពបាន ក្នុងកថាទាំងនោះ ការពោលដល់រឿងព្រះរាជា ប្រព្រឹត្តទៅជាដើមថា ព្រះបាទមហាសម្មតរាជ ព្រះបាទមន្ធាតុរាជ ព្រះបាទធម្មាសោករាជ មានអានុភាពយ៉ាងនេះ ឈ្មោះថា រាជកថា ។ ក្នុងចោរកថាជាដើម ក៏មានន័យនេះដូចគ្នា ។ ការពោលអាស្រ័យកាមគុណ ដោយន័យជាដើមថា ព្រះរាជាអង្គនោះ មានព្រះរូបឆោមផូរផង់គួរសរសើរ ដូច្នេះ នេះជាតិរច្ឆានកថា ។ តែការពោលជាទំនងយ៉ាងនេះថា សូម្បីព្រះរាជាអង្គនោះ មានអានុភាពច្រើនយ៉ាងនេះ ក៏គង់សោយទិវង្គត ដូច្នេះ ឈ្មោះថា រមែងតាំងនៅក្នុងភាពជាកម្មដ្ឋានកថា ។ សូម្បីក្នុងចោរទាំងឡាយ ការពោលអាស្រ័យកាមគុណថា ឱ ចោរនោះក្លាហាន ព្រោះអាស្រ័យកម្មនៃចោរទាំងនោះថា ចោរមូលទេព មានអានុភាពច្រើនយ៉ាងនេះ ចោរមេឃមាល មានអានុភាពច្រើនយ៉ាងនេះ ដូច្នេះ ក៏ជាតិរច្ឆានកថា សូម្បី

ក្នុងការច្បាំង ការពោលក្នុងរឿងការតយុទ្ធជាដើម ដោយការពេញចិត្តក្នុងកាមថា បុគ្គលនោះ ត្រូវបុគ្គលនោះសម្លាប់យ៉ាងនេះ ត្រូវចាក់យ៉ាងនេះ ដូច្នេះជាដើម ក៏ជាតិរច្ឆានកថា ។ តែការពោលក្នុងរឿងទាំងឡាយ មានទំនងយ៉ាងនេះថា សូម្បីជនទាំងនោះ ក៏គង់ស្លាប់ ដូច្នេះ ជាកម្មដ្ឋានកថានោះឯង ។

ម្យ៉ាងទៀត ក្នុងរឿងបាយជាដើមមិនគួរពោលដោយអំណាច ការសរសើរក្នុងកាមថា អញទំពា ស៊ី ផឹក បរិភោគ បាយជាដើម មានពណ៌ ក្លិន រសយ៉ាងនេះ តែគួរពោលដល់រឿងទឹកជាដើម ធ្វើឲ្យមានប្រយោជន៍ថា ខ្ញុំបានប្រគេនបាយ សំពត់ ទីដេក ផ្កា គ្រឿងក្រអូប ដែលសម្បូរដោយពណ៌យ៉ាងនេះ ដល់អ្នកមានសីលក្នុងកាលមុន ។ ខ្ញុំបានធ្វើការបូជាត្រង់ព្រះចេតិយដូច្នេះ ។ សូម្បីក្នុងការពោលដល់រឿងញាតិជាដើម ក៏មិនគួរពោល ដោយអំណាចការសរសើរថា ញាតិរបស់ខ្ញុំជាអ្នកក្លាហាន ជាអ្នកអាច ឬថា កាលមុន ខ្ញុំបានត្រាច់ទៅដោយយានដ៏ស្អាតយ៉ាងនេះ ។ តែគួរពោលធ្វើឲ្យមានប្រយោជន៍ថា សូម្បីញាតិរបស់ខ្ញុំទាំងនោះ ក៏បានស្លាប់ទៅដែរ ។ ឬថា កាលមុន ខ្ញុំបានប្រគេនស្បែកជើងប្រភេទនេះដល់សង្ឃ ។ សូម្បីនិយាយរឿងស្រុក ក៏មិនគួរពោលដោយអំណាចការរស់នៅល្អ រស់នៅអាក្រក់ អាហារល្អ អាហារខ្វះខាតជាដើម ឬពោលដោយអំណាចការសរសើរថា មនុស្សនៅក្នុងស្រុកនោះ ជាមនុស្សក្លាហាន ជាមនុស្សប្រតិពល ។ តែគួរពោលធ្វើឲ្យមានប្រយោជន៍ថា សូម្បីមនុស្សក្លាហានមានសទ្ធាជ្រះថ្លាក៏គង់ស្លាប់បាន។ ក្នុងការពោលរឿងនិគម រឿងនគរ រឿងជនបទ ក៏មានន័យ នេះដូចគ្នា ។

ការពោលរឿងស្រី មិនគួរពោលដោយអំណាចនៃការសរសើរ ដោយអាស្រ័យពណ៌សម្បុរ និងសណ្ឋានទ្រង់ទ្រាយជាដើម គួរពោលយ៉ាងនេះថា ស្រ្តីដែលមានសទ្ធាជ្រះថ្លា ក៏គង់ស្លាប់បាន ។ ក្នុងរឿងមនុស្សក្លាហាន ក៏មិនគួរពោលដោយការពេញចិត្តថា អ្នកចម្បាំងឈ្មោះ សន្និមិត្ត បានជាអ្នកក្លាហាន គួរពោលយ៉ាងនេះថា អ្នកចម្បាំង អ្នកក្លាហាន មានសទ្ធា ក៏គង់ស្លាប់ ។ សូម្បីការពោលដល់រឿងច្រករហក ក៏មិនគួរពោលដោយការពេញចិត្តថា ច្រកនោះតាំងនៅល្អ តាំងនៅមិនល្អ មានអ្នកក្លាហាន មានអ្នកប្រតិពល គួរពោលថា អ្នកក្លាហាន អ្នកប្រតិពល ដែលនៅច្រកនោះ ក៏គង់ស្លាប់បាន ។

បទថា **កុម្ភដ្ឋានកថា** គឺទីតម្កល់នៃក្អមទឹក លោកហៅថា កំពង់ទឹក ។ បទថា **កុម្ភទាសីកថា** សេចក្ដីថា សូម្បីកុម្ភទាសីនោះ ក៏មិនគួរពោលដោយការសរសើរថា កុម្ភទាសីគួរស្រឡាញ់ ឈ្លាសក្នុងការរាំ ច្រៀង ។ គួរពោលដោយន័យថា កុម្ភទាសីនោះ ជាអ្នកដល់ព្រមដោយសទ្ធាជាដើម ។ បទថា **បុព្វបេតកថា** សេចក្ដីថា និយាយដល់រឿងអ្នកដែលស្លាប់ទៅហើយ គឺនិយាយរឿងញាតិក្នុងអតីត ។ ក្នុងបទថា **បុព្វបេតកថា** នោះ ដូចគ្នានឹងពោលរឿងញាតិដែលនៅមានជីវិតនៅឡើយ ។ បទថា **ឆានត្តកថា** គឺនិយាយរឿងមិនមានប្រយោជន៍ មានសភាពផ្សេងៗ ក្រៅអំពីរឿងមុន និងរឿងក្រោយ ។ បទថា **លោកក្ខាយិកា** គឺសន្ទនាគ្នារឿងលោកាយតសាស្រ្ត និងរឿងក្រៅគម្ពីរ មានលោកនេះអ្នកណាសាង លោកនេះបុគ្គលនោះសាង ក្អែកស ព្រោះឆ្អឹងស កុកក្រកក្រហម ព្រោះឈាមក្រហមជាដើម ការពោល

រឿងសមុទ្រ ឥតប្រយោជន៍ថា ព្រោះហេតុអ្វីទើបហៅថា សមុទ្រ ព្រោះហេតុអ្វីទើបហៅថា សាគរ ដែលហៅថាសមុទ្រ ព្រោះលើកដៃប្រកាសថា អញជីកឈ្មោះថា សាគរ ព្រោះសាគរទេវបុត្រជីកជាដើម ។ ឈ្មោះថាពោលដល់រឿងសមុទ្រ ។ ពោលដល់ហេតុគ្មានប្រយោជន៍ថា សេចក្តីចម្រើនយ៉ាងនេះ សេចក្តីវិនាសយ៉ាងនេះជាដើម ឈ្មោះថា ពោលរឿងការចម្រើននិងការវិនាសដោយប្រការនោះៗ ។ម្យ៉ាងទៀត ក្នុងបទនេះ ការឃើញថាទៀងគឺការចម្រើន ការឃើញថា សូន្យគឺការវិនាស ។ ការចម្រើន គឺភវៈការវិនាស គឺអភវៈ ។ កាមសុខគឺការចម្រើន ការធ្វើខ្លួនឲ្យលំបាកគឺការវិនាស ។ ឈ្មោះថាតិរច្ឆានកថាមាន ៣២ យ៉ាង រួមជាមួយឥតិភវាភវកថាគឺពោលរឿងការចម្រើន ការវិនាស ៦ យ៉ាងនេះ ដោយប្រការដូច្នេះ ។ សន្ទុកបរិញ្វាជកអង្គុយរួមជាមួយ អ្នកនិយាយតិរច្ឆានកថាបែបនេះ ។

បន្ទាប់អំពីនោះ សន្ទុកបរិញ្វាជកសម្លឹងមើលបរិញ្វាជកទាំងនោះ គិតថាបរិញ្វាជកទាំងនេះ មិនគោរពកោតក្រែងដល់គ្នានិងគ្នាឡើយ ។ ម្យ៉ាងទៀតពួកយើងតាំងអំពីព្រះសមណគោតមប្រាកដឡើង ប្រៀបដូចអំពិលអំពែកក្នុងវេលាព្រះអាទិត្យរះ ។ សូម្បីលាភសក្ការៈរបស់ពួកយើងក៏សាបសូន្យ ។ បើព្រះសមណគោតម ឬសាវ័ករបស់ព្រះសមណគោតម សូម្បីឧបដ្ឋាកដែលជាគ្រហស្ថរបស់សមណគោតមនោះ គប្បីមកកាន់ទីនេះ និងគួរខ្មាសយ៉ាងក្រៃលែង ។ ទោសក្នុងបរិស័ទរមែងប្រាកដខាងលើរបស់អ្នកចម្រើនក្នុងបរិស័ទ ។ទើបសម្លឹងមើលឆ្វេងស្តាំ បានឃើញព្រះថេរៈ ដោយហេតុនោះ ទើបលោក

ពោលថា **អទ្ទសា ខោ សន្ទកោ បរិព្វាជកោ ។បេ។ តុណ្ហី អហេសុំ** សេចក្ដីថា សន្ទកបរិព្វាជកក៏បានឃើញព្រះអានន្ទមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយក៏បញ្ជប់បរិស័ទរបស់ខ្លួនថា អ្នកដ៏ចម្រើនទាំងឡាយ ចូរនិយាយតិចៗ អ្នកដ៏ចម្រើនទាំងឡាយ កុំមាត់ឡើយ ( ដ្បិត ) សមណៈឈ្មោះអានន្ទនេះ ជាសាវករបស់ព្រះសមណគោតមមកឥឡូវនេះ ក៏ពួកសាវកណារបស់ព្រះសមណគោតម ដែលអាស្រ័យនៅក្នុងក្រុងកោសម្ពី បណ្ដាសាវកទាំងនោះ អានន្ទនេះឯង លោកជាសមណៈមួយអង្គដែរ ឯពួកលោកមានអាយុទាំងនោះចូលចិត្តតែសំឡេងតិចៗ និយាយសរសើរតែសំឡេងតិចៗ ដែលព្រះសម្ពុទ្ធព្រះអង្គមានសំឡេងតិច បានទូន្មានហើយ ធ្វើដូចម្ដេចឲ្យព្រះអានន្ទជ្រាបច្បាស់ថា បរិស័ទមានសំឡេងតិចហើយសំគាល់ថា គួរនិមន្តចូលមក ។ គ្រានោះ ពួកបរិព្វាជកទាំងនោះក៏នាំគ្នាស្ងៀម ។

ក្នុងបទទាំងនោះ បទថា **សណ្ឋបេសិ** គឺឲ្យសិក្សា បានដល់បិទបាំងទោសរបស់បរិស័ទនោះ ។ ញុំាំងបរិស័ទឲ្យតាំងនៅដោយអាការដែលតាំងនៅហើយដោយល្អ ។ ដូចបុរសកាលចូលទៅកាន់ចំណោមបរិស័ទរមែងស្លៀកពាក់រៀបរយ ដើម្បីបិទបាំងទោស ។ បោសទីស្អុក ធូលី យ៉ាងណា ។ សន្ទកបរិព្វាជកឃាត់បរិស័ទថា លោកដ៏ចម្រើនទាំងឡាយ ចូរបន្ថយសំឡេងចុះ ដើម្បីបិទបាំងទោសរបស់បរិស័ទនោះ អធិប្បាយថា ឲ្យបរិស័ទតាំងនៅដោយអាការដែលតាំងនៅដោយល្អ ។ បទថា **អប្បសទ្ទកាមា** គឺប្រាថ្នាសំឡេងតិច ។ អង្គុយម្នាក់ឯង ឈរម្នាក់ឯង មិនប្រឡូកប្រឡំដោយ

ពួកគណៈ ។ បទថា **អប្បសទ្ទាវិនីតា** គឺព្រះពុទ្ធជាអ្នកមានសំឡេងតិច មានសំឡេងមិនខ្លាំង ទ្រង់ទូន្មានទុក ។ បទថា **អប្បសទ្ទស្ស វណ្ណវាទិនោ** គឺ ពោលសរសើរ ទីដែលមានសំឡេងតិច នឹងមិនមានសំឡេង ។ បទថា **ឧបសង្កមិតព្វំ មញ្ញេយ្យ** គឺគប្បីសម្គាល់ដល់ការចូលទៅក្នុងទីនេះ ។

ព្រោះហេតុអ្វី ទើបសន្ទកបរិព្វាជកនោះ បំណងនឹងចូលទៅជិតព្រះថេរៈ ព្រោះប្រាថ្នាសេចក្តីចម្រើនដល់ខ្លួន ។ បានឮថា បរិព្វាជកទាំងឡាយ កាលព្រះពុទ្ធ ឬសាវករបស់ព្រះពុទ្ធមកកាន់សម្នាក់ខ្លួន ទើបលើកខ្លួនឡើងក្នុងសម្នាក់ពួកឧបដ្ឋាកថា ថ្ងៃនេះព្រះសមណគោតមមកកាន់សម្នាក់របស់ពួកយើង ព្រះសារីបុត្រក៏មក លោកទាំងនោះមិនទៅរកបុគ្គលណាឡើយ ពួកលោកចូរឃើញថា ពួកយើង តើនឹងអន់ដូចម្តេច ។ រមែងតាំងខ្លួនទុកក្នុងទីខ្ពស់ ។ ព្យាយាមនឹងទទួលយកឧបដ្ឋាករបស់ព្រះមានព្រះភាគ ។ បានឮថា បរិព្វាជកទាំងនោះ ឃើញឧបដ្ឋាករបស់ព្រះមានព្រះភាគ ទើបពោលយ៉ាងនេះថា សូម្បីព្រះគោតមដ៏ចម្រើនដែលជាសាស្តារបស់ពួកលោកក្តី សាវករបស់ព្រះគោតមក្តី គង់មកកាន់សម្នាក់របស់ពួកយើង ពួកយើងព្រមព្រៀងគ្នានិងគ្នា ឯពួកលោកមិនប្រាថ្នានឹងសម្លឹងមើលពួកយើង មិនធ្វើសាមីចិកម្ម ពួកយើងធ្វើខុសដល់ពួកលោកឬ ។

កាលមនុស្សពួកខ្លះគិតថា សូម្បីព្រះពុទ្ធគង់យាងមកដល់សម្នាក់បរិព្វាជកទាំងនេះ ពោលថ្វីដល់ពួកយើង ។ តាំងអំពីនោះមក ពួកមនុស្សឃើញបរិព្វាជកហើយ ក៏មិនមើលងាយ ។ បទថា **តុណ្ហី អហេសុំ** គឺអង្គុយបោម

រោមសន្ទកបរិព្វាជក ។ បទថា **ស្វាគតំ ភោតោ អានន្ទស្ស** លោកសម្តែងទុកថា កាលព្រះអានន្ទមករកពួកយើងជាការមកល្អហើយ ។ កាលលោកទៅក៏នឹងទោមនស្ស ។ បទថា **ចិរស្សំ ខោ** នេះជាពាក្យពោលសម្តែងសភាពគួរស្រឡាញ់ ។ ឯព្រះថេរៈទៅអារាមរបស់បរិព្វាជកតាមវេលា ដើម្បីត្រូវការចារិក ព្រោះដូច្នោះ សន្ទកបរិព្វាជកកាន់យកការដែលធ្លាប់មកក្នុងកាលមុនទើបពោលយ៉ាងនេះ ។ កាលបរិព្វាជកពោលយ៉ាងនេះហើយ ក៏មិនបានជាអ្នករឹងត្អឹងដោយមានះ ហើយអង្គុយ ។ ទើបក្រោកអំពីអាសនៈរបស់ខ្លួនបោសអាសនៈនោះ និមន្តព្រះថេរៈឲ្យអង្គុយលើអាសនៈ ពោលថា សូមព្រះអានន្ទគង់ចុះ នេះអាសនៈក្រាលទុកហើយ ។

[ ៥៥ ] បទថា **អន្តរាកថា វិប្បកតា** ព្រះអានន្ទសួរថា កថាអ្វីដែលលោកបញ្ឈប់ក្នុងចន្លោះ តាំងអំពីពួកលោកអង្គុយសន្និបាតហូតដល់ខ្ញុំមក ។ កថាអ្វីដែលមិនទាន់ចប់ ព្រោះខ្ញុំមកជាហេតុ ។ លំដាប់នោះ បរិព្វាជកកាលសម្តែងថា កថាគ្មានប្រយោជន៍ មិនមានសារៈ អាស្រ័យវដ្តៈ មិនសមគួរនឹងពោលចំពោះមុខលោកម្ចាស់ទេ ទើបពោលពាក្យថា **តិដ្ឋតេសា ភោ** ជាដើមសេចក្តីថា ពាក្យនុ៎ះព្រះអានន្ទដ៏ចម្រើន មិនបានជាសល់ក្រទេ ចាំស្តាប់ក្នុងកាលខាងក្រោយក៏បាន ។ បទថា **នេសា ភោតោ** សេចក្តីថា សន្ទកបរិព្វាជកពោលថា បើលោកម្ចាស់ដ៏ចម្រើន បំណងនឹងស្តាប់សូម្បីខាងក្រោយ ក៏នឹងបានស្តាប់ដោយមិនលំបាក ។ កថានេះមិនមានប្រយោជន៍ដល់ពួកយើងទេ ។ ពួកយើងបានការមករបស់លោកម្ចាស់ហើយ បំណងនឹងស្តាប់កថាដែលមាន

ហេតុផលល្អដទៃឯណោះទេ ។

សន្ទកៈកាលអាពធនាព្រះធម្មទេសនា ទើបពោលពាក្យថា **សាធុ ភោ ភវន្តំយេវ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អាចរិយកេ** គឺក្នុងលទ្ធិរបស់អាចារ្យ ។ បទថា **អនស្សាសិកានិ** សេចក្តីថា ព្រហ្មចរិយធម៌ដែលវៀរសេចក្តីត្រេកអរ គឺមិនមានទំនងស្រួល ។ បទថា **សសក្កំ** ជានិបាត ចុះក្នុងអត្ថថា ដោយចំណែកមួយ អធិប្បាយថា វិញ្ញូជនមិនគប្បីនៅប្រព្រឹត្តដោយចំណែកមួយ ។ លោកអធិប្បាយថា ចំណែកវិញ្ញូជន កាលនៅប្រព្រឹត្ត មិនគប្បីឲ្យត្រេកអរ មិនគប្បីឲ្យសម្រេច មិនគប្បីឲ្យបរិបូណ៌ ។ បទថា **ញាយំ ធម្មំ កុសលំ** គឺឈ្មោះថាកុសលធម៌ ព្រោះអត្ថថា មិនមានទោសដែលជាហេតុ ។

[ ៥៦ ] បទថា **ឥធ** គឺក្នុងលោកនេះ ។ បទថា **នត្ថិ ទិន្នំ** ជាដើម លោកពោលទុកហើយ ក្នុងសាលេយ្យកសូត្រ ។ បទថា **ចាតុម្មហាភូតិកោ** គឺសម្រេច ដោយមហាភូតរូប ៤ ។ បទថា **បឋវី បឋវីកាយំ** គឺធាតុដីខាងក្នុងទៅតាមធាតុដីខាងក្រៅ ។ បទថា **អនុបេតិ** គឺទៅតាម ។ បទថា **អនុបគ្គច្ឆតិ** ជាវេវចនៈនៃបទថា **អនុបេតិ** នោះឯង ។ បទថា **អនុគច្ឆតិ** ក៏មាន ។ ដោយបទទាំង ២ នេះ លោកសម្តែងថា **ឧបេតិ ឧបគច្ឆតិ** គឺចូលទៅ ។ សូម្បីក្នុងធាតុទឹកជាដើម ក៏មានន័យនេះដូចគ្នា ។ បទថា **ឥន្ទ្រិយានិ** គឺមនិន្ទ្រិយជាគម្រប់ ៦ រមែងស្ទុះទៅកាន់អាកាស ។ បទថា **អាសន្ទិបញ្ចមា** គឺមានគ្រែអង្គួយជាគម្រប់ ៥ អធិប្បាយថា គ្រែ និងបុរស ៤ នាក់ ឈរចាប់ជើងគ្រែទាំង ៤ ។ បទថា **យាវ អាឡាហនា** សេចក្តីថា ត្រង់ទីឈាបន-

កិច្ច ។ បទថា **បធានិ** គឺរាងកាយ ។ គុណបទទាំងឡាយប្រព្រឹត្តទៅហើយ ដោយន័យជាដើមថា បុគ្គលនេះមានសីលយ៉ាងនេះ ទ្រុស្តសីលយ៉ាងនេះ ។ បទថា **បធានិ** នេះ លោកបំណងយកសរីរៈ ។ បទថា **កាបោតកានិ** គឺ មានពណ៌ប្រផេះ អធិប្បាយថា មានពណ៌ដូចស្លាបនៃសត្វព្រាប ។ បទថា **ភស្សន្តា** គឺមានផេះជាទីបំផុត ។ ក្នុងបទនេះ បាលីក៏យ៉ាងនេះ ។ បទថា **អាហុតិយោ** សេចក្តីថា ទានដែលឲ្យហើយមានប្រភេទជាគ្រឿងសក្ការៈជាដើម ដែលបួងសួង ទាំងអស់នោះ មានផេះជាទីបំផុត ។ បន្ទាប់អំពីនោះ មិនឲ្យផលឡើយ ។ បទថា **ទត្តុប្បញ្ញត្តំ** គឺបុគ្គលល្ងង់ បុគ្គលពាល បញ្ញត្តទុក បទនេះលោកអធិប្បាយថា ទាននេះបុគ្គលពាលល្ងង់ខ្លៅបញ្ញត្តទុក មិនមែនបណ្ឌិតបញ្ញត្តឡើយ ។ បុគ្គលពាលឲ្យ បណ្ឌិតទទួល ។ បទថា **អត្ថិកវាទំ** សេចក្តីថា បុគ្គលពួកខ្លះពោលវាទៈថា មានផល ដូចពាក្យថា ផលទានដែលឲ្យហើយមាន ។ ពាក្យរបស់ជនទាំងនោះ ជាពាក្យទទេ ជាពាក្យកុហក ជាពាក្យផ្តេសផ្តាស ។ បទថា **ពាលេ ច បណ្ឌិតេ ច** គឺពាល និងបណ្ឌិត ។

[ ៥៧ ] បទថា **អកតេន មេ ឯត្ថ កតំ** គឺកម្មក្នុងលទ្ធិនេះ ដោយកម្មនៃសមណៈដែលអញមិនបានធ្វើឡើយ ឈ្មោះថា ជាការធ្វើហើយ ។ ព្រហ្មចរិយៈ ដែលអញមិនធ្លាប់នៅ ឈ្មោះថា នៅហើយ ។ បទថា **ឯត្ថ** គឺ ក្នុងធម៌របស់សមណៈនេះ ។ បទថា **សមសមា** គឺស្មើគ្នាយ៉ាងក្រៃលែង ឬស្មើគ្នាដោយគុណដ៏ស្មើ ។ បទថា **សាមញ្ញំ បត្តា** គឺដល់នូវភាពជាអ្នកស្មើគ្នា ។

[ ៥៨ ] បទថា **ករតោ** ជាដើម លោកពោលទុកហើយ ក្នុងអបណ្ណក

សូត្រ ។

[ ៦០ ] បទថា **នត្ថិ ហោតុ** ក៏ដូច្នោះ ។

[ ៦២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងព្រហ្មចរិយវាសទី ៤ ដូចតទៅនេះ ឈ្មោះថា **អកដា** ព្រោះមិនមានអ្នកណាធ្វើ ។ បទថា **អកដវិធា** គឺមិនមានបែបផែន ដែលអ្នកណាធ្វើ អធិប្បាយថា មិនមានបុគ្គលណាបញ្ជាឲ្យធ្វើថា អ្នកចូរធ្វើយ៉ាងនេះ ។ បទថា **អនិម្មិតា** គឺមិនមានបុគ្គលណានិម្មិតដោយឫទ្ធិ ។ បទថា **អនិម្មាតា** គឺមិនមានបុគ្គលណានិម្មិតឲ្យ ។ អាចារ្យពួកខ្លះពោលបទថា **អនិម្មិតព្វា** មិនគប្បីនិម្មិតឲ្យ ។ បទនោះ មិនប្រាកដក្នុងបាលី មិនប្រាកដក្នុងអដ្ឋកថា ។ បទថា **វញ្ឈា** គឺអារ សត្វចិញ្ចឹមអារដែលមិនបង្កើតសត្វណាមួយ ដូចត្នោតជាដើមមិនមានផល ។ ដោយបទនេះ បដិសេធភាពដែលបឋវីជាដើមឲ្យកើតជារូបជាដើម ។ ឈ្មោះថា **កូដដ្ឋា** ព្រោះតាំងនៅដូចកំពូលភ្នំ ។ **ឯសិកដ្ឋាយិដ្ឋិតា** គឺតាំងនៅដូចសសរគោលក្នុងស្មៅដំណេកទន្សាយ ។ ក្នុងបទនោះ មានអធិប្បាយថា វត្ថុណាដែលលោកពោលថា រមែងកើត វត្ថុនោះមាន ដូចសសរគោលរមែងចេញទៅអំពីស្មៅដំណេកទន្សាយ ។ បាឋៈថា **ឯសិកដ្ឋាយដ្ឋិតា** ក៏មាន ។ អធិប្បាយថា សសរគោលដែលបោះទុកល្អហើយ មិនញាប់ញ័រ តាំងនៅមាំទាំ ។ សភាវៈ ៧ កង តាំងមាំហើយយ៉ាងនោះ ។ សូម្បី ២ បទនេះ លោកសម្ដែងដល់ការមិនវិនាសទៅនៃសភាវៈទាំង ៧ កង នោះ ។ បទថា **ន ឥញ្ជន្តិ** សេចក្ដីថា សភាវៈ ៧ កង មិនញាប់ញ័រ គឺមិនរង្គើ ព្រោះតាំងនៅមាំទាំដូចសសរ

គោល ដូច្នោះ ។ បទថា **ន វិបរិណាមេន្តិ** គឺមិនលះប្រក្រតី ។ បទថា **អញ្ញមញ្ញំ ព្យាពាធេន្តិ** គឺមិនបៀតបៀនគ្នានិងគ្នា ។ បទថា **នាលំ** គឺមិនអាច ។

គប្បីជ្រាបក្នុងបទថា **បឋវីកាយោ** ជាដើមដូចតទៅនេះថា គឺក្រុមដី ឬពួកដី ឈ្មោះថា បឋវីកាយ ។

[ ៦៣ ] បទថា **តត្ថ** គឺក្នុងកង មានជីវៈជាគម្រប់ ៧ នោះ ។ បទថា **នត្ថិ ហន្តា វា** លោកសម្ដែងទុកថា មិនមានអ្នកអាចដើម្បីសម្លាប់ឯងក្ដី ប្រើឲ្យអ្នកដទៃសម្លាប់ក្ដី ដើម្បីឲ្យក្ដៅក្រហាយក្ដី ដើម្បីប៉ះខ្ទប់ក្ដី ដើម្បីសោយសោកឯងក្ដី ដើម្បីឲ្យអ្នកដទៃសោយសោកក្ដី ដើម្បីស្ដាប់ឯងក្ដី ដើម្បីយល់ឯងក្ដី ។ បទថា **សត្តន្នំយេវ កាយានំ** លោកសម្ដែងទុកថា ដូចសស្ត្រាដែលទម្លាយក្នុងគំនរសណ្ដែកបាយជាដើម រមែងចូលទៅដោយរវាងគំនរសណ្ដែកបាយយ៉ាងណា សស្ត្រាស៊ក ចូលទៅដោយចន្លោះ ក្នុងរវាងសការៈ ៧ កង ក៏ដូច្នោះ សស្ត្រាត្រឹមតែជាសញ្ញាតែម្យ៉ាងប៉ុណ្ណោះថា អញនឹងសម្លាប់បុគ្គលនេះចោល ។ បទថា **យោនិប្បមុខសតសហស្សានិ** សេចក្ដីថា លោកសម្ដែងទិដ្ឋិឥតប្រយោជន៍ ដោយត្រឹមតែគិតគ្នេរតែម្យ៉ាងថា កំណើតដែលជាប្រធាននិងកំណើតខ្ពស់បំផុត ១ លាន ៤ សែន ៦ ពាន់ ៦ រយ ។ បទថា **បញ្ចកម្មុនោ សតានិ** សេចក្ដីថា កម្ម ៥០០ ។ សូម្បីក្នុងបទថា **បញ្ច ច កម្មានិ តីណិ ច កម្មានិ** ជាដើម ក៏មានន័យនេះដូចគ្នា ។ តែអាចារ្យពួកខ្លះពោលថា បទថា **បញ្ច កម្មានិ** គឺពោលដោយអំណាចឥន្ទ្រិយ ៥ ។ បទថា **តីណិ** គឺពោលដោយអំណាចកាយកម្មជាដើម ។ តែក្នុងបទថា **កម្មេ ច**

**អឌ្ឍកម្ម** ៥ គឺលទ្ធិរបស់កម្មនោះ គឺកាយកម្ម និងវចីកម្ម ។ មនោកម្មជាកម្មពាក់កណ្តាល ។ បទថា **ទ្វដ្ឋិបដិបទា** លោក ពោលដល់បដិបទាក្នុងទិដ្ឋិ ៦២ ។ បទថា **ទ្វត្ថន្តរកប្បា** គឺ ក្នុងកប្បនីមួយៗ មានអន្តរកប្ប ៦៤ ។ ព្រះអានន្ទត្ថេរកាលមិនដឹងកប្ប ២ ដទៃ ទើបពោលយ៉ាងនេះ ។ អភិជាតិ ៦ ពោលទុកពិស្តារហើយ ក្នុងអបណ្ណកសូត្រ ។ បទថា **អដ្ឋ បុរិសភូមិយោ** លោកពោលទុកថា បុរិសភូមិ ៨ នេះ គឺ **មន្ទភូមិ** ភូមិទន់ខ្ចី ១ **ខិឌ្ឌាភូមិ** ភូមិលេង ១ **បទវីមំសកភូមិ** ភូមិរៀនដើរ ១ **ឧជុគតភូមិ** ភូមិដើរ ១ **សេក្ខភូមិ** ភូមិសិក្សា ១ សមណភូមិ ១ **ជិនភូមិ** ភូមិអ្នករៀនដឹង ១ **បន្នភូមិ** ភូមិអ្នកចាក់ផ្ទះហើយ ១ ។

ក្នុងភូមិទាំងនោះ សត្វទាំងឡាយដែលនៅតូចខ្ចី នៅល្ងង់ខ្លៅ ព្រោះតាំងអំពីថ្ងៃកើតមកអំពីទីចង្អៀតបាន ៧ ថ្ងៃ នេះឈ្មោះថា **មន្ទភូមិ** ។ ម្យ៉ាងទៀត សត្វពួកណាមកអំពីទុគ្គតិ សត្វទាំងនោះ រមែងយំ និងយំខ្លាំងរឿយៗ ។ សត្វមកអំពីសុគតិ រឭកដល់សុគតិនោះៗ ហើយសើច នេះឈ្មោះថា **ខិឌ្ឌាភូមិ** ការចាប់ដៃ ឬជើងរបស់មាតាបិតា ឬគ្រែ ហើយឈានជើងចុះលើផែនដី ឈ្មោះថា **បទវីមំសកភូមិ** ។ គ្រាដែលអាចដើរទៅដោយជើងបាន ឈ្មោះថា **ឧជុគតភូមិ** ។ គ្រាសិក្សាសិប្បៈ ឈ្មោះថា **សេក្ខភូមិ** ។ ការចេញចាកផ្ទះហើយបួស ឈ្មោះថា **សមណភូមិ** ។ គ្រាគប់រកអាចារ្យ ហើយដឹង ឈ្មោះថា **ជិនភូមិ** ។ ម្យ៉ាងទៀត ភិក្ខុដឹង ចាក់ផ្ទះហើយ មិនរៀនអ្វីទៀត ព្រោះហេតុនោះ សមណៈដែលមិនចាំបាច់រៀនយ៉ាងនេះ ឈ្មោះថា **បន្នភូមិ** ។

បទថា **ឯកូនបញ្ញាស អាជីវសតេ** គឺការប្រព្រឹត្តទៅរបស់អាជីវក ១៤៩ បែប ។ បទថា **ឯកូនបញ្ញាស បរិព្វាជកសតេ** គឺបព្វជ្ជារបស់បរិព្វាជក ១៤៩ ។ បទថា **ឯកូនបញ្ញាស នាគាវាសសតេ** គឺនាគមណ្ឌល ១៤៩ ។ បទថា **វីសេ ឥន្ទ្រិយសតេ** គឺឥន្ទ្រិយ ១២០ ។ បទថា **តឹសេ និរយសតេ** គឺនរក ១៣០ ។ បទថា **រជោធាតុយោ** គឺទីដែលដេរដាសដោយធូលី ។ លោកពោលសំដៅដល់ខ្នងដៃ និងខ្នងជើងជាដើម ។ បទថា **សត្ត សញ្ញិ-គព្ភា** បានដល់សញ្ញីគព្ភ លោកពោលសំដៅដល់ អូដ្ឋ គោ លា ពពែ សត្វចិញ្ចឹម ម្រឹគ និងក្របី ។ បទថា **អសញ្ញិគព្ភា** បានដល់អសញ្ញីគព្ភ ៧ លោកសំដៅដល់ស្រូវសាលី ស្រូវជំណើប ស្រងែ សណ្ដែកបាយ ថ្លៅ ស្កួយ និងស្មៅគែលលក ។ បទថា **និគណ្ឋគព្ភា** គឺគភ៌ដែលកើតក្នុងថ្នាំង ។ លោកពោលសំដៅដល់ អំពៅ ឫស្សី និងដើមបបុស ។ បទថា **សត្ត ទេវា** បានដល់ ទេវតា ៧ គឺទេវតាច្រើន តែលោកពោលថា ៧ ។ សូម្បីមនុស្សក៏មិនតិច លោកក៏ពោលថា ៧ ។ បទថា **សត្ត បិសាចា** គឺបិសាចច្រើន លោកក៏ពោលថា ៧ ។ បទថា **សរា** គឺស្រះធំ លោកពោលសំដៅដល់ស្រះ ឈ្មោះថា កណ្ណមណ្ឌកៈ រថកាឡៈ អនោតត្តៈ សីហប្បបាតៈ ឆទ្ទន្តៈ មុចលិន្ទ[1] កុណាលទហៈ ។ បទថា **បវុដ្ឋា** បានដល់ ម្ចាស់តម្រា ។ បទថា **សត្តបបាតា** បានដល់ ជ្រោះធំ ៧ ។ បទថា **សត្តបបាតសតានិ** បានដល់ ជ្រោះតូច ៧០០ ។ បទថា **សត្ត សុបិនា** បាន

១- អដ្ឋកថា ឧបាលិវាទសូត្រជា មន្ទាកិនី ។

ដល់មហាសុបិន ៧ ។ បទថា **សត្ត សុបិនសត្តានិ** បានដល់ សុបិនតូច ៧០០ ។ បទថា **មហាកប្បិនោ** បានដល់ មហាកប្ប ។ ក្នុងបទនេះ លោកពោលថា រាល់ ១០០ ឆ្នាំ យកចុងស្បូវក្លាំងជ្រលក់ទឹកនាំចេញទៅម្ដង ១ តំណក់ ស្រះនោះខះអស់ ៧ ដង ទើបហៅថា មួយមហាកប្ប ។ បុគ្គលពាល និងបណ្ឌិតញ៉ាំងមហាកប្ប ៨ លាន ៤ សែន⁽¹⁾ បែបនោះឲ្យអស់ទៅ ទើបធ្វើទីបំផុតទុក្ខបាន នេះជាលទ្ធិរបស់បុគ្គលនោះ ។ បានឮថា សូម្បីបណ្ឌិតក៏មិនអាចធ្វើឲ្យបរិសុទ្ធបានក្នុងចន្លោះនោះ ។ សូម្បីបុគ្គលពាលក៏មិនច្រើនជាងនោះ ។ បទថា **សីលេន** គឺដោយសីល ដូច្នោះ លោកពោលដោយអចេលកសីល ឬសីលដទៃឯណាមួយ ។ បទថា **វតេ្តន** គឺដោយវត្តនោះ ។ បទថា **តបេន** គឺដោយការធ្វើសេចក្ដីព្យាយាមជាគ្រឿងដុតបាប អធិប្បាយថា បុគ្គលណាគិតថា អញជាបណ្ឌិត ដូច្នេះ នឹងបរិសុទ្ធមុនវេលា បុគ្គលនោះ ឈ្មោះថា រមែងអប់រំកម្ម ដែលនៅមិនទាន់ឲ្យផល បុគ្គលនោះគិតថា អញជាបុគ្គលពាល បណ្ដោយពេលវេលា អស់កាលតាមដែលពោលទុក បុគ្គលនោះ ឈ្មោះថា ពាល់ត្រូវសម្ផស្ស ដែលកម្មឲ្យផលហើយ ធ្វើឲ្យដល់ទីបំផុត ។ បទថា **ហេវំ នត្ថិ** លោកសម្ដែងថា ទាំងពីរករណីនោះ មិនអាចធ្វើបាន ។ បទថា **ទោណមិតេ** គឺវាល់ដោយនាឡិ ។ បទថា **សុខទុក្ខេ** បានដល់សុខនិងទុក្ខ ។ បទថា **បរិយន្តកតេ** គឺធ្វើទីបំផុតឲ្យអស់ បានតាមកាលកំណត់ ដូចពោលហើយ ។ បទថា **នត្ថិ ហាយនវឌ្ឍនេ** គឺសេចក្ដីវិនាស

---

១- បិដកខ្មែរជា ៨ លានចូឡមហាកប្ប ។

និងសេចក្ដីចម្រើនរមែងមិនមាន អធិប្បាយថា សង្សារវដ្ដមិនបានអស់ដល់បណ្ឌិត មិនបានវែងឆ្ងាយដល់បុគ្គលពាល ។ បទថា **ឧក្កំ សាវកំសេ** គឺលូតលាស់ឡើង និងរេចរឹល ។ ពាក្យនេះ ជាវេវចនៈ នៃសេចក្ដីវិនាស និងសេចក្ដីចម្រើន ។

ឥឡូវនេះ កាលបើមិនស្វាធ្យាយសេចក្ដីនោះដោយឧបមា ទើបសាស្ដាគឺមេលទ្ធិពោលពាក្យថា **សេយ្យថាបិ នាម** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សុត្តគុឡេ** បានដល់ ដូចអំបោះដែលមូរទុក ។ បទថា **និព្វេឋិយ–មានមេវ បលេតិ** សេចក្ដីថា កាលបុគ្គលឈរនៅលើកំពូលភ្នំ ឬចុងឈើ ហើយបោះអំបោះទៅ រមែងលាចេញ រហូតអស់អំបោះនោះ កាលអំបោះអស់ក៏ឈប់នៅក្នុងទីនោះ គឺមិនកន្លងហួសទៅ ។ លោកសម្ដែងថា បណ្ឌិត និងពាលនោះ នឹងបរិសុទ្ធឯង តាមកំណត់កាល ដូចពោលទុកហើយយ៉ាងនោះមិនបាន ។ បទថា **កិមិទំ** សាស្ដាខ្វះក្នុងលោកនេះ កាលគេសួរយ៉ាងនេះថា សេចក្ដីនេះលោកមិនដឹងឬ លោកឈ្មោះថាជាសព្វញ្ញូឬ ក៏គេចទៅក្នុងនិយតវាទ ពោលថា ខ្ញុំចូលទៅកាន់ផ្ទះស្វាត់ជាដើម ។

[ ៦៦ ] បទថា **អនុស្សវិកោ ហោតិ** គឺជាអ្នកអាស្រ័យការស្ដាប់ តាមគ្នាមក ។ បទថា **មនុស្សវសច្ចោ** គឺប្រកាន់តាមដែលស្ដាប់មកពិតៗ ។ បទថា **បិដកសម្បទាយ** សេចក្ដីថា ការយល់ព្រមដោយគន្ថ គឺបិដកបាត់ជាវគ្គ ជាបណ្ណាសក ។

[ ៦៨ ] បទថា **មន្ទោ** គឺមានបញ្ញាទន់ខ្សោយ ។ បទថា **មោមូហោ** គឺ

ជាបុគ្គលល្ងង់ក្រៃលែង ។ បទថា **វាចាវិក្ខេបំ អាបជ្ជតិ** អធិប្បាយថា ពាក្យនិយាយដូច្នេះ រមែងបោះពាក្យបោះសម្ដីទៅ ឈ្មោះថាបោះពាក្យបោះសម្ដីមិនឲ្យស្ទាប់ខ្ជួន មិនមានទីបំផុត ។ ម្យ៉ាងទៀត ត្រីមួយប្រភេទ ឈ្មោះ អមរា ( អន្ទង់ ) កាលត្រាច់ទៅក្នុងទឹក ដោយការផុសឡើង និងមុជចុះជាដើម នរណាមួយមិនអាចចាប់បានយ៉ាងណា សូម្បីវាទនេះក៏ដូច្នោះ រមែងត្រាច់ទៅខាងនេះខាងនោះ រមែងមិនចូលដល់អាការ ដែលនឹងចាប់បាន ព្រោះហេតុនោះទើបវាទនេះឈ្មោះថា អមរាវិក្ខេបៈ ។

ក្នុងពាក្យថា **ឯវន្តិបិ មេ នោ** ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅនេះថា សាស្ដានោះ កាលគេសួរថា វត្ថុនោះជាកុសលឬ ក៏ពោលថា ការឃើញរបស់ខ្ញុំថា សូម្បីយ៉ាងនោះក៏មិនមែន បន្ទាប់ពីនោះ កាលគេសួរថា អ្វីជាអកុសល ក៏ពោលថា ការឃើញរបស់ខ្ញុំថាយ៉ាងនោះក៏មិនមែន កាលគេសួរថា មានអ្វីដទៃអំពីកុសល និងអកុសលទាំងពីរឬ ក៏ពោលថា ការឃើញរបស់ខ្ញុំថា ដោយប្រការដទៃក៏មិនមែន បន្ទាប់អំពីនោះ កាលគេសួរថា ការឃើញរបស់លោកថា សូម្បីទាំង ៣ ចំណែក ក៏មិនមែនឬ ក៏ពោលបណ្ដោះបណ្ដោយយ៉ាងនោះទៀតថា ការឃើញរបស់ខ្ញុំថាមែនក៏មិនមែន មិនមែនក៏មិនមែន ដូច្នេះ ។ រមែងមិនតាំងនៅក្នុងចំណែកណាមួយ ។

បទថា **និព្វិជ្ជ បក្កមតិ** គឺសាស្ដានោះ មិនអាចជាទីពឹងដល់ខ្លួនបាន នឹងអាចជាទីពឹងដល់អញបានដូចម្ដេច ព្រោះហេតុនោះទើបនឿយណាយចៀសចេញទៅ ។ សូម្បីក្នុងអនស្សាសិកព្រហ្មចរិយៈ ក្រោយក៏មានន័យនោះដូចគ្នា ។

បទថា **ឆិទ្ទិដ្ឋ បក្កមតិ** ធុញទ្រាន់ហើយចៀសចេញទៅ គឺសាស្តានោះ មិនអាចជាទីពឹងដល់ខ្លួនបាន នឹងអាចទីពឹងដល់អញបានដូចម្តេចហ្ន៎ ព្រោះហេតុនោះទើបធុញទ្រាន់ចៀសចេញទៅ ។ សូម្បីក្នុងអនស្សាសិកព្រហ្មចរិយៈក្រោយ ក៏មានន័យនេះដូចគ្នា ។

[ ៧២ ] បទថា **សង្កិការកំ កាមេ បរិភុញ្ជិតុំ** គឺជាគ្រហស្ថមកអំពីមុនធ្វើការសន្សំហើយ បរិភោគវត្ថុកាម ។ ឥឡូវនេះ មិនគួរធ្វើការសន្សំល្ង អង្ករ សប្បិ នវនីតជាដើមយ៉ាងនេះ ហើយបរិភោគឡើយ ។ ឯល្ង និងអង្ករជាដើម រមែងប្រាកដក្នុងឋានៈនៃព្រះខីណាស្រពមិនមែនឬ ព្រោះហេតុនោះ ទើបមិនប្រាកដដល់ពួកខ្ញុំ ។ តអំពីនោះ មិនបានតាំងទុកដើម្បីប្រយោជន៍ដល់ខ្លួនរបស់អ្នក តាំងទុកដើម្បីប្រយោជន៍ដល់អ្នកបួសដែលមានជំងឺជាដើម ។ ដើម្បីព្រះអនាគាមីដូចម្តេច ។ ព្រះអនាគាមី នោះលះកាមគុណ ៥ បានដោយប្រការទាំងពួង តែព្រះអនាគាមីពិចារណានូវវត្ថុដែលលោកបានដោយធម៌ស្មើហើយទើបបរិភោគ ។

[ ៧៤ ] បទថា **បុត្តមតាយ បុត្តា** សេចក្តីថា អាជីវកទាំងនោះឈ្មោះថាជាកូនរបស់ម្តាយដែលមានកូនស្លាប់ហើយ បានឮថា សន្ទកបរិព្វាជកនោះស្តាប់ធម៌នេះហើយ សម្គាល់ថា អាជីវកស្លាប់ហើយ ទើបពោលយ៉ាងនេះ ។ ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះ ។ អាជីវកទាំងឡាយឈ្មោះថាស្លាប់ហើយ មាតារបស់អាជីវកទាំងនោះ ឈ្មោះថាជាមាតាដែលមានបុត្រស្លាប់ហើយ ដោយប្រការដូច្នេះទើបអាជីវកទាំងឡាយជាបុគ្គលឈ្មោះ

ថា ជាបុត្ររបស់មាតាដែលមានបុត្រស្លាប់ហើយ ។ បទថា **សមណោ គោតមេ** លោកសម្តែងថា ការនៅប្រព្រឹត្តព្រហ្មចរិយៈមាននៅក្នុងព្រះសមណគោតម ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។ ៚

**អដ្ឋកថាសន្ទកសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## មហាសកុលុទាយិសូត្រទី ៧

[ ៧៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង មានពួកបរិព្វាជកជាច្រើន សុទ្ធតែមានកេរ្តិ៍ឈ្មោះល្បីល្បាញ នៅអាស្រ័យក្នុងបរិព្វាជការាម ជាមោរនិវាបស្ថាន ( កន្លែងសម្រាប់ឲ្យចំណីដល់ពួកសត្វក្ងោក ) បរិព្វាជកទាំងនោះគឺ អន្នភារៈបរិព្វាជក ១ វរតរ-បរិព្វាជក ១ សកុលុទាយិបរិព្វាជក ១ និងពួកបរិព្វាជកដទៃទៀត សុទ្ធតែមានកេរ្តិ៍ឈ្មោះល្បីល្បាញ ។ លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ក្នុងវេលាបុព្វណ្ហសម័យ ។ ទើបព្រះមានព្រះភាគទ្រង់បរិវិតក្កៈយ៉ាងនេះថា ការត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងរាជគ្រឹះព្រឹកណាស់នៅឡើយ បើដូច្នោះគួរតែតថាគតចូលទៅរកសកុលុទាយិបរិព្វាជក ឯបរិព្វាជការាម ជាមោរនិវាបស្ថានសិន ។ ហើយក៏ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរចូលសំដៅទៅឯបរិព្វាជការាម មោរ-និវាបស្ថាន ។

[ ៧៦ ] ក៏សម័យនោះឯង សកុលុទាយិបរិព្វាជក កំពុងអង្គុយជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើន ដែលគឹកកងមានសំឡេងហ៊ោ សំឡេងខ្លាំងកំពុងតែនិយាយនូវតិរច្ឆានកថាផ្សេងៗជាច្រើន គឺរាជកថា ចោរកថា មហា-មត្តកថា សេនាកថា ភយកថា យុទ្ធកថា អន្នកថា បានកថា វត្ថកថា សយ-

នកថា មាលាកថា គន្ធកថា ញាតិកថា យានកថា គាមកថា និគមកថា នគរកថា ជនបទកថា ឥត្ថីកថា សូរកថា វិសិខាកថា កុម្ភដ្ឋានកថា កុម្ភទាសីកថា បុព្វបេតកថា មានត្តកថា លោកក្ខាយិកកថា សមុទ្ទក្ខាយិកកថា ឥតិភវាភវកថា ដូច្នេះខ្លះ ដូច្នោះខ្លះ ។ សកុលុទាយិបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមានសំឡេងតិចៗ អ្នកដ៏ចម្រើនទាំងឡាយ កុំនិយាយខ្លាំងឡើយ នេះព្រះសមណគោតម កំពុងស្តេចមក ក៏លោកមានអាយុនោះ ត្រូវការតែនឹងសំឡេងតិចៗ សរសើរតែសំឡេងតិចៗទេ យើងត្រូវធ្វើដូចម្តេច ឲ្យព្រះសមណគោតមនោះជ្រាបថា បរិសទ្យមានសំឡេងតិចៗ ហើយនឹងសម្គាល់នូវដំណើរដែលគួរចូលមករក ។ គ្រានោះឯង ពួកបរិព្វាជកទាំងនោះ ក៏នាំគ្នាស្ងៀម ។ ទើបព្រះមានព្រះភាគ ស្តេចចូលសំដៅទៅត្រង់ទីដែលសកុលុទាយិបរិព្វាជកនៅ ។ លំដាប់នោះឯង សកុលុទាយិបរិព្វាជក បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចចូលមកចុះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគបានស្តេចមកស្រួលហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគខានស្តេចមកក្នុងទីនេះយូរណាស់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគស្តេចគង់ នេះជាអាសនៈបានក្រាលស្រេចហើយ ។ ព្រះមានព្រះភាគក៏គង់លើអាសនៈ ដែលបរិព្វាជកក្រាលថ្វាយ ។ ចំណែកខាងសកុលុទាយិបរិព្វាជក កាន់យកនូវអាសនៈទាប ១ អង្គុយក្នុងទីដ៏សមគួរ ។ លុះសកុលុទាយិបរិព្វា-

ជក អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ម្នាលឧទាយិ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី អម្បាញ់មិញនេះ ចុះសំដីជាចន្លោះដូចម្តេចដែលអ្នកទាំងឡាយឲ្យឈប់ដាច់បាត់ទៅ ។

[ ៧៧ ] បពិត្រព្រះអង្គដ៏ចម្រើន សំដីដែលយើងខ្ញុំ អង្គុយប្រជុំគ្នានិយាយអម្បាញ់មិញនុ៎ះ សូមលើកទុកសិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សំដីនុ៎ះ ព្រះមានព្រះភាគ គង់នឹងបានទ្រង់ព្រះសណ្តាប់ក្នុងកាលជាខាងក្រោយទេ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពីថ្ងៃមុនៗ ពួកសមណព្រាហ្មណ៍ មានលទ្ធិផ្សេងៗ មកប្រជុំគ្នាក្នុងកុតូហលសាលា សំដីជាចន្លោះនេះ ក៏កើតឡើងថា អើហ្ន៎ ជាលាភរបស់អ្នកស្រុកអង្គៈនិងអ្នកស្រុកមគធៈហើយតើ អើហ្ន៎ អ្នកស្រុកអង្គៈនិងអ្នកស្រុកមគធៈ បានស្រួលហើយតើ ព្រោះពួកសមណព្រាហ្មណ៍ទាំងនេះ មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកត្រឹមត្រូវបានចូលមកនៅចាំវស្សាក្នុងក្រុងរាជគ្រឹះនេះ ។ បូរណកស្សបៈនេះ មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថា ជាអ្នកត្រឹមត្រូវ ឥឡូវបូរណកស្សបៈនោះឯង ក៏បានចូលមកនៅចាំវស្សាក្នុងក្រុងរាជគ្រឹះដែរ ។ ឯគ្រូឈ្មោះមក្ខលិគោសាលនេះឯង...អជិតកេសកម្ពល...បកុទ្ធកច្ចាយនៈ...សញ្ជយវេលដ្ឋបុត្ត...និគន្ថនាដបុត្ត មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកត្រឹមត្រូវ និគន្ថនាដបុត្តនោះឯង ក៏បានចូលមក

នៅចាំវស្សាក្នុងក្រុងរាជគ្រឹះដែរ ។ ឯព្រះសមណគោតមនេះ មានពួកមានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាអ្នកត្រឹមត្រូវ ព្រះសមណគោតមអង្គនោះឯង ទ្រង់បានចូលមកចាំវស្សា ក្នុងក្រុងរាជគ្រឹះដែរ ។ បណ្តាពួកសមណព្រាហ្មណ៍ដ៏ចម្រើន ដែលមានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលពួកជនច្រើនសន្មតថាជាសប្បុរសទាំងអស់នេះ តើគ្រូណាដែលពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជា ទាំងពួកសាវកធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យនឹងគ្រូណា ។

[ ៧៨ ] បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា គ្រូឈ្មោះបូរណកស្សបៈនេះឯង មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលជនច្រើនសន្មតហើយថា ជាអ្នកត្រឹមត្រូវ ( ក៏ពិតមែនតែ ) បូរណកស្សបៈនោះឯងពួកសាវក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ ទាំងពួកសាវក មិនធ្វើសក្ការៈ គោរព នៅអាស្រ័យនឹងបូរណកស្សបៈឡើយ ។ ព្រោះធ្លាប់មានរឿងថា បូរណកស្សបៈ បានតែសម្តែងធម៌ដល់បរិសទ្យច្រើនរយ ។ បណ្តាសាវកទាំងនោះ មានសាវកម្នាក់របស់បូរណកស្សបៈបានស្រែកឡើងថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយកុំសួរសេចក្តីនោះ នឹងបូរណកស្សបៈឡើយ បូរណកស្សបៈនោះ មិនដឹងសេចក្តីនុ៎ះទេ ពួកយើងទើបដឹងសេចក្តីនុ៎ះ អ្នកទាំងឡាយសួរសេចក្តីនុ៎ះនឹងយើងហើយ ពួកយើងនឹង

ព្យាករសេចក្ដីនុ៎ះ ដល់ពួកអ្នកដ៏ចម្រើនបាន ។ ធ្លាប់មានរឿងថា បូរណកស្សប:ផ្គងនូវដើមដៃទាំងឡាយ កន្ទក់កន្ទេញហើយមិនបានពាក្យសំដីថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមានសំឡេងតិចៗ អ្នកដ៏ចម្រើនទាំងឡាយកុំស្រែកខ្លាំងឡើយ ពួកជនទាំងនុ៎ះ មិនសួរនូវអ្នកដ៏ចម្រើនទាំងឡាយទេ ពួកជនទាំងនោះ សួរតែយើងទេ យើងនឹងព្យាករដល់ពួកជនទាំងនោះបាន ។ ចំណែកពួកសាវកជាច្រើនលើកវាទ: ( ទោសព្រោះលទ្ធិ ) ដល់បូរណកស្សប: ហើយចៀសចេញទៅដោយពាក្យថា អ្នកមិនដឹងច្បាស់នូវធម្មវិន័យនេះទេ ខ្ញុំទើបដឹងច្បាស់នូវធម្មវិន័យនេះ អ្នកដឹងច្បាស់នូវធម្មវិន័យនេះដូចម្ដេចបាន បើអ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យខ្ញុំប្រកបដោយប្រយោជន៍ ពាក្យអ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកបែរជានិយាយមុន អ្នកឯងសន្សំតែវត្តខុសមកច្រើនហើយ ខ្ញុំលើកវាទ:ដល់អ្នកហើយ អ្នកត្រូវយើងសង្កត់សង្កិនហើយ អ្នកចូរទៅរក ដោះវាទ:ចេញ បើអ្នកឯងល្មមដោះខ្លួនឯងបាន ចូរដោះមកចុះ ។ ពួកសាវក មិនធ្វើសក្ការ: មិនគោរព មិនរាប់អាន មិនបូជាបូរណកស្សប: ទាំងពួកសាវក មិនធ្វើសក្ការ:គោរព នៅអាស្រ័យនឹងបូរណកស្សប:ទេ ដោយប្រការដូច្នេះឯង មួយទៀត បូរណកស្សប:ត្រូវគេជេរ ដោយពាក្យជេរ ប្រកបដោយធម៌ ។ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា មក្ខលិគោសាលនេះ ក៏ដែរ ... អជិតកេសកម្ពល ... បកុទ្ធកច្ចាយន: ... សញ្ជយវេលដ្ឋបុត្ត ... និគន្ថនាដបុត្ត

មានពួក មានគណៈ ជាគណាចារ្យ មានឈ្មោះល្បីល្បាញ មានយស ជាមេលទ្ធិ ដែលជនច្រើនសន្មតហើយថា ជាអ្នកត្រឹមត្រូវល្អ និគន្ថនាដបុត្តនោះ ក៏ពួកសាវក មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ ពួកសាវក មិនធ្វើសក្ការគោរព នៅអាស្រ័យនឹងនិគន្ថនាដបុត្តឡើយ ។ ធ្លាប់មានរឿងថា និគន្ថនាដបុត្ត បានសម្តែងធម៌ដល់បរិសទ្យច្រើនរយ ។ ក្នុងបរិសទ្យនោះ មានសាវកម្នាក់របស់និគន្ថនាដបុត្ត បានស្រែកឡើងថា អ្នកទាំងឡាយដ៏ចម្រើន កុំសួរនូវសេចក្តីនុ៎ះនឹងនិគន្ថនាដបុត្តឡើយ និគន្ថនាដបុត្តនោះ មិនចេះដឹងសេចក្តីនុ៎ះទេ យើងទើបដឹងសេចក្តីនុ៎ះ អ្នកទាំងឡាយ សួរសេចក្តីនុ៎ះនឹងយើងហើយ យើងនឹងព្យាករសេចក្តីនុ៎ះ ដល់អ្នកដ៏ចម្រើនទាំងឡាយបាន ។ ធ្លាប់មានរឿងថា និគន្ថនាដបុត្ត ផ្គងនូវដើមដៃទាំងឡាយ កន្ទក់កន្ទេញហើយមិនបាននូវពាក្យថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមានសំឡេងតិចៗ អ្នកដ៏ចម្រើនទាំងឡាយ កុំនិយាយខ្លាំងឡើយ ពួកជនទាំងនុ៎ះ មិនសួរនូវអ្នកដ៏ចម្រើនទាំងឡាយទេ ពួកជនទាំងនុ៎ះ សួរតែយើងទេតើ យើងនឹងព្យាករដល់ពួកជនទាំងនោះបាន ។ ចំណែកខាងពួកសាវកជាច្រើនរបស់និគន្ថនាដបុត្ត លើកឡើងនូវវាទៈហើយ ចៀសចេញទៅ ដោយពាក្យថា អ្នកមិនចេះ មិនដឹងធម៌វិន័យនេះទេ ខ្ញុំទើបចេះដឹងធម៌វិន័យនេះ អ្នកចេះដឹងធម៌វិន័យនេះ ដូចម្តេចកើត អ្នកប្រតិបត្តិខុសហើយ ខ្ញុំទើបប្រតិបត្តិត្រូវ សំដីខ្ញុំប្រកបដោយប្រយោជន៍ សំដីអ្នកមិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយ ពាក្យដែលគេនិយាយក្រោយ អ្នកបែរជានិយាយ

មុន អ្នកប្រកាន់តែវត្ថុខុសមកច្រើនហើយ ខ្ញុំលើកវាទៈដល់អ្នកហើយ អ្នកត្រូវយើងសង្កត់សង្កិនហើយ ចូរអ្នកទៅរកដោះវាទៈចុះ ឬថាបើអ្នកល្មមដោះរួច ចូរដោះមកចុះ ។ និគន្ថនាដបុត្ត ពួកសាវ័កមិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជាទេ ទាំងពួកសាវ័ក មិនធ្វើសក្ការៈគោរព ហើយនៅអាស្រ័យ នឹងនិគន្ថនាដបុត្តឡើយដោយប្រការដូច្នេះឯង មួយទៀត និគន្ថ-នាដបុត្តក៏ត្រូវ គេជេរដោយពាក្យជេរប្រកបដោយធម៌ ។

[ ៧៩ ] សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា ព្រះសមណ-គោតមនេះឯង ព្រះអង្គមានពួក មានគណៈ ជាគណាចារ្យ ព្រះអង្គមានកេរ្តិ៍ឈ្មោះល្បីល្បាញ ព្រះអង្គមានយស ព្រះអង្គជាមេលទ្ធិ ដែលពួកជនច្រើន សន្មតហើយថាជាសប្បុរស ក៏ព្រះសមណគោតមនោះឯង ពួកសាវ័កធ្វើសក្ការ គោរព រាប់អាន បូជា ទាំងពួកសាវ័ក ធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យនឹងព្រះសមណគោតមថែមទៀត ។ ព្រោះធ្លាប់ឮថា ព្រះសមណគោតម បានសម្តែងធម៌ដល់បរិសទ្យជាច្រើនរយ ។ ក្នុងបរិសទ្យនោះ មានសាវ័កម្នាក់ របស់ព្រះសមណគោតមក្អកហើយ ។ មានសព្រហ្មចារីបុគ្គលម្នាក់ យកជង្គង់ទង្គិចសាវ័កនោះថា លោកមានអាយុ ចូរមានសំឡេងតិចៗ លោកមានអាយុ កុំធ្វើឲ្យឮសូរឡើយ ព្រោះព្រះមានព្រះភាគ ជាសាស្តារបស់យើងទាំងឡាយកំពុងសម្តែងធម៌ ។ ព្រះសមណគោតមសម្តែងធម៌ដល់បរិសទ្យច្រើនរយ ក្នុងសម័យណា ក្នុងសម័យនោះ សំឡេងកណ្តាស់ក្តី សំឡេងក្អកក្តី នៃពួកសាវ័ក របស់ព្រះសមណគោតម ឥតមានដល់តិច

ទ្បើយ ពួកមហាជន មានសភាពនឹកប៉ង ប្រុងចាំស្តាប់ធម៌នោះថា ព្រះមានព្រះភាគនឹងសម្តែងធម៌ណា ដល់យើងទាំងឡាយ យើងទាំងឡាយនឹងស្តាប់នូវធម៌នោះ ។ ដូចជាបុរសប្របាច់ឃ្មុំទាំងបន្គន់ ដែលពួកឃ្មុំតូចៗ ធ្វើហើយជារបស់ឥតទោស ត្រង់ផ្លូវធំបែកជា ៤ ពពួកមហាជនមានសភាពនឹកប៉ងប្រុងយកទឹកឃ្មុំនោះ មានឧបមាយ៉ាងណាមិញ ព្រះសមណគោតម សម្តែងធម៌ដល់បរិសទ្យច្រើនរយ ក្នុងសម័យណា សម័យនោះ សំឡេងកណ្តាស់ក្តីសំឡេងក្អកក្តី នៃពួកសាវករបស់ព្រះសមណគោតម ឥតមានដល់តិចទ្បើយពពួកមហាជន មានសភាពនឹកប៉ង ប្រុងចាំស្តាប់ធម៌នោះថា ព្រះមានព្រះភាគនឹងសម្តែងធម៌ណា ដល់ពួកយើង ពួកយើងនឹងស្តាប់ធម៌នោះ ។ ចំណែកពួកសាវកណា របស់ព្រះសមណគោតម ទាស់ទែងបន្តិចបន្តួចនឹងពួកស-ព្រហ្មចារីហើយ ពោលលាសិក្ខា វិលត្រឡប់ទៅរកភេទថោកទាប សាវកទាំងនោះ នៅតែសរសើរគុណព្រះសាស្តាផង សរសើរគុណព្រះធម៌ផងសរសើរគុណព្រះសង្ឃផង ជាអ្នកតិះដៀលចំពោះតែខ្លួនឯង មិនតិះដៀលគេថា យើងទាំងឡាយជាអ្នកឥតភ័ព្វ យើងទាំងឡាយជាអ្នកឥតបុណ្យ ព្រោះថា ពួកយើងបានបួសក្នុងធម្មវិន័យ ដែលព្រះមានព្រះភាគសម្តែងហើយដោយប្រពៃយ៉ាងនេះ ហើយមិនអាចនឹងប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិសុទ្ធបរិបូណ៌ ដរាបដល់អស់ជីវិតបាន ។ ពួកសាវកទាំងនោះ គង់ទៅជាអ្នកថែរក្សាវត្ត ឬជាឧបាសកប្រព្រឹត្តសមាទានក្នុងសិក្ខាបទ ៥ ។ ព្រះសមណគោតមពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាទាំងពួកសាវក

ធ្វើសក្ការៈគោរព ហើយនៅអាស្រ័យនឹងព្រះសមណគោតមថែមទៀត ដោយប្រការដូច្នេះឯង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧទាយិ ចុះអ្នកពិចារណាឃើញនូវធម៌ក្នុងតថាគតប៉ុន្មានយ៉ាង ដែលជាធម៌នាំឲ្យពួកសាវ័ករបស់តថាគតធ្វើសក្ការៈ គោរព រាប់អាន បូជា ( តថាគត ) លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ ( នឹងតថាគត ) ។

[ ៨០ ] សកុលុទាយិបរិព្វាជក ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញធម៌ ក្នុងព្រះមានព្រះភាគមាន ៥ ប្រការ ដែលជាធម៌នាំឲ្យពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជានូវព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ធម៌ ៥ ប្រការតើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីពិតថា ព្រះមានព្រះភាគ មានអាហារតិចផង សរសើរបែបភាពនៃបុគ្គលអ្នកមានអាហារតិចផង បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ការណ៍ដែលព្រះមានព្រះភាគ ព្រះអង្គមានអាហារតិចផង សរសើរបែបភាពនៃបុគ្គលអ្នកមានអាហារតិចផងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ថាជាធម៌ទី ១ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវ័កធ្វើសក្ការៈ គោរព រាប់អាន បូជានូវព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។

[ ៨១ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយ

ចីវរតាមមានតាមបានផង បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ការណ៍ដែលព្រះមានព្រះភាគ ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយចីវរតាមមានតាមបានផងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់នូវធម៌នេះឯង ថាជាធម៌ទី ២ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគលុះធ្វើសក្ការៈគោរពហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។

[ ៨២ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀតព្រះមានព្រះភាគ ទ្រង់សន្តោសដោយចង្ហាន់បិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយចង្ហាន់បិណ្ឌបាត តាមមានតាមបានផង បពិត្រព្រះអង្គដ៏ចម្រើនត្រង់ការណ៍ដែលព្រះមានព្រះភាគ ទ្រង់សន្តោសដោយចង្ហាន់ បិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយចង្ហាន់បិណ្ឌបាត តាមមានតាមបានផងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់នូវធម៌នេះឯង ថាជាធម៌ទី ៣ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈគោរពហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។

[ ៨៣ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ ទ្រង់សន្តោសដោយសេនាសនៈ តាមមានតាមបានផង សរសើរ សេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបានផង បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ការណ៍ដែលព្រះមានព្រះភាគ ទ្រង់សន្តោសដោយសេនាសនៈ តាមមានតាមបាន

ផង សរសើរសេចក្ដីសន្ដោស ដោយសេទាសទះ តាមមានតាមបានផងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់ នូវធម៌នេះឯង ថា ជាធម៌ទី ៤ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។

[ ៨៤ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះមានព្រះភាគ ទ្រង់ស្ងប់ស្ងាត់ សរសើរសេចក្ដីស្ងប់ស្ងាត់ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ការណ៍ ដែលព្រះមានព្រះភាគ ទ្រង់ស្ងប់ស្ងាត់ផង សរសើរសេចក្ដីស្ងប់ស្ងាត់ផងណា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញច្បាស់នូវធម៌នេះឯង ថា ជាធម៌ទី ៥ ក្នុងព្រះមានព្រះភាគ ដែលនាំឲ្យពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាព្រះមានព្រះភាគ លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណា ឃើញច្បាស់នូវធម៌ទាំង ៥ នេះឯង ក្នុងព្រះមានព្រះភាគ ដែលជាធម៌នាំឲ្យ ពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជានូវព្រះមានព្រះភាគ លុះធ្វើ សក្ការៈ គោរពរួចហើយនៅអាស្រ័យ ( នឹងព្រះមានព្រះភាគ ) ។

[ ៨៥ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧទាយិ បើពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ព្រះអង្គ មានអាហារតិចផង សរសើរបែបភាពរបស់បុគ្គលអ្នកមានអាហារតិចផង

សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត មានអាហារត្រឹមមួយកូនផ្តិលខ្លះ មានអាហារកន្លះកូនផ្តិលខ្លះ មានអាហារមួយសម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ ក៏មានដែរ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណាបរិភោគអាហារពេញស្មើដោយបាត្រនេះក៏មាន បរិភោគអាហារច្រើនជាងនោះទៅក៏មាន ។ ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរព ហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថាព្រះសមណគោតម ព្រះអង្គមានអាហារតិចផង សរសើរបែបភាពរបស់បុគ្គលអ្នកមានអាហារតិចផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័កណារបស់តថាគត ដែលមានអាហារត្រឹមមួយកូនផ្តិលខ្លះ មានអាហារកន្លះកូនផ្តិលខ្លះ មានអាហារមួយសម្បកផ្លែព្នៅខ្លះ មានអាហារកន្លះសម្បកផ្លែព្នៅខ្លះ ពួកសាវ័កទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគត ដោយធម៌នេះទេ លុះ ( មិន ) ធ្វើសក្ការៈ គោរពហើយ នឹងមិននៅអាស្រ័យ ( នឹងតថាគត ) ឡើយ ។

[ ៨៦ ] ម្នាលឧទាយិ បើពួកសាវ័ក ធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយចីវរតាមមានតាមបានផង សរសើរសេចក្តីសន្តោស ដោយចីវរតាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវ័ករបស់តថាគត ប្រើប្រាស់ត្រឹមសំពត់បង្សុកូល ទ្រទ្រង់ចីវរសៅហ្មង ក៏មានដែរ ពួកគេរើសនូវកំណាត់

សំពត់ទាំងឡាយ អំពីព្រៃស្មសានខ្លះ អំពីគំនរសំរាមខ្លះ អំពីរានផ្សារខ្លះ ធ្វើជាសង្ឃាដិ ហើយប្រើប្រាស់ក៏មាន ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណាប្រើប្រាស់គហបតីចីវរទាំងឡាយដ៏ជាប់ សៅហ្មងដោយកាំបិត មានរោមល្អិតដូចរោមឃ្លោក ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយចីវរតាមមានតាមបាន ផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវកណា របស់តថាគត ដែលប្រើប្រាស់ត្រឹមតែសំពត់បង្សុកូល ទ្រទ្រង់នូវចីវរសៅហ្មង ពួកគេរើស នូវកំណាត់សំពត់ អំពីព្រៃស្មសានខ្លះ អំពីគំនរសំរាមខ្លះ អំពីរានផ្សារខ្លះ មកធ្វើជាសង្ឃាដិប្រើប្រាស់ ពួកសាវកទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយធម៌នេះទេ លុះមិនធ្វើសក្ការៈ គោរពហើយ នឹង មិននៅអាស្រ័យ ( នឹងតថាគត ) ឡើយ ។

[ ៨៧ ] ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយចង្ហាន់បិណ្ឌបាតតាម មានតាមបានផង ទ្រង់សរសើរសេចក្ដីសន្តោស ដោយចង្ហាន់បិណ្ឌបាតតាម មានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់ តថាគត ប្រព្រឹត្តតែបិណ្ឌបាត ត្រាច់ទៅតាមលំដាប់ច្រក ត្រេកអរហើយក្នុង វត្ត គឺការឈរតាមទ្វារផ្ទះត្រកូលខ្ពស់និងទាប ក៏មានដែរ សាវកទាំងនោះ

រមែងចូលទៅកាន់ចន្លោះនៃផ្ទះ បើទុកជាគេនិមន្តដោយអាសនៈក៏មិនត្រេកអរ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណាឆាន់បាយស្រូវសាលីទាំងឡាយ ប្រាសចាកពណ៌ខ្មៅ មានសម្លច្រើនមុខ មានម្ហូបច្រើនមុខក្នុងទីដែលគេនិមន្ត ក៏មាន ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយបិណ្ឌបាត តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយបិណ្ឌបាតតាមមានតាមបានផង សមតាមពាក្យ អ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់តថាគត ប្រព្រឹត្តបិណ្ឌបាត ត្រាច់ ទៅតាមលំដាប់ច្រក ត្រេកអរហើយក្នុងវត្ត គឺការឈរតាមទ្វារផ្ទះត្រកូលខ្ពស់ និងទាប សាវកទាំងនោះ រមែងចូលទៅកាន់ចន្លោះផ្ទះ បើទុកជាគេនិមន្តដោយ អាសនៈក៏មិនត្រេកអរ សាវកទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយធម៌នេះទេ លុះមិនធ្វើសក្ការៈ គោរពហើយ នឹងមិននៅអាស្រ័យ ( នឹងតថាគត ) ឡើយ ។

[ ៨៨ ] ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជា តថាគត លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយសេនាសនៈ តាមមាន តាមបានផង សរសើរសេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបាន ផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់តថាគត នៅ ត្រឹមក្បែរគល់ឈើបាន នៅក្នុងទីវាលស្មោះក៏សឹងបាន សាវកទាំងនោះ

មិនចូលទៅជ្រកក្រោមដំបូលអស់ ៨ ខែឡើយ ម្នាលឧទាយិ ចំណែកតថាគតវិញ ជួនណានៅក្នុងផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូល មានទ្វារជិតស្និទ្ធ មានបង្អួចបិទបាំងហើយ ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ទ្រង់សន្តោសដោយសេនាសនៈ តាមមានតាមបានផង សរសើរសេចក្តីសន្តោសដោយសេនាសនៈ តាមមានតាមបានផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវកណា របស់តថាគត ដែលនៅត្រឹមក្បែរគល់ឈើ នៅក្នុងទីវាលស្មោះ សាវកទាំងនោះ មិនចូលទៅនៅជ្រកក្រោមដំបូលអស់ ៨ ខែបាន ពួកសាវកនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត ដោយធម៌នេះទេ លុះមិនធ្វើសក្ការៈគោរពហើយ នឹងមិននៅអាស្រ័យ ( នឹងតថាគត ) ឡើយ ។

[ ៨៩ ] ម្នាលឧទាយិ បើពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈគោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ព្រះអង្គស្ងប់ស្ងាត់ផង សរសើរសេចក្តីស្ងប់ស្ងាត់ផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវករបស់តថាគតនៅក្នុងព្រៃ ចូលទៅកាន់ព្រៃតូច នឹងព្រៃធំ ជាសេនាសនៈដ៏ស្ងាត់ ហើយសម្រេចសម្រាន្តនៅ សាវកទាំងនោះ មកប្រជុំគ្នាក្នុងកណ្តាលសង្ឃ ដើម្បីសម្តែងបាតិមោក្ខរាល់ៗ កន្លះខែ ម្នាលឧទាយិ ចំណែកតថាគតវិញ

ជូនណាទៅប្រប្ញូកប្របល់ដោយពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច រាជមហាមាត្យ តិរ្ថិយ និងពួកសាវកនៃតិរ្ថិយ ម្នាលឧទាយិ បើពួកសាវក ធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ ( នឹងតថាគត ) ដោយគិតថា ព្រះសមណគោតម ព្រះអង្គ ស្ងប់ស្ងាត់ហើយផង សរសើរសេចក្ដីស្ងប់ស្ងាត់ផង សមតាមពាក្យអ្នកថាមែន ម្នាលឧទាយិ ពួកសាវកណា របស់តថាគតដែលនៅក្នុងព្រៃ ចូលទៅកាន់ ព្រៃតូច និងព្រៃធំ ជាសេនាសនៈស្ងាត់ហើយ សម្រេចសម្រាន្តនៅ សាវក ទាំងនោះ ប្រជុំគ្នាក្នុង កណ្ដាលសង្ឃ ដើម្បីសម្ដែងបាតិមោក្ខរាល់ៗ កន្លះខែ សាវកទាំងនោះ សមជាមិនធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគតដោយ ធម៌នេះទេ លុះមិនធ្វើសក្ការៈគោរពហើយ នឹងមិននៅអាស្រ័យ ( នឹង តថាគត ) ឡើយ ។ ម្នាលឧទាយិ ពួកសាវកធ្វើសក្ការៈ គោរព រាប់អាន បូជាតថាគត លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) មិនមែនដោយសារធម៌ ទាំង ៥ ប្រការនេះដូចពាក្យអ្នកថានោះទេ ។

[ ៩០ ] ម្នាលឧទាយិ ធម៌ ៥ ដោយឡែកទេ ដែលជាធម៌នាំឲ្យពួក សាវករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ធម៌ទាំង ៥ តើដូចម្ដេចខ្លះ ម្នាលឧទាយិ ពួកសាវករបស់តថាគត ក្នុងសាសនានេះ សរសើរចំពោះ អធិសីលថា ព្រះសមណគោតម ព្រះអង្គមានសីល ព្រះអង្គប្រកបព្រម ហើយដោយសីលក្ខន្ធដ៏ប្រសើរបំផុត ។ ម្នាលឧទាយិ ត្រង់ការណ៍ដែលពួក

សាវ័ក របស់តថាគត សរសើរចំពោះអធិសីលថា ព្រះសមណគោតម ព្រះអង្គមានសីល ព្រះអង្គប្រកបព្រមហើយដោយសីលក្ខន្ធដ៏ប្រសើរបំផុតណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ១ ដែលនាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យ ( នឹងតថាគត ) ។

[ ៩១ ] ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត សរសើរចំពោះញាណទស្សនៈដ៏រុងរឿងថា ព្រះសមណគោតម កាលបើដឹងទើបនិយាយថា តថាគតដឹង ព្រះសមណគោតម កាលបើឃើញ ទើបនិយាយថា តថាគតឃើញ ព្រះសមណគោតម តែងសម្តែងធម៌ដើម្បីឲ្យត្រាស់ដឹង មិនសម្តែងដើម្បីមិនឲ្យត្រាស់ដឹងទេ ព្រះសមណគោតម តែងសម្តែងធម៌ប្រកបដោយហេតុ មិនមែនធម៌ឥតហេតុទេ ព្រះសមណគោតម តែងសម្តែងធម៌ប្រកបដោយបាដិហារ្យ មិនមែនសម្តែងធម៌ឥតបាដិហារ្យទេ ។ ម្នាលឧទាយិ ត្រង់ការណ៍ដែលពួកសាវ័ករបស់តថាគត សរសើរចំពោះញាណទស្សនៈដ៏រុងរឿងថា ព្រះសមណគោតម កាលបើដឹង ទើបនិយាយថា តថាគតដឹង ព្រះសមណគោតម កាលបើឃើញ ទើបនិយាយថា តថាគតឃើញ ព្រះសមណគោតម តែងសម្តែងធម៌ដើម្បីសេចក្តីត្រាស់ដឹង មិនមែនសម្តែងធម៌ដើម្បីសេចក្តីមិនត្រាស់ដឹងទេ ព្រះសមណគោតម តែងសម្តែងធម៌ប្រកបដោយហេតុ មិនមែនសម្តែងធម៌ឥតហេតុទេ ព្រះសមណគោតម តែងសម្តែងធម៌ប្រកបដោយបាដិហារ្យ មិនមែនសម្តែងធម៌ឥតបាដិហារ្យទេ ណា ។ ម្នាល

ឧទាយិ នេះឯងជាធម៌ទី ២ ដែលនាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការគោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ។

[ ៩២ ] ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត សរសើរចំពោះអធិប្បញ្ញាថា ព្រះសមណគោតម ព្រះអង្គមានប្រាជ្ញា ទ្រង់ប្រកបហើយដោយបញ្ញាខន្ធដ៏ប្រសើរបំផុត ឯពាក្យថា ព្រះសមណគោតម មិនឃើញនូវគន្លងនៃវាទៈនោះដែលមិនទាន់មានមក ឬថាព្រះសមណគោតម មិនមែនសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាការសង្កត់សង្កិនដោយល្អ ប្រកបដោយហេតុបានទេ ដូច្នេះនុ៎ះ មិនមានសោះឡើយ ។ ម្នាលឧទាយិ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ចុះពួកសាវ័ករបស់តថាគត កាលដឹងយ៉ាងនេះ កាលឃើញយ៉ាងនេះហើយ និយាយបង្អាក់ ( តថាគត ) ក្នុងពាក្យជាចន្លោះៗ ដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ការនុ៎ះមិនមានសោះឡើយ ។ ម្នាលឧទាយិ មួយទៀតតថាគតមិនដែលទឹកឲ្យពួកសាវ័ក ជួយប្រៀនប្រដៅសោះឡើយ តែពួកសាវ័កតែងទឹកប៉ង ឲ្យតថាគតប្រៀនប្រដៅដោយពិត ។ ម្នាលឧទាយិ ត្រង់ការណ៍ដែលពួកសាវ័ករបស់តថាគត សរសើរចំពោះអធិប្បញ្ញាថា ព្រះសមណគោតម ព្រះអង្គមានប្រាជ្ញា ទ្រង់ប្រកបព្រមហើយដោយបញ្ញាខន្ធ ដ៏ប្រសើរបំផុត ឯពាក្យថាព្រះសមណ-គោតម មិនឃើញនូវគន្លងនៃវាទៈនោះ ដែលមិនទាន់មានមក ឬថាព្រះសមណគោតម មិនមែនសង្កត់សង្កិននូវបរប្បវាទ ដែលកើតឡើងហើយឲ្យ

ជាការសន្តិតសន្តិនដោយល្អ ប្រកបដោយហេតុ ដូច្នេះនុ៎ះ មិនមានសោះទេ ណា ម្នាលឧទាយិ នេះឯងជាធម៌ទី ៣ ដែលនាំឲ្យពួកសាវ័ករបស់តថាគត តែងធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការគោរពហើយនៅ អាស្រ័យ ( នឹងតថាគត ) ។

[ ៩៣ ] ម្នាលឧទាយិ មួយទៀត ពួកសាវ័ករបស់តថាគត មានទុក្ខ បៀតបៀនហើយ មានទុក្ខគ្របសង្កត់ហើយ ព្រោះសេចក្តីទុក្ខណា ពួកសាវ័ក ទាំងនោះ ចូលមករកតថាគត ហើយសួរនូវទុក្ខអរិយសច្ច លុះសួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខអរិយសច្ច ដល់ពួកសាវ័កទាំងនោះ តថាគតធ្វើ ចិត្តរបស់សាវ័កទាំងនោះឲ្យត្រេកអរដោយការដោះស្រាយនូវប្រស្នាបាន ពួក សាវ័កទាំងនោះ ចូលមករកតថាគតសួរនូវទុក្ខសមុទយៈ... ទុក្ខនិរោធ... សួរ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច លុះសួរហើយ តថាគតក៏ដោះ ស្រាយនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដល់ពួកសាវ័កទាំងនោះ តថាគត ធ្វើចិត្តរបស់ពួកសាវ័កទាំងនោះឲ្យត្រេកអរបាន ដោយការដោះស្រាយនូវ ប្រស្នា ។ ម្នាលឧទាយិ ត្រង់ការណ៍ដែលពួកសាវ័ករបស់តថាគតមានទុក្ខ បៀតបៀនហើយ មានទុក្ខគ្របសង្កត់ហើយ ព្រោះសេចក្តីទុក្ខណា ពួក សាវ័កទាំងនោះ តែងចូលមករកតថាគតហើយ សួរនូវទុក្ខអរិយសច្ច លុះ សួរហើយ តថាគតក៏ដោះស្រាយ នូវទុក្ខអរិយសច្ចដល់ពួកសាវ័កទាំងនោះ តថាគតធ្វើចិត្តរបស់ពួកសាវ័កទាំងនោះ ឲ្យត្រេកអរបានដោយការដោះស្រាយ នូវប្រស្នា ពួកសាវ័កទាំងនោះចូលមករកតថាគតហើយ សួរនូវទុក្ខសមុ-

ទយៈ... ទុក្ខនិរោធ ... សួរនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច លុះសួរហើយ តថាគតក៏ដោះស្រាយនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចដល់ពួកសាវកទាំងនោះ តថាគតធ្វើចិត្តរបស់សាវកទាំងនោះឲ្យត្រេកអរបាន ដោយការដោះស្រាយនូវប្រស្នា ណា ។ ម្នាលឧទាយិ នេះឯងជាធម៌ទី ៤ ដែលនាំឲ្យពួកសាវករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយនៅអាស្រ័យ ( នឹងតថាគត ) ។

[ ៩៤ ] ម្នាលឧទាយិ មួយវិញទៀត តថាគតបានសម្តែងបដិបទាដល់ពួកសាវក ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយចម្រើននូវសតិប្បដ្ឋានទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាស្មារតីកម្ចាត់បង់នូវអភិជ្ឈានិងទោសមនស្សក្នុងលោក ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី... ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី ... ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោ-មនស្សក្នុងលោក សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ក៏ពួកសាវករបស់តថាគតជាច្រើន បានដល់ហើយនូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងសតិប្បដ្ឋានធម៌នេះ ។

[ ៩៥ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់ពួកសាវក ដែលជាហេតុឲ្យពួកសាវករបស់តថាគតប្រតិបត្តិ ហើយចម្រើននូវ

សម្មប្បធានទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ញុំាង សេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បីញុំាង ពួកធម៌ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងសេចក្តីប្រាថ្នាឲ្យកើត ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បី លះបង់នូវពួកធម៌ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ញុំាងសេចក្តី ប្រាថ្នាឲ្យកើត ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បីញុំាងពួកធម៌ ជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ញុំាងសេចក្តីប្រាថ្នាឲ្យ កើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងតម្កល់ចិត្ត ដើម្បីញុំាងពួកធម៌ ជា កុសលដែលកើតឡើងហើយឲ្យតាំងនៅបាន ដើម្បីមិនឲ្យវង្វេងភ្លេច ឲ្យជា ភិយ្យោភាព ជំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ឯពួកសាវករបស់ តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងសម្មប្ប- ធានធម៌ទាំងនោះ ។

[ ៩៦ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់ សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវក របស់តថាគតប្រតិបត្តិហើយ ចម្រើនឥទ្ធិបាទទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចម្រើន នូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទ ប្រកប ដោយវីរិយសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្ត សមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទប្រកបដោយវីមំសាសមាធិ និង បធានសង្ខារ ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមី

ញាណជាទីបំផុតនៃអភិញ្ញា ក្នុងឥទ្ធិបាទធម៌ទាំងនោះ ។

[ ៩៧ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់ពួកសាវក ដែលជាហេតុឲ្យពួកសាវករបស់តថាគតប្រតិបត្តិ ហើយចម្រើននូវឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសទ្ធិន្ទ្រិយ ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ចម្រើននូវវីរិយិន្ទ្រិយ ... ចម្រើននូវសតិន្ទ្រិយ ... ចម្រើននូវសមាធិន្ទ្រិយ ... ចម្រើននូវបញ្ញិន្ទ្រិយជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងឥន្ទ្រិយទាំង ៥ នោះ ។

[ ៩៨ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទា ដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតប្រតិបត្តិហើយចម្រើននូវពលធម៌ទាំង ៥ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះចម្រើននូវសទ្ធាពល ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ចម្រើនវីរិយពលៈ ... ចម្រើននូវសតិពលៈ ... ចម្រើននូវសមាធិពលៈ ... ចម្រើននូវបញ្ញាពលៈ ... ជាដំណើរទៅកាន់សេចក្តីស្ងប់រម្ងាប់ ជាដំណើរទៅកាន់សេចក្តីត្រាស់ដឹង ។ ឯពួកសាវករបស់តថាគត ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងពលធម៌ទាំង ៥ ប្រការនោះ ។

[ ៩៩ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគត ប្រតិបត្តិហើយ

ចម្រើននូវសម្ពោជ្ឈង្គធម៌ ៧ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គៈ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមទៅកាន់សេចក្តីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គៈ ។បេ។ ចម្រើននូវវីរិយសម្ពោជ្ឈង្គៈ ... ចម្រើននូវបីតិសម្ពោជ្ឈង្គៈ ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គៈ ... ចម្រើននូវសមាធិសម្ពោជ្ឈង្គៈ ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គៈ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមទៅកាន់សេចក្តីលះបង់ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងសម្ពោជ្ឈង្គធម៌ទាំង ៧ នោះ ។

[ ១០០ ] ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទា ដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតប្រតិបត្តិហើយ ចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសម្មាទិដ្ឋិ ចម្រើននូវសម្មាសង្កប្បៈ ចម្រើននូវសម្មាវាចា ចម្រើននូវសម្មាកម្មន្តៈ ចម្រើននូវសម្មាអាជីវៈ ចម្រើននូវសម្មាវាយាមៈ ចម្រើននូវសម្មាសតិ ចម្រើននូវសម្មាសមាធិ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញា ក្នុងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនោះ ។

[ ១០១ ] ម្នាលឧទាយិ មួយទៀត តថាគតបានសំដែងបដិបទាដល់

សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិ ហើយចម្រើននូវវិមោក្ខទាំងឡាយ ៨ ប្រការ ។ ( វិមោក្ខទាំង ៨ ប្រការគឺ ) បុគ្គលបាននូវរូបជ្ឈាន ឃើញនូវរូបទាំងឡាយ ( មាននីលកសិណជាដើម ) នេះជាវិមោក្ខទី ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់នូវរូបជ្ឈានខាងក្នុង ឃើញរូបទាំងឡាយខាងក្រៅ ( មាននីលកសិណជាដើម ) នេះជាវិមោក្ខជាទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈាន ក្នុងវណ្ណកសិណដ៏បរិសុទ្ធិ នេះជាវិមោក្ខទី ៣ ។ ភិក្ខុព្រោះកន្លងនូវពួករូបសញ្ញាដោយប្រការទាំងពួង ព្រោះរម្ងាប់នូវពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ក៏ចូលដល់អាកាសានញ្ចាយតនៈ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ នេះជាវិមោក្ខទី ៤ ។ ភិក្ខុព្រោះកន្លងអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង ក៏ចូលទៅដល់វិញ្ញាណញ្ចាយតនៈដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត នេះជាវិមោក្ខជាទី ៥ ។ ភិក្ខុព្រោះកន្លងវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង ក៏ចូលដល់អាកិញ្ចញ្ញាយតនៈដោយបរិកម្មថា វត្ថុតិចតួចមិនមាន នេះជាវិមោក្ខទី ៦ ។ ភិក្ខុព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង ក៏ចូលដល់នេវសញ្ញានាសញ្ញាយតនៈ នេះជាវិមោក្ខទី ៧ ។ ភិក្ខុព្រោះកន្លងនេវសញ្ញានាសញ្ញាយតនៈដោយប្រការទាំងពួង ក៏ចូលដល់សញ្ញាវេទយិតនិរោធ នេះជាវិមោក្ខទី ៨ ។ ឯសាវ័កទាំងឡាយរបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងវិមោក្ខទាំង ៨ នោះ ។

[ ១០២ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់

សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ក របស់តថាគតបានប្រតិបត្តិ ហើយចម្រើននូវអភិភាយតនៈ ៨ ប្រការ ។ អភិភាយតនៈ ៨ ប្រការ គឺបុគ្គលពួកខ្លះ មានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបបន្តិចបន្តួច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកខ្លះ មានសេចក្ដីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបធំប្រមាណមិនបាន មានពណ៌ល្អឬពណ៌អាក្រក់ គ្របសង្កត់រូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកខ្លះ មិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង ឃើញរូបខាងក្រៅដែលជារូប តិចតួច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកខ្លះ មិនមានសេចក្ដីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបធំប្រមាណមិនបាន ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកខ្លះ មិនមានសេចក្ដីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបខៀវ មានពណ៌ខៀវជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ខៀវ មានពន្លឺខៀវ ។ ដូចជាផ្កា ត្រកៀត ជាបុប្ផជាតិខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា ផ្កានេះមាន ពណ៌ខៀវ មានពន្លឺខៀវ ពុំនោះ

សោតដូចសំពត់កើតក្នុងក្រុងពារាណសីនោះ រលីងរលើបទាំងពីរខាង ជាសំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា សំពត់នេះមានពណ៌ខៀវ មានពន្លឺខៀវ សេចក្តីទាំងនេះមានឧបមាយ៉ាងណាមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកខ្លះមិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា រូបនេះមានពណ៌លឿង មានពន្លឺលឿង ។ ដូចផ្កាកណ្ណិការ ជាបុប្ផជាតិលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា ផ្កានេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោតដូចសំពត់កើតក្នុងក្រុងពារាណសីនោះ រលីងរលើបទាំងពីរខាង ជាសំពត់លឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា សំពត់នេះមានពណ៌លឿង មានពន្លឺលឿង សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបលឿង មានពណ៌លឿង ជាទីចង្អុលបង្ហាញថា រូបនេះមាន ពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តី សម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកខ្លះ មិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបក្រហម មានពណ៌

ក្រហម ជាទីចន្លុលបន្លាញថា រូបនេះមានពណ៌ក្រហម មានពន្លឺក្រហម ។ ដូចជាផ្កាចប្បារ ជាផ្កាក្រហមមាន ពណ៌ក្រហម ជាទីចន្លុលបន្លាញថា ផ្កានេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោតដូចសំពត់កើតក្នុងក្រុងពារាណសីនោះ មានសាច់រលីងរលើបទាំងពីរខាង ជាសំពត់ក្រហម មានពណ៌ក្រហម ជាទីចន្លុលបន្លាញថា សំពត់នេះមានពណ៌ក្រហម មានពន្លឺក្រហម សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះមិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបក្រហម មានពណ៌ក្រហម ជាទីចន្លុលបន្លាញថា រូបនេះមានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ មានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកខ្លះមិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ជារូបស មានពណ៌ស ជាទីចន្លុលបន្លាញថា រូបនេះមានពណ៌ស មានពន្លឺស ។ ដូចជាផ្កាយព្រឹក ជាផ្កាយស មានពណ៌ស ជាទីចន្លុលបន្លាញថា ផ្កាយនេះមានពណ៌ស មានពន្លឺស ពុំនោះសោត ដូចសំពត់កើតក្នុងក្រុងពារាណសីនោះ មានសាច់រលីងរលើបទាំងពីរខាង ជាសំពត់ស មានពណ៌ស ជាទីចន្លុលបន្លាញថា សំពត់នេះមានពណ៌ស មានពន្លឺស សេចក្តីនេះមានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចបុគ្គលពួកខ្លះ មិនមានសេចក្តីសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដែលជារូបស មានពណ៌ស ជាទីចន្លុលបន្លាញថា រូបនេះមានពណ៌ស មានពន្លឺស គ្របសង្កត់ នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះ

ថា អាត្មាអញដឹង អាត្មាអញឃើញ នេះជាអភិភាយតនៈទី ៨ ។ ឯសាវ័ក របស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញា ក្នុងអភិភាយតនៈទាំងនោះ ។

[ ១០៣ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិហើយ ចម្រើននូវកសិណាយតនៈ ១០ ប្រការ ។ ( កសិណាយតនៈទាំង ១០ នោះគឺ ) បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវបឋវីកសិណខាងលើ ខាងក្រោម នឹងទទឹង ជាកសិណតែបែបមួយ ឥតមានលាយឡំ ( នឹងកសិណឯទៀត ) មានប្រមាណមិនបាន ១ បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវអាបោកសិណ។បេ។ បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវតេជោកសិណ ... បុគ្គលពួកខ្លះស្គាល់ច្បាស់នូវវាយោកសិណ ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវនីលកសិណ ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវបីតកសិណ...បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវ លោហិតកសិណ ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវឱទាតកសិណ ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវអាកាសកសិណ ... បុគ្គលពួកខ្លះ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ខាងលើ ខាងក្រោម និងទទឹង ជាកសិណតែបែបមួយ ឥតមានលាយឡំ ( នឹងកសិណឯទៀត ) ប្រមាណមិនបាន ១ ។ ឯសាវ័កទាំងឡាយរបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុត នៃអភិញ្ញាក្នុងកសិណាយតនៈទាំង ១០ នោះ ។

[ ១០៤ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទា ដល់

សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិ ហើយចម្រើននូវឈានទាំង ៤ ប្រការ ។ ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកធម៌ទាំងឡាយជាអកុសល បានចូលបឋមជ្ឈានប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ភិក្ខុនោះញ៉ាំងកាយនេះឯង ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ។ ម្នាលឧទាយិ ដូចជាងកាត់សក់ក្តី កូនសិស្សរបស់នាយជាងកាត់សក់ក្តី ដែលឈ្លាសវៃ ដាក់លម្អិតសម្រាប់ងូតទៅក្នុងលោហភាជន៍ ហើយយកទឹកប្រោះព្រំ ប្របាច់ពូតឲ្យជាដុំ ឯដុំលម្អិតសម្រាប់ងូតនោះ ជ្រួតជ្រាបស្អិតដោយទឹក ជោកជាំស្អិតដោយទឹក សើមស្អិតដោយទឹក ទាំងខាងក្នុង និងខាងក្រៅ ទាំងមិនហូរចេញអំពីគ្នាផង សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលឧទាយិ ភិក្ខុញ៉ាំងកាយឲ្យជ្រួតជ្រាប ជោកជាំបរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ មានឧបមេយ្យដូច្នោះ ឯង ។

[ ១០៥ ] ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។បេ។ បានចូលទុតិយជ្ឈាន ភិក្ខុនោះញ៉ាំងកាយនេះឯងឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយដោយបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន

ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសមាធិ ។ ម្នាលឧទាយិ ដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើងខាងក្នុង មិនមានផ្លូវទឹកអំពីទិសខាងកើតនៃអន្លង់នោះទេ មិនមានផ្លូវទឹកអំពីទិសខាងលិចទេ មិនមានផ្លូវទឹកអំពីទិសខាងជើងទេ មិនមានផ្លូវទឹកអំពីទិសខាងត្បូងទេ ភ្លៀងសោតក៏មិនបង្អុរនូវទឹកដោយល្អម្តងៗ មានតែទទឹកដ៏ត្រជាក់ ជោរចេញអំពីអន្លង់ទឹកនោះ ញុំាងអន្លង់ទឹកនោះឯងឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយដោយទឹកត្រជាក់ ប្រទេសបន្តិចបន្តួចនៃអន្លង់ទឹកនោះទាំងអស់ សុទ្ធតែជ្រួតជ្រាបដោយទឹកត្រជាក់ សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលឧទាយិ ភិក្ខុញុំាងកាយនេះឯង ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិ និងសុខដែលកើតអំពីសមាធិគឺ បឋមជ្ឈាន ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយបីតិ និងសុខ ដែលកើតអំពីសមាធិក៏មានឧបមេយ្យយ៉ាងនោះដែរ ។

[ ១០៦ ] ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះប្រាសចាកបីតិផង ។បេ។ ចូលតតិយជ្ឈាន ភិក្ខុនោះញុំាងកាយនេះឯងឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយសេចក្តីសុខដែលគ្មានបីតិ ប្រទេសបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយសេចក្តីសុខដែលគ្មានបីតិ ។ ម្នាលឧទាយិ ដូចជាផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក

លិចនៅខាងក្នុងទឹក ដែលទឹកកំពុងចិញ្ចឹមនៅឡើយ ពួកជលជាតិទាំងនោះ រមែងជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយ ដោយទឹកនោះ រហូតដល់ចុង រហូតដល់គល់ ប្រទេសបន្តិចបន្តួចនៃផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ទាំងអស់សុទ្ធតែពាល់ត្រូវដោយទឹកនោះ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ ភិក្ខុញុំាងកាយនេះឯង ឲ្យជ្រួតជ្រាប ជោកជាំ បរិបូណ៌ ផ្សព្វផ្សាយដោយសេចក្តីសុខដែលគ្មានបីតិ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយសេចក្តីសុខ ដែលគ្មានបីតិ មានឧបមេយ្យយ៉ាងនោះដែរ ។

[ ១០៧ ] ម្នាលឧទាយិ មួយទៀត ភិក្ខុព្រោះលះបង់សេចក្តីសុខផង ។បេ។ ចូលចតុត្ថជ្ឈាន ភិក្ខុនោះអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តបរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយចិត្តបរិសុទ្ធិផូរផង់ ។ ម្នាលឧទាយិ ដូចជាបុរសអង្គុយទទូរក្បាលដោយសំពត់ស ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់បុរសនោះ សុទ្ធតែប៉ះពាល់ដោយសំពត់ស សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ ភិក្ខុអង្គុយផ្សាយទៅកាន់កាយនេះឯង ដោយចិត្តដ៏បរិសុទ្ធផូរផង់ ប្រទេសបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ សុទ្ធតែពាល់ត្រូវដោយចិត្តដ៏បរិសុទ្ធផូរផង់ មានឧបមេយ្យយ៉ាងនោះដែរ ។ ពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងឈានទាំង ៤ នោះ ។

[ ១០៨ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់

សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគត បានប្រតិបត្តិ ហើយកំណត់ដឹងយ៉ាងនេះថា រាងកាយរបស់អាត្មាអញនេះឯង មានរូប ប្រកបដោយមហាភូតទាំង ៤ កើតអំពីមាតា និងបិតា ចម្រើនដោយបាយ នឹងនំ ជាសភាវៈមិនទៀងទាត់ មិនឋិតថេរ មានការដុសខាត់បំបាត់ក្លិនអាក្រក់ គក់ប្របាច់ឬចាប់នួត បែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ឯវិញ្ញាណរបស់អាត្មាអញនេះសោត ក៏អាស្រ័យនៅនឹងរាងកាយនេះ ជាប់ជំពាក់នៅនឹងរាងកាយ នេះឯង ។ ម្នាលឧទាយិ ដូចជាកែវពៃទូរ្យល្អស្អាត មានជាតិដ៏បរិសុទ្ធ មាន ជ្រុង ៨ ដែលបុគ្គលច្នៃហើយដោយប្រពៃ គឺបាននាំយកជាតិថ្ម និងក្រួស ចេញអស់ហើយ មានសម្បុរភ្លឺថ្លាយ៉ាងវិសេស បរិបូរណ៍ដោយអាការៈទាំង ពួង មានដុសលាងជាដើម ទើបបុរសនោះយកចេសខៀវក្តី លឿងក្តី ក្រហម ក្តី សសុទ្ធក្តី សក្លាវក្តី ទៅដោតក្នុងកែវនោះ បុរសមានភ្នែកភ្លឺដាក់កែវ នោះ ក្នុងដៃ ហើយពិចារណាមើលក៏ស្គាល់ច្បាស់ថា នេះឯងជាកែវពៃទូរ្យល្អស្អាត មានជាតិបរិសុទ្ធ មានជ្រុង ៨ ដែលគេច្នៃហើយដោយប្រពៃ មានសម្បុរភ្លឺថ្លា យ៉ាងវិសេសបរិបូណ៌ដោយអាការៈទាំងពួង នេះជាចេសដែលមានសម្បុរខៀវ ឬលឿង ក្រហម សសុទ្ធ ឬសក្លាវ ដែលគេដោតទៅក្នុងកែវនោះ យ៉ាង ណាមិញ ម្នាលឧទាយិ តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយដឹងច្បាស់យ៉ាង នេះថា រាងកាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតទាំង ៤ កើតអំពីមាតា និងបិតា ចម្រើនដោយបាយនិងនំ ជាសភាវៈមិនទៀង

ទាត់ មិនឋិតថេរ មានការដុសខាត់បំបាត់ក្លិនអាក្រក់ គក់ច្របាច់ ឬចាប់ទួត បែកធ្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ឯវិញ្ញាណរបស់អាត្មាអញនេះ ក៏អាស្រ័យនៅនឹងរាងកាយនេះ ជាប់ជំពាក់នៅនឹងរាងកាយនេះ ក៏យ៉ាងនោះដែរ ។ ពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[ ១០៩ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយនិម្មិតនូវកាយដទៃចេញអំពីកាយនេះ ឲ្យជាកាយមានរូប ជាកាយសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនវិកលខូចខាត ។ ដូចបុរសដកហូតបណ្តូលស្មៅយាប្លងចេញអំពីដើមស្មៅនោះ បុរសនោះក៏យល់ច្បាស់យ៉ាងនេះថា នេះជាបណ្តូល នេះជាស្មៅយាប្លង ស្មៅយាប្លងផ្សេង បណ្តូលផ្សេង នេះជាបណ្តូលដែលអញដកចេញ អំពីស្មៅយាប្លងនេះឯង ម្នាលឧទាយិ ពុំនោះសោតដូចជាបុរសហូតដាវចេញអំពីស្រោម បុរសនោះក៏យល់ច្បាស់យ៉ាងនេះថា នេះដាវ នេះស្រោម ដាវផ្សេង ស្រោមផ្សេង នេះជាដាវដែលអញហូតចេញអំពីស្រោមនេះឯង ម្នាលឧទាយិ ពុំនោះសោតដូចបុរសដកពស់ចេញអំពីស្រោម បុរសក៏យល់ច្បាស់យ៉ាងនេះថា នេះពស់ នេះស្រោម ពស់ផ្សេង ស្រោមផ្សេង នេះពស់ដែលអញហូតចេញអំពីស្រោមនេះឯង សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់

តថាគតបានប្រតិបត្តិ ហើយនិម្មិតកាយដទៃចេញអំពីកាយនេះ ឲ្យជាកាយមានរូប ជាកាយសម្រេចអំពីចិត្ត មានអវយវៈតូចធំសព្វគ្រប់ មានឥន្ទ្រិយមិនវិកលខូចខាត មានឧបមេយ្យដូច្នោះឯង ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[ ១១០ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយតាក់តែងឫសម្តែងឫទ្ធិបានច្រើនប្រការ គឺកាយតែមួយ ធ្វើឲ្យជាកាយច្រើនក៏បាន ឬកាយច្រើនធ្វើឲ្យត្រឡប់ទៅជាកាយតែមួយវិញក៏បាន ធ្វើអាវិភាវៈបាដិហារិយ៍ក៏បាន ធ្វើតិរោភាវបាដិហារិយ៍ក៏បាន ជ្រែកចេញទៅក្រៅជញ្ជាំង ក្រៅកំផែង ក្រៅភ្នំក៏បាន ដូចគេដើរលើអាកាស ។ មុជងើបក្នុងផែនដីដូចក្នុងទឹកក៏បាន ។ ដើរលើទឹកឥតមានបែកធ្លាយ ដូចដើរលើផែនដីក៏បាន ។ អណ្តែតទៅលើអាកាសទាំងភ្នែន ដូចសកុណបក្សីក៏បាន ។ យកដៃទៅស្ទាបអង្អែលព្រះចន្ទព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិធំ មានអានុភាពធំយ៉ាងនេះក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅរហូតដល់ព្រហ្មលោកទាំងកាយក៏បាន ។ ម្នាលឧទាយិ ដូចជាស្មូនឆ្នាំង ឬកូនសិស្សរបស់ស្មូនឆ្នាំង ដែលឈ្លាសប្រសព្វ ទោះប្រាថ្នានឹងរចនាភាជន៍ណាៗ ដោយដីដែលបានធ្វើបរិកម្មល្អហើយ ក៏អាចនឹងធ្វើភាជន៍នោះៗ ឲ្យសម្រេចបាន ម្នាលឧទាយិ ពុំនោះដូចជាងភ្លុកក្តី កូនសិស្សរបស់ជាងភ្លុកក្តី ដែលឈ្លាសប្រសព្វ ទោះប្រាថ្នានឹងរចនាភ្លុកណាៗ ដោយភ្លុកដែលធ្វើបរិកម្មល្អហើយ ក៏អាចនឹងរចនាភ្លុកនោះៗ ឲ្យសម្រេចបាន

ម្នាលឧទាយិ ពុំនោះសោត ដូចជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តី ដែលឈ្លាសប្រសព្វ ទោះប្រាថ្នារចនាមាសណាៗ ដោយមាសដែលធ្វើបរិកម្ម ល្អហើយ ក៏អាចនឹងរចនាមាសនោះៗ ឲ្យសម្រេចបាន សេចក្តីទាំងនេះមាន ឧបមាយ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសម្តែង បដិបទាដល់សាវក ទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិហើយ សម្តែង ឫទ្ធិបានច្រើនប្រការ គឺកាយតែមួយ ធ្វើឲ្យទៅជាកាយច្រើនក៏បាន ឬកាយ ច្រើន ធ្វើឲ្យត្រឡប់ទៅជាកាយតែមួយវិញក៏បាន ធ្វើអាវិភាវបាដិហារ្យក៏បាន ធ្វើតិរោភាវបាដិហារ្យក៏បាន ជ្រែកចេញទៅខាងក្រៅជញ្ជាំង ក្រៅកំពែង ក្រៅ ភ្នំក៏បាន ដូចជាដើរទៅលើអាកាស ។ មុជងើបក្នុងផែនដី ដូចក្នុងទឹកក៏បាន ។ ដើរលើទឹកឥតមានបែកធ្លាយដូចដើរលើផែនដីក៏បាន ។ អណ្តែតទៅលើ អាកាសទាំងភ្នែន ដូចសកុណបក្សីក៏បាន ។ យកដៃទៅស្ទាបអង្អែលនូវព្រះ ចន្ទព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិធំ មានអានុភាពធំយ៉ាងនេះក៏បាន ញុំាង អំណាចឲ្យប្រព្រឹត្តទៅ រហូតដល់ព្រហ្មលោកទាំងកាយក៏បាន មានឧបមេយ្យ ដូច្នោះឯង ។ ពួកសាវករបស់តថាគត ជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[ ១១១ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់ សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគត បានប្រតិបត្តិ ហើយ មានត្រចៀកទិព្វដ៏បរិសុទ្ធ កន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮ សំឡេង ២ ប្រការ ទាំងសំឡេងទិព្វ ទាំងសំឡេងមនុស្ស ទាំងឆ្ងាយទាំង

ជិត ។ ម្នាលឧទាយិ ដូចបុរសអ្នកផ្លុំស័ង្ខ មានកម្លាំងអាចញ៉ាំងសំឡេងស័ង្ខឲ្យលាន់ឮទៅក្នុងទិសទាំង ៤ ឲ្យអ្នកផងដឹងបាន ដោយមិនលំបាកយ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយមានត្រចៀកទិព្វដ៏បរិសុទ្ធិ កន្លងហួសត្រចៀកមនុស្សធម្មតា រមែងឮសំឡេង ២ ប្រការ ទាំងសំឡេងទិព្វ ទាំងសំឡេងមនុស្ស ទាំងឆ្ងាយទាំងជិត ក៏យ៉ាងនោះដែរ ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[ ១១២ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទា ដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបដិបត្តិហើយ អាចកំណត់ដឹងនូវចិត្តដោយចិត្តរបស់សត្វដទៃ បុគ្គលដទៃ ចិត្តដែលប្រកបដោយរាគៈ ក៏ដឹងថាចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក៏ដឹងថា ចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងថាចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងថាចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ ក៏ដឹងថាចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈ ក៏ដឹងថាចិត្តប្រាសចាកមោហៈ ចិត្តដែលមានអារម្មណ៍មូល ក៏ដឹងថាចិត្តមានអារម្មណ៍មូល ចិត្តដែលរាយមាយ ក៏ដឹងថាចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរៈ និងអរូបាវចរៈ ក៏ដឹងថាចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ ក៏ដឹងថាចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលជាសឧត្តរៈ គឺ

លោកិយចិត្ត ក៏ដឹងថាចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈ គឺលោកុត្តរចិត្ត ក៏ដឹងថាចិត្តជាអនុត្តរៈ ចិត្តដែលតាំងមាំ ក៏ដឹងថាចិត្តតាំងមាំ ចិត្តដែលមិនតាំងមាំ ក៏ដឹងថាចិត្តមិនតាំងមាំ ចិត្តដែលរួចស្រឡះចាកកិលេសាសវៈ ក៏ដឹងថាចិត្តរួចស្រឡះចាកកិលេសាសវៈ ចិត្តដែលមិនបានរួចស្រឡះ ក៏ដឹងថាចិត្តមិនបានរួចស្រឡះ ។ ម្នាលឧទាយិ ដូចស្ត្រីក្តី បុរសក្តី ដែលនៅក្មេងពេញក្រមុំ ពេញកម្លោះ កំពុងចូលចិត្តនឹងការប្រដាប់ស្អិតស្អាងកាយ ឆ្លុះមើលស្រមោលមុខរបស់ខ្លួនក្នុងផ្ទៃកញ្ចក់ដែលបរិសុទ្ធផូរផង់ក្តី ក្នុងភាជន៍ទឹកដែលថ្លាល្អក្តី បើមុខប្រកបដោយទោស ( មានប្រជ្រុយ ដំបៅ មុន និងបួសជាដើម ) ក្តី ក៏ដឹងថាមុខប្រកបដោយទោស បើមុខឥតមានទោសក្តី ក៏ដឹងថាមុខឥតមានទោស យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយកំណត់ដឹងចិត្តដោយចិត្តរបស់សត្វដទៃ បុគ្គលដទៃ ចិត្តដែលប្រកបដោយរាគៈ ក៏ដឹងថាចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈ ក៏ដឹងថាចិត្តប្រាសចាករាគៈ ចិត្តដែលប្រកបដោយទោសៈ ក៏ដឹងថាចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈ ក៏ដឹងថាចិត្តប្រាសចាកទោសៈ ចិត្តដែលប្រកបដោយមោហៈ ... ចិត្តដែលប្រាសចាកមោហៈ ... ចិត្តដែលមានអារម្មណ៍មូល ... ចិត្តដែលមានអារម្មណ៍រាយមាយ ... ចិត្តដែលជាមហគ្គតៈ ... ចិត្តដែលមិនមែនជាមហគ្គតៈ ... ចិត្តដែលជាសឧត្តរៈ ... ចិត្តដែលជាអនុត្តរៈ ... ចិត្តដែលតាំងមាំ ... ចិត្តដែលមិនតាំងមាំ ... ចិត្ត

ដែលរួចស្រឡះ... ចិត្តដែលមិនរួចស្រឡះ... ក៏ដឹងថាចិត្តមិនរួចស្រឡះ ក៏ដូច្នោះឯង ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណជាទីបំផុតនៃអភិញ្ញាក្នុងធម៌នោះ ។

[ ១១៣ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយរលឹកឃើញនូវបុព្វេនិវាស ( លំដាប់ខន្ធដែលសត្វអាស្រ័យនៅក្នុងកាលមុន ) គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ រលឹកឃើញនូវសំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ និងសំវដ្តវិវដ្តកប្បជាច្រើនខ្លះថា អាត្មាអញបានកើតក្នុងទីឯណោះ មានឈ្មោះយ៉ាងនោះ មានគោត្រយ៉ាងនោះ មានវណ្ណៈយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខ និងទុក្ខយ៉ាងនោះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះហើយ ក៏ទៅកើតក្នុង ទីឯណោះទៀត លុះអាត្មាអញបានទៅកើតក្នុងទីនោះហើយ ក៏មានឈ្មោះយ៉ាងនោះ មានគោត្រកូលយ៉ាងនោះ មានវណ្ណយ៉ាងនោះ មានអាហារយ៉ាងនោះ ទទួលសុខ និងទុក្ខយ៉ាងនោះ មានកំណត់អាយុប៉ុណ្ណោះ លុះអាត្មាអញច្យុតអំពីទីនោះហើយ ទើបបានមកកើតក្នុងទីនេះ ។ ពួកសាវករលឹកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការៈ ( រូបនឹងអាហារជាដើម ) ព្រមទាំងឧទ្ទេស ( ឈ្មោះនឹងគោត្រកូល ) ដោយប្រការដូច្នេះ ។ ម្នាល

ឧទាយិ ដូចជាបុរសចេញអំពីស្រុករបស់ខ្លួន ហើយទៅកាន់ស្រុកដទៃ លុះចេញអំពីស្រុកនោះហើយ ទៅស្រុកដទៃទៀត បុរសនោះលុះចេញអំពីស្រុកនោះហើយ ត្រឡប់មកកាន់ស្រុកខ្លួនដដែលវិញ បុរសនោះ តែងដឹងយ៉ាងនេះថា អាត្មាអញបានចេញអំពីស្រុករបស់ខ្លួនហើយ មកដល់ស្រុកឯណោះ កាលនៅក្នុងស្រុកនោះ អាត្មាអញឈរយ៉ាងនោះ អង្គុយយ៉ាងនោះ និយាយយ៉ាងនោះ នៅស្ងៀមយ៉ាងនោះ លុះចេញអំពីស្រុកនោះហើយ បានមកដល់ស្រុកឯណោះទៀត កាលដែលនៅក្នុងស្រុកនោះឯង អាត្មាអញបានឈរយ៉ាងនោះ អង្គុយយ៉ាងនោះ និយាយយ៉ាងនោះ នៅស្ងៀមយ៉ាងនោះ អាត្មាអញនោះ លុះចេញអំពីស្រុកនោះហើយ ទើបបានត្រឡប់មកដល់ស្រុករបស់ខ្លួនដដែល យ៉ាងណាមិញ ម្នាលឧទាយិ តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគត បានប្រតិបត្តិហើយក៏រលឹកឃើញនូវបុព្វេនិវាស គឺរលឹកឃើញបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ។បេ។ ពួកសាវករលឹកឃើញនូវបុព្វេនិវាស មានប្រការដ៏ច្រើន ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ យ៉ាងនោះដែរ ។ ឯពួកសាវករបស់តថាគតជាច្រើន ក៏បានដល់បារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះ ។

[ ១១៤ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្តែងបដិបទាដល់សាវកទាំងឡាយ ដែលជាហេតុឲ្យពួកសាវករបស់តថាគតបានប្រតិបត្តិ ហើយបានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញនូវពួកសត្វ

ដែលកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានវណ្ណល្អខ្លះ មានវណ្ណអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ កំណត់ដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វទាំងនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់ អំពីសេចក្តីស្លាប់ ក៏រមែងទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ និងនរក អើហ្ន៎ ចំណែកសត្វពួកនេះវិញ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ សត្វទាំងនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏រមែងទៅកាន់សុគតិសួគ៌ទេវលោក ។ ពួកសាវកមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតាបានឃើញនូវពួកសត្វកំពុងច្យុត កំពុងកើត ជាសត្វថោកទាបខ្លះ ខ្ពង់-ខ្ពស់ខ្លះ មានវណ្ណៈល្អខ្លះ មានវណ្ណៈអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ កំណត់ដឹងនូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។ ម្នាលឧទាយិ ដូចជាផ្ទះ ២ ខ្នង មានទ្វារ បុរសមានចក្ខុ ឈរនៅត្រង់កណ្តាលផ្ទះទាំង ២ ខ្នងនោះ ក៏មើលឃើញពួកមនុស្សដែលកំពុងចូលមកក្តី ចេញទៅក្តី ដើរទៅក្តី ដើរមកក្តី យ៉ាងណា ម្នាលឧទាយិ បដិបទាដែលតថាគតបានសម្តែងហើយដល់សាវកទាំងឡាយ ដែលជាហេតុ

ឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិហើយ បានទូវទិព្វចក្ខុដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលកំពុងច្យុត កំពុងកើតជាសត្វថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានវណ្ណល្អខ្លះ មានវណ្ណអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ។បេ។ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ក៏យ៉ាងនោះដែរ ។ ឯសាវ័កទាំងឡាយរបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះ ។

[ ១១៥ ] ម្នាលឧទាយិ មួយទៀត តថាគតបានសម្ដែងបដិបទាដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគតបានប្រតិបត្តិ ហើយធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះ ដោយបញ្ញារបស់ខ្លួនហើយសម្រេចសម្រាន្តនៅ ។ ម្នាលឧទាយិ ដូចជាអន្លង់ទឹកដែលថ្លាយង់យ៉ាងវិសេស មិនល្អក់ នៅលើកំពូលភ្នំ បុរសមានចក្ខុឈរក្បែរច្រាំងអន្លង់ទឹកនោះមើលឃើញខ្ចៅខ្យងនឹងសំរាមផង ក្រួស និងអំបែងផង ហ្វូងត្រីផង កំពុងហែលខ្លះ កំពុងសំកាំងនៅខ្លះ បុរសបានដឹងយ៉ាងនេះថា អន្លង់ទឹកនេះឯងថ្លាយង់យ៉ាងវិសេស មិនមានល្អក់ នេះឯងជាខ្ចៅខ្យង និងសំរាម ក្រួស និងអំបែងក្នុងអន្លង់នោះ ហ្វូងត្រីទាំងឡាយកំពុងហែលខ្លះ កំពុងសំកាំងនៅខ្លះ យ៉ាងណាមិញ ម្នាលឧទាយិ បដិបទាដែលតថាគតបានសម្ដែងហើយដល់សាវ័កទាំងឡាយ ដែលជាហេតុឲ្យពួកសាវ័ករបស់តថាគត បានប្រតិបត្តិ

ហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះ ដោយបញ្ញារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅយ៉ាងនេះដែរ ។ ឯពួកសាវ័ករបស់តថាគតជាច្រើន ក៏បានដល់នូវបារមីញាណ ជាទីបំផុតនៃអភិញ្ញាក្នុងបដិបទានោះ ។

[ ១១៦ ] ម្នាលឧទាយិ នេះឯងធម៌ទី ៥ ដែលជាធម៌នាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការគោរពហើយ អាស្រ័យនៅ ( នឹងតថាគត ) ។ ម្នាលឧទាយិ ធម៌ទាំង ៥ នេះឯង ដែលជាធម៌នាំឲ្យពួកសាវ័ករបស់តថាគត ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយអាស្រ័យនៅ ( នឹងតថាគត ) ។ លុះព្រះមានព្រះភាគ សម្តែងភាសិតនេះចប់ហើយ សកុលុទាយិបរិព្វាជក មានចិត្តត្រេកអររីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចប់ មាហាសកុលុទាយិសូត្រទី ៧

# អដ្ឋកថា

## មហាសកុលុទាយិសូត្រ

[ ៧៥ ] មហាសកុលុទាយិសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **មោរនិវាបេ** គឺក្នុងទីនោះ ជនទាំងឡាយ បានប្រកាសឲ្យអភ័យដល់ក្ងោកទាំងឡាយ ហើយបានឲ្យអាហារ ព្រោះដូច្នោះ ទើបទីនោះឈ្មោះថា **មោរនិវាប** ជាទីឲ្យចំណីដល់សត្វក្ងោក ។ បទថា **អន្នភារោ** ជាឈ្មោះរបស់បរិព្វាជកម្នាក់ ដូចវរតរៈ ក៏ជាឈ្មោះបរិព្វាជកដូចគ្នា ។ បទថា **អញ្ញេ ច** មិនមែនត្រឹមតែបរិព្វាជក ៣ នាក់នោះប៉ុណ្ណោះទេ សូម្បីបរិព្វាជកដទៃៗ ដែលមានកិត្តិសព្ទក៏មានច្រើន ។

[ ៧៦ ] ក្នុងបទថា **អបសទ្ទស្ស វណ្ណវាទី** សេចក្ដីថា ព្រះសមណគោតមទ្រង់ពោលសរសើរគុណនៃសំឡេងតិច ។ លោកមិនពោលថា **អប្បសទ្ទវិនីតោ** ( ទូន្មានឲ្យមានសំឡេងតិច ) ទើប ពោលបទនេះ ។ ព្រោះហេតុអ្វី ព្រោះព្រះមានព្រះភាគទ្រង់មិនបានទូន្មានអ្នកដទៃ ។

[ ៧៧ ] បទថា **បុរិមានិ** គឺថ្ងៃមុនៗ សំដៅដល់ ម្សិលមិញនេះ ។ ក្រោយអំពីនោះ គឺក្រោយអំពីថ្ងៃម្សិលមិញ ។ មិនមានសាលាចំពោះ ទើបឈ្មោះថា **កុតូហលសាលា** គឺសាលាផ្សាយដំណឹង ។ សាលាដែលពួកតិរ្ថិយផ្សេងៗ និងសមណព្រាហ្មណ៍ប្រជុំសន្ទនាគ្នាច្រើនយ៉ាង លោកហៅថា **កុតូហលសាលា** ព្រោះជាទីផ្សាយដំណឹងនៃជនជាច្រើនថា បុគ្គលនេះនិយាយអ្វី បុគ្គលនេះនិយាយដូចម្ដេច ។ បាឋៈថា **កោតូហលសាលា** ក៏មាន ។

បទថា **លាភា** សេចក្តីថា នេះជាលាភរបស់អ្នកដែនអង្គៈ មគធៈ ដែលបាន ឃើញសមណព្រាហ្មណ៍ សួរប្រស្នា ឬស្តាប់ធម្មកថារបស់សមណព្រាហ្មណ៍ ទាំងនោះ ។

គប្បីជ្រាបអត្ថក្នុងបទថា **សង្ឃិនោ** ជាដើម ដូចតទៅនេះថា ឈ្មោះថា **សង្ឃិនោ** ព្រោះមានពួក គឺគណៈបព្វជិត ។ ឈ្មោះថា **គណិនោ** ព្រោះ មានគណៈនោះឯង ។ ឈ្មោះថា **គណាចរិយា** ព្រោះជា អាចារ្យរបស់ គណៈនោះ ដោយឲ្យសិក្សាដល់អាចារៈ ។ បទថា **ញាតា** គឺ មានឈ្មោះ បោះសំឡេងជាអ្នកប្រាកដ ។ ឈ្មោះថា **យសស្សិនោ** ព្រោះមាន យសខ្ពស់ ដោយគុណតាមដែលមិនពិត និងដោយគុណតាមពិត ។ បូរណកស្សបជាដើម មានយសខ្ពស់ ដោយន័យជាដើមថា ជាអ្នកប្រាថ្នាតិច សន្តោស សូម្បីសំពត់ក៏មិនស្លៀក ព្រោះជាអ្នកមានការប្រាថ្នាតិច ។ យសរបស់ព្រះតថាគតខ្ពស់ដោយព្រះគុណតាមសេចក្តីពិត មានព្រះគុណថា **ឥតិបិ សោ ភគវា** ដូច្នេះ ។ បទថា **តិត្ថករា** គឺមេលទ្ធិ ។ បទថា **សាធុសម្មតា** គឺ ជនជាច្រើនសន្មតគ្នាយ៉ាងនេះថា ល្អ ស្អាត ជាសប្បុរស ។ បទថា **ពហុជនស្ស** គឺបុគ្គលអន្ធពាល និងពាលបុថុជ្ជនដែលមិនមានការសិក្សា និង បណ្ឌិតជនអ្នកមានបញ្ញា ។ ក្នុងជនទាំងនោះ ពួកតិរ្ថិយគេសន្មតថា ជា ពាលជន ព្រះតថាគតគេសន្មតថា ជាបណ្ឌិតជន ។ ដោយន័យនេះ គប្បី ជ្រាប សេចក្តីក្នុងបទជាដើមថា **បូរណោ កស្សបោ សង្ឃី** បូរណកស្សប ជាមេគណៈ ក៏ព្រោះព្រះមានព្រះភាគទ្រង់ចែកអារម្មណ៍ ៣៨ ទ្រង់បានធ្វើ កំពង់

ជាទីចុះកាន់ព្រះនិព្វានទុកច្រើន ដូច្នោះគួរពោលថា **ជាតិត្ថកោ** ប្រែថា អ្នកធ្វើកំពង់ ។ សួរថាព្រោះហេតុអ្វី ទើបមេលទ្ធិទាំងអស់នោះ មកប្រជុំក្នុងទីនោះ ។ ឆ្លើយថា ដើម្បីរក្សាឧបដ្ឋាក និងដើម្បីលាភសក្ការៈ ។ បានឮថា មេលទ្ធិទាំងនោះ មានការត្រិះរិះថា ឧបដ្ឋាករបស់ពួកយើង គប្បីនាំគ្នាដល់ព្រះសមណគោតមថាជាទីពឹង ។ ពួកយើងនឹងរក្សាឧបដ្ឋាកទាំងនោះ ។ សូម្បីឧបដ្ឋាករបស់ពួកយើង ឃើញឧបដ្ឋាករបស់ព្រះសមណគោតមធ្វើសក្ការៈ ក៏នឹងធ្វើសក្ការៈដល់ពួកយើងដែរ ។ ព្រោះដូច្នោះ ទើបមេលទ្ធិទាំងអស់នោះនាំគ្នាទៅ ប្រជុំក្នុងទីដែលព្រះមានព្រះភាគប្រជុំ ។

[ ៧៨ ] បទថា **វាទំ អារោបេត្វា** គឺលើកទោសក្នុងវាទៈ ។ បទថា **អបក្កន្តា** គឺនាំគ្នាចៀសចេញទៅ ពួកខ្លះចៀសចេញទៅកាន់ទិស ។ ពួកខ្លះសឹក ពួកខ្លះមកកាន់សាសនានេះ ។ បទថា **សហិតម្មេ** គឺពាក្យរបស់យើងប្រកបដោយប្រយោជន៍ក្រៃលែង ប្រកបដោយអត្ថ ប្រកបដោយហេតុ ។ បទថា **អសហិតំ** គឺពាក្យរបស់លោកមិនប្រកបដោយប្រយោជន៍ ។ បទថា **អធិចិណ្ណន្តេ វិបរាវត្តំ** សេចក្តីថា កាលដែលលោកធ្លាប់មានការស្ទាត់ជំនាញ ដោយសន្សំមកអស់កាលដ៏យូរ បានប្រែប្រួលទៅហើយ ដោយពាក្យត្រឹមមួយម៉ាត់របស់យើង ។ បទថា **អារោបិតោ តេ វាទោ** គឺខ្ញុំចាប់កំហុសក្នុងវាទៈរបស់លោកបានហើយ ។ បទថា **ចរ វាទប្បមោក្ខាយ** សេចក្តីថា ចូរប្រព្រឹត្ត ដើម្បីដោះកំហុស គឺចូរសិក្សាដើម្បីទៅក្នុងទីនោះៗ ។ បទថា **និព្វេឋេហិ វា សចេ បហោសិ** ឬចូរដោះស្រាយបើអាច គឺបើអាចដោះខ្លួន

ឯង ចូរដោះស្រាយក្នុងឥឡូវនេះឯង ។ បទថា **ធម្មេន្តោសេន** គឺដោយពាក្យតិះដៀលតាមសេចក្តីពិត ។

[ ៧៩ ] បទថា **តន្តោ សោស្សាម** គឺយើងទាំងឡាយ នឹងស្តាប់ធម៌ដែលព្រះមានព្រះភាគត្រាស់ដល់ពួកយើង ។ បទថា **ខុទ្ទំ មធុំ** គឺសម្បុកឃ្មុំដែលឃ្មុំតូចៗ ធ្វើទុក ។ បទថា **អនេលកំ** គឺសម្បុកឃ្មុំដែលប្រាសចាកមេ ។ បទថា **បីឡេយ្យ** គឺគប្បីប្រេបាច់ ។ បទថា **បច្ចាសីសមានរូបោ** គឺកាន់ភាជនះ បំណងថា បុរសនោះនឹងឲ្យអញពេញភាជនៈឬទេហ្ន៎ ។ បទថា **សម្បយោជេត្វា** គឺប្រកែកគ្នាបន្តិចបន្តួច ។

[ ៨១ ] បទថា **ឥតរីតរេន** គឺតាមមានតាមបាន ។

[ ៨៤ ] បទថា **បវិវិត្តោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ជាអ្នកស្ងាត់ បរិព្វាជកពោលពាក្យនេះ សំដៅដល់ ត្រឹមកាយវិវេក ។ តែព្រះមានព្រះភាគ ទ្រង់ស្ងាត់ដោយវិវេក ៣ ។

[ ៨៥ ] បទថា **កោសកាហារាបិ** គឺមានអាហារត្រឹមតែមួយកូនផ្តិលក្នុងផ្ទះរបស់ទានបតី ដែលមានផ្តិលតូចដើម្បីដាក់អាហារយ៉ាងល្អ ។ ទានបតីទាំងឡាយ ដាក់អាហារល្អទុកក្នុងផ្តិលនោះ ហើយបរិភោគ ។ កាលបព្វជិតមកដល់ ក៏ប្រគេនអាហារដល់បព្វជិតនោះ ផ្តិលតូចនោះ ហៅថា **កោសក** ព្រោះដូច្នោះបុគ្គលណា បានញុំាងជីវិតឲ្យប្រព្រឹត្តទៅដោយអាហារមួយផ្តិលតូច បុគ្គលនោះឈ្មោះថា **កោសកាហារា** ដូច្នេះ ។ បទថា **វេឡុវាហារា** គឺមានអាហារត្រឹមតែកត្តដាក់ក្នុងសម្បុកញ្ចៅ ។ បទថា **សមតិត្តិកំ** គឺស្មើ

វណ្ណខាងក្រោមនៃកណ្ដាប់មាត់បាត្រ ។ បទថា **ឥមិនា ធម្មេន** គឺដោយធម៌ព្រោះជាអ្នកមានអាហារតិចនេះ ។ ម្យ៉ាងទៀត ក្នុងបទនេះ មិនគួរពោលថា ព្រះមានព្រះភាគ ទ្រង់មានអាហារតិចដោយអាការទាំងពួង ។ ទ្រង់មានអាហារតិចអស់កាល ៦ ឆ្នាំ ក្នុងទីដែលទ្រង់បំពេញព្យាយាម ។ ទ្រង់ញ៉ាំងព្រះជន្មជីវី ឲ្យប្រព្រឹត្តទៅដោយបាយមួយទូកដៃអស់ ៣ ខែ ក្នុងស្រុកវេរញ្ជា ។ ទ្រង់ញ៉ាំងព្រះជន្មជីពឲ្យប្រព្រឹត្តទៅដោយក្រអៅឈូកប៉ុណ្ណោះអស់ ៣ ខែ ក្នុងបាលិលេយ្យព្រៃស្រោង ។ ក្នុងទីនេះ ព្រះអង្គទ្រង់សម្ដែងដល់សេចក្ដីនេះថា តថាគតមានអាហារតិចក្នុងកាលមួយ តែសាវ័កទាំងឡាយរបស់តថាគត មិនទម្លាយធុតង្គអស់មួយជីវិត តាំងអំពីសមាទានធុតង្គមក ។ ព្រោះដូច្នោះ ឧបមាថា សាវ័កទាំងឡាយនោះ គប្បីធ្វើសក្ការៈតថាគតដោយធម៌នេះ ។ ព្រោះថា សាវ័កទាំងនោះជាអ្នកវិសេសជាងតថាគត រមែងធ្វើសក្ការៈតថាគតដោយធម៌ដទៃដែលមាន ។ លោកសម្ដែងទុកដូច្នេះ ។ ដោយន័យនេះ គប្បីជ្រាបដោយយោជនាគ្រប់វារៈ ។

[ ៧៦ ] បទថា **បំសុកូលិកា** សមាទានបំសុកូលចីវរជាវត្ត គឺសមាទានបំសុកូលិកង្គធុតង្គ ។ បទថា **លូខចីវរធរា** ទ្រទ្រង់ចីវរសៅហ្មងដោយអំបោះ ១០០ សរសៃ ។ បទថា **នន្តកានិ** គឺ ចម្រៀកសំពត់ដែលមិនមានជាយ ។ ពិតហើយ ឧបមាថា សំពត់ទាំងនោះ គប្បីមានជាយសំពត់ទាំងនោះ ហៅថា **បិលោតិកា** ។ បទថា **ឧច្ចិនិត្វា** គឺហែកចោលនូវចំណែកដែលប្រើការមិនបាន កាន់យកចំណែកដែលប្រើបានប៉ុណ្ណោះ ។ បទ

ថា **អលាវុលោមសានិ** គឺមានសរសៃអំបោះដូចគ្នានឹងរោមឃ្លោក ។ លោកសំដែងថា ល្អិត ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ មិនគួរពោលថា ព្រះសាស្តា ទ្រង់មិនសន្តោស ដោយចីវរសន្តោសឡើយ ។ ព្រោះក្នុងថ្ងៃដែលព្រះអង្គទ្រង់ទទួលយកសំពត់ បង្សុកូលធ្វើដោយសម្បកឈើ ដែលនាងបុណ្ណទាសី នាំមកអំពីព្រៃខ្មោចស្រស់ប្រគេន មហាបឋវីបានញាប់ញ័រ រហូតដល់ទឹកជាទីបំផុត ព្រះអង្គទ្រង់សំដែងសេចក្តីក្នុងបទនេះទុកថា តថាគតទទួលសំពត់បង្សុកូលម្តងប៉ុណ្ណោះ តែសាវកទាំងឡាយរបស់តថាគត មិនទម្លាយធុតង្គរហូតអស់ជីវិត តាំងអំពីសមាទានធុតង្គមក ។

[ ៨៧ ] បទថា **បិណ្ឌបាតិកា** គឺបិណ្ឌបាតជាវត្ត គឺបដិសេធអតិរេកលាភ សមាទានបិណ្ឌបាតិកង្គធុតង្គ ។ បទថា **សបទានចារិនោ** គឺត្រាច់ទៅតាមលំដាប់ច្រកជាវត្ត បដិសេធលោលុប្បចារ គឺការត្រាច់ទៅដោយសេចក្តីល្មោភ ហើយសមាទានសបទានចារិកវត្ត ។ បទថា **ឧញ្ឆាបកេ វត្តេ រតា** សេចក្តីថា ត្រេកអរក្នុងវត្តតាមប្រក្រតីរបស់ភិក្ខុទាំងឡាយ ពោលគឺការត្រាច់ទៅដើម្បីអាហារចិញ្ចឹមជីវិត ជាអ្នកឈរត្រង់ទ្វារផ្ទះ ទាំងខ្ពស់ និងទាប ប្រមូលអាហារដែលលាយឡំគ្នា ជាពំនូតហើយឆាន់ ។ បទថា **អន្តរឃរំ** គឺចន្លោះផ្ទះ តាំងអំពីធរណីទ្វារ ដូចបានពោលហើយ ក្នុងព្រហ្មាយុសូត្រ ។ ក្នុងទីនេះលោកបំណងយកតាំងពី សសរខឿន ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ មិនគួរពោលថា ព្រះសាស្តា ទ្រង់មិនសន្តោស ដោយបិណ្ឌបាតសន្តោស ។ ទាំងអស់គប្បីឲ្យពិស្តារដោយ ទំនងដូចគ្នាតាមដែលពោលហើយ ព្រោះភាព

ជាអ្នកមានអាហារតិច ។ ក្នុងទីនេះ ព្រះមានព្រះភាគ ក៏ទ្រង់សម្ដែងសេចក្ដីនេះទុកថា តថាគតមិនត្រេកអរទទួលនិមន្តន៍ក្នុងវេលាមួយប៉ុណ្ណោះ តែសាវកទាំងឡាយនៃតថាគត មិនទម្លាយធុតង្គអស់មួយជីវិត តាំងអំពីសមាទានធុតង្គមក ។

[ ៨៨ ] បទថា **រុក្ខមូលិកា** សមាទានការនៅដោយគល់ឈើជាវត្ត គឺបដិសេធ ទីប្រក់បាំង សមាទានរុក្ខមូលិកង្គធុតង្គ ។ បទថា **អព្ភោកាសិកា** សមទានទូវទីវាលជាវត្ត គឺបដិសេធទីប្រក់បាំង និងគល់ឈើ ហើយសមាទានអព្ភោកាសិកង្គធុតង្គ ។ បទថា **អដ្ឋមាសេ** សេចក្ដីថា អស់កាល ៨ ខែ គឺអស់ហេមន្តរដូវ និងគិម្ហរដូវ តែខាងក្នុងរដូវភ្លៀង ចូលទៅកាន់ទីប្រក់បាំង ដើម្បីរក្សាចីវរ ។ ដោយហេតុមានប្រមាណប៉ុណ្ណោះ មិនគួរពោលថា ព្រះសាស្ដាទ្រង់មិនសន្ដោស ដោយសេនាសនសន្ដោស តែគប្បីសម្ដែងសេនាសនសន្ដោសរបស់ព្រះអង្គ ដោយមហាបធានអស់កាល ៦ ឆ្នាំ និងដោយបាលិលេយ្យព្រៃស្រោង តែក្នុងទីនេះ ព្រះអង្គទ្រង់សម្ដែងសេចក្ដីនេះទុកថា តថាគតមិនចូលកាន់ទីប្រក់បាំងក្នុងកាលមួយប៉ុណ្ណោះ តែសាវករបស់តថាគតមិនទម្លាយធុតង្គអស់មួយជីវិត តាំងអំពីសមាទានធុតង្គមក ។

[ ៨៩ ] បទថា **អារញ្ញកា** គឺបដិសេធសេនាសនៈចុងស្រុក ហើយសមាទានអារញ្ញិកង្គធុតង្គ ។ បទថា **សង្ឃមជ្ឈេ ឱសរន្តិ** សេចក្ដីថា រមែងប្រជុំគ្នាក្នុងចំណោមសង្ឃ លោកពោលដល់ក្នុងអពទ្ធសីមា គឺសីមាដែលមិនបានចង ។ តែសាវកដែលនៅក្នុងពទ្ធសីមា រមែងធ្វើឧបោសថក្នុងលំនៅ

របស់ខ្លួន ។ ដោយហេតុមានប្រមាណប៉ុណ្ណេះ មិនគួរពោលថា ព្រះសាស្តាទ្រង់មិនស្ងាត់ ព្រោះការស្ងាត់រមែងប្រាកដដល់ព្រះអង្គយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នាដើម្បីសម្ងំអស់កាល ៨ ខែ តែក្នុងទីនេះ ព្រះអង្គទ្រង់សម្តែងសេចក្តីនេះថា តថាគតសម្ងំនៅក្នុងកាលបែបនោះម្តងម្កាល តែសាវ័ករបស់តថាគតមិនទម្លាយធុតង្គអស់មួយជីវិត តាំងអំពីសមាទានធុតង្គមក ។

[ ៩០ ] បទថា **មមំ សាវកា** គឺសាវ័កទាំងឡាយរបស់តថាគត ។

[ ៩១ ] បទថា **សនិទានំ** គឺមានហេតុ មានបច្ច័យ ។ ព្រះសាស្តាទ្រង់មិនសម្តែងដល់និព្វានដែលមិនមានបច្ច័យឬ ។ មិនមែនមិនសម្តែងឡើយ ។ តែទ្រង់សម្តែងធ្វើទេសនានោះឲ្យមានហេតុ មិនមែនមិនមានហេតុឡើយ ។ បទថា **សប្បាដិហារិយំ** សេចក្តីថា ទ្រង់សម្តែងធម៌មានការអស្ចារ្យ នេះជាវេវចនៈនៃបទមុន ។ អធិប្បាយថា មានហេតុ ។

[ ៩២ ] ពាក្យថា **វត** ក្នុងបទថា **តំ វត** ត្រឹមតែជា និបាត ។ បទថា **អនាគតំ វាទបថំ** គឺគន្លងនៃវាទៈ ដែលតាំងនៅក្នុងថ្ងៃនេះ ហើយមកខាងលើនៃបញ្ហានោះៗ ក្នុងថ្ងៃស្អែកនេះ ខានស្អែកនេះ កន្លះខែ ឬមួយឆ្នាំ ។ បទថា **ន ទក្ខតិ** គឺ មិនឃើញដោយអាការដែលសច្ចកនិគ្រន្ថញាំងហេតុ ដែលខ្លួនមកដើម្បីសង្កត់សង្កិនឲ្យវិសេស កាលនឹងពោលទើបមិនបានឃើញ ព្រោះហេតុនោះ សេចក្តីនោះមិនមែនឋានៈនឹងមាន ។ បទថា **សហធម្មេន** គឺ មានហេតុ ។ បទថា **អន្តរន្តរា កថំ ឱបាតេយ្យុំ** សេច-

ក្តីថា កាត់នូវការសន្ទនារបស់តថាគត ហើយជៀតការសន្ទនារបស់ខ្លួនចូលទៅក្នុងចន្លោះ ។ បទថា **ន ខោ បនាហំ ឧទាយិ** សេចក្តីថា ម្នាលឧទាយី តថាគតមិនបំណង ប្រៀនប្រដៅ ក្នុងសាវកទាំងឡាយនេះថា កាលការសន្ទនាដ៏ធំជាមួយអម្ពដ្ឋៈ សោណទណ្ឌៈ កូដទណ្ឌៈ និងសច្ចកនិគ្រន្ថ ជាដើម គង់ប្រព្រឹត្តទៅបាន បើការប្រើសាវករបស់តថាគតមួយរូបគួរទាញឧបមា ឬហេតុមកពោល ។ បទថា **មមំយេវ** គឺក្នុងឋានៈយ៉ាងនេះ សាវកទាំងឡាយក៏មិនបានប្រាថ្នាឱវាទដែលជាពាក្យប្រៀនប្រដៅរបស់តថាគត ។

[ ៩៣ ] បទថា **តេសាហំ ចិត្តំ អារាធេមិ** គឺតថាគតកាន់យកចិត្តនៃសាវកទាំងនោះឲ្យជល់ព្រម ឲ្យបរិបូណ៌ ដោយការព្យាករណ៍បញ្ហារបស់ព្រះអរហន្ត ។ សួរឯណោះ ឆ្លើយឯណោះ ដូចសួរស្វាយ ព្យាករខ្នុរសម្ង សួរខ្នុរសម្ង ព្យាករស្វាយ ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងបទនេះ លោកពោលដល់សីលរបស់ព្រះពុទ្ធ ក្នុងទីដែលពោលទុកហើយថា **អធិសីលេ សម្ភាវេន្តិ** ប្រែថា សរសើរ ព្រោះអធិសីល ។ លោកពោលដល់ សព្វញ្ញុតញ្ញាណ ក្នុងទីដែលពោលទុកហើយថា **អភិក្កន្តេ ញាណទស្សនេ សម្ភាវេន្តិ** ប្រែថា សរសើរ ព្រោះញាណទស្សនៈដ៏ស្អាត ។ លោកពោលដល់បញ្ញាដែលឲ្យកើតឋានៈក្នុងទីដែលពោលទុកថា **អធិប្បញ្ញាយ សម្ភាវេន្តិ** ប្រែថា សរសើរព្រោះអធិប្បញ្ញា ។ លោកពោលដល់បញ្ញាព្យាករណ៍សច្ចៈ ក្នុងទីដែលលោកពោលទុកថា **យេន ទុក្ខេន** សេចក្តីថា បញ្ញាដ៏សេស វៀរសព្វញ្ញុ-តញ្ញាណ និងបញ្ញាព្យាករណ៍សច្ចៈ រមែងជាអធិប្បញ្ញា ។

[ ៩៤ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រាប់បដិបទារបស់សាវកទាំងនោះ ដែលសម្រេចដល់ ទើបត្រាស់ថា **បុន ច បរំ ឧទាយិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អភិញ្ញា វោសានបារមិប្បត្តា** គឺសម្រេចអរហត្តដែលជាទីបំផុតនៃអភិញ្ញា និងដែលជាបារមីនៃអភិញ្ញា ។

[ ៩៥ ] បទថា **សម្មប្បធានេ** គឺសេចក្តីព្យាយាមដែលជាឧបាយ ។ បទថា **ឆន្ទំ ជនេតិ** គឺញ៉ាំងការពេញចិត្តក្នុងកុសលដែលជាកត្តុកម្យតាឲ្យកើត ។ បទថា **វាយមតិ** គឺធ្វើសេចក្តីព្យាយាម ។ បទថា **វិរិយំ អារភតិ** គឺប្រារព្ធព្យាយាម បានដល់ ញ៉ាំងសេចក្តីព្យាយាមឲ្យប្រព្រឹត្តទៅ ។ បទថា **ចិត្តំ បគ្គណ្ហាតិ** គឺលើកចិត្តឡើង ។ បទថា **បទហតិ** គឺធ្វើសេចក្តីព្យាយាមដោយឧបាយ ។ បទថា **ភាវនាយ ធារិបូរិយា** គឺដើម្បីសេចក្តីចម្រើន ដើម្បីការបរិបូណ៌ ។ ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបការតាំងមាំណា នុ៎ះជាការមិនវង្វេង ការបរិបូណ៌ណា នុ៎ះជាការចម្រើន និងការបរិបូណ៌ ។ បទមុនជាអធិប្បាយនៃបទក្រោយ ដោយប្រការដូច្នេះឯង ។

ម្យ៉ាងទៀត បុព្វភាគបដិបទានៃសាវក លោកពោលទុកដោយបរិយាយនៃកស្សបសំយុត្ត ដែលព្រះមហាកស្សបត្ថេរពោលទុកដោយរឿងសម្មប្បធានទាំង ៤ នេះ សមដូចពាក្យដែលលោកពោលទុក ក្នុងកស្សបសំយុត្ត នោះថា

ម្នាលអាវុសោ ភិក្ខុក្នុងសាសនានេះ មិនធ្វើសេចក្តីព្យាយាមដុតកម្តៅកិលេស ដោយគិតថា ពួកអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើងដល់អាត្មាអញ កាលបើកើតឡើង គប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍

ដូច្នេះឡើយ មិនធ្វើសេចក្ដីព្យាយាមដុតកម្ដៅកិលេស ដោយគិតថាពួកអកុ-សលធម៌ដ៏លាមក ដែលកើតឡើងដល់អាត្មាអញ កាលបើអាត្មាអញមិនបានលះបង់ទេ គប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដូច្នេះឡើយ មិនធ្វើសេចក្ដីព្យាយាម ដុតកម្ដៅកិលេសដោយគិតថា ពួកកុសលធម៌ដែលមិនទាន់កើតឡើង ដល់អាត្មាអញ កាលបើមិនកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដូច្នេះឡើយ មិនធ្វើសេចក្ដីព្យាយាមដុតកម្ដៅកិលេសដោយគិតថា ពួកកុសលធម៌ដែលកើតឡើងដល់អាត្មាអញហើយ កាលបើរលត់ទៅវិញ គប្បីប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ដូច្នេះឡើយ ម្នាលអាវុសោបុគ្គលជាអ្នកមិនមានសេចក្ដីព្យាយាម ជាគ្រឿងដុតកម្ដៅកិលេស យ៉ាងនេះឯង ។

ម្យ៉ាងទៀត ក្នុងបទនេះ គប្បីជ្រាបថា អកុសលធម៌ដ៏លាមក បានដល់លោភៈជាដើម ។ ពាក្យថា កុសលធម៌ដែលមិនទាន់កើត បានដល់សមថវិបស្សនា និងមគ្គប៉ុណ្ណោះ ។ សមថវិបស្សនា ឈ្មោះថា កុសលដែលកើតឡើងហើយ ។ ឯមគ្គកើតឡើងម្ដងហើយរលត់ទៅ មិនឈ្មោះថាប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសឡើយ ព្រោះមគ្គនោះ ឲ្យបច្ច័យដល់ផលហើយទើបរលត់ ។ សូម្បីក្នុងបទមុន លោកពោលទុកថា គប្បីកាន់យកសមថៈនិងវិបស្សនា តែសេចក្ដីនោះមិនត្រឹមត្រូវ ។ សមថៈ និងវិបស្សនាកើតឡើងហើយ ក្នុងកុសលធម៌ទាំងនោះ កាលរលត់ទៅ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ដើម្បីការជាក់ច្បាស់នៃអត្ថ នឹងនាំរឿងមកពោលដូចតទៅនេះ

បានឮថា ព្រះថេរៈមួយរូបជាព្រះខីណាស្រព គិតថា អញនឹងថ្វាយបង្គំ

មហាចេតិយ និងមហាពោធិព្រឹក្ស ទើបមកកាន់មហាវិហារ អំពីជនបទជាមួយសាមណេរដែលកាន់កណ្ឌៈ ជាអ្នកបានសមាបត្តិ ហើយចូលទៅកាន់បរិវេណវិហារក្នុងពេលល្ងាច កាលមហាភិក្ខុសង្ឃកំពុងថ្វាយបង្គំព្រះចេតិយ មិនចេញទៅដើម្បីថ្វាយបង្គំព្រះចេតិយ ។ ព្រោះហេតុអ្វី ព្រោះព្រះខីណាស្រពគោរពយ៉ាងក្រៃលែងក្នុងព្រះរតនត្រ័យ ដូច្នោះ កាលភិក្ខុសង្ឃថ្វាយបង្គំ ត្រឡប់ទៅហើយ ក្នុងវេលាដែលពួកមនុស្សបរិភោគអាហារពេលល្ងាច សូម្បីសាមណេរ ក៏មិនឲ្យដឹង គិតថាអញនឹងថ្វាយបង្គំព្រះចេតិយ ទើបចេញទៅតែម្នាក់ឯងប៉ុណ្ណោះ ។ សាមណេរគិតថា ព្រះថេរៈទៅម្នាក់ឯងក្នុងកាលដែលមិនមែនជាកាល អញនឹងដឹង ទើបដើរតាមស្នាមជើងព្រះឧបជ្ឈាយ៍ទៅ ។ ព្រះថេរៈមិនដឹងថា សាមណេរមក ព្រោះមិនបានគិតដល់ ទើបឡើងកាន់លានព្រះចេតិយតាមទ្វារទិសខាងត្បូង ។ សាមណេរក៏ឡើងតាមស្នាមជើងទៅ ។ ព្រះមហាថេរៈ សម្លឹងមើលព្រះមហាចេតិយ ទាញបីតិក្នុងពុទ្ធគុណជាអារម្មណ៍ សង្រួមចិត្តទាំងអស់ សរសើរ ត្រេកអរ ថ្វាយបង្គំព្រះចេតិយ សាមណេរឃើញការថ្វាយបង្គំរបស់ព្រះថេរៈ ទើបគិតថា ព្រះឧបជ្ឈាយ៍របស់អញ មានចិត្តជ្រះថ្លា ក្រៃពេក ថ្វាយបង្គំព្រះចេតិយ បើបានផ្កាហើយ គប្បីធ្វើការបូជាឬហ្ន៎ ។ កាលព្រះថេរៈក្រោកឡើងថ្វាយបង្គំលើកអញ្ជលីដាក់លើសិរសា ឈរសម្លឹងមើលព្រះមហាចេតិយ ។ សាមណេរគ្រហែមឲ្យព្រះថេរៈដឹងថាខ្លួនមក ព្រះថេរៈក្រឡេកមើល ហើយសួរថា អ្នកមកថ្មើរណា សាមណេរឆ្លើយថា ក្នុងវេលាលោកម្ចាស់ថ្វាយបង្គំព្រះចេតិយ

លោកម្ចាស់ជ្រះថ្លាពន់ពេក ទើបថ្វាយបង្គំព្រះចេតិយ ។ លោកម្ចាស់បានផ្កាហើយ គប្បីបូជាឬ ។ ព្រះថេរៈ ឆ្លើយថា អើ សាមណេរ ឈ្មោះថាការបញ្ចុះព្រះធាតុប្រមាណប៉ុណ្ណេះ ក្រៅអំពីក្នុងព្រះចេតិយនេះហើយ រមែងមិនមាន ។ អ្នកណាបានផ្កាហើយ មិនគប្បីបូជាមហាស្តូបដែលមានសភាពបែបនេះបាន ។ សាមណេរ ពោលថា បើដូច្នោះ សូមលោកម្ចាស់បង្អង់សិនខ្ញុំនឹងនាំផ្កាមក ។ រំពេចនោះឯង សាមណេរចូលឈាន ទៅព្រៃហិមពាន្តដោយឫទ្ធិ បេះផ្កាបរិបូណ៌ដោយពណ៌ និងក្លិន ដាក់ពេញធម្មក្រក កាលព្រះថេរៈមិនទាន់ដល់មុខទ្វារក្រោយ អំពីខាងត្បូង សាមណេរមក ដាក់សំពត់ធម្មក្រកខ្ចប់ផ្កាទុកក្នុងដៃ ហើយពោលថា សូមលោកម្ចាស់បូជាចុះ ។ ព្រះថេរៈពោលថា នែសាមណេរផ្ការបស់អ្នកតិចតួចពេក ។ សាមណេរពោលថា សូមលោកម្ចាស់រឭកដល់គុណរបស់ព្រះមានព្រះភាគ ហើយបូជាចុះ ។ ព្រះថេរៈឡើងជណ្តើរ អាស្រ័យទ្វារខាងក្រោយ ផ្តើមធ្វើការបូជាដោយផ្កាក្នុងវេទនសម្រាប់បូជា ។ វេទនសម្រាប់បូជា ពេញទៅដោយផ្កា ផ្កាធ្លាក់ទៅពេញក្នុងជាន់ទី ២ ដោយកម្រាស់ប្រមាណស្មើជង្គង់ ។ ព្រះថេរៈចុះអំពីជាន់ទី ២ ញុំាងជាន់ខាងក្រោមឲ្យពេញ សូម្បីជាន់ខាងក្រោមនោះក៏ពេញ ។ ព្រះថេរៈដឹងថាពេញ ទើបកៀរទីផ្ទៃខាងក្រោម ត្រឡប់ទៅ ។ លានព្រះចេតិយមានផ្កាពេញទាំងអស់ ។ កាលលានព្រះចេតិយពេញ ព្រះថេរៈពោលថា សាមណេរ ផ្កាមិនទាន់អស់ទេ ។ សាមណេរ ឆ្លើយថា សូមលោកម្ចាស់ផ្កាប់ធម្មក្រកចុះ ។ ព្រះថេរៈផ្កាប់ធម្មក្រកហើយ ។ ក្នុងកាលនោះ

ផ្កាក៏អស់ទៅ ។ ព្រះថេរៈឲ្យធម្មក្រកដល់សាមណេរហើយធ្វើប្រទក្សិណព្រះចេតិយ ដែលមានកំពែង ៦០ ហត្ថ ៣ ជុំ ថ្វាយបង្គំក្នុងទិសទាំង ៤ ហើយត្រឡប់ទៅកាន់បរិវេណ គិតថាសាមណេរនេះមានឫទ្ធិច្រើនពិត តើអាចរក្សាឥទ្ធានុភាពនេះទុកបានឬហ្ន៎ ។ បន្ទាប់មក ព្រះថេរៈឃើញថា មិនអាចរក្សាបាន ទើបពោលនឹងសាមណេរថា សាមណេរ ឥឡូវនេះ អ្នកមានឫទ្ធិច្រើន ក្នុងខាងក្រោយ កាលឫទ្ធិវិនាស នឹងផឹកទឹកអង្ករ ក្នុងដៃរបស់ស្រីតម្បាញខ្វាក់ភ្នែកម្ខាង ។ នេះឈ្មោះថា ជាទោសនៃភាពជាកំលោះ សាមណេរនោះរន្ធត់ចិត្តក្នុងពាក្យរបស់ឧបជ្ឈាយ៍ តែមិនសំណូមពរថា សូមលោកម្ចាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំចុះ ។ សាមណេរគិតថា ព្រះឧបជ្ឈាយ៍របស់អញនិយាយអ្វី ធ្វើដូចមិនបានឮពាក្យនោះ បានទៅហើយ ។ ព្រះថេរៈកាលថ្វាយបង្គំមហាចេតិយ និងមហាពោធិព្រឹក្សហើយ ទើបឲ្យសាមណេរទទួលបាត្រ និងចីវរទៅកាន់កុដេឡិតិស្សមហាវិហារ សាមណេរដើរតាមព្រះឧបជ្ឈាយ៍ទៅ មិនទៅបិណ្ឌបាត ។ តែសួរថា លោកម្ចាស់ចូលទៅកាន់ស្រុកណា កាលដឹងថា ឥឡូវនេះឧបជ្ឈាយ៍របស់ខ្លួន នឹងទៅដល់ទ្វារស្រុក ទើបកាន់បាត្រ និងចីវររបស់ខ្លួន និងរបស់ព្រះឧបជ្ឈាយ៍ ហើយហោះទៅ ប្រគេនបាត្រ និងចីវរដល់ព្រះថេរៈ ហើយទើបចូលទៅបិណ្ឌបាត ។

ព្រះថេរៈទូន្មានសព្វវេលាថា សាមណេរ អ្នកកុំធ្វើយ៉ាងនេះ ឈ្មោះថាឫទ្ធិរបស់បុថុជ្ជន ផុយ ស្រួយ មិនពិតប្រាកដ កាលបានអារម្មណ៍ មានរូបជាដើម មិនជាទីសប្បាយ សូម្បីតិចតួចប៉ុណ្ណោះ ក៏បែកធ្លាយ ។ កាលការ

វិនាសចាកសមាបត្តិមាន ការនៅប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនអាចទ្រទ្រង់ទុកបាន ។ សាមណេរមិនប្រាថ្នានឹងស្តាប់ថា ឧបជ្ឈាយ៍របស់ខ្លួនពោលអ្វី នៅតែធ្វើដូចមុន ។ ព្រះថេរៈថ្វាយបង្គំព្រះចេតិយ ទៅដោយលំដាប់ហើយ ទើបទៅកាន់កម្ពិន្ទវិហារ សូម្បីព្រះថេរៈនៅក្នុងវិហារនោះ សាមណេរក៏នៅតែធ្វើយ៉ាងនោះ ។

តមកថ្ងៃមួយ ធីតារូបស្អាត របស់ជាងតម្បាញម្នាក់ នៅក្នុងបឋមវ័យចេញអំពីស្រុកកម្ពិន្ទៈ ចុះទៅកាន់ស្រះឈូក ស្រែកច្រៀងបេះផ្កាឈូក គ្រានោះសាមណេរហោះទៅដល់ខាងចុងស្រះ ជាប់ចិត្តក្នុងសំឡេងច្រៀងរបស់ស្រីនោះដូចអ្នកលក់ត្រីក្អែកខ្វាក់ ជាប់ចិត្តក្នុងសំឡេងរបស់អ្នកចម្រៀង ដូច្នោះ ។ ក្នុងនោះឯង ឫទ្ធិរបស់សាមណេរនោះក៏វិនាស ប្រៀបដូចក្អែកបាក់ស្លាប ។ តែដោយផលនៃសមាបត្តិដែលនៅមាន សាមណេរមិនធ្លាក់ទៅលើទឹកនោះធ្លាក់ចុះដូចសម្ទីរកាដោយលំដាប់ បានឈរហើយ ក្បែរច្រាំងស្រះឈូក សាមណេរប្រញាប់ប្រញាល់ប្រគេនបាត្រ និងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់ ។ ព្រះមហាថេរៈគិតថា អញឃើញហេតុការណ៍មកអំពីមុនហើយសូម្បីហាមសាមណេរ ក៏គង់មិនត្រឡប់ ទើបមិនពោលពាក្យណាមួយ រួចចូលទៅបិណ្ឌបាត ។ សាមណេរទៅឈរត្រង់ច្រាំងស្រះឈូក រង់ចាំស្រីនោះឡើងមក ស្រីនោះក៏ឃើញសាមណេរទាំងក្នុងខណៈហោះ និងខណៈមកឈរដឹងថា សាមណេរនេះ អផ្សុក ព្រោះអាស្រ័យអញពិត ទើបពោលថា ចៀសចេញទៅលោកម្ចាស់ ។ ទើបសាមណេរនោះចៀសចេញទៅ ។ ស្រីនោះ

ឡើងមកស្មៀកសំពត់ ហើយចូលទៅរកសាមណេរ សួរថា លោកម្ចាស់ត្រូវការអ្វីឬ សាមណេរប្រាប់សេចក្តីនោះ ។ ទើបនាងសម្តែងដល់ទោសក្នុងការគ្រប់គ្រងផ្ទះ ដោយហេតុច្រើនយ៉ាង និងអានិសង្សក្នុងការប្រព្រឹត្តិព្រហ្មចរិយៈ សូម្បីកំពុងណែនាំ ក៏មិនអាចបន្ទោបង់សេចក្តីអផ្សុករបស់សាមណេរនោះបាន គិតថា សាមណេរនេះ វិនាសឫទ្ធិបែបនេះ ព្រោះអញជាហេតុ ឥឡូវនេះ មិនគួរលះបង់ ទើបពោលថា សូមលោកម្ចាស់រង់ចាំនៅទីនេះចុះ ហើយទៅផ្ទះ ប្រាប់រឿងនោះដល់ឪពុកម្តាយ ។

មាតាបិតាក៏មកហើយ ប្រៀនប្រដៅច្រើនយ៉ាង បានពោលនឹងសាមណេរដែលមិនស្តាប់ថា លោកម្ចាស់កុំយល់ពួកខ្ញុំថា មានត្រកូលខ្ពស់ ពួកខ្ញុំត្រឹមតែជាជាងតម្បាញ អាចធ្វើបានត្រឹមតែការងារតម្បាញប៉ុណ្ណោះ ។ សាមណេរពោលថា ឧបាសក ធម្មតាមនុស្សដែលជាគ្រហស្ថ គួរធ្វើការងារត្បាញ ឬគួរធ្វើការងារផែងត្រកក៏បាន ។ ប្រយោជន៍អ្វីដោយត្រឹមតែសំពត់សាដកនេះ អ្នកចូរធ្វើការទៅចុះ ជាងតម្បាញឲ្យសំពត់សាដក ដែលចងពោះហើយ នាំទៅផ្ទះ លើកកូនក្រមុំឲ្យ អ្នកកំលោះនោះរៀនយកការងាររបស់ជាងតម្បាញធ្វើការត្រង់រោងតម្បាញជាមួយពួកជាង ។ បណ្តាប្រពន្ធរបស់ជាងតម្បាញដទៃ បានត្រៀមអាហារនាំមកអំពីព្រលឹម ភរិយារបស់នាយកំលោះមិនទាន់មកនៅឡើយ ។ នាយកំលោះនោះ កាលអ្នកដទៃសម្រាកបរិភោគអាហារ ខ្ជួននៅអង្គុយត្បាញនោះឯង ។ ភរិយាបានទៅឯក្រោយ ទើបនាយកំលោះនោះពោល គំហកភរិយាថា ម្តេចក៏នាងមកយឺតម្ល៉េះ ។ ធម្មតាមាតុគ្រាមតែង

ដឹងថា សូម្បីស្តេចចក្រពត្តិដែលមានចិត្តស្រឡាញ់ខ្លួន គង់គិតថា ខ្លួនដូចជាទាសៈ ។ ព្រោះដូច្នោះ ទើបនាងពោលថា ក្នុងផ្ទះរបស់អ្នកដទៃ គេមានឧសបន្ទែ និងអំបិលស្រោប់ សូម្បីជាងតម្បាញដែលជាទាសៈនាំចេញខាងក្រៅក៏គង់មាន ។ តែខ្ញុំជាស្រីម្នាក់ឯងប៉ុណ្ណោះ សូម្បីអ្នកក៏គង់មិនដឹងថា ក្នុងផ្ទះរបស់យើង វត្ថុនេះមាន វត្ថុនេះមិនមាន ។ បើអ្នកត្រូវការ ក៏ចូរបរិភោគចុះ បើមិនត្រូវការ ក៏កុំបរិភោគ ។ នាយកំលោះនោះពោលគំហកថា នាងមិនត្រឹមតែនាំអាហារមកយឺតប៉ុណ្ណោះ ហ៊ានទ្រគោះបោះបោកដាក់យើងដោយពាក្យសម្តីទៀត រួចក្រោធ កាលមិនឃើញគ្រឿងប្រទូស្តដទៃ ទើបទាញត្រល់ត្បាញសំពត់នោះ យកអំបោះចេញ ហើយគ្រវែងទៅ កិរិយាឃើញត្រល់រសាត់មក ទើបកាំងបន្តិច ចុងត្រល់ក៏មុត កាលនាងកាន់កាំង ទើបចុងត្រល់ចូលទៅមុតក្នុងភ្នែក នាងយកដៃទាំង ២ ខ្ទប់ភ្នែក ឈាមហូរចេញអំពីទីដែលមុត ។ នាយកំលោះនោះ នឹកឃើញដល់ពាក្យរបស់ឧបជ្ឈាយ៍បានក្នុងកាលនោះថា ព្រះឧបជ្ឈាយ៍គង់សំដៅដល់ហេតុនេះ ទើបពោលនឹងអញថា ក្នុងអនាគត អ្នកនឹងត្រូវផឹកទឹកអន្ទរដែលលាងដោយដៃរបស់ស្រីតម្បាញខ្វាក់ភ្នែកម្ខាង ព្រះថេរៈគង់នឹងឃើញហេតុនេះពិត ទើបទ្រហោយំដោយសំឡេងខ្លាំងថា ឱ លោកម្ចាស់ ជាអ្នកឃើញកាលវែង ។ ពួកជាងតម្បាញដទៃៗបានពោលនឹងនាយកំលោះនោះថា ល្មមហើយអ្នក អ្នកកុំយំថ្វីឡើយ ធម្មតាភ្នែកដែលបែកហើយ មិនអាចធ្វើឲ្យដូចដើមបានដោយការយំទេ ។ នាយកំលោះនោះពោលថា ខ្ញុំមិនបានយំដល់រឿងនោះទេតែខ្ញុំយំ សំដៅដល់ហេតុ

នេះ ដូច្នោះហើយ ទើបប្រាប់រឿងទាំងអស់តាមលំដាប់ ។

សមថៈ និងវិបស្សនាកើតឡើងហើយយ៉ាងនេះ កាលរលត់រមែងប្រព្រឹត្តទៅដើម្បីការខាតប្រយោជន៍ដូច្នេះ ។ មានរឿងដទៃមួយទៀតថា

ភិក្ខុប្រមាណ ៣០ រូប ថ្វាយបង្គំកល្យាណិមហាចេតិយ ហើយចុះកាន់ផ្លូវធំ តាមព្រៃស្ងួត បានឃើញបុរសម្នាក់ធ្វើការងារ ក្នុងទីដែលភ្លើងឆេះ ក្នុងចន្លោះផ្លូវដើរមក រាងកាយរបស់បុរសនោះ ប្រឡាក់ដោយធ្យូង ។ សម្លឹងមើលសាដកមួយផ្ទាំង ប្រឡាក់ដោយធ្យូង ស្លៀកត្បៀតនឹងក្លៀក ប្រាកដដូចជង្គត់ឈើត្រូវភ្លើងឆេះ បុរសនោះធ្វើការងារក្នុងពេលថ្ងៃ ជញ្ជូនគំនរឈើដែលត្រូវភ្លើងឆេះពាក់កណ្តាលចេញ មានសក់កន្ទ្រើងដល់ខ្នង ដើរចំហៀងផ្លូវ បានឈរនៅចំពោះមុខភិក្ខុទាំងឡាយ ។

ពួកសាមណេរមើលមុខគ្នានិងគ្នា ហើយពោលថា អាវុសោ ទុំះឪរបស់លោក អ៊ំរបស់លោក មារបស់លោក ហើយទើបសួរឈ្មោះថា ឧបាសក តើអ្នកឈ្មោះអ្វី បុរសនោះត្រូវសួរដល់ឈ្មោះ ក៏ក្តៅក្រហាយ ទម្លាក់គំនរឧសរៀបចំស្លៀកសំពត់ ថ្វាយបង្គំព្រះមហាថេរៈ ទើបពោលថា សូមលោកម្ចាស់ទាំងឡាយឈប់បន្តិចសិនចុះ ព្រះថេរៈទាំងឡាយបានឈរហើយ ។ ពួកសាមណេរមកហើយ ធ្វើការចំអកចំអន់ចំពោះមុខ ព្រះមហាថេរៈទាំងឡាយ ។ ឧបាសកពោលថា លោកម្ចាស់ទាំងឡាយ ឃើញខ្ញុំហើយសើចចំអក លោកម្ចាស់កុំយល់ថា ពួកអញបានសម្រេចដល់ទីបំផុត ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ ខ្ញុំនេះឯង កាលមុនក៏ជាសមណៈដូចលោកម្ចាស់

ទាំងឡាយដែរ តែលោកម្ចាស់មិនមានសូម្បីត្រឹមតែឯកគ្គតាចិត្ត ខ្ញុំបានជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនក្នុងសាសនានេះ ខ្ញុំកាន់យកអាកាសហើយធ្វើឲ្យជាផែនដីបាន កាន់យកផែនដី ហើយធ្វើឲ្យជាអាកាសបាន ធ្វើទីឆ្ងាយឲ្យជិតបាន ធ្វើទីជិតឲ្យឆ្ងាយបាន ខ្ញុំទៅក្នុងមួយសែនចក្រវាឡដោយខណៈ ១ ។ លោកម្ចាស់ទាំងឡាយមើលដៃរបស់ខ្ញុំចុះ ឥឡូវនេះ ដូចគ្នានឹងដៃស្វា ។ ខ្ញុំអង្គុយក្នុងទីនេះ ស្ទាបព្រះចន្ទ និងព្រះអាទិត្យដោយដៃទាំង ២ នេះបាន ខ្ញុំធ្វើព្រះចន្ទ និងព្រះអាទិត្យឲ្យជាទម្រលាងជើងទាំងនេះឯង ឫទ្ធិរបស់ខ្ញុំបែបនេះ បានអស់ទៅ ព្រោះការប្រមាទ សូមលោកម្ចាស់ទាំងឡាយ កុំជាអ្នកប្រមាទឡើយ ។ ព្រោះជនទាំងឡាយ ដល់នូវសេចក្តីវិនាសបែបនេះ ដោយសេចក្តីប្រមាទ ។ បុគ្គលមិនប្រមាទ រមែងធ្វើទីបំផុតនៃជាតិ ជរា និងមរណៈបាន ។ ព្រោះដូច្នោះ លោកម្ចាស់ទាំងឡាយ ធ្វើខ្ញុំនេះឯងឲ្យជាអារម្មណ៍ ហើយពោលជាស់តឿនថា សូមលោកម្ចាស់ទាំងឡាយ កុំប្រមាទឡើយ រួចឲ្យឱវាទ កាលបុរសនោះកំពុងពោលនោះឯង ភិក្ខុ ៣០ រូបនោះ ដល់នូវការសង្វេគ ឃើញច្បាស់ បានសម្រេចអរហត្តក្នុងទីនោះឯង ដោយប្រការដូច្នេះ។

សមថវិបស្សនាដែលកើតឡើងយ៉ាងនេះ កាលរលត់ទៅ គប្បីជ្រាបថារមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ។

ម្យ៉ាងទៀត ក្នុងបទថា **អនុប្បន្នានំ ចាបកានំ** គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងបទជាដើមថា **អនុប្បន្នោ វា កាមាសវោ ន ឧប្បជ្ជតិ ។**

ម្យ៉ាងទៀត ក្នុងបទថា **ឧប្បន្នានំ ចាបកានំ** មានសេចក្តីដូចតទៅនេះថា

បាបកើតឡើង ៤ យ៉ាង គឺកើតឡើង ក្នុងបច្ចុប្បន្ន ១ កើតឡើងព្រោះសោយផលហើយប្រាសទៅ ១ កើតឡើងព្រោះធ្វើឱកាស ១ កើតឡើងព្រោះបានភូមិ ១ ។ ក្នុង ៤ យ៉ាងនោះ កិលេសពួកណាមាននៅព្រម ដែលនឹងកើតជាដើម នេះឈ្មោះថា កើតក្នុងបច្ចុប្បន្ន ។ កាលកម្មនៅស្ទុះទៅសោយរសនៃអារម្មណ៍ ហើយរលត់ទៅ ឈ្មោះថា សោយផលហើយប្រាសទៅ ។ កម្មកើតឡើងហើយរលត់ ឈ្មោះថា សោយផលហើយប្រាសទៅ ។ សូម្បីទាំង ២ យ៉ាងនោះ ក៏ឈ្មោះថា កើតឡើងព្រោះសោយផលហើយប្រាសទៅ ។ កុសលកម្ម និងអកុសលកម្ម ហាមវិបាករបស់កម្មដទៃ ហើយធ្វើឱកាសនៃវិបាករបស់ខ្លួន ។ កាលធ្វើឱកាសយ៉ាងនេះ វិបាកកាលកើតឡើងរមែងឈ្មោះថា កើតឡើងហើយ តាំងអំពីធ្វើឱកាស ។ នេះឈ្មោះថា កើតឡើងព្រោះធ្វើឱកាស ។ ម្យ៉ាងទៀត ខន្ធ ៥ ឈ្មោះថា ជាភូមិនៃវិបស្សនា ។ ខន្ធទាំង ៥ នោះ រមែងមានប្រភេទជាអតីតជាដើម ។ កិលេសដែលដេកត្រាំនៅក្នុងខន្ធទាំង ៥ នោះ មិនគួរពោលថា ជាអតីត អនាគត ឬបច្ចុប្បន្នឡើយ ព្រោះជាកិលេសដែលដេកត្រាំនៅក្នុងខន្ធ ដែលជាអតីតក៏នៅមិនទាន់លះបាន ។ សូម្បីកិលេសដែលដេកត្រាំក្នុងខន្ធជាអនាគត ឬក្នុងខន្ធជាបច្ចុប្បន្ន ក៏ឈ្មោះថាមិនទាន់លះបានពិត នេះឈ្មោះថា កើតឡើងព្រោះបានភូមិ ។ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា កិលេសដែលមិនទាន់បានដកឡើងក្នុងភូមិទាំងនោះ រមែងឈ្មោះថា កើតឡើងព្រោះបានភូមិ ។

បាបកម្មកើតឡើង ៤ យ៉ាងដទៃទៀត គឺកើតឡើងព្រោះប្រព្រឹត្ត ១ កើតឡើងព្រោះប្រកាន់អារម្មណ៍ ១ កើតឡើងព្រោះមិនសង្កត់ ១ កើតឡើងព្រោះមិនដក ១ ក្នុង ៤ យ៉ាងនោះ កម្មដែលនៅប្រព្រឹត្តទៅ មិនឈ្មោះថាកើតឡើងព្រោះការប្រព្រឹត្ត កាលបើកភ្នែកឡើងម្តងហើយ ទាញយកនិមិត្តជាអារម្មណ៍ កិលេសទាំងឡាយក្នុងខណៈដែលរឭកដល់ មិនគួរពោលថានឹងមិនកើតឡើង ។ ព្រោះហេតុអ្វី ព្រោះនៅប្រកាន់អារម្មណ៍នៅឡើយ ដូចអ្វី ដូចទឹកដោះនៃវល្លិទឹកដោះដែលត្រូវពូថៅកាត់ហើយ បុគ្គលមិនគួរពោលថា ទឹកដោះនឹងមិនចេញ យ៉ាងណា ។ សេចក្តីនេះក៏ដូច្នោះ ឈ្មោះថា កើតឡើងព្រោះប្រកាន់អារម្មណ៍ ។ កិលេសទាំងឡាយ ដែលមិនបានសង្កត់ទុកដោយសមាបត្តិ មិនគួរពោលថា នឹងមិនកើតក្នុងឋានៈនេះ ។ ព្រោះហេតុអ្វី ព្រោះមិនទាន់សង្កត់ទុកបាន ។ ដូចអ្វី ដូចបើជនទាំងឡាយគប្បីនាំយកវល្លិទឹកដោះមកដោយពូថៅ មិនគួរពោលថា ទឹកដោះមិនចេញក្នុងទីនេះ យ៉ាងណា ។ សេចក្តីនេះក៏ដូច្នោះ ឈ្មោះថា កើតឡើងមិនសង្កត់សង្កិនទុក ។ ម្យ៉ាងទៀត កិលេសទាំងឡាយ ដែលដកចេញមិនទាន់បានដោយមគ្គ រមែងកើតឡើងដល់បុគ្គលកើតក្នុងភវគ្គព្រហ្ម គប្បីឲ្យពិស្តារដោយន័យដូចពោលហើយ ដោយប្រការដូច្នេះឯង ។ នេះឈ្មោះថា កើតឡើងព្រោះមិនទាន់ដកបាន ។

ក្នុងកម្មឈាមកដែលកើតឡើងទាំងនេះ កម្មកើតឡើង ៤ យ៉ាង គឺកើតក្នុងបច្ចុប្បន្ន ១ កើតឡើងព្រោះសោយផលហើយប្រាសទៅ ១ កើតឡើងព្រោះធ្វើឱកាស ១ កើតឡើងព្រោះប្រព្រឹត្ត ១ មិនត្រូវទម្លាយដោយមគ្គ ។

កម្មលាមក ៤ យ៉ាង គឺកម្មកើតឡើងព្រោះបានភូមិ ១ កើតឡើងព្រោះទាញយកអារម្មណ៍ ១ កើតឡើងព្រោះសង្កត់ទុកមិនបាន ១ កើតឡើងព្រោះដកមិនទាន់បាន ១ ត្រូវទម្លាយដោយមគ្គ ។ ព្រោះមគ្គកាលកើត រមែងលះកិលេសទាំងនេះបាន ។ មគ្គនោះរមែងលះកិលេសពួកណាបាន កិលេសទាំងនោះ មិនគួរពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ។ សមដូចដែលលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា

ពាក្យថា លះកិលេសដែលកន្លងហើយ សំណួរថា បើលះកិលេសដែលកន្លងហើយ មានតែញុំាងកិលេសដែលអស់ហើយ ឲ្យអស់ ញុំាងកិលេសដែលរលត់ហើយ ឲ្យរលត់ ញុំាងកិលេសដែលសាបសូន្យហើយឲ្យសាបសូន្យ ញុំាងកិលេសដែលវិនាសហើយឲ្យវិនាស គឺថាកិលេសជាតណា កន្លងហើយ មិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែន លះកិលេសដែលកន្លងហើយទេ ។

ពាក្យថា លះកិលេសដែលមិនទាន់មក សំណួរថា បើលះកិលេសដែលមិនទាន់មក មានតែលះកិលេសដែលមិនទាន់កើត លះកិលេសដែលមិនទាន់ដុះ លះកិលេសដែលមិនទាន់ផុសឡើង លះកិលេសដែលមិនទាន់កើតប្រាកដ គឺថាកិលេសជាតណា ដែលមិនទាន់មក មិនមានទេ លះកិលេសជាតនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលមិនទាន់មកទេ ។

ពាក្យថា លះកិលេសដែលកើតចំពោះមុខ សំណួរថា បើលះកិលេសដែលកើតចំពោះមុខ មានតែភិក្ខុអ្នកត្រេកអរ លះរាគៈ អ្នកប្រទូស្ត លះទោសៈ

អ្នកវង្វេង លះមោហៈ អ្នកប្រកួតប្រកាន់ លះមានះ អ្នកស្ទាបអង្អែល លះទិដ្ឋិ អ្នកមានចិត្តរាយមាយ លះឧទ្ធច្ចៈ អ្នកដល់នូវការមិនដាច់ស្រេច លះវិចិកិច្ឆា អ្នកមានព្យាយាម លះអនុស័យ គឺថាធម៌ខ្មៅនិងធម៌ស តែងជាប់គ្នាជាគូប្រព្រឹត្តទៅ មគ្គភាវនាប្រកបដោយសេចក្តីសៅហ្មង ដោយធម៌ទាំងពីរនោះឬ ។ ចម្លើយថា មិនមែនលះកិលេសដែលកន្លងហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេសដែលកើតចំពោះមុខទេ ។

បើមិនមែនលះកិលេសដែលកន្លងហើយ មិនមែនលះកិលេសដែលមិនទាន់មក មិនមែនលះកិលេសដែលកើតចំពោះមុខទេ បើដូច្នោះ មានតែមគ្គភាវនាមិនមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមិនមាន ការលះកិលេសមិនមាន ការត្រាស់ដឹងធម៌មិនមានឬ ។ មិនមែនដូច្នោះទេ មគ្គភាវនាមាន ការធ្វើឲ្យជាក់ច្បាស់នូវផលមាន ការលះកិលេសមាន ការត្រាស់ដឹងនូវធម៌មានឧបមាដូចអ្វី ដូចជាដើមឈើចំទង់ មិនទាន់មានផ្លែ បុរសកាត់ផ្តាច់ឈើនុ៎ះត្រង់គល់ឯអជាតផលណារបស់ឈើនោះ ដែលមិនទាន់ចេញ ក៏លែងចេញ ដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ពក ក៏លែងពក ដែលមិនទាន់កើតប្រាកដក៏លែងកើតប្រាកដ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចការកើតជាហេតុការកើតជាបច្ច័យ នៃការកើតកិលេស ចិត្តតែងស្ទុះទៅក្នុងការមិនកើត ព្រោះឃើញទោសក្នុងការកើត ព្រោះតែចិត្តស្ទុះទៅក្នុងការមិនកើត បានជាកិលេសទាំងឡាយណា ដែលមានការកើតឡើងជាបច្ច័យ គប្បីកើតឡើងកិលេសទាំងនោះដែលមិនទាន់កើត ក៏លែងកើត ដែលមិនទាន់ដុះ ក៏លែងដុះ ដែល

មិនទាន់ផុស ក៏លែងផុស ដែលមិនទាន់កើតប្រាកដ ក៏លែងកើតប្រាកដ ។

ដើមឈើដែលមិនទាន់ចេញផ្លែមកហើយក្នុងបាលី ។ តែគប្បីសម្តែងដោយដើមឈើដែលកើតផ្លែ ។ ដូចដើមស្វាយតូចមានផ្លែ ។ ពួកមនុស្សបរិភោគផ្លែរបស់ស្វាយនោះ ។ ធ្វើផ្លែដ៏សេសឲ្យជ្រុះហើយ ដាក់កំប្រោងរហូតពេញ គ្រានោះបុរសដទៃយកពូថៅកាត់ដើមស្វាយនោះ ផ្លែរបស់ស្វាយនោះ ក្នុងអតីត មិនទាន់សូន្យទៅ ផ្លែអនាគត បច្ចុប្បន្នក៏មិនសូន្យឈ្មោះថា មិនសូន្យទាំងអស់ ។ ព្រោះមនុស្សទាំងឡាយ បរិភោគផ្លែក្នុងអតីត ផ្លែក្នុងអនាគតក៏មិនទាន់កើត ទើបមិនអាចធ្វើឲ្យសូន្យបាន តែសម័យណា ដើមស្វាយនោះត្រូវកាប់ ក្នុងពេលនោះ ផ្លែនោះឯង រមែងមិនមានព្រោះហេតុនោះ សូម្បីផ្លែក្នុងបច្ចុប្បន្នក៏មិនទាន់សូន្យ ។ តែបើដើមឈើមិនគប្បីត្រូវកាត់សោត ផ្លែរបស់ដើមឈើដែលអាស្រ័យរសដី និងរសទឹក គប្បីកើត រមែងមិនសូន្យ ព្រោះផ្លែទាំងនោះដែលមិនទាន់កើត ក៏រមែងមិនកើត ដែលមិនទាន់ដុះ ក៏រមែងមិនដុះ ដែលមិនទាន់ប្រាកដ ក៏រមែងមិនប្រាកដ យ៉ាងណា មគ្គក៏ដូច្នោះដូចគ្នា សូម្បីមិនទាន់លះកិលេសទាំងឡាយ មានអតីតជាដើមបាន សូម្បីមិនទាន់លះបាន ក៏លះមិនបាន ។ ព្រោះកាលមិនទាន់លះបាន កំណត់ដឹងខន្ធទាំងឡាយ កិលេសពួកណាគប្បីកើតឡើង កិលេសទាំងនោះដែលមិនទាន់កើត រមែងមិនកើត ដែលមិនទាន់កើតឡើង រមែងមិនកើតឡើង ដែលមិនទាន់ប្រាកដ រមែងមិនប្រាកដ ព្រោះមិនទាន់បានកំណត់ដឹងខន្ធទាំងឡាយដោយមគ្គ គប្បីឲ្យសេចក្តីនេះជាក់ច្បាស់ ពោល

ដោយថ្នាំដែលផឹក ដើម្បីមិនឲ្យស្រីដែលកូននៅខ្ចី ប្រសូតទៀត និងដើម្បីឲ្យអ្នកជំងឺជារោគ ។ មគ្គលះកិលេសពួកណា បានយ៉ាងនេះ កិលេសទាំងនោះមិនគប្បីពោលថា ជាអតីត អនាគត ឬ បច្ចុប្បន្ន ម្យ៉ាងទៀត មិនមែនមគ្គរមែងលះកិលេសមិនបាន ។ មគ្គរមែង លះកិលេសពួកណាបាន លោកពោលថា **ឧប្បន្នានំ ធាបកានំ** ជាដើម សំដៅដល់កិលេសទាំងនោះ ។ មគ្គមិនមែនលះកិលេសបានតែម្យ៉ាងប៉ុណ្ណោះ តែព្រោះមិនទាន់លះកិលេសទាំងឡាយបាន ឧបាទិន្នកក្ខន្ធគប្បីកើតឡើង តែងលះបាននូវឧបាទិន្នកក្ខន្ធនោះ ។ សមដូចលោកពោលទុកក្នុងចូឡនិទ្ទេសថា ធម៌ទាំងឡាយណា គឺនាម និងរូបគប្បីកើតក្នុងសង្សារ មានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរ-លែងតែកំណើត ៧ ចេញ ធម៌ទាំងនុ៎ះ រលត់ រម្ងាប់ ដល់នូវការវិនាសស្ងប់រម្ងាប់ ក្នុងសោតាបត្តិមគ្គនោះ ព្រោះកិរិយារលត់អភិសង្ខារវិញ្ញាណដោយសោតាបត្តិមគ្គញាណ ។

គប្បីជ្រាបសេចក្ដីពិស្ដារដូចតទៅនេះ ។ មគ្គរមែងចេញអំពីឧបាទិន្ន និងអនុបាទិន្ន គឺវិបាក និងកម្ម ដោយប្រការដូច្នេះ ។ តែបើពោលដោយភពសោតាបត្តិមគ្គ រមែងចេញអំពីអបាយភព សកទាគាមិមគ្គ រមែងចេញអំពីសុគតិភពដោយចំណែកមួយ ។ អនាគាមិមគ្គ រមែងចេញអំពីសុគតិកាមភព ។ អរហត្តមគ្គ ចេញចាកភពទាំងពួង កាលបើដូច្នោះ ការចម្រើនដើម្បីកើតឡើងនៃកុសលធម៌ដែលមិនទាន់កើតឡើងក្នុងខណៈនៃមគ្គដូចម្ដេច ដើម្បីការតាំងមាំនៃកុសលធម៌ដែលកើតឡើងហើយដូចម្ដេច ។ ដើម្បីការប្រព្រឹត្តិទៅនៃមគ្គ

នោះឯង ។ ព្រោះមគ្គ កាលប្រព្រឹត្តទៅ លោកពោលថា មគ្គមិនទាន់កើតហើយ ព្រោះមិនធ្លាប់កើតមកអំពីមុន ។ ព្រោះបុគ្គលពោលមកកាន់ឋានៈដែលមិនធ្លាប់មក ឬសោយអារម្មណ៍ដែលមិនធ្លាប់សោយ រមែងពោលថា អញមកកាន់ឋានៈដែលមិនធ្លាប់មកហើយ ។ ឬថា អញសោយអារម្មណ៍ ដែលមិនធ្លាប់សោយហើយ ការប្រព្រឹត្តិទៅនៃមគ្គនោះឯង ឈ្មោះថា **ឋិតិ** ព្រោះហេតុនោះគួរពោលថា **ឋិតិយា ភាវេតិ** ឲ្យមគ្គចម្រើនដើម្បីការតាំងមាំ ។ សេចក្ដីសង្ខេបក្នុងឥទ្ធិបាទ លោកពោលទុកហើយក្នុងចេតោខីលសូត្រ ។

[ ៩៧ ] ឈ្មោះថា **ឧបសមគាមី** ព្រោះដល់នូវការស្ងប់រម្ងាប់ ឬដើម្បីការស្ងប់កិលេស ។ ឈ្មោះថា **សម្ពោធគាមី** ព្រោះដល់នូវការត្រាស់ដឹង ឬដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងមគ្គ ។

[ ៩៩ ] បទថា **វិវេកនិស្សិតា** ជាដើម លោកពោលទុកហើយ ក្នុងការសង្រួម ក្នុងអាសវៈទាំងពួង ។ នេះជាសេចក្ដីសង្ខេបក្នុងបទនេះ ។ ឯពោធិបក្ខិយកថានេះ លោកពោលទុកក្នុងវិសុទ្ធិមគ្គដោយពិស្ដារហើយ ។

[ ១០១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងវិមោក្ខកថាដូចតទៅនេះ ។ បទថា **វិមោក្ខេ** ឈ្មោះថា វិមោក្ខព្រោះអត្ថដូចម្ដេច ព្រោះអត្ថថា រួចផុតល្អ ។ វិមោក្ខនេះ គឺអ្វី វិមោក្ខមានអត្ថថា រួចផុតដោយល្អចាកធម៌ដែលជាសត្រូវ ឈ្មោះថា **អធិមុច្ចនដ្ឋោ** មានអត្ថថា រួចផុតល្អ ។ មានអត្ថថា ផុតដោយល្អចាកអារម្មណ៍ទាំងឡាយ ដោយអំណាចការមិនត្រេកអរ ។ លោកអធិប្បាយទុកថា វិមោក្ខ ប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់នូវការកង្វល់ ដោយការ

មិនចាំបាច់សន្កត់សន្កិន ដូចទារកសណ្ដូកអវយវៈដេកលើភ្លៅឪពុក ។ តែសេចក្ដីនេះមិនមាននៅក្នុងវិមោក្ខចុងក្រោយ ។ មានក្នុងវិមោក្ខដើមៗ ទាំងអស់ ។ ក្នុងបទថា **រូបី រូបានិ បស្សតិ** មានអធិប្បាយដូចតទៅនេះថា រូបជ្ឈានដែលឲ្យកើតដោយអំណាចនីលកសិណជាដើម ក្នុងបណ្ដូកសិណ មានសក់ខាងក្នុងជាដើម ឈ្មោះថា រូប ។ ឈ្មោះថា **រូបី** ព្រោះមានរូបជ្ឈាននោះ ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** គឺ ឃើញរូប មាននីលកសិណជាដើមខាងក្រៅ ដោយឈានចក្ខុ ។ ដោយបទនេះ លោកសម្ដែងដល់រូបាវចរជ្ឈាន ៤ នៃបុគ្គល ដែលមានឈានឲ្យកើតហើយក្នុងកសិណទាំងឡាយ មានវត្ថុខាងក្នុង និងខាងក្រៅ ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** គឺមិនមានរូបសញ្ញាក្នុងខាងក្នុង អធិប្បាយថា មានរូបាវចរជ្ឈាន ដែលមិនទាន់កើតក្នុងកសិណ មានសក់របស់ខ្លួន ។ ដោយបទនេះ លោកសម្ដែងដល់រូបាវចរជ្ឈាននៃបុគ្គលមានឈាន ដែលធ្វើបរិកម្មយ៉ាងល្អទុកខាងក្រៅ ហើយឲ្យកើតខាងក្រៅ ។ ដោយបទថា **សុភន្តេវ អធិមុត្តោ ហោតិ** នេះលោកសម្ដែងដល់ឈានក្នុងវណ្ណកសិណ មាននីលកសិណជាដើមដែលវិសុទ្ធ ក្នុងបទនោះ ការបងចិត្តថា ស្អាត មិនមានក្នុងអប្បនាខាងក្នុងក៏ពិត តែសូម្បីដូច្នោះ ព្រះយោគាវចរណា ធ្វើសុភកសិណឲ្យជាអារម្មណ៍ បរិសុទ្ធដោយល្អ ព្រោះព្រះយោគាវចរនោះ រមែងដល់នូវភាពជាបុគ្គលគួរពោលថា ជាអ្នកបង្អោនចិត្តជឿថា ស្អាត ។ ដូច្នោះ ទើបលោកសម្ដែងទុកយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គ លោកពោលទុកថា ឈ្មោះថា វិមោក្ខ ព្រោះជាអ្នក

បង្អោនចិត្តជឿថា ស្អាតដូចម្តេច ។ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតចងពៀរ ឥតព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួនឲ្យស្មើនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង សត្វទាំងឡាយដែលគេមិនគួរខ្ពើមរអើម ព្រោះបានចម្រើនមេត្តា ភិក្ខុមានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ។បេ។ ភិក្ខុមានចិត្តប្រកបដោយមុទិតា ផ្សាយទៅកាន់ទិសទី ១ ។បេ។ ភិក្ខុមានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ។បេ។ យ៉ាងនេះឯងឈ្មោះថា វិមោក្ខព្រោះជាអ្នកបង្អោនចិត្តជឿថាស្អាត ។

ក្នុងបទថា **សព្វសោ រូបសញ្ញានំ** ជាដើម បទដែលគួរពោលទាំងអស់លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **អយំ អដ្ឋមោ វិមោក្ខោ** នេះជាវិមោក្ខទី ៨ គឺនេះឈ្មោះថា វិមោក្ខដ៏ឧត្តមទី ៨ ព្រោះលះខន្ធ ៤ រួចផុតហើយ ដោយប្រការទាំងពួង ។

[ ១០២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនកថាដូចតទៅនេះ ។ បទថា **អភិភាយតនានិ** គឺហេតុជាគ្រឿងគ្របសង្កត់ ។ គ្របសង្កត់ដូចម្តេច គ្របសង្កត់ធម៌ដែលជាសត្រូវខ្លះ អារម្មណ៍ខ្លះ ។ ព្រោះអភិភាយតនៈទាំងនោះ រមែងគ្របសង្កត់ធម៌ដែលជាសត្រូវ ដោយភាពជាសត្រូវ ។ គ្របសង្កត់

អារម្មណ៍ ព្រោះភាពដែលបុគ្គលជាអ្នកក្រៃលែងដោយញាណ ។

ម្យ៉ាងទៀត ក្នុងបទជាដើមថា **អជ្ឈត្តំ រូបសញ្ញី** បុគ្គលមានសញ្ញាក្នុងរូបខាងក្នុង មានសេចក្តីដូចតទៅនេះ ឈ្មោះថា **រូបសញ្ញី** គឺបុគ្គលសម្គាល់ក្នុងរូបខាងក្នុង ដោយអំណាចបរិកម្មរូបខាងក្នុង ។ ព្រោះកាលធ្វើបរិកម្មនីលបរិកម្មក្នុងខាងក្នុង រមែងធ្វើត្រង់សក់ដែលល្អ ឬត្រង់កែវភ្នែក ។ បើធ្វើបីតបរិកម្ម រមែងធ្វើត្រង់ខ្លាញ់ខាប់ ត្រង់ស្បែក ត្រង់បាតដៃ ត្រង់បាតជើង ឬត្រង់ពណ៌លឿងនៃភ្នែក ។ កាលធ្វើលោហិតបរិកម្ម រមែងធ្វើត្រង់សាច់ ត្រង់លោហិត ត្រង់អណ្តាត និងទីពណ៌ក្រហមនៃភ្នែក ។ កាលនឹងធ្វើឱទាតបរិកម្ម រមែងធ្វើត្រង់ឆ្អឹង ត្រង់ធ្មេញ ត្រង់ក្រចក ឬត្រង់ទីពណ៌សនៃភ្នែក ។ តែកសិណនោះមិនខៀវល្អ មិនលឿងល្អ មិនក្រហមល្អ មិនសល្អ រមែងជាកសិណមិនបរិសុទ្ធ ។

បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** សេចក្តីថា និមិត្តខាងក្រៅ កើតឡើងខាងក្នុង ព្រោះធ្វើបរិកម្មនៃបុគ្គលណា បុគ្គលនោះហៅថា បុគ្គលម្នាក់មានការសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅ ដោយអំណាចនៃបរិកម្មខាងក្នុង និងនៃអប្បនាខាងក្រៅយ៉ាងនេះ ។ បទថា **បរិត្តានិ** គឺមិនធំ ។ បទថា **សុវណ្ណទុព្វណ្ណានិ** គឺមានពណ៌ល្អ ឬមានពណ៌អាក្រក់ ។ គប្បីជ្រាបថា នេះលោកពោលថា ជាអភិភាយតនៈ ដោយអំណាចរូបតូចនោះឯង ។ បទថា **តានិ អភិភុយ្យ** សេចក្តីថា ដូចបុគ្គលមានទឹករំលាយអាហារល្អ បានអាហារ ត្រឹមតែមួយវែក គិតថា មានអ្វីដែលគួរបរិភោគក្នុងអាហារនេះ

ទើបចាប់ យកមកសូនជាពំនូតតែមួយ យ៉ាងណា បុគ្គលដែលក្រៃលែងដោយញាណ មានញាណមុតស្រួច គិតថា មានអ្វីដែលគួរចូលដល់ក្នុងអារម្មណ៍តូចតាចនេះ ។ នេះមិនមែនការៈរបស់អញ ទើបគ្របសង្កត់រូបទាំងនោះ ចូលដល់សមាបត្តិ ។ អធិប្បាយថា ញ៉ាំងអប្បនាឲ្យដល់ក្នុងរូបនេះ ព្រមគ្នានឹងការកើតនៃនិមិត្ត ។ លោកពោលដល់ការចងចិត្តក្នុងរូបនោះ ដោយបទនេះថា **ជានាមិ បស្សាមិ** ខ្ញុំដឹង ខ្ញុំឃើញ ។ បុគ្គលនោះ កាលចេញចាកសមាបត្តិហើយ មិនចូលសមាបត្តិក្នុងខាងក្នុង ។

បទថា **ឯវំ សញ្ញី ហោតិ** គឺដោយអភោគសញ្ញាខ្លះ ដោយឈានសញ្ញាខ្លះ អភិភវសញ្ញា គឺការសម្គាល់ដោយការគ្របសង្កត់ រមែងមានដល់បុគ្គលនោះ សូម្បីខាងក្នុងសមាបត្តិ ។ ឯអាភោគសញ្ញា គឺការសម្គាល់ដោយការចងចិត្ត រមែងមានដល់បុគ្គលដែលចេញអំពីសមាបត្តិ ។ បទថា **អប្បមាណានិ** គឺមានប្រមាណច្រើន បានដល់ច្រើន ។ គប្បីជ្រាបអត្ថ ក្នុងបទថា **អភិភុយ្យ** ដូចតទៅនេះថា ដូចបុរសដែលបរិភោគច្រើន បានអាហារមួយពេល ក៏គិតថា អាហារដទៃចូរមាន អាហារដទៃចូរមាន អាហារមួយពេលនឹងធ្វើអ្វីដល់អញបាន ទើបមិនឃើញអាហារនោះច្រើនគ្រប់គ្រាន់ យ៉ាងណា បុគ្គលដែលក្រៃលែងដោយញាណ មានញាណមុតស្រួច គិតថា អញគប្បីចូលដល់ញាណនេះបានដូចម្តេច ញាណនេះមានប្រមាណតិច ការៈក្នុងការធ្វើភាពជា អ្នកមានចិត្ត មានអារម្មណ៍តែមួយមានដល់អញ ទើបគ្របសង្កត់រូបទាំងនោះ ហើយចូលសមាបត្តិ ។ អធិប្បាយថា ញ៉ាំងអប្បនាឲ្យ

ដល់ក្នុងចិត្តនេះ ព្រមគ្នានឹងឲ្យដល់និមិត្ត ។ បទថា **អជ្ឈត្តំ អរូបសញ្ញី** សេចក្ដីថា មិនមានការសម្គាល់បរិកម្មក្នុងរូបខាងក្នុង ព្រោះមិនបាន ឬមិនមានប្រយោជន៍ ។ បទថា **ឯកោ ពហិទ្ធា រូបានិ បស្សតិ** សេចក្ដីថា បរិកម្មក្ដី និមិត្តក្ដី របស់បុគ្គលណាកើតឡើង ខាងក្រៅ ។ បុគ្គលនោះមានការសម្គាល់ក្នុងអរូបខាងក្នុង ដែលកើតឡើង ដោយអំណាចបរិកម្ម និងអប្បនាខាងក្រៅយ៉ាងនេះ លោកពោលថា បុគ្គលម្នាក់ឃើញរូបខាងក្រៅ ។ បទដ៏សេសក្នុងបទនេះ មានន័យដូចពោលហើយ ក្នុងអភិភាយតនៈទី ៤ ។ ក្នុងអភិភាយតនៈ ៤ នេះ អភិភាយតនៈតូចតាច មកហើយដោយអំណាចវិតក្កចរិត អភិភាយតនៈមិនមានប្រមាណមកហើយដោយអំណាចមោហចរិត ។ រូបពណ៌មាស មកហើយដោយអំណាច ទោសចរិត ពណ៌អាក្រក់មកហើយដោយអំណាចរាគចរិត ។ រូបទាំងនេះ ជាទីសប្បាយនៃបុគ្គលទាំងនោះ ។ ម្យ៉ាងទៀត ការដែលរូបជាទីសប្បាយ នៃបុគ្គលទាំងនោះ លោកពោលទុកក្នុងចរិតនិទ្ទេសនៃវិសុទ្ធិមគ្គ ដោយពិស្ដារហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនៈទី ៥ ជាដើមដូចតទៅនេះ បទថា **នីលានិ** លោកពោលសង្គ្រោះយកពណ៌ទាំងអស់ ។ បទថា **នីលវណ្ណានិ** គឺខៀវដោយពណ៌ ។ បទថា **នីលនិទស្សនានិ** លោកអធិប្បាយថា វណ្ណៈមិនលាយឡំមិនមានឱកាសប្រាកដដោយការសម្ដែងឲ្យឃើញជាពណ៌ខៀវសុទ្ធ។ ឯបទថា **នីលនិភាសានិ** គឺរស្មីខៀវដែលលោកពោលដោយអំណាចពន្លឺ ។ អធិប្បាយថា មានរស្មីខៀវ ប្រកបដោយរស្មីខៀវ ។ ដោយបទនេះ លោក

សម្តែងដល់ភាព ដែលរូបទាំងនោះបរិសុទ្ធ ។ ពិតហើយលោកពោលអភិភាយតនៈទាំង ៤ នេះ ដោយអំណាចពណ៌បរិសុទ្ធ ។

បទថា **ឧម្មារបុប្ផំ** គឺផ្កាត្រកៀត ព្រោះផ្កានេះសូម្បីនៅខ្ចី ក៏ខៀវសុទ្ធ ។ តែផ្កាអញ្ចែនជាដើម ប្រាកដជាផ្កាត្រកូលស ។ ព្រោះដូច្នោះ ទើបលោកកាន់យកផ្កាត្រកៀតនេះឯង មិនកាន់យកផ្កាអញ្ចែនជាដើមនោះទេ ។ បទថា **ពារាណសេយ្យកំ** គឺសំពត់ធ្វើក្នុងក្រុងពារាណសី ។ បានឮថា ក្នុងក្រុងពារាណសីនោះ សម្លីក៏ទន់ អ្នកថ្លៃសំឡីក៏ឈ្លាស ទឹកក៏ស្អាតត្រជាក់ល្អ ព្រោះដូច្នោះ ទើបសំពត់រលោងទាំងសងខាង ។ ក្នុងសងខាងប្រាកដរលោងទន់ល្អ ។ ក្នុងបទថា **បីតានិ** ជាដើមគប្បីជ្រាបដោយន័យ នេះដូចគ្នា ។ កាលកំណត់នីលកសិណ រមែងកាន់យកនិមិត្តក្នុងពណ៌ខៀវ ។

ម្យ៉ាងទៀត ក្នុងកសិណនេះ ការធ្វើកសិណ ការបរិកម្ម និងបែបនៃអប្បនា មានជាអាទិ គឺក្នុងផ្កា ក្នុងសំពត់ ឬក្នុងវណ្ណធាតុទាំងអស់ លោកពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។ បទថា **អភិញ្ញាវោសានបារមិប្បត្តា** គឺសាវកទាំងឡាយចម្រើនធម៌ទាំងនោះ ក្នុងសតិប្បដ្ឋានជាដើមអំពីមុន ក្រៅអំពីនេះហើយ សម្រេចអរហត្ត ឈ្មោះថា ជាអ្នកដល់នូវបារមីជាទីបំផុតនៃអភិញ្ញា ។ ម្យ៉ាងទៀត សាវកទាំងឡាយ ក៏ឈ្មោះថា ជាអ្នកសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ព្រោះភាពជាអ្នក មានការជំនាញដែលសន្សំមកហើយ ក្នុងអភិភាយតនៈទាំង ៨ នេះ ។

[ ១០៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកសិណកថាដូចតទៅនេះ ។ ឈ្មោះថា

**កសិណា** ព្រោះអត្ថថា ទាំងមូល ។ ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាខេត្ត ឬជាទីតាំងមាំនៃធម៌ទាំងឡាយ មានកសិណនោះជាអារម្មណ៍ ។ បទថា **ឧទ្ធំ** គឺបែរមុខទៅកាន់អាកាសខាងលើ ។ បទថា **អធោ** គឺ បែរមុខទៅកាន់ផែនដីខាងក្រោម ។ បទថា **តិរិយំ** គឺកំណត់ដោយជុំវិញ ដូចបរិវេណនៃផ្ទៃដី ។ បុគ្គលខ្លះចម្រើនកសិណខាងលើប៉ុណ្ណោះ ។ បុគ្គលខ្លះចម្រើនកសិណខាងក្រោម ។ បុគ្គលខ្លះចម្រើនកសិណជុំវិញ ដោយហេតុនោះ បុគ្គលបំណងនឹងឃើញរូប ដូចញុំាងពន្លឺឲ្យផូរផង់ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បឋវីកសិណមេកោ សញ្ជានាតិ ឧទ្ធំ អធោ តិរិយំ** ជាដើម ។ បទថា **អទ្វយំ** គឺក្នុងទិសតូចធំ ។ បទនេះលោក ពោលដើម្បីទៅដល់ការមិនមានដទៃនៃទិសមួយ ដូចបុគ្គលចូលទៅកាន់ស្ទឹង ទឹកប៉ុណ្ណោះរមែងមានក្នុងទិសទាំងអស់ មិនមែនដទៃ យ៉ាងណា ។ បឋវីកសិណក៏ដូច្នោះដូចគ្នា រមែងជាបឋវីកសិណប៉ុណ្ណោះ ។ កសិណនោះ មិនមានកសិណដទៃលាយឡំ ។ ក្នុងកសិណទាំងអស់ក៏មានន័យនេះ ។ បទថា **អប្បមាណំ** នេះលោកពោលដោយអំណាចកសិណនោះផ្សាយទៅមិនមានប្រមាណ ។ ព្រោះកសិណនោះផ្សាយទៅដោយចិត្ត រមែងផ្សាយទៅរហូត វង់កសិណប៉ុណ្ណោះ ។ រមែងកាន់យកប្រមាណថា នេះខាងដើមនៃកសិណនោះ នេះជាកណ្តាល ។

ម្យ៉ាងទៀត ក្នុងបទថា **វិញ្ញាណកសិណំ** មានសេចក្តីដូចតទៅនេះថា វិញ្ញាណដែលប្រព្រឹត្តទៅហើយ ក្នុងអាកាសដែលបើកកសិណហើយ ។ បទថា **វិញ្ញាណកសិណំ** នោះ គប្បីជ្រាបភាពដែលកសិណនោះ ទាំងខាងលើ

ខាងក្រោម និងខាងទទឹង ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅហើយនោះ ដោយអំណាចអាកាសដែលបើកកសិណ ក្នុងឧគ្ឃាដិមាកាស ដោយអំណាចរបស់កសិណ នេះជាសេចក្ដីសង្ខេបក្នុងបទនេះ ។ ឯបបរិកសិណជាដើមនេះ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ដោយពិស្តារតាមន័យនៃការចម្រើនកម្មដ្ឋាន ។ សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា សាវកទាំងឡាយជាអ្នកសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ដោយភាពជាអ្នកមានការជំនាញដែលសន្សំទុកហើយ ។

[ ១០៨ ] ក្នុងឈាន ៤ ដែលជាលំដាប់បន្តអំពីនេះក៏ដូចគ្នា ។ ឯបទដែលគួរពោលក្នុងទីនេះ ក៏បានពោលទុកហើយ ក្នុងមហាអស្សបុរសូត្រ ។ តែក្នុង វិបស្សនាញាណ លោកពោលអត្ថនៃបទជាដើមថា **រូបី** ជាដើម ។

បទថា **ឯត្ថ សិតំ ឯត្ថ បដិពទ្ធំ** បានដល់ វិញ្ញាណអាស្រ័យនឹងកាយ គឺមហាភូតរូប ៤ នេះ ។ បទថា **សុភោ** គឺស្អាត ។ បទថា **ជាតិមា** គឺតាំងនៅក្នុងអាការដែលបរិសុទ្ធ ។ បទថា **សុបរិកម្មកតោ** គឺនាយជាងច្នៃល្អហើយ មិនមានថ្ម និងក្រួស ។ បទថា **អច្ឆោ** គឺផូរផង់ក្នុងខ្លួន បរិសុទ្ធក្នុងខ្លួន ។ បទថា **វិប្បសន្នោ** គឺភ្លឺរុងរឿង ។ បទថា **សព្វាការសម្បន្នោ** គឺបរិបូណ៌ដោយអាការទាំងពួង មានខាត់ និងចោះជាដើម ។ លោកសម្ដែងដល់សម្បត្តិរបស់ពណ៌ ដោយបទថា **នីលំ** ជាដើម ព្រោះអំបោះដែលដោតទុកដូច្នោះប្រាកដ ។ បទថា **ឯវមេវ** នេះ គប្បីជ្រាបការប្រៀបធៀបយ៉ាងនោះ ។ ព្រោះករជកាយ ដូចកែវមណី វិបស្សនាញាណ ដូចអំបោះដែលដោតទុក ភិក្ខុអ្នកបានវិបស្សនា ដូចបុរស មានចក្ខុ ។ កាលដែលដឹងច្បាស់

កាយដែលមានមហាភូតរូប ៤ នៃភិក្ខុដែលអង្គុយកំណត់វិបស្សនាញាណ ដូចការដែលដឹងច្បាស់នូវកែវមណីនៃអ្នកដាក់កែវមណីទុកក្នុងដៃ ហើយពិចារណាមើលថា នេះកែវមណីដូច្នោះ ។ កាលដែលដឹងច្បាស់នូវអារម្មណ៍មានផស្សៈជាគម្រប់ ៥ ក្តី ចិត្តចេតសិកទាំងពួងក្តី វិបស្សនាញាណក្តី របស់ភិក្ខុដែលអង្គុយកំណត់វិបស្សនាញាណ ដូចកាលដែលដឹងច្បាស់នូវអំបោះថា អំបោះនេះដោតក្នុងកែវមណីនោះ ដូច្នោះ ។ ការចម្រើនញាណដូចម្តេច ។ ព្រោះការដឹងច្បាស់នូវញាណនោះ ជាការដឹងច្បាស់ បុគ្គលនោះឯង ។ម្យ៉ាងទៀត វិបស្សនាញាណនេះ ជាលំដាប់របស់មគ្គ ។ កាលបើដូច្នោះព្រោះកាលប្រារព្ធវារៈនៃអភិញ្ញា ទើបមិនមានវារៈក្នុងរវាងនៃវិបស្សនាញាណនោះ ។ ដូច្នោះ ទើបលោកសម្តែងទុកក្នុងទីនេះនោះឯង ។ ម្យ៉ាងទៀត ព្រោះការខ្លាចចំពោះភ័យកើតដល់បុគ្គលមិនពិចារណា ដោយអំណាចការមិនទៀងជាដើម បុគ្គលបាននូវសំឡេងគួរខ្លាចដោយទិព្វសោត បុគ្គលរឭកដល់ខន្ធដែលគួរខ្លាច ដោយរឭកជាតិបាន បុគ្គលឃើញរូបគួរខ្លាច ដោយទិព្វចក្ខុ ។ ដូច្នោះ ទើបលោកមិនសម្តែងបទនោះទុកក្នុងទីនេះ សូម្បីដើម្បីប្រុងប្រៀបហេតុ បន្ទោបង់នូវការខ្លាចនៃបុគ្គលមិនបានធ្វើការពិចារណា ដោយអំណាចការមិនទៀងជាដើម ដែលសម្រេចអភិញ្ញានោះ ។ សូម្បីក្នុងទីនេះ ក៏គប្បីជ្រាបថា សាវកទាំងឡាយសម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញា ដោយអរហត្ត ។

[ ១០៩ ] គប្បីជ្រាបព្រោះភាពជាបុគ្គលមានការជំនាញក្នុងមនោមយិទ្ធិ ដូចតទៅនេះ ក្នុងបទទាំងនោះ បទថា **មនោមយំ** គឺកើតអំពីចិត្ត ។ បទថា

**សព្វង្គប្បច្ចង្គី** គឺប្រកបដោយអង្គទាំងអស់ និងដោយអង្គ ៥ ។ បទថា **អហីនិន្ទ្រិយំ** គឺមានឥន្ទ្រិយមិនខ្វះខាតដោយសណ្ឋាន ព្រោះរូបនិម្មិតរបស់អ្នកមានឫទ្ធិ ដូចគ្នាតែមួយនឹងរូបជាមួយរូបនោះ ដោយអាការគ្រប់យ៉ាងយ៉ាងនេះ គឺបើអ្នកមានឫទ្ធិស រូបនិម្មិតនោះក៏ស បើអ្នកមានឫទ្ធិមានត្រចៀកមិនបានចោះ រូបនិម្មិតនោះក៏មានត្រចៀកមិនបានចោះ ។ សូម្បីឧបមា ៣ ថា **មុញ្ជម្ហា ឦសិកំ** គប្បីទាញចេញ អំពីស្មៅយាប្លងជាដើម លោកពោលដើម្បីសម្តែងភាពដូចគ្នា ។ ព្រោះបណ្តូលស្មៅយាប្លងនោះ ក៏ដូចស្មៅយាប្លងនោះឯង ។ កាលទាញដាវចេញអំពីស្រោម កាលទាញសស្ត្រាចេញអំពីស្រោម ដាវសស្ត្រា ក៏ដូចគ្នានឹងស្រោមនោះឯង ។ សូម្បីបទថា **ករណ្ឌា** នេះ ជាឈ្មោះរបស់ស្រោមពស់ មិនមែនជាឈ្មោះរបស់ប្រអប់ឫស្សី ។ ព្រោះស្រោមពស់ក៏ដូចគ្នានឹងពស់ ។ ក្នុងបទនោះ លោកសម្តែងដូចទាញ ដោយដៃថា បុរសគប្បីទាញពស់ចេញអំពីស្រោម ដែលពិត គប្បីជ្រាបថា ទាញដោយចិត្តរបស់បុរសនោះឯង ។ ព្រោះធម្មតា ពស់នេះ រមែងសក សំណកដោយខ្លួនឯង ដោយហេតុទាំង ៤ គឺតាំងនៅក្នុងកំណើតរបស់ខ្លួន ១ អាស្រ័យចន្លោះឈើ ឬចន្លោះដើមឈើ ១ ដូចស៊ីរាងកាយដោយកម្លាំង គឺព្យាយាមទាញខ្លួនចេញអំពីសំណក ១ នឿយណាយក្នុងសំណកចាស់ ១ មិនអាចសកសំណកដោយវិធីដទៃអំពីនោះបាន ។ ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលបទនេះ សំដៅដល់ការទាញដោយចិត្ត ។ ការប្រៀបធៀបក្នុងបទនេះ មានដូច្នេះថា សរីរៈនៃភិក្ខុនេះដូចគ្នានឹងស្មៅយាប្លងជាដើម ។ រូបនិម្មិតដូច

គ្មានទីនបណ្ឌលជាដើម ។ ក្នុងទីនេះ នឹងពោលដល់វិធីនិម្មិត ដោយការពោលដល់អភិញ្ញា ៥ មានឥទ្ធិវិធជាដើម លោកពោលទុកពិស្តារហើយ ក្នុងវិសុទ្ធិមគ្គគ្រប់ប្រការ គប្បីជ្រាបតាមន័យដូចពោលហើយ ក្នុងវិសុទ្ធមគ្គនោះឯង ព្រោះក្នុងទីនេះ លោកពោលបន្ថែមត្រឹមតែឧបមាប៉ុណ្ណោះ ។ គប្បីឃើញភិក្ខុដែលបានញាណ គឺឥទ្ធិវិធ ដូចជាងស្មូនផ្ទាំងអ្នកឈ្លាស ដូច្នោះ ។ គប្បីឃើញឥទ្ធិវិធញាណដូចដីស្អិត ដែលស្មូនផ្ទាំងតាក់តែងយ៉ាងល្អ ដូច្នោះ ។ គប្បីឃើញការសម្តែងឫទ្ធិរបស់ភិក្ខុនោះ ដូចការធ្វើឲ្យជាភាជនៈប្រភេទផ្សេងៗ តាមដែលខ្លួនត្រូវការហើយ ។ សូម្បីក្នុងទីនេះ គប្បីជ្រាបថា សាវកទាំងឡាយដែលសម្រេចបារមីជាទីបំផុតនៃអភិញ្ញា ដោយអំណាចនៃភាពជាអ្នក មានការជំនាញដែលសន្សំទុកហើយនោះឯង ។ ក្នុងអភិញ្ញា ៤ ដទៃអំពីនេះ ក៏ដូចគ្នា ។

[ ១១១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមានៃទិព្វសោតធាតុដូចតទៅនេះ ។ បទថា **សង្ខធមោ** គឺបុរសផ្លុំស័ង្ខ ។ បទថា **អប្បកសិរេនេវ** គឺដោយមិនលំបាកនោះឯង ។ បទថា **វិញ្ញាបេយ្យ** គឺឲ្យដឹង ។ គប្បីឃើញថា កាលដែលព្រះយោគីដឹងច្បាស់ នូវសំឡេងរបស់មនុស្សទាំងជិត និងឆ្ងាយ និងនិព្វាន ដូចកាលបុរសផ្លុំស័ង្ខ ឲ្យដឹងច្បាស់ទៅក្នុងទិសទាំង ៤ យ៉ាងនេះ សំឡេង ស័ង្ខនោះក៏ប្រាកដច្បាស់ដល់សត្វទាំងឡាយ ដែលកំណត់ថា នេះជាសំឡេងស័ង្ខ ដូច្នោះ។

[ ១២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបមានៃចេតោបរិយញ្ញាណដូចតទៅនេះ។ បទថា **ទហរោ** គឺកំលោះ ។ បទថា **យុវា** គឺប្រកបដោយភាពជាកំលោះ ។ បទថា **មណ្ឌនកជាតិកោ** គឺនៅកំលោះក្រមុំ ក៏មិនខ្ជិល សូម្បីមានសំពត់

និងរាងកាយសៅហ្មង ក៏ចូលចិត្តតែងខ្លួន ។ អធិប្បាយថា ផ្ងូតទឹកមួយថ្ងៃ ២-៣ ដង ហើយស្លៀកដណ្តប់សំពត់ស្អាត និងតែងខ្លួន ។ បទថា **សកណិកំ** គឺមុខមានទោស ដោយទោសឯណាមួយ ដូចជាប្រជ្រុយ មុន រមាស់ជាដើម ។ ក្នុងបទនោះ គប្បីជ្រាបថា ប្រៀបដូចបុរសនោះឆ្លុះមើលស្រមោលមុខ ទោសនៃមុខរមែងប្រាកដយ៉ាងណា កាលភិក្ខុអង្គុយកំណត់ចិត្ត ដោយចេតោបរិយ-ញ្ញាណក៏ដូច្នោះ ចិត្ត ១៦ យ៉ាង របស់អ្នកដទៃរមែងប្រាកដ ។ បទដែលគួរពោលក្នុងឧបមានៃបុព្វេនិវាសញ្ញាណទាំងអស់ជាដើម លោកពោលទុកហើយក្នុងមហាអស្សបុរសូត្រ ។

[ ១០៦ ] បទថា **អយំ ខោ ឧទាយិ បញ្ចមោ ធម្មោ** គឺលោកពោលធម៌ទី ៥ ធ្វើ បព្វ: ១៩ ឲ្យជាធម៌តែមួយដោយបដិបទា ។ ឧបមាដូចលោកធ្វើបព្វ: ១១ ក្នុងអដ្ឋកនាគសូត្រឲ្យជាធម៌តែមួយ ដោយអំណាចពាក្យសួរយ៉ាងណា គប្បីជ្រាបថា បព្វ: ១៩ ក្នុងទីនេះ លោកធ្វើឲ្យជាធម៌តែមួយ ដោយអំណាចបដិបទាយ៉ាងនោះ ។ គប្បីជ្រាបសាវកទាំងឡាយ សម្រេចបារមីដែលជាទីបំផុតនៃអភិញ្ញាក្នុងចំណែកទាំងឡាយ ៨ តាមលំដាប់ ក្នុងបណ្តាធម៌ ១៩ បព្វ:នេះ ក្នុងវិបស្សនាញាណ និងអាសវក្ខយញ្ញាណ ដោយអំណាចអរហត្ត ។ ក្នុងបទដ៏សេសទាំងឡាយ គប្បីជ្រាបដោយអំណាច នៃភាពជាបុគ្គលមានជំនាញដែលសន្សំមកហើយ ។ បទដ៏សេស ក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ។

**អដ្ឋកថាមហាសកុលុទាយិសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សមណមុណ្ឌិកសូត្រទី ៨

[ ១១៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង បរិព្វាជកឈ្មោះ ឧគ្គាហមានៈ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលា ១ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ ជាមួយនឹងបរិព្វាជកបរិសទ្យជាច្រើន ចំនួន ៥០០ នាក់ ។ គ្រានោះ នាយជាងឈើឈ្មោះ បញ្ចកង្គៈ ចេញអំពីក្រុងសាវត្ថី ដើម្បីទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃ ។ បញ្ចកង្គៈនាយជាងឈើ មានសេចក្តីត្រិះរិះដូច្នេះថា ( កាលនេះ ) ជាកាលមិនទាន់គួរនឹងគាល់ព្រះមានព្រះភាគនៅឡើយ ដ្បិតព្រះមានព្រះភាគ កំពុងសម្ងំ ទាំងពួកភិក្ខុអ្នកមានភាវនាជាប់ក្នុងចិត្ត ក៏មិនទាន់មានវេលាគួរនឹងទៅជួប ព្រោះពួកភិក្ខុអ្នកបានភាវនាជាប់ក្នុងចិត្ត ក៏កំពុងសម្ងំដែរ បើដូច្នោះ គួរតែអញចូលទៅរកឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ ឯអារាមរបស់ព្រះនាងមល្លិកា ដែលមានសាលា ១ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ ។ បញ្ចកង្គៈនាយជាងឈើ ក៏ចូលទៅកាន់អារាម របស់ព្រះនាងមល្លិកា ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវលទ្ធិ ។

[ ១១៨ ] សម័យនោះឯង ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ

អន្ទុយជាមួយនឹងពួកបរិព្វាជកបរិសទ្យជាច្រើន ដែលកំពុងបន្លឺសំឡេងខ្ពស់ សំឡេងខ្លាំង និយាយតិរច្ឆានកថាច្រើនប្រការ គឺនិយាយអំពីស្តេច និយាយអំពីចោរ និយាយអំពីអាមាត្យធំ និយាយអំពីសេនា និយាយអំពីភ័យ និយាយអំពីចម្បាំង និយាយអំពីបាយ និយាយអំពីទឹក និយាយអំពីសំពត់ និយាយអំពីទីដេក និយាយអំពីកម្រងផ្កា និយាយអំពីគ្រឿងក្រអូប និយាយអំពីញាតិ និយាយអំពីយាន និយាយអំពីស្រុក និយាយអំពីនិគម និយាយអំពីនគរ និយាយអំពីជនបទ និយាយអំពីស្ត្រី និយាយអំពីយោធាដ៏ក្លៀវក្លា និយាយអំពីច្រកផ្លូវ និយាយអំពីកំពង់ទឹក និយាយអំពីទាសីអ្នកដងទឹក និយាយអំពីញាតិដែលចែកឋានទៅ និយាយអំពីរឿងផ្សេងៗ ដែលឥតប្រយោជន៍ និយាយអំពីលោក និយាយអំពីរឿងជីកសមុទ្រ និយាយអំពីសេចក្តីចម្រើន និងមិនចម្រើន ដែលជាហេតុឥតប្រយោជន៍ថាដូច្នេះខ្លះ ដូច្នោះខ្លះ ។ ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ បានឃើញបញ្ចកង្គៈនាយជាងឈើមកអំពីចម្ងាយ លុះឃើញហើយ ក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា ចូរអ្នកដ៏ចម្រើនទាំងឡាយមានសំឡេងតិចៗ ចូរអ្នកដ៏ចម្រើនទាំងឡាយ កុំមាត់ឡើយ ដ្បិតបញ្ចកង្គៈនាយជាងឈើ ជាសាវ័ករបស់ព្រះសមណគោតមមក ពួកសាវ័ករបស់ព្រះសមណគោតម ជាគ្រហស្ថស្លៀកដណ្តប់ សំពត់ស អាស្រ័យនៅក្នុងក្រុងសាវត្ថីទាំងប៉ុន្មាន បណ្តាសាវ័កទាំងនោះ បញ្ចកង្គនាយជាងឈើនេះ ក៏ជាសាវ័កមួយដែរ លោកដ៏មានអាយុទាំងនោះ សុទ្ធតែជាអ្នកត្រូវការសំឡេងតិច ដ្បិតព្រះសមណគោតម ទូន្មានឲ្យជាអ្នកមានសំឡេងតិច ពោលសរសើរ

សំឡេងតិច យើងធ្វើដូចម្តេច ឲ្យតែគេដឹងច្បាស់ថា បរិសទ្យមានសំឡេងតិច ហើយសម្គាល់ថាគួរចូលមក ។ បរិព្វាជកទាំងនោះក៏នៅស្ងៀម ។ លំដាប់នោះ បញ្ចកង្គៈនាងជាងឈើ ចូលទៅរកឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ កាលបញ្ចប់ពាក្យរាក់ទាក់សំណេះសំណាល និងពាក្យ ដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[ ១១៩ ] លុះបញ្ចកង្គៈនាយជាងឈើ អង្គុយក្នុងទីសមគួរហើយ ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រ ក៏និយាយដូច្នេះថា ម្នាលនាយជាងឈើ ខ្ញុំបញ្ញត្ត បុរសបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការ ថាជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្តីញាប់ញ័រ ធម៌ ៤ ប្រការតើអ្វីខ្លះ ម្នាលនាយជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើអំពើអាក្រក់ដោយកាយ ១ មិនពោលពាក្យអាក្រក់ ១ មិនត្រិះរិះតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិត អាក្រក់ ១ ម្នាលនាយជាងឈើ ខ្ញុំបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ ៤ ប្រការនេះឯង ថាជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្តីញាប់ញ័រ ។ ឯបញ្ចកង្គៈនាយជាងឈើ មិនបានត្រេកអរ មិនបានឃាត់ការសិត របស់ឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រទេ លុះមិនបានត្រេកអរ មិនបានឃាត់ហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ដោយមានគំនិតថា អាត្មាអញ នឹងដឹងនូវ

សេចក្តីនៃភាសិតនេះ ច្បាស់លាស់ក្នុងសំណាក់ព្រះមានព្រះភាគ ។ បញ្ច-កង្គៈនាយជាងឈើ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះបញ្ចកង្គៈ នាយជាងឈើ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ តាមពាក្យចរចាទាំងប៉ុន្មានដែលបាននិយាយ ជាមួយនឹងឧគ្គាហមានបរិព្វាជក សមណមុណ្ឌិកាបុត្រដោយសព្វគ្រប់ ។

[ ១២០ ] កាលបញ្ចកង្គៈនាងជាងឈើនិយាយយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងបញ្ចកង្គៈនាយជាងឈើដូច្នេះថា ម្នាលនាយជាងឈើ បើដូចពាក្យដែលឧគ្គាមានបរិព្វាជក សមណមុណ្ឌិកាបុត្រនិយាយយ៉ាងនោះមែន កូនក្មេងតូចខ្ចីដេកផ្ងារ ( មិនទាន់ចេះក្រឡាប់នៅឡើយ ) ក៏ជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្តីញាប់ញ័រដែរ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងថាមិនមានកាយក៏បាន ព្រោះថានឹងធ្វើអំពើអាក្រក់ដោយកាយណាកើត វៀរលែងតែការបម្រះប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងថាមិនមានវាចាក៏បាន ព្រោះថានឹងពោលវាចាអាក្រក់ណាកើត វៀរលែងតែការយំប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងថាមិនមានសេចក្តីត្រិះរិះក៏បាន ព្រោះថានឹងត្រិះរិះតម្រិះអាក្រក់ណាកើត វៀរលែងតែធ្វើមុខជូរប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ ធម្មតាកូនក្មេងតូចខ្ចីដេកផ្ងារ នឹងថាមិនមានអាជីវៈក៏បាន ព្រោះ

ជានឹងប្រព្រឹត្តចិញ្ចឹមជីវិតអាក្រក់ណាកើត វៀរលែងតែការបៅដេះម្ដាយ ប៉ុណ្ណោះ ។ ម្នាលនាយជាងឈើ បើដូចជាពាក្យដែលឧគ្គាហមានបរិញ្វជកសមណមុណ្ឌិកាបុត្ត និយាយយ៉ាងនោះមែន កូនក្មេងតូចខ្ចីដេកផ្ងារ ក៏ជាអ្នកមានកុសលពេញលេញ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្ដីញាប់ញ័រដែរ ។

[ ១២១ ] ម្នាលនាយជាងឈើ តថាគតបញ្ញត្តបុរសបុគ្គលដែលប្រកបដោយធម៌ទាំង ៤ ប្រការថា មិនទាន់ជាអ្នកមានកុសលពេញលេញ មិនទាន់ជាអ្នកមានកុសលដ៏ប្រសើរ មិនទាន់ជាអ្នកដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ មិនទាន់ជាសមណៈ ឥតមានសេចក្ដីញាប់ញ័រ នៅឡើយទេ បុរសបុគ្គលនោះ គ្រាន់តែវិសេសជាងកូនក្មេងតូចខ្ចីដេកផ្ងារនេះបន្តិចទេ តើធម៌ ៤ ប្រការ តើអ្វីខ្លះ ម្នាលនាយជាងឈើ បុគ្គលក្នុងលោកនេះ មិនធ្វើអំពើអាក្រក់ដោយកាយ ១ មិនពោលវាចាអាក្រក់ ១ មិនត្រិះរិះតម្រិះអាក្រក់ ១ មិនចិញ្ចឹមជីវិតអាក្រក់ ១ ម្នាលនាយជាងឈើ តថាគតបញ្ញត្តបុរសបុគ្គលដែលប្រកបធម៌ ៤ ប្រការនេះថា មិនទាន់ជាអ្នកមានកុសលពេញលេញ មិនទាន់ជាអ្នកមានកុសលដ៏ប្រសើរ មិនទាន់ជាអ្នកដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ មិនទាន់ជាសមណៈ ឥតមានសេចក្ដីញាប់ញ័រ នៅឡើយទេ បុរសបុគ្គលនោះ គ្រាន់តែវិសេស ជាងកូនក្មេងតូចខ្ចីដេកផ្ងារបន្តិចប៉ុណ្ណោះ ។

[ ១២២ ] ម្នាលនាយជាងឈើ លុះតែបុរសបុគ្គលដែលប្រកបដោយអង្គ ១០ ទើបតថាគតបញ្ញត្តថា ជាអ្នកមានកុសលពេញលេញ មានកុសល

ដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ខ្ពង់ខ្ពស់ ជាសមណៈឥតមានសេចក្តីញាប់ញ័រមែន ។ នេះពួកសីលជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាអកុសល កើតអំពីអកុសលចិត្ត ( ទាំង ១២ ) នេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាអកុសលក្នុងលោកនេះ រលត់ឥតមានសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិដើម្បីរម្ងត់សីលជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ នេះពួកសីលជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាកុសល កើតមកអំពីកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ សីលទាំងឡាយជាកុសលក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សីលនោះ ។ បុគ្គលអ្នកប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិដើម្បីរម្ងត់សីលជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។ នេះពួកសង្កប្បៈជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ សង្កប្បៈជាអកុសលកើតមកអំពីអកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ សង្កប្បទាំងឡាយជាអកុសល

ក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែង ពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះជាប្រតិបត្តិដើម្បីរម្ងត់សង្កប្បៈទាំងឡាយជាអកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។ នេះពួកសង្កប្បជាកុសល ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់ សង្កប្បៈនោះ ។ សង្កប្បៈទាំងឡាយជាកុសលកើតមកអំពីកុសលចិត្តនេះ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ។ សង្កប្បៈទាំងឡាយជាកុសលក្នុងលោកនេះ រលត់ឥតសេសសល់ ម្នាលនាយជាងឈើ តថាគតតែងពោលថា បុគ្គលត្រូវស្គាល់សង្កប្បៈនោះ ។ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះជាប្រតិបត្តិ ដើម្បីរម្ងត់សង្កប្បៈទាំងឡាយជាកុសល ម្នាលនាយជាងឈើ តថាគតែងពោលថា បុគ្គលត្រូវស្គាល់បុគ្គលនោះ ។

[ ១២៣ ] ម្នាលនាយជាងឈើ ចុះសីលទាំងឡាយជាអកុសល តើដូចម្តេច ។ កាយកម្ម ជាអកុសល វចីកម្មជាអកុសល អាជីវៈជាបាប ម្នាលនាយជាងឈើ នេះតថាគតហៅថា សីលជាអកុសល ។ ម្នាលនាយជាងឈើ ចុះសីលជាអកុសលទាំងនេះ តើមានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សីលជាអកុសលទាំងនោះ បានពោលរួចហើយ ។ គួរពោលថា មានចិត្តជាសមុដ្ឋាន ។ ចុះចិត្តដូចម្តេច ។ ចិត្តមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺចិត្តប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកកប

ដោយមោហៈ សីលជាអកុសលទាំងឡាយ កើតអំពីចិត្តនេះ ។ ម្នាលនាយជាងឈើ ចុះសីលជាអកុសលទាំងនេះ តើរលត់ឥតសេសសល់ក្នុងទីណា។ ឯការរលត់របស់សីលទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ លះបង់កាយទុច្ចរិត ចម្រើនកាយសុចរិត លះបង់វចីទុច្ចរិត ចម្រើនវចីសុចរិត លះបង់មនោទុច្ចរិត ចម្រើនមនោសុចរិត លះបង់មិច្ឆាជីវៈ ចិញ្ចឹមជីវិតដោយសម្មាជីវៈ សីលជាអកុសលទាំងនោះ តែងរលត់ឥតសេសសល់ ក្នុងសោតាបត្តិផលនុ៎ះឯង ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិដូចម្តេច ទើបឈ្មោះថាប្រតិបត្តិ ដើម្បីរម្ងត់សីលទាំងឡាយជាអកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមកដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើតឡើង ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់ធម៌ទាំងឡាយជាអកុសលដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើតឡើង ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឲ្យឋិតស្ថេរមិនឲ្យវិនាសទៅវិញ ឲ្យរឹងរឹតតែធំទូលាយ ចម្រើនពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ឈ្មោះថាប្រតិបត្តិដើម្បីរម្ងត់សីលទាំងឡាយ ជាអកុសល ។

[ ១២៤ ] ម្នាលនាយជាងឈើ ចុះសីលទាំងឡាយជាកុសល តើដូចម្តេច ។ ម្នាលនាយជាងឈើ តថាគតពោលនូវកាយកម្ម ជាកុសល វចីកម្មជាកុសល ទាំងអាជីវបារិសុទ្ធិផង ថាជាសីល ម្នាលនាយជាងឈើ ទាំងនេះហៅថាសីលជាកុសល ។ ម្នាលនាយជាងឈើ ចុះសីលជាកុសលទាំងនេះមានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សីលជាកុសលទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានចិត្តជាសមុដ្ឋាន ។ ចុះចិត្តដូចម្តេច ។ ចិត្តមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺចិត្តប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ សីលជាកុសលកើតអំពីចិត្តនេះ ។ ម្នាលនាយជាងឈើ ចុះសីលជាកុសលទាំងនេះ រលត់ឥតសេសសល់ក្នុងទីណា ។ ការរលត់របស់សីលទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ប៉ុន្តែមិនទាន់សម្រេចត្រឹមសីលប៉ុណ្ណោះទេ រមែងដឹងច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះផងតាមសេចក្តីពិតថា សីលជាកុសលទាំងនោះ របស់ភិក្ខុនោះ រមែងរលត់ឥតសេសសល់ក្នុង អរហត្តផល ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិយ៉ាងណា ទើបហៅថាប្រតិបត្តិដើម្បីរម្ងត់សីលទាំងឡាយជាកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់ពួកធម៌ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ។បេ។ ដើម្បីញុំាងពួកធម៌ជា

កុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។បេ។ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងពួកធម៌ជាកុសល ដែលកើតឡើងហើយ ឲ្យឋិតស្ថេរ មិនឲ្យវិនាស ឲ្យរឹងរឹតតែធំទូលាយចម្រើន ពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ទើបហៅថា ប្រតិបត្តិដើម្បីរម្ងាប់សីលទាំងឡាយ ជាកុសល ។

[ ១២៥ ] ម្នាលនាយជាងឈើ សង្កប្បៈទាំងឡាយជាអកុសល តើដូចម្តេច ។ កាមសង្កប្បៈ ១ ព្យាបាទសង្កប្បៈ ១ វិហិង្សាសង្កប្បៈ ១ ម្នាលនាយជាងឈើ ទាំងនេះហៅថា សង្កប្បៈជាអកុសល ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈជាអកុសលទាំងនេះ មានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានសញ្ញាជាសមុដ្ឋាន ។ ចុះសញ្ញាដូចម្តេច ។ សញ្ញាមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺកាមសញ្ញា ១ ព្យាបាទសញ្ញា ១ វិហិង្សាសញ្ញា ១ សង្កប្បៈជាអកុសលកើតមកអំពីសញ្ញាទាំងនេះ ។ ម្នាលនាយជាងឈើ ចុះសង្កប្បៈ ជាអកុសលទាំងនេះ រលត់ឥតសេសសល់ក្នុងទីណា ។ ឯការរលត់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលអនាគាមិផល បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈមានបីតិ និងសុខៈកើតអំពីវិវេក សង្កប្បៈជាអកុសលទាំងនោះរលត់ឥតសេសសល់ក្នុងអនាគាមិផលនុ៎ះឯង ។ ម្នាលនាយជាងឈើ ចុះបុគ្គល

ប្រតិបត្តិយ៉ាងណា ទើបហៅថាប្រតិបត្តិដើម្បីរម្ងាត់សង្កប្បៈទាំងឡាយជាអកុ-សល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះញ៉ាំងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញ៉ាំងពួកធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើងមិនឲ្យកើតឡើងបាន ដើម្បីលះបង់ធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ។បេ។ ដើម្បីញ៉ាំងធម៌ទាំងឡាយជាកុសល ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។បេ។ ញ៉ាំងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញ៉ាំងធម៌ទាំងឡាយជាកុសលដែលកើតឡើងហើយ ឲ្យឋិត-ថេរមិនឲ្យវិនាសទៅវិញ ឲ្យរឹងរឹតតែធំទូលាយ ចម្រើនពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ហៅថាប្រតិបត្តិដើម្បីរលត់សង្កប្បៈទាំងឡាយជាអកុសល ។

[ ១២៦ ] ម្នាលនាយជាងឈើ ចុះសង្កប្បៈទាំងឡាយជាកុសល តើដូចម្តេច នេក្ខម្មសង្កប្បៈ ១ អព្យាបាទសង្កប្បៈ ១ អវិហិង្សាសង្កប្បៈ ១ ម្នាលនាយជាងឈើ ទាំងនេះហៅថាសង្កប្បៈជាកុសល ។ ម្នាលនាយជាងឈើចុះសង្កប្បៈទាំងឡាយជាកុសលនេះ មានអ្វីជាសមុដ្ឋាន ។ ឯសមុដ្ឋានរបស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ គួរពោលថាមានសញ្ញាជាសមុដ្ឋាន ។ ចុះសញ្ញាដូចម្តេច ។ សញ្ញាមានច្រើន មានបែបមិនតែមួយ មានប្រការផ្សេងៗ គឺនេក្ខម្មសញ្ញា ១ អព្យាបាទសញ្ញា ១ អវិហិង្សាសញ្ញា ១ សង្កប្បៈទាំងឡាយជាកុសល កើតមកអំពីសញ្ញាទាំងនេះ ។ ម្នាលនាយ

ជាងឈើ ចុះសង្កប្បៈទាំងឡាយ ជាកុសលនេះ រលត់ឥតសេសសល់ក្នុងទីណា ។ ឯការរលត់របស់សង្កប្បៈទាំងនោះ បានពោលរួចហើយ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ព្រោះរម្ងាប់វិតក្កៈ វិចារៈ ។បេ។ ចូលទុតិយជ្ឈាន សង្កប្បៈជាកុសលទាំងនេះ រលត់ឥតមានសេសសល់ ក្នុងទុតិយជ្ឈានទុំះឯង ។ ម្នាលនាយជាងឈើ ចុះបុគ្គលប្រតិបត្តិដូចម្តេច ទើបហៅថា ប្រតិបត្តិដើម្បីរម្ងត់សង្កប្បៈទាំងឡាយជាកុសល ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ដើម្បីលះបង់ធម៌ទាំងឡាយជាអកុសលដ៏លាមកដែលកើតឡើងហើយ ។បេ។ ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ។បេ។ ញុំាងឆន្ទៈឲ្យកើត ខំប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសល ដែលកើតឡើងហើយឲ្យឋិតថេរ មិនឲ្យវិនាសទៅវិញ ឲ្យរឹងរឹតតែធំទូលាយ ចម្រើនពេញបរិបូណ៌ឡើង ។ ម្នាលនាយជាងឈើ បុគ្គលប្រតិបត្តិយ៉ាងនេះ ហៅថាប្រតិបត្តិ ដើម្បីរម្ងត់សង្កប្បៈទាំងឡាយជាកុសល ។

[ ១២៧ ] ម្នាលនាយជាងឈើ ដែលតថាគតបញ្ញត្តបុរសបុគ្គលប្រកបដោយធម៌ ១០ ប្រការ ថាជាអ្នកមានកុសលដ៏បរិបូណ៌មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ឧត្តម ជាសមណៈ ឥតមានសេចក្តីញាប់ញ័រ តើអ្វីខ្លះ ។ ម្នាលនាយជាងឈើ ភិក្ខុក្នុងសាសនានេះ ប្រកបដោយ

សម្មាទិដ្ឋិជាអសេក្ខៈ ១ ប្រកបដោយសម្មាសង្កប្បៈជាអសេក្ខៈ ១ ប្រកបដោយសម្មាវាចាជាអសេក្ខៈ ១ ប្រកបដោយសម្មាកម្មន្តៈ ជាអសេក្ខៈ ១ ប្រកបដោយសម្មាអាជីវៈជាអសេក្ខៈ ១ ប្រកបដោយសម្មាវាយាមជាអសេក្ខៈ ១ ប្រកបដោយ សម្មាសតិជាអសេក្ខៈ ១ ប្រកបដោយសម្មាសមាធិជាអសេក្ខៈ ១ ប្រកបដោយសម្មាញាណជាអសេក្ខៈ ១ ប្រកបដោយសម្មាវិមុត្តិជាអសេក្ខៈ ១ ។ ម្នាលនាយជាងឈើ តថាគតបញ្ញត្តបុរសបុគ្គលប្រកបដោយធម៌ទាំង ១០ ប្រការនេះឯង ថាជាអ្នកមានកុសលដ៏បរិបូណ៌ មានកុសលដ៏ប្រសើរ ដល់នូវចំណែកបុណ្យដ៏ឧត្តម ជាសមណៈឥតមានសេចក្តីញាប់ញ័រ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ បញ្ចកង្គៈនាយជាងឈើ ក៏ត្រេកអររីករាយហើយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សមណមុណ្ឌិកសូត្រទី ៨

# អដ្ឋកថា

## សមណមុណ្ឌិកសូត្រ

[ ១១៧ ] សមណមុណ្ឌិកសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឧគ្គាហមានោ** បរិព្វាជក ឈ្មោះថា ឧគ្គាហមានៈ ឈ្មោះដើមរបស់បរិព្វាជកនោះ សុមនៈ តែព្រោះរៀនវិជ្ជាច្រើនយ៉ាង ទើបជនទាំងឡាយតាំងឈ្មោះថា ឧគ្គាហមានៈ ។ ឈ្មោះថា **សមយប្បវាទកំ** ព្រោះជាទីប្រជុំសម្តែងលទ្ធិ ។ បានឮថា ក្នុងទីនោះ ពួកព្រាហ្មណ៍ផ្តើមដោយ **ចង្កីព្រាហ្មណ៍ តារុក្ខព្រាហ្មណ៍** និង **ពោក្ខរសាតិព្រាហ្មណ៍** និគ្រន្ថ និងពួកបព្វជិត មានអចេលក៍ និងបរិព្វាជកជាដើម ប្រជុំ ប្រកាសសន្ទនា សម្តែងលទ្ធិរៀងៗ ខ្លួន ព្រោះដូច្នោះ ទើបអារាមនោះហៅថា សមយប្បវាទកៈ ។ សាលាឈ្មោះ **តិណ្ឌុកាចីរ** ព្រោះព័ទ្ធដោយជួរដើមទន្លាប់ ។ ព្រោះក្នុងទីនេះកាលដើមឡើយមានសាលាមួយខ្នង ក្រោយមក ទើបធ្វើទុកច្រើនទៀត ព្រោះអាស្រ័យបោដ្ឋបាទបរិព្វាជក ដែលជាអ្នកមានបុណ្យច្រើន ដូច្នោះ ទើបហៅថា **ឯកសាលក** ដោយបានឈ្មោះតាមសញ្ញាដល់សាលាមួយខ្នងនោះឯង ។ ឯកសាលកៈនោះ ជាសួនរបស់ព្រះរាជទេវីនៃព្រះបាទបសេនទិកោសល ឈ្មោះថា មល្លិកា ដេរដាសដោយផ្កា និងផ្លែឈើ ព្រោះធ្វើជាអារាម ទើបហៅថា អារាមរបស់ព្រះនាងមល្លិកា ។ ឧគ្គាហមានបរិព្វាជក អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកា ក្នុងនិគមតិណ្ឌុកាចីរៈដែលជាទីប្រជុំសម្តែងលទ្ធិនោះយ៉ាងសប្បាយ ។ បទថា **ទិវាទិវស្ស** គឺហួស

វេលាត្រង់ឈ្មោះថា វេលារសៀល អធិប្បាយថា ឧគ្គហមានបរិព្វាជកចេញទៅក្នុងវេលាត្រង់ហួសទៅ ជាថ្ងៃនៃថ្ងៃនោះ ។ បទថា **បដិសល្លីនោ** គឺព្រះមានព្រះភាគទ្រង់សង្រួមចិត្តអំពីអារម្មណ៍ មានរូបជាដើមនោះៗ នៅសម្ងំដល់នូវភាពមួយអង្គឯង ដោយទ្រង់ត្រេកអរក្នុងឈាន ។ បទថា **មនោ-ភាវនីយានំ** គឺអ្នកចម្រើនផ្លូវចិត្ត ។ ការប្រាសចាកនីវរណៈត្រឹមតែការគិតរមែងមានដល់ភិក្ខុដែលនឹក ដែលមនសិការ ។ ចិត្តរមែងខ្ពស់ឡើង គឺរមែងចម្រើន ។

[ ១១៨ ] បទថា **យាវតា** គឺប្រមាណប៉ុនណា ។ បទថា **អយំ តេសំ អញ្ញតរោ** គឺនាយជាងឈើនេះជាសាវកម្នាក់ ក្នុងរវាងសាវកទាំងនោះ ។ បទថា **អប្បេវ នាម** គឺឧគ្គាហមានបរិព្វាជកត្រូវការឲ្យនាយជាងឈើ ចូលទៅជិត ទើបពោល ។ ហេតុដែលត្រូវការនោះ លោកពោលទុកហើយ ក្នុងសន្ទកសូត្រ ។

[ ១១៩ ] បទថា **ឯតទវោច** គឺឧគ្គាហមានបរិព្វាជក បានពោលនឹងនាយជាងឈើនោះ ។ ឧគ្គាហមានបរិព្វាជក សម្គាល់ថា គហបតីនេះមានបញ្ញាទន់ខ្សោយ អញនឹងសង្គ្រោះគាត់ដោយធម្មកថា ហើយនឹងធ្វើឲ្យជាសាវករបស់អញ ទើបបានពោលពាក្យថា **ចតូហិ ខោ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **បញ្ញបេមិ** គឺខ្ញុំសម្តែងតាំងឡើង ។ បទថា **សម្បន្នកុសលំ** គឺមានកុសលបរិបូណ៌ ។ បទថា **បរមកុសលំ** គឺមានកុសលដ៏ខ្ពង់ខ្ពស់ ។ បទថា **អយោជ្ឈំ** គឺមិនមានអ្នកណាអាចតតាំងដោយ

វាទៈ ឲ្យញាប់ញ័របាន ជាអ្នកមិនកម្រើក ជាអ្នកមាំទាំ ។ បទថា **ន ករោតិ** គឺរមែងពោល ត្រឹមតែមិនធ្វើប៉ុណ្ណោះ ។ ម្យ៉ាងទៀត ក្នុងបទនេះ ឧគ្គាហមាន បរិញ្ជកពោលដល់ការលះដោយការសង្រួម ឬការពិចារណា ។ សូម្បី ក្នុងបទដ៏សេស ក៏មានន័យដូចគ្នា ។ បទថា **នេវ អភិនន្ទតិ** គឺនាយជាង ឈើ សម្គាល់ថា ធម្មតាពួកក្មេងទាំងឡាយ ដឹងខ្លះ មិនដឹងខ្លះ ពោលដៅ ស្មានទៅ ទើបមិនត្រេកអរ ។ បទថា **នប្បដិក្កោសិ** គឺនាយជាងឈើ សម្គាល់ថា ឧគ្គាហមានបរិញ្ជក ពោលដូចអនុលោមតាមសាសនា ដូចការ ជ្រះថ្លាក្នុងសាសនា ទើបមិនជំទាស់ ។

[ ១២០ ] បទថា **យថា ឧគ្គាហមានស្ស** គឺដូចពាក្យឧគ្គាហ មានបរិញ្ជក ។ ព្រះមានព្រះភាគសម្តែងថា តថាគតមិនពោលដូចពាក្យ របស់ឧគ្គាហមានបរិញ្ជកនោះទេ កាលបើដូច្នោះ កូនក្មេងដែលនៅដេកផ្ងារ នៅឡើយ នឹងជាសមណៈ ដែលបុគ្គលណាតតាំងមិនបាន និងជាសមណៈ ដែលមាំទាំទៅហើយ ។ បទថា **កាយោតិបិ ន ហោតិ** គឺ មិនមានការដឹង វិសេសថា កាយរបស់ខ្លួន ឬកាយរបស់អ្នកដទៃ ។ បទថា **អញ្ញត្រ ផន្ទិតមត្តា** គឺរមែងមានត្រឹមតែអាការបម្រះនទៀល ដោយការប៉ះពាល់វល្លិ លើដំណេក ឬត្រូវសង្កើចខាំ ក្រៅអំពីនោះហើយ ក៏មិនមានការធ្វើតាម កាយដទៃ ។ ម្យ៉ាងទៀត កម្មនោះនឹងមានដោយចិត្តប្រកបដោយកិលេស ប៉ុណ្ណោះ ។ បទថា **វាចាតិបិ ន ហោតិ** គឺនឹងដឹងសេចក្តីផ្សេងគ្នាថា មិច្ឆាវាចា សម្មាវាចា ក៏មិនមាន ។ បទថា **រោទិតមត្តា** គឺមានត្រឹមតែការយំនៃកូនង៉ែត

ដែលឃ្លាន និងស្រេក សូម្បីកម្មនោះមាន ក៏ដោយចិត្តប្រកបដោយកិលេស ប៉ុណ្ណោះ ។ បទថា **សង្កប្បា** គឺដឹងការផ្សេងថា មិច្ឆាសង្កប្បៈ សម្មា-សង្កប្បៈ ក៏មិនមាន ។ បទថា **វិកុជិតមត្តា** ក្រៅពីការដឹងត្រឹមតែការយំ និងការសើច គឺចិត្តរបស់ទារក មានអារម្មណ៍ក្នុងអតីតប្រព្រឹត្តទៅ ។ ទារក ដែលមកអំពីនរក រឭកដល់ទុក្ខក្នុងនរក រមែងយំ ។ មកអំពីទេវលោក រឭកដល់សម្បត្តិក្នុងទេវលោក រមែងសើច ។ កម្មនោះរមែងមានដោយចិត្ត ប្រកបដោយកិលេសប៉ុណ្ណោះ ។ បទថា **អាជីវោ** គឺដឹងនូវការផ្សេងថា មិច្ឆាជីវៈ សម្មាជីវៈ ក៏មិនមាន ។ បទថា **អញ្ញត្រ មាតុ ថញ្ញា** គឺក្រៅអំពី ទឹកដោះរបស់ម្តាយ ។ ទារកទាំងនោះ ឈ្មោះថា នៅជាទារក កាលមាតាឲ្យ បៅដោះ ក៏មិនបៅ ក្នុងវេលាដែលមាតាចាត់ចែងការងារដទៃ ខាងក្រោយមក ទើបបៅដោះ ។ មិច្ឆាជីពដទៃផុតទៅអំពីនេះ ក៏មិនមាន ។ លោកសម្តែងថា មិច្ឆាជីពនេះ រមែងមានដោយចិត្តប្រកបដោយកិលេសប៉ុណ្ណោះ ។

[ ១២១ ] ព្រះមានព្រះភាគ កាលទ្រង់បដិសេធវាទៈរបស់បរិព្វាជក យ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ដាក់មាតិកាក្នុងសេក្ខភូមិដោយព្រះអង្គ ទើបត្រាស់ព្រះតម្រាស់ថា **ចតូហិ ខោ អហំ** ដូច្នេះជាដើម ។ ក្នុងបទទាំង នោះ បទថា **សមធិគយ្ហ តិដ្ឋតិ** គឺតាំងទុកដោយល្អ ។ ក្នុងបទថា **ន កាយេន ចាបកំ កម្មំ** ជាដើម គឺមិនគ្រាន់តែមិនធ្វើតែម្យ៉ាងប៉ុណ្ណោះ ។ តែព្រះមានព្រះភាគទ្រង់បញ្ញត្ត ការលះដោយការសង្រួម និងការពិចារណា ទុកក្នុងបទនេះផងដែរ ។ ទ្រង់សំដៅដល់សេចក្តីនោះ ទើបត្រាស់ទុក ។

ឯបទថា **ឥធ ថបតិ សម្បន្នកុសលំ** ជាដើម ទ្រង់ត្រាស់ដល់ព្រះវីណាស្រេព ។

[ ១២២ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ដាក់មាតិកាក្នុងអសេក្ខភូមិ ទើបត្រាស់ថា **ឥធាហំ ខោ អហំ** ជាដើម ។ ក្នុងបទនោះ អាស្រ័យបទ ៣ ទ្រង់ដាក់ចតុក្កៈមួយ ទុក ២ បទ ។ អាស្រ័យបទមួយ ទ្រង់ដាក់ចតុក្កៈចុងក្រោយទុក ២ បទ នេះ គឺ មាតិកាក្នុងអសេក្ខភូមិ ។

[ ១២៣ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចែកមាតិកានោះ ទើបត្រាស់ ថា **កតមេ ច ថបតិ អកុសលា សីលា** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សរាគំ** គឺចិត្តប្រកបដោយលោភមូល ៨ ។ បទថា **សទោសំ** គឺចិត្ត ២ ដួង ដែលសម្បយុត្តដោយបដិឃៈ ។ បទថា **សមោហំ** គឺចិត្ត ២ ដួង ប្រកបដោយវិចិកិច្ឆា និងឧទ្ធច្ចៈក៏គួរ ចិត្តដែលជាអកុសលទាំងអស់ក៏គួរ ។ ព្រោះលោកពោលទុកថា មោហៈតែង កើតក្នុងអកុសលទាំងពួង ។ បទថា **ឥតោ សមុដ្ឋានា** ឈ្មោះថា **ឥតោសមុដ្ឋាន** ព្រោះមានសមុដ្ឋានកើតអំពីចិត្ត មានរាគៈជាដើមនេះ ។ បទថា **កុហឹ** គឺសីលដែលជាអកុសលរលត់មិនសេសសល់ ព្រោះសម្រេចឋានៈ ណា ។ បទថា **ឯត្ថេតេ** គឺតាំងនៅក្នុងសោតាបត្តិផល ។ ពិតហើយ បាតិមោក្ខសំវរសីល រមែងបរិបូណ៌ក្នុងសោតាបត្តិផល ។ ដល់នូវឋានៈនោះហើយ អកុសលសីលរលត់មិនសេសសល់ ។ម្យ៉ាងទៀត បទថា **អកុសលានំ សីលានំ** នេះ គប្បីជ្រាបថា ជាឈ្មោះនៃបុគ្គលទ្រុស្តសីលខ្លះ ជាឈ្មោះនៃធម៌ដែលជាអកុសលខ្លះ ។ បទថា **និរោធាយ បដិបន្នោ** គឺបដិបត្តិដើម្បីការរលត់ តាំង

អំពីសោតាបត្តិមគ្គ ។ តែអកុសលសីលទាំងនោះ ឈ្មោះថា ជាការរលត់ដោយការសម្រេចអរហត្ត ។

[ ១២៤ ] បទថា **វីតរាគំ** ជាដើម លោកពោលដល់កាមាវចរកុសលចិត្ត ៨ យ៉ាង ។ ដោយបទនេះ សីលដែលជាកុសល រមែងតាំងឡើង ។ បទថា **សីលវា ហោតិ** ជាអ្នកមានសីល គឺជាអ្នកបរិបូណ៌ដោយសីល និងបរិបូណ៌ដោយគុណ ។ បទថា **សីលមយោ** គឺមិនសម្រេចដោយសីលយ៉ាងនេះថា ត្រឹមប៉ុណ្ណេះក៏ល្មម មិនមានវត្ថុណាមួយដែលគួរធ្វើឲ្យក្រៃលែងជាងនេះ ។ បទថា **យត្ថស្ស តេ** ឈ្មោះថា រលត់អស់ឥតសេសសល់នៃកុសលសីលទាំងនោះរបស់ភិក្ខុនោះ គឺតាំងនៅ ក្នុងអរហត្តផល ។ ព្រោះសីលដែលជាអកុសលរលត់មិនមានសេសសល់ ព្រោះសម្រេចអរហត្តផល ។ បទថា **និរោធាយ បដិបន្នោ** គឺឈ្មោះថា បដិបត្តិដើម្បីរម្ងត់តាំងអំពីអរហត្តមគ្គ ។ កុសលសីលទាំងនោះ ឈ្មោះថា ជាការរម្ងត់ដោយការចាក់ធ្លុះនូវផល ។

[ ១២៥ ] ក្នុងកាមសញ្ញាជាដើម មានសេចក្តីដូចតទៅនេះ ។ បទថា **កាមសញ្ញា** គឺសញ្ញាក្រៅអំពីនេះកើតរួមជាមួយចិត្ត ដែលប្រកបដោយលោភៈ ៨ ដួង សញ្ញាដែលកើតរួមជាមួយទោមនស្សចិត្ត ២ ដួង ។ បទថា **បឋមំ ឈានំ** គឺបឋមជ្ឈានដែលជាអនាគាមិផល ។ បទថា **ឯត្ថេតេ** សេចក្តីថា សង្កប្បៈជាអកុសលទាំងនោះ រលត់អស់ទៅក្នុងបឋមជ្ឈាន គឺតាំងនៅក្នុងអនាគាមិផល ។ ព្រោះសង្កប្បៈជាអកុសល រមែងមិនសេសសល់ ព្រោះការ

សម្រេចអនាគាមិផល ។ បទថា **និរោធាយ បដិបន្នោ** គឺឈ្មោះថា អ្នកបដិបត្តិដើម្បីការរម្ងត់ តាំងអំពីអនាគាមិមគ្គ តែការត្រិះរិះដែលជាអកុសលទាំងនោះ ឈ្មោះថា ជាការរលត់ដោយការ សម្រេចផល ។

[ ១២៦ ] សញ្ញា ៣ មាននេក្ខម្មសញ្ញាជាដើម ជាសញ្ញាកើតរួមនឹងកាមាវចរកុសល ៨ ។ បទថា **ឯត្ថេតេ** សេចក្ដីថា សង្កប្បៈជាកុសលទាំងនេះ រលត់មិនសេសសល់ក្នុងទុតិយជ្ឈាននេះ គឺក្នុងអរហត្តផល ព្រោះថា សង្កប្បៈដែលជាកុសល រមែងរលត់មិនសេសសល់ ព្រោះការសម្រេចអរហត្តផល ដែលប្រកបដោយទុតិយជ្ឈាន ។ បទថា **និរោធាយ បដិបន្នោ** គឺឈ្មោះថា ជាអ្នកបដិបត្តិដើម្បីការរម្ងត់ រហូតដល់អរហត្តមគ្គ ។ តែសង្កប្បៈដែលជាកុសលទាំងនោះ ឈ្មោះថា ជាការរលត់ដោយការចាក់ធ្លុះនូវផល ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ដូច្នេះ ។ ៚

**សមណមុណ្ឌិកសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ចូឡសកុលុទាយិសូត្រទី ៧

[ ១២៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង បរិព្វាជកឈ្មោះសកុលុទាយិ នៅអាស្រ័យក្នុងបរិព្វាជការាម ឈ្មោះមោរនិវាបៈ ជាមួយនឹងបរិព្វាជកបរិសទ្យច្រើននាក់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ទ្រង់ស្តេចចូលទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគទ្រង់មានសេចក្តីត្រិះរិះ ក្នុងវេលានោះយ៉ាងនេះថា ការត្រាច់ទៅក្នុងក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត នៅព្រឹកណាស់នៅឡើយ បើដូច្នោះ គួរតែតថាគត ចូលទៅរកសកុលុទាយិបរិព្វាជក ឯបរិព្វាជការាមឈ្មោះមោរនិវាបៈសិន ។ ព្រះមានព្រះភាគ ក៏ទ្រង់ស្តេចចូលទៅកាន់បរិព្វាជការាម ឈ្មោះមោរនិវាបៈ ។

[ ១២៩ ] សម័យនោះឯង សកុលុទាយិបរិព្វាជក អង្គុយជាមួយនឹងបរិព្វាជកបរិសទ្យច្រើននាក់ ដែលកំពុងបន្លឺសំឡេងខ្ពស់ សំឡេងខ្លាំង និយាយតិរច្ឆានកថា ជាច្រើនប្រការគឺ និយាយអំពីស្តេច ។បេ។ និយាយអំពីសេចក្តីវិនាស និងសេចក្តីចម្រើន ដែលជាហេតុឥតប្រយោជន៍ ថាដូច្នេះខ្លះ ដូច្នោះខ្លះ ។ សកុលុទាយិបរិព្វាជក បានឃើញព្រះមានព្រះភាគ កំពុងស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏បញ្ឈប់បរិសទ្យរបស់ខ្លួនថា ចូរអ្នកដ៏ចម្រើនទាំងឡាយមានសំឡេងតិចៗ ចូរអ្នកដ៏ចម្រើនទាំងឡាយកុំមាត់អ្វីឡើយ ដ្បិត

ព្រះសមណគោតមនេះ និមន្តមក ឯព្រះសមណគោតមមានអាយុនោះជាអ្នកត្រូវការតែនឹងសំឡេងតិច ពោលសរសើរសំឡេងតិច ធ្វើដូចម្តេចឲ្យតែលោកដឹងថា បរិសទ្យមានសំឡេងតិច ហើយសម្គាល់ថា គួរចូលមក ។ ពួកបរិព្វាជកទាំងនោះ ក៏នៅស្ងៀម ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅរកសកុលុទាយិបរិព្វាជក ។ សកុលុទាយបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ស្តេចមកចុះ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរស្តេចមកនៃព្រះមានព្រះភាគជាការប្រពៃហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគបានបម្រុងនឹងធ្វើដំណើរមក ក្នុងទីនេះអស់កាលយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគនិមន្តគង់ចុះ អាសនៈនេះខ្ញុំព្រះអង្គបានក្រាលហើយ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ សកុលុទាយិបរិព្វាជកកាន់យកអាសនៈដ៏ទាប ១ អង្គុយក្នុងទីដ៏សមគួរ ។ លុះសកុលុ-ទាយិបរិព្វាជកអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលឧទាយិ អ្នកអង្គុយប្រជុំគ្នានិយាយពីរឿងអ្វី អម្បាញ់មិញនេះ ចុះពាក្យដូចម្តេចដែលអ្នកទាំងឡាយធ្វើឲ្យដាច់ពាក់កណ្តាលទៅ ។

[ ១៣០ ] សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលខ្ញុំព្រះអង្គទាំងឡាយប្រជុំគ្នានិយាយអម្បាញ់មិញនេះ លើកទុកសិន បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនុ៎ះមិនមែនជាការក្រដល់ព្រះអង្គទេ សូមទ្រង់ព្រះសណ្តាប់ជាខាងក្រោយចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គ

មិនទាន់ចូលទៅជិតបរិសទ្យនេះ បរិសទ្យនេះ ក៏អង្គុយនិយាយតិរច្ឆានកថាច្រើនប្រការ បពិត្រព្រះអង្គដ៏ចម្រើន លុះតែកាលដែលខ្ញុំព្រះអង្គចូលទៅជិតបរិសទ្យនេះ ទើបបរិសទ្យនេះ អង្គុយមើលមុខខ្ញុំព្រះអង្គ និយាយថា បពិត្រឧទាយិ យើងទាំងឡាយចង់ស្តាប់ធម៌ដែលព្រះសមណគោតមនឹងសម្តែងដល់យើងទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគទ្រង់ស្តេចចូលមករកបរិសទ្យនេះ ខ្ញុំព្រះអង្គនឹងចូលទៅដែរ ដ្បិតបរិសទ្យនេះ កំពុងតែអង្គុយមើលព្រះភក្ត្រព្រះមានព្រះភាគដោយគិតថា យើងទាំង-ឡាយចាំស្តាប់ធម៌ ដែលព្រះមានព្រះភាគនឹងសម្តែង ដល់យើងទាំងឡាយ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ បើដូច្នោះ ចូរអ្នកតាំងផ្តើមប្រស្នានោះមកតថាគតនឹងសម្តែងតបតាមហេតុក្នុងប្រស្នានុ៎ះ ។

[ ១៣១ ] សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពីថ្ងៃមុនៗ មានបុគ្គលអ្នកដឹងសព្វ ឃើញសព្វ ដឹងច្បាស់នូវញាណទស្សនៈឥតសេសសល់ និយាយថា កាលខ្ញុំដើរក្តី ឈរក្តី ដេកលក់ក្តី រលឹកក្តី ញាណទស្សនៈប្រាកដឡើងរឿយៗ មិនដាច់ បុគ្គលនោះ កាលដែលខ្ញុំព្រះអង្គសួរប្រស្នាប្រារព្ធទីបំផុតជាដើម ត្រឡប់ជាគេចកែពាក្យដទៃដោយពាក្យដទៃ យកពាក្យខាងក្រៅមកបន្ទៃបន្ទប់ ហើយសម្តែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏កើតសតិឡើង ព្រោះប្រារព្ធចំពោះព្រះមានព្រះភាគថា ឱមានតែ ព្រះមានព្រះភាគឱមានតែព្រះសុគត ទើបព្រះអង្គឈ្លាសវៃចំពោះធម៌ទាំងនេះ ។ ព្រះអង្គ

ត្រាស់ថា ម្នាលឧទាយិ ចុះបុគ្គលណាជាអ្នកដឹងសព្វ ឃើញសព្វ ដឹងច្បាស់នូវញាណទស្សនៈឥតសេសសល់ និយាយថា កាលខ្ញុំដើរក្តី ឈរក្តី ដេកលក់ក្តី រលឹកក្តី ញាណទស្សនៈក៏ប្រាកដឡើងរឿយៗ មិនដាច់ បុគ្គលនោះកាលដែលអ្នកបានសួរប្រស្នាប្រារព្ធទីបំផុតខាងដើម ក៏ត្រឡប់ជាគេចកែពាក្យដទៃដោយពាក្យដទៃ យកពាក្យខាងក្រៅមកបន្ទៃបន្ទប់ ហើយសម្តែងនូវសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីអាក់អន់ចិត្តឲ្យប្រាកដឡើង ។ សកុលុទាយិក្រាបបង្គំទូលថា និគ្រន្ថនាដបុត្រ ព្រះអង្គ ។

[ ១៣២ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ បុគ្គលណាមួយរលឹកឃើញបុព្វេនិវាសមានច្រើនប្រការគឺ រលឹកឃើញជាតិ ១ ជាតិ ២ ។បេ។ រលឹកឃើញបុព្វេនិវាស មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ( បើ ) បុគ្គលនោះសួរប្រស្នានឹងតថាគត ប្រារព្ធទីបំផុត ខាងដើម តថាគតក៏សួរប្រស្នានឹងបុគ្គលនោះ ប្រារព្ធទីបំផុតខាងដើមដែរ បុគ្គលនោះប្រារព្ធទីបំផុតខាងដើម ធ្វើចិត្តតថាគតឲ្យរីករាយ ដោយការដោះប្រស្នាបាន តថាគតក៏ប្រារព្ធទីបំផុតខាងដើម ធ្វើចិត្តបុគ្គលនោះឲ្យរីករាយ ដោយការដោះប្រស្នាបានដែរ បុគ្គលណាមួយ មានទិព្វចក្ខុបរិសុទ្ធកន្លងចក្ខុរបស់មនុស្សសាមញ្ញ ឃើញសត្វទាំងឡាយដែលច្យុត ដែលកើត ថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ។បេ។ ក៏ដឹងច្បាស់នូវពួកសត្វដែលទៅតាមយថាកម្ម ( បើ ) បុគ្គលនោះ សួរប្រស្នានឹងតថាគត ប្រារព្ធទីបំផុតខាងចុង តថាគតក៏សួរប្រស្នានឹងបុគ្គល នោះប្រារព្ធទីបំផុតខាង

ចុងដែរ បុគ្គលនោះប្រារព្ធទីបំផុតខាងចុង ធ្វើចិត្តតថាគតនោះឲ្យរីករាយ ដោយការដោះប្រស្នាបានដែរ ប៉ុន្តែណ្ហើយចុះ ឧទាយិ ទីបំផុតខាងដើមលើកទុក ទីបំផុតខាងចុងក៏លើកទុកចុះ តថាគតនឹង សម្តែងធម៌ដល់អ្នក កាលបើទីបំផុតខាងដើមនេះមាន ទីបំផុតខាងចុងនេះក៏មាន ទីបំផុតខាងចុងនេះកើតឡើងបាន ព្រោះទីបំផុតខាងដើមនេះកើតឡើង កាលបើទីបំផុតខាងដើមនេះមិនមាន ទីបំផុតខាងចុងនេះក៏មិនមាន ទីបំផុតខាងចុងនេះរលត់ទៅ ព្រោះទីបំផុតខាងដើមនេះរលត់ទៅ ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចរលឹកឃើញបុព្វេនិវាសនោះ តាមកំណត់ដែលខ្ញុំព្រះអង្គត្រូវឃើញច្បាស់ ដោយអត្តភាពនេះ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នោះបានទេ ខ្ញុំព្រះអង្គនឹងរលឹក ឃើញបុព្វេ-និវាសច្រើនប្រការ គឺរលឹកឃើញ ជាតិ ១ ជាតិ ២ ជាតិ ៣ ។បេ។ នឹងរលឹកឃើញបុព្វេនិវាសមានច្រើនប្រការព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ដូចជាព្រះមានព្រះភាគដូចម្តេចបាន បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូម្បីតែបង្សុបិសាច ( បិសាចដែលកើតក្នុងទីស្មោកគ្រោក ) ក៏ខ្ញុំព្រះអង្គមើលមិនឃើញផង ចុះនឹងឲ្យខ្ញុំព្រះអង្គរលឹកឃើញពួកសត្វដែលច្យុត ដែលកើតថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ។បេ។ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលទៅតាមយថាកម្ម ដោយទិព្វចក្ខុបរិសុទ្ធ កន្លងចក្ខុរបស់មនុស្សសាមញ្ញ ដូចជាព្រះមានព្រះភាគដូចម្តេចបាន បពិត្រព្រះអង្គដ៏ចម្រើន ពាក្យដែលព្រះអង្គបានត្រាស់នឹងខ្ញុំ

ព្រះអង្គយ៉ាងនេះថា ម្នាលឧទាយិ ណ្ហើយចុះ ទីបំផុតខាងដើមលើកទុក ទីបំផុតខាងចុងក៏លើកទុកចុះ តថាគតនឹងសម្តែងធម៌ដល់អ្នក កាលបើទីបំផុតខាងដើមនេះមាន ទីបំផុតខាងចុងនេះក៏មាន ទីបំផុតខាងចុងនេះកើតឡើងបាន ព្រោះទីបំផុតខាងដើមនេះកើតឡើង កាលបើទីបំផុតខាងដើមនេះមិនមាន ទីបំផុតខាងចុងនេះក៏មិនមាន ទីបំផុតខាងចុងនេះរលត់ទៅព្រោះទីបំផុតខាងដើមនេះរលត់ទៅ ដូច្នេះ ឥឡូវពាក្យនោះមិនទាន់ប្រាជក ដល់ខ្ញុំព្រះអង្គដោយលើសលន់ពន់ប្រមាណនៅឡើយទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាកដជានឹងធ្វើព្រះហឫទ័យនៃព្រះមានព្រះភាគ ឲ្យរីករាយដោយសារការដោះប្រស្នា ក្នុងលទ្ធិអាចារ្យ ជារបស់ខ្លួនបាន ។

[ ១៣៣ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ហេតុដូចម្តេច ដែលមានក្នុងលទ្ធិអាចារ្យ ជារបស់ខ្លួននៃអ្នក ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ឧត្តម នេះជាពន្លឺដ៏ឧត្តម ។ ព្រះអង្គត្រាស់ថា ការណ៍ដែលអ្នកត្រិះរិះក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ឧត្តម នេះជាពន្លឺដ៏ឧត្តម ចុះពន្លឺដ៏ឧត្តមនោះតើដូចម្តេច ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពន្លឺណាដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះជាពន្លឺដ៏ឧត្តម ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ពន្លឺដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន នោះតើដូចម្តេច ។ សកុលទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពន្លឺណាដែលរកពន្លឺដទៃប្រសើរជាង

ឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តម ។

[ ១៣៤ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ វាចារបស់អ្នកនុ៎ះផ្សាយទៅវែងពេកណាស់ ព្រោះអ្នកពោលថា ពន្លឺដែលរកពន្លឺដទៃប្រសើរជាង ឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តម ដូច្នេះផង ទាំងមិនកំណត់នូវពន្លឺនោះផង ។ ម្នាលឧទាយិ ដូចបុរសនិយាយយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននាងជនបទកល្យាណី ក្នុងជនបទនេះ ។ ពួកអ្នកផងសួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកប្រាថ្នាចង់បាននាងជនបទកល្យាណីណា អ្នកស្គាល់នាងជនបទកល្យាណីនោះ ថាជាក្សត្រី ឬព្រាហ្មណី ជាវេស្សី ឬសុទ្ទីដែរឬ ។ បុរសនោះ ដែលអ្នកផងសួរដូច្នេះ ក៏ឆ្លើយតបវិញថា ខ្ញុំមិនស្គាល់ទេ ។ អ្នកផងសួរបុរសនោះទៀតថា នែបុរសដ៏ចម្រើន អ្នកប្រាថ្នាចង់បាននាងជនបទកល្យាណីណា អ្នកស្គាល់នាងជនបទកល្យាណីនោះថា មានជាតិយ៉ាងនេះ មានគោត្រយ៉ាងនេះ ។បេ។ ខ្ពស់ ឬទាប ឬកណ្តាល សម្បុរខ្មៅ ឬខ្មៅស្រអែម ឬសម្បុរសណ្តែកបាយ នៅក្នុងស្រុក និគម នឹងនគរឯណោះដែរឬទេ ។ បុរសនោះដែលគេសួរដូច្នេះ ក៏ឆ្លើយតបថា ខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយនិយាយនឹងបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកមិនដែលស្គាល់ មិនដែលឃើញនាងជបទកល្យាណីណាសោះ ហើយស្រាប់តែប្រាថ្នា ចង់បាននាងនោះឬ បុរសនោះដែលអ្នកផងសួរដូច្នេះ ក៏ឆ្លើយតបថា បាទ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច កាលបើយ៉ាងនេះ ពាក្យរបស់បុរសនោះ ក្រែងយកជាការមិនបានទេដឹង ។ សកុលុទាយិក្រាប

បង្គំទូលថា ពិតមែនហើយព្រះអង្គ កាលបើយ៉ាងនេះ ពាក្យរបស់បុរសនោះយកជាការពុំបានទេ ។ ព្រះអង្គត្រាស់ថា ម្នាលឧទាយិអ្នកនិយាយថា បពិត្រព្រះអង្គដ៏ចម្រើន ពន្លឺណាដែលរកពន្លឺដទៃប្រសើរជាងឧត្តមជាងគ្មាន ពន្លឺនោះទើបជាពន្លឺដ៏ឧត្តមដូច្នេះផង ទាំងមិនកំណត់នូវពន្លឺនោះផង ក៏យ៉ាងនោះឯង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កែវមណីនិងកែវពៃទូរ្យ មានពន្លឺល្អ មានជ្រុង ៨ ដែលជាងច្នៃល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺប្រាលរន្ទាល យ៉ាងណា អត្តាបន្ទាប់អំពីមរណៈទៅ ក៏មានពន្លឺ ឥតមានរោគ យ៉ាងនោះដែរ ។

[ ១៣៥ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច កែវមណី និងកែវពៃទូរ្យ ដែលមានពន្លឺល្អ មានជ្រុង ៨ ដែលជាងច្នៃល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺប្រាស រន្ទាល និងអំពិលអំពែកដែលជាកិមិជាតិ ក្នុងវេលាយប់ងងឹតអ័ព្ទ បណ្តាពន្លឺ ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងប្រសើរជាង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលាយប់ងងឹតអ័ព្ទ បណ្តាពន្លឺទាំង ២ នេះ ពន្លឺអំពិលអំពែកដែលជាកិមិជាតិ ភ្លឺជាង ប្រសើរជាង ។

[ ១៣៦ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច អំពិលអំពែកដែលជាកិមិជាតិ ក្នុងវេលាយប់ងងឹតអ័ព្ទ និងប្រទីបប្រេងក្នុងវេលាយប់ងងឹតអ័ព្ទ បណ្តាពន្លឺទាំង ២ នេះ ពន្លឺណា ភ្លឺជាង ប្រសើរជាង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលាយប់ងងឹតអ័ព្ទ

បណ្តាពន្លឺទាំង ២ នេះ ប្រទីបប្រេងក្តីជាង ប្រសើរជាង ។

[ ១៣៧ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ប្រទីបប្រេង ក្នុងវេលាយប់ងងឹតអ័ព្ទ នឹងគំនរភ្លើងធំក្នុងវេលាយប់ងងឹតអ័ព្ទ បណ្តាពន្លឺទាំង ២ នេះ ពន្លឺណាក្តីជាង ប្រសើរជាង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវេលាយប់ងងឹតអ័ព្ទ បណ្តាពន្លឺទាំង ២ នេះ ពន្លឺគំនរភ្លើងធំក្តីជាង ប្រសើរជាង ។

[ ១៣៨ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច គំនរភ្លើង ក្នុងវេលាយប់ងងឹតអ័ព្ទ នឹងផ្កាយព្រឹកក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រី បណ្តាពន្លឺទាំង ២ នេះ ពន្លឺណា ក្តីជាង ប្រសើរជាង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បណ្តាពន្លឺទាំង ២ នេះ ពន្លឺផ្កាយព្រឹកក្នុងកាល ដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រីនេះ ក្តីជាង ប្រសើរជាង ។

[ ១៣៩ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ផ្កាយព្រឹកក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក ទៀបបច្ចូសសម័យនៃរាត្រី នឹងព្រះចន្ទក្នុងវេលាពាក់កណ្តាលអាធ្រាត្រ មិនទាន់ជ្រេក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត បណ្តាពន្លឺទាំង ២ នេះ ពន្លឺណាក្តីជាង ប្រសើរជាង ។ សកុលុទាយិក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បណ្តាពន្លឺទាំង ២ នេះ ពន្លឺព្រះចន្ទ

ក្នុងវេលាពាក់កណ្តាលអធ្រាត្រ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត នេះក្តីជាង ប្រសើរជាង ។

[ ១៤០ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ព្រះចន្ទក្នុងវេលាពាក់កណ្តាលអធ្រាត្រ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពក នាថ្ងៃឧបោសថ ១៥ កើត នឹងព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពកក្នុងសរទសម័យ នាខែខាងចុងនៃវស្សានរដូវ បណ្តាពន្លឺទាំង ២ នេះ ពន្លឺណាក្តីជាង ប្រសើរជាង ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន បណ្តាពន្លឺទាំង ២ នោះ ពន្លឺព្រះអាទិត្យក្នុងវេលាថ្ងៃត្រង់ មិនទាន់ជ្រេ ក្នុងកាលដែលមេឃស្វាងភ្លៀង ខ្ពស់ស្រឡះអំពីពពកក្នុងសរទសម័យ នាខែជាខាងចុងនៃវស្សារដូវ ពន្លឺនេះក្តីជាង ប្រសើរជាង ។ ម្នាលឧទាយិ ពួកទេវតា ដែលមិនបាច់ប្រើពន្លឺព្រះចន្ទ និងព្រះអាទិត្យនេះ មានច្រើនក្រៃលែងច្រើន តថាគតក៏ស្គាល់ច្បាស់នូវទេវតាទាំងនោះដែរ តែតថាគតមិនពោលថា ពន្លឺណាឥតមានពន្លឺដទៃ ប្រសើរជាង ឧត្តមជាងដូច្នេះទេ ម្នាលឧទាយិ ចំណែកខាងអ្នកឯង ពោលថា ពន្លឺណាដែលថោកទាបជាង អន់ជាង ពន្លឺអំពិលអំពែក ជាកិមិជាតិ ពន្លឺនោះជាពន្លឺប្រសើរដូច្នេះផង ទាំងមិនបានកំណត់ពន្លឺនោះផង ។ បពិត្រព្រះមានព្រះភាគ សូមទ្រង់ស្ទេះពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់ស្ទេះពាក្យនេះទុកចុះ។ ម្នាលឧទាយិ ម្តេចក៏អ្នកឯងនិយាយថា បពិត្រព្រះមានព្រះភាគ សូមទ្រង់

ស្ទះពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់ស្ទះពាក្យនេះទុកចុះដូច្នេះ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ ក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា នេះជាពន្លឺដ៏ប្រសើរ នេះជាពន្លឺដ៏ប្រសើរ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ កាលបើព្រះមានព្រះភាគសាកសួរ ចោទប្រកាន់ដេញដោល ក្នុងលទ្ធិអាចារ្យជារបស់ខ្លួន ( យ៉ាងនេះ ) ក៏ជាបុគ្គលសោះសូន្យទទេ ឥតបានការសោះ ។

[ ១៤១ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ លោកមានសេចក្តីសុខដោយចំណែកមួយ ចុះបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខ ដោយចំណែកមួយ មានដែរឬទេ ។ សកុលុទាយិ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានតែសេចក្តីសុខដោយចំណែកមួយក៏មាន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយក៏មាន ។ ម្នាលឧទាយិ ចុះបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខដោយចំណែកមួយ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកមួយ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត លះបង់អទិន្នាទាន វៀរស្រឡះ ចាកអទិន្នាទាន លះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆាចារ លះបង់មុសាវាទ វៀរស្រឡះចាកមុសាវាទ ម្យ៉ាងទៀត បានប្រព្រឹត្តសមាទាននូវតបៈគុណណាមួយ បពិត្រព្រះអង្គដ៏ចម្រើននេះហៅថា បដិបទាប្រកបដោយហេតុដើម្បី

ធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខដោយចំណែកមួយ ។

[ ១៤២ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ( បើ ) បុគ្គលលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខ ទាំងទុក្ខ ។ សកុលុទាយិ ក្រាបបង្គំទូលថា មានទាំងសុខ ទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ( បើ ) បុគ្គលលះបង់អទិន្នាទានវៀរស្រឡះចាកអទិន្នាទាន ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខ ទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខ ព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ( បើ ) បុគ្គលលះបង់កាមេសុមិច្ឆាចារ វៀរស្រឡះចាកកាមេសុមិច្ឆា-ចារ ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្ត សេចក្តីនោះដូចម្តេច ( បើ ) បុគ្គលលះបង់មុសាវាទ វៀរស្រឡះចាក មុសាវាទក្នុងសម័យណា សម័យនោះ តើអត្តាមាន តែសេចក្តីសុខ ដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច ( បើ ) បុគ្គលសមាទានប្រព្រឹត្តតបគុណណាមួយ ក្នុងសម័យណា សម័យនោះ តើអត្តាមានតែសេចក្តីសុខដោយចំណែកមួយ ឬមានទាំងសុខទាំងទុក្ខ ។ មានទាំងសុខទាំងទុក្ខព្រះអង្គ ។ ម្នាលឧទាយិ អ្នកចូលចិត្តសេចក្តីនោះដូចម្តេច

ការធ្វើឲ្យជាក់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ ព្រោះអាស្រ័យបដិបទាដែលមានសុខ និងទុក្ខ លាយឡំគ្នាបានដែរឬ ។ បពិត្រព្រះមានព្រះភាគ សូមទ្រង់លើកពាក្យនេះទុក បពិត្រព្រះសុគត សូមទ្រង់លើកពាក្យនេះទុក ។ ម្នាលឧទាយិ ម្តេចក៏អ្នកនិយាយថា បពិត្រព្រះមានព្រះភាគ សូមទ្រង់លើកពាក្យនេះទុកចុះ បពិត្រព្រះសុគត សូមទ្រង់លើកពាក្យនេះទុកចុះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះក្នុងលទ្ធិអាចារ្យជារបស់ខ្លួនយ៉ាងនេះថា លោកដែលមានសេចក្តីសុខ ដោយចំណែកមួយក៏មាន បដិបទាដែលប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយ ចំណែកមួយក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ កាលបើព្រះមានព្រះភាគសាកសួរ ដេញដោលក្នុងលទ្ធិអាចារ្យជារបស់ខ្លួន ( យ៉ាងនេះ ) ក៏ជាបុគ្គលសោះសូន្យទទេ មិនបានការសោះ បពិត្រព្រះអង្គដ៏ចម្រើន ចុះលោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយ បដិបទាដែលប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានតែសេចក្តីសុខដោយចំណែកមួយមានដែរឬ ។ ម្នាលឧទាយិ លោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយក៏មាន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែក មួយក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ តើដូចម្តេច ។

[ ១៨៣ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ស្ងាត់

ចាកកាមទាំងឡាយ ។បេ។ ចូលបឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ។បេ។ ចូលទុតិយជ្ឈាន ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ព្រោះប្រាសចាកបីតិ ។បេ។ ចូលតតិយជ្ឈាន សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលឧទាយិ នេះឯងហៅថា បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានសេចក្តីសុខដោយចំណែកមួយ ។ បពិត្រព្រះអង្គដ៏ចម្រើន បដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយ តើដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន ចុះលោកមានតែសេចក្តីសុខ ដោយចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ តើមានតែប៉ុណ្ណោះទេឬ ។ ម្នាលឧទាយិ លោកមានតែសេចក្តីសុខ ដោយចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ទាំងបដិបទាប្រកបដោយហេតុ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវលោកដែលមានតែសេចក្តីសុខ ដោយចំណែកមួយនោះ ក៏មិនមានត្រឹមតែប៉ុណ្ណោះដែរទេ ។

[ ១៤៤ ] កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ ពួកបរិសទ្យរបស់សកុលុទាយិបរិព្វាជក ក៏បន្លឺសំឡេងខ្ពស់ សំឡេងខ្លាំងថា ពួកយើងព្រមទាំងអាចារ្យ មិនទាន់ពេញចិត្តក្នុងហេតុនេះទេ ពួកយើងព្រមទាំងអាចារ្យ មិនទាន់ពេញចិត្តក្នុងហេតុនេះទេ ពួកយើងមិនទាន់ដឹងច្បាស់នូវគុណជាតិដ៏ក្រៃលែងជាងនេះទៅទៀតឡើយ ។ ខណៈនោះ សកុលុទាយិបរិព្វាជក ធ្វើពួកបរិព្វាជកទាំងនោះ ឲ្យមានសំឡេងតិច ហើយក្រាបបង្គំទូលសួរព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះលោកមានតែសេចក្តីសុខ ដោយ

ចំណែកមួយ ដែលបុគ្គលធ្វើឲ្យជាក់ច្បាស់ តើមានប៉ុន្មាន ។

[ ១៨៥ ] ម្នាលឧទាយិ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខ ។បេ។ ចូលចតុត្ថជ្ឈាន ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ទេវតាទាំងប៉ុន្មាន បានកើតក្នុងលោកដែលលមានតែសេចក្តីសុខដោយចំណែកមួយ ភិក្ខុនោះ រមែងឋិតនៅ រមែងចរចា រមែងសាកច្ឆា មួយអន្លើដោយទេវតា ទាំងប៉ុណ្ណោះ ម្នាលឧទាយិ លោកមានតែសេចក្តីសុខដោយចំណែកមួយដែលបុគ្គលធ្វើឲ្យជាក់ច្បាស់មានតែប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់របស់ព្រះមានព្រះភាគ ព្រោះតែធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយ តែប៉ុណ្ណោះ ទេឬ ។ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត មិនមែនព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវលោក ដែលមានតែសេចក្តីសុខដោយចំណែកមួយនុ៎ះទេ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវពួកធម៌ដទៃ ដែលប្រសើរជាង ឧត្តមជាងនៅទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលប្រសើរជាងឧត្តមជាងនោះ តើដូចម្តេច ។

[ ១៨៦ ] ព្រះអង្គត្រាស់ថា ម្នាលឧទាយិ ព្រះតថាគតទ្រង់កើតឡើងក្នុងលោកនេះជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយគុណរកបុគ្គលស្មើគ្មាន

ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្តាចារ្យរបស់ទេវតា និងមនុស្ស ទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច មិនវិលត្រឡប់មក កាន់ភព ថ្មីទៀត ។បេ។ ព្រះអង្គលះបង់នូវនីវរណធម៌ទាំង ៥ នេះ ដែលជាឧបក្កិ-លេសរបស់ចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយ ទ្រង់ស្ងាត់ចាកកាម ទាំង ឡាយ ។បេ។ ចូលបឋមជ្ឈាន ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង នេះឯង ។ ម្នាលឧទាយិ ន័យមួយទៀត ព្រោះរម្ងាប់វិតក្កៈ និង វិចារៈ ។បេ។ ចូលទុតិយជ្ឈាន... តតិយជ្ឈាន... ចតុត្ថជ្ឈាន ក៏សម្រេចនូវនៅ ដោយឥរិយាបថទាំង ៤ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុង សំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាងនេះឯង ។

[ ១៤៧ ] កាលបើចិត្តតម្កល់នឹង ជាចិត្តបរិសុទ្ធផូរផង់ ឥតមានទីទួល ពោលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជា ចិត្តនឹងធឹង ដល់នូវការមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ រមែងបង្អោន ចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរមែងរលឹកឃើញនូវបុព្វេ និវាស មានច្រើនប្រការ គឺជាតិ ១ ជាតិ ២ ។បេ។ រលឹកឃើញនូវបុព្វេ និវាស មានច្រើនប្រការ ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស ដោយប្រការ ដូច្នេះ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះ ហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលប្រសើរជាង ឧត្តមជាង នេះឯង ។

កាលបើចិត្ត ( របស់ភិក្ខុនោះ ) តម្កល់នៅល្អ ជាចិត្តបរិសុទ្ធ ផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនៅកម្ម ជាចិត្តនឹងធឹង ដល់នូវការៈមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្ត ដើម្បីចុតូបបាតញ្ញាណនៃសត្វទាំងឡាយ ភិក្ខុនោះរមែងមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ ភិក្ខុនោះរមែងឃើញពួកសត្វដែលទៅតាមយថាកម្ម ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាងនេះឯង ។ កាលបើចិត្ត ( របស់ភិក្ខុនោះ ) តម្កល់នៅនឹង ជាចិត្តបរិសុទ្ធ ផូរផង់ មិនមានទីទួលពោលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនៅកម្ម ជាចិត្តនឹងធឹង ដល់នូវការៈមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះរមែងបង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះរមែងដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។បេ។ នេះជាទីរម្ងត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាអាសវៈ ។បេ។ នេះជាហេតុឲ្យកើតអាសវៈ ។បេ។ នេះជាទីរម្ងត់អាសវៈ ដឹងច្បាស់តាមសេចក្តីពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរម្ងត់អាសវៈ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរមែងរួចស្រឡះចាកកាមាសវៈ ចិត្តរមែងរួចស្រឡះចាកភវាសវៈ ចិត្តរមែង

រួចស្រឡះចាកអវិជ្ជាសវៈ កាលបើចិត្តរួចស្រឡះហើយ ក៏មានសេចក្តីដឹងថា ចិត្តរួចស្រឡះហើយ ភិក្ខុនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបាននៅរួចហើយ សោឡសកិច្ចក៏អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង នេះឯង ។ ម្នាលឧទាយិ ពួកភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់តថាគត ព្រោះហេតុតែធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលប្រសើរជាង ឧត្តមជាង ទាំងនេះឯង ។

[ ១៤៨ ] កាលបើព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ សកុលុទាយិបរិព្វាជក ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺណាស់ បពិត្រព្រះអង្គដ៏ចម្រើន ភ្លឺណាស់ ព្រោះថា ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយនេះឯង ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ឬដូចជាបុគ្គល ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកនឹងមើលឃើញនូវរូបបាន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវបព្វជ្ជា គួរបាននូវឧបសម្បទា ក្នុងសំណាក់ព្រះមានព្រះភាគ ។

[ ១៤៩ ] កាលសកុលុទាយបរិព្វាជក និយាយយ៉ាងនេះហើយ បរិសទ្យ

របស់សកុលុទាយិបរិព្វាជក ក៏និយាយនឹងសកុលុទាយិបរិព្វាជក ដូច្នេះថា បពិត្រលោកឧទាយិដ៏ចម្រើន លោកកុំប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម សូមលោកឧទាយិដ៏ចម្រើនទៅជាអាចារ្យ កុំជាអន្តេវាសិកគេឡើយ ឲ្យដូចជាក្អមទឹកទៅពេញដោយទឹកដដែល សូមលោកឧទាយិដ៏ចម្រើន កុំប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះសមណគោតម សូមលោកឧទាយិដ៏ចម្រើន នៅជាអាចារ្យដដែល កុំជាអន្តេវាសិកគេឡើយ ។ បរិសទ្យរបស់សកុលុទាយិបរិព្វាជក ធ្វើសេចក្តីអន្តរាយយ៉ាងនេះ ដល់សកុលុទាយិ-បរិព្វាជក ក្នុងការប្រព្រឹត្តិព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

ចប់ ចូឡសកុលុទាយិសូត្រទី ៩

# អដ្ឋកថា

## ចូឡសកុលុទាយិសូត្រ

[ ១២៨ ] ចូឡសកុលុទាយិសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៣០ ] ក្នុងបទទាំងនោះ បទថា **យទា បន ភន្តេ ភគវា** គឺបរិព្វាជកបំណងនឹងស្ដាប់ធម្មកថានេះ ដើម្បីសម្ដែងការមានអាល័យ ក្នុងព្រះធម្មទេសនា ទើបពោលហើយ ។ បទថា **តញ្ញេវេត្ថ បដិភាតុ** សេចក្ដីថា បើអ្នកបំណងនឹងស្ដាប់ធម៌ បញ្ហាមួយ ហេតុមួយ ចូរប្រាកដដល់អ្នក ។ បទថា **យថា មំ បដិភាសេយ្យ** គឺជាហេតុដែលឲ្យធម្មទេសនាប្រាកដដល់ខ្ញុំ ។ លោកសម្ដែងថា កាលកថាតាំងឡើងដោយហេតុនោះ ដើម្បីនឹងស្ដាប់ធម៌បានសប្បាយ ។

[ ១៣១ ] បទថា **តស្ស មយ្ហំ ភន្តេ** សេចក្ដីថា សកុលុទាយិបរិព្វាជកនោះឃើញព្រះមានព្រះភាគនោះ គិតថា បើព្រះមានព្រះភាគប្រថាប់នៅក្នុងទីនេះ សេចក្ដីនៃភាសិតនេះនឹងប្រាកដ ទើបរឭកដល់ព្រះទសពលថា ព្រះទសពលទ្រង់នឹងធ្វើអត្ថឲ្យប្រាកដ ដូចឲ្យប្រទីប ១០០០ ដួង ដ៏រុងរឿងដូច្នោះ ។ ព្រោះដូច្នោះ ទើបសកុលុទាយិបរិព្វាជកបានពោលពាក្យថា **តស្ស មយ្ហំ ភន្តេ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អហោ នូន** ជានិបាតចុះ ក្នុងអត្ថថា ជាទីរឭកដល់ ។ ដោយហេតុនោះ កាលសកុលុទាយិបរិព្វាជក រឭកដល់ព្រះមានព្រះភាគ ទើបមានការរឭកដល់ថា **អហោ នូន**

**ភគវា អហោ ឆ្វន សុគតោ** ដូច្នេះ ។ បទថា **យោ ធម្មេសុ** សេចក្តីថា ព្រះមានព្រះភាគអង្គណាជាអ្នកឈ្លាសល្អ ឈ្លាសដោយល្អ ជំនាញមុតស្រួចក្នុងធម៌ទាំងនេះ ព្រះមានព្រះភាគអង្គនោះ ទ្រង់គប្បីពោលពិត ។ ព្រះសុគតអង្គនោះ ទ្រង់គប្បីពោលពិត ។ ព្រោះកិលេសជាគ្រឿងដល់នូវភពធំតូចតែម្យ៉ាងមួយសែនកោដិមិនតិច ប្រាកដដល់បុព្វេនិវាសញ្ញាណនៃព្រះមានព្រះភាគអង្គនោះ នេះជាអធិប្បាយក្នុងបទនេះ ដោយប្រការដូច្នេះ ។

[ ១៣២ ] បទថា **តស្ស វាហំ បុព្វន្តំ អារព្ភ** សេចក្តីថា ពិតហើយ បុគ្គលណាជាអ្នកមានលាភ បុគ្គលនោះ កាលគេពោលថា កាលមុន អ្នកបានជាក្សត្រ បានជាព្រាហ្មណ៍ កាលដឹងនឹងស្តាប់ដោយគោរព ។ ចំណែកបុគ្គលមិនមានលាភ នឹងជាយ៉ាងនេះ នឹងជាយ៉ាងនេះ ដូច្នេះក៏មាន បុគ្គលនោះរមែងសម្តែងត្រឹមតែកម្មប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា តថាគតគប្បីញ៉ាំងចិត្តរបស់បុគ្គលនោះ ឲ្យត្រេកអរបានដោយការព្យាករណ៍ បញ្ហាប្រារព្ធខន្ធអតីត ដូច្នេះ ។ បទថា **សោ វា មំ អបរន្តំ** គឺព្រោះអនាគតំសញ្ញាណ រមែងសម្រេចដល់បុគ្គលអ្នកបានទិព្វ-ចក្ខុ ។ ព្រោះ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ បទក្រៅអំពីនេះ មានន័យ ដូចបានពោលហើយខាងដើម ។

បទថា **ធម្មំ តេ ទេសិស្សាមិ** សេចក្តីថា បានឮថា សកុលុទាយិ-បរិព្វាជកនេះ កាលសម្តែងដល់ខន្ធក្នុងអតីត ក៏មិនដឹង បើសម្តែងដល់ខន្ធអនាគត ក៏មិនដឹង កាលបើដូច្នោះ ព្រះមានព្រះភាគបំណងនឹងសម្តែង

ដល់បច្ចយាការដ៏ល្អិតល្អន់ ទើបត្រាស់យ៉ាងនោះ ។ សកុលុទាយិនោះនឹងដឹងខន្ធនោះបានឬ ក៏គង់មិនដឹងខន្ធនោះភ្លាមៗ បាន តែនឹងជាបច្ច័យនៃវាសនារបស់គាត់ក្នុងអនាគត ព្រះមានព្រះភាគ ទ្រង់ឃើញដូច្នេះ ទើបត្រាស់យ៉ាងនោះ ។ បទថា **បំសុបិសាចកំ** គឺបិសាចដែលកើតក្នុងទីមិនស្អាត ។ ព្រោះថាបិសាចនោះ កាន់យកឫសឈើមួយហើយ មិនប្រាកដកាយ ។

មានរឿងតំណាលថា យក្ខិនីម្នាក់ឲ្យកូន ២ នាក់ អង្គុយត្រង់ទ្វារវត្តបុព្វារាម ហើយចូលទៅក្នុងក្រុង ដើម្បីស្វែងរកអាហារ ។ ពួកក្មេងឃើញព្រះថេរៈ កំពុងបិណ្ឌបាតមួយរូប ទើបពោលថា បពិត្រលោកម្ចាស់ ម្តាយរបស់ពួកខ្ញុំចូលទៅក្នុងព្រះនគរ បើលោកម្ចាស់ឃើញ ជួយប្រាប់ដល់ម្តាយនោះថា បើបានវត្ថុណា ចូរកាន់យកវត្ថុដែលបានហើយ ប្រញាប់ត្រឡប់មកវិញ ពួកក្មេងទាំងនោះមិន អាចរង់ចាំបាន ព្រោះការស្រេកឃ្លាន ។ ព្រះថេរៈសួរថា អាត្មានឹងឃើញម្តាយរបស់អ្នកបានដូចម្តេច ទើបពួកក្មេងពោលថា សូមលោកម្ចាស់កាន់ ឫសឈើនេះចុះ ហើយបានឲ្យឫសឈើមួយកំណាត់ យក្ខច្រើនពាន់ បានប្រាកដដល់ព្រះថេរៈ ព្រះថេរៈបានឃើញយក្ខិនីនោះ ដោយសញ្ញាដែលពួកក្មេងឲ្យ ។ ព្រះថេរៈឃើញយក្ខិនីមានរូបរាងគួរខ្ពើម គួរខ្លាច កំពុងតែដើររក វត្ថុស្មោកគ្រោកតាមថ្នល់តែម្យ៉ាង ទើបពោលសេចក្តីនេះ កាលយក្ខិនីសួរថា លោកម្ចាស់ឃើញខ្ញុំបានដូចម្តេច ទើបព្រះថេរៈបង្ហាញកំណាត់ឫសឈើឲ្យមើល យក្ខិនីកញ្ឆក់ឫសឈើយកទៅ ។ បិសាចប្រឡាក់ធូលីទាំងឡាយកាន់ ឫសឈើមួយ ហើយមិនប្រាកដកាយ ដោយប្រការដូច្នេះ ។

សកុលុទាយិបរិព្វាជកនោះពោលថា សូម្បីបិសាចធូលី ខ្ញុំព្រះអង្គមើលមិនឃើញឡើយ សំដៅដល់យក្ខិនីនោះ ។ បទថា **ន បក្ខាយតិ** គឺមិនឃើញ មិនប្រាកដ ។

[ ១៨៤ ] បទថា **ឌីឃាបិ ខោ តេ ឯសា** សេចក្តីថា ម្នាលឧទាយិ វាចារបស់អ្នកនោះ គប្បីពង្រីកចេញបានយ៉ាងយឺតយ៉ាវ ។ អធិប្បាយថា កាលពោលយ៉ាងនោះ គប្បីប្រព្រឹត្តទៅ ១០០ ឆ្នាំខ្លះ ១០០០ ឆ្នាំខ្លះ ហើយ វាចានោះ មិនគប្បីសម្តែងដើម្បីប្រយោជន៍ឡើយ ។ បទថា **អប្បាដិហីរកតំ** សេចក្តីថា ពាក្យនោះដល់នូវភាពជាពាក្យមិននាំសត្វចេញទៅ មិនមានតម្លៃ មិនមានប្រយោជន៍ ។ ឥឡូវនេះ កាលសកុលុទាយិបរិព្វាជកសម្តែងដល់វណ្ណៈនោះ ទើបពោលពាក្យថា **សេយ្យថាបិ ភន្តេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **បណ្ឌុកម្ពលេ និក្ខិត្តោ** គឺដាក់កែវពៃទូរ្យនោះទុកត្រង់សំពត់កម្ពលពណ៌លឿង ដែលមានពណ៌មិនស្មើគ្នា ។ បទថា **ឯវំវណ្ណោ អត្តា ហោតិ** នេះ សកុលុទាយីពោលពាក្យនេះថា តួខ្លួននោះក្នុងវេលាយើងស្លាប់ រមែងរុងរឿងដូចខ្លួនក្នុងសុភកិណ្ហទេវលោក សំដៅដល់ខ្លួនដែលកើតក្នុងសុភកិណ្ហទេវលោក ។

[ ១៨៥ ] បទថា **អយំ ឥមេសំ ឧភិន្នំ** សេចក្តីថា រស្មីរបស់កែវមណីមិនផ្សាយចេញខាងក្រៅ ពន្លឺរបស់អំពិលអំពែកដ៏តូច ផ្សាយចេញទៅត្រឹម ១ ធ្នាប់ ២ ធ្នាប់ និង ៤ ធ្នាប់ ឯពន្លឺអំពិលអំពែកដែលមានខ្លួនធំ រមែងផ្សាយចេញទៅប្រមាណប៉ុនបរិវេណលានបោកស្រូវ ព្រោះដូច្នោះ ទើប

សកុលុទាយីពោលយ៉ាងនោះ ។

[ ១៣៨ ] បទថា **វិគ្គេ** គឺក្លីព្រោងព្រាយ អធិប្បាយថា នៅឆ្ងាយដោយប្រាសចាកពពក ។ បទថា **វិគតវលាហកេ** គឺប្រាសចាកពពក ។ បទថា **ទេវេ** គឺភ្លៀង ។ បទថា **ឱសធិតារកា** គឺផ្កាយព្រឹក ។ ពិតហើយ ព្រោះអាចារ្យពួកខ្លះពោលថា ជនទាំងឡាយកាន់យកឱសថដោយ សញ្ញាណនោះ តាំងអំពីផ្កាយព្រឹករះ ដូច្នោះ ទើបផ្កាយនោះលោកហៅថា **ឱសធិតា-រកា** ។

[ ១៣៩ ] បទថា **អភិទោ អឌ្ឍរត្តសមយំ** គឺព្រះចន្ទក្នុងកណ្ដាលយប់ ។ ដោយបទនេះ លោកសម្ដែងដល់ព្រះចន្ទដែលតាំងនៅក្នុងសម័យ គឺក្នុងកណ្ដាលមេឃ ។ ក្នុងបទថា **អភិទោ មជ្ឈន្តិកេ** គឺព្រះអាទិត្យក្នុងពេលថ្ងៃត្រង់ ក៏មានន័យដូចគ្នា ។ បទថា **តតោ ពហូ** គឺទេវតាទាំងនោះមានច្រើនជាង គឺច្រើនជាងនោះ ។ អធិប្បាយថា មានច្រើន និងមានច្រើនជាង ។ បទថា **អាភា នានុភោន្តិ** គឺមិនអាចប្រៀប នឹងពន្លឺព្រះចន្ទ ព្រះអាទិត្យបាន ។ ពន្លឺព្រះចន្ទ និងព្រះអាទិត្យ រមែងបញ្ចេញពន្លឺដោយពន្លឺក្នុងខ្លួនរបស់ខ្លួនឯង ។

[ ១៤១ ] ឥឡូវនេះ ព្រោះសកុលុទាយីគិតថា អញនឹងសួរដល់លោកមានសេចក្ដីសុខដោយចំណែកមួយ ទើបអង្គុយស្ងៀម គេចសំណួរ ។ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ឲ្យសកុលុទាយីរឭកដល់សំណួរបាន ទើបត្រាស់ពាក្យថា **កឹ បន ឧទាយិ អត្ថិ ឯកន្តសុខោ លោកោ** ម្នាលឧទាយិ លោកមានសេចក្ដីសុខ ដោយចំណែកមួយ មានដែរឬទេ ។ ក្នុងបទទាំងនោះ

បទថា **អាការវតី** គឺមានហេតុ ។ បទថា **អញ្ញតរំ វា បន តបោគុណំ** សេចក្ដីថា គុណគឺតបៈណាមួយ ព្រះមានព្រះភាគត្រាស់សំដៅដល់លទ្ធិរបស់អចេលក៍ គឺវៀរចាកការផឹកសុរា ។ ព្រោះហេតុអ្វី ទើបសកុលុទាយីសួរថា បពិត្រព្រះអង្គដ៏ចម្រើន លោកមានសេចក្ដីសុខ ដោយចំណែកមួយមានឬ ។ បានឮថា សកុលុទាយីនោះ បានគិតថា សូម្បីអញក៏ពោលថា ខ្លួនមានសេចក្ដីសុខ ដោយចំណែកមួយ ។ម៉្យាងទៀត អញនឹងពោលបដិបទាជាសុខក្នុងកាលខ្លះ ជាទុក្ខក្នុងកាលខ្លះ ។ សូម្បីបដិបទារបស់ខ្លួន បុគ្គលមានសេចក្ដីសុខដោយចំណែកមួយ ក៏គប្បីមានសេចក្ដីសុខដោយចំណែកមួយ ។ កថារបស់ពួកយើង ជាកថាមិននាំសត្វចេញទៅ ។ ឯកថារបស់ព្រះសាស្ដាជាកថានាំសត្វចេញទៅ ព្រោះហេតុនោះ ឥឡូវនេះ អញនឹងសួរព្រះសាស្ដាហើយ ទើបដឹង ព្រោះដូច្នោះ ទើបបរិញ្វជកសួរ ។

[ ១៨៤ ] បទថា **ឯត្ថ មយំ អនស្សាម** គឺពួកយើងមិនត្រេកអរក្នុងហេតុនេះ ព្រោះហេតុអ្វី ទើបបរិស័ទរបស់សកុលុទាយិបរិញ្វជកបានពោលយ៉ាងនោះ ។ បានឮថា បរិស័ទរបស់សកុលុទាយិបរិញ្វជកទាំងនោះដឹងថា កាលមុន ពួកខ្លួនតាំងនៅក្នុងធម៌ ៥ ប្រការ ធ្វើកសិណបរិកម្ម ញុំាងតតិយជ្ឈានឲ្យកើត កាលឈានមិនទាន់វិនាស ធ្វើកាលកិរិយាហើយ កើតក្នុងជាន់សុភកិណ្ហ តែកាលកន្លងទៅ សូម្បីកសិណបរិកម្ម ក៏មិនដឹង ។ សូម្បីតតិយជ្ឈាន ក៏មិនអាចឲ្យកើតបាន ម៉្យាងទៀត ពួកជនទាំងនោះ រៀនធម៌ដែលជាចំណែកខាងដើម ៥ ថា បដិបទាមានហេតុ ។ ហើយរៀន

តតិយជ្ឈានថា លោកមានសុខដោយចំណែកមួយ ។ ព្រោះដូច្នោះ ទើបជនទាំងនោះពោលយ៉ាងនោះ ។ បទថា **ឧត្តរិតរំ** គឺវត្ថុដែលក្រៃលែងជាងធម៌ ៥ នោះ ។ លោកអធិប្បាយថា ពួកយើងមិនដឹងបដិបទា ឬលោកដែលជាសុខដោយចំណែកមួយក្រៃលែង ជាងតតិយជ្ឈាន ។ បទថា **អប្បសទ្ទេ កត្វា** គឺឃាត់បរិព្វាជកទាំងនោះដែល ផ្ដើមធ្វើសំឡេងខ្លាំង មិនឲ្យមានសំឡេងដោយរម្ងឹកម្ដងប៉ុណ្ណោះ ។

[ ១៤៥ ] ក្នុងបទថា **សច្ឆិកិរិយាហេតុ** នេះ សច្ឆិកិរិយាមាន ២ យ៉ាងគឺ **បដិលាភសច្ឆិកិរិយា ១ បច្ចក្ខសច្ឆិកិរិយា ១** ។ ក្នុងសច្ឆិកិរិយា ២ យ៉ាងនោះ បុគ្គលញ៉ាំងតតិយជ្ឈានឲ្យកើតហើយ តតិយជ្ឈានមិនទាន់វិនាស ធ្វើកាលកិរិយា កើតជាបុគ្គលមានអាយុ និងពណ៌សម្បុរស្មើនឹងទេវតាទាំងនោះ ក្នុងសុភកិណ្ហ លោកនេះឈ្មោះថា **បដិលាភសច្ឆិកិរិយា** គឺការធ្វើឲ្យជាក់ច្បាស់នូវការបាន ។ បុគ្គលញ៉ាំងចតុត្ថជ្ឈានឲ្យកើតហើយ ទៅកាន់សុភកិណ្ហលោកដោយការសម្ដែងឫទ្ធិ ហើយតាំងនៅ សន្ទនាប្រាស្រ័យជាមួយទេវតាទាំងនោះ នេះឈ្មោះថា **បច្ចក្ខសច្ឆិកិរិយា** គឺការធ្វើឲ្យជាក់ច្បាស់ដោយប្រចក្ស ។ តតិយជ្ឈានរបស់សច្ឆិកិរិយាទាំង ២ នោះ ឈ្មោះថា អាការវតីបដិបទា គឺបដិបទាមានហេតុ មិនញ៉ាំងតតិយជ្ឈានឲ្យកើត មិនអាចកើតក្នុងសុភកិណ្ហលោកបាន និងមិនអាចញ៉ាំងចតុត្ថជ្ឈានឲ្យកើតបាន ។ សកុលុទាយិសំដៅដល់សច្ឆិកិរិយាទាំង ២ នេះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុធ្វើឲ្យជាក់ច្បាស់នូវលោក មានសេចក្ដីសុខដោយ

ចំណែកមួយនោះពិតប្រាកដ ។

[ ១៤៩ ] បទថា **ឧទកមណិកោ** គឺក្អមទឹក ។ បទថា **អន្តរាយមកាសិ** គឺបានធ្វើអន្តរាយ ដោយឲ្យសកុលុទាយិបរិព្វាជកមិនបានបព្វជ្ជា ព្រោះឧប-និស្ស័យវិបត្តិ ។

បានឮថា សកុលុទាយិបរិព្វាជកនេះ បួសក្នុងសាសនារបស់ព្រះកស្សបសម្ពុទ្ធ បានបំពេញសមណធម៌ ។ កាលនោះ ភិក្ខុដែលជាសម្លាញ់ របស់លោកមួយអង្គពោលថា អាវុសោ ខ្ញុំនឿយណាយក្នុងសាសនានឹងសឹក ។ ភិក្ខុនោះកើតការលោភ ចង់បានបាត្រ និងចីវររបស់សម្លាញ់នោះ ទើបបានពោលសរសើរដល់គុណនៃភាពជាគ្រហស្ថ ។ ទើបភិក្ខុជាសម្លាញ់ឲ្យបាត្រនិងចីវរដល់ភិក្ខុនោះ ហើយក៏សឹក ។ ដោយកម្មរបស់ភិក្ខុនោះ ឥឡូវនេះ ទើបកើតអន្តរាយចំពោះបព្វជ្ជាចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ។ សូត្រមុនរបស់ព្រះមានព្រះភាគនោះ ត្រឹមតែជាភាណវារដែលលើស ។ សូត្រនេះជាភាណវារធ្ងន់ ( គោល ) ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ធម៌ដោយធម៌ ដោយបែបផែនមានប្រមាណប៉ុណ្ណេះ ។ ការសម្រេចមគ្គផលមិនកើត ដោយទេសនាម្តង តែនឹងបានជាបច្ច័យដល់ភិក្ខុនោះក្នុងអនាគត ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងធម៌ ។ ព្រះមានព្រះភាគទ្រង់ឃើញធម៌នោះ នឹងជាបច្ច័យក្នុងអនាគត កាលនៅមានព្រះជន្មនៅឡើយ ទើបទ្រង់ មិនតែងតាំងភិក្ខុសូម្បីមួយរូបទុកក្នុងឯតទគ្គៈ ក្នុងមេត្តាវិហារី គឺភិក្ខុមានធម៌ ជាគ្រឿងនៅក្នុងមេត្តា ។

ព្រះមានព្រះភាគទ្រង់ឃើញថា ក្នុងអនាគតភិក្ខុនេះ នឹងបួសក្នុងសាសនារបស់តថាគត ហើយនឹងជាភិក្ខុកំពូលជាងភិក្ខុដែលជាមេត្តាវិហារី ។ ភិក្ខុនោះ កាលព្រះមានព្រះភាគបរិនិព្វានហើយ កើតក្នុងក្រុងបាដលិបុត្រ ក្នុងសម័យរបស់ព្រះបាទធម្មាសោករាជ ហើយបួស ។ លុះបួសហើយ បានសម្រេចអរហត្ត ឈ្មោះថា អស្សគុត្តត្ថេរ បានជាអ្នកកំពូលនៃភិក្ខុដែលជាមេត្តាវិហារី ។ ដោយអានុភាពនៃមេត្តារបស់ព្រះថេរៈ សូម្បីសត្វតិរច្ឆានទាំងឡាយក៏បានទទួលមេត្តាចិត្ត ។ ព្រះថេរៈជាអាចារ្យទូន្មានភិក្ខុសង្ឃក្នុងសកលជម្ពូទ្វីប អាស្រ័យនៅត្រង់វត្តនិសេទាសនៈ ។ ព្រៃប្រមាណ ៣០ យោជន៍ បានជាផ្ទះសម្រាប់ធ្វើសេចក្តីព្យាយាមតែម្យ៉ាង ។ ព្រះថេរៈក្រាលប្រមខណ្ឌ ទុកលើអាកាស ហើយអង្គុយលើប្រមខណ្ឌនោះប្រាប់កម្មដ្ឋាន ។ ពេលវេលាកន្លងទៅ ព្រះថេរៈមិនទៅបិណ្ឌបាត អង្គុយប្រាប់កម្មដ្ឋាននៅក្នុងវិហារ ។ មនុស្សទាំងឡាយទៅកាន់វិហារ បានថ្វាយទាន ។ ព្រះបាទធម្មាសោករាជ បានស្តាប់គុណរបស់ព្រះថេរៈ មានបំណងនឹងឃើញ ទ្រង់បានបញ្ជូនមនុស្ស ឲ្យទៅនិមន្តអស់វារៈ ៣ ដង ។ ព្រះថេរៈត្រិះរិះថា អញនឹងឲ្យឱវាទដល់ភិក្ខុសង្ឃ ដូច្នេះហើយ ទើបមិនបានទៅសូម្បីតែម្តង ដោយប្រការដូច្នេះ ។

**អដ្ឋកថា ចូឡសកុលុទាយិសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## វេខណសសូត្រទី ១០

[ ១៥០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង វេខណសបរិព្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏ឋិតនៅក្នុងទីសមគួរ ។

[ ១៥១ ] លុះវេខណសបរិព្វាជក ឋិតនៅក្នុងទីសមគួរហើយ ក៏បន្លឺនូវឧទានវាចា ក្នុងសំណាក់ព្រះមានព្រះភាគថា ពន្លឺនេះថ្លៃថ្លាណាស់ ពន្លឺនេះថ្លៃថ្លាណាស់ ។ ព្រះអង្គត្រាស់សួរថា ម្នាលកច្ចានៈ ចុះហេតុអ្វីបានជាអ្នកនិយាយយ៉ាងនេះថា ពន្លឺនេះថ្លៃថ្លាណាស់ ពន្លឺនេះថ្លៃថ្លាណាស់ ចុះពន្លឺដូចម្តេច ដែលថ្លៃថ្លា ។ វេខណសបរិព្វាជក ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពន្លឺណា ដែលរកពន្លឺឯទៀត ក្លីលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះឈ្មោះថា ពន្លឺថ្លៃថ្លា ។ ព្រះអង្គត្រាស់សួរថា ម្នាលកច្ចានៈ ចុះពន្លឺដែលរកពន្លឺឯទៀត ក្លីលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះតើដូចម្តេច ។ វេខណសបរិព្វាជក ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ពន្លឺណាដែលរកពន្លឺឯទៀតក្លីលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះឯងឈ្មោះថា ពន្លឺថ្លៃថ្លា ។

[ ១៥២ ] ម្នាលកច្ចានៈ ពាក្យរបស់អ្នកនុ៎ះផ្សាយទៅវែងណាស់ ព្រោះអ្នកនិយាយថា បពិត្រព្រះគោតមដ៏ចម្រើន ពន្លឺណាដែលរកពន្លឺឯទៀតក្រៃលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះឯងឈ្មោះថា ពន្លឺថ្លៃថ្លា ដូច្នេះផង ទាំងមិនកំណត់នូវពន្លឺនោះផង ។ ម្នាលកិច្ចានៈដូចបុរសនិយាយយ៉ាងនេះថា ខ្ញុំប្រាថ្នាចង់បាននាងជនបទកល្យាណី ( ដែលនៅ ) ក្នុងជនបទនេះ ។ ជនទាំងឡាយក៏សួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកប្រាថ្នាចង់បាននាងជនបទកល្យាណីណា អ្នកស្គាល់នាងជនបទកល្យាណីនោះថា ជាស្ត្រីក្សត្រិយ៍ ឬព្រាហ្មណ៍ ជាស្ត្រីវេស្សៈ ឬសុទ្ទៈ ដែរឬទេ ។ បុរសនោះលុះមានគេសួរដូច្នេះហើយ ក៏ប្រាប់ថាខ្ញុំមិនស្គាល់ទេ ។ ជនទាំងឡាយក៏សួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើនអ្នកប្រាថ្នាចង់បាននូវនាងជនបទកល្យាណីណា អ្នកស្គាល់នាងជនបទកល្យាណីនោះថា មានសម្បុរយ៉ាងនេះ មានគោត្រយ៉ាងនេះ ។បេ។ ជាស្ត្រីខ្ពស់ឬទាប ឬក៏កណ្តាល ជាស្ត្រីសម្បុរខ្មៅ ឬខ្មៅស្រអែម ឬក៏ខ្មៅស្រស់ ( នៅ ) ក្នុងស្រុក ឬនិគម ឬក៏នគរឯណោះ ដូច្នេះដែរឬទេ ។ បុរសនោះលុះគេសួរដូច្នេះហើយ ក៏ប្រាប់ថាខ្ញុំមិនស្គាល់ទេ ។ ពួកជនក៏សួរបុរសនោះយ៉ាងនេះទៀតថា នែបុរសដ៏ចម្រើនអ្នកមិនស្គាល់ មិនឃើញនូវស្រីណា អ្នកប្រាថ្នាចង់បាននូវស្រីនោះ ឬអ្វី ។ បុរសនោះ លុះគេសួរដូច្នេះហើយ ក៏ប្រាប់ថា បាទ ។ ម្នាលកច្ចានៈ អ្នកសម្គាល់នូវសេចក្តីនោះថាដូចម្តេច កាលបើដូច្នោះ សម្តីរបស់បុរសនោះក្រែងយកជាការមិនបានទេដឹង ។ ពិតមែនហើយ ព្រះគោតមដ៏ចម្រើន កាល

បើដូច្នោះ សម្តីរបស់បុរសនោះនឹងយកជាការមិនបានទេ ។ ម្នាលកច្ចានៈ អ្នកនិយាយថា បពិត្រព្រះគោតមដ៏ចម្រើន ពន្លឺណាដែលរកពន្លឺឯទៀតក្លៃលើសលុបជាង ឬប្រសើរជាងគ្មាន ពន្លឺនោះឈ្មោះថា ពន្លឺថ្លៃថ្លាដូច្នេះផង ទាំងមិនកំណត់ នូវពន្លឺនោះផង ក៏យ៉ាងនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន កែវពៃទូរ្យ ស្អាតល្អ មានពន្លឺ មានជ្រុង ៨ ដែលជាងបានច្នៃល្អ ហើយដាក់លើសំពត់កម្ពល មានពណ៌លឿង រមែងភ្លឺច្រាលរុងរឿង ដូចម្តេចមិញ អត្តាស្លាប់ហើយ ជាសភាពមិនមានរោគ រមែងមានពន្លឺ ដូច្នោះឯង ។

[ ១៥៣ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច កែវពៃទូរ្យ ណាស្អាតល្អ មានពន្លឺ មានជ្រុង ៨ ដែលជាងបានច្នៃល្អហើយ ដាក់លើសំពត់កម្ពលមានពណ៌លឿង រមែងភ្លឺច្រាលរុងរឿង នឹងអំពិលអំពែកជាកិមិជាតិណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាពន្លឺទាំង ២ នេះ ពន្លឺអំពិលអំពែក ជាកិមិជាតិ ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង ប្រសើរជាងផង ។

[ ១៥៤ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច អំពិលអំពែក ជាកិមិជាតិណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ នឹងប្រទីបប្រេងណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោមតមដ៏ចម្រើន បណ្តាពន្លឺរបស់ទាំង ២ នេះ ពន្លឺប្រទីបប្រេង ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង

ប្រសើរជាងផង ។

[ ១៥៥ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះជាដូចម្តេច ប្រទីបប្រេងណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ នឹងគំនរភ្លើងធំណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាពន្លឺរបស់ទាំង ២ នេះ ពន្លឺគំនរភ្លើងធំ ក្នុងវេលាយប់ងងឹតឈឹងសូន្យ ភ្លឺជាងផង ប្រសើរជាងផង ។

[ ១៥៦ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះជាដូចម្តេច គំនរភ្លើងធំណា ក្នុងវេលាយប់ងងឹតឈឹងសូន្យ នឹងផ្កាយព្រឹកណា ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាពន្លឺរបស់ទាំង ២ នេះ ពន្លឺផ្កាយព្រឹក ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

[ ១៥៧ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះជាដូចម្តេច ផ្កាយព្រឹកណា ក្នុងបច្ចូសសម័យនៃរាត្រី ដែលស្រឡះប្រាសចាកពពកភ្លៀង នឹងព្រះចន្ទណាក្នុងវេលាអឡ្រាត្រមិនទាន់ជ្រៀងជ្រេ ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាពន្លឺរបស់ទាំង ២ នេះ ពន្លឺព្រះចន្ទក្នុងវេលាយប់អឡ្រាត្រមិនទាន់ជ្រៀងជ្រេ ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

[ ១៥៨ ] ម្នាលកច្ចានៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ព្រះចន្ទណាក្នុងវេលាអគ្រាត្រមិនទាន់ជ្រៀងជ្រេ ក្នុងថ្ងៃឧបោសថ ១៥ កើត ដែលស្រឡះប្រាសចាកពពកភ្លៀង នឹងព្រះអាទិត្យណា ក្នុងសម័យថ្ងៃត្រង់មិនទាន់ជ្រៀងជ្រេ នាសរទសម័យ ខែខាងចុងនៃវស្សានរដូវ ដែលស្រះឡះប្រាសចាកពពកភ្លៀង បណ្តាពន្លឺរបស់ទាំង ២ នេះ តើពន្លឺណា ភ្លឺជាងផង ប្រសើរជាងផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាពន្លឺរបស់ទាំង ២ នេះ ពន្លឺព្រះអាទិត្យ ក្នុងសម័យថ្ងៃត្រង់មិនទាន់ជ្រៀងជ្រេ នាសរទសម័យខាងចុងនៃវស្សារដូវ ដែលស្រឡះប្រាសចាកពពកភ្លៀង ភ្លឺជាងផង ប្រសើរជាងផង ។

[ ១៥៩ ] ម្នាលកច្ចានៈ ទេវតាទាំងឡាយណា មិនបានប្រើប្រាស់នូវពន្លឺព្រះចន្ទនឹងព្រះអាទិត្យទាំង ២ នេះ ទេវតាទាំងនោះ មានច្រើនក្រៃលែងជាងនោះទៅទៀត តថាគតក៏ស្គាល់ច្បាស់នូវទេវតាទាំងនោះដែរ ប៉ុន្តែតថាគតមិនបានពោលថា ពន្លឺណាដែលរកពន្លឺឯទៀតលើសលុបជាង ឬប្រសើរជាងគ្មានដូច្នេះឡើយ ម្នាលកច្ចានៈ ចំណែកអ្នកពោលថា ពន្លឺណា ដែលថោកទាបពេកផង សៅហ្មងពេកផង ជាងអំពិលពំពែកជាកិមិជាតិ ពន្លឺនោះឈ្មោះថា ពន្លឺថ្ងៃថ្លាដូច្នេះផង ទាំងមិនកំណត់នូវពន្លឺនោះផង ។ ម្នាលកច្ចានៈ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការតើដូចម្តេចខ្លះ គឺរូបដែលគួរដឹងបានដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ១ សំឡេងដែលគួរដឹងបានដោយត្រចៀក...១ ក្លិនដែលគួរដឹងបានដោយច្រមុះ...១ រសដែលគួរដឹងបាន

ដោយអណ្តាត...១ ផោដ្ឋព្វដែលគួរដឹងបានដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្ត ជាទីស្រឡាញ់ ប្រកបដោយកាម ជាទីរីករាយ ១ ម្នាល កច្ចានៈ នេះឯងឈ្មោះថា កាមគុណ ៥ ប្រការ ។ ម្នាលកច្ចានៈ ត្រង់ ដែលសេចក្តីសុខ និងសោមនស្ស កើតឡើង ព្រោះអាស្រ័យកាមគុណទាំង ៥ ប្រការនេះ នេះឯងតថាគតហៅថា កាមសុខគឺសុខក្នុងកាម ។ កាមសុខ ដោយកាមទាំងឡាយដូច្នេះឯង បណ្តាសុខទាំងនោះ សុខជាកំពូលនៃ កាម ( ព្រះនិព្វាន ) ប្រាកដជាប្រសើរជាងកាមសុខ ។

[ ១៦០ ] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខណសបរិព្វាជក ក៏សរសើរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតម ដ៏ចម្រើន អស្ចារ្យពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកពេក ណាស់ ដ្បិតព្រះគោតមដ៏ចម្រើន ទ្រង់ត្រាស់សម្តែងដូច្នេះថា កាមសុខ ដោយ កាមទាំងឡាយ បណ្តាសុខទាំងនោះ សុខដ៏ជាកំពូលនៃកាម ប្រាកដជា ប្រសើរជាងកាមសុខ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលកច្ចានៈ ខ្លួន អ្នកមានសេចក្តីយល់ឃើញផ្សេង មានសេចក្តីគាប់ចិត្តផ្សេង មានសេចក្តី ពេញចិត្តផ្សេង មានសេចក្តីព្យាយាមក្នុងទីផ្សេង មានអាចារ្យផ្សេង កម្រ នឹងដឹងថា នោះជាកាម ឬជាកាមសុខ ឬក៏ជាកាមគ្គសុខ ( ព្រះនិព្វាន ) ដូច្នេះ ម្នាលកច្ចានៈ លុះតែពួកភិក្ខុណាដែលជាអរហន្ត ខីណាស្រព បាន ប្រព្រឹត្តព្រហ្មចរិយធម៌គ្រប់គ្រាន់ហើយ ធ្វើសោឡសកិច្ចរួចស្រេចហើយ ដាក់ ចុះភារៈហើយ សម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានធម៌ជា

គ្រឿងជាប់ជំពាក់ក្នុងភពអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះឯង ទើបដឹងថា នុះជាកាមឬជាកាមសុខ ឬក៏ជាកាមគ្គសុខ ដូច្នេះបាន ។

[ ១៦១ ] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខណសបរិព្វាជក ស្រាប់តែខឹងអាក់អន់ចិត្ត ជេរប្រទេចព្រះមានព្រះភាគ បន្តុះបង្អាប់ព្រះមានព្រះភាគ ស្តីបន្ទោសព្រះមានព្រះភាគថា ព្រះសមណគោតមពេញជាមនុស្សលាមក ថាហើយ ក៏និយាយទៅនឹងព្រះមានព្រះភាគដូច្នេះថា ដំណើរនេះដូចគ្នានឹងសមណព្រាហ្មណ៍ពួកមួយក្នុងលោកនេះ មិនដឹងនូវទីបំផុតខាងដើម មិនដឹងនូវទីបំផុតខាងចុងទេ ប៉ុន្តែប្តេជ្ញាថា អាត្មាអញដឹងច្បាស់ថាជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ឯពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះ សម្រេចបានត្រឹមតែឲ្យអ្នកផងសើចចំអកលេង សម្រេចបានត្រឹមតែជាពាក្យអន់ថយលាមក ជាពាក្យឥតប្រយោជន៍ ជាពាក្យសោះសូន្យ ដោយពិត ។

[ ១៦២ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលកច្ចានៈ ពួកសមណព្រាហ្មណ៍ណា មិនដឹងនូវទីបំផុតខាងដើម មិនដឹងនូវទីបំផុតខាងចុង តែប្តេជ្ញាថា អាត្មាអញដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើ

ស្រេចហើយ មគ្គភាវនាកិច្ចឯទៀតប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយដូច្នេះ សមណព្រាហ្មណ៍នោះ រមែងមានការសន្កត់សន្កិន ប្រកបដោយធម៌នោះឯង ម្នាលកច្ចានៈ ទីបំផុតខាងដើមនិងខាងចុងចូរលើកទុកសិនចុះ បើវិញ្ញូបុរសដែលជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិដ៏ត្រង់មែន ចូរមកចុះ តថាគតនឹងប្រៀនប្រដៅ តថាគតនឹងសំម្តែងធម៌ វិញ្ញូបុរសនោះ កាលបើបានប្រតិបត្តិ តាមពាក្យប្រៀនប្រដៅដូច្នោះហើយមិនយូរឡើយ គង់នឹងដឹងដោយខ្លួនឯង នឹងឃើញដោយខ្លួនឯង ព្រោះថា ការរួចស្រឡះចាកចំណងគឺអវិជ្ជាដោយប្រពៃបាន យ៉ាងនេះឯង ។ ម្នាលកច្ចានៈ ក្មេងតូចទន់ខ្ចីកំពុងដេកផ្ងារ ដែលគេចងដោយចំណងអម្បោះ មានកជាគម្រប់ ៥ ចំណងទាំងនោះនឹងរបូតចេញទៅ ព្រោះអាស្រ័យសេចក្តីចម្រើន ព្រោះអាស្រ័យការចាស់ទុំនៃ ឥន្ទ្រិយទាំងឡាយរបស់វាៗ ក៏ដឹងថា អាត្មាអញជាអ្នក រួចចាចំណងហើយ តែមិនស្គាល់នូវចំណង ( នោះ ) ទេ មានឧបមាយ៉ាងណាមិញ ម្នាលកច្ចានៈ ( បើ ) វិញ្ញូបុរសជាអ្នកមិនអួតអាង មិនមានមាយា ប្រកបដោយជាតិដ៏ត្រង់មែន ចូរមកចុះ តថាគតនឹងប្រៀនប្រដៅ តថាគត នឹងសំម្តែងធម៌ វិញ្ញូបុរសនោះ កាលបើបានប្រតិបត្តិតាមពាក្យប្រៀនប្រដៅ ដូច្នោះហើយ មិនយូរឡើយ គង់នឹងដឹងដោយខ្លួនឯង នឹងឃើញដោយខ្លួនឯង ព្រោះថា ការរួចស្រឡះចាកចំណងគឺអវិជ្ជា ដោយប្រពៃបានយ៉ាងនេះ មានឧបមេយ្យយ៉ាងនោះឯង ។

[ ១៦៣ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេខ-

ណសបរិព្វាជក ក៏សរសើរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើនជ្រាបថា ខ្ញុំព្រះអង្គជាឧបាសកដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ ។

ចប់ វេខណសសូត្រទី ១០

ចប់ បរិព្វាជកវគ្គ ទី ៣

**ឧទ្ទាននៃបរិព្វាជកវគ្គ ជាវគ្គដ៏ប្រសើរគឺ**

ចូឡវច្ឆគោត្រសូត្រ ១ អគ្គិវច្ឆគោត្រសូត្រ ១ មហាវច្ឆគោត្រ ១
ទីឃនខសូត្រ ១ មាគណ្ឌិយសូត្រ ១ សន្ទកសូត្រ ១
មហាសកុលទាយិសូត្រ ១ សមណមុណ្ឌិកសូត្រ ១
ចូឡសកុលុទាយិសូត្រ ១ វេខណសសូត្រ ១ ។

# អដ្ឋកថា

## វេខណសសូត្រ

[ ១៥០ ] *វេខណសសូត្រ មានពាក្យផ្តើមថា* **ឯវមេ្ម សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **វេខណសោ** *បានឮថា វេខណបរិព្វាជកនេះ ជាអាចារ្យរបស់សកុលុទាយិបរិព្វាជក វេខណបរិព្វាជកនោះបានឮថា សកុលុទាយិបរិព្វាជកចាញ់ បរមវណ្ណប្បញ្ហា ទើបគិតថា សកុលុទាយិនោះ អញឲ្យរៀនយ៉ាងល្អហើយ សូម្បីសកុលុទាយីក៏រៀនបានល្អ គេចាញ់បាន ដូចម្តេចហ្ន៎ ណ្ហើយចុះ អញនឹងទៅឯង ទូលសួរបរមវណ្ណប្បញ្ហា ជាមួយព្រះសមណគោតម ហើយនឹងដឹងបាន ។ ទើបទៅកាន់ក្រុង សាវត្ថីប្រមាណ ៤៥ យោជន៍អំពីក្រុងរាជគ្រឹះ ហើយចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ឈរបន្លឺឧទានក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ ក្នុងបទនោះ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងសូត្រមុននោះឯង ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ផ្តើមថា* **បញ្ច ខោ ឥមេ** *ដូច្នេះ ។ បុគ្គលខ្លះជាអ្នកជ្រុំក្នុងនេក្ខម្មៈ បង្អោនទៅក្នុងនេក្ខម្មៈ ម្យ៉ាងទៀត បុគ្គលពួកខ្លះ ជាបព្វជិតជាអ្នកជ្រុំក្នុងកាម បង្អោនទៅក្នុងកាម ។ ពួកខ្លះជាអ្នកជ្រុំក្នុងនេក្ខម្មៈ បង្អោនទៅក្នុងនេក្ខម្មៈ ។ បុគ្គលនេះឈ្មោះថា ជាអ្នកជ្រុំក្នុងកាម បុគ្គលនោះកាលគេពោលកថានេះ និងកំណត់ភាពដែលខ្លួនបង្អោនទៅក្នុងកាម ទេសនានេះនឹងជាទីសប្បាយរបស់បុគ្គលនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ផ្តើមទេសនានេះ ។*

[ ១៦៩-៦២ ] *បទថា* **កាមគ្គសុខំ** *លោកបំណងយកនិព្វាន ។ បទថា*

**ចាបិតោ ភវិស្សតិ** គឺនឹងឲ្យដល់នូវការមិនដឹង ។ បទថា **លាមកាំយេវ សម្បជ្ជតិ** ដល់នូវភាពជាធម៌ថោកទាប គឺដល់នូវភាពជាធម៌ ត្រឹមតែវាចាដែលឥតប្រយោជន៍នោះឯង ។ បទថា **តិដ្ឋតុ បុព្វន្តោ តិដ្ឋតុ អបរន្តោ** សេចក្ដីថា ចំណុចខាងដើមលើកទុកសិនចុះ ចំណុចខាងចុងលើកទុកសិនចុះ ។ ព្រោះបុព្វេនិវាសញ្ញាណ ដែលសមគួរដល់កថាក្នុងអតីតរបស់អ្នកមិនមាន ។ ទិព្វចក្ខុញ្ញាណ ដែលសមគួរដល់កថាក្នុងអនាគតក៏មិនមាន ។ ដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ទាំង ២ យ៉ាងនោះ ក៏ចូរស្ងេះទុកសិនចុះ ។ បទថា **សុត្តពន្ធនេហិ** គឺគេចងដោយអំបោះ គឺបុគ្គលត្រូវអំបោះ ចងទុកត្រង់ដៃជើង និងក ដើម្បីមើលថែទារកនោះ ។ គ្រឿងចងនេះលោក សំដៅដល់អំបោះនោះ ។ តែកាលទារកនោះធំ គ្រឿងចងទាំងនោះផុយ នឹងរបូតទៅឯងឬកាត់ចេញទៅ ។ ព្រះមានព្រះភាគទ្រង់សម្ដែងបទនេះ ដោយបទថា **ឯវមេវ ខោ** ដូច្នោះ ការមិនដឹងទីបំផុតខាងដើមនៃអវិជ្ជា ដូចកាលដែលកូនក្មេង មិនដឹងគ្រឿងចងធ្វើដោយអំបោះ ដូច្នោះ ។ ព្រោះមិនអាចដឹងទីបំផុតនៃអវិជ្ជា បានតែការដឹងថា ការផុតនៃគ្រឿងចង គឺអវិជ្ជា ដោយអរហត្តមគ្គ ដូចគ្នានឹងការដឹងក្នុងវេលារួចផុត ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ដោយប្រការដូច្នេះ ៕

**អដ្ឋកថាវេខណសសូត្រ ចប់**

**សូត្រទី ១០ ចប់**

**បរិព្វាជកវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## រាជវគ្គ

### ឃដិការសូត្រទី ១

[ ១៦៤ ] ខ្ញុំបានស្តាប់ចាំមកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃ ច្រើនអង្គ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ង៉ាក ( ព្រះភក្ត្រ ) បែរចេញ អំពីផ្លូវ ហើយបានធ្វើនូវការញញឹម ត្រង់ទៅរកប្រទេសមួយឲ្យប្រាកដ ។ វេលានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគ ធ្វើនូវការញញឹម ឲ្យប្រាកដឡើង ( ព្រោះថា ) ព្រះតថាគតទាំងឡាយមិនដែលធ្វើនូវការញញឹមឲ្យប្រាកដដោយឥតហេតុទេ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ធ្វើនូវឧត្តរាសង្គៈ ឆៀងស្មាម្ខាង ប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ហើយក្រាបបង្គំទូលសួរចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានហេតុដូចម្តេចហ្ន៎ មានបច្ច័យដូចម្តេចហ្ន៎ ជាហេតុនាំឲ្យព្រះមានព្រះភាគ ធ្វើនូវការញញឹមឲ្យប្រាកដឡើង ( ព្រោះថា ) ព្រះតថាគតទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដដោយឥតហេតុទេ ។

[ ១៦៥ ] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ រឿងរ៉ាវធ្លាប់មានមក ហើយក្នុងប្រទេសនេះ មាននិគមមួយឈ្មោះវេកឡិគ ជានិគមស្តុកស្តម្ភ មាំមួន មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ ព្រះកស្សបៈមានព្រះភាគ

អរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមកសម្រេចសម្រាន្តឥរិយាបថ ក្នុងវេភឡិគនិគមនោះឯង ។ ម្នាលអានន្ទ អារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាននៅក្នុងទីនេះ ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែងគង់ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ ។

[ ១៦៦ ] គ្រានោះឯង ព្រះអានន្ទមានអាយុ ក្រាលសង្ឃាដិមានជាន់ ៤ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះ សូមព្រះមានព្រះភាគទ្រង់គង់សិន កាលបើព្រះអង្គគង់ហើយ ភូមិប្រទេសនេះ នឹងបានឈ្មោះថា មានព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គប្រើប្រាស់ ។ ព្រះមានព្រះភាគក៏ទ្រង់គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស៊ប់ហើយ ក៏ត្រាស់ទៅនឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ រឿងរ៉ាវធ្លាប់មានមកហើយ ក្នុងប្រទេសនេះ មាននិគមមួយឈ្មោះវេភឡិគ ជានិគមស្តុកស្តម្ភមាំមួន មានជនច្រើន មានមនុស្សកុះករ ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្លាប់ចូលមកសម្រេចសម្រាន្តឥរិយាបថក្នុងវេភឡិគនិគមនេះឯង ។ ម្នាលអានន្ទ អារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មាននៅក្នុងទីនេះឯង ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ តែងគង់ឲ្យឱវាទភិក្ខុសង្ឃក្នុងទីនេះ ។ ម្នាលអានន្ទ ក្នុងវេភឡិគនិគម មានស្មូនឆ្នាំងម្នាក់ឈ្មោះឃដិការ ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើរ របស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ ស្មូនឆ្នាំងឈ្មោះ ឃដិការនោះឯង

មានមាណពម្នាក់ ឈ្មោះជោតិបាល ជាមិត្តសំឡាញ់ពេញចិត្ត ( របស់គាត់ ) ។ ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាទៅគាល់ព្រះកស្សប មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រោះថាការបានឃើញនូវព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។

[ ១៦៧ ] ម្នាលអានន្ទ កាលដែលឃដិកាស្មូនឆ្នាំងនិយាយយ៉ាងនេះ ជោតិបាលមាណពក៏ឃាត់ឃដិកាស្មូនឆ្នាំងដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយអស់វារៈ ២ ដង ។បេ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពអស់វារៈ ៣ ដង ដូច្នេះថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សប មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំសន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ ឯជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដង ដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។ ឃដិការស្មូនឆ្នាំងតបថា នែជោតិបាល សំឡាញ់ស្មោះស្មើចិត្ត បើដូច្នោះ យើងនឹងកាន់យកខ្សែអំបោះសោត្តិ សម្រាប់ងូតទឹក ទៅកាន់ស្ទឹងដើម្បីងូតទឹក ។ ម្នាលអានន្ទ ជោតិបាលមាណព បានទទួលពាក្យឃដិការស្មូនឆ្នាំងថា យ៉ាងហ្នឹងហើយសំឡាញ់ស្មោះស្មើចិត្ត ។

[ ១៦៨ ] ម្នាលអានន្ទ លំដាប់នោះ ឃដិការស្មូនឆ្នាំងនឹងជោតិបាលមាណព ក៏នាំគ្នាយកខ្សែអំបោះសោត្តិ ទៅកាន់ស្ទឹង ដើម្បីងូតទឹក ។ ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំងនិយាយនឹងជោតិបាលមាណពថា ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ របស់ខ្ញុំ សន្មតថាជាការប្រពៃ ។

[ ១៦៩ ] ម្នាលអានន្ទ កាលបើឃដិការស្មូនឆ្នាំង និយាយយ៉ាងនេះជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងទៀតដូច្នេះថា កុំឡើយ ឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ស្រមណ៍កំណោរនោះបានជាការអ្វី ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំងនិយាយអស់វារៈ ២ ដង ។បេ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំង និយាយនឹងជោតិបាលមាណពអស់វារៈ ៣ ដងដូច្នេះថា ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទជោតិបាលមាណព ក៏ឃាត់ឃដិការស្មូនឆ្នាំងអស់វារៈ ៣ ដង ដូច្នេះថា កុំ

ឡើយ ឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់គាល់ ស្រមណ៍កំណោរនោះបានជាការអ្វី ។

[ ១៧០ ] ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង ក៏ចាប់ទាញថ្នក់ជោតិបាលមាណព និយាយលោមដូច្នេះថា ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាល សំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាចូលទៅ ដើម្បីគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រោះថា ការបានឃើញព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ ទើបជោតិបាលមាណព ឲ្យឃដិការស្មូនឆ្នាំងលែងកាន់ថ្នក់ ហើយនិយាយដូច្នេះថា កុំឡើយឃដិការសំឡាញ់ស្មោះស្មើចិត្ត ចុះអ្នកឯងចង់ឃើញស្រមណ៍កំណោរនោះបានជាការអ្វី ។ ម្នាលអានន្ទ លំដាប់នោះ ឃដិការស្មូនឆ្នាំង ក៏ចាប់ទាញសក់ជោតិបាលមាណព ដែលទើបនឹងងូតរួចហើយ និយាយលោមដូច្នេះថា ម្នាលជោតិ-បាលសំឡាញ់ស្មោះស្មើចិត្ត នេះហើយអារាមរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ នៅជិតបង្កើយទេតើ ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត មកយើងនឹងនាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ព្រោះថាការបានឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះរបស់ខ្ញុំ សន្មតថាជាការប្រពៃ ។ ម្នាលអានន្ទ គ្រានោះ ជោតិបាលមាណពមានសេចក្តីត្រិះរិះដូច្នេះថា ឱហ្ន៎ អស្ចារ្យណាស់ ឃើអើ ចំឡែក

ណាស់ មិនសមបើយដិការស្នូនធ្នាំង ជាមនុស្សមានកំណើតឋោកទាបនេះ មកហ៊ានមើលងាយ ចាប់ទាញសក់របស់អញ ដែលទើបនឹងផ្លូតហើយដូច្នេះ សោះ ប្រហែលជាដំណើររបស់អញដែលនឹងទៅនេះ មិនមែនជាដំណើរ ថោកទាបឡើយ ។ ទើបជោតិបាលមាណព សួរឃដិការស្នូនធ្នាំង ដូច្នេះថា ម្នាលឃដិការសំឡាញ់ស្មោះស្មើចិត្ត អ្នកឯងចាប់ទាញសក់ខ្ញុំដល់ត្រឹមណា ទៅទៀត ។ ឃដិការស្នូនធ្នាំងតបថា នែជោតិបាលសំឡាញ់ស្មោះស្មើចិត្ត ខ្ញុំចាប់ទាញសក់អ្នកឯង ទាល់តែខ្ញុំបានទៅគាល់ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធអង្គនោះ ដែលសន្មតថាជាការប្រពៃ ។ ជោតិបាលមាណព តបថា នែឃដិការសំឡាញ់ស្មោះស្មើចិត្ត ណ្ហើយលែង យើងនឹងទៅដែរ ។

[ ១៧១ ] ម្នាលអានន្ទ គ្រានោះឃដិការស្នូនធ្នាំង និងជោតិបាលមាណព នាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះ ចូលទៅដល់ហើយ ឃដិការស្នូនធ្នាំង ក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ឯជោតិបាលមាណព ពោលពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះកស្សបមានព្រះភាគអរហន្ត សម្មាសម្ពុទ្ធ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះឃដិការស្នូនធ្នាំង អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ជោតិបាលមាណពនេះ ជាមិត្តសំឡាញ់ពេញចិត្តនៃខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគ សម្ដែងធម៌ប្រោសជោតិបាលមាណពនេះឲ្យទាន ។

[ ១៧២ ] ម្នាលអានន្ទ គ្រានោះ ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ បានពន្យល់ឃដិការស្មូនឆ្នាំង និងជោតិបាលមាណព ឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ ម្នាលអានន្ទ ឃដិការស្មូនឆ្នាំង និងជោតិបាលមាណព លុះព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ពន្យល់ឲ្យយល់ឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ត្រេកអររីករាយចំពោះភាសិតរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួចក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះកបស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយ ក៏ចៀសចេញទៅ ។

[ ១៧៣ ] ម្នាលអានន្ទ លំដាប់នោះ ជោតិបាលមាណពសួរ ឃដិការស្មូនឆ្នាំងដូច្នេះថា ម្នាលឃដិការសំឡាញ់ស្មោះស្មើចិត្ត អ្នកឯងកាលបើស្តាប់ធម៌នេះហើយ តើអ្នកឯងនឹងចេញចាកផ្ទះចូលទៅកាន់ផ្នួសឬទេ ។ ឃដិការស្មូនឆ្នាំងតបថា ម្នាលជោតិបាលសំឡាញ់ស្មោះស្មើចិត្ត អ្នកឯងក្រែងដឹងថាខ្ញុំតែងចិញ្ចឹមមាតាបិតា ដែលចាស់ងងឹតងងល់ដែរឬ ។ ជោតិបាលមាណពតបថា ម្នាលឃដិការសំឡាញ់ស្មោះស្មើចិត្ត បើដូច្នោះខ្ញុំនឹងចេញចាកផ្ទះចូលទៅកាន់ផ្នួស ។

[ ១៧៤ ] ម្នាលអានន្ទ គ្រានោះ ឃដិការស្មូនឆ្នាំង និងជោតិបាលមាណព នាំគ្នាចូលទៅគាល់ព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ហើយ

ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអានន្ទ លុះឃដិការស្មូនឆ្នាំងអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះកស្សបមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ជោតិបាលមាណពនេះ ជាមិត្តសំឡាញ់ពេញចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះមានព្រះភាគ បំបួសជោតិបាលមាណពនេះឲ្យទាន ។ ម្នាលអានន្ទ ជោតិបាលមាណពក៏បាននូវបព្វជ្ជា បាននូវឧបសម្បទាក្នុងសម្នាក់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលអានន្ទ គ្រាកាលដែលជោតិបាលមាណព បានឧបសម្បទាមិនយូរប៉ុន្មាន ទើបនឹងឧបសម្បទាបានកន្លះខែប៉ុណ្ណោះ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់សម្រេចសម្រាន្តឥរិយាបថក្នុងវេភឡិគនិគម តាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក សំដៅទៅកាន់ក្រុងពារាណសី កាលពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ក៏បានដល់ក្រុងពារាណសីនោះ ។

[ ១៧៥ ] ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីនោះ ។ ម្នាលអានន្ទ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ បានឮដំណឹងថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ពុទ្ធដំណើរមកដល់ក្រុងពារាណសី ហើយឥឡូវទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ម្នាលអានន្ទ វេលានោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ បង្គាប់រាជបុរសឲ្យរៀបចំយានដ៏ល្អៗ ហើយឡើងគង់យានដ៏ល្អ ស្តេចចេញទៅអំពីក្រុងពារាណសីដោយយានដ៏ល្អៗ ដោយព្រះរាជានុភាពដ៏ប្រសើរ ដើម្បីគាល់ព្រះកស្សប

មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះបរយានទៅទល់ត្រឹមទីដែលល្មមឈប់យានហើយ ក៏ចុះអំពីយាន ទ្រង់ស្តេចទៅដោយព្រះបាទទទេ ចូលសំដៅទៅគាល់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ លុះស្តេចចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ រួចប្រថាប់ក្នុងទីសមគួរ ។

[ ១៧៦ ] ម្នាលអានន្ទ លុះព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ប្រថាប់ក្នុងទីសមគួរហើយ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ ម្នាលអានន្ទ លំដាប់នោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ លុះព្រះកស្សបមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យជឿជាក់ ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយក៏និមន្តព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ម្នាលអានន្ទ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ក៏ទ្រង់ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ទ្រង់ជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ធ្វើប្រទក្សិណហើយស្តេចចេញទៅ ។ ម្នាលអានន្ទ កាលនោះ ព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ លុះកន្លងរាត្រីនោះ

ហើយ ក៏ត្រាស់បង្គាប់រាជបុរសឲ្យចាត់ចែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយស្រូវសាលីមានពណ៌លឿង ជាអង្ករបាយទន់ ជាវត្ថុប្រាសចាកពណ៌ខ្មៅ មានទាំងសម្លដ៏ច្រើន និងម្ហូបក្រៀមដ៏ច្រើន ក្នុងព្រះរាជដំណាក់ របស់ព្រះអង្គ រួចហើយបង្គាប់រាជបុរស ឲ្យក្រាបទូលភត្តកាលចំពោះព្រះ កស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើនកាល ដល់ហើយ ភត្តក៏សម្រេចហើយ ។

[ ១៧៧ ] ម្នាលអានន្ទ វេលានោះ ជាវេលាបុព្វណ្ហសម័យ ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ស្តេចចូលទៅកាន់ព្រះរាជដំណាក់ នៃព្រះរាជាដែនកាសី ទ្រង់ព្រះនាមកិកិ ព្រមដោយភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ ម្នាលអានន្ទ សម័យនោះ ព្រះរាជាដែនកាសីទ្រង់ព្រះនាមកិកិ ទ្រង់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយព្រះហស្ថានៃព្រះអង្គឯង ឲ្យឆ្អែតស្កប់ស្កល់ ។ ម្នាលអានន្ទ កាលបើ ព្រះរាជាដែនកាសីព្រះនាមកិកិជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ សោយរួចស្រេចហើយ លែងលូកព្រហស្តទៅក្នុងបាត្រ ហើយ ក៏កាន់យកអាសនៈមួយទាបជាង ហើយប្រថាប់ក្នុងទីសមគួរ ។ ម្នាលអានន្ទ លុះព្រះរាជាដែនកាសីព្រះនាមកិកិ ប្រថាប់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលគង់ចាំវស្សាក្នុងក្រុងពារាណសី

របស់ខ្ញុំព្រះអង្គ ឯការបម្រើសង្ឃមានសភាពដូច្នេះ នឹងមានមិនដាច់ ។ ព្រះកស្សបមានព្រះភាគត្រាស់ថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថា ការនៅចាំវស្សា តថាគតនៅចាំរួចហើយ ។ ម្នាលអានន្ទ ព្រះបាទកិកិក្រាបបង្គំទូលអស់វារៈ ២ ដង ។បេ។ ម្នាលអានន្ទ ព្រះរាជាដែនកាសីព្រះនាមកិកិ ក្រាបបង្គំទូលព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អស់វារៈ ៣ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារាណសី របស់ខ្ញុំព្រះអង្គ ឯការបម្រើសង្ឃមានសភាពដូច្នេះ នឹងមានមិនដាច់ ។ ព្រះកស្សបមានព្រះភាគត្រាស់តបថា បពិត្រព្រះមហារាជ កុំឡើយ ព្រោះថា ការនៅចាំវស្សា តថាគតនៅចាំរួចហើយ ។ ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសីព្រះនាមកិកិ ជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មិនទ្រង់ទទួលគង់ចាំវស្សា ក្នុងក្រុងពារាណសីរបស់អញដូច្នេះហើយ ទ្រង់ក៏មានព្រះចិន្តាវាយមាយ ទ្រង់តូចព្រះហឫទ័យ ។ ម្នាលអានន្ទ វេលានោះ ព្រះរាជាដែនកាសីព្រះនាមកិកិ ក្រាបបង្គំសួរព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុះបុគ្គលដទៃណាមួយ ដែលជាអ្នកបម្រើវិសេសជាងខ្ញុំព្រះអង្គទៅទៀត តើមានដែរឬទេ ។

[ ១៣៨ ] ថ្វាយព្រះពរមហារាជ មាន ជ្បិតនិគមមួយឈ្មោះវេកឡិគ ក្នុងនិគមនោះមានស្មូនឆ្នាំងម្នាក់ឈ្មោះឃដិការ ឯឃដិការស្មូនឆ្នាំងនោះឯង ជាឧបដ្ឋាក ជាអ្នកបម្រើដ៏ប្រសើររបស់តថាគត បពិត្រព្រះមហារាជ មហាបពិត្រ

ទ្រង់ជ្រាបថា ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ មិនទ្រង់ទទួលគង់ចាំវស្សាក្នុងក្រុងពារាណសី របស់ព្រះអង្គដូច្នេះហើយ ក៏មានព្រះចិន្តាពាយមាយទ្រង់តូចព្រះហឫទ័យ ចំណែកសេចក្តីពាយមាយចិត្ត និងការតូចចិត្តរបស់ឃដិការស្មូនឆ្នាំងនោះ មិនមានក្នុងកាលឥឡូវនេះផង នឹងមិនមានតទៅផង បពិត្រមហារាជ ព្រោះថាឃដិការស្មូនឆ្នាំងជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកនូវវត្ថុដែលគេមិនបានឲ្យ វៀរការចាកប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ បពិត្រព្រះមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកប្រកបដោយ សេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង មិនមានសេចក្តីសង្ស័យក្នុងទុក្ខ មិនមានសេចក្តីសង្ស័យក្នុងហេតុជា គ្រឿងកើតឡើងនៃទុក្ខ មិនមានសេចក្តីសង្ស័យ ក្នុងធម៌ជាគ្រឿងរលត់ទុក្ខ មិនមានសេចក្តីសង្ស័យក្នុងសេចក្តីប្រតិបត្តិជាដំណើរដើម្បីទៅកាន់ទីរលត់ទុក្ខ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកបរិភោគភត្តតែមួយពេល ប្រព្រឹត្តធម៌ដ៏ប្រសើរជាអ្នកមានសីល មានកល្យាណធម៌ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកលះបង់កែវមណី និងមាស ជាអ្នកប្រាសចាកមាស និងប្រាក់ បពិត្រមហារាជ

ឃដិការស្មូនឆ្នាំង ជាអ្នកមិនជីកផែនដីដោយជំនីកផង មិនកកាយផែនដីដោយដៃខ្លួនឯងផង តែងយកតែអង្រែកទៅរែកដីប្រាំងបាក់ ឬអាចម៍ដីដែលកណ្ដុរកកាយ មកធ្វើភាជន៍ហើយ ប្រកាស ( សេចក្ដី ) យ៉ាងនេះថា ជនណាចង់បាន ( ភាជន៍ ) ចូរដាក់អង្ករមួយសំពៀត ឬក៏សណ្ដែកបាយ មួយសំពៀតក្នុងទីនេះចុះ ហើយចង់បានភាជន៍បែបណា ចូរនាំយកភាជន៍នោះ ទៅចុះ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង តែងចិញ្ចឹមមាតាបិតា ដែលចាស់ងងឹតងងល់ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ទៀងតែនឹងទៅកើតជាឱបបាតិកកំណើត ហើយបរិញ្ញនក្នុងទីនោះ មានសភាពជាអ្នកមិនត្រឡប់ចាកលោកនោះវិញ ជាធម្មតា ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ។

[ ១៧៩ ] បពិត្រព្រះមហារាជ សម័យមួយ តថាគតសម្រេចសម្រាន្តនៅក្នុងវេកឡិគនិគម ។ បពិត្រមហារាជ គ្រានោះ តថាគតស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ទីដែល មាតាបិតារបស់ឃដិការស្មូនឆ្នាំងនៅ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតាបិតារបស់ឃដិការស្មូនឆ្នាំងដូច្នេះថា ចុះភគវៈនេះចេញទៅក្នុងទីណា ។ មាតាបិតារបស់ឃដិការស្មូនឆ្នាំងក៏ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឧបដ្ឋាករបស់ ព្រះអង្គចេញទៅបាត់ហើយ សូមព្រះអង្គយកបាយអំពីឆ្នាំងនេះ យកសម្លអំពីភាជន៍នេះទៅឆាន់ចុះ ។ បពិត្រមហារាជ គ្រានោះ តថាគតក៏យកបាយអំពី ឆ្នាំងយកសម្លអំពីភាជន៍ឆាន់ រួចក៏ក្រោកចាកអាសនៈហើយចៀសចេញទៅ ។ បពិត្រមហារាជ លំដាប់នោះ ឃដិការស្មូនឆ្នាំងចូលទៅជិតមាតាបិតា លុះចូល

ទៅដល់ហើយ ក៏សួរទៅមាតាបិតាដូច្នេះថា នរណាយកបាយអំពីថ្នាំង យកសម្លអំពីភាជន៍ទៅបរិភោគ ហើយក្រោកចាកអាសនៈចៀសចេញទៅបាត់ ។ មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ យកបាយអំពីថ្នាំង យកសម្លអំពីភាជន៍ទៅឆាន់ រួចហើយក្រោកចាក អាសនៈចៀសចេញទៅ ។ បពិត្រមហារាជ វេលានោះឃដិការ ស្មូនឆ្នាំង មានសេចក្តីត្រិះរិះដូច្នេះថា អញពេញហៅមានលាភ អត្តភាពជាមនុស្សអញពេញហៅបានដោយល្អ ( ព្រោះថា ) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាលនឹងអញ ក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះ សេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការ ស្មូនឆ្នាំងអស់កន្លះខែ មិនលះបង់មាតាបិតាអស់ ៧ ថ្ងៃ ។

[ ១៨០ ] បពិត្រមហារាជ សម័យនោះ តថាគតនៅក្នុងវេភឡិគនិគមនោះឯង ។ បពិត្រមហារាជ គ្រានោះ តថាគតស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ទីដែលមាតាបិតារបស់ឃដិការស្មូនឆ្នាំងនៅ លុះចូលទៅដល់ហើយ ក៏សួរមាតាបិតា របស់ឃដិការស្មូនឆ្នាំងដូច្នេះថា ចុះភគវៈនេះចេញទៅក្នុងទីណា ។ មាតាបិតាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឧបដ្ឋាករបស់ព្រះអង្គចេញទៅបាត់ហើយ សូមព្រះអង្គយកទំកុម្ភាសអំពីកឡោបីនេះ យកសម្លអំពីភាជន៍នេះឆាន់ចុះ ។ បពិត្រមហារាជពេលនោះ តថាគតក៏យកទំកុម្ភាសអំពីកឡោបី យកសម្លអំពីភាជន៍ឆាន់រួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ បពិត្រមហារាជ

លំដាប់នោះឃដិការស្មូនឆ្នាំង ចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយ ក៏សួរមាតា បិតាដូច្នេះថា នរណាយកនំកុម្មាសអំពីកឡោប៉ី យកសម្ល អំពីភាជន៍ បរិភោគហើយក្រោកចាកអាសនៈចៀសចេញទៅបាត់ ។ មាតាបិតាប្រាប់ថា ម្នាលកូន ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ យកនំកុម្មាសអំពីកឡោប៉ី យកសម្លអំពីភាជន៍ឆាន់រួចហើយ ក្រោកចាកអាសនៈចៀសចេញទៅ ។ បពិត្រមហារាជ វេលានោះ ឃដិការស្មូនឆ្នាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហៅមានលាភ អត្តភាពជាមនុស្សអញពេញហៅបានដោយល្អ ( ព្រោះថា ) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គស្និទ្ធស្នាល នឹងអញក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះសេចក្តីសុខដែលកើតអំពីបីតិ មិនលះបង់ឃដិការស្មូនឆ្នាំងអស់កន្លះខែ មិនលះបង់មាតាបិតាអស់ ៧ ថ្ងៃ ។

[ ១៨១ ] បពិត្រមហារាជ មានកាលសម័យមួយ តថាគតនៅក្នុងវេកឡិគនិគមនោះឯង ។ សម័យនោះ កុដិក៏លេចភ្លៀង ។ បពិត្រមហារាជ ពេលនោះតថាគតប្រាប់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នាទៅ អ្នកទាំងឡាយចូរដឹងនូវស្មៅក្នុងលំនៅនៃឃដិការស្មូនឆ្នាំងចុះ ។ បពិត្រមហារាជ កាលដែលតថាគតបង្គាប់យ៉ាងនេះ ភិក្ខុទាំងនោះក៏បានតបមកនឹង តថាគតដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ស្មៅក្នុងលំនៅនៃឃដិការ ស្មូនឆ្នាំងមិនមានទេ គាត់មានតែលំនៅ ដែលប្រក់ស្មៅប៉ុណ្ណោះ ។ តថាគតតបថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំគ្នាទៅរុះរើយកស្មៅ

( ដែលប្រក់ ) ផ្ទះរបស់ឃដិការស្មូនឆ្នាំងមកចុះ ។ បពិត្រមហារាជគ្រានោះ ភិក្ខុទាំងនោះ ក៏នាំគ្នារុះរើស្មៅ ( ដែលប្រក់ ) ផ្ទះរបស់ឃដិការស្មូនឆ្នាំង ។ បពិត្រមហារាជ នៅវេលានោះ មាតាបិតារបស់ឃដិការស្មូនឆ្នាំង សួរភិក្ខុទាំងនោះដូច្នេះថា នរណារុះរើស្មៅ ( ដែលប្រក់ ) ផ្ទះ ។ ភិក្ខុទាំងឡាយតបថា ម្នាលនាង កុដិរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធលេចភ្លៀង ។ មាតារបស់ឃដិការស្មូនឆ្នាំងទូលថា បពិត្រលោកទាំងឡាយដ៏ចម្រើន ចូរលោកម្ចាស់ទាំងឡាយនាំយកទៅចុះ បពិត្រលោកមានភក្ត្រដ៏ចម្រើនទាំងឡាយ ចូរលោកម្ចាស់ទាំងឡាយនាំយកទៅចុះ ។ បពិត្រមហារាជ គ្រានោះឃដិការស្មូនឆ្នាំងចូលទៅជិតមាតាបិតា លុះចូលទៅដល់ហើយក៏សួរមាតា បិតាដូច្នេះថា នរណារុះរើយកស្មៅដែលប្រក់ផ្ទះ ( អស់ទៅ ) ។ មាតា បិតាប្រាប់ថា ម្នាលកូន បានឮថា កុដិរបស់ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធលេចភ្លៀង ។ បពិត្រមហារាជ ទើបឃដិការស្មូនឆ្នាំងមានសេចក្តីត្រិះរិះដូច្នេះថា អញពេញហៅមានលាភ អត្តភាពជាមនុស្សអញពេញហៅបានដោយល្អ ( ព្រោះថា ) ព្រះកស្សបមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ស្និទ្ធស្នាលនឹងអញក្រៃពេកយ៉ាងនេះ ។ បពិត្រមហារាជ គ្រានោះសេចក្តីសុខដែលកើតអំពីបីតី មិនលះបង់ឃដិការស្មូនឆ្នាំងអស់កន្លះខែ មិនលះបង់មាតាបិតាអស់ ៧ ថ្ងៃ ។ បពិត្រមហារាជ គ្រានោះឯង លំនៅនោះមានអាកាសជាគ្រឿងប្រក់អស់ ៣ ខែគត់ ប៉ុន្តែមិនលេចភ្លៀងទេ បពិត្រមហារាជ ឃដិការស្មូនឆ្នាំង ជាអ្នកមានសភាពដូច្នេះឯង ។ ព្រះរាជា ទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ឃដិការស្មូន

ឆ្នាំង មានលាភមែន អត្តភាពជាមនុស្ស ឃដិការស្មូនឆ្នាំងបានដោយល្អមែន ( ព្រោះថា ) ព្រះមានព្រះភាគ ព្រះអង្គទ្រង់ស្និទ្ធស្នាលក្រៃពេកយ៉ាងនេះ ។

[ ១៨២ ] ម្នាលអានន្ទ គ្រានោះ ព្រះរាជាដែនកាសី ព្រះនាមកិកិ ក៏បញ្ជូននូវអង្ករនៃស្រូវសាលី មានពណ៌លឿង ជាអង្ករបាយទន់ ចំនួន ៥០០ វាហៈផង គ្រឿងសម្ល៍ល្មមនឹងអង្ករនោះផង ( ទៅឲ្យ ) ដល់ឃដិការស្មូនឆ្នាំង ។ ម្នាលអានន្ទ គ្រានោះរាជបុរសទាំងនោះ ក៏ចូលទៅរកឃដិការស្មូនឆ្នាំង ហើយនិយាយដូច្នេះថា បពិត្រអ្នកដ៏ចម្រើន ព្រះរាជាដែនកាសីព្រះនាមកិកិ បានបញ្ជូនអង្ករនៃស្រូវសាលីមានពណ៌លឿង ជាអង្ករបាយទន់ចំនួន ៥០០ វាហៈផង គ្រឿងសម្ល៍ល្មមនឹងអង្ករនោះផង ។ ( មកឲ្យ ) អ្នកបពិត្រអ្នកដ៏ចម្រើន សូមអ្នកទទួលយកនូវវត្ថុទាំងនោះចុះ ។ ឃដិការស្មូនឆ្នាំងតបថា ព្រះរាជាព្រះអង្គមានកិច្ចច្រើន មានការងារដែលត្រូវធ្វើច្រើន ណ្ហើយ ( កុំបាច់ព្រះរាជទាន ) ដល់ខ្ញុំឡើយ វត្ថុទាំងនេះចូរថ្វាយដល់ព្រះរាជាវិញចុះ ។

[ ១៨៣ ] ម្នាលអានន្ទ ប្រហែលជាអ្នកមានសេចក្ដីត្រិះរិះយ៉ាងនេះថា បុគ្គលដទៃទេ ដែលកើតជាជោតិបាលមាណព ក្នុងសម័យនោះ ។ ម្នាលអានន្ទ ហេតុនេះ អ្នកកុំគប្បីយល់ឃើញយ៉ាងនេះឡើយ តថាគតហ្នឹងឯង ដែលកើតជាជោតិបាលមាណពក្នុងសម័យនោះ ។ លុះព្រះមានព្រះភាគ ទ្រង់សម្ដែងសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុក៏មានចិត្តរីករាយត្រេកអរ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

**ចប់ ឃដិការសូត្រទី ១**

# អដ្ឋកថា

## ឃដិការសូត្រ

[ ១៦៤ ] ឃដិការសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងឃដិការសូត្រនោះដូតទៅនេះ ។ បទថា **សិតំ បាត្វាកាសិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរដោយមហាមាគ៌ា ទ្រង់ទតភូមិបទេសមួយកន្លែង ហើយទ្រង់រំពឹងថា កាលតថាគតប្រព្រឹត្តចរិយា ធ្លាប់នៅក្នុងទីនេះខ្លះឬហ្ន៎ ដូច្នេះ ទ្រង់ឃើញថា កាលសាសនាព្រះកស្សបសម្ពុទ្ធ ទីនេះជានិគម ឈ្មោះវេកឡិគៈ ក្នុងកាលនោះ តថាគតជាមាណពឈ្មោះជោតិបាល តថាគតមានសម្លាញ់ជានាយស្មូនឆ្នាំង ឈ្មោះឃដិការ ។ តថាគត និងនាយឃដិការនោះ បានធ្វើហេតុដ៏ល្អទុកមួយក្នុងទីនេះ សេចក្ដីល្អនោះបិទបាំងនៅឡើយ មិនទាន់ប្រាកដដល់ភិក្ខុសង្ឃ ណ្ហើយចុះ តថាគតនឹងធ្វើរឿងនោះឲ្យប្រាកដដល់ភិក្ខុសង្ឃ ទ្រង់ត្រិះរិះ ដូច្នេះហើយ ទ្រង់ចៀសចេញអំពីផ្លូវ ប្រថាប់ឈរក្នុងបទេសមួយ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ ទ្រង់មានព្រះឱស្ឋញញឹម ។ ព្រះពុទ្ធទាំងឡាយ ទ្រង់មិនសើចដូចពួកមនុស្សលោកិយជនរមែងទះពោះសើចថា ទីណាៗ ដូច្នេះ ។ ឯការញញឹមរបស់ព្រះពុទ្ធទាំងឡាយ ប្រាកដត្រឹមតែអាការរីករាយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការសើចនោះ មានដោយចិត្តដែលកើតព្រមដោយសោមនស្ស ១៣ ដួង ។ ក្នុងបណ្ដាចិត្តទាំងនោះ មហាជនក្នុងលោក រមែងសើចដោយចិត្ត ៨ ដួង គឺដោយអកុសលចិត្ត ៤ ដោយកាមាវចរកុសលចិត្ត ៤ ។ ព្រះសេក្ខបុគ្គល

រមែងសើចដោយចិត្ត ៦ វៀរចិត្តដែលសម្បយុត្តដោយទិដ្ឋិខាងអកុសល ២ ចេញ ។ ព្រះខីណាស្រពរមែងញញឹមដោយចិត្ត ៥ គឺ ដោយកិរិយាចិត្តដែលជាសហេតុក ៤ ដោយកិរិយាចិត្តដែលជាអហេតុក ១ ។ ក្នុងចិត្តទាំងនោះ កាលអារម្មណ៍មានកម្លាំងមកប្រាកដ រមែងញញឹមដោយចិត្តដែលសម្បយុត្តដោយញាណ ២ ។ កាលអារម្មណ៍ទុព្វលមកប្រាកដ រមែងញញឹមដោយចិត្ត ៣ គឺដោយទុកហេតុកចិត្ត ២ ដោយអហេតុកចិត្ត ១ ។ តែក្នុងទីនេះ ចិត្តដែលកើតព្រមដោយអហេតុកកិរិយាមនោវិញ្ញាណធាតុដែលប្រកបដោយសោមនស្ស ធ្វើឲ្យការសើចត្រឹមតែជាការត្រេកអរ ឲ្យកើតអំពីកវគ្គប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការញញឹមនេះ សូម្បីមានប្រមាណតិចតួចយ៉ាងនេះ ក៏បានប្រាកដដល់ព្រះថេរៈ ។ សួរថា ប្រាកដដូចម្តេច ។ ឆ្លើយថា ធម្មតាក្នុងកាលដូច្នោះ ដួងនៃរស្មីមានប្រមាណប៉ុនដើមត្នោតធំ រុងរឿងធ្លៀលធ្លាត់ ដូចផ្លេកបន្ទោរ ១០០ ចេញអំពីព្រះឱស្ឋ ប្រៀបដូចមហាមេឃដែលញុំាងភ្លៀងឲ្យធ្លាក់ក្នុងទ្វីបទាំង ៤ តាំងឡើង អំពីព្រះចង្កូមកែវទាំង ៤ ធ្វើប្រទក្សិណព្រះសីសៈដ៏ប្រសើរ ៣ ជុំ ហើយក៏អន្តរធានបាត់ទៅត្រង់កណ្តាលព្រះចង្កូមកែវនោះឯង ។ ព្រោះហេតុនោះ ព្រះអានន្ទសូម្បីដើរតាមពីក្រោយព្រះបិដ្ឋិរបស់ព្រះមានព្រះភាគ ក៏ជ្រាបដល់ការញញឹមដោយសញ្ញានោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ភគវន្តំ ឯតទវោច** នេះ ដូចតទៅនេះ បានឮថា ព្រះអានន្ទគិតថា ព្រះមានព្រះភាគព្រះនាមថាកស្សបទ្រង់រមែងឲ្យឱវាទភិក្ខុសង្ឃ ទ្រង់ធ្វើការប្រកាសសច្ចៈទាំង ៤ អញ្ជើញឲ្យព្រះមានព្រះភាគ

សព្វព្រះទ័យ ប្រថាប់គន់ក្នុងទីនេះ ភូមិភាគនេះ ដែលព្រះពុទ្ធ ២ ព្រះអង្គទ្រង់ប្រើប្រាស់ មហាជននឹងបូជាដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម នឹងធ្វើចេតិយដ្ឋាន ទំនុកបម្រុងក៏នឹងមានស្ថានសួគ៌ជាទីទៅខាងមុខ ដូច្នោះហើយ ទើបក្រាបទូលពាក្យថា បើដូច្នោះ សូមព្រះមានព្រះភាគទ្រង់គង់សិន ដូច្នេះជាដើម ។

[ ១៧៦ ] បទថា **មុណ្ឌកេន សមណកេន** សេចក្តីថា នឹងហៅមនុស្សក្បាលត្រងោល មនុស្សត្រងោល ឬហៅសមណៈថា សមណៈរមែងសមគួរ ។ ឯជោតិបាលនេះ ខ្លាចដោយរៅហារដែលខ្លួនរៀនហើយ ក្នុងព្រាហ្មណត្រកូលព្រោះនៅមានញាណមិនទាន់ចាស់ក្លា ទើបពោលយ៉ាងនោះ ។

[ ១៦៨ ] បទថា **សោត្តិសិនានំ** បានដល់ លម្អិតបុក ដែលធ្វើសម្រាប់ងូតទឹក ។ គេយកលម្អិតថ្ម ពណ៌ដូចត្បូងទទឹម និងល័ក្ខ ស្រោក់ដោយអំបោះ សម្រាប់ដុះខ្លួន នេះលោកហៅថា លម្អិតសម្រាប់ងូត ។ ដូចលោកពោលទុកថា **តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កុរុវិន្ទិយសុត្តិកាយ នហាយន្តិ** សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាងូតទឹកដោយដុំលម្អិតថ្មឈ្មោះកុរុវិន្ទកៈ ដូច្នេះ ។ សម្ងាញ់ទាំង ២ នោះ កាន់យកលម្អិតថ្មក្រហមសម្រាប់ដុសខ្លួននោះទៅដុសខ្លួន ។ បទថា **ឯវំ សម្ម** សេចក្តីថា សូម្បីក្នុងបច្ចុប្បន្ននេះ ពួកមនុស្សមាននរណាបបួលថា ពួកយើងទៅថ្វាយបង្គំព្រះចេតិយ ទៅស្តាប់ធម៌ជាមួយគ្នាចុះ នឹងមិនធ្វើសេចក្តីឧស្សាហៈ តែបុគ្គលណាមួយបបួលថា ពួកយើងទៅមើលរបាំរាំច្រៀងជាដើមជាមួយគ្នា

ចុះ ដូច្នេះ នឹងព្រមទទួល ពាក្យដោយការបបួលត្រឹមតែម្តង យ៉ាងណា ជោតិបាលក៏ដូច្នោះដូចគ្នា កាលយជិការបបួលថា ទៅងូតទឹកជាមួយគ្នាចុះ ក៏ទទួលពាក្យ ដោយការបបួលត្រឹមតែម្តង ទើបឆ្លើយទៅយ៉ាងនោះ ។

បទថា **ជោតិបាលំ មាណវំ អាមន្តេសិ** សេចក្តីថា យជិការស្នូនផ្ទាំង ងូតទឹកដោយការបរិហារយ៉ាងល្អ ហើយឡើងមុន ឈរវង់ចាំ កាលជោតិបាល ងូតដោយការបរិហារ តាមបែបអ្នកមានឥស្សរិយយសដ៏ធំ លុះងូតស្រេច ហើយ ហៅជោតិបាលដែលកំពុងស្លៀកដណ្តប់ កំពុងធ្វើសក់ឲ្យស្ងួត ។ យជិការ កាលនឹងបបួល ទើបពោលពាក្យថា **អយំ** ព្រោះជោតិបាលនៅក្បែរគ្នា ។

[ ១៧០ ] បទថា **ឱវដ្ដិកំ វិនិវេឋេត្វា** សេចក្តីថា ព្រះពោធិសត្វកម្លាំង ដូចដំរីសារ ឱនទៅបន្តិចពោលថា ថយចេញទៅសម្លាញ់ ឲ្យយជិការស្នូនផ្ទាំង លែងការចាប់ទុកហើយ ។ បទថា **កេសេសុ បរាមសិត្វា ឯតទវោច** សេចក្តីថា បានឮថា យជិការនោះត្រិះរិះថា ជោតិបាលមាណពនេះ ជាអ្នក មានបញ្ញា កាលបានឃើញព្រះតថាគត ត្រឹមតែម្តង នឹងជ្រះថ្លាក្នុងការឃើញ ព្រះតថាគតផង នឹងជ្រះថ្លាក្នុងធម្មកថាផង ធម្មតាអ្នកជ្រះថ្លាហើយ នឹងអាច ធ្វើអាការដែលបានជ្រះថ្លា ឈ្មោះថា មិត្តរមែងមានគុណប្រយោជន៍នេះ អញ នឹងធ្វើយ៉ាងណាមួយ ចាប់សម្លាញ់អ្នកស្មើចិត្ត ទៅកាន់សម្នាក់ព្រះទសពល ឲ្យទាល់តែបាន ដូច្នោះ ទើបចាប់ជោតិបាលមាណពនោះត្រង់សក់ ហើយបាន ពោលពាក្យនោះ ។ បទថា **ឥត្តរជច្ចោ** សេចក្តីថា យជិការមានជាតិដទៃ គឺមានជាតិមិនស្មើគ្នាជាមួយអញ ដោយអត្ថថា មានជាតិទាប ។ បទថា **ន**

**វតិធំ** នេះ បានដល់ការសម្រេចក្នុងការចាប់នោះឯងថា ការចាប់អញនេះ នឹងមិនជាការចាប់ថោកទាប គឺមិនមែនការចាប់ដែលតូចតាច នឹងជាការចាប់ដែលធំ គឺយជិការស្ទូនថ្នាំងនេះ មិនបានចាប់ដោយកម្លាំងរបស់ខ្លួន នឹងចាប់ដោយកម្លាំងរបស់ព្រះសាស្តា ដូច្នេះ ។ **ឧ** អក្ខរៈ **ហិ** អក្ខរៈ **បិ** អក្ខរៈ ក្នុងបទថា **យាវតធោហិបិ** នេះ ជានិបាត សេចក្តីថា ប៉ុណ្ណោះយ៉ាងក្រៃលែង ។ ពាក្យនេះមានអធិប្បាយថា ហៅដោយវាចា និងចាប់ត្រង់ជាយថ្នក់អូសទៅ រហូតដល់ចាប់សក់ គួរធ្វើប្រយោគដើម្បីការចាប់ក្នុងសេចក្តីនោះ ។

[ ១៧២ ] បទថា **ធម្មិយា កថាយ** បានដល់ គប្បីជ្រាបធម្មកថាដែលសម្បយុត្តដោយបុព្វេនិវាសញ្ញាណ ដើម្បីបានចំពោះនូវសតិក្នុងទីនេះ ។

ព្រះមានព្រះភាគ ត្រាស់ធម្មកថា ដើម្បីឲ្យជោតិបាលនោះបាននូវសតិដោយន័យនេះថា ម្នាលជោតិបាល ខ្លួនអ្នកមិនមែនសត្វដែលចុះកាន់ឋានៈថោកទាប តែអ្នកប្រាថ្នាសព្វញ្ញុតញ្ញាណ ឈមចុះមហាពោធិបល្ល័ង្ក ធម្មតាមនុស្សដូចអ្នកមិនគួរនៅដោយសេចក្តីប្រមាទ ដូច្នេះ ។ ចំណែកព្រះថេរៈដែលនៅក្នុងសមុទ្រខាងនាយពោលថា ព្រះមានព្រះភាគ ត្រាស់ធម្មីកថាថា ជោតិបាល តថាគតបំពេញបារមី ១០ ប្រការ ត្រាស់ដឹងសព្វញ្ញុតញ្ញាណ មានភិក្ខុ ២ ម៉ឺនចោមរោម ត្រាច់ទៅក្នុងលោកដោយប្រការណា សូម្បីខ្លួនអ្នកក៏ចូរបំពេញបារមី ១០ ប្រការ សម្រេចសព្វញ្ញុតញ្ញាណ មានពួកសមណៈជាបរិវារត្រាច់ទៅក្នុងលោក ដោយប្រការដូចគ្នានឹងតថាគតយ៉ាងនេះចុះ មិនគួរនឹងប្រមាទដូច្នេះ ចិត្តរបស់ជោតិបាលនោះ រមែងបង្អោនទៅ ក្នុងបព្វជ្ជា

ដោយប្រការណា ទ្រង់ទូន្មានដល់ទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងការចេញបួស ដោយប្រការដូច្នោះ ។

បទថា **អលត្ថ ខោ អានន្ទ ។បេ។ បព្វជ្ជំ អលត្ថ ឧបសម្បទំ** សេចក្តីថា ជោតិបាលមាណពបួសហើយ បានធ្វើដូចដែលបុគ្គលជាព្រះពោធិសត្វគប្បីធ្វើធម្មតាព្រះពោធិសត្វ រមែងបព្វជ្ជាក្នុងទីចំពោះមុខនៃព្រះពុទ្ធទាំងឡាយ ។ កាលបួសហើយ រមែងមិនជាអ្នកដែលមានស្នេហ៍ធ្លាក់ចុះ ដូចសត្វក្រៅអំពីនេះ តាំងនៅក្នុងចតុប្បារិសុទ្ធិសីល ហើយរៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក សមាទានធុតង្គ ១៣ ចូលព្រៃ បំពេញគតវត្ត និងបច្ចាគតវត្ត ធ្វើសមណធម៌ ចម្រើនវិបស្សនា រហូតដល់អនុលោមញាណ ទើបឈប់ មិនធ្វើសេចក្តីព្យាយាមដើម្បីមគ្គផលតទៅ សូម្បីជោតិបាលមាណពក៏បានធ្វើយ៉ាងនោះដូចគ្នា ។

បទថា **អឌ្ឍមាសូបសម្បន្នេ** សេចក្តីថា កាលព្រះមានព្រះភាគ ទ្រង់ញុំាងទារកនៃត្រកូលឲ្យបួសហើយ មិនប្រថាប់នៅមួយខែ យាងទៅហើយក្នុងកាលសេចក្តីសោករបស់មាតាបិតាមិនទាន់ស្ងប់ ។ កុលបុត្រនោះមិនទាន់ចេះកាន់បាត្រ និងចីវរ ការស្និទ្ធជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយមិនទាន់កើត សេចក្តីស្រឡាញ់ជាមួយព្រះថេរៈទាំងឡាយមិនទាន់មាំទាំ មិនទាន់កើតការត្រេកអរក្នុងទីដែលទៅហើយ តែកាលនៅអស់កាលមានប្រមាណប៉ុណ្ណេះ មាតាបិតាក៏រមែងបានឃើញ ដោយហេតុនោះ សេចក្តីសោករបស់មាតាបិតានោះ រមែងធូរស្រាល រមែងដឹងនូវការកាន់បាត្រ និងចីវរ រមែងកើតសេចក្តីស្និទ្ធស្នាលជាមួយសាមណេរ និងភិក្ខុកំលោះទាំងឡាយ សេចក្តី

ស្រឡាញ់ព្រះថេរៈទាំងឡាយ រមែងតាំងមាំក្នុងទីដែលទៅហើយ រមែងមានការត្រេកអរក្រៃលែង រមែងមិនអផ្សុក ព្រោះដូច្នោះ ទើបគួរនៅអស់កាលមានប្រមាណប៉ុណ្ណេះ ព្រោះហេតុនោះ ព្រះមានព្រះភាគព្រះនាមថា កស្សបទ្រង់គង់នៅអស់កន្លះខែ ទ្រង់ចៀសចេញទៅហើយ ។

[ ១៧៦ ] បទថា **បណ្ឌុមុដិកស្ស សាលិនោ** បានដល់ ស្រូវសាលីក្រហមដែលធ្វើឲ្យទន់ ក្រៀមហើយ ។ បានឮថា ស្រូវសាលីនោះ តាំងអំពីព្រោះទៅ មានការបរិហារ ដូច្នេះ ផ្ទៃស្រែ ត្រូវមានការធ្វើបរិកម្មយ៉ាងល្អ ហើយយកពូជព្រោះក្នុងទីនោះ ស្រោចដោយទឹកក្រអូប ។ ក្នុងវេលាសាបព្រោះ ចងកន្ទេលផែងឬសំពត់អំពីខាងលើ ធ្វើជាពិតាន ដល់វេលាទុំ ក៏ប្រូតធ្វើជាកណ្ដាប់ ចងខ្សែព្យួរទុកឲ្យស្ងួត ក្រាលលម្អិតក្រអូប ឲ្យពេញជង្រុករក្សាទុក ហើយបើករាល់ ៣ ឆ្នាំម្ដង ។ ស្រូវសាលីក្រហមក្លិនក្រអូប ដែលទុក ៣ ឆ្នាំ យ៉ាងនេះ ធ្វើជាអង្ករបរិសុទ្ធល្អ មិនមានគ្រាប់ខ្មៅ និងតាក់តែងជារបស់ទំពា ប្រភេទផ្សេងៗ ក៏បាន ជាបាយក៏បាន ។ លោកសំដៅយកពាក្យនោះ ទើបពោលថា **បណីតញ្ច ខាទនីយំ ភោជនីយំ ។បេ។ កាលំ អារោចាបេសិ** ប្រែថា តាក់តែងខាទនីយ ភោជនីយដ៏ប្រណីត ។បេ។ ហើយឲ្យរាជបុរសក្រាបទូលកត្តកាល ។

[ ១៧៧ ] ពីរបទថា **អធិវុដ្ឋោ មេ** សេចក្ដីថា ព្រះមានព្រះភាគ ព្រះនាមកស្សបៈ ត្រាស់សំដៅដល់អ្វី ត្រាស់សំដៅដល់ថា ក្នុងពេលព្រះអង្គយាងចេញអំពី វេភឡិគៈ ឃដិការបានកាន់យកប្តេជ្ញា ដើម្បីឲ្យទ្រង់ប្រថាប់

នៅចាំវស្សាក្នុងសម្នាក់របស់ខ្លួននោះ ។ ត្រាស់សំដៅដល់ការចាំវស្សានោះ ។ បទថា **អហុទេវ អញ្ញថត្តំ អហុ ទោមនស្សំ** សេចក្ដីថា ព្រះបាទកិកិកាសិករាជទ្រង់ប្រារព្ធដល់ការមិនមានលាភ មានការទោមនស្ស មានចិត្តអាក់អន់ថា អញ មិនបានថ្វាយទានអស់ត្រីមាស នឹងមិនបានដើម្បីស្ដាប់ព្រះធម៌ នឹងមិនបានដើម្បីបដិបត្តិព្រះភិក្ខុ ២ ម៉ឺនរូប ដោយទំនងនេះហើយ ទ្រង់មិនប្រារព្ធព្រះតថាគត ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះព្រះអង្គជាសោតាបន្ន ។

បានឮថា កាលមុន ព្រះបាទកិកិកាសិករាជនោះ ទ្រង់រាប់អានព្រាហ្មណ៍តមកសម័យមួយ កាលជាយដែនបះបោរ ទ្រង់យាងទៅរម្ងាប់ ទើបត្រាស់ប្រាប់ធីតាព្រះនាមឧរច្ឆទាថា កូនជាទីស្រឡាញ់ នាងចូរកុំប្រមាទក្នុងទេវតារបស់យើង ។ ពួកព្រាហ្មណ៍ទាំងឡាយ ឃើញរាជធីតានោះហើយ នាំគ្នាអស់នូវសញ្ញាទៅ ។ រាជបុរសទាំងឡាយ កាលព្រះនាងសួរថា មនុស្សទាំងនេះគឺនរណា ក៏ឆ្លើយថា ជាទេវតារបស់ព្រះរាជា ។ ព្រះរាជធីតាត្រាស់សួរថា ឈ្មោះកុម្ភទេវតាមានរូបយ៉ាងនេះឬ ហើយព្រះនាងឡើងប្រាសាទ ។ ថ្ងៃមួយព្រះនាងឈរទតមកកាន់ផ្លូវហ្លួង ឃើញអគ្គសាវក របស់ព្រះមានព្រះភាគកស្សបៈ ព្រះនាងឲ្យនិមន្តមកហើយ ប្រគេនបិណ្ឌបាត ព្រះនាងស្ដាប់អនុមោទនានោះឯង បានជាព្រះសោតាបន្ន ទើបត្រាស់សួរថា បពិត្រលោកម្ចាស់ ភិក្ខុរូបដទៃៗ នៅមានខ្លះទេ ព្រះនាងបានឮថា ព្រះសាស្ដា មួយអន្លើដោយភិក្ខុសង្ឃ ២ ម៉ឺនអង្គ ទ្រង់ប្រថាប់នៅក្នុងឥសិបតនៈ ទើបព្រះនាងឲ្យទៅនិមន្តមកហើយថ្វាយទាន ។ ព្រះរាជាទ្រង់ញុំាងអាណាខេត្តឲ្យស្ងប់ហើយ

យានត្រឡប់មក ។ ពេលនោះ ពួកព្រាហ្មណ៍ទាំងឡាយ ក៏មកគាល់ព្រះរាជាមុននោះឯង ពោលទោសព្រះធីតា ហើយបែកគ្នាទៅ តែព្រះរាជាទ្រង់បានប្រទានពរទុកក្នុងវេលាព្រះរាជធីតាប្រសូត ។ ព្រះញាតិទាំងឡាយ សូមពរថ្វាយព្រះនាងថា សូមឲ្យគ្រងរាជ្យ ៧ ថ្ងៃ កាលនោះ ទើបព្រះរាជាទ្រង់ប្រគល់រាជសម្បត្តិឲ្យព្រះរាជធីតា ៧ ថ្ងៃ ។ ព្រះរាជធីតា ញុំាងព្រះសាស្ដាឲ្យសោយ បញ្ជាឲ្យយានព្រះរាជា មកប្រថាប់គង់ខាងក្រៅវាំងនទហើយ ។ លុះព្រះរាជា ទ្រង់ស្ដាប់អនុមោទនារបស់ព្រះសាស្ដា ក៏បានជាព្រះសោតាបន្ន ។ ធម្មតាព្រះសោតាបន្ន ទ្រង់មិនមានអាឃាតប្រារព្ធព្រះតថាគត ព្រោះដូច្នោះ ទើបលោកពោលថា **ឆ តថាគតំ អារព្ភ** ប្រែថា ការខូចចិត្ត ការទោមនស្ស មិនបានប្រារព្ធព្រះតថាគត ។

[ ១៧៨ ] បទថា **យំ ឥច្ឆតិ តំ ហរតុ** សេចក្ដីថា បានឮថា យជិការស្មូនឆ្នាំងធ្វើភាជនៈទាំងឡាយទុក មិនធ្វើការទិញ និងការលក់ ។ កាលពោលយ៉ាងនេះហើយ ទើបទៅកាន់ព្រៃដើម្បីរកឧសខ្លះ ដើម្បីរកដីខ្លះ ដើម្បីរកបន្លែខ្លះ ។ មហាជនបានឮថា យជិការស្មូនឆ្នាំងធ្វើភាជនៈស្រេចហើយ ទើបកាន់យកអង្ករ អំបិល សប្បិ ប្រេង និងទឹកអំពៅដែលល្អៗ ជាដើមមក បើភាជនៈមានតម្លៃច្រើន មូលតម្លៃមានតិច ត្រូវឲ្យទ្រព្យសមគួរ ទើបនាំយកទៅ ដូច្នោះ ទើបមហាជនមិននាំយកភាជនៈនោះទៅ ត្រូវនាំយកមូលតម្លៃមកទៀត ដោយគិតថា យជិការស្មូនឆ្នាំង ជាអ្នកជំនួញប្រកបដោយធម៌ បដិបត្តិទំនុកបម្រុងមាតាបិតា ឧបដ្ឋាកព្រះសម្មាសម្ពុទ្ធ អកុសលនឹងមានដល់យើងច្រើន

ដូច្នេះ ។ តែបើកាជនៈមានតម្លៃតិច មូលតម្លៃថ្លៃជាង ក៏ជួយរក្សាតម្លៃដែលនាំមកឲ្យល្អ ដូចម្ចាស់ផ្ទះ ហើយទើបទៅដោយគិតថា យដិការស្ទូនឆ្នាំងជាអ្នកលក់ដូរដែលប្រកបដោយធម៌ នឹងជាបុណ្យរបស់ពួកយើង ដូច្នេះ ។ ព្រះមានព្រះភាគព្រះនាមថាកស្សប កាលទ្រង់កាត់នូវគន្លងពាក្យរបស់ព្រះរាជាថា យដិការស្ទូនឆ្នាំង មានគុណដល់ម៉្លេះ ហេតុអ្វីមិនបួស ទើបត្រាស់ថា បពិត្រមហារាជ យដិការស្ទូនឆ្នាំងតែងចិញ្ចឹមមាតាបិតា ដែលចាស់ងងឹតងងល់ដូច្នេះ ។

[ ១៧៩ ] បទថា **ក្វោ នុ ខោ** សេចក្តីថា ព្រះមានព្រះភាគ ត្រាស់សួរថា យដិការស្ទូនឆ្នាំងទៅណាហ្ន៎ ។ បទថា **កុម្ភិយា** ប្រែថា អំពីឆ្នាំងបាយ ។ បទថា **បរិយោគា** ប្រែថា អំពីឆ្នាំងសម្ល ។ បទថា **បរិភុញ្ជ** ប្រែថា សូមទ្រង់ឆាន់ចុះ ។ សួរថា មាតាបិតារបស់យដិការពោលយ៉ាងនោះព្រោះហេតុអ្វី ។ ឆ្លើយថា បានឮថា យដិការស្ទូនឆ្នាំង ចម្អិនបាយហើយស្ងោសម្លហើយ ឲ្យឪពុកម្ដាយបរិភោគហើយ ទើបខ្លួនឯងបរិភោគ ហើយរៀបបាយ រៀបសម្ល ដែលជួសទុកថ្វាយព្រះមានព្រះភាគ ក្រាលអាសនៈទុក នាំយកអាហារចូល ទៅដាក់ទុកក្បែរ រៀបចំទឹកទុក ឲ្យសញ្ញាដល់មាតាបិតាហើយទើបទៅកាន់ព្រៃ ព្រោះដូច្នោះ ទើបពោលយ៉ាងនេះ ។ បទថា **អភិវិស្សដ្ឋោ** ប្រែថា ព្រះមានព្រះភាគស្និទ្ធស្នាលក្រៃលែង ។ បទថា **បីតិសុខំ ន វិជហតិ** សេចក្តី ថា យដិការស្ទូនឆ្នាំងមិនលះបីតិ សុខរហូតទៅដោយពិតនោះ យដិការស្ទូនឆ្នាំងរព្ញករឿយៗ មិនថាខណៈណា ទោះពេល

យប់ក្តី ពេលថ្ងៃក្តី ទាំងក្នុងស្រុក ទាំងក្នុងព្រៃថា ឧត្តមបុគ្គលក្នុងលោក ព្រមទាំងទេវលោក ទ្រង់ចូល មកក្នុងផ្ទះអញ កាន់យកអាមិសទៅសោយ ជាលាភរបស់អញហ្ន៎ បីតិ ៥ យ៉ាង រមែងកើតឡើងគ្រប់ៗ ខណៈ ។ លោកពោលពាក្យនោះ សំដៅដល់រឿងនេះ ។

[ ១៨០ ] បទថា **កាឡេយ្យាបិយា** ប្រែថា អំពីកឡោបី ។ សួរថា ព្រះមានព្រះភាគ ទ្រង់ធ្វើយ៉ាងនេះបានឬ ឆ្លើយថា ជាហេតុដែលប្រកបដោយធម៌ ដូចគ្នានឹង សម្លក្នុងបាត្ររបស់ភិក្ខុទាំងឡាយ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងនោះ ។ម្យ៉ាងទៀត ការបញ្ញត្តិសិក្ខាបទរមែងមានដល់សាវកទាំងឡាយប៉ុណ្ណោះ ឈ្មោះថាព្រំដែននៃសិក្ខាបទ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ។ ដូចជាផ្កា និងផ្លែឈើដែលនៅក្នុងព្រះរាជឧទ្យាន មនុស្សដទៃបេះផ្កា និងផ្លែឈើទាំងនោះ រមែងមានទោស ឯព្រះរាជាទ្រង់សោយបានតាមព្រះអធ្យាស្រ័យ សេចក្តីនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ឯព្រះថេរៈក្នុង ត្រើយសមុទ្រខាងនាយបានពោលថា ពួកទេវតាទាំងឡាយ ចាត់ចែងថ្វាយ ហើយ ដូច្នេះ ។

បទថា **ហរេថ ភន្តេ ហរេថ ភទ្រមុខា** សេចក្តីថា កូនរបស់ខ្ញុំកាលសួរថា នឹងទៅណា ក៏ឆ្លើយថា ទៅកាន់សម្នាក់ព្រះទសពល ។ រលំទៅទីណាទេដឹងហ្ន៎ ទើបមិនដឹងថា ទីប្រថាប់របស់ព្រះសាស្តាលិច ជាអ្នកមានចិត្តត្រេកអរ ហើយ ក្នុងការកាន់យក មានការសម្គាល់ថា មិនមានការខុស ទើបពោល យ៉ាងនោះ ។ បទថា **តេមាសំ អាកាសច្ឆទនំ អដ្ឋាសិ** សេចក្តីថា បានឮថា

ព្រះមានព្រះភាគ ទ្រង់គង់អស់មួយខែ ក្នុងរដូវភ្លៀង ៤ ខែ ទើបទ្រង់ឲ្យភិក្ខុទៅនាំស្បូវមក ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។ ម្យ៉ាងទៀត សេចក្ដីចំពោះបទក្នុងរឿងនេះដូចតទៅនេះ ។ ឈ្មោះថា មានអាកាសជាគ្រឿងប្រក់ ព្រោះអត្ថថា អាកាសជាគ្រឿងប្រក់នៃផ្ទះនោះ ។ បទថា **ន ចាតិវស្សិ** សេចក្ដីថា មិនមែនភ្លៀងមិនលេចតែម្យ៉ាងប៉ុណ្ណោះទេ តាមធម្មតាតំណក់ទឹកសូម្បីមួយតំណក់ក៏មិនបានលេចហើយក្នុងខាងក្នុងទីទឹកតក់នៃសំយាបជំបូលត្រង់ផ្ទះឃដិការស្ដូនថ្នាំងនេះយ៉ាងណា សូម្បីខ្យល់និងកម្ដៅថ្ងៃក៏មិនធ្វើការបៀតបៀន ដូចក្នុងផ្ទះដែលមានគ្រឿងប្រក់បាំងដ៏ក្រាស់ ដូច្នោះ ។ ការផ្សាយទៅ នៃរដូវក៏មានតាមធម្មតានោះឯង ។ ខាងក្រោយមក កាលនិគមនោះសូម្បីគេបោះបង់ទៅហើយ ទីត្រង់នោះភ្លៀងក៏មិនធ្លាក់ចំនោះឯង ។ ពួកមនុស្សកាលធ្វើការងារក្នុងរដូវភ្លៀង ក៏ទុកដាក់សាដកត្រង់ទីនោះហើយ ធ្វើការងារ ។ ទីត្រង់នោះ មានសភាពដូច្នោះរឿយៗ ទៅរហូតអស់មួយកប្ប ។ អាការដែលមានសភាពដូច្នោះ មិនមែនដោយឥទ្ធានុភាពរបស់ព្រះតថាគត តែដោយគុណសម្បត្តិរបស់មាតា និងបិតារបស់ឃដិការស្ដូនថ្នាំងនោះឯង ។ ពិតហើយ មាតា និងបិតារបស់ឃដិការស្ដូនថ្នាំងនោះ មិនបានកើតទោមនស្ស ព្រោះសេចក្ដីនោះជាបច្ច័យថា ព្រះសម្មាសម្ពុទ្ធមិនគប្បីបាន ក្នុងទីណា ទើបទ្រង់ឲ្យធ្វើការរើជំបូលផ្ទះរបស់អញ ដែលជាអ្នកខ្វាក់ភ្នែកទាំង ២ នាក់ ។ តែបែរជាកើតសោមនស្សយ៉ាងមានកម្លាំងមិនមែនតិច ដល់គាត់ថា ឱ ឧត្តមបុគ្គលក្នុងលោក និងទេវលោក ឲ្យមកនាំស្បូវអំពីផ្ទះរបស់អញទៅទៅប្រក់ព្រះគន្ធកុដិ ដូច្នេះ បណ្ឌិតគប្បីជ្រាបថា បាដិហារ្យនេះកើតឡើងដោយ

គុណសម្បត្តិរបស់មាតាបិតាយដិការស្នូទផ្ទាំងនោះឯង ដោយប្រការដូច្នេះ ។

[ ១៨២ ] ក្នុងបទថា **តណ្ឌុលវាហសតានិ** នេះ គប្បីជ្រាបថា ២០០ រទេះ ជា ១ វាហៈ ។ បទថា **តទុបិយញ្ច សូបេយ្យំ** សេចក្តីថា វត្ថុ មានប្រេង ទឹកអំពៅជាដើម ដែលសមគួរដល់អង្ករនោះ ដើម្បីស្នូបៈ បានឮថា ព្រះរាជាទ្រង់បញ្ជូនរបស់មានប្រមាណប៉ុណ្ណេះទៅ ដោយទ្រង់សម្គាល់ថា ភត្តនឹងមានដល់ភិក្ខុ ១០០០ រូប ដើម្បីប្រយោជន៍អស់ត្រៃមាស ។ បទថា **អលម្មេ ញ្ញោ វ ហោតុ** សេចក្តីថា យដិការស្នូទផ្ទាំងបដិសេធហើយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាអ្នកសម្រេចការប្រាថ្នាតិច ។ បានឮថា យដិការស្នូទផ្ទាំងនោះ មានការគិតយ៉ាងនេះថា ព្រះរាជាទ្រង់មិនធ្លាប់ឃើញអញ បញ្ជូនមកហើយ ដើម្បីអ្វីហ្ន៎ ។ បន្ទាប់អំពីនោះ ទើបត្រិះរិះថា ព្រះសាស្តា យាងទៅកាន់នគរពារាណសី ទ្រង់កាលត្រូវព្រះរាជាទូលអារាធនាឲ្យនៅចាំវស្សា ក៏ត្រាស់ប្រាប់ថា ទ្រង់ទទួលបេជ្ជារបស់អញទុកហើយ នឹងត្រាស់ប្រាប់គុណកថារបស់អញដោយពិត បុគ្គលដែលមានលាភនៃគុណកថា ដែលបានហើយ រមែងដូចជាលាភដែលអ្នករបាំរាំហើយ ទើបបាន និងដូចលាភដែលអ្នកប្រគំច្រៀងហើយទើបបាន ប្រយោជន៍អ្វីដោយវត្ថុនេះដល់អញ អញអាចធ្វើការទំនុកបម្រុងមាតាផង បិតាផង ព្រះសម្មាសម្ពុទ្ធផង ដោយលាភដែលអញធ្វើការងារហើយកើតឡើង ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថា យដិការសូត្រ ចប់**

**សូត្រទី ១ ចប់**

# សុត្តន្តបិដក

## វេរញ្ជព្រាហ្មណសូត្រទី២

[ ១៨៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅក្នុងដែនកុរុ ជាមួយនឹងពួកភិក្ខុច្រើន ទៅដល់ថុល្លកោដ្ឋិត និគម របស់អ្នកដែនកុរុទាំងឡាយ ។ ព្រាហ្មណ៍ និងគហបតីទាំងឡាយ អ្នកស្រុកថុល្លកោដ្ឋិតបានឮដំណឹងថា ព្រះសមណគោតមជាសក្យបុត្ត ទ្រង់ចេញចាកសក្យត្រកូលទ្រង់ព្រះផ្នួស ( ឥឡូវ ) ទ្រង់ពុទ្ធដំណើរមកក្នុងដែន កុរុជាមួយនឹងពួកភិក្ខុច្រើន មកដល់ថុល្លកោដ្ឋិតនិគមហើយ កិត្តិសព្ទដ៏ល្អ នៃព្រះគោតមដ៏ចម្រើននោះឯង ឮខ្ចរខ្ចាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គ នោះ ទ្រង់ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ជា ព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គជាបុគ្គលប្រសើរបំផុត ព្រះអង្គ ជាសារថីទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាសាស្តានៃទេវតានិង មនុស្សទាំងឡាយ ព្រះអង្គភ្ញាក់រលឹកហើយ ទ្រង់ចែកនូវធម៌ទាំងពួង ទ្រង់ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងទេវតា និងមនុស្សដ៏សេស ដោយប្រាជ្ញាដ៏ក្រៃលែងដោយព្រះអង្គឯង ហើយទ្រង់ប្រកាស ( នូវសេចក្តី នោះ ) ទ្រង់សម្តែងធម៌មានលម្អបទដើម បទកណ្តាលនឹងបទចុង ទ្រង់ប្រកាស នូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធ ក៏ការ បានឃើញព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះជាការប្រពៃពេក ។

[ ១៨៥ ] លំដាប់នោះឯង ពួកព្រាហ្មណ៍ និងគហបតី ក្នុងថុល្លកោដ្ឋិតនិគម បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែរាក់ទាក់ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលីទៅរកព្រះមានជោគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រ ក្នុងសំណាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយស្ងៀមក្នុងទីដ៏សមគួរ ។ លុះពួកព្រាហ្មណ៍ និងគហបតីអ្នកស្រុក ថុល្លកោដ្ឋិតអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។

[ ១៨៦ ] ទទួលជួនសម័យនោះឯង មានកុលបុត្រម្នាក់ ឈ្មោះរដ្ឋបាល ជាកូនរបស់អ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនោះឯង បានអង្គុយក្នុងបរិសទ័នោះដែរ ។ គ្រានោះ រដ្ឋបាលកុលបុត្រមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញបានដឹងធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ យ៉ាងណាៗ តែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលដែលនៅគ្រប់គ្រងផ្ទះ ងាយនឹងប្រព្រឹត្តឲ្យបរិបូរណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យផូរផង់ ដូចជាស័ង្ខដែលគេខាត់ហើយយ៉ាងនោះៗ ទេ បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្ការស្លៀកដណ្តប់សំពត់សាកាយៈ ចេញចាកផ្ទះទៅបួស ។ ចំណែកពួកព្រាហ្មណ៍ និងគហបតី អ្នកថុល្លកោដ្ឋិតៈ ដែលព្រះមាន

ព្រះភាគ ទ្រង់ពន្យល់ឲ្យយល់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយបានត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ កាលដែលពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកថុល្លកោដ្ឋិតថយចេញទៅ មិនយូរប៉ុន្មាន ទើបរដ្ឋបាលកុលបុត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះរដ្ឋបាលកុលបុត្ត អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយយ៉ាងណាៗ តែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យផូរផង់ដូចជាស័ង្ខ ដែលគេខាតហើយយ៉ាងនោះៗ ទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នានឹងកោរសក់ពុកមាត់ពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យខ្ញុំព្រះអង្គបាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលរដ្ឋបាល មាតាបិតាបានអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះមកបួសហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មាតាបិតាមិនទាន់អនុញ្ញាតឲ្យខ្ញុំព្រះអង្គចេញចាកផ្ទះមកបួសទេ ។ ម្នាលរដ្ឋបាល ព្រះតថាគតទាំងឡាយ មិនបំបួសកូនដែលមាតាបិតា មិនទាន់អនុញ្ញាតទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មាតាបិតានឹងអនុញ្ញាតឲ្យខ្ញុំព្រះអង្គ

ចេញចាកផ្ទះមកបួសយ៉ាងណា ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ។

[ ១៨៧ ] ខណៈនោះឯង រដ្ឋបាលកុលបុត្រ ក្រោកចាកអាសនៈហើយ ថ្វាយបង្គំព្រះមានជោគ ធ្វើប្រទក្សិណហើយ ចូលទៅរកមាតាបិតា លុះចូលទៅដល់ហើយ បាននិយាយនឹងមាតាបិតាយ៉ាងនេះថា បពិត្រលោកម្តាយលោកឪពុក ខ្ញុំបានយល់ច្បាស់នូវធម៌ ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយយ៉ាងណា តែព្រហ្មចរិយធម៌នេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យផូរផង់ដូចជាស័ង្ខដែលគេខាត់ហើយយ៉ាងនោះៗ បានទេ ខ្ញុំប្រាថ្នានឹងកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស សូមលោកម្តាយលោកឪពុក អនុញ្ញាតឲ្យខ្ញុំចេញចាកផ្ទះទៅបួសចុះ ។

[ ១៨៨ ] កាលបើរដ្ឋបាលកុលបុត្រនិយាយយ៉ាងនេះហើយ មាតាបិតាក៏និយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា ម្នាលរដ្ឋបាលកូន អ្នកឯងជាបុត្តតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ធ្លាប់ចម្រើនដោយសេចក្តីសុខជាអ្នកដែលគេបីបាច់រក្សាដោយសុខ នែរដ្ឋបាលកូន បាឯងមិនដែលស្គាល់ទុក្ខបន្តិចបន្តួចសោះឡើយ នែបារដ្ឋបាលកូន អ្នកចូរមកបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើចុះ កាលបើអ្នកបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើហើយ ចូរបរិភោគកាមទាំងធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ យើងមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទុកជាដល់ស្លាប់ យើងក៏មិនចង់ឃ្លាតពីបាដែរ ចំណាន់បើបានៅរស់ ( យ៉ាងនេះ ) តើយើងនឹងអនុញ្ញាតឲ្យចេញចាកផ្ទះទៅបួសដូចម្តេច

បាន ។ រដ្ឋបាលកុលបុត្តបាននិយាយនឹងមាតាបិតាជាគម្រប់ពីរដងផង ។បេ។ ជាគម្រប់បីដងផងយ៉ាងនេះថា បពិត្រមាតាបិតា ខ្ញុំយល់ច្បាស់នូវធម៌ ដែលព្រះមានជោគទ្រង់សម្តែងយ៉ាងណា តែព្រហ្មចរិយៈនេះ មិនមែនសម្រាប់បុគ្គលអ្នកនៅគ្រប់គ្រងផ្ទះ ងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌សព្វគ្រប់ ឲ្យបរិសុទ្ធសព្វគ្រប់ ឲ្យផូរផង់ដូចជាស័ង្ខដែលគេដុសខាត់ហើយយ៉ាងនោះទេ ខ្ញុំប្រាថ្នានឹងកោរសក់ ពុកមាត់ពុកចង្ការហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅបួស ហេតុនេះ សូមមាតាបិតា អនុញ្ញាតឲ្យខ្ញុំចេញចាក ផ្ទះទៅបួសចុះ ។ មាតាបិតា របស់រដ្ឋបាលកុលបុត្រ បាននិយាយនឹងរដ្ឋបាលកុលបុត្រ ជាគម្រប់បីដងយ៉ាងនេះថា នែរដ្ឋបាលកូន បាឯងជាបុត្រតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង អ្នកធ្លាប់ចម្រើនដោយសេចក្តីសុខ គេបីបាច់រក្សាមកជាសុខ នែរដ្ឋបាលកូន អ្នកមិនទាន់ស្គាល់សេចក្តីលំបាកតិចតួចសោះ នែរដ្ឋបាលកូន អ្នកចូរមកបរិភោគបាយផឹកទឹក ទាំងឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគបាយផឹកទឹក ទាំងឲ្យគេបម្រើ បរិភោគនូវកាមហើយ ចូរធ្វើបុណ្យតាមស្មគ្រចិត្តចុះ យើងមិនអនុញ្ញាតឲ្យបាចេញចាកផ្ទះទៅបួសទេ ទោះណាជាដល់ស្លាប់ យើងក៏មិនប្រាថ្នាឲ្យឃ្លាតពីអ្នកដែរ ចំណង់បើអ្នករស់នៅ ( យ៉ាងនេះ ) តើយើងនឹងអនុញ្ញាតឲ្យចេញចាកផ្ទះទៅបួសដូចម្តេចបាន ។

[ ១៨៩ ] គ្រានោះឯង រដ្ឋបាលកុលបុត្រ គិតថា មាតាបិតា មិនអនុញ្ញាត ឲ្យអាត្មាអញចេញចាកផ្ទះទៅបួសទេ ក៏ដួលដេកនៅលើទីដែលមិន

បានក្រាលដោយអ្វីៗ ត្រង់កន្លែងនោះឯង ដោយគិតថា អាត្មាអញនឹងស្លាប់ក្នុងទីនេះ ឬនឹងបានបួស ។ លំដាប់នោះឯង រដ្ឋបាលកុលបុត្រ មិនបានបរិភោគបាយអស់មួយពេល មិនបរិភោគអស់ ២ ពេល មិនបរិភោគអស់ ៣ ពេល មិនបរិភោគអស់ ៤ ពេល មិនបរិភោគអស់ ៥ ពេល មិនបរិភោគអស់ ៦ ពេល មិនបរិភោគអស់ ៧ ពេល ។

[ ១៩០ ] ពេលនោះ មាតាបិតារបស់រដ្ឋបាលកុលបុត្រនិយាយ នឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា នែរដ្ឋបាលកូន បាឯងជាកូនតែមួយ ជាទីស្រឡាញ់ ពេញចិត្តរបស់យើង អ្នកធ្លាប់ចម្រើនដោយសេចក្ដីសុខ គេថែរក្សាមកដោយសេចក្ដីសុខ នែរដ្ឋបាលកូន អ្នកមិនទាន់ស្គាល់សេចក្ដីលំបាកបន្តិចបន្តួចសោះ នែរដ្ឋបាលកូន អ្នកចូរក្រោកឡើង ចូរបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើ បរិភោគកាមហើយ ចូរធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ យើងមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះ ទៅបួសទេ ទោះណាជាដល់ស្លាប់ យើងក៏មិនចង់ឲ្យព្រាត់ប្រាស់បាឯងទេ ចំណង់បើអ្នកនៅរស់ ( យ៉ាងនេះ ) តើយើងនឹងអនុញ្ញាតឲ្យបាចេញចាកផ្ទះទៅបួសដូចម្ដេចបាន ។ កាលដែលមាតាបិតានិយាយយ៉ាងនេះហើយ រដ្ឋបាលកុលបុត្រក៏ស្ងៀម ។ មាតាបិតារបស់រដ្ឋបាលកុលបុត្រ និយាយនឹងរដ្ឋបាលកុលបុត្រ អស់វារៈ ២ ដងយ៉ាងនេះ ។បេ។ សូម្បីអស់វារៈទី ២ រដ្ឋបាលកុលបុត្រក៏នៅតែស្ងៀមទៀត ។ មាតាបិតារបស់រដ្ឋបាលកុលបុត្រ និយាយនឹងរដ្ឋបាលកុលបុត្រ ជាគម្រប់ ៣ ដងយ៉ាងនេះថា ម្នាលរដ្ឋបាល

កូន អ្នកជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង អ្នកធ្លាប់ចម្រើនដោយសេចក្តីសុខ មានគេថែរក្សាដោយសេចក្តីសុខ នែវដ្ឋបាលកូន អ្នកមិនទាន់ស្គាល់ទុក្ខបន្តិចបន្តួចសោះ នែវដ្ឋបាលកូន ចូរអ្នកក្រោកឡើង ចូរបរិភោគបាយផឹកទឹកឲ្យគេបម្រើទៅ កាលបើបរិភោគបាយផឹកទឹក ទាំងឲ្យគេបម្រើ បរិភោគកាមហើយ ចូរធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ យើងមិនអនុញ្ញាតឲ្យបាឯង ចេញចាកផ្ទះទៅបួសទេ ទោះបីដល់ស្លាប់ យើងក៏មិនប្រាថ្នា ឲ្យឃ្លាតអំពីបាដែរ ចំណង់បើអ្នកនៅរស់ត្រឡាំង តើយើងនឹងអនុញ្ញាតឲ្យបាចេញចាកផ្ទះទៅបួសដូចម្តេចបាន ។ សូម្បីអស់វារៈទី ៣ វដ្ឋបាលកុលបុត្រក៏នៅតែស្ងៀម ។

[ ១៩១ ] គ្រានោះឯង ពួកសម្លាញ់ របស់វដ្ឋបាលកុលបុត្រ នាំគ្នាចូលទៅរកវដ្ឋបាលកុលបុត្រ លុះចូលទៅដល់ហើយ ក៏និយាយនឹងវដ្ឋបាលកុលបុត្រយ៉ាងនេះថា នែវដ្ឋបាលសម្លាញ់ អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា អ្នកឯងចម្រើនដោយសេចក្តីសុខ មានគេថែរក្សាដោយសេចក្តីសុខ នែវដ្ឋបាលសម្លាញ់ អ្នកមិនទាន់ស្គាល់ទុក្ខបន្តិចបន្តួចសោះ នែវដ្ឋបាលសម្លាញ់ អ្នកចូរក្រោកឡើង ចូរបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើ បរិភោគនូវកាមហើយ ចូរធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ មាតាបិតាមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទោះណាជាដល់ស្លាប់ ក៏មាតាបិតាមិន ប្រាថ្នាឲ្យឃ្លាតពីអ្នកដែរ ចំណង់បើអ្នកនៅរស់ ( យ៉ាងនេះ ) តើមាតាបិតា នឹង

អនុញ្ញាត ឲ្យចេញចាកផ្ទះទៅបួសដូចម្ដេចបាន ។ កាលដែលពួកសម្លាញ់និយាយយ៉ាងនេះហើយ រដ្ឋបាលកុលបុត្រក៏នៅស្ងៀមទៀត ។ សូម្បីអស់វារជាគម្រប់ ២ ដង ។បេ។ ពួកសម្លាញ់របស់រដ្ឋបាលកុលបុត្រ បាននិយាយនឹងរដ្ឋបាលកុលបុត្រ ជាគម្រប់ ៣ ដងយ៉ាងនេះថា នែរដ្ឋបាលសម្លាញ់ អ្នកឯងជាកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា អ្នកធ្លាប់ចម្រើនដោយសេចក្ដីសុខ គេបីបាច់មកដោយសេចក្ដីសុខ ។បេ។ នែរដ្ឋបាលសម្លាញ់ អ្នកចូរក្រោកឡើង ចូរបរិភោគបាយផឹកទឹកទាំងឲ្យគេបម្រើទៅ កាលបើអ្នកបរិភោគបាយផឹកទឹក ឲ្យគេបម្រើ បរិភោគកាមហើយ ចូរធ្វើបុណ្យតាមស្ម័គ្រចិត្តចុះ មាតាបិតាមិនអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសទេ ទុកជាដល់ស្លាប់ ក៏មាតាបិតា មិនចង់ឲ្យព្រាត់ប្រាសចាកអ្នកទេ ចំណង់បើអ្នកនៅរស់ ( យ៉ាងនេះ ) តើមាតាបិតា នឹងអនុញ្ញាតឲ្យអ្នកចេញចាកផ្ទះទៅបួសដូចម្ដេចបាន ។ សូម្បីអស់វារៈ ៣ ដង រដ្ឋបាលកុលបុត្រក៏នៅតែស្ងៀម ។ លំដាប់នោះ ពួកសម្លាញ់របស់រដ្ឋបាលកុលបុត្រ ចូលទៅរកមាតាបិតា របស់រដ្ឋបាលកុលបុត្រ លុះចូលទៅដល់ហើយ ក៏និយាយនឹងមាតាបិតា របស់រដ្ឋបាលកុលបុត្រយ៉ាងនេះថា បពិត្រអ្នកជាម្ដាយឪពុក រដ្ឋបាលកុលបុត្រនុ៎ះនៅតែដេកលើទីដែលគ្មានក្រាលកម្រាលអ្វីៗ ត្រង់កន្លែងនោះដដែល ដោយតាំងចិត្តថា អាត្មាអញនឹងស្លាប់ក្នុងទីនេះ ឬនឹងបានបួស បើអ្នកទាំងឡាយ មិនយល់ព្រមឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួសទេ រដ្ឋបាលកុលបុត្រ មុខជានឹងស្លាប់ក្នុងទីនោះមិនខានឡើយ ពួកយើងខ្ញុំយល់ថា បើអ្នកទាំងឡាយ

យល់ព្រម ឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួស គង់តែនឹងបានឃើញរដ្ឋបាលកុលបុត្រ ដែលទៅជាអ្នកបួសតទៅ បើរដ្ឋបាលកុលបុត្រមិនត្រេកអរក្នុងភេទជាអ្នកបួសហើយ រដ្ឋបាលកុលបុត្រនោះ នឹងមានគតិឃ្លាងទៅទៀតដូចម្តេចបាន មុខជានឹងត្រឡប់មកក្នុងទីនេះវិញមិនខាន សូមអ្នកទាំងឡាយអនុញ្ញាតឲ្យរដ្ឋបាលកុលបុត្រ ចេញចាកផ្ទះទៅបួសចុះ ។

[ ១៩២ ] មាតាបិតា របស់រដ្ឋបាលកុលបុត្រនិយាយថា នែអ្នកទាំងឡាយយើងយល់ព្រមឲ្យរដ្ឋបាលកុលបុត្រចេញចាកផ្ទះទៅបួសហើយ តែថារដ្ឋ-បាលបួសរួចហើយ ត្រូវឲ្យមាតាបិតាបានឃើញផង ។ លំដាប់នោះឯងពួកសម្លាញ់របស់រដ្ឋបាលកុលបុត្រ ចូលទៅរករដ្ឋបាលកុលបុត្រ លុះចូលទៅដល់ហើយ និយាយនឹងរដ្ឋបាលកុលបុត្រយ៉ាងនេះថា មាតាបិតារបស់អ្នកយល់ព្រមឲ្យអ្នកចេញចាកផ្ទះទៅបួសហើយ តែថាបើអ្នកបួសរួចហើយ ត្រូវឲ្យមាតាបិតាបានឃើញផង ។

[ ១៩៣ ] គ្រានោះ រដ្ឋបាលកុលបុត្រក្រោកឡើង ហើយសម្រាកកម្លាំង រួចហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានជោគដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះរដ្ឋបាលកុលបុត្រ អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាបុគ្គលដែលមាតាបិតា យល់ព្រមឲ្យចេញចាកផ្ទះមកបួសហើយ សូមព្រះមានព្រះភាគទ្រង់បំបួសខ្ញុំព្រះអង្គ ។ រដ្ឋបាលកុលបុត្រក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងសំណាក់នៃព្រះមាន

ព្រះភាគ ។ លំដាប់នោះឯង កាលបើរដ្ឋបាលមានអាយុ បានឧបសម្បទា មិនយូរប៉ុន្មាន បានឧបសម្បទាត្រឹមកន្លះខែ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងថុល្លកោដ្ឋិតនិគម សមគួរតាមពុទ្ធអធ្យាស្រ័យ ហើយទ្រង់ស្តេចចេញទៅក្រុងសាវត្ថី កាលទ្រង់ព្រះពុទ្ធដំណើរទៅកាន់ចារិកតាមលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថី ។

[ ១៩៤ ] មានសេចក្តីតំណាលថា ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះរដ្ឋបាលមានអាយុ បានចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនធ្វេសប្រហែស ខំព្យាយាមដុតបង់នូវកិលេស បញ្ជូនចិត្តឲ្យបែរទៅ ( កាន់ព្រះនិព្វាន ) ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ទៅបួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា ( ព្រះរដ្ឋបាល ) ក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចារ្យ ដោយបញ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ បានសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ដោយមិនយូរប៉ុន្មានទេ លោកបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចារ្យបាននៅចប់ហើយ កិច្ចដែលត្រូវធ្វើក៏បានធ្វើហើយ គ្មានកិច្ចដទៃអំពីនេះតទៅទៀតទេ ។ ព្រះរដ្ឋបាលមានអាយុ ជាព្រះអរហន្តមួយអង្គនឹងគេដែរ ។

[ ១៩៥ ] លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព

ហើយអត់អាហារក្នុងទីដ៏សមគួរ ។ ព្រះរដ្ឋបាលមានអាយុអត់អាហារក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើព្រះមានបុណ្យទ្រង់អនុញ្ញាតខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គប្រាថ្នានឹងឲ្យមាតាបិតាបានឃើញផង ។ គ្រានោះព្រះមានជោគទ្រង់សួង់មើលចិត្តរបស់ រដ្ឋបាលមានអាយុ ដោយព្រះទ័យរបស់ព្រះអង្គ ហើយទ្រង់ធ្វើទុកក្នុងព្រះទ័យតាមន័យដែលទ្រង់បានជ្រាបថា រដ្ឋបាលកុលបុត្រជាបុគ្គលមិនគួរនឹងលះបង់សិក្ខា ហើយត្រឡប់ទៅកាន់ហីនភេទវិញទេ ។ ទើបព្រះមានជោគបានត្រាស់ទៅនឹងរដ្ឋបាលមានអាយុយ៉ាងនេះថា ម្នាលរដ្ឋបាល អ្នកសម្គាល់នូវកាលដ៏សមគួរ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ រដ្ឋបាលមានអាយុ ក្រោកចាកអាសនៈហើយថ្វាយបង្គំព្រះមានជោគ ធ្វើប្រទក្សិណ ហើយក៏ទុកដាក់សេនាសនៈស្រេចហើយ កាន់យកបាត្រនិងចីវរចេញតម្រង់ ទៅថុល្លកោដ្ឋិតនិគម ត្រាច់ទៅកាន់ចារិកតាមលំដាប់ ហើយក៏បានដល់ទៅ ថុល្លកោដ្ឋិតនិគមនោះ ។

[ ១៩៦ ] មានសេចក្តីតំណាលថា ព្រះរដ្ឋបាលដ៏មានអាយុ នៅសម្នាក់ក្នុងឧទ្យានឈ្មោះមិគាចីរៈ របស់ព្រះបាទកោរព្យៈ ជិតថុល្លកោដ្ឋិតនិគមនោះ ។ ក្នុងលំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅបិណ្ឌបាត ក្នុងថុល្លកោដ្ឋិតនិគម ។ កាលលោកត្រាច់ទៅបិណ្ឌបាតតាមលំដាប់ច្រក ក្នុងថុល្លកោដ្ឋិតនិគម វៀងទៅដល់ទីនៅអាស្រ័យរបស់បិតានៃខ្លួន ។ ទន្ទួលជួនសម័យនោះឯង បិតារបស់ព្រះរដ្ឋបាល

មានអាយុ កំពុងតែឲ្យជាងកោរកាត់ ក្នុងរោងក្បែរទ្វារកណ្ដាល ។ បិតារបស់ព្រះរដ្ឋបាលមានអាយុ បានឃើញព្រះរដ្ឋបាលមានអាយុ កំពុងនិមន្តមកអំពីចម្ងាយលុះឃើញហើយ ក៏និយាយពាក្យយ៉ាងនេះថា ពួកស្រមណ៍កំណោរទាំងនេះហើយ ដែលបំបួសកូនប្រុសតែមួយ ជាទីស្រឡាញ់ពេញចិត្តរបស់យើង ។ គ្រានោះឯង ព្រះរដ្ឋបាលមានអាយុ មិនបានទូវទាន ទាំងមិនបាននូវពាក្យប្រាប់មកវិញ ក្នុងលំនៅរបស់បិតានៃខ្លួនសោះ បានត្រឹមតែពាក្យជេរប៉ុណ្ណោះឯង ។

[ ១៩៧ ] ទទួលជួនសម័យនោះឯង នាងទាសីរបស់ញាតិនៃរដ្ឋបាលមានអាយុ កំពុងមានបំណងនឹងចាក់ចោលនំកុម្មាសផ្អូម ។ គ្រានោះ ព្រះរដ្ឋបាលមានអាយុ និយាយនឹងខ្ញុំស្រីរបស់ញាតិនោះយ៉ាងនេះថា នែនាងបើនំនោះជារបស់ត្រូវចោល ចូរនាងចាក់មកក្នុងបាត្រអាត្មានេះចុះ ។ លំដាប់នោះ ខ្ញុំស្រីរបស់ញាតិរបស់ព្រះរដ្ឋបាលមានអាយុ ក៏ចាក់នំកុម្មាសផ្អូមនោះទៅក្នុងបាត្ររបស់ព្រះរដ្ឋបាលមានអាយុ ហើយបានស្គាល់ជាក់នូវដៃជើងនឹងសំឡេង របស់ព្រះរដ្ឋបាលនោះច្បាស់ ។ គ្រានោះ ខ្ញុំស្រីរបស់ញាតិនៃព្រះរដ្ឋបាលមានអាយុ ចូលទៅរកមាតា របស់ព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ បាននិយាយជម្រាបមាតា របស់ព្រះរដ្ឋបាលមានអាយុថា បពិត្រអ្នកម្ចាស់ សូមអ្នកជ្រាប ព្រោះព្រះរដ្ឋបាលជាអយ្យបុត្ត និមន្តមកដល់ហើយ ។ មាតារបស់ព្រះរដ្ឋបាលឆ្លើយថា នែហង បើឯងនិយាយពាក្យពិតមែន អញនឹងឲ្យឯងរួចជាអ្នកជា ។ ទើបមាតារបស់ព្រះរដ្ឋបាលមានអាយុ

ចូលទៅរកបិតារបស់ព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងបិតា របស់ព្រះរដ្ឋបាលមានអាយុ យ៉ាងនេះថា បពិត្រគហបតី សូមអ្នកជ្រាប ឮថារដ្ឋបាលកុលបុត្រ និមន្តមកដល់ហើយ ។

[ ១៩៨ ] សម័យនោះឯង ព្រះរដ្ឋបាលមានអាយុ កំពុងឆាន់នំកុម្មាសផ្អូមនោះ ប្របជញ្ជាំងសាលាមួយ ។ លំដាប់នោះ បិតារបស់ព្រះរដ្ឋបាលមានអាយុ ចូលទៅរកព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងរដ្ឋបាលមានអាយុយ៉ាងនេះថា នែរដ្ឋបាលកូន មានដែរឬ លោកមកឆាន់នំកុម្មាសផ្អូមវិញ រដ្ឋបាលកូន គួរតែទៅឯផ្ទះរបស់ខ្លួនវិញ ។ ព្រះរដ្ឋបាលឆ្លើយថា នែគហបតី ពួកយើងអ្នកបួសដែលចេញចាកផ្ទះទៅបួសហើយនឹងមានផ្ទះមកពីណា នែគហបតី ព្រោះពួកយើងគ្មានផ្ទះទេ នែគហបតី អាត្មាបានទៅដល់ផ្ទះរបស់អ្នកហើយ តែមិនបានទូវទានផង មិនបានទូវការនិយាយប្រាប់វិញផង ក្នុងផ្ទះរបស់អ្នកនោះសោះ បានត្រឹមតែ ពាក្យជេរប៉ុណ្ណោះឯង ។ រដ្ឋបាលកូន លោកចូរមកយើងនឹងទៅផ្ទះ ។ ណ្ហើយគហតី ថ្ងៃនេះអាត្មាឆាន់រួចហើយ ។ រដ្ឋបាលកូន បើដូច្នោះ សូមលោកនិមន្តទទួលចង្ហាន់ក្នុងថ្ងៃស្អែក ។ ព្រះរដ្ឋបាលមានអាយុ ក៏ទទួលនិមន្តន៍ ដោយតុណ្ហីភាព ។

[ ១៩៩ ] គ្រានោះ បិតារបស់ព្រះរដ្ឋបាលមានអាយុ ដឹងច្បាស់ថា ព្រះរដ្ឋបាលមានអាយុ ទទួលនិមន្តន៍ហើយ ក៏ចូលទៅកាន់លំនៅរបស់ខ្លួនដែលធ្លាប់នៅ លុះចូលទៅដល់ហើយ ប្រើមនុស្សឲ្យលញ់ដីដោយអាចម៍គោស្រស់ រួចឲ្យគរគំនរប្រាក់និងមាសធំៗ ធ្វើឲ្យជាពីរគំនរគឺ ប្រាក់មួយគំនរ មាសមួយ

គំនរ ជាគំនរធំៗ ។ បុរសដែលឈរខាងអាយ មើលទៅបុរសឈរខាងនាយ មិនឃើញ បុរសដែលឈរខាងនាយ មើលមកបុរសឈរខាងអាយក៏មិនឃើញដូចគ្នា ហើយឲ្យបិទបាំងគំនរទាំង ២ នោះដោយកន្ទេល ឲ្យក្រាលអាសនៈទុកត្រង់កណ្តាល រួចឲ្យព័ទ្ធពន្ធដោយរបស់ដែលត្រូវធ្វើពីខាងក្រៅ ហើយហៅពួកស្រីជាគូពីមុន របស់ព្រះរដ្ឋបាលមានអាយុមក បង្គាប់ថា នែកូនស្រី ឯងរាល់គ្នាចូលមកនេះ គ្រឿងប្រដាប់ណាដែលឯងរាល់គ្នាស្អិតស្អាងហើយ ជាទីស្រឡាញ់ពេញចិត្ត របស់រដ្ឋបាលកូន ក្នុងកាលពីដើម ត្រូវឯងរាល់គ្នាស្អិតស្អាងគ្រឿងប្រដាប់នោះចុះ ។ លំដាប់តទៅ លុះកន្លងរាត្រីនោះទៅ បិតារបស់ព្រះរដ្ឋបាលមានអាយុ ឲ្យគេតាក់តែងនូវខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ក្នុងទីលំនៅរបស់ខ្លួនហើយ ប្រាប់នូវកាលដល់ព្រះរដ្ឋបាលមានអាយុថា រដ្ឋបាលកូន កាលគួរហើយ កត្តសម្រេចហើយ ។ ចំណែកខាងព្រះរដ្ឋបាលមានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យហើយនិមន្តចូលទៅត្រង់លំនៅរបស់បិតានៃខ្លួន លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ ទើបបិតារបស់ព្រះរដ្ឋបាលមានអាយុ ក៏ឲ្យបើកគំនរប្រាក់ និងមាសនោះ ហើយនិយាយនឹងព្រះរដ្ឋបាលមានអាយុយ៉ាងនេះថា នែរដ្ឋបាលកូន ទ្រព្យនេះជារបស់ខាងមាតាលោក ទ្រព្យជារបស់ខាងបិតាដោយឡែក នៅមានរបស់ខាងជីតាដោយឡែកទៀត រដ្ឋបាលកូន លោកអាចប្រើប្រាស់ភោគទាំងឡាយផង ធ្វើបុណ្យផង នែរដ្ឋបាលកូន ចូរលោកមក ចូរលាសិក្ខាវិលត្រឡប់មក

រកភេទទាប ហើយប្រើប្រាស់ភោគទាំងឡាយផង ធ្វើបុណ្យទាំងឡាយផងចុះ ។ បពិត្រគហបតី បើញោមធ្វើតាមពាក្យរបស់អាត្មា ញោមត្រូវប្រើមនុស្ស ឲ្យជញ្ជូនគំនរប្រាក់មាសនេះ ផ្ទុកក្នុងទេះហើយយកទៅចាក់ចោលក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហេតុអ្វីបានជាអាត្មាថាដូច្នោះគហបតី ព្រោះថាសេចក្តីសោក សេចក្តីខ្សឹកខ្សួល ទុក្ខទោមនស្ស និងសេចក្តីចង្អៀតចង្អល់មុខជានឹងកើតឡើងដល់ញោម ព្រោះតែទ្រព្យទាំងនោះជាហេតុ ។ ពេលនោះពួកស្រីជាគូពីមុន របស់ព្រះរដ្ឋបាលមានអាយុ នាំគ្នាឱបជើងម្ខាងម្នាក់ ហើយនិយាយនឹងព្រះរដ្ឋបាលមានអាយុយ៉ាងនេះថា បពិត្រអយ្យបុត្ត លោកប្រព្រឹត្តព្រហ្មចរិយធម៌ព្រោះហេតុ ( ចង់បាន ) ពួកស្រីអប្សរណា ពួកស្រីអប្សរទាំងនោះ តើល្អដូចម្តេចទៅ ។ ម្នាលនាង អាត្មាមិនមែនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុ ( ចង់បាន ) ពួកស្រីអប្សរទេ ។ ពួកស្រីជាគូពីមុនគិតថា រដ្ឋបាលជាអយ្យបុត្តហៅរកយើង ដោយពាក្យថានាងដូច្នេះ ក៏ជ្រប់ដួលត្រង់ទីនោះឯង ។ ទើបព្រះរដ្ឋបាលមានអាយុ និយាយនឹងបិតាថា បពិត្រគហបតី បើញោមត្រូវឲ្យភោជន ( ក៏ឲ្យមក ) កុំបៀតបៀនអាត្មាឡើយ ។ រដ្ឋបាលកូន សូមលោកនិមន្តឆាន់ចុះ ភត្តសម្រេចហើយ ។ គ្រានោះបិតារបស់ព្រះរដ្ឋបាលមានអាយុ បានចាត់ចែង ខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ឲ្យព្រះរដ្ឋបាលមានអាយុឆាន់ដោយដៃខ្លួនឯងគ្រាន់តែឆ្អែត ។

[ ២០០ ] លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ឆាន់រួចលាងដៃហើយ

ឈរសម្តែងគាថាទាំងឡាយនេះថា

ញោមចូរមើលនូវអត្តភាព ដែលសង្ខារធ្វើវិចិត្រហើយ ជាទីប្រជុំនៃដំបៅ ( ៩ អន្ទើ ) ផ្គុំឡើង ( ដោយឆ្អឹង ៣០០ កំណាត់ ) ក្តៅរោលរាល ដែលជនច្រើនគ្នាតែងត្រូវការ ជាកាយមិនទៀងទាត់ ឋិតថេរឡើយ ញោមចូរមើលរូប ដែលសង្ខារវិចិត្រហើយ ( ប្រកប ) ដោយកុណ្ឌល មណីដែលរួបរឹតហើយ ដោយឆ្អឹង និងស្បែក ល្អដោយសារតែសំពត់ ជើងទាំងឡាយវិចិត្រហើយដោយទឹកល័ក្ត មុខមាត់លាបហើយ ដោយគ្រឿងលម្អិត អាចឲ្យមនុស្សពាលវង្វេងបាន តែមិនអាចបំភាន់ដល់ អ្នកស្វែងរកត្រើយគឺព្រះនិព្វានបានឡើយ សក់ទាំងឡាយ ដែលវិចិត្រហើយ ឲ្យមានសណ្ឋានដូចជាក្រឡាចត្រង្គ ភ្នែកទាំងឡាយ លាបហើយដោយថ្នាំសម្រាប់បន្តក់ ល្មមឲ្យបុគ្គលពាលភាន់កាំងបាន តែមិនអាចបំភាន់ អ្នកស្វែងរកត្រើយបានឡើយ កាយស្អុយដែលបានប្រដាប់ហើយ ដូចជាបំពង់ថ្នាំដាក់ភ្នែកយ៉ាងថ្មីដ៏វិចិត្រ អាចបំភាន់បុគ្គលពាលបាន តែមិនអាចបំភាន់អ្នកស្វែងរកត្រើយបានឡើយ ព្រានម្រឹគដាក់នូវបង្កាត់ជាអន្ទាក់ តែម្រឹគមិនជាប់បង្កាត់ កាលបើព្រានអ្នកចងម្រឹគ កំពុងកន្ទក់កន្ទេញ អាត្មាបរិភោគបន្ទៃ

រួចហើយត្រឡប់ទៅវិញ ។

លំដាប់នោះ ព្រះរដ្ឋបាលមានអាយុ ឈរសម្តែងគាថាទាំងនេះហើយ ក៏និមន្ត ត្រង់ទៅឧទ្យានឈ្មោះមិគាចីរៈ របស់ព្រះបាទកោរព្យៈ លុះចូលទៅដល់ហើយ ក៏អង្គុយសម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។

[ ២០១ ] គ្រានោះ ព្រះរាជាកោរព្យៈ ត្រាស់ហៅឧយ្យានបាលឈ្មោះ មិគវៈថា ម្នាលមិគវៈ ឯងចូររៀបចំឧយ្យានភូមិ ឈ្មោះមិគាចីរៈ យើងនឹង ទៅមើលទីដ៏សប្បាយ ។ ឧយ្យានបាលឈ្មោះមិគវៈ ទទួលព្រះរាជឱង្ការ ព្រះបាទកោរព្យៈថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចហើយក៏ រៀបចំឧទ្យានមិគាចីរៈ បានឃើញព្រះរដ្ឋបាលមានអាយុ កំពុងគង់សម្រាក ក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម លុះឃើញហើយ ក៏ចូលទៅគាល់ព្រះ បាទកោរព្យៈ លុះចូលទៅដល់ហើយ ក្រាបទូលព្រះបាទកោរព្យៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ឧទ្យានមិគាចីរៈរបស់ព្រះអង្គស្អាតបាតហើយ ប៉ុន្តែក្នុង ទីនោះ មានកុលបុត្រឈ្មោះរដ្ឋបាលជាកូនរបស់ត្រកូលដ៏ប្រសើរ ក្នុងថុល្ល កោដ្ឋិតនិគមនេះឯង ដែលព្រះអង្គទ្រង់សរសើរដល់រឿយៗនោះ ( ឥឡូវ ) លោកគង់សម្រាកក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។ ព្រះបាទកោរព្យៈ ត្រាស់ថា ម្នាលមិគវៈសម្លាញ់ ណ្ហើយចុះ ដំណើរទៅលេងទីឧទ្យាយថ្ងៃនេះ ឥឡូវនេះ ចូរឈប់សិនចុះ ឥឡូវនេះ យើងនឹងទៅអង្គុយជិតព្រះរដ្ឋបាល ដ៏ ចម្រើននោះវិញ ។ ទើបព្រះបាទកោរព្យៈត្រាស់ថា ចូរអ្នកទាំងឡាយចំណាយ ខាទនីយភោជនីយាហារ ដែលបានតាំងតែងហើយទាំងអស់នោះចុះ ហើយ

ព្រះអង្គឲ្យទឹមយានដ៏ល្អៗ ឡើងកាន់យានល្អ បរចេញអំពីថុល្លកោដ្ឋិតនិគម ដោយយានល្អៗ ដោយអានុភាពនៃស្តេចជាធំ ដើម្បីទ្រង់ទតព្រះរដ្ឋបាលមានអាយុ ។ ទីដែលយានទៅបានត្រឹមណា ក៏ទ្រង់យាងទៅដោយយានត្រឹមនោះ ហើយទ្រង់ចុះអំពីយាន យាងដោយព្រះបាទទទេដោយបរិសទ្យអឹងកង ចូលសំដៅទៅរកព្រះរដ្ឋបាលមានអាយុ លុះចូលទៅដល់ហើយ ក៏ទ្រង់រាក់ទាក់ជាមួយនឹងព្រះរដ្ឋបាលមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យដែលគួររលឹកហើយ ទ្រង់ឈរក្នុងទីដ៏សមគួរ ។ លុះព្រះបាទកោរព្យៈទ្រង់ព្រះសណ្ឋិត ក្នុងទីដ៏សមគួរហើយ ទ្រង់មានព្រះឱង្ការនឹងព្រះរដ្ឋបាលមានអាយុយ៉ាងនេះថា ព្រះរដ្ឋបាលដ៏ចម្រើន និមន្តគង់លើកម្រាលផ្កានេះចុះ ។ ព្រះរដ្ឋបាលថ្វាយព្រះពរថា ណ្ហើយមហារាជ សូមព្រះអង្គទ្រង់គង់ចុះអាត្មាភាពអង្គុយលើអាសនៈជារបស់ខ្លួនហើយ ។ ព្រះបាទកោរព្យៈ ក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយហើយ ។

[ ២០២ ] លុះព្រះបាទកោរព្យៈ ទ្រង់គង់ស៊ប់ហើយ ក៏មានព្រះរាជឱង្ការ នេះនឹងព្រះរដ្ឋបាលមានអាយុថា បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីសាបសូន្យ ៤ យ៉ាងនេះ ដែលពួកមនុស្សខ្លះ ក្នុងលោកនេះជួបប្រទះហើយ តែងកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស សេចក្តីសាបសូន្យ ៤ យ៉ាងតើដូចម្តេច គឺសេចក្តីសាបសូន្យ ព្រោះជរា ១ សេចក្តីសាបសូន្យព្រោះព្យាធិ ១ សេចក្តីសាបសូន្យភោគៈ ១ សេចក្តីសាបសូន្យញាតិ ១ ។

[ ២០៣ ] បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យព្រោះជរា តើដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សពួកខ្លះក្នុងលោកនេះ ជាមនុស្សជរា ចម្រើនហើយដោយវ័យ មានអាយុច្រើន ដល់នូវសេចក្ដីថមថយដោយលំដាប់ ។ មនុស្សនោះពិចារណាឃើញច្បាស់ថា ឥឡូវនេះអាត្មាអញគ្រាំគ្រា ចម្រើនដោយវ័យចាស់មានអាយុច្រើន ដល់នូវសេចក្ដីថមថយដោយលំដាប់ អាត្មាអញមិនងាយនឹងធ្វើឲ្យបានភោគៈ ដែលមិនទាន់បានផង មិនអាចនឹងធ្វើភោគៈដែលរកបានហើយ ឲ្យចម្រើនឡើងផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះសេចក្ដីសាបសូន្យព្រោះជរានោះហើយ ទើបបានកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថា សេចក្ដីសាប-សូន្យព្រោះជរា ។ ដូចយ៉ាងព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវនេះ នៅក្មេងកម្លោះមានសក់ខ្មៅរលើប កំពុងប្រកបដោយវ័យដ៏ចម្រើន ដែលជាបឋមវ័យ ព្រះរដ្ឋបាលដ៏ចម្រើន មិនឈ្មោះថាមានសេចក្ដីសាបសូន្យព្រោះ ជរានោះទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន ដឹងហើយ ឃើញហើយ ឬឮអ្វីហើយ បានជាចេញចាកផ្ទះទៅបួស ។

[ ២០៤ ] បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យព្រោះព្យាធិ តើដូចម្ដេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ ជាអ្នកមានអាពាធ ដល់នូវសេចក្ដីទុក្ខឈឺធ្ងន់ ។ មនុស្សនោះពិចារណាឃើញច្បាស់

ថា ឥឡូវនេះ អាត្មាអញមានអាពាធ ដល់នូវសេចក្តីទុក្ខឈឺធ្ងន់ថែមទាំងអាត្មាអញមិនងាយនឹងធ្វើភោគៈ ដែលមិនទាន់បានឲ្យបានផង មិនអាចនឹងធ្វើភោគៈដែលបានហើយ ឲ្យបានចម្រើនឡើងផង បើដូច្នោះគួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅបួស ។ មនុស្សនោះ ជួបប្រទះសេចក្តីសាបសូន្យ ព្រោះព្យាធិនោះហើយក៏កោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថាសេចក្តីសាបសូន្យព្រោះព្យាធិ ។ ចំណែកខាងព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវនេះ គ្មានអាពាធ ឥតទុក្ខប្រកបដោយគហណីធាតុ គឺកម្មជតេជោធាតុ កំពុងឲ្យផលស្មើ គឺមិនត្រជាក់ពេក មិនក្តៅពេក ព្រះរដ្ឋបាលដ៏ចម្រើន មិនមានសេចក្តីសាបសូន្យព្រោះព្យាធិនោះទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន បានដឹង បានឃើញ ឬបានឮអ្វីហើយ បានជាចេញចាកផ្ទះទៅបួស ។

[ ២០៥ ] បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីសាបសូន្យភោគៈតើដូចម្តេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ ជាមនុស្សស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន តែភោគៈទាំងនោះ របស់អ្នកនោះ ក៏ដល់នូវការអស់រលីងទៅ ដោយលំដាប់ ។ អ្នកនោះពិចារណាឃើញថា អាត្មាអញធ្លាប់ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនមកអំពីមុនហើយ តែភោគៈទាំងនោះ របស់អាត្មាអញនោះ បានដល់នូវការអស់រលីងទៅ ដោយលំដាប់ហើយ ថែមទាំងអាត្មាអញមិនអាចនឹងធ្វើភោគៈដែល

មិនទាន់បាន ឲ្យបានដោយងាយឡើយផង មិនអាចនឹងធ្វើភោគៈដែលបាន ហើយ ឲ្យចម្រើនឡើងបានផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុក មាត់ពុកចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។ អ្នក នោះជួបប្រទះសេចក្តីសាបសូន្យភោគៈនោះហើយ ក៏កោរសក់ ពុកមាត់ ពុក ចង្ការ ស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាល ដ៏ចម្រើន នេះហៅថា សេចក្តីសាបសូន្យភោគៈ ។ ចំណែកព្រះរដ្ឋបាលដ៏ ចម្រើន ជាកូនអ្នកមានត្រកូលដ៏ប្រសើរ ក្នុងថុល្លកោដ្ឋិតនិគមនេះឯង ព្រះ រដ្ឋបាលដ៏ចម្រើន មិនឈ្មោះថា មានសេចក្តីសាបសូន្យភោគៈទេ ។ ព្រះ រដ្ឋបាលដ៏ចម្រើន ដឹងហើយ ឃើញហើយ ឬឮអ្វីហើយ បានជាចេញចាក ផ្ទះទៅបួស ។

[ ២០៦ ] បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីសាបសូន្យញាតិ តើ ដូចម្តេច បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មនុស្សខ្លះក្នុងលោកនេះ មានពួកមិត្ត អាមាត្យ ញាតិសាលោហិតច្រើន ជនជាញាតិទាំងនោះ របស់អ្នកនោះ ក៏ ដល់នូវសេចក្តីព្រាត់ប្រាសទៅដោយលំដាប់ ។ អ្នកនោះពិចារណាឃើញ ច្បាស់ថា ពីដើម អាត្មាអញមានពួកមិត្ត អាមាត្យ ញាតិសាលោហិតច្រើន តែពួកជនជាញាតិទាំងនោះរបស់អាត្មាអញនោះ ក៏ដល់នូវសេចក្តីព្រាត់ប្រាស ទៅដោយលំដាប់ ថែមទាំងអាត្មាអញមិនងាយនឹងធ្វើភោគៈ ដែលមិនទាន់ បានឲ្យបានផង មិនអាចនឹងធ្វើភោគៈ ដែលបានហើយ ឲ្យចម្រើនឡើងបាន ផង បើដូច្នោះ គួរតែអាត្មាអញកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្តប់

សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។ អ្នកនោះជួបប្រទះសេចក្ដីសាបសូន្យញាតិនោះ ក៏កោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស បពិត្រព្រះរដ្ឋបាលដ៏ចម្រើន នេះហៅថា សេចក្ដីសាបសូន្យញាតិ ។ ចំណែកព្រះរដ្ឋបាលដ៏ចម្រើន មានពួកមិត្តអាមាត្យ ញាតិសាលោហិតច្រើនក្នុងថុល្លកោដ្ឋិតនិគមនេះឯង ព្រះរដ្ឋបាលដ៏ចម្រើន មិនឈ្មោះថាមានសេចក្ដីសាបសូន្យញាតិទេ ។ ព្រះរដ្ឋបាលដ៏ចម្រើន ដឹងហើយ ឃើញហើយ ឬឮអ្វីហើយ បានជាចេញចាកផ្ទះទៅបួស។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីសាបសូន្យទាំង ៤ យ៉ាងនេះហើយ ជាហេតុឲ្យមនុស្សក្នុងលោកនេះ ដែលជួបប្រទះហើយតែងកោរសក់ ពុកមាត់ពុកចង្ការ ស្លៀកដណ្ដប់សំពត់កាសាយៈចេញចាកផ្ទះទៅបួស ។ ព្រះរដ្ឋបាលដ៏ចម្រើន មិនមានសេចក្ដីសាបសូន្យទាំងនោះទេ ។ ព្រះរដ្ឋបាលដ៏ចម្រើនដឹងហើយ ឃើញហើយ ឬឮអ្វីហើយ បានជាចេញចាកផ្ទះទៅបួស ។

[ ២០៧ ] ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហារាជ មានធម្មុទ្ទេស ៤ ប្រការ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្ដែងហើយ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮហើយផង ទើបចេញចាកផ្ទះទៅបួស ។ ធម្មុទ្ទេស ៤ យ៉ាង តើដូចម្ដេច ។ បពិត្រមហារាជ ធម្មុទ្ទេសទី ១ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្ដែងហើយថា សត្វលោកមិនទៀត តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) ដូច្នេះ

ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ២ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងឡើយ ដូច្នេះ ដែលអាត្មា ភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ៣ ព្រះមានបុណ្យព្រះអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួង ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស បពិត្រមហារាជ ធម្មុទ្ទេសទី ៤ ព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយថា សត្វលោកមានតែសេចក្តី ខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ដូច្នេះ ដែលអាត្មាភាពបានដឹងផង ឃើញផង ឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រមហារាជ ធម្មុទ្ទេសទាំង ៤ យ៉ាងនេះឯង ដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយ ជាធម៌ ដែលអាត្មាភាពបានដឹង បានឃើញ បានស្តាប់ ហើយចេញចាកផ្ទះចូលទៅ កាន់ផ្នួស ។

[ ២០៨ ] ព្រះបាទកោរព្យៈត្រាស់សួរថា ព្រះរដ្ឋបាលដ៏ចម្រើនសំដែងថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ។

ថ្វាយព្រះពរមហារាជ កាលដែលមហាបពិត្រ មានព្រះជន្មចូលក្នុងវ័យ ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរីផង ស្ទាត់ខាងវិជ្ជាសេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាជន្លជាវផង បរិបូណ៌ដោយកម្លាំងព្រះឧរូ ( ភ្លៅ ) បរិបូណ៌ដោយកម្លាំងព្រះពាហុ ( ដើមដៃ ) អង់អាចចុះសង្គ្រាមបាន តើព្រះអង្គសម្គាល់សេចក្តីក្នុងពេលនោះថាដូចម្តេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន កាលដែលខ្ញុំមានអាយុចូលក្នុងវ័យ ២០ ឆ្នាំផង គ្រប់ ២០ ឆ្នាំហើយផង បានស្ទាត់ខាងវិជ្ជាដំរីផង ស្ទាត់ខាងវិជ្ជា សេះផង ស្ទាត់ខាងវិជ្ជារថផង ស្ទាត់ខាងវិជ្ជាធ្នូផង ស្ទាត់ខាងវិជ្ជាជន្លជាវផង មានកម្លាំងភ្លៅ មានកម្លាំងដៃ អង់អាចចុះសង្គ្រាមបាន បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនណាខ្ញុំសម្គាល់ហាក់ដូចជាអ្នកមានឫទ្ធិ មិនសម្គាល់ឃើញអ្នកណាថា ស្មើដោយកម្លាំងរបស់ខ្លួនបាន ។ មហាបពិត្រព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ឥឡូវនេះ ព្រះអង្គបរិបូណ៌ដោយកម្លាំងព្រះឧរូ បរិបូណ៌ដោយកម្លាំងព្រះពាហុ អង់អាចចុះសង្គ្រាមបាន ដូចកាលពីដើមយ៉ាងនោះដែរឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុនោះមិនដូច្នោះទេ ឥឡូវនេះខ្ញុំជរាហើយ ចម្រើនដោយវ័យចាស់ មានអាយុច្រើន ដល់នូវសេចក្តីថមថយដោយលំដាប់ វ័យខ្ញុំដល់ ៨០ ឆ្នាំថ្វាយហើយ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនណាខ្ញុំគិតថា នឹងជាន់ត្រង់នេះ ខ្ញុំត្រឡប់ជាជាន់កន្លែងឯទៀតវិញ ។ បពិត្រមហារាជ ពាក្យថាសត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) នេះឯង ដែលព្រះមានព្រះភាគជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គ

នោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់សំដៅដល់ហេតុនោះដែលអាត្មាភាព បានដឹង បានឃើញ បានឮ ហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនដែលកើត ហោតែកើតបាន ពាក្យថា សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) ដែលព្រះមានព្រះភាគ ជាអរហន្ត សម្មាសម្ពុទ្ធព្រះអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ត្រាស់ហើយនេះ ប្រាកដជាទ្រង់សម្តែងត្រូវពិតហើយ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សត្វលោកមិនទៀង តែងត្រូវជរានាំចូលទៅ ( រកមរណៈ ) ពិតមែន បពិត្រព្រះរដ្ឋបាលដ៏ចម្រើន តែក្នុងរាជត្រកូលនេះ មានពួកពលដំរីផង ពួកពលសេះផង ពួកពលរថផង ពួកពលថ្មើរជើងផង ចាំការពារសេចក្តីអន្តរាយដល់ខ្ញុំដែរ ។

[ ២០៩ ] ព្រះរដ្ឋបាលដ៏ចម្រើនសម្តែងថា សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹង បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះតើត្រូវយល់ដោយប្រការដូចម្តេច ។ បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រះអង្គធ្លាប់មានអាពាធ ទាល់តែផ្ទំដាបលើទីបន្ទំខ្លះដែរឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំធ្លាប់មានអាពាធ ទាល់តែដាបនៅលើបន្ទំដែរ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ជួនណាពួកមិត្ត អាមាត្យ ញាតិសាលោហិត ឈរចោមរោមខ្ញុំនិយាយថា ព្រះបាទកោរព្យៈ ទ្រង់នឹងទិវង្គតឥឡូវនេះ ព្រះបាទកោរព្យៈ ទ្រង់នឹងទិវង្គតឥឡូវនេះ ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រះអង្គបានពួកមិត្តអាមាត្យ ញាតិសាលោហិត

ទាំងនោះ ដោយការអង្វរឲ្យជួយថា ពួកមិត្ត អាមាត្យ ញាតិសាលោហិតដ៏ចម្រើនរបស់អញចូរនាំគ្នាមក សូមឲ្យអ្នកទាំងអស់គ្នា រម្ងៃកយកវេទនានោះ ដែលជាហេតុ ឲ្យខ្ញុំសោយវេទនាបានស្រាលបន្តិចដូច្នេះដែរឬ ឬក៏ព្រះអង្គសោយវេទនាតែមួយព្រះអង្គឯងទេ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំមិនបានពួកមិត្ត អាមាត្យ ញាតិសាលោហិតទាំងនោះ ដោយសេចក្តីអង្វរថា សូមឲ្យអ្នកទាំងអស់គ្នា រម្ងៃកយកវេទនានេះ ដែលជាហេតុឲ្យខ្ញុំបានសោយវេទនាស្រាលបន្តិច ដូច្នេះទេ មានតែខ្ញុំត្រូវសោយវេទនានោះ តែឯងប៉ុណ្ណោះ ។ បពិត្រមហារាជ ត្រង់ពាក្យថា សត្វលោកឥតមានគ្រឿងការពារឥតទីពឹង នេះឯងដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮហើយ ចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនដែលកើត លោតែកើតបាន ពាក្យថា សត្វលោក មិនមានគ្រឿងការពារមិនមានទីពឹង ដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយនេះ ពេញទីជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះថាសត្វលោក មិនមានគ្រឿងការពារ មិនមានទីពឹងពិតមែន បពិត្រព្រះរដ្ឋបាលដ៏ចម្រើន តែក្នុងរាជត្រកូលនេះ មានមាសប្រាក់ច្រើន តាំងនៅលើផែនដីខ្លះ តាំងនៅលើផ្ទៃខ្លះដែរ ។

[ ២១០ ] ព្រះរដ្ឋបាលដ៏ចម្រើន សម្តែងថា សត្វលោកសុទ្ធតែមិនមាន

អ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងទៅ ដូច្នេះ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្តីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្តេច ។ បពិត្រព្រះរាជសម្ភារ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ។ ឥឡូវនេះ ព្រះអង្គបានឆ្អែតស្កប់ស្កល់គ្រប់សព្វ ឲ្យគេបម្រើដោយកាមគុណទាំង ៥ យ៉ាងណា តទៅលោកខាងមុខទៀត ព្រះអង្គនឹងបានដូចបំណងថា អាត្មាអញគង់បានឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ នេះឯងយ៉ាងនោះទៀតដែរឬ ឬក៏ពួកជនដទៃនឹងគ្រប់គ្រងភោគសម្បត្តិនេះ ( ជំនួស ) ចំណែកព្រះអង្គ នឹងទ្រង់ស្តេចទៅតាមយថាកម្ម ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ឥឡូវខ្ញុំបានឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ យ៉ាងណា ដល់ទៅខាងមុខ ខ្ញុំនឹងមិនបានដូចបំណងថា ខ្ញុំគង់បានឆ្អែតស្កប់ស្កល់សព្វគ្រប់ ឲ្យគេបម្រើដោយកាមគុណទាំង ៥ នេះឯង យ៉ាងនោះទៀតទេ តាមពិត ពួកជនដទៃ គ្រប់គ្រងភោគសម្បត្តិ ( ជំនួស ) ចំណែកខាងខ្ញុំនឹងទៅតាមយថាកម្ម ។ បពិត្រមហារាជ ត្រង់ពាក្យថា សត្វលោកសុទ្ធតែគ្មានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងអស់ នេះឯងដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹងផង បានឃើញផង បានឮផង ហើយចេញចាកផ្ទះទៅបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ហេតុដែលមិនដែលកើត លោតែកើតបាន ពាក្យថា សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួនត្រូវ

តែងលះបង់របស់ទាំងពួងទៅ ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយនេះ ពេញ ទីជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះថា សត្វលោកសុទ្ធតែ មិនមានអ្វីជារបស់ខ្លួនត្រូវតែលះបង់របស់ទាំងពួងទៅមែន ។

[ ២១១ ] ព្រះរដ្ឋបាលដ៏ចម្រើន សំដែងថា សត្វលោកសុទ្ធតែមាន សេចក្ដីខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា បពិត្រព្រះរដ្ឋបាលដ៏ចម្រើន សេចក្ដីនៃភាសិតនេះ តើត្រូវយល់ដោយប្រការដូចម្ដេច ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះថាដូចម្ដេច ព្រះអង្គគ្រប់គ្រងដែនកុរុ ដែលជា ដែនស្ដុកស្ដម្ភហើយឬ ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំគ្រប់គ្រងដែនកុរុ ដែលជាដែនស្ដុកស្ដម្ភមែន ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះ ដូចម្ដេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរទទួលស្ដាប់ ពាក្យបាន មកអំពីទិសខាងកើត ។ បុរសនោះចូលមកគាល់ព្រះអង្គ ហើយ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូម ព្រះអង្គជ្រាប ខ្ញុំព្រះអង្គទើបនឹងមកអំពីទិសខាងកើត បានឃើញជនបទ ធំ ក្នុងទិសនោះ ជាជនបទមាំមួន ស្ដុកស្ដម្ភ មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះមានពួកពលដំរី ពលសេះ ពលរថ និងពលស្មើជើងជា ច្រើន ក្នុងជនបទនោះ មានភ្លុកនិងស្បែកជាច្រើន ក្នុងជនបទនោះ មានមាស ប្រាក់ដែលគេមិនទាន់ធ្វើខ្លះ ធ្វើរួចហើយខ្លះជាច្រើន ក្នុងជនបទនោះមាន បរិវារស្ត្រីជាច្រើន ព្រះអង្គអាចនឹងច្បាំងយកបាន ដោយកម្លាំងពលត្រឹម

ប៉ុណ្ណោះ បពិត្រមហារាជ សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះដូចម្តេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះ មកគ្រប់គ្រងឲ្យបាន ។ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច បុរសរបស់ព្រះអង្គក្នុងទីនេះ ដែលគួរជឿពាក្យ គួរស្តាប់ពាក្យបាន មកអំពីទិសខាងលិច... អំពីទិសខាងជើង... អំពីទិសខាងត្បូង... អំពីប្រទេសខាងនាយសមុទ្រ ។ បុរសនោះ ចូលមកគាល់ព្រះអង្គហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ជ្រាប ខ្ញុំព្រះអង្គទើបនឹងមក អំពីប្រទេសខាងនាយសមុទ្រ បានឃើញជនបទធំនៅក្បែរសមុទ្រនោះ ជាជនបទស្តុកស្តម្ភមាំមួន មានជនច្រើន មានមនុស្សកុះករ ក្នុងជនបទនោះមានពលដំរី ពលសេះ ពលរថ និងពលថ្មើរជើងច្រើន ក្នុងជនបទនោះ មានភ្លុក និងស្បែកច្រើន ក្នុងជនបទនោះ មានមាសប្រាក់ដែលគេរចនាហើយខ្លះ មិនទាន់រចនាខ្លះជាច្រើន ក្នុងជនបទនោះ មានបរិវារស្ត្រីច្រើន ព្រះអង្គអាចច្បាំងយក ដោយពលត្រឹមប៉ុណ្ណោះ បពិត្រមហារាជ សូមព្រះអង្គច្បាំងយក តើព្រះអង្គនឹងធ្វើជនបទនោះ ដូចម្តេច ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ខ្ញុំត្រូវតែច្បាំងដណ្តើមយកជនបទនោះគ្រប់គ្រងឲ្យបាន ។ ព្រះរដ្ឋបាលថ្វាយព្រះពរថា បពិត្រមហារាជ ពាក្យថាសត្វលោកសុទ្ធតែខ្វះខាត មិនចេះឆ្អែត ជាខ្ញុំនៃតណ្ហា នេះឯងដែលព្រះមានជោគ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ទ្រង់ត្រាស់សំដៅយកហេតុនោះ ដែលអាត្មាភាពបានដឹង បានឃើញ បានឮ

ហើយចេញចាកផ្ទះមកបួស ។ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះរដ្ឋបាលដ៏ចម្រើន មិនដែលមានឡើយ ពាក្យដែលថា សត្វលោក សុទ្ធតែមានសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំនៃតណ្ហា ដែលព្រះមានបុណ្យ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយនេះ ពេញទីជាសុភាសិត បពិត្រព្រះរដ្ឋបាលដ៏ចម្រើន ព្រោះ ថាសត្វលោក សុទ្ធតែមានសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំនៃតណ្ហាមែន ។

[ ២១២ ] ព្រះរដ្ឋបាលមានអាយុ បានសំដែងធម្មុទ្ទេសនេះ លុះសំដែងធម្មុទ្ទេសនេះរួចហើយ ទើបបានសំដែងគាថាព័ន្ធនេះតទៅទៀតថា

អាត្មាភាពឃើញពួកមនុស្សអ្នកមានទ្រព្យក្នុងលោក បានទ្រព្យ គាប់ចិត្តហើយ មិនឲ្យ ( ទាន ) ព្រោះតែសេចក្តីវង្វេង រមែងធ្វើនូវការសន្សំ ព្រោះជាប់ជំពាក់នឹងទ្រព្យ រឹងរឹតតែ ប្រាថ្នានូវកាមទាំងឡាយ ឲ្យក្រៃលែងទៅទៀត ព្រះរាជាប្រាប ប្រាម ឈ្នះមនុស្សលើផែនដី ហើយគ្រប់គ្រងសម្បត្តិលើ ផែនដី មានសមុទ្ទជាទីបំផុត នៅតែមិនស្កប់នឹងប្រទេសខាង អាយសមុទ្ទ តែងប្រាថ្នានូវប្រទេសខាងនាយសមុទ្ទទៀត ព្រះ រាជាក្តី មនុស្សទាំងឡាយដទៃច្រើនក្តី តែមិនទាន់អស់តណ្ហា ហើយ រមែងចូលទៅកាន់សេចក្តីស្លាប់ មានសភាពជាអ្នក មានសេចក្តីខ្វះខាត តែងមិនលះបង់នូវរាងកាយឡើយឈ្មោះ

ថាសេចក្ដីឆ្អែតឆ្អន់ដោយកាមទាំងឡាយ រមែងមិនមានក្នុងលោកជាដាច់ខាតពួកញាតិរំសាយសក់ទាំងឡាយ ហើយកន្ទក់កន្ទេញទីងអ្នកស្លាប់ នោះថា ឱហ្ន៎ ញាតិយើងស្លាប់ហើយ យកបុគ្គលស្លាប់នោះ ដែលរុំដោយសំពត់ នាំទៅដល់ជើងថ្ករហើយដុតក្នុងទីនោះ បុគ្គលស្លាប់នោះ លះបង់ភោគៈទាំងឡាយ នៅតែសំពត់មួយ ត្រូវគេចាក់ដោយឈើស្នូល ត្រូវភ្លើងឆេះ គ្រឿងការពារទាំងឡាយ រមែងមិនមានដល់បុគ្គលស្លាប់ទេ មានតែពួកញាតិមិត្ត ឬពួកសម្លាញ់ជាទាយាទ នាំយកទ្រព្យរបស់បុគ្គលស្លាប់នោះទៅ ចំណែកសត្វក៏ទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួចរមែងមិនទៅតាមបុគ្គលស្លាប់ឡើយ ពួកកូនប្រពន្ធ ទ្រព្យនិងដែន ក៏មិនជាប់តាមទៅទេ បុគ្គលមិនបានអាយុវែង ព្រោះទ្រព្យទេ ទាំងមិនមែនលះបង់ជរាបានព្រោះទ្រព្យដែរ អ្នកប្រាជ្ញពោលថា ជីវិតនេះតិចពេកណាស់ មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា ពួកអ្នកស្តុកស្តម្ភ អ្នកកំសត់ក្តី តែងពាល់ត្រូវនូវសម្ផស្សស្លាប់ ទាំងពាលទាំងប្រាជ្ញ ក៏ពាល់ត្រូវដូច្នោះដែរ តែថា មនុស្សពាល រមែងដេកទាំងតក់ស្លុត ព្រោះសេចក្ដីល្ងង់ ចំណែកអ្នកប្រាជ្ញ បើទុកជាពាល់ត្រូវសម្ផស្សស្លាប់ក៏មិនញាប់ញ័រឡើយ ព្រោះហេតុនោះ បុគ្គលបានដល់អរហត្តផលជាទីបំផុតកិច្ច ក្នុងលោកនេះដោយបញ្ញាណា

បញ្ញានោះប្រសើរវិសេសជាងទ្រព្យ ព្រោះតែខ្លួនមិនទាន់ដល់កិច្ចជាទីបំផុត ពួកជនរមែងធ្វើអំពើអាក្រក់ក្នុងភពតូច និងភពធំទាំងឡាយ ព្រោះតែសេចក្តីវង្វេង បុគ្គលរមែងចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ព្រោះដល់នូវការអន្ទោលទៅតៗ គ្នា បុគ្គលអប្បប្រាជ្ញា ជឿបុគ្គលនោះ ក៏ចូលទៅកាន់គភ៌ផង កាន់លោកខាងមុខផង ចោរកាន់ធម៌អាក្រក់ដែលគេចាប់បាន ត្រង់កន្លែងទីត ត្រូវគេបៀតបៀនព្រោះកម្មរបស់ខ្លួន យ៉ាងណា ពួកសត្វកាន់ធម៌អាក្រក់ លះលោកនេះទៅហើយ រមែងក្តៅក្រហាយ ព្រោះកម្មរបស់ខ្លួន ក្នុងលោកខាងមុខ យ៉ាងនោះដែរ ព្រោះតែកាមទាំងឡាយដ៏វិចិត្រ មានរសឆ្ងាញ់ នឹងជាទីរីករាយដល់ចិត្ត តែងញាំញីនូវចិត្ត ដោយសភាវៈផ្សេងៗ បពិត្រមហារាជ ព្រោះហេតុនោះ អាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយ ហើយបានជាបួស មនុស្សទាំងឡាយទាំងក្មេងទាំងចាស់ លុះបែកធ្លាយសរីរៈហើយ រមែងជ្រុះចុះ ដូចជាផ្លែឈើទាំងឡាយ បពិត្រមហារាជ អាត្មាភាពបានយល់ច្បាស់ នូវហេតុនេះថា សមណភាពជាការប្រតិបត្តិមិនខុស ប្រសើរជាទីបំផុត ដូច្នេះបានជាបួស ។

ចប់ រដ្ឋបាលសូត្រទី ២

# អដ្ឋកថា

## វដ្ដបាលសូត្រ

[ ១៨៤ ] វដ្ដបាលសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងវដ្ដបាលសូត្រនោះដូតទៅនេះ បទថា **ថុល្លកោដ្ឋិតំ** បានដល់ ជង្រុកស្រូវ គឺពេញជង្រុក ។ បានឮថា ជនបទនោះមានសន្ទូង ជានិច្ច គឺគ្រាប់ស្រូវចេញចូលលានគ្រប់កាល ។ ដោយហេតុនោះ ទើបក្នុង និគមនោះ ជង្រុកទាំងឡាយពេញជានិច្ច ព្រោះដូច្នោះ ទើបជនបទនោះរាប់ បានថា ថុល្លកោដ្ឋិតៈ ប្រែថា មានស្រូវពេញជង្រុកនោះឯង ។ សួរថា ហេតុអ្វី ទើបព្រះវដ្ដបាល ឈ្មោះថា វដ្ដបាល ឆ្លើយថា ដែលឈ្មោះថា វដ្ដបាល ព្រោះជាអ្នកអាចថែរក្សារដ្ឋដែលបែងចែកបាន ។ សួរថា ឈ្មោះ របស់វដ្ដបាលកើតពីពេលណា ឆ្លើយថា កាលព្រះសម្មាសម្ពុទ្ធព្រះបទុមុត្តរៈ ។

ពិតហើយ នៅខាងចុងមួយសែនកប្បបន្ទាប់អំពីកប្បនេះ មនុស្សមានអាយុ មួយសែនឆ្នាំ ព្រះសាស្ដាព្រះនាមថា បទុមុត្តរៈកើតឡើង មានភិក្ខុមួយសែន រូបជាបរិវារ ទ្រង់យាងចារិកដើម្បីប្រោសសត្វលោក ដូចលោកពោល ទុកថា

ព្រះសាស្ដាព្រះនាមថាបទុមុត្តរៈ មានព្រះជនកព្រះនាមថាព្រះបាទអានន្ទ ព្រះជននីព្រះនាមថាព្រះនាងសុជាតា ក្នុងនគរហង្សវតី ដូច្នេះ ។

កាលនោះ ព្រះបទុមុត្តរៈទ្រង់មិនទាន់កើតឡើង ។ កុដុម្ពិកៈ ២ នាក់ក្នុង ក្រុងហង្សវតី មានសទ្ធាជ្រះថ្លា តាំងរោងទានសម្រាប់ជនក្រីក្រ អ្នកដើរផ្លូវ និងស្មូមយាចកជាដើម ។ កាលនោះ តាបស ៥០០ នាក់ដែលនៅក្នុងភ្នំ មកដល់ក្រុងហង្សវតី ។ ជនទាំង ២ នោះ ក៏ចែកតាបសគ្នាម្នាក់ពាក់កណ្ដាល

ដើម្បីទំនុកបម្រុង ។ តាបសទាំងឡាយនៅបានមួយរយៈ ក៏ត្រឡប់ទៅកាន់ភ្នំវិញ ។ តាបសជាថេរៈទាំងឡាយ ក៏បែកខ្ញែកគ្នាទៅ ។ គ្រានោះ កុដុម្ពិកៈទាំង ២ នោះ ធ្វើការទំនុកបម្រុងតាបសទាំងនោះរហូតអស់ជីវិត ។ កាលពួកតាបសបរិភោគហើយអនុមោទនា មួយរូបពោលពណ៌នាគុណរបស់កពសក្កទេវរាជ ។ មួយរូបពណ៌នាគុណរបស់នាគរាជម្ចាស់ផែនដី ។ បណ្ដាកុដុម្ពិកៈទាំង ២ ម្នាក់ប្រាថ្នាកពសក្កទេវរាជ ក៏ទៅកើតជាសក្កទេវរាជ ។ ម្នាក់ទៀតប្រាថ្នានាគពិភព ក៏កើតជានាគរាជ ឈ្មោះបាលិតៈ សក្កទេវរាជឃើញនាគនោះមកកាន់ទីបម្រើនៃខ្លួន ទើបសួរថា អ្នកនៅត្រេកអរក្រៃលែងក្នុងកំណើតនាគឬ ។ បាលិតនាគរាជនោះឆ្លើយថា មិនត្រេកអរទេ ។ សក្កទេវរាជប្រាប់ថា បើដូច្នោះ ចូរអ្នកឲ្យទានដល់ព្រះមានព្រះភាគបទុមុត្តរៈចុះ ហើយធ្វើសេចក្ដីប្រាថ្នាមកកើតក្នុងទីនេះ យើងទាំងពីរនឹងនៅជាសុខ ។ នាគរាជ និមន្តព្រះសាស្ដាថ្វាយមហាទាន ៧ ថ្ងៃ ដែលមានភិក្ខុមួយសែនរូបជាបរិវារ ឃើញសាមណេរឱរសនៃព្រះបទុមុត្តរទសពល ឈ្មោះឧបរេវតៈ ថ្ងៃទី ៧ ថ្វាយសំពត់ទិព្វដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទើបប្រាថ្នាតំណែងរបស់សាមណេរ ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអនាគតកាល ទ្រង់ឃើញថា នាគនោះនឹងបានជារាហុលកុមារឱរសរបស់ព្រះពុទ្ធឈ្មោះថាគោតមក្នុងអនាគតកាល ទើបត្រាស់ថា ការប្រាថ្នារបស់អ្នកនឹងសម្រេច ។ នាគរាជក៏ប្រាប់សេចក្ដីនោះដល់សក្កទេវរាជ ។ សក្កទេវរាជក៏ថ្វាយទាន ៧ ថ្ងៃយ៉ាងនោះដូចគ្នា ឃើញកុលបុត្រឈ្មោះរដ្ឋបាលដែលជាអ្នករក្សារដ្ឋដែលបែងចែក

គ្នា ហើយបួសដោយសទ្ធា ទើបតាំងសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល បើព្រះពុទ្ធអង្គនោះកើតឡើងក្នុងលោក ខ្ញុំព្រះអង្គសូមកើតក្នុងត្រកូលដែលអាចរក្សារដ្ឋដែលបែងចែកគ្នា គប្បីមានឈ្មោះថា រដ្ឋបាល ដែលបួសដោយសទ្ធាដូចកុលបុត្រនេះ ។ ព្រះសាស្តាទ្រង់ជ្រាបថា ការប្រាថ្នាសម្រេច ទើបត្រាស់ព្រះគាថានេះថា

ត្រកូលណា ឈ្មោះរដ្ឋបាល នឹងមានដើម្បីចិញ្ចឹមមនុស្ស
ក្នុងវណ្ណៈទាំង ៤ ព្រមទាំងព្រះរាជា កុលបុត្រនេះ នឹងកើត
ក្នុងត្រកូលនោះ ។

គប្បីជ្រាបថា ឈ្មោះនេះរបស់ព្រះរដ្ឋបាលនោះ កើតឡើងក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមថា បទុមុត្តរៈ ដោយប្រការដូច្នេះ ។

[ ១៨៦ ] បទថា **យថាយថាហំ** សេចក្តីថា ការគិតណាមួយថា **យថា យថា ខោ** ជាដើម មានហើយ ។ សេចក្តីសង្ខេបក្នុងពាក្យនោះមានដូច្នេះថា ខ្ញុំនេះឯងដឹងទូទៅដល់ធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយហេតុណាមួយ ឈ្មោះថា ខ្ញុំពិចារណាហើយ ដោយហេតុនោះ យ៉ាងនេះថា ព្រហ្មចរិយៈ គឺសិក្ខា ៣ នោះខ្ញុំគប្បីប្រព្រឹត្តឲ្យបរិបូណ៌ដោយចំណែកមួយ ព្រោះធ្វើមិនឲ្យដាច់ សូម្បីមួយថ្ងៃឲ្យដល់ចរិមកចិត្ត នឹងគប្បីប្រព្រឹត្តឲ្យបរិសុទ្ធដោយចំណែកមួយ ដូចស័ង្ខដែលដុសហើយ ដូចស័ង្ខដែលខាត់ហើយ បានដល់ ប្រៀបធៀបជាមួយស័ង្ខដែលជម្រះហើយ ព្រោះធ្វើមិនឲ្យមានមន្ទិល ដោយមន្ទិល គឺកិលេស ក្នុងមួយថ្ងៃ ហើយឲ្យដល់ចរិមកចិត្ត ។

បទថា **ឥទំ ន សុករំ អគារំ អជ្ឈាវសតា** សេចក្តីថា ព្រហ្មចរិយៈនោះ ដែលបុគ្គលនៅគ្រប់គ្រងផ្ទះ ប្រព្រឹត្តឲ្យបរិបូណ៌ដោយចំណែកមួយ ។បេ។ មិនធ្វើបានងាយឡើយ បើដូច្នោះ អញគប្បីកោរសក់ និងពុកមាត់ ពុកសង្កា ដណ្តប់សំពត់ដែលសមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយៈ ដែលឈ្មោះថាកាសាយៈ ព្រោះជ្រលក់ដោយទឹកម្ចត់ ចេញអំពីផ្ទះ បួសមិនមានផ្ទះ ។

បទថា **អចិរប្បក្កន្តេសុ ចុល្លកោដ្ឋិតកេសុ ព្រាហ្មណគហបតិកេសុ យេន ភគវា តេនុបសង្កមិ** សេចក្តីថា ក្នុងកាលព្រាហ្មណ៍ និងគហបតីទាំងនោះ មិនទាន់ក្រោកទៅ រដ្ឋបាលកុលបុត្រក៏មិនទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ ព្រោះហេតុអ្វី ព្រោះញាតិសាលោហិត មិត្តទាំងឡាយរបស់គាត់ក្នុងទីនោះជាច្រើន ក៏នឹងហួងហែង ជនទាំងនោះនឹងពោលថា អ្នកជាកូនតែមួយរបស់មាតាបិតា អ្នកមិនគួរបួស ហើយក៏ចាប់ត្រង់ដើមដៃទាញមក បន្ទាប់អំពីនោះ បព្វជ្ជានឹងអន្តរាយ ។ រដ្ឋបាល ក្រោកឡើងដើរទៅ ជាមួយបរិស័ទបានបន្តិច ហើយក៏ត្រឡប់ធ្វើលេសថា មានកិច្ចដោយសរីរៈណាមួយ ហើយចូលគាល់ព្រះមានព្រះភាគ ទូលសូមបព្វជ្ជា ដោយហេតុនោះ ទើបលោកពោលថា **អថខោ រដ្ឋបាលោ កុលបុត្តោ អចិរប្បកន្តេសុ ចុល្លកោដ្ឋិតកេសុ ។បេ។ បព្វជ្ជំ លភេយ្យំ ឧបសម្បទំ** ដូច្នេះ ។ ព្រោះចាប់តាំងអំពីពហុលកុមារបួសហើយ ព្រះមានព្រះភាគ ទ្រង់មិនបំបួសកូនដែលឪពុកម្តាយមិនអនុញ្ញាត ដូច្នោះ ទើបត្រាស់សួរថា **អនុញ្ញាតោសិ បន ត្វំ រដ្ឋបាល មាតាបិតូហិ ។បេ។ បព្វជ្ជាយ** ។

[ ១៨៧ ] ក្នុងបទថា **អម្ម តាត** នេះ រដ្ឋបាល ហៅម្តាយថា **អម្ម** ហៅឪពុកថា **តាត** ។

[ ១៨៨ ] បទថា **ឯកបុត្តោ** កូនជាកូនតែមួយប៉ុណ្ណោះ កូនណាមួយដទៃ ទោះជាបង ឬប្អូនមិនមាន ។ ក្នុងពាក្យនេះ កាលគួរនឹងពោលថា **ឯកបុត្តោ** ក៏ពោលថា **ឯកបុត្តកោ** ដោយអំណាច ការអាណិត ។ បទថា **បិយោ** ប្រែថា កើតបីតិ ។ បទថា **មនាបោ** ប្រែថា ជាទីត្រេកអរនៃចិត្ត ។ បទថា **សុខេ ឋិតោ** ប្រែថា តាំងនៅក្នុងសុខនោះឯង អធិប្បាយថា ចម្រើនសុខ ។ បទថា **សុខបរិហតោ** ប្រែថា បរិហារដោយសេចក្តីសុខ ។ តាំងអំពីកើតមក រដ្ឋបាលមានមេដោះដោយពមិនដាក់ដៃ លេងដោយគ្រឿងលេងរបស់ក្មេង មានរទេះសេះតូចៗ ជាដើម ឲ្យបរិភោគតែភោជនដែលមានរសល្អ ឈ្មោះថា បរិហារដោយសេចក្តីសុខ ។ បទថា **ន ត្វំ តាត រដ្ឋបាល កិញ្ចិ ទុក្ខស្ស ជានាសិ** សេចក្តីថា បារដ្ឋបាល បាមិនដឹង រឭកមិនបានដល់ចំណែកនៃសេចក្តីទុក្ខសូម្បីមានប្រមាណតិច ។ បទថា **មរណេនបិ តេ មយំ អកាមកា វិនា ភវិស្សាម** សេចក្តីថា បើកូនគប្បីស្លាប់សោតកាលពួកយើងនៅមានជីវិតសោត ព្រោះការស្លាប់របស់កូន ពួកយើងមិនត្រូវការ មិនប្រាថ្នា មិនពេញចិត្ត ចាំបាច់ពោលថ្វីដល់ការព្រាត់ប្រាស ឬនឹងដល់នូវសេចក្តីវិនាសអំពីកូនទៅ ។ បទថា **កឹ បន មយំ តំ** សេចក្តីថា កាលបើដូច្នោះ ហេតុដែលយើងនឹងអនុញ្ញាតឲ្យកូនរស់នៅចេញចាកផ្ទះទៅបួស ដូចម្តេចបាន ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងបទថា **កឹ បន មយំ តំ**

នេះ យ៉ាងនេះថា ដោយហេតុអ្វី ពួកយើងគប្បីអនុញ្ញាតឲ្យកូនដែលនៅមានជីវិត... ។

[ ១៨៩ ] បទថា **តត្ថេវ** សេចក្តីថា ក្នុងទីដែលមាតាបិតាមិនអនុញ្ញាត រដ្ឋបាលដួលចុះត្រង់ទីនោះឯង ។ បទថា **អនន្តរហិតាយ** សេចក្តីថា ព្រោះមិនត្រូវការ ដោយកម្រាលណាមួយ ។

[ ១៩០-១៩២ ] បទថា **បរិចារេហិ** សេចក្តីថា ទំនុកបម្រុងនូវតន្ត្រី របាំ និងអ្នកចម្រៀងជាដើម បម្រើខ្លួនតាមសេចក្តីសុខ មួយអន្លើដោយពួកសម្លាញ់ក្នុងទីនោះ អធិប្បាយថា នាំចូលទៅទីនោះទីនេះ ។ម្យ៉ាងទៀត បទថា **បរិចារេហិ** លោកអធិប្បាយថា ទំនុកបម្រុងតន្ត្រី អ្នករបាំ និងអ្នកចម្រៀងជាដើម សប្បាយត្រេកអរលេងជាមួយពួកសម្លាញ់ ។ បទថា **កាមេ បរិភុញ្ជន្តោ** សេចក្តីថា បរិភោគភោគៈព្រមជាមួយបុត្រកិរិយារបស់ខ្លួន ។ បទថា **បុញ្ញានិ ករោន្តោ** សេចក្តីថា ប្រារព្ធព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ធ្វើកុសលកម្ម ជម្រះផ្លូវទៅកាន់សុគតិ មានការថ្វាយទានជាដើម ។ បទថា **តុណ្ហី អហោសិ** បានដល់ មិនពោលប្រាស្រ័យដើម្បីកាត់ការពោលតទៅ ។ គ្រានោះ មាតាបិតាពោល ៣ ដង មិនបាននូវចម្លើយ ទើបឲ្យហៅសម្លាញ់មកពោលថា សម្លាញ់របស់អ្នកនោះចង់បួស ចូរជួយឃាត់ផងចុះ ។ សូម្បីសម្លាញ់ ទាំងនោះចូលទៅរកហើយ ពោល ៣ ដង ។ សម្រាប់សម្លាញ់ទាំងនោះ រដ្ឋបាលក៏នៅស្ងៀម ដោយហេតុនោះ ទើបលោកពោលថា **អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា ។បេ។ តុណ្ហី អហោសិ** ដូច្នេះ ។

គ្រានោះ ពួកសម្លាញ់របស់រដ្ឋបាលនោះ ក៏គិតយ៉ាងនេះថា បើសម្លាញ់នេះមិនបានបួស ក៏នឹងស្លាប់ អញក៏នឹងមិនបាននូវគុណណាមួយ តែបើគេបួសហើយ មាតាក្តី បិតាក្តី ក៏នឹងឃើញម្តងម្កាល សូម្បីអញក៏ឃើញ ធម្មតាបព្វជ្ជានេះ ជាការៈធ្ងន់ រដ្ឋបាលត្រូវកាន់បាត្រដើរទៅ ត្រាច់បិណ្ឌបាតរាល់ៗថ្ងៃ ព្រហ្មចរិយៈ មានការដេកម្តង ស៊ីម្តង ធ្ងន់ពន់ពេក ឯសម្លាញ់របស់អញនេះ ជាអ្នកក្រុង សុខុមាលជាតិ គេមិនអាចប្រព្រឹត្តព្រហ្មចរិយៈនោះបានឡើយ នឹងត្រូវមកក្នុង ទីនេះវិញដោយពិត ណ្ហើយចុះ យើងនឹងឲ្យមាតាបិតាគេអនុញ្ញាត ។ សម្លាញ់ទាំងនោះបានធ្វើយ៉ាងនោះ ។ សូម្បីមាតាបិតាធ្វើកតិកាសញ្ញានេះថា បើគេ បួសហើយ គប្បីឲ្យមាតាបិតាឃើញផង ទើបអនុញ្ញាត ។ ដោយហេតុនោះ ទើបលោកពោលថា **អថខោ រដ្ឋបាលស្ស កុលបុត្តស្ស សហាយកា យេន រដ្ឋបាលស្ស កុលបុត្តស្ស មាតាបិតរោ ។បេ។ អនុញ្ញាតោសិ មាតាបិតូហិ ។បេ។ ឧទ្ទស្សេតព្វា** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឧទ្ទស្សេតព្វា** សេចក្តីថា គប្បីមកបង្ហាញខ្លួនឲ្យមាតាបិតាបានឃើញម្តងម្កាល ។

[ ១៩៣ ] បទថា **ពលំ គហេត្វា** សេចក្តីថា បរិភោគភោជនដែលសប្បាយ បម្រុងរាងកាយ ដោយការដុស សម្អាតជាដើម មានកម្លាំងកាយហើយ សំពះមាតាបិតា លះត្រកូលញាតិ មានទឹកភ្នែកដោកមុខ ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គជាបុគ្គលដែលមាតាបិតាយល់ព្រមឲ្យចេញចាកផ្ទះមកបួសហើយ សូមព្រះមានព្រះភាគទ្រង់

បំបួសខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅ ភិក្ខុមួយរូបដែលឈរក្នុងទីជិត ប្រាប់ថា នែភិក្ខុ បើដូច្នោះ អ្នកចូរឲ្យរដ្ឋបាលបព្វជ្ជា និងឧបសម្បទាចុះ ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកាថា សាធុព្រះអង្គ បានឲ្យកុលបុត្រឈ្មោះរដ្ឋបាលដែលព្រះជិនស្រីប្រទានជាសទ្ធិវិហារិក ឲ្យបព្វជ្ជា និងឧបសម្បទា ។ ដោយហេតុនោះ ទើបលោកពោលថា **អលត្ថ ខោ រដ្ឋបាលោ កុលបុត្តោ ភគវតោ សន្តិកេ បព្វជ្ជំ អលត្ថ ឧបសម្បទំ** ដូច្នេះ ។

[ ១៩៤ ] បទថា **បព្វាជិតស្ស វិហារស្ស** សេចក្តីថា នៅយ៉ាងនេះអស់ ១២ ឆ្នាំ ។ ពិតហើយ ព្រះថេរៈអង្គនេះ ជានេយ្យបុគ្គល មានបុណ្យព្រមដោយបុណ្យចាស់ ក៏ត្រូវបំពេញសមណធម៌ដោយបំណងថា ជាព្រះអរហន្តក្នុងថ្ងៃនេះ ជាព្រះអរហន្តក្នុងថ្ងៃនេះ ឆ្នាំទី ១២ ទើបសម្រេចអរហត្ត ។ បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ព្រះថេរៈគិតថា ធម្មតាមាតាបិតារបស់អញ អនុញ្ញាតឲ្យបួស ពោលថា ចូរបាមកជួបពួកយើងម្តងម្កាលផង ហើយទើបអនុញ្ញាត ឯមាតាបិតាជាអ្នកធ្វើកិច្ចដែលធ្វើបានលំបាក អញបួសដោយអធ្យាស្រ័យយ៉ាងណា អធ្យាស្រ័យនោះដល់នូវទីបំផុតហើយ ដូច្នេះ អញនឹងទូលលាព្រះមានព្រះភាគ បង្ហាញខ្លួនដល់មាតាបិតា ហើយបំណងនឹងទូលលា ទើបចូលគាល់ ។

[ ១៩៥ ] បទថា **មនសាកាសិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ដាក់ព្រះទ័យថា កាលរដ្ឋបាលទៅហើយ នឹងមានឧបសគ្គណាមួយឬទេហ្ន៎ ។ ទ្រង់ជ្រាបថា នឹងមានពិត ទ្រង់ពិចារណាមើលថា រដ្ឋបាលនឹងអាចញាំញីឧបសគ្គ

នោះបានឬទេហ្ន៎ ទ្រង់ឃើញថា ព្រះរដ្ឋបាលនោះសម្រេចអរហត្ត ក៏ទ្រង់ជ្រាបថានឹងអាច ទើបទ្រង់អនុញ្ញាត ។ ដោយហេតុនោះ ទើបត្រាស់ថា **យស្ស ទានិ ត្វំ រដ្ឋបាល កាលំ មញ្ញសិ** ដូច្នេះ ។

[ ១៩៦ ] បទថា **មិគាចិរេ** បានដល់ ព្រះឧទ្យានមានឈ្មោះយ៉ាងនេះ ។ ព្រះរាជឧទ្យាននោះ ព្រះរាជាព្រះរាជទានដល់ពួកបព្វជិតដែលមកដល់ក្នុងកាលដែលមិនមែនជាវេលា គឺទ្រង់អនុញ្ញាតយ៉ាងនេះថា ចូរប្រើប្រាស់ឧទ្យាននេះតាមសប្បាយចុះ ។ ព្រោះដូច្នោះ ព្រះថេរៈមិនកើតសូម្បីតែគំនិតថា អញនឹងប្រាប់មាតាបិតាថា អញមកហើយ មាតាបិតានោះនឹងបញ្ជូនទឹកលាងជើង ប្រេងលាបជើងជាដើមដល់អញ ហើយចូលទៅកាន់ព្រះរាជ-ឧទ្យាននោះឯង ។ បទថា **បិណ្ឌាយ បាវិសិ** បានដល់ ចូលទៅបិណ្ឌបាតក្នុងថ្ងៃទី ២ ។ បទថា **មជ្ឈិមាយ** បានដល់ ខ្លោងទ្វារកណ្តាលនៃផ្ទះដែលមានខ្លោងទ្វារ ៧ ។ បទថា **ឧល្លិខាបេតិ** បានដល់ ឲ្យជាងកាត់សក់ ។ បទថា **ឯតទវោច** បានដល់បិតាគិតថា សមណៈទាំងនេះឲ្យកូនជាទីស្រឡាញ់តែមួយរបស់អញបួស អញមិនឃើញសូម្បីតែមួយថ្ងៃ ដូចប្រគល់ឲ្យក្នុងដៃចោរ សមណៈទាំងនេះធ្វើការគ្រោតគ្រាត គង់នឹងយល់ថា ទីនេះគួរនឹងចូលមកវិញ គួរនឹងទាញចេញទៅអំពីទីនេះ ទើបលោកពោលពាក្យថា **ឥមេហិ មុណ្ឌកេហិ** ដូច្នេះ ។

[ ១៩៧ ] បទថា **ញាតិទាសី** បានដល់ ទាសីរបស់ពួកញាតិ ។ បទថា **អាភិទោសិកំ** បានដល់ នំដែលរំលងរាត្រី គឺនំដែលកន្លងរាត្រីមួយ

ហើយ ជារបស់ផ្អូម ។ ក្នុងពាក្យនោះ មានសេចក្តីនៃបទដូច្នេះថា ឈ្មោះថា **អាភិទោស** ព្រោះត្រូវទោស គឺការផ្អូមគ្របសង្កត់ហើយ ។ **អភិទោស** នោះឯងក៏គឺ **អភិទោសិក** ។ នេះជាឈ្មោះរបស់ទំដែលកន្លងរាត្រីមួយទៅហើយ គឺទំដែលរំលងរាត្រីនោះ ។ បទថា **កុម្មាសំ** បានដល់ ទំដែលធ្វើដោយអង្ករដំណើប ។ បទថា **ឆឌ្ឌេតុកាមា ហោតិ** សេចក្តីថា ព្រោះហេតុដែលដោយហោចសូម្បីតែទាសៈក្តី កម្មករក្តី គោក្តី ក៏មិនគួរបរិភោគ ដូច្នោះ ទាសីក៏បំណង នឹងចោលទំនោះទៅខាងក្រៅដូចសំរាម ។ បទថា **សចេតំ** កាត់បទជា **សចេ ឯតំ** ។ ព្រះថេរៈហៅទាសីស្រីមេដោះរបស់ខ្លួននោះ ដោយអរិយវោហារថា **ភគិនិ** ។ បទថា **ឆឌ្ឌនីយធម្មំ** សេចក្តីថា មានការត្រូវចោលទៅជាធម្មតា ។ លោកអធិប្បាយទុកថា នែប្អូនស្រី បើវត្ថុនេះ មានការចោលទៅខាងក្រៅជាធម្មតា មិនហួងហែងទុកសោត ចូរនាងចាក់ក្នុងបាត្ររបស់អាត្មានេះចុះ ។

សួរថា ហេតុអ្វី ទើបព្រះថេរៈពោលយ៉ាងនេះ មិនជាវិញ្ញត្តិវាចា ឬបយុត្តវាចាទេឬ ឆ្លើយថា មិនដូច្នោះឡើយ ។ ព្រោះហេតុអ្វី ព្រោះទាសីលះនូវការហួងហែងហើយ ។ ពិតហើយ របស់ណាមាន ដែលនឹងត្រូវចោលទៅជាសការៈ គេលះបង់ការហួងហែងហើយ ម្ចាស់ទ្រព្យមិនហួងហែងក្នុងរបស់ណា គួរនឹងពោលថា ចូរនាំរបស់នោះមកឲ្យទាំងអស់ ចូរចាក់ចូលក្នុងបាត្រនេះ ។ ដោយហេតុនោះឯង ព្រះរដ្ឋបាលនេះ ជាអ្នកតាំងនៅក្នុងអរិយវង្សដ៏កំពូល ទើបពោលយ៉ាងនេះ ។ បទថា **ហត្ថានំ** បានដល់ ដៃទាំង ២

រាប់ តាំងអំពីកដៃរបស់ព្រះថេរៈ ដែលបង្អោនបាត្រដើម្បីទទួលអាហារ ។ បទថា **ចរណានំ** បានដល់ ជើងទាំង ២ តាំងអំពីជាយសំពត់ចុះទៅ ។ បទថា **សរស្ស** បានដល់ សំឡេងដែលបន្លឺវាចាថា នែប្អូនស្រី បើរបស់នោះ ... ជាដើម ។ បទថា **និមិត្តំ អគ្គហេសិ** សេចក្ដីថា ទាសី កាលពិចារណាមើលខ្នងដៃជាដើម ក៏នឹកឃើញចាំបាន កំណត់អាការដែលធ្លាប់កំណត់ក្នុងវេលាដែលជាគ្រហស្ថថា ខ្នងដៃ ខ្នងជើងទាំងនេះដូចគ្នានឹងខ្នងអណ្ដើកមាសម្រាមដៃដែលមូលល្អ ដូចគ្នានឹងរមូរហរតាល សំឡេងពីរោះដូចសំឡេងរបស់រដ្ឋបាលកូនរបស់អញ ។ កាលព្រះរដ្ឋបាលនោះនៅព្រៃអស់ ១២ ឆ្នាំ និងបរិភោគភោជន គឺពំនូតបាយ ពណ៌សម្បុររបស់រាងកាយ ទើបក្លាយជាបុគ្គលដទៃទៅ ។ ដោយហេតុនោះ ទាសីរបស់ញាតិឃើញព្រះថេរៈនោះទើបចាំមិនបាន តែចាំក្នុងនិមិត្ត ។ បទថា **រដ្ឋបាលស្ស មាតរំ ឯតទវោច** សេចក្ដីថា មេដោះដែលជាអ្នកធ្លាប់ថ្នាក់ថ្នមអវយវៈតូចធំរបស់ព្រះថេរៈ បានឲ្យបៅដោះ ចិញ្ចឹមមករហូតធំ ក៏មិនអាចនិយាយជាមួយបុត្រ ដែលបួសហើយ ដល់នូវភាពជាព្រះមហាខីណាស្រពជាដើមថា បពិត្រលោកម្ចាស់ លោកម្ចាស់ឬ គឺរដ្ឋបាលជាកូនរបស់ខ្ញុំ ទើបប្រញាប់ចូលទៅក្នុងផ្ទះ ពោលពាក្យនេះនឹងមាតា របស់រដ្ឋបាល ។ សព្ទថា **យគ្ឃេ** ជានិបាត ចុះក្នុងអត្ថថា ពោលរៀបរាប់ ។ សព្ទថា **ជេ** ក្នុងពាក្យថា **សចេ ជេ សច្ចំ** នេះ ជានិបាត ចុះក្នុងអត្ថថា ស្រែកហៅ ។ ពិតហើយ មនុស្សទាំងឡាយរមែងស្រែកហៅបុគ្គលដែលជាទាសៈ ទាសីក្នុងជនបទនោះ ។ ព្រោះហេតុនោះឯង

គប្បីឃើញអត្ថក្នុងបទនេះយ៉ាងនេះថា ទាសីដ៏ចម្រើន បើហាងនិយាយពិត ។ បទថា **ឧបសង្កមិ** សេចក្តីថា ហេតុអ្វីទើបចូលទៅ នាងគិតថា ស្ត្រីទាំងឡាយក្នុងត្រកូលធំ កាលចេញទៅខាងក្រៅ រមែងបានទទួលការនិន្ទា នេះជាកិច្ចប្រញាប់ អញនឹងប្រាប់កិច្ចនោះដល់សេដ្ឋី ព្រោះដូច្នោះ ទើបនាងចូលទៅ ។

[ ១៩៨ ] បទថា **អញ្ញតរំ កុឌ្ឌមូលំ** សេចក្តីថា បានឮថា ក្នុងទីនោះមានសាលាក្បែរផ្ទះរបស់ទានបតី ។ សាលានោះ គេរៀបអាសនៈទុក ទឹកនិងទឹកបាយ គេក៏តាំងទុកក្នុងសាលានោះ បព្វជិត ទាំងឡាយត្រាច់បិណ្ឌបាតហើយអង្គុយឆាន់ ។ បើបព្វជិតទាំងឡាយប្រាថ្នា ក៏នឹងកាន់យកទ្រព្យរបស់ទានបតីទាំងឡាយ ព្រោះដូច្នោះ ទីនោះក៏គប្បីជ្រាបថា ក្បែរជញ្ជាំងមួយកន្លែងនៃសាលានោះ របស់ត្រកូលមួយ ។ ពិតហើយ បព្វជិតទាំងឡាយមិនអង្គុយឆាន់ក្នុងទីដែលមិនសមគួរដូចមនុស្សអនាថាឡើយ ។ សព្ទថា **អត្ថិ** ក្នុងបទថា **អត្ថិ ឆាម តាត** នេះ ចុះក្នុងអត្ថថា មាន ។ សព្ទថា **ឆាម** ជានិបាត ចុះក្នុងអត្ថថា សួរ ឬសម្គាល់ ។ លោកអធិប្បាយថា បិតា គប្បីពោលថា បានឹងមកក្នុងទីនេះ បរិភោគនំដែលកន្លងរាត្រីរបស់យើងណា បារដ្ឋបាល ពួកយើងមានទ្រព្យហ្ន៎ មិនមែនមិនមានទ្រព្យឡើយ ។ បិតាគប្បីពោលថា ម្យ៉ាងទៀត បាគប្បីអង្គុយក្នុងទីយ៉ាងនេះ បរិភោគនំរំលងរាត្រីនៃពួកយើងណា ពួកយើងនោះនៅមានជីវិតហ្ន៎ មិនមែនជាអ្នកស្លាប់ទៅហើយទេ ។ ម្យ៉ាងទៀត បាសូម្បីត្រូវចិញ្ចឹមធំធាត់មកដោយរសភោជនដ៏ល្អ មិនមានវិការ នឹងបរិភោគនំរំលងរាត្រីដែលគួរខ្ពើមនេះ ដូចបរិភោគអមតៈភោជន

បារដ្ឋបាល សមណគុណជាគ្រឿងអាស្រ័យព្រះសាសនា ចុះស៊ប់ខាងក្នុងរបស់បា ប្រហែលជាមាន ។ គហបតីនោះមិនអាចពោលសេចក្ដីនេះឲ្យបរិបូណ៌បាន ព្រោះត្រូវទុក្ខចាក់ទម្លុះ ហើយពោលបានត្រឹមតែពាក្យប៉ុណ្ណោះថា នៃរដ្ឋបាលកូន មានដែរឬ លោកមកឆាន់នំកុម្មាសផ្អូមវិញ ។ ក្នុងសេចក្ដីនេះ អ្នកអក្ខរសាស្ត្រ ពោលលក្ខណៈនេះទុក ។ លោកធ្វើពាក្យអនាគតកាលថា **បរិភុញ្ជិស្សសិ** ជិតបទក្នុងសព្ទថា **អត្ថិ** នេះ ដោយអត្ថដែលមិនបរិបូណ៌តាមការកំណត់របស់ខ្លួន ។ ពាក្យនោះមានអត្ថដូច្នេះថា មានឬបារដ្ឋបាលដែលបាឆាន់នំកុម្មាសផ្អូម សូម្បីខ្ញុំឃើញក៏មិនជឿភ្នែកខ្លួនឯង និងអត់ធន់មិនបាន ។ គហបតី ឈរចាប់ត្រង់កណ្ដាប់មាត់បាត្ររបស់ព្រះថេរៈ ពោលនូវពាក្យមានប្រមាណប៉ុណ្ណោះ កាលបិតាឈរចាប់ត្រង់កណ្ដាប់មាត់បាត្រឯនោះឯង សូម្បីព្រះថេរៈ ក៏ឆាន់នំផ្អូមនោះ ដែលជះក្លិនផ្អូមក្នុងទីដែលបែក ដូចស៊ុតមាន់ស្អុយ ដូចគ្នានឹង កម្អួតឆ្កែ ។ បានឮថា បុថុជ្ជនមិនអាចបរិភោគនំដូច្នោះបាន ។ តែព្រះថេរៈ តាំងនៅក្នុងអរិយឫទ្ធិ ឆាន់ហាក់ដូចជាឆាន់អមតរសដ៏ជាទិព្វ ទទួលទឹកដោយធម្មក្រកលាងបាត្រ មាត់ និងដៃជើង ពោលពាក្យជាដើមថា **កុតោ នោ គហបតិ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កុតោ នោ** ប្រែថា អំពីទីណាហ្ន៎ ។ បទថា **នេវ ទានំ** សេចក្ដីថា មិនបានទានដោយទេយ្យធម៌ឡើយ ។ បទថា **ន បច្ចក្ខានំ** សេចក្ដីថា មិនបានសូម្បីតែពាក្យសាកសួរដោយបដិសណ្ឋារៈយ៉ាងនេះថា រដ្ឋបាលកូន កូនអត់ធន់បានដែរឬ មកដោយលំបាកតិចតួចដែរឬ កូនមិនឆាន់អាហារក្នុងផ្ទះមុនឬ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈពោលយ៉ាងនេះ ឆ្លើយថា ព្រោះអនុគ្រោះបិតា ។ បានឮថា ព្រះថេរៈគិតយ៉ាងនេះថា បិតាអញពោលនឹងអញយ៉ាងណា ប្រហែលជាពោលនឹងបព្វជិតដទៃ ក្នុងព្រះពុទ្ធសាសនាយ៉ាងនោះ ឯខាងក្នុងរបស់ពួកកិច្ចដែលបិទបាំងគុណដូចជាអញ ដូចផ្កាឈូកនៅក្នុងចន្លោះស្លឹក ដូចភ្លើងដែលផេះបិទបាំង ដូចខ្លឹមចន្ទន៍ដែលស្រោយបិទ ដូចកែវមុក្តាដែលដីបិទ ដូចព្រះចន្ទដែលពពកបិទ រមែងមិនមានវាចាបែបនេះនឹងប្រព្រឹត្តទៅក្នុងកិច្ចទាំងនោះ បិតាក៏នឹង តាំងនៅក្នុងការរវាំងប្រយ័ត្ន ព្រោះហេតុនោះ ទើបព្រះថេរៈពោលយ៉ាងនេះ ដោយការអនុគ្រោះ ។ បទថា **ឃរំ តាត** សេចក្តីថា គហបតីពោលថា នែបា ផ្ទះរបស់កូនមិនមានទេ មកយើងទៅផ្ទះទាំងអស់គ្នា ។ បទថា **អលំ** បានដល់ ព្រះថេរៈកាលបដិសេធ ទើបពោលយ៉ាងនេះ ព្រោះជាអ្នក សមាទានឯកាសនិកង្គធុតង្គយ៉ាងឧក្រិដ្ឋ ។ បទថា **អធិវាសេសិ** សេចក្តីថា តែព្រះថេរៈដោយប្រក្រតី ជាអ្នកសមាទានសបទានចារិកង្គធុតង្គយ៉ាងឧក្រិដ្ឋ ទើបមិនទទួលកិច្ចា ដើម្បីឆាន់ក្នុងថ្ងៃស្អែក តែទទួលដោយការអនុគ្រោះមាតា ។ បានឮថា មាតារបស់ព្រះថេរៈនឹកហើយនឹកទៀតដល់ព្រះថេរៈ ក៏កើតសេចក្តីសោកយ៉ាងធំ ទ្រហោយំ មានមុខជោកដោយទឹកភ្នែក ។ ព្រោះដូច្នោះ ព្រះថេរៈគិតថា បើអញមិនទៅសួរសុខទុក្ខមាតានោះ ហទយៈរបស់មាតា គប្បីបែក ទើបទទួលដោយសេចក្តីអនុគ្រោះ ។

[ ១៩៩ ] បទថា **ទ្វេ បុញ្ជេ** សេចក្តីថា ឲ្យធ្វើជា ២ ពំនូក គឺប្រាក់ ១ ពំនូក មាស ១ ពំនូក ។ សួរថា គំនរទ្រព្យធំប៉ុនណា ឆ្លើយថា ធំ

កាលបុរសឈរខាងនេះ មិនឃើញមជ្ឈិមបុរស ឈរខាងនោះ ។ បិតាកាល
បង្ហាញគំនរកហាបណៈ និងគំនរមាស ទើបពោលថា **ឥទំ តេ តាត** ជា
ដើម ។ បទថា **មត្តិកំ** ប្រែថា ទ្រព្យខាងម្តាយ អធិប្បាយថា ទ្រព្យនេះ ជា
របស់យាយរបស់កូន កាលម៉ែមកកាន់ផ្ទះនេះ មាតាក៏ឲ្យទ្រព្យ ដើម្បីប្រយោជន៍
ដល់គ្រឿងក្រអូប និងផ្កាជាដើម ។ បទថា **អញ្ញំ បិត្តិកំ អញ្ញំ បិតាមហំ**
សេចក្តីថា ទ្រព្យណាជារបស់បិតា និងជីតារបស់កូន ទ្រព្យនោះដែលរក្សា
ទុកនឹងប្រើការងាររដទៃមានច្រើនពន់ពេក ។ ក្នុងពាក្យនោះ ពាក្យថា **បិតា
មហំ** នេះ គប្បីជ្រាបថា ជាលោបតទ្ធិត ។ បាឋៈថា **បេតាមហំ** ក៏មាន ។
បទថា **សក្កា តាត រដ្ឋបាល** សេចក្តីថា រដ្ឋបាលកូន មិនមែនបព្វជិតតែ
ម្យ៉ាងដែលអាចធ្វើបុណ្យបាន សូម្បីអ្នកគ្រប់គ្រងផ្ទះ បរិភោគភោគៈ ក៏អាច
តាំងនៅក្នុងសរណៈ ៣ សមាទានសិក្ខាបទ ៥ ធ្វើបុណ្យ មានឲ្យទាន ជាដើម
ក្រៃលែងៗ ឡើងទៅ មកចុះកូន ។បេ។ ចូរធ្វើបុណ្យ ។ ព្រះថេរៈ ពោល
យ៉ាងនេះថា **តតោ និទានំ** សំដៅដល់ សេចក្តីសោកជាដើមដែលកើតដល់
អ្នករក្សាទ្រព្យនោះៗ និងដល់អ្នកដែលវិនាសទ្រព្យ ដោយអំណាច រាជភ័យ
ជាដើម និងទ្រព្យជាហេតុ ព្រោះទ្រព្យជាបច្ច័យ ។ កាលព្រះថេរៈ ពោល
យ៉ាងនោះ សេដ្ឋីគហបតីគិតថា អញនាំទ្រព្យនេះមកដោយបំណងឲ្យកូននេះ
សឹកឥឡូវនេះ កូននោះបែរជាផ្តើមបង្រៀនធម៌ដល់អញ កូននឹងមិនធ្វើតាម
ពាក្យរបស់អញពិត ហើយទើបក្រោកឡើង ឲ្យបើកទ្វារ បន្ទប់ខាងក្នុងរបស់
កូននោះ បញ្ជូនមុស្សទៅប្រាប់ថា បុគ្គលនេះជាប្តី ពួកនាង ចូរទៅធ្វើអ្វីមួយ

ព្យាយាមចាប់ខ្លួនមកឲ្យបាន នាងរបាំទាំងឡាយដែលនៅក្នុងវ័យទាំង ៣ ចេញទៅព័ទ្ធព្រះថេរៈទុក ។ លោកពោលពាក្យថា **បុរាណទុតិយិកា** ជាដើម សំដៅដល់ស្រីដែលជាប្រធាន ២ នាក់ ក្នុងអ្នករបាំទាំងនោះ ។ បទថា **បច្ចេកំ ចាគេសុ គហេត្វា** បានដល់ ចាប់ព្រះថេរៈនោះត្រង់ជើងម្នាក់ម្ខាង ។ សួរថា ព្រោះហេតុអ្វី ទើបនាងរបាំទាំងនោះពោលយ៉ាងនេះថា ពួកស្រីអប្សរទាំងនោះ តើល្អដូចម្ដេចទៅ ។ បានឮថា កាលនោះមនុស្សទាំងឡាយ ឃើញកំលោះរូបខ្លះ ព្រាហ្មណ៍កំលោះកូនសេដ្ឋីខ្លះជាច្រើន លះសម្បត្តិធំបួស មិនដឹងគុណរបស់បព្វជ្ជា ទើបតាំងសំណួរថា ហេតុអ្វី ទើបមនុស្សទាំង នោះបួស ពេលនោះទើបមនុស្សដទៃពោលថា ព្រោះហេតុនៃទេពអប្សរ ទេវនាដក ។ ពាក្យនោះ បានផ្សាយទៅយ៉ាងទូលំទូលាយ ។ នាងរបាំទាំង អស់នោះចាំនូវពាក្យនោះបានហើយ ទើបពោលយ៉ាងនេះ ។ ព្រះថេរៈកាលនឹងបដិសេធទើបពោលថា **ន មយំ ភគិនី** ម្នាលប្អូនស្រី អាត្មាមិនមែនប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះហេតុ ( ចង់បាន ) ពួកស្រីអប្សរទេ ។ បទថា **សមុទាចរតិ** ប្រែថា រមែងហៅ រមែងពោល ។ បទថា **តត្ថេវ មុច្ឆិតា បបតឹសុ** សេចក្ដីថា អ្នករបាំទាំងឡាយឃើញព្រះថេរៈហៅដោយពាក្យថា ប្អូនស្រី ទើបគិតថា ពួកយើងមិនបានចេញទៅខាងក្រៅអស់ ១២ ឆ្នាំ ដោយគិតថា អយ្យបុត្រនឹងមក ពួកយើងគប្បីរស់នៅដោយអំណាចរបស់ទារកពួកណា យើងអាស្រ័យលោក ក៏មិនបានទារកទាំងនោះ យើងនឹងជាអ្នកវិនាសទាំងខាងនោះ ទាំងខាងដទៃ ឈ្មោះថា លោកនេះជារបស់យើងឬ ព្រោះដូច្នោះ ពួកនាងរបាំទាំងនោះ កាល

គិតដើម្បីខ្លួនថា ឥឡូវនេះ អញមិនមានទីពឹងហើយ ក៏កើតសេចក្ដីសោកយ៉ាងខ្លាំងថា ឥឡូវនេះ លោកម្ចាស់អង្គនេះ មិនត្រូវការពួកយើង ហើយពួកយើងក៏ជាករិយា លោកគង់សម្គាល់ដូចក្មេងស្រី ដែលដេកនៅក្នុងពោះម៉ែជាមួយខ្លួន ទើបផ្កាប់មុខសន្ទប់ចុះក្នុងទីនោះឯង ។ អធិប្បាយថា ដួលទៅ ។ បទថា **មា នោ វិហោថេថ** សេចក្ដីថា កុំបង្ហាញទ្រព្យ និងបញ្ជូនមាតុគ្រាមមក បៀតបៀនអាត្មាឡើយ ។

សួរថា ព្រះថេរៈពោលយ៉ាងនោះ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះអនុគ្រោះមាតាបិតា បានឮថា សេដ្ឋីនោះសម្គាល់ថា ភេទបព្វជិតសៅហ្មង អញនឹងឲ្យដោះភេទបព្វជិតចេញ ឲ្យងូតទឹក បរិភោគរួមគ្នា ៣ នាក់ ទើបនឹងថ្វាយភិក្ខាដល់ព្រះថេរៈ ។ ព្រះថេរៈគិតថា មាតាបិតាទាំងនេះ ធ្វើអន្តរាយក្នុងអាហារដល់ព្រះទីណាស្រេពដូចជាអាត្មាអញ គប្បីជួបនូវវត្ថុដែលមិនមែនជាបុណ្យច្រើន ទើបពោលយ៉ាងនេះ ដោយសេចក្ដីអនុគ្រោះមាតាបិតានោះ ។

[ ២០០ ] បទថា **គាថា អភាសិ** ប្រែថា បានពោលគាថាទាំងឡាយ ។ បណ្ដាបទទាំងនោះ បទថា **បស្ស** គឺព្រះថេរៈពោលសំដៅបុគ្គលដែលនៅជិត ។ បទថា **ចិត្តំ** ប្រែថា ស្អាតដោយវត្ថុដែលបច្ច័យសាងឡើង ។ បទថា **ពិម្ពំ** ប្រែថា អត្តភាព ។ បទថា **អរុកាយំ** បានដល់ ប្រជុំដំបៅ គឺមុខដំបៅទាំង ៩ ។ បទថា **សមុស្សិតំ** បានដល់ ដែលចងឆ្អឹង ៣០០ កំណាត់ និងសរសៃ ៩០០ បូកលាប ដោយដុំសាច់ ៩០០ លើកឡើងដោយជុំវិញ ។ បទថា **អាតុរំ** បានដល់ក្ដៅក្រហាយជានិច្ច ព្រោះក្ដៅក្រហាយដោយជរា ក្ដៅក្រហាយដោយ

រោគ និងដោយកិលេស ។ បទថា **ពហុសង្កប្បំ** សេចក្តីថា មានការត្រិះរិះច្រើន ដោយការត្រិះរិះ គឺការប្រាថ្នាដែលកើតឡើងដល់សាកសពដទៃ ។ ពិតហើយ ពួកបុរសរមែងកើតការត្រិះរិះក្នុងរាងកាយរបស់ស្ត្រី ពួកស្ត្រីរមែងកើតការត្រិះរិះក្នុងរាងកាយរបស់បុរសទាំងនោះ ។ម្យ៉ាងទៀត ពួកក្អែក និងឆ្កែជាដើមរមែងប្រាថ្នារាងកាយនោះ ដែលជាសាកសព ដែលគេចោលក្នុងព្រៃស្មសាន ព្រោះដូច្នោះ ទើបឈ្មោះថា មានការត្រិះរិះច្រើន ។ បទថា **យស្ស នត្ថិ ធុវំ ឋិតិ** សេចក្តីថា កាយណាមិនមានការតាំងមាំដោយចំណែកមួយ ដូចមាយាថ្ងៃបណ្តើរកូន ពពុះទឹក និងក្រពេញទឹកជាដើម ភាពដែលរាងកាយនោះមានការបែកធ្លាយទៅជារបស់ធម្មតា ជារបស់ពិតប្រាកដ ។ បទថា **តចេន ឱនទ្ធំ** បានដល់ ស្រោបដោយស្បែកស្រស់ ។ បទថា **សហ វត្ថេភិ សោភតិ** សេចក្តីថា សូម្បីរូបដែលតាក់តែងឲ្យស្អាតដោយគ្រឿងក្រអូបជាដើមដោយកុណ្ឌលមណី រមែងស្រស់ស្អាត ព្រមដោយសំពត់ដែលតែងរូប វៀរសំពត់ចេញ ក៏គួរខ្ពើម មិនគួរមើល ។ បទថា **អលត្តកកតា** បានដល់ ស្រោចដោយទឹកល័ក្តស្រស់ ។ បទថា **ចុណ្ណកមក្ខិតំ** បានដល់ យកចុងគ្រាប់ស្លែ ធ្លុះមុនត្រង់មុខជាដើមចេញ យកដីប្រែកម្ទាត់ឈាមអាក្រក់ យកម្សៅល្ងធ្វើលោហិតឲ្យថ្លា យកល្មៀតខាត់ស្បែក យកម្សៅផាត់មុខ ដោយហេតុនោះ ទើបរាងកាយនោះស្អាតក្រៃលែង ។ លោកពោលពាក្យនោះ សំដៅយកកាយនោះ ។ បទថា **អដ្ឋបទកតា** សេចក្តីថា ធ្វើដោយទឹកឲ្យមានជារង្វង់មូលៗ ត្រង់ថ្ងាស បំពេញឲ្យកើតជាជួរ ៨ ។ បទថា **អញ្ជនី** បានដល់ បំពង់ថ្នាំបន្តក់ភ្នែក ។

បទថា **ឱទហិ** ប្រែថា តាំងទុក ។ បទថា **ចាសំ** បានដល់ អន្ទាក់ដែលធ្វើដោយដែក ។ បទថា **ឆាសធា** បានដល់ មិនដាប់ ។ បទថា **ធិវាបំ** បានដល់ អាហារដែលជានុយ និងស្មៅដែលពោលទុកក្នុងនិវាបសូត្រ ។ បទថា **កន្ទន្តេ** ប្រែថា កន្ទក់កន្ទេញ ។

ព្រះថេរៈធ្វើមាតាបិតាឲ្យដូចជាព្រានម្រឹគ ដោយគាថានេះ ។ ធ្វើពួកញាតិក្រៅអំពីនោះ ដូចបរិវាររបស់ព្រានម្រឹគ មាស និងប្រាក់ ដូចអន្ទាក់ ធ្វើអំពីដែក ភោជនដែលខ្លួនបរិភោគដូចនុយ និងស្មៅ ខ្លួនឯងដូចមហាម្រឹគ ។ ប្រៀបដូចមហាម្រឹគស៊ីចំណី និងស្មៅជាអាហារតាមសេចក្តីត្រូវការផឹកទឹក អើតកពិនិត្យមើលបរិវារគិតថា អញនឹងទៅកាន់ទីផុតភ័យ លោតឡើងមិនឲ្យប៉ះអន្ទាក់របស់ពួកព្រានម្រឹគ ដែលកំពុងកន្ទក់កន្ទេញ ចូលទៅកាន់ព្រៃ ត្រូវខ្យល់ត្រសៀកៗ សម្រាកនៅក្រោមគុម្ពឈើ ដែលប្រៀបដូចឆត្រមានម្លប់ក្រាស់ ឈរពិនិត្យមើលផ្លូវដែលមកយ៉ាងណា ព្រះថេរៈក៏ដូច្នោះដូចគ្នា កាលពោលគាថានេះហើយ ក៏ហោះទៅប្រាកដត្រង់ព្រះរាជឧទ្យាន ឈ្មោះថា មិគាចីរៈ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈហោះទៅ ឆ្លើយថា បានឮថាសេដ្ឋីបិតារបស់ព្រះថេរៈនោះ ឲ្យធ្វើគន្លឹះទ្វារទុកត្រង់ទ្វារទាំង ៧ ប្រាប់អ្នកប្រដាល់ទុកថា បើព្រះថេរៈចេញទៅ ចូរចាប់ដៃ និងជើងព្រះថេរៈទុក ដោះសំពត់កសាវៈ ឲ្យកាន់នូវភាពជាគ្រហស្ថ ។ ព្រោះដូច្នោះ ទើបព្រះថេរៈគិតថា មាតាបិតានោះចាប់ដៃជើងព្រះមហាខីណាស្រព ដូចអញគប្បីជួបនូវវត្ថុមិនមែនបុណ្យច្រើន បាបកម្មទុំៈ កុំមានដល់មាតាបិតាឡើយ ទើបហោះ

ទៅ ។ ព្រះថេរៈឯទាយសមុទ្រពោលថា ព្រះថេរៈឈរលើអាកាស ពោលគាថានេះ ហើយហោះទៅប្រាកដឯព្រះរាជឧទ្យានមិគាចីរៈរបស់ព្រះបាទកោរព្យៈ ។ គន្ធនៃពាក្យមានដូច្នេះ ។

[ ២០១ ] បទថា **មិគវោ** ជាឈ្មោះរបស់អ្នកយាមព្រះឧទ្យាននោះ ។ បទថា **សោធេន្តោ** បានដល់ ធ្វើផ្លូវទៅព្រះរាជឧទ្យានឲ្យស្មើ បានជម្រះទីដែលគួរជម្រះ បោសទីដែលគួរបោស និងធ្វើការកៀរខ្សាច់រោយផ្កា តម្កល់ក្អមពេញដោយទឹក តាំងដើមចេកជាដើមខាងក្នុងព្រះរាជឧទ្យាន ។ បទថា **យេន រាជា កោរព្យោ តេនុបសង្កមិ** សេចក្តីថា អ្នកយាមឧទ្យានគិតថា ព្រះរាជារបស់អញត្រាស់សរសើរកុលបុត្រនេះគ្រប់កាល ទ្រង់មានបំណងជួប តែទ្រង់មិនជ្រាបថា កុលបុត្រនោះមកហើយ ព្រោះដូច្នោះ បណ្ណាការនេះ ជារបស់ធំក្រៃលែង អញនឹងទៅក្រាបទូលព្រះរាជា ទើបទៅគាល់ព្រះបាទកោរព្យៈ ។

បទថា **កិត្តយមានោ អហោសិ** សេចក្តីថា បានឮថា ព្រះរាជានោះរឭកហើយរឭកទៀតដល់ព្រះថេរៈ ត្រាស់នូវគុណថា កុលបុត្រដែលលះសម្បត្តិធំបែបនោះបួសហើយត្រឡប់មកទៀត ក៏មិនជាប់ជំពាក់ទាំងក្នុងកណ្តាលពួកពលទាំងក្នុងកណ្តាលអ្នករបាំ ឈ្មោះថា ធ្វើកិច្ចដែលធ្វើបានលំបាក ។ ព្រះបាទកោរព្យនេះ ទ្រង់កាន់យកគុណនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **វិស្សជ្ជេថាតិ វត្វា** សេចក្តីថា វត្ថុណាសមគួរដល់បុគ្គលណា ក្នុងពួកអ្នកស្និទ្ធស្នាល មហាមាត្យ និងរេហ៍ពលជាដើម ក៏ឲ្យព្រះរាជទានវត្ថុនោះ ដល់បុគ្គលនោះ ។ បទថា **ឧស្សដាយ ឧស្សដាយ** សេចក្តីថា អឺងកងហើយៗ ទ្រង់នាំបរិស័ទ

អឹងកងដោយមហាមាត្យ ខ្ញុំរាជការ អ្នកធំជាដើមចូលទៅហើយ ។ ព្រះរាជា ទ្រង់សម្គាល់ថា កម្រាលនៅស្ដើង ទើបទ្រង់ធ្វើលំដាប់ផ្កា ជាដើមឲ្យក្រាស់ កំណត់ទុកត្រង់ទទឹង មិនប្រាប់ហើយអង្គុយក្នុងទីដូច្នោះមិនគួរទើបពោលយ៉ាង នេះថា **ឥធ ភវំ រដ្ឋបាលោ កដត្ថរេ និសីទតុ** សេចក្ដីថា បពិត្រ ព្រះរដ្ឋបាលដ៏ចម្រើន សូមគង់លើកម្រាលផ្កាក្នុងទីនេះ ។

[ ២០២ ] បទថា **បារិជុញ្ញានិ** សេចក្ដីថា ភាវៈ គឺការវិនាសណា បានដល់ ការអស់ទៅ ។

[ ២០៣ ] បទថា **ជិណ្ណោ** បានដល់ ព្រះជរា ។ បទថា **វុឌ្ឍោ** គឺ ចម្រើនដោយវ័យ ។ បទថា **មហល្លកោ** គឺចាស់ដោយជាតិ ។ បទថា **អទ្ធគតោ** គឺកន្លងកាលច្រើនវ័យហើយ ។ បទថា **វយោអនុប្បត្តោ** គឺដល់ បច្ឆិមវ័យហើយ ។ បទថា **បព្វជតិ** បានដល់ ទៅវិហារជិតៗ ថ្វាយបង្គំភិក្ខុ ឲ្យលោកកើតសេចក្ដីករុណា អារាធនាថា កាលខ្ញុំនៅកំលោះធ្វើកុសលទុកច្រើន ឥឡូវនេះជាមនុស្សចាស់ ឈ្មោះថា បព្វជ្ជានេះ របស់មនុស្សចាស់ ខ្ញុំនឹងបោស លានព្រះចេតិយ ធ្វើការបោសសម្អាតទីលំនៅ សូមឲ្យខ្ញុំបួសចុះ លោកម្ចាស់ ។ ព្រះថេរៈក៏ឲ្យបួស ដោយសេចក្ដីករុណា ។ លោកពោលពាក្យនេះសំដៅការ បួសឯចាស់នោះ ។ ក្នុងវារៈទី ២ ក៏មានន័យដូចគ្នា ។

[ ២០៤ ] បទថា **អប្បាពាធោ** បានដល់ មិនមានរោគ ។ បទថា **អប្បាតង្កោ** បានដល់ មិនមានទុក្ខ ។ បទថា **សមវេបាកិណិយា** បានដល់ ប្រកបដោយភ្លើងធាតុដែលរំលាយអាហារស្មើល្អ ។ បទថា **គហណិយា**

បានដល់ គេជាធាតុដែលកើតអំពីកម្ម ។ អាហារនៃបុគ្គលណាដែលបរិភោគហើយរមែងរលួយ ឬថា អាហាររបស់បុគ្គលណា រមែងតាំងនៅយ៉ាងនោះ ដូចអាហារដែលនៅក្នុងកញ្ចប់ប្រកបដោយភ្លើងធាតុ ដែលរលាយស្មើគ្នាទាំង ២ នោះ ។ ឯបុគ្គលណា ពេលបរិភោគហើយ ក៏កើតសេចក្តីត្រូវការអាហារ បុគ្គលនេះឈ្មោះថា ប្រកបដោយភ្លើងធាតុដែលរំលាយស្មើល្អ ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** បានដល់ មិនត្រជាក់ពេក មិនក្តៅពេក ដោយហេតុនោះឯង ។

[ ២០៥ ] បទថា **អនុបុព្វេន** សេចក្តីថា តាមលំដាប់ជាដើមថា ព្រះរាជាទ្រង់ពិចារណាក្នុងភារៈទី ២ ក៏គប្បីជ្រាបដោយលំដាប់ មានរាជភ័យ ចោរភ័យ និងឆាទកភ័យជាដើម ។

[ ២០៧ ] បទថា **ធម្មុទ្ធេសោ ឧទ្ទិដ្ឋោ** បានដល់ លើកធម្មនិទ្ទេសឡើងសម្តែង ។ បទថា **ឧបនីយតិ** បានដល់ ទៅជិតជរាមរណៈ ឬត្រូវនាំទៅក្នុងជរាមរណៈនោះ ដោយការអស់អាយុ ។ បទថា **អទ្ធុវោ** គឺវៀរចាកការតាំងនៅ ស្ថិតស្ថេរ ។ បទថា **អតាណោ** បានដល់ វៀរចាកការអាចក្នុងការតតាំង ។ បទថា **អនភិស្សរោ** បានដល់ មិនមានសរណៈ គឺវៀរចាកការអាចដែលនឹងមានសរណៈឲ្យក្រៃលែងហើយស្បើយចិត្ត ។ បទថា **អស្សកោ** គឺមិនមែនរបស់ខ្លួន វៀរចាករបស់ដែលជារបស់ខ្លួន ។ បទថា **សព្វំ បហាយ គមនីយំ** បានដល់ លោកចាំបាច់លះវត្ថុទាំងពួង ដែលកំណត់ថា ជារបស់ខ្លួនហើយទៅ ។ បទថា **តណ្ហាទាសោ** ប្រែថា ជាខ្ញុំនៃតណ្ហា ។

២០៨ ] បទថា **ហត្ថិស្មឹ** ប្រែថា ព្រោះ សិប្បៈដំរី ។ បទថា **កតាវី** បានដល់ ធ្វើកិច្ចស្រេចហើយ គឺរក្សាស្រេចហើយ អធិប្បាយថា មានសិប្បៈជំនាញ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ បទថា **ឧរុពលី** បានដល់ សម្បូរដោយកម្លាំងភ្លៅ ។ ពិតហើយបុគ្គលណា មានកម្លាំងភ្លៅដែលចាប់ខែល និងអាវុធចូលទៅកាន់កងទ័ពរបស់បរបក្ខ ទម្លាយវត្ថុដែលមិនទាន់បានទម្លាយ តម្រង់វត្ថុដែលទម្លាយទុកបានហើយ ធ្វើរាជសម្បត្តិដែលនៅក្នុងដៃនៃបរបក្ខមកបាន នេះឈ្មោះថា មានកម្លាំងភ្លៅ ។ បទថា **ពាហុពលី** បានដល់ សម្បូរដោយកម្លាំងដើមដៃ ។ ពាក្យដ៏សេសក៏ដូចគ្នានឹងន័យមុននោះឯង ។ បទថា **អល–មត្តោ** ប្រែថា មានអត្តភាពដែលអាច ។ បទថា **បរិយោធាយ វត្តិស្សន្តិ** បានដល់កំណត់កាន់យកថា នឹងគ្របសង្កត់អន្តរាយដែលកើតឡើងប្រព្រឹត្តទៅ ។ ព្រះរាជានោះ ទ្រង់នាំហេតុ នៃធម្មុទ្ទេសខាងលើមក ពោលពាក្យនេះថា លោកម្ចាស់រដ្ឋបាលដ៏ចម្រើន មាសប្រាក់ជាច្រើនក្នុងរាជត្រកូលនេះមាន ។

[ ២១២ ] បទថា **អថាបរំ ឯតទវោច** សេចក្តីថា ព្រះថេរៈបានពោលលំដាប់ ធម្មុទ្ទេស ៤ ដោយន័យជាដើមថា **បស្សាមិ លោកេ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ភិយ្យោ ច កាមេ អភិបត្ថយន្តិ** សេចក្តីថាប្រាថ្នាវត្ថុកាម និងកិលេសកាមក្រៃលែងឡើងៗ ទៅ យ៉ាងនេះថា បាន ១ ចង់បាន ២ បាន ២ ចង់បាន ៤ ។ បទថា **បសយ្ហ** បានដល់ គ្រប់គ្រងសម្បត្តិ ។ បទថា **សសាគរន្តំ** បានដល់ ប្រកបដោយសាគរជាទីបំផុត ។ បទថា **ឱរំ សមុ–ទ្ទស្ស** សេចក្តីថា មិនឆ្អែតដោយរដ្ឋរបស់ខ្លួន មានសមុទ្រជាព្រំដែន ។ បទថា

**ន ហាត្ថិ** កាត់បទជា **ន ហិ អត្ថិ** ប្រែថា មិនមានឡើយ ។ បទថា **អហោ វតានោ** កាត់បទជា **អហោ វត នុ** ម្យ៉ាងទៀត បាឋៈក៏យ៉ាងនេះដូចគ្នា ។ បទថា **អមវាតិចាហុ** កាត់បទជា **អមវំឥតិ ច អាហុ** លោកអធិប្បាយថា ញាតិព័ទ្ធជុំវិញអ្នកស្លាប់ កន្ទក់កន្ទេញ ជនទាំងឡាយពោលពាក្យជាដើមថា ឱហ្ន៎ បងរបស់យើងស្លាប់ កូនរបស់យើងស្លាប់ ។ បទថា **ផុសន្តិ ផស្សំ** គឺ ពាល់ត្រូវមរណសម្ផស្ស ។ បទថា **តថេវ ផុដ្ឋោ** សេចក្ដីថា មនុស្សល្ងង់ យ៉ាងណា សូម្បីអ្នកប្រាជ្ញក៏យ៉ាងនោះដូចគ្នា មរណផស្សៈពាល់ត្រូវហើយ ឈ្មោះថា បុគ្គលដែលមរណផស្សៈមិនពាល់ត្រូវមិនមាន ។ សេចក្ដីដែលប្លែកគ្នាមានដូច្នេះថា បទថា **ពាលោ ហិ ពាល្យា វិធិតោ វ សេតិ** សេចក្ដីថា មនុស្សល្ងង់ អាស្រ័យមរណផស្សៈចាក់ហើយនៅដេក ព្រោះជាបុគ្គលពាល ត្រូវមរណផស្សៈប៉ះខ្ទប់ហើយនៅដេក រមែងញាប់ញ័រ រមែងប្រែប្រួលដោយវិប្បដិសារៈជាដើមថា អញមិនបានធ្វើសេចក្ដីល្អទុកហ្ន៎ ។ បទថា **ធីរោ ចន វេធតិ** សេចក្ដីថា មនុស្សឈ្លាសឃើញសុគតិនិមិត្ត ក៏មិនកម្រើក មិនញាប់ញ័រ ។ បទថា **យាយ ហោសានំ ឥធាធិគច្ឆតិ** សេចក្ដីថា សម្រេចអរហត្តដែលជាទីបំផុតនៃកិច្ចទាំងពួងក្នុងលោកនេះ ដោយបញ្ញាឯណា បញ្ញានោះ ឧត្តមជាងទ្រព្យ ។ បទថា **អព្យោសិតត្តា** សេចក្ដីថា ព្រោះមិនទាន់ចប់ព្រហ្មចរិយៈ អធិប្បាយថា ព្រោះមិនទាន់មានការសម្រេចអរហត្ត ។ បទថា **ភវាភវេសុ** បានដល់ ក្នុងភពថោកទាប និងប្រណីត ។ បទថា **ឧបេតិ គព្ភញ្ច បរញ្ច លោកំ** សេចក្ដីថា កាលមនុស្សទាំងនោះកំពុងធ្វើបាប សត្វណាមួយត្រូវជួប

នូវសង្សារវដ្ដតៗ ទៅ រមែងចូលដល់គភ៌ក្នុងបរលោក ។ បទថា **តស្ស-ប្បបញ្ញោ** សេចក្ដីថា អ្នកមិនមានបញ្ញាដទៃក៏ជឿ ប្រកាន់បុគ្គលមិនមានបញ្ញាដូច្នោះ ។ បទថា **សកម្មុនា ហញ្ញតិ** សេចក្ដីថា រមែងក្ដៅក្រហាយ ដោយកម្មករណ៍មានវាយដោយផ្ដៅជាដើម ដោយអំណាចកម្មដែលខ្លួនឯងធ្វើទុក ។ បទថា **បេច្ច បរម្ហិ លោកេ** សេចក្ដីថា ទៅអំពីលោកនេះហើយ ក្ដៅក្រហាយក្នុងលោកដទៃគឺអបាយ ។ បទថា **វិរូបរូបេន** មានរូបផ្សេងៗ អធិប្បាយថា មានសភាវៈផ្សេងៗ ។ បទថា **កាមគុណេសុ** បានដល់ ឃើញទោសក្នុងកាមគុណក្នុងបច្ចុប្បន្នផង ខាងមុខផង ។ បទថា **ទហរា** ប្រែថា ទន់ខ្ចី ដោយហោចត្រឹមតែជាកលលៈ ។ បទថា **វុឌ្ឍា** គឺលើស ១០០ ឆ្នាំ ។ បទថា **អបណ្ណកំ សាមញ្ញមេវ សេយ្យោ** សេចក្ដីថា មហារាជអាត្មាភាពបួសព្រោះពិចារណាហើយថា សាមញ្ញផលប៉ុណ្ណោះមិនខុស មិនញែកជា ២ នាំសត្វចេញចាកទុក្ខដោយចំណែកមួយ ជាធម៌ដ៏ក្រៃលែងជាងផង ប្រណីតជាងផង ព្រោះដូច្នោះ ព្រះអង្គទ្រង់ឃើញ ទ្រង់ស្ដាប់យ៉ាងណា ទើបត្រាស់ពាក្យណា ចូរចាំនូវអាត្មាភាពថា អាត្មាភាពឃើញ និងស្ដាប់សេចក្ដីនេះ ទើបចេញបួស ហើយក៏បញ្ចប់ទេសនាដូច្នេះឯង ។៚

**អដ្ឋកថារដ្ឋបាលសូត្រចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## មឃទេវសូត្រទី ៣

[ ២១៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមឃទេវម្ពវ័ន ជិតក្រុងមិថិលា ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើអាការៈញញឹមព្រះឱស្ឋឲ្យប្រាកដក្នុងប្រទេសមួយ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ បានត្រិះរិះដូច្នេះថា ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ព្រះតថាគតទាំងឡាយ ទ្រង់មិនធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ដោយការឥតហេតុអ្វីឡើយ ។ ខណៈនោះ ព្រះអានន្ទមានអាយុ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ព្រះតថាគតទាំងឡាយ ទ្រង់មិនធ្វើអាការៈញញឹមព្រះឱស្ឋឲ្យប្រាកដ ដោយការឥតហេតុឡើយ ។

[ ២១៤ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ រឿងធ្លាប់មានមកហើយ ក្នុងនគរមិថិលានេះឯង មានព្រះរាជាទ្រង់ព្រះនាមថា មឃទេវ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ ទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកនិគម និងអ្នកជនបទជាព្រាហ្មណជាតិ និងគហបតិជាតិ តែងចូលរក្សាឧបោសថ ក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ នឹងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបព្រះបាទមឃ

ទេវរាជ ទ្រង់ត្រាស់ហៅខ្មាន់ព្រះកេសមកថា ម្នាលខ្មាន់ព្រះកេសសម្លាញ់ បើអ្នកឃើញសក់ស្កូវលើក្បាលរបស់អញ ក្នុងកាលណាហើយ អ្នកគប្បីប្រាប់អញក្នុងកាលនោះ ម្នាលអានន្ទ ខ្មាន់ព្រះកេសបានទទួលព្រះបន្ទូលនៃព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបខ្មាន់ព្រះកេសបានឃើញសក់ស្កូវលើព្រះសិរនៃព្រះបាទមឃទេវរាជ លុះឃើញហើយទើបក្រាបទូលព្រះបាទមឃទេវរាជដូច្នេះថា ទេវទូតប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសាស្កូវកើតលើព្រះសិរហើយ ។ ព្រះបាទមឃទេវរាជត្រាស់ថា ម្នាលខ្មាន់ព្រះ-កេសសម្លាញ់ បើដូច្នោះ ចូរអ្នកដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមដៃនៃអញមើល ។ ម្នាលអានន្ទ ខ្មាន់ព្រះកេសបានទទួលព្រះបន្ទូលនៃព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គហើយបានដកសក់ស្កូវនោះដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមព្រះហស្ត នៃព្រះបាទមឃទេវរាជ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកសួយដល់ខ្មាន់ព្រះកេស ហើយទ្រង់ឲ្យហៅព្រះរាជកុមារជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតាហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀតកាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតា និងកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ

ចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវលើក្បាលក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកស្ងួយដល់ខ្នាន់ព្រះកេស ហើយប្រដៅនូវព្រះរាជកុមារដែលជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួសក្នុងកាលនោះចុះ ព្រោះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរសណាមានហើយ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ គូនៃបុរសនោះឯងហៅថាបុរសថោកថយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កុំកូនធ្វើជាបុរសថោកថយជាងបិតាឡើយ ។

[ ២១៥ ] ម្នាលអានន្ទ គ្រានោះ ព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកស្ងួយដល់ខ្នាន់ព្រះកេសស្រេចហើយ ទ្រង់ប្រដៅព្រះរាជកុមារជាបុត្តច្បងក្នុងរាជសម្បត្តិដោយប្រពៃហើយ ទ្រង់កោរសក់ ពុកមាត់ពុកចង្ការ ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ ព្រះបាទមឃទេវរាជនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវ

សភាពធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោក ទាំងពួង ដោយអាការៈទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយបថទាំង ៤ ។ ម្នាលអានន្ទ ក៏ឯព្រះបាទមឃទេវរាជនៅលេងល្បែងក្មេង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ។ ព្រះបាទមឃទេវរាជនោះចម្រើនព្រហ្មវិហារទាំង ៤ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។

[ ២១៦ ] ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបបុត្ររបស់ព្រះបាទមឃទេវរាជ ត្រាស់ហៅខ្ញុំព្រះកេសមកថា ម្នាលខ្ញុំព្រះកេសជាសម្លាញ់ បើអ្នកបានឃើញសក់ស្កូវលើក្បាល

របស់អញ ក្នុងកាលណាហើយ អ្នកគប្បីប្រាប់អញ ក្នុងកាលនោះ ។ ម្នាលអានន្ទ ខ្មាន់ព្រះកេសទទួលព្រះបន្ទូលនៃបុត្តរបស់ព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើន ពាន់ឆ្នាំកន្លងទៅហើយ ខ្មាន់ព្រះកេសបានឃើញសក់ស្កូវ លើព្រះសិរនៃបុត្តរបស់ព្រះបាទមឃទេវរាជ លុះឃើញហើយទើបក្រាបទូលបុត្តរបស់ព្រះបាទមឃទេវរាជដូច្នេះថា ទេវទូតប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសស្កូវ ក៏កើតលើព្រះសិរហើយ ។ ព្រះរាជបុត្តត្រាស់ថា ម្នាលខ្មាន់ព្រះកេសជាសម្លាញ់ បើដូច្នោះ អ្នកចូរដកសក់ស្កូវនោះ ដោយសណ្ឋាសឲ្យស្រួល ហើយដាក់លើម្រាមដៃអញមើល ។ ម្នាលអានន្ទ ខ្មាន់ព្រះកេសបានទទួល ព្រះបន្ទូលនៃបុត្តរបស់ព្រះបាទមឃទេវរាជថា ព្រះករុណាព្រះអង្គ ហើយបានដកសក់ស្កូវនោះដោយសណ្ឋាសឲ្យស្រួល ដាក់លើម្រាមព្រះហស្តនៃបុត្តរបស់ព្រះបាទមឃទេវរាជ ។ ម្នាលអានន្ទ លំដាប់នោះ បុត្តនៃព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកសួយដល់ខ្មាន់ព្រះកេស ហើយឲ្យហៅព្រះរាជកុមារជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតាហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតានឹងកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវកើតលើក្បាល

ក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកសួយដល់ខ្នាន់ព្រះកេស ហើយប្រដៅព្រះរាជកុមារដែលជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ពុកមាត់ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថាកល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរសណាមានហើយ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្ដាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថាបុរសថោកថយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយជាងបិតាឡើយ ។

[ ២១៧ ] ម្នាលអានន្ទ គ្រានោះ បុត្តរបស់ព្រះបាទមឃទេវរាជ ព្រះរាជទានស្រុកសួយ ដល់ខ្នាន់ព្រះកេសស្រេចហើយ ប្រដៅព្រះរាជកុមារជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃហើយ កោរសក់ពុកមាត់ពុកចង្ការ ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ រាជបុត្តនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោក

ទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា ។បេ។ មានចិត្តប្រកបដោយមុទិតា ។បេ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមទីងទទីង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយដល់នូវភាពជាធំប្រមាណមិនបាន មិនមានពៀរ មិនព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួងដោយអាការៈទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលអានន្ទ ក៏ឯបុត្តនៃព្រះបាទមឃទេវរាជ នៅលេងល្បែងក្មេង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះចូលមកកាន់ផ្នួសប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ។ ព្រះរាជបុត្តនោះ ចម្រើនព្រហ្មវិហារទាំង ៤ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។

[ ២១៨ ] ម្នាលអានន្ទ ក៏ឯបុត្ត និងនត្តារបស់ព្រះបាទមឃទេវរាជនោះតៗ ព្រះវង្សអស់ចំនួនប្រាំបីម៉ឺនបួនពាន់តំណ ក៏កោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ ឥសីទាំងអម្បាលនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី

២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តាជាចិត្តទូលាយដល់នូវភាពជាធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួងដោយអាការៈទាំងពួង ក្នុងទីទាំងពួងសម្រេច សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមនិងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយដល់នូវភាពជាធំប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការៈទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ឥសីទាំងអម្បាលនោះ នៅលេងល្បែងក្មេង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះចូលមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ។ ឥសីទាំងអម្បាលនោះ ចម្រើនព្រហ្មវិហារទាំង ៤ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក ។ បណ្តាព្រះរាជាទាំងអម្បាលនោះ ព្រះបាទនិមិរាជ ជាស្តេចក្រោយបង្អស់ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទជាព្រាហ្មណជាតិ

និងគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។

[ ២១៩ ] ម្នាលអានន្ទ រឿងនេះធ្លាប់មានមកហើយតើ ពាក្យជាចន្លោះនេះ បានកើតឡើងដល់ពួកទេវតាជាន់តាវត្តិង្ស ដែលអង្គុយប្រជុំគ្នាក្នុងរោងសុធម្មាថា អើហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ អើហ្ន៎ អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃ បក្ស ។

[ ២២០ ] ម្នាលអានន្ទ លំដាប់នោះ សក្ករាជជាធំជាងទេវតា បានហៅពួកទេវតាជាន់តាវត្តិង្សមកថា ម្នាលគ្នាយើងទាំងឡាយ អ្នកទាំងឡាយចង់ឃើញព្រះបាទនិមិរាជឬទេ ។ ពួកទេវតាក្រាបទូលថា បពិត្រទ្រង់អ្នកនិទ្ទុក្ខ យើងទាំងឡាយចង់ឃើញព្រះបាទនិមិរាជដែរ ។ ម្នាលអានន្ទ សម័យនោះឯង ព្រះបាទនិមិរាជជម្រះព្រះសិរ្ស ហើយរក្សាឧបោសថ ក្នុងថ្ងៃឧបោសថទី ១៥ ហើយចូលទៅកាន់ប្រាសាទដ៏ប្រសើរ គង់នៅក្នុងជាន់លើ ។ ម្នាលអានន្ទលំដាប់នោះ សក្ករាជជាធំជាងទេវតា ក៏បំបាត់ខ្លួនអំពីពួកទេវតាជាន់តាវត្តិង្ស ហើយមកប្រាកដចំពោះព្រះភក្ត្រព្រះបាទនិមិរាជ ដូចជាបុរសមានកម្លាំងលាទូវដៃដែលបត់ចូល ឬបត់នូវដៃដែលលាចេញដូច្នោះ ។ ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជ ជាធំជាងទេវតា មានព្រះបន្ទូលពាក្យនេះ នឹងព្រះបាទនិមិរាជថា បពិត្រមហារាជ ព្រះអង្គពេញហៅជាមានលាភ បពិត្រមហារាជ អត្តភាពជា

មនុស្ស ព្រះអង្គពេញហៅបានដោយល្អ បពិត្រមហារាជ ដ្បិតពួកទេវតាជាន់តាវត្តិង្ស បានអង្គុយប្រជុំគ្នានិយាយសរសើរក្នុងរោងសុធម្មាថា អើហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ អើហ្ន៎ អត្តភាពជាមនុស្សពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ចំពោះអ្នកនិគម និងអ្នកជនបទជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ដូច្នេះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្សមានសេចក្តីប្រាថ្នា ដើម្បីឃើញព្រះអង្គ បពិត្រមហារាជ ខ្ញុំព្រះអង្គនឹងបញ្ជូនរថសម្រាប់ទឹមសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់មក ដើម្បីព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញញើតគប្បីឡើងកាន់ទិព្វយាន ។ ម្នាលអានន្ទ ព្រះបាទនិមិរាជ ទ្រង់ទទួលអញ្ជើញដោយតុណ្ហីភាព ។ ម្នាលអានន្ទ គ្រានោះសក្កទេវរាជជាធំជាងទេវតា ទ្រង់ជ្រាបថាព្រះបាទនិមិរាជ ទទួលអញ្ជើញហើយ ក៏បំបាត់ខ្លួនអំពីទីចំពោះព្រះភក្ត្រនៃព្រះបាទនិមិរាជ ទៅប្រាកដក្នុងពួកទេវតាជាន់តាវត្តិង្សវិញ ។ ដូចជាបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះ ។

[ ២២១ ] ម្នាលអានន្ទ លំដាប់នោះ សក្ករាជជាធំជាងទេវតា បានត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្រ្គោះមកថា ម្នាលមាតលិសម្លាញ់ អ្នកចូរមករៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះមួយពាន់ហើយចូលទៅថ្កាន ព្រះបាទនិមិរាជ រួចទូលយ៉ាងនេះថា បពិត្រមហារាជ រថសេះអាជានេយ្យ

ដែលទឹមដោយសេះអាជានេយ្យមួយពាន់នេះ សក្កទេវរាជជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ ដើម្បីព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញញើត គប្បីឡើងកាន់ទិព្វយានចុះ ។ ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្គ្រោះ ក៏ទទួលព្រះបន្ទូលនៃសក្កទេវរាជជាធំជាងទេវតាថា ព្រះករុណា សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ហើយរៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះ អាជានេយ្យមួយពាន់នាំចូលទៅថ្វាន ព្រះបាទនិមិរាជ ហើយទូលសេចក្តីនេះថា បពិត្រមហារាជ រថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ នេះ សក្កទេវរាជជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ ដើម្បីព្រះអង្គ បពិត្រ មហារាជ សូមព្រះអង្គកុំញញើត ចូរឡើងកាន់ទិព្វយានចុះ បពិត្រមហារាជ មួយទៀត ពួកសត្វដែលមានកម្មអាក្រក់ តែងទទួលនូវផលនៃកម្មអាក្រក់ ដោយផ្លូវណាក្តី ពួកសត្វដែលមានកម្មល្អតែងទទួលនូវផលនៃកម្មល្អ ដោយ ផ្លូវណាក្តី បណ្តាផ្លូវទាំង ២ នោះ ខ្ញុំនឹងនាំព្រះអង្គទៅតាមផ្លូវណា ។ ម្នាល មាតលិទេវបុត្ត អ្នកចូរនាំយើងទៅតាមផ្លូវទាំង ២ នោះចុះ ។ ម្នាលអានន្ទ មាតលិទេវបុត្តជាអ្នកសង្គ្រោះបានញុំាងព្រះបាទនិមិរាជឲ្យទៅដល់រោងសុធម្មា ។ ម្នាលអានន្ទ សក្កទេវរាជជាធំជាងទេវតា បានឃើញព្រះបាទនិមិរាជ ស្តេច មកអំពីចម្ងាយ លុះឃើញហើយ ទើបនិយាយពាក្យនេះនឹងព្រះបាទនិមិរាជថា បពិត្រមហារាជ សូមព្រះអង្គមកចុះ បពិត្រមហារាជ ព្រះអង្គស្តេចមកប្រពៃ ហើយ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស បានប្រជុំគ្នានិយាយក្នុងរោង សុធម្មាថា ឱហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ ឱហ្ន៎

អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថក្នុងទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ដូច្នេះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្សមានសេចក្តីប្រាថ្នា ដើម្បីឃើញព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គត្រេកអរ ចំពោះពួកទេវតា ដោយទេវានុភាពចុះ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ល្មមហើយ សូមព្រះអង្គនាំខ្ញុំទៅ កាន់ក្រុងមិថិលា ក្នុងដែន វិទេហៈនោះវិញ ខ្ញុំនឹងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ និងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ គ្រានោះឯង សក្កទេវរាជជាធំជាងទេវតា ទ្រង់ត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្រ្គោះមកថា ម្នាលមាតលិទេវបុត្តសម្លាញ់ អ្នកចូរមករៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជ ទៅកាន់ក្រុងមិថិលាក្នុងដែនវិទេហៈនោះវិញ ។ ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្រ្គោះ បានទទួលព្រះបន្ទូល នៃសក្កទេវរាជជាធំជាងទេវតាថា ព្រះករុណា សេចក្តីចម្រើនចូរមានដល់ព្រះអង្គ ហើយរៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជទៅកាន់ក្រុងមិថិលា ក្នុងដែនវិទេហៈនោះ វិញ ។

[ ២២២ ] ម្នាលអានន្ទ បានឮថា មហារាជក្នុងក្រុងមិថិលានោះ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទជាព្រាហ្មណជាតិ និងគហបតិជាតិ

តែងរក្សាឧបោសថក្នុងថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ស ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបព្រះបាទនិមិរាជត្រាស់ហៅខ្មាន់ព្រះកេសមកថា ម្នាលខ្មាន់ព្រះកេសជាសម្លាញ់ បើអ្នកបានឃើញសក់ស្កូវកើតមានលើក្បាលនៃអញ ក្នុងកាលណាហើយ អ្នកចូរប្រាប់អញក្នុងកាលនោះ ។ ម្នាលអានន្ទ ខ្មាន់ព្រះកេសទទួលព្រះបន្ទូល ព្រះបាទនិមិរាជថា ព្រះករុណាព្រះអង្គ ។ ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ខ្មាន់ព្រះកេសបានឃើញសក់ស្កូវ កើតមានលើព្រះសិរ្សនៃព្រះបាទនិមិរាជ លុះឃើញហើយ ទើបក្រាបទូលព្រះបាទនិមិរាជដូច្នេះថា ទេវទូតប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសស្កូវកើតមានលើព្រះសិរ្សហើយ ។ ម្នាលខ្មាន់ព្រះកេសជាសម្លាញ់បើដូច្នោះ អ្នកចូរដកសក់ស្កូវនោះដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមដៃនៃអញមើល ។ ម្នាលអានន្ទ ខ្មាន់ព្រះកេស បានទទួលព្រះបន្ទូលនៃព្រះបាទនិមិរាជថា ព្រះករុណាព្រះអង្គ ហើយដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល រួចដាក់លើម្រាមព្រះហស្ត នៃព្រះបាទនិមិរាជ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទនិមិរាជទ្រង់ព្រះរាជទានស្រុកសួយដល់ខ្មាន់ព្រះកេសហើយ ឲ្យហៅព្រះរាជកុមារជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតាហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន អ្នកចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ

ចំណែកបិតានឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯងបានឃើញសក់ស្កូវកើតមានលើក្បាលក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកស្នួយដល់ខ្នាន់ព្រះកេស ហើយប្រដៅនូវព្រះរាជកុមារ ដែលជាបុត្តច្បងក្នុងរាជសម្បត្តិដោយប្រពៃ ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថាកល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរសណានៅមានហើយ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថាបុរសថោកថយ ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយជាងបិតាឡើយ ។

[ ២២៣ ] ម្នាលអានន្ទ គ្រានោះ ព្រះបាទនិមិរាជទ្រង់ព្រះរាជទានស្រុកស្នួយដល់ខ្នាន់ព្រះកេសស្រេចហើយ ប្រដៅព្រះរាជកុមារជាបុត្តច្បង ក្នុងរាជសម្បត្តិឲ្យស្រួល ហើយកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង ។ ព្រះបាទនិមិរាជនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិស

ទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការៈទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី ២ ផ្សាយទៅកាន់ទិសទី ៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការៈទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលអានន្ទ ព្រះបាទនិមិរាជនៅលេងល្បែងក្មេង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាឧបរាជកំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ សោយរាជ្យជាស្តេចធំកំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ចេញចាកផ្ទះចូលមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីម៉ឺនបួនពាន់ឆ្នាំ ។ ព្រះបាទនិមិរាជនោះ ចម្រើនព្រហ្មវិហារទាំង ៤ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណ ក៏បានទៅកើតក្នុងព្រហ្មលោក ។

[ ២២៤ ] ម្នាលអានន្ទ ក៏ឯព្រះបាទនិមិរាជ ព្រះអង្គមានព្រះរាជបុត្ត ១ អង្គ ព្រះនាមថា កឡារជនកៈ ។ ព្រះរាជបុត្តនោះ មិនចេញចាកផ្ទះចូលកាន់ផ្នួសឡើយ ។ ព្រះរាជបុត្តនោះ ក៏ផ្តាច់នូវកល្យាណវត្តនោះហើយ ។

បណ្តាក្សត្រិយទាំងនោះ ព្រះរាជបុត្តនោះជាបុរសបោកថយជាងគេ ។ ម្នាល អានន្ទ ប្រហែលជាអ្នកមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះបាទមឃទេវរាជ ណា ដែលបានតាំងទុកនូវកល្យាណវត្តនោះ ព្រះបាទមឃទេវរាជនោះឯង គឺ បុគ្គលដទៃក្នុងសម័យនោះទេដឹង ម្នាលអានន្ទ រឿងនោះអ្នកកុំគប្បីយល់យ៉ាង នេះឡើយ ។ តថាគតឯងជាមឃទេវរាជក្នុងសម័យនោះ ។ តថាគតបាន តាំងទុកនូវកល្យាណវត្តនោះហើយ ប្រជុំជនជាខាងក្រោយ បានប្រព្រឹត្តតាម កល្យាណវត្តនោះ ដែលតថាគត បានតាំងទុកស្រេចហើយ ។ ម្នាលអានន្ទ តែ ថាកល្យាណវត្តនោះ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅដើម្បីរម្ងត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់ រម្ងាប់ មិនប្រព្រឹត្តទៅដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិន ប្រព្រឹត្តទៅដើម្បីព្រះនិព្វានឡើយ បានត្រឹមតែកើតក្នុងព្រហ្មលោកប៉ុណ្ណោះ ឯង ។ ម្នាលអានន្ទ ចំណែកខាងកល្យាណវត្តនេះ ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយពិត ដើម្បី ប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ ដឹង ដើម្បីព្រះនិព្វាន ។ ម្នាលអានន្ទ កល្យាណវត្តដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយពិត ដើម្បី ប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ ដឹង ដើម្បីព្រះនិព្វាន តើដូចម្តេច ។ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសេចក្តីឃើញប្រពៃ ១ សេចក្តីត្រិះរិះប្រពៃ ១ វាចាប្រពៃ ១ ការងារប្រពៃ

១ ការចិញ្ចឹមជីវិតប្រពៃ ១ សេចក្ដីព្យាយាមប្រពៃ ១ សេចក្ដីរឭកប្រពៃ ១ ការតាំងចិត្តប្រពៃ ១ ម្នាលអានន្ទ កល្យាណវត្តនេះឯង ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ។ ម្នាលអានន្ទ តថាគតពោលនូវកល្យាណវត្តនោះ ដល់អ្នកទាំងឡាយថា កល្យាណវត្តនេះ តថាគតបានតាំងទុកហើយ អ្នកទាំងឡាយគប្បីប្រព្រឹត្តតាមចុះ អ្នកទាំងឡាយ កុំជាបុរសថោកថយជាងតថាគតឡើយ ម្នាលអានន្ទ កាលបើគូនៃបុរសណាមាននៅ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅ បណ្ដាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថាបុរសថោកថយ ។ ម្នាលអានន្ទ តថាគតពោលនូវកល្យាណវត្តនោះ ដល់អ្នកទាំងឡាយយ៉ាងនេះថា កល្យាណវត្តនេះ តថាគតបានតាំងទុកហើយ អ្នកទាំងឡាយគប្បីប្រព្រឹត្តតាមចុះ អ្នកទាំងឡាយ កុំជាបុរសថោកថយជាងតថាគតឡើយ ។ លុះព្រះមានព្រះភាគ បានត្រាស់សូត្រនេះចប់ហើយ ព្រះអានន្ទដ៏មានអាយុ ជាអ្នកមានសេចក្ដីត្រេកអរ ក៏បានត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ មឃទេវសូត្រទី ៣

# អដ្ឋកថា

## មឃទេវសូត្រ

[ ២១៣ ] មឃទេវសូត្រ មានពាក្យផ្ដើមថា **ឯកំ សមយំ** ដូច្នេះជាដើម ។ ក្នុងបណ្ដាបទទាំងនោះ បទថា **មឃទេវម្ពវនេ** សេចក្ដីថា អំពីមុន ព្រះរាជាឈ្មោះថា មឃទេព ត្រាស់ប្រើឲ្យដាំចម្ការស្វាយទីនោះទុក ។ កាលដើមឈើទាំងនោះបាក់ឬសអស់ទៅហើយ តមកទៀត ព្រះរាជាទាំងឡាយអន្ដដទៃៗ ក៏បានបញ្ជាឲ្យដាំទុកទៀត ។ ទើបចម្ការនោះដល់នូវការរាប់ថា **មឃ-ទេវម្ពវន** ព្រោះសន្មតហៅមកអំពីដើម ។ បទថា **សិតំ បាត្វាកាសិ** សេចក្ដីថា ក្នុងពេលល្ងាច ព្រះមានព្រះភាគយាងចារិកទៅក្នុងវិហារ ទ្រង់ឃើញតំបន់ដែលជាទីត្រេកអរនៃចិត្ត ទើបទ្រង់រំពឹងថា តថាគតធ្លាប់នៅក្នុងទីនេះអំពីមុនឬទេហ្ន៎ ទើបទ្រង់ឃើញថា កាលមុនតថាគតជាព្រះរាជាឈ្មោះ មឃទេព បានដាំស្វាយនេះទុក ។ តថាគតបួសក្នុងទីនេះឯង ចម្រើនព្រហ្មវិហារ ៤ ទៅកើតក្នុងព្រហ្មលោក ហេតុនេះមិនប្រាកដដល់ភិក្ខុសង្ឃ តថាគត នឹងធ្វើឲ្យប្រាកដ កាលទ្រង់សម្ដែងជួរព្រះទន្ដដ៏ប្រសើរ ទើបទ្រង់ធ្វើការញញឹមឲ្យប្រាកដហើយ ។

[ ២១៤ ] ឈ្មោះថា **ធម្មិក** ព្រោះអត្ថថា ទ្រង់មានធម៌ ។ ឈ្មោះថា **ធម្មរាជា** ព្រោះអត្ថថា ទ្រង់ជាព្រះរាជាដោយធម៌ ។ ពាក្យថា ទ្រង់តាំងនៅក្នុងធម៌ គឺទ្រង់តាំងនៅក្នុងធម៌ គឺកុសលកម្មបថ ១០ ប្រការ ។ ពាក្យថា ទ្រង់ប្រព្រឹត្តធម៌ គឺទ្រង់ប្រព្រឹត្តរាជធម៌ ។ ក្នុងបទទាំងនោះ បទថា **ព្រាហ្មណគ-**

**ហាបតិកេសុ** សេចក្តីថា ទ្រង់ជាទីស្រឡាញ់ ទ្រង់រក្សាបវេណីដែលព្រះរាជាអង្គមុនៗ ឲ្យហើយដល់ពួកព្រាហ្មណ៍ ទ្រង់មិនញុំាងកិច្ចនោះឲ្យវិនាស ទ្រង់ធ្វើដោយប្រក្រតីនិយមរហូតមក ។ ពួកគហបតីទាំងឡាយ ក៏ទ្រង់បដិបត្តិដូច្នេះ ។ ពាក្យដែលលោកពោលសំដៅដល់រឿងនេះ ។ បទថា **បក្ខស្ស** លោករួមសូម្បីបាដិហារិកបក្ខចូលផង គឺបណ្ឌិតគប្បីជ្រាបថាថ្ងៃទាំងនេះ ឈ្មោះថា **ចាដិហារិកបក្ខ** គឺថ្ងៃ ៧ ថ្ងៃ ៩ ដោយអំណាចថ្ងៃអម នៃថ្ងៃឧបោសថក្នុងតិថីទី ៨ ថ្ងៃ ១៣ និងថ្ងៃបាដិបទ ដោយអំណាចថ្ងៃអមនៃថ្ងៃឧបោសថទី ១៤ ទី ១៥ ព្រះអង្គទ្រង់រក្សាឧបោសថក្នុងថ្ងៃនោះរាល់ថ្ងៃ ។

បទថា **ទេវទូតា** សេចក្តីថា មច្ចុ ឈ្មោះថា ទេវៈ ។ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ជាទូតរបស់សេចក្តីស្លាប់នោះ គឺបុគ្គលកាលសក់ស្កូវប្រាកដហើយ ក៏ហាក់ដូចឈរនៅក្នុងសម្នាក់របស់ស្តេចមច្ចុរាជ ។ ព្រោះដូច្នោះ សក់ដែលស្កូវហើយ ទើបលោកពោលថា ជាទូតរបស់មច្ចុទេវៈ ។ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ទូតដូចទេវតាទាំងឡាយក៏មាន ។ ឧបមា ដូចទេវតាដែលប្រដាប់ហើយ តាក់តែងហើយ មកឈរនៅក្នុងអាកាស ស្រែកប្រាប់ថា ក្នុងថ្ងៃនោះ អ្នកនឹងស្លាប់ដូច្នេះ ទេវទូតនោះក៏ដូច្នោះ កាលសក់ស្កូវហើយ ប្រាកដហើយ ក៏ហាក់ដូចជាទេវតាព្យាករឲ្យដូច្នោះដូចគ្នា ។ ព្រោះដូច្នោះ សក់ដែលស្កូវហើយ ទើបលោកហៅថា ទូត ដែលដូចគ្នានឹងទេវៈដូច្នេះ ។ ឈ្មោះថា **ទេវទូត** ព្រោះអត្ថថា ជាទូតនៃវិសុទ្ធិទេពក៏បាន ពិតហើយ ព្រះពោធិសត្វគ្រប់ព្រះអង្គ ទ្រង់ឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិតមុន ទ្រង់សង្វេគ

ទើបចេញបួស ។ ដូចលោកត្រាស់ទុកថា

ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខ ទាំងឃើញមនុស្សដល់នូវការអស់ទៅនៃអាយុស្លាប់ហើយ ហេតុនោះខ្ញុំលះបង់កាមជាទីត្រេកអរនៃចិត្តហើយចេញបួស ។

ដោយបរិយាយនេះ សក់ដែលស្កូវហើយ ទើបលោកហៅថា **ទេវទូត** ព្រោះជាទូតនៃវិសុទ្ធិទេព ។ បទថា **កប្បកស្ស គាមវរំ ទត្វា** សេចក្ដីថា ទ្រង់ព្រះរាជទានស្រុកដែលចម្រើនឧត្ដម មានសួយអាករ កើតឡើងរបូតមួយសែន ។ ទ្រង់ព្រះរាជទានព្រោះហេតុអ្វី ។ ព្រោះទ្រង់សង្វេគ ពិតណាស់ទ្រង់កើតការសង្វេគ ព្រោះទ្រង់ឃើញសក់ស្កូវដែលនៅត្រង់ម្រាមដៃ ទ្រង់មានព្រះជន្មទៀត ដល់ទៅ ៨៤០០០ ឆ្នាំ ។ កាលបើដូច្នោះ ក៏ទ្រង់សម្គាល់ព្រះអង្គហាក់ដូចឈរនៅក្នុងសម្នាក់របស់ស្ដេចមច្ចុរាជ ទើបទ្រង់សង្វេគ ទ្រង់ពេញព្រះទ័យក្នុងបព្វជ្ជា ។ ព្រោះដូច្នោះ ទើបលោកពោលថា

ព្រះបាទមឃទេព ដ៏ជាអធិបតីក្នុងទិស ជាអ្នកប្រាជ្ញ ទ្រង់ឃើញសក់ស្កូវលើក្បាល ទ្រង់សង្វេគ ទ្រង់ត្រេកអរក្នុងបព្វជ្ជាហើយ ។

និងពោលទុកតទៅទៀតថា

សក់ទាំងឡាយនេះនាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញហើយ ទេវទូតកើតប្រាកដហើយ ( នេះ ) ជាសម័យនៃផ្នួសរបស់អញ ។

បទថា **បុរិសយុគេ** គឺកាលយុគបុរសដែលកើតក្នុងវង្ស ។

[ ២១៥ ] បទថា **កេសមស្សុំ ឱហារេត្វា** គឺទ្រង់កោរសក់ និងពុកមាត់

ពុកចង្កា ពោលថា កាលបួសជាតាបស ក៏ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ បួស ។ បន្ទាប់អំពីនោះ ក៏ទ្រង់ព័ទ្ធព្រះកេសាដែលវែងឡើងមក ធ្វើជាជដា ត្រាច់ទៅ ។ ព្រះពោធិសត្វទ្រង់បួសជាតាបស កាលបួសហើយ ទ្រង់មិន ប្រកបរឿយៗ នូវអនេសនា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយកិច្ចា ដែលនាំ មកអំពីរាជវាំង ទ្រង់ចម្រើនព្រហ្មវិហារ ។ ព្រោះដូច្នោះ ទើបលោកពោល ថា ព្រះអង្គទ្រង់មានព្រះទ័យប្រកបដោយមេត្តាដូច្នេះជាដើម ។

បទថា **កុមារកីឡិកំ កីឡិ** ព្រះឱរស ... ទ្រង់លេងដោយភាពជាកុមារ សេចក្តីថា ដែលពួកកីឡៀងពរដោយចង្កេះ ទ្រង់លេងហើយៗ កីឡៀងទាំង ឡាយលើកព្រះកុមារនោះ ដូចបាច់នៃផ្កាឈើ ត្រាច់ទៅ ។

[ ២១៦ ] បទថា **រញ្ញោ មឃទេវស្ស បុត្តោ ។បេ។ បព្វជិ** សេចក្តីថា ក្នុងថ្ងៃដែលព្រះឱរសនេះទ្រង់ព្រះផ្នួស បានកើតមង្គល ៥ ប្រការ គឺធ្វើមតក កត្តថ្វាយព្រះបាទមឃទេវៈ ១ មង្គលគឺព្រះឱរសរបស់ព្រះបាទមឃទេវៈចេញ បួស ១ មង្គលគឺព្រះរាជបុត្ររបស់ព្រះរាជាលើកស្វេតច្ឆត្រឡើងគ្រងរាជ្យ ១ មង្គលគឺព្រះរាជបុត្ររបស់ព្រះរាជា លើកស្វេតច្ឆត្រឡើងគ្រងរាជ្យជាឧបរាជ ១ មង្គលគឺថ្វាយព្រះនាមព្រះរាជឱរសរបស់ព្រះរាជាដែលលើកស្វេតច្ឆត្រ ១ ។ ប្រជាជនបានធ្វើមង្គល ៥ ប្រការ ក្នុងគ្រាតែមួយ ។ ក្នុងផ្ទៃនៃជម្ពូទ្វីប បានលើកនង្គ័លឡើង គឺមិនចាំបាច់ធ្វើចម្ការ ភ្ជួរស្រែ ខេត្តក្រុងឧត្តមសម្បូរ ។

[ ២១៨ ] បទថា **បុត្តបបុត្តកា** សេចក្តីថា ការបន្តគ្នាមក របស់ ព្រះរាជបុត្រនៃព្រះបាទមឃទេវៈនោះ ប្រព្រឹត្តទៅហើយយ៉ាងនេះ គឺព្រះរាជបុត្រ

និងចៅបន្តៗ គ្នាទៅ ។ បទថា **បច្ឆិមកោ អហោសិ** ( ព្រះបាទនិមិជាអន្គចុងក្រោយ ) សេចក្ដីថា ក្សត្រអន្គចុងក្រោយ ដែលបានបព្វជ្ជាហើយ ។ បានឮថា ព្រះពោធិសត្វទ្រង់កើតក្នុងព្រហ្មលោកហើយ ទ្រង់ប្រមើលមើលថា កល្យាណវត្តដែលអញតាំងទុកក្នុងមនុស្សលោកនោះ នៅប្រព្រឹត្តទៅឬទេហ្ន៎ ដូច្នេះ ទ្រង់ក៏ឃើញថា នៅប្រព្រឹត្តទៅអស់កាលយូរ មានប្រមាណប៉ុណ្ណេះ តែឥឡូវនេះ មិនប្រព្រឹត្តទៅ ហើយព្រះអន្គទ្រង់ព្រះតម្រិះថា អញនឹងមិនឲ្យវង្សរបស់អញដាច់ ដូច្នេះ ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះរាជា ដែលកើតក្នុងវង្សរបស់ខ្លួន ទ្រង់មកកើតបន្តបវេណីនៃវង្សរបស់ខ្លួន ។ ដោយហេតុនោះឯង ទើបព្រះរាជកុមារនោះទ្រង់ព្រះនាមថា និមិ ។

ដោយប្រការដូច្នេះ ទើបព្រះរាជានោះជាព្រះរាជាចុងក្រោយបង្អស់របស់ព្រះរាជាដែលចេញបួសហើយ ។

បុគ្គលដែលចេញបួសចុងក្រោយ ទើបមានដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត កាលពោលដោយគុណ ក៏មានគុណដ៏ច្រើន តែគុណដែលក្រៃលែងជាងព្រះរាជាគ្រប់អន្គរបស់ព្រះបាទនិមិរាជនោះមាន ២ ប្រការ គឺព្រះអន្គទ្រង់លះទ្រព្យក្នុងទ្វារទាំង ៤ ទ្វារនីមួយៗ មួយសែនរាល់ថ្ងៃ និងទ្រង់ហាម បុគ្គលដែលមិនបានរក្សាឧបោសថចូលគាល់ ។ គឺកាលបុគ្គលដែលមិនបានរក្សាឧបោសថតាំងចិត្តថា អញនឹងចូលគាល់ព្រះរាជា ទើបទៅហៅនាយឆ្មាំទ្វារសួរថា លោករក្សាឧបោសថ ឬមិនបានរក្សា ។ បុគ្គលណាមិនបានរក្សាឧបោសថ ក៏ឃាត់បុគ្គលនោះថា ព្រះរាជាទ្រង់មិនឲ្យអ្នកដែលមិនរក្សាឧបោសថ

ចូលគាល់ឡើយ ។ ក្នុងបុគ្គលទាំងនោះ មិនមានឱកាសដែលនឹងពោលថា ពួកខ្ញុំទាំងឡាយជាអ្នកជនបទ នឹងបានភោជនក្នុងកាលណា ដូច្នេះខ្លះ ។ ពិតហើយ ម្ចាស់ក្ជាក់ងារតាក់តែងប្រុងប្រៀបពាងកត្តុទុកច្រើនពាន់ ត្រង់ទ្វារទាំង ៤ និងត្រង់លានព្រះរាជវាំង ។ ព្រោះដូច្នោះ មហាជនកោរពុកមាត់ ងូតទឹកផ្លាស់សំពត់បរិភោគភោជនតាមគាប់ចិត្ត ក្នុងទីដែលត្រូវការហើយ រួចអធិដ្ឋានអង្គឧបោសថ ទៅកាន់ទ្វារព្រះរាជវាំងបាន ។ កាលនាយទ្វារសួរហើយថា លោករក្សាឧបោសថឬ ក៏ឆ្លើយថា អើ ខ្ញុំរក្សា ដោយហេតុនោះឯង ទើបនាយទ្វារពោលថា ចូលមកចុះ ហើយនាំទៅកាន់ទ្វារព្រះរាជវាំង ។ ព្រះបាទនិមិរាជទ្រង់មានព្រះគុណធំជាង ដោយគុណទាំង ២ ប្រការនោះ ដោយប្រការដូចពោលមកនេះ ។

[ ២១៩ ] បទថា **ទេវានំ តាវត្តឹសានំ** សេចក្តីថា ពួកទេវតាដែលកើតក្នុងតាវត្តិង្ស ។ បានឮថា ទេវតាទាំងនោះតាំងនៅ ក្នុងឱវាទរបស់ព្រះរាជាដែលសោយរាជ្យក្នុងនគរមិថិលា ក្នុងវិទេហរដ្ឋ រក្សាបញ្ចសីល ធ្វើឧបោសថកម្ម ទើបទៅកើតក្នុងជាន់នោះ ពោលសរសើរគុណរបស់ព្រះរាជា ។ ពាក្យថា ពួកទេវតាជាន់តាវត្តិង្ស លោកពោលសំដៅយកទេវតាទាំងនោះ ។

[ ២២០ ] បទថា **និសិន្នោ ហោតិ** សេចក្តីថា ព្រះរាជាទ្រង់ឡើងកាន់ប្រាសាទដ៏ប្រសើរជាន់លើ ប្រថាប់គង់ពិចារណាមើលទាន និងសីល បានឮថា ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ទានធំជាងសីល ឬសីលធំជាងទាន បើទានធំជាង អញនឹងជួទក្នុងទានតែម្យ៉ាង បើសីលធំជាង អញនឹងបំពេញសីលតែ

ម្យ៉ាង កាលព្រះអង្គមិនអាចសម្រេចព្រះទ័យបានថា របស់នេះធំ របស់នេះធំ សក្កទេវរាជយាងមកប្រាកដចំពោះមុខ ។ ដោយហេតុនោះ ទើបលោកពោលទុកថា **អថ ខោ អានន្ទ ។បេ។ សម្មុខេ បាតុរហោសិ** ដូច្នេះ ។ បានឮថា សក្កទេវរាជ ត្រិះរិះយ៉ាងនេះថា ព្រះរាជាកើតសេចក្តីសង្ស័យឡើង ដើម្បីកាត់សេចក្តីសង្ស័យរបស់ព្រះអង្គ អញនឹងឆ្លើយបញ្ហា នឹងកាន់យកប្តេជ្ញាដើម្បីមកក្នុងទីនេះ ព្រោះដូច្នោះ ទើបមកប្រាកដចំពោះមុខ ។ ព្រះរាជាទ្រង់ឃើញរូបដែលមិនធ្លាប់ឃើញ ក៏ទ្រង់កើតសេចក្តីខ្លាច ព្រះលោមាក៏បះ ។ ពេលនោះសក្កទេវរាជត្រាស់នឹងព្រះរាជាថា ទ្រង់កុំខ្លាចឡើយមហារាជ សួរមកចុះ ខ្ញុំនឹងវិសជ្ជនាថ្វាយ បន្ទោបង់នូវសេចក្តីសង្ស័យរបស់ព្រះអង្គឲ្យ ដូច្នេះ ។ ព្រះរាជាត្រាស់សួរបញ្ហាថា ។

បពិត្រមហារាជ ជាធំជាងសព្វសត្វ ខ្ញុំសូមសួរព្រះអង្គ ទាន ១ ព្រហ្មចរិយៈ គឺសីល ១ មួយណាមានផលច្រើនជាង ។

សក្កទេវរាជត្រាស់ថា ឈ្មោះថា ទាន ធំដូចម្តេច សីលប៉ុណ្ណោះធំ ព្រោះជាគុណដ៏ប្រសើរបំផុត បពិត្រមហារាជ ខ្ញុំបានឲ្យទានដល់ជដិលមួយម៉ឺននាក់អស់មួយម៉ឺនឆ្នាំ ក្នុងកាលមុន គង់មិនផុតអំពីបេតវិស័យ តែបុគ្គលដែលមានសីល បរិភោគទានរបស់ខ្ញុំ បានទៅកើតក្នុងព្រហ្មលោក ដូច្នេះ ហើយត្រាស់គាថាដូចតទៅនេះ

បុគ្គលកើតក្នុងត្រកូលក្សត្រិយ៍ ដោយព្រហ្មចរិយថោកទាប ដល់នូវភាពជាទេវតា ដោយព្រហ្មចរិយជាកណ្តាល បរិសុទ្ធស្អាតដោយព្រហ្មចរិយ ខ្ពង់ខ្ពស់

ពួកអ្នកបួសប្រព្រឹត្តតបទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនោះ បុគ្គលអ្នកប្រកបដោយការសូម ណាមួយ មិនងាយបានសោះទេ ។

សក្កទេវរាជ ទ្រង់បន្ទោបង់សេចក្ដីសង្ស័យរបស់ព្រះរាជាយ៉ាងនេះហើយ កាលនឹងឲ្យកាន់យកប្បដ្ឋា ដោយការយាងទៅកាន់ទេវលោក ទើបត្រាស់ថា **លាភា វត មហារាជ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **អវិកម្បមានោ** សេចក្ដីថា ទ្រង់មិនក្រែងខ្លាច ។ បទថា **អធិវាសេសិ** សេចក្ដីថា ព្រះរាជាទ្រង់ទទួលអារាធនាហើយ ដោយព្រះតម្រាស់ថា ខ្ញុំបបួលមហាជនឲ្យបំពេញកុសល ឯខ្ញុំបានមកឃើញលំនៅរបស់លោកអ្នកមានបុណ្យទាំងឡាយហើយ អាចដើម្បីពោលបានងាយ ក្នុងទីកដីនៃមនុស្ស ដូច្នេះ ។

[ ២២១ ] បទថា **ឯវំ ភទ្ទន្តវា** សេចក្ដីថា មាតលីទេវបុត្រទូលថា ព្រះតម្រាស់របស់ព្រះអង្គ ចម្រើនពិតហ្ន៎ ខ្ញុំនឹងធ្វើយ៉ាងនោះ ។ បទថា **យោជេត្វា** សេចក្ដីថា ទឹមដោយសេះអាជានេយ្យ ១០០០ ក្នុងសម័យនោះដោយពិត ។ តែកិច្ចដែលគប្បីប្រកបចំពោះចំណែក មួយរបស់រថទាំងនោះ មិនមាន រមែងអាស្រ័យចិត្តប្រកបហើយនោះឯង ។ ឯទិព្វរថនោះធំ បណ្ដោយដល់ទៅ ១៥០ យោជន៍ ។ ពីខ្សែដល់តួរទេះ ៥០ យោជន៍ តួរទេះ ៥០ យោជន៍ ហួសតួរទេះទៅក្រោយ ៥០ យោជន៍ ចំណែកនៃរទេះប្រកបដោយរតនៈមានពណ៌ ៧ ។ ខ្ពស់ប្រៀបធៀបនឹងទេវលោក ទាបស្មើនឹងមនុស្សលោក ព្រោះដូច្នោះ មិនគប្បីកំណត់ថា បញ្ឆារថឲ្យបែរមុខទៅខាងក្រោម ។ ប្រៀប

ដូចបញ្ឆោទៅកាន់ផ្លូវដើរតាមប្រក្រតី យ៉ាងណា លុះពួកមនុស្សទទួលទានបាយក្នុងវេលាល្ងាចឆ្អែតស្រេចហើយ បញ្ឆោទៅធ្វើ ឲ្យជាគូជាមួយព្រះចន្ទ ដូច្នោះនោះឯង ។ ប្រៀបដូចព្រះចន្ទដែលរះឡើង ២ ដួង ដូច្នោះ ។ មហាជនឃើញហើយ នាំគ្នាពោលថា ព្រះចន្ទរះ ២ ហ្ន៎ ។ លុះចូលជិតមក ទើបដឹងថា មិនមែនព្រះចន្ទ ២ ជាវិមាន វិមានមួយ លុះចូលមកជិតទៀតទើបដឹងថា មិនមែនវិមានមួយ តែជារថមួយ ។ សូម្បីរថនោះចូលមកជិតហើយ ក៏ជារថតាមធម្មតានោះឯង សូម្បីសេះក៏មានប្រមាណប៉ុនសេះតាមធម្មតានោះឯង ។ កាលនាំរថមកដោយអាការយ៉ាងនេះហើយ ធ្វើប្រទក្សិណប្រាសាទ របស់ព្រះរាជាហើយបែររថទៅត្រង់សីហបញ្ជរទិសខាងកើត ធ្វើឲ្យបែរមុខទៅផ្លូវដែលសេះមក បញ្ឈប់រថត្រង់សីហបញ្ជរ យាងព្រះរាជាថា បពិត្រមហារាជ សូមព្រះអង្គឡើងគង់ចុះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ទិព្វយាន អញបានហើយ ទើបទ្រង់មិនឡើងភ្លាមៗ ។ តែទ្រង់ប្រទានឱវាទដល់អ្នកនគរថា មើលចុះ អ្នកទាំងឡាយសក្កទេវរាជ ទ្រង់យករថមកទទួលយើងនោះ ព្រះអង្គមិនបានបញ្ជូនមក ព្រោះអាស្រ័យជាតិ និងគោត្រ ឬត្រកូល និងប្រទេស តែព្រោះទ្រង់ជ្រះថ្លាក្នុងគុណគឺសីលាចារវត្តរបស់យើង ទើបបញ្ជូនមក បើពួកអ្នកទាំងឡាយរក្សាសីល ក៏គង់នឹងបញ្ជូនមកដល់អ្នកទាំងឡាយ ឈ្មោះថា សីលនេះ សមគួរហើយ ដើម្បីរក្សា យើងមិនបានទៅកាន់ទេវលោក ចូរអ្នកទាំងឡាយ ជាអ្នកមិនប្រមាទចុះ ។ ទ្រង់ទូន្មានមហាជនឲ្យតាំងនៅក្នុងសីល ៥ ហើយ ទើបយាងឡើងរថ ។

បន្ទាប់អំពីនោះ មាតលីសារថីបង្ហាញផ្លូវ ២ ក្នុងអាកាស គិតថា សូម្បីអញ ក៏នឹងធ្វើការសមគួរដល់មហារាជ ទើបពោលពាក្យជាដើមថា **អបិច មហារាជ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **កតមេន** សេចក្តីថា បពិត្រមហារាជ ក្នុងបណ្តាផ្លូវទាំងនេះ ផ្លូវមួយទៅនរក ផ្លូវមួយទៅស្ថានសួគ៌ ខ្ញុំនឹងនាំព្រះអង្គទៅផ្លូវណា ក្នុងផ្លូវទាំងនោះ ។ បទថា **យេន** សេចក្តីថា ទៅហើយដោយផ្លូវណា សត្វទាំងឡាយធ្វើកម្មដ៏លាមក រមែងសោយផលនៃកម្មដ៏លាមកក្នុងទីណា ខ្ញុំរមែងអាចដើម្បីឃើញទីនោះ ។ ក្នុងបទទី ២ ក៏មានន័យដូច្នេះ ។ សេចក្តីនៃគាថាក្នុងជាតក ដូច្នេះថា

បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំ នាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុន ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន ដូច្នេះ ។

ព្រោះហេតុនោះ ទើបព្រះបាទនិមិរាជត្រាស់ថា

ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វ អ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញឋាននៃសត្វ អ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន ។

បទថា **ឧភយេនេវ មំ** សេចក្តីថា ម្នាលមាតលី អ្នកចូរនាំខ្ញុំទៅដោយផ្លូវទាំង ២ ខ្ញុំប្រាថ្នានឹងឃើញនរក សូម្បីទេវលោកក៏ចង់ឃើញ ។ ខ្ញុំនឹងនាំព្រះអង្គទៅផ្លូវណាមុន ។ ចូរនាំទៅដោយផ្លូវនរកមុន លំដាប់នោះ ទើបមាតលិសម្តែងមហានរក ១៥ រណ្តៅ ដល់ព្រះរាជា ដោយអានុភាពរបស់ខ្លួន ។ ក្នុងសេចក្តីនេះ មានវាចាដោយពិស្តារ គប្បីជ្រាបតាមន័យដែលពោល ទុកក្នុងជាតកថា

មាតលិទេវសារថី បង្ហាញព្រះរាជា នូវស្ទឹងឈ្មោះ វេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបដោយទឹកផ្សាប្រៃកំពុងពុះ ក្តៅដូចអណ្តាតភ្លើង ។

មាតលីសារថី កាលបង្ហាញនរកហើយ ក៏បង្វិលរថ មានមុខឆ្ពោះទៅកាន់ទេវលោក កាលបង្ហាញវិមានទាំងឡាយរបស់ទេពធីតា ឈ្មោះភរណី និងគណៈទេវបុត្រ មានសោណទិន្នជាប្រធាន ទើបនាំទៅកាន់ទេវលោក ។ សូម្បីក្នុងសេចក្តីនោះ ក៏គប្បីជ្រាបពាក្យដោយពិស្តារក្នុងន័យដែលពោលទុក ក្នុងជាតកនោះឯងថា

មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលទ្រង់មិនជ្រាបថា ពិរណី ដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសីកើតក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ក្នុងជីវលោក នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវមានកាលដល់ហើយ ( ហើយក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ ) ហាក់ដូចជាមាតា ដែលត្រេកអរចំពោះបុត្តរបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន ។

កាលព្រះពោធិសត្វយាងទៅយ៉ាងនេះ គ្រាន់តែកង់រថប៉ះធរណីទ្វារ ចិត្តកូដទេវនគរ ក៏មានកោលាហល ពួកទេវតានាំគ្នាបោះបង់សក្កទេវរាជឲ្យនៅតែមួយព្រះអង្គឯង បានធ្វើការស្វាគមន៍ព្រះពោធិសត្វ ។ សក្កទេវរាជ ឃើញព្រះមហាសត្វមកដល់ហើយ កាលទ្រង់មិនអាចតម្កល់ព្រះទ័យបាន ទើបត្រាស់ថា បពិត្រមហារាជ សូមព្រះអង្គទ្រង់សោយសុខក្នុងទេវលោកទាំងឡាយ

ដោយទេវានុភាពចុះ បានឮថា សក្កទេវរាជនោះ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ព្រះរាជានេះយាងមកក្នុងថ្ងៃនេះហើយ ទ្រង់ធ្វើពួកទេវតាឲ្យនៅព្រមចំពោះមុខខ្លួនត្រឹមមួយថ្ងៃប៉ុណ្ណោះ បើនៅប្រថាប់អស់ ១ ថ្ងៃ ២ ថ្ងៃ ពួកទេវតា ក៏នឹងមិនសម្លឹងមើលអញ ដូច្នេះ ។ សក្កទេវរាជនោះ ទ្រង់ប្រណែនទើបត្រាស់យ៉ាងនោះ ដោយព្រះបំណងនេះ ដោយពាក្យថា បពិត្រមហារាជការដែលព្រះអង្គនៅក្នុងទេវលោកនេះ នឹងមិនមានបុណ្យ សូមព្រះអង្គនៅប្រថាប់ដោយបុណ្យរបស់ពួកអ្នកដទៃចុះ ។ ព្រះពោធិសត្វ កាលទ្រង់បដិសេធថា បពិត្រសក្កៈ ខ្ញុំមិនអាចស្ថិតនៅបាន ព្រោះអាស្រ័យអ្នកដទៃ ដូចជាកណ្ឌៈដែលបានមកព្រោះខ្ចីគេ ដូច្នោះទើបត្រាស់ថា ណេ្ហយចុះ លោកនិទ្ទិក្ខ ដូច្នេះជាដើម ។ សូម្បីក្នុងជាតក លោកក៏ពោលទុកថា

វត្ថុណាដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យ ដូចយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនោះក៏មានឧបមេយ្យយ៉ាងនោះឯង ។

បណ្ឌិតគប្បីសម្តែងតាមន័យដែលពោលទុកហើយក្នុងនេមិរាជជាតកនោះឯង ។ សួរថា ព្រះពោធិសត្វទ្រង់យាងទៅកាន់ទេវលោក ដោយអត្តភាពជាមនុស្សប៉ុន្មានដង ឆ្លើយថា ៤ ដង គឺកាលសោយព្រះជាតិ ជាព្រះបាទមន្ធាតុរាជម្តង កាលសោយព្រះជាតិជាព្រះបាទសាធិនៈម្តង កាលសោយព្រះជាតិជាគុត្តិលវីណាវាទកព្រាហ្មណ៍ម្តង កាលសោយព្រះជាតិ ជាព្រះបាទនិមិម្តង ។ កាលសោយព្រះជាតិជាព្រះបាទមន្ធាតុ ទ្រង់ប្រថាប់នៅក្នុងទេវលោកអស់មួយអសង្ខេយ្យឆ្នាំ ព្រះអង្គប្រថាប់នៅក្នុងទេវលោកនោះ សក្កទេវរាជចុតិអស់ ៣៦ អង្គ ។ កាលសោយព្រះជាតិជាព្រះបាទសាធិនរាជ នៅ

ប្រថាប់មួយសប្តាហ៍ ។ ដោយការរាប់ឆ្នាំមនុស្សស្មើនឹង ៧០០ ឆ្នាំ ។ កាលនៅជា គុត្តិលវីណាវាទកៈ និងកាលនៅជាព្រះបាទនិមិរាជនៅប្រថាប់ត្រឹមមួយរយៈ ដោយការរាប់ថ្ងៃគឺ ៧ ថ្ងៃមនុស្ស ។ បទថា **តត្ថេវ មិថិលំ បដិនេសិ** សេចក្តីថា មាតលីសារថីបាននាំមកប្រតិស្ឋានទុកក្នុងទីដ៏មានសិរីដូចមុននោះឯង ។

[ ២២៤ ] បទថា **កឡារជនកោ** ជាឈ្មោះរបស់ព្រះរាជបុត្រនោះ ។ ម្យ៉ាងទៀត ជនទាំងឡាយពោលថាកឡារជនក ព្រោះមានធ្មេញក្រហមកើតឡើង ។ ពាក្យថា ព្រះរាជកុមារនោះមិនបានយាងចេញអំពីព្រះរាជនិវេសន៍បួសឡើយ សេចក្តីថា ព្រះអង្គបានត្រាស់ពាក្យមានប្រមាណប៉ុណ្ណេះ ។ ពាក្យដ៏សេសទាំងអស់បានប្រាកដដូចមុននោះឯង ។ ក្នុងបទថា **សមុច្ឆេទោ ហោតិ** នេះ គប្បីជ្រាបវិភាគដូច្នេះថា បុគ្គលណាកាត់កល្យាណវត្តឲ្យដាច់សូន្យទៅ កាត់ព្រោះហេតុអ្វី បុគ្គលណាឲ្យប្រព្រឹត្តទៅ បុគ្គលណាឈ្មោះថាឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងសេចក្តីនោះ ភិក្ខុដែលមានសីល កាលមិនធ្វើសេចក្តីព្យាយាមដោយគិតថា អញមិនអាចបានអរហត្តឈ្មោះថា រមែងកាត់ ។ កល្យាណវត្តរមែងឈ្មោះថា បុគ្គលទ្រុស្តសីលកាត់ហើយ ។ ព្រះសេក្ខបុគ្គលទាំង ៧ រមែងឲ្យប្រព្រឹត្តទៅ ។ ព្រះខីណាស្រពឈ្មោះថាឲ្យប្រព្រឹត្តទៅហើយ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្ទើងាយយល់ទាំងអស់ហើយ ។ ៚

**អដ្ឋកថា មឃទេវសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## មធុរសូត្រទី ៤

[ ២២៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមហាកច្ចានមានអាយុសម្រាន្តឥរិយាបថនៅក្នុងគុន្ធាវ័ន ទៀបក្រុងមធុរា ។ ព្រះបាទមធុររាជអវន្តិបុត្ត បានឮដំណឹងថា ម្នាលគ្នាយើងដ៏ចម្រើន សមណៈឈ្មោះ កច្ចានៈឥឡូវនេះគង់នៅក្នុងគុន្ធាវ័ន ទៀបក្រុងមធុរា កត្តិសព្ទដ៏ប្រពៃយ៉ាងនេះ របស់ព្រះកច្ចានៈដ៏ចម្រើននោះឯង តែងផ្សាយទៅសព្វទិសថា លោកជាបណ្ឌិតឈ្លាសវៃ មានបញ្ញា ជាពហុស្សូត មានសម្តីដ៏វិចិត្រ មានបញ្ញាដ៏ល្អ ជាអ្នកចាស់ព្រឹទ្ធាផង ជាព្រះអរហន្តផង កាលបានឃើញព្រះអរហន្ត មានសភាពយ៉ាងនោះ ជាការញុំាងប្រយោជន៍ឲ្យសម្រេចដោយពិត ។ គ្រានោះ ព្រះបាទមធុរាជអវន្តិបុត្ត ទ្រង់ឲ្យរៀបចំយានទាំងឡាយ ដែលល្អៗ ទ្រង់ឡើងគង់យានដែលល្អៗ ហើយទ្រង់ស្តេចចេញចាកក្រុងមធុរា ដោយយានទាំងឡាយដែលល្អៗ ដើម្បីជួបនឹងព្រះមហាកច្ចានៈមានអាយុ ដោយរាជានុភាពដ៏ធំ ទ្រង់ស្តេចទៅដោយយាន កំណត់ត្រឹមផែនដី ដែលបរយានទៅបាន ហើយទ្រង់យាងចុះអំពីយាន ទ្រង់ព្រះដំណើរទៅដោយព្រះបាទា ចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយ នឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏គង់នៅក្នុងទីដ៏សមគួរ ។ ព្រះបាទមធុរាជអវន្តិបុត្ត លុះគង់នៅក្នុងទីដ៏សមគួរហើយមានព្រះបន្ទូលពាក្យនេះ នឹងព្រះមហាកច្ចានមានអាយុ

ថា បពិត្រព្រះកច្ចានៈដ៏ចម្រើន ពួកព្រាហ្មណ៍ នាំគ្នាពោលយ៉ាងនេះថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណទាប ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍ មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្តរបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ សេចក្តីនេះព្រះកច្ចានៈដ៏ចម្រើន នឹងពោលដូចម្តេចទៅវិញ ។

[ ២២៦ ] ព្រះមហាកច្ចានៈថ្វាយព្រះពរថា បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណទាប ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្តរបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម ។ មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមរតករបស់ព្រហ្ម ដូច្នេះ បពិត្រមហារាជ ឯសំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុ៎ះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច បើក្សត្រិយ៍គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយព្រទ្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើក្សត្រិយ៍ ( ដទៃ ) គប្បីជាអ្នកតើនឡើងមុន ផ្ទុំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឬទេ ។ ព្រាហ្មណ៍ក្តី...

វេស្សក្តី.... សុទ្ទៈក្តី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃ ក្សត្រិយ៍នោះ ឬទេ ។ ព្រះបាទមធុររាជត្រាស់ថា បពិត្រព្រះកច្ចានៈដ៏ចម្រើន បើក្សត្រិយ៍គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ក្សត្រិយ៍ ( ដទៃ ) ក៏ជាអ្នកត្រូវតើនឡើងមុន ផ្ទុំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឯង ។ ព្រាហ្មណ៍ក្តី... វេស្សក្តី... សុទ្ទក្តី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃក្សត្រិយ៍នោះឯង ។

[ ២២៧ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច បើព្រាហ្មណ៍គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើព្រាហ្មណ៍ ( ដទៃ ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីគាប់ចិត្ត នៃព្រាហ្មណ៍នោះ ឬទេ ។ វេស្សក្តី... សុទ្ទក្តី... ក្សត្រិយ៍ក្តី គប្បីជាអ្នកតើនឡើងមុន ផ្ទុំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃព្រាហ្មណ៍នោះឬទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន បើព្រាហ្មណ៍គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស ព្រាហ្មណ៍ ( ដទៃ ) ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃ

ព្រាហ្មណ៍នោះឯង ។ វេស្សក្តី... សុទ្ទក្តី... ក្សត្រិយ៍ក្តី ក៏ជាអ្នកត្រូវតើនឡើងមុន ផ្ទំក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃព្រាហ្មណ៍នោះឯង ។

[ ២២៨ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច បើវេស្ស គប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើវេស្សៈ ( ដទៃ ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់នៃវេស្សនោះឬទេ ។ សុទ្ទក្តី... ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សនោះឬទេ ។ បពិត្រព្រះកច្ចានៈ ដ៏ចម្រើន បើវេស្សគប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស វេស្សៈ ( ដទៃ ) ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឯង ។ សុទ្ទៈក្តី... ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឯង ។

[ ២២៩ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច បើសុទ្ទៈគប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស តើសុទ្ទៈ ( ដទៃ ) គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ

ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃសុទ្ទៈនោះឬទេ ។ ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី... វេស្សក្តី គប្បីជាអ្នកក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃវេស្សៈនោះឬទេ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន បើសុទ្ទៈគប្បីសម្រេច ( ឥទ្ធានុភាព ) ដោយទ្រព្យ ដោយស្រូវ ដោយប្រាក់ ឬដោយមាស សុទ្ទៈ ( ដទៃ ) ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃសុទ្ទៈនោះឯង ។ ក្សត្រិយ៍ក្តី... ព្រាហ្មណ៍ក្តី... វេស្សក្តី ក៏ជាអ្នកត្រូវក្រោកឡើងមុន ដេកក្រោយ ទទួលស្តាប់ការអ្វីៗ ប្រព្រឹត្តអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ នៃសុទ្ទៈនោះឯង ។

[ ២៣០ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្តេច ក្នុងវណ្ណៈទាំង ៤ នោះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ពិតមែនណាស់ហើយ កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នាទេ ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នោះឡើយ ។

[ ២៣១ ] បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនោះអ្នកប្រាជ្ញគប្បីដឹង

ដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះ ដូចម្ដេច សត្វក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាញុះញង់ ជាអ្នកមានវាចាទ្រគោះ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានសេចក្ដីលោភជាប្រក្រតី ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមានសេចក្ដីឃើញខុស លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នឹងនរក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្ដេចក្នុងរឿងនោះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន សូម្បីក្សត្រិយ៍ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាអ្នកពោលពាក្យកុហក ជាអ្នកមានវាចាញុះញង់ ជាអ្នកមានវាចាទ្រគោះ ជាអ្នកពោលពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមានសេចក្ដីលោភជាប្រក្រតី ជាអ្នកមានចិត្តព្យាបាទ ជាអ្នកមានសេចក្ដីឃើញខុស លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ខ្ញុំមានសេចក្ដីយល់ឃើញយ៉ាងនេះ ក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយយ៉ាងនេះឯង ។

[ ២៣២ ] បពិត្រមហារាជ ត្រូវហើយៗ បពិត្រមហារាជ រឿងនោះ ព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃហើយ មួយទៀត ពាក្យនោះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គ

សម្គាល់សេចក្ដីនោះដូចម្ដេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ។បេ។ ជាអ្នកមានសេចក្ដីឃើញខុស លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្ដេចក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន សូម្បីសុទ្ទៈជាអ្នកសម្លាប់សត្វ ជាអ្នកលួចទ្រព្យគេ ។បេ។ ជាអ្នកមានសេចក្ដីឃើញខុស លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ និងនរក ខ្ញុំមានសេចក្ដីយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

[ ២៣៣ ] បពិត្រមហារាជ ត្រូវហើយៗ បពិត្រមហារាជ រឿងនុ៎ះព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គ បានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ ដូចម្ដេចក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា មិនមែនមិនស្មើគ្នាទេ ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួចក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

[ ២៣៤ ] បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុង

លោកថា ពួកព្រាហ្មណ៍ជាវណ្ណខ្ពស់ ជនដទៃជាវណ្ណៈទាប ។បេ។ ជាអ្នកទទួលមត៌ក របស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច សត្វក្នុងលោកនេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ វៀរចាកពាក្យកុហក វៀរចាកវាចាញុះញង់ វៀរចាកវាចាទ្រគោះ វៀរចាកពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមិនមានសេចក្តីលោភជាប្រក្រតី ជាអ្នកមានចិត្តមិនព្យាបាទ ជាអ្នកមានសេចក្តីឃើញត្រូវ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈគប្បីទៅកើត ក្នុងសុគតិសួគ៌ទេវលោក ឬមួយមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់ឃើញដោយប្រការដូចម្តេចក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន សូម្បីក្សត្រិយ៍ ដែលវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ វៀរពាក្យកុហក វៀរចាកវាចាញុះញង់ វៀរចាកវាចាទ្រគោះ វៀរចាកពាក្យរោយរាយឥតប្រយោជន៍ ជាអ្នកមិនមានសេចក្តីលោភជាប្រក្រតី ជាអ្នកមានចិត្តមិនព្យាបាទ ជាអ្នកមានសេចក្តីឃើញត្រូវ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះ មួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

[ ២៣៥ ] បពិត្រមហារាជ ត្រូវហើយៗ បពិត្រមហារាជ រឿងនោះព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮ

អំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ ដែលវៀរចាកការសម្លាប់សត្វ ។បេ។ ជាអ្នកមានសេចក្ដីឃើញត្រូវ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ឬមិនទៅកើតទេ ឬក៏ព្រះអង្គទ្រង់យល់ឃើញដោយប្រការដូចម្ដេចក្នុងរឿងនុ៎ះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន សូម្បីសុទ្ទៈដែលវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ ។បេ។ ជាអ្នកមានសេចក្ដីឃើញត្រូវ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ គប្បីទៅកើតក្នុងសុគតិសួគ៌ទេវលោក ខ្ញុំមានសេចក្ដីយល់ឃើញយ៉ាងនេះក្នុងរឿងនុ៎ះមួយទៀត ពាក្យនុ៎ះខ្ញុំបានឮមកអំពីព្រះអរហន្តទាំងឡាយ យ៉ាងនេះឯង ។

[ ២៣៦ ] បពិត្រមហារាជ ត្រូវហើយៗ បពិត្រមហារាជ រឿងនុ៎ះ ព្រះអង្គយល់ឃើញយ៉ាងនេះ ជាការប្រពៃ មួយទៀត ពាក្យនុ៎ះព្រះអង្គបានឮអំពីព្រះអរហន្តទាំងឡាយ ក៏ជាការប្រពៃ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្ដេចក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណស្មើៗគ្នាពិតមែន ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

[ ២៣៧ ] បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុង

លោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្ម ដូច្នេះ ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច សត្វក្នុងលោកនេះ កាត់ជញ្ជាំងផ្ទះរបស់គេក្តី ប្លន់គេក្តី ធ្វើអំពើបៀតបៀនយកទ្រព្យរបស់ក្នុងផ្ទះ តែមួយក្តី ចាំស្ទាក់ផ្លូវក្តី សេពកិរិយារបស់គេក្តី បើបុរសទាំងឡាយចាប់ក្សត្រិយ៍នោះបានហើយ នាំយកមកថ្វាយព្រះអង្គថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍នេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តនូវអំពើអាក្រក់ បើព្រះអង្គប្រាថ្នានឹងដាក់ព្រះរាជអាជ្ញាណា សូមទ្រង់ដាក់ព្រះរាជអាជ្ញានោះ ដល់ចោរនេះចុះ តើព្រះអង្គគប្បីធ្វើនូវក្សត្រិយ៍នោះដូចម្តេចទៅ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន យើងខ្ញុំគប្បីសម្លាប់ក៏បាន ពុះរះក៏បាន បណ្តេញចេញក៏បាន ធ្វើឲ្យសមគួរតាមហេតុក៏បាន ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈដ៏ចម្រើន ព្រោះថា ឈ្មោះណាដែលគេហៅថាក្សត្រិយ៍ដូច្នេះអំពីមុន ឈ្មោះរបស់ក្សត្រិយ៍នោះក៏បាត់ទៅហើយ ឥឡូវនេះ ក្សត្រិយ៍នោះ ដល់នូវឈ្មោះថាជាចោរវិញ ។

[ ២៣៨ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ គប្បីកាត់នូវជញ្ជាំងផ្ទះរបស់គេក្តី ប្លន់គេក្តី ធ្វើអំពើបៀតបៀនយកទ្រព្យរបស់ក្នុងផ្ទះតែមួយក្តី ចាំស្ទាក់ផ្លូវក្តី សេពកិរិយារបស់គេក្តី បើបុរសទាំងឡាយចាប់សុទ្ទៈនោះបានហើយ នាំយកមកថ្វាយព្រះអង្គថា បពិត្រព្រះសម្មតិទេព សុទ្ទៈនេះជាចោររបស់ព្រះអង្គ ជាអ្នកប្រព្រឹត្តនូវអំពើអាក្រក់ បើព្រះអង្គប្រាថ្នានឹង

ដាក់ព្រះរាជអាជ្ញាណា សូមទ្រង់ដាក់ព្រះរាជអាជ្ញានោះ ដល់ចោរនេះចុះ តើព្រះអង្គគប្បីធ្វើនូវចោរនោះដូចម្តេចទៅ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន យើងខ្ញុំគប្បីសម្លាប់ក៏បាន ពុះរំពះក៏បាន បណ្តេញចេញក៏បាន ធ្វើឲ្យសមគួរតាមហេតុក៏បាន ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈ ដ៏ចម្រើន ព្រោះថាឈ្មោះណាដែលគេហៅថាសុទ្ទៈដូច្នេះអំពីមុន ឈ្មោះរបស់សុទ្ទៈនោះ ក៏បាត់ទៅហើយ ឥឡូវនេះ សុទ្ទៈនោះដល់នូវឈ្មោះថាជាចោរវិញ ។

[ ២៣៩ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្តេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះជាវណ្ណៈស្មើៗគ្នាពិតមែន ខ្ញុំមិនឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

[ ២៤០ ] បពិត្រមហារាជ សំឡេងសុសសាយនេះ តែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ។បេ។ ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុ៎ះអ្នកប្រាជ្ញគប្បីដឹងដោយបរិយាយដូចតទៅនេះ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ក្សត្រិយ៍ក្នុងលោកនេះ បើកោរសក់ ពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកពាក្យកុហក ជាអ្នក

បរិភោគកត្តតែម្តង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកមានសីល មានកល្យាណធម៌ តើព្រះអង្គគប្បីធ្វើក្សត្រិយ៍នោះដូចម្តេច ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន យើងខ្ញុំគប្បីថ្វាយបង្គំ គប្បីក្រោកឡើងទទួល គប្បីនិមន្តដោយអាសនៈ គប្បីទំនុកបម្រុងបព្វជិតនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ឬគប្បីចាត់ចែងនូវការរក្សាការពារគ្រប់គ្រងប្រកបដោយធម៌ ដល់បព្វជិតនោះ ដំណើរនោះព្រោះហេតុអ្វី បពិត្រព្រះកច្ចានៈដ៏ចម្រើន ព្រោះថា ឈ្មោះណាដែលគេហៅថា ក្សត្រិយ៍ដូច្នេះអំពីមុន ឈ្មោះរបស់ក្សត្រិយ៍នោះក៏បាត់ទៅហើយ ឥឡូវនេះ ក្សត្រិយ៍នោះដល់នូវឈ្មោះថាសមណៈវិញ ។

[ ២៤១ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះដូចម្តេច ព្រាហ្មណ៍ក្នុងលោកនេះ... វេស្សៈក្នុងលោកនេះ... សុទ្ទៈក្នុងលោកនេះ បើកោរសក់ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកពាក្យកុហក ជាអ្នកបរិភោគកត្តតែម្តង ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ មានសីល មានកល្យាណធម៌ តើព្រះអង្គគប្បីធ្វើសុទ្ទៈនោះដូចម្តេច ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ខ្ញុំគប្បីថ្វាយបង្គំ គប្បីក្រោកឡើងទទួល គប្បីនិមន្តដោយអាសនៈ គប្បីទំនុកបម្រុងបព្វជិតនោះដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ឬគប្បីចាត់ចែងនូវការរក្សាការពារ គ្រប់គ្រងដ៏ប្រកបដោយធម៌ដល់បព្វជិតនោះ ដំណើរនោះព្រោះហេតុអ្វី បពិត្រ

ព្រះកច្ចានៈដ៏ចម្រើន ព្រោះថាឈ្មោះណា ដែលគេហៅថាសុទ្ទៈអំពីមុន ឈ្មោះរបស់សុទ្ទនោះក៏បាត់ទៅហើយឥឡូវនេះសុទ្ទៈនោះដល់នូវឈ្មោះថា សមណៈវិញ ។

[ ២៤២ ] បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្ដីនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណៈស្មើៗគ្នា ឬមិនស្មើគ្នាទេ ឬក៏ព្រះអង្គទ្រង់មានព្រះយោបល់ដូចម្ដេច ក្នុងវណ្ណៈទាំង ៤ នេះវិញ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានប្រាកដហើយ វណ្ណៈទាំង ៤ នេះ ជាវណ្ណស្មើៗគ្នាពិតមែន ខ្ញុំមិនបានឃើញអំពើផ្សេងគ្នាបន្តិចបន្តួច ក្នុងវណ្ណៈទាំង ៤ នេះឡើយ ។

[ ២៤៣ ] បពិត្រមហារាជ សំឡេងសុសសាយនេះតែងប្រាកដក្នុងលោកថា ពួកព្រាហ្មណ៍ជាវណ្ណៈខ្ពស់ ជនដទៃជាវណ្ណៈទាប ពួកព្រាហ្មណ៍ជាវណ្ណៈស ជនដទៃជាវណ្ណៈខ្មៅ ពួកព្រាហ្មណ៍បរិសុទ្ធ ជនមិនមែនព្រាហ្មណ៍មិនបរិសុទ្ធឡើយ ពួកព្រាហ្មណ៍ជាបុត្តរបស់ព្រហ្ម ជាឱរសកើតអំពីព្រះឱស្ឋព្រហ្ម មានព្រហ្មជាកំណើត ព្រហ្មបានតាក់តែងឲ្យកើត ជាអ្នកទទួលមត៌ករបស់ព្រហ្មដូច្នេះ ដោយហេតុណា ហេតុនុ៎ះ អ្នកប្រាជ្ញគប្បីដឹងដោយបរិយាយនេះឯង ។

[ ២៤៤ ] កាលបើព្រះកច្ចានៈបានសម្ដែងយ៉ាងនេះហើយ ព្រះបាទមធុររាជអវន្តិបុត្ត បានពោលសេចក្ដីនេះទៅនឹងព្រះមហាកច្ចានៈដ៏មានអាយុវិញថា បពិត្រព្រះកច្ចានៈដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ពិរោះ

ណាស់ បពិត្រព្រះកច្ចានៈដ៏ចម្រើន ធម៌ដែលព្រះកច្ចានៈដ៏ចម្រើន សម្ដែងហើយ ដោយអនេកបរិយាយនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាគេកាន់ប្រទីបប្រេងទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សមានចក្ខុបានឃើញរូបទាំងឡាយ ខ្ញុំព្រះករុណានេះ សូមដល់នូវព្រះកច្ចានៈដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះកច្ចានៈដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណាថាជាឧបាសក ដល់នូវសរណៈគមន៍ស្មើដោយជីវិត ។

[ ២៨៥ ] បពិត្រមហារាជ ព្រះអង្គកុំយកអាត្មាភាព ជាទីពឹង ទីរលឹកឡើយ អាត្មាភាពដល់ព្រះមានព្រះភាគណា ជាទីពឹង ទីរលឹក សូមព្រះអង្គដល់នូវព្រះមានព្រះភាគនោះ ជាទីពឹង ទីរលឹកចុះ ។ បពិត្រព្រះកច្ចានៈដ៏ចម្រើន ចុះឥឡូវនេះ តើព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គគង់នៅក្នុងទីណា ។ បពិត្រមហារាជ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គបរិនិព្វានហើយ ។

[ ២៨៦ ] បពិត្រព្រះកច្ចានៈដ៏ចម្រើន បើប្រសិនជាយើងខ្ញុំឮដំណឹងថា ព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ១០ យោជន៍ យើងខ្ញុំគប្បីទៅកាន់ទីប្រមាណ ១០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះឲ្យបាន បពិត្រព្រះកច្ចានៈដ៏ចម្រើន បើប្រសិនជាយើងខ្ញុំឮដំណឹងថា ព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ២០ យោជន៍... ៣០

យោជន៍... ៤០ យោជន៍... ៥០ យោជន៍សោត យើងខ្ញុំគប្បីទៅកាន់ទីប្រមាណ ៥០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះឲ្យបាន បពិត្រព្រះកច្ចានៈដ៏ចម្រើន បើប្រសិនជាយើងខ្ញុំ ឮដំណឹងថាព្រះមានព្រះភាគនោះ នៅក្នុងទីប្រមាណ ១០០ យោជន៍ យើងខ្ញុំគប្បីទៅកាន់ទីប្រមាណ ១០០ យោជន៍ ដើម្បីឃើញព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះឲ្យបាន បពិត្រព្រះកច្ចានៈដ៏ចម្រើន កាលបើព្រះមានព្រះភាគអង្គនោះ ទ្រង់បរិនិព្វានហើយ យើងខ្ញុំសូមដល់នូវព្រះមានព្រះភាគ ដែលទ្រង់បរិនិព្វានហើយ ទាំងព្រះធម៌ទាំងព្រះភិក្ខុសង្ឃជាទីពឹងទីរលឹក សូមព្រះកច្ចានៈដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះករុណាថា ជាឧបាសក ដល់នូវសរណគមន៍ ស្មើដោយជីវិតចាប់ដើមតាំងអំពីថ្ងៃនេះទៅ ។

ចប់ មធុរសូត្រ ទី ៤

# អដ្ឋកថា

## មធុរសូត្រ

[ ២២៥ ] មធុរសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះ បទថា **មហាកច្ចានោ** គឺជាកូនរបស់បុរោហិតនៃព្រះបាទឧជ្ជេនី ក្នុងកាលជាគ្រហស្ថមានរូបស្អាត គួរពិតពិលរមិលមើល នាំមកនូវសេចក្ដីជ្រះថ្លា មានពណ៌សម្បុរដូចមាស ។ បទថា **មធុរាយំ** គឺក្នុងព្រះនគរមានឈ្មោះយ៉ាងនោះ ។ បទថា **គុន្ទាវនេ** គឺក្នុងព្រះរាជឧទ្យានឈ្មោះ កណ្ហកគុន្ទាវ័ន ។ បទថា **អវន្តិបុត្តោ** បានដល់ ជាបុត្រនៃព្រះរាជធីតាក្នុងអវន្តិរដ្ឋ ។ បទថា **វុឌ្ឍោ ចេវ អរហា ច** សេចក្ដីថា ជាកំលោះផង សមគួរផង គឺមិនបានសរសើរដូចមនុស្សចាស់ ដូច្នោះ ។ ឯព្រះថេរៈជាអ្នកចម្រើនផង ជាព្រះអរហន្តផង ។ បទថា **ព្រាហ្មណា ភោ កច្ចាន** សេចក្ដីថា បានឮថា ព្រះរាជានោះកាន់យកលទ្ធិព្រាហ្មណ៍ ដូច្នោះ ទើបពោលយ៉ាងនោះ ។ ក្នុងបទថា **ព្រាហ្មណាវ សេដ្ឋា វណ្ណា** លោកសម្ដែងថា ព្រាហ្មណ៍ ប៉ុណ្ណោះជាអ្នកប្រសើរបំផុត ក្នុងឋានៈដែលប្រាកដនៃជាតិ និងគោត្រជាដើម ។ បទថា **ហីនោ អញ្ញោ វណ្ណោ** សេចក្ដីថា លោកពោល វណ្ណៈ ៣ ក្រៅអំពីនេះ ថាជាវណ្ណៈថោកទាប ។ បទថា **សុក្កោ** ប្រែថា ស ។ បទថា **កណ្ហោ** ប្រែថា ខ្មៅ ។ បទថា **សុជ្ឈន្តិ** ប្រែថា បរិសុទ្ធក្នុងឋានៈ ដែលប្រាកដនៃជាតិ និងគោត្រជាដើម ។ បទថា **ព្រហ្មុនោ បុត្តា** បានដល់ កូនរបស់មហាព្រហ្ម ។ បទថា **ឱរសា មុខតោ ជាតា** សេចក្ដីថា នៅក្នុងទ្រូង ចេញមកអំពីមាត់ ឈ្មោះថា ឱរស ព្រោះ

អត្ថថា ធ្វើទុកត្រង់ទ្រូងឲ្យបម្រើនល្អហើយ ។ បទថា **ព្រហ្មជា** ប្រែថា កើតអំពីព្រះព្រហ្ម ។ បទថា **ព្រហ្មនិម្មិតា** បានដល់ មហាព្រហ្មនិម្មិតហើយ ។ បទថា **ព្រហ្មទាយាទា** គឺជាទាយាទនៃព្រហ្ម ។

[ ២៤៦ ] បទថា **យោសោយេវ ខោ ឃសោ** ត្រឹមតែជាវោហារ ។ បទថា **ឥជ្ឈេយ្យ** ប្រែថា គប្បីសម្រេច ។ ដោយអត្ថថា ប្រាថ្នាទ្រព្យជាដើម មានប្រមាណប៉ុនណា មនោរថរបស់បុគ្គលនោះ ក៏គប្បីពេញដោយទ្រព្យជាដើម មានប្រមាណត្រឹមនោះ ។ បទថា **ខត្តិយោបិស្ស** កាត់បទជា **ខត្តិយោ អបិ អស្ស** គឺជាអ្នកក្រោកឡើងមុន សម្រាប់បុគ្គល ដែលដល់នូវភាពជាធំ ។

[ ២៣០ ] បទថា **នេសំ ឃត្ថ កិញ្ចិ** សេចក្តីថា ក្នុងវណ្ណៈ ទាំង ៤ នេះ ខ្ញុំមិនឃើញផ្សេងគ្នាឡើយ ។

[ ២៤០ ] បទថា **អាសនេន វា និមន្តេយ្យាម** សេចក្តីថា គប្បីបោសអាសនៈ ដែលសម្រាប់អង្គុយហើយ និមន្តថា និមន្តអង្គុយទីនេះ ។ បទថា **អភិនិមន្តេយ្យាម វា នំ** សេចក្តីថា នាំអាសនៈនោះមកហើយ និមន្ត ។ ក្នុងការនិមន្តន៍នោះ អភិនីហារ គឺការគោរពមាន ២ យ៉ាង គឺគោរពដោយវាចាផង ដោយកាយផង ។ គឺកាលពោលថា លោកម្ចាស់មានសេចក្តីត្រូវការចីវរជាដើមណាមួយ ក៏សូមប្រាប់មកចុះ ក្នុងខណៈដែលលោកម្ចាស់ត្រូវការហើយ ដូច្នេះ ឈ្មោះថានិមន្តគោរពដោយវាចា ។ តែកាលកំណត់ឃើញវិការនៃចីវរជាដើមពោលថា សូមលោកម្ចាស់នាំចីវរមួយនេះទៅចុះប្រគេនចីវរទាំងនោះឈ្មោះថាគោរពបូជានិមន្តតាមផ្លូវកាយ ។ លោក

ពោលថា **អជិនិមន្តេយ្យាម វា តំ** ដូច្នេះ សំដៅយកការនិមន្តន៍ទាំង ២ នោះ ។ បទថា **រក្ខាវរណគុត្តឹ** បានដល់ គ្រប់គ្រង ពោលគឺរក្សា និងពោលគឺការការពារ ។ ឯការរក្សាដែលគេចាត់តាំងបុគ្គលឲ្យកាន់អាវុធ មិនឈ្មោះថា ការចាត់ចែង ប្រកបដោយធម៌ឡើយ ។ ឯការចាត់ចែង ហាមមិនឲ្យមនុស្សរកឧស និងរកស្លឹកឈើជាដើម ចូលទៅក្នុងទីដែលមិនគួរ ហាមព្រានម្រឹគជាដើម មិនឲ្យចាប់សត្វ ឬត្រីខាងក្នុងខេត្តវិហារ ឈ្មោះថា ការចាត់ចែងដែលប្រកបដោយធម៌ ។ លោកពោលថា **ធម្មិកំ** ព្រោះ សំដៅយក ការហាមនោះ ។

[ ២៤២ ] បទថា **ឯវំ សន្តេ** សេចក្តីថា កាលបព្វជិតទាំង ៤ វណ្ណៈ ស្មើគ្នា សក្ការៈថាជាអ្នកបួសមាន ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា មធុរសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ពោធិរាជកុមារសូត្រទី ៥

[ ២៤៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងភេសកលាវ័ន ជាទីឲ្យអភ័យដល់ម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ សម័យនោះឯង ពោធិរាជកុមារ ចាត់ការកសាងប្រាសាទ ឈ្មោះកោកនុទៈ ទើបតែនឹងហើយថ្មីៗ ដែលសមណព្រាហ្មណ៍ ឬបុគ្គលណាមួយ ជាតិជាមនុស្សមិនដែលធ្លាប់បាននៅអាស្រ័យ ។ លំដាប់នោះ ពោធិរាជកុមារ ទ្រង់ហៅសញ្ជិកាបុត្តមាណពមកប្រាប់ថា នែសញ្ជិកាបុត្រសម្លាញ់ អ្នកចូរមក អ្នកចូរចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះបាទយុគលព្រះមានព្រះភាគដោយត្បូង ទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពល និងធម៌ជាគ្រឿងនៅសប្បាយ តាមពាក្យអញថា បពិត្រព្រះអង្គដ៏ចម្រើន ពោធិរាជកុមារសូមថ្វាយបង្គំនូវព្រះបាទយុគលព្រះអង្គដោយត្បូង ទូលសួរ ការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួនកាយពល និងធម៌ជាគ្រឿងនៅសប្បាយ ហើយទូលយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ សញ្ជិកាបុត្តមាណព ទទួលព្រះបន្ទូល ពោធិរាជកុមារថា ព្រះករុណាវិសេស ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ

ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ២៤៨ ] សញ្ជិកាបុត្តមាណព លុះអង្គុយក្នុងទីដ៏សមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពោធិរាជកុមារ សូមថ្វាយបង្គំព្រះបាទយុគលព្រះគោតមជាម្ចាស់ដោយត្បូងក្រាបទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពល និងធម៌ជាគ្រឿងនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង សញ្ជិកាបុត្តមាណពដឹងថាព្រះមានព្រះភាគទទួលនិមន្តន៍ហើយ ក៏ក្រោកចាកអាសនៈ ចូលទៅគាល់ពោធិរាជកុមារ លុះចូលទៅដល់ហើយ ក៏ក្រាបទូលពោធិរាជកុមារ យ៉ាងនេះថា ខ្ញុំព្រះអង្គបានក្រាបបង្គំទូលព្រះគោតមដ៏ចម្រើននោះ តាមបន្ទូលរបស់ទ្រង់ហើយថា បពិត្រព្រះគោតមដ៏ចម្រើន ពោធិរាជកុមារសូមថ្វាយបង្គំនូវព្រះបាទយុគលព្រះគោតមដ៏ចម្រើនដោយត្បូង ទូលសួរការមិនមានអាពាធ មិនមានសេចក្តីលំបាក ការក្រោករហ័សរហួន កាយពល និងធម៌ជាទីនៅសប្បាយ មួយទៀត ពោធិរាជកុមារ ឲ្យក្រាបទូលព្រះអង្គយ៉ាងនេះថា សូមព្រះគោតមដ៏ចម្រើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ពោធិរាជកុមារ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ព្រះគោតមជាម្ចាស់ក៏បានទទួលនិមន្តន៍ហើយ ។ លុះព្រឹកឡើង ពោធិរាជកុមារចាត់ចែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គហើយ

ឲ្យក្រាលកោកនុទប្រាសាទ ដោយសំពត់សទាំងឡាយ ដរាបដល់កាំជណ្ដើរ ជាន់ខាងក្រោមបំផុត ហើយត្រាស់ហៅ សញ្ជិការបុត្តមាណពមកថា ម្នាល សញ្ជិកាបុត្តសម្លាញ់ អ្នកចូរមក អ្នកចូរចូលទៅគាល់ព្រះមានព្រះភាគ លុះ ចូលទៅដល់ហើយ ក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រ ព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។ សញ្ជិកាបុត្ត មាណព ទទួលព្រះបន្ទូលរបស់ពោធិរាជកុមារថា ព្រះករុណាវិសេស ហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំទូល ភត្តកាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន កាលគួរហើយ ភត្តក៏សម្រេចហើយ ។

[ ២៤៩ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទ្រង់ពុទ្ធដំណើរទៅកាន់និវេសនដ្ឋាន របស់ពោធិរាជកុមារ ។ សម័យនោះឯងពោធិរាជកុមារឋិតនៅខាងក្រៅខ្លោងទ្វាររង់ចាំព្រះមានព្រះភាគ ។ ពោធិរាជកុមារ បានឃើញព្រះមានព្រះភាគស្ដេចមកអំពីចម្ងាយ លុះឃើញ ហើយ ក៏ក្រោកទៅទទួល ក្រាបថ្វាយបង្គំព្រះមានព្រះភាគ នាំស្ដេចទៅកាន់ កោកនុទប្រាសាទ ។ វេលានោះ ព្រះមានព្រះភាគ ទ្រង់ឈប់បង្អង់ នៅកាំ ជណ្ដើរជាន់ខាងក្រោមបំផុត ។ លំដាប់នោះ ពោធិរាជកុមារ ក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគត ទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បី ប្រយោជន៍ និងសេចក្ដីសុខ ដល់ខ្ញុំព្រះអង្គអស់កាលជាយូរអង្វែង ។ កាល

ពោធិរាជកុមារ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់នៅស្ងៀម ។ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះអស់វារៈ ២ ដង ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគត ទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីប្រយោជន៍ និងសេចក្តីសុខ ដល់ខ្ញុំព្រះអង្គអស់កាលជាយូរអង្វែង ។ កាលពោធិរាជកុមារ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់នៅស្ងៀម ។ ពោធិរាជកុមារ ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះ អស់វារៈជាគម្រប់ ៣ ដងថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ជាន់សំពត់ទាំងឡាយ សូមព្រះសុគត ទ្រង់ជាន់សំពត់ទាំងឡាយ ដើម្បីប្រយោជន៍ និងសេចក្តីសុខ ដល់ខ្ញុំព្រះអង្គអស់កាលជាយូរអង្វែង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់បែរព្រះភក្ត្រទៅរកព្រះអានន្ទមានអាយុ ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ក៏មានថេរវាចាទៅនឹងពោធិរាជកុមារយ៉ាងនេះថា បពិត្រព្រះរាជកុមារ សូមទ្រង់សាសំពត់ចេញ ព្រះមានព្រះភាគ ព្រះអង្គមិនទ្រង់ជាន់ផ្ទាំងសំពត់ទេ ព្រះសុគតព្រះអង្គទ្រង់ប្រមើលមើលនូវប្រជុំជនជាខាងក្រោយ ។ គ្រានោះ ពោធិរាជកុមារ ទ្រង់ឲ្យសាសំពត់ចេញហើយ ទ្រង់ឲ្យក្រាលអាសនៈខាងលើកោកនុទប្រាសាទ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ឡើងកាន់កោកនុទប្រាសាទ ហើយគង់លើអាសនៈ ដែលគេក្រាលស្រេចហើយ ព្រមទាំងភិក្ខុសង្ឃ ។ លំដាប់នោះ ពោធិរាជកុមារ បានអង្គាសខាទនីយភោជនីយាហារដ៏ថ្លាញ់ពិសាថ្វាយដោយព្រះហស្តព្រះអង្គឯង ចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យ

ផ្អែតស្អប់ស្អល់ត្រាតែទ្រង់ហាមឃាត់ ។ ទើបពោធិរាជកុមារ កំណត់ជ្រាបថា ព្រះមានព្រះភាគទ្រង់សោយស្រេច លែងលូកព្រះហស្ថទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ គង់ក្នុងទីដ៏សមគួរ ។ ពោធិរាជកុមារ លុះគង់ក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ យ៉ាងនេះថា សេចក្តីសុខបុគ្គលមិនគប្បីបានដោយសេចក្តីសុខទេ សេចក្តីសុខ បុគ្គលត្រូវបានដោយសេចក្តីទុក្ខ ។

[ ២៥០ ] ម្នាលរាជកុមារ ក៏កាលតថាគត នៅជាពោធិសត្វមិនទាន់ត្រាស់ដឹងនៅឡើយ មុនអំពីកាលត្រាស់ដឹង មានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសុខ បុគ្គលមិនគប្បីបានដោយសេចក្តីសុខទេ សេចក្តីសុខ បុគ្គលត្រូវបានដោយសេចក្តីទុក្ខ ។ ម្នាលរាជកុមារ សម័យខាងក្រោយមក តថាគតនោះនៅជាកម្លោះ មានសក់ខ្មៅស្រិល ប្រកបព្រមដោយវ័យដ៏ចម្រើន គឺនៅក្នុងបឋមវ័យនៅឡើយ កាលមាតា និងបិតាមិនចង់ ( ឲ្យបួស ) មានមុខទទឹកជោកដោយទឹកភ្នែក កំពុងទួញយំ ក៏បានកោរសក់ និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកបួស ។ កាលតថាគតនោះ បានបួសដូច្នោះហើយ ក៏ស្វែងរកនូវកឹកុសលសន្តិវរបទដ៏ប្រសើរ ក៏បានចូលទៅរកអាឡារតាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បានពោលសេចក្តីនេះ ទៅនឹងអាឡារតាបសកាលាមគោត្រថា ម្នាលអាវុសោកាលាមៈ យើងប្រាថ្នានឹងមកប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះផង ។ ម្នាលរាជ

កុមារ កាលតថាគតពោលយ៉ាងនេះហើយ អាឡារតាបស កលាមគោត្រ បានពោលតបនឹងតថាគតយ៉ាងនេះថា អ្នកដ៏មានអាយុ ចូរនៅចុះ ធម៌នេះក៏ប្រាកដដូច្នោះ បើជាបុរសអ្នកដឹងសេចក្តីហើយ មិនយូរឡើយ គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ បាន ម្នាលរាជកុមារ តថាគតនោះ ក៏បានរៀនធម៌នោះឆាប់រហ័សមិនយូរឡើយ ។ ម្នាលរាជកុមារ តថាគតនោះ ពោលបានដល់ទៅញាណវាទ និងថេរវាទ ដោយអាការគ្រាន់តែទន្ទេញដោយបបូរមាត់ និងដោយអាការគ្រាន់តែចរចា ទៅមកប៉ុណ្ណោះឯងមួយទៀត តថាគតក្តី បុគ្គលដទៃក្តី ប្តេជ្ញាថា យើងដឹង យើងឃើញដូច្នេះ ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាឡារតាបស កាលាមគោត្រ នឹងញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌នេះថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ដូច្នេះ នឹងអស់ស្រេចដោយត្រឹមតែសទ្ធាប៉ុណ្ណោះនោះក៏ទេ ដោយពិតមែននោះ អាឡារតាបសកាលាមគោត្រ គ្រាន់តែដឹង គ្រាន់តែឃើញធម៌នេះ ប៉ុណ្ណោះ ។ ម្នាលរាជកុមារ កាលនោះតថាគត បានចូលទៅរកអាឡារតាបសកាលាមគោត្រទៀត លុះចូលទៅដល់ហើយ បានពោលនឹងអាឡារតាបសកាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ លោកធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹង បានត្រឹមតែប៉ុណ្ណោះទេឬ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ អាឡារតាបស

កាលាមគោត្រ ទើបបានប្រកាសប្រាប់ដល់ អាកិញ្ចញ្ញាយតនជ្ឈាន ។ ម្នាល រាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មិនមែនមានសទ្ធា តែអាឡារតាបសកាលាមគោត្រម្នាក់ឯងទេ សូម្បីយើងក៏មានសទ្ធាដូច្នោះ ដែរ មិនមែនមានវិរិយៈតែអាឡារតាបសកាលាមគោត្រម្នាក់ឯងទេសូម្បី យើងក៏មានវិរិយដូច្នោះដែរ សតិ... សមាធិ... បញ្ញា សូម្បីយើងក៏មាន បញ្ញាដូច្នោះដែរ តែទុកជាយ៉ាងដូចម្តេច យើងត្រូវតែតម្កល់សេចក្តីព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលអាឡារតាបសកាលាមគោត្រ ញុំាងអ្នក ដទៃឲ្យដឹងថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួន ឯងដូច្នេះឲ្យខាងតែបាន ។ ម្នាលរាជកុមារ មិនយូរប៉ុន្មាន តថាគតនោះ បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងយ៉ាងឆាប់ រហ័ស ។ ម្នាលរាជកុមារ លំដាប់នោះ តថាគតបានចូលទៅរកអាឡារ តាបសកាលាមគោត្រ លុះចូលទៅដល់ហើយ បានពោលនឹងអាឡារតាបស កាលាមគោត្រយ៉ាងនេះថា ម្នាលអាវុសោកាលាមៈ លោកបានធ្វើឲ្យជាក់ ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយញុំាងអ្នកដទៃ ឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេឬ ។ ម្នាលអាវុសោ យើងបានធ្វើឲ្យជាក់ច្បាស់ នូវធម៌នេះដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងបាន ត្រឹមតែប៉ុណ្ណោះទេ ។ តថាគតឆ្លើយតបថា ម្នាលអាវុសោ ខ្ញុំឯងក៏ធ្វើឲ្យជាក់ ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងតែប៉ុណ្ណោះដែរ ។ ម្នាល អាវុសោយើងពេញជាមានលាភហើយ ម្នាលអាវុសោ ភាពជាមនុស្សយើង

បានដោយល្អហើយ ព្រោះពួកយើងបានឃើញសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នកមានអាយុ ហេតុនោះយើងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់ធម៌ណា អ្នកក៏បានធ្វើឲ្យជាក់ច្បាស់ធម៌នោះដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងដូច្នោះដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់ធម៌ណាដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង យើងក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យដឹងច្បាស់ធម៌នោះដែរព្រោះហេតុនោះយើងបានដឹងធម៌ណា អ្នកក៏ដឹងធម៌នោះដែរ អ្នកដឹងធម៌ណា យើងក៏ដឹងធម៌នោះដែរ ព្រោះហេតុនោះ យើងយ៉ាងណា អ្នកក៏យ៉ាងនោះដែរ អ្នកយ៉ាងណា យើងក៏យ៉ាងនោះដែរ ។ ម្នាលអាវុសោ ឥឡូវនេះអ្នកចូរមកចុះ យើងទាំង ២ នាក់ នឹងនៅជួយគ្នា រក្សាគណៈនេះ ។ ម្នាលរាជកុមារ ព្រោះហេតុនោះ អាឡារតាបសកាលាមគោត្រ កាលជាអាចារ្យរបស់តថាគត ក៏បានតាំងតថាគត កាលនៅជាអន្តេវាសិកឲ្យស្មើនឹងខ្លួនហើយបូជាតថាគត ដោយការបូជាដ៏លើសលុប ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌នេះមិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនមែនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងត់ទុក្ខ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីរម្ងាប់ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីដឹង មិនមែនប្រព្រឹត្តទៅដើម្បីត្រាស់ដឹង មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងអាកិញ្ចញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលរាជកុមារ តថាគតនោះ មិនបានពេញចិត្តនឹងធម៌នោះ បានគេចចេញ

បាកធម៌នោះ ហើយចៀសចេញទៅ ។

[ ២៥១ ] ម្នាលរាជកុមារ តថាគតនោះ កំពុងស្វែងរក កិកុសលសន្តិវរបទដ៏ប្រសើរ បានចូលទៅរកឧទ្ទកករាមបុត្រ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងឧទ្ទកករាមបុត្រថា ម្នាលអាវុសោរាមៈ យើងប្រាថ្នានឹងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មវិន័យនេះដែរ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ ឧទ្ទកករាមបុត្របានពោលនឹងតថាគតយ៉ាងនេះថា អ្នកមានអាយុ ចូរទៅចុះ ធម៌នេះប្រាកដដូច្នោះ បើជាបុរសអ្នកដឹងសេចក្តីហើយមិនយូរឡើយ គង់នឹងធ្វើឲ្យជាក់ច្បាស់នូវលទ្ធិអាចារ្យរបស់ខ្លួន ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងបាន ។ ម្នាលរាជកុមារ តថាគតនោះ ក៏បានរៀនធម៌នោះ យ៉ាងឆាប់រហ័សមិនយូរឡើយ ។ ម្នាលរាជកុមារ តថាគតនោះ បានដល់ទៅញាណវាទនិងថេរវាទ ដោយអាការគ្រាន់តែទន្ទេញ ដោយបបូរមាត់ និងដោយអាការគ្រាន់តែចរចាទៅមកប៉ុណ្ណោះឯង មួយទៀត តថាគតក្តី បុគ្គលដទៃក្តី ប្តេជ្ញាថា យើងដឹងយើងឃើញដូច្នេះ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា រាមបុត្រនេះ នឹងញុំាងអ្នកដទៃ ឲ្យដឹងច្បាស់នូវធម៌នេះថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងដូច្នេះ នឹងអស់ស្រេចដោយត្រឹមតែសទ្ធាប៉ុណ្ណោះនោះក៏ទេ ដោយពិតមែននោះ រាមបុត្តនេះ គ្រាន់តែដឹង គ្រាន់តែឃើញធម៌នេះប៉ុណ្ណោះ ។ ម្នាលរាជកុមារ កាលនោះតថាគតចូលទៅរកឧទ្ទកករាមបុត្រទៀត លុះចូលទៅដល់ហើយក៏បានពោលនឹងឧទ្ទកករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ លោកបានធ្វើ

ឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលរាជកុមារ កាលតថាគត ពោលយ៉ាងនេះហើយ ឧទ្ទករាមបុត្រ ក៏បានប្រកាសប្រាប់ដល់ទៅនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា មិនមែនមានសទ្ធា តែរាមបុត្រម្នាក់ឯងទេ សូម្បីយើងក៏មានសទ្ធាដូច្នោះដែរ មិនមែនមានវិរិយៈ តែរាមបុត្រម្នាក់ឯងទេ ។បេ។ សតិ... សមាធិ... បញ្ញា សូម្បីយើងក៏មានបញ្ញាដូច្នោះដែរ តែទុកជាយ៉ាងដូចម្តេចក៏ដោយ យើងត្រូវតែតម្កល់ព្យាយាម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលឧទ្ទករាមបុត្រញ៉ាំងអ្នកដទៃឲ្យដឹងថា អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងដូច្នេះឲ្យខាងតែបាន ។ ម្នាលរាជកុមារមិនយូរប៉ុន្មាន តថាគតនោះ បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងយ៉ាងឆាប់រហ័ស ។ ម្នាលរាជកុមារ លំដាប់នោះ តថាគតបានចូលទៅរកឧទ្ទករាមបុត្រ លុះចូលទៅដល់ហើយ បានពោលនឹងឧទ្ទករាមបុត្រយ៉ាងនេះថា ម្នាលអាវុសោរាមៈ លោកបានធ្វើឲ្យជាក់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងហើយញ៉ាំងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេឬ ។ ឧទ្ទកតាបស ឆ្លើយតបថា ម្នាលអាវុសោ យើងបានធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងបានត្រឹមតែប៉ុណ្ណោះទេ ។ ម្នាលអាវុសោ ខ្ញុំឯងក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌នេះ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងតែប៉ុណ្ណោះដែរ ។ ម្នាលអាវុសោ យើងពេញជាមានលាភហើយ ម្នាលអាវុសោ ភាពជា

មនុស្សយើងបានដោយល្អហើយ ពួកយើងបានឃើញសព្រហ្មចារីបុគ្គល ប្រហែលដូចជាអ្នកដ៏មានអាយុ ព្រោះហេតុនោះ យើងរាមៈ បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌ណា អ្នកក៏បានធ្វើឲ្យជាក់ច្បាស់នូវធម៌នោះដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងដូច្នោះដែរ អ្នកបានធ្វើឲ្យជាក់ច្បាស់នូវធម៌ណា ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង យើងរាមៈក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវធម៌នោះដែរ ព្រោះហេតុនោះ យើងរាមៈ បានដឹងធម៌ណា អ្នកក៏ដឹងធម៌នោះដែរ អ្នកដឹងធម៌ណា យើងរាមៈ ក៏ដឹងធម៌នោះដែរ ព្រោះហេតុនោះ យើងរាមៈយ៉ាងណា អ្នកក៏យ៉ាងនោះដែរ អ្នកយ៉ាងណា យើងរាមៈក៏យ៉ាងនោះដែរ ម្នាលអាវុសោ ឥឡូវនេះ អ្នកចូរមកចុះ ចូរអ្នករក្សាគណៈនេះចុះ ។ ម្នាលរាជកុមារ ព្រោះហេតុនោះ ឧទ្ទករាមបុត្រ កាលជាសព្រហ្មចារីរបស់តថាគត បានតាំងតថាគតក្នុងតំណែងជាអាចារ្យ ហើយក៏បូជា តថាគតដោយការបូជាដ៏លើសលុប ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌នេះមិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនមែនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងត់ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនមែនប្រព្រឹត្តទៅ ដើម្បីសេចក្តីចេះដឹង មិនមែនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន គ្រាន់តែប្រព្រឹត្តទៅ ដើម្បីកើតក្នុងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះ ។ ម្នាលរាជកុមារ តថាគតនោះឯង មិនចេញចិត្តនឹងធម៌នោះ

បានគេចចេញចាកធម៌នោះ ហើយចៀសចេញទៅ ។

[ ២៥២ ] ម្នាលរាជកុមារ តថាគតនោះឯង កាលស្វែងរកកុសល សន្តិវរបទដ៏ប្រសើរត្រាច់ទៅកាន់ចារិក ក្នុងដែនមគធៈដោយលំដាប់ សំដៅទៅឯឧរុវេលាប្រទេសសេនានិគម ។ ក្នុងទីនោះ តថាគតបានឃើញនូវភូមិភាគគួរជាទីត្រេកអរផង នៅជងព្រៃដែលត្រជាក់ត្រជុំផង នូវស្ទឹងកំពុងហូរមានទឹកដ៏ត្រជាក់ មានកំពង់រាបស្មើ គួរជាទីរីករាយផង ទាំងគោចរគ្រាម ក៏តាំងនៅដោយជុំវិញ ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ភូមិភាគគួរជាទីត្រេកអរហ្ន៎ ជងព្រៃក៏ត្រជាក់ត្រជុំ ទាំងស្ទឹងដែលកំពុងហូរ មានទឹកត្រជាក់ មានកំពង់រាបស្មើ គួរជាទីរីករាយ ទាំងគោចរគ្រាម ក៏តាំងនៅដោយជុំវិញទីនេះហ្ន៎ ល្មមតាំងសេចក្តីព្យាយាមរបស់កុលបុត្រអ្នកមានប្រយោជន៍ដោយសេចក្តីព្យាយាម ។ ម្នាលរាជកុមារ តថាគតនោះ បានអង្គុយសំចតនៅក្នុងទីនោះ ដោយគិតថា ទីនេះល្មមតាំងសេចក្តីព្យាយាមបាន ។

[ ២៥៣ ] ម្នាលរាជកុមារ ឧបមា ៣ ប្រការ មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្តាប់មកពីមុន ក៏បានកើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ប្រៀបដូចឈើស្រស់ ប្រកបដោយជ័រដែលបុគ្គលត្រាំទុកនៅក្នុងទឹក ។ កាលបុរសគិតថា យើងនឹងកាន់យកឈើពំនួតខាងលើ មកពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតប្រាកដឡើងបាន ។ ម្នាលរាជកុមារ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះកាលកាន់យកឈើពំនួតខាងលើ មកពួតនឹងឈើស្រស់ដែលប្រកបដោយជ័រ ដែលបុគ្គល ត្រាំទុកនៅក្នុងទឹក

ឯណោះ នឹងពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើត ប្រាកដឡើងបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនកើតទេ រឿងនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះឈើឯណោះនៅស្រស់ប្រកបដោយជ័រថែមទាំងឈើនោះសោត ក៏ត្រាំនៅក្នុងទឹកផង ឯបុរសនោះ គ្រាន់តែបានចំណែកនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់តែប៉ុណ្ណោះ ។ ម្នាលរាជកុមារ សេចក្តីនេះ មានឧបមេយ្យដូចពួកសមណព្រាហ្មណ៍ណាមួយ មិនបានចៀសចេញចាកកាមទាំងឡាយដោយកាយ សមណព្រាហ្មណ៍ទាំងនោះ ថែមទាំងមានសេចក្តីពេញចិត្តព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះកាម សេចក្តីស្រេកឃ្លានព្រោះកាម និងសេចក្តីក្រហល់ក្រហាយ ព្រោះកាមក្នុងកាមទាំងឡាយ កាមនោះជារបស់ដែលសមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ដោយប្រពៃ និងមិនបានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃពួដ៏ខាងក្នុង ។ ប្រសិនបើពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ បានទទួលវេទនា ជាទុក្ខ ដ៏ក្លៀវក្លា ខ្លាចផ្សាដែលកើតអំពីសេចក្តីព្យាយាម ពួកសមណព្រាហ្មណ៍ទាំងនោះ មិនគួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចម្រើននោះ មិនបានទទួលទុក្ខវេទនា ដ៏ក្លៀវក្លាខ្លាចផ្សា ដែលកើតអំពីសេចក្តីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ ម្នាលរាជកុមារ នេះឯងឧបមាជាដំបូង មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានឮមកអំពីមុន មកប្រាកដដល់តថាគត។

[ ២៥៤ ] ម្នាលរាជកុមារ មានឧបមាទី ២ ដទៃទៀតដែលមិនសូវជាអស្ចារ្យណាស់ណា តថាគតមិនធ្លាប់បានឮមកពីមុន ក៏បានកើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ដូចឈើស្រស់ប្រកបដោយជ័រ ដែលគេដាក់លើគោកនៅឆ្ងាយពីទឹក ។ កាលបុរសគិតថា យើងនឹងកាន់យកឈើពំនួតខាងលើ មកពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតប្រាកដឡើង ។ ម្នាលរាជកុមារ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះកាលកាន់យកឈើពំនួតខាងលើ មកពួតនឹងឈើស្រស់ប្រកបដោយជ័រ ដែលគេដាក់លើគោកនៅឆ្ងាយពីទឹកឯណោះ នឹងពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនកើតទេ រឿងនោះព្រោះហេតុអ្វី បពិត្រព្រះអង្គ ដ៏ចម្រើន ព្រោះឈើឯណោះនៅស្រស់ប្រកបដោយជ័រពិតមែន តែគេដាក់លើគោកនៅឆ្ងាយពីទឹក ឯបុរសនោះ គ្រាន់តែបានភាគនៃសេចក្តីលំបាក និងសេចក្តីចង្អៀតចង្អល់ប៉ុណ្ណោះ ។ ម្នាលរាជកុមារ សេចក្តីនេះមានឧបមេយ្យដូចពួកសមណព្រាហ្មណ៍ណាមួយចៀស ចេញចាកកាម ទាំងឡាយដោយកាយហើយ តែសមណព្រាហ្មណ៍ទាំងនោះ មានសេចក្តីពេញចិត្តព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះកាម សេចក្តីស្រេកឃ្លានព្រោះកាម និងសេចក្តីក្រហល់ក្រហាយព្រោះកាមក្នុងវត្ថុកាមទាំងឡាយ ទាំងកាមនោះ សមណព្រាហ្មណ៍ទាំងនោះ មិនបានលះបង់ដោយប្រពៃ ទាំងមិនបានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ បានទទួលវេទនា ជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា

ដែលកើតអំពីសេចក្ដីព្យាយាម ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏មិនគួរដើម្បី នឹងដឹង ដើម្បីនឹងឃើញ ដើម្បីនឹងត្រាស់ដឹងនូវព្រះនិព្វានដ៏ប្រសើរបានឡើយ ។ បើទុកជាពួកសមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ មិនបានសោយវេទនាជាទុក្ខ ដ៏ក្លៀវក្លា ខ្លោចផ្សា ដែលកើតអំពីសេចក្ដីព្យាយាមនោះទេ ពួកសមណព្រាហ្មណ៍ ទាំងនោះ ក៏មិនគួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីនឹងត្រាស់ដឹងនូវព្រះ និព្វានដ៏ប្រសើរបានឡើយ ។ ម្នាលរាជកុមារ នេះឯងជាឧបមាទី ២ មិន សូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្ដាប់មកអំពីមុន ក៏កើត ប្រាកដដល់តថាគត ។

[ ២៥៥ ] ម្នាលរាជកុមារ មានឧបមាទី ៣ ដទៃទៀត ដែលមិនសូវជា អស្ចារ្យណាស់ណា ដែលតថាគត មិនធ្លាប់បានស្ដាប់មកអំពីមុន ក៏កើត ប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ដូចឈើស្ងួតជាឈើពុក ដែលគេ ដាក់លើគោកនៅឆ្ងាយពីទឹក ។ កាលបុរសគិតថា យើងនឹងកាន់យកឈើ ពំនួតខាងលើមកពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតប្រាកដឡើង ។ ម្នាលរាជកុមារ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច បុរសនោះ កាលកាន់យក ឈើពំនួតខាងលើ មកពួតនឹងឈើស្ងួតជាឈើពុក ដែលគេដាក់លើគោក នៅ ឆ្ងាយពីទឹកឯណោះ នឹងពួតឲ្យកើតភ្លើង នឹងធ្វើតេជោធាតុឲ្យកើតបានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះទើបកើតបាន រឿងនោះព្រោះហេតុអ្វី បពិត្រ ព្រះអង្គដ៏ចម្រើន ព្រោះឈើស្ងួតឯណោះ ជាឈើពុក ថែមទាំងឈើនោះសោត គេដាក់លើគោកនៅឆ្ងាយពីទឹកផង ។ ម្នាលរាជកុមារ សេចក្ដីនេះមានឧបមេយ្យ

ដូចពួកសមណព្រាហ្មណ៍ណាមួយ ចៀសចេញចាកកាមទាំងឡាយ ដោយកាយហើយ ទាំងសេចក្តីពេញចិត្តព្រោះកាម សេចក្តីស្នេហាព្រោះកាម សេចក្តីជ្រប់ព្រោះកាម សេចក្តីស្រេកឃ្លានព្រោះកាម និងសេចក្តីក្រហល់ក្រហាយព្រោះកាម ក្នុងវត្ថុកាមទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ក៏បានលះបង់ដោយប្រពៃ បានធ្វើឲ្យស្ងប់រម្ងាប់ដោយប្រពៃ នូវវត្ថុកាមនោះ ឰដ៏ខាងក្នុង ។ ទោះបីពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ បានទទួលវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ដែលកើត អំពីសេចក្តីព្យាយាម ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹង នូវព្រះនិព្វានដ៏ប្រសើរបាន ។ បើទុកជា ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ មិនបានទទួលវេទនាជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ដែលកើតអំពីសេចក្តីព្យាយាមទេ ពួកសមណព្រាហ្មណ៍ទាំងនោះ ក៏គួរដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានដ៏ ប្រសើរបាន ។ ម្នាលរាជកុមារ នេះឯងជាឧបមាទី ៣ មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្តាប់មកអំពីមុនក៏កើតប្រាកដដល់តថាគត ។ ម្នាលរាជកុមារ ឧបមាទាំង ៣ ប្រការនេះឯងហើយ មិនសូវជាអស្ចារ្យណាស់ណា ដែលតថាគតមិនធ្លាប់បានស្តាប់មកអំពីមុន ក៏កើតប្រាកដដល់តថាគត ។

[ ២៥៦ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរអាត្មាអញខាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្តាត សង្កត់សង្កិន បៀតបៀន ដុតកម្តៅចិត្តដោយចិត្ត ។ ម្នាលរាជកុមារ តថាគតនោះ

ឯង ខាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្តាត សង្កត់សង្កិន បៀតបៀន ដុតកម្តៅចិត្តដោយចិត្ត ។ ម្នាលរាជកុមារ កាលតថាគត នោះខាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្តាត សង្កត់សង្កិន បៀតបៀន ដុតកម្តៅចិត្តដោយចិត្ត ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ។ ម្នាលរាជកុមារ បុរសដែលមានកម្លាំង គប្បីចាប់បុរសមានកម្លាំងខ្សោយជាង ត្រង់ក្បាលឬកហើយ សង្កត់សង្កិន បៀតបៀន ញាំញីយ៉ាងណា ម្នាលរាជកុមារ កាលតថាគត ខាំធ្មេញដោយធ្មេញ ទល់ពិតានដោយអណ្តាត សង្កត់សង្កិន បៀតបៀន ដុតកម្តៅចិត្តដោយចិត្ត ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ សេចក្តីព្យាយាមដែលតថាគត បានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំមួនហើយ ក៏មិនរាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏លំបាកនោះមកបណ្តាលចាក់ដោត ។

[ ២៥៧ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរតែសម្ងំឈាន គឺមិនដកដង្ហើមជាអារម្មណ៍ ។ ម្នាលរាជកុមារ តថាគតនោះឯង ក៏បានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារនឹងតាមនាសិកៈ ។ ម្នាលរាជកុមារ កាលតថាគតអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារ និងនាសិកៈ សំឡេងខ្យល់ដែលចេញតាមកណ្ណសោត ខ្លាំងលើសប្រមាណ ។ ដូចជាស្នប់របស់ជាងលោហជាតិដែលកំពុងសប់ តែងមានសំឡេងខ្លាំងយ៉ាងណា ម្នាលរាជកុមារ កាលតថាគតអត់ខ្យល់អស្សាស

បស្សាសៈ តាមមុខទ្វារ និងតាមនាសិកៈ សំឡេងខ្យល់ដែលចេញតាមកណ្ណសោត ក៏ខ្លាំងលើសប្រមាណ យ៉ាងនោះដែរ ។ ម្នាលរាជកុមារ តែសេចក្ដីព្យាយាមដែលតថាគត បានប្រារព្ធហើយ មិនធូរថយ សតិដែលតថាគតតម្កល់មាំហើយ ក៏មិនវាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ កើតព្រោះសេចក្ដីព្យាយាម ដោយសេចក្ដីព្យាយាមដ៏លំបាកនោះឯង មកបណ្ដាលចាក់ដោត ។

[ ២៥៨ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរសម្ងំឈាន គឺមិនដកដង្ហើមជាអារម្មណ៍ទៀត ។ ម្នាលរាជកុមារ តថាគតនោះ អត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិកៈ និងកណ្ណសោត ។ ម្នាលរាជកុមារ កាលតថាគតនោះ អត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារ តាមនាសិក និងកណ្ណសោត ខ្យល់យ៉ាងខ្លាំងលើសប្រមាណ ក៏វិលមកចាក់ដោតត្រង់ក្បាល ។ ម្នាលរាជកុមារ បុរសដែលមានកម្លាំង គប្បីចោះក្បាលដោយដែកស្រួចដ៏មុត យ៉ាងណា ម្នាលរាជកុមារ កាលតថាគត អត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោត ខ្យល់យ៉ាងខ្លាំងលើសប្រមាណ ក៏វិលត្រឡប់មកចាក់ដោតក្បាល យ៉ាងនោះដែរ ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្ដីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំហើយ ក៏មិនវាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់ កើតព្រោះសេចក្ដីព្យាយាម ដោយសេចក្ដីព្យាយាមដ៏លំបាកនោះ មកបណ្ដាល

ចាក់ដោត ។

[ ២៥៩ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ អាត្មាអញគួរតែសម្ងំឈាន គឺមិនដកដង្ហើមជាអារម្មណ៍ទៀត ។ ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោត ។ ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារតាមនាសិក និងតាមកណ្ណសោតហើយ វេទនាកើតក្នុងក្បាល ពួដ៏ក្បាលខ្លាំងលើសប្រមាណ ។ ម្នាលរាជកុមារ ដូចបុរសមានកម្លាំងគប្បីចងត្របែងនូវចំណងក្បាលពួដ៏ក្បាល ដោយព្រ័ត្រដ៏មាំ ( យ៉ាងណា ) ម្នាលរាជកុមារ កាលតថាគត បានអត់ខ្យល់អស្សាបស្សាស តាមមុខទ្វារ តាមនាសិកៈ និងតាមកណ្ណសោតហើយ វេទនាកើតក្នុងក្បាល ពួដ៏ក្បាល ដ៏ខ្លាំងលើសប្រមាណ ក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្តីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំហើយ ក៏មិនរាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយមិនទាន់ស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលចាក់ដោត ។

[ ២៦០ ] ម្នាលរាជកុមារ តថាគតនោះឯង ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញសម្ងំឈាន គឺមិនដកដង្ហើមជាអារម្មណ៍ទៀត ។ ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាបស្សាសៈ តាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោត ។ ម្នាលរាជកុមារ កាល

តថាគតបានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារ តាមនាសិក និង កណ្ណសោត ខ្យល់លើសប្រមាណក៏កាត់នូវដំបារផ្ទៃ ។ ម្នាលរាជកុមារដូច ជាបុរសជាអ្នកសម្លាប់គោក្តី អ្នកជំនួយរបស់បុរសសម្លាប់គោក្តី ជាអ្នកប្រសព្វ វាងវៃ កាត់ដំបារផ្ទៃគោ ដោយកាំបិតសម្រាប់កាត់ពន្ទះនូវសាច់គោដ៏មុត ( យ៉ាងណា ) ម្នាលរាជកុមារ កាលតថាគតបានអត់ខ្យល់អស្សាស បស្សាសៈតាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោត ខ្យល់ខ្លាំងលើស ប្រមាណ ក៏កាត់នូវតំបារផ្ទៃក៏ដូច្នោះដែរ ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្តី ព្យាយាមដែលតថាគតបានប្រារព្ធហើយ មិនធូរថយ សតិដែលតថាគតបាន តម្កល់មាំហើយ ក៏មិនបានវាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ ក្រវាយ មិនបានស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យា-យាមដ៏លំបាកនោះឯង មកបណ្តាលចាក់ដោត ។

[ ២៦១ ] ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាង នេះថា បើដូច្នោះ គួរតែអាត្មាអញសម្ងំឈាន គឺមិនដកដង្ហើមជាអារម្មណ៍ ទៀត ។ ម្នាលរាជកុមារ តថាគតនោះឯង បានអត់ខ្យល់អស្សាសបស្សាសៈ តាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោត ។ ម្នាលរាជកុមារ កាល តថាគតអត់ខ្យល់អស្សាសបស្សាសៈតាមមុខទ្វារ តាមនាសិក និងតាម កណ្ណសោត សេចក្តីក្តៅក្រហាយដ៏ខ្លាំងលើសប្រមាណ ក៏កើតមានក្នុងកាយ ។ ម្នាលរាជកុមារ ដូចជាបុរសមានកម្លាំង ២ នាក់ ចាប់បុរសដែលមានកម្លាំង ខ្សោយ ត្រង់ដើមដៃម្ខាងម្នាក់ហើយគប្បីផ្ទេរឲ្យក្រហល់ក្រហាយក្នុងរណ្តៅរងើក

ភ្លើន ( យ៉ាងណា ) ម្នាលរាជកុមារ កាលតថាគតអត់ខ្យល់អស្សាស បស្សាសៈ តាមមុខទ្វារ តាមនាសិក និងតាមកណ្ណសោតហើយ សេចក្តីក្តៅក្រហល់ក្រហាយ ខ្លាំងលើសប្រមាណក៏កើតមានក្នុងកាយ ដូច្នោះឯង ។ ម្នាលរាជកុមារ ប៉ុន្តែសេចក្តីព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានតម្កល់មាំហើយ ក៏មិនបានរាយមាយ ប៉ុន្តែកាយរបស់តថាគត នៅតែក្រវល់ក្រវាយ មិនស្ងប់រម្ងាប់ កើតព្រោះសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលចាក់ដោត ។

[ ២៦២ ] ម្នាលរាជកុមារ គ្រានោះ ពួកទេវតាឃើញតថាគតហើយ បាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមធ្វើមរណកាលទៅហើយ ។ ទេវតាពួកខ្លះបាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមមិនទាន់ធ្វើមរណកាលទេ តែព្រះសមណគោតម នឹងធ្វើមរណកាលឥឡូវនេះ ។ ទេវតាពួកខ្លះនិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតម មិនទាន់ធ្វើមរណកាលទេ ទាំងមិនធ្វើមរណកាលក្នុងកាលឥឡូវនេះដែរ ព្រះសមណគោតម ជាព្រះអរហន្តនុ៎ះជាវិហារធម៌ទេតើ សភាពយ៉ាងនេះ រមែងមានដល់ព្រះអរហន្ត ។

[ ២៦៣ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញប្រតិបត្តិដើម្បីផ្តាច់បង់អាហារដោយប្រការទាំងពួង ។ ម្នាលរាជកុមារ លំដាប់នោះ ពួកទេវតាទាំងនោះ បានចូលមករកតថាគតហើយនាំគ្នានិយាយយ៉ាងនេះថា បពិត្រអ្នកនិទ្ទុក្ខ អ្នកកុំប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួងឡើយ ។ បពិត្រអ្នកនិទ្ទុក្ខ ប្រសិនបើអ្នក

នឹងប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួងហើយ ពួកយើងនឹងបញ្ចូលឱជាទិព្វតាមរន្ធរោមរបស់អ្នក នឹងញុំាងអ្នកឲ្យរស់នៅដោយឱជាទិព្វនោះ ។ ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើអាត្មាអញ នឹងប្តេជ្ញាចំពោះពួកទេវតាថា ជាអ្នកមិនបរិភោគ ដោយប្រការទាំងពួងទៅ ពួកទេវតាទាំងនេះ នឹងបញ្ចូលឱជាទិព្វតាមរន្ធរោមរបស់អាត្មាអញ ចំណែកខាងអាត្មាអញ គប្បីញុំាងជីវិតឲ្យរស់នៅដោយឱជាទិព្វនោះ ពាក្យនោះនឹងជាពាក្យកុហកនៃអាត្មាអញ ។ ម្នាលរាជកុមារ តថាគតនោះ ក៏ឃាត់ពួកទេវតាទាំងនោះហើយ និយាយថា ណ្ហើយ កុំឡើយ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញសម្រេចអាហារកិច្ច បន្តិចៗ ចំនួនមួយទូកដៃៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្តែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្តែកកង់ខ្លះ ពុំនោះសោតប៉ុនសាច់រលីងឈូកខ្លះ ។ ម្នាលរាជកុមារ តថាគតនោះក៏បានសម្រេចអាហារកិច្ចបន្តិចៗ ចំនួនជាមួយទូកដៃៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្តែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្តែកកង់ខ្លះ ពុំនោះសោត ប៉ុនរលីងឈូកខ្លះ ។ ម្នាលរាជកុមារ កាលតថាគតនោះ សម្រេចអាហារកិច្ច បន្ថយចុះបន្តិចម្តងៗ ចំនួនមួយទូកដៃៗ ខ្លះ ប៉ុនសាច់គ្រាប់សណ្តែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្តែកកង់ខ្លះ ពុំនោះសោត ប៉ុនសាច់រលីងឈូកខ្លះ កាយ ( របស់តថាគត ) ក៏ដល់នូវការស្គាំងស្គមខ្លាំង លើសប្រមាណ ។

[ ២៦៤ ] អវយវៈតូច និងអវយវៈធំ របស់តថាគត បៀបដូចវល្លិមានថ្នាំងច្រើន នឹងវល្លិមានថ្នាំងខ្មៅ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ត្រគាករបស់តថាគត ( ក៏ស្លៀតចូលគ្នា ) ដូចជាស្នាមជើងឱដ្ឋ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ទ្រនុងឆ្អឹងខ្នងរបស់តថាគត ក៏រដិបរដុបដូចខ្សែល្អួសដែលគេវេញចូលគ្នា ព្រោះទោសដែលមានអាហារតិចនោះឯង ។ របៀបឆ្អឹងជំនីរតថាគត ក៏រគីមរគាមដូចបង្កង់នៃសាលាចាស់ ដ៏រគីមរគាម ព្រោះទោសដែលមានអាហារតិចនោះឯង ។ ប្រស្រីភ្នែកទាំងឡាយរបស់តថាគត ក៏ជ្រៅខូងចូលទៅក្នុងរណ្ដៅភ្នែក ដូចកំពែងទឹកដ៏ខូងជ្រៅចូលទៅក្នុងអណ្ដូងទឹកដ៏ជ្រៅ ព្រោះទោសដែលមានអាហារតិចនោះឯង ។ សម្បុរស្បែកក្បាលសម្រាប់ទទួលសម្ផស្សរបស់តថាគត ក៏ស្វិតជ្រីវទៅ ដូចផ្លែឃ្លោកខ្ចីដែលគេកាត់ចេញអំពីទង ហើយក៏ស្វិតស្រពោនទៅ ដោយខ្យល់នឹងកម្ដៅ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគតនោះឯងគិតថា អាត្មាអញ នឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវឆ្អឹងខ្នងវិញ គិតថាអាត្មាអញនឹងស្ទាបឆ្អឹងខ្នង ក៏ចាប់ត្រូវស្បែកពោះវិញ ។ ម្នាលរាជកុមារ ស្បែកពោះរបស់តថាគតជាប់គ្នាជាបជល់ឆ្អឹងខ្នង ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគតនោះឯងគិតថា នឹងបន្ទោបង់នូវវច្ចៈ ឬមូត្រ ក៏ដួលពោបនៅក្នុងទីនោះ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ តថាគតនោះឯង កាលធ្វើកាយនេះឲ្យស្រួល ទើបស្ទាបខ្លួនដោយដៃ ។ ម្នាលរាជកុមារ កាលតថាគតនោះ ស្ទាបខ្លួនដោយបាតដៃទៅ

រោមទាំងឡាយ សុទ្ធតែមានឫសស្អុយធ្លាក់ចេញពីកាយ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ គ្រានោះ មនុស្សទាំងឡាយឃើញតថាគតហើយ ក៏នាំគ្នានិយាយយ៉ាងនេះថា ព្រះសមណគោតមមានសម្បុរខ្មៅ ។ មនុស្សទាំងឡាយពួកខ្លះ នាំគ្នានិយាយយ៉ាងនេះថា ព្រះសមណគោតម មិនមែនមានសម្បុរខ្មៅទេ ព្រះសមណគោតមមានសម្បុរសណ្តែកបាយទេតើ ។ មនុស្សទាំងឡាយពួកខ្លះ និយាយគ្នាយ៉ាងនេះថា ព្រះសមណគោតមមិនមែនមានសម្បុរខ្មៅទេ ទាំងមិនមែនមានសម្បុរសណ្តែកបាយ គឺព្រះសមណគោតម មានសម្បុរប្រផេះទេតើ ។ ម្នាលរាជកុមារ ឆវិវណ្ណរបស់តថាគត ដ៏បរិសុទ្ធផូរផង់ដល់ម្ល៉េះ ហើយត្រឡប់ទៅជាអាប់អន់ទៅវិញ ព្រោះទោសដែលមានអហារតិចនោះឯង ។

[ ២៦៥ ] ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានទទួលវេទនាជាទុក្ខដ៏ក្លៀវក្លាខ្លោចផ្សា ដែលកើតអំពីសេចក្តីព្យាយាម មានកំណត់តែត្រឹមប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។ មួយទៀត ពួកសមណព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងទទួលវេទនា ជាទុក្ខដ៏ក្លៀវក្លា ខ្លោចផ្សា ដែលកើតអំពីសេចក្តីព្យាយាម មានកំណត់ត្រឹមតែប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។ ពួកសមណព្រាហ្មណ៍ណាក្នុងបច្ចុប្បន្ន កំពុងទទួលវេទនាជាទុក្ខដ៏ក្លៀវក្លាខ្លោចផ្សា ដែលកើតអំពីសេចក្តីព្យាយាម មានកំណត់ត្រឹមតែប៉ុណ្ណេះ មិនលើសជាងនេះឡើយ ។ តែទោះបីដូច្នោះ តថាគតក៏នៅតែមិនបានត្រាស់ដឹង

នូវឧត្តរិមនុស្សធម៌ជាគុណវិសេសគួរដើម្បីឃើញដោយប្រាជ្ញារបស់ព្រះអរិយៈ ដោយទុក្ករកិរិយាដ៏ខ្លាចផ្សានេះបានឡើយ ទំនងផ្លូវត្រាស់ដឹង នឹងមានជាយ៉ាង ដទៃទេដឹង ។

[ ២៦៦ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា យើងនៅចាំបាន កាលការ ( ប្រត់ព្រះនង្គ័ល ) របស់សក្កៈជាបិតា យើងអង្គុយនៅក្រោមម្លប់ជម្ពូព្រឹក្សដ៏ត្រជាក់ បានស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈានមានវិតក្កៈ និងវិចារៈ មានបីតិនិងសុខដែលកើតអំពីវិវេក ឱផ្លូវនេះទេដឹងជាផ្លូវនៃកិរិយាត្រាស់ដឹង ។ ម្នាលរាជកុមារ វិញ្ញាណដែលស្ទុះទៅតាមសតិ ក៏កើតឡើងដល់តថាគតថា នេះហើយប្រាកដជាផ្លូវនៃការត្រាស់ដឹង ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញខ្លាចសេចក្តីសុខ ដែលជាសុខក្រៅអំពីកាមទាំងឡាយ ដែលជាសុខក្រៅអំពីអកុសលធម៌ទាំងឡាយដែរឬ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនគួរខ្លាចសេចក្តីសុខ ដែលជាសុខ ក្រៅអំពីកាមទាំងឡាយ ដែលជាសុខក្រៅអំពីអកុសលធម៌ទាំងឡាយឡើយ ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សេចក្តីសុខនោះ ដែលបុគ្គលមានរាងកាយដល់នូវសេចក្តីស្គាំងស្គមលើសប្រមាណយ៉ាងនេះ មិនងាយនឹងធ្វើឲ្យសម្រេចបានឡើយ បើដូច្នោះ គួរតែអាត្មាអញបរិភោគអាហារដ៏គ្រោតគ្រាត គឺបាយនិងនំកុម្មាសឡើងវិញ ។ ម្នាលរាជកុមារ តថាគតនោះឯង ក៏បានបរិភោគ

អាហារដ៏គ្រោតគ្រាតគឺបាយ និងនំកុម្មាស ។ ម្នាលរាជកុមារ សម័យនោះឯង ពួកបញ្ចវគ្គិយភិក្ខុដែលបម្រើតថាគតដោយគិតថា ព្រះសមណគោតមបើត្រាស់ដឹងធម៌ណា នឹងសម្តែងធម៌នោះ ប្រាប់ដល់យើងទាំងឡាយ ។ ម្នាលរាជកុមារ កាលនោះ តថាគតបានបរិភោគអាហារដ៏គ្រោតគ្រាតគឺបាយ និងនំកុម្មាស គ្រានោះពួកបញ្ចវគ្គិយភិក្ខុអម្បាលនោះ ក៏នឿយណាយនឹងតថាគត ហើយចៀសចេញទៅដោយគិតថា ព្រះសមណគោតមជាអ្នកល្មោភឃ្លាតចាកសេចក្តីព្យាយាម ត្រឡប់មកដើម្បីល្មោភវិញ ។ ម្នាលរាជកុមារ លុះតថាគតបរិភោគអាហារដ៏គ្រោតគ្រាតហើយ ក៏បម្រុងរាងកាយឲ្យមានកម្លាំង ហើយស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រោះរម្ងាប់វិតក្កៈ និងវិចារៈ ទាំងឡាយ ។បេ។ បានដល់ទុតិយជ្ឈាន... បានដល់តតិយជ្ឈាន... បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[ ២៦៧ ] តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម មិនបានញាប់ញ័រតាមអារម្មណ៍យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ។ តថាគតនោះ រលឹកឃើញនូវបុព្វេនិវាសច្រើនប្រការ គឺរលឹកបាន ១ ជាតិ ២ ជាតិ ។បេ។ តថាគតរលឹកឃើញនូវបុព្វេនិវាសច្រើនប្រការព្រមទាំងអាការៈព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ ។ ម្នាលរាជកុមារ នេះជាវិជ្ជាទី ១ ដែលតថាគតបានក្នុងបឋមយាមនៃរាត្រី

អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដោយពិត ។

[ ២៦៨ ] តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ ឥតមានទីទួលគឺកិលេស ប្រាសឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម មិនបានញាប់ញ័រទៅតាមអារម្មណ៍ ដោយប្រការដូច្នេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ គឺប្រាជ្ញាដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ។ តថាគតនោះ មានទិព្វចក្ខុកន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញនូវពួកសត្វដែលច្យុត ដែលកើតជាសត្វថោកទាប ខ្ពង់ខ្ពស់ មានរូបល្អ រូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ។បេ។ តថាគតឃើញច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។ ម្នាលរាជកុមារ នេះឯងជាវិជ្ជាទី ២ ដែលតថាគតបានហើយ ក្នុងមជ្ឈិមយាមនៃរាត្រី អវិជ្ជាបាត់ហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគត ដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកម្តៅកិលេសឲ្យក្តៅ មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានដោយពិត ។

[ ២៦៩ ] តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្មមិនបានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះបានដឹងច្បាស់តាម ពិតថា

នេះជាទុក្ខ ។បេ។ បានដឹងច្បាស់តាមពិតថា នេះជាបដិបទាជាហេតុ ឲ្យរលត់សេចក្តីទុក្ខ បានដឹងច្បាស់តាមពិតថា នេះជាអាសវៈ ។បេ។ បានដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យដល់នូវសេចក្តីរម្ងត់អាសវៈ ។ កាលតថាគតនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរបស់តថាគតក៏រួចចាក កាមាសវៈផង ... ចិត្តរបស់តថាគតក៏រួចចាកភវាសវៈផង ... ចិត្តរបស់តថាគតក៏រួចចាកអវិជ្ជាសវៈផង កាលចិត្តរួចស្រឡះហើយ សេចក្តីដឹងក៏កើតប្រាកដថា ចិត្តផុតស្រឡះហើយ ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើក៏ធ្វើស្រេចហើយ ឥតមានកិច្ចដទៃប្រព្រឹត្តទៅដើម្បីកិច្ចនេះទៀតឡើយ ។ ម្នាលរាជកុមារ នេះឯងជាវិជ្ជាទី ៣ ដែលតថាគតបានហើយ ក្នុងបច្ឆិមយាមនៃរាត្រី អវិជ្ជាបាត់ទៅហើយ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅហើយ ពន្លឺក៏កើតឡើងដល់តថាគតដែលជាអ្នកមិនប្រមាទ ព្យាយាមដុតកម្តៅកិលេសឲ្យក្តៅ បញ្ជូនចិត្តទៅកាន់ព្រះនិព្វានដោយពិត ។

[ ២៧០ ] ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ធម៌ដែលតថាគតបានត្រាស់ដឹងហើយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ជាធម៌ដែលសត្វឃើញបានដោយកម្រ ជាធម៌ដែលសត្វត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីត្រាច់ចុះនៃវិតក្កៈបាន ជាធម៌ដ៏ល្អិតជាធម៌ដែលអ្នកប្រាជ្ញគប្បីដឹងបាន ។ ក៏ពួកសត្វនេះ សុទ្ធតែនៅកំពុងរីករាយ ក្នុងសេចក្តីអាល័យ កំពុងត្រេកត្រអាលក្នុងសេចក្តីអាល័យ កំពុងស្រើបស្រាលក្នុងសេចក្តីអាល័យ ( ចំពោះកាមទាំងឡាយនៅឡើយ ) ។ មួយទៀត

បដិច្ចសមុប្បាទធម៌ គឺធម៌ជាបច្ច័យនៃគ្នានឹងគ្នាណា បដិច្ចសមុប្បាទធម៌នេះ ជាហេតុនាំឲ្យពពួកសត្វដែលនៅរីករាយក្នុងសេចក្ដីអាល័យនៅ ត្រេកត្រអាលក្នុងសេចក្ដីអាល័យ នៅស្រើបស្រាលក្នុងសេចក្ដីអាល័យ គេឃើញបានដោយក្រក្រៃពេកណាស់ ។ មួយទៀត ធម៌ណាសម្រាប់រម្ងាប់បង់នូវសង្ខារទាំងពួង សម្រាប់លះបោលនូវឧបធិគឺកិលេសទាំងអស់ ជាទីអស់ទៅនៃតណ្ហា ជាទីនឿយណាយចាករាគៈ ជាទីរលត់នៃសេចក្ដីទុក្ខគឺព្រះនិព្វាន ធម៌ទាំងអម្បាលនេះ ជាហេតុនាំឲ្យពពួកសត្វ ឃើញបានដោយក្រក្រៃពេកណាស់ ។ បើទុកជាតថាគតសម្ដែងធម៌ទៅ ក៏គង់សត្វទាំងឡាយដទៃមិនអាចនឹងត្រាស់ដឹងនូវធម៌របស់តថាគតបានឡើយ សេចក្ដីលំបាក និងសេចក្ដីនឿយព្រួយនោះ មុខជានឹងមានដល់តថាគតមិនខាន ។ ម្នាលរាជកុមារ កាលណោះគាថាទាំងឡាយមិនសូវជាអស្ចារ្យណាស់ណានេះ ដែលតថាគតមិនដែលបានឮក្នុងកាលមុន ក៏កើតប្រាកដដល់តថាគតថា

ណ្ហើយចុះ ឥឡូវនេះ តថាគតគួរសម្ដែងធម៌ដែលតថាគតបានត្រាស់ដឹងហើយ ដោយសេចក្ដីលំបាកនោះចុះ សត្វទាំងឡាយដែលរាគៈទោសៈ គ្របសង្កត់ហើយ មិនងាយនឹងត្រាស់ដឹងនូវធម៌នេះបានទេ សត្វទាំងឡាយដែលកំពុងត្រេកអរដោយរាគៈ ដែលគំនរងងឹតគឺអវិជ្ជាកំពុងរួបរឹត មិនឃើញនូវធម៌ដែលនាំឲ្យពួកសត្វ ដល់នូវព្រះនិព្វាន ជាធម៌ដ៏ល្អិត សុខុមជ្រាលជ្រៅ ដែលសត្វឃើញបានដោយកម្រ

នោះបានទេ ។

ម្នាលរាជកុមារ កាលដែលតថាគតពិចារណាឃើញ ដោយន័យដែលត្រិះរិះដូច្នេះហើយ ចិត្តក៏ឱនទៅ ដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនឱនទៅដើម្បីសំដែងធម៌ឡើយ ។

[ ២៧១ ] ម្នាលរាជកុមារ លំដាប់នោះ សហម្បតិព្រហ្ម ដឹងនូវសេចក្តីត្រិះរិះក្នុងចិត្តរបស់តថាគតដោយចិត្តរបស់ខ្លួនហើយ ទើបរំពឹងគិតដូច្នេះថា ឱលោកវិនាសតើហ្ន៎ ឱលោកវិនាសតើហ្ន៎ ព្រោះតថាគតជាអរហន្តសម្មាសម្ពុទ្ធមានព្រះទ័យបង្អោនទៅ ដើម្បីសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅដើម្បីសំដែងធម៌ ។ ម្នាលរាជកុមារ គ្រានោះឯង សហម្បតិព្រហ្ម ក៏បាត់អំពីព្រហ្មលោក មកប្រាកដក្នុងទីចំពោះមុខតថាគត ដូចបុរសមានកម្លាំងលាចេញ នូវដើមដៃដែលគេបត់ចូល ឬបត់ចូលនូវដើមដៃដែលលាចេញ ។ ម្នាលរាជកុមារ លំដាប់នោះ សហម្បតិព្រហ្ម ធ្វើសំពត់ឧត្តរាសង្គឆៀងស្មាម្ខាង ប្រណម្យអញ្ជលីថ្វាយបង្គំចំពោះតថាគត ពោលពាក្យនេះនឹងតថាគតថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សំដែងធម៌ សូមព្រះសុគត សំដែងធម៌ ( ដ្បិត ) សត្វទាំងឡាយ ដែលមានក្អែកមានធូលីគឺរាគាទិក្កិលេសដ៏ស្រាលតិច តែខានស្តាប់ធម៌ មុខជានឹងសាបសូន្យមិនខាន សត្វទាំងឡាយដែលបម្រុងនឹងត្រាស់ដឹងនូវធម៌ក៏គង់មានដែរ ។ ម្នាលរាជកុមារ សហម្បតិព្រហ្ម បានពោលពាក្យនេះ លុះពោលពាក្យនេះរួចហើយ ក៏ពោលពាក្យដទៃតទៅទៀតដូច្នេះថា

ពីមុនរៀងមក ធម៌ដែលជនទាំងឡាយ អ្នកប្រកបដោយ
មន្ទិល តែងគិតជាធម៌មិនបរិសុទ្ធទេ កើតប្រាកដហើយក្នុង
ដែនមគធៈ សូមព្រះអង្គ បើកនូវទ្វារនៃព្រះនិព្វានចុះ សត្វ
ទាំងឡាយ ប្រុងចាំស្តាប់ធម៌ ដែលព្រះអង្គជាអ្នកប្រាសចាក
មន្ទិល ទ្រង់ត្រាស់ដឹង ( តាមលំអានព្រះពុទ្ធអំពីបុរាណ )
ដូចបុរសអ្នកមានចក្ខុ ឈរនៅលើកំពូលភ្នំដ៏ហើយដោយថ្ម
សុទ្ធ ក្រឡេកមើលឃើញ ប្រជុំជនដោយជុំវិញ យ៉ាងណា
មិញ បពិត្រព្រះអង្គអ្នកមានបញ្ញាល្អ មានសមន្តចក្ខុ ព្រះ
អង្គជាអ្នកមានសេចក្តីសោកទៅប្រាសហើយ សូមទ្រង់ឡើង
កាន់ប្រាសាទដ៏ហើយដោយធម៌ ពិចារណាមើលប្រជុំជនអ្នក
ប្រឡាំដោយសេចក្តីសោក ដែលជាតិជរាកំពុងគ្របសង្កត់
មានឧបមេយ្យ ដូច្នោះដែរ បពិត្រព្រះអង្គអ្នកមានព្យាយាម
អ្នកឈ្នះសង្គ្រាម អ្នកនាំពួកសត្វ អ្នកមិនជំពាក់បំណុលគឺ
កាម សូមព្រះអង្គក្រោក សូមទ្រង់ត្រាច់ទៅក្នុងលោក សូម
ព្រះមានព្រះភាគទ្រង់សម្តែងធម៌ សត្វទាំងឡាយដែល
បម្រុងត្រាស់ដឹងធម៌ក៏មាន ។

[ ២៧២ ] ម្នាលរាជកុមារ គ្រានោះឯង តថាគតដឹងច្បាស់នូវសេចក្តី អារាធនា របស់សហម្បតិព្រហ្មផង អាស្រ័យនូវសេចក្តីករុណាដល់ពួកសត្វផង ទើបរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ។ ម្នាលរាជកុមារ កាល

តថាគតរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវសត្វទាំងឡាយ មានក្អែកមានធូលីគឺរាគាទិក្កិលេសតិច ( ខ្លះ ) មានក្អែកមានធូលីគឺរាគាទិក្កិលេសច្រើន ( ខ្លះ ) មានឥន្ទ្រិយក្លា ( ខ្លះ ) មានឥន្ទ្រិយទន់ ( ខ្លះ ) មានអាការៈល្អ ( ខ្លះ ) មានអាការអាក្រក់ ( ខ្លះ ) ជាសត្វដែលគួរឲ្យត្រាស់ដឹងបានដោយងាយ ( ខ្លះ ) ឲ្យត្រាស់ដឹងបានដោយក្រ ( ខ្លះ ) ជាអ្នកឃើញទោស និងភ័យក្នុងបរលោក ( ខ្លះ ) ។ ដូចជាផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី ក្នុងគុម្ពនៃព្រលិតក្តី ក្នុងគុម្ពនៃឈូកក្រហមក្តី ក្នុងគុម្ពនៃឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹកនៅឡើយ មានផ្កាជលជាតិពួកខ្លះ គឺព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ឋិតនៅត្រឹមស្មើនឹងទឹក មានផ្កាជលជាតិពួកខ្លះ គឺផ្កាព្រលិតក្តី ផ្កាឈូកក្រហមក្តី ផ្កាឈូកសក្តី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក ដុះខ្ពស់ឡើងផុតទឹក មិនជាប់ជំពាក់ដោយទឹក មានឧបមាយ៉ាងណាមិញ ម្នាលរាជកុមារ កាលតថាគតរមិលមើលនូវសត្វលោកដោយពុទ្ធចក្ខុ បានឃើញនូវសត្វទាំងឡាយ មានក្អែកមានធូលីគឺ រាគាទិក្កិលេសតិច ( ខ្លះ ) មានក្អែកមានធូលីគឺ រាគាទិក្កិលេសច្រើន ( ខ្លះ ) មានឥន្ទ្រិយក្លា ( ខ្លះ ) មានឥន្ទ្រិយទន់ ( ខ្លះ ) មានអាការៈល្អ ( ខ្លះ ) មានអាការអាក្រក់ ( ខ្លះ ) ជាសត្វដែលគួរឲ្យត្រាស់ដឹងបានដោយងាយ ( ខ្លះ ) ឲ្យត្រាស់ដឹងបានដោយកម្រ ( ខ្លះ ) សត្វចំពួកខ្លះឃើញទោសនិងភ័យក្នុងបរលោក មានឧបមេយ្យ

ដូច្នោះឯង ម្នាលរាជកុមារ គ្រានោះ តថាគតបានសម្តែងជាបទគាថា ចំពោះសហម្បតិព្រហ្មថា

ទ្វារនៃព្រះនិព្វានទាំងនោះ បើកហើយ សត្វទាំងឡាយណា
មានសោតប្បសាទ សត្វទាំងឡាយនោះ ចូរបញ្ចេញនូវសទ្ធា
ចុះ ។ ម្នាលមហាព្រហ្ម តថាគតសម្គាល់ក្នុងការលំបាក
បានជាមិនសម្តែងធម៌ដ៏ឧត្តម ដែលតថាគត ស្ទាត់ហើយ
ក្នុងសំណាក់មនុស្សទាំងឡាយ ។

ម្នាលរាជកុមារ គ្រានោះឯង សហម្បតិព្រហ្មគិតថា ខ្លួនអញជាបុគ្គលដែលព្រះមានព្រះភាគ ទ្រង់យល់ព្រម ដើម្បីនឹងសម្តែងធម៌ហើយ ( លុះគិតហើយ ) ក៏ថ្វាយបង្គំលាតថាគតធ្វើប្រទក្សិណហើយ ក៏បាត់អំពីទីនោះទៅ ។

[ ២៧៣ ] ម្នាលរាជកុមារ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណាអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគត នោះមានសេចក្តីត្រិះរិះយ៉ាងនេះតទៅទៀតថា អាឡារកាលាមគោត្រនេះ ជាបណ្ឌិតជាអ្នកឈ្លាសវៃ ជាអ្នកមានប្រាជ្ញា មានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចយូរមកហើយ បើដូច្នោះ គួរតថាគតសម្តែងធម៌ ដល់អាឡារកាលាមគោត្រជាមុនចុះ តាបសនោះអាចនឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ គ្រានោះ មានពួកទេវតាចូលមករកតថាគត ហើយប្រាប់យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អាឡារកាលាមគោត្រ ធ្វើកាលកិរិយាស្លាប់ ៧ ថ្ងៃទៅហើយ ។ ឯញាណ

ទស្សនៈ ក៏កើតឡើងដល់តថាគតថា អាឡារកាលាមគោត្រ ធ្វើកាលកិរិយា ស្លាប់ទៅ ៧ ថ្ងៃហើយមែន ។ ម្នាលរាជកុមារ ទើបតថាគតមានសេចក្តី ត្រិះរិះ យ៉ាងនេះថា ឱ អាឡារកាលាមគោត្រមានសេចក្តីវិនាសធំ ប្រសិនបើ អាឡារកាលាមគោត្រនោះ បានស្តាប់ធម៌នេះ នឹងត្រាស់ដឹងធម៌បានមួយ រំពេច ។ ម្នាលរាជកុមារ តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើ ដូច្នោះ តថាគត គួរសម្តែងធម៌ដល់អ្នកណាជាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹង ធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគតនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះទៀតថា ឧទ្ទករាមបុត្រនេះឯង ជាបណ្ឌិតមានបញ្ញាឈ្លាសវៃ ជា មេធាវី មានភ្នែកមានធូលីគឺរាគាទិក្កិលេសតិចមកយូរហើយ បើដូច្នោះគួរ តថាគត សម្តែងធម៌ដល់ឧទ្ទករាមបុត្រជាមុនចុះ តាបសនោះនឹងត្រាស់ដឹងធម៌ នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ គ្រានោះមានពួកទេវតា ចូលមក រកតថាគត ហើយប្រាប់យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឧទ្ទករាមបុត្រ ធ្វើកាលកិរិយា ស្លាប់ អំពីពេលព្រលប់ទៅហើយ ។ ញាណទស្សនៈ ក៏កើតឡើងដល់ តថាគតថា ឧទ្ទករាមបុត្រធ្វើកាលកិរិយាស្លាប់ អំពីពេល ព្រលប់ទៅហើយមែន ។ ម្នាលរាជកុមារតថាគតនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា ឱ ឧទ្ទករាមបុត្រមានសេចក្តីវិនាសធំ ប្រសិនបើតាបសនោះ បានស្តាប់ធម៌នេះ នឹងត្រាស់ដឹងដោយឆាប់រហ័ស ។ ម្នាលរាជកុមារ តថាគត នោះមានសេចក្តីត្រិះរិះតទៅទៀតថា តថាគតគួរសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ អ្នកណានឹងត្រាស់ដឹងធម៌នេះឆាប់រហ័សបាន ។ ម្នាលរាជកុមារ តថាគត

នោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បញ្ចវគ្គិយភិក្ខុទាំងឡាយ មានឧបការច្រើន ដល់តថាគតព្រោះបាន បម្រើតថាគត កាលដែលកំពុងបញ្ជូនចិត្តទៅកាន់ព្យាយាម បើដូច្នោះគួរតថាគតសម្តែងធម៌ដល់បញ្ចវគ្គិយភិក្ខុជាមុនចុះ ។ ម្នាលរាជកុមារ តថាគតនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះទៀតថា ឥឡូវនេះពួកបញ្ចវគ្គិយភិក្ខុនៅក្នុងទីណា ។ ម្នាលរាជកុមារ លុះតថាគតនោះ បានឃើញបញ្ចវគ្គិយភិក្ខុទាំងឡាយ នៅក្នុងព្រៃឥសិបតនមិគទាយវន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាត កន្លងលើសចក្ខុរបស់មនុស្ស ។ ម្នាលរាជកុមារ គ្រានោះតថាគតនៅក្នុងឧរុវេលប្រទេស តាមសមគួរដល់អធ្យាស្រ័យ ទើបបានចរទៅកាន់ចារិក សំដៅទៅរកក្រុងពារាណសី ។

[ ២៧៤ ] ម្នាលរាជកុមារ មានអាជីវកឈ្មោះឧបកៈ បានឃើញតថាគតទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃគយាប្រទេស និងចន្លោះនៃពោធិព្រឹក្ស លុះឃើញហើយក៏ពោលពាក្យនេះនឹងតថាគតថា ម្នាលអាវុសោ ឥន្ទ្រិយទាំងឡាយរបស់អ្នកជ្រះថ្លាណាស់ ឆវីវណ្ណរបស់អ្នកក៏បរិសុទ្ធផូរផង់ ម្នាលអាវុសោ អ្នកបួសឧទ្ទិសចំពោះគ្រូណា អ្នកណាជាគ្រូរបស់អ្នក អ្នកពេញចិត្តនឹងធម៌របស់គ្រូណា ។ ម្នាលរាជកុមារ កាលឧបកាជីវកសួរយ៉ាងនេះហើយ តថាគតក៏ឆ្លើយតបដោយពាក្យជាគាថាទៅរកឧបកាជីវកថា

តថាគតជាអ្នកគ្របសង្កត់នូវតេភូមិកធម៌ទាំងអស់ ត្រាស់
ដឹងនូវចតុភូមិកធម៌ទាំងអស់ បានលះបោលនូវតេភូមិកធម៌
ទាំងអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះអស់តណ្ហា

ដឹងច្បាស់នូវចតុព្វមិកធម៌ដោយខ្លួនឯង ( ចាំបាច់ ) ចំពោះបុគ្គលណា ។ តថាគតមិនមានអាចារ្យទេ មិនមានបុគ្គលដទៃស្មើនឹងតថាគត ក្នុងលោកនេះ ព្រមទាំងទេវលោក មិនមានបុគ្គលប្រៀបផ្ទឹមនឹងតថាគតបានឡើយ ព្រោះតថាគតជាអរហន្តក្នុងលោក ជាសាស្តាខ្ពស់ផុត មានតែតថាគតមួយជាសម្មាសម្ពុទ្ធ តថាគតមានសេចក្តីត្រជាក់ មានភ្លើងកិលេសរលត់អស់ហើយ ឥឡូវតថាគត ទៅកាន់បុរីនៃពួកជនអ្នកកាសី ដើម្បីសម្តែងធម្មចក្រ តថាគតនឹងវាយស្គរគឺអមតៈនិព្វាន ចំពោះសត្វលោក ដែលងងឹតគឺអវិជ្ជាកំពុងគ្របសង្កត់ ។

ឧបកាជីវកតបថា ម្នាលអាវុសោ អ្នកប្តេជ្ញាខ្លួនអ្នកយ៉ាងណា អ្នកគួរ ( ដើម្បីបាននូវឈ្មោះ ) ថា អនន្តជិនៈ ( យ៉ាងនោះឯង ) ។ តថាគតក៏តប យ៉ាងនេះទៀតថា

ជនទាំងឡាយណា បានដល់នូវអាសវក្ខ័យ ជនទាំងនោះឈ្មោះជិនៈ ប្រាកដដូចតថាគតដែរ ។ តថាគតបានឈ្នះបាបធម៌ទាំងអស់ហើយ ម្នាលឧបកៈ ព្រោះហេតុនោះ ទើបតថាគតឈ្មោះថា ជិនៈ ។

ម្នាលរាជកុមារ កាលតថាគត តបយ៉ាងនេះហើយ ឧបកាជីវកក៏ ពោលថា ម្នាលអាវុសោពាក្យយ៉ាងហ្នឹងពិតមែនហើយ ( ថាហើយ ) ក៏ងក់ក្បាល

លៀនអណ្តាតកាន់យកផ្លូវផ្សេង ចៀសចេញទៅ ។

[ ២៧៥ ] គ្រានោះ តថាគតចរទៅកាន់ចារិក តាមលំដាប់ហើយ ក៏ចូលទៅក្រុងពារាណសី រួចហើយទៅឯឥសិបតនមិគទាយវ័ន សំដៅទៅរកកន្លែងដែលបញ្ចវគ្គិយភិក្ខុនៅ ។ ម្នាលរាជកុមារ ពួកបញ្ចវគ្គិយភិក្ខុបានឃើញតថាគតមកអំពីចម្ងាយ លុះឃើញហើយក៏ប្តេជ្ញាគ្នាថា ម្នាលអាវុសោ សមណគោតមនេះ ជាអ្នកប្រតិបត្តិដើម្បីល្មោភ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់ដើម្បីភាវៈល្មោភ ឥឡូវនេះ លោកនិមន្តមក យើងទាំងអស់គ្នា មិនគួរថ្វាយបង្គំ មិនគួរក្រោកទទួលលោកទេ មិនគួរទទួលបាត្រចីវរលោកឡើយ ប៉ុន្តែយើងត្រូវក្រាលអាសនៈបម្រុងទុក បើលោកនឹងចង់គង់ក៏គង់ចុះ ។ ម្នាលរាជកុមារ តថាគតចូលទៅរកបញ្ចវគ្គិយភិក្ខុដោយប្រការណាៗ បញ្ចវគ្គិយភិក្ខុទាំងនោះក៏មិនអាចដើម្បីឋិតនៅក្នុងពាក្យប្តេជ្ញារបស់ខ្លួន ដោយប្រការដូច្នោះៗបានឡើយ ក៏ស្រាប់តែខ្លះក្រោកទទួលតថាគត ខ្លះទទួលបាត្រចីវរ របស់តថាគត ខ្លះក្រាលអាសនៈឲ្យ ខ្លះតម្កល់ទឹកលាងជើង ប៉ុន្តែពួកបញ្ចវគ្គិយភិក្ខុ ក៏នៅតែហៅតថាគតដោយចំណោះផង ដោយពាក្យថាអាវុសោផង ។ ម្នាលរាជកុមារ កាលពួកបញ្ចវគ្គិយភិក្ខុ ពោលពាក្យហៅតថាគតយ៉ាងនេះហើយ តថាគតពោលយ៉ាងនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា កុំហៅតថាគតដោយចំណោះ និងពាក្យថាអាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងសោតបសាទចុះ តថាគតនឹងប្រៀនប្រដៅអមតធម៌ ដែល

តថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិគួរតាមពាក្យប្រៀនប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ កាលតថាគតពោលយ៉ាងនេះហើយ ពួកបញ្ចវគ្គិយភិក្ខុក៏ពោលពាក្យនេះ នឹងតថាគតទៀតថា ម្នាលអាវុសោគោតម ព្រះអង្គមិនទាន់ត្រាស់ដឹងឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណទស្សនៈដ៏ឧត្តមអាចកម្ចាត់បង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយការប្រតិបត្តិនោះផង ដោយអំពើដែលអ្នកដទៃ ធ្វើត្រាប់បានដោយកម្រផង ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើនហើយ ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីភាពល្មោភច្រើនហើយ ក៏នឹងបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ដ៏វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់កិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ លុះបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ តថាគតក៏ពោលនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់មកដើម្បីល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងសោតបសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវ

នេះ តថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើប្រតិបត្តិគួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ ពួកបញ្ចវគ្គិយភិក្ខុ បានពោលពាក្យនេះនឹងតថាគតជាគម្រប់ ២ ដងថា ម្នាលអាវុសោគោតម ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេស ដោយការប្រព្រឹត្តិនោះផង ដោយសេចក្តីប្រតិបត្តិនោះផង ដោយអំពើដែលជនដទៃធ្វើត្រាប់បានដោយកម្រផង ឥឡូវនេះព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកសេចក្តីព្យាយាមហើយ វិលត្រឡប់មកដើម្បីភាពល្មោភច្រើនហើយ នឹងបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេស ដោយញាណទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់នូវកិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ ឯតថាគតក៏បានពោលពាក្យនេះ នឹងបញ្ចវគ្គិយភិក្ខុទាំងឡាយ ជាគម្រប់ ២ ដងថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនប្រតិបត្តិដើម្បីល្មោភច្រើនទេ មិនឃ្លាតចាកព្យាយាមទេ មិនវិលត្រឡប់ដើម្បីមកល្មោភច្រើនដូច្នោះទេ ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងសោតបសាទចុះ តថាគតនឹងប្រៀនប្រដៅនូវអមតធម៌ ដែលតថាគតត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បី

ប្រយោជន៍ដល់អនុត្តរធម៌ណា អ្នកទាំងឡាយ កាលបើបានប្រតិបត្តិគួរដល់ពាក្យប្រដៅរបស់តថាគតហើយ ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ បញ្ចវគ្គិយភិក្ខុ បានពោលពាក្យនេះនឹងតថាគតអស់វារៈ ជាគម្រប់ ៣ ដងទៀតថា ម្នាលអាវុសោ ព្រះអង្គមិនទាន់បានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌វិសេសដោយញាណទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់កិលេស ដោយការប្រព្រឹត្តិនោះផង ដោយសេចក្តីប្រតិបត្តិនោះផង ដោយអំពើដែលជនដទៃធ្វើត្រាប់បានដោយកម្រនោះផង ឥឡូវនេះ ព្រះអង្គប្រតិបត្តិដើម្បីល្មោភច្រើន ឃ្លាតចាកព្យាយាមហើយ វិលត្រឡប់មកដើម្បីល្មោភច្រើន នឹងបានត្រាស់ដឹងនូវឧត្តរិមនុស្សធម៌ ជាធម៌ដ៏វិសេសដោយញាណទស្សនៈដ៏ឧត្តម អាចកម្ចាត់បង់កិលេសដូចម្តេចបាន ។ ម្នាលរាជកុមារ កាលបើបញ្ចវគ្គិយភិក្ខុទាំងឡាយ ពោលពាក្យយ៉ាងនេះហើយ តថាគតក៏ពោលពាក្យនេះនឹងបញ្ចវគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចាំបានដែរឬ ពាក្យមានសភាពយ៉ាងនេះ ជាពាក្យដែលតថាគត ធ្លាប់បានពោលមកអំពីមុនឬអ្វី ។ បញ្ចវគ្គិយភិក្ខុទាំងឡាយតបថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យហ្នឹងព្រះអង្គមិនដែលពោលទេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតបានជាអរហន្តសម្មាសម្ពុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រុងសោតបសាទចុះ តថាគតនឹងប្រៀនប្រដៅ នូវអមតធម៌ដែលតថាគតបានត្រាស់ដឹងហើយ ឥឡូវតថាគតនឹងសម្តែងធម៌ ក៏កុលបុត្រ

ទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា កាលបើអ្នកទាំងឡាយ ប្រតិបត្តិគួរតាមពាក្យប្រដៅរបស់តថាគត ពុំយូរឡើយ មុខជានឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ ម្នាលរាជកុមារ តថាគតអាចញុំាងបញ្ចវគ្គិយភិក្ខុទាំងឡាយ ឲ្យយល់ច្បាស់ ( ក្នុងពេលនោះ ) បាន ។ ម្នាលរាជកុមារ តថាគតបានប្រៀនប្រដៅភិក្ខុទាំងឡាយតែ ២ រូប ។ ភិក្ខុ ៣ រូបនាំគ្នាត្រាច់ទៅបិណ្ឌបាត ។ ភិក្ខុ ៣ រូប ដែលត្រាច់ទៅបិណ្ឌបាត នាំមកនូវអាហារណា អាហារនោះ យើង ៦ នាក់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ម្នាលរាជកុមារ តថាគតប្រដៅភិក្ខុ ៣ រូប ។ ពួកភិក្ខុ ២ រូបត្រាច់ទៅបិណ្ឌបាត នាំមកនូវអាហារណា អាហារនោះ យើងទាំង ៦ នាក់ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ។ ម្នាលរាជកុមារ គ្រានោះឯង ពួកបញ្ចវគ្គិយភិក្ខុកាលបើតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏កុលបុត្តទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ពុំយូរឡើយ ក៏បានត្រាស់ដឹងដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈហើយ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[ ២៧៦ ] កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ពោធិរាជកុមារ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកាលយូរប៉ុន្មានទៅ ភិក្ខុដែលបានព្រះតថាគតជាអ្នកនែនាំ ( យ៉ាងនេះ )

ហើយ កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា នឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះនូវអនុត្តរធម៌នោះ ដែលមានមគ្គព្រហ្មចរិយៈជាទីបំផុត ។ ម្នាលរាជកុមារ បើដូច្នោះ តថាគតនឹងត្រឡប់សួរទ្រង់ក្នុងប្រស្នានោះវិញ ទ្រង់គប្បីដោះស្រាយប្រស្នានោះ តាមដែលទ្រង់ឃើញថាសមគួរចុះ ម្នាលរាជកុមារ ទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច ទ្រង់ជាអ្នកឈ្លាស ក្នុងសិល្បសាស្រ្ត ក្នុងកាលឡើងជិះដំរី និងការកាន់កង្វេរឬ ។ បពិត្រព្រះអង្គដ៏ចម្រើនយ៉ាងនេះមែនហើយ ខ្ញុំព្រះអង្គជាអ្នកឈ្លាស ក្នុងសិល្បសាស្រ្តក្នុងការឡើងជិះដំរី និងការចាប់កាន់កង្វេរ ។

[ ២៧៧ ] ម្នាលរាជកុមារ ទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច បុរសក្នុងនគរនេះគិតថា ពោធិរាជកុមារ ចេះសិល្បសាស្រ្តឡើងជិះដំរី និងចាប់កាន់កង្វេរ អាត្មាអញនឹងសូមរៀនសិល្បសាស្រ្តឡើងជិះដំរី និងចាប់កាន់កង្វេរក្នុងសំណាក់របស់ពោធិរាជកុមារនោះ ។ តែថាបុរសនោះជាអ្នកមិនមានសទ្ធា សិល្បសាស្រ្តទាំងប៉ុន្មានដែលគេគប្បីបានដោយសទ្ធា សិល្បសាស្រ្តនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមានអាពាធច្រើន សិល្បសាស្រ្តទាំងប៉ុន្មាន ដែលគេគប្បីបានដោយមិនមានអាពាធ សិល្បសាស្រ្តនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកអួតអាង មានមាយា សិល្បសាស្រ្តទាំងប៉ុន្មានដែលគេគប្បីបានដោយការមិនអួតអាង ទាំងមិនមានមាយា សិល្បសាស្រ្តនោះ ក៏មិនគប្បី

សម្រេចបានឡើយ ។ មួយយ៉ាងទៀត បុរសនោះជាអ្នកខ្ជិលច្រអូស សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយមានព្យាយាម ប្រារព្ធហើយ សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ មួយយ៉ាងវិញទៀត បុរសនោះជាអ្នកអាប់ប្រាជ្ញា សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយមានប្រាជ្ញា សិល្បសាស្ត្រនោះ ក៏មិនគប្បីសម្រេចបានឡើយ ។ ម្នាលរាជកុមារ ទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះគប្បីសិក្សា សិល្បសាស្ត្រឡើងជិះដំរី និងចាប់កាន់កង្វេរក្នុងសម្នាក់របស់ព្រះអង្គ បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះ ដែលប្រកបដោយអង្គ សូម្បីតែមួយៗ ក៏មិនគប្បីសិក្សាសិល្បសាស្ត្រ ឡើងជិះដំរី និងចាប់កាន់ កង្វេរក្នុងសម្នាក់ខ្ញុំព្រះអង្គបានឡើយ នឹងបាច់ពោលទៅថ្វីដល់បុគ្គលដែលប្រកបដោយអង្គ ៥ នោះ ។

[ ២៧៨ ] ម្នាលរាជកុមារ ទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច បុរសក្នុងនគរនេះគិតថា ពោធិរាជកុមារ ចេះសិល្បសាស្ត្រឡើងជិះដំរី នឹងចាប់កាន់កង្វេរ អាត្មាអញនឹងសូមសិក្សាសិល្បសាស្ត្រឡើងជិះដំរី នឹងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ពោធិរាជកុមារនោះ ។ ឯបុរសនោះ ជាអ្នកមានសទ្ធា សិល្បសាស្ត្រទាំងប៉ុន្មានដែលគេគប្បីបានដោយសទ្ធា សិល្បសាស្ត្រនោះ ក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមានអាពាធតិច សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយអាពាធតិច សិល្បសាស្ត្រនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះជាអ្នកមិនអួត

អាងមិនមានមាយា សិល្បសាស្ត្រទាំងប៉ុន្មានដែលគេគប្បីបាន ដោយការមិនអួតអាង មិនមានមាយា សិល្បសាស្ត្រនោះ ក៏គប្បីសម្រេចបាន ។ មួយយ៉ាងទៀត បុរសនោះ ជាអ្នកមានសេចក្តីព្យាយាមប្រារព្ធហើយ សិល្បសាស្ត្រទាំងប៉ុន្មាន ដែលគេគប្បីបានដោយមានសេចក្តីព្យាយាមប្រារព្ធហើយ សិល្បនោះក៏គប្បីសម្រេចបាន ។ មួយយ៉ាងវិញទៀត បុរសនោះជាអ្នកមានប្រាជ្ញា សិល្បសាស្ត្រទាំងប៉ុន្មានដែលគេគប្បីបានដោយមានប្រាជ្ញា សិល្បសាស្ត្រនោះ ក៏គប្បីសម្រេចបាន ។ ម្នាលរាជកុមារ ទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច បុរសនោះ គប្បីសិក្សាសិល្បសាស្ត្រឡើងជិះដំរីនឹងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ទ្រង់បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះដែលប្រកបដោយអង្គ សូម្បីតែមួយៗ ក៏គប្បីសិក្សាសិល្បសាស្ត្រឡើងជិះដំរី និងចាប់កាន់កង្វេរ ក្នុងសំណាក់របស់ខ្ញុំព្រះអង្គបាន នឹងបាច់ពោលទៅថ្វីដល់បុគ្គលប្រកបដោយអង្គ ៥ ។

[ ២៧៩ ] ម្នាលរាជកុមារ អង្គនៃសេចក្តីព្យាយាមរបស់ភិក្ខុ ៥ ប្រការនេះក៏ដូច្នោះដែរ ។ អង្គទាំង ៥ ប្រការតើដូចម្តេចខ្លះ ។ ម្នាលរាជកុមារ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះ

អង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្ស ទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់ មកកាន់ភពថ្មីទៀត ។ ភិក្ខុនោះជាអ្នកមានអាពាធតិច មានទុក្ខតិច ប្រកប ដោយតេជោធាតុ មានវិបាកដ៏ស្មើគ្នា គឺមិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាង កណ្តាល ល្មមអត់ធន់ធ្វើសេចក្តីព្យាយាមបាន ។ ភិក្ខុនោះជាអ្នកមិនអួតអាង មិនមានមាយា សម្តែងខ្លួនឲ្យច្បាស់ក្នុងសាស្តា ឬវិញ្ញូជនទាំងឡាយជា សព្រហ្មចារីបុគ្គលតាមសេចក្តីពិត ។ ភិក្ខុនោះជាអ្នកមានសេចក្តីព្យាយាម ប្រារព្ធ ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ជាអ្នកមានកម្លាំង ដើម្បី ធ្វើកុសលធម៌ទាំងឡាយ ឲ្យកើតឡើងបាន ជាអ្នកមានសេចក្តីព្យាយាមដ៏មាំ មួន មិនបានបោះបង់ធុរៈក្នុងកុសលធម៌ ។ ភិក្ខុនោះជាអ្នកមានប្រាជ្ញា ប្រកប ដោយប្រាជ្ញាជាគ្រឿងកំណត់ដឹងនូវការកើតឡើង និងសេចក្តីវិនាសទៅវិញ ប្រកបដោយប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងទម្លាយបង់នូវលោភៈជាដើម ជាគ្រឿង កំណត់នូវការក្ស័យទៅនៃសេចក្តីទុក្ខដោយប្រពៃ ។ ម្នាលរាជកុមារ អង្គនៃ សេចក្តីព្យាយាមទាំងឡាយរបស់ភិក្ខុមាន ៥ ប្រការ នេះឯង ។ ម្នាល រាជកុមារ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះ ហើយ បាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ដែលចេញចាក ផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា នឹងបាន ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ចូលទៅសម្រេចសម្រាន្តនៅដោយឥរិយា-

បថទាំង ៤ អស់ ៧ ឆ្នាំ ។ ម្នាលរាជកុមារ ៧ ឆ្នាំលើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ បានតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា នឹងបានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ចូលទៅសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៦ ឆ្នាំ... អស់ ៥ ឆ្នាំ... អស់ ៤ ឆ្នាំ... អស់ ៣ ឆ្នាំ... អស់ ២ ឆ្នាំ... អស់ ១ ឆ្នាំ ។ ម្នាលរាជកុមារ មួយឆ្នាំក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះ កាលបាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា គង់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៧ ខែ ។ ម្នាលរាជកុមារ ៧ ខែក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ ប្រការនេះហើយ កាលបានតថាគតជាអ្នកណែនាំ ក៏កុលបុត្តទាំងឡាយ ចេញចាកផ្ទះចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់ ៦ ខែ ... អស់ ៥ ខែ ... អស់ ៤ ខែ ... អស់ ៣ ខែ ... អស់ ២ ខែ

... អស់ ១ ខែ... អស់កន្លះខែ ។ ម្នាលរាជកុមារ កន្លះខែក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្ដីព្យាយាម ៥ ប្រការនេះហើយ កាលបាននូវតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា គង់នឹងបានធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះចំពោះអនុត្តរធម៌នោះ ដែលជា ទីបំផុតនៃមគ្គព្រហ្មចរិយៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់យប់ និងថ្ងៃ ៧ ។ ម្នាលរាជកុមារ យប់ និងថ្ងៃ ៧ ក៏លើកទុកចុះ ។ ម្នាលរាជកុមារ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្ដីព្យាយាម ៥ ប្រការនេះហើយ កាលបានតថាគតជាអ្នកណែនាំ ក៏កុលបុត្រទាំងឡាយ ដែលចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា គង់បានធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញារបស់ខ្លួន ក្នុងបច្ចុប្បន្ននេះ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ អស់យប់ និងថ្ងៃ ៦ ... អស់យប់និងថ្ងៃ ៥ ... អស់យប់និងថ្ងៃ ៤ ... អស់យប់និងថ្ងៃ ៣ ... អស់យប់និងថ្ងៃ ២ ... អស់យប់នឹងថ្ងៃ ១ ។ ម្នាលរាជកុមារ យប់មួយថ្ងៃមួយក៏លើកទុកចុះ ។ ភិក្ខុដែលប្រកបដោយអង្គនៃសេចក្ដីព្យាយាម ៥ ប្រការនេះហើយ កាលបាននូវតថាគតជាអ្នកណែនាំ តថាគតប្រៀនប្រដៅក្នុងវេលាល្ងាច លុះព្រឹកឡើងនឹងបានសម្រេចគុណវិសេសក៏មាន តថាគតប្រដៅក្នុងវេលាព្រឹក លុះវេលាល្ងាចនឹងបានសម្រេចនូវគុណវិសេសក៏មាន ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ

ពោធិរាជកុមារ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា ព្រះពុទ្ធជាអស្ចារ្យ ព្រះធម៌ជាអស្ចារ្យ ទាំងភាវៈនៃធម៌ដែលព្រះអង្គត្រាស់ហើយដោយប្រពៃក៏អស្ចារ្យ ព្រោះថា សត្វដែលព្រះអង្គប្រៀនប្រដៅក្នុងវេលាល្ងាច លុះព្រឹកឡើងនឹងបានសម្រេចគុណវិសេសក៏មាន ព្រះអង្គប្រដៅក្នុងវេលាព្រឹក វេលាល្ងាចនឹងបានសម្រេចគុណវិសេសក៏មាន ។

[ ២៨០ ] កាលពោធិរាជកុមារក្រាបទូលយ៉ាងនេះហើយ សញ្ជិកាបុត្តមាណពបានក្រាបទូលពោធិរាជកុមារយ៉ាងនេះវិញថា ពោធិរាជកុមារជាម្ចាស់នេះ គ្រាន់តែប្រកាសសេចក្តីថា ព្រះពុទ្ធជាអស្ចារ្យ ព្រះធម៌ជាអស្ចារ្យ ភាវៈនៃធម៌ដែលព្រះអង្គត្រាស់ហើយ ក៏ជាអស្ចារ្យដូច្នេះ ប៉ុន្តែពោធិរាជកុមារ ជាម្ចាស់មិនទាន់ដល់ព្រះគោតមនោះផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹកនៅឡើយ ។

[ ២៨១ ] ម្នាលសញ្ជិកាបុត្តសម្លាញ់ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលសញ្ជិកាបុត្តសម្លាញ់ អ្នកកុំពោលយ៉ាងនេះឡើយ ម្នាលសញ្ជិកាបុត្តសម្លាញ់ ពាក្យនោះខ្ញុំបានស្តាប់ក្នុងទីចំពោះមុខ ខ្ញុំបានទទួលក្នុងទីចំពោះមុខនៃព្រះមាតាជាម្ចាស់ ម្នាលសញ្ជិកាបុត្តសម្លាញ់ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី សម័យនោះឯង ព្រះមាតាជាម្ចាស់របស់ខ្ញុំទ្រង់គភ៌ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ លុះព្រះមាតាជាម្ចាស់របស់ខ្ញុំគង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមាន

ព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទារកដែលនៅក្នុងគភ៌របស់ខ្ញុំម្ចាស់នេះ ទោះបីជាកុមារក្តី ជាកុមារីក្តី សូមដល់ព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផងជាទីពឹងទីរលឹក សូមព្រះមានព្រះភាគចាំទុកនូវទារកនោះថា ជាឧបាសក អ្នកដល់នូវព្រះត្រៃសរណគមស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតទៅ ដូច្នេះ ម្នាលសញ្ជិកាបុត្តសម្លាញ់ សម័យមួយទៀត ព្រះមានព្រះភាគស្តេចគង់នៅនាភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ម្រឹគ ជិតក្រុងឈ្មោះសុំសុមារគិរៈ ក្នុងភគ្គជនបទ គ្រានោះឯង មេនំបានបំបៅខ្ញុំលើក្លៀកហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចឈរនៅក្នុងទីដ៏សមគួរ លុះមេនំឈរក្នុងទីដ៏សមគួរហើយបានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពោធិរាជកុមារនេះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក សូមព្រះមានព្រះភាគ ចាំទុកនូវពោធិរាជកុមារនោះ ថាជាឧបាសក អ្នកដល់នូវព្រះត្រៃសរណគមស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះទៅ ម្នាលសញ្ជិកាបុត្តសម្លាញ់ ខ្ញុំនុ៎ះបានដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹកអស់វារៈជាគម្រប់ ៣ ដងផង សូមព្រះមានព្រះភាគចាំនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវព្រះត្រៃសរណគមស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ ។

ចប់ ពោធិរាជកុមារសូត្រទី ៥

# អដ្ឋកថា

## ពោធិរាជកុមារសូត្រ

[ ២៤៧ ] *ពោធិរាជកុមារសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនេះ បទថា* **កោកនទោ** *សេចក្តីថា ផ្កាឈូក លោកហៅថា កោកនទៈប្រាសាទដែលជាមណ្ឌលនោះ លោកធ្វើបង្ហាញឲ្យដូចផ្កាឈូកដែលមើលឃើញ ព្រោះដូច្នោះ ទើបដល់នូវការរាប់ថា កោកនទប្រាសាទ ។*

[ ២៤៨ ] *កាំជណ្តើរជាន់ដំបូង លោកហៅថា ជណ្តើរជាន់ក្រោម ក្នុងបទថា* **យាវ បច្ឆិមសោបានកឡេវរា** *នេះ ។*

[ ២៤៩ ] *បទថា* **អទ្ទសា ខោ** *សេចក្តីថា បុគ្គលដែលឈរត្រង់ខ្លោងទ្វារនោះឯងដើម្បីត្រូវការមើលក៏ឃើញហើយ ។ បទថា* **ភគវា តុណ្ហី អហោសិ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រំពឹងមើលថា ព្រះរាជកុមារទ្រង់ធ្វើសក្ការៈធំនេះ ដើម្បីប្រាថ្នាអ្វីហ្ន៎ ទើបទ្រង់ជ្រាបថា ទ្រង់ធ្វើព្រោះប្រាថ្នាព្រះឱរស ។ ព្រះរាជកុមារនោះ មិនមានឱរស ទ្រង់ប្រាថ្នាព្រះឱរសបានឮថា ជនទាំងឡាយធ្វើអធិការ ការធ្វើដែលធំក្រៃលែងដល់ព្រះពុទ្ធទាំងឡាយ ទើបនឹងបានវត្ថុដូចចិត្តប្រាថ្នា ដូច្នេះ ។ ព្រះរាជកុមារទ្រង់ធ្វើសេចក្តីប្រាថ្នាថា បើអញបានបុត្រសោត ព្រះសម្មាសម្ពុទ្ធទ្រង់នឹងជាន់បន្ទះសំពត់របស់អញ បើអញមិនបាន ទ្រង់នឹងមិនជាន់ ទើបប្រើឲ្យក្រាលសំពត់ទុក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលថា បុត្ររបស់ព្រះរាជានេះ*

នឹងមានឬទេហ្ន៎ ហើយទ្រង់ឃើញថា នឹងមិនមាន ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ក្នុងកាលមុន ព្រះរាជានោះ នៅក្នុងកោះមួយ ទ្រង់បរិភោគកូនបក្សី ដោយមានឆន្ទៈស្មើគ្នា ។ បើមាតុគ្រាមរបស់ព្រះរាជាគប្បីមានចិត្តជាទៃសោត ក៏នឹងបានបុត្រ តែជនទាំង ២ មានឆន្ទៈស្មើគ្នា ធ្វើបាបកម្មទុក ដូច្នេះ ទើបបុត្ររបស់ព្រះរាជានេះមិនមាន ដូច្នេះ ។ តែបើតថាគតជាន់សំពត់ព្រះរាជកុមារ ក៏នឹងសម្គាល់ខុសបានថា កិត្តិសព្ទបានផ្សាយក្នុងលោកថា បុគ្គលធ្វើអធិការដល់ព្រះពុទ្ធទាំងឡាយហើយ រមែងបានវត្ថុដែលខ្លួនប្រាថ្នាហើយ អញបានធ្វើអភិនីហារដ៏ច្រើនផង អញក៏មិនបានបុត្រផង កិត្តិសព្ទនេះមិនពិត ។ សូម្បីពួកតិរ្ថិយទាំងឡាយ ក៏តិះដៀលថា ឈ្មោះថា វត្ថុដែលមិនគួរធ្វើរបស់សមណៈទាំងឡាយមិនមាន ពួកសមណៈជាន់ផ្ទាំងសំពត់ត្រាច់ទៅដូច្នេះ ។ កាលជាន់ក្នុងឥឡូវនេះភិក្ខុជាច្រើនដែលដឹងចិត្តអ្នកដទៃ ភិក្ខុទាំងនោះជ្រាបថាគួរក៏នឹងជាន់ ដែលជ្រាបថាមិនគួរក៏នឹងមិនជាន់ ក្នុងអនាគតនឹងមានឧបនិស្ស័យតិច ជនទាំងឡាយនឹងមិនដឹងអនាគត ។ កាលភិក្ខុទាំងនោះជាន់ បើវត្ថុដែលគេប្រាថ្នាសម្រេចសោត សេចក្តីនុ៎ះចាត់ជាការល្អ បើមិនសម្រេច ( ក៏នឹងតិះដៀល ) ព្រះមានព្រះភាគទ្រង់មិនប្រាថ្នានឹងជាន់ ទើបទ្រង់ស្ងៀម ដោយហេតុទាំងនេះ គឺ ពួកមនុស្សនឹងក្តៅក្រហាយជាខាងក្រោយថា ក្នុងកាលមុន បុគ្គលធ្វើអភិនីហារដល់ភិក្ខុសង្ឃ រមែងបានវត្ថុដែលប្រាថ្នាហើយ ព្រោះភិក្ខុទាំងឡាយបដិបត្តិបរិបូណ៌ ឥឡូវនេះមិនបានប្រហែលជាពួកភិក្ខុទាំងនេះ មិនអាចនឹងបដិបត្តិឲ្យបរិបូណ៌ ដូច្នេះ ។ ទើប

ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវជាន់កម្រាលសំពត់ទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។ តែកាលភិក្ខុទាំងឡាយមិនកន្ទង់បទបញ្ញត្តិ ដើម្បីភាពជាមង្គល ទើបព្រះមានព្រះភាគទ្រង់តាំងអនុប្បញ្ញត្តិទុកដើម្បីឲ្យជាន់បានថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលគ្រហស្ថអង្វរ ដើម្បីប្រយោជន៍ជាមង្គល ជាន់កម្រាលសំពត់បាន ដូច្នេះ ។

បទថា **បច្ឆិមំ ជនតំ តថាគតោ អបលោកេតិ** សេចក្តីថា ព្រះថេរៈពោលសំដៅហេតុទី ៣ ក្នុងបណ្តាហេតុដែលពោលហើយ ។ ព្រោះហេតុអ្វីទើបលោកពោល ពាក្យថា **ឆ ខោ សុខេន សុខំ** ដូច្នេះ ។ ព្រោះលោកសម្គាល់ថា ប្រហែលព្រះសម្មាសម្ពុទ្ធ មានសេចក្តីសម្គាល់ក្នុងកាមសុខល្លិកានុយោគ ទើបទ្រង់មិនជាន់ ព្រោះដូច្នោះ សូម្បីអញក៏នឹងមានធនូះស្មើដោយព្រះសាស្តា ដូច្នេះ ទើបពោលយ៉ាងនោះ ។

[ ២៥០ ] បទថា **សោ ខោ អហំ** ជាដើម រហូតដល់ **យាវ រត្តិយា បច្ឆិមេ យាមេ** បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងមហាសច្ចសូត្រនោះឯង តអំពីនោះ គឺតាំងអំពីបទថា **បញ្ចវគ្គិយានំ អាសវក្ខយា** គប្បីជ្រាបដោយន័យដែលពោលទុកក្នុងបាសរាសិសូត្រ នោះឯង ។

[ ២៧៧ ] បទថា **អង្កុសគ្គណ្ហេ សិប្បេ** បានដល់ សិប្បៈរបស់អ្នកកាន់កង្វេរ ។ បទថា **កុសលោ អហំ** សេចក្តីថា ខ្ញុំជាអ្នកឈ្លាស ។ កុមារនេះរៀនសិប្បៈ ក្នុងសម្នាក់របស់អ្នកណា ។ បិតារៀនក្នុងសម្នាក់របស់ជីតា កុមារនេះរៀនក្នុងសម្នាក់បិតា ។

បានឮថា ក្នុងនគរកោសម្ពី ព្រះរាជាព្រះនាមថា បរន្តបៈ ទ្រង់កំពុងសោយ-រាជ្យ ។ ព្រះរាជមហេសីមានព្រះគភ៌ ព្រះនាងអង្គុយដណ្ដប់សំពត់កម្ពលពណ៌ ក្រហមអាំងថ្ងៃ ជាមួយព្រះរាជាត្រង់ជាយព្រះដំណាក់ ។ មានបក្សីហត្ថិលិង្គមួយ សម្គាល់ថា ជាដុំសាច់ ចុះមកចាបយកព្រះនាងទៅក្នុងអា-កាស ។ ព្រះនាងខ្លាចបក្សីទម្លាក់ព្រះនាងចោល ទើបនៅស្ងៀម ។ បក្សីនោះនាំព្រះនាងទៅចុះត្រង់ប្រគាបឈើនាជើងភ្នំមួយកន្លែង ទើបព្រះនាងទះដៃ ធ្វើសំឡេងខ្លាំងឡើង បក្សីភិតភ័យគេចទៅហើយ ព្រះនាងក៏ប្រសូតព្រះឱរស លើប្រគាបឈើនោះឯង ។ កាលភ្លៀងធ្លាក់ចុះក្នុងរាត្រី វេលាយាម ៣ ទើបព្រះនាងយកសំពត់កម្ពលដណ្ដប់ប្រថាប់គង់ ។ ក្នុងទីមិនឆ្ងាយអំពីជើងភ្នំនោះ មានតាបសមួយរូបនៅអាស្រ័យ ដោយសំឡេងយំរបស់ព្រះនាងនោះ ទើបតាបសមកកាន់គល់ឈើ ក្នុងកាលអរុណរះឡើង សួរព្រះនាងដល់ជាតិ ហើយដាក់ជណ្ដើរឲ្យនាងចុះមក នាំទៅកាន់លំនៅរបស់ខ្លួន ឲ្យបរិភោគបបរ ។ ព្រោះទារកកាន់យករដូវនៃពពក និងរដូវនៃភ្នំកើតហើយ ទើបតាំងឈ្មោះថា ឧទេន ។ តាបសរកផ្លែឈើមកចិញ្ចឹមជនទាំង ២ ថ្ងៃមួយព្រះនាងធ្វើការ ទទួលក្នុងវេលាតាបសត្រឡប់សម្ដែងមាយាស្ត្រី ធ្វើតាបសឲ្យបែកធ្លាយសីលហើយ កាលជនទាំងនោះ នៅរួមគ្នា កាលវេលាក៏កន្លងទៅ ព្រះបាទបរន្តបៈ សោយទិវង្គតហើយ ។ តាបសងើបមើលផ្កាយនក្ខត្តឫក្សក្នុងវេលារាត្រីក៏ដឹងថា ព្រះរាជាសោយទិវង្គត ទើបសួរថា ព្រះរាជារបស់នាងសោយទិវង្គតហើយ នាងត្រូវការឲ្យបុត្រ

របស់នាងនៅក្នុងទីនេះ ឬនឹងឲ្យលើកស្វេតច្ឆត្រក្នុងរាជ្យសម្បត្តិរបស់បិតា ។ ទើបព្រះនាងនិទានរឿងរ៉ាវទាំងអស់តាំងអំពីដើមមក ឲ្យព្រះឱរសជ្រាប ព្រះ-ឱរសត្រូវការលើកស្វេតច្ឆត្ររបស់ព្រះបិតាទើបប្រាប់ដល់តាបស ។ តាបសចេះវិជ្ជាចាប់ដំរី ។ សួរថា វិជ្ជានោះតាបសបានមកអំពីណា ។ ឆ្លើយថា បានមកអំពីសម្នាក់សក្កទេវរាជ ។ បានឮថា ក្នុងកាលមុន សក្កទេវ-រាជមកទំនុកបម្រុងតាបសនោះ បានសួរថា លោកម្ចាស់លំបាកដោយរឿងអ្វីខ្លះ ទើបតាបសទូលថា មានអន្តរាយទាក់ទងជាមួយដំរី ។ ទើបសក្ក-ទេវរាជឲ្យនូវវិជ្ជាចាប់ដំរី និងពិណដល់តាបសនោះ បង្រៀនថា បើត្រូវការឲ្យដំរីគេចចូរដេញខ្សែមួយនេះ ហើយរាយមន្តនេះ កាលបំណងនឹងឲ្យដំរីមកក៏ចូររាយមន្តនេះ ដូច្នេះ ។ ទើបតាបសបង្រៀនសិប្បៈនោះដល់កុមារ ព្រះកុមារនោះឡើងដើមជ្រៃមួយដើម កាលដំរីទាំងឡាយមកហើយ ក៏ដេញពិណរាយមន្ត ។ ដំរីទាំងឡាយខ្លាចគេចទៅហើយ ។ ព្រះកុមារ ជ្រាបអានុ-ភាពរបស់សិប្បៈ ថ្ងៃស្អែកឡើង ទើបប្រកបសិប្បៈហៅដំរី ។ ដំរីដែលជាមេហ្វូងក៏មក បង្អោនកចូលទៅក្បែរ ។ ព្រះរាជកុមារឡើងកដំរីហើយជ្រើសដំរីជំទង់ៗ ដែលល្មមនឹងច្បាំងបានហើយ ក៏យកសំពត់កម្ពល និងព្រះទម្រង់ទៅថ្វាយបង្គំមាតាបិតាទៅដោយលំដាប់ ទៅកាន់ស្រុកនោះៗ ប្រមូលមនុស្សម្នាប្រាប់ថា ខ្ញុំជាឱរសរបស់ព្រះរាជា ត្រូវការសម្បត្តិទើបមក ហើយទៅព័ទ្ធព្រះនគរទុក ប្រកាសថា យើងជាឱរសរបស់ព្រះរាជា ចូរអ្នកទាំងឡាយប្រគល់ស្វេតច្ឆត្រដល់យើង កាលជនទាំងនោះមិនជឿ ក៏បង្ហាញសំពត់កម្ពល

និងព្រះទម្រង់ឲ្យមើល បានលើកស្វេតច្ឆត្រឡើងគ្រងរាជ្យហើយ ។ ព្រះរាជានោះ មានព្រះទ័យជាក់តែក្នុងដំរី កាលមានគេទូលថា ទីត្រង់នោះមានដំរីស្អាត ទ្រង់ក៏យាងទៅចាប់ ។ ព្រះបាទចណ្ឌបជ្ជោត ទ្រង់ត្រិះរិះថា អញនឹងរៀនសិប្បៈក្នុងសម្នាក់របស់ស្តេចឧទេន ទើបបញ្ជាឲ្យធ្វើដំរីឈើឡើង ឲ្យទាហានអង្គុយក្នុងដំរីនោះ លុះព្រះរាជានោះយាងមកដើម្បីចាប់ដំរី ក៏ត្រូវចាប់បាន បញ្ជូនធីតាទៅដើម្បីរៀនសិប្បៈចាប់ដំរីក្នុងសម្នាក់របស់ព្រះរាជា ។ ព្រះអង្គបានសម្រេចសង្វាសជាមួយព្រះធីតានោះ ហើយនាំគ្នាគេចទៅកាន់ព្រះនគររបស់ព្រះអង្គ ។ ពោធិរាជកុមារនេះទ្រង់កើតក្នុងព្រះគភ៌របស់ព្រះធីតានោះ ទើបបានរៀនសិប្បៈ គឺមន្តក្នុងសម្នាក់របស់ព្រះជនកនៃព្រះអង្គ ។

[ ២៧៩ ] បទថា **បធានិយង្គានិ** សេចក្តីថា ការផ្តើមព្យាយាម លោកហៅថា បធាន ។ សេចក្តីព្យាយាមរបស់ភិក្ខុនោះមាន ហេតុនោះ ភិក្ខុនោះឈ្មោះថា **បធានីយ** អ្នកមានព្យាយាម អង្គនៃភិក្ខុអ្នកមានព្យាយាម ហេតុនោះឈ្មោះ ថា **បធានិយង្គ** ។ បទថា **សទ្ធោ** បានដល់ បុគ្គលប្រកបដោយសទ្ធា ។ សទ្ធានោះមាន ៤ ប្រការ គឺអាគមនសទ្ធា ១ អធិគមនសទ្ធា ១ ឱកប្បនសទ្ធា ១ បសាទសទ្ធា ១ ក្នុងបណ្តាសទ្ធា ៤ យ៉ាងនោះ ការជឿចំពោះព្រះសព្វញ្ញូពោធិសត្វ ឈ្មោះថា **អាគមនសទ្ធា** ព្រោះមកហើយ ចាប់តាំងអំពីការប្រាថ្នា ។ ឈ្មោះថា **អធិគមនសទ្ធា** ព្រោះសម្រេចហើយ ដោយការចាក់ធ្លុះនៃព្រះអរិយសាវកទាំងឡាយ ។ ការដាក់ចិត្តជឿដោយការមិនញាប់ញ័រ កាលគេពោលថា **ពុទ្ធោ ធម្មោ សង្ឃោ** ឈ្មោះថា

**ឱកប្បនសទ្ធា**។ ការកើតឡើងនៃការជ្រះថ្លា ឈ្មោះថា **បសាទសទ្ធា**។ ក្នុងទីនេះបំណងយក ឱកប្បនសទ្ធា ។ បទថា **ពោធិ** បានដល់ មគ្គញ្ញាណ ៤ ។ បុគ្គលរមែងជឿថា ព្រះសាស្ដាទ្រង់ចាក់ធ្លុះនូវមគ្គញ្ញាណ ៤ នោះដោយល្អហើយ ។ ម្យ៉ាងទៀត ពាក្យនេះជាកំពូលនៃទេសនានោះឯង ។ ការជឿក្នុងព្រះរតនៈទាំង ៣ លោកបំណងយកហើយ ដោយអង្គនេះ ។ គឺបុគ្គលណាមានសេចក្ដីជ្រះថ្លា ក្នុងព្រះពុទ្ធជាដើមយ៉ាងខ្លាំងក្លា បធានវីរិយៈនៃបុគ្គលនោះរមែងសម្រេច ។ បទថា **អប្បាពាធោ** បានដល់ ការមិនមានរោគ ។ បទថា **អប្បាតង្កោ** បានដល់ ការមិនមានទុក្ខ ។ បទថា **សមវេបាកិនិយា** សេចក្ដីថា មានវិបាកស្មើគ្នា ។ បទថា **គហណិយា** បានដល់ តេជោធាតុដែលកើតអំពីកម្ម ។ បទថា **នាតិសីតាយ នាច្ចុណ្ហាយ** សេចក្ដីថា បុគ្គលមានធាតុដែលត្រជាក់ខ្លាំង ក៏ខ្លាចការត្រជាក់ អ្នកមានធាតុក្ដៅខ្លាំង ក៏ខ្លាចការក្ដៅ ។ សេចក្ដីព្យាយាមរបស់បុគ្គលទាំងនោះ នឹងមិនសម្រេច ។ នឹងសម្រេចដល់បុគ្គលដែលមានភាពជាកណ្ដាលៗ ។ ព្រោះដូច្នោះ ទើបលោកពោលថា **មជ្ឈិមាយ បធានក្ខមាយ** ។ បទថា **យថាភូតំ អត្តានំ អាវិកត្តា** សេចក្ដីថា ប្រកាសទោសរបស់ខ្លួនតាមការពិត ។ បទថា **ឧទយត្ថគាមិនិយា** សេចក្ដីថា អាចដល់ គឺកំណត់ដល់ការកើត និងការរលត់ ។ ដោយពាក្យនេះ លោកពោលដល់ឧទយព្វយញ្ញាណ ដែលកំណត់លក្ខណៈ ៥០ ។ បទថា **អរិយាយ** បានដល់ បរិសុទ្ធ ។ បទថា **និព្វេធិកាយ** សេចក្ដីថា អាចទម្លាយបង់នូវគំនរលោភៈជាដើមបានក្នុងកាលមុន ។ បទ

ថា **សម្មាទុក្ខក្ខយគាមិនិយា** សេចក្តីថា ឲ្យដល់នូវការអស់ទៅនៃទុក្ខ ដែលនឹងត្រូវធ្វើឲ្យអស់នោះ ព្រោះលះកិលេសទាំងឡាយបានដោយតទង្គ-ប្បហាន ។ ដោយបទទាំងអស់នោះ ត្រាស់វិបស្សនាញាណតែម្យ៉ាង ដោយប្រការដូច្នេះ ។ ពិតហើយ សេចក្តីព្យាយាម រមែងមិនសម្រេចដល់ អ្នកមានបញ្ញាគ្រោតគ្រាត ។ ពិតហើយ ដោយពាក្យនេះ គប្បីជ្រាបថា អង្គ នៃភិក្ខុដែលមានសេចក្តីព្យាយាមទាំង ៥ ជាលោកិយទាំងអស់ ។ បទថា **សាយមនុសិដ្ឋោ ចាតោ វិសេសមធិគច្ឆតិ** ទូន្មានពេលល្ងាច សម្រេចគុណ វិសេសក្នុងពេលព្រឹក សេចក្តីថា កាលព្រះអាទិត្យអស្តង្គត ក៏ប្រៀនប្រដៅ លុះអរុណរះក៏សម្រេចគុណវិសេស ។ បទថា **ចាតមនុសិដ្ឋោ សាយំ** សេចក្តីថា លុះអរុណរះក៏ទូន្មាន ក្នុងវេលាព្រះអាទិត្យអស្តង្គតក៏សម្រេច គុណវិសេស ។ ឯព្រះទេសនានេះ លោកពោលដោយអំណាចនេយ្យបុគ្គល ។ ពិតហើយ នេយ្យបុគ្គលសូម្បីមានបញ្ញាថោកថយ ក៏សម្រេចអរហត្តបាន ដោយ ៧ ថ្ងៃ ។ មានបញ្ញាខ្លាំងក្លាដោយ ១ ថ្ងៃ គប្បីជ្រាបពាក្យដ៏សេស ដោយអំណាចនៃបញ្ញាដែលជាកណ្តាលៗ ។ បទថា **អហោ ពុទ្ធោ អហោ ធម្មោ អហោ ធម្មស្ស ស្វាក្ខាតតា** សេចក្តីថា ព្រោះភិក្ខុឲ្យអាចារ្យប្រាប់កម្ម ដ្ឋានក្នុងវេលាព្រឹក ក្នុងពេលល្ងាចសម្រេចអរហត្ត ព្រោះធម៌របស់ព្រះពុទ្ធ ទាំងឡាយ មានគុណដ៏ក្រៃលែង និងព្រោះធម៌ដែលព្រះពុទ្ធត្រាស់ល្អហើយ ដូច្នោះ កាលទ្រង់សរសើរ ទើបពោលយ៉ាងនោះ ។ បទថា **យត្រ ហិ នាម** ជានិបាត ប្រើក្នុងអត្ថថា គួរអស្ចារ្យ ។

[ ២៨១ ] បទថា **កុច្ឆិមតិ** បានដល់ សត្វដែលជិតនឹងចុតិ ។ បទថា **យោ មេ អយំ ភន្តេ កុច្ឆិគតោ** សេចក្តីថា សរណៈ រមែងឈ្មោះថា កាន់យកហើយដោយអាការយ៉ាងនេះឬ ។ មិនទាន់ជាការកាន់យកហើយ ។ ធម្មតាការដល់សរណៈដោយអចិត្តកៈរមែងមិនមាន ។ ឯការរក្សារមែងប្រាកដចំពោះហើយ ។ ក្រោយមកមាតាបិតាបានដាស់តឿនកុមារនោះឲ្យរឭកបានថា ម្នាលកូន កាលកូននៅក្នុងគភ៌មាតាក៏ឲ្យកាន់យកសរណៈនោះ ដូច្នេះ កាលវេលា ព្រះរាជកុមារនោះដឹងក្តីក៏កំណត់បានហើយ ញុំាងសតិឲ្យកើតឡើងថា អញជាឧបាសកដល់សរណៈហើយ ដូច្នេះ ក្នុងកាលណា ក្នុងកាលនោះ រមែងឈ្មោះថា ដល់នូវសរណៈហើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ៕៚

**អដ្ឋកថា ពោធិរាជកុមារសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## អង្គុលិមាលសូត្រទី ៦

[ ២៨២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់សម្រេចព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ សម័យនោះឯង ក្នុងដែនព្រះបាទបសេនទិកោសល មានចោរម្នាក់ឈ្មោះអង្គុលិមាល ជាមនុស្សក្រោធ មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀននិងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ។ ចោរនោះ តែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ទើបស្តេចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់ពីបិណ្ឌបាតក្នុងកាលជាខាងក្រោយនៃភត្ត ទ្រង់ក៏រៀបចំសេនាសនៈ រួបប្រដាប់បាត្រនិងចីវរ ស្តេចទៅកាន់ផ្លូវឆ្ងាយ សំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ បានឃើញព្រះមានបុណ្យ កំពុងស្តេចទៅកាន់ផ្លូវឆ្ងាយ សំដៅទៅត្រង់ទីដែលអង្គុលិមាលចោរនៅ លុះឃើញហើយក៏ក្រាបទូលព្រះមានបុណ្យដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សក្រោធ មានដៃប្រឡាក់

ឈាម ស្និទ្ធក្នុងការបៀតបៀន និងការសម្លាប់ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ចោរនោះតែងធ្វើស្រុកឲ្យទៅជា មិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាលចោរ ( ទាំងអស់ ) ។ កាលបើពួកមនុស្សក្រាបទូលយ៉ាងនេះ ព្រះមានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

[ ២៨៣ ] ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យជាគម្រប់ ២ ដងដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្និទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរ ពួកសត្វមានជីវិតឡើយ ចោរនោះតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះតែងសម្លាប់ពួកមនុស្សកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តី វិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាលចោរ ( ទាំងអស់ ) ។ លំដាប់នោះឯង ព្រះមានបុណ្យ

ក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

[ ២៨៤ ] ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យជាគម្រប់ ៣ ដងទៀតដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គកុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្អិទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរ ពួកសត្វមានជីវិតឡើយ ចោរនោះតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្សកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនោះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃអង្គុលិមាលចោរ ( ទាំងអស់ ) ។ គ្រានោះឯង ព្រះមានបុណ្យក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ ។

[ ២៨៥ ] ឯអង្គុលិមាលចោរ ក៏បានឃើញព្រះមានបុណ្យកំពុងតែស្តេចមកអំពីចម្ងាយ ។ លុះឃើញហើយ ក៏ត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់ ព្រោះបុរស ១០ នាក់ក្តី ២០ នាក់ក្តី ៣០ នាក់ក្តី ៤០ នាក់ក្តី នាំគ្នាដើរជាពួកៗ មកកាន់ផ្លូវនេះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃរបស់អញ ( ទាំងអស់ ) ចុះសមណៈនេះតែម្នាក់ឯង ឥតមានគ្នាសោះ ក៏ហ៊ានដើរមក ហាក់ដូចជាមិនកោតញញើត

ឡើយ បើដូច្នោះ អញនឹងសម្លាប់សមណៈនេះឲ្យក្ស័យជីវិត ។ គ្រានោះ អង្គុលិមាលចោរ ក៏ចាប់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ដេញព្រះមានព្រះភាគជាប់តាមក្រោយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់សំម្តែងឫទ្ធិធ្វើឲ្យអង្គុលិមាលចោរ ដែលរត់ពេញទំហឹងហើយ មិនឲ្យរត់តាមទាន់ព្រះអង្គដែលស្តេចដើរដំណើរប្រក្រតី ។ គ្រានោះ អង្គុលិមាលចោរមានសេចក្តីត្រិះរិះដូច្នេះថា យីអើ អស្ចារ្យណាស់ យីអើ ចម្លែកណាស់ព្រោះកាលពីមុនៗ មក អញស្ទុះដេញចាប់ដំរីកំពុងបោលក៏បាន ស្ទុះដេញចាប់សេះកំពុងផាយក៏បាន ស្ទុះដេញចាប់រថកំពុងលឿនក៏បាន ស្ទុះដេញចាប់ម្រឹគកំពុងបោលក៏បាន ចម្លែកតែម្តងនេះ ហេតុអ្វីបានជាអញរត់ពេញទំហឹងហើយ ក៏នៅតែមិនទាន់សមណៈនេះ ដែលដើរតាមដំណើរប្រក្រតីដូច្នេះ ។ អង្គុលិមាលចោរឈប់ឈរស្ងៀម ស្រែកឃាត់ព្រះមានបុណ្យថា ឈប់សិនសមណៈ ឈប់សិនសមណៈ ។ ព្រះមានបុណ្យត្រាស់តបថា នែអង្គុលិមាលតថាគតឈប់ហើយ អ្នកឯងចូរឈប់ដែរទៅ ។

[ ២៨៦ ] គ្រានោះ អង្គុលិមាលចោរ គិតថា ពួកសមណៈនេះជាសក្យបុត្ត ធ្លាប់និយាយតែពាក្យពិត ប្តេជ្ញាតែពាក្យពិត ចម្លែកតែសមណៈនេះ កំពុងដើរទេ ម្តេចឡើយក៏និយាយថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកចូរឈប់ដែរទៅ បើដូច្នោះ អញត្រូវសួរសមណៈនេះមើល ។ លំដាប់នោះ អង្គុលិមាលចោរ ក៏ពោលនឹងព្រះមានព្រះភាគ ដោយគាថាដូច្នេះថា

នែសមណៈ លោកកំពុងដើរសោះទេ ត្រឡប់និយាយថា

តថាគតឈប់ហើយ ថែមទាំងថាឲ្យខ្ញុំដែលឈប់ហើយថា អ្នកឯងទេ មិនទាន់ឈប់ដូច្នេះវិញ នែសមណៈ ខ្ញុំសូមសួរដំណើរនុ៎ះនឹងលោក លោកដែលឈប់ហើយ តើដូចម្តេច ខ្ញុំដែលមិនទាន់ឈប់តើដូចម្តេច ។ ព្រះអង្គតបថា នែអង្គុលិមាល តថាគតបានឈ្មោះថា ឈប់ហើយ ( នោះ ) ព្រោះដាក់ចុះនូវគ្រឿងវាយដំចំពោះពពួកសត្វទាំងអស់សព្វៗកាល ឯអ្នកឯងជាអ្នកមិនសង្រួមក្នុងពួកសត្វ ព្រោះហេតុនោះ តថាគតទើបឈ្មោះថាជាអ្នកឈប់ហើយ អ្នកឯងឈ្មោះថា ជាអ្នកមិនទាន់ឈប់ ។ អង្គុលិមាលចោរតបថា នែសមណៈ លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតានឹងមនុស្សតែងបូជា លោកមកកាន់មហាវ័ន ( ដើម្បីសង្គ្រោះ ) ដល់ខ្ញុំអស់កាលយូរហើយ ខ្ញុំនឹងប្រព្រឹត្តតាម នឹងលះបង់នូវបាបចោលចេញ ព្រោះបានស្តាប់នូវគាថា របស់ព្រះអង្គ ដែលប្រកបដោយធម៌ ( ចោរ ) ថាដូច្នេះហើយ ក៏គរវែងដាវ និងអាវុធចោលទៅក្នុងត្រពាំង ក្នុងជ្រោះ ក្នុងរណ្តៅ អង្គុលិមាលចោរ ក៏បានថ្វាយបង្គំព្រះបាទានៃព្រះសុគត ហើយសូមផ្នួសនឹងព្រះអង្គក្នុងទីនោះឯង ។ ចំណែកព្រះពុទ្ធ ព្រះអង្គប្រកបដោយករុណា ទ្រង់ស្វែងរកនូវគុណដ៏ធំ ដែលជាគ្រូនៃមនុស្សលោកព្រមទាំងទេវលោក បានត្រាស់ហៅអង្គុលិមាលចោរនោះថា អ្នកចូរមក

ជាភិក្ខុចុះ ដូច្នេះក្នុងគ្រានោះ ភិក្ខុភាពនោះឯង ក៏កើតមានដល់អង្គុលិមាលចោរនោះ ។

គ្រានោះ ព្រះភគវន្តមុនី ទ្រង់យកអង្គុលិមាលភិក្ខុមានអាយុជាបច្ឆាសមណៈ ស្តេចធ្វើពុទ្ធដំណើរ សំដៅទៅក្រុងសាវត្ថី ។ ព្រះអង្គកាលស្តេចចារិកតាមលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ ។

[ ២៨៧ ] ដំណាលថា ព្រះភគវន្តមុនី ព្រះអង្គគង់នៅក្នុងជេតវនារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គាប់ជួនសម័យនោះ ពួកមហាជនកំពុងតែប្រជុំគ្នាទៀបទ្វារខាងក្នុងបុរី របស់ព្រះបាទបសេនទិកោសល ស្រែកហ៊ោគឹកកងថា បពិត្រព្រះសម្មតិទេពក្នុងដែនរបស់ព្រះអង្គមានចោរ ឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀននិងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ វាតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ សូមព្រះសម្មតិទេព កម្ចាត់អង្គុលិមាលចោរនោះចេញ ។ លំដាប់នោះ ព្រះបាទបសេនិកោសល ស្តេចចេញអំពីក្រុងសាវត្ថី ដោយអស្សយានចំនួន ៥០០ ស្តេចចូលទៅកាន់អារាមក្នុងវេលាទាំងថ្ងៃ បរយានទៅទល់ត្រឹមទីដែលឈប់យាន ហើយស្តេចចុះអំពីយាន ស្តេចទៅតែព្រះបាទាទទេ ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។

[ ២៨៨ ] លុះព្រះបាទបសេនទិកោសលគង់ក្នុងទីដ៏សមគួរហើយ ព្រះមានបុណ្យ ទ្រង់ត្រាស់សួរថា បពិត្រមហារាជ ទំនងជាមហាបពិត្រខ្ញាល់នឹងព្រះបាទមគធសេនិយពិម្ពិសារ ឬខ្ញាល់នឹងស្តេច លិច្ឆវីអ្នកក្រុងវេសាលី ឬក៏ខ្ញាល់នឹងពួកស្តេចដែលជាបច្ចាមិត្តឯទៀត ឬអ្វី ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនខឹងនឹងព្រះបាទមគធសេនិយពិម្ពិសារ មិនខឹងនឹងស្តេចលិច្ឆវី អ្នកក្រុងវេសាលី មិនខឹងនឹងពួកស្តេច ដែលជាបច្ចាមិត្តឯទៀតទេ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងដែនរបស់ខ្ញុំព្រះអង្គ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្និទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ វាតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃមកធ្វើជាកម្រងពាក់ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងកម្ចាត់អង្គុលិមាលចោរនោះចេញ ។ ព្រះមានបុណ្យ ត្រាស់ថា បពិត្រមហារាជ ចុះបើមហាបពិត្រត្រឡប់ជាឃើញអង្គុលិមាល កោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះទៅកាន់ផ្នួស វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកមុសាវាទ បរិភោគកត្តែមួយពេល ប្រព្រឹត្តធម៌ដ៏ប្រសើរមានសីល មានធម៌ដ៏ល្អវិញ តើមហាបពិត្រត្រូវធ្វើអង្គុលិមាលនោះដូចម្តេចទៅ ។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីថ្វាយបង្គំ ឬ ក្រោកទៅទទួល

និមន្តដោយអាសនៈ ឬទំនុកបម្រុងនូវអង្គុលិមាលនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សារោគជាបច្ច័យដល់អ្នកជំងឺ និងបរិក្ខារទាំងឡាយ ឬនឹងចាត់ចែងនូវការរក្សា សេចក្ដីការពារ និងការគ្រប់គ្រង ប្រកបដោយធម៌ ដល់អង្គុលិមាលនោះ បពិត្រព្រះអង្គដ៏ចម្រើន បើអង្គុលិមាលចោរនោះ ធ្លាប់ជាមនុស្សទ្រុស្តសីល មានធម៌ដ៏លាមកហើយ ធ្វើម្តេចនឹងសង្រួមក្នុងសីលយ៉ាងនោះកើត ។

[ ២៨៩ ] ជួនសម័យនោះឯង អង្គុលិមាលភិក្ខុមានអាយុ កំពុងអង្គុយជិតព្រះមានព្រះភាគ ។ គ្រានោះ ព្រះមានព្រះភាគ លើកព្រះហស្តខាងស្តាំចង្អុលបង្ហាញព្រះបាទបសេនទិកោសលថា បពិត្រមហារាជ នុ៎ះហ្ន៎អង្គុលិមាល ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ក៏មានសេចក្ដីភ័យភិត តក់ស្លុត ព្រឺរោម ព្រឺស្បែកឡើងមួយរំពេច ។ គ្រានោះ ព្រះមានព្រះភាគជ្រាបជាក់ ថាព្រះបាទបសេនទិកោសល ទ្រង់ភ័យញ័រចំប្រប់ ព្រឺរោម ដូច្នោះហើយ ក៏ត្រាស់ទៅនឹងព្រះបាទបសេនទិកោសល ដូច្នេះថា បពិត្រមហារាជ សូមមហាបពិត្រកុំភ័យឡើយ បពិត្រមហារាជ សូមមហាបពិត្រកុំភ័យឡើយ ភ័យអំពីសម្នាក់អង្គុលិមាលនេះ មិនមានដល់មហាបពិត្រទេ ។ លំដាប់នោះ ភ័យណាក្តី សេចក្តីតក់ស្លុតណាក្តី សេចក្តីព្រឺរោមព្រឺស្បែកណាក្តី បានកើតមានដល់ព្រះបាទបសេនទិកោសល ភ័យជាដើមនោះ ក៏ស្ងប់រម្ងាប់ បាត់ទៅក្នុងលំដាប់នោះឯង ។ គ្រានោះ ព្រះបាទបសេនទិកោសល ក៏ចូលទៅជិតអង្គុលិមាលភិក្ខុមានអាយុ លុះចូលទៅដល់ហើយ ក៏មានព្រះឱង្ការ សួរ

អង្គុលិមាលភិក្ខុមានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ឈ្មោះអង្គុលិមាលឬ ។ អង្គុលិមាលមានអាយុតបថា ថ្វាយព្រះពរមហារាជ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះបិតាលោកម្ចាស់គោត្រអ្វី មាតាលោកម្ចាស់គោត្រអ្វី ។ អង្គុលិមាលមានអាយុតបថា ថ្វាយព្រះពរមហារាជ បិតា ( អាត្មាភាព ) ជាគគ្គគោត្រ មាតា ( អាត្មាភាព ) ជាមន្តានីគោត្រ ។ ព្រះបាទបសេនទិកោសល មានព្រះរាជឱង្ការបវារណាថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់គគ្គគោត្រមន្តានីបុត្រ អភិរម្យចុះ ខ្ញុំព្រះករុណានឹងទំនុកបម្រុងដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សារោគជាបច្ច័យដល់អ្នកជំងឺ និងបរិក្ខារទាំងឡាយ ដល់លោកម្ចាស់ គគ្គគោត្រមន្តានីបុត្រ ។ សម័យនោះឯង អង្គុលិមាលមានអាយុ ប្រព្រឹត្តនៅតែក្នុងព្រៃ ប្រព្រឹត្តតែបិណ្ឌបាត ប្រើប្រាស់តែសំពត់បង្សុកូល ប្រើប្រាស់តែចីវរ ៣ ។ បានជាកាលនោះ អង្គុលិមាលភិក្ខុមានអាយុ ថ្វាយព្រះពរព្រះបាទបសេនទិកោសលថា ពុំបាច់ទេមហារាជ អាត្មាភាពមានត្រៃចីវរគ្រប់គ្រាន់ហើយ ។

[ ២៩០ ] លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចម្លែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន

ព្រោះថា ព្រះមានព្រះភាគ ព្រះអង្គអាចទូន្មានបុរស ដែលគេទូន្មានមិនបាន អាចរម្ងាប់បុរសដែលគេរម្ងាប់មិនបាន អាចរម្ងត់ពុតត្បុតបុរសដែលគេរម្ងត់មិនបាន បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតខ្ញុំព្រះអង្គ មិនអាចនឹងទូន្មាននូវបុរសណា ដោយអាជ្ញាក្តី ដោយគ្រឿងសស្ត្រាវុធក្តី ព្រះមានព្រះភាគ អាចទូន្មានបុរសនោះ បានដោយមិនបាច់មានអាជ្ញា ដោយមិនបាច់មានគ្រឿងសស្ត្រាវុធ បពិត្រព្រះអង្គដ៏ចម្រើន ក៏ឥឡូវនេះ ខ្ញុំព្រះអង្គ សូមថ្វាយបង្គំលាទៅវិញ ព្រោះខ្ញុំព្រះអង្គមានកិច្ចការច្រើន មានការរវល់ច្រើន ។ ព្រះអង្គត្រាស់ថា ថ្វាយព្រះពរមហារាជ សូមមហាបពិត្រទ្រង់ជ្រាបនូវកាលដ៏គួរនឹងស្តេចយាងទៅក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ក៏ក្រោកចាកអាសនៈហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណស្តេចចេញទៅ ។

[ ២៩១ ] លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ រួចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ អង្គុលិមាលមានអាយុ កាលទៅតាមលំដាប់ច្រកដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី បានជួបនឹងស្ត្រីម្នាក់ វង្វេងស្មារតីព្រោះគភ៌ មិនសប្បាយព្រោះគភ៌ ។ លុះលោកឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ពួកសត្វលំបាកណាស់ ។ លំដាប់នោះ អង្គុលិមាលមានអាយុ ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាតក្នុងកាលជាខាងក្រោយភត្តហើយ ក៏ចៀងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ

រូបអង្គុលិមាលមានអាយុ អង្គុយក្នុងទីដ៏សមគួរ ។ លុះអង្គុលិមាលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្លៀកស្បង់ ប្រដាប់បាត្រចីវរក្នុងបុព្វណ្ហសម័យក្នុងទីឯណោះ រូបចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកំពុងដើរទៅតាមលំដាប់ច្រក ដើម្បីបិណ្ឌបាតក្នុងក្រុងសាវត្ថី បានជួបនឹងស្ត្រីម្នាក់វង្វេងស្មារតីព្រោះគភ៌ មិនសប្បាយព្រោះគភ៌ លុះខ្ញុំព្រះអង្គឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ ពួកសត្វលំបាកណាស់ ។

[ ២៩២ ] ព្រះអង្គត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្ត្រីនោះយ៉ាងនេះថា នែនាង តាំងពីអាត្មាកើតមកមិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចនេះ សូមសិរីសួស្តីកើតមានដល់នាង សូមសិរីសួស្តីកើតមានដល់គភ៌ ។ អង្គុលិមាលទូលថា បពិត្រព្រះអង្គដ៏ចម្រើន សម្បជានមុសាវាទនឹងមានដល់ខ្ញុំព្រះអង្គដោយពិត បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គបានក្លែងផ្តាច់ផ្តិលជីវិតសត្វជាច្រើន ។ ព្រះអង្គត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្ត្រីនោះយ៉ាងនេះថា នែនាង តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ ( បានជាអរិយបុគ្គល ) មិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចនេះ សូមសិរីសួស្តី កើតមានដល់នាង សូមសិរីសួស្តី កើតមានដល់គភ៌ ។

អង្គុលិមាលមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានបុណ្យថា ករុណាព្រះអង្គ ហើយក៏ចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងស្ត្រីនោះ ដូច្នេះថា នែនាង តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ មិនដែលក្លែងផ្តាច់ ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់ នាង សូមសិរីសួស្តីកើតមានដល់គភ៌ ។ គ្រានោះឯង សិរីសួស្តី ក៏បាន កើតដល់ស្ត្រីនោះ សិរីសួស្តីក៏បានកើតដល់គភ៌ ។

[ ២៩៣ ] លំដាប់នោះ អង្គុលិមាលមានអាយុ ជាបុគ្គលម្នាក់ឯង ដោះ ខ្លួនចេញចាកពួក ឥតមានសេចក្តីធ្វេសប្រហែស មានព្យាយាមដុតនូវកិលេស ប្រថុយលះបង់នូវអត្តភាព ពួកកុលបុត្រដែលចេញចាកផ្ទះហើយចូលទៅកាន់ ផ្នួសដោយប្រពៃដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏ បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយ ប្រាជ្ញារបស់ខ្លួនដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អាត្មាអស់ ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃក្រៅពីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ អង្គុលិមាលមានអាយុ រាប់ ថាជាព្រះអរហន្ត ១ រូបដែរ ។

[ ២៩៤ ] លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ប្រដាប់ បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅដើម្បីបិណ្ឌបាត ក្នុងក្រុង

សាវត្ថី ។ សម័យនោះឯង មនុស្សដទៃយកដុំដីគ្រវែងចោល ធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន មនុស្សដទៃយកដំបងគ្រវែងចោលធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន មនុស្សដទៃយកក្រួសផ្ចាត់ធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន គ្រានោះអង្គុលិមាលមានអាយុ ( មានរបួស ) បែកសីសៈ ហូរឈាម បែកបាត្រ រហែកសង្ឃាដិ ក៏ដើរចូលទៅគាល់ព្រះមានបុណ្យ ។ ព្រះមានបុណ្យ បានទតឃើញអង្គុលិមាលមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ត្រាស់ទូន្មានអង្គុលិមាលមានអាយុដូច្នេះថា ព្រាហ្មណ៍ ចូរអ្នកខំអត់ទ្រាំទៅ ព្រាហ្មណ៍ចូរអ្នកខំអត់ធ្មត់ទៅ អ្នកគួរនឹងឆេះក្នុងនរកជាច្រើនឆ្នាំ ជាច្រើនរយឆ្នាំ ជាច្រើនពាន់ឆ្នាំ ដោយវិបាកនៃកម្មណា ម្នាលព្រាហ្មណ៍ អ្នកបានទទួលរងវិបាកនៃកម្មនោះ ក្នុងបច្ចុប្បន្ននេះ ( តែប៉ុណ្ណេះ ) ទេ ។

[ ២៩៥ ] វេលានោះ អង្គុលិមាលមានអាយុ ទៅនៅក្នុងទីរហោស្ថានពួនសម្ងំតែម្នាក់ឯង បានប្រទះនូវវិមុត្តិសុខ ទើបបន្លឺឧទាននេះក្នុងវេលានោះ ថា

បុគ្គលណា ធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះមិនធ្វេសប្រហែសវិញ បុគ្គលនោះឈ្មោះថា ញុំាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក បាបកម្មដែលបុគ្គលណាធ្វើហើយ តែបុគ្គលនោះត្រឡប់ជាបិទបាន គឺមិនទទួលផលកម្មវិញ ដោយសារកុសលគឺមគ្គ បុគ្គលនោះឈ្មោះថា ញុំាំងលោកនេះឲ្យភ្លឺច្បាស់ ដូច

ព្រះចន្ទផុតស្រឡះចាកពពក ភិក្ខុណាកំលោះនៅឡើយប្រកបព្យាយាមក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯង ឈ្មោះថាញ៉ាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទផុតស្រឡះចាកពពក សូមពួកមនុស្សជាសត្រូវស្តាប់ធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំប្រកបព្យាយាមក្នុងពុទ្ធសាសនា ពួកសប្បុរសណាតែងដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំសេពគប់ពួកសប្បុរសទាំងនោះចុះ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ស្តាប់ធម៌ជាទីផូរផង់គឺខន្តិទាំងជាទីសរសើរនូវការមិនខឹងគឺមេត្តា តាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំបំពេញនូវធម៌នោះផង មនុស្សណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់នូវសេចក្តីសុខគឺព្រះនិព្វាន ចូររក្សានូវមនុស្សដែលប្រកបដោយតណ្ហា និងមនុស្សដែលមិនមានតណ្ហា ។ ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹក ( តាមប្រឡាយទឹក ) ពួកអ្នកធ្វើកូនសរ រមែងពត់កូនសរ ពួកអ្នកចាំងឈើ រមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយ រមែងទូន្មានខ្លួនបានដូច្នោះដែរ ។ ពួកមនុស្សខ្លះទូន្មានដោយដំបង ដោយកង្វេរ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានប្រាជ្ញា ដែលព្រះមានបុណ្យ ជាតាទិបុគ្គល មិនបានយកដំបង ឬគ្រឿងសស្ត្រាវុធ

( មកទូន្មានខ្ញុំទេ ) កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ ( ជាអ្នកមិនបៀតបៀនគេ ) តែជាអ្នកបៀតបៀនគេ ដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់គឺសមតាមឈ្មោះដើមខ្ញុំ ហើយព្រោះខ្ញុំមិនបៀតបៀនអ្នកណាមួយទៀតទេ កាលពីដើមខ្ញុំជាចោរមាននាមប្រាកដថា អង្គុលិមាល ដែលជំនន់ជំបន់ព្យាត់ទៅ ( តែឥឡូវនេះ )ខ្ញុំបានដល់នូវព្រះពុទ្ធជាទីពឹងហើយ កាលពីដើមខ្ញុំមានដៃប្រឡាក់ឈាម មាននាមប្រាកដថា អង្គុលិមាល ( តែឥឡូវនេះ ) សរណគមន៍ខ្ញុំបានដល់ហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំបានធ្វើអំពើដែលគួរទៅកាន់ទុគ្គតិដូច្នោះច្រើនពិតមែន តែកម្មវិបាកគឺមគ្គចេតនាបានមកអប់រំ ( ក្នុងសន្ដានខ្ញុំហើយ ) ខ្ញុំជាអ្នកលែងចំពាក់បំណុលគឺកិលេសបរិភោគភោជន ពួកជនពាលឥតប្រាជ្ញាតែងប្រកបសេចក្ដីប្រមាទ ឯអ្នកប្រាជ្ញតែងរក្សាសេចក្ដីមិនប្រមាទទុក ដូចរក្សាទ្រព្យដ៏ថ្លៃថ្លា សូមអ្នកទាំង-ឡាយកុំប្រកបសេចក្ដីប្រមាទឡើយ កុំប្រកបសេចក្ដីត្រេកអរនឹងការមូលមិត្តក្នុងកាមឡើយ ព្រោះថាបុគ្គលអ្នក មិនធ្វេសប្រហែស ខំដុតបំផ្លាញ ( នូវកិលេស ) រមែងបានដល់នូវសេចក្ដីសុខដ៏ទូលាយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេគំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្ដាធម៌ទាំងឡាយ

ដែលព្រះអង្គចែករលែកល្អហើយ ព្រះនិព្វានណាជាគុណជាតិដ៏ប្រសើរ ខ្ញុំបានដល់នូវព្រះនិព្វាននោះហើយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ វិជ្ជា ៣ ប្រការ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនាខ្ញុំបានធ្វើតាមហើយ ។

## ចប់ អង្គុលិមាលសូត្រទី ៦

# អដ្ឋកថា

## អង្គុលិមាលសូត្រ

[ ២៨២ ] អង្គុលិមាលសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ សួរថា ក្នុងព្រះសូត្រនេះ ពាក្យថា ទ្រទ្រង់កម្រងនៃម្រាមដៃ ទ្រទ្រង់ទុក ព្រោះហេតុអ្វី ។ ឆ្លើយថា ទ្រទ្រង់ទុកតាមពាក្យរបស់អាចារ្យ ។ ក្នុងសេចក្ដីនោះ មានអនុបុព្វីកថាដូចតទៅនេះ

បានឮថា អង្គុលិមាលនេះ បដិសន្ធិក្នុងគភ៌នៃព្រាហ្មណី ឈ្មោះមន្តានី របស់បុរោហិតនៃព្រះបាទកោសល ។ ព្រាហ្មណីបានប្រសូតបុត្រក្នុងវេលាកណ្ដាលរាត្រី ។ ក្នុងវេលាដែលអង្គុលិមាលនោះប្រសូតចាកផ្ទៃម្ដាយ អាវុធទាំងឡាយក្នុងនគរទាំងមូល ភ្លឺរន្ទាលប្រាលផ្លោ ។ សូម្បីពន្លឺត្រង់ទីមង្គលរបស់ព្រះរាជា សូម្បីស្រោមដាវដែលនៅក្នុងបន្ទប់ផ្ទំដ៏ជាសិរី ក៏ភ្លឺរុងរឿង ។ ទើបព្រាហ្មណ៍ក្រោកចេញមក ងើយមើលផ្កាយនក្ខត្តឫក្សក៏ដឹងថា កូនរបស់ខ្លួនកើតឡើងដោយផ្កាយឫក្សចោរ ទើបចូលគាល់ព្រះរាជាដល់ការផ្ទំជាសុខ ។

ព្រះរាជាត្រាស់ថា លោកអាចារ្យ ខ្ញុំដេកជាសុខបានអំពីណា អាវុធដែលជាមង្គលរបស់ខ្ញុំ ចេញពន្លឺរុងរឿង ប្រហែលជាមានអន្តរាយដល់រដ្ឋ ឬដល់ជីវិត ។ បុរោហិតទូលថា បពិត្រមហារាជ ទ្រង់កុំព្រួយឡើយ កុមារកើតហើយក្នុងផ្ទះរបស់ទូលបង្គំ អាវុធទាំងឡាយ មិនមែនរុងរឿងដោយអានុភាពរបស់កុមារនោះទេ ព្រះរាជាត្រាស់ថា តើមានហេតុអ្វីលោកអាចារ្យ ។ បពិត្រព្រះមហារាជ កូនខ្ញុំនឹងជាចោរ ។ ព្រះរាជាសួរថា គេជាចោរម្នាក់ឯង ឬជាចោរប្រទូស្តរាជសម្បត្តិ ។ បុរោហិតទូលថា គេជាចោរម្នាក់ឯងព្រះអង្គ ។

បុរោហិតកាលទូលយ៉ាងនោះហើយ ដើម្បីយកចិត្តព្រះរាជា ទើបទូលថា ខ្ញុំនឹងសម្លាប់វាចោលព្រះអង្គ ។ ព្រះរាជាពោលថា បើជាចោរធម្មតាម្នាក់ឯង នឹងធ្វើអ្វីបានដូចក្អួរស្រូវមួយក្អួរក្នុងស្រែរាប់ពាន់ករីស ចូរថែទាំគេទុកចុះ ។ កាលនឹងតាំងឈ្មោះកុមារនោះ របស់ទាំងនេះ គឺស្រោមដាវដែលជាមង្គល ដាក់ក្នុងទីដេក ព្រួញទុកត្រង់ជ្រុង កាំបិតតូចសម្រាប់ចិតត្នោត ទុកក្នុងប៉ុយ សំឡី កាលចេះឡើងចែងចាំងពន្លឺ តែមិនបៀតបៀនគ្នា ដូច្នោះ ទើបឲ្យឈ្មោះ ថា អហឹសកៈ ។ លុះដល់វេលាឲ្យរៀនសិប្បៈ ក៏បញ្ជូនទៅកាន់នគរតក្កសិលា ។ អហឹសកកុមារនោះ ជាធម្មន្តេវាសិក ( កូនសិស្សដែលរៀនដោយ មិនមានវង្វាន់គ្រូ ) ផ្ដើមរៀនសិប្បៈហើយ ជាបុគ្គលដល់ព្រមដោយវត្ត តាំង ចិត្តបម្រើ ប្រព្រឹត្តជាទីពេញចិត្ត ជាអ្នកពោលវាចាពីរោះ ។ ឯអន្តេវាសិក ដ៏សេស ជាពាហិរកអន្តេវាសិក ( កូនសិស្សដែលរៀនមានវង្វាន់គ្រូ ) ។ អន្តេវាសិកទាំងនោះអង្គុយប្រឹក្សាគ្នាថា ចាប់ពីពេលដែលអហឹសកមាណពមក ពួកយើងមិនប្រាកដឡើយ យើងនឹងទម្លាយគេបានដូចម្ដេច នឹងពោលថា អាល្ងង់ ក៏ពោលមិនបាន ព្រោះមានបញ្ញាជាងយើងគ្រប់គ្នា ថាមានវត្តមិនល្អ ក៏ មិនអាចនិយាយ ព្រោះជាអ្នកសម្បូរដោយវត្ត ថាមានជាតិថោកទាប ក៏ពោល មិនបាន ព្រោះសម្បូរដោយជាតិ ពួកយើងនឹងធ្វើដូចម្ដេចហ្ន៎ ខណៈនោះ ប្រឹក្សាជាមួយអ្នកមានគំនិតមុតស្រួចម្នាក់ថា យើងនឹងធ្វើឱកាសអាចារ្យទម្លាយ គេចេញ បំបែកគ្នាជា ៣ ពួក ពួកទី ១ ត្រូវនាំគ្នាចូលទៅរកអាចារ្យ ថ្វាយ បង្គំហើយ នៅឈរ ។ បើអាចារ្យសួរថា មានរឿងអ្វីបា ។ ក៏ប្រាប់ថា

ពួកខ្ញុំបានដឹងរឿងមួយក្នុងផ្ទះនេះ ។ កាលអាចារ្យសួរថា មានរឿងអ្វីបា ។ ក៏ពោលថា ពួកខ្ញុំដឹងថា អហឹសកមាណព នឹងប្រទូស្តរវាងលោកអាចារ្យ ។ អាចារ្យក៏គំហក បណ្តេញចេញទៅថា ចេញទៅ ឯងជាមនុស្សថោកទាប ឯងកុំទម្លាយបុត្ររបស់យើងក្នុងរវាងយើងឡើយ ។ បន្ទាប់អំពីនោះ ក្រុមទី ២ ក៏ទៅ ក្រុមទី ៣ ក៏ទៅទៀត ទាំង ៣ ពួក ក៏ពោលទំនងតែមួយ ហើយពោលថា បើលោកអាចារ្យមិនជឿពួកខ្ញុំ ក៏ចូលពិចារណាឯងចុះ ។ លោកអាចារ្យ ឃើញសិស្សទាំងឡាយ ពោលដោយការអើពើ ទើបសម្រេចចិត្តថា ប្រហែលជាពិត ទើបគិតថា អញនឹងសម្លាប់វាចោល ។ តទៅទើបគិតទៀតថា បើអញសម្លាប់វា មនុស្សម្នានឹងគិតថា អាចារ្យទិសាបាមោក្ខ ញុំាំងទោសឲ្យកើតឡើងដល់មាណព ដែលមករៀនសិប្បៈក្នុងសម្នាក់របស់ខ្លួន សម្លាប់ចោលដូច្នេះ ក៏នឹងមិនមកដើម្បីរៀនសិប្បៈទៀត ដោយអាការយ៉ាងនេះ អញក៏វិនាសលាភ កុំធ្វើដូច្នោះឡើយ អញនឹងប្រាប់វាថា នៅមានសិប្បៈវិជ្ជាចុងក្រោយ ហើយពោលថា ឯងត្រូវសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ ក្នុងរឿងនេះ ឯងតែម្នាក់ឯងក្រោកឡើងសម្លាប់មនុស្សឲ្យគ្រប់មួយពាន់ ។ ពេលនោះទើបអាចារ្យពោលនឹងអហឹសកកុមារថា ណ្ហើយចុះបា ចូរបាសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ កាលធ្វើបានដូច្នេះ ក៏ជាការធ្វើឧបចារដល់សិប្បៈ ការបូជាគ្រូ ដូច្នេះ ទើបអហឹសកកុមារពោលថា បពិត្រលោកអាចារ្យ ខ្ញុំកើតមកក្នុងត្រកូលដែលមិនបៀតបៀន ខ្ញុំមិនអាចធ្វើដូច្នោះបានទេ ។ អាចារ្យពោលថា សិប្បៈដែលមិនបានតម្លៃបូជាគ្រូ ក៏មិនឲ្យផលឡើយ ។ ទើប

អហិង្សកុមារនោះកាន់អាវុធ ៥ ប្រការ ថ្វាយបង្គំអាចារ្យ ចូលកាន់ព្រៃ ឈរក្នុងទីដែលមនុស្សចូលទៅកាន់ព្រៃខ្លះ ត្រង់ទីកណ្ដាលព្រៃខ្លះ ត្រង់ទីដែលមនុស្សចេញអំពីព្រៃខ្លះ សម្លាប់មនុស្សជាច្រើន ។ ក៏មិនកាន់យកសំពត់ ឬសំពត់ជូតក្បាល ធ្វើត្រឹមតែការកំណត់ថា ១ - ២ ដូច្នេះ ដើរទៅ សូម្បីការរាប់ក៏កំណត់មិនបាន ។ តែដោយធម្មតាអហឹសកកុមារនេះ ជាអ្នកមានបញ្ញា តែចិត្តមិនតាំងនៅមាំបាន ព្រោះបាណាតិបាត ។ ដូច្នោះ ទើបកំណត់ការរាប់មិនបានតាមលំដាប់ ។ អហិង្សកកុមារកាត់ម្រាមបាន ១ ក៏រក្សាទុកក្នុងទីដែលរក្សាទុក ម្រាមដៃក៏វិនាសទៅ បន្ទាប់អំពីនោះ ទើបដោតធ្វើជាមាល័យពាក់ត្រង់កទុក ។ ដោយហេតុនោះឯង ទើបប្រាកដឈ្មោះថា អង្គុលិមាល ។ អង្គុលិមាលនោះ ត្រាច់ទៅកាន់ព្រៃទាំងមូល រហូតមិនមាននរណាអាចទៅព្រៃដើម្បីរកឧសជាដើម ។ ក្នុងពេលយប់ក៏ចូលមកកាន់ស្រុក យកជើងធាក់ទ្វារ ។ បន្ទាប់អំពីនោះក៏សម្លាប់មនុស្សដែលដេកនោះឯង កំណត់ថា ១ - ១ ដើរទៅ ។ ស្រុកក៏គេបោះបង់ទៅរហូតដល់និគម ។ និគមក៏គេបោះបង់ទៅ នៅសល់តែក្នុងក្រុង ។ ពួកមនុស្សបោលផ្ទះសម្បែង អូសដៃកូនធ្វើដំណើរមកក្នុងនគរសាវត្ថី ដែលមានចម្ងាយផ្លូវ ៣ យោជន៍ បោះជំរំស្នាក់នៅប្រជុំគ្នា ត្រង់លានព្រះរាជវាំង យំរៀបរាប់ថា បពិត្រសម្មតិទេព ក្នុងដែនរបស់ព្រះអង្គមានចោរឈ្មោះអង្គុលិមាលជាដើម ។ ក្នុងលំដាប់នោះ ព្រាហ្មណ៍ដឹងថាចោរអង្គុលិមាលនោះ ពិតជាកូនរបស់ខ្លួន ទើបពោលនឹងព្រាហ្មណីថា នែនាងដ៏ចម្រើន ចោរឈ្មោះអង្គុលិមាលកើតឡើងហើយ ចោរនោះមិនមែននរណា

គឺអហឹសកកុមារកូនរបស់នាងនោះឯង ឥឡូវនេះ ព្រះរាជានឹងចេញទៅចាប់កូន យើងគួរធ្វើដូចម្តេច ។ ព្រាហ្មណីពោលថា សូមបងទៅចុះ នាំកូនរបស់យើងមក ។ ព្រាហ្មណ៍ពោលថា នែនាងដ៏ចម្រើន ខ្ញុំមិនហ៊ានទៅទេ ព្រោះជន ៤ ពួក មិនគួរទុកចិត្ត គឺចោរដែលធ្លាប់ជាសម្លាញ់មកអំពីមុន ១ សម្លាញ់ដែលធ្លាប់ស្រឡាញ់គ្នាក្នុងកាលមុន ១ ព្រះរាជា ១ ភរិយាដែលនៅក្នុងត្រកូលញាតិ ១ តែចិត្តរបស់ម្តាយជាចិត្តដែលទន់ ដូច្នោះ ទើបព្រាហ្មណីពោលថា ខ្ញុំនឹងទៅនាំកូនរបស់ខ្ញុំមក ដូច្នេះ ចេញទៅហើយ ។

ក្នុងថ្ងៃនោះ ព្រះមានព្រះភាគប្រមើលមើលលោកក្នុងបច្ចូសសម័យថ្ងៃជិតរះ ទ្រង់ឃើញអង្គុលិមាល ទើបទ្រង់ព្រះតម្រិះថា កាលតថាគតទៅ នឹងជាសួស្តីដល់គេ បុគ្គលដែលនៅក្នុងព្រៃមិនមានស្រុក កាលស្តាប់គាថា ដែលប្រកបដោយបទ ៤ ចេញបួសក្នុងសម្នាក់របស់តថាគតហើយ នឹងធ្វើឲ្យជាក់ច្បាស់នូវអភិញ្ញា ៦ បើតថាគតមិនទៅ អង្គុលិមាលនឹងធ្វើខុសក្នុងមាតា នឹងជាបុគ្គលដែលបុគ្គលណាមួយស្រង់ឡើងមិនបាន តថាគតនឹងធ្វើការសង្គ្រោះអង្គុលិមាល ដូច្នេះ ។ ហើយទ្រង់ស្លៀកដណ្តប់ក្នុងវេលាព្រឹក ចូលទៅដើម្បីបិណ្ឌបាត ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ បំណងនឹងសង្គ្រោះអង្គុលិមាល ទើបចេញអំពីវិហារ ដើម្បីនឹងសម្តែងសេចក្តីនេះ ទើបលោកពោលថា **អថ ខោ ភគវា** ដូច្នេះជាដើម ។ បទថា **សង្គម្ម សង្គម្ម** ជាពួកៗ ឃ្លាំសង្កេត ។ បទថា **ហត្ថត្ថំ គច្ឆន្តិ** សេចក្តីថា ដល់នូវការតាំងនៅមិនបានក្នុងដៃ គឺវិនាសទៅ ។ សួរថា មនុស្សទាំងនោះស្គាល់ព្រះមានព្រះភាគហើយ ពោលយ៉ាង

នេះ ចាំមិនបានឬ ឆ្លើយថា ចាំមិនបាន ។ ព្រោះព្រះមានព្រះភាគ ទ្រង់និម្មិតភេទយានទៅត្រឹមតែមួយព្រះអង្គឯង ។ ក្នុងសម័យនោះសូម្បីចោរវង្វេងក្នុងចិត្ត ព្រោះបរិភោគយ៉ាងលំបាក ដេកក៏លំបាក មកអស់កាលដ៏យូរ ។ ម្យ៉ាងទៀត ពួកមនុស្សត្រូវចោរអង្គុលិមាលសម្លាប់ទៅប៉ុន្មាន ត្រូវសម្លាប់ទៅ ៩៩៩ នាក់ ហើយ ។ ចោរនោះមានសេចក្តីសម្គាល់ថា ឥឡូវនេះបាន ១ ទៀតក៏នឹងគ្រប់ ១០០០ តាំងចិត្តថា ឃើញអ្នកណាមុនក៏នឹងសម្លាប់អ្នកនោះឲ្យគ្រប់ចំនួន ធ្វើឧបចារដល់សិប្បៈ គឺបូជាគ្រូ កោរសក់និងពុកមាត់ពុកចង្កា ហើយផ្លាស់សំពត់ ទៅជួបមាតាបិតា ដូច្នេះ ទើបចេញអំពីព្រៃមកកាន់មាត់ព្រៃឈរនៅក្នុងចំណែកទីបំផុតម្ខាង បានឃើញព្រះមានព្រះភាគហើយ ។ ដើម្បីសម្តែងសេចក្តីនេះ ទើបលោកពោលថា **អទ្ទសា ខោ** ដូច្នេះជាដើម ។

[ ២៨៥ ] បទថា **ឥទ្ធាភិសង្ខារំ អភិសង្ខាសិ** សេចក្តីថា ទ្រង់បណ្តាលឲ្យហាក់ដូចជាផែនដីធំ មានរលកតាំងឡើង ហើយទ្រង់ជាន់នៅផ្ទៃកម្ខាង ពន្លាតក្នុងខាងក្នុងចេញមក ។ អង្គុលិមាលដោះគ្រឿងដែលសម្រាប់ពាក់ព្រួញចេញដើរទៅ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងទួលធំនៅខាងមុខ ហើយទ្រង់នៅត្រង់កណ្តាល ចោរនៅត្រង់ទីបំផុត ។ អង្គុលិមាលគិតថា អញនឹងដេញទាន់ចាប់បានក្នុងឥឡូវនេះ ទើបប្រញាប់ស្ទុះទៅ ដោយកម្លាំងដ៏រហ័ស។ ព្រះមានព្រះភាគទ្រង់នៅទីបំផុតត្រង់ទួល ចោរនៅត្រង់កណ្តាល គេប្រញាប់ស្ទុះមកដោយរហ័ស គិតថា មុខជាទាន់ចាប់បានត្រង់នេះ ។ ព្រះមាន

ព្រះភាគ ទ្រង់ក៏បណ្តាលអួរ ឬផែនដីទុកខាងមុខទៀត ដោយទំនងនេះ អស់ចម្ងាយផ្លូវ ៣ យោជន៍ ។ ចោរហត់នឿយ ទឹកមាត់ក្នុងមាត់ស្ងួតអស់ ញើសហូរចេញអំពីក្លៀក ។ គ្រានោះ ក៏មានគំនិតគិតដូច្នេះថា គួរអស្ចារ្យពន់ពេក ។

បទថា **មិគំបិ** សេចក្តីថា សូម្បីម្រឹគ ក៏គង់ចាប់បាន ។ ក្នុងពេលដែលឃ្លាន ក៏ចាប់យកមកជាអាហារបាន ។ បានឮថា ចោរនោះគោះគុម្ពោតព្រៃណាមួយ ឲ្យម្រឹគក្រោកឡើងគេចទៅ បន្ទាប់មក ក៏ដេញតាមម្រឹគបានដូចចិត្តប្រាថ្នា ហើយអាំងសាច់បរិភោគ ។

[ ២៨៦ ] បទថា **បុច្ឆឈ្យំ** សេចក្តីថា សមណៈនេះកំពុងដើរទៅនោះឯង ក៏ពោលថា ឈប់ហើយ ឯអញកំពុងឈប់ ក៏ថាមិនឈប់ ដោយហេតុណា ធ្វើម្តេចហ្ន៎ អញគប្បីសួរហេតុនោះជាមួយសមណៈនេះ ។ បទថា **ឆិធាយ** សេចក្តីថា សូម្បីអាជ្ញាដែលបុគ្គលគប្បីឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ ដើម្បីបៀតបៀន តថាគតដាក់អាជ្ញានោះ គឺនាំចេញ ពិចារណាដោយមេត្តា ខន្តីប្រព្រឹត្តទៅក្នុងសារាណីយធម៌ទាំងឡាយ ដោយអវិហឹង្សា ។ បទថា **តុវមដ្ឋិតោសិ** សេចក្តីថា កាលអ្នកសម្លាប់សត្វ មានប្រមាណ ១០០០ នេះ ព្រោះ មិនមានការសង្រួមក្នុងសត្វដែលមានបាណទាំងឡាយ មេត្តាក្តី ខន្តីក្តី បដិសង្ខាក្តី អវិហិង្សាក្តី សារាណីយធម៌ក្តី របស់អ្នកមិនមាន ដូច្នោះ ទើបអ្នកឈ្មោះថា មិនទាន់ឈប់ ។ មានពាក្យអធិប្បាយថា សូម្បីឈប់ហើយដោយឥរិយាបថក្នុងខណៈនេះ អ្នកក៏នឹងស្ទុះទៅក្នុងនរក គឺនឹងស្ទុះទៅក្នុងកំណើតតិរច្ឆាន ក្នុងបេតវិស័យ ឬក្នុងអសុរកាយ ។ ក្នុងលំដាប់នោះ

ចោរគិតថា ការបន្លឺសីហនាទនេះធំ ការបន្លឺសីហនាទដ៏ធំនេះ នឹងជារបស់អ្នកដទៃទៅមិនបាន ការបន្លឺនេះ ត្រូវតែជារបស់ព្រះសមណៈ ព្រះនាមថា សិទ្ធត្ថ ដែលជាឱរសនៃព្រះនាងមហាមាយា អាត្មាអញប្រហែលជាព្រះសម្មាសម្ពុទ្ធដ៏មានចក្ខុមុតថ្លាទ្រង់ឃើញហើយហ្ន៎ ព្រះមានព្រះភាគយាងមកដើម្បីធ្វើការសង្គ្រោះដល់អញ ដូច្នេះ ទើបពោលថា **ចិរស្សំ វត មេ** ដូច្នេះជាដើម ។

ក្នុងបណ្តាបទទាំងនោះ បទថា **មហិតោ** សេចក្តីថា ដែលទេវតា និងមនុស្សជាដើមបូជាហើយ ដោយការបូជាបច្ច័យ ៤ ។ បទថា **បច្ចុបាទិ** សេចក្តីថា ទ្រង់យាងមកកាន់ព្រៃធំនេះ ដើម្បីសង្គ្រោះអញ ដោយកន្លងកាលយូរមកហើយ ។ បទថា **បជហិស្សំ ទាបំ** សេចក្តីថា ខ្ញុំព្រះអង្គនឹងលះបាប ។ បទថា **ឥច្ចេវ** ប្រែថា ពោលយ៉ាងនេះហើយ ។ បទថា **អាវុធំ** បានដល់ អាវុធ ៥ ប្រការ ។ បទថា **សោព្ភ** គឺដែលជាច់ទៅម្ខាង ( អណ្តូង ) ។ បទ ថា **បចាត** បានដល់ ដាច់ម្ខាង ( ជ្រោះ ) ។ បទថា **នរកេ** គឺទីបែកក្រហែង ។ ម្យ៉ាងទៀត ក្នុងទីនេះ លោកពោលដល់ព្រៃប៉ុណ្ណោះ ដោយបទទាំង ៣ នេះ ។ បទថា **អកិរិ** បានដល់ បន្សាត់ទៅ គឺបោះទៅ ។ បទថា **តមេហិ ភិក្ខុហិ តទា អវោច** សេចក្តីថា ព្រះមានព្រះភាគ កាលញ៉ាំងអង្គុលិមាលនេះឲ្យបួស ក៏មិនមានកិច្ចក្នុងការស្វែងរកថា នឹងបានកាំបិតតូចពីណាហ្ន៎ នឹងបានបាត្រ ចីវរអំពីណា ដូច្នេះ ។ ម្យ៉ាងទៀត ទ្រង់ប្រមើលមើលកម្ម ។ ពេលនោះ ទ្រង់ក៏ជ្រាបថា អង្គុលិមាលនេះធ្លាប់បានប្រគេនគណ្ឋៈ គឺបរិក្ខារ ៨ ដល់អ្នកមានសីលក្នុងកាលមុន ទើបទ្រង់

លាព្រះហស្តស្តាំចេញ ត្រាស់ថា **ឯហិ ភិក្ខុ ស្វាក្ខាតោ ធម្មោ ចរ ព្រហ្ម-ចរិយំ សម្មាទុក្ខស្ស អន្តកិរិយាយ** ចូរអ្នកមកជាភិក្ខុចុះ ធម៌តថាគតពោលទុកល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈ ដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ដូច្នេះ ។ អង្គុលិមាលនោះបានចំពោះនូវបាត្រ និងចីវរដែលសម្រេចហើយដោយឫទ្ធិ ជំណាលគ្នានឹងព្រះតម្រាស់នោះឯង ។ ក្នុងរំពេចនោះ យាវាសភេទរបស់លោកអន្តរធានទៅ សមណភេទប្រាកដហើយ ។

បរិក្ខារ ៨ ដូចដែលលោកពោលទុកយ៉ាងនេះថា

ត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធចង្កេះ រួមជា ៨ នឹងតម្រងទឹក សមគួរដល់ភិក្ខុប្រកបព្យាយាមហើយ ដូច្នេះ ។

ជារបស់ប្រចាំសម្រាប់ខ្លួនកើតឡើងហើយ ។ បទថា **ឯសេវ តស្ស អហុ ភិក្ខុភាវោ** សេចក្តីថា ភាពជាឯហិភិក្ខុនេះ បានជាភិក្ខុភាវៈ ដល់អង្គុលិមាលនោះ ។ ឈ្មោះថា មិនមែនឧបសម្បទាដោយឡែក ក្រៅអំពីឯហិភិក្ខុនោះឡើយ ។ បទថា **បច្ឆាសមណេន** បានដល់ បច្ឆាសមណៈអ្នកកាន់ភណ្ឌៈ ។ សេចក្តីថា ព្រះមានព្រះភាគ ឲ្យព្រះអង្គុលិមាល កាន់បាត្រនិងចីវររបស់ព្រះអង្គ ហើយទ្រង់ធ្វើអង្គុលិមាលភិក្ខុឲ្យជាបច្ឆាសមណៈយាងទៅហើយ ។ ឯមាតារបស់អង្គុលិមាលនោះមិនដឹង ព្រោះនៅឆ្ងាយគ្នាប្រមាណ ៨ ឧសភៈ ដង្ហោយហៅថា បាអហិស្សកៈ កូនឈរក្នុងទីណា កូនអង្គុយក្នុងទីណា កូនទៅណា ហេតុអ្វីមិននិយាយជាមួយម្តាយណាកូន ដូច្នេះ កាលមិនឃើញទើបមកក្នុងទីនេះឯង ។

[ ២៨៧ ] បទថា **បញ្ចមត្តេហិ អស្សសតេហិ** សេចក្ដីថា បើចោរបរាជ័យ អញនឹងទៅតាមចាប់ចោរនោះ បើអញបរាជ័យ អញនឹងគេចទៅដូច្នោះ ។ ទើបចេញទៅដោយកម្លាំងដ៏សមគួរ ។ បទថា **យេន អារាមោ** សេចក្ដីថា មកកាន់អារាម ព្រោះហេតុអ្វី ។ បានឮថា ព្រះរាជានោះទ្រង់ខ្លាចចោរ មិនបានបំណងនឹងទៅព្រោះចោរ ទ្រង់ចេញទៅព្រោះខ្លាចចំពោះពាក្យនិន្ទា ។ ព្រោះដូច្នោះ ទើបព្រះរាជាព្រះតម្រិះថា អញនឹងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ហើយនៅអង្គុយ ព្រះសាស្ដានឹងត្រាស់សួរថា មហារាជនាំពលចេញមក ព្រោះហេតុអ្វី ដូច្នេះ ពេលនោះ អញនឹងទូលថា ព្រះមានព្រះភាគមិនបានសង្គ្រោះខ្ញុំព្រះអង្គដោយ ប្រយោជន៍ក្នុងសម្បរាយិកភពតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ក៏ទ្រង់សង្គ្រោះផងដែរ ព្រះមានព្រះភាគទ្រង់នឹងព្រះតម្រិះថា បើអញឈ្នះ ទ្រង់នឹងព្រងើយ បើអញចាញ់ ក៏នឹងត្រាស់ថា មហាបពិត្រ ប្រយោជន៍អ្វី ដោយការយាងមកប្រារព្ធចោរម្នាក់ បន្ទាប់អំពីនោះ មនុស្សទាំងឡាយ នឹងដឹងអញយ៉ាងនេះថា ព្រះរាជាយាងចេញចាប់ចោរ តែព្រះសម្មាសម្ពុទ្ធទ្រង់ឃាត់ហើយ ដូច្នេះ ឃើញថា នឹងផុតពាក្យនិន្ទាដោយប្រការនេះ ទើបទ្រង់យាងទៅ ។

សួរថា ព្រះរាជាត្រាស់ថា ចោរអង្គុលិមាលនោះមកអំពីណា ព្រោះហេតុអ្វី ។ ឆ្លើយថា ទ្រង់ត្រាស់ដើម្បីដឹងព្រះមានព្រះភាគថា ព្រះមានព្រះភាគ ទ្រង់ប្រមើល មើលឧបនិស្ស័យរបស់ចោរអង្គុលិមាលនោះហើយ ទ្រង់គប្បីនាំចោរនោះមកឲ្យបួស ។

[ ២៨៩ ] បទថា **រញ្ញោ** សេចក្ដីថា ព្រះរាជាប៉ុណ្ណោះ ទ្រង់ខ្លាចមួយព្រះអង្គឯងក៏ទេ ។ មហាជនដទៃក៏ខ្លាចបោះខែល និងអាវុធគេចទៅក្នុងទីចំពោះមុខនោះឯង ចូលកាន់ក្រុងបិទទ្វារ ឡើងកាន់ប៉ម ឈរសម្លឹង មើល និងពោលយ៉ាងនេះថា អង្គុលិមាលដឹងថា ព្រះរាជាមកកាន់សម្នាក់ របស់អញដូច្នេះហើយ មកអង្គុយត្រង់វត្តជេតពនចាំ ព្រះរាជាត្រូវចោរអង្គុលិមាលចាប់ទៅហើយ តែពួកយើងគេចផុតហើយ ។ បទថា **ឆត្ថិ តេ ឥតោ ភយំ** សេចក្ដីថា ឥឡូវនេះ អង្គុលិមាលនេះ មិនសម្លាប់សូម្បីស្រមោចក្រហម ភ័យអំពីសម្នាក់អង្គុលិមាលនេះ រមែងមិនមានដល់ព្រះអង្គឡើយ ។

សួរថា លោកពោលដោយបទថា **កថំ គោត្តា** ដូច្នេះ ព្រោះហេតុអ្វី ។ ឆ្លើយថា លោកសម្គាល់ថា ការដែលនឹងកាន់យកឈ្មោះ ដែលកើតឡើងព្រោះកម្មដ៏គ្រោតគ្រាត ហើយហៅបព្វជិត រមែងមិនគួរ អញនឹងហៅលោកដោយអំណាចនៃគោត្ររបស់មាតាបិតា ដូច្នេះ ទើបសួរហើយ ។ បទថា **បរិក្ខារានំ** សេចក្ដីថា ខ្ញុំនឹងធ្វើការខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់បរិក្ខារទាំងនោះ ព្រះរាជាកំពុងពោលនោះឯង ក៏ទ្រង់ដោះសំពត់សាដកដែលរុំពោះ ទុកក្នុងទីទៀបជើងរបស់ព្រះថេរៈហើយ ។ ធុតង្គ ៤ មានការនៅព្រៃជាដើម មកហើយក្នុងព្រះបាលី ។ តែព្រះថេរៈបានសមាទានធុតង្គហើយទាំង ១៣ នោះឯង ព្រោះដូច្នោះ ទើបលោកពោលថា **អលំ** កុំឡើយ ដូច្នេះ ។

[ ២៩០ ] សួរថា លោកសំដៅដល់អ្វី ទើបពោលថា **យញ្ហិ មយំ ភន្តេ** ដូច្នេះ ។ ឆ្លើយថា លោកចាប់ដីរដាដើម ដែលព្រះរាជាបញ្ជូនមកហើយ

ក្នុងទីដែលមកហើយថា អញដេញតាមចាប់សូម្បីដំរីដែលរត់បាន ដូច្នេះ ។ សូម្បីព្រះរាជាក៏ទ្រង់បញ្ជូនដំរីជាដើមជាច្រើន ទៅតែម្តងយ៉ាងនេះថា ចូរយក ដំរីទៅព័ទ្ធលោក ហើយចាប់មក ចូរយកសេះទៅព័ទ្ធ ចូរយករថទៅព័ទ្ធ ហើយចាប់មក ។ កាលមនុស្សទៅហើយយ៉ាងនេះ កាលអគ្គិលិមាលក្រោក ឡើង បន្លឺសំឡេងថា វ៉ឺយ យើងជាអគ្គិលិមាល សូម្បីតែមនុស្សម្នាក់ក៏មិន អាចដកអាវុធ ។ មនុស្សទាំងអស់នោះ ស្លាប់ហើយ ។ ដំរីក៏ជាដំរីព្រៃ សេះក៏ជាសេះព្រៃ រថក៏នឹងបាក់បែក ត្រង់នោះឯង ។ ព្រះរាជាសំដៅយក រឿងដូចពោលមកនេះ ទើបត្រាស់យ៉ាងនោះ ។

[ ២៩១ ] បទថា **បិណ្ឌាយ ចារិសិ** នេះ មិនមែនអគ្គិលិមាលចូល ទៅលើកទី ១ ពាក្យនេះ លោកពោលសំដៅយកថ្ងៃដែលឃើញស្ត្រី ។ អគ្គិលិមាលភិក្ខុនេះ ចូលទៅបិណ្ឌបាតរាល់ថ្ងៃដូចគ្នា ។ តែពួកមនុស្សឃើញ លោកហើយ រមែងភ័យខ្លាច រមែងគេចទៅខ្លះ បិទទ្វារខ្លះ ។ ពួកខ្លះ គ្រាន់ តែបានឮថា អគ្គិលិមាល ក៏រត់ចូលទៅព្រៃខ្លះ ចូលផ្ទះបិទទ្វារខ្លះ ។ កាល ទាល់ច្រក ក៏ឈរបែរខ្នងឲ្យ ។ ព្រះថេរៈមិនបានបបរសូម្បីត្រឹមតែមួយ គ្រាឡាក បាយត្រឹមតែមួយវែក រមែងលំបាកដោយបិណ្ឌបាត ។ កាលមិន បានខាងក្រៅ ក៏ចូលទៅកាន់ព្រះនគរ ដោយគិតថា ក្រុងទូទៅដល់មនុស្ស គ្រប់គ្នា ។ លុះចូលទៅតាមទ្វារនោះ ក៏មានហេតុឲ្យសំឡេងបន្លកលាន់ចេញ មកទាំងពាន់ៗ សំឡេងថា អគ្គិលិមាលមកហើយៗ ។ បទថា **ឯតទហោសិ** សេចក្តីថា មានហើយ ព្រោះការកើតឡើងនៃករុណា ។ កាលអគ្គិលិមាល

សម្លាប់មនុស្សដល់ទៅមួយពាន់ខ្វះមួយ ក៏មិនមានសេចក្តីករុណាត្រឹមតែម្នាក់ក្នុងថ្ងៃមួយ គ្រាន់តែឃើញស្រីមានគភ៌ក័យស្ទង់ហើយ សេចក្តីករុណាកើតឡើងបានដូចម្តេច កើតឡើងបានដោយកម្លាំងនៃបព្វជ្ជា ។ ពិតហើយ សេចក្តីករុណានោះ ជាកម្លាំងនៃបព្វជ្ជា ។

[ ២៩២ ] បទថា **តេនហិ** សេចក្តីថា ព្រោះលោកកើតសេចក្តីករុណានោះ ។ បទ ថា **អរិយាយ ជាតិយា** សេចក្តីថា ម្នាលអង្គុលិមាល អ្នកកុំកាន់យកហេតុនោះឡើយ នុ៎ះមិនមែនជាជាតិរបស់អ្នកទេ នុ៎ះជាពេលកាលនៅជាគ្រហស្ថ រមែងសម្លាប់សត្វខ្លះ រមែងធ្វើអទិន្នាទានជាដើមខ្លះ ។ តែឥឡូវនេះ ជាតិរបស់អ្នក ឈ្មោះថា អរិយជាតិ ។ ព្រោះហេតុនោះ បើអ្នករង្កៀសនឹងពោល យ៉ាងនេះថា **យតោ អហំ ភគិនិ ជាតោ** សោត ព្រោះហេតុនោះឯង ទើបទ្រង់បញ្ជូនទៅហើយ ដោយព្រះតម្រាស់ថា អ្នកចូរពោលឲ្យផ្សេងទៅយ៉ាង នេះថា **អរិយាយ ជាតិយា** ដូច្នេះ ។

បទថា **តំ ឥត្ថី ឯតទវោច** សេចក្តីថា ធម្មតាការប្រសូតិបុត្ររបស់ស្រីទាំងឡាយ បុរសមិនគួរចូលទៅ ហេតុអ្វីទើបព្រះអង្គុលិមាលត្ថេរ មកធ្វើសច្ចកិរិយា ដើម្បីប្រសូតដោយសួស្តីបាន បានឮថា ជនទាំងនោះបិតបាំងវាំងននក្រាលអាសនៈទុកខាងក្រៅវាំងនន សម្រាប់ព្រះថេរៈ ។ ព្រះថេរៈគង់លើតាំងនោះ ធ្វើសច្ចកិរិយាថា **យតោ អហំ ភគិនិ សព្វញ្ញុពុទ្ធស្ស អរិយាយ ជាតិយា ជាតោ** ម្នាលប្អូនស្រី តាំងអំពីអាត្មាកើតហើយក្នុងអរិយជាតិ នៃព្រះសព្វញ្ញុពុទ្ធ ។ ទារកក៏កើតមក ដូចទឹកហូរចេញអំពីធម្មក្រក ដំណាលគ្នា

នឹងសច្ចវាចានោះឯង ។ ម្ដាយក្ដី កូនក្ដី មានសួស្ដីហើយ ។ ព្រះបរិត្តនេះ លោកពោលថា នេះឈ្មោះថា មហាបរិត្ត មិនមានអន្តរាយណាមួយមក ទម្លាយបានឡើយ ។ ជនទាំងឡាយ បានធ្វើតាំងទុកត្រង់ទីដែលព្រះថេរៈ អង្គុយធ្វើសច្ចកិរិយា ។ ជនទាំងឡាយ រមែងនាំស្ត្រីតែសត្វញី ដែលមាន គភ៌មកឲ្យដេកត្រង់តាំងនោះ ។ ក្នុងវេលានោះឯង ក៏ប្រសូតបានដោយងាយ ។ សត្វណាទ្រុឌទ្រោមមកមិនបាន ក៏យកទឹកលាងតាំងនោះទៅស្រោចក្បាល ក៏ ប្រសូតបានក្នុងខណៈនោះឯង ។ សូម្បីរោគណាមួយដទៃ ក៏ស្ងប់ទៅ ។ បានឮថា ព្រះមហាបរិត្តនេះ មានបាដិហារ្យតាំងនៅអស់មួយកប្ប ។

សួរថា ព្រះមានព្រះភាគ ឲ្យព្រះថេរៈធ្វើវេជ្ជកម្មឬ ។ ឆ្លើយថា ព្រះអង្គ មិនបានឲ្យធ្វើ ។ ព្រោះពួកមនុស្សគ្រាន់តែឃើញព្រះថេរៈ ក៏ខ្លាចគេចទៅ ។ ព្រះថេរៈរមែងលំបាកដោយភិក្ខាហារ រមែងមិនអាចធ្វើសមណធម៌បាន ។ ទ្រង់ ឲ្យធ្វើសច្ចកិរិយា ព្រោះសង្គ្រោះព្រះថេរៈនោះ ។

បានឮមកថា ព្រះមានព្រះភាគ មានបរិវិតក្កៈយ៉ាងនេះថា ឥឡូវនេះ អង្គុលិមាលត្រូវត្រឡប់បាននូវមេត្តាចិត្ត ធ្វើសួស្ដីឲ្យដល់ពួកមនុស្ស ដោយសច្ច កិរិយា ដូច្នោះ ពួកមនុស្សរមែងសម្គាល់ថា គួរចូលទៅរកព្រះថេរៈ បន្ទាប់ ពីនោះ នឹងមិនលំបាកដោយភិក្ខាហារ អាចធ្វើសមណធម៌បាន ទើបឲ្យធ្វើសច្ច កិរិយា ព្រោះទ្រង់អនុគ្រោះដោយប្រការដូច្នេះ ។ សច្ចកិរិយាមិនមែនជាវេជ្ជ កម្មឡើយ ។ម្យ៉ាងទៀត កាលព្រះថេរៈផ្ដើមមូលកម្មដ្ឋាន ដោយតាំងចិត្តថា អញនឹងធ្វើសមណធម៌ ហើយទៅអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាក

ពេលថ្ងៃ ចិត្តក៏មិនតម្កល់ចំពោះព្រះកម្មដ្ឋាន រមែងប្រាកដចំពោះទីដែលលោកឈរត្រង់ព្រៃហើយ សម្លាប់ពួកមនុស្សប៉ុណ្ណោះ ។ អាការនៃ វាចាក្តី វិការនៃដៃ និងជើងរបស់មនុស្សដែលខ្លាចស្លាប់ថា ខ្ញុំជាមនុស្សក្រីក្រ ខ្ញុំមានកូនតូចៗ សូមឲ្យជីវិតដល់ខ្ញុំចុះលោក ដូច្នេះ មកកាន់គន្លងមនោទ្វារវជ្ជនៈ លោកមានសេចក្តីក្តៅក្រហាយ ត្រូវក្រោកទៅអំពីទីនោះ ។ ពេលនោះ ព្រះមានព្រះភាគ ឲ្យធ្វើសច្ចកិរិយាដោយអរិយជាតិ ដោយទ្រង់សម្លឹងឃើញថា ព្រះអង្គុលិមាល ត្រូវធ្វើជាតិនោះឲ្យជាអញ្ញោហារិកជាមុនសិន ហើយចម្រើនវិបស្សនា ទើបនឹងសម្រេចអរហត្តបាន ។

[ ២៩៣ ] បទថា **ឯកោ វូបកដ្ឋោ** ជាដើម លោកពោលទុកពិស្តារហើយ ក្នុងវត្ថសូត្រ ។

[ ២៩៤ ] បទថា **អញ្ញេនបិ លេឌ្ឌុខិត្តោ** សេចក្តីថា ដុំដីជាដើមដែលមនុស្សគ្រវែងទៅ ដោយចំណែកនៃទិសណាមួយក៏ដោយ ក្នុងទីនេះ ត្រឹមតែព័ទ្ធរបងទុកដោយជុំវិញ ដើម្បីការពារ ក្អែក ឆ្កែ និងជ្រូកជាដើម ឲ្យត្រឡប់ទៅ ក៏ធ្លាក់ចុះត្រង់កាយរបស់ព្រះថេរៈទៀត ។ ការរស់នៅយ៉ាងនេះ ក្នុងទីដែលមានប្រមាណប៉ុនណា អន្ទាក់វែង ដែលដាក់ទុក រហូតលោកត្រាច់បិណ្ឌបាតត្រឡប់ហើយ ក៏ភ្ជាត់អន្ទាក់ទាល់តែបាន ។

បទថា **ភិន្នេន សីសេន** សេចក្តីថា ទម្លាយស្បែក បែករហូតដល់ឆ្អឹង ។ បទថា **ព្រាហ្មណា** លោកពោលសំដៅដល់ភាពជាព្រះខីណាស្រព ។ បទថា **យស្ស ខោ ត្វំ ព្រាហ្មណា កម្មស្ស វិបាកេន** នេះ លោកពោលសំដៅយក

ទិដ្ឋធម្មវេទនីយកម្មដែលជាសភាគគ្នា ។ ពិតហើយ កម្មដែលលោកធ្វើនោះឯង រមែងញ៉ាំងចំណែកទាំង ៣ ឲ្យពេញក្នុងបណ្តាចិត្ត ៧ ដួង ចេតនាក្នុងជវនចិត្តដួងដំបូងជាកុសលក្តី អកុសលក្តី ក៏រមែងឈ្មោះថា ទិដ្ឋធម្មវេទនីយកម្ម ។ កម្មនោះរមែងឲ្យនូវវិបាកក្នុងអត្តភាពនេះប៉ុណ្ណោះ កាលមិនអាចដូច្នោះរមែង ឈ្មោះថាជាអហោសិកម្ម ដោយពួក ៣ គឺអហោសិកម្ម (**នាហោសិ កម្មវិបាកោ**) កម្មវិបាកមិនមានហើយ (**នភវិស្សតិ កម្មវិបាកោ**) កម្មវិបាកនឹង មិនមាន (**នត្ថិ កម្មវិបាកោ**) មិនមានកម្មវិបាក ។ ជវនចេតនាដួងទី ៧ ដែលឲ្យសម្រេចប្រយោជន៍ ឈ្មោះថា ឧបបជ្ជវេទនីយកម្ម ។ កម្មនោះរមែង ឲ្យផលក្នុងអត្តភាពបន្ទាប់ ។ បើមិនអាចឲ្យផលទេ កម្មនោះឈ្មោះថា ជាអហោសិកម្មដោយន័យដែលពោលហើយនោះឯង ។ ជវនចេតនា ៥ ដួង ក្នុងចន្លោះនៃកម្មទាំង ២ រមែងឈ្មោះថា អបរាបរិយវេទនីយកម្ម ។ កម្មនោះ រមែងបានឱកាសកាលណា រមែងឲ្យផលកាលនោះ ក្នុងអនាគត ។ បើនៅ មានការវិលវល់ក្នុងសង្សារ ឈ្មោះថា អហោសិកម្មរមែងមិនមាន ។ កម្មទាំង ២ នេះរបស់ព្រះថេរៈ គឺឧបបជ្ជវេទនីយកម្ម ១ អបរាបរិយវេទនីយកម្ម ១ ដែលអរហត្តមគ្គធ្វើឲ្យអស់ ដកឡើងស្រេចហើយ ។ នៅមានតែទិដ្ឋធម្មវេទនីយកម្ម ។ កម្មនោះ សូម្បីលោកដល់នូវភាពជាព្រះអរហន្តហើយ ក៏នៅឲ្យផលនោះឯង ។ ព្រះមានព្រះភាគ ទ្រង់សំដៅដល់កម្មនោះ ទើបត្រាស់ថា **យស្ស ខោ ត្វំ** ជាដើម ព្រោះដូច្នោះ ក្នុងបទថា **យស្ស ខោ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា **យាទិសស្ស ខោ ត្វំ ព្រាហ្មណ កម្មស្ស វិបាកេន**

ប្រែថា ម្នាលព្រាហ្មណ៍ ដោយផលនៃកម្មណា ។

[ ២៩៥ ] បទថា **អព្ភា មុត្តោវ** នេះ គ្រាន់តែជាកំពូលនៃទេសនា ។ ក្នុងទីនេះ លោកបំណងយកព្រះចន្ទផុតចាកគ្រឿងសៅហ្មងទាំងនេះ គឺពពក ទឹកសន្សើម ផ្សែង ធូលី រាហូ ។ ភិក្ខុជាអ្នកផុតហើយចាកកិលេស គឺសេចក្តីប្រមាទ ជាអ្នកមិនប្រមាទហើយ រមែងញុំាងលោក គឺខន្ធ អាយតនៈ និងធាតុរបស់ខ្លួននេះឲ្យរុងរឿងផុសផង់ គឺធ្វើនូវការងងឹត គឺកិលេស ដែលខ្លួនកម្ចាត់ចេញហើយ ដូចព្រះចន្ទមិនមានគ្រឿងសៅហ្មង ដូចពោលមកនេះ រមែងញុំាងលោកឲ្យភ្លឺស្វាង ដូច្នោះ ។ បទថា **កុសលេន បិថីយតិ** សេចក្តីថា រមែងបិទ ដោយកុសល គឺមគ្គ បានដល់ ធ្វើមិនឲ្យមានបដិសន្ធិទៀត ។ បទថា **យុញ្ជតិ ពុទ្ធសាសនេ** សេចក្តីថា ប្រកបហើយ ប្រកបទូទៅហើយ ដោយកាយ វាចា និងដោយចិត្ត នៅក្នុងព្រះពុទ្ធសាសនា ។ គាថាទាំង ៣ នេះ ជាឧទានគាថា របស់ព្រះថេរៈ បានឮថា ព្រះថេរៈធ្វើអាការការពារខ្លួន ទើបពោលពាក្យថា **ទិសា ហិ មេ** នេះ ។ ក្នុងបទទាំងនោះ បទថា **ទិសា ហិ មេ** សេចក្តីថា ពួកជនដែលជាសត្រូវរបស់យើង រមែងតិះដៀលយើង យ៉ាងនេះ សូមឲ្យព្រះអង្គុលិមាលចូរសោយទុក្ខ ដូចពួកយើងទាំងឡាយដែលសោយទុក្ខ ព្រោះអំណាចពួកញាតិត្រូវអង្គុលិមាលសម្លាប់ហើយ ដូច្នោះ ដោយសេចក្តីថា ជនទាំងនោះ ចូរបានត្រេកអរក្នុងធម្មកថា គឺសច្ចៈ ៤ របស់យើងគ្រប់ទិស ។ បទថា **យុញ្ជន្តុ** សេចក្តីថា អ្នកប្រកបហើយ ប្រកបទូទៅ ហើយដោយកាយ វាចា និងចិត្ត ។ បទថា **យេ ធម្មមេវាទបយន្តិ សន្តោ**

សេចក្តីថា មនុស្សល្អ គឺសប្បុរសពួកណា រមែងប្រកាន់ធម៌នោះឯង គឺសមាទាន គឺកាន់យក ជនទាំងនោះជាសត្រូវរបស់អញ ចូរគប់រក ចូរសេពដោយអត្ថថា ចូរមានរូបជាទីស្រឡាញ់ចុះ ។ បទថា **អវិរោធបសំសនំ** គឺមេត្តា លោកហៅថា អវិរោធ គឺការមិនក្រោធ ដោយអត្ថថា សេចក្តីមេត្តានិងការសរសើរ ។ បទ ថា **សុណន្តុ ធម្មំ កាលេន** សេចក្តីថា សូមស្តាប់ខន្តិធម៌ មេត្តាធម៌ បដិសង្ខាធម៌ និងសារាណីយធម៌គ្រប់ៗ ខណៈ ។ បទថា **តញ្ច អនុវិធីយន្តុ** សេចក្តីថា ចូរធ្វើតាម គឺបំពេញធម៌នោះឲ្យបរិបូណ៌ ។ បទថា **ន ហិ ជាតុ សោ មមំ ហឹសេ** សេចក្តីថា បុគ្គលណា ជាអ្នកប៉ងប្រទូស្តចំពោះអញ បុគ្គល នោះកុំគប្បីបៀតបៀនអញដោយចំណែកមួយ ។ បទថា **អញ្ញំ វា បន កិញ្ចិ នំ** សេចក្តីថា ចូរកុំបៀតបៀន ចូរកុំធ្វើឲ្យលំបាកនូវអញតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន សូម្បីអ្នកដទៃណាមួយ ក៏កុំបៀតបៀនកុំធ្វើឲ្យលំបាកឡើយ ។ បទថា **បប្បុយ្យ បរមំ សន្តឹ** បានដល់ ដល់នូវព្រះនិព្វានដែលមានសេចក្តីស្ងប់ដ៏ក្រៃលែង ។ បទថា **រក្ខេយ្យ តសថាវរេ** សេចក្តីថា បុគ្គលនៅមានតណ្ហា លោកហៅថា ជាអ្នកមានសេចក្តីភ្ញាក់ផ្អើល បុគ្គលមិនមានតណ្ហា លោកហៅថា ជាអ្នកមាំទាំ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះ បុគ្គលណាដល់នូវព្រះនិព្វាន បុគ្គលនោះរមែងជាបុគ្គលដែលអាចដើម្បីរក្សាការភ័យខ្លាច និងការមិនញាប់ញ័រទាំងអស់បាន ព្រោះដូច្នោះ បុគ្គលដូចអញរមែងដល់នូវព្រះនិព្វាន ជនទាំងឡាយរមែងបៀតបៀនអញ ដោយចំណែកមួយក៏ទេ ដូច្នេះ ។ លោកពោលគាថាទាំង ៣ នេះ

ដើម្បីការពារខ្លួន ។

ឥឡូវនេះ កាលសម្តែងការបដិបត្តិខ្លួនឯង ទើបត្រាស់ពាក្យថា **ឧទកញ្ហិ ន យន្តិ នេត្តិកា** ជាដើម ។ បទថា **នេត្តិកា** ក្នុងគាថានោះ សេចក្តីថា ជនណាជម្រះប្រឡាយឲ្យស្អាត ទប់ទឹកក្នុងទីដែលគួរទប់ បង្ហូរទឹកចូលទៅ ។ បទថា **ឧសុការា នមយន្តិ** សេចក្តីថា ជាងព្រួញលាបព្រួញដោយបាយ ម៉ានរោលត្រង់រងើកភ្លើង ពត់ទីដែលកោងធ្វើឲ្យត្រង់ ។ បទថា **តេជនំ** បាន ដល់ព្រួញ ជាងព្រួញរមែងពត់ព្រួញនោះ និងឲ្យអ្នកដទៃពត់ ដូច្នោះ ទើប ហៅថា **តេជនំ** ។ បទថា **អត្តានំ ទមយន្តិ** សេចក្តីថា បណ្ឌិតរមែងទូន្មាន ខ្លួន គឺធ្វើឲ្យត្រង់ គឺឲ្យអស់ពុតសន៍ ដូចបុគ្គលបង្ហូរទឹក រមែងនាំទៅដោយផ្លូវ ត្រង់ ជាងផ្ទុកធ្វើព្រួញឲ្យត្រង់ ជាងឈើ ក៏ចាំងឈើឲ្យត្រង់ ដូច្នោះ ។ បទថា **តាទិនា** សេចក្តីថា ព្រះមានព្រះភាគ ជាតាទិបុគ្គល ដោយអាការ ៥ ដែលមិនមានខុសប្រក្រតី ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម គឺព្រះ-សាស្តាជាអ្នកដល់លក្ខណៈនៃការមិនញាប់ញ័រយ៉ាងនេះ គឺឈ្មោះថា ជាតាទិ បុគ្គល ព្រោះអត្ថថា មិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា តាទិបុគ្គល ព្រោះអត្ថថា ខ្ជាក់ចេញហើយ ឈ្មោះថា តាទិបុគ្គល ព្រោះ អត្ថថា លះបង់ហើយ ឈ្មោះថា តាទិបុគ្គល ព្រោះអត្ថថា ឆ្លងបានហើយ ឈ្មោះថា តាទិបុគ្គល ព្រោះសម្តែងចេញនូវភាពមិនញាប់ញ័រនោះ ។ បទថា **ភវនេត្តិ** បានដល់ ខ្សែនៃភព ។ ពាក្យនេះជាឈ្មោះនៃតណ្ហា ។ ពិតហើយ សត្វទាំងឡាយត្រូវតណ្ហានោះចងហបទ័យ នាំទៅកាន់ភពនោះៗ ដូចគោដែល

គេលាមទុកដោយខ្សែត្រង់ក ដូច្នោះ ព្រោះដូច្នោះ ទើបលោកហៅថា **ភវនេត្តិ** គឺតណ្ហានាំសត្វទៅកាន់ភព ។ បទថា **ផុដ្ឋោ កម្ម វិបាកេន** សេចក្តីថា បុគ្គលដែលមគ្គចេតនាពាល់ត្រូវហើយ ព្រោះកម្មដែលមគ្គចេតនាដុត គឺដុតកម្ទេចឲ្យដល់នូវការអស់ទៅ ដូច្នោះ មគ្គចេតនានោះ ទើបលោកហៅថា កម្មវិបាក ។ ព្រះអង្គុលិមាលនេះដែលកម្មវិបាកនោះពាល់ត្រូវហើយ ។ បទថា **អនណោ** បានដល់ ជាអ្នកមិនមានកិលេស រមែងមិនមែនប្រព្រឹត្តទៅដើម្បីទុក្ខវេទនា ។ម្យ៉ាងទៀត ក្នុងបទថា **អនណោ ភុញ្ជាមិ** ខ្ញុំជាអ្នកបរិភោគមិនមានបំណុល នេះគប្បីជ្រាបការបរិភោគ ៤ យ៉ាង គឺថេយ្យបរិ-ភោគ ១ ឥណបរិភោគ ១ ទាយជ្ជបរិភោគ ១ សាមិបរិភោគ ១ ។ ក្នុងបណ្តាបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អ្នកទ្រុស្តសីល ឈ្មោះថា ថេយ្យបរិភោគ អ្នកទ្រុស្តសីលនោះ លួចបច្ច័យ ៤ បរិភោគ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគ ក៏បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគដុំបាយរបស់អ្នកស្រុក ដោយភាពជាចោរ ដូច្នេះ ។ ឯការមិនពិចា-រណា ហើយបរិភោគរបស់អ្នកមានសីល ឈ្មោះថា ឥណបរិភោគ គឺបរិភោគជាប់ដោយបំណុល ការបរិភោគរបស់ព្រះសេក្ខៈ ៧ ពួក ឈ្មោះថា ទាយជ្ជបរិភោគ គឺបរិភោគដោយភាពជាមត៌ក ។ ការបរិភោគរបស់ព្រះខីណាស្រពឈ្មោះថា សាមិបរិភោគ គឺបរិភោគក្នុងភាពជាម្ចាស់ ។ បទថា មិនមានបំណុល ក្នុងទីនេះ លោកពោលសំដៅយកការមិនមានបំណុល គឺកិលេស ។បាឋៈថា **អនិណោ** ដូច្នេះក៏មាន ។ បទថា **ភុញ្ជាមិ ភោជនំ** លោកពោល

សំដៅយកសាមិបរិភោគ ។ បទថា **កាមរតិសន្ថវំ** សេចក្តីថា អ្នកទាំងឡាយ កុំប្រកបរឿយៗ គឺកុំធ្វើនូវការសរសើរ ដោយការត្រេកអរ ព្រោះតណ្ហា ក្នុងកាមទាំង ២ ។ បទថា **ឧយិទំ ឧម្មន្តិតំ មម** សេចក្តីថា ការដែលអញឃើញព្រះសម្មាសម្ពុទ្ធ ហើយគិតថា អញនឹងបួសឯណា ការគិតរបស់អញនោះ មិនមែនជាការគិតអាក្រក់ឡើយ ។ បទថា **សុវិភត្តេសុ ធម្មេសុ** សេចក្តីថា ក្នុងធម៌ដែលតថាគតកើតឡើងក្នុងលោក យ៉ាងនេះថា តថាគតជាសាស្តាចែកល្អហើយទាំងនោះ ព្រះនិព្វានជាធម៌ប្រសើរបំផុតណា តថាគតចូលដល់ហើយ ចូលដល់ព្រមហើយ នូវព្រះនិព្វាននោះឯង ព្រោះដូច្នោះ ការមកដល់របស់តថាគតនេះ ជាការមកល្អហើយ មិនប្រាសចាកប្រយោជន៍ ។ បទថា **តិស្សោ វិជ្ជា** បានដល់ បុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយបញ្ញា ។ បទថា **កតំ ពុទ្ធស្ស សាសនំ** សេចក្តីថា កិច្ចដែលគួរធ្វើក្នុងសាសនារបស់ព្រះពុទ្ធឯណានៅមាន កិច្ចទាំងអស់នោះខ្ញុំធ្វើហើយ ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យដល់ទីបំផុត ដោយវិជ្ជា ៣ និង លោកុត្តរធម៌ ៩ ដោយប្រការដូច្នេះ ។ ៚

**អដ្ឋកថា អង្គុលិមាលសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## បិយជាតិកសូត្រទី ៧

[ ២៩៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង គហបតីម្នាក់មានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ។ ព្រោះកូននោះធ្វើកាលកិរិយាទៅ ការងារទាំងឡាយក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ ( ដល់គាត់ ) ឡើយ ។ គាត់តែងតែទៅកាន់ឈាបនដ្ឋានយំរកថា ឱកូនតូចថ្មើមថ្ងៃ អ្នកនៅក្នុងទីណា ឱកូនតូចថ្មើមថ្ងៃ អ្នកនៅក្នុងទីណា ។ គ្រាក្រោយមក គហបតីនោះ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។

[ ២៩៧ ] លុះគហបតី អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានបុណ្យទ្រង់ត្រាស់ដូច្នេះថា ម្នាលគបហតី អ្នកតាំងនៅក្នុងចិត្តរបស់ខ្លួន គឺនៅរស់ទេ តែហាក់ដូចជាមិនមានឥន្ទ្រិយ គឺមនោវិញ្ញាណ ( ព្រោះ ) ឥន្ទ្រិយរបស់អ្នកប្រែសម្បុរប្លែក ។ គហបតី ទូលថា ឱព្រះអង្គដ៏ចម្រើន ឥន្ទ្រិយរបស់ខ្ញុំព្រះអង្គ នឹងមិនប្រែពណ៌សម្បុរប្លែកណាក៏បាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ព្រោះវាធ្វើកាលកិរិយាទៅ ការងារក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ ( ដល់ខ្ញុំព្រះអង្គ ) សោះ ខ្ញុំព្រះអង្គនោះ តែងទៅកាន់ឈាបនដ្ឋាន ហើយ

យំរកថា ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា ។ ព្រះមានបុណ្យត្រាស់ថា ដំណើរនុ៎ះយ៉ាងនោះមែនគហបតីដំណើរនុ៎ះ យ៉ាងនោះមែនគហបតី ពិតមែន គហបតី សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខតូចចិត្ត ការចង្អៀតចង្អល់ចិត្តតែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ គបហាតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាហេតុនៃសេចក្តីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដែរ បពិត្រព្រះអង្គដ៏ចម្រើន តែបើតាមដែលពិតនោះ សេចក្តីត្រេកអរ និងសេចក្តីរីករាយ តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ខណៈនោះ គហបតីនោះ មិនត្រេកអរ មិនឃាត់ហាមនូវភាសិតរបស់ព្រះមានបុណ្យទេ ក៏ក្រោកចាកអាសនៈ ចេញទៅ ។

[ ២៩៨ ] សម័យនោះ មានពួកអ្នកលេងល្បែងភ្នាល់ច្រើននាក់ កំពុងលេងដោយល្បែងភ្នាល់ទាំងឡាយ ក្នុងទីមិនឆ្ងាយប៉ុន្មានអំពីព្រះមានបុណ្យ ។ ចំណែកគហបតីនោះ ក៏ចូលទៅរកពួកអ្នកលេងល្បែងភ្នាល់នោះ លុះចូលទៅដល់ហើយ ក៏និយាយទៅនឹងអ្នកលេងល្បែងភ្នាល់នោះដូច្នេះថា នែអ្នកដ៏ចម្រើនទាំងឡាយ អម្បាញ់មិញនេះ ខ្ញុំបានចូលទៅគាល់ព្រះសមណគោតម លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះសមណគោតមរួចអង្គុយក្នុងទីដ៏សមគួរ នៃអ្នកដ៏ចម្រើនទាំងឡាយ លុះខ្ញុំអង្គុយក្នុងទីដ៏សមគួរហើយ ព្រះសមណ-

គោតមទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកឋិតនៅក្នុងចិត្តរបស់ខ្លួនគឺរស់នៅទេ តែហាក់ដូចជាមិនមានឥន្ទ្រិយ ( ព្រោះ ) ឥន្ទ្រិយរបស់អ្នក ប្រែសម្បុរប្លែកដូច្នេះ នៃអ្នកដ៏ចម្រើនទាំងឡាយ កាលព្រះសមណគោតម ត្រាស់យ៉ាងនេះ ខ្ញុំក៏បានតបទៅនឹងព្រះសមណគោតមវិញថា ឱព្រះអង្គដ៏ចម្រើន ឥន្ទ្រិយរបស់ខ្ញុំព្រះអង្គ នឹងមិនប្រែពណ៌សម្បុរប្លែកណាក៏បាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ព្រោះតែវាធ្វើកាលកិរិយាទៅ ការងារក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ ( ដល់ខ្ញុំ ) សោះ ខ្ញុំព្រះអង្គនោះឯងតែងទៅកាន់ឈាបនដ្ឋានយំរកថា ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា ដូច្នេះ ទើបព្រះសមណគោតមត្រាស់ថា ដំណើរនុ៎ះយ៉ាងនេះមែនគហបតី ដំណើរនុ៎ះយ៉ាងនេះមែនគហបតី ពិតមែនគហបតី សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ( កាលបើព្រះមានបុណ្យទ្រង់ត្រាស់យ៉ាងនេះ ខ្ញុំក៏ទូលតបវិញ ) ថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាហេតុនៃសេចក្តីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតមែន បពិត្រព្រះអង្គដ៏ចម្រើន តែតាមដែលពិតនោះ សេចក្តីត្រេកអរ និងសេចក្តីរីករាយ តែងកើតមកពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះ នៃអ្នក

ដ៏ចម្រើនទាំងឡាយ កាលនោះខ្ញុំក៏មិនត្រេកអរ មិនឃាត់ហាមនូវភាសិតរបស់ព្រះសមណគោតមទេ ខ្ញុំក្រោកចាកអាសនៈហើយក៏ចេញមក ។ ពួកអ្នកលេងល្បែងភ្នាល់ឆ្លើយតបថា បពិត្រលោកគហបតី ពាក្យដែលលោកមានប្រសាសន៍នុ៎ះ ត្រូវហើយ បពិត្រលោកគហបតី ពាក្យដែលលោកមានប្រសាសន៍នុ៎ះ ត្រូវហើយ បពិត្រលោកគហបតិ សេចក្តីត្រេកអរ និងសេចក្តីរីករាយតែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដោយពិត ។ ទើបគហបតីនោះគិតថា ពាក្យរបស់អាត្មាអញសមគ្នា នឹងពួកអ្នកលេងល្បែងភ្នាល់ ដូច្នេះ រួចក៏ចេញទៅ ។

[ ២៩៩ ] គ្រានោះឯង ដំណើរវាចានេះ ក៏ព្ធខ្ចរខ្ចាយតាមលំដាប់ រហូតចូលទៅខាងក្នុងព្រះរាជវាំង ។ វេលានោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់សួរទៅនាងមល្លិការាជទេវីថា នែមល្លិកា ព្រះសមណគោតម ( ជាគ្រូ ) របស់នាងបានសម្តែងព្រះវាចានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួលសេចក្តីទុក្ខតូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្តតែងកើតមកអំពីសេចក្តីស្រឡាញ់មានសេចក្តីស្រឡាញ់ជាដែនកើត ដូច្នេះមែនឬអ្វី ។ ព្រះនាងមល្លិការាជទេវីក្រាបបង្គំទូលថា បពិត្រព្រះមហារាជ បើពាក្យនោះ ព្រះមានបុណ្យទ្រង់សម្តែងមែន ដំណើរនុ៎ះក៏ពិតយ៉ាងនោះឯង ។ ព្រះបាទបសេនទិកោសល ទ្រង់បន្ទោសថា មិនសមបើយ៉ាងនេះៗ សោះ ព្រះសមណគោតម ពោលនូវពាក្យណា មល្លិកានេះ ហ៊ាននិយាយចាក់បណ្តោយតាមពាក្យនោះៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមហារាជ បើពាក្យនោះព្រះមានបុណ្យ

ទ្រង់សម្តែងមែន ដំណើរនុ៎ះក៏ពិតយ៉ាងនោះដូច្នេះសោះ ប្រៀបដូចអាចារ្យនិយាយពាក្យណាៗ ដល់កូនសិស្សៗ ក៏និយាយចាក់បណ្តោយតាមពាក្យនោះៗ របស់អាចារ្យនោះថា បពិត្រលោកអាចារ្យដំណើរនុ៎ះយ៉ាងហ្នឹងមែន បពិត្រលោកអាចារ្យដំណើរនុ៎ះយ៉ាងហ្នឹងមែន សេចក្តីនេះមានឧបមាយ៉ាងណា នែមល្លិកា ព្រះសមណគោតមពោលនូវពាក្យណាៗ នាងក៏និយាយចាក់បណ្តោយតាមពាក្យនោះៗ របស់ព្រះសមណគោតមនោះថា បពិត្រព្រះមហារាជ បើពាក្យនោះ ព្រះមានបុណ្យទ្រង់សម្តែងមែន ដំណើរនុ៎ះក៏ពិតយ៉ាងនោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ នែមល្លិកា ចូរនាងចៀសអំពីមុខអញចេញទៅ ( ព្រោះ ) នាងខិលខូចណាស់ ។

[ ៣០០ ] គ្រានោះ ព្រះនាងមល្លិការាជទេវី មានព្រះសវនីយ៍ទៅរកនាឡិជង្ឃព្រាហ្មណ៍ថា នែព្រាហ្មណ៍ ចូរអ្នកមកអាយ ចូរអ្នកចូលទៅគាល់ព្រះភគវន្តមុនី លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះភគវន្តមុនីដោយត្បូងរួចទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័សកម្លាំង ការគង់នៅជាសុខ តាមពាក្យខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមល្លិការាជទេវី សូមថ្វាយបង្គំព្រះបាទា របស់ព្រះមានព្រះភាគដោយត្បូងទាំងសូមទូលសួរនូវការមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័សកម្លាំង ការគង់នៅជាសុខដូច្នេះ រួចចូរអ្នកទូលសួរយ៉ាងនេះទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគបានសម្តែងព្រះវាចានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមក

អំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះឬអ្វី បើព្រះមានព្រះភាគ ទ្រង់ដោះស្រាយប្រាប់អ្នកយ៉ាងណា ចូរអ្នកចងចាំពាក្យនោះឲ្យល្អ ហើយមកប្រាប់ដល់ខ្ញុំវិញ ព្រោះព្រះតថាគតទាំងឡាយ មិនពោលពាក្យដែលមិនពិតប្រាកដឡើយ ។ នាឡិជង្ឃព្រាហ្មណ៍ ទទួលព្រះវាចា របស់ព្រះនាងមល្លិកាអគ្គទេវីថា ទទួលព្រះសវនីយ៍ករុណាវិសេស ដូច្នេះ រួចក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះមានបុណ្យ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនាឡិជង្ឃព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលពាក្យនុ៎ះចំពោះព្រះមានបុណ្យថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះនាងមល្លិកាអគ្គទេវី សូមថ្វាយបង្គំព្រះបាទារបស់ព្រះគោតមដ៏ចម្រើនដោយត្បូង ទាំងសូមសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស កម្លាំង ការគង់នៅជាសុខ មួយទៀត ព្រះនាងសូមទូលសួរយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ បានសម្តែងព្រះវាចានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ ជាដែនកើត ដូច្នេះឬអ្វី ។ ព្រះអង្គត្រាស់ថា អើព្រាហ្មណ៍ ពាក្យនុ៎ះ គថាគតថាយ៉ាងនោះមែន អើព្រាហ្មណ៍ ពាក្យនុ៎ះ តថាគតថាយ៉ាងនោះមែន ម្នាលព្រាហ្មណ៍ ពិតមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់

ជាដែនកើត ។ ម្នាលព្រាហ្មណ៍ គេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពី សេចក្តីស្រឡាញ់មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះ ដោយបរិយាយនេះ ។

[ ៣០១ ] ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មានមាតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើកាលកិរិយាទៅ ។ តាំងអំពីកាលកិរិយានៃមាតានោះ ស្ត្រីនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រករហកសព្វផ្លូវត្រៃឡែងកែង ស្រែកសួរយ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញមាតាខ្ញុំដែរឬ ឱអ្នកទាំងឡាយ បានឃើញមាតាខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពី សេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មាតាបិតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាល ... បងប្អូនប្រុសបានធ្វើមរណកាល ... បងប្អូនស្រីបានធ្វើមរណកាល ... កូនប្រុសបានធ្វើមរណកាល ... កូនស្រីបានធ្វើមរណកាល ... ស្វាមីបានធ្វើមរណកាល ។ តាំងអំពីកាលកិរិយានៃស្វាមីនោះ ស្ត្រីនោះក៏ទៅជាឆ្កួតមានចិត្តរវើរវាយ ដើរសព្វច្រករហក សព្វផ្លូវត្រៃឡែងកែង ស្រែកសួរយ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញស្វាមីខ្ញុំដែរឬ ឱអ្នកទាំងឡាយ បានឃើញស្វាមីខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់

ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០២ ] ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មានមាតាបុរសម្នាក់ ក្នុងក្រុងសាវត្ថីនោះឯង បានធ្វើមរណកាលទៅ ។ តាំងអំពីមរណកាល នៃមាតានោះ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រកល្ហក សព្វផ្លូវត្រៀងកែង ស្រែកសួរយ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញម្តាយខ្ញុំដែរឬ ឱអ្នកទាំងឡាយ បានឃើញម្តាយខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយ មានបិតាបុរសម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាល ... បងប្អូនប្រុសបានធ្វើមរណកាល ... បងប្អូនស្រីបានធ្វើមរណកាល ... កូនប្រុសបានធ្វើមរណកាល ... កូនស្រីបានធ្វើមរណកាល ... ប្រពន្ធបានធ្វើមរណកាលទៅ ។ តាំងអំពីមរណកាលនៃភរិយានោះ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រករហក សព្វផ្លូវត្រៀងកែងស្រែកសួរយ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញប្រពន្ធខ្ញុំដែរឬ ឱអ្នកទាំងឡាយបានឃើញប្រពន្ធខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៣ ] ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ ក្នុងក្រុងសាវត្ថីនេះ មានស្ត្រីម្នាក់បានទៅកាន់ត្រកូលនៃញាត គឺមានប្តី ។ ពួកញាតិទាំងនោះ របស់ស្ត្រីនោះ មានប្រាថ្នានឹងផ្តាច់ប្តីចេញ ហើយលើក ( នាងនោះ ) ឲ្យទៅបុរសឯទៀតវិញ តែនាងនោះមិនចង់បានបុរសនោះសោះ ។ ទើបស្ត្រីនោះនិយាយនឹងប្តីដូច្នេះថា បពិត្រអយ្យបុត្ត ពួកញាតិរបស់ខ្ញុំនេះ មានប្រាថ្នានឹងផ្តាច់អ្នកចេញ ហើយលើកខ្ញុំឲ្យទៅបុរសឯទៀតវិញ តែខ្ញុំមិនចង់បានបុរសនោះសោះ ។ គ្រានោះ បុរសនោះក៏កាប់ស្ត្រីនោះជា ២ កំណាត់ ហើយវះពោះខ្លួនឯង ដោយប្រាថ្នាថា សូមឲ្យយើងទាំង ២ នាក់បានជួបគ្នា ទៅក្នុងបរលោក ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៤ ] គ្រានោះ នាឡិជង្ឃព្រាហ្មណ៍ ក៏ត្រេកអរអនុមោទនា ចំពោះភាសិតរបស់ព្រះមានបុណ្យ រួចក្រោកអំពីអាសនៈ ចូលទៅគាល់ព្រះនាងមល្លិការាជទេវី លុះចូលទៅដល់ហើយ ក៏ក្រាបទូលនូវពាក្យដែលខ្លួនបានចរចា ជាមួយនឹងព្រះមានបុណ្យ ដល់ព្រះនាងមល្លិការាជទេវីដោយសព្វគ្រប់ ។ គ្រានោះ ព្រះនាងមល្លិការាជទេវី ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ ក៏ក្រាបទូលសួរព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច រាជកុមារីព្រះនាមវជិរី ព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ ព្រះបាទបសេនទិកោសល

មានព្រះបន្ទូលតបថា អើមល្លិកា វជិរីកុមារី អញស្រឡាញ់ ។ នាងមល្លិកាទូលសួរថា បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ( បើ ) វជិរីកុមារី ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ ព្រះអង្គឬទេ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលតបថា អើមល្លិកា ( បើ ) នាងវជិរីកុមារី ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងខានកើតឡើងដល់អញ ឯណាក៏បាន ។ ព្រះនាងមល្លិកាราជទេវីទូលថា បពិត្រព្រះមហារាជ ព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយ បានជាសំដែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៥ ] បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថា ដូចម្តេច នាងវាសភខត្តិយា តើព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ អើមល្លិកា នាងវាសភខត្តិយា អញស្រឡាញ់ ។ បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ( បើ ) នាងវាសភខត្តិយា ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា ( បើ ) នាងវាសភខត្តិយា

ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់បើ សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងខានកើតឡើងដល់អញឯណាក៏បាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៦ ] បពិត្រមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថា ដូចម្តេច វិឌូឌភសេនាបតី តើព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ អើមល្លិកា វិឌូឌភសេនាបតី អញស្រឡាញ់ ។ បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថាដូចម្តេច បើវិឌូឌភសេនាបតី ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា ( បើ ) វិឌូឌភសេនាបតី ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដូចគ្នា ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងខានកើតដល់អញឯណាក៏បាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយ បានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តី

ស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៧ ] បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថាដូចម្តេច ចុះខុទ្ទំម្ចាស់ តើព្រះអង្គសព្វព្រះរាជហឫទ័យដែរឬ ។ អើមល្លិកា ឯងក៏ជាទីស្រឡាញ់របស់អញដែរ ។ បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច បើខ្ញុំម្ចាស់ប្រែប្រួល ព្រាត់ប្រាសនិរាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា ( បើ ) ឯងប្រែប្រួល ព្រាត់ប្រាសនិរាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណាន់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងខានកើតឡើងដល់អញឯណាក៏បាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៨ ] បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ដែនកាសី និងដែនកោសល តើព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ អើមល្លិកា ដែនកាសី និងដែនកោសល ជាទីស្រឡាញ់របស់អញ ម្នាលមល្លិកា ( ព្រោះ ) យើងប្រើប្រាស់ខ្លឹមចន្ទន៍ ដែលបានមកអំពីដែនកាសី ទ្រទ្រង់ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ ដោយអានុភាពនៃដែនកាសី

និងដែនកោសល ។ បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច ( បើ ) ដែនកាសី និងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។ ឱមល្លិកា បើដែនកាសី និងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ សូម្បីជីវិតរបស់អញ ក៏មុខជាវិបត្តិប្រែប្រួលទៅដែរ ចំណាន់បើ សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត នឹងខានកើតដល់អញឯណាក៏បាន ។ បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត តែងកើតឡើងមកអំពី សេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ ៣០៩ ] ព្រះបាទបសេនទិកោសលមានព្រះរាជឱង្ការថា អស្ចារ្យណាស់ មល្លិកា ចម្លែកណាស់ មល្លិកា ព្រោះព្រះមានព្រះភាគអង្គនោះ ប្រហែលជាទ្រង់ត្រាស់ដឹង ឃើញច្បាស់ដោយប្រាជ្ញាមែន ម្នាលមល្លិកា នាងចូរមកអាយ ចូរនាងឲ្យនូវទឹក សម្រាប់លាងជម្រះ ( ដល់អញ ) ។ តពីនោះមក ព្រះបាទបសេនទិកោសល ក្រោកអំពីអាសនៈធ្វើសំពត់ឧត្តរា សង្គៈឆៀងព្រះអង្សាម្ខាង ប្រណម្យអញ្ជលីឆ្ពោះត្រង់ទីព្រះមានព្រះភាគគង់ បន្លឺនូវឧទានអស់វារៈ ៣ ដងថា

ខ្ញុំសូមថ្វាយបង្គំ ចំពោះព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ

ខ្ញុំសូមថ្វាយបង្គំ ។បេ។ ព្រះសម្មាសម្ពុទ្ធអង្គនោះ ។

## ចប់ បិយជាតិកសូត្រ ជាគម្រប់ ៧

# អដ្ឋកថា

## បិយជាតិកសូត្រ

[ ២៩៦ ] បិយជាតិកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **នេវ កម្មន្តា បដិភន្តិ** សេចក្ដីថា ការងាររមែងមិនប្រាកដទាំងអស់ដោយប្រការទាំងពួង គឺរមែងមិនប្រាកដដោយការកំណត់តាមប្រក្រតី ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះនោះឯង ។ បទថា **ន បដិភន្តិ** ក្នុងព្រះសូត្រនេះ ប្រែថា មិនត្រូវចិត្ត ។ បទថា **អាឡាហនំ** ប្រែថា ព្រៃខ្មោច ។

[ ២៩៧ ] បទថា **អញ្ញថត្តំ** បានដល់ ការកើតដោយប្រការដទៃ ព្រោះមានពណ៌សម្បុរប្លែកៗ ។ ធម៌ដែលគប្បីដឹងច្បាស់ដោយចិត្ត ឈ្មោះថា ឥន្ទ្រិយ ។ តែពាក្យនេះ លោកពោលសំដៅដល់ឱកាសដែលឥន្ទ្រិយតាំងនៅហើយ ។

[ ២៩៨ ] បទថា **បិយជាតិកា** សេចក្ដីថា រមែងកើតអំពីសេចក្ដីស្រឡាញ់ ។ បទថា **បិយប្បភុត្តិកា** សេចក្ដីថា មានមកអំពីរបស់ដែលស្រឡាញ់ ។ បទថា **សចេ តំ មហារាជ** សេចក្ដីថា សូម្បីកំណត់អត្ថនៃព្រះតម្រាស់នោះ ទើបពោលយ៉ាងនោះ ដោយសទ្ធាក្នុងព្រះសាស្ដា ។ បទថា **ចរ បិរេ** សេចក្ដីថា អ្នកចូរចៀសទៅផ្លូវដទៃ ដោយអត្ថថា នាងកុំឈរនៅក្នុងទីនេះក៏បាន ។ម្យ៉ាងទៀត បទថា **ចរ បិរេ** គឺចូរនាងទៅផ្លូវដទៃ អធិប្បាយថា កុំឈរក្នុងទីនេះ ។

[ ៣០៣ ] បទថា **ទ្វិធា ឆេត្វា** សេចក្តីថា កាត់ គឺធ្វើឲ្យជា ២ ចំណែក ដោយដាវ ។ បទថា **អត្តានំ ឧប្បាលេសិ** សេចក្តីថា យកដាវនោះឯងវះពោះរបស់ខ្លួន ។ បើស្រីនោះមិនជាទីស្រឡាញ់របស់ប្រុសនោះ ឥឡូវនេះ ប្រុសនោះ មិនគប្បីសម្លាប់ខ្លួនដោយគិតថា អញនឹងរកស្រីដទៃ ។ តែព្រោះស្រីនោះ ជាទីស្រឡាញ់របស់បុរសនោះ ដូច្នោះ បុរសនោះប្រាថ្នាសេចក្តីព្រមព្រៀងនឹងស្រីនោះក្នុងបរលោក ទើបធ្វើយ៉ាងនោះ ។

[ ៣០៤ ] បទថា **បិយា តេ វជិរី** សេចក្តីថា បានឮថា ព្រះនាងមានព្រះតម្រិះយ៉ាងនេះ ព្រះនាងពោលយ៉ាងនោះ ព្រោះគិតថា បើអញពោលពាក្យជាដើមថា បពិត្រមហារាជ រឿងធ្លាប់មានមកហើយ ក្នុងព្រះនគរសាវត្ថីនេះ មានស្រីម្នាក់ ព្រះអង្គគប្បីបដិសេធអញថា អ្នកណាបានធ្វើយ៉ាងនោះដល់នាងចូរថយទៅ សេចក្តីនោះមិនមានទេ អញនឹងញ៉ាំងស្ដ្រីនោះឲ្យយល់ដោយអាការប្រព្រឹត្តិទៅនោះឯង ។

ក្នុងបទថា **វិបរិណាមញ្ញថាភាវា** នេះ បណ្ឌិតគប្បីជ្រាបការប្រែប្រួលព្រោះសេចក្តីស្លាប់ ដោយប្រការដទៃ ឬដោយការគេចទៅជាមួយបុគ្គលណាមួយក៏បាន ។

[ ៣០៥ ] បទថា **វាសភាយ** សេចក្តីថា ព្រះទេវីរបស់ព្រះរាជាមួយអង្គព្រះនាមវាសភា លោកពោលសំដៅដល់ព្រះនាងនោះ ។

បទថា **បិយា តេ អហំ** លោកពោលខាងក្រោយបង្អស់ ព្រោះហេតុអ្វី បានឮថា ការត្រិះរិះនេះមានហើយដល់ព្រះនាងនោះ ទើបទូលសួរឯក្រោយបង្អស់

ដើម្បីឲ្យជាទីតាំងនៃវាទៈថា ព្រះរាជានេះទ្រង់ពិរោធអញ បើអញ គប្បីសួរមុនអ្នកដទៃបន្តស់ថា ខ្ញុំម្ចាស់ជាទីស្រឡាញ់របស់ព្រះអង្គឬ ព្រះអង្គ ក៏គប្បីត្រាស់ថា នាងមិនជាទីស្រឡាញ់របស់អញទេ ចូរចៀសចេញទៅ កាលបើដូច្នេះ វាទៈក៏នឹងមិនបានតាំងឡើង បណ្ឌិតគប្បីជ្រាបការប្រែប្រួល ដោយភាពជាបុគ្គលត្រូវបោលក្នុងដែនកាសីកោសល ការកើតដោយប្រការដទៃ ដោយនៅក្នុងកណ្ដាប់ដៃព្រះរាជា ដែលជាបដិបក្ខទាំងឡាយ គឺជាព្រះរាជា ដែលជាសត្រូវ ។

[ ៣០៩ ] បទថា **អាចមេហិ** សេចក្ដីថា នាងចូរយកទឹកខ្ពុរមាត់មក ។ ព្រះបាទបសេនទិកោសលទ្រង់ខ្ពុរហើយ ទ្រង់លុបព្រះភក្ត្រ និងលាងព្រះហស្ថ និងព្រះបាទហើយ ទ្រង់បិទព្រះឱស្ឋហើយ បំណងនឹងនមស្ការព្រះសាស្ដា ទើបត្រាស់យ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ។ ៚

**អដ្ឋកថា បិយជាតិកសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ពាហិតិយសូត្រទី ៨

[ ៣១០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តព្រះជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ដល់ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយកត្ត ក៏ចូលទៅឯប្រាសាទ ឈ្មោះបុព្វារាម ជារបស់មិគារមាតា ដើម្បីនៅសម្រាកក្នុងវេលាថ្ងៃ ។

[ ៣១១ ] សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់ឡើងគង់ព្រះទីនាំងនាគេន្ទ្រ ឈ្មោះឯកបុណ្ឌរីកៈ បរទៅក្នុងក្រុងសាវត្ថីទាំងថ្ងៃ ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញព្រះអានន្ទមានអាយុ កំពុងនិមន្តមកអំពីចម្ងាយ លុះឃើញហើយទ្រង់ត្រាស់ទៅនឹងមហាមាត្យឈ្មោះសិរិវឌ្ឍៈថា ម្នាលសិរិវឌ្ឍសម្លាញ់ នុ៎ះព្រះអានន្ទមានអាយុរបស់យើងឬ ។ សិរិវឌ្ឍមហាមាត្យ ក្រាបបង្គំទូលថា ព្រះករុណាវិសេសមហារាជ នុ៎ះហើយព្រះអានន្ទមានអាយុ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ហៅបុរសម្នាក់មកថា ម្នាលបុរសអើយ ចូរឯងមកអាយ ឯងចូរទៅ ឯព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទ នៃព្រះអានន្ទមានអាយុ ដោយក្បាលតាមពាក្យរបស់អញថា បពិត្រលោកដ៏ចម្រើន ព្រះបាទ

បសេនទិកោសល សូមថ្វាយបង្គំព្រះបាទនៃព្រះអានន្ទមានអាយុដោយសិរ្សៈ រួចហើយ ចូរពោលយ៉ាងនេះតទៅទៀតថា បពិត្រលោកដ៏ចម្រើន បើព្រះអានន្ទមិនមានកិច្ចណាមួយ ដែលគួរធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទអនុគ្រោះរង់ចាំមួយរំពេចសិន ។ បុរសនោះទទួល ព្រះរាជឱង្ការព្រះបាទបសេនទិកោសលថា ព្រះករុណាវិសេសព្រះសម្មតិទេព ហើយចូលទៅរកព្រះអានន្ទមានអាយុ ត្រង់កន្លែងដែលលោកគង់នៅ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះអានន្ទមានអាយុដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចម្រើន ព្រះបាទបសេនទិកោសល សូមថ្វាយបង្គំព្រះបាទនៃព្រះអានន្ទមានអាយុដោយសិរ្សៈ បពិត្រលោកដ៏ចម្រើន បើព្រះអានន្ទមានអាយុ មិនមានកិច្ចណាមួយ ដែលត្រូវធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទមានអាយុ អនុគ្រោះរង់ចាំមួយរំពេចសិន ។ ព្រះអានន្ទមានអាយុ ក៏ទទួលនិមន្តន៍ដោយ តុណ្ហីភាព ។

[ ៣១២ ] គ្រានោះព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជដំណើរទៅដរាបដល់អស់ទីដែលដំរីគួរទៅបាន ហើយចុះអំពីព្រះទីនាំងនាគេន្ទ្រ យាងទៅដោយព្រះបាទា ចូលទៅត្រង់ទីដែលព្រះអានន្ទមានអាយុគង់នៅ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទមានអាយុដោយគោរព ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់ក្នុងទីដ៏សមគួរហើយ ទ្រង់ត្រាស់ពាក្យនេះ ទៅរកព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចម្រើន

បើព្រះអានន្ទមានអាយុមិនមានកិច្ចណាមួយ ដែលគួរធ្វើដោយប្រញាប់ទេ បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទមានអាយុ អនុគ្រោះនិមន្តទៅគង់ឆ្នេរស្ទឹងអចិរវតី ។ ព្រះអានន្ទមានអាយុ ក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះអានន្ទមានអាយុ និមន្តចូលទៅឯឆ្នេរស្ទឹងអចិរវតី លុះចូលទៅដល់ហើយ ទៅគង់លើអាសនៈដែលគេក្រាលបម្រុងទុកក្រោមម្លប់ឈើមួយដើម ។ គ្រានោះឯង ព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជដំណើរទៅដោយព្រះទីនាំងនាគេន្ទ្រៈ ដរាបដល់ទីដែលគួរដើរទៅបាន ហើយទ្រង់ចុះអំពីព្រះទីនាំងនាគេន្ទ្រៈ ស្តេចទៅដោយព្រះបាទា ចូលទៅត្រង់ទីដែល ព្រះអានន្ទមានអាយុគង់នៅ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំព្រះអានន្ទមានអាយុដោយគោរព ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់នៅក្នុងទីដ៏សមគួរហើយ ទ្រង់ត្រាស់ពាក្យនេះ ទៅរកព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទមានអាយុ និមន្តគង់លើកម្រាលទីនាំងដំរីនេះចុះ ។ ព្រះអានន្ទមានអាយុតបថា ថ្វាយព្រះពរមហារាជ សូមព្រះអង្គគង់ចុះ អាត្មាភាពអង្គុយលើអាសនៈ របស់ខ្លួនបានហើយ ។ ព្រះបាទបសេនទិកោសល ទ្រង់គង់លើអាសនៈ ដែលគេក្រាលបម្រុងទុក ។

[ ៣១៣ ] លុះព្រះបាទបសេនទិកោសលគង់ស្ងប់ហើយ ទ្រង់ត្រាស់ពាក្យនេះនឹងព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន កាយសមាចារ ( ការប្រព្រឹត្តល្អដោយកាយ ) ណា ដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសបាន តើព្រះមានព្រះភាគអង្គនោះ ប្រព្រឹត្តកាយសមាចារ

មានសភាពដូច្នោះដែរឬទេ ព្រះអានន្ទតបថា បពិត្រមហារាជ កាយសមាចារណា ដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញ ពោលទោសបាន ព្រះមានព្រះភាគអង្គនោះ ព្រះអង្គមិនប្រព្រឹត្តកាយសមាចារ មានសភាពដូច្នោះទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះព្រះមានព្រះភាគអង្គនោះ ព្រះអង្គប្រព្រឹត្តវចីសមាចារ ( ការប្រព្រឹត្តល្អដោយវាចា ) មានសភាពដូច្នោះដែរឬទេ ។បេ។ មនោសមាចារ ( ការប្រព្រឹត្តល្អដោយចិត្ត ) ណា ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសបាន ព្រះអង្គប្រព្រឹត្តមនោសមាចារ មានសភាពដូច្នោះដែរឬទេ ។ បពិត្រមហារាជ មនោសមាចារណា ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសបាន ព្រះមានព្រះភាគអង្គនោះ ព្រះអង្គមិនប្រព្រឹត្តមនោសមាចារ មានសភាពដូច្នោះទេ ។

[ ៣១៤ ] ព្រះរាជាត្រាស់ថា បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចម្លែកណាស់ បពិត្រលោកដ៏ចម្រើន ព្រោះថា យើងខ្ញុំមិនអាចនឹងបំពេញនូវពាក្យណាដោយប្រស្នាបាន បពិត្រលោកដ៏ចម្រើន ពាក្យនោះ ក្រែងតែព្រះអានន្ទមានអាយុ ទើបអាចនឹងបំពេញដោយ ការដោះស្រាយនូវប្រស្នាបាន បពិត្រលោកដ៏ចម្រើន ពួកបុគ្គលពាល ដែលមិនឈ្លាសវៃ មិនបានពិចារណា មិនបានស្ទាបស្ទង់មើលហើយ ពោលនូវគុណ និងទោសរបស់បុគ្គលទាំងឡាយដទៃ យើងខ្ញុំមិនប្រកាន់យកពាក្យនោះ ( របស់បុគ្គលទាំងឡាយនោះ ) ថា មានខ្លឹមសារទេ បពិត្រលោកដ៏ចម្រើន បើបុគ្គលណាឈ្លាសវាងវៃជាអ្នកប្រាជ្ញ បានពិចារណា បានស្ទាបស្ទង់មើលហើយ ពោលនូវ

គុណ និងទោសរបស់បុគ្គលទាំងឡាយដទៃ យើងខ្ញុំប្រកាន់យកពាក្យនោះ ( របស់បុគ្គលទាំងឡាយនោះ ) ថា មានខ្លឹមសារ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារ ដែលពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញពោលទោសបាន តើដូចម្តេច ។ ព្រះអានន្ទតបថា បពិត្រមហារាជ កាយសមាចារដែលជាអកុសល ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារ ដែលជាអកុសល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារដែលប្រកបដោយទោស ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារដែលប្រកបដោយទោស តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារ ដែលប្រកបដោយសេចក្តីបៀតបៀន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារ ដែលប្រកបដោយសេចក្តីបៀតបៀនតើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារ ដែលមានសេចក្តីទុក្ខជាផល ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារ ដែលមានសេចក្តីទុក្ខជាផល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារណា ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំង ២ គឺខ្លួនឯង និងបុគ្គលដទៃផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះរមែងចម្រើន កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ បពិត្រមហារាជ កាយសមាចារ មានសភាពដូច្នេះ ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសបាន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះវចីសមាចារ ។បេ។ មនោសមាចារ ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសបាន តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារជា

អកុសល ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះមនោសមាចារជាអកុសល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលប្រកបដោយទោស ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះមនោសមាចារ ដែលប្រកបដោយទោស តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលប្រកបដោយសេចក្តីបៀតបៀន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះមនោសមាចារដែលប្រកប ដោយសេចក្តីបៀតបៀន តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារដែលមានសេចក្តីទុក្ខជាផល ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះមនោសមាចារដែលមានសេចក្តីទុក្ខជាផល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារណា ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅដើម្បីបៀតបៀនបុគ្គលទាំង ២ ផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ រមែងចម្រើនឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ បពិត្រមហារាជ មនោសមាចារ មានសភាពដូច្នោះឯង ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញពោលទោសបាន ។

[ ៣១៥ ] ព្រះរាជាត្រាស់ថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះព្រះមានព្រះភាគអង្គនោះ គ្រាន់តែពោលសរសើរនូវការលះបង់នូវអកុសលធម៌ទាំងឡាយ ទាំងអស់តែម្យ៉ាងឬ ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ ព្រះតថាគតទ្រង់លះបង់ នូវអកុសលធម៌ទាំងឡាយទាំងអស់ហើយ ទ្រង់ប្រកបដោយកុសលធម៌តែម្យ៉ាង ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះកាយសមាចារដែលគួរឲ្យពួកសមណព្រាហ្មណ៍ ជាអ្នកប្រាជ្ញពោលទោសមិនបាន តើដូចម្តេច ។

បពិត្រមហារាជ កាយសមាចារជាកុសល ។ បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារជាកុសល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមិនមានទោស ។ បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារមិនមានទោសតើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារ មិនមានសេចក្តីបៀតបៀន ។ បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារ មិនមានសេចក្តីបៀតបៀនតើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមានសេចក្តីសុខជាផល ។ បពិត្រលោកដ៏ចម្រើន ចុះកាយសមាចារមានសេចក្តីសុខជាផល តើដូចម្តេច ។ បពិត្រមហារាជ កាយសមាចារមិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង អកុសលធម៌ទាំងឡាយ របស់បុគ្គលនោះ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយរមែងចម្រើនឡើង បពិត្រមហារាជ កាយសមាចារមានសភាពដូច្នេះឯង ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសមិនបាន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះវចីសមាចារ ។បេ។ មនោសមាចារ ដែលពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសមិនបាន តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារជាកុសល ។ បពិត្រលោកដ៏ចម្រើន ចុះមនោសមាចារជាកុសល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារមិនមានទោស ។ បពិត្រលោកដ៏ចម្រើន មនោសមាចារមិនមានទោស តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ មិនមានសេចក្តីបៀតបៀន ។ បពិត្រលោកដ៏ចម្រើន ចុះមនោសមាចារ មិនមានសេចក្តីបៀតបៀន តើដូចម្តេច ។ បពិត្រមហារាជ

មនោសមាចារ មានសេចក្តីសុខជាផល ។ បពិត្រលោកដ៏ចម្រើន ចុះមនោសមាចារ មានសេចក្តីសុខជាផល តើដូចម្តេច ។ បពិត្រមហារាជ មនោសមាចារ មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង អកុសលធម៌ទាំងឡាយរបស់បុគ្គលនោះ រមែងសាបសូន្យ កុសលធម៌ទាំងឡាយ រមែងចម្រើនឡើង បពិត្រមហារាជ មនោសមាចារ មានសភាពដូច្នេះឯង ដែលគួរឲ្យពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ ពោលទោសមិនបាន ។

[ ៣១៦ ] ព្រះបាទបសេនទិកោសលត្រាស់ថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះព្រះមានព្រះភាគអង្គនោះ គ្រាន់តែពោលសរសើរនូវការបំពេញកុសលធម៌ទាំងអស់តែម៉្យាងឬ ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ ព្រះតថាគតទ្រង់លះបង់នូវអកុសលធម៌ទាំងអស់ ហើយទ្រង់ប្រកបដោយកុសលធម៌តែម៉្យាង ។

[ ៣១៧ ] បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចម្លែកណាស់ បពិត្រលោកដ៏ចម្រើន ពាក្យនេះពេញជាសុភាសិតដែលព្រះអានន្ទមានអាយុពោលហើយ បពិត្រលោកដ៏ចម្រើន ម្យ៉ាងទៀត យើងខ្ញុំជាអ្នកត្រេកអរពេញចិត្ត ដោយសុភាសិតរបស់ព្រះអានន្ទមានអាយុនេះពេកណាស់ បពិត្រលោកដ៏ចម្រើន លុះយើងខ្ញុំជាអ្នកត្រេកអរពេញចិត្ត ដោយសុភាសិតរបស់ព្រះអានន្ទដ៏មានអាយុ យ៉ាងនេះហើយ បពិត្រលោកដ៏ចម្រើន ប្រសិនបើហត្ថិរតន៍ គួរដល់ព្រះអានន្ទមានអាយុ យើងនឹងប្រគេនហត្ថិរតន៍ ដល់ព្រះ

អានន្ទមានអាយុ បពិត្រលោកដ៏ចម្រើន ប្រសិនបើអស្សរតន៍ គួរដល់ព្រះអានន្ទមានអាយុ យើងនឹងប្រគេនអស្សរតន៍ដល់ព្រះអានន្ទមានអាយុ បពិត្រលោកដ៏ចម្រើន ប្រសិនបើស្រុកសួយ គួរដល់ព្រះអានន្ទមានអាយុ យើងនឹងប្រគេនស្រុកសួយដល់ព្រះអានន្ទមានអាយុ បពិត្រលោកដ៏ចម្រើន ប៉ុន្តែយើងខ្ញុំបានដឹងហេតុនេះថា វត្ថុមានហត្ថិរតន៍ជាដើមនេះ មិនគួរដល់ព្រះអានន្ទមានអាយុទេ បពិត្រលោកដ៏ចម្រើន មានតែសំពត់ ពាហិតិការបស់ខ្ញុំនេះ មានបណ្តោយ ១៦ ហត្ថ ទទឹង ៨ ហត្ថ ដែលព្រះបាទមគធអជាតសត្តុវេទេហីបុត្ត ដាក់ក្នុងស្រោមចត្រហើយផ្ញើមកឲ្យខ្ញុំ បពិត្រលោកដ៏ចម្រើន សូមព្រះអានន្ទមានអាយុ ទទួលយកនូវសំពត់នោះ ដើម្បីសេចក្តីអនុគ្រោះដល់ខ្ញុំ ។ ព្រះអានន្ទតបថា ថ្វាយព្រះពរមហារាជ ត្រៃចីវររបស់អាត្មាភាពគ្រប់គ្រាន់ហើយ ។

[ ៣១៨ ] ព្រះរាជាត្រាស់ថា បពិត្រលោកដ៏ចម្រើន ស្ទឹងអចិរវតីនេះ ព្រះអានន្ទមានអាយុក្តី យើងខ្ញុំក្តី បានឃើញស្រាប់ហើយ មហាមេឃដែលបង្អុរភ្លៀងចុះមកខាងលើភ្នំ កាលបើយ៉ាងនេះ ស្ទឹងអចិរវតីនេះ ក៏នឹងហូរហៀរទឹកទៅកាន់មាត់ច្រាំងទាំង ២ ខាង យ៉ាងណាមិញ បពិត្រលោកដ៏ចម្រើន ព្រះអានន្ទមានអាយុ នឹងធ្វើនូវត្រៃចីវររបស់ខ្លួន ដោយសំពត់ពាហិតិកានេះ ចំណែកត្រៃចីវរណា ដែលជាចីវរចាស់របស់ព្រះអានន្ទមានអាយុ ព្រះអានន្ទនឹងចែករំលែកត្រៃចីវរចាស់នោះ ឲ្យដល់ពួកសព្រហ្មចារី ក៏យ៉ាងនោះដែរ កាលបើមានការណ៍យ៉ាងនេះ ទក្ខិណាទានរបស់យើងខ្ញុំនេះ ទំនងជានឹងហូរហៀរទៅបាន បពិត្រលោកម្ចាស់ដ៏ចម្រើន សូមព្រះអានន្ទមានអាយុ ទទួល

យកនូវសំពត់ពាហិតិកាចុះ ។ ព្រះអានន្ទមានអាយុ ក៏ទទួលយកសំពត់ពាហិតិកា ។ លំដាប់នោះ ព្រះបាទបសេនទិកោសល បានត្រាស់ពាក្យនេះទៅរកព្រះអានន្ទមានអាយុថា បពិត្រព្រះអានន្ទដ៏ចម្រើន យើងខ្ញុំត្រឡប់ទៅឥឡូវនេះហើយ ព្រោះយើងខ្ញុំមានកិច្ចច្រើន មានការរវល់ច្រើន ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ សូមមហាបពិត្រ សម្គាល់កាលដ៏គួរក្នុងកាលឥឡូវនេះចុះ ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រេកអរនឹងភាសិតរបស់ព្រះអានន្ទមានអាយុ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះអានន្ទមានអាយុដោយគោរព ធ្វើប្រទក្សិណរួចចៀសចេញទៅ ។

[ ៣១៩ ] គ្រាកាលដែលព្រះបាទបសេនទិកោសល ទ្រង់ចៀសចេញទៅមិនយូរប៉ុន្មាន ទើបព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលកថាសល្លាបៈដែលលោកចរចា ជាមួយនឹងព្រះបាទបសេនទិកោសលទាំងប៉ុន្មាន ដល់ព្រះមានព្រះភាគទាំងអស់ រួចថ្វាយសំពត់ពាហិតិកានោះ ទៅព្រះមានព្រះភាគ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុ ទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទបសេនទិកោសល ឈ្មោះថាមាន លាភហើយ ម្នាលភិក្ខុទាំងឡាយ អត្តភាពជាមនុស្ស ព្រះបាទបសេនទិកោសល ឈ្មោះថាបានដោយប្រពៃហើយ ព្រោះហេតុដែលព្រះបាទបសេនទិកោសល ទ្រង់បានជួបអានន្ទ ទ្រង់បានចូលទៅជិតអានន្ទ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់

ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយមានចិត្តត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចប់ ពាហិតិយសូត្រទី ៨

# អដ្ឋកថា

## ពាហិតិយសូត្រ

[ ៣១០ ] ពាហិតិយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ៣១១ ] ក្នុងព្រះសូត្រនោះ បទថា **ឯកបុណ្ឌរីក នាគំ** បានដល់ ដំរីដែលមានឈ្មោះយ៉ាងនេះ បានឮថា លើថ្ពាល់នៃដំរីរបស់ស្ដេចដំរីនោះ មានពណ៌ស ប្រមាណប៉ុនផ្លែត្នោត ព្រោះដូច្នោះ ទើបតាំងឈ្មោះស្ដេចដំរីនោះថា ឯកបុណ្ឌរីក ។ បទថា **សិរិវឌ្ឍំ មហាមត្តំ** បានដល់មហាមាត្យដែលមានឈ្មោះយ៉ាងនោះ ដែលឡើងជិះដំរីមួយទៀតដោយឡែកទៅផង ដើម្បីសន្ទនាតាមផាសុក ។ បទថា **នោ** ក្នុងបទថា **អាយស្មា នោ** នេះ ជានិបាតប្រើក្នុងការសួរ ។ មហាមាត្យកំណត់អាការដែលព្រះថេរៈទ្រទ្រង់សង្ឃាដិនិងបាត្របាន ទើបក្រាបទូលថា បពិត្រមហារាជ ។

[ ៣១៣ ] បទថា **ឱទារម្ភោ** សេចក្ដីថា ការតិះដៀល គឺការលើកទោស ព្រះរាជាត្រាស់សួរថា ខ្ញុំនឹងសួរដូចម្ដេច ។ ព្រះរាជាត្រាស់សួរថា ព្រះសូត្រនេះដែលកើតឡើងក្នុងរឿងដែលល្អ ខ្ញុំនឹងសួររឿងនោះ ។

[ ៣១៤ ] បទថា **យំ ហិ មយំ ភន្តេ** សេចក្ដីថា បពិត្រលោកដ៏ចម្រើន យើងទាំងឡាយមិនអាចកាន់យកបទថា ដែលសមណព្រាហ្មណ៍អ្នកដឹងច្បាស់នេះឲ្យបរិបូណ៌ដោយបញ្ហាបាន ហេតុនោះ ព្រះអានន្ទដែលពោលយ៉ាងនោះ ឲ្យបរិបូណ៌ហើយ ។ បទថា **អក្កុសលោ** បានដល់ ដែលកើតអំពីការមិនឈ្លាស ។ បទថា **សាវជ្ជោ** សេចក្ដីថា ប្រព្រឹត្តទៅជាមួយ នឹង

ទោស ។ បទថា **សព្យាបជ្ឈា** សេចក្តីថា ប្រព្រឹត្តទៅដោយទុក្ខ ។ ក្នុងបទថា **ទុក្ខវិបាកោ** នេះ លោកពោលដល់វិបាកដែលហូរចេញ ។

[ ៣១៥ ] បទថា **តស្ស** សេចក្តីថា តែកាយសមាចារដែលប្រព្រឹត្តទៅហើយ ដើម្បីប្រយោជន៍ដល់ការបៀតបៀនខ្លួនឯងជាដើម ដូចដែលពោលហើយនោះ ។

[ ៣១៦ ] ក្នុងពាក្យថា បពិត្រមហារាជ ព្រះតថាគត ទ្រង់លះបង់នូវអកុសលធម៌ទាំងអស់ ហើយទ្រង់ប្រកបដោយកុសលធម៌តែម្យ៉ាង នេះគឺព្រះថេរៈ សរសើរការលះអកុសលធម៌អស់គ្រប់យ៉ាងនោះឯង កាលលោកពោលថា សូមថ្វាយព្រះពរ រមែងសរសើរ ពាក្យសួររមែងមានដោយប្រការណាឈ្មោះថា ពោលអត្ថដោយប្រការនោះ ម្យ៉ាងទៀត ព្យាករទាំងនេះ មិនគប្បីជាការៈ ព្រោះមិនទាន់លះអកុសលបាន គប្បីសរសើរការលះ ម្យ៉ាងទៀតដើម្បីសម្តែងថា ព្រះមានព្រះភាគទ្រង់ធ្វើយ៉ាងណា ក៏មានប្រក្រតីពោលយ៉ាងនោះ ព្រោះទ្រង់លះអកុសលបានហើយ ទើបព្យាករយ៉ាងនោះ ។ សូម្បីក្នុងចំណែកសក៏មានន័យដូចគ្នា ។

[ ៣១៧ ] បទថា **ពាហិតិកា** នេះ ជាឈ្មោះរបស់ សំពត់ដែលកើតក្នុងពាហិតិរដ្ឋ ។ បទថា **សោឡសសមា អាយាមេន** សេចក្តីថា ដោយបណ្តោយមានប្រមាណ ១៦ ហត្ថគត់ ។ បទថា **អដ្ឋសមា វិត្ថារេន** ដោយអត្ថថា ដោយទទឹង ៨ ហត្ថគត់ ។ បទថា **ភគវតោ ទាសិ** សេចក្តីថា បានថ្វាយដល់ព្រះមានព្រះភាគ ។ កាលថ្វាយហើយ បានចងធ្វើជាពិតានក្នុង

*ព្រះគន្ធកុដិ ។ តាំងអំពីនោះមក ព្រះគន្ធកុដិ ក៏ស្អាតដោយក្រៃលែងហួសប្រមាណ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ។ម្យ៉ាងទៀត ទេសនានេះចប់ហើយដោយអំណាច នេយ្យបុគ្គល ដូច្នេះ ។ ០ៜៜ*

## អដ្ឋកថា ពាហិតិយសូត្រ ចប់

## សូត្រទី ៨ ចប់

# សុត្តន្តបិដក

## ធម្មចេតិយសូត្រទី ៩

[ ៣២០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមេទឡុបនិគមរបស់ពួកសក្យៈ ក្នុងសក្កជនបទ ។ សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់បានមកដល់នគរតូចដោយកិច្ចនីមួយ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់បង្គាប់អាមាត្យឈ្មោះ ទីឃការាយនៈថា ម្នាលការាយនៈសម្លាញ់ អ្នកឯងចូរទឹមយានល្អៗ យើងនឹងទៅកាន់ទីឧទ្យាន ដើម្បីមើលទីដែលល្អ ។ ទីឃការាយនាមាត្យទទួលព្រះរាជឱង្ការ របស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយប្រើបុរសឲ្យទឹមយានល្អ ៗ ស្រេចហើយត្រឡប់មកក្រាបបង្គំទូលព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព យានល្អៗ បានទឹមរួចស្រេចហើយ សូមព្រះអង្គសម្គាល់កាលដ៏សមគួរក្នុងកាលឥឡូវនេះ ។

[ ៣២១ ] លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ឡើងកាន់យានដ៏ល្អទ្រង់ព្រះរាជដំណើរទៅដោយយានល្អៗ ឆ្ពោះទៅកាន់សួនច្បារដោយអានុភាពជាស្តេចធំ ស្តេចទៅដោយយាន ដរាបដល់ទីដែលគួរបរយានទៅបាន ទើបទ្រង់ចុះអំពីយាន ស្តេចទៅដោយព្រះបាទចូលទៅកាន់សួនច្បារ ។ ព្រះបាទបសេនទិកោសល ទ្រង់យាងចង្ក្រមទៅមកក្នុងសួនច្បារបន្តិច ដើម្បីសម្រាកព្រះជង្ឃា បានទតឃើញម្លប់ឈើទាំងឡាយនាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិចៗ ឥតមានសំឡេងគឹកកង ប្រាសចាកខ្យល់បក់មកអំពីសរីរៈ

នៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ លុះឃើញហើយក៏មានបីតិកើតឡើង ប្រារព្ធចំពោះព្រះមានព្រះភាគថា ម្លប់ឈើទាំងនេះ នាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិចៗ ឥតមានសំឡេងគឹកកង ប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ ដូចជាទីដែលយើងធ្លាប់ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះដែរ ។ ទើបព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ទៅនឹងទីឃការាយនាមាត្យថា ម្នាលការាយនៈសម្លាញ់ ម្លប់ឈើទាំងឡាយនេះ នាំមកនូវសេចក្តីជ្រះថ្លា គួរជាទីជ្រះថ្លា មានសំឡេងតិចៗ ឥតមានសំឡេងគឹកកង ប្រាសចាកខ្យល់បក់មកអំពីសរីរៈនៃមនុស្ស គួរជាទីធ្វើការសម្ងាត់នៃមនុស្ស ជាទីគួរដល់វិវេកក្នុងវេលាយប់ ដូចជាទីដែលយើងធ្លាប់ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធដែរ ម្នាលការាយនៈសម្លាញ់ ចុះឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធនោះ ព្រះអង្គគង់ក្នុងទីណា ។ ទីឃការាយនាមាត្យក្រាបបង្គំទូលតបថា បពិត្រមហារាជ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះគង់នៅក្នុងមេទឡុបនិគម របស់ពួកសក្យៈ ។ ព្រះរាជាត្រាស់ថា ម្នាលការាយនៈសម្លាញ់ ចុះមេទឡុបនិគមរបស់ពួកសក្យៈ ទៅអំពីនគរតូចនេះទៅ តើចម្ងាយប៉ុន្មាន ។ ទីឃការាយនាមាត្យក្រាបបង្គំទូលតបថា បពិត្រមហារាជ មិនជាឆ្ងាយណាស់ណាទេ ប្រហែលជា ៣ យោជន៍ប៉ុណ្ណោះ ព្រះអង្គអាចស្តេចទៅដល់ មិនពេញមួយថ្ងៃទេ ។ ព្រះរាជាត្រាស់ថា ម្នាលការាយនៈសម្លាញ់

បើដូច្នោះ អ្នកឯងចូរទឹមយានល្អៗ យើងនឹងទៅដើម្បីគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ទីឃការាយនាមាត្យ ទទួលយកព្រះរាជឱង្ការរបស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស រួចប្រើគេឲ្យទឹមយានល្អៗ ស្រេចហើយ ក្រាបបង្គំទូលព្រះបាទសេបនទិកោសលថា បពិត្រព្រះសម្មតិទេព យានល្អៗ បានទឹមបម្រុងព្រះអង្គរួចស្រេចហើយ សូមព្រះអង្គសម្គាល់នូវកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។

[ ៣២២ ] គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់ឡើងកាន់យានដ៏ល្អហើយ ស្ដេចចេញអំពីនគរតូចទៅដោយយានល្អៗ បរសំដៅទៅត្រង់ មេទឡុបនិគមរបស់ពួកសក្យ ទៅមិនពេញមួយថ្ងៃប៉ុណ្ណោះឯង ក៏បានទៅដល់មេទឡុបនិគមរបស់ពួកសក្យ ហើយត្រោះទៅកាន់សួនច្បារ ទ្រង់យានទៅដោយយាន ដរាបដល់ទីដែលគួរបរយានទៅបាន ហើយទ្រង់ចុះអំពីយាន ស្ដេចទៅដោយព្រះបាទ ចូលទៅកាន់សួនច្បារ ។ សម័យនោះឯង ពួកភិក្ខុច្រើនរូប កំពុងចង្រ្កមក្នុងទីវាល ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ចូលសំដៅទៅរកភិក្ខុទាំងឡាយនោះ លុះចូលទៅដល់ហើយ មានព្រះរាជឱង្ការនេះទៅរកពួកភិក្ខុថា បពិត្រលោកទាំងឡាយដ៏ចម្រើន ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គគង់ក្នុងទីណា ព្រោះយើងទាំងឡាយ ចង់ជួបនឹងព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ ភិក្ខុទាំងនោះថ្វាយព្រះពរថា បពិត្រមហារាជ វិហារនុ៎ះបិទទ្វារជិតទៅហើយ ព្រោះហេតុនោះ សូមព្រះអង្គធ្វើព្រះស្ងួរសៀងតិចៗ ស្ដេចចូលទៅសន្សឹមៗ លុះចូលទៅ

ដល់របៀង ធ្វើព្រះឧកាសិត ( គ្រហែម ) រួចគោះសន្ទះទ្វារ ព្រះមានព្រះភាគ នឹងបើកទ្វារថ្វាយព្រះអង្គ ។ ទើបព្រះបាទបសេនទិកោសល ទ្រង់ហុចព្រះខាន់ និងមកុដឲ្យទៅទីឃការាយនាមាត្យ ក្នុងទីនោះឯង ។ លំដាប់នោះ ទីឃការាយនាមាត្យ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ មហារាជទ្រង់ស្តេចចូលទៅតែមួយព្រះអង្គឯងទេ ឥឡូវនេះ គួរអាត្មាអញនៅចាំក្នុងទីនេះចុះ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅត្រង់វិហារ ដែលមានទ្វារបិទនោះ ធ្វើព្រះសូរសៀងតិចៗ ស្តេចចូលទៅសន្សឹមៗ លុះចូលទៅដល់របៀងហើយ ក៏ទ្រង់ធ្វើព្រះឧកាសិត ហើយគោះសន្ទះទ្វារ ។ ព្រះមានព្រះភាគ ក៏ទ្រង់បើកទ្វារ ។ ទើបព្រះបាទបសេនទិកោសល ចូលទៅកាន់វិហារហើយ ក្រាបចុះទៀបព្រះបាទយុគលនៃព្រះមានព្រះភាគ ដោយសិរ្សផងទ្រង់ព្រះចុម្ពិត ( ជញ្ជក់ ) ព្រះបាទយុគលនៃព្រះមានព្រះភាគដោយព្រះឱស្ឋផង ប្របាច់ដោយព្រះហស្តទាំងឡាយផង ប្រកាសនាមផងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះ បសេនទិកោសល បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាស្តេចឈ្មោះ បសេនទិកោសល ។ ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ ចុះមហាបពិត្រ បានឃើញនូវអំណាចនៃប្រយោជន៍ដូចម្តេច បានជាទ្រង់ធ្វើសេចក្តីឱនលំទោនយ៉ាងក្រៃលែង មានសភាពយ៉ាងនេះក្នុងសរីរៈនេះ ហើយសម្តែងនូវការបូជាដោយសេចក្តីរាប់អាន ( ដល់ម៉្លេះ ) ។

[ ៣២៣ ] ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានយល់ធម៌ ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមាន

ព្រះភាគទ្រង់ត្រាស់ដឹងដោយប្រពៃ ព្រះធម៌គឺព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។ បពិត្រព្រះមានព្រះភាគដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញសមណព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ប្រព្រឹត្តព្រហ្មចរិយធម៌មានកំណត់ ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ។ លុះដល់មកសម័យខាងក្រោយ ក៏ស្រាប់តែពួកសមណព្រាហ្មណ៍នោះ លាងលាបខ្លួនឲ្យស្អាត កោរសក់ ពុកមាត់ពុកចង្កា ហើយឆ្អែតស្កប់ស្កល់មូលមិត្ត ផ្តេកផ្តិត ដោយកាមគុណទាំង ៥ ទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញភិក្ខុទាំងឡាយក្នុងសាសនានេះ បានប្រព្រឹត្តព្រហ្មចរិយធម៌ មានជីវិតជាទីបំផុត ឲ្យបរិបូណ៌ បរិសុទ្ធដរាបដល់អស់ជីវិត ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណារកមើលមិនឃើញមានបុគ្គលដទៃ ខាងក្រៅព្រះពុទ្ធសាសនានេះ ប្រព្រឹត្តព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះហើយដែលនាំឲ្យខ្ញុំព្រះអង្គបានយល់ធម៌ ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃ ព្រះធម៌គឺព្រះមានព្រះភាគត្រាស់សម្តែងហើយដោយប្រពៃ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។

[ ៣២៤ ] បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ច្រើនមានតែពួកព្រះរាជាទាស់ទែងគ្នានឹងពួកព្រះរាជាក៏មាន ពួកក្សត្រទាស់ទែងគ្នានឹងពួកក្សត្រក៏មាន ពួកព្រាហ្មណ៍ទាស់ទែងគ្នានឹងពួកព្រាហ្មណ៍ក៏មាន ពួកគហបតីទាស់ទែងគ្នានឹងពួកគហបតីក៏មាន មាតាទាស់ទែងនឹងបុត្រក៏មាន បុត្រទាស់ទែងនឹងមាតា

ក៏មាន បិតាទាស់ទែងនឹងបុត្រក៏មាន បុត្រទាស់ទែងនឹងបិតាក៏មាន បងប្អូនប្រុសទាស់ទែងនឹងបងប្អូនស្រីក៏មាន បងប្អូនស្រីទាស់ទែងនឹងបងប្អូនប្រុសក៏មាន សម្លាញ់ទាស់ទែងនឹងសម្លាញ់ក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញតែពួកភិក្ខុក្នុងសាសនានេះហើយ ដែលមានសេចក្តីព្រមព្រៀងស្រស់ស្រាយ មិនទាស់ទែងគ្នា ដូចជាទឹកដែលលាយដោយទឹកដោះស្រស់ សម្លឹងមៀងមើលគ្នានឹងគ្នាដោយចក្ខុជាទីស្រឡាញ់ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណារកមើលមិនឃើញមានបរិស័ទឯទៀត ខាងក្រៅព្រះពុទ្ធសាសនានេះ ឲ្យមានសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះហើយដែលនាំឲ្យខ្ញុំព្រះអង្គមានសេចក្តីយល់ធម៌ ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគ ព្រះអង្គត្រាស់ដឹងដោយប្រពៃ ព្រះធម៌គឺព្រះមានព្រះភាគ ត្រាស់សម្តែងហើយដោយប្រពៃ ព្រះសង្ឃជាសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃ ។

[ ៣២៥ ] បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ខ្ញុំព្រះអង្គដើរក្រឡឹងមើលអំពីសួនច្បារមួយទៅសួនច្បារមួយ អំពីឧទ្យានមួយទៅឧទ្យានមួយ ឃើញសមណព្រាហ្មណ៍ពួកមួយក្នុងទីនោះ ស្គាំងស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿងស្លេកស្លាំងមានខ្នងរវាមដោយសរសៃ មិនទំនងឲ្យពួកជនរមិលមើលជាប់ភ្នែកបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងនេះ ទំនងជាប្រព្រឹត្តព្រហ្មចរិយធម៌ ទាំងមិនត្រេកអរ ពុំនោះសោតលោកមានអាយុទាំងនោះ ធ្វើបាបកម្មណាមួយ ដ៏កំបាំង

បានជាលោកមានអាយុទាំងនេះ ស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿង ស្ទួកស្ទាំង មានខ្នួនរវាមដោយសរសៃ មិនទំនងឲ្យជាប់ភ្នែកដល់ជនអ្នកមើល ។ ខ្ញុំព្រះអង្គក៏ចូលទៅរក ពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ដូចម្តេចបានជាលោកមានអាយុទាំងឡាយ ស្គម សៅហ្មង អាប់សម្បុរ កើតរោគលឿងស្ទួកស្ទាំង មានខ្នួនរវាមដោយសរសៃ មិនទំនងឲ្យជាប់ភ្នែកដល់ជនអ្នកមើលដូច្នេះ ។ សមណព្រាហ្មណ៍ទាំងនោះនិយាយយ៉ាងនេះថា បពិត្រមហារាជ យើងទាំងឡាយមានរោគជាប់តាមពូជមក ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញពួកភិក្ខុក្នុងសាសនានេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ មានសេចក្តីខ្វល់ខ្វាយតិច មានរោមសម្ងំបហើយ ចិញ្ចឹមជីវិតដោយសារទានរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកមានអាយុទាំងឡាយនេះ ដឹងនូវគុណវិសេសដទៃក្រៃលែងជាងកាលមុន ក្នុងសាសនារបស់ព្រះមានបុណ្យនោះ ដោយពិតហើយ បានជាលោកមានអាយុទាំងនេះ មានចិត្តរីករាយក្រៃពេក មានចិត្តខ្ពស់បំផុត មានសភាពត្រេកអរក្រៃពេក មានឥន្ទ្រិយពេញលេញ មានសេចក្តីខ្វល់ខ្វាយតិច មានរោមសម្ងំបហើយ ចិញ្ចឹមជីវិតដោយទានរបស់អ្នកដទៃ មានចិត្តមានសភាពដូចជាម្រឹគ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គ បានយល់ធម៌ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគ ត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌ព្រះ

មានព្រះភាគ សំដែងហើយដោយប្រពៃមែន ព្រះសង្ឃជាសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃមែន ។

[ ៣២៦ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ខ្ញុំព្រះអង្គជារាជា ជាក្សត្របានមុទ្ធាភិសេកហើយ លួមសម្លាប់មនុស្សដែលគួរសម្លាប់ក៏បាន មនុស្សគួរបម្រើនក៏ឲ្យបម្រើនបាន មនុស្សគួរបណ្តេញក៏ឲ្យបណ្តេញបាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គនោះកំពុងអង្គុយក្នុងរោងសម្រាប់កាត់ក្តី ហើយមានពួកជនហ៊ាននិយាយស្ទាក់សម្តី ត្រង់ពាក់កណ្តាល ខ្ញុំព្រះអង្គនោះក៏បាននិយាយឃាត់ថា អ្នកដ៏ចម្រើនទាំងឡាយ កុំធ្វើសម្តីរបស់ខ្ញុំដែលកំពុងអង្គុយក្នុងរោងសម្រាប់កាត់ក្តី ឲ្យដាច់ពាក់កណ្តាលឡើយ អ្នកដ៏ចម្រើនទាំងឡាយបង្អង់ចាំខ្ញុំនិយាយឲ្យចប់សិន ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សក៏នៅតែនិយាយស្ទាក់សម្តី របស់ខ្ញុំព្រះអង្គត្រង់ពាក់កណ្តាលដដែល ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញតែពួកភិក្ខុក្នុងសាសនានេះ បើមានព្រះមានព្រះភាគ កំពុងសំដែងធម៌ដល់បរិសទ្យច្រើនរយក្នុងសម័យណា សម័យនោះពួកសាវករបស់ព្រះមានព្រះភាគ ក៏ឥតមានសំឡេងកណ្តាស់ ឬសំឡេងក្អកគ្រហែមឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុធ្លាប់មានពីមុនមក បើព្រះមានព្រះភាគ កំពុងសំដែងធម៌ដល់បរិសទ្យច្រើនរយ ហើយមានសាវករបស់ព្រះមានព្រះភាគណាមួយក្អកឡើងក្នុងទីនោះ ។ នឹងមានសព្រហ្មចារីបុគ្គលណាមួយ គោះនូវសាវកនោះដោយជង្គង់ថា លោកមានអាយុចូរធ្វើសំឡេងតិច លោកមានអាយុ កុំធ្វើសំឡេងខ្លាំងឡើយ ដ្បិតព្រះមានព្រះភាគជាគ្រូយើង

កំពុងសម្តែងធម៌ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អើអស្ចារ្យណាស់ហ្ន៎ ចំឡែកណាស់ហ្ន៎ បរិសទ្យដែលព្រះអង្គទូន្មានបានងាយយ៉ាងនេះ ដោយមិនបាច់អាងអាជ្ញា មិនបាច់អាងគ្រឿងសស្ត្រាឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាមើលមិនឃើញបរិសទ្យដទៃក្រៅពីព្រះពុទ្ធសាសនា ឲ្យទូន្មានបានដោយងាយយ៉ាងនេះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯង ( ដែលនាំឲ្យ ) ខ្ញុំព្រះអង្គបានយល់ធម៌ក្នុងសំណាក់ព្រះមានព្រះភាគថា ព្រះមានព្រះភាគ ត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌ព្រះមានព្រះភាគសម្តែងទុក ហើយដោយប្រពៃមែន ព្រះសង្ឃជាសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិ ដោយប្រពៃមែន ។

[ ៣២៧ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ខ្ញុំព្រះអង្គបានឃើញខត្តិយបណ្ឌិតពួកខ្លះក្នុងលោកនេះ ជាអ្នកមានប្រាជ្ញាល្អិត អាចញុំាងនូវបរប្បវាទបាន មានសភាពដូចជាអ្នកបាញ់ម្រឹគសាហាវ ។ ពួកខត្តិយបណ្ឌិតទាំងនោះហាក់ដូចជាទម្លាយនូវទិដ្ឋិដោយប្រាជ្ញាបាន ។ ខត្តិយបណ្ឌិត ទាំងនោះបានឮថា ព្រះសមណគោតម និមន្តចូលមកកាន់ស្រុកឬនិគមឯណោះ ។ ខត្តិយបណ្ឌិតទាំងនោះក៏តាក់តែងប្រស្នាហើយគិតគ្នាថា យើងនឹងចូលទៅសួរប្រស្នានេះនឹងព្រះសមណគោតម កាលយើងសួរទៅហើយ បើព្រះសមណគោតមដោះស្រាយមិនរួចយ៉ាងនេះទេ យើងនឹងលើកវាទៈ គឺពោលទោស របស់ព្រះសមណគោតមយ៉ាងនេះ មួយទៀត កាលយើងសួរយ៉ាងនេះហើយ បើព្រះសមណគោតម ដោះស្រាយមិនរួចយ៉ាងនេះទេ យើងនឹងលើកវាទរបស់

ព្រះសមណគោតមនោះយ៉ាងនេះថែមទៀត ។ ខត្តិយបណ្ឌិតទាំងនោះ បានឮថា ព្រះសមណគោតម និមន្តចូលមកកាន់ស្រុក ឬ និគមឯណោះ ។ ខត្តិយបណ្ឌិតទាំងនោះ ក៏ចូលមករកព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ពន្យល់ខត្តិយបណ្ឌិតទាំងនោះឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លុះព្រះមានព្រះភាគ បានពន្យល់ពួកខត្តិយបណ្ឌិតឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏មិនហ៊ាននាំគ្នាសួរប្រស្នានឹងព្រះមានព្រះភាគ មិនដឹងជានឹងលើកវាទពីណាកើត តាមពិតត្រឡប់សម្រេចជាសាវ័ក របស់ព្រះមានព្រះភាគវិញ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គយល់ធម៌ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ព្រះមានជោគព្រះអង្គត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌គឺព្រះមានជោគសម្តែងហើយ ដោយប្រពៃមែន ព្រះសង្ឃជាសាវ័ករបស់ព្រះមានជោគ ប្រតិបត្តិដោយប្រពៃមែន ។

[ ៣២៨ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ខ្ញុំព្រះអង្គបានឃើញព្រាហ្មណ៍បណ្ឌិតពួកខ្លះក្នុងលោកនេះ ។បេ។ គហបតិបណ្ឌិត ... សមណបណ្ឌិតមានប្រាជ្ញាល្អិត អាចញាំញីនូវបរប្បវាទបាន មានសភាពដូចជាអ្នកសម្លាប់ម្រឹគសាហាវ ។ សមណបណ្ឌិតទាំងនោះហាក់ដូចជាទម្លាយនូវទិដ្ឋិដោយប្រាជ្ញាបាន ។ បណ្ឌិតទាំងនោះបានឮថា ព្រះសមណគោតម និមន្តចូលមក កាន់ស្រុកឬនិគមឯណោះ ។ គេក៏តាក់តែងប្រស្នាដោយគិតថា យើងទាំងឡាយ នឹងចូលទៅសួរប្រស្នានេះនឹងព្រះសមណគោតម កាលយើង

សួរ យ៉ាងនេះទៅហើយ បើព្រះសមណគោតម ដោះស្រាយមិនរួចយ៉ាងនេះ ទេ យើងនឹងលើកវាទរបស់ព្រះសមណគោតមនោះ យ៉ាងនេះ មួយទៀត កាលយើងសួរយ៉ាងនេះទៅហើយ បើព្រះសមណគោតមដោះស្រាយមិនរួច យ៉ាងនេះទេ យើងទាំងឡាយ នឹងលើកវាទរបស់ព្រះសមណគោតមនោះ យ៉ាង នេះថែមទៀត ។ បណ្ឌិតទាំងនោះបានឮថា ព្រះសមណគោតម និមន្តចូល មកកាន់ស្រុក ឬនិគមឯណោះ ។ គេក៏នាំគ្នាចូលមករកព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកបណ្ឌិតទាំងនោះ ឲ្យយល់ច្បាស់ ឲ្យកាន់យក តាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ។ លុះព្រះមានជោគទ្រង់ពន្យល់ បណ្ឌិតទាំងនោះ ឲ្យយល់ច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីក រាយដោយធម្មីកថាហើយ ក៏មិនហ៊ាននាំគ្នាសួរប្រស្នាចំពោះព្រះមានព្រះភាគ ឡើយនឹងលើកវាទមកពីណាកើត តាមពិតទៅជាសូមឱកាសនឹងព្រះមាន-ព្រះភាគ ហើយចេញចាកផ្ទះ ចូលទៅកាន់ភាពមិនមានផ្ទះដោយបព្វជ្ជាវិញ ។ ព្រះមានព្រះភាគ ក៏បំបួសបណ្ឌិតទាំងនោះ ។ បណ្ឌិតទាំងនោះ លុះបួស ដូច្នោះហើយក៏ចៀសចេញទៅ ឥតមានសេចក្តីប្រមាទ មានព្យាយាម មាន ចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្រដែលចេញចាកផ្ទះ ចូលកាន់ ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន ក៏បាន ធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌នោះ ដ៏ជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ក្នុង បច្ចុប្បន្ននេះដោយប្រាជ្ញារបស់ខ្លួន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថ ទាំង ៤ ។ បណ្ឌិតទាំងនោះក៏ពោលយ៉ាងនេះថា អើយើងទាំងឡាយ មិន

វិនាសទេ ព្រោះថាកាល ពីដើមយើងទាំងឡាយមិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ មិនមែនជាព្រាហ្មណ៍ ប្តេជ្ញាខ្លួនថាជាព្រាហ្មណ៍ មិនមែនជាព្រះអរហន្តប្តេជ្ញាខ្លួនថាជាព្រះអរហន្ត ឥឡូវនេះយើងទាំងឡាយ បានជាសមណពិតហើយ ឥឡូវនេះយើងទាំងឡាយបានជាព្រាហ្មណ៍ពិតហើយ ឥឡូវនេះយើងទាំងឡាយបានជាអរហន្តពិតហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងដែលនាំឲ្យខ្ញុំព្រះអង្គ យល់ធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគថា ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌ព្រះមានព្រះភាគសម្តែងហើយដោយប្រពៃមែន ព្រះសង្ឃជាសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិហើយដោយប្រពៃមែន ។

[ ៣២៩ ] បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ពួកជាងឈើ ( ពីរនាក់ ) ឥសិទន្តៈ ១ បុរាណៈ ១ ទាំងនេះមានបាយរបស់ខ្ញុំព្រះអង្គ ដូចជាបាយគេ មានយានរបស់ខ្ញុំព្រះអង្គក៏ដូចជាយានគេ ខ្ញុំព្រះអង្គបានឲ្យជីវិត បានតាំងយសដល់ជាងឈើទាំងនោះ តែពួកជាងឈើមិនធ្វើសេចក្តីឱនលំទោន មករកខ្ញុំព្រះអង្គ ដូចជាធ្វើចំពោះព្រះមានព្រះភាគឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានលើកពួកសេនាចេញទៅដើម្បីល្បងមើលនូវពួកជាងឈើ ឈ្មោះឥសិទន្តៈ និងបុរាណៈទាំងនេះ ហើយឈប់សម្រាកក្នុងកន្លែងចង្អៀតមួយ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកជាងឈើឈ្មោះ ឥសិទន្តៈ និងបុរាណៈទាំងនេះ ញុំាងកាលឲ្យកន្លងទៅដោយធម្មីកថា អស់រាត្រីជាច្រើន បើឮដំណឹងថា ព្រះមានព្រះភាគ គង់នៅក្នុងទីណា ក៏បែរក្បាល ទៅត្រង់ទីនោះ

ហើយដេកសណ្ដូកជើងមកលើខ្ញុំព្រះអង្គវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចម្លែកពេកណាស់ ជាងឈើឈ្មោះឥសិទត្ត: និងបូរាណៈនេះ មានបាយរបស់អញក៏ដូចជាបាយគេ មានយានរបស់អញ ក៏ដូចជាយានគេ អញបានឲ្យជីវិត បានតាំងយសដល់ជាងឈើទាំងនោះ តែជាងឈើទាំងនោះ មិនធ្វើសេចក្ដីឱនលំទោនមករកអញ ដូចជាធ្វើចំពោះព្រះមានព្រះភាគសោះ ។ លោកមានអាយុទាំងនេះ ដឹងនូវគុណវិសេសដ៏ក្រៃលែង ទាំងខាងដើម ខាងចុង ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងដែលនាំខ្ញុំព្រះអង្គ បានយល់ធម៌ក្នុងសំណាក់នៃព្រះមានព្រះភាគថា ព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃមែន ព្រះធម៌ គឺព្រះមានព្រះភាគសម្ដែងហើយដោយប្រពៃមែន ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃមែន ។

[ ៣៣០ ] បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត ព្រះមានព្រះភាគក៏ជាក្សត្រ ខ្ញុំព្រះអង្គក៏ជាក្សត្រ ព្រះមានព្រះភាគក៏ជាអ្នកកោសល ខ្ញុំព្រះអង្គក៏ជាអ្នកកោសល ព្រះមានព្រះភាគមានព្រះជន្ម ៨០ ខ្ញុំព្រះអង្គក៏មានអាយុ ៨០ បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ដែលព្រះមានព្រះភាគជាក្សត្រ ខ្ញុំព្រះអង្គក៏ជាក្សត្រ ព្រះមានព្រះភាគក៏ជាអ្នកកោសល ខ្ញុំព្រះអង្គក៏ជាអ្នកកោសល ព្រះមានព្រះភាគ ក៏មានព្រះជន្ម ៨០ ខ្ញុំព្រះអង្គក៏មានអាយុ ៨០ ។ បពិត្រព្រះអង្គដ៏ចម្រើន តែត្រឡប់ជាខ្ញុំព្រះអង្គគួរដើម្បីធ្វើនូវសេចក្ដីឱនលំទោនក្រៃលែង

ក្នុងព្រះមានព្រះភាគ ដើម្បីសម្តែងនូវការបូជាដោយសេចក្តីរាប់អាន ចំពោះព្រះអង្គវិញ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានកិច្ចច្រើន មានការរវល់ច្រើន ចង់ត្រឡប់ទៅវិញចាប់ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សូមព្រះអង្គសម្គាល់នូវកាលដ៏គួរក្នុងកាលឥឡូវនេះចុះ ។ ទើបព្រះបាទបសេនទិកោសល ក្រោកអំពីអាសនៈ ហើយថ្វាយបង្គំលាព្រះមានព្រះភាគដោយគោរព ធ្វើប្រទក្សិណហើយ ស្តេចចេញទៅ ។

[ ៣៣១ ] កាលព្រះបាទបសេនទិកោសល ស្តេចចេញទៅមិនទាន់បានយូរប៉ុន្មាន ទើបព្រះមានព្រះភាគត្រាស់ទៅនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ព្រះបាទបសេនទិកោសលនេះ ទ្រង់សម្តែងនូវពាក្យដែលធ្វើការគោរព ក្នុងធម៌ទាំងឡាយ ហើយក្រោកអំពីអាសនៈស្តេចចេញទៅ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររៀននូវពាក្យដែលធ្វើនូវសេចក្តីគោរព ក្នុងធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ចូរទន្ទេញពាក្យដែលធ្វើការគោរពក្នុងធម៌ ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នា ចូរចងចាំទុកពាក្យដែលធ្វើការគោរពក្នុងធម៌ ម្នាលភិក្ខុទាំងឡាយ ព្រោះពាក្យដែលធ្វើការគោរពក្នុងធម៌ដ៏ប្រកបដោយប្រយោជន៍ ជាអាទិព្រហ្មចរិយកៈ ។ លុះព្រះមានព្រះភាគទ្រង់សម្តែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ធម្មចេតិយសូត្រទី ៩

# អដ្ឋកថា

## ធម្មចេតិយសូត្រ

[៣២០] ធម្មចេតិយសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

ក្នុងព្រះសូត្រនោះ បទថា **មេទឡុបំ** ជាឈ្មោះរបស់និគមនោះ ។ បាន ឮថា និគមនោះមានដុំថ្មពណ៌ដូចខ្លាញ់ខាប់ ដែលកើតឡើងដេរដាសក្នុងទីនោះៗ ព្រោះដូច្នោះ ទើបដល់នូវការរាប់ថា **មេទឡុប** ម្យ៉ាងទៀត សេនាសនៈ ក្នុង និគមនោះក៏មិនពិតប្រាកដ ព្រោះដូច្នោះ ទើបមិនបានពោលទុក ។ បទថា **នគរកំ** បានដល់ និគមមួយរបស់ស្តេចសក្យៈមានឈ្មោះយ៉ាងនោះ ។ បទថា **កេនចិទេវ ករណីយេន** គឺមិនមែនដោយករណីណាដទៃ តែព្រះបាទបសេន ទិកោសលនេះ ត្រាស់បញ្ជាថា ពួកអ្នកចូរចាប់ពន្ធុលសេនាបតី មួយអន្ទើ ដោយកូនទាំង ៣២ នាក់ ឲ្យបានក្នុងថ្ងៃមួយ ។ ក្នុងថ្ងៃនោះ នាងមល្លិកា ភរិយាពន្ធុលសេនាបតីនោះ ទូលនិមន្តព្រះមានព្រះភាគ មួយអន្ទើដោយភិក្ខុ ៥០០ រូប ។ លុះភិក្ខុមានព្រះពុទ្ធជាប្រធាននិមន្តដល់ផ្ទះ ប្រថាប់គង់ហើយ មេកងក៏នាំដំណឹងមកថា លោកសេនាបតីដល់នូវអសញ្ញកម្មហើយ មកឲ្យនាង មល្លិកា ។ នាងទទួលសំបុត្រសួរថា ជាដំណឹងល្អ ឬដំណឹងអាក្រក់ ក៏ប្រាប់ ថា ព្រះរាជាទ្រង់ឲ្យចាប់សេនាបតី មួយអន្ទើដោយបុត្រ ៣២ នាក់ ប្រហារ ជីវិតព្រមគ្នា ។ នាងពោលថា ពួកអ្នកកុំធ្វើឲ្យភ្ញាក់ផ្អើលដល់មហាជន ហើយយកលិខិតដាក់ក្នុងថ្នក់សំពត់ អង្គាសភិក្ខុសង្ឃ ។ ក្នុងពេលនោះ មេការ លើកថ្នាំងទឹកដោះមួយថ្នាំងធំមក ថ្នាំងសប្បិនោះប៉ះនឹងធរណីទ្វារបែក

ទើបឲ្យនាំថ្នាំងដទៃមកអង្គាសព្រះភិក្ខុសង្ឃ ។

ព្រះសាស្តា ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ទើបត្រាស់ថា នាងមិនគួរគិតព្រោះហេតុថ្នាំងសប្បិបែក ដើម្បីជាហេតុឲ្យតាំងកថាឡើង ។ ខណៈនោះ នាងមល្លិកានាំសំបុត្រចេញមកដាក់ត្រង់ចំពោះព្រះភក្ត្រព្រះមានព្រះភាគ រួចក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នេះជាដំណឹងការស្លាប់របស់សេនាបតី និងកូន ៣២ នាក់ ខ្ញុំម្ចាស់មិនបានគិតក្នុងរឿងនេះ ហេតុអ្វីនឹងគិតព្រោះត្រឹមតែ ថ្នាំងសប្បិបែក ។ ព្រះមានព្រះភាគ ទ្រង់ធ្វើធម្មីកថាឲ្យបដិសំយុត្តដោយ សាមញ្ញលក្ខណៈ មានអនិច្ចំជាដើមថា ម្នាលនាងមល្លិកាកុំគិតច្រើនថ្វីឡើយ ធម្មតាក្នុងសង្សារវដ្តដែលមានទីបំផុតខាងដើម ដែលបុគ្គលណាមួយដឹងមិនបានហើយ រមែងប្រព្រឹត្តទៅ ដូច្នេះ ហើយទ្រង់យាងត្រឡប់ នាងមល្លិកាហៅកូនប្រសា ៣២ នាក់ មកឲ្យឱវាទ ។ ព្រះរាជាបញ្ជាឲ្យនាងមល្លិកា ចូលគាល់ត្រាស់សួរថា ក្នុងរវាងសេនាបតី និងយើង ទោសដែលបែកគ្នាមានឬមិនមាន នាងទូលថា មិនមានទេ ព្រះអង្គ ។ ព្រះរាជាទ្រង់ជ្រាបថា សេនាបតីនោះមិនមានកំហុសតាមពាក្យរបស់នាង ទើបមានវិប្បដិសារី កើតទោមនស្សដ៏ខ្លាំងក្លា ។ ព្រះអង្គទ្រង់រំពឹងថា បាននាំសម្លាញ់ដែលប្រសើររបស់យើង ធ្វើវត្ថុដែលមិនមានទោសបែបនេះមកហើយ ឲ្យវិនាសហើយ តាំងអំពីនោះ ទៅក៏មិនបានទូវការសប្បាយព្រះហឫទ័យក្នុងប្រាសាទ ឬក្នុងពួកស្រីស្នំ ឬសេចក្តីសុខក្នុងរាជសម្បត្តិ ទ្រង់ផ្តើមត្រាច់ទៅក្នុងទីនោះៗ ។ កិច្ចនេះឯង មានហើយ ។ សំដៅដល់រឿងនេះ ទើបពោលថា **តេនចិ សមយេន** ដូច្នេះ ។

បទថា **ឱយំ ភាវាយនំ** សេចក្ដីថា ទីយភាវាយនៈដែលជាក្ដួយរបស់ពន្ធុលសេនាបតីគិតថា ព្រះរាជាសម្លាប់អ៊ំរបស់អញដែលមិនបានធ្វើខុសដោយមិនមានហេតុ ព្រះរាជាបានតាំងអញទុកក្នុងតំណែងសេនាបតីហើយ ។ ពាក្យនោះលោកពោលសំដៅដល់រឿងនេះ ។

[ ៣២១ ] បទថា **មហាច្ចរាជានុភាវេន** សេចក្ដីថា ដោយរាជានុភាពដ៏ធំ ដោយអត្ថថា ដោយពួកពលសន្ធឹកសន្ធាប់ ស្អាតដោយភេទដ៏វិចិត្រ ជាន់ធរណីឲ្យវិនាស ប្រៀបដូចញាំងសាគរឲ្យជោរជន់ ដូច្នោះ ។ បទថា **ចាសាទិកានិ** សេចក្ដីថា ដែលឲ្យកើតការជ្រះថ្លា ព្រមទាំងគួរទស្សនានោះឯង ។ បទថា **ចាសាទនីយានិ** ជាវេវចនៈនៃពាក្យនោះ ។ ម្យ៉ាងទៀត បទថា **ចាសាទិកានិ** សេចក្ដីថា គួរមើល ។ បទថា **ចាសាទនីយានិ** បានដល់ កើតនូវការជ្រះថ្លា ។ បទថា **អប្បសទ្ទានិ** គឺមិនមានសំឡេង ។ បទថា **អប្បនិគ្ឃោសានិ** សេចក្ដីថា វៀរចាកសំឡេងអឺងកង ព្រោះអត្ថថា មិនប្រាកដ ។ បទថា **វិជនវាតានិ** សេចក្ដីថា ប្រាសចាកក្លិនរបស់មនុស្ស ។ បទថា **មនុស្ស-រាហាសេយ្យកានិ** សេចក្ដីថា រមែងសមគួរដល់ការងារដែលគប្បីធ្វើក្នុងទីកំបាំងរបស់មនុស្ស ដោយអត្ថថា សមគួរដល់បុគ្គលដែលប្រឹក្សាយ៉ាងកំបាំង ។ បទថា **បដិសល្លានសារុប្បានិ** សេចក្ដីថា សមគួរដល់ភាពជាបុគ្គលម្នាក់ឯងនៅពួនសម្ងំ ។ បទថា **យត្ថ សុទំ មយំ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់មិនធ្លាប់ទៅក្នុងទីនោះ ក្នុងពាក្យនេះ មានអត្ថដូច្នេះ ព្រះមានព្រះភាគ គួរយាងចូលទៅក្នុងទីដូច្នោះ ព្រោះជាទីដែលពួកយើងទាំងឡាយ មានសេចក្ដីសុខ ។

បទថា **អត្ថិ មហារាជា** សេចក្ដីថា សេនាបតីអ្នកឈ្លាស រមែងជ្រាបថា ព្រះរាជាទ្រង់រាប់អានព្រះមានព្រះភាគ ។ សេនាបតីនោះ បញ្ជូនចារបុរសទៅ រហូតដឹងទីប្រថាប់របស់ព្រះមានព្រះភាគ ដោយគិតថា បើព្រះរាជាសួរអញថា ព្រះមានព្រះភាគប្រថាប់នៅទីណា ក៏គួរក្រាបទូលបានដោយមិនយឺតយូរ ព្រោះដូច្នោះ ទើបពោលយ៉ាងនោះ ។

[៣២២] បទថា **អារាមំ ចាវិសិ** សេចក្ដីថា ទ្រង់តាំងព្រះពន្លាទុកក្រៅនិគម ហើយយាងចូលទៅជាមួយការាយនសេនាបតី ។ លោកពោលថា **វិហារោ** សំដៅយកព្រះគន្ធកុដិ ។ បទថា **អាឡិន្ទំ** ប្រែថា មុខ ។ បទថា **ឧក្កាសិត្វា** គឺធ្វើសំឡេងគ្រហែម ។ បទថា **អគ្គឡំ** គឺសន្ទះទ្វារ ។ បទថា **អាកោដេហិ** លោកពោលអធិប្បាយថា ទ្រង់គោះក្បែរសោទ្វាររឿយៗ ដោយចុងក្រចក ។ បានឮថា ពួកអមនុស្សរមែងគោះខ្ពស់ពេក ទីឃជាតិ មានពស់ជាដើម គោះទាបពេក ទើបមិនគោះយ៉ាងនោះ គឺគោះក្បែរគន្លឹះត្រង់កណ្ដាល នេះជាមារយាទក្នុងការគោះទ្វារ បុរាណាចារ្យពោលសម្ដែង ដោយប្រការដូច្នេះ ។ បទថា **តត្ថេវ** គឺក្នុងទីដែលភិក្ខុទាំងឡាយពោលហើយនោះឯង ។ ពាក្យថា **ខគ្គញ្ច ឧណ្ហីសញ្ច** នោះ ត្រឹមតែជាទេសនា ។ ម្យ៉ាងទៀត ព្រះរាជាទ្រង់ប្រគល់រាជកកុធភណ្ឌទាំង ៥ ដែលមកហើយ គឺផ្លិតវាលវីជនី ១ ឧណ្ហិស ១ ព្រះខ័ន ១ ឆត្រ ១ ទ្រនាប់ព្រះបាទ ១ ព្រះរាជាទ្រង់ចុះអំពីយានដែលចតទុក ។

សួរថា ព្រះរាជាទ្រង់ប្រគល់បញ្ចរាជកកុធភណ្ឌ ព្រោះហេតុអ្វី ឆ្លើយថា

ព្រោះមិនគួរយាងចូលទៅសម្នាក់ព្រះសម្មាសម្ពុទ្ធ ដែលជាទីគោរពក្រៃលែង ដោយភេទនៃឥស្សរិយយស ទ្រង់គិតថា នឹងចូលគាល់ត្រឹមតែព្រះអង្គជាអ្នកបានសន្ទនាតាមពេញព្រះហឫទ័យរបស់ព្រះអង្គ ។ ក្នុងបណ្តារាជកកុធ-កណ្ឋទាំង ៥ ព្រះអង្គឲ្យត្រឡប់ហើយ ក៏មិនបានពោលថា អ្នកចូរត្រឡប់ ។ នឹងត្រឡប់ឯងទាំងអស់នោះឯង ។ ព្រះរាជាទ្រង់ប្រគល់ទៅ ដោយហេតុ ២ ប្រការ ដូចពោលមកនេះ ។ បទថា **រហាយតិ** សេចក្តីថា រមែងធ្វើទីកំបាំង គឺលាក់បាំង ។ បានឮថា សេនាបតីនោះ មានបំណងដូច្នេះថា ព្រះរាជានេះក្នុងគ្រាមុន ក៏ប្រឹក្សាចតុកណ្ណមន្តជាមួយព្រះសមណគោតម ហើយឲ្យចាប់អំរបស់អញ និងកូន ៣២ នាក់ សូម្បីគ្រានេះក៏គង់ប្រឹក្សាចតុកណ្ណមន្ត ប្រើឲ្យចាប់អញទៀតទេដឹងហ្ន៎ សេនាបតីនោះមានការគិតដូច្នេះ ព្រោះអំណាចនៃសេចក្តីក្រោធ ។

បទថា **វិវរិ ភគវា ទ្វារំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនបានក្រោកឡើងបើកទ្វារ តែទ្រង់លាព្រះហស្ត ត្រាស់ថា ចូរបើកចុះ បន្ទាប់អំពីនោះទ្វារក៏បើកឯងនោះឯង ហាក់ដូចជាពោលថា បពិត្រព្រះមានព្រះភាគ ព្រះអង្គកាលឲ្យទានក្នុងនៃកប្បមិនមែនតិច មិនធ្លាប់បានធ្វើកម្ម គឺការបិទទ្វារដោយដៃរបស់ព្រះអង្គ ឯទ្វារនោះ ព្រោះបើកចេញដោយព្រះហឫទ័យរបស់ព្រះមានព្រះភាគ ព្រោះដូច្នោះ ទើបគួរពោលបានថា ព្រះមានព្រះភាគបើកទ្វារហើយ ។ បទថា **វិហារំ បវិសិត្វា** សេចក្តីថា ចូលទៅកាន់ព្រះគន្ធកុដិហើយ ។ កាលព្រះរាជាចូលទៅហើយ ការាយនសេនាបតីក៏កាន់យកបញ្ចរាជកកុធកណ្ឋ

ត្រឡប់ចូលជំរំ ហៅវិឌូឌភៈមកថា មិត្រជាទីស្រឡាញ់ ចូរលើកឆត្រឡើង ។ វិឌូឌភៈសួរថា ព្រះជនករបស់ខ្ញុំទៅហើយឬ ។ ទីឃការាយនៈឆ្លើយថា កុំចាំបាច់សួរដល់ព្រះជនកឡើយ បើព្រះអង្គម្ចាស់មិនលើក ខ្ញុំនឹងកាន់ឆត្រនោះលើកឡើងឯង ។ ទើបវិឌូឌភៈពោលថា ខ្ញុំនឹងលើកឯងសម្លាញ់ ។ ការាយនសេនាបតីទុកសេះមួយ ដាវមួយ ស្រីស្នំម្នាក់ប៉ុណ្ណោះឲ្យព្រះរាជា ប្រាប់ថា បើព្រះរាជាចង់មានជីវិត កុំតាមមកឡើយ ហើយលើកឆត្រឲ្យវិឌូឌភៈ ហើយនាំវិឌូឌភៈនោះទៅកាន់នគរសាវត្ថី ។

[៣២៣] បទថា **ធម្មន្វយោ** សេចក្តីថា ដឹងតាមអនុមាន គឺយល់ក្នុងធម៌ ពោល គឺបច្ចក្ខញាណ ។

ឥឡូវនេះ ពាក្យថា **សម្មាសម្ពុទ្ធោ ភគវា** ដូច្នេះជាដើម រមែងមានដល់ព្រះរាជានោះ ដោយការដឹងតាមធម៌ឯណា ដើម្បីសម្តែងការដឹងតាមធម៌នោះ ទើបពោលថា **ឥធ បនាហំ ភន្តេ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អាបាណកោដិកំ** សេចក្តីថា ជីវិត ឈ្មោះថា បាណ ធ្វើខេត្តដែននៃជីវិតដែលមានខ្យល់បាណជាទីបំផុតនោះទុកខាងក្នុង លោកអធិប្បាយថា ក្នុងសម័យជិតស្លាប់ ក៏គង់ត្រាច់ទៅនោះឯង ទើបឈានកន្លងជីវិតនោះទៅមិនបាន ។ បាឋៈថា **អាបណកោដិកំ** ដូច្នេះក៏មាន ។ ដោយអត្ថថា មានជីវិតជាទីបំផុតជុំវិញ ។ អធិប្បាយថា បុគ្គលខ្លះឈានកន្លង មិនធ្វើជីវិតដែលមានបាណជាទីបំផុតនៃជីវិតត្រាច់ទៅ ព្រោះហេតុនៃជីវិតឯណា ភិក្ខុទាំងឡាយមិនដូច្នោះឡើយ ។ ពាក្យថា **អយម្បិ ខោ មេ ភន្តេ** ព្រះអដ្ឋកថាចារ្យរមែង

សម្ដែងថា សេចក្ដីនេះរមែងយ៉ាងនេះ ព្រោះព្រះសម្ពុទ្ធទ្រង់ត្រាស់ដឹងល្អហើយ ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន ការជ្រះថ្លាក្នុងធម៌ ក្នុងព្រះមានព្រះភាគ របស់ខ្ញុំព្រះអង្គនេះ រមែងមានយ៉ាងនេះ ។ ក្នុងបទគ្រប់បទក៏មានន័យដូច្នេះឯង ។

[៣២៥] បទថា **ន វិយ មញ្ញេ ចក្ខុំ ពន្ធន្តេ** សេចក្ដីថា ហាក់បីដូចមិនឲ្យពួកជនរមិលមើលជាប់ភ្នែកបាន ។ ព្រោះសម្លឹងមើលឃើញដោយ មិនគួរជ្រះថ្លា ហើយមិនធ្វើកិច្ចក្នុងការសម្លឹងមើលទៀត ដូច្នោះ ទើបបុគ្គល ឈ្មោះថា មិនជាប់ភ្នែក ។ ដូចការជ្រះថ្លាហើយ ញ៉ាំងកិច្ចក្នុងការមើលរឿយៗ ដូច្នោះ ទើបបុគ្គលនោះឈ្មោះថា ជាប់ភ្នែក ។ ឯលោកទាំងនេះ ជាអ្នកមិនគួរជ្រះថ្លា ដូច្នោះ ទើបព្រះរាជាត្រាស់យ៉ាងនោះ ។ បទថា **ពន្ធុករោគោ នោ** បានដល់ រោគនៃត្រកូល គឺរោគតពូជ ។ អាចារ្យ ទាំងឡាយពោលថា មានរោគបែបនេះ កើតក្នុងត្រកូលរបស់យើងទាំងឡាយ ។ បទថា **ឱឡារំ** គឺមានសក្តិធំ ។ បទថា **បុព្វេនាបរំ** បានដល់ ដទៃ គឺបែក ផ្សេងអំពីមុន គឺធ្វើកសិណបរិកម្ម រហូតកើតសមាបត្តិ ឈ្មោះថា ដឹងទូលំទូលាយ គឺវិសេសជាងមុនក្នុងពាក្យនោះ ។ ធ្វើសមាបត្តិឲ្យជាបទដ្ឋាន ចម្រើនវិបស្សនា កាន់យកអរហត្ត ឈ្មោះថា ដឹងទូលំទូលាយ គឺវិសេសជាង អំពីមុន ។

[៣២៦] បទថា **ឃាតេតាយំ វា ឃាតេតុំ** សេចក្ដីថា ដើម្បីឲ្យសម្លាប់ បុគ្គលដែលគួរសម្លាប់ ។ បទថា **ជាបេតាយំ វា ជាបេតុំ** សេចក្ដីថា រឹបជាន់បុគ្គលដែលគួររឹបជាន់ដោយទ្រព្យ គឺធ្វើឲ្យវិនាសអស់ មិន

មានទ្រព្យ ។ បទថា **បព្ពាជេតាយំ វា បព្ពាជេតុំ** គឺឲ្យនិរទេសបុគ្គលដែលគួរនិរទេសចាក រដ្ឋ ។

[ ៣២៩ ] បទថា **ឥសិទត្តបុរាណា** គឺឥសិទត្តៈ និងបុរាណៈ ។ ក្នុងបុគ្គលទាំង ២ នោះ ម្នាក់ជាព្រហ្មចារី ម្នាក់ជាសទារសន្តោស គឺត្រេកអរតែក្នុងកិរិយារបស់ខ្លួន ។ បទថា **មមភត្តា** សេចក្តីថា ឈ្មោះថា **មមភត្តា** ព្រោះអត្ថថា ភត្តដែលជារបស់នៃខ្លួនរបស់ជនទាំងនោះមាន ។ បទថា **មមយានា** សេចក្តីថា ឈ្មោះថា យានរបស់ខ្ញុំព្រះអង្គ ព្រោះអត្ថថា យានដែលជារបស់ខ្ញុំព្រះអង្គមាន ។ បទថា **ជីវិតំ ទាតា** បានដល់ ជាអ្នកឲ្យការប្រព្រឹត្តិទៅនៃជីវិត ។ បទថា **វីមំសមានោ** គឺកាលសាកល្បង ។

បានឮថា ក្នុងកាលនោះ ព្រះរាជាទ្រង់មិនបានផ្ទំលក់ឡើយ ទ្រង់ផ្ទំធ្វើហាក់ដូចជាលក់ ។ ពេលនោះ បានត្រាស់សួរជាងឈើទាំងនោះថា ព្រះមានព្រះភាគប្រថាប់ក្នុងទិសណា កាលទ្រង់បានជ្រាបថា ក្នុងចំណែកនៃទិសនោះ ទើបប្រឹក្សាគ្នាថា ព្រះរាជាទ្រង់បែរព្រះសីសៈទៅកាន់ទិសាភាគ ដែលព្រះសម្មាសម្ពុទ្ធប្រថាប់ បែរព្រះបាទមកខាងនេះ បើព្រះសាស្តាបែរព្រះសីសៈទៅកាន់ទិសាភាគដែលព្រះរាជាប្រថាប់បែរព្រះបាទមក យើងនឹងធ្វើយ៉ាងណាល្អ បន្ទាប់អំពីនោះ ទើបជាងឈើទាំងនោះគិតគ្នាថា ព្រះរាជាទ្រង់ទាស់ព្រះហឫទ័យ ទ្រង់ឲ្យវត្ថុណាដល់ពួកយើង ក៏ទ្រង់ឈប់ឲ្យ ជាងឈើទាំងឡាយពោលថា ពួកយើងមិនអាចបែរជើងទៅកាន់បទេសព្រះសាស្តាបាន ទើបបែរជើងទៅរកព្រះរាជា ហើយដេក ។ ព្រះរាជានេះទ្រង់សំដៅដល់សេចក្តីនោះ

ទើបត្រាស់ យ៉ាងនេះ ។

[៣៣០] បទថា **បក្កាមិ** សេចក្តីថា ព្រះរាជាយាងចេញអំពីព្រះគន្ធកុដិ ហើយ យាងដល់ទីដែលការាយនៈនៅ មិនឃើញការាយនៈនោះក្នុងទីនោះ ទើបយាងទៅកាន់ព្រះពន្លា ។ ក្នុងទីនោះ ក៏មិនឃើញបុគ្គលណាមួយ ទើបត្រាស់សួរស្រីនោះ ។ ស្រីនោះក្រាបទូលរឿងរ៉ាវទាំងអស់ឲ្យទ្រង់ជ្រាប ព្រះរាជាទ្រង់ព្រះតម្រិះថា ឥឡូវនេះ អញមិនគួរទៅក្នុងព្រះនគរនោះតែម្នាក់ឯង អញនឹងទៅកាន់នគររាជគ្រឹះ ត្រឡប់មកជាមួយក្មួយអញ ហើយដណ្តើមយករាជសម្បត្តិរបស់អញ ដូច្នេះ ។ កាលព្រះរាជាយាងទៅកាន់នគររាជគ្រឹះ ទ្រង់បានសោយព្រះក្រយាហារដែលមានរសថោកថយ ( កណាជកកត្ត ) ទ្រង់សោយទឹកដែលល្អក់ក្នុងចន្លោះផ្លូវ ។ អាហាររបស់ព្រះអង្គដែលមានប្រក្រតីជាសុខុមាលជាតិ មិនរលួយទៅដោយងាយឡើយ ។ ព្រះអង្គយាងដល់នគរក៏ជាវេលាវិកាល សូម្បីទ្វារព្រះនគរក៏បិទហើយ ។ ទ្រង់ព្រះតម្រិះថា ថ្ងៃនេះដេកត្រង់សាលានេះ ព្រឹកឡើងសឹមចូលទៅរកក្មួយរបស់អញ ដូច្នេះ ទើបទ្រង់ផ្ទុំត្រង់សាលាខាងក្រៅព្រះនគរ ។ ព្រះអង្គទ្រង់ក្រោករហូតរាត្រី ចេញទៅខាងក្រៅច្រើនដង ។ តាំងអំពីនោះ ទ្រង់មិនអាចយាងទៅដោយជើង ទ្រង់ផ្ទុំកើយភ្លៅរបស់ស្រីនោះ លុះទៀបភ្លឺក៏សោយទិវង្គតហើយ ។ ស្រីនោះដឹងថា ព្រះរាជាសោយទិវង្គតហើយ ក៏បរិទេវនា ទ្រហោយំដោយសំឡេងខ្លាំងថា ឥឡូវនេះ ព្រះបាទកោសលស្វាមីរបស់ខ្ញុំ សោយរាជសម្បត្តិក្នុងរដ្ឋទាំង ២ មកផ្ទុំសោយទិវង្គតដូចមនុស្សអនាថា ត្រង់សាលារបស់មនុស្ស

អនាថា ខាងក្រៅព្រះនគរនៃអ្នកដទៃ ដូច្នេះជាដើម ។ ពួកមនុស្សបានឮដំណឹង ទើបមកក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាបានយាងមកទតហើយ ទ្រង់ចាំបាន ទ្រង់ជ្រាបហេតុដែលយាងមកហើយ ទ្រង់រៀបចំធ្វើសរីរកិច្ចឲ្យសមនឹងព្រះកិត្តិយស ទ្រង់ឲ្យមេក្នាក់ងាររវាយគងប្រកាសថា យើងនឹងចាប់ស្តេចវិឌូឌភៈ ប្រជុំពួកពលឲ្យដល់ព្រមហើយ អមាត្យទាំងឡាយនាំគ្នាមកក្រាបទៀបយុគលបាទទូលថា បពិត្រព្រះអង្គ បើម្ចាស់អ៊ំរបស់ព្រះអង្គមិនមានរោគ ព្រះអង្គគួរយាង តែឥឡូវនេះ សូម្បីព្រះបាទវិឌូឌភៈ ក៏នឹងសមគួរលើកឆត្រឡើង ព្រោះអាស្រ័យព្រះអង្គនោះឯង ទូលព្រះរាជាឲ្យយល់ហើយ ឃាត់ ។

[ ៣៣១ ] បទថា **ធម្មចេតិយានិ** ជាពាក្យប្រាប់ដល់ការធ្វើសេចក្តីគោរពធម៌ ។ ពិតហើយ កាលធ្វើសេចក្តីគោរពក្នុងរតនៈ ១ ក្នុងបណ្តារតនៈទាំង ៣ ក៏ ឈ្មោះថា ធ្វើគ្រប់រតនៈនោះឯង ព្រោះដូច្នោះ កាលធ្វើសេចក្តីគោរពក្នុងព្រះមានព្រះភាគ ក៏ឈ្មោះថា ធ្វើសេចក្តីគោរពក្នុងព្រះធម៌ផងដែរ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ធម្មចេតិយទាំងឡាយ ។ បទថា **អាទិព្រហ្មចរិយកានិ** សេចក្តីថា ជាខាងដើមនៃមគ្គព្រហ្មចរិយៈដោយអត្ថថា ដែលជាបដិបទាក្នុងចំណែកខាងដើម ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។ ៚

**ធម្មចេតិយសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## កណ្ណកត្ថលសូត្រទី ១០

[ ៣៣២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងភូមិប្រទេស ឈ្មោះកណ្ណកត្ថលៈ ជាទីឲ្យអភ័យដល់ពួកម្រឹគ ជិតក្រុងឧទញ្ញា ។ សម័យនោះឯង ព្រះបាទបសេនទិកោសល បានមកដល់ឧទញ្ញានគរ ដោយកិច្ចនីមួយ ។ គ្រានោះ ព្រះបាទបសេនទិកោសល ត្រាស់ហៅបុរសម្នាក់ថា ម្នាលបុរសដ៏ចម្រើន អ្នកឯងចូរមកនេះ ចូរអ្នកឯងចូលទៅរកព្រះមានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់នៅ លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមានព្រះភាគដោយក្បាល តាមពាក្យរបស់យើង រួចហើយចូរសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទបសេនទិកោសលថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយសិរ្សៈ ហើយទ្រង់សួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខ រួចអ្នកឯងចូរពោលយ៉ាងនេះតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ឮថា ថ្ងៃនេះព្រះបាទបសេនទិកោសលទ្រង់សោយក្រយាស្ងោយក្នុងវេលាព្រឹកនេះហើយ ក្នុងកាលជាខាងក្រោយកត្ត ទ្រង់នឹងចូលមកគាល់ព្រះមានព្រះភាគ ។ បុរសនោះទទួលព្រះឱង្ការ របស់ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅគាល់ព្រះមានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់

ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានពោលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទបសេនទិកោសល ថ្វាយបង្គំព្រះបាទទាំងគូរបស់ព្រះមានព្រះភាគដោយសិរ្ស: ហើយទ្រង់សួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខ ហើយទ្រង់ត្រាស់ យ៉ាងនេះតទៅទៀតថា បពិត្រព្រះអង្គដ៏ចម្រើន ឮថា ថ្ងៃនេះ ព្រះបាទបសេនទិកោសល កាលបើទ្រង់សោយព្រះក្រយាស្ងោយ ក្នុងវេលាព្រឹករួចហើយ វេលាខាងក្រោយកត្ត ទ្រង់នឹងចូលមកគាល់ព្រះមានព្រះភាគ ។

[ ៣៣៣ ] ព្រះភគិនី ( ជាបជាបតី ) ព្រះនាមសោមា និងព្រះនាមសកុលា បានឮថា ថ្ងៃនេះ ព្រះបាទបសេនទិកោសល កាលទ្រង់សោយព្រះក្រយាស្ងោយក្នុងវេលាព្រឹករួចហើយ ខាងក្រោយកត្ត ទ្រង់នឹងស្ដេចទៅ គាល់ព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះនាងសោមា និងព្រះនាងសកុលា ចូលទៅគាល់ព្រះបាទបសេនទិកោសល ក្នុងកន្លែងសម្រាប់សោយ ហើយបានពោលពាក្យនេះថា បពិត្រមហារាជ បើដូច្នោះ សូមព្រះអង្គ ថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគដោយសិរ្ស: តាមពាក្យរបស់ខ្ញុំម្ចាស់ទាំងឡាយផងសូមទ្រង់សួរនូវការមិនអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខផងថា បពិត្រព្រះអង្គដ៏ចម្រើន នាងសោមា និងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគ

ដោយសិរ្សៈ ហើយសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខសាន្ត ។

[៣៣៤] គ្រានោះ ព្រះបាទបសេនទិកោសល សោយព្រះក្រយាស្ងាយក្នុងវេលាព្រឹករួចហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយព្រះបង្គំព្រះមានព្រះភាគដោយគោរព ហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន នាងសោមា និងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគដោយសិរ្សៈ ទូលសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការគង់នៅជាសុខសាន្ត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជ ចុះនាងសោមា និងនាងសកុលា រកអ្នកបម្រើដទៃមិនបានឬ ។ ព្រះបាទបសេនទិកោសលក្រាបបង្គំទូលថា នាងសោមា និងនាងសកុលា បានឮថា ក្នុងថ្ងៃនេះ ព្រះបាទបសេនទិកោសល កាលទ្រង់សោយព្រះក្រយាស្ងាយក្នុងវេលាព្រឹករួចហើយ ក្នុងវេលាខាងក្រោយភត្ត នឹងយាងចូលទៅដើម្បីគាល់ព្រះមានព្រះភាគដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ក៏លំដាប់នោះ នាងសោមា និងនាងសកុលា ចូលមករកខ្ញុំព្រះអង្គ ត្រង់កន្លែងសម្រាប់ទទួលភត្ត ហើយពោលពាក្យនេះនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ សូមព្រះអង្គថ្វាយបង្គំព្រះបាទទាំងគូនៃព្រះមានព្រះភាគដោយសិរ្សៈ តាមពាក្យរបស់ខ្ញុំម្ចាស់ទាំងឡាយផង ទូលសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបាន

រហ័សរហួន ព្រះកាយពល ការទ្រទ្រង់គង់នៅជាសុខថា នាងសោមា និងនាងសកុលា សូមថ្វាយបង្គំព្រះបាទទាំងគូដោយសិរ្បៈ ទូលសួរនូវការមិនមានអាពាធ ការមិនមានទុក្ខ ការក្រោកទៅមកបានរហ័សរហួន ព្រះកាយពល ការទ្រទ្រង់គង់នៅជាសុខ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សូមឲ្យនាងសោមា និងនាងសកុលា បានសេចក្តីសុខទាំងអស់គ្នា ។

[ ៣៣៥ ] គ្រានោះ ព្រះបាទបសេនទិកោសលបានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើនខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ពោលយ៉ាងនេះថា គ្មានសមណព្រាហ្មណ៍ណា ដែលជាអ្នកដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈដោយឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុទេ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណា ពោលយ៉ាងនេះថា ព្រះសមណគោតម និយាយយ៉ាងនេះ គ្មានសមណព្រាហ្មណ៍ណាដែលដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈ ដោយឥតសេសសល់ ពាក្យដូច្នេះនេះមិនសមហេតុទេ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយនោះ ពោលតាមពាក្យរបស់ព្រះមានព្រះភាគ មិនមែនពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិតទេ ឈ្មោះថាព្យាករនូវធម៌ដ៏សមគួរដល់នូវលោកុត្តរធម៌ ទាំងពាក្យតូចពាក្យធំប្រកបដោយធម៌ណានីមួយ ក៏មិនដល់នូវទីគួរតិះដៀលទេឬ ។ ព្រះមានព្រះភាគ ត្រាស់ថា បពិត្រមហារាជ ជនទាំងឡាយណាពោលយ៉ាងនេះថា ព្រះសមណគោតមនិយាយយ៉ាងនេះថា គ្មានសមណៈ ឬព្រាហ្មណ៍ដែលដឹងសព្វ ឃើញសព្វ ប្តេជ្ញានូវញាណទស្សនៈ ដោយឥតសេសសល់

ពាក្យដូច្នេះនេះមិនសមហេតុឡើយ ជនទាំងឡាយនេះ ពោលតាមពាក្យដែល តថាគតពោលហើយ ទាំងមិនឈ្មោះថា ពោលបង្កាច់តថាគត ដោយពាក្យមិន ទៀង មិនពិតទេ ។

[ ៣៣៦ ] លំដាប់នោះ ព្រះបាទបសេនទិកោសល ត្រាស់ហៅសេនាបតី ឈ្មោះវិឌូឌភៈមកហើយ សួរថា ម្នាលសេនាបតី នរណាហ្ន៎ នឹងអាចពោល កថាវត្ថុនេះ ក្នុងខាងក្នុងនៃព្រះបរមរាជវាំងបាន ។ វិឌូឌភសេនាបតី ក្រាប បង្គំទូលថា បពិត្រមហារាជ មានតែសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ។ ទើបព្រះបាទបសេនទិកោសល ត្រាស់ហៅបុរសម្នាក់មកហើយប្រាប់ថា ម្នាល បុរសអើយ អ្នកឯងចូរមកអាយ អ្នកចូរទៅហៅសញ្ជយព្រាហ្មណ៍ ជាអាកាស គោត្រ តាមពាក្យរបស់យើងថា បពិត្រលោកដ៏ចម្រើន ព្រះបាទបសេនទិ កោសល ទ្រង់មានព្រះឱង្ការឲ្យហៅលោក ។ បុរសនោះទទួលព្រះឱង្ការរបស់ ព្រះបាទបសេនទិកោសលថា ព្រះករុណាថ្លៃវិសេស ហើយចូលទៅរកសញ្ជយ- ព្រាហ្មណ៍ជាអាកាសគោត្រ លុះចូលទៅដល់ហើយ បានពោលពាក្យនេះទៅ រកសញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រថា បពិត្រលោកដ៏ចម្រើន ព្រះបាទ បសេនទិកោសល ទ្រង់មានព្រះរាជឱង្ការឲ្យហៅលោក ។ លំដាប់នោះ ព្រះ បាទបសេនទិកោសល បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះ អង្គដ៏ចម្រើន ព្រះមានព្រះភាគ បានពោលពាក្យឯទៀត ព្រោះសំដៅហេតុណា មួយ អ្នកផងចូលចិត្តពាក្យនោះ ដោយប្រការដទៃដែរឬ បពិត្រព្រះអង្គដ៏ ចម្រើន ចុះព្រះមានព្រះភាគ ជ្រាបនូវពាក្យតាមសមគួរហើយ ទើបពោល

វាចាឬ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ តថាគតដឹងយ៉ាងនេះ ហើយ ទើបពោលវាចាថា គ្មានសមណព្រាហ្មណ៍ណា ដែលដឹងនូវហេតុ ទាំងពួង ឃើញនូវហេតុទាំងពួងតែម្តង សេចក្តីនេះមិនសមហេតុឡើយ ។ ព្រះបាទបសេនទិកោសល ទ្រង់ត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមាន ព្រះភាគ សម្តែងពាក្យសមហេតុ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ សម្តែងពាក្យដែលប្រព្រឹត្តទៅមួយអន្លើដោយហេតុថា គ្មានសមណៈ ឬ ព្រាហ្មណ៍ណា ដែលដឹងនូវហេតុទាំងពួង ឃើញនូវហេតុទាំងពួងតែម្តង រឿង ដូច្នេះនេះ មិនសមហេតុឡើយ បពិត្រព្រះអង្គដ៏ចម្រើន វណ្ណៈមាន ៤ គឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រព្រះអង្គដ៏ចម្រើន ត្រកូលទាំង ៤ នេះ មានសេចក្តីវិសេស ទាំងមានសេចក្តីផ្សេងគ្នាដែរឬទេ ។

[៣៣៧] បពិត្រមហារាជ វណ្ណៈទាំង ៤ នេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រមហារាជ បណ្តាវណ្ណៈទាំង ៤ នេះ មានតែ វណ្ណៈ ២ គឺក្សត្រ ១ ព្រាហ្មណ៍ ១ ដែលប្រាកដជាប្រសើរជាងគេ ព្រោះ វណ្ណៈទាំង ២ នេះ គួរដល់ការថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម និង សាមីចិកម្ម ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនទូលសួរនូវគុណក្នុង បច្ចុប្បន្ន នឹងព្រះមានព្រះភាគទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទូលសួរ នូវគុណ ដែលប្រព្រឹត្តទៅក្នុងបរលោក នឹងព្រះមានព្រះភាគថា បពិត្រព្រះ អង្គដ៏ចម្រើន ត្រង់វណ្ណៈទាំង ៤ នេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រព្រះអង្គដ៏ចម្រើន វណ្ណៈទាំង ៤ នេះ មានសេចក្តី

វិសេស និងសេចក្តីផ្សេងគ្នាដែរឬទេ ។

[ ៣៣៨ ] បពិត្រមហារាជ អង្គនៃសេចក្តីព្យាយាមនេះមាន ៥ ។ ចុះអង្គនៃសេចក្តីព្យាយាមមាន ៥ តើដូចម្តេចខ្លះ ។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿនូវការត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ១ ។ ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយការចាប់បដិសន្ធិ មានវិបាកដ៏ស្មើគ្នា គឺមិនត្រជាក់ពេក មិនក្តៅពេក ជាកណ្តាល អត់ទ្រាំនូវសេចក្តីព្យាយាមបាន ១ ។ ជាអ្នកមិនអួតអាង មិនមានមាយា ធ្វើនូវខ្លួនឲ្យជាក់ច្បាស់តាមសេចក្តីពិតក្នុង ព្រះសាស្តាផង ក្នុងសព្រហ្មចារីជាអ្នកប្រាជ្ញទាំងឡាយផង ១ ។ ជាអ្នកប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ដើម្បីបំពេញនូវធម៌ទាំងឡាយជាកុសល មានកម្លាំងចិត្ត មានព្យាយាមដ៏មាំមួន មិនដាក់ចុះនូវធុរៈក្នុងធម៌ទាំងឡាយជាកុសលឡើយ ១ ។ ជាអ្នកមានប្រាជ្ញា ប្រកបដោយបញ្ញាដ៏ប្រសើរ ស្គាល់សេចក្តីកើតឡើង និងវិនាសទៅ ជាបញ្ញាដល់នូវសេចក្តី

អស់ទៅនៃទុក្ខ ដែលជាគ្រឿងនឿយណាយ ១ ។ បពិត្រមហារាជ នេះឯង ជាអង្គនៃសេចក្តីព្យាយាមទាំង ៥ ។ បពិត្រមហារាជ វណ្ណៈទាំង ៤ នេះ គឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំង ៤ នោះ បើបាន ប្រកបដោយអង្គនៃសេចក្តីព្យាយាមទាំង ៥ នេះហើយ ការប្រកបនោះ នៃ វណ្ណៈទាំងនោះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ សេចក្តីចម្រើន អស់កាលជាយូរ អង្វែង ។

[ ៣៣៩ ] បពិត្រព្រះអង្គដ៏ចម្រើន វណ្ណៈទាំង ៤ នេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះ បើប្រកបដោយអង្គនៃ សេចក្តីព្យាយាមទាំង ៥ នេះ បពិត្រព្រះអង្គដ៏ចម្រើន តើវណ្ណៈទាំងនោះ មានសេចក្តីវិសេសជាងគ្នា ផ្សេងគ្នា ក្នុងហេតុនុ៎ះដែរឬ ។ បពិត្រមហារាជ នេះហើយដែលតថាគតពោលថា សេចក្តីព្យាយាមខុសគ្នា ក្នុងហេតុនុ៎ះឯង ។ បពិត្រមហារាជ ដូចសត្វ ២ ពួក គឺដំរី គួរទូន្មាន ឬសេះគួរទូន្មាន ឬគោគួរ ទូន្មាន ១ ពួក គេបានទូន្មានប្រដៅល្អហើយ សត្វពួក ទី ២ ទៀត គឺដំរីគួរ ទូន្មាន ឬសេះគួរទូន្មាន ឬគោគួរទូន្មាន ១ ពួក តែគេមិនបានទូន្មាន មិនបាន ប្រៀនប្រដៅទេ បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច សត្វ ២ ពួកណា គឺដំរីគួរទូន្មាន ឬ សេះគួរទូន្មាន ឬគោគួរទូន្មាន ១ ពួក គេបាន ទូន្មានល្អ ប្រៀនប្រដៅល្អហើយ ក៏សត្វទាំងនោះ លុះគេទូន្មានហើយ បានដល់ នូវហេតុតាមដែលទូន្មាន លុះគេទូន្មានហើយ ក៏បានដល់នូវទីតាមដែលទូន្មាន ដែរឬ ។ បពិត្រព្រះអង្គ ដ៏ចម្រើន សេចក្តីនុ៎ះយ៉ាងនេះហើយ ។ សត្វពួកទី

២ ណា គឺដំរីគួរទូន្មាន ឬសេះគួរទូន្មាន ឬគោគួរទូន្មាន ១ ពួក តែគេមិនបានទូន្មាន មិនបានប្រៀនប្រដៅទេ សត្វទាំងនោះ កាលបើគេមិនបានទូន្មានហើយ តើបានដល់នូវហេតុតាមដែលទូន្មាន កាលបើគេមិនបានទូន្មានហើយ តើបានដល់នូវទីតាមដែលទូន្មាន ដូចជាពួកសត្វទាំងនោះ គឺដំរីគួរទូន្មាន ឬសេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេបានទូន្មានល្អ ប្រដៅល្អហើយដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនុ៎ះមិនដូច្នោះទេ ។ បពិត្រមហារាជ សេចក្តីនេះ មានឧបមេយ្យដូចបុគ្គលមានសទ្ធា មិនមានអាពាធ ជាអ្នកមិនអួតអាង មិនមានមាយា ប្រារព្ធនូវសេចក្តីព្យាយាមមានប្រាជ្ញា រមែងដល់នូវហេតុណា បុគ្គលគ្មានសទ្ធា មានអាពាធច្រើន ជាអ្នកអួតអាង មានមាយា ខ្ជិលច្រអូស ឥតប្រាជ្ញា នឹងដល់នូវហេតុនោះដូចគ្នា ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

[ ៣៤០ ] បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ពោលនូវពាក្យដ៏សមគួរដល់ហេតុ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ពោលនូវពាក្យប្រព្រឹត្តទៅមួយអន្លើដោយហេតុ បពិត្រព្រះអង្គដ៏ចម្រើន វណ្ណៈទាំង ៤ នេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះ បើប្រកបដោយអង្គនៃសេចក្តីព្យាយាម ៥ នេះ វណ្ណៈទាំងនោះឈ្មោះថា មានសេចក្តីព្យាយាមដោយពិត បពិត្រព្រះអង្គដ៏ចម្រើន វណ្ណៈទាំងនោះ មានសេចក្តីវិសេសជាងគ្នា ផ្សេងគ្នាក្នុងហេតុនុ៎ះឯង ។ បពិត្រមហារាជ តថាគតមិនពោលនូវអំពើផ្សេងៗ បន្តិចបន្តួចក្នុងហេតុនុ៎ះ គឺវិមុត្តិដោយវិមុត្តិទេ ។ បពិត្រមហារាជ ដូចបុរសយកឧសសាលព្រឹក្សដែលស្ងួតមកបង្កាត់ភ្លើង ភ្លើងក៏កើត

ឡើង ។ មានបុរសម្នាក់ទៀត យកឧសស្វាយដែលស្ងួតមកបង្កាត់ភ្លើង ភ្លើងក៏កើតឡើងដែរ ។ បុរសម្នាក់ទៀត យកឧសល្វាដែលស្ងួតមកបង្កាត់ភ្លើង ភ្លើងក៏កើតឡើងដែរ ។ បពិត្រមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថាដូចម្តេច អំពើបន្តិចបន្តួចផ្សេងៗ របស់ភ្លើងទាំងនោះដែលកើតអំពីឧសផ្សេងៗ គឺអណ្តាតភ្លើង ដោយអណ្តាតភ្លើងក្តី ពណ៌ដោយពណ៌ក្តី ពន្លឺដោយពន្លឺក្តី ខុសគ្នាដែរឬ ។ សេចក្តីនេះមិនដូច្នោះទេព្រះអង្គ ។ បពិត្រមហារាជ តេជៈណាដែលបុគ្គលមិនបានញុំញីដោយព្យាយាម ដែលកើតអំពីព្យាយាម តថាគតមិនពោលនូវអំពើបន្តិចបន្តួចថា ផ្សេងគ្នាក្នុងតេជៈនោះ គឺវិមុត្តិដោយវិមុត្តិយ៉ាងនេះទេ ។

[ ៣៤១ ] បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ពោលពាក្យប្រព្រឹត្តទៅមួយអន្លើដោយហេតុ បពិត្រព្រះអង្គដ៏ចម្រើន ចុះទេវតាមានដែរឬ ។ បពិត្រមហារាជ ចុះហេតុដូចម្តេច បានជាទ្រង់ត្រឡប់សួរយ៉ាងនេះវិញថា បពិត្រព្រះអង្គដ៏ចម្រើន ចុះទេវតាមានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើទេវតាមានមែន ទេវតាទាំងនោះ មុខជានឹងមកកាន់អត្តភាពជាមនុស្សនេះពុំខាន ឬបើមិនមានទេ ( ទេវតាទាំងនោះ ) នឹងមិនមកកាន់អត្តភាពជាមនុស្សនេះឡើយ ។ បពិត្រមហារាជ ពួកទេវតាណា មានសេចក្តីព្យាបាទ ទេវតាទាំងនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្តីព្យាបាទ ទេវតាទាំងនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ ។

[ ៣៤២ ] កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ

វិឌូឌភសេនាបតី ក៏បានពោលតបទៅនឹងព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណា មានសេចក្តីព្យាបាទ ទេវតាទាំងនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្តីព្យាបាទ ទេវតាទាំងនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ ហើយញ៉ាំងទេវតាដែលមានព្យាបាទទាំងនោះ ឲ្យកក្រើកចាកទីនោះ ឬបណ្តេញចេញ ។ លំដាប់នោះ ព្រះអានន្ទ មានសេចក្តីត្រិះរិះយ៉ាងនេះថា វិឌូឌភសេនាបតីនេះ ជាបុត្តរបស់ព្រះបាទបសេនទិកោសល ឯអាត្មាអញជាបុត្តរបស់ព្រះមានព្រះភាគ កាលនេះជាកាលឲ្យបុត្តប្រឹក្សាជាមួយនឹងបុត្ត ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ហៅវិឌូឌភសេនាបតីមកថា បពិត្រសេនាបតី បើដូច្នោះ អាត្មាភាពនឹងសួរប្រស្នាចំពោះទ្រង់ក្នុងដំណើរនេះវិញ ប្រស្នាគួរដល់ទ្រង់យ៉ាងណា សូមទ្រង់ដោះស្រាយ យ៉ាងនោះចុះ បពិត្រសេនាបតី ចុះទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច ដែនរបស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល សោយរាជសម្បត្តិជាឥស្សរាធិបតី ក្នុងដែនណា ព្រះបាទបសេនទិកោសលអាចធ្វើឲ្យកក្រើក ឬបណ្តេញនូវសមណព្រាហ្មណ៍ ដែលមានបុណ្យក្តី ឥតបុណ្យក្តី មានសេចក្តីប្រព្រឹត្តល្អក្តី មិនមានសេចក្តីប្រព្រឹត្តល្អក្តី ឲ្យចេញចាកតំណែងនោះ ក្នុងទីដែននោះបានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ដែនរបស់ព្រះបាទបសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល សោយរាជសម្បត្តិជាឥស្សរាធិបតី ក្នុងដែនណា ព្រះបាទបសេនទិកោសលអាចដើម្បីធ្វើឲ្យកក្រើក បណ្តេញចេញនូវសមណព្រាហ្មណ៍

ដែលមានបុណ្យ ឬឥតបុណ្យ ប្រព្រឹត្តល្អ ឬប្រព្រឹត្តអាក្រក់ ឲ្យចេញចាក តំណែងនោះ ក្នុងទីដែននោះបាន ។ បពិត្រសេនាបតី ទ្រង់សម្គាល់នូវសេចក្តីនោះថាដូចម្តេច ទីដែលមិនមែនជាដែនរបស់ព្រះបាទ បសេនទិកោសលត្រឹមណា មួយទៀត ព្រះបាទបសេនទិកោសល មិនបានសោយរាជសម្បត្តិ ជាឥស្សរាធិបតីក្នុងដែនណា ព្រះបាទបសេនទិកោសល អាចដើម្បីធ្វើឲ្យកក្រើក បណ្តេញនូវសមណព្រាហ្មណ៍ ដែលមានបុណ្យ ឬឥតបុណ្យ ប្រព្រឹត្តល្អ ឬប្រព្រឹត្តអាក្រក់ ឲ្យចេញចាកតំណែងនោះបានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ទីដែលមិនមែនជាដែនរបស់ព្រះបាទបសេនទិកោសល ត្រឹមណាមួយទៀត ព្រះបាទបសេនទិកោសល មិនបានសោយរាជសម្បត្តិ ជាឥស្សរាធិបតីក្នុងដែនណា ព្រះបាទបសេនទិកោសល មិនអាចដើម្បីធ្វើឲ្យកក្រើក ឬបណ្តេញនូវសមណៈ ឬព្រាហ្មណ៍ ដែលមានបុណ្យ ឬឥតបុណ្យ មានព្រហ្មចរិយធម៌ ឬមិនមានព្រហ្មចរិយធម៌ ឲ្យចេញចាកតំណែងនោះ ក្នុងដែននោះបានទេ ។ បពិត្រសេនាបតី ចុះទ្រង់សម្គាល់នូវសេចក្តីនោះថាដូចម្តេច ទ្រង់បានឮថា ពួកទេវតាជាន់តាវត្តិង្សមានដែរឬ ។ ព្រះករុណាយ៉ាងហ្នឹងហើយ ខ្ញុំបានឮថា ពួកទេវតាជាន់តាវត្តិង្សមាន តែឥឡូវនេះ ព្រះបាទបសេនទិកោសលដ៏ចម្រើន ក៏ទ្រង់ឮថា ពួកទេវតាជាន់តាវត្តិង្សមានដែរ ។ បពិត្រសេនាបតី ចុះទ្រង់សម្គាល់សេចក្តីនោះថាដូចម្តេច ព្រះបាទបសេនទិកោសល អាចដើម្បីធ្វើឲ្យកក្រើក ឬបណ្តេញពួកទេវតាជាន់តាវត្តិង្ស ឲ្យចេញចាកទីនោះបានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះបាទបសេនទិកោសល មិនអាច

ដើម្បីមើលពួកទេវតាជាន់តាវត្តិង្សឃើញទេ នឹងទៅបំបរបង់ ឬបណ្តេញ ( ទេវតាទាំងនោះ ) ឲ្យចេញចាកទីនោះឯណាបាន ។ បពិត្រសេនាបតី យ៉ាងនោះពិតហើយ ពួកទេវតាណា មានសេចក្តីព្យាបាទ ទេវតាទាំងនោះ មកកាន់អត្តភាពជាមនុស្សនេះ ពួកទេវតាណា មិនមានសេចក្តីព្យាបាទ ទេវតាទាំងនោះ មិនមកកាន់អត្តភាពជាមនុស្សនេះទេ ( ទេវតាទាំងនោះ ) មិនអាចដើម្បីមើលឃើញ នូវពួកទេវតាទាំងនោះឃើញទេ នឹងទៅបំបរបង់ ឬបណ្តេញ ( ទេវតាទាំងនោះ ) ឲ្យចេញចាកទីឯណាបាន ។ គ្រានោះ ព្រះបាទបសេនទិកោសល ទូលសួរទៅព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះឈ្មោះអ្វី ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ឈ្មោះអានន្ទ ។

[៣៨៣] ព្រះរាជាមានព្រះឱង្ការថា អើហ្ន៎ ព្រះអានន្ទទេតើ អើហ្ន៎ រូបព្រះអានន្ទទេតើ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទមានអាយុ ចេះសម្តែងពាក្យសមគួរដល់ហេតុ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអានន្ទមានអាយុ ចេះសម្តែងពាក្យប្រព្រឹត្តទៅ មួយអន្លើដោយហេតុ បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះព្រហ្មមានដែរឬ ។ ព្រះអានន្ទថ្វាយព្រះពរថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គមានព្រះឱង្ការសួរ យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រហ្មមានដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើព្រហ្មនោះមានមែន មុខជានឹងមកកាន់អត្តភាពជាមនុស្សនេះ មិនខានទេ បើមិនមានទេ មិនបានមកកាន់អត្តភាពជាមនុស្សនេះឡើយ ។ បពិត្រមហារាជ បើព្រហ្មណា មានសេចក្តីព្យាបាទ ព្រហ្មនោះ ទើបមកកាន់អត្តភាពជាមនុស្សនេះ ព្រហ្មណា មិនមានសេចក្តី

ព្យាបាទទេ ព្រហ្មនោះ មិនបានមកកាន់អត្តភាពជាមនុស្សនេះទេ ។ លំដាប់នោះ មានបុរសម្នាក់ ក្រាបបង្គំទូលព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រមហារាជ សញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រមកដល់ហើយ ។ ទើបព្រះបាទបសេនទិកោសល មានព្រះឱង្ការទៅ នឹងសញ្ជយព្រាហ្មណ៍ ជាអាកាសគោត្រដូច្នេះថា ម្នាលព្រាហ្មណ៍ នរណាហ្ន៎ អាចពោលនូវកថាវត្ថុនេះ ក្នុងខាងក្នុងនៃបុរីរបស់ស្ដេចបាន ។ សញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ក្រាបបង្គំទូលថា បពិត្រមហារាជ មានតែវិឌូឌភសេនាបតី ។ ឯវិឌូឌភសេនាបតី ពោលយ៉ាងនេះថា បពិត្រមហារាជ មានតែសញ្ជយព្រាហ្មណ៍ជាអាកាសគោត្រ ។ គ្រានោះ មានបុរសម្នាក់ទៀត បានក្រាបបង្គំទូលព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រមហារាជ កាលនេះគួរស្ដេចយាងហើយ ។

[ ៣៨៤ ] លំដាប់នោះ ព្រះបាទបសេនទិកោសល បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំបានទូលសួរនូវសព្វញ្ញុតញ្ញាណ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគក៏បានព្យាករនូវសព្វញ្ញុតញ្ញាណ ការព្យាករណ៍នេះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំបានទូលសួរនូវសេចក្ដីស្អាតនៃវណ្ណៈទាំង ៤ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវសេចក្ដីស្អាត នៃវណ្ណៈទាំង ៤ ហើយ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំរីករាយដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំបានសួរនូវពួកទេវតាជាជំ នឹង

ព្រះមានព្រះភាគហើយ ព្រះមានព្រះភាគ ក៏បានព្យាករនូវពួកទេវតា ជាធំ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំបានទូលសួរ នូវព្រហ្មជាធំ នឹងព្រះមានព្រះភាគហើយ ព្រះមានព្រះភាគក៏បានព្យាករ នូវព្រហ្មជាធំ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរ ដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត យើងខ្ញុំបានទូលសួរនូវហេតុណាៗ នឹងព្រះមានព្រះភាគ ព្រះមានព្រះភាគ ក៏បានព្យាករនូវហេតុនោះៗ ការព្យាករណ៍នោះ គាប់ចិត្តផង គួរដល់យើងខ្ញុំផង យើងខ្ញុំបានត្រេកអរដោយការព្យាករណ៍នោះ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវយើងខ្ញុំមានកិច្ចច្រើន មានការងារដែលត្រូវធ្វើច្រើន យើងខ្ញុំសូមថ្វាយបង្គំលាត្រឡប់ទៅវិញ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ សូមព្រះអង្គសម្គាល់នូវកាលដ៏គួរ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់សព្វព្រះរាជហឫទ័យ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ធ្វើប្រទក្សិណ ហើយស្ដេចចេញទៅ ។

កណ្ណកត្ថលសូត្រទី ១០ ចប់

រាជវគ្គទី ៤ ចប់

ឧទ្ទាននៃរាជវគ្គនោះគឺ

ជោតិសបាលកសូត្រ ១ រដ្ឋបាលសូត្រ ១ មឃទេវសូត្រ ១ មធុរសូត្រ ១ ពោធិរាជកុមារសូត្រ ១ អង្គុលិមាលសូត្រ ១ ( បិយជាតិកសូត្រ ១ ពាហិតិយសូត្រ ១ ) ធម្មចេតិយសូត្រ ១ កណ្ណកត្ថលសូត្រ ១ គ្រប់ជា ១០ សូត្រ ។

# អដ្ឋកថា

## កណ្ណកត្ថលសូត្រទី ១០

[៣៣២] កណ្ណកត្ថលសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

ក្នុងព្រះសូត្រនេះ បទថា **ឧទញ្ញាយំ** នេះ ជាឈ្មោះរបស់រដ្ឋផង នគរនោះផង ថា **ឧទញ្ញា**។ ព្រះមានព្រះភាគ ទ្រង់អាស្រ័យឧទញ្ញានគរប្រថាប់នៅ ។ បទថា **កណ្ណកត្ថលេ មិគទាយេ** សេចក្តីថា ក្នុងទីមិនឆ្ងាយអំពីព្រះនគរនោះ មានតំបន់មួយជាទីត្រេកអរ ឈ្មោះថា **កណ្ណកត្ថល**។ ភូមិភាគនោះ គេតែងហៅថា **មិគទាយវន** ព្រោះទ្រង់ព្រះរាជទានអភ័យដល់ម្រឹគ ទាំងឡាយ ។ ក្នុងកណ្ណកត្ថលមិគទាយវ័ននោះ ។ បទថា **កេនចិទេវករណីយេន** សេចក្តីថា មិនមែនកិច្ចដទៃ ជាករណីយកិច្ចដូចដែលបានពោលក្នុងសូត្រមុនហើយនោះឯង ។

[៣៣៣] បទថា **សោមា ច ភគិនី សកុលា ច ភគិនី** សេចក្តីថា ភគិនីទាំង ២ គឺព្រះនាងសោមា និងព្រះនាងសកុលា នាងជាបជាបតីរបស់ព្រះរាជា ។ បទថា **ភត្តាភិហារេ** បានដល់ ក្នុងទីសោយព្រះក្រយាហារ ។ ទីសោយព្រះក្រយាហាររបស់ព្រះរាជា ព្រះនាងគ្រប់អង្គត្រូវកាន់វែកជាដើមទៅបម្រើព្រះរាជា ។ ព្រះនាងទាំង ២ នោះបានទៅហើយ ដោយទំនងនោះ ។

[៣៣៤] បទថា **កឹ បន មហារាជា** ជាពាក្យសួរថា ព្រោះហេតុអ្វីទើបត្រាស់យ៉ាងនោះ ឆ្លើយថា ដើម្បីដោះពាក្យនិន្ទារបស់ព្រះរាជា ។ ព្រោះពួក បរិស័ទគប្បីគិតយ៉ាងនេះថា ព្រះរាជានេះ កាលយាងមក ក៏នៅតែនាំ

ដំណឹងរបស់មាតុគ្រាមមកទូលផងដែរ ពួកយើងសម្គាល់ថា មកគាល់ព្រះមានព្រះភាគ ដោយធម្មតារបស់ខ្លួន តែព្រះករុណាជីវិតតម្កល់លើត្បូង យកដំណឹងរបស់មាតុគ្រាមមក ប្រហែលជាទាសៈរបស់មាតុគ្រាមទេដឹង សូម្បីពីមុនទ្រង់ក៏យាងមកដោយហេតុនេះដូចគ្នា ដូច្នេះ ។ម្យ៉ាងទៀត ព្រះរាជានោះត្រូវសួរហើយ នឹងទូលដល់ហេតុដែលមករបស់ខ្លួន ពាក្យនិន្ទានេះ នឹងមិនកើតឡើងដល់ព្រះអង្គ ដោយអាការយ៉ាងនេះ ព្រោះដូច្នោះ ដើម្បីដោះនូវពាក្យនិន្ទា ទើបត្រាស់យ៉ាងនោះ ។

[ ៣៣៦ ] បទថា **អត្ថុនាហាសិ** ប្រែថា ពោលហើយ ។ បទថា **សកិទេវ សព្វំ ញស្សតិ សព្វំ ទក្ខិតិ** មិនមាន សមណៈ ឬព្រាហ្មណ៍ ដែលដឹងធម៌ទាំងពួង និងឃើញធម៌ទាំងពួងក្នុងគ្រាតែមួយ សេចក្តីថា បុគ្គលណានឹងដឹង ឬនឹងឃើញធម៌ទាំងពួងដែលជាអតីត អនាគត និងបច្ចុប្បន្ន ដោយអាវជ្ជនៈ ១ ដោយចិត្តដួង ១ ដោយជវនចិត្ត ១ បុគ្គលនោះរមែងមិនមាន ។ ពិតហើយ បុគ្គលណាមួយ សូម្បីគិតហើយថា អញនឹងដឹងរឿងគ្រប់យ៉ាងដែលជាអតីតដោយចិត្តដួង ១ ក៏មិនអាចដឹង អតីតបានអស់ នឹងដឹងបានត្រឹមតែមួយថ្ងៃប៉ុណ្ណោះ។ ចំណែកដែលជាអនាគត និងបច្ចុប្បន្ន ក៏នឹងមិនដឹងវត្ថុគ្រប់យ៉ាងដោយចិត្តនោះ ។ ក្នុងបទក្រៅអំពីនេះ ក៏ន័យនេះ ។ ត្រាស់បញ្ហានេះ ដោយចិត្ត ១ ដួងយ៉ាងនេះឯង ។ បទថា **ហេតុរូបំ** បានដល់ ភាវៈនៃហេតុដែលកើតអំពីហេតុ ។ បទថា **សហេតុរូបំ** បានដល់ ដែលជាជាតិនៃផលដែលមានហេតុ ។

[៣៣៧] បទថា **សម្បរាយិកាហំ ភន្តេ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន

ខ្ញុំព្រះអង្គសូមទូលសួរដល់គុណ ដែលនឹងមានខាងមុខ ។

[៣៣៨] បទថា **បញ្ចិមានិ** សេចក្ដីថា ព្រះមានព្រះភាគ ត្រាស់អង្គជាទីតាំងនៃសេចក្ដីព្យាយាម ៥ ឲ្យលាយដោយលោកុត្តរក្នុងព្រះសូត្រនេះ ។ តែព្រះបូឡសមុទត្ថេរដែលនៅក្នុងករវលង្គណៈ កាលគេសួរថា លោកម្ចាស់ពេញចិត្តអ្វី ដូច្នេះ ក៏ឆ្លើយថា ខ្ញុំពេញចិត្តលោកុត្តរតែម្យ៉ាង ។

[៣៣៩] បទថា **បធានវេមត្តតំ** បានដល់ ការផ្សេងគ្នានៃសេចក្ដីព្យាយាម ។ ពិតហើយ សេចក្ដីព្យាយាមរបស់បុថុជ្ជនម្យ៉ាង របស់ព្រះសោតាបន្នម្យ៉ាង របស់ព្រះសកទាគាមីម្យ៉ាង របស់ព្រះអនាគាមីម្យ៉ាង របស់ព្រះអរហន្តក៏ម្យ៉ាង របស់ព្រះអសីតិមហាសាវ័កក៏ម្យ៉ាង របស់ព្រះអគ្គសាវ័កទាំង ២ ម្យ៉ាង របស់ព្រះបច្ចេកពុទ្ធម្យ៉ាង របស់ព្រះសព្វញ្ញុពុទ្ធក៏ម្យ៉ាង ។ សេចក្ដីព្យាយាមរបស់បុថុជ្ជន មិនដល់ការព្យាយាមរបស់ព្រះសោតាបន្ន ។ បេ ។ សេចក្ដីព្យាយាមរបស់ព្រះបច្ចេកពុទ្ធ ក៏មិនដល់សេចក្ដីព្យាយាមរបស់ព្រះសព្វញ្ញុពុទ្ធ ។ ព្រះមានព្រះភាគត្រាស់ថា **បធានវេមត្តតំ វទាមិ** ប្រែថា តថាគតពោលការផ្សេងគ្នា ដោយសេចក្ដីព្យាយាម ទ្រង់សំដៅយកសេចក្ដីនេះ ។

បទថា **ឧទ្ធការណំ គច្ឆេយ្យុំ** សេចក្ដីថា ក្នុងបណ្ដាការទូន្មានទាំងឡាយមានទូន្មានមិនឲ្យកោង មិនឲ្យបាក់ដោត និងឲ្យដាក់ធុរៈ ហេតុឯណារមែងប្រាកដ គប្បីចូលដល់ហេតុនោះ ។ បទថា **ឧទ្ធភូមឹ** បានដល់ កាន់ភូមិសត្វដែលទូន្មានហើយ គប្បីទៅ ។ សូម្បីបុគ្គល ៤ ពួក គឺបុថុជ្ជន ព្រះសោតាបន្នសកទាគាមី អនាគាមី ឈ្មោះថា អ្នកមិនមានសទ្ធាក្នុងបទទាំងឡាយថា

**អស្សទ្ធោ** ជាដើម ។ ពិតហើយ បុថុជ្ជន ឈ្មោះថា មិនមានសទ្ធា ព្រោះមិនដល់សទ្ធារបស់ព្រះសោតាបន្ន ។ ព្រះសោតាបន្ន ... របស់ព្រះសកទាគាមី ។ ព្រះសកទាគាមី ... របស់ព្រះអនាគាមី ។ ព្រះអនាគាមី ឈ្មោះថា មិនមានសទ្ធា ព្រោះមិនដល់សទ្ធារបស់ព្រះអរហន្ត ។ ការអាពាធ រមែងកើតឡើងដល់ព្រះអរហន្ត ព្រោះដូច្នោះ អាពាធទាំង ៥ ឈ្មោះថា អាពាធច្រើន ។ ព្រះអរិយសាវករមែងមិនមានឈ្មោះថា ជាអ្នកអួតអាង ជាអ្នកមានមាយា ព្រោះហេតុនោះឯង ទើបព្រះថេរៈពោលថា តថាគតពេញចិត្តដែលនឹងត្រាស់អង្គនៃសេចក្ដីព្យាយាម ៥ ឲ្យលាយដោយលោកុត្តរ ។ ឯក្នុងអស្សខឡុង្គសូត្រត្រាស់ទុកថា ឈ្មោះថា សម្មាធិនៃព្រះអរិយសាវកមកហើយ ក្នុងព្រះតម្រាស់នេះថា **តយោ ច ភិក្ខវេ អស្ស ខឡុង្គេ តយោ ច បរិសខឡុង្គេ ទេសេស្សាមិ** ដោយ អំណាចនៃបុថុជ្ជននោះ ព្រោះដូច្នោះ ទើបត្រាស់ថា លាយដោយលោកុត្តរ ។

ឯបុថុជ្ជនមិនទាន់ដល់ព្រមនូវសេចក្ដីព្យាយាមក្នុងសោតាបត្តិមគ្គ ។បេ។ ព្រះអនាគាមីមិនទាន់ដល់ព្រមនូវសេចក្ដីព្យាយាមក្នុងអរហត្តមគ្គ ។ សូម្បីអ្នកខ្ជិលច្រអូសក៏មាន ៤ ដូចគ្នា ដូចបុគ្គលមិនមានសទ្ធា ។ បុគ្គលមានបញ្ញាថោកថយក៏ដូចគ្នា ។ ម្យ៉ាងទៀត គប្បីជ្រាបការប្រៀបធៀបដោយឧបមាក្នុងចំណែកខ្មៅ ដោយពាក្យថា **អទន្តហត្ថិអាជានេយ្យោ** ដូចដំរីដែលមិនទាន់ទូន្មាន និងក្នុងចំណែកស ដោយពាក្យថា **យថា បន ទន្តហត្ថិអាជានេយ្យោ** ដូចដំរីដែលទូន្មានហើយជាដើម ដូច្នេះជាដើម ។ បុគ្គលដែលរៀរមគ្គប្បធាន

ប្រៀបដូចដំរីដែលមិនបានទូន្មាន បុគ្គលមានមគ្គប្បធាន ប្រៀបដូចដំរីដែលមានខ្លួនទូន្មានហើយ ដំរីដែលមិនទាន់បានទូន្មាន ក៏មិនអាចដើម្បីធ្វើអាការកោងគេច រលាស់ធុរៈទៅកាន់ការទូន្មានហើយ ឬដល់នូវការទូន្មានហើយ បានយ៉ាងណា បុគ្គលវៀរចាកមគ្គប្បធាន ក៏ដូច្នោះដូចគ្នា រមែងមិនអាចដើម្បីសម្រេចគុណ ដែលបុគ្គលអ្នកមានមគ្គប្បធានគប្បីដល់ ឬគប្បីញ៉ាំងគុណ ដែលបុគ្គលមានមគ្គប្បធាន គប្បីឲ្យកើត ឲ្យកើតឡើង ។

ម្យ៉ាងទៀត ដំរីជាដើមដែលទូន្មានហើយ មិនធ្វើអាការកោង មិនចាក់ទម្រុះ មិនបោះបង់ធុរៈ រមែងអាចទៅកាន់ទីដែលសត្វទូន្មានហើយ គប្បីទៅ ឬគប្បីដល់ភូមិដែលសត្វទូន្មានហើយ គប្បីដល់ យ៉ាងណា បុគ្គលមានមគ្គប្បធាន ក៏ដូច្នោះដូចគ្នា ក៏អាចសម្រេចគុណដែលអ្នកមានមគ្គប្បធានគប្បីសម្រេច អាចញ៉ាំងគុណដែលបុគ្គលមានមគ្គប្បធាន គប្បីឲ្យកើត ឲ្យកើតឡើងបាន ។ លោកអធិប្បាយទុកដូច្នេះថា បុគ្គលមានសោតាបត្តិមគ្គប្បធាន រមែងអាចសម្រេចឱកាស ដែលអ្នកមានសោតាបត្តិមគ្គប្បធានសម្រេច ដើម្បីនឹងញ៉ាំងគុណដែលបុគ្គលមានសោតាបត្តិមគ្គប្បធាន គប្បីឲ្យកើតឡើង កើតឡើងបាន ។បេ។ បុគ្គលមានអរហត្តមគ្គប្បធាន រមែងអាចសម្រេចឱកាស ដែលបុគ្គលមានអរហត្តមគ្គប្បធានសម្រេច ដើម្បីញ៉ាំងគុណដែលបុគ្គលមាន អរហត្តមគ្គប្បធាន គប្បីឲ្យកើតឡើង កើតឡើងបាន ។

[៣៨០] បទថា **សម្មប្បធានា** បានដល់ ការដល់ព្រម គឺការធ្វើចំពោះទាក់ទង ដោយមគ្គប្បធាន ។ បទថា **ន កិញ្ចិ នានាករណំ វទាមិ យទិទំ**

**វិមុត្តិយា វិមុត្តានំ** ប្រែថា តថាគតមិនពោលនូវអំពើផ្សេងៗ បន្តិចបន្តួចក្នុងហេតុនុ៎ះ គឺវិមុត្តិដោយវិមុត្តិទេ សេចក្តីថា ការធ្វើផ្សេងៗគ្នា ប្រារព្ធផលវិមុត្តិនៃបុគ្គលក្រៅអំពីនេះ និងផលវិមុត្តិនៃបុគ្គលម្នាក់ដែលគួរពោលឯណា តថាគតមិនពោលដល់ការធ្វើផ្សេងគ្នា ដែលគួរពោលនោះដូចម្តេច គឺតថាគតពោលថាមិនមានការផ្សេងគ្នា ។ បទថា **អច្ចិយា វា អច្ចឹ** សេចក្តីថា ឬអណ្តាតភ្លើង និងអណ្តាតភ្លើង ។ សូម្បីពីរបទដ៏សេសក៏មានន័យដូចគ្នា ។ បទថា **អច្ចិ** នេះជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។

[៣៤១] បទថា **កឹ បន ត្វំ មហារាជ** សេចក្តីថា បពិត្រមហារាជ ទ្រង់មិនជ្រាបឬថា ទេវតាមានយ៉ាងនេះ គឺទេវតាជាន់ចាតុម្មហារាជមាន ទេវតាជាន់តាវត្តិង្សមាន ។បេ។ ទេវតាជាន់បរនិម្មិតវសវត្តីមាន ទេវតាជាន់ខ្ពស់ឡើងទៅទៀតមាន ព្រះអង្គត្រាស់យ៉ាងនេះ ព្រោះហេតុអ្វី ។

បន្ទាប់អំពីនោះ ព្រះរាជាកាលត្រាស់សួរពាក្យនេះថា ខ្ញុំព្រះអង្គដឹងថា មានតែទេវតាទាំងឡាយមកកាន់មនុស្សលោក ឬមិនមកកាន់មនុស្សលោក ទើបត្រាស់ថា **យទិ វា តេ ភន្តេ** ដូច្នេះជាដើម ។ បទថា **សព្យាបជ្ឈា** បានដល់ មានទុក្ខ គឺមិនទាន់លះផ្លូវចិត្ត គឺមិនទាន់លះទុក្ខផ្លូវចិត្តបានដោយសមុច្ឆេទ ។ បទថា **អាគន្តារោ** សេចក្តីថា បុគ្គលមកដោយអំណាចបដិសន្ធិ ។ បទថា **អព្យាបជ្ឈា** បានដល់ កាត់សេចក្តីទុក្ខបានជាសមុច្ឆេទ ។ បទថា **អនាគន្តារោ** បានដល់ បុគ្គលមិនមកដោយអំណាចនៃបដិសន្ធិ ។

[ ៣៤២ ] បទថា **បហោតិ** ប្រែថា រមែងអាច ។ ពិតហើយ ព្រះរាជា

រមែងអាច ធ្វើបុគ្គលដែលដល់ព្រមដោយលាភ និងសក្ការៈ សូម្បីមានបុណ្យ ដោយមិនមានបុគ្គលណាចូលទៅជិតបាន ឲ្យឃ្លាតចាកឋានៈនោះ ។ រមែងអាច ធ្វើ សូម្បីបុគ្គលមិនមានបុណ្យនោះ ដែលមិនបានត្រឹមតែត្រាច់ទៅកាន់ស្រុក ទាំងមូល ដើម្បីដុំបាយ ហើយញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបាន ដោយប្រការ ដែលនឹងជាអ្នកដល់ព្រមដោយលាភ និងសក្ការៈ ឲ្យឃ្លាតចាកឋានៈនោះ ។ រមែងអាចប្រកបសូម្បីបុគ្គលវិនាសនូវព្រហ្មចរិយៈ គឺសីលដោយស្រី ឲ្យសឹក ដោយកម្លាំង ឬឲ្យឃ្លាតឋានៈនោះ មិនឲ្យអមាត្យ ដែលដល់ព្រមដោយកាម គុណ សូម្បីមិនបានប្រព្រឹត្តព្រហ្មចរិយៈ ឲ្យចូលទៅកាន់គុក មិនឲ្យឃើញ សូម្បីមុខរបស់ស្រីទាំងឡាយ ឈ្មោះថា រមែងឲ្យឃ្លាតចាកឋានៈនោះ តែ កាលឲ្យឃ្លាតចាករដ្ឋ ឈ្មោះថា បណ្តេញទៅតាមត្រូវការ ។

បទថា **ចក្ខុនាយតិ ចក្ខុហោន្តិ** សេចក្តីថា ទេវតាដែលមានទុក្ខ រមែងមិនអាចឃើញដោយចក្ខុវិញ្ញាណនូវទេវតាដែលមានទុក្ខជាន់កាមាវចរ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានឋានៈក្នុងភពនោះដោយសម គួរ ។ តែរមែងអាចដើម្បីនឹងឃើញដោយចក្ខុវិញ្ញាណ នូវទេវតាជាន់រូបាវចរ ថា រមែងឈរផង រមែងអង្គុយផង ក្នុងវិមានជាមួយគ្នានោះឯង ។ តែមិន អាចឃើញដើម្បីកំណត់ ដើម្បីចាក់ធ្លុះ នូវលក្ខណៈដែលទេវតាទាំងនេះឃើញ ហើយ កំណត់ហើយ ចាក់ធ្លុះហើយ ។ រមែងមិនអាចឃើញដោយញាណចក្ខុ ដោយប្រការដូច្នេះ ។ ទាំងមិនអាចឃើញទេវតាដែលខ្ពស់ៗ ទៅ ដោយការ ឃើញដោយចក្ខុវិញ្ញាណ ដូច្នេះ ។ បទថា **កោ នាមោ អយំ ភន្តេ** សេចក្តីថា

ព្រះរាជាសូម្បីទ្រង់ស្គាល់ព្រះថេរៈ ក៏ត្រាស់សួរដូចមិនស្គាល់ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះជាអ្នកប្រាថ្នាដើម្បីទ្រង់សរសើរ ។

[ ៣៤៣ ] បទថា **អាគច្ឆុំ** បានដល់ មានសភាវៈគួរត្រេកអរ ។ សូម្បីការត្រាស់សួរដល់ព្រហ្ម ក៏គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។ បទថា **អថខោ អញ្ញតរោ បុរិសោ** សេចក្តីថា បានឮថា វាចានោះវិឌូឌភៈនោះឯងត្រាស់ហើយ ។ ជនទាំងនោះក្រោធហើយថា លោកពោលហើយ លោកពោលហើយ ទើបឲ្យពួកពលរៀងៗខ្លួនក្រោកឡើង ធ្វើការឈ្លោះនូវគ្នានឹងគ្នាក្នុងទីនោះឯង រាជបុរសនោះបានពោលពាក្យនោះ ដើម្បីឃាត់ដោយប្រការនេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ។ ម្យ៉ាងទៀត ទេសនានេះចប់ហើយដោយអំណាចនេយ្យបុគ្គល ដូច្នេះឯង ។ ៚

អដ្ឋកថា កណ្ណកត្ថលសូត្រ ចប់

សូត្រទី ១០ ចប់

វគ្គទី ៤ ចប់

# ក្បាលទី ១៦

# សុត្តន្តបិដក ទាលីប្រែ -២៣

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


ចូឡរាហុលោវាទសូត្រទី ១ ...... ...... ...... ...... ...... ...... ...... .. ២

អដ្ឋកថា ចូឡរាហុលោវាទសូត្រ ...... ...... ...... ...... ...... ...... .... ១៥

មហារាហុលោវាទសូត្រទី ២ ...... ...... ...... ..... ..... ..... ..... .... ២៣

អដ្ឋកថា មហារាហុលោវាទសូត្រ ...... ...... ...... ...... ...... ...... .... ៣៥

ចូឡមាលុង្ក្យោវាទសូត្រទី ៣ ...... ...... ...... ...... ..... ..... ..... .... ៥១

អដ្ឋកថា ចូឡមាលុង្ក្យោវាទសូត្រ ...... ...... ...... ...... ...... ..... ... ៦៤

មហាមាលុង្ក្យោវាទសូត្រទី ៤ ...... ...... ...... ...... ...... ...... ..... . ៦៧

អដ្ឋកថា មហាមាលុង្ក្យោវាទសូត្រ ...... ...... ...... ...... ...... ...... ...៧៩

ភទ្ទាលិសូត្រទី ៥ ...... ...... ...... ...... ...... ..... ..... ..... ..... ... ៨៦

អដ្ឋកថា ភទ្ទាលិសូត្រ ...... ...... ...... ...... ..... ..... ..... ..... .... ១០៧

លដុកិកោបមសូត្រទី ៦ ...... ..... ..... ..... ..... ..... ..... ..... ..... ១២៧

អដ្ឋកថា លដុកិកោបមសូត្រ ...... ...... ...... ...... ...... ...... ..... ១៤៧

ចាតុមសូត្រទី ៧ ...... ...... ...... ...... ...... ...... ...... ..... ..... ... ១៥៩

អដ្ឋកថា ចាតុមសូត្រ ...... ...... ...... ...... ...... ...... ..... ..... .... ១៧២

នឡកបានសូត្រទី ៨ ...... ...... ...... ...... ...... ...... ..... ..... ..... ១៨០

អដ្ឋកថា នឡកបានសូត្រ ...... ...... ...... ...... ..... ..... ..... .... ១៩៥

គោលិស្សាសូត្រទី ៩ ...... ...... ...... ...... ...... ...... ..... ..... ..... ២០១

អដ្ឋកថា គោលិស្សាសូត្រ ...... ...... ...... ...... ...... ...... ..... ..... ២១១

កីដាគិរីសូត្រទី ១០ ...... ...... ...... ...... ...... ...... ...... ...... ..... ២១៥

អដ្ឋកថា កីដាគិរិសូត្រ ...... ...... ...... ...... ...... ...... ..... ..... .... ២៣៦

# សុត្តន្តបិដក ចាលីប្រែ -២៤

ចូឡវច្ឆគោត្តសូត្រទី ១ ...... ..... ..... ..... ..... ..... ..... ..... ..... ២៤៨
អដ្ឋកថា ចូឡវច្ឆគោត្តសូត្រ ..... ...... ...... ...... ...... ..... ..... ..... ២៥៤
អគ្គិវច្ឆគោត្តសូត្រទី ២ ...... ...... ...... ..... ..... ..... ..... ..... .... ២៥៧
អដ្ឋកថា អគ្គិវច្ឆគោត្តសូត្រ ...... ...... ...... ...... ...... ...... ...... ... ២៧០
មហាវច្ឆគោត្តសូត្រទី ៣ ...... ...... ...... ...... ...... ...... ..... .... ២៧៤
អដ្ឋកថា មហាវច្ឆគោត្តសូត្រ ..... ...... ...... ..... ...... ...... ..... .... ២៩១
ទីឃនខសូត្រទី ៤ ...... ...... ...... ...... ...... ...... ...... ...... ..... ២៩៦
អដ្ឋកថា ទីឃនខសូត្រ ...... ...... ...... ...... ...... ...... ..... ..... .. ៣០៥
មាគណ្ឌិយសូត្រទី ៥ ...... ...... ...... ...... ...... ...... ..... ..... ... ៣១៥
អដ្ឋកថា មាគណ្ឌិយសូត្រ ...... ..... ..... ..... ..... ..... ..... ..... ... ៣៣៩
សន្ទកសូត្រទី ៦ ...... ...... ...... ...... ...... ...... ...... ..... ..... ... ៣៥៤
អដ្ឋកថា សន្ទកសូត្រ ...... ...... ...... ..... ..... ..... ..... ..... ..... ៣៨៥
មហាសុកុលុទាយិសូត្រទី ៧ ....... ...... ...... ...... ...... ...... ..... ៤០៤
អដ្ឋកថា មហាសុកុលុទាយិសូត្រ ...... ...... ...... ...... ...... ..... . ៤៤៦
រឿងសាមណេរមានឫទ្ធិច្រើន ...... ...... ...... ...... ...... ..... ..... .. ៤៥៦
រឿងបុរស និងភិក្ខុ ៣០ រូប ...... ...... ...... ...... ...... ...... ..... .... ៤៦៣
សមណមុណ្ឌកសូត្រទី ៨ ...... ...... ...... ...... ...... ...... ..... . ៤៨៤
អដ្ឋកថា សមណមុណ្ឌកសូត្រ ...... ...... ...... ...... ...... ...... .... ៤៩៧
ចូឡសុកុលុទាយិសូត្រទី ៩ ...... ...... ...... ...... ..... ..... ..... .. ៥០៤
អដ្ឋកថា ចូឡសុកុលុទាយិសូត្រ ...... ...... ...... ...... ..... ..... ... ៥២៣
វេខណសសូត្រទី ១០ ...... ...... ...... ...... ..... ..... ..... ..... . ៥៣២

អដ្ឋកថា វេខណសសូត្រ ...... ...... ...... ...... ...... ...... ..... ... ៥៤១

## រាជវគ្គ

ឃដិការសូត្រទី ១ ...... ...... ...... ...... ..... ..... ..... ..... ..... . ៥៤៣

អដ្ឋកថា ឃដិការសូត្រ ...... ...... ...... ..... ..... ..... ..... ..... . ៥៦០

រដ្ឋបាលសូត្រទី ២ ...... ...... ...... ...... ...... ..... ..... ..... ..... . ៥៧៣

អដ្ឋកថា រដ្ឋបាលសូត្រ ...... ...... ...... ...... ...... ..... ...... ..... .. ៦០៥

មឃទេវសូត្រទី ៣ ...... ...... ...... ...... ...... ...... ...... ..... ... ៦៣០

អដ្ឋកថា មឃទេវសូត្រ ...... ...... ..... ..... ..... ..... ..... ..... .. ៦៤៧

មធុរសូត្រទី ៤ ...... ...... ...... ...... ...... ...... ...... ..... ..... ... ៦៦០

អដ្ឋកថា មធុរសូត្រ ...... ...... ...... ...... ...... ...... ...... ..... .. ៦៧៥

ពោធិរាជកុមារសូត្រទី ៥ ...... ...... ...... ...... ...... ...... ...... ... ៦៧៨

អដ្ឋកថា ពោធិរាជកុមារសូត្រ ...... ...... ...... ...... ...... ...... ..... . ៧២៧

អង្គុលិមាលសូត្រទី ៦ ...... ...... ...... ..... ..... ..... ..... ..... ... ៧៣៦

អដ្ឋកថា អង្គុលិមាលសូត្រ ...... ...... ...... ...... ..... ..... ..... .. ៧៥២

បិយជាតិកសូត្រទី ៧ ...... ...... ...... ...... ...... ...... ..... ..... . ៧៧៣

អដ្ឋកថា បិយជាតិកសូត្រ ...... ...... ...... ...... ...... ...... ..... .. ៧៨៧

ពាហិតិយសូត្រទី ៨ ...... ...... ...... ...... ...... ...... ...... ..... .. ៧៩០

អដ្ឋកថា ពាហិតិយសូត្រ ...... ...... ...... ...... ...... ...... ..... .. ៨០១

ធម្មចេតិយសូត្រទី ៩ ...... ...... ...... ...... ...... ...... ...... ..... .. ៨០៤

អដ្ឋកថា ធម្មចេតិយសូត្រ ...... ...... ...... ...... ...... ...... ...... ... ៨១៨

កណ្ណកត្ថលសូត្រទី ១០ ...... ...... ...... ...... ...... ...... ...... .... ៨២៨

អដ្ឋកថា កណ្ណកត្ថលសូត្រ ...... ...... ...... ...... ...... ...... ..... ... ៨៤៤